**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៧

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 28-Dec-2017, 15:52
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះ: សម្ងាត់/Confidential

ឋានៈនៃចំណាត់ថ្នាក់ឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សារណាបញ្ចប់ការជំនុំជម្រះដោយផ្ទាល់មាត់ដែលបានកែប្រែរបស់សហមេធាវីនាំមុខ ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០២/០២**

---

**ដាក់ដោយ៖**

**សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី៖**

ពេជ អង្គ

Marie GUIRAUD

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

ជេត វណ្ណលី

ហុង គីមសួន

**នៅចំពោះមុខ៖**

**អង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម យ៉ា សុខន

ចៅក្រម Jean-Marc LAVERGNE

ចៅក្រម យូរ ឧត្តរា

ចៅក្រម Claudia FENZ

គឹម ម៉េងឃី

ឡោ ជុនធី

ម៉ុច សុវណ្ណារី

ស៊ិន សុវ៉ន

សំ សុគង់

វ៉ែន ពៅ

ទី ស្រ៊ីនណា

Laure DESFORGES
Ferdinand DJAMMEN NZEPA
Isabelle DURAND
Françoise GAUTRY
Emmanuel JACOMY
Martine JACQUIN
Yiqiang Y. LIU
Daniel LOSQ
Christine MARTINEAU
Lyma NGUYEN
Mahesh RAI
Nushin SARKARATI

**ផ្ញើជូន៖**

**ការិយាល័យសហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

**ជនជាប់ចោទ៖**

ខៀវ សំផន

នួន ជា

**សហមេធាវីការពារក្តី៖**

សុន អរុណ

Victor KOPPE

គង់ សំអុន

Anta GUISSÉ

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

Olivier BAHOUGNE

# មាតិកា

**មាតិកា** ........................................................ 3

**I. សេចក្ដីផ្ដើម** ........................................................ 9

*ក. ក្រុមដើមបណ្ដឹងរដ្ឋប្បវេណីដែលបានរួមបញ្ចូលគ្នាតែមួយ* ........................................................ *10*

*ខ. បណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២* ........................................................ *13*

១. ការចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ ........................................................ 13

២. ការស្នើសុំសំណើផ្លូវចិត្តជាសមូហភាព ........................................................ 31

**II. ច្បាប់ជាធរមាន** ........................................................ **37**

*ក. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ* ........................................................ *37*

១. ធាតុផ្សំបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអនុលោមតាមមាត្រា ៥ នៃច្បាប់ អ.វ.ត.ក ........................................................ 37

២. ធាតុផ្សំនៃឧក្រិដ្ឋកម្ម ........................................................ 42

*ខ. បទល្មើសប្រល័យពូជសាសន៍ (ក្រោមទម្រង់ជាការធ្វើមនុស្សឃាត)* ........................................................ *59*

**III. ការវាយតម្លៃលើភស្តុតាងរបស់ដើមបណ្ដឹងរដ្ឋបវេណី** ........................................................ **63**

*ក. ទិដ្ឋភាពទូទៅ* ........................................................ *63*

*ខ. បញ្ហាពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណឯកសារ* ........................................................ *69*

*គ. ពេលវេលាកន្លង* ........................................................ *72*

*ឃ. បរិបទវប្បធម៌ពិសេសដោយឡែក និងរោគសញ្ញាឈឺចាប់ផ្លូវចិត្ត* ........................................................ *74*

*ង. ការវាយតម្លៃការយល់ព្រមដោយសារកាលៈទេសៈបង្ខិតបង្ខំ* ........................................................ *77*

*ច. កិច្ចពិភាក្សាដេញដោល* ........................................................ *79*

*ឆ. ការវាយតម្លៃត្រួតគ្នានៃតម្លៃជាភស្តុតាង* ........................................................ *80*

**IV. ការបង្ហាញភស្តុតាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងបទឧក្រិដ្ឋ** ........................................................ **82**

ជំពូក ១. សហករណ៍ស្រុកត្រាំកក់ ........................................................ 82

*ក. ទិដ្ឋភាពទូទៅនៃភស្តុតាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី* ........................................................ *83*

*ខ. ភស្តុតាងដែលផ្អែកលើឧក្រិដ្ឋកម្មដែលផ្ដល់ដោយដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសវនាការ* ........................................................ *89*

១. ការធ្វើឱ្យទៅជាទាសករ ........................................................ 89

២. អំពើអមនុស្សធម៌ផ្សេងទៀត ........................................................ 107

៣. ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល ........................................................ 127

៤. ការដាក់ក្នុងមន្ទីរឃុំឃាំង ........................................................ 134

៥. ការធ្វើទារុណកម្ម ........................................................ 136

៦. ការនិរទេស ..... 139
៧. ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ..... 140
៨. ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុជាតិសាសន៍ ..... 147
៩. ការធ្វើទុក្ខបុកម្នេញផ្នែកសាសនាប្រឆាំងនឹងពុទ្ធសាសនិកជន ..... 147
*គ. ព្យសនកម្ម ..... 149*
*ព្យសនកម្មរាងកាយភ្លាមៗ* ..... 149
ជំពូក ២. មន្ទីរសន្តិសុខក្រាំងតាចាន់ ..... 156
*ក. ទិដ្ឋភាពទូទៅនៃភស្តុតាងដើមបណ្ដឹងរដ្ឋប្បវេណី ..... 157*
*ខ. ភស្តុតាងមូលដ្ឋានបទល្មើសដែលផ្ដល់ដោយដើមបណ្ដឹងរដ្ឋប្បវេណីនៅពេលសវនាការ ..... 172*
១. ការដាក់ពន្ធនាគារ ..... 172
២. ការធ្វើឱ្យទៅជាទាសករ ..... 174
៣. អំពើអមនុស្សធម៌ផ្សេងៗទៀត ..... 177
៤. ទារុណកម្ម ..... 183
៥. មនុស្សឃាតនិងការសម្លាប់រង្គាល ..... 187
៦. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ..... 203
*គ. ផលប៉ះពាល់ ..... 204*
១. ផលប៉ះពាល់ផ្លូវកាយ ..... 204
២. ផលប៉ះពាល់ផ្លូវចិត្ត ..... 205
ជំពូក ៣. ការដ្ឋានទំនប់ត្រពាំងថ្ម ..... 206
*ក. ទិដ្ឋភាពរួមនៃភស្តុតាងពីដើមបណ្ដឹងរដ្ឋប្បវេណី ..... 206*
*ខ. ភស្តុតាងនៅកន្លែងកើតហេតុ ដែលដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់ឱ្យក្នុងពេលសវនាការ ..... 213*
១. ការធ្វើឱ្យទៅជាទាសករ ..... 213
២. អំពើអមនុស្សធម៌ផ្សេងៗទៀត ..... 221
៣. ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល ..... 233
៤. ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ..... 234
*គ. ព្យសនកម្ម ..... 235*
១. ព្យសនកម្មផ្នែករាងកាយ ..... 235
២. ព្យសនកម្មផ្លូវចិត្ត ..... 237
៣. ព្យសនកម្មផ្នែកសម្ភារៈ ..... 240
ជំពូក ៤. ការដ្ឋានទំនប់ ១ មករា ..... 241
*ក. ទិដ្ឋភាពរួមនៃភស្តុតាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ..... 241*
*ខ. ភស្តុតាងនៅកន្លែងកើតហេតុដែលដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់នៅពេលសវនាការ ..... 244*

១. ការធ្វើឱ្យទៅជាទាសករ ........ 245

២. អំពើអមនុស្សធម៌ផ្សេងៗទៀត ........ 255

៣. ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល ........ 273

៤. ការធ្វើទុក្ខបុកម្នេញដោយសារនយោបាយ ........ 278

*គ. ព្យសនកម្ម ........ 280*

១. ព្យសនកម្មផ្នែករាងកាយ ........ 280

២. ព្យសនកម្មផ្លូវចិត្ត ........ 283

៣. ព្យសនកម្មផ្នែកសម្ភារៈ ........ 287

ជំពូក ៥. ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ........ 287

*ក. ទិដ្ឋភាពរួមនៃភស្តុតាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ........ 288*

*ខ. ភស្តុតាងដែលជាមូលដ្ឋានឧក្រិដ្ឋកម្មដែលបានផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណីនៅពេលសវនាការ ........ 292*

១. ការធ្វើឱ្យទៅជាទាសករ ........ 292

២. អំពើអមនុស្សធម៌ផ្សេងៗទៀត ........ 297

*គ. ព្យសនកម្ម ........ 302*

១. ព្យសនកម្មផ្នែករាងកាយ ........ 302

២. ព្យសនកម្មផ្លូវចិត្ត ........ 303

ជំពូក ៦. ការប្រព្រឹត្តិលើជនជាតិចាម ........ 305

*ក. ទិដ្ឋភាពទូទៅនៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ........ 307*

*ខ. ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពាក់ព័ន្ធនឹងការធ្វើទុក្ខបុកម្នេញជនជាតិចាម ដោយមូលហេតុសាសនា .... 331*

១. អំពើ ........ 332

២. គោលនយោបាយមកពីថ្នាក់លើ៖ ជនជាតិចាមត្រូវគេចាត់ទុកថាជាខ្មាំង ........ 342

*គ. ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការបះបោររបស់ប្រជាជនចាមនៅស្វាយឃ្លាំង និងផលវិបាករបស់វា ........ 345*

១. ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល ........ 345

២. ការចាប់ដាក់ពន្ធនាគារ ........ 347

៣. ទារុណកម្ម ........ 348

៤. អំពើអមនុស្សធម៌ដទៃទៀត ........ 349

៥. ភស្តុតាងទាក់ទងការប្រព្រឹត្តិ ........ 352

*ឃ. ភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងការជម្លៀសប្រជាជនដំណាក់កាលទី២ (ចាម) ........ 353*

១. អំពើអមនុស្សធម៌ដទៃទៀត ........ 353

២. ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល ........ 359

*ង. ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងវត្តអូរត្រកួន ........ 361*

១. អំពើប្រល័យពូជសាសន៍ (តាមរយៈការសម្លាប់) ..... 361

២. ការចាប់ដាក់ពន្ធនាគារ ..... 365

*ច. ភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណីដែលបានបង្ហាញនៅភូមិទ្រា ..... 365*

១. ការចាប់ដាក់ពន្ធនាគារ ..... 365

២. អំពើប្រល័យពូជសាសន៍តាមរយៈ (ការសម្លាប់) ..... 366

៣. ការធ្វើមនុស្សឃាត ..... 369

*ឆ. ព្យសនកម្ម ..... 370*

១. ព្យសនកម្មលើរូបរាងកាយ ..... 370

២. ព្យសនកម្មផ្លូវចិត្ត ..... 371

៣. ព្យសនកម្មសម្ភារៈ ..... 378

ជំពូក ៧. ការប្រព្រឹត្តិលើជនជាតិវៀតណាម ..... 379

*ក. ទិដ្ឋភាពទូទៅនៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ..... 380*

*ខ. ភស្តុតាងផ្អែកលើបទឧក្រិដ្ឋដែលផ្តល់ដើមបណ្តឹងរដ្ឋប្បវេណីនៅសវនាការ ..... 406*

១. ការជម្លៀសចេញឆ្លងកាត់តាមព្រៃវែង និងស្វាយរៀង ..... 406

២. អំពើប្រល័យពូជសាសន៍ (តាមរយៈការសម្លាប់) នៅព្រៃវែង និងស្វាយរៀង ក្នុងឆ្នាំ ១៩៧៧ នៅក្រចេះ ក្នុងឆ្នាំ ១៩៧៨ ..... 411

*គ. ព្យសនកម្ម ..... 433*

១. ព្យសនកម្មលើរូបរាងកាយ ..... 433

២. ព្យសនកម្មផ្លូវចិត្ត ..... 434

៣. ការបាត់បង់ទ្រព្យសម្បត្តិ ..... 441

ជំពូក ៨. ការបោសសម្អាតនៅភូមិភាគបូព៌ា ..... 442

*ក. ទិដ្ឋភាពទូទៅនៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ..... 442*

ខ. តួនាទីរបស់កម្មាភិបាលភូមិភាគនិរតី ..... 452

១. ព្យសនកម្មលើរាងកាយ ..... 453

២. ព្យសនកម្មផ្លូវចិត្ត ..... 457

ជំពូក ៩៖ មន្ទីរសន្តិសុខភ្នំក្រោល ..... 460

*ក. ទិដ្ឋភាពទូទៅនៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ..... 461*

*ខ. ភស្តុតាងផ្អែកលើឧក្រិដ្ឋកម្ម ដែលដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ នៅក្នុងពេលសវនាការ ..... 467*

១. ការដាក់ក្នុងមន្ទីរឃុំឃាំង ..... 467

២. ការដាក់ឲ្យទៅជាទាសករ ..... 470

៣. ការធ្វើទារុណកម្ម ..... 471

៤. អំពើអមនុស្សធម៌ដទៃទៀត ..... 473

*គ. ព្យសនកម្ម* ............ *475*
ជំពូក ១០៖ មន្ទីរសន្តិសុខស-២១ ............ 477
*ក. ទិដ្ឋភាពទូទៅនៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី* ............ *477*
*ខ. ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម* ............ *495*
១. ការដាក់ក្នុងមន្ទីរឃុំឃាំង ............ 495
២. ការធ្វើទារុណកម្ម ............ 506
*៣. អំពើមនុស្សឃាត និងការសម្លាប់រង្គាល* ............ *509*
៤. ការដាក់ឱ្យទៅជាទាសករ ............ 517
៥. អំពើអមនុស្សធម៌ដទៃទៀត ............ 518
*គ. ព្យសនកម្ម* ............ *520*
១. ព្យសនកម្មរូបរាងកាយ ............ 520
២. ព្យសនកម្មផ្លូវចិត្ត ............ 522
ជំពូក ១១. ការចេញបទបញ្ជាអំពីការរៀបអាពាហ៍ពិពាហ៍ ............ 531
*ក. សេចក្តីសង្ខេបនៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី* ............ *532*
*ខ. ទិន្នន័យរួមអំពីភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី* ............ *577*
១. ឆ្នាំនៃការរៀបអាពាហ៍ពិពាហ៍ ............ 577
២. ទីតាំងនៃពិធីរៀបអាពាហ៍ពិពាហ៍ ............ 579
៣. ចំនួនគូស្រករដែលបានរៀបអាពាហ៍ពិពាហ៍ ............ 582
៤. អាយុរបស់គូស្រករដែលបានរៀបអាពាហ៍ពិពាហ៍ ............ 585
*គ. ភស្តុតាងអំពីឧក្រិដ្ឋកម្ម ដែលដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ នៅក្នុងផ្នែកសវនាការទាក់ទងអំពើអមនុស្សធម៌ដទៃទៀត* ............ *588*
១. ការសម្រេចចិត្តរៀបអាពាហ៍ពិពាហ៍ ............ 588
២. ដំណើរការចាប់គូ ............ 601
៣. ពិធីរៀបការ ............ 613
៤. ទំនាក់ទំនងជាប្តីប្រពន្ធ ពិធីក្រោយពេលរៀបការ ............ 635
៥. ការមានផ្ទៃពោះ និងការរលូតកូន ............ 671
៦. ការបន្តជីវិតជាប្តីប្រពន្ធ ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ............ 674
*ឃ. ព្យសនកម្ម* ............ *677*
១. ព្យសនកម្មផ្លូវកាយ ............ 677
២. ព្យសនកម្មផ្លូវចិត្ត ............ 683
៣. ព្យសនកម្មផ្នែកសម្ភារៈ ............ 702
ជំពូក ១២. តួនាទីរបស់ជនជាប់ចោទ ............ 703

*ក. ទិដ្ឋភាពទូទៅនៃភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ..................... 703*
១. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ ..................... 703
២. ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ផុន ..................... 707
៣. ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ..................... 712
៤. ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន ..................... 715
៥. ភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដទៃទៀត ..................... 717
*ខ. ភ័ស្តុតាងដែលផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសវនាការ ..................... 719*
១. ភ័ស្តុតាងទាក់ទងនឹង នួន ជា ..................... 719
២. ភ័ស្តុតាងទាក់ទងខៀវ សំផន ..................... 725

**V. ផ្នែកសម្រេចសេចក្តី ..................... 732**

**ឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ**

**ឧបសម្ព័ន្ធ ក÷** ក្រុមដើមបណ្តឹងរដ្ឋប្បវេណីរួម និង ព័ត៌មានស្តីពីភាពអាចទទួលយកបានជាដើមបណ្តឹងរដ្ឋប្បវេណី

**ឧបសម្ព័ន្ធ ខ÷** វេទិកា និង ការពិគ្រោះយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០២/០២

**ឧបសម្ព័ន្ធ គ÷** សារណាជាលាយលក្ខណ៍អក្សររបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង ០០២/០២

**ឧបសម្ព័ន្ធ ឃ ដែលបានកែប្រែ÷** ការធ្វើបទបង្ហាញអំពីឯកសារគន្លឹះ

**ឧបសម្ព័ន្ធ ង ដែលបានកែប្រែ÷** សំណួរទៅកាន់ជនជាប់ចោទ

**ឧបសម្ព័ន្ធ ច÷** ដើមបណ្តឹងរដ្ឋប្បវេណី និងសាច់ញាតិរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានចូល ឬត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខ ស-២១

**ឧបសម្ព័ន្ធ ឆ ដែលបានកែប្រែ÷** កាលកំណត់ពេលដាក់បង្ហាញភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលជាជនរងគ្រោះដោយប្រយោលនៃការកំណត់ការរៀបអាពាហ៍ពិពាហ៍ នៅពេលជំនុំជម្រះ

# I. សេចក្តីផ្តើម

1. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ("សហមេធាវីនាំមុខ") សូមដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល ("សេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល") អនុលោមតាមសេចក្តីបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦[1] និងថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៧[2]។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់ឱ្យសហមេធាវីនាំមុខមាន ៥៥០ ទំព័រ សម្រាប់សារណាស្តីពីបញ្ហាទាំងអស់ រួមទាំងសំណងផង[3]។ អង្គជំនុំជម្រះសាលាដំបូងបានកំណត់យកថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៧ ជាថ្ងៃផុតកំណត់នៃសេចក្តីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោល និងថ្ងៃទី ៣០ ខែ ឧសភា ជាថ្ងៃផុតកំណត់សម្រាប់បណ្តឹងទាមទារសំណងជាចុងក្រោយ[4]។

2. សារណានេះបែងចែកជាបួនផ្នែក។ ផ្នែកទីមួយផ្តល់សេចក្តីសង្ខេបអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក ក្នុងអំឡុងកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០២/០២។ ផ្នែកទីពីរនៃសារណានេះមានច្បាប់ជាធរមានដែលត្រូវបានយកមកអនុវត្តនៅក្នុងសារណានេះ។ ផ្នែកទីបីរម្លឹកអំពីគោលការណ៍ណែនាំដែលត្រូវប្រើប្រាស់ នៅពេលវាយតម្លៃភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ផ្នែកទីបួនបង្ហាញអំពីភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងឧក្រិដ្ឋកម្មដែលស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ដែលត្រូវបានរៀបចំទៅតាមវគ្គសវនាការផ្សេងៗ[5]។ ផ្នែក

---

[1] អនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូង សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល និងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលនៅក្នុងសំណុំរឿង ០០២/០២ ឯកសារ **E449/1** ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦។

[2] អនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូង សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំពន្យារពេលកំណត់សម្រាប់ការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល និងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/២ ឯកសារ **E457/6** ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៧។

[3] អនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូង សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល និងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលនៅក្នុងសំណុំរឿង ០០២/០២ ឯកសារ **E449/1** ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៦ កថាខណ្ឌ ៩។

[4] អនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូង សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំពន្យារពេលកំណត់សម្រាប់ការដាក់សារណាបញ្ចប់កិច្ចពិភាក្សាដេញដោល និងសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/២ ឯកសារ **E457/6** ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៧ កថាខណ្ឌ ១៧។

[5] សហមេធាវីនាំមុខកត់សម្គាល់ថា គ្មានដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់បានផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងមន្ទីរសន្តិសុខអូរកន្សែងឡើយ ប៉ុន្តែឯកសារត្រូវបានលើកមកបង្ហាញក្នុងសវនាការឯកសារគន្លឹះសម្រាប់មន្ទីរសន្តិសុខ។ *សូមមើល* ឧបសម្ព័ន្ធ ឃ ៖ ការបង្ហាញឯកសារគន្លឹះ។

នេះក៏បង្ហាញផងដែរអំពីការប្រមូលផ្តុំមិនពេញលេញនៃព្យសនកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរងទាក់ទងនឹងវគ្គសវនាការនីមួយៗ។ សហមេធាវីនាំមុខកត់សម្គាល់ឃើញថា បណ្តឹងទាមទារសំណងជាចុងក្រោយនឹងបង្ហាញអំពីគម្រោងសំណងដែលបានស្នើឡើងចំនួន ១៧ ដែលនឹងត្រូវស្នើសុំឱ្យទទួលស្គាល់ជាសំណងតុលាការដើម្បីផ្តល់ប្រយោជន៍ទៅដើមបណ្តឹងរដ្ឋប្បវេណីចំពោះព្យសនកម្មដែលពួកគាត់បានទទួលរង ដែលជាលទ្ធផលនៃឧក្រិដ្ឋកម្មដែលត្រូវបានជំនុំជម្រះក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២[6]។

## ក. ក្រុមដើមបណ្តឹងរដ្ឋប្បវេណីដែលបានរួមបញ្ចូលគ្នាតែមួយ

3. ការិយាល័យសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស) បានទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២.១១៧ រូប ដោយសំអាងថា ពួកគាត់អាចបានទទួលរងព្យសនកម្មផ្ទាល់ ឬប្រយោលពីឧក្រិដ្ឋកម្ម

[6] ការទាមទារចុងក្រោយនូវសំណងជំងឺចិត្តត្រូវមានការទទួលស្គាល់គម្រោងខាងក្រោមក្នុងទម្រង់ជាការផ្តល់សំណងជំងឺចិត្តផ្លូវតុលាការក្នុងសំណុំរឿង ០០២/២ ៖ ការរៀនសូត្រតាមកម្មវិធីស្តីពីប្រវត្តិខ្មែរក្រហម ការអប់រំស្តីពីប្រវត្តិខ្មែរក្រហមតាមរយៈការបណ្តុះបណ្តាល និងសិក្ខាសាលាសម្រាប់គ្រូបង្រៀន និងនៅតាមសាកលវិទ្យាល័យ។ គម្រោងអណ្តើក ៖ គម្រោងថ្មីតាមបណ្តាញផ្សព្វផ្សាយចម្រុះ តាមរយៈការជំរុញការយល់ដឹងពីប្រវត្តិសាស្ត្រ និងភាពក្លាហានរបស់ប្រជាជនស៊ីវិលនៅកម្ពុជា។ គម្រោងបណ្តាញផ្សព្វផ្សាយសហគមន៍ ៖ ជនជាតិចាម និងខ្មែរក្រហម។ អង្គការផ្កាស្លាក្រោម ៖ អាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបខ្មែរក្រហម។ សំឡេងជនជាតិដើមភាគតិច ៖ ការលើកកម្ពស់ការយល់ដឹងជាសាធារណៈស្តីពីការប្រព្រឹត្តចំពោះជនជាតិដើមភាគតិចក្នុងរបបខ្មែរក្រហម។ រឿងរ៉ាវអាថ៍កំបាំងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលចូលរួមក្នុងសំណុំរឿង ០០២/២ នៅ អ.វ.ត.ក។ កម្មវិធីប្រកួតតែងចម្រៀងយុវជនស្តីពីអនុស្សាវរីយ៍កម្ពុជា។ ការគូសព្រាងគំនូរមន្ទីរសន្តិសុខក្រាំងតាចាន់។ ការទទួលបានកំណត់ហេតុតុលាការស្តីពីការជំនុំជម្រះទោសខ្មែរក្រហម និងឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅមជ្ឈមណ្ឌលតម្កល់ឯកសារច្បាប់ដែលពាក់ព័ន្ធនឹង អ.វ.ត.ក (LDC)។ ការព្យាបាល និងការផ្សះផ្សាជនរងគ្រោះដោយសារការធ្វើទារុណកម្មក្នុងរបបខ្មែរក្រហម។ ការបង្កើនសុខភាព និងសុខុមាលភាពផ្លូវចិត្ត និងការកាត់បន្ថយហានិភ័យនៃភាពក្រីក្រ និងការផាត់ចោលក្នុងសង្គមរបស់ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន និងមនុស្សចាស់ដែលងាយរងគ្រោះផ្សេងទៀតនៅកម្ពុជា។ វេទិកាអប់រំសាធារណៈ និងការតាំងបង្ហាញជាអចិន្ត្រៃយ៍ស្តីពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ គម្រោងបណ្តាញផ្សព្វផ្សាយសហគមន៍ ៖ ជនជាតិដើម និងខ្មែរក្រហម។ លទ្ធភាពទទួលបាន និងការផ្សព្វផ្សាយបណ្ណសារច្បាប់ និងប្រវត្តិសាស្ត្រដែលពាក់ព័ន្ធនឹងខ្មែរក្រហម។ ការបោះពុម្ពផ្សាយ និងចែកចាយសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងទម្រង់ទាំងស្រុង និងសង្ខេប ដល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/២។ មជ្ឈមណ្ឌលសិក្សាសន្តិភាពសហគមន៍ភ្នំសំពៅ និងការប្រព្រឹត្តចំពោះពុទ្ធសាសនិកក្នុងរបបខ្មែរក្រហម។ សហមេធាវីនាំមុខអន្តរជាតិគាំទ្រការរួមបញ្ចូលការអប់រំផ្នែកច្បាប់ និងការអប់រំពលរដ្ឋសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីជាជនជាតិភាគតិចក្នុងទម្រង់ជាសំណើផ្តល់សំណងជំងឺចិត្តផ្លូវតុលាការ។

ដែលត្រូវបានចោទប្រកាន់[7]។ ទាក់ទងនឹងឧក្រិដ្ឋកម្មនានាក្នុងវិសាលភាពនៃសំណុំរឿង ០០២ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៣០៨ ត្រូវបានទទួលស្គាល់ដោយផ្អែកលើឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់ទាក់ទងនឹងការផ្លាស់ទីលំនៅប្រជាជន។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៣២ ត្រូវបានទទួលស្គាល់ដោយផ្អែកលើឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់នៅតាមការដ្ឋាន និងសហករណ៍។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៨៤ រូបត្រូវបានទទួលស្គាល់ដោយផ្អែកលើឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់នៅតាមមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្ស។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១១៥ ត្រូវបានទទួលស្គាល់ដោយផ្អែកលើឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់ថាត្រូវបានប្រព្រឹត្តក្នុងអំឡុងពេលបោសសម្អាត។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៨៧ រូបត្រូវបានទទួលស្គាល់ដោយផ្អែកលើឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់ទាក់ទងនឹងការប្រព្រឹត្តិមកលើពុទ្ធសាសនិក។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤៦ រូបត្រូវបានទទួលស្គាល់ដោយផ្អែកលើឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់ទាក់ទងនឹងការប្រព្រឹត្តិមកលើប្រជាជនចាម។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៧ រូបត្រូវបានទទួលស្គាល់ដោយផ្អែកលើឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់ទាក់ទងនឹងការប្រព្រឹត្តិទៅលើប្រជាជនវៀតណាម ហើយដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៦៣ រូបត្រូវបានទទួលស្គាល់ដោយផ្អែកលើឧក្រិដ្ឋកម្មនានាដែលត្រូវបានចោទប្រកាន់ទាក់ទងនឹងបទប្បញ្ញត្តិនៃអាពាហ៍ពិពាហ៍[8]។

4. អង្គបុរេជំនុំជម្រះ (អ.ប.ជ) បានទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៧៥២ រូបទៀត បន្ទាប់ពីមានបណ្តឹងឧទ្ធរណ៍ជំទាស់នឹងសេចក្តីសម្រេចស្តីពីភាពអាចទទួលយកបាន[9]។ អ.ប.ជ បានទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣ រូប ដោយសំអាងលើព្យសនកម្មដែលបានទទួលរងទាក់ទងនឹងការនិរទេស ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៧ រូបទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១១២៧ រូប ទាក់ទងនឹងការធ្វើឲ្យទៅជាទាសករ ដើមបណ្តឹងរដ្ឋប្បវេណី ចំនួន ២៧ រូបទាក់ទងនឹងការបាត់ខ្លួនដោយបង្ខំ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១១៦ រូបទាក់

[7] *សូមមើល* ឧបសម្ព័ន្ធ ក.១ ៖ ក្រុមរួមនៃដើមបណ្តឹងរដ្ឋប្បវេណី និងព័ត៌មានស្តីពីភាពអាចទទួលយកបាន។ ក.ស.ច.ស និង អ.ប.ជ បានប្រើប្រាស់មូលដ្ឋានផ្សេងៗនៃភាពអាចទទួលយកបាន។ ជាទូទៅ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានទទួលយកដោយផ្អែកលើមូលដ្ឋានលើសពីមួយ។ ដូច្នេះ ចំនួនដែលបានរៀបរាប់ខាងលើមិនត្រូវគ្នានឹងចំនួនដើមបណ្តឹងរដ្ឋប្បវេណីសរុបដែលត្រូវបានទទួលយកឡើយ។

[8] *សូមមើល* ឧបសម្ព័ន្ធ ក.១ ៖ ក្រុមរួមនៃដើមបណ្តឹងរដ្ឋប្បវេណី និងព័ត៌មានស្តីពីភាពអាចទទួលយកបាន។

[9] *សូមមើល* ឧបសម្ព័ន្ធ ក.១ ៖ ក្រុមរួមនៃដើមបណ្តឹងរដ្ឋប្បវេណី និងព័ត៌មានស្តីពីភាពអាចទទួលយកបាន។

ទងនឹងបទប្បញ្ញត្តិនៃអាពាហ៍ពិពាហ៍ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣ រូបទាក់ទងនឹងការបោសសម្អាតផ្ទៃក្នុង ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១២ រូបទាក់ទងនឹងមន្ទីរសន្តិសុខ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៧ រូបទាក់ទងនឹងសហករណ៍ និងការដ្ឋាន ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១០១ រូបទាក់ទងនឹងការប្រព្រឹត្តិមកលើពុទ្ធសាសនិក ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៩៥ រូបទាក់ទងនឹងការប្រព្រឹត្តិមកលើ ប្រជាជនចាម និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៥ រូបទាក់ទងនឹងការប្រព្រឹត្តិមកលើប្រជាជន វៀតណាម[10]។

5. ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៣៨៦៧ រូបដែលពាក្យសុំរបស់ពួកគាត់ត្រូវប្រកាសទទួលស្គាល់ដោយ ក.ស.ច.ស ឬ អ.ប.ជ នៅចុងបញ្ចប់នៃកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០២ ពុំបានចូលរួមជាលក្ខណៈបុគ្គលនៅដំណាក់កាលជំនុំជម្រះឡើយ ប៉ុន្តែចូលរួមជាផ្នែកក្រុមដែលបានរួមបញ្ចូលគ្នាតែមួយ។ សហមេធាវីនាំមុខតំណាងផលប្រយោជន៍របស់ក្រុមដើមបណ្តឹងរដ្ឋប្បវេណីដែលបានរួមបញ្ចូលគ្នាតែមួយ ដោយមានការគាំទ្រពីសំណាក់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី[11]។

6. ក្រុមដែលបានរួមបញ្ចូលគ្នាតែមួយមានសមាសភាពភាគច្រើនជាដើមបណ្តឹងរដ្ឋប្បវេណីពីភ្នំពេញ និងខេត្តនៅជុំវិញនេះ។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រមាណ ២១៩៥ រូប រស់នៅក្នុងខេត្តចំនួន ៨ ក្នុង និងជុំវិញរាជធានីភ្នំពេញ[12] និងប្រមាណ ១០៩៣ រូប រស់នៅតាមបណ្តាខេត្តចំនួន ១២ ដទៃទៀត ដែលចំនួនច្រើនបំផុតនៅកំពង់ធំ (២១២) និងពោធិសាត់ (២៦៨)[13]។

---

[10] *សូមមើល* ឧបសម្ព័ន្ធ ក.១ ៖ ក្រុមរួមនៃដើមបណ្តឹងរដ្ឋប្បវេណី និងព័ត៌មានស្តីពីភាពអាចទទួលយកបាន។

[11] វិធាន ១២ *ស្ទួនពីរ* នៃវិធានផ្ទៃក្នុង (វិសោធនកម្មទី ៩)។

[12] ភ្នំពេញ (១៣២) កណ្តាល (៣៣៧) ព្រៃវែង (២០០) កំពង់ឆ្នាំង (១៥៣) កំពង់ចាម (៩៩៧) កំពត (៥១៨) តាកែវ (៨១) កំពង់ស្ពឺ (៣០៧)។ ចំនួនទាំងនេះជាចំនួនប៉ាន់ស្មាន និងឆ្លុះបញ្ចាំងពីអាសយដ្ឋាននៅពេលទទួលយកការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

[13] រតនគិរី (៣៣) មណ្ឌលគិរី (៥៨) ក្រចេះ (១០១) កំពង់ធំ (២១២) ព្រះវិហារ (៦០) ឧត្តរមានជ័យ (១៧) បន្ទាយមានជ័យ (១២៩) បាត់ដំបង (៦៣) ប៉ៃលិន (១៤) ពោធិ៍សាត់ (២៦៨) កោះកុង (៦៣) កំពង់សោម (៧៥)។ ចំនួនទាំងនេះជាចំនួនប៉ាន់ស្មាន និងឆ្លុះបញ្ចាំងពីអាសយដ្ឋាននៅពេលទទួលយកការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

7. ចំនួនដើមបណ្តឹងរដ្ឋប្បវេណីដែលបង្កើតបានជាក្រុមដែលរួមបញ្ចូលគ្នាតែមួយ មានការប្រែប្រួលក្នុងអំឡុងដំណើរការនៃសំណុំរឿង ០០២[14]។ ចាប់តាំងពីពេលចាប់ផ្តើមកិច្ចដំណើរការនីតិវិធី ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៨១ បានស្លាប់[15]។ បណ្តឹងចំនួន ៣៤ របស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្លាប់ ត្រូវបានបន្តដោយសាច់ញាតិដែលនៅរស់ តាមរយៈបណ្តឹងរបស់អ្នកទទួលសិទ្ធិបន្ត[16]។

8. ចំពោះស្ថានភាពរបស់ពួកគាត់ក្នុងអំឡុងរបបខ្មែរក្រហម ក្នុងចំណោមសំណាកនៃដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៤ រូប ដែលបានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ក្នុងអំឡុងសវនាការលើសំណុំរឿង ០០២/០២ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១០ រូបមានអាយុក្រោម ១៦ ឆ្នាំក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ សំណាកនេះរួមមានដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានចាត់ទុកជាប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន និង ១៦ រូបជាអតីតខ្មែរក្រហម។ ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបជាអ្នកធ្វើមាតុភូមិនិវត្តន៍ពីប្រទេសបារាំង[17]។

## ខ. បណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២

9. វិធាន ២៣(១) នៃវិធានផ្ទៃក្នុង ចែងថា គោលបំណងនៃបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មានពីរ។ គោលបំណងទីមួយគឺដើម្បីចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដោយគាំទ្រដល់ការចោទប្រកាន់ ហើយគោលបំណងទីពីរគឺទាមទារសំណងផ្លូវចិត្តជាសមូហភាពដូចមានចែងក្នុងវិធាន ២៣ *ស្ទួនបួន*។

### ១. ការចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ

#### ១.១. គោលការណ៍ណែនាំ

---

[14] វិសាលភាពតូចនៃការជំនុំជម្រះទោសនេះមិនជះឥទ្ធិពលលើការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬសមាសភាពក្រុមរួមនៃដើមបណ្តឹងរដ្ឋប្បវេណីឡើយ។ វិធាន ៨៩ *ស្ទួន ៣*(៤) នៃវិធានផ្ទៃក្នុង (វិសោធនកម្មទី ៩)។

[15] ព័ត៌មានទាំងនេះត្រូវបានប្រមែប្រមូលពីមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ឬតាមរយៈអង្គភាពនេះផ្ទាល់។ សហមេធាវីនាំមុខកត់សម្គាល់ថា សាច់ញាតិភាគច្រើនរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្លាប់ មិនបានផ្តល់សំបុត្រមរណភាពឡើយ។

[16] *សូមមើល* ឧបសម្ព័ន្ធ ក.២ ៖ បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលបានស្លាប់ដោយមានការអះអាងរបស់សន្តិជនក្នុងសំណុំរឿង ០០២/២។

[17] *សូមមើល* ឧបសម្ព័ន្ធ ក.១ ៖ ក្រុមរួមនៃដើមបណ្តឹងរដ្ឋប្បវេណី និងព័ត៌មានស្តីពីភាពអាចទទួលយកបាន។

### i. ការគាំទ្រដល់ការចោទប្រកាន់ ដោយនៅតែបន្តស្វយ័តភាព

10. ជា "ភាគី" មួយនៃកិច្ចដំណើរការនីតិវិធីនៃ អ.វ.ត.ក ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិដូចសហព្រះរាជអាជ្ញា និងជនជាប់ចោទដែរ ហើយពួកគាត់មានសិទ្ធិផ្នែកនីតិវិធីយ៉ាងទូលំទូលាយ។ តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីមានលក្ខណៈពិសេស នៅពេលវិធានផ្ទៃក្នុងចែងថា ការិយាល័យសហព្រះរាជអាជ្ញាត្រូវអនុវត្តបណ្តឹងអាជ្ញាក្នុង "ការចោទប្រកាន់ចំពោះបទឧក្រិដ្ឋទាំងឡាយណាដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ"[18] តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺ "ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌ [...] ដោយគាំទ្រដល់ការចោទប្រកាន់" និងទាមទារសំណងផ្លូវចិត្ត និងសមូហភាពសម្រាប់ផលប្រយោជន៍នៃដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់ព្យសនកម្មដែលបានទទួលរងជាលទ្ធផលនៃឧក្រិដ្ឋកម្មដែលស្ថិតក្រោមការជំនុំជម្រះ[19]។

11. សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីបានគូសបញ្ជាក់ជាហូរហែរថា "ការគាំទ្រដល់ការចោទប្រកាន់" ត្រូវតែចាត់ទុកថាគាំទ្រដល់ការអនុវត្តបណ្តឹងអាជ្ញា ជាជាងការគាំទ្រទៅការិយាល័យសហព្រះរាជអាជ្ញា[20]។ ដូចដែលសហមេធាវីនាំមុខបានលើកឡើងពីពេលមុន ពួកគាត់ "ត្រូវបានផ្តល់ឱ្យនូវអាណត្តិការងារ *ជាក់លាក់* ដើម្បី "តំណាងឱ្យផលប្រយោជន៍របស់បណ្តុំដើមបណ្តឹងរដ្ឋប្បវេណី ដែលបានរួមគ្នាជាក្រុមតែមួយ" ដែលផ្ទុយពីសហព្រះរាជអាជ្ញា ដែលមានតួនាទីតំណាងឱ្យ "ផលប្រយោជន៍*ទូទៅ* របស់សង្គម" ដែលជាក្រុមមួយដែលជនរងគ្រោះត្រូវបានចាត់ទុកថាស្ថិតក្នុងនោះ ក្នុងចំណោមអ្នកដទៃផ្សេងទៀតទាំងអស់"[21]។

12. អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានផ្តល់ "សិទ្ធិផ្នែកនីតិវិធីផ្សេងៗ" ទៅតាមមុខងារ និងការទទួលខុសត្រូវជាក់លាក់របស់ខ្លួននៅក្នុងកិច្ចដំណើរការនីតិវិធី[22]។

---

[18] វិធាន ៤៩ នៃវិធានផ្ទៃក្នុង (វិសោធនកម្មទី ៩)។

[19] វិធាន ២៣ នៃវិធានផ្ទៃក្នុង (វិសោធនកម្មទី ៩)។

[20] *សូមមើល* ខ. សំណើបន្ទាន់របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំថ្លែងបើកក្នុងនាមឱ្យក្រុមរួមនៃដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ **E316/1** ចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ១៨។

[21] សំណើបន្ទាន់របស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សុំថ្លែងបើកក្នុងនាមឱ្យក្រុមរួមនៃដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ **E316/1** ចុះថ្ងៃទី ៨ ខែ តុលា ឆ្នាំ ២០១៤ កថាខណ្ឌ ១៩។

[22] សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងបណ្តឹងសារទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ **F10/2** ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ១១។

13. ក្នុងអំឡុងដំណើរការនៃសំណុំរឿង ០០២/០២ ផលប្រយោជន៍នៃដើមបណ្តឹងរដ្ឋប្បវេណី និងយុទ្ធសាស្ត្ររបស់ការិយាល័យសហព្រះរាជអាជ្ញា ពុំតែងតែស្របគ្នាគ្រប់ពេលឡើយ។ គួរឲ្យកត់សម្គាល់ សហមេធាវីនាំមុខបានប្រកាន់យកទស្សនៈខុសៗគ្នា ស្តីពីភស្តុតាងដែលបានពីទារុណកម្ម ការដាក់បង្ហាញឯកសារពីសំណុំរឿង ០០៣ និង ០០៤ និងថាតើការរំលោភសេពសន្ថវៈក្រៅបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ស្ថិតក្នុងវិសាលភាពនៃសំណុំរឿង ០០២/០២ ដែរឬទេនោះ។

14. ក្នុងការវាយតម្លៃអំពីផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី សហមេធាវីនាំមុខបានប្តឹងម្តងទៀត ទាក់ទងនឹងស្ថានភាពនៃបទចោទដែលនៅសេសសល់ក្នុងសំណុំរឿង ០០២ គឺ បទចោទទាំងឡាយដែលពុំទាន់ត្រូវបានចាត់ការដោយសំណុំរឿង០០២/០១ ឬសំណុំរឿង០០២/០២ ដោយសំអាងថា ដើមបណ្តឹងរដ្ឋប្បវេណីមានសិទ្ធិដឹងអំពីកិច្ចដំណើរការនីតិវិធីដែលពួកគាត់ជាភាគី។

### ii. ការគោរពសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

15. សហមេធាវីនាំមុខបានទទួលស្គាល់សារៈសំខាន់នៃការជំនុំជម្រះដោយយុត្តិធម៌ដើម្បីជាប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី និងតែងតែបានទុកឲ្យអង្គជំនុំជម្រះសាលាដំបូងជាអ្នកសម្រេច ឬបានគាំទ្រក្រុមមេធាវីការពារក្តី នៅពេលពាក់ព័ន្ធនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ជាសារវ័ន្ត[23]។

[23] *សូមមើល ឧ.* ប្រតិចារឹក ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **E1/242.1** ទំព័រ ៦២ បន្ទាត់ ១៨-២២ ("សូមអរគុណលោកប្រធាន។ ប្រធានបទសំខាន់នេះ ខ្ញុំគិតថា វាជាការមានប្រយោជន៍ណាស់។ ខ្ញុំមិនយល់--សោកស្តាយដែលថា មេធាវីការពារក្តីចេញទៅដោយមិនទាន់បានស្តាប់មតិយោបល់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រោះថាសិទ្ធិ--គឺថាយើងត្រូវគោរពសិទ្ធិទាំងសងខាង ទាំងការពារក្តីផង ទាំងខាងដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ យើងធ្វើយ៉ាងណាឲ្យសិទ្ធិរបស់ជនជាប់ចោទ ឬខាងការពារក្តីត្រូវបានគោរព ហើយទាំងសងខាងធ្វើយ៉ាងណាដើម្បីឲ្យមានយុត្តិធម៌ទាំងអស់គ្នា")។ ប្រតិចារឹក ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១៤ ឯកសារ **E1/244.1** ទំព័រ ៣១-៣៣ បន្ទាត់ ២៤-៧ ("ខ្ញុំមានការកត់សម្គាល់ខ្លីៗទេ ដើម្បីគាំទ្រដល់សំណើរបស់សហព្រះរាជអាជ្ញា ដែលត្រូវតែងតាំងមេធាវីមិត្តរបស់តុលាការដើម្បីជួយតំណាងឲ្យលោក នួន ជា ហើយលោក ខៀវ សំផន ក្នុងសំណុំរឿង ០០២/២។ កាលពីម្សិលមិញយើងបានដាក់សារណាមួយគាំទ្រសំណើរបស់គាត់។ ខ្ញុំចង់និយាយតែពីរម៉ាត់ទេ។ ជាបឋម ខ្ញុំបាននិយាយរួចហើយ ហើយឥឡូវថ្ងៃនេះ ខ្ញុំនិយាយម្តងទៀត ពីព្រោះថាសហភាតារបស់ខ្ញុំនេះដែលមានវត្តមាននៅទីនេះ។ យើងយល់ពីច្បាប់ជាមូលដ្ឋានរបស់ជនជាប់ចោទក្នុងការចូលរួមយ៉ាងសកម្មក្នុងការការពារខ្លួន។ [...] ហើយក៏ត្រូវគិតពីផលប្រយោជន៍ដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ ហើយកាលណាជនជាប់ចោទមានមេធាវីការពារ គឺសិទ្ធិរបស់គាត់ត្រូវបានការពារហើយ។")។

## ១.២. ទម្រង់បែបបទនៃការចូលរួម

16. អង្គជំនុំជម្រះតុលាការកំពូលបានទទួលស្គាល់ “សិទ្ធិចូលរួមយ៉ាងពេញលេញដែលដើមបណ្តឹងរដ្ឋប្បវេណីមានផ្អែកតាមក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងវិធានផ្ទៃក្នុងនៅមុនដំណាក់កាលជំនុំជម្រះ ក្នុងដំណាក់កាលជំនុំជម្រះ និងក្នុងដំណាក់កាលបណ្តឹងសាទុក្ខ”[24]។

### i. ការចូលរួមកិច្ចដំណើរការនីតិវិធីតុលាការ

17. សិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌមានសិទ្ធិចូលរួមសវនាការ។ វិធានផ្ទៃក្នុងបានកំណត់ឲ្យអង្គភាពគាំពារជនរងគ្រោះទទួលខុសត្រូវក្នុងការធានាអំពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងកិច្ចដំណើរការនីតិវិធីតុលាការ ដែលនាំឲ្យដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រមាណ ១០ បានចូលរួមសវនាការតុលាការក្នុងមួយថ្ងៃ ហើយតាមការប៉ាន់ស្មាន ដោយដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១.៦៣៥ រូបបានចូលរួមកន្លងមក[25]។

### ii. វេទិកាព័ត៌មាន និងការពិគ្រោះយោបល់

18. សិទ្ធិចូលរួមក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌរួមមានសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការទទួលបានព័ត៌មាន និងការពិគ្រោះយោបល់។ សហមេធាវីនាំមុខបានព្យាយាមដើម្បីធានាថា សិទ្ធិនេះត្រូវបានផ្តល់ទៅដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ ដែលជាសមាជិកនៃក្រុមដែលរួមបញ្ចូលគ្នាតែមួយ។ ក្រោមការផ្តួចផ្តើមរបស់ខ្លួន សហមេធាវីនាំមុខបានចំណាយធនធានជាច្រើនក្នុងការរៃអង្គាសដើម្បីរៀបចំការពិគ្រោះយោបល់នានាដើម្បីសម្រេចគោលបំណងនេះ។ សហមេធាវីនាំមុខបានសហការជាមួយអង្គភាពគាំពារជនរងគ្រោះក្នុងការរៀបចំការពិគ្រោះយោបល់ និងវេទិកាផ្តល់ព័ត៌មានចំនួន ៦ ស្តីពីកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២ ដែលដើមបណ្តឹងរដ្ឋប្បវេណីចំនួន

---

ប្រតិចារឹក ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/264.1** ទំព័រ ៤០ បន្ទាត់ ១១-១២ (“ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ យើងយល់អំពីកង្វល់របស់មេធាវីការពារក្តី ពីព្រោះថាយើងដូចជាស្ថិតនៅក្នុងស្ថានភាពមួយដូចគ្នាអ៊ីចឹង”)។

[24] សេចក្តីសម្រេចលើសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងបណ្តឹងសារទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ **F10/2** ចុះថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ១១។

[25] ចំនួននេះផ្តល់ដោយអង្គភាពគាំពារជនរងគ្រោះ។ ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនអាចនឹងបានចូលរួមក្នុងដំណើរការនីតិវិធីលើសពីម្តង។ មេធាវីនាំមុខបានកត់សម្គាល់ទៀតថា ដើមបណ្តឹងរដ្ឋប្បវេណីប្រហែល ៤០០ នាក់មិនអាចចូលរួមក្នុងដំណើរការនីតិវិធី ឬវេទិកាបាន ដោយសារជរាភាព ឬបញ្ហាសុខភាព។

៦០៩ បានចូលរួម។ វេទិកាទាំងនេះត្រូវបានរៀបចំនៅមណ្ឌលគិរី ភ្នំពេញ បន្ទាយមានជ័យ និងកំពង់ចាម។ សហមេធាវីនាំមុខសហការជាមួយ *Justice pour le Cambodge* រៀបចំវេទិកាផ្ដល់ព័ត៌មាន និងពិគ្រោះយោបល់ចំនួនបីបន្ថែមទៀតនៅភ្នំពេញ ដោយបានផ្ដល់លទ្ធភាពឲ្យដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ១៤២ រូបទៀត ចែករំលែកទស្សនៈរបស់ពួកគាត់។ ក្នុងអំឡុងពេលនៃសំណុំរឿង ០០២/០២ អង្គភាពគាំពារជនរងគ្រោះបានរៀបចំវេទិកាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៩ ដែលក្នុងនោះសហមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីបានចូលរួម ដោយទៅដល់ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ១២៦៥ រូប[26]។

19. សហមេធាវីនាំមុខ និងមេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ក៏បានជូនដំណឹង និងបានពិគ្រោះជាមួយដើមបណ្ដឹងរដ្ឋប្បវេណីដែលបានចូលរួមកិច្ចដំណើរការនីតិវិធីតុលាការដែរ។

### iii. ការដាក់ភស្តុតាង

#### *ភស្តុតាងជាលាយលក្ខណ៍អក្សរ*

20. អនុលោមតាមវិធានផ្ទៃក្នុង និងយុត្តិសាស្ត្រនៃ អ.វ.ត.ក អង្គជំនុំជម្រះសាលាដំបូងបានផ្អែកការសម្រេចរបស់ខ្លួនទៅលើភស្តុតាងដែលមាននៅចំពោះមុខខ្លួន ដែលត្រូវមានការពិភាក្សាតទល់[27] និងភស្តុតាងដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ[28]។ ក្នុងន័យនេះ សហមេធាវីនាំមុខបានដាក់បញ្ជីឯកសាររបស់ខ្លួនដែលបានដាក់នៅពេលចាប់ផ្ដើមសវនាការក្នុងសំណុំរឿង ០០២/០២[29]។

---

[26] *សូមមើល* ឧបសម្ព័ន្ធ ខ ៖ វេទិកា និងការពិគ្រោះយោបល់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២។

[27] វិធាន ៨៧ (២) នៃវិធានផ្ទៃក្នុង (វិសោធនកម្មទី ៩) ចែងថា "សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ត្រូវផ្អែកលើភស្តុតាងដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយដែលភស្តុតាងនោះត្រូវឆ្លងកាត់ការជជែកដេញដោល"។

[28] វិធាន ៨៧ (៣) នៃវិធានផ្ទៃក្នុង (វិសោធនកម្មទី ៩) ចែងថា "អង្គជំនុំជម្រះសាលាដំបូង ធ្វើសេចក្ដីសម្រេចដោយផ្អែកលើភស្តុតាងដែលមាននៅក្នុងសំណុំរឿង ប្រសិនបើភាគីយកភស្តុតាងទាំងនោះមកដាក់នៅចំពោះមុខអង្គជំនុំជម្រះ ឬប្រសិនបើអង្គជំនុំជម្រះខ្លួនឯងយកភស្តុតាងទាំងនោះមកដាក់នៅចំពោះមុខភាគី"។

[29] បញ្ជីឯកសារ និងវត្ថុតាងរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីដែលបានធ្វើបច្ចុប្បន្នភាព ស្របតាមវិធាន ៨០ សម្រាប់សំណុំរឿង ០០២/០២ ជាមួយឧបសម្ព័ន្ធសម្ងាត់ V ឯកសារ **E305/14** ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៤។ *សូមមើលបន្ថែមទៀត* សំណើរបស់មេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្របតាមវិធាន ៨៧ (៤) ឲ្យទទួលយកភស្តុតាងសក្ខីកម្មផ្ទាល់មាត់ និងឯកសារ និងវត្ថុតាងដែលពាក់ព័ន្ធនឹងសាក្សី អ្នកជំនាញ និងដើមបណ្ដឹងរដ្ឋប្បវេណីដែលត្រូវបានស្នើឲ្យផ្ដល់សក្ខីកម្មក្នុងសំណុំរឿង ០០២/០២ ឯកសារ **E307/6** ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤។

ដោយហេតុថា អង្គជំនុំជម្រះសាលាដំបូងក៏អាចសំអាងលើភស្តុតាងថ្មីដែលត្រូវបានដាក់នៅចំពោះមុខខ្លួនដោយភាគីនានា[30] សហមេធាវីនាំមុខបានដាក់សំណើជាលាយលក្ខណ៍អក្សរចំនួន ៦ អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ក្នុងអំឡុងសវនាការក្នុងសំណុំរឿង០០២/០២ ទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានជ្រើសរើសដើម្បីផ្តល់សក្ខីកម្ម[31]។

21. ទាក់ទងនឹងឯកសារភស្តុតាង បញ្ហានានាដែលកើតចេញពីភាពមិនត្រឹមត្រូវក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានដឹង និងពិភាក្សានៅក្នុងតុលាការ[32]។ ដោយគិតអំពីបញ្ហាទាំងនេះ

---

[30] វិធាន ៨៧ (៣) នៃវិធានផ្ទៃក្នុង (វិសោធនកម្មទី ៩) ចែងថា "ក្នុងកំឡុងពេលសវនាការ តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ ឬតាមការស្នើសុំរបស់ភាគី អង្គជំនុំជម្រះអាចកោះហៅ ឬស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត។ គ្រប់ភាគីដែលបានស្នើសុំ ត្រូវបញ្ជាក់មូលហេតុនៃការស្នើសុំនេះឱ្យបានច្បាស់លាស់។ អង្គជំនុំជម្រះនឹងធ្វើសេចក្តីសម្រេចចំពោះការស្នើសុំនោះ ផ្អែកតាមខ្លឹមសារដែលមានចែងនៅក្នុងវិធាន ៨៧ (៣) ខាងលើ។ ភាគីដែលស្នើសុំត្រូវតែធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថា សក្ខីកម្ម ឬភស្តុតាងដែលបានស្នើសុំនោះ ពុំអាចរកបាននៅមុនពេលការចាប់ផ្តើមជំនុំជម្រះ"។

[31] *សូមមើល* ឧបសម្ព័ន្ធ គ ៖ សារណាជាលាយលក្ខណ៍អក្សររបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២។

[32] ក្នុងសវនាការលើកទីមួយស្តីពីព្យសនកម្ម និងការឈឺចាប់ សហមេធាវីនាំមុខបានបញ្ជាក់ថា "ចំពោះយើង គឺយើងត្រូវតែបំភ្លឺអំពីរបៀបដែលព័ត៌មានទាំងអស់នេះត្រូវបានប្រមូល ហើយនឹងអ្វីដែលយើងចង់ដាក់នៅចំពោះមុខអង្គជំនុំជម្រះជាឯកសារភស្តុតាង។ ខ្ញុំគិតថា សវនាការលើឯកសារគឺនៅពេលក្រោយទេ ឥឡូវនេះ យើងកំពុងតែបំពុលសវនាការទៅលើផលប៉ះពាល់នៃឧក្រិដ្ឋកម្មហើយ។ អ្វីដែលសំខាន់ថ្ងៃនេះ គឺជាសក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះ អ្វីៗគឺសម្រេចទៅលើអង្គជំនុំជម្រះទៅលើចំណុចនេះ។ ចំពោះខ្ញុំគឺខ្ញុំត្រូវតែបំភ្លឺអំពីបញ្ហាពាក់ព័ន្ធទៅនឹងកំហុសជាក់ស្តែងដែលមាននៅក្នុងទម្រង់ព័ត៌មានជនរងគ្រោះ ក៏ដូចជាទម្រង់បែបបទព័ត៌មានបន្ថែម។ យើងក៏ដូចភាគីផ្សេងទៀតដែរ យើងក៏ឃើញមានការពិត ហើយនិងមាន-- និងបញ្ហាទាំងអស់ទាំងអស់ហ្នឹងដែរ<ដែលបានដាក់ចូលក្នុងសំណុំរឿងរួចហើយនោះ>។ ក៏ប៉ុន្តែខ្ញុំសង្ឃឹមថា<ដើមបណ្តឹងរដ្ឋប្បវេណីមានឱកាសថ្លែងទុក្ខរបស់ខ្លួន ដោយយើងមិនត្រូវប្រើប្រាស់ពេលវេលាជ្រុលហួសហេតុលើបញ្ហានេះឡើយ។ តាមពិតទៅវាសំខាន់មែន ប៉ុន្តែសម្រាប់ថ្ងៃនេះបើ>ធ្វើយ៉ាង <នេះទៀតនោះវាបំពុលកិច្ចពិភាក្សាក្នុងអង្គជំនុំជម្រះជាមិនខាន>"។ ប្រតិចារឹក ឯកសារ **E1/288.1** ទំព័រ ១៣-១៤ បន្ទាត់ ១៦-១។ *សូមមើលផងដែរ* មតិយោបល់របស់មេធាវីការពារក្តី ខៀវ សំផន កាលពីថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០១៥ "ទាក់ទងទៅនឹងចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំសូមធ្វើការកត់សម្គាល់ដំបូង កាលពីបឋមនុង ដូចកាលខ្ញុំបានលើកឡើងកាលពីព្រឹកមិញហើយគឺថា ការសុំផ្តល់តម្លៃជាភស្តុតាងឱ្យតិចបំផុត។" ប្រតិចារឹក ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/342.1** ទំព័រ ១៧ បន្ទាត់ ៩-១១។ *និង* មតិយោបល់របស់មេធាវីការពារក្តី ខៀវ សំផន "អ៊ីចឹងក្នុងរយៈពេលខ្លីនោះ យើងពិបាកនឹងជឿទុកចិត្តទៅលើចំណុចនេះណាស់ ក៏ប៉ុន្តែខ្ញុំនឹកឃើញថា ពេលខ្លះទៅព័ត៌មានដែលផ្តល់ជូនដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីនោះ គឺមាននៅក្នុងទម្រង់ព័ត៌មានបន្ថែមនោះ គឺវាសុទ្ធតែជាព័ត៌មានមិនត្រឹមត្រូវនៅពេលដែលយើងឱ្យដើមបណ្តឹងរដ្ឋប្បវេណីមកផ្តល់សក្ខីកម្មនៅក្នុង

ពីដើមដំបូងក្នុងកិច្ចដំណើរការនីតិវិធី សហមេធាវីនាំមុខបានអនុវត្តវិធីសាស្ត្រមួយដើម្បីធានាថា ព័ត៌មានដែលបានបង្ហាញក្នុងតុលាការពីពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មានភាពត្រឹមត្រូវក្នុងកម្រិតដែលមានការផ្ទៀងផ្ទាត់ជាមួយដើមបណ្តឹងរដ្ឋប្បវេណី[33]។ វិធីសាស្ត្រនេះត្រូវបានពន្យល់ក្នុងតុលាការ និងទៅកាន់សាធារណជនក្នុងអំឡុងពេលបង្ហាញឯកសារសំខាន់ៗ នៅក្នុងសវនាការវគ្គទីបី[34]ទីបួន[35]និងទីប្រាំ[36]។ ក្នុងអំឡុងសវនាការពិនិត្យឯកសារសំខាន់ៗ សហមេធាវីនាំ

---

សវនាការនោះ។ អ៊ីចឹងទោះបីជាមានការពិនិត្យផ្ទៀងផ្ទាត់ឡើងវិញដោយមេធាវីក៏ដោយនោះ ក៏យើងគួរតែត្រូវកោះហៅដើមបណ្តឹងមកផ្តល់សក្ខីកម្មដែរ ដើម្បីឲ្យគាត់តទល់ជាមួយនឹងភ័ស្តុតាងផ្សេងៗ នៅក្នុងពេលដែលភាគីសួរដេញដោលទៅលើដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់នោះ។ នេះជាចំណុចដែលខ្ញុំចង់បញ្ជាក់។" ប្រតិចារឹក ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/392.1** ទំព័រ ១៦-១៧ បន្ទាត់ ២២-៣។ *និងផងដែរ* មតិយោបល់របស់មេធាវីការពារក្តី ខៀវ សំផន ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៦ "ដូចកន្លងមកហើយ គឺថាសហមេធាវីនាំមុខតែងតែធ្វើឲ្យយើងជឿជាក់ថា គាត់បានធ្វើការផ្ទៀងផ្ទាត់ជាមុនរួចហើយនូវកំណត់ហេតុស្តាប់ចម្លើយទាំងអស់នេះៗ។ ហើយដូចសព្វដឹងអ៊ីចឹង គឺខ្ញុំនឹងរំលឹកភាគីថា ទោះបីខ្ញុំមិនមានការសង្ស័យចំពោះភាពស្មោះត្រង់របស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្តី ក៏ការផ្ទៀងផ្ទាត់ ដែលគេបានធ្វើឡើងហ្នឹង មិនមានអ្វីត្រូវធ្វើជាមួយនឹងការសួរដេញដោលក្នុងអំឡុងពេលសវនាការដែរ។ ការពិនិត្យដែលធ្វើឡើងដោយក្រុមមេធាវីការពារក្តី មានជ្រុងខុសគ្នាពីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី។ ឥឡូវ ខ្ញុំនិយាយពីចំណុចនេះអស់ហើយ ឥឡូវ ខ្ញុំសូមឆ្លើយតបទៅនឹងការបង្ហាញឯកសាររបស់សហព្រះរាជអាជ្ញាតែម្តង ដែលជាផ្នែកសំខាន់ក្នុងការធ្វើអន្តរាគមន៍របស់ខ្ញុំ។" ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/471.1** ទំព័រ ៤ បន្ទាត់ ២-១០។

[33] ក្នុងការពន្យល់ពីវិធីសាស្ត្ររបស់ខ្លួន សហមេធាវីនាំមុខបានបញ្ជាក់ថា "ខ្ញុំចង់ជម្រាបជូនថា ខ្លឹមសារនៃឯកសារទាំងអស់ដែលយើងបានបង្ហាញនេះ ពីម្សិលមិញ ហើយនិងថ្ងៃនេះ គឺជាខ្លឹមសារនៃពាក្យសុំដើមបណ្តឹងរដ្ឋប្បវេណី ហើយនិងព័ត៌មានបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានផ្ទៀងផ្ទាត់អស់ហើយជាមុន ពេលចាប់ផ្តើមសវនាការនេះ គឺផ្ទៀងផ្ទាត់ដោយមេធាវីដែលបានជួបកូនក្តីរបស់ខ្លួន។ ជូនដោយបុគ្គលិកនៅផ្នែកការងារយើង គឺយើងផ្ទៀងផ្ទាត់ពីខ្លឹមសារនៃចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែលមិនទាន់ស្លាប់" ប្រតិចារឹក ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/391.1** ទំព័រ ១៣ បន្ទាត់ ៨-១២។ សហមេធាវីនាំមុខបានពន្យល់បន្ថែមទៀតថា "ខ្ញុំសូមជម្រាបជូនអង្គជំនុំជម្រះ និងភាគីទាំងអស់ថា ព័ត៌មានទាំងអស់ដែលយើងបង្ហាញនៅថ្ងៃនេះ ហើយនិងព័ត៌មានទាំងអស់ដែលមាននៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់ដើម បណ្តឹងរដ្ឋប្បវេណី ត្រូវបានរៀបចំដោយការិយាល័យរបស់យើងជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណីផ្ទាល់តែម្តង លើកលែងតែដើមបណ្តឹងរដ្ឋប្បវេណីដែលស្លាប់បាត់ទៅហើយ" ប្រតិចារឹក ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/456.1** ទំព័រ ៧០ បន្ទាត់ ១៤-១៨។

[34] ប្រតិចារឹក ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/391.1** ទំព័រ ១៣ បន្ទាត់ ១៧-១៨។

[35] ប្រតិចារឹក ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/456.1** ទំព័រ ៧០ បន្ទាត់ ១៤-១៨។

[36] ប្រតិចារឹក ថ្ងៃទី ៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/470.1** ទំព័រ ៦៤ បន្ទាត់ ១៤-២០។

មុខបានបង្ហាញឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១០០ ដូចដែលបានបង្ហាញក្នុងឧបសម្ព័ន្ធ ឃ ទាក់ទងនឹងការបង្ហាញឯកសារសំខាន់ៗ[37]។

### *ភស្តុតាងផ្ទាល់មាត់*

22. សហមេធាវីនាំមុខបានស្នើឡើងនូវបញ្ជីលម្អិតនៃដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីផ្តល់សក្ខីកម្មស្តីពីអង្គហេតុពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ក្នុងវិសាលភាពនៃការជំនុំជម្រះក្នុងសំណុំរឿង០០២/០២[38]។ លក្ខខណ្ឌវិនិច្ឆ័យសម្រាប់ការជ្រើសរើសដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះអាស្រ័យទៅលើភាពទំនេរ សុខភាពរបស់ពួកគាត់ អង្គហេតុនានាដែលអាចពាក់ព័ន្ធសម្រាប់ការចោទប្រកាន់ផ្នែកព្រហ្មទណ្ឌនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងឆន្ទៈក្នុងការផ្តល់សក្ខីកម្ម។

23. លើសពីនេះទៀត និងជាការគួរឲ្យកត់សម្គាល់ សហមេធាវីនាំមុខ នៅចុងបញ្ចប់នៃវគ្គសវនាការនីមួយៗ អនុលោមតាមសេចក្តីបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង[39] បានដាក់បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់សក្ខីកម្មស្តីពីផលប៉ះពាល់នៃឧក្រិដ្ឋកម្មនានាដែលសំខាន់ចំពោះវគ្គសវនាការណាមួយ[40]។ សហមេធាវីនាំមុខត្រូវបានផ្តល់ឲ្យនូវសិទ្ធិសេរីភាពក្នុងការរៀបចំសវនាការ

---

[37] *សូមមើល* ឧបសម្ព័ន្ធ ឃ ៖ ការបង្ហាញឯកសារគន្លឹះ។

[38] បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្របតាមវិធាន ៨០ សម្រាប់សំណុំរឿង ០០២/០២ ជាមួយឧបសម្ព័ន្ធសម្ងាត់ ឯកសារ **E305/7** ចុះថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៤ (ស្នើសុំដើមបណ្តឹងរដ្ឋប្បវេណី ៦៩ នាក់)។ សហមេធាវីនាំមុខបានដាក់សំណើបន្ថែមទៀតក្នុងពេលជំនុំជម្រះទោស ដោយស្នើឲ្យមានដើមបណ្តឹងរដ្ឋប្បវេណីម្នាក់សម្រាប់អង្គហេតុមួយ និងដើមបណ្តឹងរដ្ឋប្បវេណី ២៦ នាក់ឲ្យធ្វើសក្ខីកម្មក្នុងសវនាការស្តីពីព្យសនកម្មក្នុងការជំនុំជម្រះទោសនោះ។

[39] អនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី ព័ត៌មានអំពី (១) សវនាការលើការបង្ហាញឯកសារគន្លឹះក្នុងសំណុំរឿង ០០២/០២ និង (២) សវនាការលើផលប៉ះពាល់ និងព្យសនកម្មទៅលើដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២ ឯកសារ **E315/1** ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ៧-៩។

[40] បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីរបស់សហមេធាវីនាំមុខ ដែលនឹងមកផ្តល់សក្ខីកម្មក្នុងអំឡុងពេលសវនាការស្តីពីព្យសនកម្មទៅលើដើមបណ្តឹងរដ្ឋប្បវេណី (ជាមួយឧបសម្ព័ន្ធសម្ងាត់) ឯកសារ **E315/1/1** ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៥។ បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវផ្តល់សក្ខីកម្ម នៅក្នុងអំឡុងពេលសវនាការលើការថ្លែងពីការឈឺចាប់ទាក់ទិននឹងវគ្គជំនុំជម្រះទីពីររបស់សហមេធាវីនាំមុខ (ជាមួយឧបសម្ព័ន្ធសម្ងាត់) ឯកសារ **E315/1/3** ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៥។ សំណើរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីសុំដាក់បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវផ្តល់សក្ខីកម្មនៅក្នុងអំឡុងពេលសវនាការលើព្យសនកម្មដែលបានទទួល (ផ្នែកជំនុំជម្រះទី ៣) និងសំណើ អនុលោមតាមវិធាន ៨៧ (៤) (ដោយមានឧបសម្ព័ន្ធ

ស្តីពីផលប៉ះពាល់ និង "ដើម្បីកំណត់ថាតើពេលវេលាដែលត្រូវបានផ្តល់ឲ្យនឹងត្រូវចាត់ចែងដូចម្តេច"[41]។ សហមេធាវីនាំមុខបានធានាថា មេធាវីការពារក្តី និងអង្គជំនុំជម្រះសាលាដំបូង មានពេលវេលាគ្រប់គ្រាន់ដើម្បីសាកសួរដើមបណ្តឹងរដ្ឋប្បវេណីអំពីអង្គហេតុនានាដែលចេញពីសក្ខីកម្មរបស់ពួកគាត់ស្តីពីព្យសនកម្ម[42]។ ភាគីទាំងនេះមានឱកាសដាក់ចម្លើយតបរបស់ពួកគាត់ និង/ឬ

សម្ងាត់) ឯកសារ **E315/1/4** ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៦។ សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអំពីបញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ដែលនឹងត្រូវផ្តល់សក្ខីកម្មនាសវនាការលើផលប៉ះពាល់ និងព្យសនកម្មដែលបានទទួលរង (វគ្គជំនុំជម្រះទីបួន) ឯកសារ **E315/1/6** ចុះថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៦។ សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអំពីបញ្ជីឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលនឹងត្រូវផ្តល់សក្ខីកម្មក្នុងអំឡុងពេលសវនាការលើផលប៉ះពាល់ និងព្យសនកម្មដែលបានទទួលរង (វគ្គជំនុំជម្រះទីប្រាំ) ឯកសារ **E315/1/7** ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៦។

41 អនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីព័ត៌មានអំពី (១) សវនាការលើការបង្ហាញឯកសារគន្លឹះក្នុងសំណុំរឿង ០០២/០២ និង (២) សវនាការលើផលប៉ះពាល់ និងព្យសនកម្មទៅលើដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២ ឯកសារ **E315/1** ចុះថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ៩។

42 *សូមមើល* សំណើកាលវិភាគសម្រាប់សវនាការស្តីពីព្យសនកម្មដែលទទួលរងដោយដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ **E315/1/1.1** ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១៥ ERN (EN) 01079207 ដែលគេទុករយៈពេល ២៥ នាទីសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ដើម្បីប្រើប្រាស់ទៅតាមឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង (សហមេធាវីនាំមុខមានរយៈពេល ៤០ នាទីសម្រាប់ការពិនិត្យផ្ទៀងផ្ទាត់)។ ការរៀបចំនេះត្រូវបានផ្លាស់ប្តូរបន្ទាប់ពីមានបញ្ហាប្រឈមក្នុងអំឡុងពេលសវនាការស្តីពីផលប៉ះពាល់លើវគ្គជំនុំជម្រះទី ១ ដែលដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនមិនអាចមានពេលវេលាគ្រប់គ្រាន់ក្នុងការបញ្ជាក់ពីការឈឺចាប់របស់ខ្លួន ដោយសារពេលវេលាបន្ថែមដែលប្រើប្រាស់ក្នុងពេលពិនិត្យដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនដោយមេធាវីការពារក្តី។ *សូមមើល ឧ.* ដើមបណ្តឹងរដ្ឋប្បវេណី ឡិប នាង អាចបង្ហាញពីការឈឺចាប់របស់ខ្លួនរយៈពេល ១៨ នាទី ដែលផ្ទុយពីរយៈពេលគ្រោងទុកពីដំបូង ៤០ នាទី (ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ៧៩ បន្ទាត់ ៦-ទំព័រ ៨៧ បន្ទាត់ ៩។ បន្ទាប់មក សហមេធាវីនាំមុខបានអនុវត្តក្របខ័ណ្ឌពេលវេលាកាន់តែវែងដើម្បីឲ្យដើមបណ្តឹងរដ្ឋប្បវេណី "បញ្ចប់សក្ខីកម្មរបស់ខ្លួនស្តីពីព្យសនកម្មបានទាំងស្រុងក្នុងរយៈពេលកំណត់សម្រាប់ពួកគេ" និងធានាថា "ចំណុចនេះមិនរងផលប៉ះពាល់ដោយសារការជំទាស់ណាមួយពីភាគីនានា"។ បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវផ្តល់សក្ខីកម្មនៅក្នុងអំឡុងពេលសវនាការលើការថ្លែងពីការឈឺចាប់ ទាក់ទិននឹងវគ្គជំនុំជម្រះទីពីររបស់សហមេធាវីនាំមុខ (ជាមួយឧបសម្ព័ន្ធសម្ងាត់) ឯកសារ **E315/1/3** ចុះថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៥ កថាខណ្ឌ ៨។ *សូមមើលបន្ថែមទៀត* ឧបសម្ព័ន្ធ ១ ៖ សំណើកាលវិភាគសម្រាប់សវនាការស្តីពីព្យសនកម្មដែលទទួលរងដោយដើមបណ្តឹងរដ្ឋប្បវេណី ៖ វគ្គជំនុំជម្រះទី ២ ធ្វើបច្ចុប្បន្នភាពថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ **E315/1/3.3** ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១៥ ERN (EN) 01134680 ដែលរចនាសម្ព័ន្ធនៃសវនាការដែលផ្តល់រយៈពេល ៦០ នាទីសម្រាប់សវនាការស្តីពីផលប៉ះពាល់ និងរយៈពេល ៧៥ នាទីសម្រាប់ការពិនិត្យដោយភាគីផ្សេងទៀត និងអង្គជំនុំជម្រះសាលាដំបូង។ *សូមមើលផងដែរ* សំណើរបស់សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីសុំដាក់បញ្ជីឈ្មោះដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវផ្តល់សក្ខីកម្មនៅក្នុងអំឡុងពេលសវនាការលើព្យសនកម្មដែលបានទទួល (ផ្នែកជំនុំជម្រះទី ៣) និងសំណើ អនុលោមតាមវិធាន ៨៧ (៤) (ដោយមានឧបសម្ព័ន្ធសម្ងាត់) ឯកសារ **E315/1/4** ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៦ ដែល

ការជំទាស់ទៅនឹងសារណានីមួយៗក្នុងចំណោមសារណាទាំងនេះ ព្រមទាំងទៅនឹងរចនាសម្ព័ន្ធនៃសវនាការទាំងនេះ[43]។

24. សរុបមក ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ៦៤ រូបបានផ្ដល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះក្នុងអំឡុងសវនាការក្នុងសំណុំរឿង០០២/០២ ដោយផ្ដល់ភស្តុតាងអំពីទាំងអង្គហេតុពាក់ព័ន្ធនឹងវិសាលភាពនៃសំណុំរឿង ០០២/០២ និងព្យសនកម្មដែលពួកគាត់បានទទួលរង[44]។

## iv. សារណាជាលាយលក្ខណ៍អក្សរ

25. សហមេធាវីនាំមុខបានបង្ហាញផងដែរអំពីផលប្រយោជន៍នៃក្រុមដើមបណ្ដឹងរដ្ឋប្បវេណីដែលបានរួមបញ្ចូលគ្នាតែមួយ នៅក្នុងការដាក់សារណាជាលាយលក្ខណ៍អក្សររបស់សហមេធាវីចំនួនជាង ៥០ ជូនអង្គជំនុំជម្រះ ជំនួសមុខឱ្យដើមបណ្ដឹងរដ្ឋប្បវេណី[45]។ សារណាទាំងនេះគ្រប់ដណ្ដប់លើប្រធានបទសំខាន់ៗ ដែលកើតមានក្នុងអំឡុងដំណើរការនៃសំណុំរឿង០០២/០២ និងបានព្យាយាមលើកស្ទួយការប្រព្រឹត្តិទៅដោយយុត្តិធម៌ និងប្រកបដោយប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធីអនុលោមតាមវិធាន ១២ *ស្ទួន* (២) នៃវិធានផ្ទៃក្នុង។ សហមេធាវីនាំមុខបានប្រកាន់យកវិធីសាស្ត្រមិនជំទាស់ទៅនឹងសំណើសុំកោះហៅសាក្សីបន្ថែម ឬភស្តុតាងថ្មី ដោយមានការលើកលែងមួយ

អនុញ្ញាតឱ្យប្រើប្រាស់រចនាសម្ព័ន្ធស្រដៀងគ្នា។ សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអំពីបញ្ជីឈ្មោះដើមបណ្ដឹងរដ្ឋប្បវេណី ដែលនឹងត្រូវផ្ដល់សក្ខីកម្មនាសវនាការលើផលប៉ះពាល់ និងព្យសនកម្មដែលបានទទួលរង (វគ្គជំនុំជម្រះទីបួន) ឯកសារ **E315/1/6** ចុះថ្ងៃទី ១ ខែ សីហា ឆ្នាំ ២០១៦ កថាខណ្ឌ ៧ ផ្ដល់រយៈពេល ៣០-៥០ នាទីសម្រាប់សក្ខីកម្មស្ដីពីផលប៉ះពាល់ និងរយៈពេល ៤៥-៦៥ នាទី សម្រាប់ការពិនិត្យដោយភាគីផ្សេងទៀត និងអង្គជំនុំជម្រះសាលាដំបូងទៅតាមទំហំនៃការចោទប្រកាន់បទឧក្រិដ្ឋ។ សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអំពីបញ្ជីឈ្មោះរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលនឹងត្រូវផ្ដល់សក្ខីកម្មក្នុងអំឡុងពេលសវនាការលើផលប៉ះពាល់ និងព្យសនកម្មដែលបានទទួលរង (វគ្គជំនុំជម្រះទីប្រាំ) ឯកសារ **E315/1/7** ចុះថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៦ ដែលផ្ដល់រយៈពេល ៣០ នាទីសម្រាប់សក្ខីកម្មស្ដីពីផលប៉ះពាល់ និងរយៈពេល ៥០ នាទីសម្រាប់ការពិនិត្យដោយភាគីផ្សេងទៀត និងអង្គជំនុំជម្រះសាលាដំបូង។

[43] *សូមមើល ឧ.* ចម្លើយតបរបស់មេធាវីការពារក្ដី លោក ខៀវ សំផន ទៅនឹងសំណើរបស់ដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងសវនាការស្ដីអំពីទុក្ខសោកវេទនាទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ ឯកសារស **E315/1/8** ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦។

[44] សេចក្ដីសម្រេចកាត់បន្ថយវិសាលភាពនៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ មិនប៉ះពាល់ដល់ការចូលរួមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឬសមាសភាពនៃបណ្ដុំដើមបណ្ដឹងរដ្ឋប្បវេណីឡើយ។ វិធាន ៨៩ *ស្ទួនបី* (៤) នៃវិធានផ្ទៃក្នុង (វិសោធនកម្មទី ៩)។

[45] *សូមមើល* ឧបសម្ព័ន្ធ គ ៖ សារណាជាលាយលក្ខណ៍អក្សររបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២។

ចំនួនតូចប៉ុណ្ណោះដែលកើតចេញពីការប្រើប្រាស់ភស្តុតាងដែលបានពីទារុណកម្ម ឬដែលផ្ទុយទៅនឹងវិធានផ្ទៃក្នុង[46]។

26. ចំពោះបញ្ហានីតិវិធីទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណីដែលផ្តល់សក្ខីកម្ម សហមេធាវីនាំមុខបានដាក់សារណាជាលាយលក្ខណ៍អក្សរមួយចំនួន ទាក់ទងនឹងការប្រព្រឹត្តិរបស់គាត់ និងវិសាលភាពនៃការសួរដេញដោលរបស់គាត់[47] និងបានដាក់សំណើសុំភស្តុតាងថ្មីៗសម្រាប់ឯកសារនានាទាក់ទងនឹងសក្ខីកម្មរបស់ពួកគាត់[48]។

---

[46] *សូមមើល* ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទៅនឹងសំណើរួមរបស់ នួន ជា អនុលោមតាមវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុង សុំស្តាប់សាក្សីបន្ថែមអំពីសហករណ៍ស្រុកត្រាំកក់ និងមន្ទីរសន្តិសុខក្រាំងតាចាន់ ឯកសារ **E346/1** ចុះថ្ងៃទី ១០ ខែ មេសា ឆ្នាំ ២០១៥ កថាខណ្ឌ ២៣។ សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨៧ (៤) ពាក់ព័ន្ធដើមបណ្តឹងរដ្ឋប្បវេណី D22/2500 ដោយភ្ជាប់ជាមួយឧបសម្ព័ន្ធ ក សម្ងាត់ ឯកសារ **E344** ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០១៦។ *សូមមើលឯកសារពាក់ព័ន្ធនឹងសំណើសុំឱ្យទទួលយកភស្តុតាងដែលពាក់ព័ន្ធនឹងការធ្វើទារុណកម្ម* ៖ ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧ (៤) ដែលស្នើសុំឱ្យទទួលយកជាភស្តុតាងនូវឯកសាររបស់ Robert Lemkin (2-TCW-877) និងឯកសារពាក់ព័ន្ធមួយទៀតមុនពេលស្តាប់សក្ខីកម្មសាក្សី ទាត់ ធឿន (2-TCW-829) (ឯកសារ E416) ឯកសារ **E416/2** ចុះថ្ងៃទី ៤ ខែ កក្កដា ឆ្នាំ ២០១៦ កថាខណ្ឌ ៩ កថាខណ្ឌ ១៣ កថាខណ្ឌ ១៤។ សេចក្តីសន្និដ្ឋានរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងទៅនឹងភាពអាចទទួលយកបាន និងការអនុញ្ញាតដោយច្បាប់ឱ្យប្រើប្រាស់ភស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ឯកសារ **E350/3** ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៥។

[47] *សូមមើល ឧ.* ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើរបស់ក្រុមមេធាវីការពារក្តី ខៀវ សំផន ថ្ងៃទី ២៣ ខែ មេសា ឆ្នាំ ២០១៥ (ឯកសារ E348) ឯកសារ **E348/2** ចុះថ្ងៃទី ១ ខែ ឧសភា ឆ្នាំ ២០១៥។ សារណាតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើរួមរបស់ក្រុមមេធាវីការពារក្តី ស្តីពីការអនុវត្តមួយចំនួនពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញ ឯកសារ **E355/2** ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៥។

[48] *សូមមើល ឧ.* សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨៧ (៤) ពាក់ព័ន្ធនឹងសៀវភៅកំណត់ហេតុប្រចាំថ្ងៃក្នុងរបបកម្ពុជាប្រជាធិបតេយ្យរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខសម្គាល់ 2-TCCP-296 ឯកសារ **E323** ចុះថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១៣។ សំណើរបស់សហមេធាវីនាំមុខអនុលោមតាមវិធាន ៨៧ (៤) ទាក់ទិននឹងដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខសម្គាល់ 2-TCCP-243 ឯកសារ **E400** ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ ២០១៦។ សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨៧ (៤) ពាក់ព័ន្ធនឹងវត្ថុតាងសម្រាប់ប្រើប្រាស់ក្នុងអំឡុងពេលសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីដែលមានលេខសម្គាល់ 2-TCCP-296 ឯកសារ **E332** ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០១៤។ សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៨៧ (៤) សុំឱ្យទទួលយកភស្តុតាង

27. ពាក់ព័ន្ធនឹងការថែរក្សាសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីទាំងនេះ សហមេធាវីនាំមុខបានដាក់សារណាដោយបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង បញ្ជាក់អំពីវិធីសាស្ត្រអនុវត្តរបស់ខ្លួនទាក់ទងនឹងភស្តុតាងដែលបានពីទារុណកម្ម ដែលថា ភ័ស្តុតាងដែលបានពីទារុណកម្មគឺមិនអាចទទួលយកបាន លើកលែងតែចំពោះភ័ស្តុតាងប្រឆាំងនឹងបុគ្គលណាម្នាក់ដែលត្រូវបានចោទប្រកាន់អំពីទារុណកម្ម ដែលជាភ័ស្តុតាងបង្ហាញថាចម្លើយត្រូវបានបង្កើតឡើង ថាភាគីពុំអាចផ្អែកការសួរសំណួរទៅលើភស្តុតាងដែលបានពីទារុណកម្ម ដែលសន្និដ្ឋាន ឬព្យាយាមបញ្ជាក់ថា ខ្លឹមសាររបស់វាអាចជាការពិត និងថា ការប្រើប្រាស់ដែលអាចអនុញ្ញាតគឺទាក់ទងនឹងចំណារ ឬគំនូសសញ្ញាលើភស្តុតាងដែលបានពីទារុណកម្មដែលត្រូវបានធ្វើដោយអ្នកសួរចម្លើយ ឬសមាជិកដទៃទៀតនៃរបបកម្ពុជាប្រជាធិបតេយ្យ[49]។ សហមេធាវីនាំមុខក៏បានព្យាយាមការពារការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល នៅពេលពួកគាត់យល់ឃើញថា ភ័ស្តុតាងថ្មីនឹងផ្ទុយនឹងមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងទារុណកម្ម[50]។

28. សហមេធាវីនាំមុខក៏បានដាក់ចម្លើយតបលើផ្នែកខ្លឹមសារ ក្នុងករណីដែលមានភាពសមស្របត្រូវធ្វើដូច្នោះ។ ជាឧទាហរណ៍ ទោះបីជាសហមេធាវីនាំមុខ ជាគោលការណ៍ ពុំបានជំទាស់ទៅលើសំណើសុំភស្តុតាងដោះបន្ទុកបន្ថែមរបស់ក្រុមមេធាវីការពារក្តី ទាក់ទងនឹងសំណើសុំភ័ស្តុតាងថ្មីៗ ទាក់ទងនឹងមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង សហមេធាវីនាំមុខបានឆ្លើយតបដោយស្នើសុំការបញ្ជាក់បន្ថែមអំពីថាតើសំណើនេះទាក់ទងដីកាដំណោះស្រាយ និង/ឬ ភ័ស្តុតាងដែលមានរួចហើយ

សក្ខីកម្មផ្ទាល់មាត់ និងឯកសារ និងវត្ថុតាងដែលពាក់ព័ន្ធនឹងសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីដែលស្នើសុំធ្វើសក្ខីកម្មក្នុងសំណុំរឿង ០០២/០២ ឯកសារ **E307/6** ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ ២០១៤។

49 សេចក្តីសន្និដ្ឋានរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងទៅនឹងភាពអាចទទួលយកបាន និងការអនុញ្ញាតដោយច្បាប់ឱ្យប្រើប្រាស់ភ័ស្តុតាងដែលបានមកពីការធ្វើទារុណកម្ម ឯកសារ **E350/3** ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០១៥។

50 *សូមមើល ឧ.* ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើរបស់ នួន ជា អនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុងសុំប្រើប្រាស់ចម្លើយសារភាព ស-២១ មួយចំនួន ឯកសារ **E399/1** ចុះថ្ងៃទី ២ ខែ ឧសភា ឆ្នាំ ២០១៦។ ចម្លើយតបរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីទៅនឹងសំណើរបស់ នួន ជា អនុលោមតាមវិធាន ៨៧ (៤) ដែលស្នើសុំឱ្យទទួលយកជាភ័ស្តុតាងនូវឯកសាររបស់ Robert Lemkin (2-TCW-877) និងឯកសារពាក់ព័ន្ធមួយទៀត មុនពេលស្តាប់សក្ខីកម្មសាក្សី ទាត់ ធឿន (2-TCW-829) (ឯកសារ E416) ឯកសារ **E416/2** ថ្ងៃទី ៤ ខែ កក្កដា ឆ្នាំ ២០១៦ កថាខណ្ឌ ១៣-១៤។

នៅចំពោះមុខអង្គជំនុំជម្រះយ៉ាងដូចម្ដេច[51]។ ទាក់ទងនឹងសារណារបស់ នួន ជា ស្ដីពីភាពពាក់ព័ន្ធនៃភស្តុតាងដែលត្រូវបាននិយាយថាទាក់ទងនឹងការបះបោរក្បត់ សហមេធាវីនាំមុខត្រូវឆ្លើយតបដោយហេតុថា សារណានេះមិនបំពេញលក្ខខណ្ឌតម្រូវនៃវិធានផ្ទៃក្នុង និងផ្អែកលើការយល់ច្រឡំជាមូលដ្ឋានអំពីក្របខណ្ឌការងារ អ.វ.ត.ក និងប្រព័ន្ធច្បាប់ស៊ីវិល[52]។ ប៉ុន្ដែទាក់ទងការកោះហៅសាក្សីដែលមានរហស្សនាម 2-TCW-831 សាក្សីម្នាក់ដែលក្រុមមេធាវីការពារក្ដី នួន ជា បានព្យាយាមពន្លឿន សហមេធាវីនាំមុខបានឯកភាពតាមការសម្រេចរបស់អង្គជំនុំជម្រះ និងបានកត់សម្គាល់ឃើញថា មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងដើមបណ្ដឹងរដ្ឋប្បវេណីខ្លះបានទទួលស្គាល់ថាសាក្សីដែលមានរហស្សនាម 2-TCW-831 អាចផ្ដល់ព័ត៌មានដែលអាចជួយបញ្ជាក់ការពិតដែលជាផលប្រយោជន៍នៃដើមបណ្ដឹងរដ្ឋប្បវេណី[53]។

29. ក្នុងអំឡុងដំណើរការនីតិវិធី សហមេធាវីនាំមុខបានស្នើសុំការបញ្ជាក់អំពីវិសាលភាពនៃបទចោទរំលោភសេពសន្ថវៈក្រោយបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ទាក់ទងនឹងការចោទប្រកាន់លើអង្គហេតុនៅសហករណ៍ត្រាំកក់ ស-២១ និងមន្ទីរសន្ដិសុខក្រាំងតាចាន់[54]។ សហមេធាវីនាំមុខបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងបញ្ជាក់ថា ខ្លួនបានទទួលជាផ្លូវការតាមរយៈដីកាដំណោះស្រាយនូវការចោទប្រកាន់លើអង្គហេតុអំពីបទរំលោភសេពសន្ថវៈនៅតាមទីតាំងដែលបានលើកឡើង

---

[51] ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើទីមួយរបស់ នួន ជា អនុលោមតាមវិធាន ៨៧ (៤) និងវិធាន ៩៣ ទាក់ទងការជំនុំជម្រះលើសំណុំរឿង ០០២/០២ ស្ដីពីមន្ទីរសន្ដិសុខ និងការបោសសម្អាតផ្ទៃក្នុង ឯកសារ **E391/1** ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៦។

[52] ចម្លើយតបរបស់សហមេធាវីនាំមុខ ទៅនឹងសារណារបស់ នួន ជា ស្ដីពីភាពពាក់ព័ន្ធនៃភស្តុតាងអំពីការបះបោរក្បត់ ទៅនឹងការទទួលខុសត្រូវព្រហ្មទណ្ឌរបស់គាត់ក្នុងសំណុំរឿង ០០២/០២ ឯកសារ **E395/5** ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៦។

[53] ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើទីពីរ និងទីបីរបស់ នួន ជា ស្ដីពីមន្ទីរសន្ដិសុខ និងការបោសសម្អាតផ្ទៃក្នុង ឯកសារ **E392/1** ចុះថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១ កថាខណ្ឌ ២៣-២៤។

[54] សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុងស្ដីពីការបញ្ជាក់ពីវិសាលភាពនៃសំណុំរឿង ០០២/០២ ទាក់ទងនឹងបទចោទនៃការរំលោភសេពសន្ថវៈ នៅក្រោយបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឯកសារ **E306/7** ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៦។ សូមមើលផងដែរ ការចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងចម្លើយរបស់មេធាវីការពារក្ដី ខៀវ សំផន តបសំណើសុំការបញ្ជាក់បំភ្លឺស្ដីពីការរំលោភសេពសន្ថវៈនៅក្រោយបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឯកសារ **E306/7/2** ចុះថ្ងៃទី ៤ ខែ ឧសភា ឆ្នាំ ២០១៦។

ខាងលើ[55]។ អង្គជំនុំជម្រះសាលាដំបូងបានបដិសេធសំណើនេះ[56]។ សហមេធាវីនាំមុខបានប្ដឹងឧទ្ធរណ៍ជំទាស់សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដោយលើកទឡ្ហីករណ៍ថាអង្គជំនុំជម្រះសាលាដំបូងបានយល់ច្រឡំលើសំណើសុំការបញ្ជាក់ថាជាសំណើសុំកំណត់ប្រភេទបទល្មើសឡើងវិញ និងថា ការអានដ៏ត្រឹមត្រូវនៃដីកាដំណោះស្រាយ គឺផ្អែកលើការចោទប្រកាន់លើអង្គហេតុនានាដែលមាន ពុំមែនការកំណត់ប្រភេទបទល្មើសដែលស្នើឡើងដោយការិយាល័យសហចៅក្រមស៊ើបអង្កេតឡើយ[57]។

30. ដើម្បីផ្ដល់ឱ្យដើមបណ្ដឹងរដ្ឋប្បវេណីនូវព័ត៌មានទាក់ទងបទចោទដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០២ សហមេធាវីនាំមុខបានដាក់សារណារបស់ពួកគាត់ ទាក់ទងនឹងឋានៈនៃបទចោទដែលនៅសេសសល់ក្នុងសំណុំរឿង ០០២/០២។ ដោយហេតុថា កិច្ចដំណើរការនីតិវិធីកំពុងជិតចប់ក្នុងសំណុំរឿង០០២/០២ សហមេធាវីនាំមុខបានកត់សម្គាល់ឃើញថា ពុំមានការបញ្ជាក់អំពីឋានៈនៃការចោទប្រកាន់លើអង្គហេតុដែលត្រូវបានដកចេញពីវិសាលភាពនៃសំណុំរឿង០០២/០២ ឡើយ។ ដើម្បីបំពេញកាតព្វកិច្ចរបស់ពួកគាត់ក្នុងការជូនដំណឹងដល់ដើមបណ្ដឹងរដ្ឋប្បវេណីអំពី ឋានៈនៃកិច្ចដំណើរការនីតិវិធី ពិសេសអ្នកទាំងឡាយដែលរងការប៉ះពាល់ដោយផ្ទាល់ពីឋានៈនៃបទចោទដែលនៅសេសសល់ សហមេធាវីនាំមុខបានស្នើសុំការបញ្ជាក់បន្ថែម ឬព័ត៌មានទាក់ទងនឹងបទចោទ

---

[55] សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុងស្ដីពីការបញ្ជាក់ពីវិសាលភាពនៃសំណុំរឿង ០០២/០២ ទាក់ទងនឹងបទចោទនៃការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឯកសារ **E306/7** ចុះថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ២៨។

[56] សេចក្ដីសម្រេចលើសារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីអនុលោមតាមវិធាន ៩២ នៃវិធានផ្ទៃក្នុងស្ដីពីការបញ្ជាក់ពីវិសាលភាពនៃសំណុំរឿង ០០២/០២ ទាក់ទងនឹងបទចោទនៃការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឯកសារ **E306/7/3** ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦។ *និងសូមមើលផងដែរ* សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗរបស់ដើមបណ្ដឹងរដ្ឋប្បវេណីជំទាស់សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើវិសាលភាពនៃសំណុំរឿង ០០២/០២ ទាក់ទងការចោទប្រកាន់ពីបទរំលោភសេពសន្ថវៈ ឯកសារ **E306/7/3/1/4** ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១៧។

[57] បណ្ដឹងសាទុក្ខភ្លាមៗរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងចំពោះសំណើសុំការបញ្ជាក់ពីវិសាលភាព ទាក់ទងនឹងបទចោទនៃការរំលោភសេពសន្ថវៈនៅក្រៅបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឯកសារ **E306/7/3/1/1** ចុះថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៦។

ដែលនៅសេសសល់ក្នុងសំណុំរឿង ០០២ ដើម្បីពួកគាត់អាចបំពេញកាតព្វកិច្ចរបស់ពួកគាត់អនុលោមតាមវិធានផ្ទៃក្នុង[58]។

31. សហមេធាវីនាំមុខក៏បានដាក់សំណើសុំភស្តុតាងថ្មីមួយសម្រាប់ឯកសារដែលទើបតែត្រូវបានបោះពុម្ពផ្សាយដែលមានចំណងជើង “The Mental Health Outcomes Resulting from Crimes Committed by the Khmer Rouge Regime Before the Extraordinary Chambers in the Courts of Cambodia in Case 002/02”[59]។ ឯកសារនេះត្រូវបង្កើតឡើងដោយមន្ទីរពិសោធន៍ Human Rights in Trauma Mental Health Laboratory នៅសាកលវិទ្យាល័យ Stanford ហើយបានពិនិត្យឯកសារផ្នែកវេជ្ជសាស្ត្រ សតិអារម្មណ៍ និងផ្លូវចិត្ត ដែលវិភាគអំពីផលប៉ះពាល់នៃការប៉ះទង្គិចផ្លូវចិត្តដែលអ្នករួចពីស្លាប់នៃរបបខ្មែរក្រហមបានទទួលរង[60]។ សហមេធាវីនាំមុខយល់ឃើញថា ភស្តុតាងនេះមានភាពចាំបាច់ក្នុងការទទួលស្គាល់ពីព្យសនកម្មផ្លូវចិត្តដែលទទួលរងដោយដើមបណ្តឹងរដ្ឋប្បវេណី និងក្នុងការទទួលស្គាល់ពីភាពសមស្របនៃគម្រោងសំណងទាំងឡាយដែលនឹងត្រូវបានបង្ហាញក្នុងបណ្តឹងទាមទារសំណងជាចុងក្រោយ។

## v. ចម្លើយស្តីពីព្យសនកម្ម

32. ដើមបណ្តឹងរដ្ឋប្បវេណីដែលផ្តល់សក្ខីកម្មម្នាក់ៗ ដែលត្រូវបានជ្រើសរើសដោយអង្គជំនុំជម្រះសាលាដំបូង ដើម្បីផ្តល់សក្ខីកម្មស្តីពីអង្គហេតុ ត្រូវបានផ្តល់ឱកាសឲ្យផ្តល់ចម្លើយអំពីទុក្ខវេទនានៅចុងបញ្ចប់នៃសក្ខីកម្មរបស់ពួកគាត់ ហើយដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៦ បានផ្តល់សក្ខីកម្មអំពីព្យសនកម្មដែលពួកគាត់បានទទួលរង ជាលទ្ធផលនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ក្នុងអំឡុងសវនាការស្តីពីផលប៉ះពាល់ចំនួន ៥ នេះ។ ចម្លើយទាំងនេះគូសបញ្ជាក់អំពីព្យសនកម្មផ្លូវចិត្ត ផ្លូវកាយ

---

58 សំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំសេចក្តីបញ្ជាក់ ទាក់ទងនឹងបទចោទដែលនៅសេសសល់ក្នុងសំណុំរឿង ០០២ ឯកសារ **E439** ចុះថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១៦។

59 សំណើរបស់សហមេធាវីនាំមុខអនុលោមតាមវិធាន ៨៧ (៤) ស្នើសុំឲ្យមានការទទួលស្គាល់ឯកសារមួយជាឯកសារភស្តុតាង ឯកសារ **E285/2** ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០១៦។

60 លទ្ធផលនៃសុខភាពផ្លូវចិត្តដែលទាក់ទងនឹងឧក្រិដ្ឋកម្មនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាក្នុងសំណុំរឿង ០០២/០២ ឯកសារ **E3/10790**។

និងសម្ភារៈ ដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង ហើយព្យសនកម្មមានភាពខុសៗគ្នាទៅតាមឧក្រិដ្ឋកម្មដែលពួកគាត់បានឆ្លងកាត់[61]។

---

[61] *ឧទាហរណ៍* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/340.1** ទំព័រ ១៥ បន្ទាត់ ៧-១៣ ("ខ្ញុំនៅកងចល័តធ្វើការធ្ងន់ ហូបមិនគ្រប់គ្រាន់ ដេកមិនពេញភ្នែក គឺថាខ្ញុំ ក្នុងចិត្តខ្ញុំនេះរកអ្វីមកប្រៀបធៀបមិនបាន គឺថាឃ្លានខ្លាំងពេក និយាយជំនុំគ្នាថា "ខ្ញុំឱ្យតែបាយខ្ញុំហូបឱ្យឆ្អែត មាន់ស្ងោរខ្ញុំមួយចាន ដូចពីសង្គមហ្នឹង យកខ្ញុំទៅសម្លាប់ចុះ ខ្ញុំមិនស្តាយជីវិតខ្ញុំទេ ឱ្យតែបានឆ្អែតមួយពេលបានហើយ" ជំនុំគ្នាអ៊ីចឹង។ អ្ហ! អ្នកខ្លះទៅគេថាបានអាហារមួយចានគេយកទៅសម្លាប់ក៏គេមិនស្តាយដូចគ្នា។ គិតទៅនិយាយតែពីរឿងស៊ី បំណាច់យើងឃ្លានពេកៗ ហ៊ានយកជីវិតទៅប្តូរការសម្លាប់ជំនាន់នោះឱ្យតែបានឆ្អែតៗ មួយពេលគេយកទៅសម្លាប់ចោលទៅ អត់មានស្តាយទេ")។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវិដា ប្រតិចារឹក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ៦៦ បន្ទាត់ ២-៧ ("ខ្ញុំមិនដឹងនិយាយប្រាប់ថាខ្ញុំឈឺចាប់ប៉ុនណាទេ។ ខ្ញុំ ទឹកភ្នែកខ្ញុំស្ទើរតែសឹងរាល់ថ្ងៃ ខ្ញុំនិយាយប្រាប់គេ បើអ្នកណាគេជឿក៏ជឿ។ កូនប្រុសខ្ញុំទេ អ្នកលបមើលឃើញ ឃើញតែខ្ញុំយំបិទទ្វារ។ តែអត់មានអ្នកណាដឹងថាខ្ញុំពិបាកទេ ទាល់តែលបមើលឃើញ បើមិនលបមើលទេ គេអត់ដឹងទេ។ ខ្ញុំសុំឱ្យជួយបកស្រាយនឹងរឿងពិតហ្នឹងឱ្យពួកខ្ញុំស្តាប់ផង ខ្ញុំអត់ចង់បកស្រាយ និងការដោះសារខ្លួនដើម្បីឱ្យរួចខ្លួនណា។ ជីវិតម្នាក់ៗកើតមកគង់តែដល់ថ្ងៃស្លាប់ទេ មុននឹងស្លាប់ យើងចេះ យើងស្រឡាញ់ប្រជាជនឱ្យកូនខ្មែរយើងដឹងប្រវត្តិសាស្ត្រពិតៗផង")។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ៦០-៦១ បន្ទាត់ ១៦-១ ("ផលវិបាកទាំងអស់ដែលធ្លាក់មកលើរូបខ្ញុំ គឺយើងធ្លាប់រស់នៅជួបជុំគ្រួសារ មានក្តីសុខ ដល់ពេលរបបនោះចូលមក គឺយើងបាត់អស់រលីង គឺបាត់បង់គ្រប់យ៉ាង បាត់បង់ផ្ទះសម្បែងទ្រព្យសម្បត្តិ ឪពុកម្តាយ បងប្អូន គឺខ្ញុំរស់នៅតែម្នាក់ឯង។ ខ្ញុំបាត់បង់គ្មានសល់ ទុក្ខលំបាកដែលខ្ញុំមិនធ្លាប់ស្គាល់ គឺខ្ញុំស្គាល់អស់ហើយ។ ភាពឯកោហ្នឹងយ៉ាងណា អ្នកណាដែលឯកោដូចខ្ញុំ អ្នកនោះនឹងដឹង អ្នកដែលគេមិនឯកោ គឺគេមិនដឹងទេ។ [...] ខ្ញុំខ្លាចណាស់ ខ្ញុំខ្លាចមែនទែន ខ្លាចបាក់ស្បាតអស់ហើយ")។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី ពៅ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ១៥ បន្ទាត់ ១៤-១៨ ("ទី ១ ដែលប៉ះពាល់មកដល់បច្ចុប្បន្នរាល់ថ្ងៃនេះ ទី ១ ការងារចំណេះដឹង។ ទី ២ គឺមរកត ទ្រព្យសម្បត្តិដែលឪពុកម្តាយខ្ញុំខំសន្សំទុកសម្រាប់កូនចៅជំនាន់ក្រោយ។ អ៊ីចឹងខ្មែរក្រហមឱ្យលះបង់ឱ្យអស់។ ហើយចំណេះដឹងនេះ ហើយគឺជាកត្តាមួយដែលសំខាន់សម្រាប់មនុស្សគ្រប់រូប។ តែរីឯខ្ញុំវិញ អត់មានចំណេះដឹងទាល់តែសោះ នេះហើយធ្វើឱ្យខ្ញុំមានការបារម្ភរហូតមកដល់បច្ចុប្បន្ន សព្វថ្ងៃនេះ")។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/446.1** ទំព័រ ១០ បន្ទាត់ ១-៨ ("ខ្ញុំបានចូលបម្រើកងទ័ពបដិវត្តន៍កម្ពុជាប្រជាធិបតេយ្យនៅខែ ៥ ឆ្នាំ ១៩៧៥ ពេលនោះ រូបខ្ញុំបាទមានការជឿជាក់នឹងអង្គការថ្នាក់លើដឹកនាំពិតប្រាកដ ហ៊ានលះបង់អាយុជីវិតដើម្បីប្រទេសជាតិ និងមាតុភូមិ និងប្រជាជនពិតៗ ដោយអស់ពីកម្លាំងកាយចិត្តមិនខ្លាចពលីជីវិតឡើយ។ ខ្ញុំបាទគោរពតាមផែនការរបស់បក្ស អនុវត្តវិន័យបានត្រឹមត្រូវ និងចុះប្រឡូកជាមួយគ្រាប់រំសេវប្រយុទ្ធជាមួយខ្មាំងទាំងយប់ទាំងថ្ងៃ គ្មាន ថ្ងៃខ្លះដាច់ស្បៀងអាហារ ២ ថ្ងៃ ទៅ ៣ ថ្ងៃ ជួនអត់ទឹកផឹកក៏មានដែរ គឺមានការលំបាកណាស់។ ប៉ុន្តែជាលទ្ធផលរូបខ្ញុំបាទ និងក្រុមទាហានបូព៌ាជាច្រើននាក់ទៀត ត្រូវបានអង្គការចោទប្រកាន់ថា ក្បត់បក្ស និងចាប់យកទៅសម្លាប់ចោលទៅវិញ ធ្វើឱ្យខ្ញុំមានការតក់ស្លុតជាខ្លាំង។ ខ្ញុំពិតជាហួសនឹងរបបនុងណាស់")។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/477.1** ទំព័រ ១៩ បន្ទាត់ ២០-២៣

## vi. ការសួរសំណួរទៅជនជាប់ចោទ

33. លក្ខណៈពិសេសនៃសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក គឺលទ្ធភាពរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដើម្បីសួរសំណួរទៅជនជាប់ចោទ ប្រសិនបើពួកគាត់មានបំណងសួរ។ ជនជាប់ចោទក្នុងសំណុំរឿង ០០២/០២ បានអនុវត្តសិទ្ធិរបស់ពួកគាត់ក្នុងការនៅស្ងៀមមិនឆ្លើយតប និងបដិសេធមិនឆ្លើយសំណួរដែលបានសួរ។

34. ទោះជាយ៉ាងណាក៏ដោយ ដើមបណ្ដឹងរដ្ឋប្បវេណីដែលផ្ដល់សក្ខីកម្មចំនួន ៥២ រូប ក្នុងចំណោម ៦៤ រូប បានសម្រេចសួរសំណួររបស់ពួកគាត់ក្នុងសវនាការជាសាធារណៈ និងប្រធានបទមួយចំនួនបានលេចចេញ។ ដើមបណ្ដឹងរដ្ឋប្បវេណីចង់ដឹងមូលហេតុដែលពួកគាត់មិនបានមានចំណីអាហារគ្រប់គ្រាន់ដើម្បីបរិភោគ។ ឧទាហរណ៍ ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឡៀប បានសួរ "ហេតុអ្វីបានប្រជាជនត្រូវបានប្រើឱ្យធ្វើការដូចសត្វពាហនៈ និងហេតុអ្វីបានជា <ប្រជាជន> មិនត្រូវបានផ្ដល់ចំណីអាហារគ្រប់គ្រាន់ដើម្បីបរិភោគពីព្រោះមានផលិតកម្មស្រូវច្រើន? <ខ្លះបានឃ្លានដាច់ពោះស្លាប់>"[62]។ ចំពោះអាពាហ៍ពិពាហ៍ក្នុងអំឡុងរបបនេះ ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ បានសួរ "ហេតុអ្វីមនុស្សដែលយើងមិនស្គាល់គ្នា ត្រូវបានចាប់គូឱ្យរៀបការ? តើដើម្បីអ្វី?"[63]។

("ដល់រៀបការៗរួចហើយនេះ កាលណាដែលយើងធ្វើការងារ នៅគេបង្ខំចិត្តរួមដំណេក ការរំលោភ ការមើលងាយ មើលថោកឱ្យយើងឈឺចាប់។ ឈឺចាប់យ៉ាងខ្លាំងនៅក្នុងជីវិតរបស់ខ្ញុំនេះ ថាគ្មានប្រៀបផ្ទឹមបានទេ។ ទោះបីជាខ្ញុំស្លាប់ ក៏ខ្ញុំនៅការចងចាំចំពោះរបបដែលបានធ្វើអំពើឧក្រិដ្ឋកម្មចំពោះរូបខ្ញុំ"។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី យស់ ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** បន្ទាត់ ៤៦ បន្ទាត់ ៤-៩ ("អាពាហ៍ពិពាហ៍នេះខ្ញុំសោកស្ដាយបំផុត។ សោកស្ដាយត្រង់ថា គូដណ្ដឹងរបស់ខ្ញុំហ្នឹងត្រូវបានគ្នាជាប្ដីប្រពន្ធទៅអនាគត ហើយមិនបានគ្នា ដូចជាផ្លែឈើកំពុងតែពេញហើយបេះដាច់មិតមកដូចផ្លែស្វាយស្រក់ជ័រ អាខ្ញុំពេលហ្នឹងនៅប្រធានកងហ្នឹងផ្ដាច់មនោសញ្ចេតនាខ្ញុំ ហើយខ្ញុំគ្មានសិទ្ធិតវ៉ាអី មានតែចុកទ្រូង ចុកថ្លើមពិបាកក្នុងចិត្ត។ សព្វថ្ងៃឱ្យតែនឹកឃើញរឿងហ្នឹង ខ្ញុំដូចថាវាហួសចិត្តតែម្ដង។ ខ្ញុំនឹងថាកើតមកវាជាតិនេះ ហើយចំសម័យអីវេទនាខ្លាំងម្ល៉េះ"។

[62] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឡៀប ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/467.1** ទំព័រ ៥៧ បន្ទាត់ ៦-៨។

[63] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/483.1** ទំព័រ ៥៦ បន្ទាត់ ៧-៨។

35. សំណួររបស់ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ១៤ រូប បានស្វែងរកការទទួលស្គាល់ពីការទទួលខុសត្រូវរបស់ជនជាប់ចោទចំពោះហេតុការណ៍នានាដែលបានកើតឡើងក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ។ ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ស៊ាង សុវីដា បានសួរ “គាត់ចេះតែប្រកែកថា គាត់អត់បានដឹង អត់បានអី ខាងថ្នាក់ក្រោមធ្វើ។ អ៊ីចឹងពេលជំនាន់នោះគាត់មានតែតំណែង តែគាត់អត់តួនាទី ឬក៏អត់មានអំណាចអ្វីទាំងអស់ហើយយ៉ាងម៉េច ខ្ញុំឆ្ងល់។ តែគាត់មិនអាចលម្អិត ខ្ញុំចង់ឲ្យលោកព្រះរាជអាជ្ញា ចៅក្រមជួយឲ្យគាត់មានពេលរាយឲ្យបានល្អិតល្អន់រឿងហ្នឹងឲ្យបានច្បាស់សម្រាប់ទុកឲ្យប្រវត្តិសាស្ត្រខ្មែរនេះ ឲ្យបានកូនខ្មែរក្រោយដឹងផង។ [...] ពួកខ្ញុំចង់ឲ្យមានពេលវេលាឲ្យច្រើន ឲ្យលោកបកស្រាយឲ្យអស់”[64]។ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ១៨ រូប ចង់បានចម្លើយ និងការពិតអំពីអ្វីដែលបានកើតឡើងក្នុងអំឡុង កម្ពុជាប្រជាធិបតេយ្យ។ ជាឧទាហរណ៍និងនិយាយឲ្យងាយយល់គឺ ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ ណូ សាទេស បានសួរថាតើ “តើអ្វីទៅជាគោលបំណងនៃការធ្វើបដិវត្តន៍?”[65]។ ដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ធី បានឆ្ងល់ថា “ហេតុអ្វីពួកគាត់មិនយកថ្ងៃជ័យជម្នះ ១៧ មេសា ១៩៧៥ ដើម្បីអភិវឌ្ឍន៍ប្រទេសតាមជំហានលោតផ្លោះ ដូចដែលពួកគាត់បាននិយាយក្នុងពាក្យស្លោករបស់ពួកគាត់ <ប៉ុន្តែ ដើម្បីសម្លាប់មនុស្ស និងបំផ្លាញប្រទេសទៅវិញ>?”[66]។ ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ូ ដាវ ដែលបានចូលរួមបដិវត្តន៍ បានសួរ “ខ្ញុំបានខំដើរតាមមាគ៌ាបក្ស។ ខ្ញុំបានបូជាជីវិត និងមិនដែលគិតថាខ្ញុំ <នឹង> ស្លាប់នៅពេលណាឡើយ។ ហើយនៅពេលកម្ពុជាប្រជាធិបតេយ្យត្រូវបានបង្កើតឡើង ហេតុអ្វីឪពុកម្ដាយខ្ញុំ បងប្អូនខ្ញុំ និងសាច់ញាតិខ្ញុំ និងខ្ញុំ និងយុទ្ធមិត្តរបស់ខ្ញុំ ត្រូវបានធ្វើទារុណកម្ម ចាប់ដាក់គុក និងបង្ខំឲ្យធ្វើការទាំងថ្ងៃយប់ ដោយមិនមានអាហារគ្រប់គ្រាន់ ហើយពួកគាត់បាន

---

64 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សៀង សុវីដា ប្រតិចារឹក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ៦៣-៦៤ បន្ទាត់ ២២-២ ទំព័រ ៦៦ បន្ទាត់ ១២។

65 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី នោ សាតាស់ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/351.1** ទំព័រ ៥៦ បន្ទាត់ ១១-១២។

66 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ធី ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/394.1** ទំព័រ ២៨ បន្ទាត់ ១២-១៥។

បាត់ខ្លួនជាបន្តបន្ទាប់ ហេតុអ្វីបានជាមានរឿងដូច្នេះកើតឡើង?”[67]។ ព័ត៌មាននេះ និងព័ត៌មានបន្ថែមទាក់ទងនឹងការសួរសំណួរទៅជនជាប់ចោទមានក្នុងឧបសម្ព័ន្ធ ង[68]។

## ២. ការស្នើសុំសំណើផ្លូវចិត្តជាសមូហភាព

36. ផ្នែកទីពីរនៃបណ្ដឹងរបស់ដើមបណ្ដឹងរដ្ឋប្បវេណី គឺលទ្ធភាពស្នើសុំសំណងសម្រាប់ព្យសនកម្មដែលបានទទួលរង ដែលជាលទ្ធផលនៃឧក្រិដ្ឋកម្មដែលត្រូវបានជំនុំជម្រះ និងអាចត្រូវបានផ្ដល់ ក្នុងករណីមានការផ្ដន្ទាទោស។ អនុលោមតាមក្របខណ្ឌការងារនៃ អ.វ.ត.ក ដូចមានចែងក្នុងវិធាន ២៣ *ស្ទួនបី* នៃវិធានផ្ទៃក្នុង មានតែសំណងផ្លូវចិត្តជាសមូហភាពប៉ុណ្ណោះសម្រាប់ដើមបណ្ដឹងរដ្ឋប្បវេណី ហើយសំណងត្រូវតែផ្ដល់ផលប្រយោជន៍ទៅដើមបណ្ដឹងរដ្ឋប្បវេណីដែលលើកឡើងអំពីព្យសនកម្មដែលបានបង្កឡើងដោយឧក្រិដ្ឋកម្មក្រោមវិសាលភាពនៃសំណុំរឿង ០០២/០២។ គ្មានលទ្ធភាពមានសំណងជាប្រាក់ជាលក្ខណៈបុគ្គលឡើយ[69]។

### ២.១. ប្រភេទនៃសំណង

37. ក្របខណ្ឌ អ.វ.ត.ក ចែងតែអំពីសំណងផ្លូវចិត្តជាសមូហភាព ដោយសំណងជាប្រាក់ជាលក្ខណៈបុគ្គល ពុំមានចែងក្នុងវិធានផ្ទៃក្នុងឡើយ។ នៅថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១៤ ដើម បណ្ដឹងរដ្ឋប្បវេណីដែលរងការប៉ះពាល់ដោយកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២/០១ បាន ព្យាយាមដាក់ញត្តិជូនអង្គជំនុំជម្រះសាលាដំបូង ដើម្បីលើកឡើងអំពីអសមត្ថភាពនៃក្របខណ្ឌ អ.វ.ត.ក ក្នុងការផ្ដល់សំណងជាប្រាក់ជាលក្ខណៈបុគ្គល និងសំដែងការមិនពេញចិត្តរបស់ពួកគាត់ ចំពោះគម្រោងសំណងនេះ[70]។ សហមេធាវីនាំមុខ ក្នុងរបាយការណ៍បណ្ដោះអាសន្នស្ដីពីសំណង

[67] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ូ ដារ ប្រតិចារឹក ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/499.1** [កោសលប់] ទំព័រ ១៧-១៨ បន្ទាត់ ២២-១។

[68] *សូមមើល* ឧបសម្ព័ន្ធ ង ៖ សំណួរសួរទៅជនជាប់ចោទ។

[69] អនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្នើសុំឲ្យមានការបញ្ជាក់ពីការទទួលបានញត្តិ ឯកសារ **E352/1** ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៥ កថាខណ្ឌ ២។

[70] *សូមមើល* របាយការណ៍បណ្ដោះអាសន្នរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណីស្ដីពីសំណងនៅក្នុងសំណុំរឿង ០០២/០២ និងសំណើពាក់ព័ន្ធ ឯកសារ **E352** ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ កថាខណ្ឌ ១៧ និងឧបសម្ព័ន្ធ ៣ ៖ អនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូង និងលិខិតរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឯកសារ **E352.4** ចុះថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤។

(ឯកសារ E352) បានស្នើសុំដាក់ញត្តិស្តីពីសំណងជាប្រាក់ជាលក្ខណៈបុគ្គល (ឯកសារ E352.4) ជាផ្លូវការ នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីបានបន្តបញ្ជូនសំណើរបស់ពួកគាត់[71]។ ក្នុងការទទួលស្គាល់អំពីការទទួលញត្តិនេះ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា "ញត្តិនេះត្រូវបានដាក់យ៉ាងត្រឹមត្រូវ ហើយនាពេលនេះបានបង្ហាញខ្លួននៅក្នុងសំណុំឯកសារនៃសំណុំរឿង០០២។ ប៉ុន្តែអង្គជំនុំជម្រះគូសបញ្ជាក់ថា អ.វ.ត.ក គ្មានយុត្តាធិការដើម្បីបង្គាប់ឲ្យអនុវត្ត ឬការចំណាយនៃវិធានការសំណង។ វាអាចត្រឹមតែអនុវត្តសំណងផ្លូវចិត្តជាសមូហភាពប៉ុណ្ណោះ"[72]។

## ២.២. ទម្រង់នៃការអនុវត្ត

38. វិធាន ២៣ *ស្ទួនបី* (៣)(ក) និង (ខ) ចែងអំពីទម្រង់ចំនួនពីរនៃការអនុវត្តគម្រោងសំណងដែលត្រូវបានទទួលស្គាល់ដោយតុលាការ។ គម្រោងអាចត្រូវបានរៀបចំ ឲ្យទណ្ឌិតរ៉ាប់រងថ្លៃសំណង ឬគំរោងទាំងនោះអាចត្រូវបានបង្កើតឡើង និងត្រូវបានផ្តល់ផ្គង់ដោយមជ្ឈដ្ឋានខាងក្រៅ ដោយសហការជាមួយសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ។

39. មុនថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១០ វិធាន ២៣ *ស្ទួនបួន* (១) ចែងច្បាស់ថា សំណង "សោហ៊ុយនៃសំណងត្រូវតែជាបន្ទុករបស់ទណ្ឌិត"[73]។

40. វិធាននេះត្រូវបានធ្វើវិសោធនកម្មជាបន្តបន្ទាប់ដើម្បីការពារជនរងគ្រោះពីចុងចោទដែលក្រីក្រ តាមរយៈការអនុញ្ញាតឲ្យតតិយភាគីចំណាយលើការផ្តល់សំណង[74]។

---

[71] របាយការណ៍បណ្តោះអាសន្នរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្តីពីសំណងនៅក្នុងសំណុំរឿង ០០២/០២ ឯកសារ **E352** ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ កថាខណ្ឌ ១៧។

[72] អនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូង ស្តីពីសំណើរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីស្នើសុំឲ្យមានការបញ្ជាក់ពីការទទួលបានញត្តិ ឯកសារ **E352/1** ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ២០១៥ កថាខណ្ឌ ២។

[73] វិធាន ២៣ *ស្ទួនបួន* (១) នៃវិធានផ្ទៃក្នុង (វិសោធនកម្មទី ៥) ថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ ២០១០។

[74] សាលក្រមក្នុងសំណុំរឿង ០០១ បានគូសបញ្ជាក់ថា "នៅពេលដែលពិរុទ្ធជនត្រូវបានរកឃើញថាជាអ្នកទីទ័លក្រគ្មានលទ្ធភាព ក៏ អ.វ.ត.ក មិនមានយន្តការដែលអនុញ្ញាតឲ្យមានការសងជំនួស ឬបន្ថែមសំណងដែលបានធ្វើឡើងប្រឆាំងនឹងអ្នកទាំងនោះដោយមូលនិធិដែលផ្តល់ដោយអាជ្ញាធរជាតិ ឬតតិយជនបានឡើយ សាលក្រមសំណុំរឿង ០០១ ឯកសារ **E188** កថាខណ្ឌ ៦៦៥។

41. អវត្តមាននៃឃ្លា "ត្រូវតែផ្ដល់ប្រឆាំង" ក្នុងការតាក់តែងនាពេលបច្ចុប្បន្ននៃវិធាន ជាការសំខាន់ពិសេសក្នុងបរិបទនៃវិធីបំបែកវិធាននេះជាមួយ "មួយណាក៏បាន" និង "ឬ" ពាក់ព័ន្ធទម្រង់នៃការអនុវត្តចំនួនពីរដែលបានលើកឡើងខាងលើ។ ក្នុងសំណុំរឿង ០០២/០១ នៅពេលសម្រេចថា "មធ្យោបាយនៃការផ្ដល់សំណងចំនួនពីរដែលមាននៅចំពោះមុខ អ.វ.ត.ក មិនមែនគ្រាន់តែមានលក្ខណៈខុសគ្នាប៉ុណ្ណោះទេ ប៉ុន្តែមធ្យោបាយនីមួយៗមានលក្ខណៈមិនអាស្រ័យគ្នានោះទេ"[75]។ អង្គជំនុំជម្រះសាលាដំបូងបានអនុវត្តតាមពាក្យពេចន៍នៃវិធានដែលត្រូវបានធ្វើវិសោធនកម្ម។ ហេតុដូច្នេះ ពាក្យពេចន៍បច្ចុប្បន្នប៉ះពាល់ដល់គោលការណ៍ដ៏សំខាន់នៃច្បាប់អន្តរជាតិ ដែលទណ្ឌិតជាអ្នកទទួលខុសត្រូវចំពោះព្យសនកម្មដែលគាត់បានបង្ក។ គោលការណ៍នេះត្រូវបានទទួលស្គាល់ដោយគោលការណ៍ និងការណែនាំជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្ដីពីសិទ្ធិទទួលបានដំណោះស្រាយ និងសំណង[76] ព្រមទាំងត្រូវបានចែងក្នុងប្រព័ន្ធសំណងនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (ICC) ដូចដែលបានពិភាក្សាខាងក្រោម។

42. បន្ទាប់ពីមានសាលក្រមលើសំណុំរឿ ០០២/០១ តុលាការ ICC បានកំណត់យ៉ាងច្បាស់ថាការបង្គាប់ឱ្យសងសំណងត្រូវធ្វើចំពោះទណ្ឌិត ហើយក្នុងការធ្វើដូច្នោះ ឆ្លុះបញ្ចាំងអំពីយុត្តិសាស្ត្រអន្តរជាតិស្ដីពីសំណង។ អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ក្នុង *សាលដីកាលើបណ្ដឹងឧទ្ធរណ៍ជំទាស់ "សេចក្ដីសម្រេចបង្កើតគោលការណ៍ និងនីតិវិធីសម្រាប់អនុវត្តចំពោះសំណង" ចុះថ្ងៃទី ៧ ខែសីហា ឆ្នាំ ២០១២* បានពិចារណាអំពីបញ្ហាថាតើការបង្គាប់ឱ្យសងសំណងគួរត្រូវបានធ្វើចំពោះទណ្ឌិតដែរឬទេ នៅពេលដែលការបង្គាប់មួយត្រូវបានធ្វើឡើងតាមរយៈមូលនិធិសម្រាប់ជនរងគ្រោះ ក្នុងករណីទណ្ឌិតជាជនក្រីក្រ។ អង្គជំនុំជម្រះតុលាការឧទ្ធរណ៍បានសម្រេចថា "ការបង្គាប់

[75] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ១១១៨។

[76] គោលការណ៍គ្រឹះ និងគោលការណ៍ណែនាំស្ដីពីសិទ្ធិទទួលបានសំណងជំងឺចិត្តសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សារួមនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ មហាសន្និបាតអង្គការសហប្រជាជាតិ សេចក្ដីសម្រេចលេខ A/RES/60/147 ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០០៦ កថាខណ្ឌ ១៥ ("ក្នុងករណីដែលមានការរកឃើញថាបុគ្គលម្នាក់ដែលជានីតិបុគ្គល ឬនីតិបុគ្គលផ្សេងទៀត ទទួលខុសត្រូវលើការផ្ដល់សំណងដល់ជនរងគ្រោះ ភាគីនោះគួរផ្ដល់សំណងដល់ជនរងគ្រោះ ឬផ្ដល់សំណងដល់រដ្ឋប្រសិនបើរដ្ឋបានផ្ដល់សំណងជាស្រេចដលើជនរងគ្រោះនោះ") កថាខណ្ឌ ១៦ (រដ្ឋគួរខិតខំបង្កើតកម្មវិធីជាតិសម្រាប់ការផ្ដល់សំណង និងជំនួយផ្សេងទៀតដល់ជនរងគ្រោះក្នុងករណីដែលភាគីនានាទទួលខុសត្រូវលើព្យសនកម្មដែលទទួលរង មិនអាច ឬគ្មានឆន្ទៈបំពេញកាតព្វកិច្ចរបស់ខ្លួន")។

ឲ្យសងសំណង ត្រូវចេញ ក្នុងកាលៈទេសៈ*ទាំងអស់* ចំពោះទណ្ឌិត។ នៅពេលសមស្រប ការបង្គាប់ឲ្យសងសំណងអាច *បន្ថែមពីលើនេះ* ត្រូវបានធ្វើតាមរយៈមូលនិធិ”[77]។

43. សំខាន់ចំពោះសំអាងហេតុរបស់អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ គឺគោលការណ៍ដែលថា ការបង្គាប់ឲ្យសងសំណង “ទាក់ទងជាសារវន្តជាមួយ *បុគ្គល* ដែលការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌរបស់គាត់ត្រូវបានបង្ហាញក្នុងការផ្តន្ទាទោស”[78]។ ការអនុវត្តជាក់ស្តែងជាលទ្ធផលនៃវិធានទាំងនេះ គឺថា ការសងសំណងត្រូវបានបង្គាប់ទៅលើទណ្ឌិត សូម្បីតែនៅពេលដែលសំណងទាំងនោះ នឹងត្រូវអនុវត្ត និងផ្តល់ថវិកាតាមរយៈមូលនិធិសម្រាប់ជនរងគ្រោះក៏ដោយ ប្រសិនបើទណ្ឌិតពុំអាចអនុវត្តតាមការបង្គាប់ដោយហេតុផលក្រីក្រ[79]។

44. ដោយកត់សម្គាល់អំពីភាពក្រីក្ររបស់ជនជាប់ចោទទាំងពីរក្នុងសំណុំរឿងនេះ និងអំពីយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីបញ្ហានេះ សំណើសុំសំណងនីមួយៗដែលនឹងមាននៅក្នុងបណ្តឹងទាមទារសំណងជាចុងក្រោយ នឹងត្រូវស្នើសុំតាមរយៈវិធាន២៣ *ស្ទួនបួន* (៣)(ខ) នៃវិធានផ្ទៃក្នុង[80]។ ការអនុវត្ត និងការផ្តល់ថវិកានៃសំណងដែលបានស្នើឡើង ត្រូវបានស្នើសុំពីអង្គការក្រៅរដ្ឋាភិបាល និងពីរាជរដ្ឋាភិបាលកម្ពុជាតាមរយៈការិយាល័យរដ្ឋបាល។ សហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ បានពិគ្រោះជាមួយដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកពាក់ព័ន្ធដទៃទៀត ដើម្បីកំណត់អត្តសញ្ញាណ និងបង្កើតការផ្តល់សំណងប្រកបដោយអត្ថន័យ។

---

[77] ស្ថានភាពក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោក្នុងរឿងក្តីរដ្ឋអាជ្ញាតទល់នឹង Thomas Lubanga Dyilo សំណុំរឿងលេខ ICC-01/04-01/06 A A 2 A 3 *សាលក្រមបណ្តឹងសាទុក្ខប្រឆាំងនឹង “សេចក្តីសម្រេចបង្កើតគោលការណ៍ និងនីតិវិធីសម្រាប់ការផ្តល់សំណង” ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១២* ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ កថាខណ្ឌ ៧៦។

[78] ស្ថានភាពក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោក្នុងរឿងក្តីរដ្ឋអាជ្ញាតទល់នឹង Thomas Lubanga Dyilo សំណុំរឿងលេខ ICC-01/04-01/06-3129-AnxA *សាលក្រមបណ្តឹងសាទុក្ខប្រឆាំងនឹង “សេចក្តីសម្រេចបង្កើតគោលការណ៍ និងនីតិវិធីសម្រាប់ការផ្តល់សំណង” ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១២* ឧបសម្ព័ន្ធ ក ៖ ដីកាបង្គាប់ឲ្យផ្តល់សំណង ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ កថាខណ្ឌ ២០។

[79] ស្ថានភាពក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោក្នុងរឿងក្តីរដ្ឋអាជ្ញាតទល់នឹង Thomas Lubanga Dyilo សំណុំរឿងលេខ ICC-01/04-01/06 A A 2 A 3 *សាលក្រមបណ្តឹងសាទុក្ខប្រឆាំងនឹង “សេចក្តីសម្រេចបង្កើតគោលការណ៍ និងនីតិវិធីសម្រាប់ការផ្តល់សំណង” ថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១២* ចុះថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០១៥ កថាខណ្ឌ ៥។

[80] *សូមមើល* របាយការណ៍បណ្តោះអាសន្នរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្តីពីសំណងនៅក្នុងសំណុំរឿង ០០២/០២ និងសំណើពាក់ព័ន្ធ ឯកសារ E352 ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ កថាខណ្ឌ ៣។

## ២.៣. វិធីសាស្ត្រ និងសារណា

45. សហមេធាវីនាំមុខបានអនុវត្តតាមការអនុវត្តនៅក្នុងសំណុំរឿង ០០២/០១ ក្នុងការចាប់ផ្ដើមអនុវត្តការផ្ដល់សំណង មុនពេលមានសាលក្រម[81]។ ជាផ្នែកមួយនៃវិធីសាស្ត្ររបស់ពួកគាត់ក្នុងការកំណត់អត្តសញ្ញាណ បង្កើត និងអនុវត្តគំរោងសំណង សហមេធាវីនាំមុខបានដឹងថា ខ្លឹមសារនៃគំរោងសំណងរមែងលើកលែងអំពីហេតុការណ៍នានាដែលជាកម្មវត្ថុនៃកិច្ចដំណើរការនីតិវិធីដែលកំពុងប្រព្រឹត្តទៅ។ ពួកគាត់បានព្យាយាមលើកទឹកចិត្តដៃគូដើម្បីបង្កើតខ្លឹមសារនៃគំរោងទាំងនោះពីបទពិសោធន៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី និងដើម្បីគោរពការសន្និដ្ឋានជាមុនថាគ្មានទោសរបស់ជនជាប់ចោទ រហូតដល់ពេលមានសាលក្រមស្ថាពរ។

46. ការបង្កើតគំរោងសំណងត្រូវបានផ្អែកលើ និងឆ្លុះបញ្ចាំងពីបំណងប្រាថ្នារបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ សហមេធាវីនាំមុខបានដាក់សារណាចំនួនពីរក្នុងអំឡុងដំណើរការនៃសំណុំរឿង០០២/០២ ដែលគូសបញ្ជាក់អំពីដំណើរការពិគ្រោះយោបល់ជាមួយដើមបណ្ដឹងរដ្ឋប្បវេណី និងការវិវត្តន៍នៃការបង្កើតគំរោងសំណងសម្រាប់សំណុំរឿង ០០២/០២[82]។ របាយការណ៍ទីមួយដែលរៀបរាប់អំពីដំណើរការដែលគំរោងសំណងត្រូវបានកំណត់ឡើង ដោយចាប់ផ្ដើមជាមួយពាក្យសុំពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីដំបូង ដែលត្រូវតែដាក់ ដើម្បីក្លាយជាដើមបណ្ដឹងរដ្ឋប្បវេណី និងការពិគ្រោះយោបល់ជាបន្តបន្ទាប់ជាមួយអ្នកពាក់ព័ន្ធ និងដើមបណ្ដឹងរដ្ឋប្បវេណីរហូតដល់ខែ កក្កដា ឆ្នាំ ២០១៥។ សហមេធាវីនាំមុខបានបន្តកំណត់អត្តសញ្ញាណ និងបង្កើតគំរោងនានាដែលឆ្លុះបញ្ចាំងអំពីប្រភេទនានាដែលតំណាងដោយគោលការណ៍ជាមូលដ្ឋាន និងគោលការណ៍ណែនាំស្ដីពីសិទ្ធិ

---

[81] អនុស្សារណៈរបស់អង្គជំនុំជម្រះសាលាដំបូង ស្ដីពីការចង្អុលបង្ហាញអំពីគម្រោងជាអាទិភាពសម្រាប់ការអនុវត្តសំណង (វិធាន ៨០ *ស្ទួន* (៤)) ឯកសារ **E218/7** ចុះថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ២ ("ដោយពិចារណាទៅលើបញ្ហាប្រឈមនានាក្នុងការអនុវត្តសំណង ដូចដែលបានលើកឡើងដោយសហមេធាវីនាំមុខអន្តរជាតិក្នុងការរៀបចំសវនាការថ្មីៗកន្លងទៅនេះ អង្គជំនុំជម្រះសូមគូសបញ្ជាក់ថា ការអនុវត្តវិធានការទាំងនេះអាចនឹងចាប់ផ្ដើមមុនការចេញសាលក្រមក្នុងសំណុំរឿង ០០២/០១។ គោលបំណងនេះគឺស្របទៅនឹងការអនុម័តវិធាន ២៣ *ស្ទួនបួន* (៣) (ខ) នៃវិធានផ្ទៃក្នុង ដែលនឹងជំរុញដល់ការអនុវត្តសំណងប្រកបដោយអត្ថន័យក្នុងពេលវេលាដ៏សមស្របដោយមានជំនួយពីមូលនិធិម្ចាស់ជំនួយ និងកិច្ចសហការពីខាងក្រៅ។ បន្ថែមលើនេះទៀត សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី និងអង្គភាពគាំពារជនរងគ្រោះត្រូវបានស្នើឲ្យកំណត់អំពីមូលដ្ឋាននៃមូលនិធិអាទិភាពឲ្យបានឆាប់ ដើម្បីគាំទ្រគម្រោងទាំងនោះ ដែលនឹងត្រូវស្នើសុំជាសំណង")។

[82] របាយការណ៍បណ្ដោះអាសន្នរបស់សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី ស្ដីពីសំណងនៅក្នុងសំណុំរឿង ០០២/០២ និងសំណើពាក់ព័ន្ធ ឯកសារ **E352** ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥។

ទទួលបានដំណោះស្រាយ និងសំណង ដែលផ្តល់បដិទាន ការសងជំងឺចិត្ត ការស្តារនីតិសម្បទា ការសង និងការធានាអំពីភាពមិនច្រំដែល ជាសំណងសម្រាប់ព្យសនកម្មដែលបានទទួលរង[83]។

47. សារណាទីពីរដែលរៀបរាប់អំពីពិគ្រោះយោបល់ជាមួយដើមបណ្តឹងរដ្ឋប្បវេណី ដែលបានកើតមាន រវាងខែ កក្កដា ឆ្នាំ ២០១៥ និងខែ កក្កដា ឆ្នាំ ២០១៦ និងបានរៀបរាប់ជាលម្អិតអំពីគំរោងអាទិភាព ចំនួន ៩ ដែលត្រូវបានកំណត់អត្តសញ្ញាណ និងត្រូវបានបង្កើតឡើងជាគំរោងសំណងដែលបានស្នើឡើង[84]។ សារណានេះក៏ថែមទាំងបានផ្តល់កាលវិភាគសម្រាប់ការអនុវត្ត និងបានកំណត់អត្តសញ្ញាណគំរោងទាំងឡាយដែលបានទទួលថវិកាគ្រប់គ្រាន់។

48. ដើម្បីបំពេញអាណត្តិការងាររបស់ពួកគាត់ សហមេធាវីនាំមុខបានព្យាយាមពិគ្រោះយោបល់ជាមួយដើមបណ្តឹងរដ្ឋប្បវេណីឲ្យបានចំនួនច្រើនតាមដែលអាចធ្វើទៅបាន នៅគ្រប់ដំណាក់កាលនៃដំណើរការបង្កើតសំណងនេះ។ ពួកគាត់បានប្រើប្រាស់យន្តការចំនួនបី ដើម្បីជូនដំណឹង និងពិគ្រោះជាមួយដើមបណ្តឹងរដ្ឋប្បវេណីស្តីពីគំរោងសំណង បន្ថែមពីលើការពិគ្រោះដែលធ្វើឡើងដោយមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ៗ និងកូនក្តីរបស់ពួកគាត់។ ទីមួយ វេទិកាដើម បណ្តឹងរដ្ឋប្បវេណី[85] ដែលត្រូវបានរៀបចំដោយអង្គភាពគាំពារជនរងគ្រោះ ការពិគ្រោះអំពីសំណង និងវេទិកាផ្តល់ព័ត៌មានស្តីពីសំណុំរឿង០០២/០២ ដែលត្រូវបានរៀបចំដោយសហមេធាវីនាំមុខ និងអង្គភាពគាំពារជនរងគ្រោះ[86] និងការពិគ្រោះជាក់លាក់អំពីគំរោងដែលត្រូវបានរៀបចំដោយដៃគូអនុវត្ត។ ជាលទ្ធផល ផ្នែកគាំពារជនរងគ្រោះ និងសហមេធាវីនាំមុខ បានរៀបចំការពិគ្រោះយោ

---

[83] គោលការណ៍គ្រឹះ និងគោលការណ៍ណែនាំស្តីពីសិទ្ធិទទួលបានសំណងជំងឺចិត្តសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សារួមនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់មនុស្សធម៌អន្តរជាតិ មហាសន្និបាតអង្គការសហប្រជាជាតិ សេចក្តីសម្រេចលេខ 60/147 ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១៥ មាត្រា ១៨-២៣។

[84] សារណារបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងគម្រោងសំណងសម្រាប់អនុវត្តក្នុងសំណុំរឿង ០០២/០២ និងឧបសម្ព័ន្ធ (សម្ងាត់) ចំនួនបួន ឯកសារ **E352/2/1** ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០១៦។

[85] ដៃគូអនុវត្តន៍ត្រូវបានអញ្ជើញឲ្យបង្ហាញពីគម្រោងរបស់ខ្លួន និងទទួលបានយោបល់ត្រឡប់ពីដើមបណ្តឹងរដ្ឋប្បវេណីដើម្បីបង្កើតជាគម្រោងទៅតាមទស្សនៈរបស់ពួកគេ និងបង្កើនអត្ថប្រយោជន៍ដែលពួកគេនឹងទទួលបាន។

[86] *សូមមើល* ឧបសម្ព័ន្ធ ខ ៖ វេទិកា និងការពិគ្រោះយោបល់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០២/០២។

បល់ជាមួយដើមបណ្ដឹងរដ្ឋប្បវេណីចំនួនជាង ២០១៦ ស្ដីពីគំរោងសំណងនានាសម្រាប់សំណុំរឿងនេះ[87]។

## II. ច្បាប់ជាធរមាន

### ក. ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ

#### ១. ធាតុផ្សំបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិអនុលោមតាមមាត្រា ៥ នៃច្បាប់ អ.វ.ត.ក[88]

49. ក្នុងផ្នែកនេះ សហមេធាវីនាំមុខនឹងពិភាក្សាអំពីច្បាប់ជាធរមាន និងសំអាងច្បាប់ពាក់ព័ន្ធក្នុងសំណុំរឿង ០០២/០១ ទាក់ទងនឹងធាតុផ្សំរួមនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ បទល្មើសជាមូលដ្ឋានដែលរៀបរាប់ខាងក្រោម គ្រាន់តែជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ប្រសិនបើធាតុផ្សំបរិបទដូចតទៅនេះត្រូវបានបង្ហាញ (i) ការវាយប្រហារមួយ (ii) ដែលជាទូទៅ ឬជាលក្ខណៈប្រព័ន្ធ (iii) សំដៅទៅលើប្រជាជនស៊ីវិល (iv) ដោយមូលហេតុជាតិសាសន៍ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា (v) មានចំណងពាក់ព័ន្ធរវាងអំពើរបស់ចារីផ្ទាល់ និងការវាយប្រហារ ហើយ (vi) ចារីមានការដឹងឮដែលជាលក្ខខណ្ឌតម្រូវ[89]។

*ការវាយប្រហារ*

50. ក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថាមាន "ការវាយប្រហារទៅលើប្រជាជនស៊ីវិលកម្ពុជា" និងបានគូសបញ្ជាក់ថា "ការវាយប្រហារមានច្រើនទម្រង់ ដោយរួមបញ្ចូល ការជម្លៀសដោយបង្ខំ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការបាត់ខ្លួនដោយបង្ខំ និង

[87] ចំនួននេះមិនរួមបញ្ចូលដើមបណ្ដឹងរដ្ឋប្បវេណីដែលបានចូលរួមក្នុងការពិគ្រោះយោបល់ដែលរៀបចំឡើងដោយដៃគូអនុវត្តន៍សម្រាប់គម្រោងមួយចំនួនឡើយ។

[88] មាត្រា ៥ នៃច្បាប់ អ.វ.ត.ក៖ អង្គជំនុំជម្រះវិសាមញ្ញមានអំណាចវិនិច្ឆ័យទោសជនសង្ស័យទាំងឡាយដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងអំឡុងថ្ងៃ ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩។ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលគ្មានអាជ្ញាយុកាលគឺអំពើណាមួយដូចខាងក្រោម ដែលវាយប្រហារជាទូទៅ ឬដោយមានការរៀបចំប្រឆាំងនឹងប្រជាជនស៊ីវិលដោយមូលហេតុជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនាណាមួយ ដូចជា ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ពូជសាសន៍ ឬសាសនា អំពើអមនុស្សធម៌ផ្សេងៗទៀត។

[89] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ E313 កថាខណ្ឌ ១៧៧។

ការធ្វើទុក្ខបុកម្នេញ។ ការវាយប្រហារនេះបានដាក់ប្រជាជនស៊ីវិលរាប់លាននាក់ជាជនរងគ្រោះនៅទូទាំងកម្ពុជា និងបានបណ្ដាលឱ្យជនភៀសខ្លួនមួយចំនួនរត់ភៀសខ្លួនទៅប្រទេសជិតខាង"[90]។ ជាសំខាន់ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា "ការវាយប្រហារត្រូវបានអនុវត្តដើម្បីជំរុញ និងអនុលោមតាមគោលនយោបាយ និងផែនការបក្ស ដើម្បីកសាងសង្គមនិយម និងការពារប្រទេស"[91]។

*ជាទូទៅ/ជាលក្ខណៈប្រព័ន្ធ*

51. អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ បានសម្រេចថា ការវាយប្រហារជាទូទៅ "សំដៅទៅដល់ការវាយប្រហារជាទ្រង់ទ្រាយធំ និងជនរងគ្រោះមានចំនួនច្រើន ចំណែកពាក្យ "ជាលក្ខណៈប្រព័ន្ធ" សំដៅទៅដល់អំពើហិង្សាដែលត្រូវបានរៀបចំឡើយ និងការមិនមានការកើតឡើងដោយចៃដន្យ"[92]។ ដោយដកស្រង់សាលក្រមក្នុងសំណុំរឿង ០០១ អង្គជំនុំជម្រះបានបញ្ជាក់អះអាងថា "ការវាយប្រហារជាទូទៅអាចសំដៅទៅដល់ "អានុភាពគ្រួតនៃស៊េរីនៃអំពើអមនុស្សធម៌ ឬអានុភាពទោលនៃអំពើអមនុស្សធម៌ក្នុងទំហំធំធេង"[93]។ ការវាយប្រហារជាប្រព័ន្ធ "ត្រូវបានបង្ហាញជាទូទៅជាលំនាំនៃឧក្រិដ្ឋកម្មដែលពាក់ព័ន្ធការត្រួតជាន់ដែលមិនមែនដោយចៃដន្យនូវទង្វើឧក្រិដ្ឋដែលស្រដៀងជាទៀងទាត់"[94]។ អង្គជំនុំជម្រះបានសន្និដ្ឋានក្នុងសំណុំរឿង ០០២/០១ ថា ខ្លួន "ជឿជាក់ថាការវាយប្រហារនេះមានលក្ខណៈជាទូទៅ ដោយពិចារណាទៅលើវិសាលភាពភូមិសាស្ត្រ និងចំនួនជនរងគ្រោះ។ អង្គជំនុំជម្រះក៏យល់ឃើញថាការវាយប្រហារនេះមានលក្ខណៈ ជាប្រព័ន្ធ ដោយសារវិសាលភាព និងទំហំឧក្រិដ្ឋកម្មទាំងនោះ ពុំអាចជាការវាយប្រហារដោយចៃដន្យ និងត្រូវបានអនុវត្តផ្ទួនៗនិង *ដោយចេតនាដើម្បីជំរុញ និងអនុលោមតាមគោលនយោបាយបក្ស*"[95]។

52. ទាក់ទងការវាយប្រហារជាទូទៅ អង្គជំនុំជម្រះសាលាដំបូងបានគាំទ្រការសម្រេចរបស់ខ្លួន ដោយបានកត់សម្គាល់ថា "នៅត្រឹមឆ្នាំ ២០០៨ មជ្ឈមណ្ឌលឯកសារកម្ពុជា ("DC-Cam") បានកំណត់

[90] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ១៩៣។

[91] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ១៩៣។

[92] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ១៧៩។

[93] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ១៧៩។

[94] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ១៧៩។

[95] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ១៩៣ (សេចក្ដីបញ្ជាក់បន្ថែម)។

អត្តសញ្ញាណសាកសពមនុស្សចំនួន ១.៣ លាននាក់ នៅតាមទីតាំងនៃរណ្ដៅសាកសពរួមចំនួន ៣៩០ នៅទូទាំងកម្ពុជា។ អ្នកជំនាញសន្និដ្ឋានថាមានលទ្ធភាពខ្ពស់ដែលថាទីតាំងរណ្ដៅសាកសពរួមទាំងនោះ មានត្រឹមតែសំណាកមនុស្សស្លាប់ដែលជាលទ្ធផលនៃគោល នយោបាយ និងសកម្មភាពរបស់ខ្មែរក្រហមក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ។ មានលទ្ធភាពដែលថាទីតាំងរណ្ដៅ ជាច្រើនមិនដែលត្រូវបានកំណត់អត្តសញ្ញាណ និងថាមនុស្សជាច្រើនដែលបានស្លាប់ មិនដែលត្រូវបានកប់ឡើយ។ ជាទូទៅ ការព្យាករណ៍នានាបង្ហាញថាមនុស្សចំនួនចន្លោះពី ៦០០.០០០ ទៅ ៣លាននាក់បានស្លាប់ ដោយសារគោលនយោបាយ និងសកម្មភាពរបស់ខ្មែរក្រហម។ ក្នុងចំនួននេះ អ្នកជំនាញនានា ទទួលស្គាល់ការព្យាករណ៍នានាដែលស្ថិតនៅពីចន្លោះ ១.៥ លាន ទៅ ២ លាននាក់ ថាជាការព្យាករណ៍ដ៏សុក្រិតបំផុត”[96]។

*ប្រជាជនស៊ីវិល*

53. អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ បានសម្រេចថាគ្មាននិយមន័យច្បាស់លាស់នៃជនស៊ីវិលក្រោមច្បាប់ទម្លាប់អន្តរជាតិក្នុងខែ មេសា ឆ្នាំ ១៩៧៥ ឡើយ។ ហេតុដូច្នេះ អង្គជំនុំជម្រះបានផ្អែកការសម្រេចរបស់ខ្លួនលើអត្ថន័យទូទៅនៃពាក្យ “ជនស៊ីវិល” នៅពេលនោះ។ អង្គជំនុំជម្រះបានសម្រេចថា “នៅពេលពាក់ព័ន្ធបទចោទនៅទីនេះ ប្រជាជនស៊ីវិលរួមបញ្ចូល ជនទាំងអស់ដែលមិនមែនជាសមាជិកនៃកងកម្លាំងប្រដាប់អាវុធ ឬអ្នកដែលមិនត្រូវបានទទួលស្គាល់ជាយុទ្ធជន”[97]។ អង្គជំនុំជម្រះតុលាការកំពូលបានគាំទ្រការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា “ប្រជាជនដែលត្រូវបានដាក់ជាគោលដៅចាំបាច់ជាជនស៊ីវិល *ជាចម្បង* ប៉ុណ្ណោះ ដើម្បីបំពេញធាតុផ្សំ*រួម*នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ”[98]។

54. ទាក់ទងឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តទៅលើទាហានខ្មែរក្រហមដោយខ្មែរក្រហមខ្លួនឯង សហមេធាវីនាំមុខកត់សម្គាល់ឃើញថា ក.ស.ច.ស នាពេលថ្មីៗបានសម្រេចថា អត្ថន័យនៃ “ប្រជាជនស៊ីវិល” រួមបញ្ចូលកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋ ឬអង្គការរបស់ខ្លួន និងចងកាតព្វកិច្ចចំពោះ

[96] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ១៩៤។

[97] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ១៨៥។

[98] សាលដីកាលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៧៤០។

ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩[99] "លើកលែងតែកងកម្លាំងប្រដាប់អាវុធដែលត្រូវបានវាយប្រហារ ពិតជាបានមានសម្ព័ន្ធភាពជាមួយ ឬផ្តល់ការគាំទ្រពាក់ព័ន្ធផ្នែកយោធាទៅគូបដិបក្ខក្នុងជម្លោះ"[100]។ ហេតុដូច្នេះ ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តទៅលើទាហានរបស់ខ្មែរក្រហមខ្លួនឯង ស្ថិតក្នុងប្រភេទនេះ។

55. សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសន្និដ្ឋានថា ការបកស្រាយទូលាយអំពីពាក្យជនស៊ីវិលត្រូវមានគោលដៅ និងគោលបំណងនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងស៊ីសង្វាក់ជាមួយនឹងការបកស្រាយអំពីច្បាប់ក្នុងយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ និងគោលការណ៍នីត្យានុកូលភាព[101]។ ក.ស.ច.ស បានគូសបញ្ជាក់ទៀតថា គ្មានយុត្តិកម្មដើម្បីដកចេញកងកម្លាំងប្រដាប់អាវុធរបស់រដ្ឋពីការការពារផ្នែកច្បាប់ក្រោមច្បាប់ស្តីពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ តាមរយៈការកំណត់ប្រភេទដោយផ្អែកលើស្ថានភាព/ឋានៈនៃសត្រូវ ដោយមិនវាយតម្លៃលើសកម្មភាពជាក់ស្តែងរបស់ជនទាំងនោះ[102]។ ក.ស.ច.ស បានសន្និដ្ឋានថា "គ្មានយុត្តិកម្មជាក់ស្តែង ដែលនឹងផ្តល់អាណត្តិ ឬអនុញ្ញាតឱ្យមានការប្រព្រឹត្តិផ្សេងគ្នាទៅលើទាហាននៃរបបមួយ ដោយសារតែឋានៈការងារជាផ្លូវការរបស់ពួកគាត់ឡើយ"[103]។

### *មូលដ្ឋាន/មូលដ្ឋានគ្រឹះនៃការវាយប្រហារ*

56. មាត្រា ៥ នៃច្បាប់ អ.វ.ត.ក តម្រូវថា ការវាយប្រហារត្រូវតែអនុវត្តដោយហេតុផលជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា "ពាក្យពេចន៍

---

[99] ការជូនដំណឹងស្តីពីការបកស្រាយ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធរបស់របប ឬរដ្ឋនោះ ចុះថ្ងៃទី ៧ ខែ កុម្ភៈ ឆ្នាំ ២០១៧ ឯកសារ **D191/18** កថាខណ្ឌ ៥៦។

[100] ការជូនដំណឹងស្តីពីការបកស្រាយ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធរបស់របប ឬរដ្ឋនោះ ឯកសារ **D191/18** កថាខណ្ឌ ៥៧។

[101] ការជូនដំណឹងស្តីពីការបកស្រាយ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធរបស់របប ឬរដ្ឋនោះ ឯកសារ **D191/18** កថាខណ្ឌ ៤៣ ៥៥ ៦៥ និង ៦៧។

[102] ការជូនដំណឹងស្តីពីការបកស្រាយ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធរបស់របប ឬរដ្ឋនោះ ឯកសារ **D191/18** កថាខណ្ឌ ៦៣ និង ៦៥។

[103] ការជូនដំណឹងស្តីពីការបកស្រាយ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធរបស់របប ឬរដ្ឋនោះ ឯកសារ **D191/18** កថាខណ្ឌ ៦៥។

នៃធាតុផ្សំរួម តម្រូវថា ការវាយប្រហារត្រូវតែផ្អែកលើហេតុផលជាតិ នយោបាយ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ប៉ុន្តែ មិនមែនផ្អែកលើមូលហេតុរើសអើងជាចាំបាច់ឡើយ"[104]។

57. អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ បានសម្រេចថា លក្ខខណ្ឌតម្រូវនេះត្រូវបានបំពេញដោយហេតុថា "ការវាយប្រហារលើប្រជាជនស៊ីវិលត្រូវបានអនុវត្តដោយហេតុផលនយោបាយ អនុលោមតាមផែនការ និងគោលនយោបាយរបស់បក្ស ដើម្បីកសាងសង្គមនិយម និងដើម្បីការពារប្រទេស"[105]។

***ចំណងទាក់ទងរវាងអំពើរបស់ចារីផ្ទាល់ និងការវាយប្រហារ***

58. អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ បានសម្រេចថា អំពើរបស់ចារីផ្ទាល់ "ត្រូវតែតាមលក្ខណៈ ឬផលវិបាករបស់វា [...] ជាផ្នែកមួយនៃការវាយប្រហារ"[106]។ អង្គជំនុំជម្រះតុលាការកំពូលបានគាំទ្រការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង[107] និងបានបញ្ជាក់ថា "អំពើរបស់ជនជាប់ចោទ សូម្បីតែនៅពេលពួកគាត់ពុំមែនជាចារីផ្ទាល់ ត្រូវតែជាផ្នែកមួយនៃការវាយប្រហារ"[108]។ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា អង្គជំនុំជម្រះសាលាដំបូងពុំបានប្រព្រឹត្តកំហុសនៅពេលខ្លួន "បានបន្តស្វែងរកចំណងទាក់ទងរវាង អំពើរបស់ជនជាប់ចោទ និងការវាយប្រហារ និងបានយោងទៅរក [ក្នុងការសម្រេចរបស់ខ្លួនជា] "អំពើរបស់ចារីផ្ទាល់និងជនជាប់ចោទ"[109]។

***ធាតុផ្សំអត្តនោម័ត/ការដឹងឮ***

59. ចុងក្រោយ ជនជាប់ចោទ និងចារីផ្ទាល់ ត្រូវតែដឹងថា អំពើរបស់ពួកគាត់គឺជាផ្នែកមួយនៃការវាយប្រហារ[110]។

---

[104] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៧៤៥។

[105] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ១៩៥។

[106] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ១៩០។

[107] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៧៥៣។

[108] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៧៥៤។

[109] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៧៥៤។

[110] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ១៩៧។

60. អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានក្នុងសំណុំរឿង ០០២/០១ ថា "ដោយពិចារណាអំពីទ្រង់ទ្រាយ និងវិសាលភាពនៃការវាយប្រហារ និងការពិតដែលថាវាត្រូវបានអនុវត្តដើម្បីជំរុញ និងអនុលោមតាមគោលនយោបាយ និងផែនការបក្ស អង្គជំនុំជម្រះជឿជាក់ថាទាំងចារីផ្ទាល់និងជនជាប់ចោទបានដឹងអំពីការវាយប្រហារលើប្រជាជនស៊ីវិល និងថាអំពើរបស់ពួកគាត់ជាផ្នែកមួយនៃការវាយប្រហារនេះ"[111]។

61. អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានក្នុងសំណុំរឿង ០០២/០១ ថា "ចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និងបន្តយ៉ាងហោចណាស់រហូតដល់ខែ ធ្នូ ឆ្នាំ ១៩៧៧ ដែលរយៈកាលពេលវេលាដែលជាបញ្ហាក្នុងសំណុំរឿង ០០២/០១ មានការវាយប្រហារជាទូទៅនិងជាលក្ខណៈប្រព័ន្ធទៅលើប្រជាជនស៊ីវិលនៃកម្ពុជា"[112]។

## ២. ធាតុផ្សំនៃឧក្រិដ្ឋកម្ម

### ២.១. ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល

62. អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់អះអាងអំពីធាតុផ្សំនៃការធ្វើមនុស្សឃាត និងបានបញ្ជាក់បំភ្លឺអំពីធាតុផ្សំនៃការសម្លាប់រង្គាល។ ធាតុផ្សំសត្យានុម័តនៃការធ្វើមនុស្សឃាត គឺជាអំពើសកម្ម ឬអំពើអកម្មដែលបានបង្កឱ្យមនុស្សស្លាប់។ *ធាតុផ្សំអត្តនោម័ត* ដែលជាលក្ខខណ្ឌតម្រូវគឺ "ចេតនា

[111] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ១៩៧។

[112] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ១៩៣។ សម្រាប់ជាមូលដ្ឋាននៃសំអាងហេតុនេះ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងពីការប្រព្រឹត្តរបស់ខ្មែរក្រហមក្នុងអំឡុងពេល ដែលត្រូវជំនុំជម្រះក្នុងសំណុំរឿង ០០២/០១។ *សូមមើលផងដែរ* សាលក្រមសំណុំរឿង ០០២/០១ កថាខណ្ឌ ១៦៩៖ "នៅចន្លោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ និង ខែ ធ្នូ ឆ្នាំ ១៩៧៧ ដែលជាអំឡុងពេលដែលត្រូវជំនុំជម្រះនៅក្នុងសំណុំរឿង ០០២/០១ ខ្មែរក្រហមបានបង្ខំឱ្យប្រជាជនផ្លាស់ទីលំនៅពីទីក្រុង និងទីប្រជុំជនទូទាំងប្រទេសកម្ពុជាទៅកាន់តំបន់ជនបទ និងចន្លោះតំបន់ជនបទទាំងនេះដើម្បីកំទេចខ្មាំង ទាំងខាងក្នុង និងខាងក្រៅ និងដើម្បីរារាំងការគំរាមបះបោរ លុបបំបាត់ និងលត់ដំវណ្ណៈនាយទុន និងវណ្ណៈសក្តិភូមិ និងបង្កើត និងពង្រីកសហករណ៍។ បក្សកុម្មុយនីស្តកម្ពុជាបានកំណត់អត្តសញ្ញាណ "ប្រជាជនថ្មី" ដែលរួមបញ្ចូលអតីតមន្ត្រីរដ្ឋការ បញ្ញវ័ន្ត ម្ចាស់ដី ពួកនាយទុន ពួកសក្តិភូមិ និងគហបតីតូចតាចថាជាខ្មាំងសំខាន់ៗរបស់បដិវត្តន៍ និងសមូហភាវូបនីយកម្ម។ ដើម្បីកំទេចខ្មាំងទាំងនេះ ខ្មែរក្រហមបានអប់រំកែប្រែ ជម្លៀស និងលុបបំបាត់ "ប្រជាជនថ្មី" និងក្រុមផ្សេងទៀតដែលមិនសក្តិសមនឹងការបង្កើតរបបសង្គមនិយម រួមទាំង អតីតមន្ត្រីរដ្ឋការរបបខ្មែរសាធារណរដ្ឋ និងពុទ្ធសាសនិកជន ជនជាតិចាម និងជនជាតិវៀតណាម")។

ផ្ទាល់ព្រមទាំងការសម្លាប់ជា *ចេតនាប្រយោល /* ការសម្លាប់ដោយការធ្វេសប្រហែស”[113]។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ទៀតថា “ការផ្តន្ទាទោសពីបទមនុស្សឃាត ពុំត្រូវបានរារាំងដោយសារការពុំមានលទ្ធភាពបង្ហាញឱ្យបានត្រឹមត្រូវអំពីចំនួនមនុស្សស្លាប់សរុប ឬកំណត់អត្តសញ្ញាណទៅតាមករណីនីមួយៗ នៃចារីផ្ទាល់ និងជនរងគ្រោះរបស់ពួកគាត់ឡើយ។ អង្គជំនុំជម្រះតុលាការកំពូលក៏បានឯកភាពជាមួយអង្គជំនុំជម្រះតុលាការឧទ្ធរណ៍ ICTY ក្នុងសំណុំរឿង Kvocka ដែលថា ភស្តុតាងលើសពីវិមតិសង្ស័យដែលថាមនុស្សម្នាក់ត្រូវបានធ្វើឃាត ពុំតម្រូវជាចាំបាច់នូវភស្តុតាងដែលថាសាកសពអ្នកស្លាប់នោះត្រូវបានរកឃើញឡើយ។ ប៉ុន្តែ ការពិតអំពីការស្លាប់របស់ជននោះ អាចត្រូវបានសន្និដ្ឋាន ទៅតាមកាលៈទេសៈពីភស្តុតាងទាំងអស់ដែលបង្ហាញអង្គជំនុំជម្រះសាលាដំបូង។ ប៉ុន្តែដើម្បីគាំទ្រ ការសម្រេចជាទូទៅមួយដែលថាការសម្លាប់បានកើតឡើងហួសពីវិមតិសង្ស័យ កាលៈទេសៈជាក់លាក់នៃការសម្លាប់ត្រូវតែបង្ហាញហួសពីវិមតិសង្ស័យ ដោយមិនគិតថាតើការផ្តន្ទាទោសជាក់លាក់សម្រាប់ការសម្លាប់សម្រាប់កាលៈទេសៈនីមួយៗ ត្រូវបានបញ្ចូលដែរឬទេឡើយ។ ជាការពិត ការសន្និដ្ឋានជាទូទៅដែលថាការធ្វើមនុស្សឃាតបានកើតឡើង ពុំអាចត្រូវបាននិយាយថាត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យឡើយ ប្រសិនបើគ្មានកាលៈទេសៈជាក់លាក់ណាមួយដែលគាំទ្រថាការសន្និដ្ឋាននោះត្រូវបានធ្វើក្នុងបទដ្ឋាននេះ”[114]។

63. ពាក់ព័ន្ធការសម្លាប់ដោយសារលក្ខខណ្ឌនានា ទាក់ទងនឹងការជម្លៀសប្រជាជនពីភ្នំពេញ អង្គជំនុំជម្រះតុលាការកំពូល “បានគូសបញ្ជាក់ថា ដើម្បីបង្ហាញអំពីអំពើមនុស្សឃាតជាផ្នែកមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មានភាពចាំបាច់ដែលថាកាលៈទេសៈនៃការស្លាប់ដែលបានបង្កឡើង ដោយលក្ខខណ្ឌនានានៃការជម្លៀស ត្រូវបានបង្ហាញឱ្យហួសពីវិមតិសង្ស័យ”[115]។

64. អង្គជំនុំជម្រះតុលាការកំពូល ក្នុងការបញ្ជាក់អំពីធាតុផ្សំសត្យានុម័តនៃអំពើមនុស្សឃាតបានគូសបញ្ជាក់ថា “បើទោះបីជាមានការទទួលស្គាល់ភាពខុសគ្នារវាងសញ្ញាណនៃ *Recklessness* និង *ចេតនាប្រយោល* បើនិយាយដោយត្រួសៗគឺ ចំណុចទីមួយជាការផ្តោតទៅលើទិដ្ឋភាពនៃការយល់ដឹង ហើយទីពីរលើទិដ្ឋភាពនៃឆន្ទៈនៅក្នុងអាកប្បកិរិយារបស់ចារីចំពោះលទ្ធផលក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ឃើញថា ពុំឃើញមានភាពខុសគ្នាច្បាស់លាស់នោះឡើយ ដោយ

[113] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ F36 កថាខណ្ឌ ៤០៩។

[114] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ F36 កថាខណ្ឌ ៤២០។

[115] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ F36 កថាខណ្ឌ ៤៥៣។

សារនៅក្នុងគោលការណ៍នៃ *ចេតនាប្រយោល* មានគំនិតបញ្ជាក់ពីធាតុផ្សំសត្យានុម័ត នៃភាពដែលនឹងកើតមាន និង "ការបង្ហាញពីភាពមិនអើពើ" ដែលនេះគ្រប់គ្រាន់សម្រាប់ដាក់ឱ្យទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ រីឯយុត្តិសាស្ត្រដែលផ្អែកលើគោលការណ៍ ក៏មានការពាក់ព័ន្ធទៅនឹងការសន្និដ្ឋានអំពីចេតនាផងដែរ។ ដូច្នេះអង្គជំនុំជម្រះតុលាការកំពូលនឹងប្រើប្រាស់ពាក្យ *ចេតនាប្រយោល* នេះដូចអង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញក្នុងរឿងក្តី *Stakic* ដែរ។ បន្ថែមលើនេះទៀត អង្គជំនុំជម្រះទទួលស្គាល់ថាផ្អែកតាមករណីជាក់ស្តែង ការបង្ហាញពី *Recklessness* នៅក្នុងការធ្វើមនុស្សឃាត ទំនងជាបំពេញតាមលក្ខខណ្ឌវិនិច្ឆ័យនៃ *Recklessness* ហើយការបង្ហាញចេតនាប្រយោលទំនងជាបំពេញតាមលក្ខណវិនិច្ឆ័យនៃ *Recklessness* ដែលសញ្ញាណទាំងពីរនេះបំពេញគ្នាទៅវិញទៅមក"[116]។

65. ទាក់ទងនឹងការសម្លាប់រង្គាល អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា ធាតុផ្សំសត្យានុម័តត្រូវបានកំណត់ថាជាអំពើសកម្ម ឬអំពើអកម្ម ឬការរួមបញ្ចូលគ្នានៃអំពើនីមួយៗ ដែលបណ្តាលឱ្យមានមនុស្សស្លាប់ជាទ្រង់ទ្រាយធំ និងបានបញ្ជាក់ទាក់ទងនឹងធាតុផ្សំអត្តនោម័ត ដែលត្រូវបានតម្រូវ ដែលថា *ចេតនាជាក់លាក់* គឺនៅពុំទាន់គ្រប់គ្រាន់។ ប៉ុន្តែ "ចេតនាផ្ទាល់ក្នុងការសម្លាប់ត្រូវតែបង្ហាញ"[117]។

## ២.២. ការធ្វើឱ្យទៅជាទាសករ

[116] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៣៩១ (ក្នុងរឿងក្តី Stakic និងការដកស្រង់ដោយអង្គជំនុំជម្រះតុលាការកំពូលក្នុងកថាខណ្ឌ ៣៩០ "ការកំណត់និយមន័យដែលជាលក្ខណៈបច្ចេកទេសលើ ចេតនាប្រយោល (dolus eventualis) មានដូចតទៅ ៖ ប្រសិនបើចារីបង្ហាញពីអាកប្បកិរិយាដែលបង្កឱ្យបាត់បង់ជីវិត ចារីមានចេតនាសម្លាប់ដោយសារចារី "សម្របសម្រួលខ្លួនទទួលយក" ឬ "ស្រុះស្រួលទទួលយក" បើទោះបីទំនងជានឹងមានការស្លាប់ក៏ដោយ។ ដូច្នេះប្រសិនបើការសម្លាប់ត្រូវបានប្រព្រឹត្តឡើងដោយ "មិនអើពើអំពីតម្លៃជីវិតរបស់មនុស្ស" បើទោះបីអំពើនោះមានហានិភ័យតិចតួចយ៉ាងណាក៏ដោយ ក៏អាចកំណត់បានជាការសម្លាប់មនុស្សដោយចេតនា។ ការសម្លាប់ក្នុងទ្រង់ទ្រាយធំ ដែលត្រូវបានចាត់ចំណាត់ថ្នាក់ជាការធ្វើមនុស្សឃាតដោយប្រយោលនៅក្នុងសហរដ្ឋអាមេរិក អាចបំពេញតាមលក្ខណៈវិនិច្ឆ័យនៃប្រព័ន្ធច្បាប់ស៊ីវិលស្តីពីចេតនាប្រយោល (dolus eventualis)។ អង្គជំនុំជម្រះសាលាដំបូង បញ្ជាក់ថា គោលគំនិតនៃចេតនាប្រយោល (dolus eventualis) ពុំបានរួមបញ្ចូលនូវបទដ្ឋាននៃការធ្វេសប្រហែស ឬធ្វេសប្រហែសទាំងស្រុងឡើយ"។

[117] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៥២២។

66. អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០០១ បានកំណត់ *ធាតុផ្សំសត្យានុម័ត* នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃការធ្វើឱ្យទៅជាទាសករថាជា "ការប្រើអំណាចណាមួយឬទាំងអស់ក្នុងនាមជាម្ចាស់លើមនុស្ស" និងធាតុផ្សំអត្តនោម័ត ថាជា "ការប្រើប្រាស់ដោយចេតនានូវអំណាចណាមួយ ឬទាំងអស់ក្នុងនាមជាម្ចាស់លើមនុស្ស"[118]។

67. អង្គជំនុំជម្រះតុលាការកំពូលក៏បានបញ្ជាក់ទៀតថា *សញ្ញាណ* នៃការធ្វើឱ្យទៅជាទាសករ ដូចដែលត្រូវបានកំណត់ដោយអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY ក្នុងសំណុំរឿង *Kunarac* និងបានផ្អែកការពិនិត្យរបស់ខ្លួនអំពីយុត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទី២ កត្តាទាំងឡាយដែលត្រូវបានកំណត់អត្តសញ្ញាណ មានភាពស៊ីសង្វាក់ជាមួយច្បាប់ទម្លាប់អន្តរជាតិក្នុងអំឡុងយុត្តាធិការពេលវេលានៃ អ.វ.ត.ក[119]។

68. សញ្ញាណនៃការធ្វើឱ្យទៅជាទាសករក្នុងអំឡុងរយៈកាលពេលវេលាពាក់ព័ន្ធ គឺ "ការគ្រប់គ្រងលើការដើរហើររបស់មនុស្សណាម្នាក់ ការគ្រប់គ្រងជារូបវន្តលើកន្លែងរស់នៅ ការគ្រប់គ្រងលើផ្លូវចិត្ត ការចាត់វិធានការដើម្បីទប់ស្កាត់ ឬរារាំងមិនឱ្យគេចខ្លួន ការប្រើកម្លាំង ការគំរាមកំហែងអំពីការប្រើកម្លាំង ឬការបង្ខិតបង្ខំ រយៈពេលនៃការធ្វើឱ្យទៅជាទាសករ ការអះអាងជាម្ចាស់កម្មសិទ្ធិផ្តាច់មុខ ការដាក់ឱ្យស្ថិតនៅក្រោមការប្រព្រឹត្តិយ៉ាងព្រៃផ្សៃ និងការរំលោភបំពាន ការគ្រប់គ្រងលើផ្លូវភេទ និងការធ្វើពលកម្មដោយបង្ខំ"[120]។

---

[118] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១ ឯកសារ **F28** កថាខណ្ឌ ១៥២ និង ១៥៣។ *សូមមើលផងដែរ* មាត្រា ១ (១) នៃអនុសញ្ញាស្តីពីទាសភាព ថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ១៩២៦។

[119] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១ ឯកសារ **F28** កថាខណ្ឌ ១៥៤។

[120] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១ ឯកសារ **F28** កថាខណ្ឌ ១១៩ (ការដកស្រង់សាលក្រមសំណុំរឿង ០០១ និង សាលដីការឿងក្តី Kunarac)។ ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូល បានបញ្ជាក់ថា "អាស្រ័យហេតុនេះ អង្គជំនុំជម្រះដែលពិនិត្យមើលពីសញ្ញាណនៃអំពើធ្វើឱ្យទៅជាទាសករ ជាសំខាន់នោះ ត្រូវតែកំណត់អំពីសញ្ញាណនៃ "កម្មសិទ្ធិ" គឺថា អង្គហេតុទាំងឡាយដែលចង្អុលបញ្ជាក់ថា ជនរងគ្រោះ ត្រូវបានគេបន្ទាបឋានៈមកជាទំនិញ មានន័យថាបុគ្គលនោះគឺជាកម្មវត្ថុនៃ "ការចាត់ចែង" ដែលជនរងគ្រោះជាបុរស ឬស្ត្រី ត្រូវគេប្រើប្រាស់ (ឧ. ក្នុងគោលបំណងផ្លូវភេទ) ត្រូវបានគេជិះជាន់ជាប្រយោជន៍សេដ្ឋកិច្ច ត្រូវបានគេប្រើប្រាស់ក្នុងគោលបំណងសម្រាប់ដោះដូរសវីរាង្គ ហើយទីបញ្ចប់ត្រូវបានគេបោះចោល។ ច្បាស់ណាស់ថា ការប្រើប្រាស់អំណាចទាំងឡាយក្នុងនាមជាម្ចាស់លើមនុស្ស តម្រូវឱ្យមានការត្រួតត្រាយ៉ាងតឹងរ៉ឹងលើជនរងគ្រោះ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ អំពើធ្វើឱ្យទៅទាសករមិនមានអត្ថិភាពឡើយនៅក្នុងករណីដែលការត្រួតត្រាមានគោលដៅមួយ

69. អង្គជំនុំជម្រះតុលាការកំពូលបានគាំទ្រវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូង ចំពោះការងារពលកម្មដោយបង្ខំ ដោយបានពន្យល់ថា "ប្រសិនបើពិនិត្យមើលសញ្ញាណពាក់ព័ន្ធដទៃទៀតពលកម្មដោយបង្ខំអាចឈានទៅដល់កម្រិតជាអំពើធ្វើឱ្យទៅជាទាសករបាន ដោយពុំចាំបាច់មានភស្តុតាងបន្ថែមអំពីការធ្វើបាបនោះទេ"[121]។ ប៉ុន្តែ ការសម្រេចអំពីការធ្វើឱ្យទៅជាទាសករ "ចាំបាច់ត្រូវកំណត់អំពីសញ្ញាណជាម្ចាស់ និងអង្គហេតុនៃបទចោទពីការធ្វើឱ្យទៅជាទាសករត្រូវវាយតម្លៃតាមអត្ថន័យ នៃភាពជាម្ចាស់" និងថា "ការអនុវត្តសិទ្ធិអំណាចដែលភ្ជាប់មកជាមួយលើបុគ្គលណាម្នាក់តម្រូវឱ្យ មានការត្រួតត្រាក្នុងកម្រិតជាដុំកំភួនទៅលើជនរងគ្រោះ""[122]។ ពុំអាចមានការសម្រេចអំពីការធ្វើឱ្យទៅជាទាសករបានឡើយ "នៅពេលដែលការត្រួតត្រាមានគោលដៅក្រៅពីជំរុញឱ្យមានការអនុវត្តសិទ្ធិអំណាចដែលភ្ជាប់ទៅនឹងភាពជាម្ចាស់"[123]។

## ២.៣. ការនិរទេស

70. ការនិរទេស ដែលមានចែងក្នុងអនុសញ្ញាហ្សឺណែវឆ្នាំ ១៩៤៩ និងបានថ្កោលទោសក្នុងសាលក្រម Nuremberg ថាជា "ឧក្រិដ្ឋកម្មសង្គ្រាម" និងជា "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ"[124] ត្រូវបានកំណត់ជាបទល្មើសក្រោមច្បាប់អន្តរជាតិក្នុងអំឡុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក[125]។ យុត្តិសាស្ត្រអន្តរជាតិបង្ហាញថា ធាតុផ្សំសត្យានុម័តនៃការនិរទេស "ផ្សំឡើងដោយការនិរទេសដោយបង្ខំនូវបុគ្គលនានា កាត់ព្រំដែនរដ្ឋមួយពីតំបន់ដែលពួកគាត់មានវត្តមានដោយស្របច្បាប់ដោយមិនមានហេតុផលដែលអនុញ្ញាតក្រោមច្បាប់អន្តរជាតិ"[126]។ សម្រាប់ធាតុផ្សំអត្តនោម័ត វា

---

ច្បាស់លាស់ផ្សេង ក្រៅពីការផ្តល់លទ្ធភាពឱ្យមានការប្រើប្រាស់អំណាចទាំងឡាយក្នុងនាមជាម្ចាស់"។ សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១ ឯកសារ **F28** កថាខណ្ឌ ១៥៦។

[121] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១ ឯកសារ **F28** កថាខណ្ឌ ១២៦ ១៥៤ ១៥៨។

[122] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១ ឯកសារ **F28** កថាខណ្ឌ ១៥៦។

[123] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១ ឯកសារ **F28** កថាខណ្ឌ ១៥៦។

[124] មាត្រា ៦ (ខ) និង ៦ (គ) នៃធម្មនុញ្ញសាលាក្តីយោធាអន្តរជាតិ ឆ្នាំ ១៩៤៥។

[125] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៥៧៤ ដែលសង្ខេបពីគោលជំហររបស់ នួន ជា ចំពោះការផ្លាស់ទីលំនៅដោយបង្ខំ *ធៀបនឹង* ការនិរទេស។ *សូមមើលផងដែរ* មាត្រា ៤៩ នៃអនុសញ្ញាទីក្រុងហ្សឺណែវ (IV) ពាក់ព័ន្ធនឹងការការពារប្រជាជនស៊ីវិលក្នុងពេលមានសង្គ្រាម។ ទីក្រុងហ្សឺណែវ ថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩។

[126] *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Brdjanin* សំណុំរឿងលេខ IT-99-36-T សាលក្រម ចុះថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០០៤ កថាខណ្ឌ ៥៤៤។ សូមមើលផងដែរ *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Krstic* សំណុំរឿងលេខ IT-98-33-T តុលាការ ICTY (អង្គជំនុំជម្រះ

គ្រប់គ្រាន់ដើម្បីបង្ហាញអំពីចេតនារបស់ជនជាប់ចោទក្នុងការនិរទេសមនុស្សដោយបង្ខំ ដោយមិនមែនធ្វើឡើងជាបណ្ដោះអាសន្នឡើយ។ គ្មានលក្ខខណ្ឌតម្រូវដើម្បីបង្ហាញអំពីចេតនាដែលថាការនិរទេសមនុស្សទាំងនោះមានភាពអចិន្ត្រៃយ៍ឡើយ[127]។ ចំណុចនេះមិនស្របជាមួយអនុសញ្ញាទីក្រុងហ្សឺណែវដែលចែងថា មិនមានធាតុផ្សំនៃឧក្រិដ្ឋកម្មនៃការនិរទេសដែលតម្រូវថា អ្នកដែលត្រូវបាននិរទេសមិនត្រូវវិលត្រឡប់មកវិញ ដូចដែលបានគាំទ្រដោយអង្គជំនុំជម្រះតុលាការឧទ្ធរណ៍ក្នុងរឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Milomir Stakic* [128]។ ហេតុដូច្នេះ វាគ្រប់គ្រាន់ក្នុងការបង្ហាញថាជនជាប់ចោទបានមានចេតនានិរទេសជាអចិន្ត្រៃយ៍ ឬជម្លៀសជនរងគ្រោះឆ្លងកាត់ព្រំដែនពាក់ព័ន្ធ[129]។

---

សាលាដំបូង) សាលក្រមចុះថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០០១ កថាខណ្ឌ ៥២១ ៖ "ការនិរទេសចាត់ទុកជាការផ្លាស់ទីលំនៅហួសពីព្រំដែនរបស់រដ្ឋ"។ ត្រូវបានបញ្ជាក់ក្នុង *រឿងក្ដីរដ្ឋអាជ្ញាតទល់នឹង Krnojelac* សំណុំរឿងលេខ IT-97-25-T តុលាការ ICTY (អង្គជំនុំជម្រះសាលាដំបូង) សាលក្រម ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០០២ កថាខណ្ឌ ៤៧៤។ ការផ្លាស់ទីលំនៅ ឬការនិរទេសមនុស្សដោយស្របច្បាប់ រួមមាន *ក្នុងចំណោមចំណុចផ្សេងទៀត* ដូចជា ភាពចាំបាច់ក្នុងការការពារសន្តិសុខជាតិ សណ្ដាប់ធ្នាប់សាធារណៈ ឬសុខភាពសាធារណៈ។ *សូមមើល* មាត្រា ១២ (៣) នៃកតិកាសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ពិធីសារលេខ ៤ មាត្រា ២ (៣) នៃអនុសញ្ញាអឺរ៉ុបស្ដីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន មាត្រា ២២ (៣) និង (៤) នៃអនុសញ្ញាអាមេរិកស្ដីពីសិទ្ធិមនុស្ស និងមាត្រា ១២ (២) នៃធម្មនុញ្ញអាហ្វ្រិក (ទីក្រុងបង់ហ្ស៊ុល) ស្ដីពីច្បាប់សិទ្ធិមនុស្ស។

[127] រឿងក្ដីរដ្ឋអាជ្ញាតទល់នឹង Krajisnik សំណុំរឿងលេខ IT-00-39-T សាលក្រម និងការជំនុំជម្រះទោស (ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៦) កថាខណ្ឌ ៧២៦។ រឿងក្ដីរដ្ឋអាជ្ញាតទល់នឹង Popovic និងអ្នកផ្សេងទៀត សំណុំរឿងលេខ IT-05-88-T សាលក្រម និងការជំនុំជម្រះទោស (ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០) កថាខណ្ឌ ៩០៥។ *សូមមើលផងដែរ* មាត្រា ៤៩ នៃអនុសញ្ញាទីក្រុងហ្សឺណែវ (IV) ស្ដីពីជនស៊ីវិល ឆ្នាំ ១៩៤៩ និង *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Milomir Stakic (សាលដីកា)* សំណុំរឿងលេខ IT-97-24-A តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ កថាខណ្ឌ ៣០៧។

[128] មាត្រា ៤៩ នៃអនុញ្ញាទីក្រុងហ្សឺណែវ (IV) ស្ដីពីប្រជាជនស៊ីវិល ឆ្នាំ ១៩៤៩។ *សូមមើលផងដែរ រឿងក្ដីរដ្ឋអាជ្ញាតទល់នឹង Milomir Stakic (សាលដីកាលើបណ្ដឹងសាទុក្ខ)* សំណុំរឿងលេខ IT-97-24-A តុលាការឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី (ICTY) ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ កថាខណ្ឌ ៣០៧។

[129] រឿងក្ដីរដ្ឋអាជ្ញាតទល់នឹង Milutinovic និងអ្នកផ្សេងទៀត សំណុំរឿងលេខ IT-05-87-T សាលក្រម (ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៩) កថាខណ្ឌ ១៦៤។ រឿងក្ដីរដ្ឋអាជ្ញាតទល់នឹង Popovic និងអ្នកផ្សេងទៀត សំណុំរឿងលេខ IT-05-88-T សាលក្រម និងការជំនុំជម្រះទោស (ចុះថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ ២០១០) កថាខណ្ឌ ៩០៤។

71. ឧក្រិដ្ឋកម្មនៃការនិរទេស សន្មតទុកជាមុនអំពីការនិរទេសមនុស្សដោយបង្ខំ តាមរយៈការបណ្តេញ ឬអំពើបង្ខិតបង្ខំដទៃទៀត[130] ដូចជា ការភ័យខ្លាចអំពើហិង្សា ការឃុំឃាំង ការគៀបសង្កត់ផ្លូវចិត្ត និងកាលៈទេសៈបែបនេះដទៃទៀត ដែលជម្រើសពិតប្រាកដគឺពុំអាចធ្វើទៅបាន[131]។ ប្រសិនបើប្រជាជនស៊ីវិលរត់ភៀសខ្លួនដោយសារការភ័យខ្លាចការស្លាប់ ឬអំពើរើសអើងដទៃទៀត ការមិនស្ម័គ្រចិត្តដែលមាននៅក្នុងជម្រើសនៃការរត់ភៀសខ្លួនរារាំងសមត្ថភាពនៃការយល់ព្រមពិតប្រាកដ ដែលនេះគឺជាឧក្រិដ្ឋកម្មនៃការនិរទេស[132]។ អវត្តមាននៃជម្រើសដោយស្ម័គ្រចិត្ត ធ្វើឱ្យការនិរទេសមានភាពមិនស្របច្បាប់។ ការយល់ព្រម ឬសំណើរបស់បុគ្គលណាម្នាក់ សុំឱ្យជម្លៀស ឬនិរទេស ត្រូវតែផ្តល់ដោយស្ម័គ្រចិត្តដែលជាលទ្ធផលនៃឆន្ទៈសេរីរបស់ពួកគាត់ និងត្រូវទទួលបានការវាយតម្លៃដោយពិចារណាអំពីកាលៈទេសៈជុំវិញ[133]។

## ២.៤. ការចាប់ដាក់ពន្ធនាគារ

[130] ធាតុផ្សំនៃបទល្មើសប្រើប្រាស់ការបកស្រាយយ៉ាងទូលំទូលាយនៃ "ការគាបសង្កត់" ដែលរួមបញ្ចូល "ការគំរាមប្រើកម្លាំង ឬការគាបសង្កត់ ដូចជា ការគាបសង្កត់ដែលកើតចេញពីការភ័យខ្លាចអំពើហិង្សា ការបង្ខិតបង្ខំ ការឃុំឃាំង ការគាបសង្កត់ផ្លូវចិត្ត ឬការរំលោភបំពានអំណាច លើបុគ្គលនោះ ឬបុគ្គលទាំងនោះ ឬអ្នកផ្សេងទៀត ឬការទាញប្រយោជន៍ពីបរិយាកាសបង្ខិតបង្ខំ។ *សូមមើល* n.12 នៃធាតុផ្សំបទល្មើស មាត្រា ៧ (១) (ឃ) នៃលក្ខន្តិកៈតុលាការឧក្រិដ្ឋកម្មអន្តរជាតិ។

[131] *"ការផ្លាស់ទីលំនៅដោយបង្ខំមានន័យថា ប្រជាជនត្រូវបានជម្លៀសចេញផ្ទុយពីឆន្ទៈរបស់ខ្លួន ឬគ្មានជម្រើសពិតប្រាកដ... ការភ័យខ្លាចអំពើហិង្សា ការបង្ខិតបង្ខំ ការឃុំឃាំង ការគាបសង្កត់ផ្លូវចិត្ត និងកាលៈទេសៈផ្សេងទៀតដែលអាចបង្កើតបរិយាកាសដែលគ្មានជម្រើសប៉ុន្តែត្រូវចាកចេញ ដែលស្មើនឹងការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ...ការផ្លាស់ទីលំនៅប្រជាជនដែលបានធ្វើឡើងទៅតាមកិច្ចព្រមព្រៀងក្នុងចំណោមមេដឹកនាំនយោបាយ ឬយោធា ឬស្ថិតក្រោមអំណាចរបស់គណៈកម្មាធិការកាកបាទក្រហម និងអឌ្ឍចន្ទក្រហមអន្តរជាតិ (ICRC) ឬអង្គការអព្យាក្រឹតមួយផ្សេងទៀត មិនធ្វើឱ្យការផ្លាស់ទីលំនៅធ្វើឡើងដោយស្ម័គ្រចិត្ត..."* ។ *សូមមើល* រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Krajisnik សំណុំរឿងលេខ IT-00-39-T សាលក្រម និងការជំនុំជម្រះទោស (ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៦) កថាខណ្ឌ ៧២៤។

[132] *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Krstic* សំណុំរឿងលេខ IT-98-33-T សំណុំរឿង ICTY (អង្គជំនុំជម្រះសាលាដំបូង) សាលក្រម ចុះថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០០១ កថាខណ្ឌ ៥២៨ *បន្តបន្ទាប់*។ *រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Krajisnik* សំណុំរឿងលេខ IT-00-39-T សំណុំរឿង ICTY (អង្គជំនុំជម្រះសាលាដំបូង) សាលក្រម ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ៧២៤។

[133] រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Stakic សំណុំរឿងលេខ IT-97-24-A សាលក្រម (ចុះថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦) កថាខណ្ឌ ២៧៩។ រឿងក្តីរដ្ឋអាជ្ញាតទល់នឹង Martic សំណុំរឿងលេខ IT-95-11-T សាលក្រម (ចុះថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧) កថាខណ្ឌ ១០៨។

72. ធាតុផ្សំសត្យានុម័តនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃការចាប់ដាក់ពន្ធនាគារគឺជា "ការដកហូតតាមទំនើងចិត្តនូវសេរីភាពរបស់បុគ្គលណាម្នាក់ដោយគ្មានដំណើរការត្រឹមត្រូវនៃច្បាប់"[134] ។ អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ បានពន្យល់ថា "ការដកហូតជាបឋមនូវសេរីភាពនឹងជាការដកហូតតាមទំនើងចិត្ត ប្រសិនបើគ្មានមូលដ្ឋានគតិយុត្តិដើម្បីផ្តល់យុត្តិកម្មដល់ទង្វើនោះ។ ប្រសិនបើច្បាប់ជាតិត្រូវបានយកមកសំអាង ជាយុត្តិកម្មត្រង់ប្រការនេះ គេត្រូវតែបង្ហាញថាបញ្ញត្តិពាក់ព័ន្ធ ពុំរំលោភច្បាប់អន្តរជាតិ។ ប្រសិនបើមូលដ្ឋានគតិយុត្តិសម្រាប់ការដកហូតដំបូងនេះ ពុំមានអត្ថិភាព វាត្រូវតែបន្តមានអត្ថិភាពនៅពេញមួយរយៈកាលនៃការចាប់ដាក់ពន្ធនាគារ។ ក្នុងករណីដែលមូលដ្ឋានស្របច្បាប់នៃការចាប់ដាក់ពន្ធនាគារ ឈប់យកមកអនុវត្ត ការចាប់ដាក់ពន្ធនាគារដែលត្រូវបានបន្ត អាចត្រូវបានចាត់ទុកជាការចាប់ដាក់ពន្ធនាគារតាមទំនើងចិត្ត"[135]។

73. អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង០០១បានបញ្ជាក់លម្អិតថា "មិនមែនរាល់ការរំលោភបំពានបន្តិចបន្តួចនៃសិទ្ធិសេរីភាពបង្កើតជាធាតុផ្សំសម្ភារៈនៃការដាក់ក្នុងមន្ទីរឃុំឃាំងដែលជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនោះទេ"[136]។ ដើម្បីបំពេញលក្ខខណ្ឌធាតុផ្សំអត្តនោម័ត "គេត្រូវតែបង្ហាញថាចារីមានចេតនាដកហូតតាមទំនើងចិត្តនូវសេរីភាពរបស់បុគ្គល ឬចារីបានប្រព្រឹត្តដោយការដឹងយ៉ាងសមហេតុផលថាសកម្មភាពរបស់ខ្លួនមុខជាបង្កឲ្យមានការដកហូតតាមទំនើងចិត្តនូវសេរីភាពរបស់បុគ្គល"[137]។

## ២.៥. ទារុណកម្ម

74. *ធាតុផ្សំសត្យានុម័ត* នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃទារុណកម្មគឺ "អំពើណាមួយដែលបណ្តាលឲ្យមានការឈឺចាប់ ឬការរងទុក្ខយ៉ាងធ្ងន់ធ្ងរផ្នែករាយកាយ ឬស្មារតី"[138]។ អំពើនេះត្រូវតែសម្រាប់គោលបំណងនានាដូចជាដើម្បីទទួលបានព័ត៌មាន ឬ ចម្លើយសារភាព ការផ្តន្ទាទោស ឬការបំភិតបំភ័យ[139] និងត្រូវតែបង្កឡើងដោយ ឬតាមការញុះញង់របស់មន្ត្រីសាធារណៈ[140]។ ធាតុ

[134] សាលក្រមសំណុំរឿង ០០១ ឯកសារ E188 កថាខណ្ឌ ៣៤៧។

[135] សាលក្រមសំណុំរឿង ០០១ ឯកសារ E188 កថាខណ្ឌ ៣៤៨។

[136] សាលក្រមសំណុំរឿង ០០១ ឯកសារ E188 កថាខណ្ឌ ៣៤៩។

[137] សាលក្រមសំណុំរឿង ០០១ ឯកសារ E188 កថាខណ្ឌ ៣៥០។

[138] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១ ឯកសារ F28 កថាខណ្ឌ ១៩៥ ២០៥។

[139] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១ ឯកសារ F28 កថាខណ្ឌ ១៩៥ ២០៣ និង ២០៥។

ផ្សំអត្តនោម័តដែលត្រូវបានតម្រូវ គឺថា "ការឈឺចាប់និងទុក្ខវេទនាដែលជាទារុណកម្ម ត្រូវបង្កឡើងដោយចេតនា"[141]។

75. នៅពេលពិចារណាអំពីនិយមន័យនៃទារុណកម្ម អង្គជំនុំជម្រះតុលាការកំពូលបានយោងទៅរកសេចក្ដីអធិប្បាយរបស់ ICRC ដែលបានគូសបញ្ជាក់ថា ការបង្កទុក្ខវេទនាៗទៅលើបុគ្គលណាម្នាក់ដើម្បីទទួលបានពីជននោះ ឬពីជនម្នាក់ទៀត នូវចម្លើយសារភាព ឬព័ត៌មាន។ ត្រូវតែជាលើសពីការបំពាន បូរណភាពរាងកាយ ឬស្មារតីរបស់ជនណាម្នាក់[142]។ អ្វីដែលសំខាន់គឺមិនមែនជាការឈឺចាប់ ដូចគោលបំណងនៅពីក្រោយការបង្កឡើងរបស់វាឡើយ[143]។ អង្គជំនុំជម្រះតុលាការកំពូលបានយោងទៅរកសំណុំរឿងក្រិក១៩៦៩ ដែលគណៈកម្មការអឺរ៉ុបបានគូសបញ្ជាក់ថា "ពាក្យ "ទារុណកម្ម" ... ជាទូទៅមានទម្រង់ជាអំពើអមនុស្សធម៌យ៉ាងធ្ងន់ធ្ងរ"[144]។

## ២.៦. ការធ្វើទុក្ខបុកម្នេញ

76. ឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ត្រូវបានកំណត់និយមន័យថាជា "អំពើសកម្ម ឬអំពើអកម្មដែលរើសអើងជាក់ស្ដែង និងដែលបដិសេធ ឬរំលោភលើសិទ្ធិជាសារវ័ន្តដែលមានចែងក្នុងច្បាប់ទម្លាប់អន្តរជាតិ ឬសន្ធិសញ្ញា"។ ធាតុផ្សំអត្តនោម័តដែលត្រូវបានតម្រូវគឺ "ការប្រព្រឹត្តិដោយចេតនានូវអំពើសកម្ម ឬអកម្មដោយចេតនារើសអើងដោយហេតុផលនយោបាយ ពូជសាសន៍ ឬសាសនា"[145]។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់បំភ្លឺថាក្រុមនយោបាយមួយត្រូវតែជាក្រុមជាក់លាក់។

77. ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល និងការធ្វើឲ្យទៅជាទាសករ ត្រូវបានចាត់ទុកជាការធ្វើទុក្ខបុកម្នេញ[146]។

---

[140] សាលដីកាលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០១ ឯកសារ F28 កថាខណ្ឌ ១៩៥ ២០៥។

[141] សាលក្រមសំណុំរឿង ០០១ ឯកសារ E188 កថាខណ្ឌ ៣៥៨។

[142] សាលដីកាលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០១ ឯកសារ F28 កថាខណ្ឌ ២០០។

[143] សាលដីកាលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០១ ឯកសារ F28 កថាខណ្ឌ ២០០។

[144] សាលដីកាលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០១ ឯកសារ F28 កថាខណ្ឌ ២០២។

[145] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ E313 កថាខណ្ឌ ៤២៧។

[146] សាលដីកាលើបណ្ដឹងសាទុក្ខក្នុងសំណុំរឿង ០០១ ឯកសារ F28 កថាខណ្ឌ ២៥៣ ២៥៤។

78. ជាងនេះទៀត អំពើសកម្ម ឬអំពើអកម្មជាក់លាក់នានា ពុំគួរត្រូវបានវិភាគដាច់ដោយឡែកឡើយ។ "អង្គជំនុំជម្រះតុលាការកំពូលបញ្ជាក់ថា យោងតាមយុត្តិសាស្ត្រតុលាការក្រោយសង្គ្រាមលោកលើកទី២ ចំណុចសំខាន់បំផុតនៃការវិភាគនេះ មិនមែនស្ថិតនៅលើការកំណត់ថាតើអំពើសកម្ម ឬអកម្មនៃការធ្វើទុក្ខបុកម្នេញជាក់លាក់*នេះ* រំលោភសិទ្ធិមនុស្សជាសារវ័ន្តដែរឬយ៉ាងណាឡើយ។ ប៉ុន្តែ ស្ថិតនៅលើការកំណត់ថាតើអំពើសកម្ម ឬអកម្មនៃការធ្វើទុក្ខបុកម្នេញនេះ នៅពេលពិចារណាជារួម និងទៅតាមបរិបទ នាំឲ្យមានការរំលោភសិទ្ធិជាសារវ័ន្តដោយកម្រោល ឬឥតលាក់លៀម ដែល*មានភាពធ្ងន់ធ្ងរ ឬស្ថានទម្ងន់ស្មើគ្នាទៅនឹងបទល្មើសមូលដ្ឋានដទៃទៀត នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរឬយ៉ាងណា...*"[147]។

79. អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចទៀតថា "ចាំបាច់ត្រូវតែមានអំពើសកម្ម ឬអកម្ម ដែលរើសអើងជាក់ស្តែង និងរើសអើងប្រឆាំងនឹងក្រុមជាក់លាក់ណាមួយដែលបានកំណត់ក្នុងលក្ខណវិនិច្ឆ័យណាមួយ។ ផ្ទុយមកវិញ មិនមានការរើសអើងជាក់ស្តែងនោះទេ នៅពេលដែល ១) នៅក្នុងអង្គហេតុ ចារីមានការភ័ន្តច្រឡំលើជនរងគ្រោះដោយមិនដឹងថាតើជនរងគ្រោះ ពិតជាស្ថិតក្នុងក្រុមគោលដៅ ដែលត្រូវបានកំណត់ដោយអត្តនោម័តដែរឬយ៉ាង ឬ ២) ចារីកំណត់គោលដៅជនរងគ្រោះដោយមិនគិតថាតើជនរងគ្រោះស្ថិតនៅក្នុងលក្ខណៈវិនិច្ឆ័យនៃការរើសអើងដែរឬយ៉ាងណា ឬក៏អាចនិយាយបានថានៅពេលដែលចារីកំណត់គោលដៅដោយមិនរើសមុខ"[148]។

80. ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃការធ្វើទុក្ខបុកម្នេញ អង្គជំនុំជម្រះតុលាការកំពូលបានសម្រេចថា "ការរើសអើងទៅលើក្រុមមួយ" ជាធាតុផ្សំមួយដ៏សំខាន់[149]។ ដើម្បីធានាថាក្រុមដែលត្រូវបានកំណត់គោលដៅជាក់ច្បាស់ ដែលរងការធ្វើទុក្ខបុកម្នេញដោយសារ "ហេតុផលដ៏ស្មុគស្មាញ" ពុំត្រូវបានទុកចោលដោយគ្មានការការពារ អង្គជំនុំជម្រះតុលាការកំពូលបានគូសបញ្ជាក់ថា នៅពេលកំណត់និយមន័យក្រុមដែលជាគោលដៅនៃការធ្វើទុក្ខបុកម្នេញ វាមានភាពសមស្រប និងចាំបាច់ ដើម្បីពិចារណាអំពីទស្សនៈរបស់ចារី[150]។ ប្រការសំខាន់ អង្គជំនុំជម្រះ

[147] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១ ឯកសារ **F28** កថាខណ្ឌ ២៥៧ (សេចក្តីបញ្ជាក់ដើម)។

[148] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០១ ឯកសារ **F28** កថាខណ្ឌ ២៧៧។

[149] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៧៥៤។

[150] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៦៧៩។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា វិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងដែលស្របជាមួយនឹងវិធីសាស្ត្រនៅក្នុងសាលដីការឿងក្តី *ឌុច*(001-F28)។

តុលាការកំពូលបានសម្រេចថា ទង្វើដែលជាឧក្រិដ្ឋកម្មនៃការធ្វើទុក្ខបុកម្នេញត្រូវតែរើសអើងជាក់ស្តែង ព្រមទាំងដាក់គោលដៅទៅលើជនរងដែលជាសមាជិកក្រុមដែលត្រូវបានកំណត់គោលដៅយ៉ាងជាក់ច្បាស់គ្រប់គ្រាន់ដែលត្រូវបានដាក់ជាគោលដៅដោយហេតុផលនយោបាយ ពូជ សាសន៍ ឬសាសនា"[151]។

### i. "ប្រជាជន ១៧ មេសា"

81. អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ បានធ្វើការកត់សម្គាល់ថា សូម្បីតែនៅមុនពេលជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ ខ្មែរក្រហម "បានបង្កើតឱ្យមានការស្អប់ខ្ពើមចំពោះអ្នកទីក្រុង"[152]។ នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ប្រជាជនទីក្រុងដែលត្រូវបានជម្លៀសត្រូវបានដាក់ឈ្មោះថា "ប្រជាជន១៧មេសា" ឬ "ប្រជាជនថ្មី" ដែលជាវិធីបែងចែកពួកគាត់ពីប្រជាជនមូលដ្ឋានដែលត្រូវបានដាក់ឈ្មោះថា "ប្រជាជន១៨មេសា" "ប្រជាជនចាស់" ឬ "ប្រជាជនមូលដ្ឋាន"[153]។ អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថា ប្រជាជនដែលបានរស់នៅទីក្រុងត្រូវបានស្គាល់ថាជា "ប្រជាជន១៧មេសា" ឬ "ប្រជាជនថ្មី"[154]។ "ប្រជាជន១៧មេសា" រួមបញ្ចូលអ្នករស់នៅទីក្រុងទាំងអស់ដែលត្រូវបានចាត់ទុកថាមានធាតុផ្សំទីក្រុងដ៏ពុករលួយ[155] ដែលជាពិសេសអតីតអ្នករដ្ឋការនៃសាធារណរដ្ឋខ្មែរ បញ្ញវ័ន្ត ម្ចាស់ដី នាយទុន អ្នកមូលធន និងគហបតី[156] ដែលអ្នកទាំងអស់នោះត្រូវបានចាត់ទុកជាសត្រូវនៃបដិវត្តន៍សង្គមនិយម[157]។

82. អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានក្នុងសំណុំរឿង ០០២/០១ ថាទាហានខ្មែរក្រហមបានមានចេតនារើសអើងដោយមូលហេតុនយោបាយ និងបានអនុវត្តដោយចេតនារើសអើងដែលចាំបាច់ក្នុងការប្រព្រឹត្តិរបស់ពួកគាត់ទៅលើប្រជាជនទីក្រុងដែលត្រូវបានជម្លៀស[158]។ ទាក់ទងការផ្លាស់ទី

---

[151] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៧៤៤។

[152] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ៥១៧។

[153] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ៥១៧។

[154] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ៥៦៩។

[155] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ១១២ ៨៧៣។

[156] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ១៦៩ ៦១៣។

[157] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ១៦៩។

[158] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ៥៧១។

លំនៅប្រជាជនដំណាក់កាលទី ១ និង ទី២ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា "ប្រជាជន ១៧មេសា" គឺជាផ្នែកមួយនៃក្រុមដែលត្រូវបានកំណត់ជាគោលដៅជាក់ច្បាស់ និងជាគោលដៅនៃការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ[159]។

83. អង្គជំនុំជម្រះតុលាការកំពូល ដោយបានកត់សម្គាល់ឃើញថា អង្គជំនុំជម្រះសាលាដំបូងបានប្រើប្រាស់ពាក្យពេចន៍មួយចំនួនផ្សេងគ្នា ដែលអាចផ្លាស់ប្តូរគ្នាបាន ដើម្បីសំដៅទៅរក "ប្រជាជន១៧មេសា" ដោយរួមបញ្ចូល "ប្រជាជនថ្មី" និង "ប្រជាជនទីក្រុង" បានបញ្ជាក់ថា អង្គជំនុំជម្រះសាលាដំបូងបានកំពុងសំដៅទៅរកក្រុមមនុស្សដដែលនេះពីដើមដល់ចប់ ដែលនោះគឺ ប្រជាជនដែលរស់នៅទីក្រុងភ្នំពេញនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[160]។ អង្គជំនុំជម្រះតុលាការកំពូលនៅពេលបន្ទាប់មកបានសម្រេចថា ការសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីបង្ហាញថាវាជាប្រជាជនទីក្រុងទាំងមូលដែលត្រូវបានចាត់ទុកជាការគំរាមកំហែងដល់គោលដៅនយោបាយបក្សដែលបានរួមបញ្ចូលបុគ្គលដែលបានកំពុងរស់នៅទីក្រុងជាយូរមកហើយ ព្រមទាំងអ្នកដែលបានមកនៅទីក្រុងដើម្បីស្វែងរកជម្រក ក្នុងអំឡុងពេលមានការប្រយុទ្ធគ្នាពីឆ្នាំ ១៩៧០ ដល់ ១៩៧៥[161]។

## ii. មន្ត្រីយោធា និងមន្ត្រីស៊ីវិលនៃសាធារណរដ្ឋខ្មែរ

84. ក្រៅពីប្រជាជនទីក្រុងដែលរស់នៅក្នុងទីក្រុងភ្នំពេញនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដែលត្រូវបានជម្លៀស នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានកំណត់អត្តសញ្ញាណប្រជាជនពីរក្រុមផ្សេងទៀត ដែលជាគោលដៅនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោ

---

[159] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ៥៦៩ ៦៥៣។ ខ. ក្នុងសហករណ៍ ប្រជាជនត្រូវបានបែងចែកជាប្រភេទផ្សេងៗ រួមទាំង សមាជិកសហករណ៍ពេញសិទ្ធិ ("ប្រជាជនមូលដ្ឋាននៅតាមសហករណ៍") សមាជិកសហករណ៍ត្រៀម ("ប្រជាជនមូលដ្ឋានទាំងឡាយណាដែលមានស្ថានភាពហិរញ្ញវត្ថុប្រសើរនៅមុនខែ មេសា ឆ្នាំ ១៩៧៥) និង "សមាជិកបញ្ញើរបស់សហករណ៍" ("ប្រជាជន ១៧ មេសា")។ *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ៦២១។ កម្លាំងពលកម្មត្រូវបានចាត់តាំង និងបែងចែកទៅតាមប្រភេទទាំងនេះ។ *សូមមើល* សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ៧៩៧។ ហើយ "ប្រជាជន ១៧ មេសា" បានរងការប្រព្រឹត្តមកលើតឹងរ៉ឹងជាង និងលក្ខខណ្ឌរស់នៅលំបាកវេទនាជាងប្រជាជនផ្សេងទៀត។ *សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ៦៥០។

[160] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៦៨៣។

[161] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៦៨៣។

បាយ ដែលពាក់ព័ន្ធទៅនឹង ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ រួមមាន៖ នាយទាហាន និងមន្ត្រីរដ្ឋការស៊ីវិលជាន់ខ្ពស់នៃរបបសាធារណរដ្ឋខ្មែរ និងនាយទាហាននិងមន្ត្រីរដ្ឋការស៊ីវិលដទៃទៀត ដែលមានតួនាទីនៅក្នុងរបបសាធារណរដ្ឋខ្មែរ រួមទាំងទាហាននិងមន្ត្រីរដ្ឋការស៊ីវិល[162]។

85. នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ក្រុមមនុស្សទាំងពីរក្រុមនេះផ្សំបង្កើតជាក្រុមមនុស្សដែលមានចំនួនសមល្មម ពីព្រោះពួកគេអាចត្រូវកំណត់អត្តសញ្ញាណដោយផ្អែកទៅលើលក្ខណវិនិច្ឆ័យដែលត្រូវបានបង្កើតឡើងដោយរបបខ្មែរក្រហម និងដោយសារសំអាងហេតុបានបង្ហាញថាសាវតាររបស់ពួកគេអាចត្រូវបានបញ្ជាក់[163]។

## ២.៧. អំពើអមនុស្សធម៌ផ្សេងៗទៀត

86. អង្គជំនុំជម្រះតុលាការកំពូល នៅក្នុងសំណុំរឿង ០០២/០១ បញ្ជាក់ថា សំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងដែលថា “មិនមានការមន្ទិលសង្ស័យដោយអនុលោមទៅតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិឆ្នាំ១៩៧៥ “អំពើអមនុស្សធម៌ផ្សេងៗទៀត” ត្រូវបានទទួលស្គាល់ថាជាប្រភេទនៃអំពើជាក់លាក់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ”[164]។ អង្គជំនុំជម្រះតុលាការកំពូលកត់សម្គាល់ថា ទោះបីជាធាតុផ្សំនៃបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ត្រូវបានចែងយ៉ាងលម្អិតនៅក្នុងច្បាប់អន្តរជាតិ ការអនុវត្តន៍ធាតុផ្សំទាំងនេះចំពោះសេណារីយ៉ូពិតប្រាកដជាក់លាក់ណាមួយដោយមិនរំលោភគោលការណ៍ *គ្មានបទល្មើស បើគ្មានច្បាប់ចែង (nullum crimen sine lege certa)*[165] ត្រូវបានអនុវត្តខុសៗគ្នា ដោយស្ថាប័នតុលាការផ្សេងៗគ្នា[166]។

---

[162] សាលក្រមអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ៥៦៩។ សម្រាប់ប្រធានបទនៃការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ អង្គជំនុំជម្រះសាលាដំបូងលើកឡើងថា យោងតាមព្រឹត្តិការណ៍នៃទួលពោធិ៍ជ្រៃដែលផ្តោតលើអតីតទាហាន លន់ នល់ ទាហានទាំងនេះគឺជាផ្នែកមួយនៃ “ក្រុមត្រូវបានគេស្គាល់យ៉ាងច្បាស់”។*សូមមើល* សាលក្រមអង្គជំនុំជម្រះសាលាដំបូងលើសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ៦៨៥។

[163] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ៥៦៩។

[164] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៥៧៦។

[165] អង្គជំនុំជម្រះតុលាការកំពូលបានរកឃើញនូវទស្សនទាន *ចរិតលក្ខណៈប្រហាក់ប្រហែលគ្នា (ejustdem generis)* និងការសំអាងរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងរឿងក្តី *Kupreskic* ទៅតាមច្បាប់មនុស្សធម៌ និងសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិ ដែលជួយដល់ការផ្តល់ “ការធានាដ៏សំខាន់” ក្នុងការធានាថា បទឧក្រិដ្ឋដែលរងការចោទប្រកាន់ក្រោមប្រភេទដែលនៅសេសសល់នៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មានលក្ខណៈ និងស្ថានទម្ងន់ស្រដៀងគ្នាទៅនឹងបទឧក្រិដ្ឋផ្សេងទៀតដែលចាត់ទុកថា

87. អង្គជំនុំជម្រះតុលាការកំពូលមិនយល់ស្របជាមួយនឹងការវាយបង្ហាញរបស់អង្គជំនុំជម្រះសាលាដំបូងនូវធាតុផ្សំនៃបទឧក្រិដ្ឋនៃការផ្លាស់ទីលំនៅដោយបង្ខំ[167] និងការធ្វើឱ្យបាត់ខ្លួនដោយបង្ខំពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី១ និងទី២ ទេ។

88. អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ព្រមទាំងការផ្លាស់ទីលំនៅដោយបង្ខំ និងការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ មិនមានអត្ថិភាពជាប្រភេទដាច់ដោយឡែកនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះឡើយ ក្នុងអំឡុងពេលនៃយុត្តាធិការក្នុងពេលវេលារបស់ អ.វ.ត.ក.។ អង្គជំនុំជម្រះយល់ឃើញថា បទឧក្រិដ្ឋនៃ "ការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ ឬការផ្លាស់ទីលំនៅដោយបង្ខំ នៅក្នុងឆ្នាំ១៩៧៥ មិនបានបង្កើតប្រភេទដាច់ដោយឡែកនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនោះឡើយ ហើយការធ្វើឱ្យបាត់ខ្លួនដោយបង្ខំ និងការផ្លាស់ទីលំនៅដោយបង្ខំ ក៏មិនមាននិយមន័យផ្លូវច្បាប់ និងធាតុផ្សំផ្លូវច្បាប់ជាក់លាក់នោះដែរ" អាស្រ័យហេតុនេះ "ការវាយបង្ហាញធាតុផ្សំដាច់ដោយឡែកនៃបទឧក្រិដ្ឋទាំងនេះ គឺ "មិនត្រឹមត្រូវតាមផ្លូវច្បាប់"[168] ទេ។ អង្គជំនុំជម្រះតុលាការកំពូលជ្រើសរើសធ្វើការពិនិត្យថាតើ "កាលៈទេសៈជាក់លាក់នៃរឿងក្តីបច្ចុប្បន្ននេះ ពិតជាបំពេញទៅតាមនិយមន័យនៃអំពើអមនុស្សធម៌ផ្សេងៗទៀតដែរឬទេ"[169]។ បន្ទាប់ពីរកឃើញថា និយមន័យរបស់អង្គជំនុំជម្រះសាលាដំបូងមិនពេញលេញតាមផ្លូវច្បាប់ អង្គជំនុំជម្រះ ធ្វើ "ការវិភាគបែបសន្តនិយម" ដើម្បីស្វែងយល់ថាតើ កាលៈទេសៈពិតប្រាកដនៃដំណាក់កាលនីមួយៗ មាន "ចរិតលក្ខណៈ និងកម្រិតធ្ងន់ធ្ងរ [...] ប្រហាក់ប្រហែលទៅនឹងកាលៈ

---

ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៥៧៨ ៥៨២-៨៣។

[166] សាលដីកាលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៥៨១-៥៨៦។

[167] អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០២/០១ បានកំណត់និយមន័យ *ធាតុផ្សំសត្យានុម័ត* និង *ចេតនា* ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងទៀតក្រោមទម្រង់ការជម្លៀសដោយបង្ខំថាជា "(i) ចេតនា (ii) នៃការផ្លាស់ទីលំនៅដោយបង្ខំរបស់បុគ្គលជាច្រើន (iii) ឱ្យចាកចេញពីតំបន់មួយដែលពួកគេរស់នៅដោយស្របច្បាប់ (iv) ដោយគ្មានយុត្តិកម្មសមស្រប តាមរយៈការព្រួយបារម្ភអំពីសន្តិសុខរបស់ជនស៊ីវិល ឬភាពចាំបាច់ណាមួយខាងផ្នែកយោធា" និង "អាចត្រូវបានចាត់ទុកថាមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងឧក្រិដ្ឋកម្មដទៃទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែរ"។ សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ៤៥០ និងកថាខណ្ឌ ៤៥៥។

[168] សាលដីកាសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៥៨៩។

[169] សាលដីកាសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៥៨៩។

ទេសៈនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលត្រូវបានបញ្ជាក់ ដែរឬទេ"[170] និង/ឬ ស្វែងយល់ថា តើគេបានរំលោភបំពាន "គោលការណ៍ទូលំទូលាយស្តីពីសិទ្ធិមនុស្ស"[171] ដែរឬទេ។ ក្នុងការវាយតម្លៃទៅលើមូលដ្ឋាននៃបណ្តឹងសាទុក្ខរបស់ជនជាប់ចោទ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា "ការប្រព្រឹត្តិដែលរំលោភបំពានសិទ្ធិជាសារវ័ន្តរបស់មនុស្ស ដូចដែលត្រូវបានបញ្ជាក់នៅក្នុងលិខិតុបករណ៍ច្បាប់អន្តរជាតិ" ដោយអនុលោមទៅតាមគោលការណ៍ *ចរិតលក្ខណៈប្រហាក់ប្រហែលគ្នា (ejusdem generis)* មានភាពប្រហាក់ប្រហែលទៅនឹង "ធាតុផ្សំរូបវ័ន្តដែលជាប្រពៃណីត្រូវបានចាត់ទុក" ថាជាអំពើអមនុស្សធម៌ផ្សេងៗទៀត[172]។ អង្គជំនុំជម្រះយល់ឃើញថា ដើម្បីគោរពតាមគោលការណ៍*គ្មានបទល្មើស បើគ្មានច្បាប់ចែង (nullum crimen sine lege certa)* អង្គជំនុំជម្រះត្រូវ "កំណត់អត្តសញ្ញាណនៃការបញ្ជាក់ច្បាស់លាស់នូវសិទ្ធិ និងការហាមឃាត់ដែលមានចែងនៅក្នុងលិខិតុបករណ៍ស្តីពីសិទ្ធិមនុស្ស ដែលអាចអនុវត្តបាននៅក្នុងអំឡុងពេលពាក់ព័ន្ធនឹងបទចោទនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត"[173]។

89. ដោយពិចារណាទៅលើស្ថានភាពទាំងមូលនៃកាលៈទេសៈនៃទីតាំងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់នីមួយៗ គេត្រូវមានធាតុផ្សំដូចខាងក្រោម (i) អំពើសកម្ម ឬអកម្មដែលមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងអំពើជាក់លាក់ដទៃទៀតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ (ii) អំពើសកម្ម ឬអកម្មដែលបណ្តាលឲ្យមានការឈឺចាប់ ឬព្យសនកម្មធ្ងន់ធ្ងរលើរូបកាយ ឬផ្លូវចិត្ត ឬ

170 សាលដីកាសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៥៨០។

171 សាលដីកាសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៥៨៥។

172 សាលដីកាសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៥៨៤។

173 សាលដីកាសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៥៨៤។ និង "អង្គជំនុំជម្រះតុលាការកំពូលពិចារណាឃើញថា គោលការណ៍*គ្មានបទល្មើសបើគ្មានច្បាប់ចែង* ត្រូវបានគោរព ប្រសិនបើអំពើប្រព្រឹត្តជាក់លាក់ដែលត្រូវបានរកឃើញថាជាអំពើអមនុស្សធម៌ផ្សេងៗទៀតនោះ រំលោភបំពានលើសិទ្ធិជាសារវ័ន្តរបស់ជនជាប់ចោទ និងមានភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នាទៅនឹងអំពើជាក់លាក់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ផ្អែកតាមការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូល ចំណុចនេះតម្រូវឲ្យមានការពិចារណាដោយផ្អែកតាមករណីជាក់ស្តែងនីមួយៗអំពីផលប៉ះពាល់នៃអំពើប្រព្រឹត្តទៅលើជនរងគ្រោះ និងថាតើអំពើនេះអាចប្រហាក់ប្រហែលគ្នាទៅនឹងបទឧក្រិដ្ឋជាក់លាក់នៅក្នុងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរឬយ៉ាងណា (ឯកសារ **F36** កថាខណ្ឌ ៥៨៦)។

ជាការធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិ (iii) អំពើសកម្ម ឬអកម្មដែលត្រូវបានប្រព្រឹត្តឡើងដោយចេតនា[174]។

***ការផ្លាស់ទីលំនៅប្រជាជន/ការផ្លាស់ទីលំនៅដោយបង្ខំដំណាក់កាលទី២***

90. ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ក្នុងអំឡុងការផ្លាស់ទីលំនៅដំណាក់កាលទី១ និងទី២ ត្រូវបានលើកឡើងជាចម្បងនៅក្នុងសំណុំរឿង ០០២/០១។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា ជនជាប់ចោទទាំងពីរទទួលខុសត្រូវតាមរយៈសហឧក្រិដ្ឋកម្មរួម ចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅដំណាក់កាលទី១ និងទី២ នៅក្នុងសំណុំរឿង ០០២/០១[175]។ ដូចដែលបានលើកឡើងនៅខាងលើ អង្គជំនុំជម្រះសាលាដំបូង ក្នុងការបំបែកកិច្ចដំណើការនិតិវិធីនៃសំណុំរឿង ០០២ បានដាក់កំហិត អង្គហេតុពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ ត្រឹមតែអង្គហេតុទាំងឡាយណាដែលពាក់ព័ន្ធនឹងការប្រព្រឹត្តិចំពោះជនជាតិចាមក្នុងសំណុំរឿង ០០២/០២ តែប៉ុណ្ណោះ[176]។ ដូច្នេះ ក្នុងសំណុំរឿង ០០២/០២ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ត្រូវបានចោទប្រកាន់ត្រង់ចំណុចនេះពាក់ព័ន្ធនឹងការប្រព្រឹត្តិលើជនជាតិចាម[177]។

91. នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូង យល់ឃើញថា “ការផ្លាស់ទីលំនៅជនជាតិភាគតិចចាម បង្កើតជាមូលដ្ឋាននៃបទចោទ ទាំងការផ្លាស់ទីលំនៅដោយបង្ខំ និងការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុសាសនា ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅប្រជាជន (ដំណាក់កាលទី២)” និងយល់ឃើញថា “មូលដ្ឋានអង្គហេតុនៃបទចោទទាំងពីរនេះដូចគ្នា ហើយបទចោទជាប់ពាក់ព័ន្ធគ្នាពុំ

---

[174] សាលដីកាសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៥៨០។

[175] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ៩៤០ កថាខណ្ឌ ៩៩៦។

[176] សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធីបន្ថែមលើសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ឯកសារ **E301/9/1**។ សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះសំណុំរឿងលេខ ០០២/០២ ឯកសារ **E301/9/1.1**។ សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ៦២៧។

[177] ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ២៦៦ កថាខណ្ឌ ១៤៤៨-១៤៥២។ សេចក្ដីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះសំណុំរឿងលេខ ០០២/០២ ឯកសារ **E301/9/1.1**។

អាចញែកចេញពីគ្នាបាន”[178]។ អង្គជំនុំជម្រះសាលាដំបូង បានបដិសេធមិនធ្វើសំអាងហេតុពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅជនជាតិចាមដោយបង្ខំ ពីព្រោះសំអាងហេតុទាំងនេះនឹងត្រូវធ្វើនៅក្នុងសំណុំរឿង០០២/០២ ក៏ប៉ុន្តែសំអាងហេតុស្តីពីការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ នៅក្នុងសំណុំរឿង០០២/០១ មានភាពពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការប្រព្រឹត្តិចំពោះជនជាតិចាម[179]។ ជាពិសេស អង្គជំនុំជម្រះសាលាដំបូង បានផ្តល់សំអាងហេតុដោយផ្អែកលើអង្គហេតុដែលថា “កងទ័ព និងកម្មាភិបាលខ្មែរក្រហម បានអនុវត្តការផ្លាស់ទីលំនៅរបស់ប្រជាជនដោយចេតនា និងដោយបង្ខំ ដោយគ្មានមូលដ្ឋានដែលត្រូវបានអនុញ្ញាតក្រោមច្បាប់អន្តរជាតិ ពីភូមិភាគមួយទៅភូមិភាគមួយ និងនៅក្នុងភូមិភាគ”[180] និងថា “ការផ្លាស់ទីលំនៅទាំងនេះត្រូវបានធ្វើឡើងក្រោមលក្ខខណ្ឌអមនុស្សធម៌”[181]។ សេចក្តីសំអាងហេតុលើអង្គហេតុជាក់លាក់ស្តីពីការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ ត្រូវបានធ្វើឡើងកាន់តែលម្អិតនៅក្នុងសាលក្រមសំណុំរឿង ០០២/០១[182]។

92. បន្ថែមទៅលើការរំលោភបំពាន “សិទ្ធិទទួលបានសេរីភាព សិទ្ធិទទួលបានសន្តិសុខរបស់មនុស្ស និងសិទ្ធិរួចផុតពីការប្រព្រឹត្តិឃោរឃៅអមនុស្សធម៌” ដែលត្រូវបានលើកឡើងខាងលើ អង្គជំនុំជម្រះតុលាការកំពូលយល់ឃើញថា លក្ខខណ្ឌអង្គហេតុជាក់លាក់អំពីការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ ដូចជា “កង្វះស្បៀងអាហារនិងទឹក” “កង្វះសម្ភារអនាម័យ” និង “កង្វះថ្នាំពេទ្យ និងការផ្តល់ជំនួយ”[183] “ការពិតដែលថា ប្រជាជនមួយចំនួនបានស្លាប់ក្នុងអំឡុងពេលផ្លាស់ទីលំនៅដំណាក់កាលទី២ ដោយសារលក្ខខណ្ឌបែបបនេះ”[184] និងប្រការដែលថា “មានករណីបែបបាក់គ្រួសារ”[185]

---

[178] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ៦២៧។

[179] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ៦២៧។

[180] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ៦៣៨។

[181] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ៦៣៩។

[182] ក្នុងសាលក្រម (ឯកសារ **E313**) របស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានរកឃើញថា សម្រាប់ការផ្លាស់ទីលំនៅប្រជាជនក្នុងដំណាក់កាលទី ១ និងដំណាក់កាលទី ២៖ ប្រជាជនត្រូវបានផ្លាស់ទីលំនៅ (កថាខណ្ឌ ៥៧៩) ទៅតាមបញ្ជារបស់របបកម្ពុជាប្រជាធិបតេយ្យ (កថាខណ្ឌ ៥៧៧-៥៧៨) ដោយគ្មានការយល់ព្រមពីពួកគេ និងថា ប្រជាជនដែលត្រូវបានផ្លាស់ទីលំនៅទាំងនោះបានជួបប្រទះ “ការលំបាក នៅក្នុងអំឡុងពេល និងក្រោយពេលផ្លាស់ទីលំនៅ” (កថាខណ្ឌ ៥៨២)។ ចំពោះដំណាក់កាលដ៏លំបាកនៃការផ្លាស់ទីលំនៅ និងគោលបំណង *សូមមើលឧទាហរណ៍* សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ៥៨២ កថាខណ្ឌ ៥៩៤ កថាខណ្ឌ ៥៩៧ កថាខណ្ឌ ៦០០ កថាខណ្ឌ ៦០១ កថាខណ្ឌ ៦១៣ កថាខណ្ឌ ៦៣៧ កថាខណ្ឌ ៨០៣។

[183] សាលដីកាសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៦២៤-៦២៨។

[184] សាលដីកាសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៦៥៨។

គឺមានចរិតលក្ខណៈ និងកម្រិតធ្ងន់ធ្ងរគ្រប់គ្រាន់ ដែលធ្វើឲ្យសេចក្តីបញ្ជាក់របស់អង្គជំនុំជម្រះសាលាដំបូង អំពីបទឧក្រិដ្ឋនៃអំពើអមនុស្សធម៌ផ្សេងៗទៀតនៃការផ្លាស់ទីលំនៅដោយបង្ខំ "ពុំមែនជាការមិនសមហេតុផល"[186] នោះឡើយ។ ជាងនេះទៅទៀត អង្គជំនុំជម្រះតុលាការកំពូលបានធ្វើសេចក្តីសន្និដ្ឋានដោយសមហេតុផលថា អង្គជំនុំជម្រះសាលាដំបូងបានយល់ឃើញដោយសមហេតុផលថា ការផ្លាស់ទីលំនៅក្នុងអំឡុងពេលនៃការផ្លាស់ទីលំនៅដំណាក់កាលទី២ មិនអាចត្រូវបានធ្វើយុត្តិកម្មដោយសារតែភាពចាំបាច់ផ្នែកយោធា ឬដោយសារមូលហេតុសន្តិសុខរបស់ប្រជាជនស៊ីវិល នោះឡើយ[187]។

## ខ. បទល្មើសប្រល័យពូជសាសន៍ (ក្រោមទម្រង់ជាការធ្វើមនុស្សឃាត)

93. ជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទល្មើសប្រល័យពូជសាសន៍ ដោយបានសម្លាប់ជនជាតិចាម និងជនជាតិវៀតណាម។ បទឧក្រិដ្ឋប្រល័យពូជសាសន៍ នៅ អ.វ.ត.ក. ប្រកាន់យកនិយមន័យដែលត្រូវបានចែងនៅក្នុងមាត្រា២ នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍។ បទល្មើសប្រល័យពូជសាសន៍ ដូចដែលត្រូវបានកំណត់និយមន័យនៅក្នុងច្បាប់របស់ អ.វ.ត.ក. គឺជាបទឧក្រិដ្ឋដែលអាចត្រូវផ្តន្ទាទោសនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅពេលអំពើទាំងនោះត្រូវបានប្រព្រឹត្តដូចដែលត្រូវបានចោទប្រកាន់នៅក្នុង ដីកាដំណោះស្រាយ[188]។

94. អំពើមនុស្សឃាតគឺជាធាតុផ្សំមួយនៃបទល្មើសប្រល័យពូជសាសន៍ នៅពេលដែល អំពើនោះ "ត្រូវបានប្រព្រឹត្តឡើងដោយមានចេតនាបំផ្លាញបំផ្លាញ ទាំងស្រុង ឬមួយផ្នែក នៃក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬសាសនា ណាមួយតែម្តង។"[189]

95. អាស្រ័យហេតុនេះ ដើម្បីផ្តន្ទាទោសជនជាប់ចោទពីបទល្មើសប្រល័យពូជសាសន៍នៅក្នុងរឿងក្តីនេះ ត្រូវមានភ័ស្តុតាងបង្ហាញថា (i) ចារីមានចេតនាសម្លាប់សមាជិកម្នាក់ ឬច្រើននាក់នៃក្រុមមនុស្ស

[185] សាលដីកាសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៦៥៨។

[186] សាលដីកាសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៦២៨ កថាខណ្ឌ ៦៣០ កថាខណ្ឌ ៦៤១ កថាខណ្ឌ ៦៤៦។

[187] សាលដីកាសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៦៤៦។

[188] ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៣១០-១៣១២។

[189] អនុសញ្ញាស្តីពីការទប់ស្កាត់ និងផ្តន្ទាទោសចំពោះអំពើឧក្រិដ្ឋប្រល័យពូជសាសន៍ ចុះថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ១៩៤៨ មាត្រា II។

ដែលត្រូវបានកំណត់គោលដៅ (ii) ជនរងគ្រោះគឺជាសមាជិករបស់ក្រុមដែលត្រូវបានកំណត់គោលដៅនោះ (iii) ដោយមានចេតនាបំផ្លិចបំផ្លាញក្រុមនោះ ទាំងស្រុង ឬមួយផ្នែក តែម្តង។

***ការធ្វើមនុស្សឃាតសមាជិកក្រុមមនុស្ស***

96. ធាតុផ្សំចាំបាច់ដើម្បីបំពេញតាមអត្ថន័យនៃឃ្លា "ក្រោមទម្រង់ជាការធ្វើមនុស្សឃាត" គឺដូចទៅនឹងធាតុផ្សំនៃការធ្វើមនុស្សឃាតដោយចេតនា/ឃាតកម្ម[190]។ អាស្រ័យដូចនេះ ត្រូវមានភស្តុតាងបង្ហាញថា (i) អំពើសកម្ម ឬ អកម្មរបស់ជនជាប់ចោទ ឬរបស់ជនណាម្នាក់ ឬ ច្រើននាក់ ដែលជនជាប់ចោទជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើសកម្ម ឬ អកម្មដែលបណ្តាលឲ្យជនរងគ្រោះស្លាប់ និង (ii) ចេតនារបស់ជនជាប់ចោទ ឬជនណាម្នាក់ ឬច្រើននាក់ ដែលជនជាប់ចោទជាអ្នកទទួលខុសត្រូវព្រហ្មទណ្ឌចំពោះការសម្លាប់នេះ ឬ ការបង្កឲ្យមានព្យសនកម្មលើរូបរាងកាយធ្ងន់ធ្ងរដោយដឹងថាអំពើសកម្ម ឬអកម្មនោះមុខជាបង្កឲ្យមានការបាត់បង់ជីវិតមនុស្ស[191]។

97. ជាងនេះទៅទៀត ត្រូវមានភស្តុតាងបង្ហាញថា ជនរងគ្រោះនៃការធ្វើមនុស្សឃាត គឺជាសមាជិកម្នាក់របស់ក្រុមមនុស្សដែលត្រូវការពារ ឬត្រូវបានចារីយល់ឃើញថាជាសមាជិកម្នាក់របស់ក្រុមមនុស្សដែលត្រូវការពារ[192]។ មាត្រាទី២ នៃអនុសញ្ញា ការពារក្រុមជាតិ ជាតិពន្ធុ ពូជសាសន៍ ឬ សាសនា "ណាមួយតែម្តង"។

98. ក្រុមជាតិពន្ធុ ត្រូវបានកំណត់និយមន័យថាជាក្រុមមនុស្សដែលមានសមាជិកដែលប្រើប្រាស់ភាសា និងមានវប្បធម៌ដូចគ្នា ឬក្រុមមនុស្សដែលមានចរិតលក្ខណៈដោយឡែករបស់ខ្លួនតែម្តង ឬ ក្រុមមនុស្សដែលត្រូវបានកំណត់អត្តសញ្ញាណដាច់ដោយឡែកដោយអ្នកដទៃ[193]។
ទស្សនាទានពូជសាសន៍ ត្រូវគេប្រើប្រាស់ដើម្បីពិពណ៌នាពីក្រុមសង្គមដែលសមាជិកបង្ហាញនូវ

---

[190] សូមមើល សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ៥១២។ រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Brdjanin* សំណុំរឿងលេខ IT-99-36-T សាលក្រម ចុះថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០០៤ កថាខណ្ឌ ៣៨១ កថាខណ្ឌ ៦៨៩។

[191] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ៥១៣។

[192] រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Muhimana* សំណុំរឿងលេខ ICTR-95-1B-T សាលក្រម ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៥ កថាខណ្ឌ ៥០០។ រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Kajelijeli* សំណុំរឿងលេខ ICTR-98-44A-T សាលក្រម និងការផ្តន្ទាទោស ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០០៣ កថាខណ្ឌ ៨១៣។

[193] រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Kayishema* សំណុំរឿងលេខ ICTR-95-1-T សាលក្រម ចុះថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ១៩៩៩ កថាខណ្ឌ ៩៨។

លក្ខណៈរាងកាយពីកំណើតដូចគ្នាដែលអាចមើលឃើញ ដូចជាពណ៌សម្បុរ ឬ រូបរាងកាយ[194]។ លក្ខណៈទាំងនេះ ជាទូទៅជាប់ពាក់ព័ន្ធទៅនឹងភូមិសាស្ត្រ[195]។

99. ជាការចាំបាច់ ដែលត្រូវមានភស្តុតាងបង្ហាញថា ជនរងគ្រោះត្រូវបានចារីគិតថា ជាសមាជិករបស់ក្រុមមនុស្សដែលត្រូវការពារ[196]។

***ចេតនានៃបទល្មើសប្រល័យពូជសាសន៍***

100. ក្រៅពីបំពេញធាតុផ្សំអង្គច្បាប់នៃការធ្វើមនុស្សឃាត ត្រូវមានចេតនាបន្ថែមមួយស្រទាប់ទៀត។ ត្រូវមានភស្តុតាងបង្ហាញថា ជនជាប់ចោទ ឬ មនុស្សដែលអំពើសកម្ម/អកម្មរបស់ខ្លួនដែលជនជាប់ចោទ ទទួលខុសត្រូវព្រហ្មទណ្ឌ មានចេតនាបំផ្លិចបំផ្លាញក្រុមមនុស្សដែលត្រូវបានកំណត់គោលដៅ ទាំងស្រុង ឬមួយផ្នែក។

***"ទាំងស្រុង ឬ មួយផ្នែក"***

101. ចេតនាត្រូវតែជាចេតនាបំផ្លិចបំផ្លាញក្រុមមនុស្សនោះ មិនមែនគ្រាន់តែបំផ្លិចបំផ្លាញបុគ្គលមួយចំនួន ដោយសារពួកគេជាសមាជិកនៅក្នុងក្រុមពិសេសណាមួយឡើយ[197]។ ជនរងគ្រោះគួរត្រូវបានចាត់ទុកថាជាក្រុមមនុស្សនោះផ្ទាល់តែម្តង គឺ មិនមែនជាជនរងគ្រោះបុគ្គលនោះឡើយ[198]។ អារម្មណ៍របស់ចារីកំណត់ថាអ្នកណាជាសមាជិកក្រុមមនុស្សនោះទាំងមូល ហើយនោះគឺជាគោលដៅពិតប្រាកដនៃបទឧក្រិដ្ឋ។ អាស្រ័យហេតុនេះ ក្រុមមនុស្សដែលត្រូវគេកំណត់គោលដៅ

---

[194] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Akayesu* សំណុំរឿងលេខ ICTR-96-4-T សាលក្រម ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥១៤។

[195] ដូចជាជើងទំព័រខាងលើ។

[196] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Muhimana* សំណុំរឿងលេខ ICTR-95-1B-T សាលក្រម ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៥ កថាខណ្ឌ ៥០០។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kajelijeli* សំណុំរឿងលេខ ICTR-98-44A-T សាលក្រម និងការផ្តន្ទាទោស ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០០៣ កថាខណ្ឌ ៨១៣។

[197] សូមមើល រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Bagilishema* សំណុំរឿងលេខ ICTR-95-1A-T សាលក្រម ចុះថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០០១ កថាខណ្ឌ ៦៤។

[198] សូមមើល រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Muvunyi* សំណុំរឿងលេខ ICTR-2000-55A-T សាលក្រម និងការផ្តន្ទាទោស ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ៤៨៥។

អាចជាផ្នែកមួយនៃក្រុមមនុស្សមួយធំជាង។ ឧទាហរណ៍ អំពើប្រល័យពូជសាសន៍អាចត្រូវគេប្រព្រឹត្តប្រឆាំងនឹងសមាជិកក្រុមមនុស្សធំជាងណាមួយ ដែលរស់នៅក្នុងតំបន់ជាក់លាក់ណាមួយ[199]។ ក៏ប៉ុន្តែ វាត្រូវតែជាផ្នែកមួយដ៏សំខាន់នៃក្រុមនោះ។ “គោលបំណងនៃអនុសញ្ញាប្រល័យពូជសាសន៍ គឺ បង្ការការបំផ្លិចបំផ្លាញដោយចេតនា នូវក្រុមមនុស្សទាំងស្រុង ហើយផ្នែកនៃក្រុមដែលត្រូវគេកំណត់គោលដៅ ត្រូវមានបរិមាណសមល្មមដែលអាចមានផលប៉ះពាល់ទៅលើក្រុមទាំងមូល”[200]។

102. ចេតនានៃបទល្មើសប្រល័យពូជសាសន៍ ត្រូវបានបង្ហាញយ៉ាងល្អបំផុតដោយភ័ស្តុតាងផ្ទាល់ ក៏ប៉ុន្តែ យុត្តិសាស្ត្ររបស់ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (ICL) មានភាពស៊ីសង្វាក់ដែលថាមានកត្តាពាក់ព័ន្ធផ្សេងៗទៀតដើម្បីទាញការសន្និដ្ឋានអំពីចេតនាជាក់លាក់ លើសពីពាក្យសម្ដី និងសកម្មភាព ដែលកត្តាទាំងនោះ រួមមាន បរិបទទូទៅ ភាពច្រំដែលនៃអំពើបំផ្លិចបំផ្លាញ/រើសអើង ចរិតលក្ខណៈជាប្រព័ន្ធនៃការធ្វើមនុស្សឃាត ការរៀបចំផែនការវិធីសាស្ត្រ ចរិតលក្ខណៈនៃភាពឃោរឃៅ (រួមមាន វិសាលភាព ទីតាំង អាវុធ កម្រិតព្យសនកម្ម ការកំណត់គោលដៅទ្រព្យសម្បត្តិរបស់សមាជិកក្រុមមនុស្សនោះ ការប្រើប្រាស់ភាសាអាក្រក់ចំពោះសមាជិកក្រុមមនុស្សនោះ[201]។ កត្តាផ្សេងទៀតដែលពាក់ព័ន្ធផងដែរ គឺ វិសាលភាព ការផាត់ចោលនូវសមាជិកនៃក្រុមដ៏ទៃៗទៀត និងមនោគមន៍វិជ្ជានយោបាយដែលនាំឲ្យមានការកើតឡើងនូវអំពើដែលត្រូវបានចោទប្រកាន់[202]។

---

[199] សូមមើល រឿងក្ដី*រដ្ឋអាជ្ញា តទល់នឹង Krstic* សំណុំរឿងលេខ ICTR-98-33 សាលដីកា ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៤ កថាខណ្ឌ ១៥-១៧។

[200] សូមមើល រឿងក្ដី*រដ្ឋអាជ្ញា តទល់នឹង Krstic* សំណុំរឿងលេខ ICTR-98-33 សាលដីកា ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០០៤ កថាខណ្ឌ ៨។

[201] រឿងក្ដី*រដ្ឋអាជ្ញា តទល់នឹង Muhimana* សំណុំរឿងលេខ ICTR-95-1B-T សាលក្រម ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៥ កថាខណ្ឌ ៤៩០។ រឿងក្ដី*រដ្ឋអាជ្ញា តទល់នឹង Gacumbitsi* សំណុំរឿងលេខ ICTR-2001-64-T សាលក្រម ចុះថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០០៤ កថាខណ្ឌ ២៥២។ រឿងក្ដី*រដ្ឋអាជ្ញា តទល់នឹង Kajelijeli* សំណុំរឿងលេខ ICTR-98-44A-T សាលក្រម និងការផ្ដន្ទាទោស ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០០៣ កថាខណ្ឌ ៨០៦។ រឿងក្ដី*រដ្ឋអាជ្ញា តទល់នឹង Simba* សំណុំរឿងលេខ ICTR-2001-76-T សាលក្រម ចុះថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០០៥ កថាខណ្ឌ ៤១៣។

[202] រឿងក្ដី*រដ្ឋអាជ្ញា តទល់នឹង Kalimanzira* សំណុំរឿងលេខ ICTR-05-88-T សាលក្រម ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០០៩ កថាខណ្ឌ ៧៣១។ រឿងក្ដី*រដ្ឋអាជ្ញា តទល់នឹង Muvunyi* សំណុំរឿងលេខ ICTR-00-55A-T សាលក្រម ចុះថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១០ កថាខណ្ឌ ២៩។

*ចេតនាបំផ្លិចបំផ្លាញក្រុម "ណាមួយតែម្តង"*

103. ពាក្យ "ណាមួយតែម្តង" មានសារៈសំខាន់យ៉ាងខ្លាំង ពីព្រោះពាក្យនេះបង្ហាញថា បទឧក្រិដ្ឋប្រល័យពូជសាសន៍តម្រូវឱ្យមានចេតនាបំផ្លិចបំផ្លាញក្រុមមនុស្សណាមួយ ដោយសារតែសមាជិកភាពរបស់ពួកគេនៅក្នុងក្រុមមនុស្សជាក់លាក់ណាមួយ។

104. លក្ខខណ្ឌតម្រូវរបស់ពាក្យ "ណាមួយតែម្តង" ត្រូវបានបកស្រាយនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (ICL) ថាជាការមិនហាមឃាត់កត្តាជំរុញផ្សេងទៀត ពោលគឺ អំពើដែលត្រូវបានហាមឃាត់ត្រូវបានប្រព្រឹត្តចំពោះជនរងគ្រោះដោយសារតែសមាជិកភាពរបស់ពួកគេនៅក្នុងក្រុមមនុស្សដែលត្រូវបានកំណត់គោលដៅ ប៉ុន្តែ មិនមែនដោយសារតែសមាជិកភាពរបស់ពួកគេនៅក្នុងក្រុមមនុស្សនោះ តែមួយមុខគត់នោះឡើយ[203]។

## III. ការវាយតម្លៃលើភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី

## ក. និដ្ឋភាពទូទៅ

105. សហមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីរម្លឹកអំពីយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូលពាក់ព័ន្ធនឹងតម្លៃជាភស្តុតាងនៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ដោយសារជាភាគីមួយនៃនិតិវិធីព្រហ្មទណ្ឌ ដែលជាផ្នែកមួយនៃក្រុមបណ្តុំរួមគ្នាដូចដែលបានលើកឡើងខាងលើ[204] ពួកគេមិន អាចផ្តល់សក្ខីកម្មក្នុងនាមជាសាក្សីនោះឡើយ[205]។ អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថាតួនាទីពិសេសដោយឡែករបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅ អ.វ.ត.ក គឺកត្តាទាំងអស់ដែល " អង្គជំនុំ ជម្រះសាលាដំបូងដាក់បញ្ចូលក្នុងការអនុវត្តនូវវិធីសាស្ត្ររបស់ខ្លួន និងត្រូវបានពិចារណានៅពេលធ្វើការវាយតម្លៃលើតម្លៃជាភស្តុតាង និងលើទម្ងន់នៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី

---

[203] សូមមើល រឿងក្តី *Niyitegeka តទល់នឹងរដ្ឋអាជ្ញា* សំណុំរឿងលេខ ICTR-96-14-A សាលក្រម ចុះថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០០៤ កថាខណ្ឌ ៥៣។

[204] *សូមមើលបន្ថែម* វិធានផ្ទៃក្នុង ទំព័រ ៨០ "ដើមបណ្តឹងរដ្ឋប្បវេណី" ទំព័រ ៨១ "ភាគី"។

[205] វិធាន ២៣(៤) នៃវិធានផ្ទៃក្នុង។

នីមួយៗ" ក៏ប៉ុន្តែ អង្គជំនុំជម្រះតុលាការកំពូលក៏បានបញ្ជាក់ថា *តាមធម្មតា* កត្តាទាំងអស់នេះ ពុំបានបង្ហាញ ពីកំហុសអង្គច្បាប់នៅក្នុងវិធីសាស្ត្ររបស់អង្គជំនុំជម្រះសាលាដំបូងឡើយ[206]។

106. អង្គជំនុំជម្រះតុលាការកំពូលបានបញ្ជាក់ថា ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី អាចនឹងត្រូវយកមកប្រើប្រាស់ដោយអង្គជំនុំជម្រះសាលាដំបូង នៅក្នុងការសម្រេចតាមលំនាំច្បាប់របស់ខ្លួន ដើម្បីឈានទៅរកការធ្វើសំអាងហេតុលើអង្គហេតុ និងអង្គច្បាប់ ទោះបីជាភស្តុតាងទាំងនោះអាចពាក់ព័ន្ធ ឬពុំពាក់ព័ន្ធនឹងពិរុទ្ធភាពរបស់ជនជាប់ចោទក៏ដោយ[207]។

107. នៅក្នុងសំណុំរឿង ០០២/០១ អង្គជំនុំជម្រះសាលាដំបូងបានពិចារណាទៅលើកាលៈទេសៈនៃការបង្កើត និងប្រភព និងមូលហេតុរបស់អ្នកនិពន្ធអត្ថបទ នៅពេលអង្គជំនុំជម្រះវាយតម្លៃលើតម្លៃជាភស្តុតាងរបស់ឯកសារទាំងនោះ[208]។ នៅក្នុងរឿងក្តីបច្ចុប្បន្ន សហមេធាវីនាំមុខទទូចឱ្យអង្គជំនុំជម្រះសាលាដំបូងអនុវត្តបទដ្ឋានប្រហាក់ប្រហែលគ្នា ដោយពិចារណាទៅលើកត្តាទាំងឡាយដែលពួកគេបានលើកឡើង ដែលអាចជួយដល់ការវាយតម្លៃភាពដែលអាចជឿជាក់បាននៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ នៅក្នុងសារណានេះ សហមេធាវីនាំមុខពន្យល់បង្ហាញកត្តាទាំងឡាយដែលពាក់ព័ន្ធនឹងការវាយតម្លៃលើតម្លៃជាភស្តុតាងនៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ នៅចុងបញ្ចប់ សហមេធាវីនាំមុខនឹងផ្តោតយ៉ាងទូលំទូលាយទៅលើបញ្ហាពាក់ព័ន្ធនឹងប្រភព និងគុណភាពនៃសក្ខីកម្ម និងឯកសារដែលត្រូវបានផ្តល់ជូនដោយដើមបណ្តឹងរដ្ឋប្បវេណី។

108. សហមេធាវីនាំមុខសូមលើកឡើងថា ប្រការនេះមិនគ្រាន់តែបង្កើនទម្ងន់នៃភស្តុតាងជាឯកសារប៉ុណ្ណោះទេ គឺថែមទាំងផ្តល់បរិបទសម្រាប់ការវាយតម្លៃភាពដែលអាចជឿជាក់បាននៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជាពិសេស ពេលដើម្បបណ្តឹងរដ្ឋប្បវេណីទាំងនោះត្រូវបានសួរតទល់ដោយភាគីផ្សេងៗទៀត ដោយរួមទាំងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងឯកសារគាំទ្រដែលពួកគេបានដាក់។

109. ដើម្បីឱ្យងាយស្រួលក្នុងការពិនិត្យកត្តាដាច់ដោយឡែករបស់ភស្តុតាងទាំងនោះ ភស្តុតាងជាឯកសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី អាចត្រូវបែងចែកជាបួនប្រភេទឯកសារ (i) ពាក្យសុំតាំងខ្លួនជាដើម

---

[206] សាលដីកាសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៣១៥។

[207] សាលដីកាសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៣១១-៣១៥។

[208] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ៣៤។

បណ្ដឹងរដ្ឋប្បវេណី (ii) ព័ត៌មានបន្ថែម (iii) កំណត់ហេតុស្ដាប់ចម្លើយរបស់សហចៅក្រមស៊ើបអង្កេត និង (iv) ឯកសារគាំទ្រ និង/ឬ ឯកសារដែលត្រូវបានដាក់ជូននៅពេលជាមួយគ្នា ដែលជាផ្នែកមួយនៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីរបស់ពួកគេ។

110. ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី គឺជាឯកសារដែលមានទម្រង់ស្តង់ដារដែលអាចត្រូវបំពេញដោយដើមបណ្ដឹងរដ្ឋប្បវេណី ឬបុគ្គលដែលតំណាងដើមបណ្ដឹងរដ្ឋប្បវេណី[209]។ បន្ទាប់ពីបំពេញពាក្យសុំបានត្រឹមត្រូវ ពាក្យសុំនោះត្រូវចុះហត្ថលេខា ឬផ្ដិតមេដៃដោយដើមបណ្ដឹងរដ្ឋប្បវេណីដោយផ្ទាល់។ ពាក្យសុំនោះក៏មានហត្ថលេខារបស់សាក្សីឯករាជ្យ និងអ្នកតំណាងដើមបណ្ដឹងរដ្ឋប្បវេណីប្រសិនបើមាន[210]។

111. អង្គជំនុំជម្រះសាលាដំបូងផ្ដល់តម្លៃជាភ័ស្តុតាងមានកម្រិតដល់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី[211]។ ក្រុមមេធាវីការពារក្ដីមានសេរីភាពប្រើប្រាស់ពាក្យសុំទាំងនេះ ក្នុងអំឡុងពេលសួរដេញដោល ដើម្បីសួរតទល់ និងបញ្ជាក់អំពីអង្គហេតុដែលត្រូវបានផ្ដល់នៅក្នុងតុលាការ ដែលនេះ

---

[209] សេចក្ដីណែនាំអនុវត្តស្ដីពីការចូលរួមរបស់ជនរងគ្រោះ ០២/២០០៧/ វិសោធនកម្ម ១ មាត្រា ៣-៤។

[210] *សូមមើល* ផ្នែក ឃ នៃទំរង់បែបបទពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។

[211] គោលការណ៍ណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីការដាក់បង្ហាញពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសំណុំរឿង ០០៣ និង ០០៤ នៅក្នុងសំណុំរឿង ០០២/០២ ឯកសារ **E319/14/2** ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១៥ កថាខណ្ឌ ៤៖ "អង្គជំនុំជម្រះសូមរំលឹកដល់ភាគីថា ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីមានតម្លៃជាភ័ស្តុតាងតិចជាងកំណត់ហេតុនៃការស្ដាប់ចម្លើយ ហើយអង្គជំនុំជម្រះក៏បានសំអាងលើតែពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសាលក្រមលើសំណុំរឿង ០០២/០១ ដើម្បីផ្ទៀងផ្ទាត់ភ័ស្តុតាងផ្សេងទៀតតែប៉ុណ្ណោះទេ"។ *សូមមើលផងដែរ* សេចក្ដីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្ដាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ **E96/7** ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ២៩។ *សូមមើលបន្ថែម* សេចក្ដីសម្រេចលើការជំទាស់ទៅនឹងឯកសារទាំងឡាយដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះក្នុងសំណុំរឿង ០០២/០២ ឯកសារ **E305/17** ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០១៥ កថាខណ្ឌ ២៥។ សេចក្ដីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនៅក្នុងឧបសម្ព័ន្ធ A6-A11 និង A14-A20 របស់សហព្រះរាជអាជ្ញា និងឯកសារដែលបានស្នើឡើងដោយភាគីផ្សេងទៀត ឯកសារ **E185/1**កថាខណ្ឌ ១៣។

គឺជាសិទ្ធិអំណាចដែលពួកគេបានប្រើប្រាស់ជាញឹកញាប់ សូម្បីតែពាក់ព័ន្ធនឹងកាលៈទេសៈ ដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានកត់ត្រា[212]។

112. វិធានផ្ទៃក្នុងតម្រូវឲ្យ "ពាក្យសុំ ត្រូវមានព័ត៌មានលម្អិតស្តីពីឋានៈជាជនរងគ្រោះ ត្រូវរៀបរាប់ជាក់លាក់អំពីបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ និងភ្ជាប់ជាមួយនូវភ័ស្តុតាងនៃព្យសនកម្មដែលទទួលរង ឬដែលបង្ហាញនូវពិរុទ្ធភាពរបស់ចារីដែលត្រូវបានចោទប្រកាន់"[213]។ តែទោះជាយ៉ាណាក៏ដោយ ចាប់តាំងពីពេលនោះ រហូតមកដល់ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ចរិតលក្ខណៈ និងវិសាលភាពជាក់លាក់ នៃបទចោទប្រកាន់ព្រហ្មទណ្ឌ មិនត្រូវបានលាតត្រដាងនៅឡើយ ពីព្រោះដីកាដំណោះស្រាយ មិនទាន់ត្រូវបានដាក់ចេញនៅឡើយ។ ករណីនេះកាត់បន្ថយគុណភាពព័ត៌មានដែលដើមបណ្តឹងរដ្ឋប្បវេណីអាចកត់ត្រា និង/ឬផ្តោតចំពោះ នៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ខ្លួន ពីព្រោះវិសាលភាពនៃបទឧក្រិដ្ឋដែលត្រូវចោទប្រកាន់ ដែលគេអាចលើកឡើងនៅក្នុងពាក្យសុំរបស់គេ មិនទាន់ត្រូវបានលាតត្រដាងឲ្យដឹងនៅឡើយទេ។

113. លើសពីនេះទៅទៀត ព័ត៌មានភាគច្រើននៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានសរសេរដោយសមាជិក និង/ឬបុគ្គលិករបស់អង្គការមិនមែនរដ្ឋាភិបាលនានា។ មានអង្គការមិនមែនរដ្ឋាភិបាលចំនួន ១១ ចូលរួមពាក់ព័ន្ធនឹងការងារទាំងនេះ[214] ហើយពាក្យសុំទាំងនោះត្រូវបានដាក់ជូនតាមរយៈអង្គការមិនមែនរដ្ឋាភិបាលទាំងនេះ។ សហមេធាវីនាំមុខ មិនមានទិន្នន័យអំពីចំនួនពាក្យសុំដែលត្រូវបានដាក់ជូនតាមរយៈអង្គការមិនមែនរដ្ឋាភិបាលនីមួយៗនោះឡើយ ក៏ប៉ុន្តែសហមេធាវីនាំមុខ មានព័ត៌មានស្តីពីពាក្យសុំដែលត្រូវបានទទួលយកដោយសហចៅក្រមស៊ើបអង្កេត ឬដោយអង្គបុរេជំនុំជម្រះ[215]។ អង្គការមិនមែនរដ្ឋាភិបាលនីមួយៗ មានលក្ខខណ្ឌ

[212] *សូមមើល ឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/252.1** ទំព័រ ១១-១២ (មេធាវីការពារក្តី នួន ជា) ទំព័រ ១៩-២០ (មេធាវីការពារក្តី ខៀវ សំផន)។ ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ១៧-១៩ (មេធាវីការពារក្តី ខៀវ សំផន)។

[213] វិធានផ្ទៃក្នុង ២៣ *ស្ទួន* (៤)។

[214] FIDH KID ADHOC KKHRA មានសិទ្ធិចូលទៅកាន់ Justice Asia DC-CAM CDP ASF France CJR CVKR ASRIC។

[215] FIDH (ក្នុងចំណោមពាក្យសុំសរុបដែលបានដាក់តាមរយៈពួកគេ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៤ នាក់ត្រូវបានទទួលយក) KID (ក្នុងចំណោមពាក្យសុំសរុបដែលបានដាក់តាមរយៈពួកគេ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៧៩២ នាក់ត្រូវបានទទួលយក) ADHOC (ក្នុងចំណោមពាក្យសុំសរុបដែលបានដាក់តាមរយៈពួកគេ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៨១៩ នាក់ត្រូវបានទទួល

សម្រាប់បុគ្គលិករបស់ខ្លួន ការគ្រប់គ្រងគុណភាព សមត្ថភាពបណ្តុះបណ្តាល និងកម្រិតធនធានហិរញ្ញវត្ថុ ដោយឡែកៗពីគ្នា។

114. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួន ត្រូវបានដាក់ជូនតាមរយៈក្រុមផ្សព្វផ្សាយរបស់អង្គភាពគាំពារជនរងគ្រោះនៃ អ.វ.ត.ក. [216]។ ក៏ប៉ុន្តែ មិនមានបណ្តាញផ្សព្វផ្សាយដែលមានលក្ខណៈឯកភាពគ្នាតែមួយនៅ អ.វ.ត.ក. នោះឡើយ ដើម្បីសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលទាំងនេះ និង/ឬ ដើម្បីធ្វើឱ្យមានស្តង់ដារសម្រាប់មធ្យោបាយ និង/ឬ កិច្ចដំណើរការ សម្រាប់កត់ត្រាព័ត៌មាននៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី សម្រាប់សំណុំរឿង ០០២ នោះឡើយ។

115. ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចាប់ផ្តើមធ្វើឡើងនៅដើមឆ្នាំ២០០៧[217]។ ប្រហែលមួយភាគបួននៃដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានទទួលយក បានដាក់ពាក្យសុំរបស់ពួកគេនៅឆ្នាំ ២០០៧-២០០៨[218] នៅពេលដែលវិសាលភាពនៃការស៊ើបអង្កេតមិនទាន់ត្រូវបានកំណត់ទាំងស្រុង។

---

យក) KKHRA (ក្នុងចំណោមពាក្យសុំសរុបដែលបានដាក់តាមរយៈពួកគេ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៩៤ នាក់ត្រូវបានទទួលយក) មានសិទ្ធចូលទៅកាន់ Justice Asia (ក្នុងចំណោមពាក្យសុំសរុបដែលបានដាក់តាមរយៈពួកគេ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៧ នាក់ត្រូវបានទទួលយក) DC-CAM (ក្នុងចំណោមពាក្យសុំសរុបដែលបានដាក់តាមរយៈពួកគេ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៣៨ នាក់ត្រូវបានទទួលយក) CDP (ក្នុងចំណោមពាក្យសុំសរុបដែលបានដាក់តាមរយៈពួកគេ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤៩ នាក់ត្រូវបានទទួលយក) ASF France (ក្នុងចំណោមពាក្យសុំសរុបដែលបានដាក់តាមរយៈពួកគេ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៨ នាក់ត្រូវបានទទួលយក) CJR (ក្នុងចំណោមពាក្យសុំសរុបដែលបានដាក់តាមរយៈពួកគេ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៥៩ នាក់ត្រូវបានទទួលយក) CVKR (ក្នុងចំណោមពាក្យសុំសរុបដែលបានដាក់តាមរយៈពួកគេ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២០ នាក់ត្រូវបានទទួលយក) (ក្នុងចំណោមពាក្យសុំសរុបដែលបានដាក់តាមរយៈពួកគេ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤១ នាក់ត្រូវបានទទួលយក)។

[216] មានពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១៤៨ ដែលត្រូវបានដាក់តាមរយៈក្រុមការងារចុះមូលដ្ឋានរបស់អង្គភាពជនរងគ្រោះរបស់ អ.វ.ត.ក។

[217] ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីទាំងនោះដែលត្រូវបានទទួលយក មានដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រហែល ៦៥ នាក់ដែលបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគេនៅក្នុងឆ្នាំ ២០០៧។

[218] ដើមបណ្តឹងរដ្ឋប្បវេណីដែលបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងឆ្នាំ ២០០៧ មានចំនួន ៦៥ នាក់។ ដើមបណ្តឹងរដ្ឋប្បវេណីដែលបានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងឆ្នាំ ២០០៨ មានចំនួន ៨៤៩ នាក់។

116. បញ្ហាប្រឈមនានាដែលត្រូវបានលើកឡើងខាងលើ មានកម្រិតកាន់តែធ្ងន់ធ្ងរសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលបំពេញទម្រង់ពាក្យសុំដោយខ្លួនឯង។ ក្រុមនេះ មានដើមបណ្តឹងរដ្ឋប្បវេណី ចំនួន ៤៩៤ នាក់។

117. បញ្ហាទាំងនេះត្រូវបានកាត់បន្ថយបានមួយកម្រិត នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានស្តាប់ចម្លើយដោយអ្នកស៊ើបអង្កេតមកពីការិយាល័យសហចៅក្រមស៊ើបអង្កេត (ក.ស.ច.ស.)។ អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា សេចក្តីថ្លែងការណ៍ទាំងនេះនៅតែទទួលបានការសន្មតថាមានភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន[219]។

118. អង្គជំនុំជម្រះសាលាដំបូងបានពិចារណាលើកត្តាខាងក្រោម នៅពេលវាយតម្លៃ តម្លៃជាភស្តុតាងនៃកំណត់ហេតុស្តាប់ចម្លើយរបស់ ក.ស.ច.ស គឺ “ថាតើភស្តុតាងនេះ (ក) មានចរិតលក្ខណៈត្រួតគ្នាដែលនៅក្នុងនោះសាក្សីដ៏ទៃទៀតនឹងផ្តល់ ឬបានផ្តល់រួចហើយនូវសក្ខីកម្មផ្ទាល់មាត់លើអង្គហេតុស្រដៀងគ្នា (ខ) មានការទាក់ទងនឹងសាវតារជាប្រវត្តិសាស្ត្រ ជានយោបាយ ឬជាយោធា ដែលពាក់ព័ន្ធទៅនឹងភស្តុតាងនៃកន្លែងដែលបទឧក្រិដ្ឋបានកើតឡើង ឬផ្តល់សក្ខីកម្មអំពីកម្រិតធាតុផ្សំនៃបទឧក្រិដ្ឋកម្មអន្តរជាតិ (ដូចជា អត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ឬចរិតលក្ខណៈនៃការវាយប្រហារជាទូទៅ ឬជាលក្ខណៈប្រព័ន្ធ) (គ) មានការវិភាគមួយជាទូទៅ ឬជាស្ថិតិ ស្តីពីសមាសភាពជាតិពន្ធុនៃប្រជាជននៅតាមទីកន្លែងនានាដែលមានការទាក់ទងដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ (ឃ) ពាក់ព័ន្ធនឹងផលប៉ះពាល់នៃឧក្រិដ្ឋកម្មទៅលើជនរងគ្រោះ (ង) មិនអាចដាក់ឱ្យស្ថិតឱ្យមានការតទល់គ្នា ពីព្រោះក្រោយមក សាក្សីផ្តល់ចម្លើយនោះបានស្លាប់ ឬមិនអាចតាមរកឃើញទោះបីជាមានការខិតខំប្រឹងប្រែងយ៉ាងសមស្របក៏ដោយ ឬមានបញ្ហាសុខភាពដែលមិនអាចមកផ្តល់សក្ខីកម្មដោយផ្ទាល់មាត់បាន”[220]។

[219] សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E96/7 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ២៦។

[220] សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E96/7 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ២២។

119. អង្គជំនុំជម្រះសាលាដំបូងបានទទួលស្គាល់ថា នៅពេលបុគ្គលដែលត្រូវបានធ្វើសម្ភាសដោយ ក.ស.ច.ស មិនត្រូវបានកោះហៅមកផ្តល់សក្ខីកម្ម សេចក្តីថ្លែងការណ៍ជាលាយលក្ខណ៍អក្សររបស់ពួកគេអាចត្រូវបានផ្តល់តម្លៃជាភស្តុតាង ឬទម្ងន់ "តិចតួច ប្រសិនបើមាន" ដោយសារមិនមានឱកាសសម្រាប់ធ្វើការសួរតទល់ ឬដោយសារមានកង្វះខាតគួរឲ្យកត់សម្គាល់នៅក្នុងសេចក្តីថ្លែងការណ៍ទាំងនេះ[221]។ ការកំហិតដែលមានចំពោះសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដោយផ្អែកទៅលើសេចក្តីថ្លែងការណ៍ទាំងនេះ គឺថា សេចក្តីថ្លែងការណ៍ទាំងនេះមិនមែនជាមូលដ្ឋានតែមួយគត់សម្រាប់ធ្វើជាសំអាងហេតុពាក់ព័ន្ធនឹងអំពើ និងការប្រព្រឹត្តិរបស់ជនជាប់ចោទនោះឡើយ។

## ខ. បញ្ហាពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណឯកសារ

120. ក្នុងអំឡុងពេលសួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងតុលាការ បញ្ហាពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណបានកើតឡើង។ សហមេធាវីនាំមុខគូសបញ្ជាក់ថា សម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលផ្តល់សក្ខីកម្ម អត្តសញ្ញាណរបស់ពួកគេត្រូវបានបញ្ជាក់ដោយសហចៅក្រមស៊ើបអង្កេត នៅពេលធ្វើការសម្រេចទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគេ និងនៅក្នុងតុលាការផងដែរ នៅពេលប្រធានអង្គជំនុំជម្រះ សួរសំណួរផ្តើមដល់ពួកគេ។

121. ជាញឹកញាប់ និងដោយសារហេតុផលផ្សេងៗជាច្រើន អត្តសញ្ញាណប័ណ្ណ មានព័ត៌មានដែលមិនស៊ីសង្វាក់ជាមួយនឹងព័ត៌មានដែលត្រូវបានផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគេ ឬនៅក្នុងតុលាការ ជាពិសេស ពាក់ព័ន្ធនឹងកាលបរិច្ឆេទកំណើត[222]។ ភាពខុសគ្នានៃកាលបរិច្ឆេទត្រូវបានពន្យល់ដោយដើមបណ្តឹងរដ្ឋប្បវេណីមួយរូបថា

[221] សេចក្តីសម្រេចលើសំណើសុំរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សី និងឯកសារនានានៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឯកសារ E96/7 ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១២ កថាខណ្ឌ ២៧។

[222] *សូមមើលឧទាហរណ៍* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវិដា ចុះថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ E1/308.1 ទំព័រ ៤ បន្ទាត់ ២០ - ទំព័រ ៥ បន្ទាត់ ៨៖ "សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖ សូមអរគុណ លោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់។ សៈ ជម្រាបសួរលោកស្រី សៀង សុវិដា។ នៅព្រឹកនេះ ខ្ញុំនឹងសួរសំណួរមួយចំនួនទៅកាន់លោកស្រី។ សំណួរទី១ គឺខ្ញុំចង់សុំបំភ្លឺ លោកស្រីឆ្លើយជូនលោកប្រធានថា លោកស្រីកើតនៅឆ្នាំ ១៩៦៤ ក៏ប៉ុន្តែនៅពេលដែលយើងអានអត្តសញ្ញាណប័ណ្ណលោកស្រី ដែលភ្ជាប់ទៅនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

បណ្តាលមកពីការគណនាកាលបរិច្ឆេទកំណើតខុសតាមរយៈការប្រើប្រាស់ប្រតិទិនចិន[223] ឬដោយសារការភ្លេចភ្លាំង។ ករណីបែបនេះ មិនមែនកើតឡើងចំពោះតែដើមបណ្តឹងរដ្ឋប្បវេណីនោះឡើយ

---

នោះ គឺឯកសារ D22/2531 ក្នុងនោះគេដាក់ថ្ងៃខែឆ្នាំកំណត់លោកស្រីគឺ ១៩៦៧។ អ៊ីចឹងលោកស្រីអាចបញ្ជាក់ជូនបានទេថា ហេតុអ្វីបានជាអត្តសញ្ញាណប័ណ្ណរបស់លោកស្រីគឺឆ្នាំ ១៩៦៧ ហើយអម្បាញ់មិញនេះ លោកស្រីឆ្លើយជូនលោកប្រធានថាឆ្នាំ ១៩៦៤? អ៊ីចឹងតើមួយណាដែលត្រឹមត្រូវដែរលោកស្រី? លោកស្រី សៀង សុរិដា៖ ឆ៖ ចាស ជម្រាបសួរ។ ពេលដែលនាងខ្ញុំចេញពីភ្នំពេញមក ពេលចេញពីរបប ប៉ុល ពត មក នាងខ្ញុំជាកូនកំព្រា រស់នៅជាមួយឪពុកមា និងម្តាយមីងរបស់នាងខ្ញុំ គាត់ដាក់ប្រវត្តិរូប ហើយឈ្មោះអីគាត់ដូរ ដាក់តាមជាខ្មែរ ហើយគាត់ដាក់តាមឱ្យសមស្របនឹងកូនរបស់គាត់ មិនឱ្យឃ្លាតឆ្ងាយពីហ្នឹងពេក។ តែដល់ឆ្នាំពិតប្រាកដនាងខ្ញុំ គឺកើតឆ្នាំ ១៩៦៤ ជាឆ្នាំពិតប្រាកដ។ ហើយប្រើរាល់ថ្ងៃនេះគឺ ១៩៦៧។ នេះជាការពិតប្រាកដរបស់នាងខ្ញុំ"។ *សូមមើលផងដែរ* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី ២ ខែ កញ្ញាឆ្នាំ ២០១៥ ឯកសារ **E1/340.1** ទំព័រ ៤-៥ បន្ទាត់ ១១-៤៖ "លោក ឡោ ជុនធី៖ បាទ សូមអគុណលោកប្រធាន។ ដំបូងខ្ញុំបាទសូមគោរពអង្គជំនុំជម្រះទាំងមូល។ ខ្ញុំបាទ ឡោ ជុនធី ដែលជាមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ នៅពេលនេះ ខ្ញុំបាទសូមសួរសំណួរទៅលើលោក សម ស័ក្ត ដែលនឹងថ្លែងអំពីទុក្ខសោកក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលពិសេសផ្តែកពាក់ព័ន្ធទៅនឹងទំនប់ត្រពាំងថ្ម។ ស៖ ជាដំបូង ខ្ញុំសូមសួរបញ្ជាក់លោកបន្តិចពាក់ព័ន្ធនឹងលោកបានឆ្លើយអម្បាញ់មិញថា លោកកើតនៅភូមិភ្នំពីរស្វាយទង មាត់ជ្រូក ប៉ុន្តែអ្វីដែលនៅក្នុងអត្តសញ្ញាណប័ណ្ណរបស់លោកបានដាក់ថា "ស្រុកកំណត់ នៅឃុំតាអូ ស្រុកគីរីវង់ ខេត្តតាកែវ វិញ" ចំណុចនេះ លោកអាចបញ្ជាក់ជូនអង្គជំនុំជម្រះបានទេ? លោក សម ស័ក្ត៖ ឆ៖ បាទ អគុណ។ ខ្ញុំពិតជាកំណើតកើតជានៅកម្ពុជាក្រោមពិតមែន ក៏ប៉ុន្តែខ្ញុំមករស់នៅក្នុងទឹកដីស្រុកគីរីវង់នេះតាំងពីយូរមក រៀននៅស្រុកគីរីវង់ ពេលនោះ ខ្ញុំបានចូលធ្វើជាកងទ័ព ខ្ញុំក៏កែប្រែស្រុកកំណើតរបស់ខ្ញុំឱ្យទៅជាភូមិរបស់ប្រពន្ធខ្ញុំវិញ បាទ។ ស៖ តើមានហេតុផលអីដែលអត់ទេ បានជាលោកសម្រេចដាក់ការកែប្រែនេះ? ឆ៖ បាទ កាលនោះ ខ្ញុំធ្វើជាកងទ័ពអ៊ីចឹង ខ្ញុំមិនចង់ឱ្យគេដឹងថា ខ្ញុំជាខ្មែរក្រោម ក៏ខ្ញុំដាក់នៅជាខ្មែរលើវិញ"។

[223] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៥៥-៥៦ បន្ទាត់ ១៤-៥ ៖ "ស៖ ជាដំបូង ខ្ញុំបាទសុំបញ្ជាក់បន្តិចដែលអ្នកស្រីបញ្ជាក់ជូនលោកប្រធានអម្បាញ់មិញ ពាក់ព័ន្ធទៅនឹងថ្ងៃខែឆ្នាំកំណើតរបស់លោកស្រី ៗថា តើថ្ងៃខែឆ្នាំកំណើតដែលលោកស្រីបានដាក់នៅក្នុងអត្តសញ្ញាណប័ណ្ណ ហើយនិងអ្វីដែលលោកស្រីបាននិយាយអម្បាញ់មិញ វាជាការមួយដែលយើងពីមុនមកមានហេតុការណ៍អីបានយើងដាក់ទៅតាមនុ៎ង? លោកស្រី ព្រាប សុឃឿន៖ ឆ៖ ចាស ខ្ញុំសូមឆ្លើយ។ កាលដែលខ្ញុំបានធ្វើអត្តកាលពីឆ្នាំដែលគេធ្វើឆ្នាំមុននុ៎ង ខ្ញុំបានប្រាប់ខែឆ្នាំគេថា ខ្ញុំកើតនៅឆ្នាំរក ប៉ុន្តែខ្ញុំអត់ដឹងថាកើតនៅខែអីទេ។ អ៊ីចឹងអ្នកសរសេរគាត់ថា អ៊ីចឹងគិតមើលកើតខែណា។ អាហ្នឹងក៏យើងនិយាយពីរដូវកាលប្រាប់គាត់។ ដល់អ៊ីចឹងគាត់ដាក់តាមថ្ងៃខែឆ្នាំហ្នឹងឱ្យទៅ។ អ៊ីចឹងគឺថា ខ្ញុំអត់ចេះអី គឺខ្ញុំទទួលយកពីនុ៎ងមកប្រើប្រាស់ទល់សព្វថ្ងៃ។ ស៖ បាទអគុណ។ អ៊ីចឹងមានន័យថា ការអ្វីដែលការកត់ត្រានៅក្នុងអត្តសញ្ញាប័ណ្ណ ហើយនិងអាយុពិតវាខុសគ្នា ឬមួយយ៉ាងម៉េច? ឆ៖ ចាស បើខ្ញុំរាប់ទៅតាមក្នុងអត្ត ខ្ញុំកើតនៅថ្ងៃទី ១២ ខែ ១០ ឆ្នាំ ១៩៥១ និងខ្ញុំកើត គឺអត្តបងៗអាយុខ្ញុំ ខ្ញុំប្អូនទេ ព្រោះខ្ញុំកើតឆ្នាំរក។ ស៖ តើឆ្នាំនេះ អ្នកស្រីអាយុប៉ុន្មានហើយ? ឆ៖ ចាស ខ្ញុំបើរាប់ទៅតាមរដូវកាលនៃឆ្នាំខ្ញុំគិតស្មើនឹងសព្វថ្ងៃ ៦២ ឆ្នាំ"។ *សូមមើលបន្ថែម* ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ២-៣។

ករណីបែបនេះក៏កើតមានឡើងចំពោះសាក្សីមួយចំនួនផងដែរ[224]។ជួនកាល មានការយល់ច្រឡំអំពីឯកសារបញ្ជាក់អត្តសញ្ញាណដែលដើមបណ្តឹងរដ្ឋប្បវេណីបានភ្ជាប់ជាមួយនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគេ[225]។ ចំណុចដែលគួរឲ្យកត់សម្គាល់ផងដែរគឺដើមបណ្តឹងរដ្ឋប្បវេណីមួយរូបបានផ្តល់សក្ខីកម្មថា ឯកសារបញ្ជាក់អត្តសញ្ញាណដើមរបស់គាត់ត្រូវបានបំផ្លាញក្នុងអំឡុងរបបនោះ[226] ហើយដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀតបានផ្តល់សក្ខីកម្មថា ស្វាមីរបស់គាត់មិនមានឯកសារបញ្ជាក់អត្តសញ្ញាណក្នុងអំឡុងរបបនោះនៅពេលនោះឡើយ[227]។

122. ភាពខុសគ្នាស្រដៀងគ្នានេះត្រូវបានលើកឡើងនៅក្នុងតុលាការ ពាក់ព័ន្ធទៅនឹងឈ្មោះ និងឈ្មោះហៅក្រៅ ដែលត្រូវបានប្រើនៅពេលមុន ក្នុងអំឡុង និងក្រោយ របបកម្ពុជាប្រជាធិបតេយ្យ[228]។ ដើមបណ្តឹងរដ្ឋប្បវេណី លី ហួរ ទទួលនូវផលវិបាកយ៉ាងធ្ងន់ធ្ងរ ដោយសារតែកំហុសអក្ខរាវិរុទ្ធនៅក្នុងឯកសារបញ្ជាក់អត្តសញ្ញាណរបស់គាត់។ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ត្រូវបានបដិសេធដោយអង្គជំនុំជម្រះសាលាដំបូងដោយសារមូលហេតុកំហុសអក្ខរាវិរុទ្ធ ក៏ប៉ុន្តែការបដិសេធនេះត្រូវបានផ្លាស់ប្តូរនាពេលក្រោយមក តាមរយៈបណ្តឹងសាទុក្ខ[229]។ នៅក្នុងសំណុំរឿង ០០២ គាត់ប្រឈមនឹងការលំបាកក្នុងការទទួលបានការទាមទារសំណងសម្រាប់អ្នកស្នងរបស់គាត់[230]។

---

[224] *សូមមើលឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ៩ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/365.1** ទំព័រ ៣៥ បន្ទាត់ ៤-១៩។ ប្រតិចារឹក ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/373.1** ទំព័រ ៩-១០ បន្ទាត់ ១៧-១៩។ ប្រតិចារឹក ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/377.1** ទំព័រ ៧ បន្ទាត់ ១៥-២២។ ប្រតិចារឹក ថ្ងៃទី ៩ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/398.1**ទំព័រ ២-៤ បន្ទាត់ ២៤-១១។

[225] ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ១៥-១៦ បន្ទាត់ ១-១៣។

[226] ប្រតិចារឹក ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/262.1** ទំព័រ ៩ បន្ទាត់ ១៥-១៨។

[227] ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ១១ បន្ទាត់ ១៣-១៦។

[228] *សូមមើលឧទាហរណ៍* ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ៧-៨ បន្ទាត់ ១០-៥។ ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី បានពន្យល់ថា គាត់បានប្រើប្រាស់ឈ្មោះ "ជុំ ម៉ាញ" ហៅ ម៉ី ក្នុងអំឡុងរបបនេះ ហើយឈ្មោះនេះមាននៅក្នុងបញ្ជីអ្នកទោសរបស់ ក.ស.ព និងបញ្ជីមួយក្នុងចំណោមបញ្ជីផ្សេងៗទៀត ឯកសារ **E3/342** លេខ ១៥៨៣។

[229] *សូមមើលឧទាហរណ៍* ចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសំណើលើកទីបួនរបស់ នួន ជា ស្តីពីមន្ទីរសន្តិសុខ និងការបោសសម្អាតផ្ទៃក្នុង ឯកសារ **E412/1** ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០១៦ កថាខណ្ឌ ៧ និងកថាខណ្ឌ ៩។

[230] *សូមមើល* ឧបសម្ព័ន្ធ I៖ លិខិតដែលទទួលបានពីអ្នកដាក់ពាក្យប្តឹង និងអ្នកគ្រប់គ្រងពាក្យសុំផ្ញើទៅកាន់អង្គភាពគាំពារជនរងគ្រោះ ឯកសារ **E412/1.1** ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០១៦ ទំព័រ ១។

123. សហមេធាវីនាំមុខ លើកឡើងថា ក្រុមមេធាវីការពារក្តី មានសិទ្ធិសួរដេញដោល និងតទល់ជាមួយនឹងដើមបណ្តឹងរដ្ឋប្បវេណី អំពីភាពខុសគ្នានៃព័ត៌មានអំពីអត្តសញ្ញាណរបស់ពួកគេដែលពួកគេបានផ្តល់ជូន។ អាស្រ័យហេតុនេះ សហមេធាវីនាំមុខ ទទួចថា ការពន្យល់ដោយដើមបណ្តឹងរដ្ឋប្បវេណីអំពីភាពខុសគ្នាបែបនេះ អាចនឹងត្រូវយកមកពិចារណា នៅពេលធ្វើការវាយតម្លៃ ថាតើភាពខុសគ្នាទាំងនេះប៉ះពាល់ភាពអាចជឿជាក់នៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំងមូលដែរឬទេ[231]។ ភាគច្រើន ភាពល្អៀងខុសគ្នាបន្តិចបន្តួចបែបនេះ មិនធ្វើឲ្យសក្ខីកម្មទាំងមូល (ឬមួយផ្នែក) បាត់បង់ភាពអាចជឿជាក់បាននោះឡើយ ហើយអង្គជំនុំជម្រះសាលាដំបូងនៅតែអាចយកសក្ខីកម្មទាំងនេះធ្វើជាមូលដ្ឋាន ដើម្បីធ្វើការសំអាងទាំងលើអង្គហេតុ និងអង្គច្បាប់។

## គ. ពេលវេលាកន្លង

124. ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្ម ៤០ឆ្នាំក្រោយពេលព្រឹត្តិការណ៍ពាក់ព័ន្ធនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់[232] បានកើតឡើង ហើយរម្លឹកព័ត៌មានដែលពួកគេបានចងចាំ និងកត់ត្រាទុក

[231] សូមមើលឧទាហរណ៍ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Jean-Pierre Bemba Gombo Bemba* សាលក្រមអនុលោមតាមមាត្រា ៧៤ នៃលក្ខន្តិកៈ ICC-01/05-01/08-3343 ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ៤៩២ ដែលអង្គជំនុំជម្រះបានពិចារណាលើភាពមិនស៊ីសង្វាក់គ្នានៅក្នុងសក្ខីកម្មរបស់សាក្សី និងបានមើលទៅលើរបៀបដែលសក្ខីកម្មទាំងនោះអាចត្រូវបានពន្យល់ដោយហេតុផល "ក្នុងអំឡុងពេលរវាងព្រឹត្តិការណ៍ និងសក្ខីកម្ម កាលៈទេសៈ និងផលលំបាករបស់គាត់ដែលពិភាក្សាអំពីទិដ្ឋភាពផ្ទាល់ខ្លួនបែបនេះនៅក្នុងតុលាការ"។ អង្គជំនុំជម្រះបានរកឃើញភាពមិនស៊ីសង្វាក់គ្នាដែលមិន"រារាំង"ដល់ភាពជឿទុកចិត្តរបស់គាត់។

[232] *សូមមើលឧទាហរណ៍* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជួ គឹមឡុន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/252.1** ទំព័រ ៤៨។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ញឹម ហាល់ ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ **E1/336.1** ទំព័រ ១២-១៣។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ១២-១៥។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ១៨-១៩ ទំព័រ ៣៣ ទំព័រ ៤៣-៤៤ និងទំព័រ ៤៨-៤៩។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៥៨-៥៩។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/412.1** ទំព័រ ៤៨។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៥០-៥១។

រយៈពេលជាង៥ឆ្នាំកន្លងទៅ[233]។ គេដឹងថា អង្គជំនុំជម្រះសាលាដំបូងផ្ដល់ការអនុញ្ញាតចំពោះអង្គហេតុដែលត្រូវបានរម្លឹកបន្ទាប់ពីពេលវេលាដ៏វែងបានកន្លងផុតទៅ ជាពិសេសនៅពេលដែលបុគ្គលទាំងនោះនៅមានវ័យក្មេង នៅពេលព្រឹត្តិការណ៍ទាំងនោះបានកើតឡើង[234] ឬត្រូវបានធ្វើឱ្យភ័យតក់ស្លុតដោយហេតុការណ៍ទាំងនោះ ហើយដោយសារហេតុនេះ "អាចនឹងមានការលំបាកក្នុងការផ្ដល់នូវរឿងរ៉ាវដែលស៊ីសង្វាក់ ពេញលេញ និងសមហេតុសមផល"[235]។

125. សហព្រះរាជអាជ្ញា... 

233 *សូមមើលឧទាហរណ៍* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សុគ្គានី ប្រតិចារិក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ៥២-៥៣។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារិក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/351.1** ទំព័រ ២៤-២៥។

234 *សូមមើលបន្ថែម* រឿងក្ដី *Kunarac និងអ្នកផ្សេងទៀត* សាលក្រម IT-96-23 & 23/1 ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ៥៦៥៖ "សាក្សីជាច្រើនក្នុងចំណោមសាក្សីទាំងនេះជាអនីតិជនក្នុងពេលកើតមានព្រឹត្តិការណ៍ទាំងនោះ ដែលពួកគេបានពិពណ៌នាថា ពួកគេមួយចំនួននៅក្មេងរហូតដល់អាយុដប់ប្រាំឆ្នាំ។ កម្រិតនៃសេចក្ដីលម្អិតពីការរំឭករឿងរ៉ាវដែលរំពឹងថាអាចនឹងទទួលបានពីសាក្សីបែបនេះ មានភាពខុសគ្នាពីរឿងរ៉ាវដែលរំពឹងថានឹងទទួលបានពីសាក្សីដែលមានអាយុច្រើនជាងនេះនៅក្នុងពេលដូចគ្នា។នោះមិនមែនបង្ហាញថា អង្គជំនុំជម្រះសាលាដំបូងតម្រូវឱ្យមានកម្រិតពេញចិត្តទាបណាមួយមុនពេលទទួលយកភស្តុតាងដែលបានមកពីសាក្សីក្មេងៗទាំងនេះនោះទេ"។

235 រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង* *Germain Katanga* សាលក្រមអនុលោមតាមមាត្រា ៧៤ នៃលក្ខន្តិកៈ ICC-01/04-01/07 ចុះថ្ងៃទី ៧ ខែ មីនា ឆ្នាំ ២០១៤ កថាខណ្ឌ ៨៣។ *សូមមើលបន្ថែម* រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង* *Thomas Lubanga Dyilo* សាលក្រមអនុលោមតាមមាត្រា ៧៤ នៃលក្ខន្តិកៈ ICC-01/04-01/06 ចុះថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០១២ កថាខណ្ឌ ១០៣។ រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង* *Mathieu Ngudjolo* សាលក្រមអនុលោមតាមមាត្រា ៧៤ នៃលក្ខន្តិកៈ ICC-01/04-02/12 ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ៤៩។ *សូមមើលបន្ថែម* រឿងក្ដី *Delalić* et al. សាលក្រម IT-96-21-T ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥៩៦៖ "ក្នុងករណីជាច្រើន មានពេលវេលាដ៏គួរឱ្យកត់សម្គាល់រវាងព្រឹត្តិការណ៍ ដែលសាក្សីទាំងនេះកំពុងផ្ដល់សក្ខីកម្ម ការផ្ដល់ចម្លើយជាមុន និងសក្ខីកម្មរបស់ពួកគេនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។ អង្គជំនុំជម្រះសាលាដំបូងទទួលស្គាល់ការលំបាកក្នុងការរំឭកឡើងវិញនូវសេចក្ដីលម្អិតច្បាស់លាស់ ជាច្រើនឆ្នាំបន្ទាប់ពីអង្គហេតុ និងភាពស្ទើរតែមិនអាចទៅរួចទេក្នុងការដែលឱ្យពួកគេរៀបរាប់ឡើងវិញនូវសេចក្ដីលម្អិតតាមលក្ខណៈដូចគ្នានៅគ្រប់ពេលដែលត្រូវបានស្នើសុំឱ្យធ្វើដូច្នេះ"។ *សូមមើលផងដែរ* រឿងក្ដី *Muhimana* សាលក្រម សំណុំរឿងលេខ ICTR- 95-1B-T ចុះថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៥ កថាខណ្ឌ ៦៥។ រឿងក្ដី *Kamuhanda* សាលក្រម សំណុំរឿងលេខ ICTR-95-54A-T ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៤ កថាខណ្ឌ ៣៤-៣៥។

ថ្លែងការណ៍ពីពេលមុននោះឡើយ[236] ដោយបានពន្យល់បន្ថែមថា "តាមរយៈចរិតលក្ខណៈនៃសក្ខីកម្មផ្ទាល់មាត់ សាក្សីអាចនឹងរៀបរាប់បន្ថែមទៅលើរឿងរ៉ាវដែលបានលើកឡើងនៅក្នុងសេចក្តីថ្លែងការណ៍ក្នុងនាមជាសាក្សីរបស់ពួកគេ និងឆ្លើយសំណួរដែលសួរនៅពេលជំនុំជម្រះ កាន់តែក្បោះក្បាយពេញលេញ"។ នៅពេលជំនុំជម្រះ សាក្សីអាចនឹងត្រូវសួរសំណួរដែលមិនធ្លាប់ត្រូវបានសួរពីមុនមក។ ជាងនេះទៅទៀត នៅក្នុងតុលាការ សាក្សីជាច្រើនចងចាំព័ត៌មានលម្អិតដែលពួកគេបានភ្លេចពីពេលមុន"[237]។ ករណីនេះ ពាក់ព័ន្ធទៅនឹងបរិបទនៃភាពខុសគ្នារវាងកាលៈទេសៈដែលពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានធ្វើឡើង និងចរិតលក្ខណៈនៃការសួរដេញដោលដែលគេរំពឹងទុក និងដែលត្រូវធ្វើឡើងនៅក្នុងតុលាការដោយមេធាវីដែលទទួលបានការបណ្តុះបណ្តាល។

## ឃ. បរិបទវប្បធម៌ពិសេសដោយឡែក និងរោគសញ្ញាឈឺចាប់ផ្លូវចិត្ត

126. បញ្ហាវប្បធម៌ ក៏តម្រូវឱ្យអង្គជំនុំជម្រះសាលាដំបូងយកចិត្តទុកដាក់ជាពិសេសចំពោះការលំបាករបស់ដើមបណ្តឹងរដ្ឋប្បវេណី (ជាពិសេសចំពោះអ្នកមិនចេះអក្សរ) នៅពេលពួកគេត្រូវផ្តល់ព័ត៌មានជាក់លាក់អំពីកាលបរិច្ឆេទ ពេលវេលា ចម្ងាយ ទិសដៅ និងទីតាំង។ សហមេធាវីនាំមុខស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងពិចារណាពេញលេញនូវភាពជាក់ស្តែងបែបនេះ មុនពេលធ្វើការសន្និដ្ឋានអវិជ្ជមានពាក់ព័ន្ធនឹងភាពអាចជឿជាក់របស់ដើមបណ្តឹងរដ្ឋប្បវេណីដោយផ្អែកលើត្រឹមតែអ្វីដែលពួកគេមិនបានជួបប្រទះ ពាក់ព័ន្ធនឹងការយល់ដឹងបែបបស្ចិមប្រទេស និងការយល់ដឹងអំពីទស្សនទានទាំងនេះ។

127. កត្តាដ៏សំខាន់មួយក្នុងការវាយតម្លៃភាពស៊ីសង្វាក់នៃសក្ខីកម្មដែលត្រូវបានថតទុក ឬផ្សាយផ្ទាល់ពីដើមបណ្តឹងរដ្ឋប្បវេណី គឺធាតុផ្សំនៃការចងចាំដែលត្រូវបានប៉ះទង្គិចដោយរោគសញ្ញាឈឺចាប់ផ្លូវចិត្ត។ ករណីនេះកើតឡើងជាពិសេសនៅក្នុងកាលៈទេសៈដែលដើមបណ្តឹងរដ្ឋប្បវេណីកំពុងផ្តល់

---

[236] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Moinina Fofana Allieu Kondewa (ជនជាប់ចោទ CDF)* សំណុំរឿងលេខ SCSL-04-14-T សាលក្រម ចុះថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០០៧ កថាខណ្ឌ ២៦២។ សូមមើលបន្ថែម រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Issa Hassan Sesay Morris Kallon និង Augustine Gbao (ជនជាប់ចោទ RUF)* (សាលក្រម) សំណុំរឿងលេខ SCSL-04-15-T ចុះថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០០៧ កថាខណ្ឌ ៤៩១។

[237] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Moinina Fofana Allieu Kondewa (ជនជាប់ចោទ CDF)* សំណុំរឿងលេខ SCSL-04-14-T សាលក្រម ចុះថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០០៧ កថាខណ្ឌ ២៦៣។

សក្ខីកម្មអំពីការចងចាំនូវបទពិសោធន៍ពីអតីតកាលដែលធ្វើឱ្យមានការឈឺចាប់យ៉ាងខ្លាំង ដូចជានៅពេលរម្លឹកអំពីអង្គហេតុពាក់ព័ន្ធនឹងការបាត់បង់សមាជិកគ្រួសារ ការធ្វើទារុណកម្ម ការឈឺចាប់ដ៏ខ្លាំងក្លា ការលំបាកផ្លូវកាយ និងផ្លូវចិត្ត និងការមើលឃើញអំពើហិង្សា ឬសាកសព ដោយផ្ទាល់ភ្នែក។

128. ភស្តុតាងដែលបានមកពីកាលៈទេសៈដែលនាំឱ្យមានការឈឺចាប់ ពុំ "ធ្វើឱ្យភស្តុតាងរបស់សាក្សីមិនមានភាពជឿជាក់"[238] នោះឡើយ។ គេមិនអាចរំពឹងថា អ្នករស់រានមានជីវិតផុតពីបទពិសោធន៍ដែលធ្វើឱ្យឈឺចាប់ អាចរម្លឹកនូវព័ត៌មានលម្អិតអំពីអង្គហេតុសំខាន់ៗ និងពាក់ព័ន្ធទៅនឹងហេតុការណ៍បែបនោះនោះឡើយ[239]។ សហមេធាវីនាំមុខលើកឡើងថា ជាទូទៅ គេដឹងថា "ការរម្លឹកនិងរៀបរាប់ព្រឹត្តិការណ៍ដែលធ្វើឱ្យឈឺចាប់បែបនោះ អាចនឹងបង្កឱ្យមានប្រតិកម្មផ្នែកអារម្មណ៍ និងចិត្តសាស្ត្រយ៉ាងខ្លាំង ដូចជា អារម្មណ៍ឈឺចាប់ អារម្មណ៍ភ័យខ្លាច និងអារម្មណ៍បាត់បង់" ដែលអាច "ធ្វើឱ្យសាក្សីបាត់បង់សមត្ថភាពសំដែងចេញនូវមតិយោបល់ផ្ទាល់ខ្លួនបានច្បាស់ ឬបង្ហាញរឿងរ៉ាវពេញលេញ នៃបទពិសោធន៍របស់ពួកគេ នៅក្នុងបរិបទតុលាការ"[240]។ នៅតុលាការ ICTY អង្គជំនុំជម្រះសាលាដំបូងបានពិចារណាថា "ភាពមិនស៊ីសង្វាក់" បែបនេះ នៅក្នុងកាលៈទេសៈខ្លះ អាច "បង្ហាញនូវភាពគួរឱ្យជឿជាក់បាន និងអវត្តមាននៃការរំខានសាក្សី"[241]។

129. សហមេធាវីនាំមុខលើកឡើងថា ចំពោះដើមបណ្តឹងរដ្ឋប្បវេណីដែលភ្លេច ឬច្រឡំព័ត៌មានលម្អិតតូចៗ គេមិនត្រូវមានការសង្ស័យទៅលើសក្ខីកម្មរបស់ពួកគេពាក់ព័ន្ធនឹងអង្គហេតុចំបងដែលពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មនោះឡើយ ដរាបណាអង្គជំនុំជម្រះសាលាដំបូងធ្វើ "ការវាយតម្លៃទូទៅលើចរិត

---

238 រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Jean-Pierre Bemba Gombo Bemba* សាលក្រមអនុលោមតាមមាត្រា ៧៤ នៃលក្ខន្តិកៈ ICC-01/05-01/08-3343 ចុះថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០១៦ កថាខណ្ឌ ២៦១។

239 រឿងក្តី *Kunarac et al.* សាលក្រម IT-96-23 & 23/1 ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ៥៦៤។

240 រឿងក្តី *Delalić et al.* សាលក្រម IT-96-21-T ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ កថាខណ្ឌ ៥៩៥។ *សូមមើលបន្ថែម* រឿងក្តី *Kamuhanda* សាលក្រម សំណុំរឿងលេខ ICTR-95-54A-T ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០៤ កថាខណ្ឌ ៣៤។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Alex Tamba Brima Brima Bazzy Kamara និង Santigie Borbor Kanu (ជនជាប់ចោទ AFRC)* សំណុំរឿងលេខ SCSL-04-16-T សាលក្រម ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៧ កថាខណ្ឌ ១១១។

241 រឿងក្តី *Furundžija* សាលក្រម IT-95-17/1-T ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៨ កថាខណ្ឌ ១១៣។

លក្ខណៈនៃសក្ដីកម្មនោះ”[242] និងធានាថា ទោះជាយ៉ាងណាក៏ដោយ ដើមបណ្ដឹងរដ្ឋប្បវេណី “រៀបរាប់ខ្លឹមសារនៃព្រឹត្តិការណ៍ដែលត្រូវបានចោទប្រកាន់ យ៉ាងលម្អិតដែលអាចទទួលយកបាន”[243]។

130. ជាងនេះទៅទៀត អង្គជំនុំជម្រះសាលាដំបូងនៅក្នុងសំណុំរឿង ០០២/០១ បានពិចារណាអំពី “ព្យសនកម្មផ្លូវចិត្ត” ដែលដើមបណ្ដឹងរដ្ឋប្បវេណីទទួលរង និងយោងទៅលើមធ្យោបាយដែលជំងឺបាក់ស្បាតអាចស្ដែងចេញដោយខ្លួនវា “តាមរយៈការនឹកឃើញឡើងវិញនូវហេតុការណ៍ពីអតីតកាលថាដូចនៅថ្មីៗ ការស្ទាក់ស្ទើរមិនពិភាក្សា ឬមិនចង់ទៅមើលកន្លែងពីមុនៗ ការញ៉ើរខ្លួនប្រាណ និងជំងឺគេងមិនលក់”[244]។ ជាឧទាហរណ៍ ដើមបណ្ដឹងរដ្ឋប្បវេណីមួយរូប បានពន្យល់អំពីរបៀបដែលការលំបាកផ្នែករាងកាយ និងព្យសនកម្ម ក្នុងអំឡុងរបបនោះប៉ះពាល់ដល់ការចងចាំរបស់គាត់រហូតមកដល់សព្វថ្ងៃនេះ[245] ហើយដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបទៀតពន្យល់អំពីរបៀបដែលការឈឺចាប់ផ្លូវចិត្តរបស់គាត់ធ្វើឱ្យគាត់ភ្លេចភ្លាំង[246]។ ដើមបណ្ដឹងរដ្ឋប្បវេណីមួយរូបទៀត ពន្យល់អំពីរបៀបដែល ដំណើរទស្សនកិច្ចមន្ទីរសន្តិសុខ ស ២១ នាពេលថ្មីៗនេះធ្វើឱ្យគាត់វិលមុខ[247]។

131. នៅក្នុងបរិបទកម្ពុជា បណ្ឌិត ឈឹម សុធារ៉ា បានពន្យល់ថា “ប្រជាជនកម្ពុជា” ដែលទទួលរងជំងឺប៉ះទង្គិចផ្លូវចិត្ត ជាញឹកញាប់ហាក់ដូចជាបង្ហាញនូវរោគសញ្ញា “គេចវេស” នៃជំងឺបាក់ស្បាតដោយពួកគេ “មិនចង់និយាយអំពីអ្វីដែលបានកើតឡើងនៅក្នុងអតីតកាល ឬអ្វីដែលពួកគេបានជួបប្រទះពីព្រោះ តាមរយៈការរម្លឹកអំពីហេតុការណ៍ទាំងនោះ ពួកគេនឹងទទួលអារម្មណ៍ឈឺចាប់”[248]។

---

[242] រឿងក្ដី *Delalić et al.* សាលដីកា IT-96-21-A ចុះថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ៤៩៧។

[243] រឿងក្ដី *Kunarac et al.* សាលក្រម IT-96-23 & 23/1 ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០១ កថាខណ្ឌ ៥៦៤។ សូមមើលបន្ថែម រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Alex Tamba Brima Brima Bazzy Kamara និង Santigie Borbor Kanu (ជនជាប់ចោទ AFRC)* សំណុំរឿងលេខ SCSL-04-16-T សាលក្រម ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ២០០៧ កថាខណ្ឌ ១១៣។

[244] សាលក្រមសំណុំរឿង ០០២/០១ ឯកសារ **E313** កថាខណ្ឌ ១១៥០។

[245] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/364.1** ទំព័រ ១១-១២ បន្ទាត់ ១៨-១។

[246] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/283.1** ទំព័រ ១៤ បន្ទាត់ ៨-១៦ និង ទំព័រ ៣៧-៣៨ បន្ទាត់ ១៩-១០។

[247] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ផែ ហ៊ាប ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៣៤ បន្ទាត់ ២៣-២៥។

[248] ប្រតិចារឹក ថ្ងៃទី ៥ ខែ មិថុនា ឆ្នាំ ២០១៣ ឯកសារ **E1/201.1** ទំព័រ ៦៧-៦៩។

## ខ. ការវាយតម្លៃការយល់ព្រមដោយសារកាលៈទេសៈបង្ខិតបង្ខំ

132. សហមេធាវីនាំមុខលើកឡើងថា អង្គជំនុំជម្រះសាលាដំបូងគួរពិចារណាយុត្តិសាស្ត្រអន្តរជាតិដោយរម្លឹកថា អត្ថិភាពនៃកាលៈទេសៈបង្ខិតបង្ខំ អាចកាត់បន្ថយឱកាសនៃការយល់ព្រមពិតប្រាកដនៅក្នុងបរិបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមួយចំនួន។

133. ពាក់ព័ន្ធនឹងការគ្រប់គ្រងការរៀបអាពាហ៍ពិពាហ៍ ទោះបីជាធាតុផ្សំនៃបទឧក្រិដ្ឋរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ នៅអ.វ.ត.ក. និងនៅតុលាការពិសេសសម្រាប់ប្រទេសសេរ៉ាឡេអូន (SCSL)ខុសគ្នាក៏ដោយ អង្គជំនុំជម្រះសាលាដំបូងនៅក្នុងរឿងក្ដី រដ្ឋអាជ្ញា *តទល់នឹង Issa Hassan Sesay, Morris Kallon និង Augustine Gbao* យល់ឃើញថា នៅក្នុងកាលៈទេសៈអមិត្ត និងបង្ខិតបង្ខំ "ការយល់ព្រមពិតប្រាកដមិនអាចកើតមាននោះឡើយ"[249]។ ករណីនេះត្រូវបានបញ្ជាក់ដោយសាលដីកាលើបណ្ដឹងសាទុក្ខ ដែលសម្រេចថាក្នុងករណីដែលលក្ខខណ្ឌតម្រូវអង្គច្បាប់របស់បទល្មើសត្រូវបានបង្ហាញ ពោលគឺជនជាប់ចោទ "តាមរយៈកម្លាំង ការគម្រាមប្រើកម្លាំង ឬការបង្ខិតបង្ខំ ឬតាមរយៈការកេងយកប្រយោជន៍ពីកាលៈទេសៈបង្ខិតបង្ខំ" បានបង្ខំឱ្យបុគ្គលម្នាក់ ឬច្រើននាក់ធ្វើជាដៃគូអាពាហ៍ពិពាហ៍ ហើយនៅក្នុងករណីដែលអំពើបែបនេះ "ត្រូវបានគេដឹងថាជាផ្នែកមួយនៃការវាយប្រហារយ៉ាងទូលំទូលាយ ឬជាប្រព័ន្ធ ប្រឆាំងនឹងក្រុមប្រជាជនស៊ីវិលណាមួយ.... *ការយល់ព្រមមិនអាចកើតមាននោះឡើយហើយអាស្រ័យហេតុនេះ មិនអាចយកមកធ្វើការពិចារណានោះឡើយ*"[250]។ ក្នុងករណីដែលមានសំអាងហេតុគ្រប់គ្រាន់ ដើម្បីបង្កើតធាតុផ្សំសត្យានុម័តនៃការរៀបអាពាហ៍ ពិពាហ៍ដោយបង្ខំ គេមិនតម្រូវឱ្យ "ធ្វើការត្រួតពិនិត្យបញ្ហានៃការយល់ព្រមនិងជាពិសេសធ្វើការវាយតម្លៃថាតើជនរងគ្រោះគ្រប់រូបបានជំទាស់ដែរឬទេ"[251]។

---

[249] រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Issa Hassan Sesay Morris Kallon* និង *Augustine Gbao (*ជនជាប់ចោទ *RUF*) ថ្ងៃទី ២ ខែមីនា ឆ្នាំ ២០០៩ សាលក្រមរបស់តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន សាលក្រម សំណុំរឿងលេខ SCSL-04-140T កថាខណ្ឌ ១៤៦៦។

[250] រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Issa Hassan Sesay Morris Kallon* និង *Augustine Gbao (*ជនជាប់ចោទ *RUF*) ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ២០០៩ សាលក្រមរបស់តុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន សាលដីកា សំណុំរឿងលេខ SCSL-04-15-A កថាខណ្ឌ ៧៣៦ (បញ្ជាក់បន្ថែម)។

[251] *ដូចជើងទំព័រខាងលើ* កថាខណ្ឌ ៧៤០។

134. ពាក់ព័ន្ធនឹងការបណ្តេញចេញ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅក្នុងរឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Krajisnik* បានយល់ឃើញថា "ការផ្លាស់ទីលំនៅដោយបង្ខំ មានន័យថាប្រជាជនត្រូវបានផ្លាស់ទីលំនៅដោយផ្ទុយពីឆន្ទៈរបស់ពួកគេ ឬដោយគ្មានជម្រើសពិតប្រាកដ។ ភាពភ័យខ្លាចចំពោះអំពើហិង្សា ការបង្ខិតបង្ខំ ការឃុំខ្លួន ការគៀបសង្កត់ផ្លូវចិត្ត និងកាលៈទេសៈបែបនេះផ្សេងៗទៀតអាចបង្កើតបរិយាកាសមួយដែលគ្មានជម្រើសណាផ្សេងក្រៅពីចាកចេញ ដែលករណីនេះគឺជាការផ្លាស់ទីលំនៅប្រជាជនដោយបង្ខំ...."[252]។ ដោយយល់ស្របតាមសាលដីកាលើបណ្តឹងសាទុក្ខនៅក្នុងរឿងក្តី *Krnojelac* ពាក់ព័ន្ធនឹងការផ្លាស់ទីលំនៅដោយបង្ខំ ដោយវាត្រូវអនុវត្តដូចៗគ្នាចំពោះគ្រប់បទឧក្រិដ្ឋនៃការបណ្តេញចេញទាំងអស់ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅក្នុងរឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Stakic*បញ្ជាក់ថា "អវត្តមានជម្រើសពិតប្រាកដគឺជាអ្វីដែលធ្វើឱ្យការផ្លាស់ទីលំនៅមានភាពមិនស្របច្បាប់"[253]។ ប្រសិនបើក្រុមប្រជាជនស៊ីវិលរត់គេចខ្លួនដោយសារភ័យខ្លាចសេចក្តីស្លាប់ ឬអំពើរើសអើងផ្សេងៗទៀត ភាពបង្ខិតបង្ខំក្នុងជម្រើសរត់គេចខ្លួន នឹងកាត់បន្ថយការយល់ព្រមពិតប្រាកដ[254]។ ទោះបីជាមនុស្សម្នាក់អាចនឹងយល់ព្រមចាកចេញ ក៏ប៉ុន្តែការយល់ព្រមបែបនោះត្រូវធ្វើការវាយតម្លៃដោយពិនិត្យទៅលើកាលៈទេសៈជុំវិញ ថាតើការយល់ព្រមនោះត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្ត និងស្របតាមឆន្ទៈសេរីរបស់បុគ្គលនោះដែរឬទេ[255]។

---

[252] *សូមមើល៖* រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Krajisnik* ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៦ សាលក្រម និងការផ្តន្ទាទោស សំណុំរឿងលេខ IT-00-39-T កថាខណ្ឌ ៧២៤ ដោយដកស្រង់សំដីសាលដីការឿងក្តី *Krnojelac* កថាខណ្ឌ ២២៩ និងកថាខណ្ឌ ២៣៣។ សាលដីការឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Stakić* សំណុំរឿងលេខ IT-97-24-A ថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ២៧៩ និងកថាខណ្ឌ ២៨១។ អង្គជំនុំជម្រះតុលាការឧទ្ធរណ៍ក្នុងរឿង*ក្តី រដ្ឋអាជ្ញា តទល់នឹង Stakic* បានរកឃើញថា "ការផ្លាស់ប្តូរទីកន្លែងដោយបង្ខំទៅលើប្រជាជនតាមរយៈការបណ្តេញចេញ ឬទម្រង់នៃការបង្ខិតបង្ខំផ្សេងទៀត..." ដើម្បីបង្កើតបានជា*ធាតុផ្សំសត្យានុម័ត* ចំពោះឧក្រិដ្ឋកម្មនៃការនិរទេស។

[253] សាលដីការឿងក្តី *Stakić* កថាខណ្ឌ ២៧៩។

[254] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Krstic* សំណុំរឿងលេខ IT-98-33-T ចុះថ្ងៃទី ២ ខែ សីហា ឆ្នាំ ២០០១ សាលក្រម កថាខណ្ឌ ៥២៩ បន្តបន្ទាប់។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Krajisnik* សំណុំរឿងលេខ IT-00-39-T ថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ ២០០៦ កថាខណ្ឌ ៧២៤។

[255] រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Stakic* ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០០៦ សាលដីកា សំណុំរឿងលេខ IT-97-24-A កថាខណ្ឌ ២៧៩។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Martic* ថ្ងៃទី ១២ ខែ មិថុនា ឆ្នាំ ២០០៧ សាលដីកា សំណុំរឿងលេខ IT-95-11-T កថាខណ្ឌ ១០៨។ *សូមមើលផងដែរ* សាលក្រមរឿងក្តី *Kunarac* សំណុំរឿងលេខ IT-96-23-T និង IT-96-23/1-T សាលក្រម កថាខណ្ឌ ៤៦០ ដែលត្រូវបានបញ្ជាក់ក្នុងសាលដីការឿងក្តី *Kunarac* សំណុំរឿងលេខ IT-96-23 កថាខណ្ឌ ១២៧-១២៨ (ក្នុង

## ច. កិច្ចពិភាក្សាដេញដោល

135. ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានជ្រើសរើសឱ្យបង្ហាញខ្លួននៅក្នុងតុលាការ ដើម្បីផ្តល់សក្ខីកម្ម លើអង្គហេតុនានា ត្រូវបានសួរដេញដោលដោយគ្រប់ភាគីទាំងអស់ ពោលគឺភាគីនីមួយៗ ព្រមទាំង អង្គជំនុំជម្រះមានឱកាសសួរសំណួរពួកគេ។ គ្រប់ភាគីទាំងអស់ត្រូវបានផ្តល់ពេលវេលាស្មើគ្នាដើម្បី សួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណី និងអាចស្នើសុំពេលវេលាបន្ថែម ក្នុងករណីចាំបាច់[256]។

136. ក្នុងអំឡុងសវនាការស្តីពីផលប៉ះពាល់នីមួយៗ ក្រុមមេធាវីការពារក្តីអនុវត្តសិទ្ធិរបស់ខ្លួនធ្វើការសាក ពិសោធន៍អង្គហេតុនានា ហើយអង្គហេតុទាំងនោះនឹងត្រូវដាក់ឱ្យធ្វើការពិភាក្សាដេញដោល។ នៅ ពេលមួយ នៅពេលមានការស្នើសុំពីក្រុមមេធាវីការពារក្តី ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ត្រូវបានកោះ

---

បរិបទនៃការរំលោភសេពសន្ថវៈ)។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍សម្រាប់រឿងក្តី *Kunarac* ឧទាហរណ៍ បើទោះជាបានតម្កល់ និយមន័យនៃពាក្យសេពសន្ថវៈរបស់អង្គជំនុំជម្រះសាលាដំបូង ដែលនិយមន័យនេះបានផ្តោតលើភាពអវត្តមាននៃការព្រមព្រៀង ថាជាធាតុផ្សំខាងសម្ភារមួយ *ដែលមិនអាចខ្វះខាតបាន* នៃការរំលោភសេពសន្ថវៈ ដែលត្រូវបានទទួលស្គាល់ថា ក្នុងកាលៈទេសៈ "បង្ខិតបង្ខំស្ទើរតែជាសកលលោក" ដូចជា កាលៈទេសៈដែលមានប្រៀប "ក្នុងករណីភាគច្រើនដែលត្រូវបានចោទប្រកាន់ថាជា ឧក្រិដ្ឋកម្មសង្គ្រាម ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ"នោះ "ការព្រមព្រៀងពិតប្រាកដនឹងមិនអាចកើតមាននោះទេ"។ *សូមមើល* រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Kunarac និងអ្នកផ្សេង* ចុះថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០០១ សាលក្រម សំណុំរឿងលេខ IT-96-23 & IT-96-23/1 កថាខណ្ឌ ១៣០។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាឧទ្ធរណ៍សម្រាប់រឿងក្តី *Gacumbitsi* បាន លើកឡើងថា៖ "ការកាត់សេចក្តីអាចបង្ហាញឱ្យឃើញពីភាពមិនព្រមព្រៀងដោយគ្មានវិមតិសង្ស័យតាមរយៈការបង្ហាញនូវ អត្ថិភាពនៃកាលៈទេសៈបង្ខិតបង្ខំ ដែលស្ថិតក្រោមកាលៈទេសៈនេះ ការព្រមព្រៀងពោរពេញដោយអត្ថន័យមិនអាចធ្វើទៅបាន នោះទេ...។ អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិសេរីភាពក្នុងការសន្និដ្ឋានចំពោះភាពមិនព្រមព្រៀងចេញពីប្រវត្តិកាលៈទេសៈ ដូច ជាយុទ្ធនាការប្រល័យពូជសាសន៍ដែលកំពុងបន្តកើតមាន ឬការឃុំឃាំងជនរងគ្រោះ"។ *សូមមើល* រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Gacumbitsi* ថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ២០០៦ សាលដីកា សំណុំរឿងលេខ ICTR-2001-64 កថាខណ្ឌ ១៥៥។

[256] នៅពេលដែលស្នើសុំ ក្រុមមេធាវីការពារក្តីត្រូវបានផ្តល់ជូនពេលវេលាបន្ថែមទៀត ដើម្បីពិនិត្យមើលដើមបណ្តឹងរដ្ឋប្បវេណី អំពីការបង្ហាញសារៈសំខាន់ចំពោះសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់ការជំនុំជម្រះក្តី។ សូមមើលឧទាហរណ៍ កំណត់ ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីសវនាការលើអង្គសេចក្តីនៃសំណុំរឿង ០០២ នៅថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦ (ថ្ងៃទី ៤៦៤) ឯកសារ **E1/483** ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦៖ សេចក្តីសម្រេចផ្ទាល់មាត់លើសំណើសុំបន្ថែមពេល វេលាដើម្បីស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី 2-TCCP-298។

ហៅ ដើម្បីឱ្យគេសាកសួរដេញដោលលើអង្គហេតុនានាដែលត្រូវបានលើកឡើងពេលគាត់ផ្តល់សក្ខីកម្ម[257]។

137. អាស្រ័យហេតុនេះ ភស្តុតាង ដែលត្រូវបានដាក់ជូនដោយសហមេធាវីនាំមុខ ក្នុងទម្រង់ជាសក្ខីកម្ម ឬជាឯកសារ ត្រូវបានយកមកពិភាក្សាដេញដោលទាំងនៅដំណាក់កាលដាក់បញ្ចូលឯកសារនិងក្នុងតុលាការ។ អាស្រ័យហេតុនេះ ដោយបានបំពេញតាមលក្ខខ័ណ្ឌវិនិច្ឆ័យដ៏សំខាន់ដោយអនុលោមតាមវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងអាចយកភស្តុតាងដែលទទួលបានពីដើមបណ្តឹងរដ្ឋប្បវេណីធ្វើជាមូលដ្ឋានដើម្បីធ្វើសេចក្តីសំអាងលើអង្គហេតុ និងអង្គច្បាប់ ស្តីពីអង្គហេតុនានាពាក់ព័ន្ធនឹងការចោទប្រកាន់ព្រហ្មទណ្ឌនៅក្នុងដីកាដំណោះស្រាយដែលជាផ្នែកមួយនៃសំណុំរឿង០០២/០២។

## ឆ. ការវាយតម្លៃគ្រួតគ្លានៃតម្លៃជាភស្តុតាង

138. ដោយសារសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវបានបង្ហាញនៅក្នុងតុលាការ ត្រូវបានយកមកធ្វើការពិភាក្សាដេញដោលដោយគ្រប់ភាគីទាំងអស់ អង្គជំនុំជម្រះសាលាដំបូងមានសិទ្ធិសម្រេច

---

[257] *សូមមើលឧទាហរណ៍* ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធឹម ដែលបានផ្តល់សក្ខីកម្មក្នុងអំឡុងសវនាការលើសេចក្តីថ្លែងរៀបរាប់ទុក្ខសោក វេទនា និងស្ថានភាពព្យសនកម្ម សម្រាប់ផ្នែកទីមួយ នៅថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ហើយបន្ទាប់មកត្រូវបានស្នើសុំដោយមេធាវីការពារក្តី នួន ជា ឲ្យរំឭករឿងរ៉ាវឡើងវិញ។ សូមមើល សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធឹម ប្រតិចារឹក ចុះថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ សំណើសុំរបស់មេធាវីការពារក្តី នួន ជា ទំព័រ ៤១ បន្ទាត់ ២-៨៖ (“ខ្ញុំសូមលើកជូននូវសំណើមួយ។ ខ្ញុំសូមស្នើថា យើងគួរតែឈប់សួរទៅដើមបណ្តឹងរដ្ឋប្បវេណី ហើយគិតថា គួរតែអញ្ជើញគាត់ត្រឡប់មកទីនេះម្តងទៀតនៅពេលណាមួយ ដើម្បីផ្តល់សក្ខីកម្មឲ្យបានពេញលេញវិញ។ ខ្ញុំជឿជាក់ថា គាត់គឺជាសាក្សីដែលមានការពាក់ព័ន្ធ គឺជា ចម្លើយគាត់មានភាពទាក់ទងគ្នា ហើយខ្ញុំក៏ចង់សួរគាត់ជាច្រើនសំណួរផងដែរ។ ពិចារណាលើការកត់សម្គាល់ពីមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងអង្គជំនុំជម្រះសាលាដំបូងថា តើឥឡូវនេះយើងគួរតែផ្តោតទៅលើព្យសនកម្មរបស់បណ្តឹង ហើយហៅគាត់ឲ្យមកផ្តល់សក្ខីកម្មក្នុងនាមជាសាក្សីបានដែរឬយ៉ាងណា?”)។ សេចក្តីសម្រេចផ្ទាល់មាត់ដោយអង្គជំនុំជម្រះសាលាដំបូង៖ ទំព័រ ៤៤ បន្ទាត់ ១២-១៩ ៖ “បាទ ឥឡូវនេះបន្ទាប់ពីស្តាប់សំណើសុំរបស់មេធាវីកាពារក្តី នួន ជា និងមតិយោបល់របស់ភាគីពាក់ព័ន្ធ ហើយនិងបានពិនិត្យពិភាក្សាក្នុងចំណោមចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះសម្រេចបញ្ឈប់ការស្តាប់សេចក្តីរៀបរាប់ទុក្ខសោកវេទនារបស់ដើមបណ្តឹងរដ្ឋប្បវេណីនេះ ក្នុងនាមអ្នករៀបរាប់អំពីស្ថានភាពទុក្ខសោវេទនា និងស្ថានភាពព្យសនកម្មដោយលើកពេលទៅ -- គាត់ទៅស្តាប់នៅពេលក្រោយនៅពេលណាមួយសមស្រប ដោយអញ្ជើញគាត់មកឲ្យផ្តល់សក្ខីកម្មលើសក្ខីកម្មអង្គហេតុ ដែលពេលនេះគាត់អាចប្រើប្រាស់ក្នុងការឆ្លើយតបទៅនឹងសំណួរសួរអំពីអង្គហេតុផង ហើយនិងអំពីស្ថានភាពទុក្ខសោកវេទនា ព្យសកម្ម និងសំណើសុំផ្សេងៗរបស់គាត់ក្នុងនាមជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះផង”)។

ថាតើដើមបណ្ដឹងរដ្ឋប្បវេណីណាម្នាក់អាចគួរឱ្យជឿជាក់ ចំពោះបញ្ហាមួយចំនួននិងមិនគួរឱ្យជឿជាក់ចំពោះបញ្ហាផ្សេងៗទៀត ដរាបណាអង្គជំនុំជម្រះពិចារណាអំពីផលប៉ះពាល់នៃភាពមិនគួរឱ្យជឿជាក់បែបនោះទៅលើផ្នែកផ្សេងទៀតនៃសក្ខីកម្ម[258]។

139. សហមេធាវីនាំមុខយល់ឃើញថាភស្តុតាងត្រួត មិនមែនក្លាយជាភាពគ្រប់គ្រាន់នៃភស្តុតាងមិនផ្ទាល់សម្រាប់បង្កើតអង្គហេតុសំខាន់ៗហួសពីវិមតិសង្ស័យសមហេតុផលនោះឡើយ[259]។អាស្រ័យហេតុនេះ នៅក្នុងសារណាបិទបញ្ចប់ការពិភាក្សា ដោយសារមានការប្រុងប្រយ័ត្នខ្ពស់ សហមេធាវីនាំមុខ មិនបានពឹងផ្អែកទៅលើពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី និងព័ត៌មានបន្ថែមដែលជាផ្នែកមួយនៃពាក្យសុំតាំងខ្លួនជាដើម្បណ្ដឹងរដ្ឋប្បវេណីនោះឡើយ នៅពេលពួកគេព្យាយាមបង្ហាញធាតុផ្សំនៃបទឧក្រិដ្ឋ និងទំនួលខុសត្រូវព្រហ្មទណ្ឌ ដែលត្រូវបានចោទប្រកាន់នៅក្នុងដីកាដំណោះស្រាយ។

140. អង្គជំនុំជម្រះសាលាដំបូង នៅក្នុងរឿងក្ដី *Akayesu* ពិចារណាលើ “ភាពមិនស៊ីសង្វាក់ និងភាពផ្ទុយគ្នារវាងសេចក្ដីថ្លែងការណ៍ទាំងអស់នេះ និងសក្ខីកម្មនៅក្នុងសវនាការ យ៉ាងប្រុងប្រយ័ត្នដោយសារហេតុផលទាំងនេះ និងដោយពិចារណាទៅលើគម្លាតពេលវេលា រវាងការធ្វើសេចក្ដីថ្លែងការណ៍ និងការបង្ហាញភស្តុតាងនៅពេលសវនាការ ការលំបាកក្នុងការចងចាំព័ត៌មានលម្អិតរយៈពេលជាច្រើនឆ្នាំក្រោយពេលព្រឹត្តិការណ៍កើតឡើង ការលំបាកក្នុងការបកប្រែ និងប្រការដែលថាសាក្សីជាច្រើន មិនចេះអក្សរ និងបញ្ជាក់ថាពួកគេមិនបានអានសេចក្ដីថ្លែងការណ៍ជាលាយលក្ខណ៍អក្សររបស់ពួកគេនោះឡើយ។ លើសពីនេះទៅទៀត សេចក្ដីថ្លែងការណ៍មិនត្រូវបានធ្វើឡើងក្រោមទម្រង់ជាការប្រកាសជាឱឡារិក និងមិនត្រូវបានធ្វើឡើងដោយមន្ត្រីតុលាការនោះឡើយ”[260]។

141. អាស្រ័យហេតុនេះ សហមេធាវីនាំមុខស្នើសុំអង្គជំនុំជម្រះសាលាដំបូងពិចារណាភស្តុតាងនីមួយៗដែលទទួលបានពីសក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់ៗ ដោយវាយតម្លៃលើកាលៈទេសៈរបស់ពួកគេម្នាក់ៗ និងដោយពិចារណាលើកត្តាទាំងឡាយដែលត្រូវបានលើកឡើងខាងលើ។

---

[258] រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Mathieu Ngudjolo* សាលក្រមអនុលោមតាមមាត្រា ៧៤ នៃលក្ខន្តិកៈ ICC-01/04-02/12 ចុះថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១២ កថាខណ្ឌ ៥០។

[259] ធៀបជាមួយសាលដីកាសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៤១៩។

[260] រឿងក្ដី *រដ្ឋអាជ្ញា តទល់នឹង Akayesu* សាលក្រម ICTR-96-4-T ចុះថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ១៩៩៨ កថាខណ្ឌ ១៣៧។

## IV. ការបង្ហាញភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងបទឧក្រិដ្ឋ

142. នៅក្នុងសារណាបិទបញ្ចប់ការពិភាក្សានេះ សហមេធាវីនាំមុខបង្ហាញសក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី៦៤នាក់ ដោយសារសក្ខីកម្មនេះពាក់ព័ន្ធនឹងភ័ស្តុតាងនៅទីតាំងបទឧក្រិដ្ឋដែលពាក់ព័ន្ធនឹងវិសាលភាពរបស់សំណុំរឿង០០២/០២។ សហមេធាវីនាំមុខ លើកឡើងថាភ័ស្តុតាងក្នុងជំពូកទាំងនេះនឹងជួយដល់អង្គជំនុំជម្រះ ក្នុងការកំណត់លក្ខណៈរបស់ធាតុផ្សំសត្យានុម័តនៃបទឧក្រិដ្ឋដែលត្រូវបានបញ្ជូនទៅជំនុំជម្រះ។ មានតែសក្ខីកម្មផ្ទាល់មាត់តែប៉ុណ្ណោះដែលត្រូវបានយកមកពិចារណា ដោយត្រូវបានបំពេញបន្ថែមដោយកំណត់ហេតុស្តាប់ចម្លើយនៅពេលសមស្រប។ ដោយសារដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានអនុញ្ញាតិឱ្យចូលរួមក្នុងកិច្ចដំណើរការនិតិវិធីដោយផ្អែកលើមូលដ្ឋានព្យសនកម្មដែលពួកគេទទួលរងដែលបណ្តាលមកពីបទឧក្រិដ្ឋ ដែលត្រូវបានបញ្ជូនទៅជំនុំជម្រះសក្ខីកម្មស្តីពីព្យសនកម្មនៅក្នុងជំពូកនីមួយៗ នឹងបង្ហាញទំនាក់ទំនងរវាងបទឧក្រិដ្ឋនិងព្យសនកម្មដែលពួកគេទទួលរងដោយសារតែបទឧក្រិដ្ឋទាំងនោះ។

### ជំពូក ១. សហករណ៍ស្រុកត្រាំកក់[261]

[261] អង្គជំនុំជម្រះសាលាដំបូងទទួលបានអង្គហេតុនានាជុំវិញការបង្កើត និងការប្រព្រឹត្តិទៅរបស់សហករណ៍ត្រាំកក់ រួមទាំងស្ថានភាពធ្វើការងារ និងស្ថានភាពរស់នៅ ការកំណត់ប្រជាជនថាជាសត្រូវ ការកសាង ការចាប់ខ្លួន ឬការបាត់ខ្លួនអ្នកដែលបានប្រព្រឹត្តកំហុសផ្សេងៗ និងការប្រព្រឹត្តទៅលើក្រុមពិសេសនានា មានដូចជា អ្នកដែលមានការពាក់ព័ន្ធជាមួយអតីតសាធារណៈរដ្ឋខ្មែរ ជនជាតិវៀតណាម និងព្រះសង្ឃពុទ្ធសាសនា។ ការចោទប្រកាន់លើអង្គហេតុទាំងនេះបានកើតមានឡើងក្នុងបរិបទនៃការអនុវត្តគោលនយោបាយទីមួយក្នុងចំណោមគោលនយោបាយចំនួនប្រាំពាក់ព័ន្ធនឹង "ការបង្កើត និងការទាញយកប្រយោជន៍ពីសហករណ៍ និងពីការដ្ឋានតាមរយៈគ្រប់មធ្យោបាយចាំបាច់។" ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៣០២-៣២១ និងកថាខណ្ឌ ១៦៨-១៧០។ សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះសំណុំរឿងលេខ ០០២/០២ ឯកសារ **E301/9/1.1**។ អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងបន្ថែមថា អង្គរកា "គឺជាផ្នែកមួយដែលពាក់ព័ន្ធទាំងជាមួយនឹងសហករណ៍ត្រាំកក់ ហើយក៏ពាក់ព័ន្ធផងដែរជាមួយនឹងមន្ទីរសន្តិសុខក្រាំងតាចាន់។" ប្រតិចារឹក ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/289.1** ទំព័រ ២៦-២៧ បន្ទាត់ ៩-១៦។ ដោយឈរលើមូលដ្ឋាននៃការចោទប្រកាន់លើអង្គហេតុទាំងនេះ ជនជាប់ចោទត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវបានចោទប្រកាន់ថាបានកើតមានឡើងនៅក្នុងសហករណ៍ត្រាំកក់៖ ការធ្វើឱ្យទៅជាទាសករ ការសម្លាប់បំផុតពូជ ការនិរទេស ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញផ្អែកសាសនា (ចាម និងព្រះសង្ឃពុទ្ធសាសនា) ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុពូជសាសន៍ (ជនជាតិវៀតណាម) អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់នៃការរំលោភសេពសន្ថវៈ (ក្រោបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ និង

## ក. និជ្ជភាពទូទៅនៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី

143. ដើមបណ្តឹងរដ្ឋប្បវេណីបីនាក់គឺ អ៊ុំ សុផានី ជូ គឹមឡូន និង អ៊ុង សារឿន បានផ្តល់ភស្តុតាង ដែលភ្ជាប់ជនជាប់ចោទទៅនឹងសហករណ៍ស្រុកត្រាំកក់ ដូចដែលបានពិភាក្សាក្នុងជំពូក ១២[262]។ ដើមបណ្តឹងរដ្ឋប្បវេណីប្រាំនាក់គឺ យ៉ែម ខុន្ធី ប៊ុន សារឿន អ៊ុំ វណ្ណៈ និង ឡិប នាង បានផ្តល់សក្ខីកម្មអំពីលក្ខខណ្ឌនានាដែលពួកគេបានជួបប្រទះ និងព្យសនកម្មដែលពួកគេបានទទួលរង នៅពេលដែលពួកគេនៅក្មេង ឬស្ថិតក្នុងវ័យជំទង់។ ដើមបណ្តឹងរដ្ឋប្បវេណី គាក សាន់ ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ និងដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធីម បានផ្តល់ភស្តុតាងបន្ថែមទាក់ទងនឹងវគ្គសវនាការនេះ[263]។

144. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី បានរស់នៅក្នុងឃុំត្រពាំងធំខាងត្បូង ភូមិត្រពាំងជម្រៅ[264]។ គាត់ជាប្រជាជនថ្មី ដែលបានរៀបការជាមួយប្រជាជនមូលដ្ឋាន ហើយក្នុងអំឡុងរបបនេះ គាត់ត្រូវបានចាត់តាំងឱ្យធ្វើស្រែ[265] ហើយគាត់ក៏បានចូលរួមធ្វើកិច្ចការជាច្រើនផ្សេងទៀតផងដែរ[266]។

---

ក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ) ការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស អាពាហ៍ពិពាហ៍ដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ។ ឃាតកម្មមិនត្រូវបានចោទប្រកាន់នោះទេទាក់ទងនឹងសហករណ៍ត្រាំកក់។ ទោះជាយ៉ាងណា ការណ៍នេះមិនផាត់អង្គជំនុំជម្រះសាលាដំបូងចេញពីការផ្លាស់ប្តូរការកំណត់អង្គហេតុដែលខ្លួនទទួលបាននោះទេ។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៣៨១ កថាខណ្ឌ ១៣៩១ កថាខណ្ឌ ១៣៩៧ កថាខណ្ឌ ១៤០២ កថាខណ្ឌ ១៤០៨ ["សហករណ៍ត្រាំកក់ក្នុងក្របខ័ណ្ឌនៃការប្រព្រឹត្តចំពោះជនជាតិចាម"] កថាខណ្ឌ ១៤១៦ កថាខណ្ឌ ១៤២១ កថាខណ្ឌ ១៤២៦ កថាខណ្ឌ ១៤៣៤ និង កថាខណ្ឌ ១៤៧០។ សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងការជំនុំជម្រះសំណុំរឿងលេខ ០០២/០២ ឯកសារ **E301/9/1.1**។ សាលដីកាសំណុំរឿង ០០២/០១ ឯកសារ **F36** កថាខណ្ឌ ៥៦១-៥៦២។

[262] *សូមមើល* ជំពូកទី ១២៖ តួនាទីរបស់ជនជាប់ចោទ។

[263] ដើមបណ្តឹងរដ្ឋប្បវេណីចំនួនហាសិបមួយនាក់ត្រូវបានទទួលយកដោយ ក.ស.ច.ស ដោយឈរលើមូលដ្ឋានឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នៅសហករណ៍ត្រាំកក់ (ដីកាដំណោះស្រាយ ឯកសារលេខ **D427** កថាខណ្ឌ ៣២២)។ ដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ត្រូវបានទទួលយកដោយ អ.ប.ជ។

[264] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/250.1** ទំព័រ ៤៤ បន្ទាត់ ១២-១៥។

[265] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/250.1** ទំព័រ ៤៤ បន្ទាត់ ១៧។

[266] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/250.1** ទំព័រ ៥២ បន្ទាត់ ៦-១២។

ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ដែលបានទទួលរងការប្រព្រឹត្តផ្សេងពីគេដោយសារគាត់បានរៀបការជាមួយប្រជាជនមូលដ្ឋាននោះ បានផ្តល់ភ័ស្តុតាងនៅសាលាក្តីថា គាត់មិនអាចជ្រើសរើសការងារដោយខ្លួនគាត់បានទេ[267]។ ទោះជាយ៉ាងណាក្តី ការងារត្រូវបានផ្តល់ឱ្យផ្អែកលើកម្លាំងរបស់ជនរងគ្រោះ ដោយគាត់បានពន្យល់ថា ពីព្រោះគាត់ខ្សោយ គាត់អាចស្នើសុំមិនធ្វើការងារធ្ងន់បាន[268]។ ទោះជាយ៉ាងណា គាត់បានផ្តល់សក្ខីកម្មថា ពួកគេនឹងត្រូវធ្វើការ ២៤ ម៉ោងក្នុងមួយថ្ងៃ[269]។ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី បានថ្លែងថា គាត់បានកើតកូនម្នាក់នៅមន្ទីរពេទ្យត្រពាំងគល់ បើទោះជាមន្ទីរពេទ្យនោះមានបុគ្គលិកគ្មានបទពិសោធន៍ក្តី[270]។ គាត់ក៏ជាអ្នកនិពន្ធសៀវភៅកំណត់ហេតុ និងចម្រៀងមួយចំនួនផងដែរ ដែលរៀបរាប់ពីរយៈពេលប្រាំឆ្នាំស្ថិតក្រោមរបបខ្មែរក្រហម[271]។

145. ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ដែលជាប្រជាជនថ្មីមកពីទីក្រុងភ្នំពេញ[272] ត្រូវបានបញ្ជូនឱ្យទៅរស់នៅក្នុងកងបី (ក-៣) នៅឃុំលាយបូរ[273]។ ឪពុករបស់គាត់គឺជាអតីតពេទ្យទាហានក្នុងរបបលន់ នល់[274]។ នៅពេលប្តីរបស់គាត់ត្រូវបានគេយកទៅបាត់ ដើមបណ្តឹងរដ្ឋប្បវេណីមានផ្ទៃ

[267] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/250.1 ទំព័រ ៥០ បន្ទាត់ ១១។

[268] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/251.1 ទំព័រ ៦៥ បន្ទាត់ ១០-១១។

[269] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/250.1 ទំព័រ ៥២-៥៣ បន្ទាត់ ២២-៣។

[270] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/250.1 ទំព័រ ៦៤-៦៥ បន្ទាត់ ១៩-១៩។

[271] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/252.1 ទំព័រ ២៧ បន្ទាត់ ១-១១។

[272] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/252.1 ទំព័រ ៣៥ បន្ទាត់ ៤-៥។

[273] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/253.1 ទំព័រ ៨ បន្ទាត់ ២២។

[274] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/252.1 ទំព័រ ៣៥ បន្ទាត់ ១០។

ពោះ[275]។ ប្ដីរបស់គាត់ជាមន្ត្រីរដ្ឋការក្នុងរបបចាស់[276]។ គាត់បានផ្ដល់កំណើតកូនម្នាក់នៅស្រុកត្រាំកក់[277]។ ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន បានធ្វើការងារផ្សេងៗជាច្រើន ខណៈពេលស្ថិតនៅក្នុងកងចល័ត រួមទាំងជីកប្រឡាយចាប់ពីឆ្នាំ ១៩៧៦ រហូតដល់រដូវប្រាំងឆ្នាំ ១៩៧៧[278]។ ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន បានផ្ដល់សក្ខីកម្មថា គាត់បានចូលរួមកិច្ចប្រជុំធំៗនៅវត្តលាយបូរ ដែលមាន តា ម៉ុក ធ្វើជាប្រធាន[279]។

146. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុង សារឿន ដែលជាប្រជាជនថ្មី[280] គឺជាអ្នកលក់អង្ករនៅផ្សារណាត់ក្នុងខេត្តតាកែវ ហើយប្ដីរបស់គាត់ជាអតីតទាហាន លន់ នល់[281]។ ពួកគេត្រូវបានជម្លៀសទៅកាន់ភូមិព្រៃឈើទាល ក្នុងស្រុកត្រាំកក់ មុនពេលគាត់ត្រូវបានបញ្ជូនទៅកាន់ភូមិអង្គនរាយណ៍ ឃុំលាយបូរ នាពេលក្រោយមក[282]។ នៅឆ្នាំ ១៩៧៦ គាត់ត្រូវបានគេផ្លាស់ទៅភូមិជ្រៃជម្រៅ ឃុំលាយបូរ ជាទីដែលគាត់ត្រូវបានគេប្រើឱ្យជីកប្រឡាយ[283]។ ជាថ្មីម្ដងទៀតក្នុងឆ្នាំ ១៩៧៨ គាត់ត្រូវបានគេផ្លាស់

[275] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/253.1** ទំព័រ ៣៩-៤០ បន្ទាត់ ២៣-២៣។

[276] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/253.1** ទំព័រ ៣៩-៤០ បន្ទាត់ ២៣-២៣។

[277] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/253.1** ទំព័រ ៣៩-៤០ បន្ទាត់ ២៣-២៣ ។

[278] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/252.1** ទំព័រ ៤៥ បន្ទាត់ ៧-១៣។

[279] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/252.1** ទំព័រ ៧០ បន្ទាត់ ១៣-១៦។

[280] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ៥ បន្ទាត់ ៨-៩។

[281] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ៣ បន្ទាត់ ២១-២២។

[282] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ៥ បន្ទាត់ ៨-១០។

[283] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ៥ បន្ទាត់ ១១-១៤។

ទៅកាន់ចំការសៀម ដើម្បីជីកប្រឡាយ និងលើកទំនប់នៅទីនោះ[284]។ ក្នុងអំឡុងពេលនេះ ប្តីរបស់គាត់ត្រូវបានសម្លាប់ ហើយកូនរបស់គាត់បានស្លាប់ដោយសារជំងឺ និងកង្វះអាហារ។ គាត់ក៏ត្រូវបានគេចាត់ទុកថាជាប្រជាជន ១៧ មេសា ផងដែរ[285]។

147. ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ ត្រូវបានចាត់តាំងឱ្យទៅធ្វើការនៅកងចល័តមួយនៅក្បាលពោធិ៍។ ក្នុងចំណោមរឿងរ៉ាវផ្សេងៗ គាត់បានផ្តល់សក្ខីកម្មថា គាត់ត្រូវបានគេប្រើឱ្យធ្វើស្រែប្រាំង និងលើកទំនប់ និងជីកប្រឡាយស្រោចស្រព[286]។ ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ និងគ្រួសាររបស់គាត់បានរត់គេចខ្លួនទៅកាន់ប្រទេសវៀតណាមក្នុងនាមជាជនភៀសខ្លួន ហើយត្រូវបានដោះដូរត្រលប់មកប្រទេសកម្ពុជាវិញក្នុងឆ្នាំ ១៩៧៦[287]។ គាត់បានលើកឡើងថា គាត់ជាប្រជាជនកម្ពុជាលើ ឬកម្ពុជា ប៉ុន្តែថា គាត់បានរត់គេចខ្លួនទៅកាន់ប្រទេសវៀតណាម[288]។ ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា នៅពេលគាត់បានវិលត្រលប់មកប្រទេសកម្ពុជាវិញ គាត់ត្រូវបានគេចាត់ទុកថាជាមនុស្សម្នាក់ក្នុងចំណោម "ប្រជាជនកម្ពុជាក្រោម"[289]។ គាត់បានផ្តល់សក្ខីកម្មអំពីម៉ោងការងារដ៏វែងដែលពួកកម្មករបានស៊ូទ្រាំធ្វើដោយមានពេលសម្រាកតិចតួច[290] និងបានផ្តល់សក្ខីកម្មអំពីការ

---

[284] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ៥ បន្ទាត់ ២០-២១។

[285] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ៥ បន្ទាត់ ១២-១៣។

[286] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/262.1** ទំព័រ ១០ បន្ទាត់ ២៣-២៤។

[287] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/262.1** ទំព័រ ៣ បន្ទាត់ ១៤-១៦។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/262.1** ទំព័រ ២៥ បន្ទាត់ ៥-៩។

[288] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/262.1** ទំព័រ ៤៤ បន្ទាត់ ២៣-២៤។

[289] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/262.1** ទំព័រ ៤៥ បន្ទាត់ ៣-៥។

[290] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/262.1** ទំព័រ ២៦ បន្ទាត់ ៤-១១។

ស្លាប់របស់សមាជិកពីរនាក់នៃកងរបស់គាត់[291]។ ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ បានផ្តល់សក្ខីកម្ម ថា គាត់បានឃើញ តា ម៉ុក មកធ្វើអធិការកិច្ចនៅការដ្ឋានរបស់គាត់ចំនួនពីរដងក្នុងឆ្នាំ ១៩៧៧[292]។

148. ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធីម ដែលជាប្រជាជនថ្មី ត្រូវបានផ្លាស់ទៅកាន់ភូមិត្រពាំងធំខាងជើង ស្រុកត្រាំកក់ក្នុងឆ្នាំ ១៩៧៧ ពីស្រុកគីរីវង់ ជាទីដែលគាត់បានធ្វើការនៅក្នុងកងរទេះដឹកជញ្ជូន[293]។ គាត់បានផ្តល់សក្ខីកម្មថា គាត់ត្រូវបានចាប់ខ្លួន ហើយក្រោយមកឃុំឃាំងនៅផ្សារអង្គរកា[294]។ ដើមបណ្តឹងរដ្ឋប្បវេណី បានផ្តល់សក្ខីកម្មអំពីលក្ខខណ្ឌនៃការឃុំឃាំងរបស់គាត់[295]។ ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធីម បានពន្យល់ថា បន្ទាប់ពីរយៈពេលបីខែដំបូងនៃការឃុំខ្លួនគាត់នៅក្នុងគុក គាត់ត្រូវបាន "គេបញ្ចេញឱ្យទៅធ្វើការ"[296]។

149. ដើមបណ្តឹងរដ្ឋប្បវេណី យ៉ែម ខុន្នី ត្រូវបានបញ្ជូនទៅកាន់ព្រៃខាប់ នៅពេលដែលគាត់មានអាយុ ១៤ ឆ្នាំ[297] ជាទីដែលគាត់ត្រូវបានចាត់តាំងឱ្យរែកដី[298]។ គាត់បានផ្តល់សក្ខីកម្មអំពីកង្វះអាហារ និង

---

[291] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ ប្រតិចារិក ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/262.1** ទំព័រ ៣៣ បន្ទាត់ ២១-២៥។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ ប្រតិចារិក ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/262.1** ទំព័រ ២៧ បន្ទាត់ ១-៦។

[292] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ ប្រតិចារិក ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/262.1** ទំព័រ ២៩ បន្ទាត់ ១៦។

[293] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធីម ប្រតិចារិក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ២៣ បន្ទាត់ ២១-២២។

[294] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធីម ប្រតិចារិក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ៣២ បន្ទាត់ ៧។

[295] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធីម ប្រតិចារិក ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/289.1** ទំព័រ ២៥ បន្ទាត់ ១៤-១៨ និងទំព័រ ២៥-២៦ បន្ទាត់ ២៤-៤។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធីម ប្រតិចារិក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ៣៤ បន្ទាត់ ៩-១៨។

[296] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធីម ប្រតិចារិក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ៣៣-៣៤ បន្ទាត់ ២៤-៥ ទំព័រ ៣៤ បន្ទាត់ ១០។

[297] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យ៉ែម ខុន្នី ប្រតិចារិក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ៧០ បន្ទាត់ ១០-១៥។

[298] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យ៉ែម ខុន្នី ប្រតិចារិក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ៧១ បន្ទាត់ ៥។

លក្ខខណ្ឌការងារ[299]។ ទាក់ទងនឹងសមាជិកគ្រួសាររបស់គាត់ ពួកគេត្រូវបានបំបែកចេញពីគ្នា ហើយដាក់ឲ្យធ្វើការនៅកងផ្សេងៗគ្នា[300]។

150. ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន មានអាយុដប់មួយឆ្នាំក្នុងឆ្នាំ ១៩៧៥ នៅពេលដែលគាត់ត្រូវបានបញ្ជូនទៅភូមិត្រពាំងថែង ហើយត្រូវបានបំបែកចេញពីឪពុកម្តាយរបស់គាត់ និងឲ្យធ្វើការក្នុងកងកុមារ[301]។ ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន បានផ្តល់សក្ខីកម្មថា ព្រះសង្ឃមកពីវត្តនៅជិតសហករណ៍ត្រពាំងថែង ត្រូវបានគេយកចេញទៅបាត់ រួមទាំងបងប្រុស និងពូរបស់គាត់ផងដែរ[302]។

151. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម វណ្ណៈ មានអាយុប្រាំបីឆ្នាំ ហើយគាត់ត្រូវបានគេចាត់ទុកថាជាប្រជាជនថ្មី។ គាត់ត្រូវបានគេបញ្ជូលក្នុងកងចល័តនៅភូមិឈើទាល[303]។ ក្រោយមក គាត់ត្រូវបានគេបង្ខំឲ្យផ្លាស់ទៅភូមិអង្គនរាយណ៍នៅពាក់កណ្តាលឆ្នាំ ១៩៧៥[304]។ កងចល័តកុមាររបស់គាត់មានមូលដ្ឋាននៅស្រុក ១០៥[305]។ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម វណ្ណៈ បានផ្តល់សក្ខីកម្មថា កុមារ

---

[299] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យ៉ែម ឌុន្នី ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ៨-៩ បន្ទាត់ ២៥-៣។

[300] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យ៉ែម ឌុន្នី ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ៧១ បន្ទាត់ ២៤-២៥។

[301] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ១៨ បន្ទាត់ ១៣ ទំព័រ ២៨ បន្ទាត់ ៦។

[302] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ២៤-២៥ បន្ទាត់ ១៩-២។

[303] សក្ខីកម្មផ្ទាល់មាត់របស់ អ៊ុម វណ្ណៈ ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ៤៥ បន្ទាត់ ២៣-២៤ ទំព័រ ៤៦ បន្ទាត់ ១៧។

[304] សក្ខីកម្មផ្ទាល់មាត់របស់ អ៊ុម វណ្ណៈ ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ៤៣ បន្ទាត់ ៩-១២ និង ទំព័រ ៤៦ បន្ទាត់ ៣-៧។

[305] សក្ខីកម្មផ្ទាល់មាត់របស់ អ៊ុម វណ្ណៈ ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ៤៤ បន្ទាត់ ៧-៨។

មិនត្រូវបានអនុញ្ញាតឱ្យទៅលេងឪពុកម្ដាយរបស់ខ្លួនឡើយ ក្រៅពីការដែលគេរៀបចំឱ្យទៅលេងផ្ទះប្រចាំខែ[306]។

152. ដើមបណ្ដឹងរដ្ឋប្បវេណី ឡឹប នាង ដែលមានអាយុ ១១ ឆ្នាំនៅពេលនោះ បានផ្ដល់សក្ខីកម្មពាក់ព័ន្ធនឹងលក្ខខណ្ឌរស់នៅក្នុងសហករណ៍ត្រាំកក់។ ដើមបណ្ដឹងរដ្ឋប្បវេណី ដែលជាជនជាតិចាម រស់នៅក្នុងភូមិត្នោតចាង ឃុំត្នោតចាង ស្រុកត្រាំកក់ ហើយក្រោយមកត្រូវបានចាត់តាំងទៅធ្វើការនៅភូមិ ១០៩ ដែលជាភូមិមួយផ្សេងទៀតស្ថិតក្នុងស្រុកត្រាំកក់ដែរ[307]។ ដើមបណ្ដឹងរដ្ឋប្បវេណី ឡឹប នាង បានផ្ដល់សក្ខីកម្មអំពីលក្ខខណ្ឌការងារដែលគាត់បានជួបប្រទះ និងកង្វះអាហារ[308]។ គាត់ក៏បានពន្យល់ផងដែរថា បងប្អូនបង្កើតរបស់គាត់ត្រូវបានគេយកទៅបាត់មិនដែលឃើញត្រលប់មកវិញទេ[309]។

## ខ. ភស្តុតាងដែលផ្អែកលើឧក្រិដ្ឋកម្មដែលផ្ដល់ដោយដើមបណ្ដឹងរដ្ឋប្បវេណីក្នុងសវនាការ

### ១. ការធ្វើឱ្យនៅជាទាសករ

153. ភស្តុតាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានផ្ដល់នៅក្នុងសវនាការ បង្ហាញថា កម្មករនៅស្រុកត្រាំកក់ជាកម្មវត្ថុនៃការអនុវត្តអំណាចណាមួយ ឬទាំងអស់ ដែលភ្ជាប់ទៅនឹងសិទ្ធិជាម្ចាស់កម្មសិទ្ធិលើជនណាម្នាក់។

### ១.១. ពលកម្មដោយបង្ខំ

154. ដើមបណ្ដឹងរដ្ឋប្បវេណី បេង បឿន បានផ្ដល់សក្ខីកម្មថា៖ “ខ្ញុំដើរនៅបៀតហ្នឹង ខ្ញុំអ្នកមើលគោដែលខ្ញុំគេឱ្យសម្រាក ពីព្រោះអីខាងខ្ញុំគេឱ្យម្ដងទៅនេះម្ដងទៅនោះ ម្ដងមកខាងតាៗ ម្ដងខាងចល័ត

[306] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ឹម វណ្ណៈ ប្រតិចារឹក ឯកសារ **E1/288.1** ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ ទំព័រ ៤៦ បន្ទាត់ ១៤-២៣។

[307] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ឡឹប នាង ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ៧៤ បន្ទាត់ ៩-១ និងទំព័រ ៧៩ បន្ទាត់ ១៦-២១។

[308] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ឡឹប នាង ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ៧៨-៧៩ បន្ទាត់ ៨-៣។

[309] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ឡឹប នាង ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/ 288.1** ទំព័រ ៧៥ បន្ទាត់ ៤-៧។

ម្តុងខាងភ្លូវអ៊ីចឹងទៅ សម្រេចតែគេប្រើ”[310]។ ដូចគ្នានេះដែរ ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន បានពិពណ៌នាថា “ហើយធ្វើការផ្លាស់ប្តូរគ្រប់លេណដ្ឋានទាំងអស់ តាមកន្លែងណាគេត្រូវការ គេបញ្ជូនទៅកន្លែងហ្នឹង កន្លែងណាគេត្រូវសម្រុក បញ្ជូនទៅកន្លែងហ្នឹងរហូត”[311]។ ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ បានរំឮកឡើងវិញថា៖ “ទៅនៅធ្វើស្រែប្រាំង ជីកប្រឡាយ រែកដីនៅទីនោះ”[312]។

155. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី បានផ្តល់សក្ខីកម្មថា គាត់ត្រូវតែធ្វើការ “ទាល់តែយើង ទាល់តែមានការអនុញ្ញាតពីអង្គការ ទាល់តែសុំការអនុញ្ញាត។ យើងអត់អាចឈប់ដោយសេរីស្រេចតែចិត្តយើងទេ”[313]។

156. ដើមបណ្តឹងរដ្ឋប្បវេណី គាក សាន់ បានផ្តល់សក្ខីកម្មថា៖ “ខ្ញុំមិនបានសម្រាកទេ។ គេបង្ខំឱ្យធ្វើការ គេធ្វើគ្រប់គ្នាមិនបានសម្រាក”[314]។ គាត់បានពន្យល់ថា៖ “គេមិនឱ្យយើងសម្រាក ឱ្យខំធ្វើរកឱ្យឆាប់ហើយ”[315]។

157. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន បានផ្តល់សក្ខីកម្មថា៖ “នាងខ្ញុំនៅកងចល័តៗរែកដី ធ្វើប្រឡាយ។ នាងខ្ញុំលីស៊ីម៉ងត៍នៅវ៉ារទេះភ្លើងមួយក្រុមគ្នា ១២ នាក់ស្រីៗ។ យប់អង្គការស្នើឱ្យជួយជំនួយលីស៊ីម៉ងត៍ អំបិលដាក់ឃ្លាំង”[316]។ គាត់បានបន្ថែមថា៖ “៧៨ អង្គការយកខ្ញុំទៅភ្នំ -- ចម្ការ

[310] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី បេង បឿន ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ៥០-៥១ បន្ទាត់ ២៣-១។

[311] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/252.1** ទំព័រ ៤៥ បន្ទាត់ ២០-២១។

[312] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/262.1** ទំព័រ ១០ បន្ទាត់ ២៣-២៤។

[313] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/250.1** ទំព័រ ៥៣ បន្ទាត់ ១១-២។

[314] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី គាក សាន់ ប្រតិចារឹក ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/286.1** ទំព័រ ២៥ បន្ទាត់ ៨។

[315] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី គាក សាន់ ប្រតិចារឹក ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/286.1** ទំព័រ ២៥ បន្ទាត់ ១១។

[316] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ៥ បន្ទាត់ ១៤-១៧។

សៀង នៅធ្វើនៅចម្ការសៀងទៀត ប្រឡាយ ទំនប់ និងអាងទំនប់ចម្ការសៀង។ ទារុណកម្មខ្ញុំនៅហ្នឹង នាទី១៧ហ្នឹងបីនាក់ ឱ្យនៅទារុណកម្មនៅហ្នឹង"[317]។

158. ដើមបណ្ដឹងរដ្ឋប្បវេណី ថាន់ ធីម ដែលបានផ្ដល់សក្ខីកម្មទាក់ទងនឹងការឃុំខ្លួនគាត់នៅផ្សារអង្គរកា បានផ្ដល់សក្ខីកម្មអំពីការធ្វើការបន្ទាប់ពីការឃុំឃាំងគាត់រយៈពេលបីខែដំបូង។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានឱ្យដឹងថា៖ "ខ្ញុំហ្នឹងជាប់នៅក្នុងគុក៣ខែ។ ដល់គ្រប់រយៈពេល៣ខែហ្នឹង បាន លោក ម៉េង ហ្នឹងហៅខ្ញុំសួរម្ដងទៀត។ សួរៗ ដេញដោលតាំងពីដំបូងថា ៧០ នៅឯណា? ៧២ នៅឯណា? ៧៣ នៅឯណា? ៧៤-៧៥ នៅឯណា? ហើយខ្ញុំឆ្លើយតាមដំណើរហ្នឹងអ៊ីចឹងទៅបានគេឱ្យខ្ញុំចេញធ្វើការបាទ។ មិនមែនជាប់៣ខែហ្នឹងបានរួចទេ គឺជាប់រហូតដល់វៀតណាមបុកឡើង តាំងពីឆ្នាំ៧៨បាទ ជាប់ឆ្នាំ៧៨ រហូតដល់វៀតណាមបុកឡើង"[318]។

159. ដើមបណ្ដឹងរដ្ឋប្បវេណីបានពិពណ៌នាថា៖ "គេឱ្យខ្ញុំរែកទឹកហ្នឹងស្រោចដំណាំជិតៗហ្នឹង បាទ។ រែកទឹកស្រោចដំណាំជិតៗហ្នឹង ហើយយើងនៅក្នុងគុកហ្នឹង និយាយពីដើរ ជើងដើរដីហ្នឹង និយាយពីក្ដៅសឹងឆេះជើង ដើរមិនបានទេ ព្រោះសាច់វាខ្ចី បាទ។ ឈឺមាំណាស់ ឈឺខ្លាំងមែនទែន ប៉ុន្តែហេតុតែចង់រស់ ចេះខំរែកទឹកហ្នឹងស្រោចដំណាំនៅអាជិតៗអាគុកគេហ្នឹង។ គេមានស្រះទឹកមួយនៅជិតនុ៎ង ហើយខ្ញុំហ្នឹងក៏រែកទឹកហ្នឹងស្រោចដំណាំហ្នឹងជិតៗហ្នឹងបាទ"[319]។ គាត់បន្ថែមថា៖ "ពេលយប់ គេដាក់ខ្នោះជើងវិញដដែលបាទ អត់មានថាលែងយើងទេ គឺពេលថ្ងៃអ៊ីចឹងចេញធ្វើការ ពេលយប់គេយកមក គេបញ្ចូលខ្នោះយើងវិញដដែល"[320]។

## ១.២. ការអះអាងពីសិទ្ធិផ្ដាច់មុខ

---

[317] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ៥ បន្ទាត់ ២០-២១។

[318] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ថាន់ ធីម ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ -៣៤ បន្ទាត់ ១-៥។

[319] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ថាន់ ធីម ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ៣៤ បន្ទាត់ ១៤-១៨។

[320] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ថាន់ ធីម ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ៣៤ បន្ទាត់ ២១-២២។

160. ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ បានផ្តល់សក្ខីកម្មថា រាល់ឯកសារអត្តសញ្ញាណទាំងអស់ត្រូវបានប្រមូល ហើយត្រូវបានដុតបំផ្លាញចោលនៅពេលដែលគ្រួសាររបស់គាត់មកដល់ប្រទេសកម្ពុជា។ គាត់បានថ្លែងថា៖ "យើងមានចាស់ ដែលវ័យចំណាស់ចាប់ពីអាយុ ២០ឡើងទៅ គាត់មានកាត។ កាតខ្មៅមួយកាលនោះសម័យដើម មានតែកាត។ អ៊ីចឹងកាត ឬអ្វីដែលពាក់ព័ន្ធ គឺគេប្រមូលដុតចោលអស់"[321]។ គាត់បានបន្ថែមថា៖ "គេប្រាប់ថា នៅទីនេះមានអង្គការគ្រប់គ្រងហើយ។ ហើយគេបានប្រជុំប្រាប់ថា ពេលនេះ នៅទីនេះមានសហករណ៍មានអង្គការប្រមូលផ្តុំ អ៊ីចឹងមិនបាច់ឲ្យពុកម៉ែបងប្អូនពិបាកអីទៀតទេ អ៊ីចឹងមកដឹងតែពេលឆ្អិនដឹងតែហូបទៅ កុំបាច់ខ្វល់ខ្វាយរឿងដាំស្លអីបាទ"[322]។

161. ទាក់ទងនឹងការរៀបចំការរស់នៅ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី បានថ្លែងថា៖ "អង្គការគេធ្វើផ្ទះឲ្យខ្ញុំទៅស្នាក់នៅនៅភូមិត្រពាំងអង្គ គឺគេប្រមូលពួកថ្មីទាំងអស់ឲ្យទៅនៅជុំគ្នានៅទីនោះ ពីព្រោះស្រួលគេក្តោបក្តាប់"[323]។

## ១.៣. ការគ្រប់គ្រង

### i. ការគ្រប់គ្រងចិត្តវិទ្យា

#### *ការបង្កើតឲ្យមានបរិយាកាសភ័យខ្លាច*

162. ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ បានផ្តល់សក្ខីកម្មថា៖ "សម័យនោះ ទាំងគេទាំងខ្ញុំ អ៊ីចឹងការគោរពវិន័យរបស់អង្គការចាត់តាំងរបស់គេហ្នឹង គឺគ្មានអ្នកណាហ៊ានដើរឆ្វេចឆ្វាចទេ មនុស្សម្នាក់ៗភ័យខ្លាចតែអារឿងស្លាប់ រឿងគេយកទៅសម្លាប់ ឬមួយគេយកទៅដោយសម្ងាត់ ដោយយើងមិនដឹង

[321] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/262.1** ទំព័រ ៨ បន្ទាត់ ១៦-១៨។

[322] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/262.1** ទំព័រ ៨-១០ បន្ទាត់ ២៣-៤។

[323] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/251.1** ទំព័រ ៤៨-៤៩ បន្ទាត់ ២៣-១។

ខ្លួន។ អ៊ីចឹង គឺគ្មានអ្នកណាបានដើរសេរី បានធ្វើខុសពីគោលការណ៍នៃច្បាប់របស់គេទេ បាទ"[324]។

163. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន បានផ្តល់សក្ខីកម្មថា៖ "គវ៉ាត្រូវយកទៅសម្លាប់បាត់ បានតែសុំថែមគឺអត់បានហូង ឱ្យប៉ុន្មានគឺហូបប៉ុណ្ណឹង។ ចេះតែទ្រាំទៅហូបឆ្អែតមិនឆ្អែតចេះតែទ្រាំអ៊ីចឹងទៅ រកត្នោតទុំ រើសត្នោតទុំ គល់ចេក គល់ល្ហុងហ្នឹងចាស យកមកស្ងោរហូបទៅ លួចហូបទៀតហ្នឹងលួចហូបអត់ឱ្យឃើញទេ"[325]។

164. ដូចគ្នានេះដែរ ដើមបណ្តឹងរដ្ឋប្បវេណី យ៉ែម ខុន្នី បានផ្តល់សក្ខីកម្មថា គាត់ត្រូវបានបង្ខំឱ្យនិយាយថា បបរលាយព្រលិតរបស់គាត់មានរសជាតិឆ្ងាញ់។ គាត់និយាយថា៖ "បើមិនឆ្លើយអ៊ីចឹងទេ ធ្វើបាបធ្វើទោសទុក្ខ ដល់ហើយហ្នឹងចេះតែឆ្លើយទៅឱ្យតែហូបឱ្យរួចខ្លួន ឱ្យរស់តែមួយគ្រាៗទៅ។ គ្រាន់តែៗឆ្លើយមិននេះហ្នឹងក៏យកទៅ (ឮមិនច្បាស់)។ ថាហូបមិនឆ្អែតហ្នឹងក៏យកទៅកសាងដែរ។ យកកុមារហ្នឹងទៅកសាងថា ថ្ងៃមុខថ្ងៃក្រោយកុំនិយាយអ៊ីចឹង។ គេឱ្យហូបឱ្យឆ្អែតៗហើយ បើគ្នាថាបើគ្នាមិនឆ្អែតអង្គុយវង់តុជាមួយខ្ញុំហ្នឹង គ្រាន់តែថាគ្នាមិនឆ្អែត ហៅគ្នាយកទៅកសាងភ្លាម។ ហើយបានតែឃើញអ៊ីចឹង បានពួកខ្ញុំហ្នឹងឆ្លើយថាឆ្ងាញ់ ថាឆ្អែតអ៊ីចឹងទៅ។ កុំឱ្យគេយកទៅកសាងហើយបើយកទៅកសាងក៏ពិបាកដែរ នៅផ្ទាញ់ផ្ទាលនៅហ្នឹង។ ចង់អ៊ីចេះចង់អ៊ីចុះ។ ហើយដល់ហើយពួកខ្ញុំហ្នឹងក៏មានសេចក្តីថា គេមកសួរអ៊ីចឹងថា ឆ្ងាញ់ទេ? ដល់ឆ្លើយថា ឆ្ងាញ់ ប៉ុន្តែមិនឆ្ងាញ់ទេ ម៉ែឪអាណាដែលហូបគល់ចេក ដែលហូបគល់ល្ហុង ដែលហូបដំឡូង ដែលហូបពោតអាក្រហមហ្នឹងស្ងោរហើយដាក់ចានជងអីឱ្យហូប"[326]។

165. ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡុន បានផ្តល់សក្ខីកម្មថា៖ "ឮញថាត្អែរថា "ហូបអត់ឆ្អែត នៅហូបបាយអត់ឆ្អែត ហើយធ្វើស្រែ ខំធ្វើស្រែបានផលច្រើនតែស្រូវដឹកបាត់អស់ អត់មានអីហូប" តើ --

---

[324] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/262.1** ទំព័រ ៣៣ បន្ទាត់ ១-៤។

[325] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ១៦ បន្ទាត់ ៣-៥។

[326] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យ៉ែម ខុន្នី ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ៨-៩ បន្ទាត់ ១៨-១។

អត់មាននិយាយឱ្យគេឮទេ ត្អូញត្អែរប្រាប់គ្នាយើងទេ តែគេឮ គេចាប់យកទៅវៃចោល"[327]។ គាត់បានបន្ថែមថា៖ "ក្នុងអង្គប្រជុំ អត់មានអ្នកណាហ៊ានហើបមាត់មួយសោះ តែពេលមកផ្ទះ តែមានខ្សឹបគ្នា តែគេឮអត់បាន"[328]។

166. ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ បានផ្តល់សក្ខីកម្មថា៖ "ការវាយចាប់ចង វាធ្វើបាបហ្នឹងជារៀងហូរហែរាល់ថ្ងៃហ្នឹង ប៉ុន្តែគេអត់ថាយកទៅវៃចោល ឬយកទៅសម្លាប់ទេ គេថាយកទៅរៀនសូត្រ ហើយសម័យនុ៎ង ខ្ញុំឃើញគេចងជាហូរហែអ៊ីចឹង ប៉ុន្តែថា គេថាយកទៅរៀនសូត្រ ហើយអ៊ីចឹងយើងក៏មិនបានសួរនាំគេដែរ គ្រាន់តែឃើញអ៊ីចឹងភ័យរកតែព្រលឹង រកតែអាយុជីវិតដូចគ្នាហ្នឹង។ មាននរណាបានទៅសួរនាំគេសម័យនោះ គេបិទសិទ្ធិយើងមិនឱ្យនិយាយស្តី មិនឱ្យដឹងឮអីទាំងអស់"[329]។ ដោយពន្យល់លម្អិត ដើមបណ្តឹងរដ្ឋប្បវេណីនេះបានថ្លែងថា៖ "កាលពីសម័យនោះ គ្មានអ្នកណាម្នាក់ហ៊ានតវ៉ាទេ។ កាលណាអ្នកណាហ៊ានតវ៉ា ហ៊ានរឹងរូស គេថាយើងហ្នឹងខ្មាំងក្នុងសហករណ៍។ អ៊ីចឹងរស់អត់បានយូរទេ គឺគេមានវិធានការយកទៅដោយមិនដឹងខ្លួនបាទ"[330]។

167. ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន បានរំឭកឡើងវិញអំពីរបៀបដែលពាក្យ "ក្បាលអ្នកណា សក់អ្នកហ្នឹង" ត្រូវបាន "គេនិយាយតែអ៊ីចឹងរហូត"[331]។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្ថែមថា៖ "ជាទូទៅៗ ប្រជុំសាមញ្ញ ១០ថ្ងៃម្តង ប្រជុំធំមួយខែម្តង។ ប្រជុំធំមីទ្បីង គឺមានពាក្យហ្នឹងជាសាមញ្ញទូទៅ"[332]។ គាត់បានពន្យល់ថា៖ "ក្បាលអ្នកណា សក់អ្នកហ្នឹង មូលហេតុមកពីដាក់លក្ខខណ្ឌបែប

---

[327] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/252.1 ទំព័រ ៧០ បន្ទាត់ ១៩-២១។

[328] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/252.1 ទំព័រ ៧០-៧១ បន្ទាត់ ២៥-១។

[329] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ E1/262.1 ទំព័រ ១៨ បន្ទាត់ ៥-៩។

[330] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ E1/262.1 ទំព័រ ៣៣ បន្ទាត់ ១៦-១៨។

[331] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/253.1 ទំព័រ ៥១ បន្ទាត់ ៧។

[332] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/253.1 ទំព័រ ៥១ បន្ទាត់ ២១-២២។

នេះ គឺមិនអាចមានបង ឬមានប្អូន មានឪពុក មានម្តាយ ជួយកូនណាបាន ជួយបងប្អូនណាបាន ឡើយ។ តែអ្នកណាខុស អ្នកហ្នឹងត្រូវអង្គការចាប់ចងយកទៅ អត់មានអ្នកណាមកធានាជួយបាន ជាដាច់ខាត។ នេះជាថា "ក្បាលអ្នកណាសក់អ្នកហ្នឹង""[333]។

***ការពិនិត្យតាមដាន និងតួនាទីរបស់ប្រជាជនមូលដ្ឋាន***

168. ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន បានពន្យល់ថា៖ "អ្នកចាស់ ១៨ ចាំលបឱបក្តាប់អ្នកថ្មី តើមាន និយាយអ្វីដែលខុសហ្នឹងមាគ៌ាគេឬអត់? ឃ្លានបាយ ហេវបាយ ហូបមិនឆ្អែត ឲ្យអ្នកចាស់ធ្វើការជា មួយនឹងអ្នកថ្មីហ្នឹងគឺលបឱបក្តាប់ បើមាននិយាយខុស គេនឹងយកយើងទៅកសាង។ បើកសាងបើ មានទោសឡើងគេស្អប់យើង គេដាក់ទោសធ្ងន់ គេយកយើងទៅរៀនសូត្របាត់។ ហ្នឹងអ្នកចាស់គេ ធ្វើការជាមួយយើងដើម្បីឱបក្តាប់យើងអ្នកថ្មី។ អត់មានអ្នកចាស់ធ្វើដោយខ្លួនទេ ធ្វើជាមួយគ្នាទាំង អស់"[334]។

169. ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ បានផ្តល់សក្ខីកម្មថា៖ "នៅសម័យខ្មែរក្រហមហ្នឹង គេបែងចែក ច្រើនៗប្រភេទបាទ។ វាមានកងកុមារ កងផលិត កងអ៊ីមេម៉ាយ កងកសិករ កងពូកសិករ កង ពូពោះម៉ាយអ៊ីចឹងទៅ កងយុវជន កងផលិត អ៊ីចឹងវាច្រើនប្រភេទណាស់របស់គេ គេរៀបចំរចនា សម្ព័ន្ធរបស់គេច្រើនណាស់។ ប៉ុន្តែ ក្នុងមួយកងៗហ្នឹង វាគេហៅកង៥០ៗ កង៥០ហ្នឹងគឺមាន៥០ នាក់ បើអ៊ីចឹងមនុស្សហ្នឹង ១៧មេសា ហើយនិងអ្នកមកពីស្រុកឃ្មួនហ្នឹងគឺរស់នៅជាមួយគ្នា។ អ៊ីចឹងថ្នាក់ដឹកនាំរបស់វា មានមេកង ពីរទៅបីនាក់ ពួកមូលដ្ឋានហ្នឹងគេអ្នកដឹកនាំយើង។ ហើយ អ៊ីចឹងគេបញ្ជាលើយើងទាំងពីការធ្វើការ ទាំងពីរដេកដើរឈរអង្គុយ បូករួមទាំងអស់នៅលើគេ ហ្នឹង"[335]។

[333] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/253.1** ទំព័រ ៥១ បន្ទាត់ ៧-១២។

[334] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/253.1** ទំព័រ ១៥ បន្ទាត់ ៩-១៣។

[335] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/262.1** ទំព័រ ១២-១៣ បន្ទាត់ ២១-២។

170. ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន បានរំឭកឡើងវិញថា មានមេដឹកនាំម្នាក់ដើម្បីរៀបចំក្មេងៗ ដោយនិយាយថា៖ "មានគ្រូ មានអីហ្នឹង គេដឹកនាំសម្រាប់នាំយើងធ្វើការ តែគេឲ្យតែយើងខំធ្វើការ មិនដែលបានមានសាលាមានអីឯណា បានរៀនបានចេះដឹង អត់មាន"[336]។

171. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី បានផ្តល់សក្ខីកម្មថា៖ "គេប្រមូលផ្តុំដូច្នេះ ដើម្បីស្រួលទៅធ្វើការងារផង និងស្រួលគេឱបក្តាប់ផង។ បើយើងនៅជាមួយប្រជាជនថ្មីដូចគ្នា យើងអាចហ៊ានលួចនិយាយរំឭកពីអនុស្សាវរីយ៍កាលយើងនៅភ្នំពេញ។ ប៉ុន្តែលុះដល់យើងមករស់នៅជាមួយអ្នកមូលដ្ឋានចាស់ដូច្នេះ គឺយើងនៅស្ងៀមស្ងាត់ដូចមនុស្សគអ៊ីចឹង។ មានតែភ្នែកសម្រាប់តែផ្លូវ ដើរឆ្ពោះទៅការដ្ឋាន ឯមាត់ទុកសម្រាប់តែបរិភោគបាយតែប៉ុណ្ណោះ និងសម្រាប់និយាយការងារសំខាន់ចាំបាច់"[337]។

172. ដើមបណ្តឹងរដ្ឋប្បវេណី បេង បឿន បានផ្តល់សក្ខីកម្មថា៖ "ខ្ញុំបានឮម្តាយក្មេកប្រាប់ថា កូនឯងកុំមាត់កុំកអីឲ្យសោះ ដេក ហើយដាំដើមគ កុំមាត់"[338]។ គាត់បន្ថែមថា៖ "ពេលទៅធ្វើកងចល័ត ឬកន្លែងទីនានាក៏ហូបអាហារមិនបានគ្រប់គ្រាន់ដែរ ហើយកម្លាំងពលកម្មក៏ឲ្យខំប្រឹង ឲ្យធ្វើស្រែកុំឲ្យសល់ដីមួយចំអាម។ ហើយស្រូវធ្វើបានគ្រប់គ្រាន់តែហូបមិនគ្រប់គ្រាន់ ពេលមកហូបម្តងៗតាំងដើរមកក្រវែលជុំវិញតុខ្លួនខ្ញុំ ដែលហូបរួមគ្នាប៉ុន្មាននាក់ហ្នឹង។ សួរថា ហូបឆ្អែតទេ បើឆ្លើយថា មិនឆ្អែត ក៏មិនបាន។ ហើយសួរឆ្ងាញ់ទេ ហើយខ្ញុំថាមិនឆ្ងាញ់ក៏មិនបាន សុទ្ធតែមានរឿងយកទៅសម្លាប់ចោលទាំងអស់"[339]។

### ii. ការគ្រប់គ្រងលើការបំលាស់ទី - វិធានការដែលត្រូវបានចាត់ឡើងដើម្បីទប់ស្កាត់ ឬរារាំងការរត់គេចខ្លួន

[336] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ E1/288.1 ទំព័រ ២៩ បន្ទាត់ ១៣-១៥។

[337] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/251.1 ទំព័រ ៥២ បន្ទាត់ ១៥-១៩។

[338] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី បេង បឿន ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ E1/287.1 ទំព័រ ៥២ បន្ទាត់ ២០-២១។

[339] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី បេង បឿន ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ E1/287.1 ទំព័រ ៥២ ទំព័រ ១០-១៤ ត្រង់ [១៤:២៧:៤៦]។

173. ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន បានផ្តល់សក្ខីកម្មថា គាត់មិនត្រូវបានអនុញ្ញាតឱ្យវិលត្រលប់ទៅផ្ទះវិញទេនៅពេលដែលគាត់ត្រូវបានជម្លៀសនោះ។ គាត់បានថ្លែងថា៖ "គេអត់មានបានឱ្យមកមើលភូមិចាស់ មកមើលស្អីៗហ្នឹងវិញអត់ទេ អត់មានបានមកទេ គេអត់ឱ្យមកទេ គិតតែខំធ្វើការដើម្បីបំពេញការងាររបស់បក្ស"[340]។

174. ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ បានពន្យល់ថា កម្មករចាំបាច់ត្រូវការការអនុញ្ញាតក្នុងការដើរហើរក្នុងការដ្ឋាន ហើយបានពិពណ៌នាអំពីនីតិវិធីដើរហើរនេះ។ គាត់បានផ្តល់សក្ខីកម្មថា៖ "កាលពីសម័យនោះ អ៊ីចឹងការយើងធ្វើកំពុងពលកម្មនៅក្នុងការដ្ឋានហ្នឹង បើយើងត្រូវបត់ដៃ ឬបង់ជើងអីគេឱ្យយើងជម្រាបមេពួក ឬមេក្រុមរបស់គេ ថាខ្ញុំទៅបត់ជើង ឬមួយបត់ដៃ ហើយរយៈពេលប៉ុន្មាននាទី ឬប៉ុន្មានម៉ោង។ កាលណាបើយើងទៅយូរ ហ្នឹងគេថាយើងសតិអារម្មណ៍"[341]។

175. ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់លម្អិតថា៖ "កាលពីសម័យនោះ សម័យខ្មែរក្រហម គេយកទ្រឹស្តីមួយគេថា "អង្គការចាត់តាំង"។ បើយើងដើរក្រៅអង្គការចាត់តាំង ក្រៅពីភារកិច្ចដែលគ្មានអង្គការចាត់តាំង អាហ្នឹងគឺគ្មាននរណាហ៊ានដើរ។ បើទីតាំងយើង ឧទាហរណ៍ទីតាំងនៅចំណុចណាមួយ អ៊ីចឹងគេដាក់គោលដៅឱ្យដើរចម្ងាយ ១៣០ម៉ែត្រ ឬ ១០០ម៉ែត្រពីទីតាំងហ្នឹង។ គេអត់មានឱ្យដើរទៅគម្លាតឆ្ងាយទេ"[342]។

### iii. ការគ្រប់គ្រងលើជីវិតគ្រួសារ

176. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម វណ្ណៈ បានផ្តល់សក្ខីកម្មថា៖ "គេវាយធ្វើបាប ធ្វើទារុណកម្មហ្នឹងមកពីគេបាត់យើងពីកង យប់ឡើងគេដើររាប់ចំនួនមនុស្ស បើសិនជាមិនឃើញយើងនៅកន្លែងនោះ យើងម៉ោងបីភ្លឺឡើង ឡើងទៅវិញ លួចរត់មកហើយ ម៉ោងបីភ្លឺឡើងទៅវិញ ទម្រាំដើរដល់កងវាម៉ោងប្រាំ។ ទៅដល់ហ្នឹង យើងមិនទាន់បានធ្វើការផង គេសួរយើងយប់មិញយើងទៅណា? ហើយឆ្លើយ

[340] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ២៨ បន្ទាត់ ២-៣។

[341] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/262.1** ទំព័រ ៣២ បន្ទាត់ ៧-១០។

[342] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/262.1** ទំព័រ ៣២ បន្ទាត់ ១៩-២២។

ប្រាប់គេថា ខ្ញុំសុំមិត្តបង ខ្ញុំសុំទៅមើលម្ដាយខ្ញុំឈឺ។ តែគេថា យើងហ្នឹងចង់តែទៅផ្ទះ ទៅផ្ទះហ្នឹង មានបានអីមក ម៉ែឪហ្នឹងជួយយើងបាន នៅធ្វើការជាមួយអង្គការទៅ។ ហើយយើង ពួកខ្ញុំហ្នឹងក៏ឮសួរសម្ដីគេនិយាយអ៊ីចឹង ពួកខ្ញុំក៏នឹងឃើញភិតភ័យក្នុងខ្លួន។ គេថា "ឥឡូវបើអ្នកណាមិនគោរពវិន័យ ចាប់វាចងវៃហើយ ចាំឲ្យវាទៅធ្វើការ"។ មេកងបញ្ជាអ៊ីចឹង ពួកកុមារទាំងអស់ហ្នឹង គេចាប់នាងខ្ញុំចង ហើយវៃធ្វើបាបទៅ"[343]។

177. ដើមបណ្ដឹងរដ្ឋប្បវេណី យ៉ែម ខុន្នី បានពិពណ៌នាអំពីរបៀបដែលគាត់ "បែកពីគាត់ [គ្រួសារ] អ៊ីចឹងទៅ សុំគេមកលេង។ សុំមកលេងអ៊ីចឹងគេថា មិនទាន់ធ្វើការឲ្យគេហើយផងទៅសុំទៅលេង ទើបមក។ ហើយខ្ញុំពួកថ្មី ខ្ញុំមិនដឹងអី ចេះតែសុំគេមក នឹកម៉ែឪ ចេះនឹកប្អូន នឹកយាយ យាយគាត់ចាស់ ចេះតែសុំៗ ដល់សុំគេថា "ឥឡូវចង់សុំទៅអី?" ដល់ខ្ញុំថា "ខ្ញុំសុំទៅមួយកំណាត់ថ្ងៃទៅ" គេថា "បើសុំមួយកំណាត់ថ្ងៃ នោះបង្គីនៅមួយសម្រាប់ យកទៅកាប់ដីដំបូកទៅ"។ គេថាអ៊ីចឹងឲ្យខ្ញុំៗ"[344]។

178. ដើមបណ្ដឹងរដ្ឋប្បវេណី អៀម យេន បានផ្ដល់សក្ខីកម្មថា៖ "ការបែកពីឪពុកម្ដាយហ្នឹង ខ្ញុំបែកតាំងពីឆ្នាំ ១៩៧៦ ហ្នឹង ប៉ុន្តែគេឲ្យមានជួបឪពុកម្ដាយក្នុងមួយខែបីដង។ ដល់តែពេលយូរទៅ គេកាត់បន្ថយនៅត្រឹមតែមួយខែម្ដងទេ មិនដាច់រហូតទេ ប៉ុន្តែខ្ញុំត្រូវការឪពុកម្ដាយខ្ញុំ ការថ្នាក់ថ្នម ខ្ញុំនឹករឭកគាត់ពេក"[345]។ គាត់បានពន្យល់អំពីរបៀបដែលគាត់ "រត់ [ចេញពី] កងទៀតហ្នឹង ខ្ញុំរត់កងរត់ជាពីរលើកបីលើក។ គេតាមចាប់ខ្ញុំមកធ្វើបាបអ៊ីចឹង"[346]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានពិពណ៌នាអំពីរបៀបដែលគាត់ "នឹករឭកពេក ចង់ខ្ញុំសុំគេទៅជួបឪពុកម្ដាយ ក៏គេមិនឲ្យទៅដែរ ព្រោះអីគេមានផែនការគេថា ថ្ងៃ១០ ថ្ងៃ២០ ថ្ងៃ៣០ បើអ៊ីចឹងគេកាត់បន្ថយហើយ ខ្ញុំសូមទៅក៏គេមិនឲ្យខ្ញុំទៅ

---

343 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ វណ្ណៈ ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ៤៩ បន្ទាត់ ៦-១៣។

344 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី យ៉ែម ខុន្នី ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ៧២ បន្ទាត់ ៤-៨។

345 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អៀម យ៉េន ប្រតិចារឹក ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/286.1** ទំព័រ ៥០ បន្ទាត់ ១៧-១៩។

346 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អៀម យ៉េន ប្រតិចារឹក ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/286.1** ទំព័រ ៤៧ បន្ទាត់ ២២-២៣។

ដែរ ព្រោះខ្ញុំសុំម្តងពីរដងអ៊ីចឹងក៏គេមិនឲ្យទៅដែរ គេថាឲ្យយើងដឹងតែពីធ្វើការតាមកង"[347]។ ដើមបណ្តឹងរដ្ឋប្បវេណី អៀម យេន បានបញ្ជាក់ថា គាត់ត្រូវបាន "គេចាប់ទៅដីកកប់ហ្នឹង ពេលនោះ ខ្ញុំរត់គេចពីកងហ្នឹង ខ្ញុំសុំមិនបាន ខ្ញុំរត់គេចមក ដើម្បីរកជួបឪពុកម្តាយរបស់ខ្ញុំ"[348]។

179. ដើមបណ្តឹងរដ្ឋប្បវេណី យ៉ែម ខុន្នី ដែលមានអាយុ ១៤ ឆ្នាំនៅពេលនោះ បានផ្តល់សក្ខីកម្មថា៖ "មុនដំបូងនៅជាមួយគ្រួសារ មួយពោះមួយ មួយយាយអ៊ីចឹងទៅ។ ដល់ខ្ញុំនេះទៅ គេបំបែកតាមកងៗទៅនៅតាមកងទៅ។ ហើយឪពុកម្តាយខ្ញុំហ្នឹង នៅតាមប្អូនខ្ញុំហ្នឹងទៅ ហើយខ្ញុំទៅធ្វើការទៅ បងខ្ញុំទៅធ្វើការដែរទៅ"[349]។

180. ដើមបណ្តឹងរដ្ឋប្បវេណី តាក សាន់ បានផ្តល់សក្ខីកម្មថា៖ "មុនដំបូងគេឲ្យនៅ [ជាមួយគ្រួសារ និងប្តី] ដល់យូរទៅគេបំបែកជាកងជាក្រុមអ៊ីចឹងទៅ"[350]។

### iv. ការបរិភោគអាហាររួម

181. ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន បានផ្តល់សក្ខីកម្មថា៖ "យើងហូបតែក្នុងសហករណ៍ហ្នឹងទេ។ អ៊ីចឹងហើយបានមានអ្នកហេរ អ្នកហាត់ត្លញហ្នឹង បានមានគេយកទៅវែរចោល"[351]។

182. ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា ទាក់ទងនឹងការ "ហូបរួម គឺបាយបបរមួយវែកត្រឡោក។ បបរមួយវែកត្រឡោកហ្នឹងឆ្នាំងសម្លមួយដាក់កណ្តាល ហើយតុយើងហូបប្អូននាក់។ មួយវែកៗម្នាក់ហ្នឹងអស់ប៉ុណ្ណឹងឈប់ហើយ អត់មានអីថែមទៀតទេ។ ហើយអ៊ីចឹងទៅ យើងអត់ស្ងូវឆ្អែត

347 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អៀម យ៉េន ប្រតិចារឹក ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/286.1** ទំព័រ ៥០ បន្ទាត់ ២៣-២៥។

348 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អៀម យ៉េន ប្រតិចារឹក ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/286.1** ទំព័រ ៥១ បន្ទាត់ ៣-៤។

349 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យ៉ែម ខុន្នី ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ៧១-៧២ បន្ទាត់ ២៤-១។

350 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី តាក សាន់ ប្រតិចារឹក ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/286.1** ទំព័រ ២៣ បន្ទាត់ ១៩។

351 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/252.1** ទំព័រ ៤៧ បន្ទាត់ ១០-១១។

ដល់យើងសម្រុកការងារ តែមានភ្លាត់មាត់ថា "ហូបបាយអត់ឆ្អែត ហេវហត់" គេត្រូវចាប់យកទៅរៀនសូត្រហើយ មិនដឹងរៀនសូត្រម៉េច រៀនសូត្រទៅបាត់រហូត។"[352]។

### v. ការគ្រប់គ្រងលើផ្លូវភេទ

183. ទាក់ទងនឹង "ខុសសីលធម៌" ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡន បានផ្តល់សក្ខីកម្មថា៖ "ខុសសីលធម៌គេ អ្នកណាដែលខុសសីលធម៌ គេចាប់យកទៅរែកដី។ ដាក់រែកដីក្នុងមួយថ្ងៃឲ្យហើយប៉ុន្មានម៉ែត្រៗអ៊ីចឹងទៅ។ ហើយយើងដើរទៅរែកដី យើងគ្រាន់តែងាកមើលអ៊ីចឹងទៅ ឃើញគេរែកដីពីរគូ ខុសសីលធម៌ពីរគូ ដាក់ឲ្យរែកដីក្នុងមួយប្រឡាយហ្នឹង ពីរគូហ្នឹងចាស"[353]។ គាត់បានបន្ថែមថា៖ "គេថាលបស្រលាញ់គ្នាៗ ហើយស្ត្រីហ្នឹងមេម៉ាយ ហើយលបស្រលាញ់ជាមួយនឹងពូៗ។ ពូៗហ្នឹងខុសសីលធម៌គេដឹង គេដាក់ទារុណកម្មឲ្យរែកដី។ ហើយមួយចំនួនទៀតដាក់ទារុណកម្ម ហើយខ្មាសគេចងកសម្លាប់ខ្លួនចាស"[354]។ ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា៖ "ត្រង់ចងកខ្លួនឯង ឬក៏គេអ្នកចង ខ្ញុំអត់ដឹងទេ ព្រោះអ្នកមូលដ្ឋានគេមកនិយាយប្រាប់ថា អ៊ីហ្នឹងចងកសម្លាប់ខ្លួនចាស"[355]។

184. ទាក់ទងនឹងអ្នកដែលសម្លាប់ខ្លួនបន្ទាប់ពីរំលោភបំពានក្រមសីលធម៌ ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡន បានពន្យល់ថា គាត់ "ឮតាមគេ។ គេហ្នឹងជាអ្នកមូលដ្ឋានទៀតណាមកប្រាប់ហ្នឹង។ បែបមានចាប់សម្លាប់មែនក៏មិនដឹង ប៉ុន្តែអ្នកមូលដ្ឋានគេមកប្រាប់ខ្ញុំថា "អូះ! អ៊ីហ្នឹងខ្មាសគេ ឥឡូវចងកសម្លាប់ខ្លួនហើយ"។ ខ្ញុំអត់បានឃើញទេ ប៉ុន្តែដឹងតែខុសសីលធម៌ គេយកទៅដាក់នៅវត្តៗលាយបួរគេដាក់គុកនៅហ្នឹង"[356]។

---

[352] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/252.1 ទំព័រ ៤៧ បន្ទាត់ ៨-១៤។

[353] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/252.1 ទំព័រ ៥៧ បន្ទាត់ ១៤-១៧។

[354] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/252.1 ទំព័រ ៥៧ បន្ទាត់ ២០-២២។

[355] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/252.1 ទំព័រ ៥៨ បន្ទាត់ ៥-៦។

[356] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/252.1 ទំព័រ ៥៨ បន្ទាត់ ២-៤។

## ១.៤. ការប្រព្រឹត្ត និងការរំលោភបំពានដ៏ឃោរឃៅ

### i. ការរំលោភបំពានលើរាងកាយ

185. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម វណ្ណៈ បានផ្តល់សក្ខីកម្មថា គាត់ត្រូវបានដាក់ទោសបីដង។ លើកទីបី កើតមានឡើងនៅពេលដែលគាត់ឈឺធ្ងន់ និងមិនធ្វើការ។ "ខ្ញុំឈឺគ្រុនក្តៅៗយប់ៗអ៊ីចឹងថ្ងៃ -- យប់ក៏ក្តៅ ថ្ងៃក៏ក្តៅដែរ សុំគេឈប់ គេមិនឱ្យខ្ញុំឈប់ទេ តែខ្ញុំទៅសុំថ្នាំពេទ្យ មិនដែលបានថ្នាំពេទ្យទេ បានតែម្សៅដំឡូងមី ហើយក្រោយមក ម្តាយរបស់ខ្ញុំបានឱ្យទឹកដាំពីស្លឹកឈើផឹក។ ហើយក្រោយមក មនុស្សម្នាក់ចាប់ខ្ញុំម្តងទៀតដោយសារខ្ញុំមិនធ្វើការ តែទៅផឹកទឹកថ្នាំបុរាណវិញ។ បន្ទាប់មក ចាប់នាងខ្ញុំចងភ្ជាប់នឹងដើមឈើ ហើយនាំគ្នាវ៉ៃធ្វើបាបនាងខ្ញុំកុមារហ្នឹងចំនួន ២០នាក់ ទាំងខ្លួនខ្ញុំមានជំងឺជាប់ខ្លួន"[357]។

186. ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា៖ "មិនត្រឹមតែប៉ុណ្ណោះ វាមិនមែនវ៉ៃនឹងដៃទេ សូម្បីតែឫស្សីជាប់នឹងដែកគោល វាវ៉ៃនាងខ្ញុំមានស្លាកស្នាមលុះសព្វថ្ងៃ ចងនាំខ្ញុំសន្លប់នៅនឹងដើមឈើមិនដឹងខ្លួន។ គេចងខ្ញុំចោល១យប់ទល់ភ្លឺ។ លុះត្រាភ្លឺឡើង ខ្ញុំដឹងខ្លួនៗខ្ញុំហូរឈាមពេញខ្លួន។ ពេលខ្ញុំឈឺចាប់ ខ្ញុំត្រូវការថ្នាក់ថ្នមពីឪពុកម្តាយ តែរកឪពុកម្តាយមិនឃើញ។ ពេលនោះស្រែកដង្ហោយហៅក៏គ្មានអ្នកណាមកជួយខ្ញុំៗមានតែម្នាក់ឯង គ្មានអ្នកណាមកជិតខ្ញុំទាំងអស់។ មើលទៅឃើញតែអ្នកធ្វើបាប។ ខ្ញុំរកអ្នកណាមិនឃើញ ខ្ញុំនឹកឃើញដល់ឪពុកម្តាយ នឹកឃើញដល់បងប្រុសម្នាក់ដែលគាត់បានជួយបីបាច់ថែក្សាខ្ញុំ។ ខ្ញុំនៅដាច់ចេញពីឪពុកម្តាយខ្ញុំ បងខ្ញុំនោះគាត់ប្រហែលជា ១ខែ គាត់លួចមកមើលខ្ញុំម្តង បានឆ្មោតទុំបានដំឡូងដុតមកផ្ញើខ្ញុំ ដាក់ហោប៉ៅខោ។ ពេលថ្ងៃត្រង់ លួចមកមើលខ្ញុំមួយភ្លែតៗ ដើម្បីយកមកឱ្យប្អូនហូប។ ហើយលួងលោមខ្ញុំកុំឱ្យខ្ញុំយំ កុំឱ្យខ្ញុំនិយាយអី ឱ្យខ្ញុំខំប្រឹងធ្វើការ ខ្លាចអង្គការយកទៅសម្លាប់ចោល "អូន ខំប្រឹងធ្វើការទៅ""[358]។

187. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន បានផ្តល់សក្ខីកម្មថា "ក្មេង អាយុប៉ុណ្ណឹង ១៥ឆ្នាំ តវ៉ាហូបមិនឆ្អែត លួចបាយសំណាំអ្នកសេដ្ឋកិច្ចទៅរកត្រី យកទៅហូបគេយកទៅសម្លាប់ឃើញ យកទៅ

---

[357] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម វណ្ណៈ ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ៤៩-៥០ បន្ទាត់ ២១-១។

[358] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម វណ្ណៈ ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ៥០ បន្ទាត់ ៣-១២។

សម្លាប់ហ្នុង”[359]។ គាត់បានបន្ថែមថា៖ “កាលហ្នឹងកុមារហ្នឹងអាយុ ១៥ឆ្នាំ លួចបាយសំណុំខាងសេដ្ឋកិច្ចហ្នឹងយកទៅហូប ដល់ហើយគ្រូសិក្សាគេរាយការណ៍ទៅសិក្សា យកកុមារហ្នឹងទៅបាត់សម្លាប់បាត់ហ្នុង”[360]។

188. ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ បានផ្តល់សក្ខីកម្មថា៖ “ខ្ញុំមិនអាចគណនាបាន ឬប្រហែលប៉ុន្មាន ឬទំហំប៉ុន្មានអីប៉ុន្មានទេ ប៉ុន្តែបើយើងរស់នៅក្នុងកងហ្នឹង អាហ្នឹងគេថាអ្នកគោរពអង្គការវិន័យហ្នឹងគឺចេះតែធ្វើអ៊ីចឹងទៅ ធ្វើអត់ដឹងអត់ដឹងថ្ងៃ អត់ដឹងពេលវេលាម៉ោងសម្រាកទេ។ ហើយបើអ្នកណាខុសវិន័យរបស់គេ គឺគេទណ្ឌកម្មឲ្យរែកតែ ៤ម៉ែត្រ ឬ៣ម៉ែត្រអីក្នុងមួយថ្ងៃហ្នឹងឲ្យហើយ អាហ្នឹងគឺត្រូវតែហើយ”[361]។ គាត់ក៏បានពន្យល់ផងដែរថា៖ “បើសិនណាយើងចាប់ត្រីបាន ត្រូវយកទៅដាក់ក្នុងសហករណ៍។ បើយើងលួចលាក់ អាហ្នឹងគេចាប់ជាកម្លាំង មួយកងហារបស់គេអ៊ីចឹង គេឲ្យរកត្រីឲ្យយើងតែបុគ្គលម្នាក់ឯងហូបឲ្យអស់។ អាហ្នឹងកន្លែងខ្ញុំនៅគឺអ៊ីចឹងតែម្តង។ សកម្មភាពរបស់វាធ្វើទារុណកម្មមកលើយើងខ្លាំងណាស់”[362]។

189. ដើមបណ្តឹងរដ្ឋប្បវេណី អៀម យេន បានពិពណ៌នាអំពីការដាក់ទណ្ឌកម្មលើរាងកាយ ដែលគាត់បានទទួលរង បន្ទាប់ពីការប៉ុនប៉ងលួចដំឡូង[363]។ គាត់បានថ្លែងថា៖ “គេចងជើងខ្ញុំហ្នឹងជាប់គ្នាហើយដល់ដៃខ្ញុំហ្នឹងគេចងទៅក្រោយ ហើយខ្ញុំមានសក់ក្បាលបន្តិច អាបង្គួច អាចម្រឹងបង្គួចហ្នឹងចងសក់ខ្ញុំអ៊ីចឹងជាប់អាចម្រឹងបង្គួចនោះមួយថ្ងៃ។ ដល់ពេលអ៊ីចឹង ខ្ញុំស្រេកទឹក ស្រេកទឹកពេក ខ្ញុំថាចុះអង្កាលហ្នឹង ខ្ញុំហៅមិត្តបង “មិត្តបងអ្នា! ខ្ញុំសុំទឹកហូបបន្តិចមក” ហើយហៅក៏ហៅ គេបង្អត់អាហារខ្ញុំហ្នឹងអត់មានឲ្យអីហូបឯណា។ ខ្ញុំហៅអ៊ីចឹង ទៅម្តងមិនឮពីរដងមិនឮ ដល់ប្រហែល

---

[359] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ១៦ បន្ទាត់ ៩-១០។

[360] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ១៦ បន្ទាត់ ១៦-១៧។

[361] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/262.1** ទំព័រ ៣០ បន្ទាត់ ១២-១៥។

[362] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/262.1** ទំព័រ ១២ បន្ទាត់ ៧-១០។

[363] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អៀម យ៉េន ប្រតិចារឹក ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/286.1** ទំព័រ ៤៨ បន្ទាត់ ១-៦។

បីដងអ៊ីចឹង ខ្ញុំថា "មិត្តបង ខ្ញុំសុំទឹកបន្តិចមក" ដល់ខ្ញុំថា សុំហូប គេបញ្ច្រុកទឹកខ្ញុំ។ ដល់ពេលនេះ ប្រធានកងហ្នឹងគេឱ្យប្រធានក្រុមហ្នឹង គេយករំពាត់មួយហ្នឹង មិនឫស្សីទេ ខ្ញុំមើលរំពាត់ហ្នឹងខ្ញុំមើលរាងដូចជាមិនឃើញដែរ រាងស្មុងៗ ព្រោះអីគេចងខ្ញុំទៅអ៊ីចឹងហើយហ្នឹង ខ្ញុំមើលទៅខ្ញុំថាដូចជាបំពង់ឈើមួយប្រហែលជាប៉ុនមេដៃ គេយកមកដល់អ៊ីចឹងវ៉ៃពោះខ្ញុំខ្វាច់ៗ ហើយព្រមានថា "ថ្ងៃក្រោយឈប់ដើរលួចអ៊ីចឹងទៀត" ហើយខ្ញុំហ្នឹងក៏ឆ្លើយថា "ចាស""[364]។

190. ដើមបណ្ដឹងរដ្ឋប្បវេណីបានពន្យល់ថា គាត់បានស្នើសុំគេទៅបត់ជើងធំ និងថា គាត់ ""ធ្វើសំងំ [បត់ជើងធំ] ឱ្យបានយូរបន្តិចទៅ ឱ្យដៃយើងបាត់ហើម មើលដៃខ្ញុំនេះហើមធំណាស់"។ ដល់តែពេលយប់ ពេលថាយប់ពេលកងកុមារមកពីធ្វើការក្រុមជាមួយគ្នា ពួកខ្ញុំហ្នឹងអីហ្នឹងមកពីធ្វើការវិញអ៊ីចឹង គេក៏មើលឃើញពួកខ្ញុំបីហ្នឹងចងនៅលើផ្ទះដែរ។ អ៊ីចឹងក៏គេហៅពួកខ្ញុំហ្នឹងចូលអង្គប្រជុំ។ អង្គប្រជុំមានកុមារដូចគ្នាអ៊ីចឹង គេថា ពេលយប់ហ្នឹងប្រជុំៗកុមារគ្នាឯងអ្នកគេធ្វើការ ដូចថា គេធ្វើការសកម្មអ៊ីចឹង គេមកថា "ខ្ញុំសូមទិតៀន ហើយស្វ័យទិតៀនអ្នកណាដែលបានធ្វើខុសត្រូវទទួលកំហុស" ហើយខ្ញុំហ្នឹងដឹងខ្លួន ក៏ខ្ញុំឡើង។ ដល់ពេលអ៊ីចឹងទៅ ក៏គេឱ្យខ្ញុំហ្នឹងធ្វើការធម្មតាអ៊ីចឹងវិញទៅ"[365]។

191. ដើមបណ្ដឹងរដ្ឋប្បវេណី គាក សាន់ បានផ្ដល់សក្ខីកម្មថា គាត់ត្រូវភ្ជួរដីលាមកមនុស្ស ៖ "នាងខ្ញុំ គេប្រើខ្ញុំឱ្យភ្ជួរ ហើយខ្ញុំចេះតែភ្ជួរទៅ ខ្ញុំខ្លាចគេធ្វើបាបខ្ញុំ" ហើយ "បើ<សន្ទូង>ងាប់ គេយកយើងធ្វើទណ្ឌកម្មអ៊ីចឹងទៅ ប្រែពេក"[366]។

192. ដើមបណ្ដឹងរដ្ឋប្បវេណី យ៉ែម ខុន្នី បានពន្យល់ថា ប្រជាជននឹងត្រូវបាន "កសាង" ដែល "គេយកទៅស្ដីយើងហ្នឹងណា ហើយគេដាក់ទណ្ឌកម្មឱ្យរែកដីអ៊ីចឹងទៀតទៅថែម ដូចថា មួយថ្ងៃហ្នឹង ២០ អម្រែកអ៊ីចឹង គេដាក់លើសទៅជាជាង ២០ ហ្នឹងទៅ។ បានពួកខ្ញុំហ្នឹងខ្លាចធ្វើអ៊ីចឹង ធ្វើវាមិនទាន់។ បើជើងអីរុំនស្គមដូចឆ្អឹងនៅតែឆ្អឹង គ្មានស្អី ថាស្គមគ្រាន់តែដើរទាក់ស្មៅក៏ដួលដែរ។ ដល់តែយើង

[364] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អៀម យ៉េន ប្រតិចារឹក ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/286.1** ទំព័រ ៤៨ បន្ទាត់ ១២-២២។

[365] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អៀម យ៉េន ប្រតិចារឹក ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/286.1** ទំព័រ ៤៩ បន្ទាត់ ១-១១។

[366] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី គាក សាន់ ប្រតិចារឹក ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/286.1** ទំព័រ ៣៣ បន្ទាត់ ៣។

ដួលទៅ ថាយើងនេះពុត ដល់យើងឈឺ ថាយើងនេះពុត ធ្វើស្អីមិនកើត។ ហើយពុតស្អី បើគ្មានជីវជាតិឱ្យឆ្ងាញ់ ឱ្យនេះផង។ ស្គមឡើងជង្គង់អីវ៉ិនមួយជង្គង់ដូចជង្គង់កុក លើសជង្គង់កុកផង អាហ្នឹងជង្គង់មនុស្ស"[367]។

### ii. ទណ្ឌកម្មបង្អត់អាហារ

193. ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡួន បានបញ្ជាក់ថា "អ៊ីចឹងរបបគេតឹងរ៉ឹងណាស់ យើងអត់ធ្វើការគេត្រូវបង្អត់បាយយើង"[368]។ "ហើយកូនយើងទោះបីជាមិនទាន់ជា ក៏យើងត្រូវតែធ្វើការដែរ យើងឈប់បានតែមួយកំណាត់ថ្ងៃអ៊ីចឹងទៅ ហើយក៏មួយថ្ងៃអ៊ីចឹងទៅ។ ត្រូវទៅធ្វើការវិញ មិនទាន់ជាក៏ត្រូវតែទៅដែរ តែឈប់យូរ គេថាយើងសតិអារម្មណ៍ៗហ្នឹង គេយកយើងទៅវ៉ៃចោល អត់ហ៊ានឈប់យូរទេ"[369]។

194. ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡួន បានផ្តល់សក្ខីកម្មបន្ថែមទៀតថា ស្ត្រីដែលត្រូវមើលថែកូនរបស់ខ្លួនដែលមានជំងឺត្រូវបានបង្អត់អាហារ "យើងឈប់កូនឈឺ គេផ្តាច់អាហារយើង។ យើងហូបអាហាររបស់កូនដែលកូនឈឺហ្នឹង"[370]។

195. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម វណ្ណៈ បានផ្តល់សក្ខីកម្មថា "គេឱ្យពួកខ្ញុំទៅជីកសែងដីប្រឡាយហ្នឹង ចាប់តាំងពីម៉ោងប្រាំមួយព្រឹករហូតដល់ម៉ោងដប់មួយកន្លះថ្ងៃត្រង់។ បើពួកខ្ញុំធ្វើមិនហើយ គេមិនឱ្យបាយហូបទេ ពីព្រោះគេដាក់កំណត់កុមារហ្នឹងឱ្យគ្នា ១០ នាក់ហ្នឹងឱ្យហើយដីចំនួន ១០ ម៉ែត្រការ៉េហ្នឹង។ តែពួកខ្ញុំជួនកាលក៏ធ្វើហើយ ជួនកាលក៏ធ្វើមិនហើយ។ ហើយបើកាលណាជួបប្រទះដីទន់ទៅ ពួកខ្ញុំក៏បានធ្វើក្នុងមួយថ្ងៃទល់យប់ហ្នឹងហើយ។ បើថាដីរឹងទៅ កុមារខ្ញុំធ្វើមិនបានទេ។

---

[367] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យ៉ែម ខុន្នី ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ E1/288.1 ទំព័រ ៩ បន្ទាត់ ៦-១១។

[368] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡួន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/252.1 ទំព័រ ៤៦ បន្ទាត់ ១១-១២។

[369] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡួន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/252.1 ទំព័រ ៤៦ បន្ទាត់ ១៧-២០។

[370] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡួន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/253.1 ទំព័រ ១៥ បន្ទាត់ ២៣-២៥។

បើធ្វើមិនបាន គេមិនឱ្យហូបបបរទេ"[371]។ គាត់បានបន្តផ្តល់សក្ខីកម្មទៀតថា "នៅឆ្នាំ៧៧ ចុងឆ្នាំ ៧៧ នាងខ្ញុំទៅកាប់ទន្រ្ទានខែត្រ។ ក្នុង១ថ្ងៃគេឱ្យកាប់ឱ្យបានប្រាំបីបាច់ បើមិនបានដូចការកំណត់របស់ប្រធានកង គេមិនឱ្យហូបបបរទេ។ ហើយបើកាប់ បើរើសអាចម៍គោ ឱ្យរើសឱ្យបានបីបាវផ្ទួត បើរើសមិនបាន គេមិនឱ្យហូបបាយដែរ។"[372]។

196. ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន បានផ្តល់សក្ខីកម្មថា "បើយើងខំធ្វើការពេញលក្ខណៈដែលគេកំណត់ឱ្យហ្នឹង គេអត់ៗគេមិនបង្អត់យើងទេ។ តែបើសិនណាថា យើងធ្វើមិនហើយ គេត្រូវដកត្រូវដកជីវភាពយើងក្នុងពាក់កណ្តាលហើយ។ យើងត្រូវតែហើយ សម្រេចផែនការណ៍របស់អង្គការ"[373]។ "គេឱ្យខ្ញុំទៅដឹកមើលគោហ្នឹងរាកអាចម៍។ ដល់ពេលរាកអាចម៍ហ្នឹង គេបង្អត់បាយខ្ញុំ។ ហើយគេបង្អត់បាយ គេពីរនាក់ គេឱ្យមួយនាក់ទេ"[374]។ នៅពេលបរិយាយពីមូលហេតុដែលគាត់ត្រូវទទួលខុសត្រូវ គាត់បានពន្យល់ថា "ខ្ញុំអត់បានដឹងពីរឿងហេតុហ្នឹងដែរ ព្រោះខ្ញុំវាអត់ដឹង។ ឃើញគោវារាកអាចម៍ ស្មានថាគោវាស៊ីស្មៅខ្ចី វាប៉ះវារាកវាអី ខ្ញុំអត់ដឹង។ តែដល់ពេលឃើញរាកអ៊ីចឹងទៅ គេថាបើគោរាកអាចម៍ ម៉េចក៏មិនប្រាប់គេ។ ហើយខ្ញុំក៏មិនបានចាប់អារម្មណ៍ថាគោហ្នឹងវាឈឺជំងឺអីៗ ខ្ញុំវាមិនដឹង ស្មានថាវាស៊ីស្មៅខ្ចី ហើយវារាក ខ្ញុំមិនដឹង។ ដល់តែពេលគេហៅខ្ញុំទៅសួរ ហើយទៅព្រមានអ៊ីចឹងទៅ ខ្ញុំវាដូចវាឆ្ងល់"[375]។

---

[371] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម វណ្ណៈ ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ៤៧-៤៨ បន្ទាត់ ២៣-២។

[372] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម វណ្ណៈ ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ៥៣ បន្ទាត់ ១២-១៤។

[373] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ៣៥ បន្ទាត់ ៥-៧។

[374] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ៣៥ បន្ទាត់ ១២-១៤។

[375] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ៣៥ បន្ទាត់ ១៧-២០។

197. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សាវឿន បានផ្តល់សក្ខីកម្មថា "នាងខ្ញុំឈឺៗ ស្រាប់តែតំណាងកង គណៈកម្មការសេដ្ឋកិច្ចដាំបាយចុងភៅហ្នឹងថា ដកបាយខ្ញុំ ថាខ្ញុំឈឺសតិអារម្មណ៍ ហើយកាលហ្នឹងខ្ញុំ ឈឺគ្រុនចាញ់ ឈឺចេញកើតចៃ កើតអីមកពីខ្វះខាតអីហ្នឹង ជំនាន់ហ្នឹង ៧៦ ហ្នឹង ខ្ញុំឈឺៗខ្លាំង"[376]។

198. ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធីម បានផ្តល់សក្ខីកម្មថា "អារឿងអាហារហ្នឹង មិនដែលបានគ្រប់ គ្រាន់ គឺហូបតែបបរាវហ្នឹង បបររាវរហូតអត់ដែលបានហូបគ្រប់គ្រាន់ទេ"[377]។ គាត់បានបន្តទៀត ថា "អាខ្លះក៏គ្នាឈឺអ៊ីចឹងទៅ អាក្បាលជង្គង់ត្រមែងត្រមោង ក្បាលជង្គង់ធំជាងភ្លៅទៀត ដើរយោង តែអាគ្នាមិនចង់រួចផងទេ ហើយអាខ្លះក៏ឈឺទៅ គេថា ឈឺសតិអារម្មណ៍ ឈឺសតិអារម្មណ៍អី ដល់ រួចទៅគ្នាឈឺពិតប្រាកដ ដល់រួចទៅ គេថា "យី! ទុកវាក៏វាមិនចំណេញ ដកចេញក៏មិនខាត" យក ទៅបាត់អស់ទៅ"[378]។ "ពួកគេដែលមិនធ្វើការមិនបានហ្នឹង គឺអាហារបើតាមដែលខ្ញុំដឹងគឺគេបន្ថយ ទៀត គេថាឈឺហើយត្រូវបន្ថយទៀត ឲ្យគ្នាហូបបបររាវហើយហ្នឹងណា។ ហើយបើតាមពិតទៅ គេថាយើងអត់មានពលកម្មអី មិនចេញធ្វើការងារអី មិនបាច់ហូបច្រើនទេ ហូបបន្តិចៗបានហើយ អ៊ីចឹងបាទ"[379]។

199. ដើមបណ្តឹងរដ្ឋប្បវេណី តាក សាន់ បានផ្តល់សក្ខីកម្មថា កម្មករត្រូវបានគំរាមបន្ថយរបបអាហារ ប្រសិនបើពួកគេមិនអាចបញ្ចប់ការងាររបស់ខ្លួនបាន។ គាត់បានផ្តល់សក្ខីកម្មថា "នាងខ្ញុំគេគ្រាន់តែ គំរាមហ្នឹង តែហូបគេឲ្យនៅឲ្យហូបអ៊ីចឹង ប៉ុន្តែវាហូបមិនឆ្អែតគ្រប់គ្រាន់ទេ"[380]។

[376] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សាវឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ១៦ បន្ទាត់ ២១-២៣។

[377] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធីម ប្រតិចារឹក ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/289.1** ទំព័រ ២០ បន្ទាត់ ២៤-២៥។

[378] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធីម ប្រតិចារឹក ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/289.1** ទំព័រ ២១ បន្ទាត់ ៣-៦។

[379] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធីម ប្រតិចារឹក ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/289.1** ទំព័រ ២១ បន្ទាត់ ១០-១២។

[380] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី តាក សាន់ ប្រតិចារឹក ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/286.1** ទំព័រ ៣២ បន្ទាត់ ២៣-២៤។

## ២. អំពើអមនុស្សធម៌ផ្សេងទៀត

200. ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់នៅក្នុងសវនាការ បានបញ្ជាក់ថា ដំណើរការរបស់អង្គការក្នុងការបង្កើត និងធ្វើប្រតិបត្តិការសហករណ៍ និងការដ្ឋាន ដូចជា សហករណ៍ត្រាំកក់ ក្នុងគោលបំណងដាក់ប្រជាជនឱ្យធ្វើការ និងកែមុខ អប់រំកសាង និង "កំទេច" ខ្មាំង ជាការបំពានលើសិទ្ធិមានជីវិត និងសិទ្ធិទទួលបានជីវភាពគ្រប់គ្រាន់ សិទ្ធិមិនប្រឈមនឹងអំពើឃោរឃៅ អមនុស្សធម៌ និងបន្ថោកបន្ទាប និងសិទ្ធិមិនត្រូវបានចាប់ខ្លួនតាមទំនើងចិត្ត[381]។ អំពើនេះស្មើនឹងអំពើដែលមានលក្ខណៈ និងស្ថានទម្ងន់ដូចឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិផ្សេងទៀត និងបង្កព្យសនកម្មធ្ងន់ធ្ងរ ឬបង្កើតជាការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស។

### ២.១. លក្ខខណ្ឌការងារ

201. ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ បានផ្តល់សក្ខីកម្មថា "ហើយការធ្វើពលកម្មគឺពេលទៅដល់មុនដំបូងគឺថាធ្វើពី ក្រោកពីព្រលឹមអ៊ីចឹង ដល់ម៉ោងដប់មួយ វាឱ្យបាយហូបហើយ។ ដល់យូរទៅម៉ោងមួយដណ្តប់ហ្នឹងក៏គ្មានទាន់បានបាយដែរ រហូតដល់ម៉ោងពីរដណ្តប់ ដល់យូរៗទៅវាថាមិនបាច់មើលបាយទេ មើលការងារ ហើយការងារហើយចាំគិតបាយ អ៊ីចឹងរហូតដល់ម៉ោងពីរ ម៉ោងបី។ អ៊ីចឹងមួយថ្ងៃហ្នឹង ២៤ ម៉ោង ខ្ញុំនិយាយ ២៤ ម៉ោង មួយយប់មួយថ្ងៃហ្នឹង យើងអាចហូបបានតែពីរដងទេ។ ម៉ោង រយៈពេលម៉ោងបីហ្នឹង យើងហូបម្តង ដល់ក្រោយមកដល់ពេលល្ងាចម៉ោងពីរដណ្តប់យប់ហ្នឹងបានៗហូបៗ។ អ៊ីចឹងគេថាការងារ គេឱ្យមើលការងារ ការស្ទូងដក ការសាបព្រោះ ធាក់រហាត់ហ្នឹង គេឱ្យមើលទឹក កាលណាបើទឹកពេញអាហ្នឹងចាំហៅរបាយ បើកាលណាទឹកមិនទាន់ពេញកុំហៅ។ គេនិយាយតែប៉ុណ្ណឹង"[382]។

202. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម វណ្ណៈ បានផ្តល់សក្ខីកម្មថា ពេលខ្លះ ពេលយប់មានឱ្យកុមារមកកាប់រណ្តៅដាំដូងក្នុងកងចល័តនៅភូមិជ្រៃ[383]។ គាត់បានពន្យល់ថា "ការកាប់រណ្តៅដាំដូងនោះ វាមិន

---

[381] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៤៨ មាត្រា ២ មាត្រា ៥ មាត្រា ៩ និងមាត្រា ២៥។

[382] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/262.1** ទំព័រ ២៦ បន្ទាត់ ៤-១១។

[383] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម វណ្ណៈ ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ៥៧ បន្ទាត់ ៤។

ស្រួលទេ ពីព្រោះកុមារវាឱ្យកាប់តាំងពីម៉ោងប្រាំមួយរហូតដល់ម៉ោងដប់យប់ ឱ្យបានគ្រប់ចំនួន បើយើងកាប់មិនបាន វានៅបង្ខំឱ្យយើងកាប់ទាល់តែបាន។ វាហួសកម្លាំងកុមារនឹងធ្វើ។ ពួកខ្ញុំនឿយហត់យ៉ាងណាក៏មិនហ៊ានប្រកែកដែរ"[384]។ "ខ្ញុំទទួលការកាប់រណ្តៅនេះពេលយប់ហ្នឹង ក្នុងមួយខែហ្នឹង ខ្វះតែពីរបីថ្ងៃទេ ចន្លោះដែលពួកនាងខ្ញុំមិនធ្វើ"[385]។ នៅពេលដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានផ្លាស់ទៅភូមិខ្នារ គាត់បានបញ្ជាក់ថា "ពេលថ្ងៃ កាប់ទន្រ្ទានខែត្រ រើសអាចម៍គោ រែកដីដំបូក។ ពេលយប់ ខ្ញុំមកកាប់រណ្តៅដាំដូង និងចេកនៅវត្តខ្នារ បៀតវត្ត នៅម្តុំវត្តខ្នារ"[386]។

203. ដើមបណ្តឹងរដ្ឋប្បវេណី បេង បឿន បានផ្តល់សក្ខីកម្មថា "ការងារក្នុងកងចល័តបើខ្ញុំមើលទៅវាមិនល្អទេ គឺការងារសុទ្ធតែធ្ងន់។ ហើយកងចល័តដែលទៅខាងស្រែប្រាំងក៏សុទ្ធតែប្តូរស្លាប់ប្តូររស់ ហើយកងចល័តរបស់ខ្ញុំមួយទៀត ខាងជីកទំនប់នៅទួលក្រួសក៏យ៉ាប់។ ហើយសុទ្ធតែរែកឡើងកម្ពស់ ៦ ម៉ែត្រ ហើយឱ្យស្រែកហ៊ោសប្បាយនៅពេលដែល គេថាប្រតិភូគេមកម្តងៗ។ កន្លែងណាក៏សុទ្ធតែយ៉ាប់ទាំងអស់ អត់មានកន្លែងណាស្រួលទេ"[387]។

204. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី បានផ្តល់សក្ខីកម្មថា "កាលណារដូវច្រូតកាត់ គឺខ្ញុំធ្វើការសឹងតែមួយថ្ងៃ មួយយប់ទល់ភ្លឺ ប៉ុន្តែគ្រាន់តែថា ពេលណាយើងហូបបាយក៏ហូបទៅ ជួនកាល យើងលួចសម្រាកអី ដូចថា គេងលក់នៅលើគំនរចំបើងហ្នឹង គឺថាគេសឹងធ្វើទាល់ភ្លឺ ព្រោះអីគេធ្វើដាក់ គេធ្វើអា អ្នកណាមានកម្លាំងធ្វើទៅ អ្នកណាលក់ក៏លក់ទៅ គឺថាសឹងតែទាល់ភ្លឺ។ តើបើសិនជា នៅរដូវប្រាំងវិញ គឺយើងមានពេល មានម៉ោង ដូចថាម៉ោងពីព្រលឹមអ៊ីចឹង យើងរែកស្រូវ រែកអាចម៍គោ ឬ

---

[384] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម វណ្ណៈ ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ E1/288.1 ទំព័រ ៥៧ បន្ទាត់ ៦-៨។

[385] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម វណ្ណៈ ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ E1/288.1 ទំព័រ ៥៧ បន្ទាត់ ១០-១១។

[386] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម វណ្ណៈ ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ E1/288.1 ទំព័រ ៥៧ បន្ទាត់ ២៣-២៥។

[387] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី បេង បឿន ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ E1/287.1 ទំព័រ ៥៦ បន្ទាត់ ១៦-១៩។

ក៏រែកដីដំបូកអីដាក់ស្រែបានសម្រាកបន្តិច ហើយចូលចុះទៅទៀត។ ហើយបើយប់ឡើង យើងធ្វើជីកប្រឡាយជីកត្រពាំង។ អ៊ីចឹងជួនកាលដល់ម៉ោងដប់យប់ៗ"[388]។

## ២.២. លក្ខខណ្ឌរស់នៅ

### i. អាហារមិនគ្រប់គ្រាន់

205. យោងតាមផ្នែក ខ (១) ខាងលើពាក់ព័ន្ធនឹងការធ្វើឱ្យទៅជាទាសករ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មជាបន្តបន្ទាប់ស្តីពីអាហារមិនគ្រប់គ្រាន់ដែលបង្កជាភាពអត់ឃ្លាន និងការបង្អត់អាហារ។ ឧទាហរណ៍ ដើមបណ្តឹងរដ្ឋប្បវេណី តាក សាន់ បានរៀបរាប់ពីអារម្មណ៍របស់គាត់ថា "ជួនកាលហូបមិនឆ្អែតអ៊ីចឹងទៅ ក៏ខ្ញុំទឹកភ្នែកអ៊ីចឹងទៅ ដើរចេញទៅ ហូបហើយ ប៉ុន្តែមិនឱ្យគេឃើញ"[389]។

206. ដើមបណ្តឹងរដ្ឋប្បវេណី ជូ គីមឡន បានផ្តល់សក្ខីកម្មថា "នៅមើលថៃតែអាតួចហ្នឹង អាតួចជាងគេហ្នឹង ប៉ុនដល់យើងអត់បាយហូប ហូបអត់ឆ្អែត គេចែកបាយបបរហ្នឹង អាហ្នឹងទៅបានយូរមកបន្តិច បានគេបាយរួម។ មុនដំបូង គេចែកពោតដល់ឆ្នាំ ១៩៧៥ ហ្នឹង ដល់ខែណាទេ គេចែកៗឱ្យហូបរួមហើយ។ ៧៥ ហ្នឹងទៅបានយូរខែបន្តិច គេចែកបាយហូបរួម អាកូនហ្នឹងក៏ហូបអត់ឆ្អែត"[390]។

207. ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ បានផ្តល់សក្ខីកម្មថា ក្នុងកងចល័តរបស់គាត់នៅភូមិអូរក្រូច "មានអ្នកអត់បាយហ្នឹង អត់បាយស្លាប់ហ្នឹងពីរនាក់ដែរ។ អ៊ីចឹងគេបន្តប់បន្លែ គេថាមកពីខ្យល់គ ប៉ុន្តែអ្នកហ្នឹងកាលពីសម័យនោះវា កើត វាត្រូវមុតចប អ៊ីចឹងវាទៅចេញទៅជាដំបៅ ទៅជាមហារីក។

[388] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/250.1** ទំព័រ ៥២-៥៣ បន្ទាត់ ២២-៣។

[389] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី តាក សាន់ ប្រតិចារឹក ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/286.1** ទំព័រ ៣៧ បន្ទាត់ ១៨-១៩។

[390] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គីមឡន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/252.1** ទំព័រ ៤០ បន្ទាត់ ១៧-២០។

អ៊ីចឹងគេឱ្យហូបអត់ឆ្អែតទេ។ កាលណាហូប យើងឈឺហើយហូបបាយ គេថាយើងសតិអារម្មណ៍។ អ៊ីចឹងគេចេះតែបន្ថយអាហារអ៊ីចឹងរហូតដាច់ពោះស្លាប់នៅអូរក្រូចបាទ”[391]។

208. កុមារម្នាក់នៅអំឡុងពេលនោះ ដែលជាដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម វណ្ណៈ បានរៀបរាប់ថា “ពួកក្មេងៗខ្ញុំកាលណាដែលស្រេកឃ្លានពេកដើរទៅក្បែរៗព្រៃហ្នឹង សុំគេទៅបត់ជើងធំហ្នឹងប៉ុន្តែការពិតមិនមែនបត់ជើងធំទេ ពួកខ្ញុំទៅបេះស្លឹកថ្មីងបួតយកមកដាក់ហោប៉ៅលួចហូបពេលកាលណាដែលស្រេកឃ្លានពេក”[392]។ “ត្រូវពួកខ្ញុំពេលណាដែលអត់ គេបង្អត់ហ្នឹង ខ្ញុំហៅរពេកក៏ទៅលួចដំឡូងកន្លែងតាៗគាត់ដាំទៅ ជួនក៏ទៅឃើញតាៗនៅកន្លែងហ្នឹងក៏អត់ហ៊ានលួចដែរ បើគាត់ទៅបាត់ទៅក៏លួចដកដំឡូងហ្នឹងហូប មិនបានដំឡូងឆ្អិនទេ ហូបដំឡូងឆៅ”[393]។

## ២.៣. កង្វះការថែទាំផ្នែកវេជ្ជសាស្ត្រ

209. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី បានផ្តល់សក្ខីកម្មស្តីពីការសម្រាលកូនទីពីររបស់គាត់។ គាត់បានរៀបរាប់ថា “ខ្ញុំចេះតែឈឺពោះ ស្រីម្នាក់ជាប្រធានពេទ្យក៏មកមើលខ្ញុំដែរ។ នាងនោះដល់ឃើញខ្ញុំកើតកូនមិនស្រួលដូចគេដូចឯង ក៏មកពិនិត្យខ្ញុំញឹកញាប់ណាស់។ គេពិនិត្យទៅគេនិយាយថា កូននៅពោះខ្ញុំនេះមិននៅទេ។ បានសេចក្តីថា កូននោះស្លាប់ហើយ។ ខ្ញុំក៏ប្រាប់ពេទ្យថា បើដូច្នេះ ពេទ្យប្រញាប់យកចេញទៅ ខ្ញុំឈឺខ្លាំងណាស់”[394]។ មេពេទ្យនោះនៅក្មេង ខ្ញុំគិតថាប្រហែលជាគ្មានបទពិសោធន៍អ្វីទេ។ បានជាគ្រាន់មកស្ទាបពោះខ្ញុំ ហើយវិនិច្ឆ័យថា កូននោះស្លាប់នៅក្នុងពោះ។ ខ្ញុំ

[391] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/262.1** ទំព័រ ៣៣ បន្ទាត់ ២១-២៥។

[392] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម វណ្ណៈ ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ៤៨ បន្ទាត់ ១៥-១៧។

[393] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម វណ្ណៈ ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ៥៦ បន្ទាត់ ២០-២២។ ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា “ចាស ដែលខ្ញុំមិនបានទៅធ្វើការ គេកាត់របបអាហារហ្នឹង វាច្រើនដងណាស់ ក៏ប៉ុន្តែគេកាត់ បើខ្ញុំអត់បានទៅធ្វើហ្នឹង ជួនកាលគេកាត់ពេលព្រឹក អ៊ីចឹង ថ្ងៃត្រង់អ៊ីចឹង ជួនកាលក៏កាត់ពេលល្ងាចអ៊ីចឹងទៅ វាច្រើនដងអ៊ីចឹងដែរ”។ ការណ៍នេះបានកើតឡើង “ចំនួន១ខែ ឬក៏២ខែម្តងទេ មិនមែនរាល់សប្តាហ៍ទេ”។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម វណ្ណៈ ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ៧១ បន្ទាត់ ៧-១៣។

[394] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/250.1** ទំព័រ ៦៤ បន្ទាត់ ១៤-១៦។

ក៏និយាយថា "សូមពេទ្យយកចេញទៅ ពីព្រោះខ្ញុំឈឺខ្លាំងណាស់" ព្រោះខ្ញុំមិនដែលកើតនេះជាកូនកើតដំបូង។ បើសិនណាជាពេទ្យ គេមានសមត្ថភាព គេច្បាស់ជាមានវិធីហើយ ប៉ុន្តែនេះពេទ្យអត់សមត្ថភាពទេ គឺទុកខ្ញុំចោលតាំងពីខ្ញុំឈឺពោះពេលព្រលឹមថ្ងៃពុធ រហូតដល់ព្រលឹមថ្ងៃព្រហស្បតិ៍ទៀត គឺកើតៗដោយគេហៅថាយថាកម្ម កើតដោយធម្មជាតិមក"[395]។ "ប្រាកដណាស់ គឺថារារស់ដល់សព្វថ្ងៃនេះ ឈ្មោះ ស៊ូ បុទម"[396]។

210. ពេទ្យដែលខ្ញុំទៅសម្រាលកូននោះឈ្មោះហៅថា "ពេទ្យត្រពាំងគល់" ប៉ុន្តែមិនមែនជាពេទ្យទេ គឺតាំងនៅក្នុងវត្ត។ ពេទ្យនោះធ្វើពីឈើ មានខាងត្បូង ខាងជើង ខាងលិច។ ខាងជើង ខាងត្បូង គឺជាអ្នកជំងឺស្រាលចូលទៅ។ ខាងត្បូងជាអ្នកឈឺកើតកូន ចំណែកខាងលិចគឺជាអ្នកជំងឺធ្ងន់។ ជំងឺធ្ងន់គឺថាតែកាលណាចូលទៅគឺស្លាប់ហើយ។ ភាគច្រើនគឺស្លាប់អត់មានអាចជាមកវិញទេ។ ចំណែកឯមន្ទីរកន្លែងដែលខ្ញុំកើតកូន គឺជាសាលារៀនទេ គេយកធ្វើមន្ទីរពេទ្យហ្នឹង។ គេសាលាវែងអ៊ុំចឹង គេគ្រាន់តែបាំងមួយកំណាត់ហ្នឹងធ្វើជាកន្លែងពេទ្យ កន្លែងសម្រាលកូន មួយកំណាត់ទៀតសម្រាប់ស្ត្រីដែលកើតកូនហើយរស់ ដូចថារង់ចាំថ្ងៃចេញមក កើតកូនហើយមកគេងនៅមួយបន្ទប់ជុំគ្នាអ៊ុំចឹង។ ហើយគេដុតខសអ៊ុំចឹងទៅឱ្យវា គេហៅថា អាំងភ្លើង ឆេះទៅមានផ្សែងមានអីហ្នឹង គឺទាំងអស់គ្នាហ្នឹងនាំគ្នានៅក្នុងបន្ទប់ហ្នឹងហប់ដោយផ្សែងហ្នឹងទៅ ហើយមន្ទីរពេទ្យហ្នឹងគ្មានបង្គន់ គ្មានមុងគ្មានអីទេ អត់មានអីនេះទេ គឺថាចំណែកឯថ្នាំសង្កូវវិញគឺមានតែថ្នាំមូលៗ ដែលយើងថាថ្នាំអាចម៍ទន្សាយ ដូចថា ខ្មៅៗ វាមិនដឹងថាឈ្មោះថ្នាំអី។ ហើយស៊ីរ៉ូមដែលគេចាក់នោះ ខ្ញុំមិនដឹងគេយកទឹកអីមកទេ"[397]។

211. ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ បានផ្តល់សក្ខីកម្មថា "នៅកងយុវជន សម័យអាពត ខ្ញុំមិនដែលឃើញមានថ្នាំ មានការងារព្យាបាលដូចថាអ្នកជំងឺ អ្នកអីនៅក្នុងកងយុវជនខ្ញុំមិនដែលមានអ្នកទៅដេកពេទ្យទេ ព្រោះអីគេមិនឱ្យទៅដេកពេទ្យ ឬមួយគេមិនឈឺយ៉ាងណាក៏គេមិនដែលយកទៅ

---

[395] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/250.1** ទំព័រ ៦៤ បន្ទាត់ ២០-២៥។

[396] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/250.1** ទំព័រ ៦៥ បន្ទាត់ ៣។

[397] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/250.1** ទំព័រ ៦៥ បន្ទាត់ ៨-១៩។

ព្យាបាលតាមមន្ទីរពេទ្យ ឬមួយតាមគ្លីនិកផ្សេងៗដែរ។ អ៊ីចឹងកាលណាឈឺ បើយើងឈឺ អត់បាយ ងាប់ហ្នឹង ព្រោះអីវា អាហ្នឹងផ្តាច់ការថាអានៅតំបន់ហ្នឹងគេថា សម័យហ្នឹងកង់ប្រវត្តិសាស្ត្រតែ វិលៗហើយ តែខ្វាស់បាក់ តែខ្វាស់ជើងបាក់ជើង ខ្វាស់ដៃបាក់ដៃ"[398]។

212. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន បានផ្តល់សក្ខីកម្មថា "ខ្ញុំឈឺគ្រុនចាញ់ ឈឺចេញកើតចៃ កើតអីមកពីខ្វះខាតអ៊ីហ្នឹង ជំនាន់ហ្នឹង ៧៦ ហ្នឹង ខ្ញុំឈឺៗខ្លាំង យកទៅខ្ញុំដាក់មន្ទីរពេទ្យឃុំលាយបូរហ្នឹង។ ពេទ្យហ្នឹងចែកជាមុខសញ្ញាទៀត ពេទ្យថា ១៧ ឃុំលាយបូរ"[399]។ "យកខ្ញុំទៅចាក់សេរ៉ូមឱ្យលេបថ្នាំៗគ្រាប់ដូចធ្វើជាដំឡូងមី ហើយសេរ៉ូមជាទឹកដូងយកស្រស់ យកទៅ យកដាក់ជើងខ្ញុំហ្នឹងខូច ដើរទៅខ្ញើកៗទល់សព្វថ្ងៃនៅឈឺដែរ ខ្ញុំនាងខ្ញុំបានតានោះ គាត់ប្រាប់ថា "តែទុកស្វិតជើងហើយ" គាត់ឱ្យរកអង្ក្រង ពន្លៃ ស្រា ឱ្យស៊ុំមេស្រាយកមកស្អំរឹតទៅ"[400]។

## ២.៤. ការបាត់ខ្លួន

### *ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ៖ ការបាត់ខ្លួនរបស់សមាជិកគ្រួសារពីស្រុកត្រាំកក់*

213. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី បានពន្យល់ពីមូលហេតុដែលលោកស្រីសរសេរថា "កាលណាបាត់ខ្លួន គឺបាត់បង់អាយុជីវិតហើយ បាត់បង់សូន្យសង្ខារហើយ"។ "ខ្ញុំសរសេររឿងហ្នឹង ពីព្រោះខ្ញុំទៅដល់ភ្លាមបានប្រាំបួនថ្ងៃ ខ្ញុំឃើញបងស្រីថ្លៃខ្ញុំយំ។ ហើយខ្ញុំឃើញម្តាយក្មេកខ្ញុំប្រាប់ថា "កុំយំៗប្រយ័ត្នគេយកទៅ"។ ពេលគាត់យំហ្នឹង ដូចថាគាត់មិនបាននិយាយប្រាប់ខ្ញុំផ្ទាល់ទេ ប៉ុន្តែខ្ញុំលឺអ្នកដូចថា សាច់ញាតិអីប្តីខ្ញុំហ្នឹងថា "គេយកបងថ្លៃខ្ញុំទៅហើយ"។ ហើយដល់ពេលចុងរហូត ទៅចុះៗខ្ញុំទៅដល់ដំបូងនោះ ទៅដល់គេយកទៅដំបូង ដល់ពេលខ្ញុំតែងបទភ្លេងហ្នឹងជិតៗចប់ ជិតចុង ៧៥ អត់ឃើញត្រឡប់មកវិញៗ ហើយខ្ញុំដឹង ខ្ញុំលឺគេថាតែទៅហើយបាត់ហើយ អត់ ហើយមិនមែនមានតែគាត់មួយទេ មានស្ត្រីៗមួយគំនរទៀត ដែលមានប្តីជានាយទាហាន ជាគ្រូបង្រៀនជាអី គេយក

---

[398] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/262.1** ទំព័រ ២៧ បន្ទាត់ ១-៦។

[399] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ១៦ បន្ទាត់ ២៣-២៤។

[400] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ១៧ បន្ទាត់ ២-៤។

ទៅបាត់អ៊ីចឹងហើយ ហើយគេប្រមូលផ្តុំនារីៗអស់ហ្នឹង គេដាក់ថា "កងមេម៉ាយ"។ ខ្ញុំគ្រាន់តែលឺពាក្យ "កងមេម៉ាយ" គឺបានន័យថាប្តី អត់ប្តីហើយ មេម៉ាយហ្នឹង។ គេដាក់ឈ្មោះ "កងមេម៉ាយ" អ៊ីចឹងហ្នង។ អ៊ីចឹងបានខ្ញុំៗសន្មតថា ទៅហើយអត់ត្រឡប់មកវិញទេ"[401]។

214. ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា បងថ្លៃទីបីរបស់គាត់ ហុក ហេង ជាអ្នកបើកបរយន្តហោះ។ នៅពេលនោះគាត់ (ដើមបណ្តឹង) ស្នាក់នៅផ្ទះរបស់ឪពុកម្តាយគាត់នៅស្រុកត្រាំកក់។ គាត់បានផ្តល់សក្ខីកម្មថា "មិនមែនជាបងខ្ញុំបង្កើតទេ តែជាបងថ្លៃខ្ញុំទី បងថ្លៃទី ៣ បងថ្លៃទី ៧។ បងហ្នឹងបងស្រីបង្កើតរបស់ប្តីខ្ញុំឈ្មោះ ស៊ូ សុភាព ជាស្រី ហើយបងថ្លៃហ្នឹងឈ្មោះ ហុក ហេង គាត់ជាអ្នកបើកបរយន្តហោះ។ ពេលដែលទៅដល់ស្រុកត្រាំកក់បាន ៩ ថ្ងៃ ហ្នឹង ខ្ញុំសួរគាត់ក្រោយមកទៀតទេ គឺថាគាត់បានថា ពេលដែល ៩ ថ្ងៃគឺគេយកទៅ ប៉ុន្តែពេលគេយកទៅ ខ្ញុំអត់បានឃើញទេ ឃើញតែបងស្រីខ្ញុំយំ ហើយម្តាយក្មេកខ្ញុំថា "កុំយំ"[402]។

***ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ៖ ការបាត់ខ្លួនបងប្រុស និងក្មួយប្រុស***

215. ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន បានផ្តល់សក្ខីកម្មថា "បងប្រុសខ្ញុំម្នាក់ទៀត ធ្វើទាហាននៅខេត្តតាកែវ នៅជិតអូរតែលខេត្តបន្ទាយស៊ីប។ គាត់ធ្វើទាហានយូរដែលហើយ គាត់មានបុណ្យស័ក្តិ។ ហើយពេលបែកពីតាកែវទៅដល់វត្តចំប៉ា គេចាប់គាត់ចងចងច្រើនគ្នាបណ្តើរទៅ យកទៅរៀនសូត្រ។ រៀនសូត្របាត់រហូតមិនដឹងជារៀនសូត្ររបៀបម៉េចទេបាត់រហូត។ ចាស ហើយបងថ្លៃខ្ញុំក៏គាត់ចាំប្តីគាត់អត់ឃើញវិលមកវិញ ទៅរៀនអត់ឃើញវិលមកវិញ គាត់ក៏ប្រាប់ម៉ែខ្ញុំ គាត់ទៅស្រុកគាត់ ទៅស្រុកគាត់នៅជិតភ្នំជីសូរ"[403]។

216. ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន បានផ្តល់សក្ខីកម្មថា "ក្មេងដែលដកដំឡូងគេហូបក៏ត្រូវគេសម្លាប់។ ជីដូនមួយគ្រាន់តែនិយាយ វាច្រឡំមាត់ និយាយថា "ម៉ាក់។ ទៅមើលម៉ាក់ ចង់សុំច្បាប់ពី

[401] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/250.1** ទំព័រ ៥៥-៥៦ បន្ទាត់ ២៣-៦។

[402] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/251.1** ទំព័រ ៥៩ បន្ទាត់ ២១-២៥។

[403] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/252.1** ទំព័រ ៤៤ បន្ទាត់ ២-៦។

កងយុវជនទៅមើលម៉ាក់នៅភូមិ” គេថាយើងមិនជម្រុះជម្រះពីពុករលួយ ពីសក្តិភូមិ ក៏គេចាប់យកទៅរៀនសូត្រ។ មិនដឹងជារៀនសូត្រនៅណា បាត់រហូតដល់សព្វថ្ងៃ។ ឈ្មោះ ចន្ធី ជីដូនមួយខ្ញុំប្រុស។ ក្មួយជីដូនមួយ”[404]។

### ដើមបណ្តឹងរដ្ឋប្បវេណី ជូ គីមឡុន ៖ ការបាត់ខ្លួនកម្មករ ៣ នាក់នៅឆ្នាំ ១៩៧៧

217. ដើមបណ្តឹងរដ្ឋប្បវេណី ជូ គីមឡុន បានផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងការបាត់ខ្លួនកម្មករ ៣ នាក់នៅពេលមេដឹកនាំជាន់ខ្ពស់ចុះតាមមូលដ្ឋានថា “តាំងពីយើង ៧៦ រហូតដល់ ៧៧ ខែប្រាំង ឲ្យតែខែប្រាំងយើងច្រូតហើយ (...) ហើយអ្នកដឹកប្រឡាយហ្នឹង មិត្តភក្តិខ្ញុំមានបីនាក់ ដែលត្រូវបានបាត់ខ្លួនដោយសារត្អូញត្អែរថា “ហូបបាយអត់ឆ្អែត”។ ហើយ គាត់ គាត់ថា គាត់មានតែប៉ុណ្ណឹងហូបបាយអត់ឆ្អែតបាត់ខ្លួនទាំងបីនាក់”[405]។ គាត់បានពន្យល់ថា “ឆ្នាំ ១៩៧៧ ហ្នឹង ខ្ញុំដើរកងមុខទៅឆ្ងាយ ៧៧ ហ្នឹង ប៉ុន្តែខែមិនដឹងខែណា ខ្ញុំចាំមិនច្បាស់ មិនដឹងជាខែ ២ ខែ ៣ ឬក៏ខែ ៤ ខែ ៥ ខ្ញុំចាំខែអត់ច្បាស់ទេ ព្រោះវា យើងវាយូរ អត់ច្បាស់។ ហើយមេដឹកនាំទាំងបីនាក់ហ្នឹងគាត់ជិះឡានទៅ។ ជិះឡានទៅឈប់នៅកន្លែងស្ពានីយ៍គោលស្ពានអូរចំបក់ហ្នឹង គាត់ចុះដើរមើលពួកខ្ញុំរែកដី ដើរអ៊ីចឹងទៅលិចទៅ ហើយមេកង មេគណៈឃុំអីទៅតាមទាំងអស់។ ដើរទៅតាមជាមួយគាត់ទាំងអស់។ ហើយបន្ទាប់មក បានមួយថ្ងៃពីរថ្ងៃ បានមានបាត់មិត្តភក្តិខ្ញុំអស់បីនាក់ ចាស”[406]។

### ដើមបណ្តឹងរដ្ឋប្បវេណី ជូ គីមឡុន ៖ ការបាត់ខ្លួនមិត្តភក្តិពីរនាក់

218. ដើមបណ្តឹងរដ្ឋប្បវេណី ជូ គីមឡុន បានផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងស្ត្រីពីរនាក់ “ជាមិត្តភក្តិខ្ញុំនៅធ្វើការកង កងជិតជាប់ៗគ្នា។ ហើយគាត់ជាប្អូនរបស់លោកៗ ប្អូនរបស់លោកអ្នកចម្រៀងនៅវិទ្យុជាតិ អ៊ុយ សាមិត អ៊ុយ សាម៉ាន ហើយប្អូនលោក អ៊ុយ សាខន ជាអ្នកភ្លេង។ ចាស មិត្ត ស្រីៗពីរនាក់ហ្នឹងជាមិត្តភក្តិខ្ញុំធ្វើការនៅកង ហើយគាត់រែកដី គាត់ខ្លាំងពូកែណាស់ គ្មានអ្នកណាខ្លាំងដល់គាត់

---

[404] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គីមឡុន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/253.1 ទំព័រ ៦៧ បន្ទាត់ ២១-២៤។

[405] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គីមឡុន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/252.1 ទំព័រ ៤៨-៤៩ បន្ទាត់ ២៤-១៣។

[406] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គីមឡុន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/252.1 ទំព័រ ៤៩ បន្ទាត់ ២០-២៥។

ទេ។ គាត់រែកបង្គី បីមួយចំហៀងៗ។ រែកខ្លាំងហើយ ក៏គាត់ត្អូញៗថា "ហូបបាយអត់ឆ្អែតទេ" ហើយឱ្យពង្រឹងគោលជំហរៗប្ដេជ្ញាប្រឹងរែកដី ហើយហូបបាយអត់ឆ្អែត "ស្ពឹកល្ងាចព្រឹក ត្រឡាចព្រឹកល្ងាច ល្ងាចត្រឡាចស្ល អ៊ីចឹងរាល់ថ្ងៃហើយហូបអត់កើត"។ និយាយតែប៉ុណ្ណឹងគត់ ហើយក៏គេចាប់គាត់យកទៅឱ្យនៅពាណិជ្ជ គេឱ្យទៅហូបបាយឆ្អែត គេយកគាត់ឱ្យនៅពាណិជ្ជលាយបូរឱ្យទៅហូបឆ្អែត ឱ្យរែងអង្ករ។ រែងអង្ករនៅពាណិជ្ជហ្នឹង ហើយក៏ពួកនីរសារភូមិខ្ញុំហ្នឹង នីរសារភូមិខ្ញុំៗនៅហ្នឹង គេយកព័ត៌មាន យកនាំព័ត៌មានមកចូលភូមិ គេដឹងរឿងមិត្តខ្ញុំពីរនាក់ហ្នឹងទាំងអស់។ មានអ្នកកម្មាភិបាលនៅក្នុងហ្នឹង គឺចាប់រំលោភគ្រប់គ្នាទាំងអស់ នៅពាណិជ្ជ សាលាឃុំលាយបូរ។ បំពាននូវមិត្តភក្តិខ្ញុំពីរនាក់ហ្នឹងទាំងអស់។ ហ្នឹងឈ្លបភូមិខ្ញុំគេយកសំបុត្រអី មានការរាយការណ៍អីគេនីរសារឃុំភូមិហ្នឹងគេមកហើយ។ ហើយមកគាត់ទៅវិញ គាត់បាននិយាយលេងជាមួយខ្ញុំថា "អូយ! អត់បានទេ តែមានខុសគឺយកដាក់ពាណិជ្ជហ្នឹង ពួកគណៈឃុំ ពួកអ្នកធំនៅក្នុងហ្នឹង គឺគេរំលោភហើយជាការស្រេច។ ហើយគេនាំយកទៅបាត់ មិនដឹងគេយកដាក់នៅគុកណា សម្លាប់នៅកន្លែងណា បាត់រហូត"[407]។

### *ការបាត់ខ្លួនគ្រួសារជនជាតិវៀតណាម និងខ្មែរក្រោម*

219. ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡន បានផ្ដល់សក្ខីកម្មថា "គេបានប្រាប់ថា ជនជាតិវៀតណាម បើមានជនជាតិវៀតណាមនៅក្នុងភូមិយើង ត្រូវតែប្រមូលបញ្ជូនទៅស្រុកគេវិញ។ គេបោសសម្អាតប្រមូលទៅស្រុកគេវិញ ដើម្បីកុំឱ្យមានវៀតណាម"[408]។ "មេកងគេប្រាប់គាត់អ៊ីចឹងថា "គេឱ្យខ្ញុំទៅស្រុកវិញ។ គេថា ឱ្យខ្ញុំទៅតាមកាត់ទៅតាមត្រាំកក់។ ទៅតាមកំពត តាមទូក តាមកប៉ាល់។ តែអ្នកទាំងអស់នុង ពេលដែលទៅបាត់ យើងបានដឹងតាមខ្សឹបខ្សៀវ អ្នកដែលមូលដ្ឋានគេប្រាប់យើងថា "មិនមែនជាការពិតទេ"។ គេប្រាប់តែប៉ុណ្ណឹង។ គេថាវគ្គរៀនសូត្រ មិនមែនជាការ

---

[407] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/252.1 ទំព័រ ៥៨-៥៩ បន្ទាត់ ១២-១។

[408] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/253.1 ទំព័រ ១៩ បន្ទាត់ ២០-២២។

ពិតទេ យកទៅរៀនសូត្រហើយ"[409]។ "គេអ្នកមូលដ្ឋាន គេអាចដឹងការពិត បានគេប៉ានប្រាប់យើងថា មិនមែនបញ្ជូនទៅស្រុកទេ គឺជាការកុហកទេ"[410]។

220. ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន បានផ្តល់សក្ខីកម្មបន្ថែមទៀតថា គាត់ធ្វើការជាមួយពួកកម្ពុជាក្រោម។ "ជនជាតិវៀតណាមមួយគ្រួសារ និងជនជាតិខ្មែរក្រហម។ និយាយប៉ៃឡាំៗ និយាយវៀតណាមក៏ប៉ៃឡាំដែរ។ ហើយគ្រួសារមានប្តីមានប្រពន្ធ។ ស្ទួង អត់ចេះស្ទួងផង។ គាត់ស្ទួងដើរទៅមុខ ហើយយើងគ្រប់គ្នាដើរមកក្រោយ។ ដល់មេកងមេក្រុមយើងឃើញអ៊ីចឹង គេក៏ចុចឈ្មោះបញ្ជូនគាត់។ គេទៅប្រាប់គាត់ថា បញ្ជូនគាត់ទៅវៀតណាមវិញ ១៩៧៦។ ចាប់ គេបញ្ជូនគាត់ទៅវៀតណាមវិញ។ តាមការពិត ជាល្បិចពិសពុលដែលគេកុហកបោកប្រាស់។ គេបញ្ជូនគាត់ទៅធ្វើទារុណកម្មសម្លាប់ មិនដឹងជាសម្លាប់នៅឯណាទេ ពីរគ្រួសារ មានកូនតូច មានបី មានប្រពន្ធ រែកអម្រែកទៅ។ មកលាពួកខ្ញុំទៀត ធ្លាប់ស្ទួងជាមួយគ្នា។ មកលាថា "ប្រធានកងគេឱ្យខ្ញុំទៅស្រុកវិញ ខ្ញុំអរណាស់ គេបញ្ជូនខ្ញុំទៅស្រុកវិញ"។ គាត់អរ ហើយគាត់មកលាទៅ ហើយបាត់អត់មានដឹងគេសម្លាប់ឯណា"[411]។

221. គាត់បានបរិយាយក្នុងការធ្វើសក្ខីកម្មរបស់ខ្លួនពាក់ព័ន្ធនឹងមូលដ្ឋាននៃការដឹងឮរបស់គាត់។ គាត់បានពន្យល់ថា "គាត់ដឹងដោយរបៀបថា ពួកខ្មែរក្រហមមានចាប់មនុស្សលួចដំឡូង ដកដំឡូងអី ថាយកទៅពេលយប់ ទៅសម្លាប់ចោល។ ដឹងតាមរបៀបហ្នឹង របៀបថាពួកខ្មែរក្រហមមិនអាចបញ្ជូនជនជាតិវៀតណាម កម្ពុជាក្រោមហ្នឹងទៅប្រទេសទេ មានតែយកទៅសម្លាប់ទេ។ ដឹងដោយសារឃើញរបៀបរបបដែលឃោរឃៅ កាប់សម្លាប់រង្គាលហ្នឹង។ ដឹងតាមរបៀបចាស តាមរបៀប

---

[409] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/253.1** ទំព័រ ២០ បន្ទាត់ ១-៤។

[410] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/253.1** ទំព័រ ២០ បន្ទាត់ ៨-៩។

[411] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/252.1** ទំព័រ ៧១ បន្ទាត់ ១១-១៩។

ហ្នឹង។ យកទៅសម្លាប់ ដោយគ្មានគិតអាណិតថា ជីវិតមនុស្សរស់មក ខំរស់ ខំហូបបាយចង់រស់ គ្រប់ៗគ្នា តែយកទៅសម្លាប់ដូចជាសត្វធាតុតិរច្ឆាន"[412]។

***ការបាត់ខ្លួនស្វាមីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី តាក សាន់***

222. ពាក់ព័ន្ធនឹងស្វាមីរបស់គាត់ ដើមបណ្ដឹងរដ្ឋប្បវេណី តាក សាន់ បានផ្ដល់សក្ខីកម្មថា "ប្ដីខ្ញុំទៅរទេះ បីបួនប្រាំ ប្រាំមួយហ្នឹង បាត់ទាំងអស់។ ពេលម៉ោងប្រាំឡើងមក ឃើញតែគោបាត់ប្ដីខ្ញុំ ឃើញរទេះ ឃើញអីមក បាត់អស់រលីង។ ហើយខ្ញុំក៏ខ្ញុំមិនហ៊ានសួរទៀត មិនហ៊ានសួរប្ដីខ្ញុំថា ទៅណាមកណា ខ្ញុំមិនហ៊ានសួរទេ ខ្ញុំខ្លាច"[413]។ "ខ្ញុំមិនបានឃើញទេ។ ឲ្យ ប៉ុន្តែគេឲ្យប្ដីខ្ញុំហ្នឹង នាងខ្ញុំហ្នឹងទៅដឹក ស្រូវ អ៊ីចឹងថា យកទៅដាល់ យកមកដាល់អំបុកចែកគ្នាហូប។ ហើយដល់រួចទៅស្រាប់ប្ដីខ្ញុំទៅបាត់ អ៊ីចឹងទៅ បាត់មិនដឹងទៅអីណាមកអីណាអ៊ីចឹងទៅ មិនដឹងថាគេយកទៅអីណា។ មិនដឹងគេយក ទៅសម្លាប់នៅកន្លែងណា"[414]។ គាត់បានពន្យល់ថា "យកខ្លួនទៅបាត់ មានន័យថា មានតែប្ដីខ្ញុំគេ យកទៅណាបាត់ហ្នឹង មានតែយកទៅសម្លាប់ចោល បើមិនឃើញផង។ មកតែរទេះគោវិញ ទៅ ប៉ុន្មានរទេះបាត់ទាំងអស់"[415]។ ដើមបណ្ដឹងរដ្ឋប្បវេណី តាក សាន់ បានបញ្ជាក់ថា "នាងខ្ញុំអត់ ឃើញទេ។ ឲ្យគាត់ហ្នឹងទៅដឹកស្រូវពូជហ្នឹង ស្រាប់តែទៅនឹងវាឃើញតែរទេះគោមកវិញ តែប្ដីខ្ញុំ អត់ឃើញ រទេះគោទៅប៉ុន្មានហ្នឹង អត់ឃើញមកទាំងអស់គ្នា បាត់ទាំងអស់រហូតដល់ខ្ញុំបែកហ្នឹង

---

[412] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/252.1** ទំព័រ ៧១-៧២ បន្ទាត់ ២១-១។

[413] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី តាក សាន់ ប្រតិចារឹក ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/286.1** ទំព័រ ២៤ បន្ទាត់ ១៤-១៦។

[414] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី តាក សាន់ ប្រតិចារឹក ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/286.1** ទំព័រ ៣៨ បន្ទាត់ ៣-៦។

[415] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី តាក សាន់ ប្រតិចារឹក ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/286.1** ទំព័រ ៣៨ បន្ទាត់ ១១-១២។

ខ្ញុំរត់មកហ្នឹងបាត់រហូត"[416]។ "គាត់ចេញទៅអត់ឃើញត្រឡប់មកវិញទេ។ ធ្លាប់តែនៅ ដល់តែពេលហូបបាយហូបទឹកអីមកមូលគ្នា ហូបសហករណ៍"[417]។

### ការបាត់ខ្លួនឪពុករបស់ អ៊ុង សារឿន និងមន្ត្រីសាធារណរដ្ឋខ្មែរផ្សេងទៀត

223. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន បានផ្តល់សក្ខីកម្មថា "ប្រជាជនចេញពីក្នុងខេត្តតាកែវទៅច្រើនរាប់ម៉ឺនរាប់លានក្នុងខេត្តចេញទាំងអស់ជម្លៀសទៅទាំងអស់"[418]។ នៅវត្តចំប៉ាលើ "គាត់មានដើរកត់ថា "មិត្តយើងធ្វើអី? ប្រាប់មក! ខ្ញុំរកការងារឲ្យធ្វើវិញចូលធ្វើកន្លែងដដែលវិញ"។ ហើយគាត់ចាញ់ប្រាជ្ញា អត់ដឹង ដូចនាងខ្ញុំក៏អត់ដឹងដែរ ប្រាប់ទៅ កត់ថ្ងៃក្រោយ ស្រង់ឈ្មោះហ្នឹងយកទៅបាត់ៗទៅ"[419]។ ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា មានការបាត់ខ្លួនប្រជាជន "ដូចជា មាខ្ញុំគាត់ធ្វើគិញ គ្រូ ប៉េអឹម ប៉ូលីស ទាហាន គយ យកទៅ ថាទៅធ្វើការ បាត់រហូតទល់សព្វថ្ងៃ"[420]។

### ការបាត់ខ្លួនបងប្រុសរបស់ អ៊ុង សារឿន ឈ្មោះ អ៊ុង លឹម

224. បងប្រុងរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ឈ្មោះ អ៊ុង លឹម "រកសេដ្ឋកិច្ច ដល់ពេលរកបានអ៊ីចឹងទៅគាត់អ្នក ១៧ មេសា ដូចថា គាត់ស្គាល់អ៊ីចឹង គាត់សុំឲ្យត្រីមួយ ដល់ថ្ងៃក្រោយឡើងគេកសាងបងខ្ញុំ ស្រាប់យកទៅបាត់ទៅ"[421]។

### ការបាត់ខ្លួនមិត្តភក្តិរបស់ អ៊ុង សារឿន នៅឆ្នាំ ១៩៧៧

[416] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី តាក សាន់ ប្រតិចារឹក ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/286.1** ទំព័រ ៣៨ បន្ទាត់ ១៦-១៨។

[417] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី តាក សាន់ ប្រតិចារឹក ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/286.1 E1/283.1** ទំព័រ ៣៨ បន្ទាត់ ២២-២៣។

[418] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ១៨ បន្ទាត់ ១១-១២។

[419] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ១៨ បន្ទាត់ ១៦-១៨។

[420] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ១៨ បន្ទាត់ ២១-២២។

[421] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ១៩ បន្ទាត់ ៤-៥។

225. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន បានផ្តល់សក្ខីកម្មថា នៅឆ្នាំ ១៩៧៧ មិត្តរបស់គាត់ "ប៉ិនលួចអាហារ។ គាត់ហោរ គាត់លួចយកទៅហូប ទាន់ អង្គការទាន់ យកចាប់ពីរនាក់ទៅបាត់យកទៅរំលោភបាត់ដល់ថ្ងៃ បាត់រហូតទល់សព្វថ្ងៃ។ យកទៅសម្លាប់បាត់ទៅ អត់ឃើញមកវិញ"[422]។

*ការបាត់ខ្លួនរបស់យុវជនដែលបានលួចអាហារ*

226. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន បានផ្តល់សក្ខីកម្មបន្ថែមទៀតថា គាត់បានឃើញខ្មែរក្រហមយកកម្មករចេញទៅ៖ "កងយុវជន គាត់ហូបមិនឆ្អែត គាត់លួចៗជាដំឡូង លួចជាពោត អំពៅដាំខ្លួនឯងហ្នឹង ឪឡឹក តែបាន គេយកទៅកសាង ឃើញបណ្តើរទៅ ជួនណាក៏បានមកវិញ ជួនណាក៏បាត់ទៅ"[423]។ "យូរៗឃើញម្តង នាងខ្ញុំយូរៗឃើញម្តង"[424]។ "នាងខ្ញុំឃើញថ្ងៃ។ បើយប់ នាងខ្ញុំអត់ដឹងទេ ឃើញតែពេលថ្ងៃ"[425]។

*ការបាត់ខ្លួនសមាជិកគ្រួសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី យ៉ែម ខុន្នី*

227. ដើមបណ្តឹងរដ្ឋប្បវេណី យ៉ែម ខុន្នី បានផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងការបាត់ខ្លួនសមាជិកគ្រួសាររបស់គាត់ថា "ដល់ហើយគេដាក់ឡានទៅមិនយកទៅឯណា បាត់បង់ជីវិតអស់រលីង គ្មានសល់ ពោះមួយនៅសល់តែខ្ញុំម្នាក់រាល់ថ្ងៃ។ ទោះបីឈឺថ្កាត់ក៏មិនដឹងមានឪពុកម្តាយ មានបងប្អូនអីឯណាមករក្សានៅដេកលើរានទៅកន្លែងសហករណ៍ហ្នឹង"[426]។

*ការបាត់ខ្លួនសមាជិកគ្រួសាររបស់ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន*

---

[422] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ៥ បន្ទាត់ ១៨-១៩។

[423] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ១៧ បន្ទាត់ ១៧-១៩។

[424] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ១៧ បន្ទាត់ ២២។

[425] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ១៧ បន្ទាត់ ២៤។

[426] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យ៉ែម ខុន្នី ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ៧៤ បន្ទាត់ ៣-៥។

228. ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន បានផ្តល់សក្ខីកម្មថា នៅវត្តមួយជិតសហករណ៍ត្រពាំងថែង ព្រះសង្ឃទាំងអស់ត្រូវបានបញ្ជូនទៅក្រាំងតាចាន់ ៖ "បើគិតទៅលោកវាមាន ១៥ អង្គ តែ ១៥ អង្គ ទាំងលោកបង ហើយលោកពូខ្ញុំ។ តែមិនដឹងជាយកទៅខាងណា ព្រោះបាត់ទាំងអស់ហើយ អត់មានឃើញ។ ទៅដល់នៅសល់តែវត្ត កុដិអីវិនអត់មានឃើញទេ កុដិឈើបាត់អស់ នៅសល់តែកុដិថ្ម។ មិនដឹងជាគេយកទៅខាងណាខាងណី។ ហើយវិហារវិញហ្នឹងឃើញចាក់សោរជិត មិនដឹងជាដាក់ស្អីៗក្នុងហ្នឹង ខ្ញុំវាមិនបានដឹងដែរ គ្រាន់តែទៅជួយរៀបចំប៉ុណ្ណឹង ហើយខ្ញុំក៏បកមកសហករណ៍វិញមក គេថាហើយៗ យើងទៅក្រោយវិញ។ ក៏នាំគ្នាមកសហករណ៍ត្រពាំងថែងហ្នឹងវិញមក។ បានឮដំណឹងថា ពូវ៉ន ប្រាប់ហ្នឹងក៏ទៅៗ ប៉ុន្តែខ្ញុំនិយាយកាត់ទៅអំមិញ វាមិនយាយអត់បាន"[427]។

(២២៨*ស្ទួន*) ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន បានផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងការបាត់ខ្លួនបងប្រុសរបស់គាត់ ដែលជាព្រះសង្ឃដែលត្រូវចាប់ផ្សឹក រួចនាំយកទៅ ៖ "ព្រលឹមឡើងហ្នឹង បានទៅធ្វើការពីរបីថ្ងៃហ្នឹង ខ្ញុំក៏ទៅជួបជាមួយប្រធានឈ្លបគេហ្នឹង គេថាឲ្យទៅជួយមើលអីវ៉ាន់នៅឯវត្ត។ ហើយខ្ញុំស្មានថាលោកបងនៅហ្នឹង ខ្ញុំអត់បានដឹងដែរ ក៏ខំទៅហ្នឹងថាបានជួបលោកបង។ ដល់ពេលហើយអ៊ីចឹងទៅ ក៏ទៅអត់បានជួបលោកបង គេទៅណាអស់រលីង នៅសល់តែជីពរ។ ឃើញតែជីពរ ឃើញតែអី ហ្នឹងខ្ញុំក៏ គេឲ្យប្រមូលអាជីពរប្រមូលអីហ្នឹង។ ហើយឃើញព្រះអង្គឃើញអីហ្នឹងតាមកុដិហ្នឹង ឃើញបាក់ឃើញអីហ្នឹងក៏ប្រមូល ចេះតែប្រមូលយកមកដាក់នៅកន្លែងហ្នឹងជាមួយប្រធានឈ្លប។ ខ្ញុំក៏វាហួសចិត្តដែលបាត់លោកបងផង ណាមួយទៅកន្លែងដែលធ្លាប់គោរពបូជា ទៅជាស្ងាត់ឈឹងបាត់លោក បាត់អីអស់អ៊ីចឹងទៅ ខ្ញុំវាមានការស្តុតអស់ហើយវាបាត់ការ វារកនឹកឃើញអីក៏វាលែងឃើញហើយ ណាមួយបាត់ឪពុក ណាមួយបាត់លោកបង។ ហើយដឹងលោកពូដែលនៅបួសនៅវត្តចាក់ជ្រុំហ្នឹង។ ដល់ហេតុការណ៍ទាំងអស់នេះទៅវាឃើញទៅវាដូចថា វាទុក្ខសោកបន្តរហូតគ្មានពេលទំនេរ។ វាមានតែការបាត់បង់រហូតតាំងពី៧៥ រហូតទល់គ្នានឹង ៧៩"[428]។

***ការបាត់ខ្លួនបងប្អូនបង្កើតរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឡឹប នាង***

---

[427] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ២៧ បន្ទាត់ ៤-១០។

[428] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ២៦ បន្ទាត់ ១-១២។

229. ដើមបណ្តឹងរដ្ឋប្បវេណី ឡិប នាង បានផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងការបាត់ខ្លួនបងប្អូនបង្កើតរបស់គាត់ ថា "ខ្ញុំកំពុងជីកប្រឡាយ ប្អូនខ្ញុំខ្មែរក្រហមដឹករទេះសេះដាក់ ១២ នាក់យកទៅ។ យកប្អូនខ្ញុំទៅ យកទៅ ដល់ប្អូនខ្ញុំស្រែកថា បងអើយ! ខ្ញុំទៅហើយ។ ទៅយកទៅបាត់រហូតទៀត។ បាត់បងពីរ បាត់ប្អូនពីរ។ បងក៏បាត់ប្អូនក៏បាត់ បាត់អស់ ដល់អត់មានម៉ែមានឪ នៅឡោតោតែឯង"[429]។ ប្អូនពីរនាក់របស់ខ្ញុំឈ្មោះ "ឡិប ឡេះ និង ឡិប វី"[430]។

230. ដើមបណ្តឹងរដ្ឋប្បវេណី ឡិប នាង បានពន្យល់ថា បងប្រុស ឡិប ឡេះ និងបងស្រី ឡិប មើ របស់គាត់ ត្រូវបានគេយកទៅបាត់រហូត បន្ទាប់ពីពួកគេមានជំងឺ ៖ "ខ្ញុំនៅឆ្នោតថាងហ្នឹង ធ្វើការនៅហ្នឹង បងខ្ញុំឈឺ។ បងប្រុសឈឺ បងស្រីឈឺ ដល់ឈឺហើយយកទៅពេទ្យ ដល់យកទៅៗបាត់រហូត។ អត់មានឃើញដឹងបងដឹងប្អូនដឹងយកទៅដល់ណា។ យកទៅពេទ្យយកទៅបាត់រហូត អត់មានឃើញយកមកវិញទេ"[431]។ "គាត់ឈឺរាក ហើយក្តៅ។ យកទៅពេទ្យ យកទៅៗបាត់រហូត"[432]។

### *ការបាត់ខ្លួនរបស់អ្នកវិលត្រឡប់ពីវៀតណាមក្នុងបរិបទនៃកម្មវិធីដោះដូរគ្នា*

231. ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ បានផ្តល់សក្ខីកម្មថា "បើតាមការឃ្លាំមើល ហើយការពិនិត្យឃើញផ្ទាល់ អ៊ីចឹងពេលយើងផ្លាស់ប្តូរមកហ្នឹង គឺអ្នកស្រុកនៅភូមិខ្ញុំហ្នឹង វាមានច្រើនណាស់។ អ៊ីចឹងក្រោយពេលថ្ងៃរំដោះហើយ ខ្លះបាត់ទាំងគ្រួសារៗ ខ្លះណានៅសល់តែកូនម្នាក់អ៊ីចឹងទៅច្រើនៗគ្រួសារបាទ។ អ៊ីចឹងការដែលវាយកទៅសម្លាប់ ដោយប្រការណា បង្អត់បាយ ឬមួយយកទៅព្យាបាទដោយអំពើអមនុស្សធម៌ផ្សេងៗទៀត ក៏ខ្ញុំមិនដឹងថា គាត់នៅទីកន្លែងណាដែរណា អាហ្នឹង

[429] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡិប នាង ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ៧៩ បន្ទាត់ ២៣-២៥។

[430] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡិប នាង ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ៨០ បន្ទាត់ ១៤។

[431] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡិប នាង ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ E1/ 288.1 ទំព័រ ៧៩ បន្ទាត់ ១៥-១៧។

[432] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡិប នាង ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/ 288.1** ទំព័រ ៧៩ បន្ទាត់ ២០។

ខ្ញុំអត់ដឹងដែរ។ ប៉ុនក្រោយថ្ងៃរំដោះហើយ ឃើញបាត់មនុស្សច្រើន"[433]។ គាត់បានផ្តល់សក្ខីកម្មបន្ថែមទៀតថា "បាទ អាហ្នឹងបើខ្ញុំជម្រាបជូនលោកប្រធានឱ្យបានជ្រាបថា អ្នកដែលទៅរស់នៅជាមួយខ្ញុំហ្នឹងណា អ្នកមកពីវៀតណាមហ្នឹង មកពីវៀត--មកនៅខ្មែរហ្នឹង ពេលយើងរំដោះហើយ អាហ្នឹងអ្នកនៅជិតៗខ្ញុំហ្នឹងនៅសល់ប្រាំមួយនាក់បាទ"[434]។

*ការបាត់ខ្លួនប្អូនថ្លៃប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី បេង ហឿន*

232. ដើមបណ្តឹងរដ្ឋប្បវេណី បេង ហឿន បានផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងការបាត់ខ្លួនបងថ្លៃប្រុសរបស់គាត់ថា "ការបាត់នោះមកពីមេកងគាត់ចេះតែសួរដេញដោល ហើយនិយាយលេងៗ ក៏ប្អូនខ្ញុំវាចេះតែថា ខ្ញុំក៏ចេះដែរបើកឡាន ខ្ញុំក៏ចេះដែរបើកកប៉ាល់ហោះ ខ្ញុំដ៏ចេះដែររវៃដាក់ទីឡូ ចេះសព្វគ្រប់ពេក ដល់ប៉ុន្មានថ្ងៃប្រហែលជាបីបួនថ្ងៃក្រោយមក ស្រាប់តែបាត់សូនឈឹងតែម្តង។ ព្រោះអីវាចេះសព្វគ្រប់ពេក តាមខ្ញុំឮគេខ្សឹបប្រាប់មក អ្នកជិតខាងដែលស្រឡាញ់រាប់អានខ្ញុំ គេថា ឲ្យតែអួតចេះអ្វីគឺវាមិនឱ្យចេះលើវាទាំងអស់។ ដូច្នេះ បានជាបាត់ប្អូនខ្ញុំពេលហ្នឹងទៅ"[435]។ ក្រោយមក គាត់បានបន្ថែមទៀតថា "...បាត់ខ្លួនដោយមិនដឹងខ្លួន។ ដូច្នេះ ខ្ញុំសង្ស័យថា យកប្អូនខ្ញុំទៅសម្លាប់ចោល"[436]។

233. ដើមបណ្តឹងរដ្ឋប្បវេណី បេង ហឿន បានផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងការបាត់ខ្លួនប្អូនថ្លៃប្រុសម្នាក់ទៀត ប្រពន្ធ និងកូនៗរបស់គាត់ថា "ពេលដែលមកពីស្រែប្រាំងហើយ គេឱ្យខ្ញុំសម្រាកនៅក្នុងភូមិនៅក្នុងសហករណ៍ គេឱ្យខ្ញុំមើលគោៗ ហើយក៏ប្រើពុះអុស ពុះអ៊ុំចឹងទៅ។ ខ្ញុំក៏ដើរៗទៅមើលគោ ដេញគោក៏ប្អូនថ្លៃមួយទៀត ប្អូនថ្លៃខាងប្រពន្ធបង្កើតនឹងក៏វាឡើងបេះដូងៗ ពេលនោះ វាឃើញខ្ញុំក៏បោះដូងឱ្យខ្ញុំមួយថា "បង" គ្រាន់តែបងហ្នឹង បោះឱ្យមកៗស្រាប់តែ វាចុះដល់ក្រោម មានគេដឹកដៃទៅ

[433] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី វី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/262.1** ទំព័រ ២៨ បន្ទាត់ ៩-១៣។

[434] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី វី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/262.1** ទំព័រ ៤២-៤៣ បន្ទាត់ ២៤-២ (នៅក្នុងការឆ្លើយតបទៅនឹងសំណួរពាក់ព័ន្ធនឹងក្រុមដែលបានមកដល់ជាមួយគាត់ក្នុងស្រុកត្រាំកក់ក្នុងឆ្នាំ ១៩៧៦ ទំព័រ ៤១-៤២ បន្ទាត់ ២០-១)។

[435] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី បេង ហឿន ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ៤៩ បន្ទាត់ ១៧-២១។

[436] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី បេង ហឿន ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ៦០ បន្ទាត់ ៤-៦។

ទៀត។ ដឹកដៃទៅ ខ្ញុំអត់ដឹងថា ទៅណាទេ ដល់ខ្ញុំមកសហករណ៍វិញបានមើលឃើញទៅ គេចង ស្លាបសេកពីក្រោយអូសទាញទៅទាំងថ្ងៃត្រង់។ ហើយបានកូនខ្ញុំបាទ យំតាម ទៅប្រាប់មកដល់ ប្រាប់ខ្ញុំ...។ បានកូនខ្ញុំរត់ទៅប្រាប់ប្រពន្ធអាប្ដូ នោះ ក៏ប្រពន្ធ ប្ដូ នោះស្ទុះទៅឃើញ ក៏ស្រែកយំអង្វរ សុំគេមកទាំងកូនខ្ញុំទាំងអីហ្នឹងថា "កុំយំ អញយកតែខ្មាំងទេ" ហើយពេលនោះ ក៏អ្នកបណ្ដើរប្អូនថ្លៃ ខ្ញុំនោះ ច្រានឲ្យដួលមកក្រោយមក ហើយក៏គេនាំយកទៅ ទៅបាត់ទៅ មិនដឹងទៅទីកន្លែង ណា"[437]។ "អ្នកមូលដ្ឋាននៅហ្នឹងគេថា "អ្វីក៏ដោយជារបស់រួមទាំងអស់ មិនឲ្យហូបឯកជនទេ"។ បើហ៊ានបោះឲ្យខ្ញុំមួយហ្នឹង គឺចោទគាត់ហ្នឹងជាខ្មាំងតែម្ដង"[438]។

234. ពាក់ព័ន្ធនឹងការចាប់ខ្លួនប្អូនថ្លៃប្រុសម្នាក់ទៀតរបស់គាត់ ដើមបណ្ដឹងរដ្ឋប្បវេណី បេង ហឿន បាន រៀបរាប់ថាបានមើលឃើញហេតុការណ៍នោះដោយផ្ទាល់ភ្នែកថា "ខ្ញុំឃើញពីភ្នែកពិតតែម្ដង ពីចុះពី ដូងមក គេដើរបានមកដល់សហករណ៍ ខ្ញុំក៏ដើរតាមដល់ពីក្រោយ ហើយក៏ពេលនោះ ក៏ឃើញកូន រត់មកតាម ប្រាប់ថា គេចាប់ ពូប្ដូ ទៅបានខ្ញុំមើលឃើញទៅ។ ហេតុនេះហើយ បានខ្ញុំថាឃើញ ជាក់ស្ដែងនឹងភ្នែកខ្ញុំ"[439]។

## *ការបាត់ខ្លួនបងប្រុសរបស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ឹម វណ្ណៈ*

235. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ឹម វណ្ណៈ បានផ្ដល់សក្ខីកម្មពាក់ព័ន្ធនឹងការបាត់ខ្លួនបងប្រុសរបស់គាត់ អ៊ឹម ម៉ាច ថា "ពេលនោះបានជានាងខ្ញុំមិនទាន់បានព័ត៌មានអំពីថា បងប្រុសនាងខ្ញុំធ្វើជាទាហាន លន់ នល់ នោះ នាងខ្ញុំកាលពីមុនឮសួរថា គេថាបងប្រុសនាងខ្ញុំខុសសីលធម៌ សង្កត់ដៃនារីនៅនឹង ក្ដារ។ តែក្រោយមក អ្នកម្ដាយខ្ញុំថា "កូន បងប្រុសរបស់កូនឯងមិនមែនខុសសីលធម៌ទេ បងប្រុស កូនឯងអតីតជាទាហាន លន់ នល់។ កូនដឹងទេ?"[440]។ "អ្នកម្ដាយរបស់ខ្ញុំអ្នកប្រាប់ហ្នឹង គាត់ថា គេ

---

[437] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី បេង ហឿន ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ៤៩-៥០ បន្ទាត់ ២៥-១០។

[438] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី បេង ហឿន ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ៥០ បន្ទាត់ ១៤-១៦។

[439] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី បេង ហឿន ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ៥៩ បន្ទាត់ ១១-១៣។

[440] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ឹម វណ្ណៈ ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ៥១ បន្ទាត់ ២០-២៤។

តាមដានពីរឿងទាហានហ្នឹងយូរហើយ។ កូនឯងមិនដឹងទេ គេតាមដានបងកូនឯងយូរហើយពីរឿងទាហានហ្នឹង ប៉ុន្តែគេរកលេសចោទបងកូនឯងមិនបាន ប៉ុន្តែឥឡូវគេថា បងកូនឯងខុសសីលធម៌អ៊ីចឹងទៅ ដើម្បីយកសម្លាប់ ងាយស្រួលនឹងយកទៅសម្លាប់”[441]។ គាត់បានឆ្លើយថា “ធ្លាប់ឃើញ” នៅពេលត្រូវបានសួរថា តើគាត់ធ្លាប់បានឃើញគាត់ស្លៀកឯកសណ្ឋានទាហានទេ មុនឆ្នាំ ១៩៧៥[442]។

236. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម វណ្ណៈ បានផ្តល់ភ័ស្តុតាងចម្លងស្តីពីការបាត់ខ្លួនបងប្រុសគាត់ថា “នៅពេលនាងខ្ញុំដើររួច បានទៅធ្វើការនឹងគេ គាត់ក៏ ខ្ញុំក៏បានដំឡូងដុតមួយមើម ខ្ញុំលួចគេបានដំឡូងដុតមួយមើមហ្នឹង ខ្ញុំក៏ទៅរកគាត់ ពេលថ្ងៃបាយហើយ ថ្ងៃត្រង់ហ្នឹង។ ខ្ញុំនៅកងបៀតកន្លែងគាត់ធ្វើការហ្នឹង ខ្ញុំទៅរកគាត់។ ទៅរកគាត់ ទៅដល់សួរគេ ដើរអើតមើលកន្លែងគាត់ធ្វើការ មិនឃើញគាត់ៗ ខ្ញុំក៏សួរគេអ្នកស្រុក អ្នកភូមិនៅជាមួយគាត់ហ្នឹងឈ្មោះ សុវណ្ណ សួរគេទៅថាឃើញបងប្រុសខ្ញុំទេ? គេថា គេហៅកេសខ្ញុំមកខ្សឹប គេថាកុំមាត់ឮពេក ចាំបងប្រាប់ថា បងប្រុសអូនឯង មេកងស្មើដាក់ឡានយកទៅបាត់ហើយ។ ខ្ញុំសួរគាត់ថា គេយកគាត់ទៅណា? គាត់ថាគាត់ក៏មិនដឹងដែរ ឃើញដាក់ឡានមកលិចមក”[443]។

### *ការបាត់ខ្លួន វណ្ណារ៉ា*

237. ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡន បានផ្តល់ភ័ស្តុតាងចម្លងស្តីពីការចាប់ខ្លួន និងសម្លាប់ វណ្ណារ៉ា បន្ទាប់ពីគាត់បានលួចដំឡូងមួយមើមថា “ខ្ញុំបានដឹងរយៈពេលយូរ មកដល់-- បងខ្ញុំមកប្រាប់ៗហ្នឹង មិនដឹងជាប្រហែលជាកន្លះខែជាង។ បងខ្ញុំគាត់នៅសំរោងៗហ្នឹងគាត់មកប្រាប់ថា ហូបមិនឆ្អែត លួចដកដំឡូងគេដុតហូបជាញឹកញាប់ មិនមែនមួយដងពីរដងទេ លួចដកដំឡូងគេជាញឹកញាប់ ហើយត្រូវគេចាប់ចងសម្លាប់ហើយ ចងសម្លាប់”។ គាត់បានបញ្ជាក់ថា “រយៈពេលដែលគេចាប់ទៅសម្លាប់ គឺគេចាប់ទៅថ្ងៃហ្នឹង យប់ឡើងគេសម្លាប់ហើយ អត់មានទុកយូរទេ”។ បងខ្ញុំថា គេ

[441] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម វណ្ណៈ ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ E1/288.1 ទំព័រ ៥២ បន្ទាត់ ៥-៨។

[442] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម វណ្ណៈ ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ E1/288.1 ទំព័រ ៦៥ បន្ទាត់ ២២-២៣។

[443] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម វណ្ណៈ ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ E1/288.1 ទំព័រ ៥០-៥១ បន្ទាត់ ២០-១។

ចាប់យកទៅសម្លាប់ គេមិនដែលទុកយូរទេ យើងខ្លាំងលួចដំឡូង"[444]។ ដើមបណ្តឹងរដ្ឋប្បវេណី បានផ្តល់សក្ខីកម្មថា អ្នកនៅតំបន់ ១០៧ ដែលបានសម្លាប់បងប្រុសរបស់គាត់ ហើយ "គឺខុស ទីតាំងគ្នា។ ខ្ញុំមិនអាចដឹងអ្នកណាជាអ្នកសម្លាប់ ខ្ញុំអត់ដឹងទេ"[445]។

***ការបាត់ខ្លួនកុមារអាយុ ១៥ ឆ្នាំ ដែលបានលួចអាហារ***

238. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន បានផ្តល់សក្ខីកម្មបន្ថែមទៀតពាក់ព័ន្ធនឹងការយកកុមារអាយុ ១៥ ម្នាក់ទៅសម្លាប់។ គាត់បានលើកឡើងថា "ក្មេងហ្នឹង តវាំហូបមិនឆ្អែត លួចបាយសំណុំអ្នកសេដ្ឋកិច្ចទៅរកត្រី យកទៅហូប គេយកទៅសម្លាប់ ឃើញយកទៅសម្លាប់ហ្នឹង"[446]។ ដើមបណ្តឹងរដ្ឋប្បវេណីបានបរិយាយថា "កាលហ្នឹង កុមារហ្នឹង អាយុ ១៥ ឆ្នាំ លួចបាយសំណុំខាងសេដ្ឋកិច្ចរកត្រីហ្នឹង យកទៅហូប ដល់ហើយគ្រូសិក្សា គេរាយការណ៍ទៅសិក្សា យកកុមារហ្នឹងទៅបាត់សម្លាប់បាត់ហ្នឹង"[447]។ គាត់បានបញ្ជាក់ថា គាត់បានឃើញឧបទ្ទេវហេតុនោះដោយផ្ទាល់ភ្នែក[448]។ ផ្អែកតាមការសួរចម្លើយរបស់មេធាវីការពារក្តី ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា "កុមារលួចបាយទៅ ហើយយកទៅសម្លាប់"[449]។ "សេដ្ឋកិច្ចហ្នឹងរាយការណ៍ទៅគ្រូសិក្សា។ គ្រូសិក្សាហ្នឹង គេឱ្យនីរសារមកយកកុមារទៅបាត់ទៅ"[450]។

---

[444] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡុន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/253.1 ទំព័រ ៥២ បន្ទាត់ ១៨-១៩។

[445] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡុន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/253.1 ទំព័រ ៥២ បន្ទាត់ ១៨-១៩។

[446] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ E1/283.1 ទំព័រ ១៦ បន្ទាត់ ១១-១៥។

[447] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ E1/283.1 ទំព័រ ១៦ បន្ទាត់ ១៦-១៧។

[448] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ E1/283.1 ទំព័រ ១៦ បន្ទាត់ ១៦។

[449] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ E1/283.1 ទំព័រ ៣៩ បន្ទាត់ ១១។

[450] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ E1/283.1 ទំព័រ ៣៩ បន្ទាត់ ១៧-១៨។

## ២.៥. លក្ខខណ្ឌនៃការឃុំខ្លួននៅផ្សារអង្គរកា

239. ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធីម បានផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងលក្ខខណ្ឌនៃការឃុំខ្លួនគាត់នៅអង្គរកាថា "មុនដំបូង ខ្ញុំទៅឃើញភ្លើងហ្នឹងស្មានតែកន្លែងគេជីករណ្តៅអ៊ីចឹងទៅ ដល់រួចទៅបានខ្ញុំឃើញរោងមួយដែលសង់ផ្ទាល់ដី គេដាក់រនាបក្តារ ជញ្ជាំងក្តារ ដំបូលប្រក់ស័ង្កសី ប្រហែលជាទទឹង ៥ ម៉ែត្រ បណ្តោយ ១០ ម៉ែត្រជាងអីៗហ្នឹង។ ហើយដល់រួចទៅ ឈ្មោះ ម៉េង ហ្នឹង គេក៏យកអាសោទ្វារគុកហ្នឹងយកមកចាក់ ចាក់ហើយគេបើកទ្វារហ្នឹងទៅ គេរុញខ្ញុំបញ្ចូលទៅហ្នឹងទៅ ថាចូលទៅហ្នឹង ចង់ប្រកាច់ ចុះវាឆ្អេះអាទឹកនោមផង ស្អុយលាមកយើងហ្នឹងផង។ ដល់ហើយចូលទៅដល់ក្នុងហ្នឹងចង់ងាប់ម្តងទៀតហើយ ក្លិនស្អុយអសោច"[451]។ "ពួកគាត់ទាំងអស់ហ្នឹងគ្នាហ្នឹង (អ្នកទោស) ដូចអត់មានសុខភាពល្អទេ។ ខ្ញុំមើលទៅ នៅតែស្បែកដណ្តប់ឆ្អឹងដូចតែគ្នាទេ។ ខ្ញុំចូលទៅមុនដំបូង ខ្ញុំថែមទាំងអាណិតម្នាក់ឈ្មោះ អៀម សុខា ហ្នឹងទៀត។ ដូចថា គ្នាស្គមនៅតែស្បែកដណ្តប់ឆ្អឹងហ្នឹង ហើយរបបរបស់ខ្ញុំហ្នឹង គេឱ្យ ដួសមកឱ្យខ្ញុំមួយវែកក្រឡុម មួយវែកដួសសម្លហ្នឹងដួសមកឱ្យខ្ញុំ ខ្ញុំក៏អត់ហូបទេ។ ខ្ញុំថា ឃើញគ្នាវាស្គមស្គាំងពេក មានតែស្បែកដណ្តប់ឆ្អឹង។ ប៉ុន្តែអារឿងសុខភាព ខ្ញុំថាអត់មាននរណាមួយ អ្នកណាមួយមានសុខភាពល្អទេ អត់មានទេ។ អ្នកទោសទាំងអស់ហ្នឹង គ្មានតែសោះ"[452]។

240. ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា "ខ្ញុំបាទជាប់គុកហ្នឹងវារហូតដល់បុកដែកខ្នោះហ្នឹង ចុះគេដាក់អ្នកមុនហ្នឹង - អ្នកមុនគេឱ្យចេញទៅធ្វើការ ខ្ញុំហ្នឹងគេអត់ទាន់ឱ្យចេញទៅធ្វើការទេ អ៊ីចឹងដល់រួចទៅគេដកខ្នោះ។ ពេលព្រលឹមអ៊ីចឹង គេៗហូតដែករនុកហ្នឹងបាទ គេហូតដែករនុកហ្នឹងចេញទៅបញ្ចេញអ្នកមុនហ្នឹងទៅធ្វើការ នៅតែខ្ញុំម្នាក់ឯកគត់។ ដល់គេបញ្ចូលមកវិញ គេមិនបុកដែកខ្នោះហ្នឹងមកវិញ បុកទៅវាខុសរន្ធហ្នឹង ខ្ញុំតម្រង់មិនទាន់ត្រូវជើងឈាមល្អាច រហូតដល់ដំបៅរលួសរលួយជើងទៅទៀត អត់មានថ្នាំអីព្យាបាលេ។ បាទលោកមេធាវី ខ្ញុំជម្រាបអ៊ីចឹង អត់មានថ្នាំសង្កូវព្យាបាលទេជំនាន់នោះ។ ឈាមជើងល្អាច និយាយពីជើងទៅជាដំបៅ ឥឡូវហ្នឹងបើមិនជឿខ្ញុំ ខ្ញុំលាត់

---

[451] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធីម ប្រតិចារឹក ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ E1/289.1 ទំព័រ ២៥ បន្ទាត់ ១៥-២០។

[452] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធីម ប្រតិចារឹក ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ E1/289.1 ទំព័រ ២៥-២៦ បន្ទាត់ ២៤-៤។

ជើងឲ្យមើលស្នាម ទាល់តែឥឡូវ គន្លាក់ជើងអស់រលីងហើយ។ ហើយខ្ញុំ វា -- ជើងហ្នឹងអង្គុយយូរ អ៊ីចឹងហើយស្រិលហើមអ៊ីចឹងហ្នង"[453]។

241. ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា "ការឈឺចាប់របស់ខ្ញុំហ្នឹងមិនអាចមានអ្វីមកប្រៀបផ្ទឹមបានទេបាទ។ ខ្ញុំនឹកថាខ្ញុំនឹងមិនបានរស់មានថ្ងៃនេះទេ ខ្ញុំនឹកក្នុងចិត្តខ្ញុំ។ ព្រោះថាការឈឺចាប់អាផ្នែកផ្លូវកាយហ្នឹងវាឈឺហើយ ផ្លូវចិត្តហ្នឹងក៏វាពិបាកណាស់ទៅទៀត។ បត់ដៃ បត់ជើងអីហ្នឹងមិនងាយទេ ខ្ញុំថា ខ្ញុំតាំងពីខ្ញុំកើតមក ខ្ញុំមិនដែលជួបប្រទះទេ ទើបមកក្នុងជំនាន់ ៣ ឆ្នាំហ្នឹង ខ្ញុំជួបប្រទះធ្ងន់ធ្ងរយ៉ាងនេះ។ បត់ដៃ បត់ជើងអី គេមាន យើងដកទល់ជើងគ្នាអ៊ីចឹង។ បាទ គ្រែគេនោះពីរល្វែងមួយល្វែងខាងស្រីៗទៅ មួយល្វែងទៀតខាងបុរសៗ ហើយប្រឡោះកណ្តាល ហ្នឹងគេដាក់ខាបមួយ។ ខាបមិនមែនមួយ ខាបប្រហែលជាពីរបី។ ហើយខ្ញុំជាប់ជើងពីរពិបាកណាស់។ ពិបាករឿងបត់ជើងបត់ដៃហ្នឹង។ ទាល់រក គេអ្នកជាប់ជើងមួយ ទាញមកឲ្យជិត ខ្ញុំចាប់ខាបហ្នឹងដាក់មកក្រោយហ្នឹង បានជុះបត់ជើងបានបាទ។ ហ្នឹងការឈឺចាប់របស់ខ្ញុំទាំងផ្លូវកាយ ទាំងចិត្តគ្មាន មិនអាច គ្មានអីមកប្រៀបផ្ទឹមបានទេ ខ្ញុំថា ខ្ញុំស្លាប់ហើយ អត់នៅទេ។ ហើយមួយនោះ ដាច់ពោះបាយស្លាប់នៅជាប់គ្នានឹងខ្ញុំហ្នឹង មិនខ្ចីយកចេញទៀត ប្រហែលជា ២ យប់ ៣ ថ្ងៃបានយកចេញ។ បាទវាដាច់ជាតិបាយ ជាតិនេះអ៊ីចឹង ជាតិបបរ ដូចថាគ្នាឃ្លានមាំពេក ឈ្មោះវា អាប៉ាត់ៗ អាហ្នឹងនៅជាប់គ្នាហ្នឹងខ្ញុំតែម្តង។ ហើយខ្ញុំពិចារណារូបខ្ញុំ ថាខ្ញុំក៏ដូចជាគេអ៊ីចឹងដែរមើលទៅ"[454]។

## ៣. ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល

242. ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់នៅក្នុងសវនាការ បានបង្ហាញថា អំពើសកម្ម ឬអំពើអកម្មដែលធ្វើឲ្យមានការស្លាប់បាត់បង់ជីវិតត្រូវបានប្រព្រឹត្តឡើងនៅសហករណ៍ត្រាំកក់។

### ៣.១. ករណីជាក់លាក់នៃការកាប់សម្លាប់

#### *ការធ្វើមនុស្សឃាតប្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គីមឡុន*

[453] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធីម ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ E1/287.1 ទំព័រ ២៧ បន្ទាត់ ៧-១៥។

[454] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធីម ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ E1/287.1 ទំព័រ ២៧-២៨ បន្ទាត់ ២១-៧។

243. ដើមបណ្តឹងរដ្ឋប្បវេណី ជួន គឹមឡូន បានរៀបរាប់ពីការចាប់ខ្លួន និងសម្លាប់ប្តីរបស់លោកស្រីនៅឆ្នាំ ១៩៧៥ នៅរយៈពេល ៣ ឬ ៤ ខែបន្ទាប់ពីគាត់បានមកដល់ស្រុកត្រាកក់ នៅខែ សីហា[455]។ លោកស្រីបានផ្តល់សក្ខីកម្មថា "ដល់ពេលយប់ហ្នឹង ថ្ងៃដែលគេយកប្តីខ្ញុំទៅហ្នឹង គេយកទៅម៉ោងប្រាំបួន ខ្ញុំកំពុងនឹងលួងកូនឲ្យដេក។ គេមកហៅគាត់ទៅប្រជុំរៀនសូត្រ ហើយខ្ញុំបានតវ៉ានឹងគេទៀតថា "ម៉ោងប្រាំបួនហើយប្រជុំអីទៀត?" ថា "អត់ទេ តារិត ឲ្យហៅទៅប្រជុំ ប្រជុំរៀនសូត្រ"។ ហើយគាត់ក៏ឡើងលើកអាវពាក់ ហើយស្លៀកអត់បានស្លៀកខោទេ ថាប្រជុំមួយភ្លែតទេ គាត់ក៏លើកអាវពាក់ហើយស្លៀកក្រមាដើរចេញទៅ"[456]។

244. "ទៅបាត់រហូតដល់ ប្រហែលជាមួយម៉ោងកន្លះ មួយម៉ោងកន្លះ ឬពីរម៉ោងទេ ស្រាប់តែឮសូរស្នូរកាំភ្លើងបាញ់បីគ្រាប់។ ពេលទៅហ្នឹងស្ពាយកាំភ្លើងមួយដើម ចាស។ អាពួកឈ្លបបីនាក់យកទៅហ្នឹងមានប្រធានភូមិ និងឈ្លបឃុំ គេស្ពាយកាំភ្លើងមួយដើម យកគាត់ទៅហ្នឹង។ ហើយបន្ទាប់មកស្អែកឡើងៗ ពីបានមួយថ្ងៃ គេបញ្ជូនខ្ញុំចេញពីហ្នឹងហើយ ពីខាងជើងសាលាឃុំហ្នឹង គេបញ្ជូនចេញទៅហើយ។ គេបញ្ជូនខ្ញុំឲ្យទៅនៅកងផ្សេង ភូមិផ្សេង ខាងត្បូងសាលាឃុំៗលាយប្តូរម្តង ចាស។ ហើយប្រើធ្វើការអ្វីៗគ្រប់មុខជាទម្ងន់"[457]។

245. ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា ប្រជាជនមូលដ្ឋាន "បានប្រាប់ខ្ញុំថា គេសម្លាប់ហើយ។ គេសម្លាប់ប្តីខ្ញុំហើយ គេយកទៅសម្លាប់ហើយ ចងស្លាបសេក ស្ពាយកាំភ្លើងបណ្តើរយកទៅហើយ។ ហើយគាត់យំមួយយប់ទល់ភ្លឺ ទាំងខ្ញុំទាំងគាត់"[458]។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា គាត់បានដឹងពីការសម្លាប់ប្តីរបស់គាត់ក្រោយការដួលរលំរបបនេះ "នៅឆ្នាំ ១៩៨៩ ឬ ១៩៩០"[459]។ "គេ

---

[455] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/253.1 ទំព័រ ២៩ បន្ទាត់ ៦-២២។

[456] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/252.1 ទំព័រ ៣៨ បន្ទាត់ ៩-១៣។

[457] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/252.1 ទំព័រ ៣៨-៣៩ បន្ទាត់ ២៣-៤។

[458] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/253.1 ទំព័រ ៣០ បន្ទាត់ ៦-៨។

[459] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/253.1 ទំព័រ ៣១ បន្ទាត់ ១២។

ប្រាប់ខ្ញុំផ្ទាល់ ដល់ពេលបែក ១៧ មេសា ៧៩ បានគេប្រាប់។ គេប្រាប់ខ្ញុំថា គេសម្លាប់ប្ដីខ្ញុំនៅខាងលិចវត្តឬរ។ អាហ្នឹងកូន -- ឪពុកវាប្រាប់កូន កូនគេយកប្រាប់ខ្ញុំ។ គេថានោះសម្លាប់បង នួន នៅនោះ នៅព្រៃ ព្រៃដើមឈើទាលគុម្ពឫស្សី។ បានខ្ញុំដឹង ព្រោះសង្គមនោះអត់មានអ្នកណាហ៊ានហើបទេ។ ដល់មកសង្គម ៧៩ ហ្នឹង យូរណាស់ គេទើបប្រាប់ខ្ញុំៗប្រហែលជាឆ្នាំ ៨០ ហើយហ្នឹង គេទើបនឹងហ៊ានប្រាប់”[460]។

## *ការធ្វើមនុស្សឃាតក្មួយប្រុសរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន*

246. ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន បានផ្ដល់សក្ខីកម្មពាក់ព័ន្ធនឹងការវះពោះក្មួយប្រុសរបស់គាត់។ គាត់បានផ្ដល់សក្ខីកម្មថា “កូនគាត់មួយដែលថាធ្វើលោកហ្នឹង ធ្វើលោកហ្នឹង កូនប្រុសច្បងបង្អស់បួសធ្វើលោក ជាអ្នកចាស់ អ្នកមូលដ្ឋាន។ អ្នកមូលដ្ឋានហ្នឹង គេឲ្យផ្សឹកៗ ផ្សឹកដើម្បីស្ពាយកាំភ្លើងដើម្បីបាញ់បំបែកតាកែវ បំបែកភ្នំពេញហ្នឹង។ ដល់បាញ់បំបែកហើយអ៊ីចឹង ដល់ពេលបែកហ្នឹងស្រាប់តែគេដឹង គេដឹងថា ក្មួយខ្ញុំហ្នឹងកូនខ្មាំង ឪពុកវាធ្វើទាហានពាក់ស័ក្ដិច្រើន ហើយដឹងអ៊ីចឹងក៏គេឲ្យប្រពន្ធ។ អាហ្នឹងគេផ្សឹកហើយ គេធ្វើទាហានហ្នឹង គេប្ដេជ្ញាៗជាមួយពេទ្យស្រី ពេទ្យស្រីនៅម្ដុំជិតភ្នំជីសូរ ខាងត្បូងភ្នំជីសូរ ប្ដេជ្ញាជាមួយពេទ្យស្រីហ្នឹងហើយ ពេលដឹងថា ហ្នឹងជាកូនខ្មាំង ឪពុកធ្វើទាហានស័ក្ដិធំតាកែវ ជាទ័ពសាហាវ ទ័ពខ្លាំងអ៊ីចឹង គេឲ្យប្រពន្ធហ្នឹង ប្រពន្ធធ្វើពេទ្យ ពេទ្យស្រីហ្នឹងវះ វះពោះប្ដីយកប្រមាត់ យកទៅធ្វើថ្នាំអីតទៅទៀត អ៊ីចឹងណះ! ធ្វើថ្នាំតទៅទៀត។ បែក ៧៥ ហើយហ្នឹង គេដឹងៗថា ឪពុកកូនហ្នឹងជាមន្ត្រីធ្វើធំ គេឲ្យប្រពន្ធហ្នឹងចាប់ផ្ដើមសម្លាប់ប្ដី។ នុងគេសួរថា ៖ “ហ៊ានសម្លាប់អត់?” គេថា ៖ “ហ៊ាន”។ ហ៊ានអ៊ីចឹងដើម្បីគេឡើងបុណ្យស័ក្ដិ តែមានសម្លាប់មានអ៊ីចឹងគេឡើងបុណ្យស័ក្ដិទៀត”[461]។

247. ដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ជាក់ថា គាត់ត្រូវបានសម្លាប់ដោយសារគេដឹងថា គាត់ជាកូនរបស់អតីតមន្ត្រីរដ្ឋការ និងបញ្ជាក់ថា លោកស្រីមិនបានមើលឃើញពីការស្លាប់របស់គាត់ឡើយ។ ប៉ុន្តែដើមបណ្ដឹងរដ្ឋប្បវេណីបានពន្យល់ថា “យាយបង្កើតអ្នកឃើញ ព្រោះចៅហ្នឹងនៅជាមួយគាត់ផ្ទាល់

[460] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/253.1 ទំព័រ ៣០-៣១ បន្ទាត់ ២៥-៣។

[461] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/252.1 ទំព័រ ៥៤ បន្ទាត់ ១៥-២០។

ដែរ។ យាយបង្កើតនៅជាមួយគ្នានៅជិតកន្លែងពាណិជ្ជកម្ម សង្គមកិច្ច យាយបង្កើតឃើញផ្ទាល់"[462]។ លោកស្រីបានបញ្ជាក់ថា គាត់បានដឹងពីហេតុការណ៍នេះនៅអំឡុងឆ្នាំ ១៩៨០-១៩៨២ នៅពេលដែលយាយបង្កើតរបស់គាត់មកប្រាប់ម្តាយរបស់គាត់ពីហេតុការណ៍នោះ[463]។

***ការសម្លាប់អ្នកទោស ១៥ នាក់ដោយកងឈ្លប***

248. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម វណ្ណៈ បានពិពណ៌នាអំពីការឃើញដោយផ្ទាល់ភ្នែកនូវកងឈ្លបដែលបានយកអ្នកទោស ១៥ នាក់ទៅសម្លាប់៖ "ចាស ខ្ញុំទៅរើស ទៅកាប់ទន្រ្ទានខែត្រនៅម៉ុំវត្តឫស្សីទេព នៅភូមិច្រេស ឃុំរការក្នុង។ នាងខ្ញុំឃើញឈ្លបចំនួនប្រាំពីរនាក់បណ្តើរមនុស្សចំនួន ១៥ នាក់។ ពួកខ្ញុំហ្នឹង មួយក្រុមហ្នឹង បំបែកជាពីរ ប្រាំនាក់ទៅចូលខាងនេះ ប្រាំនាក់ចូលខាងនោះ តែពួកខ្ញុំកាច់ទន្រ្ទានខែត្របានគ្រប់ចំនួនហើយ ពួកខ្ញុំក៏បបួលគ្នាចូលទៅបេះផ្លែរពាក់ទុំ។ ពេលនោះ ខ្ញុំឃើញឈ្លបបណ្តើរមនុស្សចាស់ មានកាន់គល់ឫស្សី។ គ្នាបីនាក់កាន់គល់ឫស្សី គ្នាបួននាក់កាន់កាំភ្លើង ស្ពាយកាំភ្លើងនៅនឹងស្មា តែអ្នកស្ពាយកាំភ្លើងនោះរាងតូចៗទេ កាំភ្លើងចង់អូសដី។ ពួកខ្ញុំឃើញអ៊ីចឹង ពួកខ្ញុំភ័យខ្លាចណាស់ ខ្ញុំលាក់ខ្លួនក្នុងគម្ពោតរពាក់ចំនួនប្រហែលជា ២០ ម៉ែត្រពីកន្លែងឈ្លបសម្លាប់មនុស្សនោះ។ ពួកខ្ញុំឃើញឈ្លបចាប់ម្តងម្នាក់ៗ វាយក្បាលនឹងគល់ឫស្សី ស្រែកយំទ្រហឹងពេញទាំងព្រៃទាំងអស់។ ពួកខ្ញុំឃើញអ៊ីចឹង ភ័យខ្លាំងណាស់ ខ្ញុំពួនក្រាបដល់ដី ញាក់ ខ្ញុំភ័យពេក ខ្ញុំសន្លប់បាត់ស្មារតី។ កុមារទាំងបួននាក់នោះ ឃើញខ្ញុំសន្លប់ក៏នាំគ្នាច្របាច់ ហើយបិទមាត់ទាំងអស់គ្នាមិនហ៊ានស្រែកទេ ព្រោះខ្លាច បើសិនជាពួកវាឃើញខ្ញុំ ក៏វាសម្លាប់ពួកខ្ញុំចោលដែរ។ ឃើញឈាមបាចពាសពេញនឹងព្រៃឈើទាំងអស់"[464]។ នៅពេលនោះ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម វណ្ណៈ កំពុងធ្វើការនៅក្នុង "កងចល័ត នៅខាងកើតថ្នល់រទេះភ្លើងនៅក្នុងឃុំរការក្នុង"[465]។

---

[462] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/253.1 ទំព័រ ១៦-១៧ បន្ទាត់ ២៥-១។

[463] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/253.1 ទំព័រ ៥៦ បន្ទាត់ ២៣-២៥។

[464] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម វណ្ណៈ ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ E1/288.1 ទំព័រ ៥៣-៥៤ បន្ទាត់ ២២-៧។

[465] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម វណ្ណៈ ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ E1/288.1 ទំព័រ ៥៦ បន្ទាត់ ២។

## ៣.២. ការស្លាប់ដោយសារលក្ខខណ្ឌ

### *ការស្លាប់កូនស្រីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន*

249. ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន បានផ្ដល់សក្ខីកម្មទាក់ទងនឹងការស្លាប់កូនស្រីរបស់គាត់អាយុបីឆ្នាំនៅក្នុងឆ្នាំ ១៩៧៦ ដោយសារតែការថែទាំការថែទាំផ្នែកវេជ្ជសាស្ត្រមិនគ្រប់គ្រាន និងភាពអត់ឃ្លាន[466]។ ដើមបណ្ដឹងរដ្ឋប្បវេណីម្នាក់នេះ បានអះអាងថា កូនស្រីគាត់បានស្លាប់“ដោយសារតែអត់អាហារ។ អត់អាហារហ្នឹងធ្វើឲ្យឈឺ អត់អាហារអត់អីមានហូបឲ្យឆ្អែត ធ្វើឲ្យឈឺ ហើយទើបស្លាប់”[467]។ “មុនដំបូងកើតកញ្ជ្រឹល អ៊ីចឹងលាប់ លាប់កញ្ជ្រឹលអ៊ីចឹងអាចទៅជាឈឺ ឈឺហើយជ្រុះសក់ ហើយយើងយកទៅពេទ្យ ទៅស្លាប់។ អត់មានថ្នាំព្យាបាលចាស ដើមមកពីអត់អាហារហ្នឹងតែម្ដងពីព្រោះវារើសដីហូប វារើសសម្បកក្ដាមហូប ចាស”[468]។

250. ឆ្លើយទៅនឹងសំណួររបស់មេធាវីការពារក្ដី ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន បានរៀបរាប់ថា “ដល់ពេលអ៊ីចឹង វាហូបអីអត់កើតទេ ដល់ពេលវាលាប់អ៊ីចឹង វាហូបបាយ ហូបអីអត់កើតចាស ត្រូវដាច់ៗចំណីដែលយើងគ្មានរបស់អ្វីដែលជាសម្រាប់ប៉ូវ ហូបបាយអត់កើត ដល់ពេលដាច់ចំណីពេលហ្នឹង ចាស។ អត់មានថ្នាំពេទ្យ អត់មានអីទាំងអស់”[469]។ គាត់បានបន្តទៀតថា “ចំណីអាហារបើទោះបីជាមាន ក៏ឈឺហើយយើងអត់មានថ្នាំ។ ជាពិសេស គឺអត់មានថ្នាំហ្នឹងតែម្ដង អត់ថ្នាំព្យាបាល ម្ល៉ោះហើយគឺទៅតាមហ្នឹង គឺត្រូវស្លាប់ដោយសារអត់មានថ្នាំ និងហូបចំណី

---

[466] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/253.1 ទំព័រ ២៧ បន្ទាត់ ១៣-១៥។

[467] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/253.1 ទំព័រ ២៧ បន្ទាត់ ១៣-១៥។

[468] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/253.1 ទំព័រ ២៧ បន្ទាត់ ២១-២៥។

[469] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/253.1 ទំព័រ ២៨ បន្ទាត់ ១១-១៣។

អាហារអត់ លែងកើតចាស"[470]។ "គួបផ្សំជាមួយគ្នាទាំងពីរមុខ។ អត់ចំណីអាហារហូបគ្រប់គ្រាន់ ហើយនិងមានជំងឺកើតកញ្ជ្រិល គួបផ្សំជាមួយគ្នា និងអត់ថ្នាំពេទ្យបូករួមបញ្ចូលគ្នា"[471]។

***ការស្លាប់កូនប្រុសអាយុ ១ ឆ្នាំរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន***

251. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន បានផ្តល់សក្ខីកម្មទាក់ទងនឹងការស្លាប់កូនប្រុសគាត់អាយុមួយឆ្នាំដោយសារកើតជំងឺកញ្ជ្រិល នៅពេលស្ថិតក្រោមការថែទាំរបស់ "ស្ត្រីចំណាស់នៅក្នុងកង"។ ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា គាត់ និងសមាជិកគ្រួសាររបស់គាត់ "ចាស បំបែកខ្ញុំពីឆ្នាំ ៧៦ ហ្នឹង កូនម្នាក់។ គ្រួសារខ្ញុំនៅកង បែកគ្នាៗបាត់រហូត ដល់មកសព្វថ្ងៃហ្នឹងអត់ឃើញ"[472]។ "ចាស កូនមួយ-កូនប្រុស។ កូនអាយុមួយខួប ស្លាប់ទៀត"[473]។ "ចាស កូនប្រុសខ្ញុំហ្នឹងនៅជាមួយវាទៅកងប្រមូលផ្តុំយកទៅដាក់ជាមួយយាយៗ។ ឱ្យយាយមើល យាយធ្វើការអត់កើត ឱ្យយាយមើល។ ហើយកូនប្រុសខ្ញុំហ្នឹង យាយៗគាត់ប្រាប់ថា កើតកញ្ជ្រិលស្លាប់ទៅ។ នាងខ្ញុំនៅកងប្រមូលផ្តុំ"[474]។ គាត់បានពន្យល់ថា "ចាស មានអាយុ២ឆ្នាំ ៣ឆ្នាំ ស្លាប់ច្រើន ឱ្យយាយៗមើល"[475]។ ដើមបណ្តឹងរដ្ឋប្បវេណី បានរៀបរាប់បន្ថែមទៀតថា "ចាស នៅជិតផ្ទះខ្ញុំហ្នឹង កុមារៗតូចៗហ្នឹង នៅកន្លែងកង៣ហ្នឹង ស្លាប់ ខ្ញុំដឹង ចំនួនជា ប្រាំពីរ ប្រាំបីនាក់"[476]។

[470] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡុន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/253.1** ទំព័រ ២៨ បន្ទាត់ ១៨-២០។

[471] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡុន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/253.1** ទំព័រ ២៨ បន្ទាត់ ២៤-២៥។

[472] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ៦ បន្ទាត់ ១២-១៣។

[473] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ៦ បន្ទាត់ ១៦។

[474] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ៦ បន្ទាត់ ១៩-២១។

[475] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ៣៦ បន្ទាត់ ២០។

[476] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ៣៦ បន្ទាត់ ២៣-២៤។

### *ការស្លាប់បងស្រីរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី*

252. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី បានផ្តល់សក្ខីកម្មថា បងស្រីគាត់បានស្លាប់ដោយសារជំងឺពិសនៅលើជើង។ គាត់ "មានជំងឺធ្ងន់ ហើយកើតដំបៅ កើតពិសនៅជើង ទើបបានគេបញ្ជូនទៅមន្ទីរពេទ្យស្រុកត្រពាំងអង្គ។ សូមទោស ស្រុកត្រពាំងគល់"[477]។ បងស្រីគាត់ "ស្លាប់នៅមន្ទីរពេទ្យ"[478]។ ដើមបណ្តឹងរដ្ឋប្បវេណីមិនបាននៅជាមួយនោះទេនៅពេលបងស្រីគាត់ស្លាប់ "យើងជាបងប្អូនប្រទាក់លោហិតជាមួយគ្នា តែងតែចង់នៅជិតស្និទ្ធ ដើម្បីឱ្យគាត់បានបិទភ្នែកជិត ប៉ុន្តែគឺថាពេទ្យមិនអនុញ្ញាត"[479]។ ដើមបណ្តឹងរដ្ឋប្បវេណី "មិនត្រូវបានអនុញ្ញាតឱ្យទៅទេ"[480]។ ប៉ុន្តែ "ក្រោយមកយូរថ្ងៃ ទើបមានគេប្រាប់ខ្ញុំ អ្នកភូមិប្រាប់ខ្ញុំថា បងស្រីខ្ញុំស្លាប់ហើយ។ ខ្ញុំទ្រហោយំតែម្នាក់ឯងនៅកណ្តាលវាស្រែ"[481]។

### *ការស្លាប់កម្មករពីរនាក់នៅក្នុងកងចល័តរបស់ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ*

253. ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ បានផ្តល់សក្ខីកម្មទាក់ទងនឹងជំងឺ និងភាពអត់ឃ្លានដែលបណ្តាលឱ្យស្លាប់សមាជិកកងចល័តរបស់គាត់ពីរនាក់។ "បាទ សម័យនោះ មានកងយុវជនរបស់ខ្ញុំហ្នឹង នៅអូរក្រូចហ្នឹង មានអ្នកអត់បាយហ្នឹង អត់បាយហ្នឹងស្លាប់ពីរនាក់ដែរ។ អ៊ីចឹងគេបន្តប់បន្តែ គេថាមកពីខ្យល់គ ប៉ុន្តែអ្នកហ្នឹងកាលពីសម័យនោះវាកើត វាត្រូវមុតចប អ៊ីចឹងវាទៅ ចេញទៅជាដំបៅ ទៅ

---

[477] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/251.1 ទំព័រ ៤៦ បន្ទាត់ ១៣-១៤។

[478] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/251.1 ទំព័រ ៤៦ បន្ទាត់ ១៧។

[479] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/251.1 ទំព័រ ៤៦ បន្ទាត់ ២៤-២៥។

[480] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/251.1 ទំព័រ ៤៧ បន្ទាត់ ៤។

[481] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/251.1 ទំព័រ ៤៧ បន្ទាត់ ៦-៧។

ជាមហារីក។ អ៊ីចឹងគេឱ្យហូបអត់ឆ្អែតទេ។ កាលណាហូប យើងឈឺហើយហូបបាយ គេថាយើងសតិអារម្មណ៍។ អ៊ីចឹង គេចេះតែបន្ថយៗអាហារ អ៊ីចឹងរហូតដាច់ពោះស្លាប់នៅអូរក្រូចបាទ"[482]។

## ៤. ការដាក់ក្នុងមន្ទីរឃុំឃាំង

254. ភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់នៅក្នុងសវនាការ បង្ហាញថា ប្រជាជនត្រូវបានដកហូតសេរីភាពតាមទំនើងចិត្តដោយគ្មាននីតិវិធីច្បាប់ត្រឹមត្រូវនៅក្នុងសហករណ៍ត្រាំកក់។

### *ការឃុំខ្លួនដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធឹម នៅផ្សារអង្គរកា*

255. ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធឹម បានពន្យល់ថា "គេចាប់ខ្លួនហ្នឹងខ្ញុំ ដោយសារថា កូនស្រីខ្ញុំមីច្បងនោះ វាកងជាមួយនឹងនាង អៀម យេន ដែលឡើងធ្វើសក្ខីកម្មមុនខ្ញុំនេះ។ វាកង វាដើរលួចកាច់អំពៅ កាច់អីគេអ៊ីចឹងទៅដល់រួចទៅគេចាប់វ៉ៃ វាឱ្យឆ្លើយថា ខ្ញុំនឹងធ្វើទាហានពាក់ស័ក្តិ២ នៅភ្នំពេញហ្នឹងបានគេឱ្យរួច។ ហើយក្មេងវាចេះតែឆ្លើយទៅ។ វាមិនដឹងឪទៅងាប់ឯណា គេចាប់ឪយកទៅវ៉ៃចោល វាមិនដឹងឯណា។ បាទ ដោយសារកូនហ្នឹង"[483]។

256. ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធឹម បានពិពណ៌នាអំពីការចាប់ខ្លួនគាត់ខណៈពេលគាត់កំពុងធ្វើការនៅស្រុកត្រាំកក់ ហើយបន្ទាប់មកត្រូវបានឃុំខ្លួននៅផ្សារអង្គរកាក្នុងឆ្នាំ ១៩៧៧ ថា "គេថាជូនខ្ញុំទៅប្រជុំមួយភ្លែត។ ដល់អ៊ីចឹងទៅ គាត់នាំខ្ញុំទៅកន្លែងឈ្លប។ ទៅដល់កន្លែងឈ្លបហ្នឹង ឈ្លបហ្នឹងគេចេញមក បញ្ចូលបួននាក់ទៅប្រាំនាក់ បាទ។ ចេញមកចាប់ឱបខ្ញុំបាទជាប់ ចាប់ឱបខ្ញុំបាទអ៊ីចឹងហើយ គេយកខ្សែគោហ្នឹងយកមកចងខ្ញុំបាទហ្នឹង ចងស្លាបសេកហ្នឹងទៅក្រោយបីចំណង បទបីចំណង។ បីចំណងអ៊ីចឹងទៅ ដល់រួចទៅ បន្ទាប់មក ខ្ញុំនឹកថា ខ្ញុំស្លាប់ហើយពេលហ្នឹង គ្មានរស់ទេព្រោះស្លាប់ដោយអត់មានទោសកំហុសសអីសោះ។ បាទដល់រួចទៅគេវ៉ៃខ្ញុំហ្នឹង"[484]។

---

[482] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែ កុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/262.1** ទំព័រ ៣៣ បន្ទាត់ ២១-២៥។

[483] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធឹម ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ៣៣ បន្ទាត់ ១១-១៤។

[484] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធឹម ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ២៤ បន្ទាត់ ៤-៩។

257. “ហើយដល់រួចអ៊ីចឹងទៅ គេរើសអស់ចិត្ត គេសួរចម្លើយអស់ចិត្ត បានគេដឹកខ្ញុំបាទតាមរទេះសេះមក នៅម្តុំអង្គរកា។ ម្តុំអង្គរកាហ្នឹង នៅនឹងផ្សារអង្គរកាហ្នឹងតែម្តង ប៉ុន្តែផ្សារអង្គរកាហ្នឹងប្រហែលជាកន្លែងស្រុកគេហើយ ព្រោះកន្លែងស្រុកគេ។ ដល់អ៊ីចឹងគេធាក់ខ្ញុំបាទធ្លាក់ពីលើរទេះសេះអ៊ីចឹងមក។ [...] ហើយខ្ញុំដើរកាត់វាលស្រែអ៊ីចឹងទៅលិចៗផ្សារអង្គរកាហ្នឹង ស្រាប់តែមានចង្កៀងផ្លុងៗនៅកន្លែងហ្នឹង នៅកន្លែងនេះហ្នឹង។ ខ្ញុំថាប្រហែលជាកន្លែងរណ្តៅគេនៅចាំដឹកអីសម្លាប់ខ្ញុំនៅកន្លែងហើយ មិនស្រួល។ ដល់ពេលចូលទៅដល់ជិតទៅ បានឃើញមានជារោងមួយ មន្ទីរគុកគេហ្នឹង។ គេសង់ពីឈើ ជញ្ជាំងក្តារ រនាបក្តារ។ អ៊ីចឹងទៅ ដល់រួចទៅ គេញាត់ខ្ញុំ គេប្រធានឈ្លប -- ប្រធានគុកគេហ្នឹងឈ្មោះ តាម៉េងៗ ហើយគាត់ចាក់សោ ចាក់អីទ្វារទៅ បានរុញខ្ញុំទៅក្នុងហ្នឹង ហើយមនុស្សឡើងឲ្យអិលដូចអ៊ីចឹង បានមនុស្សនៅជាប់ហ្នឹង។ ដល់រួចទៅគាត់ -- គេក៏ដុតភ្លើងបំភ្លឺអ៊ីចឹងទៅ គេយកអាខ្នោះកងជើងហ្នឹង មកឲ្យខ្ញុំពីរបាទ មកឲ្យខ្ញុំពីរ។ កងជើងគេដាក់ខ្នោះខ្ញុំហ្នឹង។ កងដែកហ្នឹងគេមានចោះរន្ធសងខាង។ អ៊ីចឹងគេដាក់ -- គេយកមកឲ្យពីរអ៊ីចឹងគេមានចាក់សោរនុកនៅឯក្រៅ ហើយគេហូតដែករនុកហ្នឹងចេញមកបាន -- ដល់រួចទៅបានគេយកកងហ្នឹងមកឲ្យខ្ញុំ។ យកមកឲ្យខ្ញុំៗជាប់ដៃចំណងទៅក្រោយបីចំណងរឹងក្រញង់ហើយ ខ្ញុំមានដាក់អីកើត គេអ្នកដាក់ឲ្យៗ។ ដល់រួចទៅគេស៊កដែករនុកមកពីក្រៅអ៊ីចឹងមកចូលក្នុងហ្នឹងវិញទៅបាទ។ ជាប់ជើង ជាប់ខ្នោះចូលក្នុងខ្នោះហើយបានគេស្រាយចំណងដៃហ្នឹងឲ្យខ្ញុំ។ គ្រាន់តែស្រាយហើយ ដៃហ្នឹងគ្មានដឹងដៃដឹងអីទេ ហើម -- ចុះដៃបីចំណងស្លាបសេកទៅក្រោយមិនធម្មតា”[485]។

258. “គេបានដាក់ខ្ញុំនៅកន្លែងហ្នឹងទាំងយប់ទាំងថ្ងៃៗហ្នឹង អត់ឲ្យចេញទៅណាទេ ប្រហែលជា៣ខែ។ ៣ខែហ្នឹងបាន ដល់ពួកគេជាប់មុនៗ គេជាប់តែខ្នោះជើងមួយ ជើងម្ខាង ខ្ញុំហ្នឹងជើងទាំងពីរ ដេកបានតែផ្ងារអ៊ីចឹងរហូត រើខ្លួនមិនរួច ពិបាក”[486]។

259. ដើមបណ្តឹងរដ្ឋប្បវេណី ចាន់ ធីម បានផ្តល់សក្ខីកម្មថា នៅក្នុងមន្ទីរឃុំឃាំងហ្នឹង “វាមានទាំងស្ត្រីដូចខ្ញុំបាននិយាយហើយ ខ្ញុំថាមួយល្វែងអ៊ីចឹងទៅស្ត្រី ខ្ញុំដេកទល់ជើងគ្នានឹងស្រីៗអ៊ីចឹងទៅហើយមួយប្រឡោះនេះ ខាងនេះបុរស ហើយអ៊ីចឹងបុរសហ្នឹងប្រហែលជាចូល ១០ នាក់ដែរ ហើយស្ត្រី

[485] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចាន់ ធីម ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ២៤-២៥ បន្ទាត់ ១៧-១៣។

[486] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចាន់ ធីម ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ២៥ បន្ទាត់ ១៥-១៧។

ហ្នឹងប្រហែលជាខ្ពង់ជាង១០ នាក់ដែរ។ ហើយនារីមួយទៀត ស្ត្រីមួយទៀតនោះ គាត់មានទាំងកូន បំបៅឲ្យបៅដោះ ហើយជើងជាប់ខ្នោះទៀត ហើយមិនដឹងហេតុអី ខ្ញុំក៏មិនដឹងមូលហេតុដែរស្ត្រី ហ្នឹង ម្នាក់ហ្នឹង ឃើញកូនតូចនៅបៅដោះ"[487]។ "បាទ អ្នកទោសនៅអង្គរកាហ្នឹង ដល់រួចទៅវា អ៊ីចេះ ដល់រួចទៅចូលនៅនុងបានមួយប្រាវៗ ហ្នឹង គឺថាដល់រូបគេបញ្ចេញទៅទៀត។ គេចង បញ្ចេញ ខ្ញុំនៅតែលបមើលនៅក្នុងគុកហ្នឹង។ គុកហ្នឹងវាជញ្ជាំងក្តារ អ៊ីចឹងទៅ តានូវ ហ្នឹងគាត់អ្នក បិតត្រចៀកភ្នែកៗ"[488]។

## ៥. ការធ្វើទារុណកម្ម

260. ភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់នៅក្នុងសវនាការ បញ្ជាក់ថា អំពើនានាដែល បង្កឲ្យមានការឈឺចាប់ ឬការរងទុក្ខធ្ងន់ធ្ងរ ទោះបីលើផ្លូវកាយ ឬផ្លូវចិត្ត ត្រូវបានប្រព្រឹត្តឡើងក្នុង គោលបំណងដើម្បីទទួលបានព័ត៌មាន ឬជាការដាក់ទណ្ឌកម្មនៅសហករណ៍ត្រាំកក់ និងមន្ទីរឃុំ ឃាំងអង្គរកា។

### *ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធីម*

261. ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធីម បានផ្តល់សក្ខីកម្មអំពីការទទួលរងការវាយដំបន្ទាប់ពីការចាប់ខ្លួន គាត់ និងក្នុងខណៈពេលដែលគាត់ត្រូវបានឃុំខ្លួននៅអង្គរកា។ "គេចេញមកចាប់ឱបខ្ញុំបាទជាប់ ចាប់ឱបខ្ញុំបាទអ៊ីចឹងហើយ គេយកខ្សែគោហ្នឹងយកមកចងខ្ញុំបាទហ្នឹង ចងស្លាបសេកហ្នឹងទៅ ក្រោយបីចំណាង បាទ បីចំណាង។ បីចំណាងអ៊ីចឹងទៅ ដល់រួចទៅ បន្ទាប់មក ខ្ញុំនឹកថា ខ្ញុំស្លាប់ហើយ ពេលហ្នឹង គ្មានរស់ទេ ព្រោះស្លាប់ដោយអត់មានទោសកំហុសសអីសោះ។ បាទដល់រួចទៅគេវៃ ខ្ញុំហ្នឹង ម្នាក់ចូលអ៊ីចឹង វៃដួលត្រលប់ត្រលិនអ៊ីចឹងទៅ គេសួរចម្លើយ "អ្អែង! នៅភ្នំពេញ នៅធ្វើស្អី? អ្អែង ឆ្លើយប្រាប់គេឲ្យត្រង់មក""[489]។

---

[487] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធីម ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ២៨ បន្ទាត់ ១២-១៧។

[488] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធីម ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ៣៨ បន្ទាត់ ២៣-២៥។

[489] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធីម ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ២៤ បន្ទាត់ ៦-១០។

262. "ពួកប៉ុល ពត វានិយាយមកយើងអ៊ីចឹង វាថា អត់មានក្រមសីលធម៌អីទេ នៅក្នុងខ្លួនវាហ្នឹង វាសុទ្ធ "អ្អែង" អ៊ីចឹងហ្នុង។ "អ្អែង នៅក្រុងភ្នំពេញ អ្អែង ធ្វើអី? អ្អែង ធ្វើទាហាន ឬមួយក៏ធ្វើអី? ខ្ញុំឆ្លើយតបប្រាប់គេថា "មិត្តអើយ ខ្ញុំអត់មានធ្វើអីទេ អត់មានធ្វើទាហានទេ។ ខ្ញុំជាកម្មករ។ ខ្ញុំជាអ្នករកស៊ីកាប់ឧស កាប់អីលក់។ ខ្ញុំនៅនឹងជំរំហ្នឹង ក៏ខ្ញុំអត់មានធ្វើអីដែរ ខ្ញុំជាកម្មករទេ"។ ដល់អ៊ីចឹងទៅគេក៏--ម្នាក់វ៉ៃអស់ចិត្ត ម្នាក់ចូលមកវ៉ៃទៀត សួរចម្លើយខ្ញុំនៅតែដដែលៗ។ គេថា "អ្អែង ឆ្លើយប្រាប់អញឲ្យត្រង់មក បើអ្អែងឆ្លើយប្រាប់អញត្រង់ អញលែងអ្អែងទៅឥឡូវ"។ ហើយខ្ញុំមិនដឹងស្អី លាតត្រដាងប្រាប់គេឲ្យត្រង់។ ខ្ញុំថា ខ្ញុំជាកម្មករ ជាអ្នកកាប់ឧសកាប់អី លក់អ៊ីចឹងទៅចិញ្ចឹមជីវិតកូនប្រពន្ធហ្នឹង"[490]។

263. ដើមបណ្តឹងរដ្ឋប្បវេណីបន្តពន្យល់ថា "ខ្ញុំវាតូចចិត្តដែរ ខ្ញុំអត់មានរឿងទោសកំហុសអីសោះ យកខ្ញុំទៅធ្វើទារុណកម្មបាទ។ យកខ្ញុំទៅធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរយ៉ាងនេះ។ បើមានទោសកំហុសអី ខ្ញុំអត់ខ្លាចទេ ខ្ញុំអត់ខ្លាចនឹងទទួល ប៉ុន្តែខ្ញុំអត់មានទោសកំហុសអីសោះ"[491]។

264. ពាក់ព័ន្ធនឹងលក្ខណៈនៃការវាយដំដែលគាត់បានទទួលរង ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មកម្មថា "បាទ គេវ៉ៃខ្ញុំបាទនឹងដំបងពីងពង់ ឬស្សីពីងពង់យើង ឬស្សីតាន់ ប៉ុនភ្លៅដៃហ្នឹង សំពងតែម្តង។ អាហ្នឹងគេវ៉ៃសួរចម្លើយ វ៉ៃនឹងឬស្សីពីងពង់"។ "បាទ គេវ៉ៃផ្លាស់ប្តូរគ្នា ព្រោះថាគ្នាគេប៉ុន្មាននាក់ហ្នឹងគេ--អាមួយវ៉ៃហត់អ៊ីចឹងទៅ មួយចូលវ៉ៃទៀត មួយវ៉ៃហត់ ចូលវ៉ៃ ទាល់តែខ្ញុំនឹងសន្លប់ទៅបានដឹងខ្លួនឡើងវិញ បានគេដឹក អ៊ីចឹងទៅ រទេះសេះដឹកទៅផ្សារអង្គរកាដាក់គុកហ្នឹង"[492]។

***ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម វណ្ណៈ***

---

[490] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធឹម ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ២៤ បន្ទាត់ ១០-១៧។

[491] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធឹម ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ២៥ បន្ទាត់ ១៣-១៥។

[492] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធឹម ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/287.1** ទំព័រ ២៦ បន្ទាត់ ១-៧។

265. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម វណ្ណៈ បានផ្តល់សក្ខីកម្មថា "មេកងបញ្ជាអ៊ីចឹង ពួកកុមារទាំងអស់ហ្នឹង គេចាប់នាងខ្ញុំហ្នឹងចង ហើយវ៉ៃធ្វើបាបទៅ"[493]។ មេកងហ្នឹងស្រីឈ្មោះ សារូ[494]។ គាត់បានផ្តល់សក្ខីកម្មថា "ហើយខ្ញុំធ្លាប់ឮអ្នកម្តាយខ្ញុំថា បើសិនជាឈឺឱ្យច្របាច់ស្លឹកស្ដៅហ្នឹងផឹកទៅ ព្រោះយើងគ្មានថ្នាំសង្កូវព្យាបាលទេកូន។ តែនាងខ្ញុំក៏ទៅបេះស្លឹកស្ដៅច្របាច់ផឹក។ តែទៅជួបប្រទះនឹងឈ្លបម្នាក់ថាក្មេងកុមារមិនធ្វើការ គេមករាយការណ៍ប្រាប់អង្គការៗចាប់នាងខ្ញុំចង់ភ្ជាប់នឹងដើមឈើ ហើយនាំគ្នាវ៉ៃធ្វើបាបនាងខ្ញុំកុមារហ្នឹងចំនួន ២០នាក់ ទាំងខ្លួនខ្ញុំមានជំងឺជាប់ខ្លួន។ មិនត្រឹមតែប៉ុណ្ណោះ វាមិនមែនវ៉ៃនឹងដៃទេ សូម្បីតែឬស្សីជាប់នឹងដែកគោល វាវ៉ៃនាងខ្ញុំមានស្លាកស្នាមលុះសព្វថ្ងៃ ចងនាំខ្ញុំសន្លប់នៅនឹងដើមឈើមិនដឹងខ្លួន។ គេចងខ្ញុំចោល១យប់ទល់ភ្លឺ។ លុះត្រាភ្លឺឡើង ខ្ញុំដឹងខ្លួនៗខ្ញុំហូរឈាមពេញខ្លួន។ ចាប់បោកក្បាលខ្ញុំនឹងដើមឈើ"[495]។

### *ដើមបណ្តឹងរដ្ឋប្បវេណី អៀម យេន*

266. ដើមបណ្តឹងរដ្ឋប្បវេណី អៀម យេន ដែលជាកុមារម្នាក់នៅពេលនោះ បានផ្តល់សក្ខីកម្មថា ចំពោះការដាក់ទណ្ឌកម្មដោយសារការរត់ចេញពីកងរបស់គាត់ ដើម្បីទៅលេងឪពុកម្តាយរបស់គាត់ គាត់ត្រូវបានគេកប់។ "ចាស ពេលនោះ គេជីកដីកប់នោះ គេជីកជារណ្តៅមួយល្មមខ្លួនខ្ញុំហ្នឹង វាអត់ធំទេ វាតូចល្មម តែគេជីកខ្ញុំហ្នឹងកប់ខ្ញុំតែត្រឹមកទេ គេកប់ជាការព្រមានខ្ញុំទេ ថាថ្ងៃក្រោយកុំឱ្យធ្វើអ៊ីចឹងទៀត"[496]។ "ចាស ពេលកប់ហ្នឹងអាហារអត់មានឱ្យខ្ញុំហូប ទឹកក៏ស្រេកចង់ស្លាប់ហើយ។ រីឯរាងកាយខ្ញុំហ្នឹងក៏ចុកចាប់ពេញខ្លួន ខ្ញុំស្រែកទ្រហោយំរកម៉ែរកឪមកជួយក៏មិនឃើញដែរ ព្រោះអីខ្ញុំកាលជីកកប់ហ្នឹង អត់មានជីកកប់ក្នុងអង្គប្រជុំឯណាទេ។ ជីបកប់ហ្នឹងពេលដែលគេយកខ្ញុំបានមកៗ អ៊ីចឹងពេលកងកុមារខ្ញុំហ្នឹង ចេញទៅធ្វើការអស់ហើយ គេកប់ខ្ញុំហ្នឹងនៅកន្លែងកងហ្នឹងតែ

---

[493] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម វណ្ណៈ ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ E1/288.1 ទំព័រ ៤៩ បន្ទាត់ ១២-១៣។

[494] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម វណ្ណៈ ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ E1/288.1 ទំព័រ ៤៩ បន្ទាត់ ១៧។

[495] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម វណ្ណៈ ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ E1/288.1 ទំព័រ ៤៩-៥០ បន្ទាត់ ២០-៥។

[496] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អៀម យ៉េន ប្រតិចារឹក ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ E1/286.1 ទំព័រ ៥១ បន្ទាត់ ៨-៩។

ម្តង កងដែលស្នាក់អាស្រ័យនៅរាល់ថ្ងៃហ្នឹង”[497]។ ដើមបណ្តឹងរដ្ឋប្បវេណីបានពិពណ៌នាថា “ការដែលជីកកប់ខ្ញុំហ្នឹង ខ្ញុំរកអ្វីប្រៀបផ្ទឹមពុំបានទេ ព្រោះអីខ្ញុំជាប់តែត្រឹមកហ្នឹង ទាំងអស់រលីង ហើយខ្ញុំមានដៃឯណារើបាន ខ្ញុំស្រែកទ្រហោយំហ្នឹង ខ្ញុំដឹងហៅម៉ែ ហៅឪឯណា បើរកម៉ែរកឪមិនឃើញ ឃើញតែការឈឺចាប់”[498]។

## ៦. ការនិរទេស

267. ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់នៅក្នុងសវនាការ បង្ហាញថា ជនជាតិភាគតិចវៀតណាមដែលរស់នៅស្របច្បាប់នៅក្នុងប្រទេសកម្ពុជា ត្រូវបានបង្ខំឱ្យនិរទេសឆ្លងកាត់ព្រំដែនកម្ពុជា/វៀតណាមដោយគ្មានមូលដ្ឋានណាមួយដែលត្រូវបានអនុញ្ញាតក្រោមច្បាប់អន្តរជាតិ។

268. ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ បានផ្តល់សក្ខីកម្មថា គាត់បានរត់ភៀសខ្លួនទៅវៀតណាមមុនរបបខ្មែរក្រហមដោយសារតែសង្គ្រាមរវាងរបប លន់ នល់ និង “កងកម្លាំងរបស់ ប៉ុល ពត”។ នៅក្នុងឆ្នាំ ១៩៧៦ គាត់ និងក្រុមគ្រួសាររបស់គាត់បានឮអំពីការដោះដូរប្រជាជនដែលជាការព្រមព្រៀងរវាងវៀតណាម និងខ្មែរក្រហម។ គាត់បានផ្តល់សក្ខីកម្មថា “បាទ ខ្ញុំចងចាំថា កាលខ្ញុំរស់នៅកម្ពុជាក្រោម គេបានយកឃ្លួនយកទៅដូរយកខ្មែរយើងពីក្រោមមកវិញក្នុងអំឡុងឆ្នាំ ១៩៧៦ បាទ”[499]។ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា “ពេលនោះ ខ្ញុំក៏អត់ដឹងពីនយោបាយរបស់ខ្មែរក្រហមដែរ ព្រមទាំងបងប្អូនប្រជាពលរដ្ឋទាំងអស់ ដែលបានគេភៀសខ្លួនទៅនៅប្រទេសគេ។ ក្រោយពីការដោះដូរហ្នឹង ក៏ខ្ញុំអត់មានស៊ីជម្រៅនឹងការប្តូរផ្លាស់ដែរ ដោយសារយើងនឹកឃើញថាភូមិស្រុកកំណត់តែងមានមនោសញ្ចេតនានឹករឭក។ អ៊ីចឹងតែងវិលមកវិញ”[500]។ ចំពោះអ្នកផ្សេងទៀត

[497] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អៀម យ៉េន ប្រតិចារឹក ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/286.1** ទំព័រ ៥១ បន្ទាត់ ១២-១៦។

[498] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អៀម យ៉េន ប្រតិចារឹក ថ្ងៃទី ១ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/286.1** ទំព័រ ៥១ បន្ទាត់ ២១-២៣។

[499] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ ប្រតិចារឹក ថ្ងៃទី ១២ ខែកុម្ភៈ ឆ្នាំ ២០១៥ ឯកសារ **E1/262.1** ទំព័រ ៤៦ បន្ទាត់ ៩-១០។

[500] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ពៅ រី ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/262.1** ទំព័រ ៧ បន្ទាត់ ៧-១១។

"បាទ ពេលនោះមានបងប្អូនយើងខ្លះ គេអត់មកដែរបង លោកប្រធាន។ គេរស់នៅទីនុងរហូតមកដល់សព្វថ្ងៃអ៊ីចឹងដែរ"[501]។

269. ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា ការដោះដូរបានប្រព្រឹត្តទៅ "នៅច្រកទ្វារអន្តរជាតិថ្មល់ដាច់ បច្ចុប្បន្នហ្នឹង គេហៅទ្វារអន្តរជាតិ។ កាលពីសម័យដើម គេហៅថា "ថ្មល់ដាច់ៗ" ទទេទេបាទ។ ហើយអ៊ីចឹងយើងផ្លាស់ប្តូរតាមហ្នឹង។ ហើយអ៊ីចឹង វៀតណាមវាទៅមុនយើងប្រហែលជាបីថ្ងៃ បានយើងឡើងមក ព្រោះអីវៀតណាម គេកាលណាអត់មានថ្នូរឲ្យគេ គេអត់ឲ្យយើងមកដែរហ្នឹង។ កាលណាបានប្រជាពលរដ្ឋគេទៅដល់ដៃគេហើយ បានគេឲ្យយើងមក"[502]។

## ៧. ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ

270. ភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់នៅក្នុងសវនាការ បញ្ជាក់ថា ការចាប់ខ្លួនដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធីម បងថ្លៃរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ឪពុក ប្តី និងពូរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គីមឡុន បងប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម វណ្ណៈ ព្រមទាំងការបាត់ខ្លួនបងប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គីមឡុន និងពូរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន ស្មើនឹងអំពើធ្វើទុក្ខបុកម្នេញប្រឆាំងនឹងអតីតទាហាន លន់ នល់ និងមន្ត្រីសាធារណរដ្ឋខ្មែរ។ ការបាត់ខ្លួនបងប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន និងការកំណត់អំពីលក្ខខណ្ឌរស់នៅ និងការងារពិបាកខ្លាំងជាងលើប្រជាជន ១៧ មេសា ស្មើនឹងអំពើធ្វើទុក្ខបុកម្នេញប្រឆាំងនឹងប្រជាជនថ្មី[503]។

### ៧.១. ការដាក់ទណ្ឌកម្មធ្ងន់ធ្ងរជាងលើប្រជាជនថ្មី

271. ដើមបណ្តឹងរដ្ឋប្បវេណី ជូ គីមឡុន បានផ្តល់សក្ខីកម្មថា "ប្រជាជនចាស់ និងប្រជាជនថ្មីមានខុសៗគ្នាដោយឡែកដាច់ពីគ្នា។ ពួកគេពួកមូលដ្ឋាន ពួកយើងពួក១៧មេសា រង់ចាំតែថ្ងៃដែលយើងមានកំហុស គេនឹងយកយើងទៅរៀនសូត្រៗ គឺអ្នកថ្មីយកទៅសម្លាប់ គេយកអ្នកថ្មីយកទៅសម្លាប់

[501] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ពៅ រី ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ E1/262.1 ទំព័រ ២៤ បន្ទាត់ ២២-២៤។

[502] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ពៅ រី ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ E1/262.1 ទំព័រ ២៥ បន្ទាត់ ៥-៩។

[503] *សូមមើល* ផ្នែកខ(១) ខ(២) ខ(៣) ខ(៤) ខាងលើ។

ចោល។ អ្នកចាស់អត់ដែលមានឃើញបាត់ម្នាក់សោះតាំងពីខ្ញុំទៅនៅហ្នឹងប្រមាណ ៣ ឆ្នាំ ៨ ខែ ២០ ថ្ងៃ អត់មានដែលបាត់អ្នកចាស់ទេ បាត់តែអ្នកថ្មីរហូតចាស"[504]។

272. ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ បានពន្យល់ពីរបៀបអ្នកដែលត្រឡប់មកពីវៀតណាម និងប្រជាជន ១៧ មេសា ត្រូវបានគេធ្វើបាប។ "អ៊ីចឹងចំណែកពួកខ្ញុំដប់ -- មកពីយួន និងបងប្អូនចេញពីភ្នំពេញទៅ ប្រជាពលរដ្ឋ ប្រជាជន១៧ មេសា ហ្នឹង គេចាត់ទុកដូចជាខ្ញុំកញ្ជះដាច់ថ្លៃរបស់គេអ៊ីចឹង។ ជាឧបករណ៍មួយសម្រាប់គេរើគេតប់។ អ៊ីចឹងការហូប ការដេក ដើរ ឈរ អង្គុយ គឺក្រឹតវិន័យគេតឹងតែងណាស់។ អត់មានយើងដើររហេតរហូតបាន ឬមួយហូប បើសិនណាយើងចាប់ត្រីបាន ត្រូវយកទៅដាក់ក្នុងសហករណ៍។ បើយើងលួចលាក់ អាហ្នឹងគេចាប់ជាកម្លាំង មួយកងហាររបស់គេអ៊ីចឹង គេឱ្យរកត្រីឱ្យយើងតែបុគ្គលម្នាក់ឯងហូបឱ្យអស់។ អាហ្នឹងកន្លែងខ្ញុំនៅគឺអ៊ីចឹងតែម្តង។ សកម្មភាពរបស់វាធ្វើទារុណកម្មមកលើយើងខ្លាំងណាស់"[505]។ គាត់បានពន្យល់ថា "បាទប្រជាពលរដ្ឋ ១៧ និងអ្នកមកពីយួនហ្នឹង ជីវភាពដូចគ្នា។ គឺបើ --ព្រោះអីយើងនៅអង្គភាពតែមួយ។ អ៊ីចឹងបើ ១០០ នាក់ហ្នឹង បបរក្នុង ១០០ នាក់ហ្នឹង ១០ កំប៉ុង គឺហូបដូចគ្នាទាំងអស់។ បើគ្មានបបរដំឡូងម្នាក់មួយកង់ហ្នឹង គឺមួយកង់ដូចគ្នា បាទជំនួសបាយបាទ"[506]។

### ៧.២. លក្ខខណ្ឌការងារ និងរស់នៅខុសគ្នា

273. ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ បានបញ្ជាក់បន្ថែមទៀតថា "កាលពីសម័យខ្មែរក្រហម គ្មានជនណាម្នាក់ទំនេរទេ ឱ្យតែប្រជាពលរដ្ឋអ្នកដែល ១៧ ឬអ្នកមកពីយួនហ្នឹង ដោយឡែកតែពួកមូលដ្ឋានហ្នឹង គឺគេជាមេរបស់យើង គេដឹកនាំច្រមុះយើងទាំងអស់គ្នា កុំថាឡើយតែកូនក្មេងតូច ឬមួយចាស់ជរា ក៏គេនៅមានសិទ្ធិជាងយើងដែរ"[507]។

---

[504] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/252.1** ទំព័រ ៦២ បន្ទាត់ ២៥ ដល់ទំព័រ ៦៣ បន្ទាត់ ៣។

[505] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ពៅ រី ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/262.1** ទំព័រ ១២ បន្ទាត់ ៤-១០។

[506] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ពៅ រី ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/262.1** ទំព័រ ១២ បន្ទាត់ ២-១៦។

[507] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ពៅ រី ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/262.1** ទំព័រ ៥២ បន្ទាត់ ១-៤។

274. ដើមបណ្តឹងរដ្ឋប្បវេណី តាក សាន់ ក៏បានផ្តល់ភ័ស្តុតាងជូនអង្គជំនុំជម្រះសាលាដំបូងផងដែរទាក់ទងនឹងលក្ខខណ្ឌខុសគ្នាដែលប្រជាជនថ្មីបានជួបប្រទះ។ ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា ខណៈដែលគាត់ត្រូវ "ដាក់ឡូកឡំគ្នាទាំងអស់ហ្នឹង"[508]។ "មាននៅធ្វើបីបួនប្រាំនាក់អ៊ីចឹងទៅ ប៉ុន្តែពួកខ្ញុំប្រឹងប្រែងជាងគេ គេអ្នកមូលដ្ឋានគេមិនសូវប្រឹងទេ"[509]។

275. ពាក់ព័ន្ធនឹងផ្ទះសម្បែងដែលបានផ្តល់ជូនប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន បានពន្យល់ថា ក-១ "ជាសហករណ៍គំរូ"[510] និង "ជាផ្ទះគំរូ ផ្ទះក្បឿង។ គណៈឃុំ និង ឈ្លបនៅទីនោះ។ គណៈឃុំទាំងអស់ គឺនៅផ្ទះគំរូ កង១ ទាំងអស់ គឺជាផ្ទះក្បឿង។ ឯយើងពលករនៅដោយឡែក"[511]។ "ផ្ទះគំរូជាផ្ទះក្បឿង ជញ្ជាំងក្តារ មានរ៉ៃនីវជិតៗ ដូចផ្ទះយើងពីដើម ហើយគេនៅតែគណៈឃុំ គណៈស្រុក គណៈឃុំទេ"[512]។ ទោះជាយ៉ាងនេះក្តី ដើមបណ្តឹងរដ្ឋប្បវេណីរស់នៅក្នុង "កង ៣។ សហករណ៍ពួក ១៧ ចាស"[513]។ អង្គភាព ក-៣ ស្ថិតនៅ "ខាងត្បូងសាលាឃុំប្រហែលជាមួយគីឡូ។ សហករណ៍ខ្ញុំពួក ១៧ មេសា នៅខាងត្បូងនៅខ្ទមៗ តូចៗ។ សហករណ៍គេៗធ្វើជារោងធំ"[514]។ "យើងជាអ្នកថ្មីហ្នឹង គឺតយ៉ាកជារោង។ ខ្ញុំនឹងនៅតយ៉ាកពីរោងផ្ទះគេមក។ គេៗអ្នកមូលដ្ឋាន ផ្ទះគេរាងវែងបន្តិច ប៉ុន្តែស្លឹកដូចគ្នា ប៉ុន្តែរាងធំបន្តិច វែង ហើយផ្ទះយើងអ្នកថ្មីគេឱ្យតតូចៗ។ អ្នកថ្មីទាំងអស់ គឺគេសង់ៗជារោងតូចៗ អាចសម្រាន្តអស់ជិតគ្នាៗអ៊ីចឹងទៅមួយ

[508] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី តាក សាន់ ប្រតិចារឹក ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/286.1** ទំព័រ ៣២ បន្ទាត់ ៩។

[509] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី តាក សាន់ ប្រតិចារឹក ថ្ងៃទី៤ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/286.1** ទំព័រ ៣២ បន្ទាត់ ១៣-១៤។

[510] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/253.1** ទំព័រ ៨ បន្ទាត់ ១៧។

[511] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/253.1** ទំព័រ ៩ បន្ទាត់ ៩-១០។

[512] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/253.1** ទំព័រ ៩ បន្ទាត់ ១៤-១៥។

[513] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/253.1** ទំព័រ ៨ បន្ទាត់ ២២។

[514] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/253.1** ទំព័រ ៨ បន្ទាត់ ១៨-១៩។

កន្លែងបីនាក់ មួយកន្លែងពីរនាក់ បីនាក់អ៊ីចឹងបាន។ អត់មាន--ហូបអាហារក៏ខុសគ្នា ដូចនិយាយជម្រាបពីម្សិលមិញ ចាស"[515]។ "ចងជញ្ជាំងជាធាងដូង ប្រក់ជាស្លឹកត្នោត ជញ្ជាំងជាស្លឹកត្នោត"[516]។

276. ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡន បានពិពណ៌នាពីការភ័យខ្លាចរបស់ "ប្រជាជន ១៧ មេសា" ចំពោះការណ៍ដែលគេយកទៅសម្លាប់ចោល ដោយបានអះអាងថា "គេថាពួកយើងពួកអ្នក១៧ហ្នឹង ពួកអ្នកនៅទីក្រុងខ្ជិល មិនចេះធ្វើអី សុទ្ធតែជាអ្នកធ្លាប់ស្រណុក ហើយអ៊ីចឹងហើយគេចង់កម្ទេចចោលឱ្យអស់ ពួកដែលខ្ជិល ពួកដែលធ្វើ មានជាប់ៗពាក់ព័ន្ធនឹងអ្នកធ្វើមន្ត្រីរាជការពីសង្គមចាស់សង្គម លន់ នល់ ហ្នឹង គេត្រូវកម្ទេចចោលឱ្យអស់។ ហើយម្ល៉ោះហើយ យើងអ្នក១៧ថ្មីហ្នឹង ចេះតែភ័យខ្លាចគេសម្លាប់ចោល គេប្រើអីធ្វើហ្នឹង កើតទាំងអស់ គឺប្រើអីធ្វើហ្នឹង កើតទាំងអស់។ អ៊ីចឹងបានៗរស់ដល់សព្វថ្ងៃ ចាស"[517]។

277. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន បានបញ្ជាក់ពីភាពខុសគ្នារវាងសហករណ៍គំរូ ក-៣ និងក-១។ សហករណ៍គំរូ "នៅពីខាងត្បូងភូមិនាងខ្ញុំនៅ។ ខ្ញុំអ្នក១៧ ដាក់ពីខាងជើង កណ្តាលដាក់ កង២ កង១ នៅពីខាងត្បូងជិតសាលាឃុំ។ មន្ទីរពេទ្យក៏ខុសគ្នាដែរ សហករណ៍បាយក៏ខុសគ្នាដែរ"[518]។ គាត់បានពន្យល់ថា កងគំរូក៏ខុសគ្នាដែរ "ពីព្រោះគាត់អត់ពាក់ព័ន្ធអ្នក១៧មេសា គាត់ល្អ"[519]។

## ៧.៣. របបអាហារ

---

[515] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡន ប្រតិចារឹក ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/253.1** ទំព័រ ៩ បន្ទាត់ ១-៥។

[516] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡន ប្រតិចារឹក ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/253.1** ទំព័រ ៩ បន្ទាត់ ១៥-១៦។

[517] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡន ប្រតិចារឹក ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/252.1** ទំព័រ ៤៦ បន្ទាត់ ២៥ - ទំព័រ ៤៧ បន្ទាត់ ១-៤។

[518] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម សារឿន ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/283.1** ទំព័រ ១៩ បន្ទាត់ ១៧-១៩។

[519] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម សារឿន ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/283.1** ទំព័រ ទំព័រ ១៩ បន្ទាត់ ២៥។

278. ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន បានផ្តល់សក្ខីកម្មពាក់ព័ន្ធនឹងការប្រព្រឹត្តផ្សេងគ្នាចំពោះប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន។ ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា "ហូប អ្នកចាស់គេហូបជាមួយយើងមែនពិតនៅសហករណ៍មែនពិត តែក្នុងផ្ទះគេៗមានរបបគេនៅក្នុងផ្ទះ គេមានអង្ករគេនៅក្នុងផ្ទះសម្រាប់ស្រគូរហូបបន្ថែមពេលព្រឹក។ គេអាចពេលព្រឹក វាអាចដាំហូបបន្ថែមគេចេញទៅធ្វើការបាន។ តែយើងអ្នកថ្មីអត់មានទេ យើងហូបតែក្នុងសហករណ៍ហ្នឹងទេ។ អ៊ីចឹងហើយបានមានអ្នកហេវ អ្នកហាត់ត្លួញហ្នឹង បានមានគេយកទៅវៃចោល"[520]។

279. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សារឿន បានបញ្ជាក់ថា "ចាស ពីមុនអ្នកប្រជាជន១៧ ហើយប្រជាជនភេទទី២ហូបរួមគ្នា។ ដល់តែពេលក្រោយស្រង់ឈ្មោះ ប្រជាជន១៧ដាក់ផ្សេង ប្រជាជនទី២ពាក់ព័ន្ធនឹងផ្សេង ទី១ផ្សេង"[521]។ "កាលហ្នឹង ចេញដំបូងឲ្យគាត់មានផ្ទះ មានទីលំនៅ នៅស្រួលក៏ឲ្យចតនៅក្បែរៗហ្នឹង អ៊ីចឹងទៅ ហើយដល់ពេលៗបំបែក ហូបផ្សេង"[522]។ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សារឿន បានពន្យល់ថា ប្រជាជនមូលដ្ឋានបានទទួលរបបអាហារច្រើនជាងពីព្រោះពួកគេ "មានសិទ្ធិសុំគ្នាគាត់បាន។ បើនាងខ្ញុំ១៧ អត់ហ៊ានចូលទៅចង្ក្រានបាយទេ គេអាចខ្លាចដាក់ថ្នាំបំពុល អត់ឲ្យចូលជិតទេ"[523]។ លើសពីនេះទៀត "អ្នក១៧ ឲ្យហូបមុន។ អ្នកមូលដ្ឋានគាត់ហូបពេលក្រោយគ្នាគាត់ អ្នកចុងភៅបានម្ហូបត្រីធំៗគាត់ គ្នាគាត់ស៊ី អត់ឲ្យខ្ញុំដឹងផង។ ១៧ គាត់ចែកបាយម្ហូបហ្នឹងឲ្យមុន"[524]។

280. ពាក់ព័ន្ធនឹងរបបអាហារ ដើមបណ្តឹងរដ្ឋប្បវេណី តាក សាន់ បានពន្យល់ថា "ខ្ញុំមើលទៅដូចជាមិនស្មើទេ ពួកមូលដ្ឋានអ៊ីចឹងទៅ គេហូបរាងក្រែលបន្តិចទៅ ហើយពួកខ្ញុំថ្មីអ៊ីចឹងទៅក៏រាងបន្ថយបន្តិច

---

[520] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/252.1** ទំព័រ ៤៨ បន្ទាត់ ៨-១១។

[521] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សារឿន ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/283.1** ទំព័រ ៣៧ បន្ទាត់ ១៥-១៦។

[522] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សារឿន ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/283.1** ទំព័រ ៣៧ បន្ទាត់ ១៤-២៥។

[523] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សារឿន ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/283.1** ទំព័រ ៣៨ បន្ទាត់ ១១-១២។

[524] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សារឿន ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/283.1** ទំព័រ ៣៨ បន្ទាត់ ១៦-១៧។

អ៊ុចឹងទៅ”[525]។ គាត់ដឹងបែបនេះ ពីព្រោះ “ខ្ញុំហូបនៅជាមួយ តុជាមួយតែគ្នាហ្នឹង។ ប៉ុន្តែគេក្រុម -- គេអង្គុយតុអ៊ុចឹងទៅ ហើយខ្ញុំអង្គុយតុខាងជិតហ្នឹងទៅ ឃើញ”[526]។

## ៧.៤. ចេតនានៃការប្រព្រឹត្តការរើសអើង

*ការចុះឈ្មោះ*

281. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន បានរំឭកឡើងវិញពីការជម្លៀសរូបគាត់ទៅវត្តចំប៉ាលើ។ គាត់បានពិពណ៌នាថា “ចាស ប្រជាជនចេញពីក្នុងខេត្តតាកែវទៅច្រើនរាប់ម៉ឺន រាប់លានក្នុងខេត្ត ចេញទាំងអស់ ជម្លៀសទៅទាំងអស់”[527]។ ដើមបណ្តឹងរដ្ឋប្បវេណីបានបំភ្លឺថា “គាត់មានដើរកត់ថា “មិត្តយើងធ្វើអី? ប្រាប់មក! ខ្ញុំរកការងារឲ្យធ្វើវិញ ចូលធ្វើកន្លែងដដែលវិញ”។ ហើយគាត់ចាញ់ប្រាជ្ញា អត់ដឹង ដូចនាងខ្ញុំក៏អត់ដឹងដែរ ប្រាប់ទៅ កត់ថ្ងៃក្រោយ ស្រង់ឈ្មោះហ្នឹងយកទៅបាត់ៗទៅ”[528]។ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន បានពិពណ៌នាថា មានការបាត់ខ្លួននៅឯវត្តនោះ “ចាស បាត់ មាខ្ញុំ គាត់ធ្វើគិញ គ្រូ ប៉េអឹម ប៉ូលីស គយ យកទៅ ថាទៅធ្វើការបាត់រហូតទល់សព្វថ្ងៃ”[529]។

---

[525] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អៀម យ៉េន ប្រតិចារឹក ថ្ងៃទី១ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/286.1** ទំព័រ ៣៧ បន្ទាត់ ៤-៥។

[526] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អៀម យ៉េន ប្រតិចារឹក ថ្ងៃទី១ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/286.1** ទំព័រ ៣៧ បន្ទាត់ ១១-១២។

[527] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម សារឿន ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/283.1** ទំព័រ ១៨ បន្ទាត់ ១១-១២។

[528] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម សារឿន ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/283.1** ទំព័រ ១៨ បន្ទាត់ ១៦-១៨។

[529] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម សារឿន ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/283.1** ទំព័រ ១៨ បន្ទាត់ ២១-២២។

282. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម សារឿន បានបញ្ជាក់ថា ក្រោយមក អ្នកដែលទទួលខុសត្រូវរោងបាយសហករណ៍ស្គាល់ប្រជាជន ១៧ មេសា តាមរយៈប្រជាជនមូលដ្ឋាន "ដើរកត់ឈ្មោះ។ មេភូមិ មេក្រុមៗកត់ឈ្មោះឲ្យមេភូមិ។ មេភូមិដឹងបែងចែក"[530]។

283. ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ បានពន្យល់ថា "បាទ បើតាមខ្ញុំពិនិត្យសកម្មភាពរបស់វា គឺវាលម្អិតណាស់បាទ។ យើងអ្នកមកពីភ្នំពេញ១៧ហ្នឹងវាដឹង។ អ៊ីចឹង រាល់សកម្មភាពការងារ វាៗធ្វើទារុណកម្មមកលើយើង តែយួន ហើយនិងមកពីភ្នំពេញហ្នឹងបាទ។ ដោយឡែក អ្នកមូលដ្ឋានហ្នឹងគេអត់មានហាត់នឿយលំបាកលំបិនដូចយើងទេបាទ"[531]។

## *ការធ្វើជីវប្រវត្តិ*

284. ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ដែលជាប្រជាជនថ្មី បានផ្តល់សក្ខីកម្មថា "គេហៅធ្វើប្រវត្តិរូបពីរដង បញ្ជូនទៅដល់ស្រុកត្រាំកក់ហ្នឹង នៅពោធិ៍ព្រះសង្ឃហ្នឹង ធ្វើប្រវត្តិរូបម្តង។ ដល់មកប្រមូលភូមិមកនៅខ្ទមហ្នឹង ធ្វើប្រវត្តិរូបម្តងទៀត។ ធ្វើប្រវត្តិរូបហើយម្តងទៀត ថាគាត់អត់មានធ្វើការទេ គាត់ធ្វើពេទ្យ ព្យាបាលរបួស និងធ្វើពេទ្យ។ ប្រាប់អ៊ីចឹងហើយ ដល់ហើយ គេថ្ងៃក្រោយទៀត គេមកឆែក។ ឆែកឆេរក្នុងខោអាវហ្នឹង ដែលមានដោយរូបថត។ រូបថតហ្នឹង ថតទើបតែថតកាលមុនឆ្នាំហ្នឹង ហើយដាក់ក្នុងហោប៉ៅហ្នឹង មិនទាន់បានយកចេញ។ ហើយដល់ពេល គេវាយៗរំដោះបែកទៅ ក៏អាខោអាវប្រមូលញាត់ក្នុងស្បោងសហ្នឹង ក៏យកមក។ យកមក ក៏ចាក់ជជុះទៅ ឃើញរូបថត ចាស"[532]។ ទោះជាយ៉ាងនេះក្តី "ប្រជាជនចាស់មានតួនាទីអីត្រូវធ្វើប្រវត្តិរូប។ ប្រជាជនចាស់គេមកធ្វើប្រវត្តិរូបយើងអ្នកថ្មី។ ប្រជាជនចាស់អត់មានទេ គេប្រវត្តិរូបគេមានតាំងពីឆ្នាំ ៧១

[530] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម សារឿន ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/283.1** ទំព័រ ៣៧ បន្ទាត់ ២២។

[531] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ពៅ រី ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/262.1** ទំព័រ ១៣ បន្ទាត់ ៧-១០។

[532] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/252.1** ទំព័រ ៦២ បន្ទាត់ ៥-៩។

ឆ្នាំ ៧២ មករហូត។ ហើយយើងនេះ ៧៥ នេះ ១៧មេសានេះ យើងចុះទៅ គេត្រូវធ្វើប្រវត្តិរូបទាំងអស់ ចាស”[533]។

285. ដើមបណ្តឹងរដ្ឋប្បវេណី បានផ្តល់សក្ខីកម្មថា “ប្រធានភូមិៗ អនុប្រធានភូមិ អាស្មីគេ នាវីៗគេទៀត គេដើរមក ដើរសួរប្រវត្តិរូបយើងហ្នឹង មានគ្នាបីនាក់។ គេធ្វើខ្លួនគេ គេកត់ខ្លួនគេ យើងអត់មានតួនាទីអីកត់ យើងមានប៊ិក មានសៀវភៅមកពីណា អត់មានទេ។”[534]

## ៨. ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុជាតិសាសន៍

286. ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់នៅក្នុងសវនាការ បញ្ជាក់ថា ការបាត់ខ្លួននៃក្រុមគ្រួសារដែលបានត្រឡប់មកពីវៀតណាមជាមួយនឹង វី ពៅ មាននៅក្នុងផ្នែក ខ(៦) ជាការធ្វើទុក្ខបុកម្នេញដោយមូលហេតុពូជសាសន៍។

287. ដើមបណ្តឹងរដ្ឋប្បវេណី វី ពៅ បានពន្យល់ថា នៅពេលគាត់ និងក្រុមរបស់គាត់ បានត្រឡប់មកប្រទេសកម្ពុជាវិញ មិនមានការធ្វើជីវប្រវត្តិអ្វីឡើយនៅពេលពួកគាត់មកដល់។ ដើមបណ្តឹងរដ្ឋប្បវេណី វី ពៅ បានពន្យល់ថា ការណ៍នេះគឺដោយសារ “គេដឹងថាយើងមកពីយួនហើយ”[535]។

## ៩. ការធ្វើទុក្ខបុកម្នេញផ្នែកសាសនាប្រឆាំងនឹងពុទ្ធសាសនិកជន

288. ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់នៅក្នុងសវនាការ បញ្ជាក់ថា ការបាត់ខ្លួនបងប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន និងព្រះសង្ឃ ១៥ អង្គ ពីវត្តនៅជិតសហករណ៍ត្រពាំងថែង ការចាប់ផ្សឹកក្មួយប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ព្រមទាំងការវាយកម្ទេច និងការកែប្រែទីវត្តអារាម គឺជាអំពើធ្វើទុក្ខបុកម្នេញប្រឆាំងនឹងពុទ្ធសាសនិក។

[533] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/252.1** ទំព័រ ៦២ បន្ទាត់ ១៥-១៧។

[534] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/252.1** ទំព័រ ៦២ បន្ទាត់ ២០-២២។

[535] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ពៅ វី ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/262.1** ទំព័រ ៤៦ បន្ទាត់ ៥-៦។

289. ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន បានបំភ្លឺពីអ្វីដែលគាត់បានឃើញនៅវត្តនៅជិតមន្ទីរសន្តិសុខក្រាំងតាចាន់ថា៖ "រឿងអារម្មណ៍ខ្ញុំ វានឹកឃើញថាវាសោកស្តាយដែរ កន្លែងធ្លាប់បូជា កន្លែងគោរពទាល់តែទៅអត់មានលោក គ្មានអីអ៊ីចឹង ដឹងជាថា វាពិបាក ធ្លាប់មានបុណ្យមានទាន ដល់ពេលអត់មានបុណ្យមានទាន អ៊ីចឹងខ្ញុំក៏វាពិបាក។ ការនឹងគោរពបូជា វាដូចថា វាគ្មានអីទីពឹងអីទាំងអស់។ វាសាសនាក៏វាអស់ ណាមួយទៅវាបាត់បង់គោរពបូជា ដឹងទៅធ្វើស្អីនៅកន្លែងណាកើត វាមិនដែលជួបប្រទះ វាមិនដែលឃើញ។ ទើបតែជំនាន់ហ្នឹងបានខ្ញុំឃើញ របៀបរបបហ្នឹង វាដូចជាវាអស្ចារ្យពេកហើយ"[536]។

290. ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡុន បានពិពណ៌នាពីរបៀបដែល "វត្តអារាមក្លាយជាទីឃុំឃាំងរបស់ជនស្លូតត្រង់"[537]។ គាត់បានផ្តល់សក្ខីកម្មថា "វត្តលាយបូរ កាលពីជំនាន់សង្គមប្រជាធិបតេយ្យខ្មែរក្រហមហ្នឹង ក្លាយជាកន្លែងដាក់កុមារ ហើយអ្នកទោសក៏មានដាក់នៅកន្លែងហ្នឹងដែរ ហើយនិងកុមារ។ អ្នកទោសមានទោសក៏នៅ ដាក់នៅវត្តលាយបូរដែរ តែមានច្រើនកន្លែង មានវិហារ មានសាលា មានកុដិលោក។ កន្លែងវត្តអារាមហ្នឹងក្លាយជាកន្លែងអ្នកទោសពីសង្គម ប៉ុលពត តែឥឡូវគេជឿនលឿនល្អ"[538]។

291. ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន បានផ្តល់សក្ខីកម្មថា "ខ្ញុំក៏ទៅហ្នឹងទៅ ទៅដល់ហ្នឹង នឹងឃើញថាទៅវត្ត មានលោកដូចវត្តឯណោះអត់ ខ្ញុំចង់ដឹងដែរ ដល់ពេលទៅដល់ហ្នឹង ពេលទៅដល់ស្ងាត់ឈឹង។ ឃើញតែស្រះគេបូមហើយ នៅក្រៀមៗហ្នឹង គេចាប់ផ្តើមវាស់ដី វាស់អីហ្នឹងចែកទៅម៉ាក្នុងបីនាក់ -- បីម៉ែត្រ បណ្តោយអ៊ីចឹងទៅគេឲ្យក្នុងម្នាក់ ហើយអាចាស់ៗហ្នឹង វា២ម៉ែត្រ ទទឹងអ៊ីចេះ បណ្តោយអ៊ីចេះបីជម្រៅប្រាំតឹក។ ដល់ពេលកាប់ហ្នឹង ក៏ចេះតែកាប់ៗហ្នឹងទៅ ខ្ញុំចេះតែឆ្លុះចុះវត្តធ្លាប់មានលោក ក៏ស្ងាត់ឈឹងអ៊ីចឹង ហើយព្រះវិហារហ្នឹងក៏ដឹងព្រះទៅឯណា បើអត់ឃើញ ឃើញតែវិហារទទេ។ ឆ្លុះ ហើយវិហារនោះ វិហារធ្វើអំពីឈើ អត់ធ្វើអំពីថ្មទេ វិហារវត្តបាខុង

[536] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន ប្រតិចារឹក ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/288.1** ទំព័រ ២៦ បន្ទាត់ ១៩-២៣។

[537] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡុន ប្រតិចារឹក ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/253.1** ទំព័រ ៦៨ បន្ទាត់ ៥-៦។

[538] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡុន ប្រតិចារឹក ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/253.1** ទំព័រ ១២ បន្ទាត់ ១៦-១៩។

ហ្នឹង។ ហើយអាកុដិអីក៏អត់ឃើញ ឃើញតែសាលាថ្មមួយនៅហ្នឹង ហើយឃើញតែឈ្លបឃើញអីគេនៅហ្នឹង"[539]។

292. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី បានផ្តល់សក្ខីកម្មថា គាត់បានសម្រាលកូននៅក្នុងវត្ត "ពេទ្យដែលខ្ញុំទៅសម្រាលកូននោះឈ្មោះហៅថា "ពេទ្យត្រពាំងគល់" ប៉ុន្តែមិនមែនជាពេទ្យទេ គឺតាំងនៅក្នុងវត្ត"[540]។

## គ. ព្យសនកម្ម

### ១. ព្យសនកម្មរាងកាយ

*ព្យសនកម្មរាងកាយភ្លាមៗ*

293. ដើមបណ្តឹងរដ្ឋប្បវេណី យែម ខុន្នី បានពិពណ៌នាអំពីព្យសនកម្មភ្លាមៗដែលគាត់បានទទួលរងដោយសារអាហារមិនគ្រប់គ្រាន់ និងការធ្វើការហួសកម្លាំង។ គាត់បានថ្លែងថា៖ "បើជើងអីវ៉ិនស្គមដូចឆ្អឹងនៅតែឆ្អឹង គ្មានស្អី ថាស្គមគ្រាន់តែដើរទាក់ស្មៅក៏ដួលដែរ។ ដល់តែយើងដួលទៅ ថាយើងនេះពុត ដល់យើងឈឺ ថាយើងនេះពុត ធ្វើស្អីមិនកើត។ ហើយពុតស្អី បើគ្មានជីវជាតិឲ្យឆ្ងាញ់ ឲ្យនេះផង។ ស្គមឡើងជង្គង់អីវ៉ិន មួយជង្គង់ដូចជង្គង់កុក លើសជង្គង់កុកផង អាហ្នឹងជង្គង់មនុស្ស"[541]។

294. ដើមបណ្តឹងរដ្ឋប្បវេណី ជូ គីមឡូន បានផ្តល់សក្ខីកម្មអំពីការធ្វើការទាំងជើងឈឺ និងផលវិបាកដែលទទួលរងដោយសារជំងឺនេះ។ គាត់បានពិពណ៌នាថា៖ "ដល់ខែស្ទូង គេឲ្យយើងរែកជីដាក់ស្រែង

---

[539] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន ប្រតិចារឹក ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/288.1** ទំព័រ ៣១-៣២ បន្ទាត់ ១៩-៣។

[540] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី២២ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/250.1** ទំព័រ ៦៥ បន្ទាត់ ៨-៩។

[541] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យែម ខុន្នី ប្រតិចារឹក ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/288.1** ទំព័រ ៩ បន្ទាត់ ៨-១១។

ស្ទូង មានការលំបាក ហើយយើងៗ មានកើត -- ពេលខែស្ទូងហ្នឹង គេឱ្យយើងស្ទូងហ្នឹងៗ ជើងយើងហ្នឹងកើតដំបៅឃ្លួន ឈឺ ហូរទឹក មានខ្ទុះហូរទឹក"[542]។

295. ដើមបណ្តឹងរដ្ឋប្បវេណី ថាន់ ធីម បានពិពណ៌នាអំពីការឈឺចាប់ផ្នែករាងកាយ ដែលគាត់បានទទួលរងក្នុងអំឡុងការឃុំឃាំងនៅផ្សារអង្គរកា។ គាត់បានថ្លែងថា៖ "ការឈឺចាប់របស់ខ្ញុំហ្នឹងមិនអាចមានអ្វីមកប្រៀបផ្ទឹមបានទេបាទ។ ខ្ញុំនឹកថា ខ្ញុំនឹងមិនបានរស់មានថ្ងៃនេះទេ ខ្ញុំនឹកក្នុងចិត្តខ្ញុំ។ ព្រោះថាឈឺចាប់អាផ្នែកផ្លូវកាយហ្នឹងវាឈឺហើយ ផ្លូវចិត្តហ្នឹងក៏វាពិបាកណាស់ទៀត។ បត់ដៃបត់ជើងអីហ្នឹងមិនងាយទេ ខ្ញុំថា ខ្ញុំតាំងពីខ្ញុំកើតមក ខ្ញុំមិនដែលជួបប្រទះទេ ទើបមកក្នុងជំនាន់៣ឆ្នាំហ្នឹង ខ្ញុំជួបប្រទះធ្ងន់ធ្ងរយ៉ាងនេះ"[543]។

## *ព្យសនកម្មផ្នែករាងកាយរយៈពេលវែង*

296. ដើមបណ្តឹងរដ្ឋប្បវេណី អៀម យ៉េន បានផ្តល់សក្ខីកម្មអំពីព្យសនកម្មផ្នែករាងកាយរយៈពេលយូរដែលគាត់បន្តរងការឈឺចាប់។ គាត់បានថ្លែងថា៖ "ចាស សុខភាពក៏មិនមាំមួនអីដែរ ព្រោះអីកាលនោះនៅក្មេងកុមារតូចប្រើធ្វើការហួសកម្លាំង"[544]។ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មអំពីការរងការឈឺចាប់ផ្នែករាងកាយដែលគាត់បានទទួល ខណៈគាត់ត្រូវបានដាក់ទណ្ឌកម្ម។ គាត់បានថ្លែងថា៖ "ចាស ពេលកប់ហ្នឹង អាហារអត់មានឱ្យហូប ទឹកក៏ស្រេកចង់ស្លាប់ហើយ។ រីឯរាងកាយខ្ញុំហ្នឹងក៏ចុកចាប់ពេញខ្លួន ខ្ញុំស្រែកទ្រហោយំរកម៉ែរកឪមកជួយក៏មិនឃើញដែរ ព្រោះអីខ្ញុំកាលជីកកប់ហ្នឹង អត់មានជីកកប់ក្នុងអង្គប្រជុំឯណាទេ។ ជីកកប់ហ្នឹងពេលដែលគេយកខ្ញុំបានមកៗ អ៊ីចឹង ពេលកងកុមារខ្ញុំហ្នឹង ចេញទៅធ្វើការអស់ហើយ គេកប់ខ្ញុំហ្នឹងនៅកន្លែងកងហ្នឹងតែម្តង កងដែលស្នាក់អាស្រ័យនៅរាល់ថ្ងៃហ្នឹង"[545]។

---

[542] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គីមឡូន ប្រតិចារឹក ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥ ឯកសារ E1/253.1 ទំព័រ ៦៧ បន្ទាត់ ១៨-១៩។

[543] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ថាញ់ ធីម ប្រតិចារឹក ថ្ងៃទី២ ខែមេសា ឆ្នាំ២០១៥ ឯកសារ E1/287.1 ទំព័រ ២៧ បន្ទាត់ ២១-២៤។

[544] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អៀម យ៉េន ប្រតិចារឹក ថ្ងៃទី១ ខែមេសា ឆ្នាំ២០១៥ ឯកសារ E1/286.1 ទំព័រ ៥២ បន្ទាត់ ១១-១២។

[545] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អៀម យ៉េន ប្រតិចារឹក ថ្ងៃទី១ ខែមេសា ឆ្នាំ២០១៥ ឯកសារ E1/286.1 ទំព័រ ៥១ បន្ទាត់ ១២-១៦។

297. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ឹម វណ្ណៈ បានផ្ដល់សក្ខីកម្មថា៖ "ចាស ខ្លួនខ្ញុំសព្វថ្ងៃមានជំងឺជាប់ខ្លួនរហូត។ ខ្ញុំពុំបានរៀនសូត្រដូចគេឯងទេ នាងខ្ញុំរៀនបានតែត្រឹមថ្នាក់ទី៤ ទី៥ប៉ុណ្ណោះ ពីព្រោះនាងខ្ញុំមានជំងឺជាប់ខ្លួនផង ណាមួយឪពុកម្ដាយចាស់ មិនបានរៀនសូត្រទេ"[546]។

## ២. ព្យសនកម្មផ្លូវចិត្ត

*ព្យសនកម្មភ្លាមៗ*

298. ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន បានពិពណ៌នាថា៖ "គេបញ្ជូនខ្ញុំចេញពីហ្នឹងទៅនៅខាងត្បូងសាលាឃុំ។ ខាងត្បូងសាលាឃុំ ក៏ប្រសូតបានកូនប្រុស១ ហើយក៏គេប្រើធ្វើទារុណកម្មដើម្បីឱ្យ -- គ្មានទឹកថាយើងជាកូនខ្ចី អត់មានពេទ្យ អត់មានថ្នាំ អត់មានអីទេ គឺថាគេឱ្យយើងទៅច្រូតបាន ២៧ ថ្ងៃគេឱ្យខ្ញុំទៅច្រូត។ ដូច្នេះ ការឈឺចាប់ហ្នឹងវាមិនអាចបំភ្លេចបាន។ រហូតដល់យើងធ្វើច្រូតហើយ ដល់ច្រូតហើយគេឱ្យយើងកាយអាចម៍ៗលាយ។ ដល់ច្រូតហើយដល់ពេលគេប្រមូលផ្ទាំងបាយរួម ហើយ គេប្រមូលផ្ទាំងបាយរួម គេឱ្យហូបរួម។ ហូបរួមហើយគេឱ្យយើងកាយ កាយលាមកហាល នៅជុំវិញសហករណ៍ ដែលយើងហូបបាយហ្នឹង គេធ្វើបង្គន់ជុំវិញហ្នឹង ហូបបាយហើយត្រូវទៅបង្គន់ហ្នឹងអត់ឱ្យចូលតាមផ្ទះទេ ហើយយើងកាយហាល១ ហើយយើងចិញ្ច្រាំសន្សំជី ខ្ញុំកូនខ្ចីគេឱ្យសន្សំជី ចិញ្ច្រាំទន្រ្ទានខែត្រ ហើយនិងកាយលាមកហ្នឹងទៅចាក់ក្នុងរណ្ដៅទន្រ្ទានខែត្រហ្នឹង ហើយពេញមួយរណ្ដៅ១គេលុប"[547]។

299. ដើមបណ្ដឹងរដ្ឋប្បវេណី តាក សាន់ បានពិពណ៌នាអំពីការឈឺចាប់របស់គាត់ដោយសារគេបំបែកគាត់ចេញពីកូនរបស់គាត់។ គាត់បានថ្លែងថា៖ "ទឹកឃើញកូន ហើយនិងម្ដាយហ្នឹងស្រឡាញ់កូន ហើយកូនមិនបានជួប កូនទៅឆ្ងាយពីភ្នែក ម្ល៉ោះហើយចេះតែទឹកកូនអ៊ីចឹងហើយ មិនដឹងធ្វើ

[546] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ វណ្ណៈ ប្រតិចារឹក ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ឯកសារ E1/288.1 ទំព័រ ៥៤ បន្ទាត់ ១២-១៤។

[547] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥ ឯកសារ E1/253.1 ទំព័រ ៦៦ បន្ទាត់ ១៨ ដល់ទំព័រ ៦៧ បន្ទាត់ ៨។

ម៉ែច"[548]។ គាត់បានបន្ថែមថា៖ "ខ្ញុំមានកូនមួយទៀត ពោះធំ។ ដល់រួចទៅមុនហ្នឹងយកប្ដីខ្ញុំទៅបាត់ទៅ មិនដឹងយកទៅឯណា ហើយខ្ញុំកូនង៉ែតតែម្នាក់ឯងនៅក្នុងពេទ្យ"[549]។

*ព្យសនកម្មរយៈពេលវែង- ចង់បានចម្លើយអំពីអតីតកាល*

300. ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន បានផ្ដល់សក្ខីកម្មថា៖ "តែការចុកចាប់ដែលខ្មែរៗជាតិខ្មែរសម្លាប់ខ្មែរដូចគ្នា តើគាត់ធ្វើបដិវត្តន៍យ៉ាងណា? តើបដិវត្តន៍គាត់ថាគាត់វាយរំដោះទីក្រុងភ្នំពេញ។ គាត់ធ្វើបដិវត្តន៍ឲ្យមានឋានៈស្មើគ្នា រំដោះពីនឹមចក្រពត្តិអាមេរិកកាំង។ ចុះបើគាត់រំដោះ មូលហេតុអ្វីក៏គាត់ចាំបាច់មានកាប់សម្លាប់? បើរំដោះឲ្យបាយហូប ឲ្យមានព្រះពុទ្ធសាសនា ឲ្យមានសាលារៀន វប្បធម៌ ហ្នឹងជាការត្រឹមត្រូវ។ ចុះគាត់រំដោះៗរបៀបណា? រំដោះហេតុអ្វីក៏បង្អត់បាយ? ហេតុអ្វីក៏អត់មានសាលារៀន អត់មានរៀនព្រះពុទ្ធសាសនា អត់មានវត្តអារាម។ វត្តអារាមក្លាយជាទីឃុំឃាំងរបស់ជនស្លូតត្រង់"[550]។

301. ដើមបណ្ដឹងរដ្ឋប្បវេណីបានបន្តថា៖ "តើចំណុចនេះតើគាត់យល់យ៉ាងណា? និងអង្គតុលាការសូមវែកញែក។ ហើយចំណុចមួយទៀត ដែលគាត់មិនព្រមទទួលសារភាពថាគាត់បានប្រព្រឹត្ត និងគាត់មិនបានដឹងថាមានកាប់សម្លាប់។ តើមូលហេតុអីបានគាត់ពោលពាក្យមួយម៉ាត់ដូច្នេះ មួយឃ្លានេះ? គាត់អត់បានកាប់សម្លាប់ អត់បានដឹងគេកាប់សម្លាប់ប្រជាជនទេ។ កាប់សម្លាប់ប្រជាជនមិនមែនទើបតែកាប់សម្លាប់នៅពេលនេះទេ កាប់សម្លាប់រហូតដល់តែ៣ឆ្នាំ ៨ខែ ២០ថ្ងៃ។ តើមូលហេតុអីបានជាគាត់ឆ្លើយបដិសេធយ៉ាងដូច្នេះ? ខ្ញុំសូមឲ្យអង្គតុលាការជួយបំភ្លឺរឿងនេះ និងរកយុត្តិធម៌ ហើយនិងខូចខាតរបស់ទ្រព្យខ្ញុំដែលមានសេសសល់នៅភ្នំពេញ គឺផ្ទះបីខ្នង និងដី ហើយនិងមានកូនឡានតូចមួយទៀត។ តើជារបស់ទ្រព្យដែលខំសន្សំរកស៊ីតាំងពីណាពីណី ហើយដល់យើងមកបាត

[548] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី តាក សាន់ ប្រតិចារឹក ថ្ងៃទី១ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/286.1** ទំព័រ ២៤ បន្ទាត់ ៥-១។

[549] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី តាក សាន់ ប្រតិចារឹក ថ្ងៃទី១ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/286.1** ទំព័រ ២៤ បន្ទាត់ ៩-១០។

[550] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/253.1** ទំព័រ ៦៧ បន្ទាត់ ២០ ដល់ទំព័រ ៦៨ បន្ទាត់ ៦។

ដែទទេយើងនៅអត់ៗ រហេមរហាមដល់សព្វថ្ងៃ។ តើសូមតុលាការវែកញែករកយុត្តិធម៌ ជួយបំភ្លឺ តើមូលហេតុអីបានគាត់ឆ្លើយពាក្យអត់ទាំងពីរឃ្លានេះ”[551]។

302. ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ បានបន្ទរអារម្មណ៍នេះ ដោយពន្យល់ថា៖ “បើនិយាយអំពីការទុក្ខសោកក្នុងរបបប្រល័យពូជសាសន៍នោះ បើខ្ញុំនិយាយទៅខ្ញុំមិនចង់បានអ្វីដែលគួរឲ្យសម្រាប់ខ្លួនខ្ញុំទេ។ ប៉ុន្តែខ្ញុំចង់ថា ខ្ញុំសព្វថ្ងៃនេះវាមានវិប្បដិសារីដល់ម្តាយដល់ឪពុក ដល់ប្អូនរបស់ខ្ញុំ និងបងប្អូនដែលបានរងទុក្ខ ដែលពួកខ្មែរក្រហមធ្វើទារុណកម្មកាប់សម្លាប់សាហាវព្រៃផ្សៃដោយអំពើអយុត្តិធម៌ធ្វើប្រតិកម្មមកលើក្រុមគ្រួសាររបស់ខ្ញុំនេះ។ អ៊ីចឹងខ្ញុំគ្រាន់ថា អ្វីទាំងឡាយណាសូមឲ្យខាងអង្គការសហប្រជាជាតិ ព្រមទាំងតុលាការសាលាក្តីខ្មែរក្រហមហ្នឹងមេត្រាជួយធ្វើយ៉ាងណាកុំឲ្យមានអារបបឃោឃៅព្រៃផ្សៃអ៊ីចឹងវិលត្រឡប់មកបានទៀត ហើយក៏សំណូមពរឲ្យខាងផ្នែកតុលាការហ្នឹង ជួយធ្វើការវិនិច្ឆ័យ កាត់ទោសពួកមេខ្លោងរបស់ខ្មែរក្រហមហ្នឹងឲ្យសមៗនឹងកំហុសធ្ងន់ ដែលខ្លួនបានប្រព្រឹត្តទៅលើប្រជាពលរដ្ឋកម្ពុជាទូទាំងប្រទេសដែលគាត់បានធ្វើទុក្ខបុកម្នេញដល់បងប្អូនខ្មែរយើងកន្លងមក”[552]។

303. ដើម្បីពិពណ៌នាអំពីការឈឺចាប់របស់គាត់ ដើមបណ្តឹងរដ្ឋប្បវេណី បេង បឿន បានថ្លែងថា៖ “ខ្ញុំបាទអន់ចិត្ត និងឈឺចិត្តដោយសារមូលហេតុអ្វីដែលយកប្អូនថ្លៃទៅហើយ មិនប្រាប់មូលហេតុ មានកំហុសរឿងអ្វី។ យកទៅហើយ អត់មានប្រាប់កំហុសថា អ្នកឯងមានទោសអីៗ ឬក៏ផ្តល់ដំណឹងថាអញយកប្អូនមិត្តឯងទៅហើយ ក៏មិនឮសម្តីមួយម៉ាត់។ ហើយរឿងបេះដូងហ្នឹងមួយទៀត ក៏មិនប្រាប់កំហុសគ្នាថា អ្នកឯងកុំហូបឯកជន គឺរបស់នេះសុទ្ធតែជារបស់រួម គឺមិនប្រាប់កំហុសអ្វីទាំងអស់។ រួចមកដល់ជាឪពុកក្មេកមួយរូបដែលគាត់ចិញ្ចឹមបីបាច់ថែរក្សាខ្ញុំ និងឲ្យកូនគាត់មកធ្វើជាគ្រួសារខ្ញុំម្នាក់ហ្នឹង គាត់ថ្នាក់ថ្នមបងថ្លៃខ្ញុំហ្នឹងក៏គាត់ស្រឡាញ់ខ្ញុំ រឿងអីទាំងបងទាំងប្អូន ក៏គាត់មិន

---

[551] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៥ ឯកសារ **E1/253.1** ទំព័រ ៦៨ បន្ទាត់ ៧-១៥។

[552] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ពៅ រី ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/262.1** ទំព័រ ៦០ បន្ទាត់ ៤-១២។

ឲ្យទៅមើល ឬក៏ទៅជួបមុខចុងក្រោយបង្អស់ហ្នឹង។ ខ្ញុំតូចចិត្តណាស់សព្វថ្ងៃ ខ្ញុំឈឺចិត្តណាស់ តែបើខ្ញុំបាននិយាយ អ៊ីចឹងហើយ មើលឃើញនូវតែរឿងថ្មីៗនៅនឹងមុខ"[553]។

***ព្យសនកម្មរយៈពេលវែង - សុខភាពផ្លូវចិត្ត***

304. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុង សារឿន បានផ្តល់សក្ខីកម្មថា៖ "ខ្ញុំបានខ្ញុំចង់ដាក់ពាក្យបណ្តឹង ខ្ញុំស្លាប់បងប្អូន ប្តី កូន ឪពុកម្តាយ សាច់ញាតិ ទ្រព្យរបស់អីអស់ច្រើន"[554]។ គាត់បានថ្លែងបន្តថា៖ "ខ្ញុំចាសនាងខ្ញុំនិយាយកាលខ្ញុំមកដាក់ពាក្យ។ ខ្ញុំៗសម្រាន្តមិនលក់ ឈឺក្បាលរសេះរសោះហើយថប់ៗទ្រូង ខ្ញុំគិតឃើញរឿងហ្នឹងចេះតែរឿងថ្មី ខ្លួនខ្ញុំផ្ទាល់ហ្នឹង"[555]។ នៅក្នុងការពិពណ៌នាអំពីការចងចាំ ឬការភ្លេចភ្លាំងរបស់គាត់ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា៖ "ចាស ខ្ញុំនិយាយ ប៉ុន្តែខ្ញុំចងចាំឥឡូវ ខ្ញុំអត់ភ្លេចភ្លាំងទេ អារម្មណ៍ខ្ញុំឥឡូវសម្រាន្តស្រួល។ ខ្ញុំបានថ្នាំពី ធី.ភី.អូ ម៉េច ខ្ញុំអត់សូវចងចាំ បើថ្នាំហើយ លេច អារម្មណ៍ខ្ញុំស្រួល ឥឡូវហ្នឹងស្រួល អត់មានភ្លេចភ្លាំងទេ នឹកឃើញរឿងដើម"[556]។ គាត់បានពន្យល់ថា៖ "កាលហ្នឹងនាងខ្ញុំសម្រាន្តអត់លក់ ហើយរសេះរសោះ ហើយដល់ពេលខ្ញុំនឹកឃើញរឿងដើមអ៊ីចឹង រសេះរសោះអ៊ីចឹង សម្រាន្តអត់លក់ ខ្ញុំរសាប់រសល់ ប៉ុន្តែនាងខ្ញុំចងចាំទាំងអស់"[557]។

305. ដើមបណ្តឹងរដ្ឋប្បវេណី អៀម យេន ដែលនៅជាកុមារនៅឡើយក្នុងពេលដែលគាត់ត្រូវបានចាប់ខ្លួន ហើយកប់ និងរងការវាយដំនោះ បានពន្យល់ថា៖ "ចាស មកដល់ពេលនេះ ការឈឺចាប់របស់ខ្ញុំ

---

[553] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី បេង បឿន ប្រតិចារឹក ថ្ងៃទី២ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/287.1** ទំព័រ ៥១-៥២ បន្ទាត់ ២២-៤។

[554] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម សារឿន ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/283.1** ទំព័រ ១៤ បន្ទាត់ ១៥-១៦។

[555] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម សារឿន ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/283.1** ទំព័រ ១៥ បន្ទាត់ ៣-៥។

[556] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម សារឿន ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/283.1** ទំព័រ ១៥ បន្ទាត់ ១០-១២។

[557] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុម សារឿន ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/283.1** ទំព័រ ៣៩ បន្ទាត់ ២៤-២៥។

កាលណាខ្ញុំនឹកឃើញ ខ្ញុំនឹកឃើញនៅក្នុងមុខ ខ្ញុំជានិច្ច នឹកឃើញក្នុងខ្លួនចិត្តខ្ញុំ ដូចកាលជំនាន់ដែលខ្ញុំរស់នៅ ដូចមុនហ្នឹងដដែលអ៊ីចឹង ឲ្យតែពេលខ្ញុំនឹកឃើញ”[558]។

*ព្យសនកម្មរយៈពេលវែង - ភាពសោកសង្រេង និងការព្រាត់ប្រាស់គ្រួសារ*

306. ដើមបណ្តឹងរដ្ឋប្បវេណី យ៉ែម ខុន្នី បានពិពណ៌នាអំពីភាពរងទុក្ខវេទនាដោយសារការបាត់បង់សមាជិកគ្រួសាររបស់គាត់។ គាត់បានថ្លែងថា៖ “បើនៅជិតគ្នារក្សា មើលឃើញនូវមុខមាត់ ដល់ពោះមួយខ្ញុំទៅបាត់បង់អស់ទៅ គ្មានអ្នកណាទីពឹង”[559]។ “ខ្ញុំឈឺចាប់ តែបាត់ខាងឪពុកម្តាយហ្នឹង ហើយនិងពោះមួយ ឲ្យខ្ញុំនៅកំសត់ម្នាក់ឯង មើលទៅគេ គេមានពោះមួយ ដល់មកខ្ញុំគ្មានពោះមួយ។ មើលទៅកំសត់ខំប្រឹងធ្វើការអត់ឃ្លានអីចេះតែទ្រាំៗរហូតដល់តែបែកៗអាពត”[560]។

307. ទាក់ទងនឹងការបាត់បង់ប្តីរបស់គាត់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដើមបណ្តឹងរដ្ឋប្បវេណី តាក សាន់ បានពន្យល់ថា៖ “នាងខ្ញុំលំបាកដែរ គ្រាន់ខ្ញុំថា ខ្ញុំអត់យកប្តីទៀតហ្នឹង ខ្ញុំនៅតែជាមួយកូនអ៊ីចឹងទៅ។ នាងខ្ញុំឈប់យក និយាយទៅខ្ញុំនឹកតែប្តីខ្ញុំហ្នឹង បានតែខ្ញុំឈប់យក”[561]។ សម្រាប់សាច់ញាតិផ្សេងទៀតរបស់គាត់ ដែលគាត់មិនបានទទួលដំណឹងថាតើពួកគេបានស្លាប់នៅទីណានោះ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា៖ “នាងខ្ញុំដល់ខែបុណ្យទាន ខ្ញុំដុតធូកដុតអីឧទ្ទិសទៅដែរ ប៉ុន្តែមិនដឹងប្តីខ្ញុំស្លាប់នៅឯណា អីឯណាខ្ញុំមិនដឹង”[562]។ សម្រាប់សំណាង ដើមបណ្តឹងរដ្ឋប្បវេណី

[558] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អៀម យ៉េន ប្រតិចារឹក ថ្ងៃទី១ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/286.1** ទំព័រ ៥២ បន្ទាត់ ២-៤។

[559] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យ៉ែម ខុន្នី ប្រតិចារឹក ថ្ងៃទី២ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/287.1** ទំព័រ ៧៥ បន្ទាត់ ៤-៥។

[560] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យ៉ែម ខុន្នី ប្រតិចារឹក ថ្ងៃទី២ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/287.1** ទំព័រ ៧៥ បន្ទាត់ ១៩-២១។

[561] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី តាក សាន់ ប្រតិចារឹក ថ្ងៃទី១ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/286.1** ទំព័រ ២៩ បន្ទាត់ ១១-១២។

[562] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី តាក សាន់ ប្រតិចារឹក ថ្ងៃទី១ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/286.1** ទំព័រ ២៩ បន្ទាត់ ១៦-១៧។

តាក សាន់ បានថ្លែងថា៖ "ខ្ញុំមិនចង់ទាមទារអីទេ ចង់ទាមទារឲ្យបានប្ដីខ្ញុំ ខ្ញុំស្ដាយប្ដីខ្ញុំពេក កូនប្ដី"[563]។

308. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុម វណ្ណៈ បានផ្ដល់សក្ខីកម្មអំពីការឈឺចាប់ដោយសារការបាត់បង់មនុស្សជាទីស្រឡាញ់របស់គាត់។ គាត់បានថ្លែងថា៖ "ការនឹករឭកៗស្រឡាញ់ទាំងអស់ ក៏ប៉ុន្តែធ្ងន់ចិត្តជាងគេបងប្រុសម្នាក់ដែលគាត់ស្លាប់ទៅហ្នឹង គាត់ធ្លាប់យកលួចនេះលួចនោះគេយកមកឲ្យហូបរហូត គាត់មកសួរសុខទុក្ខខ្ញុំរហូតជាងបងប្អូនទាំងអស់"[564]។ គាត់បានបន្ថែមថា៖ "ខ្លួនខ្ញុំសព្វថ្ងៃនេះ ឲ្យតែខ្ញុំនឹកឃើញអំពីរឿងស្លាប់របស់បងប្រុសខ្ញុំ ហើយនិងធ្វើបាបរាងកាយខ្ញុំៗនឹកឃើញថ្មើរម៉ានប្រៀបដូចជាកើតថ្មីៗនៅនឹងភ្នែករបស់នាងខ្ញុំ"[565]។

## ជំពូក ២. មន្ទីរសន្តិសុខក្រាំងតាចាន់[566]

---

[563] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី តាក សាន់ ប្រតិចារឹក ថ្ងៃទី១ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/286.1** ទំព័រ ៤៤ បន្ទាត់ ១១។

[564] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ វណ្ណៈ ប្រតិចារឹក ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/288.1** ទំព័រ ៥៤ បន្ទាត់ ១៧-១៩។

[565] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ វណ្ណៈ ប្រតិចារឹក ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/288.1** ទំព័រ ៥៤ បន្ទាត់ ២៣-២៤។

[566] អង្គជំនុំជម្រះសាលាដំបូង ត្រូវបានប្ដឹងអំពីអង្គហេតុនានាជុំវិញការបង្កើត និងដំណើរការនៃមន្ទីរសន្តិសុខក្រាំងតាចាន់ រួមមានការចាប់ខ្លួន ការឃុំឃាំង ការសួរចម្លើយ និងការសម្លាប់អ្នកទោស។ ក្រាំងតាចាន់ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៧៣ និងមានដំណើរការពេញអំឡុងយុត្តិធិការពេលវេលារបស់តុលាការ។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៤៨៩ -៥១៤ មន្ទីរសន្តិសុខក្រាំងតាចាន់ មានទីតាំងស្ថិតនៅចម្ងាយប្រមាណ៣៣គីឡូម៉ែត្រ ពីទីរួមខេត្តតាកែវ ហើយស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈកម្មាធិការស្រុក១០៥។ របាយការណ៍កំណត់អត្តសញ្ញាណទីកន្លែង ដែលត្រូវបានធ្វើឡើងដោយ ក.ស.ច.ស ទាក់ទងនឹងក្រាំងតាចាន់ ពិពណ៌នាអំពីទម្រង់នៃបរិវេណ និងអគារដែលមាននៅក្នុងពេលនោះ និងភ្ជាប់ឧបសម្ព័ន្ធជាមួយផែនទី និងរូបថត។ របាយការណ៍កំណត់អត្តសញ្ញាណទីកន្លែង កត់ត្រាថា "មានការខុសគ្នាខ្លះរវាងការពិពណ៌នារបស់សាក្សី [រួមទាំង សយ សែន] ចំពោះលក្ខណៈខាងក្រៅលំអិតនៃគុកនោះ ប៉ុន្តែជាទូទៅគុកនោះអាចត្រូវបានពិពណ៌នាបានថាជាបរិវេណមួយដែលមានអគារច្រើន ដែលត្រូវបានប្រើប្រាស់សម្រាប់ឃុំឃាំងអ្នកទោស ធ្វើទារុណកម្ម/សួរចម្លើយអ្នកទោស ជាកន្លែងស្នាក់នៅរបស់ឆ្មាំគុក និងជាកន្លែងហូបបាយផ្សេងគ្នារបស់ឆ្មាំគុក និងអ្នកទោស។ បរិវេណខាងក្នុងព័ទ្ធជុំវិញទៅដោយរបង ដោយមានក្លោងទ្វារពីរចូលទៅកាន់ទីនោះ គឺក្លោងទ្វារខាងកើត និងក្លោងទ្វារខាងលិច។ មានរបងព្រំប្រទល់កណ្ដាល ឬរបងទីពីរ ចម្ងាយប្រហែល ៥០ម ពីបរិវេណខាងក្នុង និងរបងខាងក្រៅ ឬរបងទីបី ចម្ងាយប្រហែល១០០ម ទៅ១៣០ម ពីបរិវេណខាងក្នុង។" ដីកាដំណោះស្រាយ ឯកសារ D427 កថាខណ្ឌ ៤៨៩ របាយការណ៍កំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខក្រាំងតាចាន់ ឯកសារ

## ក. ទិដ្ឋភាពទូទៅនៃភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណី

309. ដើមបណ្តឹងរដ្ឋប្បវេណីចំនួន២នាក់បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះពាក់ព័ន្ធនឹងបទពិសោធន៍ដែលពួកគេធ្លាប់ឆ្លងកាត់នៅមន្ទីរសន្តិសុខក្រាំងតាចាន់ ហើយភាគីដើមបណ្តឹងរដ្ឋប្បវេណីចំនួន៤នាក់បានផ្តល់សក្ខីកម្មថាមិត្តភក្តិឬសាច់ញាតិរបស់ពួកគេត្រូវគេយកទៅក្រាំងតាចាន់[567]។

310. ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ សយ សែន បានផ្តល់កំណត់ហេតុស្តាប់ចម្លើយចំនួន២ច្បាប់[568] ហើយ ជួយដល់អ្នកស៊ើបអង្កេតក្នុងការចុះទៅពិនិត្យមន្ទីរសន្តិសុខក្រាំងតាចាន់[569]។ គាត់ក៏បានផ្តល់សក្ខីកម្មបន្ថែម ជូនដល់អ្នកស៊ើបអង្កេតនៅឆ្នាំ២០១៣ផងដែរ[570]។ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ សយ សែន បានផ្តល់សក្ខីកម្មនៅអំឡុងពេលសវនាការជំនុំជម្រះក្តីសំណុំរឿង០០២/០២ ថា គាត់ត្រូវបានចាប់ ខ្លួននិងឃុំឃាំងនៅក្រាំងតាចាន់[571]។ គាត់ត្រូវបានចាប់ខ្លួននៅឆ្នាំ១៩៧៤ ប្រហែល

---

E3/5828 ថ្ងៃទី១៧ ខែមីនា ឆ្នាំ ២០០៩ KH ERN 00365708។ ឧក្រិដ្ឋកម្មដែលបានចោទថាបានកើតឡើងនៅក្រាំងតាចាន់ គឺស្ថិតនៅក្នុងគោលបំណងរួមដែល "ត្រូវបានអនុវត្តដើម្បីសម្រេចបាន និងការពារបដិវត្តន៍សង្គមនិយម គឺការលត់ដំនូវ "*សមាសភាពមិនល្អ*" និងការសម្លាប់ "*ខ្មាំង*" ទាំងនៅក្នុងជួរបក្ស និងក្រៅជួរបក្ស តាមមធ្យោបាយណាក៏ដោយដែលចាំបាច់។" ដីកាដំណោះស្រាយ ឯកសារ D427 កថាខណ្ឌ ១៧៨។ ផ្អែកលើការចោទប្រកាន់លើអង្គហេតុទាំងនេះ ជនជាប់ចោទ ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ដែលបានកើតឡើងនៅមន្ទីរសន្តិសុខក្រាំងតាចាន់ រួមមានការឃុំឃាំង ការធ្វើឱ្យទៅជាទាសករ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុជាតិសាសន៍ និងអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៣៧៣ ១៣៨១ ១៣៩១ ១៤០២ ១៤០៨ ១៤១៦ ១៤២២ ១៤២៦ (ការរំលោភផ្លូវភេទនៅក្នុងមន្ទីរសន្តិសុខ និងសហករណ៍) ១៤៣០ ១៤៣៤ ១៤៤២។ ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងសំណុំរឿង០០២/០២ **E301/9/1.1**។

567 ក.ស.ច.ស បានទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន១១នាក់ទាក់ទងនឹងមន្ទីរសន្តិសុខក្រាំងតាចាន់ (ដីកាដំណោះស្រាយ) ឯកសារ **D427** កថាខណ្ឌ៥១៥១)។

568 កំណត់ហេតុស្តាប់ចម្លើយ សយ សែន ឯកសារ **E3/5129** ថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៧ កំណត់ហេតុស្តាប់ចម្លើយ សយ សែន ឯកសារ **E3/5214** ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៨។

569 របាយការណ៍កំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខក្រាំងតាចាន់ ឯកសារ E3/5828 ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ ឧបសម្ព័ន្ធ ឃ៖ ប្លង់នៃមន្ទីរសន្តិសុខក្រាំងតាចាន់ ដែលបានចងក្រងចេញពីព័ត៌មានដែលផ្តល់ឱ្យដោយសយ សែន ឯកសារ **E3/5830**។

570 កំណត់ហេតុស្តាប់ចម្លើយ សយ សែន ឯកសារ **E3/9589** ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៣។

571 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/258.1** ទំព័រ ៥៧ បន្ទាត់ ២២។

អាយុ ១៥ ឬ ១៦ ឆ្នាំ[572] ហើយនៅក្រាំងតាចាន់រហូតដល់ឆ្នាំ១៩៧៩[573]។ គាត់រៀបរាប់ថាគាត់ត្រូវបានចាប់និងឃុំឃាំងក្នុង នាមជាជនស៊ីវិល នៅពេលដែលគាត់ "មិនបានប្រព្រឹត្តអ្វីខុសឡើយ"[574]។ ប៉ុន្តែឪពុករបស់គាត់គឺជា ប្រធានស្រុកនៅក្នុងរបបសីហនុ[575]។ គាត់ផ្តល់សក្ខីកម្មថាគាត់ត្រូវបានចាប់ខ្លួននៅភូមិត្រពាំងលាន រួចបញ្ជូនទៅមន្ទីរអង្គការដែលជាកងយុវជនស្នាក់នៅ[576]។ គាត់ត្រូវបានបញ្ជូនទៅគុកតាកែលនៅត្រពាំងព្រីង មុនពេលបញ្ជូនទៅក្រាំងតាចាន់ពេលយប់[577]។ ដើមបណ្តឹងរដ្ឋប្បវេណីពន្យល់ថាចុងបញ្ចប់ គាត់ត្រូវបានបញ្ជូនទៅក្រាំងតាចាន់ពីព្រោះគាត់នៅក្មេងពេកមិនអាចនៅក្នុងកងយុវជនបានទេ[578] ហើយថាទាហានពីក្រាំងតាចាន់បានមកត្រពាំងព្រីងដើម្បីនាំអ្នកទោស ក្នុងនោះរួមទាំងគាត់ផងដែរ បណ្តើរមកក្រាំងតាចាន់[579]។ អ្នកទោសត្រូវគេចងដៃហើយដើរថ្មើជើង[580]។ ក្រោយពីមកដល់ក្រាំង តាចាន់ ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ត្រូវបានដាក់ខ្នោះ[581]។ គាត់ត្រូវបានសួរចម្លើយ "អស់រយៈពេលប្រហែលកន្លះខែ ឬ១០ថ្ងៃ"ក្រោយពីមក

[572] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/257.1** ទំព័រ ៥៧ បន្ទាត់ ៦-៧។

[573] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/258.1** ទំព័រ ២៨ បន្ទាត់ ១៨-១៩។

[574] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៤៨ បន្ទាត់ ៧។

[575] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៤៨ បន្ទាត់ ៥-៦។

[576] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៥៩ បន្ទាត់ ៩-១០។

[577] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៥៩ បន្ទាត់ ១១-១២។

[578] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៣៨ បន្ទាត់ ១-៣។

[579] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៦០ បន្ទាត់ ១-២។

[580] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៦០ បន្ទាត់ ១-២។

[581] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៣៨ បន្ទាត់ ៦-៧។

ដល់ក្រាំងតាចាន់[582]។ ប្រហែល១ខែក្រោយមក គាត់ត្រូវគេចាត់តាំងឲ្យធ្វើការផ្សេងៗទាំងក្នុង និងក្រៅអគារគុក ដែលបង្គាប់ដោយបុគ្គលិកនៅ ក្រាំងតាចាន់[583]។ ដើមបណ្តឹងរដ្ឋប្បវេណីនេះ ពន្យល់ថាគាត់ត្រូវបានគេអនុញ្ញាតឲ្យធ្វើពលកម្មពី ព្រោះគាត់ក្មេងជាងគេ[584]។ គាត់ត្រូវបានគេ ប្រាប់កុំឲ្យមាត់ប្រាប់គេថាគេនឹងអនុញ្ញាតឲ្យរួចខ្លួន បើមិនចឹងទេនឹងត្រូវគេសម្លាប់មិនខាន[585]។

311. កិច្ចការមួយដែលគេឲ្យដើមបណ្តឹងរដ្ឋប្បវេណីនេះធ្វើគឺកប់សាកសពអ្នកដែលស្លាប់នៅក្រាំងតាចាន់ ដែលការងារនេះតម្រូវឲ្យមានការជីករណ្តៅសម្រាប់សាកសព និងសែងអ្នកទោសដែលស្លាប់ ដាក់ក្នុងផ្នូរ[586]។ គេក៏ប្រាប់ឲ្យគាត់ដាំដើមដូងលើទីតាំងរណ្តៅសាកសពរួមទាំងនោះផងដែរ[587]។

---

[582] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៧៩ បន្ទាត់ ១-២។

[583] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹកថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៣៨ បន្ទាត់ ១៣-១៨ និង ទំព័រ ៣៨ បន្ទាត់ ២១ ដល់ទំព័រ ៣៩ បន្ទាត់ ២។

[584] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៣៨ បន្ទាត់ ២១ - ២៣។

[585] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៣៨ បន្ទាត់ ២១ - ២៣។

[586] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៣៨ បន្ទាត់ ២៤-២៥។ *សូមមើលផងដែរ* របាយការណ៍កំណត់អត្តសញ្ញាណទីកន្លែង មន្ទីរសន្តិសុខក្រាំងតាចាន់ ឯកសារ E3/5828 ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ KH ERN 00365711 ("សយ សែន បានបញ្ជាក់ថា គាត់ត្រូវបានគេបញ្ជាឲ្យជីករណ្តៅកប់សាកសពជារៀងរាល់ថ្ងៃ។ ឆ្មាំគុក ប្រាប់គាត់នៅពេលព្រឹកអំពីចំនួនអ្នកទោសប៉ុន្មាននាក់ ដែលត្រូវប្រហារជីវិតនៅថ្ងៃនោះ ហើយគាត់នឹងជីករណ្តៅតម្រូវទៅតាមចំនួននោះ។ អ្នកទោសត្រូវបានយកទៅកន្លែងនោះ ហើយត្រូវបានប្រហារជីវិតនៅបន្តិចក្រោយមកក្នុងថ្ងៃដដែលនោះ ហើយសាកសពទាំងនោះក៏ត្រូវបានកប់។ រណ្តៅកប់សាកសព ទាំងនោះមានជម្រៅ១ម ទៅ១៥ម ប៉ុណ្ណោះ ហើយក្រោយនោះមួយថ្ងៃ ឬពីរថ្ងៃ សាកសពទាំងនោះចាប់ផ្តើមហើយ ធ្វើឲ្យប្រេះ ដី។ នៅពេលដែលមានក្លិនស្អុយខ្លាំងពេក ប្រធានគុកឈ្មោះ តាអាន់ បានបញ្ជាឲ្យសយ សែន កប់សាកសពទាំងនោះម្តងទៀត និងជីករណ្តៅថ្មីនៅទីតាំងមួយផ្សេងទៀត។ សយ សែន បានចង្អុលបង្ហាញទីតាំងមួយចំនួន ដែលគាត់បានកប់សាកសពអ្នកទោស ដែលត្រូវបានប្រហារជីវិតជាច្រើន។")

[587] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៣៩ បន្ទាត់ ១-៣។

ការងារជាប្រចាំរបស់គាត់មានដូចជាឃ្វាលក្របី និងគោ និងភ្ជួររាស់ដីស្រែ[588]។ គាត់ផ្តល់សក្ខីកម្មថាគាត់ត្រូវបានគេឱ្យធ្វើកិច្ចការផ្សេងៗទៀតផងដែរដូចជាសែងទឹកនោមនិងលាមក[589]។ គាត់ពន្យល់ថា គាត់ត្រូវបានគេឱ្យប្រមូលត្រឡោកដូងដែលមានទឹកនោមនិងលាមក ទៅចាក់ក្នុងធុងរួចហើយ យកសម្បកដូងទទេទៅឱ្យអ្នកទោសម្នាក់ៗដើម្បីឱ្យគេយកទៅដួសទឹកផឹក[590]។ ដើមបណ្តឹងរដ្ឋប្បវេណីក៏ត្រូវបានគេឱ្យឡើងត្នោតយកមកធ្វើទឹកត្នោតជូរ និងបានផ្តល់សក្ខីកម្មថា ឆ្មាំសន្តិសុខបានដឹងអំពីរឿងនេះ[591]។ ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មថាកិច្ចការមួយទៀតរបស់គាត់គឺរាប់ចំនួនអ្នកទោសនៅអគារឃុំឃាំងដែលគាត់ដេកនៅទីនោះ នៅពេលល្ងាចរាយការណ៍អំពីចំនួនអ្នកទោស ហើយបានពន្យល់ថាឆ្មាំដទៃទៀតមករាប់មួយម៉ោងម្តងនៅពេលយប់[592]។ ដើមបណ្តឹងរដ្ឋប្បវេណីកត់សម្គាល់ថាចំនួនអ្នកទោសប្រែប្រួលរហូត ដោយមានអ្នកទោសចូល និងចេញ[593]។

312. ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ សូត្រ សាំង ជាឆ្មាំយាមមន្ទីរសន្តិសុខក្រាំងតាចាន់។ គាត់បានផ្តល់សក្ខីកម្មថា គាត់បានចូលធ្វើយោធានៅឆ្នាំ១៩៧២ឬ១៩៧៣ ហើយនៅឆ្នាំ១៩៧៥ ឬ១៩៧៦ អង្គភាពរបស់គាត់ឈរជើងនៅភ្នំដំរីរមៀល ហើយទទួលការងារចាប់ជនក្បត់ជាតិ[594]។ នៅត្រឹមឆ្នាំ១៩៧៧

[588] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/258.1** ទំព័រ ៥៧ បន្ទាត់ ៣-៤។

[589] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/258.1** ទំព័រ ៥៧ បន្ទាត់ ១៤-១៥។

[590] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៤២ បន្ទាត់ ១១-១៦។

[591] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/282.1** ទំព័រ ៦៥ បន្ទាត់ ១៦-១៨។

[592] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹកថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៨២ បន្ទាត់ ៣-៥។

[593] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹកថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ១៩ បន្ទាត់ ៨-១៤។

[594] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/281.1** ទំព័រ ៧ បន្ទាត់ ៤-៩។

គេចាត់តាំងឲ្យគាត់យាមក្រាំងតាចាន់[595]។ នៅឆ្នាំ១៩៧៨ គាត់ត្រូវបានផ្ទេរត្រឡប់មកកងពល២១០ វិញដើម្បីវាយកងទ័ពវៀតណាម[596]។

313. នៅមន្ទីរសន្តិសុខក្រាំងតាចាន់ ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង បានផ្តល់សក្ខីកម្មថា គាត់ត្រូវបានប្រធានសន្តិសុខអប់រំដើម្បីផ្តល់សន្តិសុខនិងសុវត្ថិភាពដល់មន្ទីរទាំងមូល ហើយឲ្យគាត់ប្តេជ្ញាចិត្តថាប្រសិនបើបុគ្គលណាឬអ្នកទោសណាគេចខ្លួន នោះនឹងត្រូវអស់ជីវិត[597]។ ដើមបណ្តឹងរដ្ឋប្បវេណីក៏បានពិភាក្សារចនាសម្ព័ន្ធដឹកនាំរបស់មន្ទីរសន្តិសុខ គំនូសព្រាងនៃបរិវេណ និងលក្ខខណ្ឌរស់នៅរបស់អ្នកទោស។ ដើមបណ្តឹងរដ្ឋប្បវេណីផ្តល់សក្ខីកម្មថាអ្នកទោសត្រូវបានគេសួរចម្លើយ ហើយបានបញ្ជាក់ថាមានការសម្លាប់កើតឡើងនៅក្រាំងតាចាន់[598]។

***ការទំនាក់ទំនងជាមួយមន្ទីរស្រុក***

314. ដើមបណ្តឹងរដ្ឋប្បវេណី សយ សេន ផ្តល់សក្ខីកម្មថា មន្ទីរសន្តិសុខក្រាំងតាចាន់ស្ថិតក្នុងស្រុក ១០៥[599]។ ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង ត្រូវបានគេសួរចម្លើយអំពីភាពញឹកញាប់ដែលនិរសាបញ្ជូនលិខិតពីមន្ទីរស្រុកទៅក្រាំងតាចាន់។ គាត់បានឆ្លើយតបថា “ខ្ញុំមិនដឹងប្រាកដថាញឹកញាប់ប៉ុណ្ណាទេ ពីព្រោះខ្ញុំមិននៅកន្លែងនោះជាប់ទេ”[600]។ ប៉ុន្តែ គាត់បានថ្លែងថា “បាទ ក្នុងប្រធានស្រុក គេមានសិទ្ធិចាប់មនុស្ស។ តាមចាប់រយៈណា ធ្វើយ៉ាងម៉េចៗ ខ្ញុំអត់ដឹងទេ ប៉ុនគ្រាន់តែថា

[595] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/281.1** ទំព័រ ៧ បន្ទាត់ ៩-១៥ ទំព័រ ៨ បន្ទាត់ ១-៧។

[596] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/281.1** ទំព័រ ៩ បន្ទាត់ ៩-១០។

[597] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/281.1** ទំព័រ ៩ បន្ទាត់ ១៣-១៦។

[598] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/281.1** ទំព័រ ១០ បន្ទាត់ ១៩-២០ ទំព័រ ៤១ បន្ទាត់ ២៤ ដល់ទំព័រ ៤២ បន្ទាត់ ៣។

[599] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៥២ បន្ទាត់ ១៨-២០។ *សូមមើលផងដែរ* កំណត់ហេតុស្តាប់ចម្លើយ សយ សែន ឯកសារ **E3/5214** ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៨ KH ERN 00223066-00223067។

[600] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/281.1** ទំព័រ ៤០ បន្ទាត់ ២៤ ដល់ទំព័រ ៤១ បន្ទាត់ ៦។

ដូចជាមានបងប្អូនថា ឥឡូវខ្ញុំធ្វើខុសនៅទីហ្នឹង គេមានសិទ្ធិចេញគេស្រាវជ្រាវពីណា ពីតាអាន់ទៅ។ តាអាន់ គេឱ្យនីរសារទៅយកសំបុត្រហ្នឹងទៅឱ្យកន្លែងមន្ទីរស្រុក។ មន្ទីរស្រុក មិនដឹងមន្ទីរស្រុកគេនៅណាទេបាទ"[601]។

315. ភាគីដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន បានផ្ដល់សក្ខីកម្មថា ស៊ាន់ ដែលជានិរសាស្រុក "បានចែកសំបុត្រដល់បុគ្គល៣នាក់ ជាអាទិ៍ ប្រធាន អនុប្រធាន និង សមាជិកគណៈកម្មាធិការគុក"[602]។ គាត់ ពន្យល់ថា "ជារឿយៗ ពេលពួកគេបានទទួលសំបុត្រហើយ ពួកគេនឹងចាត់តាំងយោធាឱ្យអនុវត្ត។ ឧទាហរណ៍ថា ប្រសិនបើពួកគេបានទទួលសំបុត្រថ្ងៃនេះ ចឹងពួកគេនឹងបញ្ជូនយោធាទៅអនុវត្តថ្ងៃស្អែក"[603]។ ឧទាហរណ៍ នៅពេលគេប្រើទឹកប៊ិចក្រហមនៅខាងខ្នងសំបុត្រ ទោះបីជាខ្ញុំមិនចេះអានក៏ ដោយ ទឹកប៊ិចក្រហមនោះមានន័យថា អ្នកទោសត្រូវតែកម្ទេច ។ ដូច្នេះ ប្រសិនបើវាជាកិច្ចការ ប្រញ៉ាប់ អ្នកទោសនឹងត្រូវសម្លាប់នៅថ្ងៃនោះតែម្ដង។ បើមិនអញ្ចឹងទេ អ្នកទោសនឹងត្រូវកម្ទេច នៅថ្ងៃបន្ទាប់។ គេធ្វើដូចធម្មតាដើម្បីមិនឱ្យអ្នកទោសដឹងថាមានអ្វីកើតឡើង"[604]។

### *វចនាសម្ព័ន្ធ និងបុគ្គលិក*

316. ដើមបណ្ដឹងរដ្ឋប្បវេណីបានដឹងពីយោធា និងឆ្មាំគុក ថាគុកនោះប្រតិបត្តិការដោយខាងភូមិភាគ ហើយថាអ្នកទោសមកពី តាកែវ ទូកមាស កំពត តាកែវ ខេត្តកណ្ដាលនិងកំពង់ស្ពឺ[605]។ ពាក់ព័ន្ធនឹងសិទ្ធិផ្ដល់ដល់ "យោធា" ដែលគេហៅថាឆ្មាំសន្តិសុខដែរនោះ គាត់បានផ្ដល់សក្ខីកម្មថា យោធា មាន

---

[601] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/282.1** ទំព័រ ៣៦ បន្ទាត់ ១៨-២១។

[602] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/257.1** ទំព័រ ២០ បន្ទាត់ ១-២។

[603] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/257.1** ទំព័រ ២០ បន្ទាត់ ៥-៧។

[604] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/257.1** ទំព័រ ២០ បន្ទាត់ ១០-១៥។

[605] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៦១ បន្ទាត់ ១៣-១៤។ *សូមមើលផងដែរ* កំណត់ហេតុស្ដាប់ចម្លើយ សយ សែន ឯកសារ **E3/5214** ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៨ KH ERN 00223066-00223067។

តួនាទីចាប់និងសម្លាប់មនុស្ស[606]។ យោធាទាំងនេះមិនត្រឹមតែយាមក្រាំងតាចាន់ប៉ុណ្ណោះទេ ប៉ុន្តែពួក គេថែមទាំងទៅស្រែរនោង ភូមិពោធិ៍ដើម្បីយកអ្នកទោសទៀតផង[607]។

317. ពាក់ព័ន្ធនឹងឋានានុក្រមដឹកនាំនៅក្រាំងតាចាន់ ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មថាមានឆ្មាំសន្តិសុខចំនួន១២នាក់ ដែលគេហៅថា យុទ្ធជន ហើយថាមានប្រធានចំនួន១នាក់ និងអនុប្រធានចំនួន២នាក់ សរុបទាំងអស់ចំនួន១៥នាក់[608]។ នៅពេលចំនួនអ្នកទោសកើនឡើង បុគ្គលិកនិងយោធានឹងត្រូវគេបញ្ជូនទៅកន្លែងគុកបន្ថែមទៀត[609]។ តា ឆេន គឺជាប្រធានទី១ ក្រោយមក តា អាន ជំនួសក្រោយឆ្នាំ១៩៧៥[610]។ ឌុច តូច គឺជាអ្នកវាយអង្គុលីលេខ[611]។ ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មអំពីថាតើបុគ្គលិកនៅក្រាំងតាចាន់ជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាឬយ៉ាងណា៖ “ខ្ញុំដឹងថា តាឆេន និង មឿន គឺជាកម្មាភិបាលធំជាងគេ ហើយ ឌុច ធំ គឺជាអនុប្រធាន។ ខ្ញុំដឹងថា ចា ឆេន និង តា មឿន គឺជាបក្ខជន ហើយ តា សៀង ក៏ជាបក្ខជនដែរ”[612]។ “តាអាន គឺជាប្រធាន តាពេញ ជាអនុប្រធាន។ តាមពិត តា ពេញ ជាសមាជិក ចំណែក ឌុច ធំ ជាអនុប្រធាន”[613]។

---

606 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/282.1** ទំព័រ ៧៧ បន្ទាត់ ២១-២២។

607 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/282.1** ទំព័រ ៧៧ បន្ទាត់ ២៥ ដល់ទំព័រ ៧៨ បន្ទាត់ ១។

608 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៣៩ បន្ទាត់ ៩-១២។

609 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៦៦ បន្ទាត់ ៩-១២។

610 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹកថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៦៣ បន្ទាត់ ២២-២៥។

611 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹកថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៦៤ បន្ទាត់ ៨-១៥។

612 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/282.1** ទំព័រ ៦០ បន្ទាត់ ២៤ ដល់ទំព័រ ៦១ បន្ទាត់ ១។

613 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/282.1** ទំព័រ ៦១ បន្ទាត់ ៣-៤។

*សមាសភាពអ្នកជាប់ឃុំឃាំង*

318. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មថា ចំនួនអ្នកទោសនៅក្រាំងតាចាន់មានការប្រែប្រួល[614]។ ពាក់ព័ន្ធនឹងចំណុះអគារគុកដាក់អ្នកទោស ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ផ្តល់សក្ខីកម្មថា នៅពេលអគារពេញ គឺ អ្នកទោសអាចមានចំនួន១០០នាក់ជាង ដោយកត់សម្គាល់ថា នៅពេលអគារចំនួន២ទៀតត្រូវបានសាងសង់បន្ថែមគឺផ្ទុកអ្នកទោសបានតិចជាង១០០នាក់[615]។

319. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ផ្តល់សក្ខីកម្មថា នៅក្រាំងតាចាន់ មានអ្នកទោសកុមារ និងស្ត្រី ។ កុមារក្មេងៗគេមិនដាច់ច្រវាក់ឬខ្នោះទេ ហើយគេឲ្យនៅជិតឪពុកម្តាយពួកគេ[616]។ ចំពោះ ទីកន្លែងឃុំអ្នកទោសស្ត្រីវិញ គាត់ផ្តល់សក្ខីកម្មថា មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ស្ត្រីនៅជួរផ្សេង ហើយអ្នកទោសបុរសនៅក្នុងអគារ[617]។ ប៉ុន្តែ ក្រោយថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ស្ត្រីនិងបុរសគេ

[614] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/257.1** ទំព័រ ៥០ បន្ទាត់ ២៥ ដល់ទំព័រ ៥១ បន្ទាត់ ៦: ("បានន័យថាអត់កំណត់ វាមានតិចមានច្រើនៗ ហើយកាលណាច្រើន កាលណាចង្អៀតគ្នាអីចឹង កាលណាអត់ទាន់ធ្វើគុកហ្នឹងបានថែមគុកថ្មីពីរទៀត ណែន ឡើងណែនគរលើគ្នាផ្អៀងមួយប្រឡោះដែក រនុកដែកហ្នឹងវាមានគរបានរយៈកាលដាក់ដី ទំហំក្តារ មួយម៉ែត្រហ្នឹងដាក់បានបួននាក់ ដល់ពេលមនុស្សមកច្រើន គាត់ដាក់ក្តារប្រឡោះជើងហ្នឹង ស៊កជើងនឹងអាប្រឡោះជើង អាប្រឡោះត្រយូវខ្នោះហ្នឹងមួយម៉ែត្រៗហ្នឹងគឺអាចដាក់បានដល់ប្រាំពីរប្រាំបីនាក់ ក្នុងមួយប្រឡោះមួយម៉ែត្រ ម្ខាង ហ្នឹងម្ខាងប្រឡោះក្នុងមួយម៉ែត្រ។ ហ្នឹងវាអត់អាចកំណត់បានទេ ខ្ញុំម៉្យាងក៏ខ្ញុំអត់បានរាប់ ខ្ញុំអត់មនសិទ្ធិអីដើររាប់ គ្រាន់តែលើកបាយលើកទឹកលើកចំណីទៅឲ្យហើយ អត់បានរាប់ទេបាទ។")

[615] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/257.1** ទំព័រ ៥១ បន្ទាត់ ២១-២៣។ *សូមមើលផងដែរ* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/257.1** ទំព័រ ៦២ បន្ទាត់ ២-១២ ("បើនិយាយថាដាក់ពេញណែនដូចខ្ញុំនិយាយអំមិញថា ក្នុងមួយម៉ែត្រប្រឡោះដែកហ្នឹង ក្នុងមួយម៉ែត្រហ្នឹង ប្រឡោះដែកមានទំពក់មួយៗ។ ក្នុងហ្នឹងរយៈកាលពីមុន កាលអត់ទាន់មនុស្សជាប់ដាក់បានមួយប្រឡោះតែពីរនាក់ បីនាក់ទេ ទូលាយអ្នកទោសហ្នឹងសម្រាន្តកើត ប៉ុន្តែដល់ពេលមនុស្សមកច្រើន ចាប់មកច្រើនមក វាដាក់មួយប្រឡោះហ្នឹងឡើងដល់ ៨នាក់ ឬក៏៩នាក់ ហើយនិង៧នាក់ក្នុងមួយប្រឡោះ។ បើអីចឹងក្នុងមួយគុកសរុបពីរខ្សែ ពីជួរហ្នឹងអាច ១០០ជាងក្នុងមួយគុក ១០០ជាងទៅ២០០ តែប៉ុណ្ណឹងទេ បាទ។")

[616] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៤៩ បន្ទាត់ ៦-៩។

[617] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹកថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៤២ បន្ទាត់ ២៥ ដល់ទំព័រ ៤៣ បន្ទាត់ ៣។

ដាក់រួមគ្នានៅក្នុងជួរតែមួយ ក្នុងអគារតែមួយ[618]។ ដើមបណ្ដឹងរដ្ឋប្បវេណី ថ្លែងនៅក្នុងអំឡុងនីតិវិធីស៊ើបអង្កេតថា អ្នកទោសស្ត្រីជាច្រើនត្រូវបានផ្ដាំគុករំលោភនិងសម្លាប់[619]។

320. ទាក់ទិននឹងអ្នកទោសដែលគេចោទថាខុសសីលធម៌ ដើមបណ្ដឹងរដ្ឋប្បវេណី សូត្រ សាំង បានផ្ដល់សក្ខីកម្មថា បុគ្គលនោះនឹងបាត់ខ្លួនដោយសារមិនដាច់ខាតចំពោះអង្គការ មិនថាជាយោធា ជាយុវជន ឬជាយុវនារី នៅក្នុងកងចល័តនោះទេ[620]។ ប៉ុន្តែ គាត់និយាយថាគាត់មិនដែលឃើញ ករណីខុសសីលធម៌កើតឡើងនៅក្រាំងតាចាន់ទេ[621]។

321. ដើមបណ្ដឹងរដ្ឋប្បវេណី សូត្រ សាំង ក៏បានផ្ដល់សក្ខីកម្មថា ប្រជាជនត្រូវបានសម្លាប់នៅក្រាំងតាចាន់[622]។ គាត់ថ្លែងថា ទាំងអ្នកទោសបុរសនិងស្ត្រីត្រូវបានសម្លាប់[623]។ គាត់ក៏បានផ្ដល់សក្ខីកម្មផងដែរថាកុមារក៏ត្រូវបានសម្លាប់នៅទីនោះដែរ[624] ហើយថាពួកគេត្រូវនាំយកទៅគុកជាមួយឪពុកម្ដាយរបស់ពួកគេ[625]។

*ប្រជាជន១៧មេសា និងអតីតទាហាន លន់ នល់*

---

[618] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៤២ បន្ទាត់២៥ ដល់ទំព័រ ៤៣ បន្ទាត់ ៣។

[619] កំណត់ហេតុស្ដាប់ចម្លើយ សយ សែន ឯកសារ **E3/5214** ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៨ KH ERN 00223066-00223068។

[620] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/281.1** ទំព័រ ៥២ បន្ទាត់ ១៩-២៣។

[621] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/281.1** ទំព័រ ៥២ បន្ទាត់ ២៥ ដល់ទំព័រ ៥៣ បន្ទាត់ ១។

[622] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/281.1** ទំព័រ ៤៦ បន្ទាត់ ៥-៦។

[623] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/282.1** ទំព័រ ១៧ បន្ទាត់ ៩-១០។

[624] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/281.1** ទំព័រ ៤៦ បន្ទាត់ ២៣-២៥។

[625] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/281.1** ទំព័រ ១១ បន្ទាត់ ២០-២១ ២៣-២៤។

322. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មថាគាត់ដឹងពីវត្តមាននិងស្ថានភាពប្រជាជន ១៧មេសា និងអតីត ទាហាន លន់ នល់ ពីព្រោះទាំងឆ្មាំនិងអ្នកទោសក្រាំងតាចាន់ប្រាប់គាត់[626]។ គាត់ថ្លែងថា "ទាំងពីរ ពីជនរងគ្រោះនិងយោធា។ យោធាពីរបីនាក់ទុកចិត្តខ្ញុំ ហើយជួនកាលពួកគេនិយាយលេងជាមួយខ្ញុំ និងប្រាប់ខ្ញុំអំពីរឿងនោះ"[627]។ គាត់ផ្តល់សក្ខីកម្មថា "គឺ ស៊ឹម ជួនកាល ឌុច តូច, ស៊ាន់ ឬសាំង"ដែលផ្តល់ព័ត៌មានដល់គាត់[628]។

323. គាត់ពន្យល់ថាចំនួនអ្នកទោសកើនឡើងក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ហើយក្នុងនោះរួមមានអតីតទាហាន លន់ នល់ និងអ្នកមកពីភ្នំពេញ ដែលគេហៅថា អ្នក១៧មេសា។ "ចំនួនអ្នកទោសកើនឡើងក្រោយពេលប្រទេសត្រូវបានរំដោះ ពោលគឺ ក្រោយពួកគេរំដោះភ្នំពេញ។ អតីតទាហាន លន់ នល់ ទាំងនោះត្រូវគេចាត់ទុកថាជាឈ្លើយសឹក ហើយប្រជាជនភ្នំពេញគេចាត់ទុកថាប្រជាជន១៧មេសា ហើយពួកគេត្រូវបានយកទៅទីនោះ។ ពេលនោះពួកគេចោទថាប្រជាជនទាំងនោះមានការពាក់ព័ន្ធ។ ក្នុងករណីខ្ញុំ ឪពុកខ្ញុំធ្វើការរបបមុន ហើយខ្ញុំក៏ត្រូវបានគេចោទថាពាក់ព័ន្ធ។ ប្រជាជនដទៃទៀតត្រូវបានចោទថាជាភ្នាក់ងារ សេអ៊ីអា។ ប្រជាជន១៧ មេសាភាគច្រើន ក្រោយថ្ងៃរំដោះ ត្រូវគេសួរអំពីឋានន្តរសក្តិរបស់ពួកគេក្នុងរបបមុន"[629]។

---

626 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៦៦ បន្ទាត់ ១៩-២៤។

627 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៦៦ បន្ទាត់ ២២-២៤។

628 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៦៦ បន្ទាត់ ២៥ ដល់ទំព័រ ៦៧ បន្ទាត់ ៣។

629 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៦៦ បន្ទាត់ ៩-១៧។ *សូមមើលផងដែរ* កំណត់ហេតុស្តាប់ចម្លើយ សយ សែន ឯកសារ **E3/5214** ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៨ KH ERN 00223065 (ដើមបណ្តឹងរដ្ឋប្បវេណី បានផ្តល់សក្ខីកម្មថា អ្នកទោសភាគច្រើន ត្រូវបានសម្លាប់ "គឺនៅក្នុងឆ្នាំ១៩៧៥។ អ្នកទោសដែលនាំមកភាគច្រើន គេមិនមានការដាក់ខ្នោះទេ គេបញ្ចូលក្នុងគុករួចហើយគេហៅចេញទៅវិញ យកទៅសម្លាប់តែម្តង។ អ្នកទោសភាគច្រើនជាអ្នក១៧មេសា។")

324. ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង ត្រូវបានចោទសួរថាតើមានអ្នកទោសជាអតីតទាហាន លន់ នល់ ឬមន្ត្រីរដ្ឋការដែរឬទេ ឬដែលពាក់ព័ន្ធនឹងពួក លន់ នល់ នៅក្រាំងតាចាន់។ គាត់ឆ្លើយថា "មាន"[630]។

325. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានពន្យល់ថា មានអ្នកទោសធ្ងន់និងអ្នកទោសស្រាល ហើយបានពន្យល់អំពីការប្រព្រឹត្តមកលើអ្នកទោសទាំងនេះ[631]។ តាមការយល់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រជាជន១៧មេសា ត្រូវបានចាត់ទុកថាជាអ្នកទោសធ្ងន់ ចំណែកឯប្រជាជនមូលដ្ឋាន គឺជាអ្នកទោសស្រាល[632]។ ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថាអ្នកទោសខ្លះដែលលួចដំឡូងហូប ក្នុងមន្ទីរក្រាំងតាចាន់ត្រូវបានវាយដំនិងដាក់ខ្នោះ ហើយមានពេលខ្លះវាយដំរហូតដល់ស្លាប់[633]។

### *គំនូសព្រាងមន្ទីរសន្តិសុខក្រាំងតាចាន់*

326. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានពន្យល់ដល់អង្គជំនុំជម្រះថាគុកមានរបងចំនួនបីជុំវិញគុក៖ របងទីមួយគឺក្រាស់ និងមានរាយ លួសបន្លា។របងទីពីរស្ថិតនៅខាងកើតទីតាំង ហើយរបបងទីបីស្ថិតនៅទិសខាងត្បូង[634]។ ទាក់ទិននឹងហេដ្ឋារចនាសម្ព័ន្ធជាក់ស្តែងវិញ ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មថា មានអគារចំនួន២មុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងអគារចំនួន២ ដែលមានលួសបន្លាព័ទ្ធជុំវិញគឺសាងសង់ដំណាក់កាលក្រោយសម្រាប់អ្នកទោស[635]។

---

[630] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/281.1** ទំព័រ ២៧ បន្ទាត់ ២២។

[631] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៦៥ បន្ទាត់ ១៦-២៣។

[632] កំណត់ហេតុស្តាប់ចម្លើយ សយ សែន ឯកសារ **E3/5214** ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៨ KH ERN 00223066-00223068។

[633] កំណត់ហេតុស្តាប់ចម្លើយ សយ សែន ឯកសារ **E3/5214** ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៨ KH ERN 00223066-00223068។

[634] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹកថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៤៨ បន្ទាត់ ២៤ ដល់ទំព័រ ៤៩ បន្ទាត់ ២។

[635] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៦១ បន្ទាត់ ២២-២៣ ឧបសម្ព័ន្ធ ឃ៖ ប្លង់នៃមន្ទីរសន្តិសុខក្រាំងតាចាន់ ដែលចងក្រងចេញពីព័ត៌មានដែលផ្តល់ឲ្យដោយសាក្សី សយ សែន ឯកសារ **E3/5830**។ កំណត់ហេតុស្តាប់ចម្លើយ សយ សែន **E3/5214** ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៨ KH ERN 00223066 ("ផ្ទះសម្រាប់ដាក់អ្នកទោសមានទាំងអស់ចំនួន៤ គឺផ្ទះកណ្តាលពីរ សម្រាប់ដាក់អ្នកទោសធ្ងន់ ដោយដាក់ខ្នោះជើងទាំងដៃទាំងយប់ទាំងថ្ងៃ អ្នកទោសទាំងនោះជាអ្នក១៧ មេសា។ គេដោះខ្នោះចេញនៅពេលដែលអ្នកទោសត្រូវយកទៅសួរ

មានក្លោងទ្វារនៅទិសខាងកើតនិងទិសខាងលិចគុក[636]។ គេវាយជួងនៅពេលគេយកអ្នកទោសចូលបរិវេណគុក[637]។ ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មថាចំពោះអ្នកទោសដែលគេឲ្យធ្វើការ ពួកគេនឹងធ្វើការនៅចន្លោះរបងទី១និងរបងទី២នៃបរិវេណនោះ[638]។

327. ក្នុងកំឡុងការផ្តល់សក្ខីកម្មរបស់គាត់នៅតុលាការ ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មអំពីអគារគុក និងមូលដ្ឋានក្រាំងតាចាន់។ "ដំបូងឡើយ នៅឆ្នាំ១៩៧៤ មានតែអគារចំនួន២ប៉ុណ្ណោះ។ ខ្ញុំត្រូវគេឃុំឃាំងនៅអគារខាងលិចអស់ជាច្រើនខែមុនពេលគេយកទៅអគារខាងកើត ។ ក្រោយមក គេយកខ្ញុំទៅដាក់អគារថ្មីមួយទៀត ដែលស្ថិតនៅទិសខាងកើតផងដែរ"[639]។

---

ចម្លើយតែប៉ុណ្ណោះ។ ផ្ទះខាងលើចមានដាក់អ្នកទោសស្រាលមួយចំហៀង អ្នកទោសធ្ងន់មួយចំហៀង។ ឯផ្ទះខាងកើត សម្រាប់ដាក់អ្នកទោសមូលដ្ឋាន និងអ្នកទោស១៧ មេសា ដោយដាក់ខ្នោះទាំងជើងទាំងដៃ។ អ្នកទោសគេដាក់ខ្នោះជើងទាំងពីរ ចំពោះអ្នកទោសធ្ងន់គេដាក់ខ្នោះដៃថែមទៀត។ផ្ទះនីមួយៗមានទទឹងប្រហែល៧ម៉ែត្រ និងបណ្តោយប្រហែល៣០ម៉ែត្រ។ អ្នកទោសត្រូវគេដាក់ខ្នោះឲ្យដេកក្បាលទល់នឹងជញ្ជាំង។ ក្នុងផ្ទះនីមួយៗមានដាក់អ្នកទោសពីរជួរ។ ពេលអ្នកទោសឈឺបត់ដៃបត់ជើងពេលយប់គេមានត្រឡោកដូងមួយ ឲ្យបត់ដៃជើងដាក់ ហើយហុចតៗគ្នាទៅដាក់ក្នុងកាដុងមួយនៅក្នុងផ្ទះដាក់អ្នកទោសនីមួយៗ។ ការបត់ដៃជើងរបស់អ្នកទោសមិនមានទឹកលាងសំអាតទេ ហើយអ្នកទោសក៏មិនបានទទួលទឹកសម្រាប់ងូតសម្អាតរាងកាយដែរ។ អ្នកទោសមានស្លាប់មួយថ្ងៃមួយនាក់ ពីរនាក់ បីនាក់ក្នុងមួយផ្ទះៗ។")

[636] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៦៣ បន្ទាត់ ៥-១១។ ឧបសម្ព័ន្ធ យ៖ ប្លង់នៃមន្ទីរសន្តិសុខក្រាំងតាចាន់ ដែលចងក្រងចេញពីព័ត៌មានដែលផ្តល់ឲ្យដោយសាក្សី សយ សែន ឯកសារ **E3/5830**។

[637] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៦៣ បន្ទាត់ ១១-១៣។ របាយការណ៍កំណត់អត្តសញ្ញាណទៅកន្លែង មន្ទីរសន្តិសុខក្រាំងតាចាន់ ឯកសារ **E3/5828** ថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ KH ERN 00365709 (ដើមបណ្តឹងរដ្ឋប្បវេណី បានជួយអ្នកស៊ើបអង្កេតក្នុងការកំណត់អត្តសញ្ញាណ "កន្លែងដែលគាត់បានបញ្ជាក់ថាធ្លាប់ជាក្លោងទ្វារចូលទៅកាន់របងកណ្តាលនៅក្នុងបរិវេណទីពីរ។
កងឈ្លបឃុំបាននាំអ្នកទោសថ្មីៗចូលតាមក្លោងទ្វារនេះ ហើយបានវាយជួងដែលគេធ្វើបណ្តោះអាសន្ន (ដែកកង់ឡានកញ្ចាស់មួយ) ដើម្បីជាសញ្ញាឲ្យឆ្មាំគុកចេញមកយកអ្នកទោសថ្មីៗ។ កងឈ្លបទាំងនោះមិនត្រូវបានអនុញ្ញាតឲ្យចូលទៅខាងក្នុងបរិវេណគុកនោះឡើយ។ ការនិយាយរៀបរាប់របស់ សយ សែន បញ្ជាក់ពីការពិតនៃចម្លើយរបស់អតីតឆ្មាំគុក ស្រី ថន ដែលបាននិយាយថាគាត់មានការងារទទួលមនុស្សដែលកងឈ្លបបានចាប់បញ្ជូនមក"។

[638] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹកថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៨១ បន្ទាត់ ២៤-២៥។

[639] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹកថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៦៥ បន្ទាត់ ៣-៦។

ពាក់ព័ន្ធនឹងការបន្ថែមអគារចំនួន២ទៀត គាត់បានផ្តល់សក្ខីកម្មថា "ខ្ញុំដឹងដោយសារចំនួនអ្នកទោសគេបញ្ជូនទៅច្រើនឡើងៗ ពួកគេសាងសង់អគារចំនួន២ខ្នងទៀតនៅខាងកើតបរិវេណ (មានភ្ជាប់រូបភាពអគារទាំងពីរខ្នង"[640]។ "នៅក្នុងបរិវេណគុក អគារដែលខ្ញុំចង់រៀបរាប់ប្រាប់គឺមានទំហំខុសៗគ្នា។ ជួនកាលអគារមានទទឹង៥ម៉ែត្រ បណ្តោយ១២ម៉ែត្រ ៩ម៉ែត្រ ឬ១៥ម៉ែត្រ ហើយអគារភាគច្រើនសាងសង់ដោយអ្នកទោស ហើយនៅក្រោមកម្រាលដែលយើងដេកលើ គេក្រាលល្មសបន្ទា ហើយគេក៏ប្រើកូនឈើសម្រាប់ទប់ជញ្ជាំងផងដែរ។ អំពីដំបូលវិញ គឺគេប្រើល្មសបន្ទាផងដែរ ប៉ុន្តែដំបូលប្រកក្បឿងញឹកណាស់ដើម្បីកុំឲ្យល្ហូចរត់តាមដំបូល"[641]។

## *កន្លែងសួរចម្លើយ*

328. ក្នុងកំឡុងការផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានរៀបរាប់អំពីកន្លែងសួរចម្លើយនិងបុគ្គលិកទទួលបន្ទុកសួរចម្លើយ។ គាត់បានផ្តល់សក្ខីកម្មថា មានតែកន្លែងមួយដែលគេសួរចម្លើយ ហើយថា ទីតាំងនោះនៅដដែលនៅកំឡុងពេលដែលគាត់ជាប់ឃុំឃាំង[642]។ ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានពន្យល់ថា បន្ទប់សួរចម្លើយមិនស្ថិតនៅក្នុងអគារទេ តែមានជញ្ជាំងធ្វើពីធាងដូងនិងប្រកដំបូលស្បូវ[643]។ ជញ្ជាំងក្រោយដែលគេព្យួរអាវុធនិងបរិក្ខាផ្សេងៗនោះ[644]គឺធ្វើពីឈើ[645]។ មានវេរ៉ង់ដាទាបនៅមុខកន្លែងសួរចម្លើយ មានឈើមួយ ដុំ

[640] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹកថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/257.1** ទំព័រ ២៧ បន្ទាត់ ១៣-១៥។

[641] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹកថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៤៨ បន្ទាត់ ១២-២១។

[642] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/257.1** ទំព័រ ៣៦ បន្ទាត់ ៤១។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/258.1** ទំព័រ ៥២ បន្ទាត់ ២៥ ដល់ទំព័រ ៥៣ បន្ទាត់ ២។

[643] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/257.1** ទំព័រ ២៨ បន្ទាត់ ១៥-១៩។

[644] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/257.1** ទំព័រ ២៩ បន្ទាត់ ៤-៩។

[645] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/257.1** ទំព័រ ២៨ បន្ទាត់ ១៥-២៥។

និង កៅអីឈើមួយ។ អ្នកយាមនិងកម្មាភិបាលអង្គុយនៅម្ខាង ហើយប្រធានអង្គុយទល់មុខឈើមួយដុំនោះ[646]។

329. ដើមបណ្ដឹងរដ្ឋប្បវេណី សួត្រ សាំង បានផ្ដល់សក្ខីកម្មថាមានកន្លែងសម្លាប់មួយស្ថិតនៅខាងត្បូងកន្លែងសួរចម្លើយ[647]។

*កន្លែងផ្សេងទៀតក្នុងបរិវេណគុក*

330. ដើមបណ្ដឹងរដ្ឋប្បវេណី សយ សេន បានរៀបរាប់ថា មានចម្ការដំឡូងមួយនៅចន្លោះអគារអ្នកទោស និងផ្ទះសួរចម្លើយដែលមើលឃើញតែដំបូលប៉ុណ្ណោះ[648]។ ហួសពីចម្ការ និងនៅទិសខាងលិចនៃកន្លែងសួរចម្លើយគឺមាន "គុកក្រោមដីមួយ" ឬ "គុកងងឹត"[649]។

331. ដើមបណ្ដឹងរដ្ឋប្បវេណីបានរៀបរាប់ដំណើររឿងឡើងវិញថាដើមដូងគេដាំនៅលើសាកសពដែលគេកប់រួច[650]។ នៅឆ្នាំ១៩៧៧ សាកសពគេកប់ហួសពីបរិវេណទីមួយ នៅពេលដែល "មានការ

[646] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៧១ បន្ទាត់ ១-៥។

[647] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សួត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/281.1** ទំព័រ ៤៥ បន្ទាត់ ៣-៤។

[648] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹកថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/257.1** ទំព័រ ២៨ បន្ទាត់ ២៣-២៥។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៧០ បន្ទាត់ ២០-២១។

[649] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹកថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/257.1** ទំព័រ ៥១ បន្ទាត់ ១-៣។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/257.1** ទំព័រ ៥០ បន្ទាត់ ១១-២០។

[650] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹកថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៧២ បន្ទាត់ ១០-១១។

សម្លាប់ ខ្លាំង"[651]។ ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន បានពន្យល់ថា នៅពេល ដែលមានកន្លែងកប់សាកសពច្រើននៅបរិវេណទីមួយ សាកសពទៅកប់នៅហួស ពីបរិវេណទីពីរបន្តិច[652]។

***ដើមបណ្តឹងរដ្ឋប្បវេណីជាមួយក្រុមគ្រួសារឬមិត្តភក្តិដែលគេយកទៅក្រាំងតាចាន់***

332. ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន៤នាក់ផ្សេងទៀត បានរៀបរាប់អំពីការឃុំឃាំងសាច់ញាតិ ឬមិត្តភក្តិរបស់ពួកគេនៅមន្ទីរសន្តិសុខក្រាំងតាចាន់។

333. ភាគីដើមបណ្ដឹងរដ្ឋប្បវេណី ប៊ុន សារឿន បានផ្ដល់សក្ខីកម្មអំពីការឃុំឃាំងឪពុករបស់គាត់នៅក្រាំងតាចាន់[653]។ គាត់បានផ្ដល់សក្ខីកម្មថាឪពុករបស់គាត់គឺជាប្រធានក្រុមនៅក្នុងរបប លន់ នល់[654]។

334. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ឹម សារឿន បានផ្ដល់សក្ខីកម្មអំពីការចាប់ខ្លួនប្ដី បងប្រុស ឪពុក និង ឪពុកមារបស់គាត់ ដែលគេចាប់យកទៅឃុំឃាំងនៅក្រាំងតាចាន់ក្នុងឆ្នាំ១៩៧៦-១៩៧៧[655]។ គាត់ផ្ដល់សក្ខីកម្មបន្ថែមទៀតថា ឈ្មោះរបស់បងប្រុស ឪពុក និង ឪពុកមា គឺឃើញនៅក្នុង របាយការណ៍មួយរបស់ក្រាំងតាចាន់[656]។

---

[651] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹកថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៧២ បន្ទាត់ ២២ ដល់ទំព័រ ៧៣ បន្ទាត់ ៣។

[652] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹកថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៧៣ បន្ទាត់ ១-៣។

[653] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៊ុន សារឿន ប្រតិចារឹក ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/288.1** ទំព័រ ៣២ បន្ទាត់ ៦-១១។

[654] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៊ុន សារឿន ប្រតិចារឹក ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/288.1** ទំព័រ ៣២ បន្ទាត់ ១៩។

[655] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ឹម សារឿន ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/283.1** ទំព័រ ១១ បន្ទាត់ ១១-១៥ ទំព័រ ១០-១១។

[656] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ឹម សារឿន ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/283.1** ទំព័រ ១៨ បន្ទាត់ ៨-១០។

335. ដើមបណ្ដឹងរដ្ឋប្បវេណី រី ពៅ បានផ្ដល់សក្ខីកម្មអំពីមរណភាពរបស់ ចាន់ ដែលនៅក្នុងកងចល័តជាមួយគ្នា។ ដើមបណ្ដឹងរដ្ឋប្បវេណី បានផ្ដល់សក្ខីកម្មថាគាត់បានឃើញសាកសពរបស់ចាន់ នៅក្នុងបរិវេណមន្ទីរសន្តិសុខក្រាំងតាចាន់[657]។

336. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ូ ដាវ បានផ្ដល់សក្ខីកម្មថា គាត់បានបាត់បង់ឪពុកនិងឪពុកមា ដែលគាត់ដឹងថាត្រូវគេសម្លាប់នៅមន្ទីរសន្តិសុខក្រាំងតាចាន់[658]។

## ខ. ភ័ស្តុតាងមូលដ្ឋានបទល្មើសដែលផ្ដល់ដោយដើមបណ្ដឹងរដ្ឋប្បវេណីនៅពេលសវនាការ

### ១. ការដាក់ពន្ធនាគារ

337. ភ័ស្តុតាងដើមបណ្ដឹងរដ្ឋប្បវេណីដែលលើកឡើងនៅពេលសវនាការ កំណត់បានថា ប្រជាជនដែលគេបញ្ជូនទៅក្រាំងតាចាន់ត្រូវបានដកសិទ្ធិសេរីភាពតាមទំនើងចិត្តដោយគ្មានគោរពតាមនីតិវិធីត្រឹមត្រូវតាមច្បាប់ឡើយ។

338. ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន បានផ្ដល់សក្ខីកម្មថា គាត់ត្រូវបានចាប់ខ្លួននិងឃុំឃាំងនៅក្រាំងតាចាន់ក្នុងនាមជាជនស៊ីវិល ដោយគ្មានប្រព្រឹត្តអ្វីខុសឡើយ[659]។ ពាក់ព័ន្ធនឹងពេលវេលានៃការចាប់ខ្លួន គាត់ផ្ដល់សក្ខីកម្មថា "ខ្ញុំអាចចាំបានឆ្នាំនោះគឺឆ្នាំ១៩៧៤ ប៉ុន្តែមិនចាំខែទេ"[660]។ គាត់ថែមទាំងផ្ដល់សក្ខីកម្មទៀតថា គាត់ "បានរត់គេចពីគុកនោះនៅឆ្នាំ១៩៧៩ នៅពេលវៀតណាមចូលមក"[661]។ ពេលគេឃុំឃាំងនៅទីនោះ គឺខ្ញុំនៅក្មេង ហើយប្រហែលជាមិនអាចចងចាំបាន មិន

[657] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ពៅ រី ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/262.1** ទំព័រ ១៨ បន្ទាត់ ២២ ដល់ទំព័រ ១៩ បន្ទាត់ ១១។

[658] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ូ ដាវ ប្រតិចារឹក ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/499.1** ទំព័រ ១០ បន្ទាត់ ២៣ ដល់ទំព័រ ១១ បន្ទាត់ ១៩ ទំព័រ ១៣ បន្ទាត់ ១១-១៤។

[659] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹកថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៤៨ បន្ទាត់ ៦-៧។

[660] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៤៤ បន្ទាត់ ១៨-១៩។

[661] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/258.1** ទំព័រ ៤៦ បន្ទាត់ ៩-១០។

នឹកឃើញគ្រប់យ៉ាងនោះទេ។ ខ្ញុំជឿថាគេឃុំឃាំងខ្ញុំគឺដោយសារឪពុករបស់ខ្ញុំជាប្រធានស្រុកក្នុងរបប សីហនុ។ ខ្ញុំខ្លួនឯងផ្ទាល់មិនបានប្រព្រឹត្តអ្វីខុសទេ ហើយនៅពេលនោះពួកគេចំពាញ់ប្រវត្តិរូប រកមុខសញ្ញាពួកមូលធននិងសក្តិភូមិ"[662]។ ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មថា នៅពេលមកដល់ក្រាំងតាចាន់ "គ្មានការថតរូបទេនៅពេលនោះ។ អ្នកទោសទាំងអស់គេមិនគិតឋានៈទេ ពួកគេត្រូវបញ្ជូនទៅអគារនោះ ហើយចាក់សោរ។ គេទុក ចោលនៅទីនោះ។ ពួកគេនឹងហៅមកសួរចម្លើយ២ឬ៣ថ្ងៃក្រោយពេលមកដល់"[663]។

339. ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង បានផ្តល់សក្ខីកម្មថា "តាមខ្ញុំសង្កេតឃើញនៅក្នុងទីនោះគឺកូនក្មេងតូចមានទៅតាមឪពុកម្តាយបាទ"[664]។

340. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានពិពណ៌នាថា "ចំពោះអ្នកទោសដែលគេនាំចូលមកដំបូងមិនគិតថាទោសធ្ងន់ឬទោសស្រាល នឹងត្រូវគេដាក់ច្រវ៉ាក់ រួចហើយដាក់ខ្នោះជាប់ជាមួយដែកវែងមួយ"[665]។ "មានអ្នកទោសចំនួន២ជួរ ក្បាលទល់នឹងជញ្ជាំង។ គេយកកងដែកស៊កជាមួយកជើងដើម្បីភ្ជាប់ជាមួយនឹងដែកវែងមួយ"[666]។ "ពេលគេផ្ទេរខ្ញុំទៅទីនោះ ខ្ញុំចាំមិនបាន ប្រហែលជាកន្លះខែ ឬ១០ថ្ងៃ គេមិនសួរចម្លើយខ្ញុំទេ ប៉ុន្តែគេដាក់ច្រវ៉ាក់និងឃុំឃាំង ទាំងយប់ទាំងថ្ងៃ"[667]។

***ការឃុំឃាំងឪពុកដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន***

---

[662] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៤៨ បន្ទាត់ ៤-៩។

[663] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹកថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៦០ បន្ទាត់ ១៣-១៦។

[664] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/281.1** ទំព័រ ១១ បន្ទាត់ ២៥។

[665] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/257.1** ទំព័រ ៤៨ បន្ទាត់ ៧-៩។

[666] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/257.1** ទំព័រ ៤៨ បន្ទាត់ ១៤-១៦។

[667] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៣៨ បន្ទាត់ ៥-៧។

341. ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន បានផ្តល់សក្ខីកម្មថា នៅពេលគាត់រស់នៅសហករណ៍ត្រពាំងជើង ខ្ញុំបានជួប "ដល់ជួបពូរ៉ន គាត់ថា អ្អែង! គិតទៅឯណា? ខ្ញុំថា ខ្ញុំ គេឱ្យមកធ្វើការ ប៉ុន្តែដល់ធ្វើការ ខ្ញុំចេះតែដើរមកក្បែរថ្នល់ហ្នឹងមក ប៉ុន្តែហួសម៉ោងគេធ្វើការ ហូបបាយហើយ។ ដល់ពេល គាត់ថា អញឃើញឪអ្អែងនៅមន្ទីរក្រាំងតាចាន់ ឃើញគេវ៉ៃធ្វើបាប ធ្វើអីហ្នឹង។ ខ្ញុំក៏ដល់ឮសួរអីចឹង ធ្វើបាបម៉េច កន្លែងហ្នឹងគេហៅអី ក៏ខ្ញុំអត់ដឹងដែរ ឮថាគេយកទៅបាត់ៗ អីចឹងគាត់នៅរស់ទេចុះ។ គាត់ថា ឃើញនៅហ្នឹង គេធ្វើបាប គេវ៉ៃគេអីនៅហ្នឹង។ ហើយផ្ទះគាត់នៅចម្ងាយប្រហែលជា១០០ម៉ែត្រពីមន្ទីរក្រាំងតាចាន់ហ្នឹង។ ដល់ខ្ញុំឃើញហេតុផលអីចឹង ក៏ខ្ញុំទៅៗហ្នឹង ដល់ពេលអត់ទាន់បាននឹងទៅផង ក៏បបួលម៉ែបបួលអីហ្នឹងទៅៗអាកន្លែងមន្ទីរហ្នឹង។ ទៅដល់ហ្នឹង ឃើញគាត់នៅរែកទឹករែកអីស្រោចដំណាំនៅហ្នឹង។ ដល់ពេលឃើញអីចឹងទៅ ខ្ញុំក៏យំក៏ស្រែក ដែលឃើញអីចឹង វារកអ្វីប្រៀបធៀបមិនបាន ឃើញគាត់មើលគាត់សឹងមិនស្គាល់"[668]។

342. "ចាប់ទៅអាពេលបែកហ្នឹង។ ពេលបែកយើង ពួកគេហៅថាពួក១៧ៗទៅហ្នឹង"[669]។ ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន បានពន្យល់ថា "គាត់ជាប្រធានភូមិនៅភូមិព្រៃឈើទាលហ្នឹង អ៊ំខ្ញុំហ្នឹង ហើយឪខ្ញុំជាប្រធានក្រុមជំនាន់ លន់ នល់ ហ្នឹង"[670]។

## ២. ការធ្វើឱ្យនៅជាទាសករ

343. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មថា ប្រហែលជាមួយខែក្រោយពីគេឃុំឃាំង គាត់អាចចេញពីអគារគុកដែលគាត់ជាប់ឃុំ[671]។ "គេអនុញ្ញាតឱ្យខ្ញុំចេញក្រៅធ្វើស្រែ ក្នុងនោះរួម

---

[668] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន ប្រតិចារឹក ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/288.1** ទំព័រ ២៤-២៥ បន្ទាត់ ២៣-៧។

[669] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន ប្រតិចារឹក ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/288.1** ទំព័រ ៣៤ បន្ទាត់ ១៦។

[670] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន ប្រតិចារឹក ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/288.1** ទំព័រ ៣៤ បន្ទាត់ ១៩-២០។

[671] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹកថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៣៨ បន្ទាត់ ១៣-១៤។

មានជម្រុះស្មៅ ឬរែកលាមកពីកន្លែងឃុំឃាំង។ ហើយ តា ឆេន ក៏ឱ្យធ្វើដែរ។ មួយរយៈមក គេក៏ទុកចិត្តខ្ញុំ ហើយអនុញ្ញាតឱ្យខ្ញុំធ្វើការខាងក្រៅ ដូចជាឃ្វាលគោ ជាដើម”[672]។

344. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មថា គាត់អាចមិនអាចបដិសេធមិនព្រម ទទួលកិច្ចការដែលគេឱ្យគាត់ទេ។ “ទេ ខ្ញុំមិនអាចធ្វើចឹងបានទេ។ ខ្ញុំរង់ចាំតែគេចាត់តាំង”[673]។ យើងធ្វើតាមបញ្ជាគេ គេឱ្យធ្វើអ្វីយើងធ្វើហ្នឹង”[674]។

345. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានរៀបរាប់ថាបានទទួលការណែនាំឱ្យជីករណ្តៅ។ “ឧទាហរណ៍ គេនឹងសម្លាប់ល្ងាចហ្នឹង ចឹងគេបញ្ជាខ្ញុំ តាឆេន និង តា នន សរុបបីនាក់ និងយោធាម្នាក់ឈរមើលយើង។ គេបញ្ជាយើងឱ្យធ្វើតាម ជាពិសេសទំហំ និងជម្រៅរណ្តៅ ហើយយើងជីកទៅតាមការណែនាំ។ យើងមិនអាចជីកតាមចិត្តយើងនោះទេពីព្រោះគេមានអ្នកគ្រប់គ្រងនៅទីនោះ”[675]។

346. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានពន្យល់ថា អ្នកទោសខ្លះគេចាត់ឱ្យធ្វើពលកម្ម។ “អគារខាងកើតគេដាក់អ្នកទោសទាំងនោះដែលគេអនុញ្ញាតឱ្យធ្វើការខាងក្នុងបរិវេណ”[676]។ គាត់បាន

---

[672] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹកថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៣៨ បន្ទាត់ ១៣-១៨។

[673] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៣៩ បន្ទាត់ ២២។

[674] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/258.1** ទំព័រ ៧០ បន្ទាត់ ៥។

[675] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៨៦ បន្ទាត់ ២០-២៥។ សូមមើលផងដែរ កំណត់ហេតុស្តាប់ចម្លើយ សយ សែន ឯកសារ **E3/5214** ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៩ KH ERN 00223063-00223064។

[676] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៦៧ បន្ទាត់ ៩-១១។

ផ្តល់សក្ខីកម្មថា អ្នកទោសទាំងនេះគេអនុញ្ញាតឱ្យធ្វើស្រែខាងក្រៅ[677]។ "ការដ្ឋាន"នោះគឺស្ថិតនៅខាងក្រៅទីមួយ រវាងរបងទី១និងរបងទី២នៃបរិវេណនោះ"[678]។

*ការគ្រប់គ្រងចលនាក្នុងកំឡុងពេលធ្វើពលកម្ម*

347. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មថា ប្រសិនបើអ្នកទោសធ្វើពលកម្មនៅទីវាល ពួកគេស្ថិតនៅក្រោមការឃ្លាំមើល។ គាត់ផ្តល់សក្ខីកម្មថា "នៅពេលដែលគេអនុញ្ញាត ឱ្យធ្វើស្រែនៅខាងក្រៅ ដូចថា មានអ្នកទោសចំនួន៧នាក់ចឹង ហើយមានអ្នកទោសច្រើនណាស់ ហើយពួកគេបញ្ជាខ្ញុំថា "អ្នកឯងត្រូវតែនៅទីនោះមើលពួកគេ ហើយប្រយ័ត្ន បើអ្នកទោសរត់ អ្នកឯងនឹងត្រូវស្លាប់"។បាទ ខ្ញុំមើលនៅការដ្ឋាន"[679]។ ពួកគេបញ្ជាឱ្យខ្ញុំមកអគារឃុំឃាំងវិញនៅ ពេលល្ងាច។ ខ្ញុំត្រូវដាក់ច្រវ៉ាក់ខ្លួនឯង ប៉ុន្តែពួកគេជាអ្នកចាក់សោទ្វាពីក្រៅ។ ប៉ុន្តែប្រសិនបើមានសាកសពនៅក្នុងអគារ ខ្ញុំត្រូវតែយកទៅកប់រួចត្រឡប់មកអគារដាក់ខ្នោះខ្លួនឯងវិញ"[680]។

348. ទោះបីជាគេមិនដាក់ខ្នោះនិងអាចធ្វើពលកម្មក្នុងកំលុងម៉ោងធ្វើការក្តី ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានរៀបរាប់អំពីរបៀបដែលគេកម្រិតឱ្យដើរ។ ដូចជា គាត់និយាយថា "ខ្ញុំអាចដើរបានតែត្រឹមផ្ទះបាយអ្នកទោស ហើយបានតែនៅពេលសន្តិសុខបញ្ជាឱ្យទៅយកអ្វីមួយ ពេលនោះខ្ញុំអាចទៅផ្ទះបាយទាំងនោះដែលសន្តិសុខទាំងនោះប្រើប្រាស់"[681]។

349. ទាក់ទិននឹងអ្នកជាប់ឃុំឃាំងដទៃទៀតដែលគេចាត់តាំងឱ្យធ្វើការងារពលកម្មនៅវាល ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មថាអ្នកទោសនៅតែគេដាក់ខ្នោះពេលយប់បន្ទាប់ពីត្រឡប់

[677] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៨១ បន្ទាត់ ១៦។

[678] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៨១ បន្ទាត់ ២៤-២៥។

[679] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៨១ បន្ទាត់ ១៦-២០។

[680] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៤១ បន្ទាត់ ៣-៦។

[681] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៦៩ បន្ទាត់ ១២-១៤។

មកគុកវិញ[682]។ គាត់បានផ្ដល់សក្ខីកម្មថា អ្នកជាប់ឃុំឃាំងដែលធ្វើពលកម្មត្រូវគេឃុំឃាំងដាច់ដោយឡែក ដោយនិយាយថា "អ្នកទោសដែលគេអនុញ្ញាតឱ្យធ្វើការ គឺគេដាក់នៅផ្ទះខាងកើតនៅរោងបាយ"[683]។

*ការគំរាមដាក់ទណ្ឌកម្ម*

350. ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន បានផ្ដល់សក្ខីកម្មថា "ខ្ញុំត្រូវគេដោះលែងឱ្យធ្វើពលកម្មពីព្រោះគាត់បានប្រាប់ខ្ញុំថា ខ្ញុំក្មេងជាងគេ ហើយប្រាប់ខ្ញុំកុំឱ្យមាត់ប្រាប់គេដើម្បីគេឱ្យរួចខ្លួន បើប្រាប់គេគេនឹងសម្លាប់។ ដូច្នេះគេក៏ដោះលែងខ្ញុំឱ្យធ្វើការក្នុងបរិវេណ ឱ្យឃ្វាលក្របី និងជីករណ្ដៅកប់សាកសព ព្រមទាំងយកអ្នកទោសដែលស្លាប់ជាប់ខ្នោះ រួចហើយគេបញ្ជាឱ្យអូសយកទៅកប់នៅក្នុងរណ្ដៅនោះ។ រួចហើយគេបញ្ជាយើងឱ្យដាំដើមដូងនៅលើផ្នូរនោះជាមួយ តា ឆេន"[684]។

*ការប្រព្រឹត្តឃោរឃៅ ការបំពាន និងការប្រើកម្លាំង*

351. ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន បានរៀបរាប់ឡើងវិញអំពីពេលដែលគាត់ហៀបនឹងត្រូវគេសម្លាប់នៅក្រាំងតាចាន់។ "មានពេលមួយ គេវាយខ្ញុំនឹងស្នូកកាំភ្លើងចំក្បាល ប៉ុន្តែខ្ញុំត្រូវគេវាយនឹងខ្សែតីជាច្រើនលើកនៅពេលដែលខ្ញុំបេះបន្លែ ឬស្លឹកដំឡូងជ្វា ប៉ុន្តែវាយខ្លាំងជាងគេបំផុតគឺនៅពេលខ្ញុំលួចដំឡូងឈើហូប"[685]។

## ៣. អំពើអមនុស្សធម៌ផ្សេងៗទៀត

352. ភស្តុតាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលលើកឡើងនៅក្នុងសវនាការគូសបញ្ជាក់ថាការប្រព្រឹត្តិរបស់ ប.ក.ក ក្នុងការបង្កើតនិងប្រតិបត្តិការមន្ទីរសន្តិសុខក្រាំងតាចាន់គឺពោរពេញទៅដោយការ

---

[682] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៤ បន្ទាត់ ២៥ ដល់ទំព័រ ៥ បន្ទាត់ ១ ទំព័រ ៨២ បន្ទាត់ ៣។

[683] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/258.1** ទំព័រ ៥២ បន្ទាត់ ៨។

[684] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៣៨ បន្ទាត់ ២១ ដល់ទំព័រ ៣៩ បន្ទាត់ ២។

[685] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៥៥ បន្ទាត់ ១១-១៤។

រំលោភបំពានទៅលើសិទ្ធិរស់រានមានជីវិតនិងសិទ្ធិទទួលបានស្តង់ដារស់នៅសមរម្យ សិទ្ធិចាកផុតពីការប្រព្រឹត្តអំពើឃោរឃៅ និងអំពើអមនុស្សធម៌ អំពើបន្ទាបបន្ថោក មកលើអ្នកជាប់ឃុំឃាំង[686]។ ការប្រព្រឹត្តនោះគឺជាអំពើដែលមានលក្ខណៈប្រហែលគ្នានិងធ្ងន់ធ្ងរស្រដៀងគ្នានឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយបានបណ្តាលឲ្យដើមបណ្តឹងរដ្ឋប្បវេណីមានផលប៉ះពាល់ធ្ងន់ធ្ងរ ឬបង្កើតបានជាការវាយប្រហារមយយទោលើភាពថ្លៃថ្នូររបស់មនុស្ស។

*លក្ខខណ្ឌរស់នៅទូទៅ*

353. ទាក់ទិននឹងអ្នកទោសដែលត្រូវគេដាក់ខ្នោះនិងឃុំឃាំងទាំងយប់ទាំងថ្ងៃ ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មថា "វាបើនិយាយពីអ្នកទោសនៅក្នុងហ្នឹងវិញ គួរណានិយាយមិនចេញ ហើយក៏និយាយមិនរួចដែរពីបញ្ហារបស់ខ្ញុំ និយាយមិនចេញ។ បានន័យថា វាហួសនិស្ស័យហួសអាល័យមិនដែលជួប ហើយក៏មិនដែលឃើញ តាំងខ្ញុំចេះកើតមកមិនដែលឃើញទេ អត់ដែលឃើញ។ វេទនាហួសខ្លាំងណាស់ និយាយពីសម្រាន្តវិញ វាសង្កើចហើយចៃមិនដឹងយកទៅណាអស់ទេ ចៃសាច់យើងហ្នឹង។ គ្រាន់តែអ្នកចៃ ហើយសង្កើចខាំស្លាប់ក្នុងមួយយប់ អត់បាត់ពីគុកមួយបាត់ពីបួននាក់និងបីនាក់ទេក្នុងមួយយប់ ចៃហើយសង្កើចខាំ។ ហ្នឹងចៃហើយសង្កើចខាំ និងពីបញ្ហាអត់អាហារផង"[687]។

354. ចំពោះអ្នកទោសដែល "គេដាក់ខ្នោះនិងឃុំឃាំងទាំងយប់ទាំងថ្ងៃ"[688] ដើមបណ្តឹង រដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មថា "ពួកគេលំបាកវេទនាណាស់"[689]។

*ការថែទាំវេជ្ជសាស្ត្រមិនគ្រប់គ្រាន់*

---

686 សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ថ្ងៃទី១០ ខែធ្នូ ឆ្នាំ ១៩៤៨ មាត្រា ២ ៥ ៩ ២៥។

687 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៤១ បន្ទាត់ ១៥-២០។

688 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៤១ បន្ទាត់ ១០-១១។

689 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៤១ បន្ទាត់ ១៥-១៨។

355. ដើមបណ្ដឹងរដ្ឋប្បវេណី សួត្រ សាំង បានផ្ដល់សក្ខីកម្មថា "ក្នុងនោះគឺ បងប្អូនអ្នកទោសដែលជាប់នៅក្នុងនោះ គឺដូចមិនដែលមានឃើញផ្ដល់ថ្នាំ ពេទ្យឱ្យទេបាទ"[690]។

356. ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ត្រូវរងរបួសនិងបានពន្យល់ថា របួសរបស់គាត់មិនត្រូវបានព្យាបាលទេ។ "ជាការពិតណាស់ ដំបៅក្លាយ ម្ដងហើយម្ដងទៀត។ ខ្ញុំបានយកក្រមារបស់ម្ដាយខ្ញុំទៅវាយកូនកង្កែបយកមកកិនជាមួយអំបិល រួចយកមកលាបលើមុខរបួស ដើម្បីព្យាបាលបណ្ដោះអាសន្ន"[691]។

357. ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ផ្ដល់សក្ខីកម្មបន្ថែមទៀតថា "និយាយអំពីអ្នកទោសជាប់ខ្នោះ និង ជាប់ឃុំឃាំង គឺគ្មានពាក្យអ្វីនឹងថ្លែងទេ។ វាហួសពីការយល់របស់ខ្ញុំទៅទៀត។ ពួកគេវេទនាណាស់។ មានសង្កើចនិងសត្វល្អិតជុំវិញពួកគេ។ យ៉ាងហោចណាស់មានអ្នកទោស៣ឬ៤នាក់បានស្លាប់ដោយសារសង្កើចខាំនិង ស្លាប់ដោយអត់អាហារ។ ដូច្នេះ ខ្ញុំចាំបានលម្អិតមួយចំនួនប៉ុន្តែភ្លេចចំណុចខ្លះៗ"[692]។

### *អាហារមិនគ្រប់គ្រាន់*

358. ដើមបណ្ដឹងរដ្ឋប្បវេណី សួត្រ សាំង បានផ្ដល់សក្ខីកម្មទាក់ទិននឹងកង្វះអាហារសម្រាប់អ្នកជាប់ឃុំឃាំងនៅក្រាំងតាចាន់។ "ក្នុងជីវភាពនៅក្នុងទីនោះ គឺបងប្អូនអ្នកទោសមិនបានអាហារគ្រប់គ្រាន់ទេបាទ។ មានបបរមានៗបបរលាយដំឡូងក៏មាន បបរទឹករាយក៏មាន អាហ្នឹងជាការពិតណាស់បាទ"[693]។

---

[690] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សួត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/281.1** ទំព័រ ៣៦ បន្ទាត់ ៦-៧។

[691] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៧៦ បន្ទាត់ ៣-៦។

[692] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៤១ បន្ទាត់ ១៥-២១។

[693] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សួត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/281.1** ទំព័រ ១២ បន្ទាត់ ២៣-២៤។

359. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មថា "មានអគារចំនួន៤ ហើយអ្នកទោសមានចំនួនមិនទៀងទេ ជួនកាលមានប្រហែល៥០ ជួនកាល១០០ ជួនកាល៧០ ឬជួនកាល២០នាក់ក្នុង១អគារ ប៉ុន្តែបរិមាណអង្ករដែលគេយកទៅដាំបាយគឺបរិមាណតិចណាស់ ប្រហែល៤កំប៉ុង។ ប៉ុន្តែគេយកត្រឡោកដូងដួសឱ្យអ្នកទោសម្នាក់ៗ។ គេឱ្យខ្ញុំរែកបបរទៅអគារមួយទៀត និងយកទៅឱ្យអ្នកទោសទាំងនោះហូប។ មានគ្រាប់បបរតិចតួចនៅរងបាតខ្លះ ហើយខ្ញុំដួសមកហូបខ្លួនឯង។ ប៉ុន្តែអ្នកទោសដទៃទៀតបានទទួលតែគ្រាប់អង្ករតិចតួចប៉ុណ្ណោះក្នុងបបររាវៗនោះ"[694]។

360. ពាក់ព័ន្ធនឹងអ្នកទោសដែលត្រូវគេសួរចម្លើយ ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មថា គាត់បានទទួលការណែនាំ "មិនឱ្យជញ្ជូនម្ហូបអាហារទៅឱ្យអ្នកទោសទាំងនោះទេ"[695]។

361. ក្នុងកំឡុងពេលស្តាប់ចម្លើយ ដើមបណ្តឹងរដ្ឋប្បវេណី បានរៀបរាប់លម្អិតថា "ជាទូទៅ អ្នកទោសទទួលបានបបររាវៗ ចំណែកអ្នកទោសដែលគេដាក់ក្នុងផ្ទះឃុំឃាំង ទទួលបានតែទឹកបបរប៉ុណ្ណោះ។ អ្នកទោសដែលគេឱ្យធ្វើការទទួលបានគ្រាប់[បបរ]ខ្លះនៅបាត។ មានអ្នកទោសតែ៦ទៅ៧ប៉ុណ្ណោះដែរគេឱ្យធ្វើការ។ កិច្ចការរបស់ពួកគេរួមមានធ្វើការនៅវាលស្រែ រែកទឹក ពុះអុស និង ដាំដំណាំផ្សេងៗ ជាមួយនឹងការដាំស្ល និងយកបបរឱ្យអ្នកទោសនៅជាប់ខ្នោះ"[696]។

### *អនាម័យមិនគ្រប់គ្រាន់*

362. ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង បានផ្តល់សក្ខីកម្មថា "បើតាមខ្ញុំនៅខាងក្រៅនេះ គឺមិនបានអ្នកទោសបងប្អូនដែលជាប់ពិរុទ្ធក្នុងនោះ គឺមិនមានបានថ្នាំសង្កូវ ឬមួយដុសលាងខ្លួន សម្អាតអនាម័យខ្លួនបានត្រឹមត្រូវទេបាទ"[697]។

---

[694] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៤០ បន្ទាត់ ១៤-២២។

[695] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/257.1** ទំព័រ ២៣ បន្ទាត់ ១១-១២។

[696] កំណត់ហេតុស្តាប់ចម្លើយ សយ សែន ឯកសារ **E3/5214** ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៨ KH ERN 00223067-00223068។

[697] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/281.1** ទំព័រ ១២ បន្ទាត់ ៨-៩។

363. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មថា គេយកត្រឡោកដូងដែលទៅដួសទឹក និង សម្រាប់បន្ទោរបង់។ "ពួកគេបន្ទោរបង់ដោយខ្លួនឯង។ ខ្ញុំមិនចង់និយាយរឿងហ្នឹងទេ។ ជើងទាំងពីរជាប់ខ្នោះ ចឹងពួកគេផ្អៀងខ្លួន។ ជើងទាំងពីរជាប់ខ្នោះ ហើយពួកគេប្រើត្រឡោក ដូងបន្ទោបង់ ហើយហុចពីអ្នកទោសម្នាក់ទៅម្នាក់ទៀតតគ្នា រួចគេចាក់ចូលធុង។ ហើយពួកគេ ប្រើប្រាស់ត្រឡោកដូងដដែលគ្រាន់តែលាងទឹក ហើយយកទៅដួសទឹកឱ្យអ្នកទោសផឹក"[698]។

364. អ្នកទោសប្រុសនិងអ្នកទោសស្រីគេឃុំឃាំងជាមួយគ្នាក្រោយពេលរំដោះភ្នំពេញ[699]។ ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មថា "ចំពោះអ្នកទោសស្រី ដេលគេដាក់ខ្នោះ គឺពិបាក ជាងគេ។ ប៉ុន្តែគ្មាននណាម្នាក់និយាយទេ ពួកគេបន្ទោរបង់ដោយខ្លួនឯងដូចគេដូចឯង។ គេពុំមានអារម្មណ៍ថាគេគ្មានសិទ្ធិអៀនខ្មាស់នោះទេ"[700]។

365. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មទៀតថា "ក្រោយពេលបាយ គេឱ្យខ្ញុំសែងធុងជាមួយនឹងត្រឡោកដូង ដាក់នៅតាមផ្លូវដែលអ្នកទោសរៀបហូបអាហារ ហើយអ្នកណាចង់ បានទឹកពួកគេប្រើត្រឡោកដូងដួសទឹកពីធុងនោះ។ ចឹងអ្នកណាហូបហើយមុននឹងយកត្រឡោកដូងនោះដួសទឹកពីធុងទៅផឹកនិងលុបមុខ។ គេត្រូវធ្វើ ឱ្យលឿនៗ បើមិនចឹងទេអ្នកយាមនឹងស្តីបន្ទោស"[701]។

366. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ក៏បានពន្យល់ថាសាកសពគេមិនយកចេញភ្លាមៗពីកន្លែងឃុំឃាំងទេ។ គេយកចេញនៅល្ងាចបន្ទាប់។ "អ្នកណាស្លាប់យប់ គេទុករហូតដល់ម៉ោង៥ល្ងាច។ គេមិនយកសាកសពចេញនៅពេលព្រឹកទេ។ គេរង់ចាំរហូតដល់ល្ងាច។ គេរង់ចាំរហូតដល់ពេល

[698] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៤២ បន្ទាត់ ១-៧។

[699] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៤២ បន្ទាត់ ២៥ ដល់ទំព័រ ៤៣ បន្ទាត់ ៣។

[700] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៤៣ បន្ទាត់ ៩-១៤។

[701] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៣៦ បន្ទាត់ ១២-២០។

អ្នកទោសត្រឡប់មកពីធ្វើការវិញ ហើយគេនឹងយកសាកសពនោះចេញ។ ខ្ញុំគឺជាអ្នកដែលគេបញ្ជាឱ្យដោះខ្នោះចេញពីសាសព។ ចឹងគេឱ្យខ្ញុំយកសាកសពចេញនៅម៉ោង ៤ឬ៤:៣០ល្ងាច"[702]។

***ជម្រកមិនគ្រប់គ្រាន់***

367. ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន បានរៀបរាប់ការណ៍ដែលគុកនោះមានពេលខ្លះដាក់មនុស្សពេញណែន។ ទាក់ទិននឹងចំនួនចំណុះអគារគុក គាត់បានផ្ដល់សក្ខីកម្មថា "នៅពេល[អគារនោះ] ពេញចំនួនមនុស្សអតិបរមាគឺ១០០នាក់ ឬច្រើនជាងនេះ។ នៅពេលពេញណែនពេក ចំនួនអ្នកទោស អាចឡើងដល់ ២០០នាក់។ ប៉ុន្តែនៅពេលគេសង់អគារចំនួន២ទៀតរួច ចំនួនអ្នកទោសក៏ថយចុះ គឺអគារមួយមានអ្នកទោសតិចជាង១០០នាក់"[703]។ ចំនួនអ្នកទោសប្រែប្រួល ជួនកាលតិចជួនកាលច្រើន។ ពេលអគារថ្មីមិនទាន់សង់ អ្នកទោសក្នុងអគារទាំងនេះគឺពេញតែម្ដង។ ជួនកាលបណ្ដោយ១ម៉ែត្រ មានអ្នកទោសចំនួន៤នាក់។ ដោយសាររនុកដែកសម្រាប់ស៊កជា មួយ ខ្នោះអ្នកទោសអាចដាក់អ្នកទោសបានរហូតដល់៧នាក់ក្នុង១ជួរ។ តាមពិតខ្ញុំមិនបានរាប់ចំនួន អ្នកទោសក្នុងអគារនីមួយៗទេនៅពេលដែលខ្ញុំយកម្ហូបអាហារទៅឱ្យពួកគេ។ ខ្ញុំគ្មានសិទ្ធិរាប់ចំនួន ពួកគេទេ"[704]។ នៅពេលគុកឡើងពេញ ដូចខ្ញុំបានប្រាប់អញ្ចឹង គឺរនុកដែកបណ្ដោយ១ម៉ែត្រ មានអ្នកទោសតែ២ឬ៣នាក់ប៉ុណ្ណោះ ទុកកន្លែងឱ្យអ្នកទោសដេក។ ប៉ុន្តែនៅពេល គេយកអ្នកទោសចូលទៀត រនុកដែកដដែលហ្នឹង គេអាចដាក់អ្នកទោសបានរហូតដល់៧ទៅ៨នាក់។ ដូច្នេះ ទាំងសងខាងពីរជួរនៅអគារនោះ គឺអាចដាក់អ្នកទោសបានពី១០០ទៅ២០០នាក់"[705]។

---

[702] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៣៨ បន្ទាត់ ៥-១២។

[703] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/257.1** ទំព័រ ៥១ បន្ទាត់ ១២-១៧។

[704] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/257.1** ទំព័រ ៥០ បន្ទាត់ ២៥ ដល់ទំព័រ ៥១ បន្ទាត់ ៦។

[705] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/257.1** ទំព័រ ៥១ បន្ទាត់ ១២-១៧។

## ៤. ទារុណកម្ម

368. ភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលលើកឡើងនៅក្នុងសវនាការកំណត់បានថា អំពើដែលបង្កឲ្យមានការឈឺចាប់ឬវេទនាធ្ងន់ធ្ងរត្រូវបានប្រព្រឹត្តដោយបុគ្គលិកមន្ទីរសន្តិសុខក្រាំងតាចាន់ដើម្បីយកចម្លើយ ឬជាទម្រង់ទណ្ឌកម្ម។

### *ទារុណកម្មក្នុងបរិបទសួរចម្លើយ*

369. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានរៀបរាប់ថា អ្នកជាប់ឃុំឃាំង "គេយកទៅសួរចម្លើយនៅកន្លែងសួរចម្លើយ ហើយពួកគេត្រូវបានវាយដំ នៅពេលដែលគេដើរមិនរួច ពេលនោះគេឲ្យខ្ញុំលីអ្នកនោះចូលទៅក្នុងអគារ ហើយជួនកាលយើងត្រូវតែសែងពួកគេ។ ពួកគេត្រូវបានធ្វើទារុណកម្ម ហើយនៅពេលយកចូលក្នុងអគារ ពួកគេនឹងត្រូវដាក់ច្រវ៉ាក់និងខ្នោះម្តងទៀត ហើយពួកគេមិនទទួលបានបាយឬបបរហូបទេ។ កាលនោះពួកគេរងការចោទប្រកាន់ថាក្បត់ជាតិ ដូច្នេះ គេមិនឲ្យហូបអាហារទេនៅកំឡុងពេលនោះ"[706]។

370. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មថា មានការធ្វើទារុណកម្មនៅក្រាំងតាចាន់។ គាត់បានពន្យល់ថា គាត់អាចចូលទៅក្នុងបន្ទប់សួរចម្លើយដើម្បី "បោសសម្អាតឥដ្ឋ"នៅពេលព្រឹកមុនពេលចាប់ផ្តើមសួរចម្លើយ[707]។ គាត់បានផ្តល់សក្ខីកម្មថា "គោលបំណងនៃការសួរចម្លើយគឺដូចខ្ញុំបាននិយាយខាងដើមអញ្ចឹង គឺថាពាក់ព័ន្ធនឹងភ្នាក់ងារ សេអ៊ីអា របស់ លន់ នល់ ឬថាតើពួកគេមានជាប់ខ្សែរយៈ ព្រំ សាន ដែរឬទេ"[708]។ គាត់បានពន្យល់ថា សំណួរខ្លះពាក់ព័ន្ធនឹងជួរកងទ័ពរបបមុន[709]។ គាត់ក៏បានរៀបរាប់អំពីពេលដែលគាត់ខ្លួនឯងត្រូវគេសួរចម្លើយផងដែរ៖ "នៅពេលគេបញ្ជូនខ្ញុំទៅក្រាំងតាចាន់ គេឃុំឃាំងខ្ញុំយូរ ប្រហែលជាង១០ថ្ងៃ ឬ១ខែ រួចហើយគេសួរចម្លើយ

---

[706] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៤៩ បន្ទាត់ ១២-២៤។

[707] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៧១ បន្ទាត់ ១០-១២។

[708] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/257.1** ទំព័រ ២១ បន្ទាត់ ៣-៥។

[709] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/257.1** ទំព័រ ២១ បន្ទាត់ ៣-៥។

ខ្ញុំ"[710]។ ក្នុងកំឡុងពេលសួរចម្លើយ សំណួរគឺថា "តើអ្នកឯងមានជាប់ខ្សែរយៈអ្នកណានៅអង្គតាសោម ឬកន្លែងផ្សេងដែរទេ?"[711]។

371. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានថ្លែងថា "តាមការសង្កេតរបស់ខ្ញុំ ប្រសិនបើអ្នកទោសមានវ័យចំណាស់ឬអាចថាពួកគេរងការចោទប្រកាន់ថាមានខ្សែរយៈអតីតរបប លន់ នល់ ពួកគេនឹងត្រូវរងទារុណកម្ម។ ចំពោះអ្នកមូលដ្ឋានវិញ អាចថាមាន២ ឬ៣នាក់ ក្នុងចំណោម១០នាក់ នឹងត្រូវរងទារុណកម្មក្នុងកំលុងពេលសួរចម្លើយ"[712]។

372. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មថា "មានតែប្រធាន អនុប្រធាន ក្នុងនោះ មាន អាន និង ពេញ ដែលជាអ្នកសួរចម្លើយ"[713]។ ដើមបណ្តឹងរដ្ឋប្បវេណី បានពន្យល់ថា "តាចេង ឬ តា ពេញ គឺជាអ្នកដែលទៅយកអ្នកទោស ហើយដោះខ្នោះ រួចបណ្តើរអ្នកទោសទៅផ្ទះសួរចម្លើយ រួចហើយយកអ្នកទោសត្រឡប់មកវិញ។ បើមិនអញ្ចឹងទេគឺពួកគេនឹងវាយអ្នកទោស រហូតដល់សន្លប់។ ក្រោយមក គាត់មកផ្ទះគាត់។ គាត់ប្រាប់ខ្ញុំឱ្យទៅខាងត្បូង និងមើលខុសត្រូវទៅ។ ពេលអ្នកទោសត្រូវបានវាយវាយនឹងដំបងដល់ស្លាប់ តា ចេន និង ខ្ញុំ ត្រូវគេបញ្ជាឱ្យអូសសាកសពចេញក្រៅ"[714]។

373. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានពន្យល់ថា "អ្នកទោសដែលត្រូវបានធ្វើទារុណកម្ម និង ឃុំឃាំង [នៅក្រាំងតាចាន់]មិនអាចនៅយូរជាង១ខែឡើយ"[715]។ គាត់ក៏បានរំលឹកថាបានឃើញការ

---

[710] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៧៩ បន្ទាត់ ១-៤។

[711] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៧៩ បន្ទាត់ ៤-៦។

[712] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/257.1** ទំព័រ ២១ បន្ទាត់ ៨-១០។

[713] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៥៦ បន្ទាត់ ១០-១១។

[714] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៨៤ បន្ទាត់ ២៣ ដល់ទំព័រ ៨៥ បន្ទាត់ ៩។

[715] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៥៣ បន្ទាត់ ១០-១១។

ធ្វើទារុណកម្មទៅលើអ្នកជាប់ឃុំឃាំងចំនួន២នាក់ ដែលបន្ទាប់មកក៏បានស្លាប់។ "ខ្ញុំបានឃើញតែ ឃឿន និង ប្ដី យាយ ញ៉ តែប៉ុណ្ណោះ ដែលត្រូវគេធ្វើទារុណកម្មកំលុងពេលសួរចម្លើយ។ ហើយក្រោយមក ពួកគេក៏ស្លាប់ដោយសារការវាយដំ"[716]។

374. ដើមបណ្ដឹងរដ្ឋប្បវេណី សួត្រ សាំង បានផ្ដល់សក្ខីកម្មថា គាត់អាចឮសម្រែកអ្នកទោស ដែលគេកំពុងសួរចម្លើយ។ "ក្នុងសម្រែកបងប្អូនអ្នកទោស មិនមែន ខ្ញុំរស់នៅទីហ្នឹងពិតជាឮហើយ។ ឮ ដោយសារទី១ គេវៃសួរចម្លើយនេះក៏ឮ។ អាហ្នឹងឮជាក់ស្ដែងតែម្ដងបាទ"[717]។

***វិធីសួរចម្លើយ***

375. ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន បានពន្យល់ថា ការវាយដំគឺគេប្រើជាវិធីមួយក្នុងការធ្វើទារុណកម្ម។ "ចំពោះឧបករណ៍សួរចម្លើយ ពួកគេប្រើដំបងឫស្សី ប៉ុណ្ណោះ មាន៣ទៅ៤ដុំ"[718]។ គាត់ថ្លែងថា ដំបងឫស្សីទាំងនោះមាន "ប្រវែង៧០ឬ៦០សង់ទីម៉ែត្រ សម្រាប់វាយអ្នកទោស"។ ហើយនៅក្នុងបន្ទប់នោះ មាន៣ទៅ៤ដំបង"[719]។

376. ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ផ្ដល់សក្ខីកម្មបន្ថែមទៀតទាក់ទិននឹងការប្រើដង្កាប់ ក្រមា និង ថង់ប្លាស្ទិក។ "ខ្ញុំដឹងអំពីការប្រើដង្កាប់។ ដង្កាប់គេប្រើសម្រាប់ចាប់ទាញឬធ្វើឲ្យឈឺដោះ ឬចុង

[716] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ E1/258.1 ទំព័រ ៥៨ បន្ទាត់ ៤-៥។

[717] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សួត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ E1/281.1 ទំព័រ ៦០ បន្ទាត់ ១៨-១៩។

[718] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ E1/256.1 ទំព័រ ៧១ បន្ទាត់ ៥-៦។

[719] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ E1/257.1 ទំព័រ ២១ បន្ទាត់ ១៤-១៥។

ដោះអ្នកទោសស្ត្រី”[720]។ គាត់ក៏បានថ្លែងទៀតថា “មានក្រមា និងថង់ប្លាស្ទិកពីរបីដើម្បីគ្របមុខអ្នកទោស”[721]។

377. ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង បានរៀបរាប់ថាបានឃើញការធ្វើទារុណកម្មអ្នកទោស។ “គេយកដំបងវាយសួរចម្លើយ និងយកថង់ប្លាស្ទិកមកដើម្បីឲ្យថប់ដង្ហើម ឲ្យអ្នកទោសចេញជាចម្លើយឲ្យគេបាទ”[722]។ នៅពេលសួរថាតើមានវិធីធ្វើទារុណកម្មផ្សេងទៀតក្រៅពីការវាយនិង ប្រើថង់ប្លាស្ទិកដែរឬទេ គាត់បានផ្តល់សក្ខីកម្មថា គាត់ “ខ្ញុំបាទក៏មិនបានដឹងដែរ រឿងធ្វើទារុណកម្មក្រៅពីនេះ”[723]។

***គុកងងឹត***

378. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មថា មានអ្នកទោសខ្លះគេដាក់ក្នុង “បន្ទប់ងងឹត”។ “អ្នកទោសខ្លះ គេដាក់ក្នុង ដូចលោកនិយាយអញ្ចឹងគឺ ក្នុងគុកងងឹត ប៉ុន្តែ តាមពិត គុកក្រោមដី។ គេវាយលួសបន្លានៅក្នុងគុកនោះ។ គុកនោះធំ ប្រមាណ៣ឬ៤ម៉ែត្រ ហើយគេធ្វើ ដំបូលស្រួចរាងកោណ។ ក្រោយពេលអ្នកទោសត្រូវគេវាយរួច គេប្រើខ្សែពួរ។ ខ្សែពួរនោះធំ គេ ចង ចង្កេះអ្នកទោសនោះរួចទម្លាក់ចូលទៅក្នុងគុកក្រោមដី។ មួយសន្ទុះក្រោយមក អ្នកទោសសន្លប់ហើយ គេយកអ្នកទោសឡើងមកវិញ។ តាជឹម និង ខ្ញុំ ត្រូវគេបង្គាប់ឲ្យដកអ្នកទោសចេញ និងអូសត្រឡប់ទៅក្នុងអគារឃុំឃាំងវិញ”[724]។

***ការធ្វើទារុណកម្មជាទណ្ឌកម្មក្រៅបរិបទនៃការសួរចម្លើយ***

---

720 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ E1/257.1 ទំព័រ ២១ បន្ទាត់ ១-២។

721 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ E1/256.1 ទំព័រ ៧១ បន្ទាត់ ៦-៧។

722 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ E1/281.1 ទំព័រ ៣៩-៤០ បន្ទាត់ ២៥-១។

723 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ E1/281.1 ទំព័រ ១១ បន្ទាត់ ៧។

724 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ E1/257.1 ទំព័រ ៥០ បន្ទាត់ ១១-២០។

379. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មថាអ្នកទោសត្រូវបានធ្វើទារុណកម្មប្រសិនបើមានកំហុស[725]។ គាត់បានផ្តល់សក្ខីកម្មថា "អ្នកទោសណាក៏ដោយដែលធ្វើឱ្យឮសូរសំឡេងខ្នោះគឺនឹងត្រូវគេវាយដល់ស្លាប់យប់ហ្នឹង"។ ឆ្មាំគុកផ្លាស់ប្តូរវេនគ្នាយាមម្តង២នាក់ ដើម្បីយាមអ្នកទោសគ្រប់ម៉ោង។ បើនណាម្នាក់រំកិល គឺគេប្រើដងភ្លាប់ឆែកមើលខ្នោះ។ បើខ្នោះនោះគេឃើញរលុង អ្នកទោសនោះនឹងត្រូវគេវាយដល់ស្លាប់យប់ហ្នឹងនៅចំពោះមុខអ្នកទោសទាំងអស់ក្នុងអគារនោះ"[726]។

380. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មថា "មានពេលមួយគេវាយខ្ញុំនឹងស្នូកកាំភ្លើងចំក្បាល ប៉ុន្តែគេវាយខ្ញុំនឹងខ្សែតីជាច្រើនដង ពេលខ្ញុំបេះបន្លែ ឬស្លឹកដំឡូង ប៉ុន្តែវាយខ្លាំងជាងគេគឺពេលដែលខ្ញុំលួចដំឡូងហូប"[727]។ គាត់ក៏បានផ្តល់សក្ខីកម្មថាបានទទួលការណែនាំ "មិនឱ្យបញ្ជូនអាហារទៅឱ្យអ្នកទោសទាំងនោះ"ដែលត្រូវបានសួរចម្លើយឡើយ[728]។

## ៥. មនុស្សឃាតនិងការសម្លាប់រង្គាល

381. ភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណីដែលលើកឡើងនៅក្នុងសវនាការបង្ហាញអំពីការសម្លាប់ទ្រង់ទ្រាយធំ លើបុរស ស្ត្រី កុមារ និងទារក ដោយផ្ទាល់ពេលមកដល់មន្ទីរសន្តិសុខក្រាំងតាចាន់ ឬក៏ឡុងពេលឃុំឃាំង។ មរណភាពទាំងនេះបង្កឡើងដោយអំពើរបស់បុគ្គលិកមន្ទីរសន្តិសុខនោះ តាមរយៈការដាក់លក្ខខណ្ឌរស់នៅលំបាកវេទនានៅក្នុងមន្ទីរឃុំឃាំង។

### ៥.១. ភស្តុតាងទូទៅនៃការសម្លាប់

---

[725] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹកថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ E1/257.1 ទំព័រ ២៤ បន្ទាត់ ២៥ ដល់ទំព័រ ២៥ បន្ទាត់ ៣។

[726] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ E1/256.1 ទំព័រ ៤២ បន្ទាត់ ១៨-២២។

[727] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ E1/256.1 ទំព័រ ៥៥ បន្ទាត់ ១១-១៤។

[728] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ E1/257.1 ទំព័រ ២៣ បន្ទាត់ ១១-១២។

382. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មថា "ប្រធាន គេដើរពិនិត្យមើលដោយមានកាំពិតផង ហើយទាហាន និង ផ្នាំងទៃទៀតជាអ្នកសម្លាប់។ ទាំងអស់គ្នាចូលរួមក្នុងការសម្លាប់"[729]។

383. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មថា អ្នកទោសគេយកចេញពីអគារទៅទីតាំងសម្លាប់។ "មុនពេលគេយកអ្នកទោសទៅសម្លាប់ គេបើកអគារ ហើយនិយាយថាគេឱ្យអ្នកទោសត្រឡប់ទៅសហករណ៍រៀងៗខ្លួនវិញ ដូច្នេះត្រូវតែធ្វើតាមផែនការរបស់អង្គការ ប៉ុន្តែគេយកទៅមុនតែមួយចំនួនប៉ុណ្ណោះ។ ពេលនោះគែអានឈ្មោះពីបញ្ជី ហើយគេរំលឹកអ្នកទោសម្តងទៀតឱ្យដើរតាមផែនការអង្គការ កុំប្រឆាំងកង់ប្រវត្តិសាស្ត្ររបស់អង្គការ។ គេហៅឈ្មោះពីរនាក់ម្តង ហើយអ្នកដែលគេហៅឈ្មោះគឺគេដោះខ្នោះចេញមក ចេញមកក្រៅអគារ ហើយគេបណ្តើរទៅខាងត្បូងគុគ ដែលមានព្រៃចម្ការដំឡូង ហើយទាហាន២នាក់រង់ចាំនៅទីនោះ។ គេស្នើឱ្យរំមុខនិងចងដៃទៅក្រោយ។ មានចម្ងាយប្រហែល១០ម៉ែត្រពីគុក ហើយគេនិយាយថា មូលហេតុគឺកុំឱ្យពួកគេ សងសឹកនឹងអង្គការ"[730]។

384. "ពេលនោះគឺយកពួកគេទៅកន្លែងសម្លាប់ ហើយគេចាក់មីក្រូ ហើយជួនកាលពុះអុសនៅជិតនោះដើម្បីកុំឱ្យឮសំឡេងសម្លាប់ដែលពួកគេហៀបនឹងធ្វើ។ គេចាក់ចម្រៀងខ្មែរក្រហម ហើយក្រោយពេលសម្លាប់រួច គេត្រឡប់មកទៀត។ពេលគេត្រឡប់មកទៀត គេបន្ថយសំឡេងមីក្រូ និងសំឡេងពុះអុស"[731]។

385. ដើមបណ្តឹងរដ្ឋប្បវេណី បានពន្យល់ថា "អ្នកទោសត្រូវគេបណ្តើរដល់មាត់រណ្តៅ រួចគេឱ្យលុតជង្គង់ចុះ ហើយគេវាយនឹងត្បូងចបចំគល់ក រួចគេធាក់ទម្លាក់ក្នុងរណ្តៅ ហើយ បន្ទាប់មក ចំពោះបុរសឬមនុស្សចាស់ដូចដែលខ្ញុំនិយាយពីមុន គឺគេប្រើកាំបិតផ្គាក់ប្រវែង៤០ទៅ៥០សង់ទីម៉ែត្រអាក រួចទម្លាក់ចូលទៅក្នុងរណ្តៅ រួចហើយគេដោះសម្លៀកបំពាក់អ្នកទាំងនោះយកដាក់១គំនរ។

[729] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៨៥ បន្ទាត់ ២៣ ដល់ទំព័រ ៨៦ បន្ទាត់ ១។

[730] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៥២ បន្ទាត់ ៤-១៥។

[731] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៥២ បន្ទាត់ ១៥-២០។

ក្រោយពេលពួកគេបញ្ចប់ការសម្លាប់ថ្ងៃនោះហើយ គេបញ្ជាឲ្យខ្ញុំប្រមូលសម្លៀកបំពាក់យកទៅក្នុងស្រះទឹក រួចគក់ នៅខាងលិចគុក រួចហាលពីរបីថ្ងៃ។ រួចហើយខ្ញុំយកសម្លៀកបំពាកទាំងនោះទុកក្នុងឃ្លាំងនៅជិតកន្លែងសួរចម្លើយ។ ក្រោយមក មានឡានមកដឹកសម្លៀកបំពាក់ទាំងនោះទៅសហករណ៍"[732]។

386. ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង ត្រូវបានចោទសួរថាតើគេសម្លាប់មនុស្សនៅក្រាំងតាចាន់ ឬយ៉ាងណា។ "បងប្អូនជនរងគ្រោះដែលស្លាប់នៅក្នុងក្រាំងតាចាន់ហ្នឹង នឹងមិនបានជាប្រាកដថាប៉ុន្មាននាក់ ឬប៉ុន្មាននាក់ ខ្ញុំអត់ដឹងទេបាទ ប៉ុន្តែពិតជាស្លាប់នៅក្នុងទីហ្នឹងមែន"[733]។ គាត់បានរៀបរាប់លំអិតថា "មានអ្នកទោសប្រុស និងអ្នកទោសស្រី។ ពួកគេត្រូវបានសម្លាប់"[734]។ "សម្លាប់នៅក្នុងក្រាំងតាចាន់ កុមារ ក្មេងតូចនេះ គឺខ្ញុំដឹងតាមរយៈ ធម្មតាតែបាត់ម្តាយ បាត់កូន បើបាត់កូនពិតជាសម្លាប់ហើយ។ បាទ ខ្ញុំដឹងតាមរយៈប៉ុណ្ណឹងទេបាទ"[735]។

387. ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង បានផ្តល់សក្ខីកម្មថា "នៅក្នុងក្រាំងតាចាន់ សម្លាប់មនុស្ស គេសម្លាប់ដោយនឹងត្បូងចប ឬនឹងគល់ឫស្សី បាទ"[736]។ គាត់ថ្លែងថា គាត់បាន "ឃើញផ្ទាល់ភ្នែកនូវការសម្លាប់ នៅកន្លែងនោះ ព្រមទាំងសាកសពផងដែរ។ ការគាស់សាកសព ទាំងនោះបញ្ជាក់អំពីអ្វីដែល ខ្ញុំបាន ឃើញផ្ទាល់នៅពេលនោះ"[737]។

## ៥.២. ការសម្លាប់ជាក់ស្តែងមួយចំនួន

[732] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៥២ បន្ទាត់ ៤-១៣។

[733] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/281.1** ទំព័រ ៦២ បន្ទាត់ ៩-១០។

[734] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/282.1** ទំព័រ ១៧ បន្ទាត់ ៩-១០។

[735] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/281.1** ទំព័រ ៤៧ បន្ទាត់ ២៤-២៥។

[736] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/281.1** ទំព័រ ៤៧ បន្ទាត់ ៦-៧។

[737] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/282.1** ទំព័រ ៣១ បន្ទាត់ ១-៣។

### ការសម្លាប់ តារាភាពយន្ត គីម ណូវ៉ា និង ណុប ណែម ជាអាទិ៍

388. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មទាក់ទិននឹងតារាភាពយន្តពីររូប គឺ គីម ណូវ៉ា និង ណុប ណែម។ "ចំពោះតារាភាពយន្តពីររូប ខ្ញុំឃើញមករសៀលថ្ងៃមួយ ហើយក្រោយមកគេយកចេញទៅសម្លាប់ល្ងាចនោះ។ ពួកគេមិនត្រូវបានឃុំឃាំងទេ"[738]។ "តារាភាពយន្តទាំងពីររូបគេយកចូលមក ប៉ុន្តែខ្ញុំមិនចាំឆ្នាំទេ។ ប៉ុន្តែ គឺក្រោយថ្ងៃរំដោះ។ អ្នកទាំងពីរ មិនត្រូវបានឃុំឃាំងទេ។ ពួកគេត្រូវបានយកចូលមក ហើយប្តីគេយកទៅសម្លាប់មុនភ្លាម។ រួចមក គឺប្រពន្ធនិងកូនម្នាក់ត្រូវបានគេលេងសើចដោយមនុស្សទទួលបន្ទុកនៅទីនោះ។ក្រោយមកប្រពន្ធនិងកូននោះត្រូវបានយកទៅសម្លាប់"[739]។ មានអ្នកទោសដែលគេឃុំឃាំងរួចហើយ។ អ្នកទោសដែលជាអ្នកមូលដ្ឋាន គឺគេឃុំឃាំងយូរជាងអ្នក១៧មេសា។ ចំពោះអ្នកដែលល្បី ឧទាហរណ៍ដូចជា តារាភាពយន្ត ស្ត្រី និង តារាភាពយន្តបុរស រួមមាន គីម ណូវ៉ា ណុប ណែម ខ្ញុំស្គាល់ឈ្មោះពីព្រោះប្រធានមន្ទីរប្រាប់ខ្ញុំ ហើយពួកគេយកប្តីទៅសម្លាប់មុន។ ហើយបុគ្គលិកបិចផ្ទាល់ និង ប៉ះខ្លួនប្រាណគីម ណូវ៉ា។ កូនគាត់ក៏សួរថា "តើប៉ានៅទីនោះយូរប៉ុន្មានទៅ?" ហើយម្តាយប្រាប់កូនវិញថាគាត់នឹងត្រឡប់មកវិញ។ ហើយក្រោយមកគេបញ្ជូន គីម ណូវ៉ា និង កូនៗ ហើយសម្លាប់ចោលនៅម៉ោងប្រហែល៤រសៀល។ ខ្ញុំឃើញផ្ទាល់ភ្នែកតែម្តង"[740]។

### ការស្លាប់របស់ សុខ សយ ត្រូវជា ឪពុក ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន

389. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់ភស្តុតាងពាក្យចចាមអារ៉ាមទាក់ទិននឹងការស្លាប់របស់ឪពុកគាត់ ឈ្មោះ សុខ សយ ដែល "ត្រូវជាឪពុកខ្ញុំពីព្រោះម្តាយខ្ញុំគឺជាអ្នកបានរៀបការ រស់នៅជាមួយគាត់មុន"[741]។ គាត់បានផ្តល់សក្ខីកម្មថា ឪពុករបស់គាត់ស្លាប់នៅក្រាំងតាចាន់។ "ខ្ញុំបាត់

[738] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ E1/258.1 ទំព័រ ៣២ បន្ទាត់ ១៥-១៦។

[739] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ E1/258.1 ទំព័រ ៣ បន្ទាត់ ១៦ ដល់ទំព័រ ៣២ បន្ទាត់ ២២។

[740] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ E1/256.1 ទំព័រ ៨២ បន្ទាត់ ១៥ ដល់ទំព័រ ៨៣ បន្ទាត់ ២។ សូមមើលផងដែរ ទំព័រ ៨៣ បន្ទាត់ ៧-១៥។

[741] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ E1/256.1 ទំព័រ ៣៤ បន្ទាត់ ២០-២២។

បង់ឪពុកម្នាក់នៅក្នុងគុកនោះ"[742]។ ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់អំពីរបៀបដែលគាត់ដឹងពីការសម្លាប់ឪពុករបស់គាត់។ "ខ្ញុំឮពីទាហាន និងចាស់ៗប្រាប់ខ្ញុំ ប៉ុន្តែប្រធាន គឺមិនបានប្រាប់ខ្ញុំទេ ប៉ុន្តែទាហានដទៃទៀតដែលអាណិតខ្ញុំ បានប្រាប់ខ្ញុំអំពីរឿងនេះ"[743]។ គាត់បានផ្តល់សក្ខីកម្មថា គាត់បានទុករបស់របររបស់ឪពុកគាត់ក្រោយពេលគេសម្លាប់គាត់។ "មួក សារ៉ុង និងអាវយឺត ក្រោយពេលបោកគក់ហើយគឺខ្ញុំយកទុកប្រើខ្លួនឯង ប៉ុន្តែ ចេង អនុប្រធាន យកមួកនោះពាក់ ហើយជួនកាលអ្នកផ្សេងទៀតក៏បានស្លៀកពាក់ និង ពាក់មួករបស់ឪពុកខ្ញុំដែរ។ ជួនកាល តា អាន ពាក់មួកនោះ។ ដូច្នេះ ខ្ញុំបានអាវនិងសារ៉ុងគាត់ទុកដណ្តប់ខ្លួនពេលយប់"[744]។

***ការស្លាប់របស់កូនពីរនាក់***

390. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មអំពីការសម្លាប់កុមារនៅក្រាំងតាចាន់។ "ខ្ញុំឃើញហេតុការណ៍សម្លាប់កុមារម្នាក់។ ឪពុកម្តាយគេសម្លាប់មុន ហើយ កូន២នាក់ត្រូវគេយកមកជាមួយ។ ពីរបីថ្ងៃក្រោយគេសម្លាប់ឪពុកម្តាយ កុមារទាំងពីរ ម្នាក់ក្មេង ជាងអាយុប្រហែល ៣ទៅ៤ឆ្នាំនិងម្នាក់ទៀតអាយុ៥ទៅ៦ឆ្នាំ ប៉ុន្តែកុមារក្មេងជាងគេយកទៅមុន។ កាលពីពេលនោះ ខ្ញុំឡើងត្នោតពេលរសៀលដើម្បីយក ទឹកត្នោតឲ្យប្រធាន ហើយខ្ញុំមើល ឃើញពីលើចុងត្នោត ឃើញកុមារទាំងពីរនោះត្រូវគេយកទៅ។ ហើយតាមធម្មតា ពេលខ្ញុំកំពុង ឡើងត្នោត គឺគេចាំយកទឹកត្នោត ហើយថ្ងៃនោះខ្ញុំឮសំឡេងកុមារ ហើយឮសំឡេងបោកកុមារទៅ នឹងដើមត្នោតហើយ ប្រមាត់ គឺគេយកចេញពីកុមារនិងព្យួរនៅទីនោះ។ មានរណ្តៅតូចមួយនៅខាង ត្បូងដើមត្នោត ហើយមានពីរនាក់ទៀតរង់ចាំនៅទីនោះ។ ខ្ញុំមិនចុះមកយកទេ។ ខ្ញុំគ្រាន់តែអង្គុយនៅលើចុងត្នោត។ តាមពិតមានដើមត្នោតមួយជួរ ហើយខ្ញុំអាចឆ្លងពីដើមត្នោតមួយទៅដើមត្នោតមួយទៀត។ ដូច្នេះ ដូចខ្ញុំបាននិយាយចឹងគឺថាគេសម្លាប់កុមារក្មេងជាងគេមុន ដោយបោកនឹង គល់ត្នោត ហើយគេយកកុមារបង(ស្រី)ឲ្យអង្គុយនៅខាងលិចគល់ត្នោត ហើយគេយកចប ប្រហែលប្រវែង១ម៉ែត្រ

[742] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៥៥ បន្ទាត់ ១៦។

[743] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៥៥ បន្ទាត់ ១៨-២០។

[744] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៥៥ បន្ទាត់ ២២ ដល់ទំព័រ ៥៦ បន្ទាត់ ១។

វាយចំកញ្ចឹងក។ គេមិនរំមុខដូចមនុស្សធំទេ ហើយមនុស្សចាស់ពេលគេ វាយនឹងត្បូងចប គេយកកាំបិតផ្គាក់អារក ប៉ុន្តែក្នុងករណីនេះគឺគេវាយ កុមារនេះនឹងចប់រួចអូស សាកសពដាក់ក្នុងរណ្តៅ។ រួចហើយពួកគេដើរត្រឡប់ទៅវិញធ្វើធម្មតា។ នេះជាអ្វីដែលខ្ញុំឃើញហេតុការណ៍នោះផ្ទាល់"[745]។

391. ដើមបណ្តឹងរដ្ឋប្បវេណី ផ្តល់សក្ខីកម្មបន្ថែមទៀតថា មានកុមារដទៃទៀតត្រូវបានគេសម្លាប់ផងដែរ "បាទ។ ខ្ញុំថែមទាំងស្គាល់ឃាតករមួយចំនួនហើយអ្នកខ្លះនៅរស់ដល់បច្ចុប្បន្ន"[746]។

### *ការស្លាប់របស់ តានន*

392. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មអំពីការស្លាប់របស់ តានន ដែលធ្លាប់ជីករណ្តៅកប់សាកសពជាមយយដើមបណ្តឹងរដ្ឋប្បវេណី។ ដើមបណ្តឹងរដ្ឋប្បវេណី បានពន្យល់ថា "តានន ក៏ស្លាប់នៅទីនោះដែរ។ មុនពេលគាត់ស្លាប់ គេឲ្យគាត់ជីករណ្តៅ។ ខ្ញុំគិតថាឲ្យតែពេល ជីករណ្តៅ គឺត្រូវតែមានការសម្លាប់"[747]។ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សេចក្តីលំអិតថែមទៀតក្នុងកំឡុងកិច្ចស្តាប់ចម្លើយជាមួយ ក.ស.ច.ស ដែលក្នុងនោះគាត់ពន្យល់ថា គាត់ "ដឹងថា តានន ត្រូវបានគេសម្លាប់នៅមន្ទីរក្រាំងតាចាន់ពីព្រោះ តានន គឺជាអ្នកទោសដែលគេសម្រាលទោសឲ្យនិងឲ្យធ្វើការដូចខ្ញុំដែរ។ មានពេលខ្លះគេប្រើឲ្យគាត់ទៅយកត្រីមកឲ្យឃោធាហូប។ ក្រោយមកគេឲ្យគាត់ដាំស្លសម្រាប់អ្នកទោស។ ថ្ងៃមួយនៅកន្លែងចុងភៅ គាត់និយាយជាមួយខ្ញុំ ដោយប្រាប់ខ្ញុំថា "ខ្ញុំប្រហែលជាត្រូវស្លាប់មុនអ្នកឯងហើយ"។ នៅពេលគាត់កំពុងនិយាយជាមួយខ្ញុំ រំពេចនោះស្រាប់តែ ឈ្មោះ ចេង ជាទាហាននៅក្រាំងតាចាន់ បានមកហៅខ្ញុំ។ ដោយគាត់បាត់ខ្លួន យូរពេក ខ្ញុំបានដើរទៅមើលកន្លែងដែលគេសម្លាប់អ្នកទោស ហើយខ្ញុំក៏ឃើញសាកសពគាត់។ គេសម្លាប់គាត់

[745] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៤៥ បន្ទាត់ ២៣ ដល់ទំព័រ ៤៦ បន្ទាត់ ២៥។

[746] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៤៧ បន្ទាត់ ៥-៦។

[747] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹកថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៥៦ បន្ទាត់ ១៨-២០។

រួចដាក់នៅក្រោមដើមឈើទាល ចម្ងាយប្រហែល៧០ម៉ែត្រពីគុក”[748]។ “បទល្មើសរបស់គាត់គឺគាត់ជាមនុស្សហាណ្ឌួយ”[749]។

*ការស្លាប់ដោយការគេចខ្លួន*

393. ដើមបណ្តឹងរដ្ឋប្បវេណី សុយ សែន បានផ្តល់សក្ខីកម្មអំពីការស្លាប់របស់ឈ្មោះ ស៊ិន ជាអ្នកទោសនៅក្រាំងតាចាន់ដែលប៉ុនប៉ងរត់។ “អ្នកទោសឈ្មោះ ស៊ិន គាត់ប៉ុនប៉ងរត់គេចពេលរសៀល គឺក្រោយពេលគេចែកម្ហូបអាហារឱ្យយើងហូប។ យើងត្រូវទៅដកស្មៅនៅវាយស្រែ។ ដោយសារស្មៅខ្ពស់ ហើយនៅពេលនោះ គាត់កំពុងតែរត់គេច គាត់ត្រូវគេបាញ់ដោយកាំភ្លើងកាប៊ីន។ ដូច្នេះក្រោយពេលឮគេបាញ់ យោធាដទៃទៀត ម្នាក់ៗបំពាក់ដោយកាំភ្លើងអាកា ក៏រត់ពីបរិវេណទៅកន្លែងនោះ ហើយបន្ទាប់មកអ្នកទោសនោះត្រូវគេបាញ់ស្លាប់”[750]។

*ការស្លាប់របស់ជនរងគ្រោះស្ត្រីដែលគេរំលោភ*

394. ដើមបណ្តឹងរដ្ឋប្បវេណី សុយ សែន បានផ្តល់សក្ខីកម្មទាក់ទិននឹងការស្លាប់របស់ស្ត្រី២នាក់មកពីកងចល័តដែលត្រូវបានរំលោភមុនពេលស្លាប់។ “ឌុច បានសម្លាប់ពួកគេ ហើយគាត់បញ្ជាឱ្យខ្ញុំ កប់ពួកគេ រួចហើយគាត់សួរថាខ្ញុំមានឃើញក្បាលគ្រាប់M-79នៅក្នុងយោនីពួកគេដែរឬទេ ខ្ញុំឆ្លើយថាឃើញ”[751]។ គាត់បានបំភ្លឺបញ្ជាក់ថា “មានឌុចតូច និង សាំង។ មាន២នាក់ហ្នឹងដែល “រំលោភនារី២នាក់ពីកងចល័ត ហើយបានយកគ្រាប់ M-79 ស៊កចូលក្នុងយោនីរបស់នារីទាំងនោះ[752]។

---

748 កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សុយ សែន ឯកសារ **E3/5214** ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៨ KH ERN 00223063-00223064។

749 កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សុយ សែន ឯកសារ **E3/5214** ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៨ KH ERN 00223063-00223064។

750 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/257.1** ទំព័រ ២៩ បន្ទាត់ ១៧-២២។

751 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/282.1** ទំព័រ ៩០ បន្ទាត់ ៨-១១។

752 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/257.1** ទំព័រ ២៤ បន្ទាត់ ២-៣។ *សូមមើលផងដែរ* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុយ សែន ប្រតិចារឹក ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/258.1** ទំព័រ ៧ បន្ទាត់ ២១-២៤។

395. ដើមបណ្តឹងរដ្ឋប្បវេណី បានរៀបរាប់ពីរបៀបដែលឆ្មាំម្នាក់បានណែនាំឱ្យគាត់ទៅកន្លែងខាងត្បូងអគារគុក៖ "នៅពេលខ្ញុំទៅទីនោះ តាមពិតគាត់ទើបរំលោភនារី២នាក់មកពីកងចល័ត ហើយយកក្បាលគ្រាប់ M-79ស៊កចូលក្នុងយោនី។ ខ្ញុំត្រូវបានបញ្ជាឱ្យកប់សាកសពទាំងនោះ ហើយខ្ញុំអាចប្រាប់អ្នកអំពីគុកនោះ"[753]។ គាត់បានពន្យល់ថា "កន្លែងនោះគឺគេហាម ហើយនៅពេលដែលឆ្មាំសន្តិសុខឱ្យអ្នកទោសទៅធ្វើអ្វីមួយ ទើបអ្នកទោសអាចចូលបាន។ ដំបូង ក្រោយពីគាត់ធ្វើរួចរាល់ហើយ ទើបគាត់បញ្ជូនខ្ញុំទៅកប់សាកសព ហើយក្រោយពីវិលត្រឡប់មកវិញ គាត់សួរខ្ញុំថាបានឃើញអ្វីដែរឬទេ។ ពិតហើយគឺខ្ញុំឃើញក្បាលគ្រាប់ដែលគាត់ស៊កចូលយោនី"[754]។

***ការសម្លាប់ ឈ្មោះ ចាន់***

396. ដើមបណ្តឹងរដ្ឋប្បវេណី រី ពៅ បានផ្តល់សក្ខីកម្មអំពីការស្លាប់របស់ឈ្មោះ ចាន់ ដែលនៅក្នុងកងចល័តជាមួយនឹងគាត់ដែរ។ "ចាន់ នៅកងចល័តជាមួយខ្ញុំ ហើយគាត់ក៏មកពីវៀតណាមដែរ។ នៅវៀតណាម យើងរសើនៅក្នុងភូមិជាមួយគ្នា។ ដោយគេដាក់ឱ្យរស់នៅជាមួយគ្នា ខ្ញុំស្គាល់គាត់។ ហើយពេលយើងត្រឡប់មករបបខ្មែរក្រហម គេដាក់យើងក្នុងកងជាមួយគ្នា"[755]។ ដូចដែលខ្ញុំទើបតែនិយាយអញ្ចឹង ខ្ញុំឃើញអ្វីដែលបានកើតឡើងចំពោះគាត់ ប៉ុន្តែមិនបានសង្កេតលំអិតឬថាមានសាកសពប៉ុន្មាននាក់នៅជុំវិញឡើយ ឬថាតើឈ្លបឬយោធាប៉ុន្មាននាក់នៅកន្លែងនោះដើម្បីយកមនុស្សទៅសម្លាប់ឡើយ។ ហើយខ្ញុំគ្រាន់តែឃើញគាត់ដេកក្នុងរណ្តៅ ហើយរណ្តៅនោះគឺប្រហែលបណ្តោយ២០ម៉ែត្រស្ថិតនៅក្នុងព្រៃ ហើយគាត់ឱ្យសំឡេង ហើយប្រាប់ខ្ញុំ។ តាមពិតបើអ្នកជឿ

---

[753] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៥៤ បន្ទាត់ ៤-១៤។

[754] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/258.1** ទំព័រ ៥៩ បន្ទាត់ ១០-១៤។ *សូមមើលផងដែរ* កំណត់ហេតុស្តាប់ចម្លើយ សយ សែន ឯកសារ **E3/5214** ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៨ KH ERN 00223067 ("អ្នកទោសមួយចំនួនខ្លះទៀតដែលនៅក្នុងមន្ទីរក្រាំងតាចាន់នោះ ត្រូវបានចាប់រំលោភ និងសម្លាប់ដោយទ័ព ដែលជាអ្នកការពារនៅក្នុងមន្ទីរនេះ។ ទ័ពដែលតែងតែប្រព្រឹត្តអំពើរំលោភលើអ្នកទោសដែលគេបញ្ជូនមកមានឈ្មោះ ឌុច តូច។ ហេតុដែលខ្ញុំដឹងពីព្រោះ ឌុចតូចនេះ ពេលរំលោភ និងសម្លាប់ហើយប្រាប់ឱ្យខ្ញុំទៅមើល និងយកទៅកប់អ្នកទោសខ្លះមានគ្រាប់កាំភ្លើងសុវ៉ាន់ធីណែ ញុកនៅប្រដាប់ភេទ ហើយគ្មានសម្លៀកបំពាក់ទេ។")

[755] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ពៅ រី ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/262.1** ទំព័រ ១៩ បន្ទាត់ ១៥-១៨។

លើអបិយជំនឿ គឺខ្ញុំគិតថាខ្ញុំត្រូវខ្មោចលង។ ប៉ុន្តែ នៅក្នុងរបប ប៉ុល ពត អបិយជំនឿត្រូវគេហាមឃាត់។ ពេលនោះគាត់ស្រែកហៅខ្ញុំ ពេលនោះខ្ញុំដឹងថាគាត់គឺជា ចាន់"[756]។

397. ដើមបណ្តឹងរដ្ឋប្បវេណី បានពន្យល់ថា គាត់ឃើញ ចាន់ នៅជិតក្រាំងតាចាន់។ "ប្រសិនបើ យើងនិយាយអំពីបទពិសោធន៍ខ្ញុំនៅក្នុងរយៈកាលខ្មែរក្រហមជាពិសេសនៅពេលខ្ញុំនៅភូមិពងទឹក ដែលស្ថិតនៅមិនឆ្ងាយពីក្រាំងតាចាន់ទេ ប៉ុន្តែខ្ញុំពិបាក មិនដឹងថានៅទីណាឬទីតាំងណាដែលគេបញ្ជូនខ្ញុំទោ។ ឧទាហរណ៍ ខ្ញុំមិនដឹងថាមានកងឈ្លបនៅក្រាំងតាចាន់ផង។ មានថ្ងៃមួយ ពេលខ្ញុំកំពុង ភ្ជួរស្រែ នៅពេលសម្រាកគោទៅស៊ីស្មៅជិតព្រៃមួយក្បែរក្រាំងតាចាន់។ មានព្រៃធំមួយនៅជិតនោះ ហើយខ្ញុំមិនដឹងថាក្រាំងតាចាន់ គេប្រើសម្រាប់ធ្វើអ្វីនោះទេកាលពីពេលនោះ។ នៅពេលខ្ញុំទៅយកគោ ខ្ញុំឃើញបុរសម្នាក់ឈ្មោះ ចាន់ ដែលធ្វើការក្នុងកងរបស់ខ្ញុំដែរ ហើយខ្ញុំមិនដឹងកាលបរិច្ឆេទពិតប្រាកដដែលគេសម្លាប់គាត់ឡើយ។ ខ្ញុំឃើញឈាមប្រឡាក់ពេញផ្ទៃមុខនិងខ្លួន ហើយគាត់ ដកចង្កាមាន់ ហើយប្រាប់ខ្ញុំឱ្យប្រាប់ម្តាយគាត់ផងថាគាត់មិនរស់ទេ។ ឈ្លប បានទៅហូបបាយថ្ងៃអស់ហើយ។ ពេលដែលខ្ញុំឃើញគាត់ ខ្ញុំរន្ធត់។ ដូច្នេះខ្ញុំក៏ប្រញាប់ប្រញាល់ប្រមូលគោរួចត្រឡប់ទៅកន្លែងខ្ញុំស្នាក់នៅវិញ។ ខ្ញុំបានឃើញហេតុការណ៍នោះដោយផ្ទាល់ ប៉ុន្តែមិននៅទីនោះពិនិត្យមើលយូរទេ ថាតើមានមនុស្សប៉ុន្មាននាក់ត្រូវបានសម្លាប់ ឬអ្នកណាខ្លះ ដកចង្កាមាន់។ ខ្ញុំគ្រាន់តែដឹងថាម្នាក់ឈ្មោះ ចាន់ នោះគឺកំពុងដកចង្កាមាន់នៅពេលដែលខ្ញុំឃើញគាត់។ ហើយខ្ញុំដឹងតាមរយៈអ្វីដែលខ្ញុំឮដោយផ្ទាល់ពីយុវជនខ្មែរក្រហម ឬប្រជាជនមូលដ្ឋាន ពួកគេនិយាយថាពួកគេអាចសម្លាប់យើងយ៉ាងងាយបំផុត គឺគ្រាន់តែដំបងឬគល់ឫស្សី គឺវាយស្លាប់ហើយ"[757]។

### *ការស្លាប់របស់ អ៊ួយ មុត ត្រូវជាប្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម សារឿន*

398. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម សារឿន បានផ្តល់សក្ខីកម្មអំពីការស្លាប់របស់ប្តីគាត់ឈ្មោះ អ៊ួយ មុត។ "អ៊ុយ មុត ហ្នឹងគ្រួសាររបស់ខ្ញុំ ហើយ ហ៊ូ ហ្នឹងគាត់ជាប់គុកនៅក្រាំងតាចាន់ជាមួយគ្នាទាហាន

[756] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ពៅ រី ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/262.1** ទំព័រ ២០ បន្ទាត់ ១១-១៦។

[757] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ពៅ រី ប្រតិចារឹក ថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/262.1** ទំព័រ ១៨ បន្ទាត់ ២២ ដល់ទំព័រ ១៩ បន្ទាត់ ១២។

ជំនាន់ លន់ នល់។ គាត់ថា "កុំចាំមើលផ្លូវអី អ៊ុយ មុត ហ្នឹងស្លាប់ហើយ"។ គាត់បានរួចមកវិញ ចាំរំដោះទាន់"[758]។

399. គាត់បានរៀបរាប់ថាបានដឹងអំពីការស្លាប់របស់ អ៊ុយ មុត តាមរយៈ ហ៊ួ។ "គាត់ជួបថា មិនបាច់ចាំផ្លូវទេ ឈ្មោះ អ៊ុយ មុត ហ្នឹងយកទៅមន្ទីរឃុំឃាំងកន្លែងគាត់។ ហើយដល់ហើយឈ្មោះហ្នឹងបញ្ជូនទៅក្រាំងតាចាន់ហើយ។ គាត់បាននិយាយតែប៉ុណ្ណឹង"[759]។ គាត់បញ្ជាក់ថា ជឹម គឺជាឆ្មាំគុកនៅគុកអង្គតាសោម ក្នុងស្រុក ត្រាំកក់[760]។

400. ដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានសាកសួរអំពីថាតើគាត់បាននិយាយដោយផ្ទាល់ជាមួយ ជឹម អំពីអ្វីដែលបានកើតឡើងចំពោះប្ដីរបស់គាត់ដែរឬយ៉ាងណា[761]។ "ជឹម ហ្នឹង គាត់ផ្ដល់ ព្រោះគាត់នៅស្រុកកំណើតភូមិខ្ញុំដែរ ប៉ុនគាត់អ្នកទី១ ទ័ព"[762]។ "គាត់ប្រាប់ពេល៧៩ ជួបគាត់ ចាប់គាត់ហ្នឹងមន្ទីរឃុំឃាំងនៅខេត្តតាកែវទៀត។ ដល់សព្វថ្ងៃ គាត់អត់ហ៊ានចូលស្រុកផង ទៅនៅខេត្តបាត់ដំបង។ ឥឡូវគាត់ស្លាប់ហើយ អត់ហ៊ានមកនៅស្រុកកំណើតផង"[763]។

### *ការសម្លាប់សមាជិកគ្រួសាររបស់ អ៊ឹម សារឿន*

401. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ឹម សារឿន បានផ្ដល់សក្ខីកម្មអំពីវាសនារបស់បងប្រុស ឪពុក និងឪពុកមារបស់គាត់ក្រោយពេលគេបញ្ជូនទៅក្រាំងតាចាន់។ "បងខ្ញុំ អ៊ឹង លីម គាត់រកសេដ្ឋកិច្ច

[758] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ឹម សារឿន ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/283.1** ទំព័រ ១១-១២ បន្ទាត់ ២៥-២។

[759] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ឹម សារឿន ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/283.1** ទំព័រ ១១ បន្ទាត់ ១៥-១៧។

[760] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ឹម សារឿន ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/283.1** ទំព័រ ១០ បន្ទាត់ ២១-២២។

[761] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ឹម សារឿន ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/283.1** ទំព័រ ១១ បន្ទាត់ ៣-៧។

[762] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ឹម សារឿន ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/283.1** ទំព័រ ១៤ បន្ទាត់ ៦។

[763] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ឹម សារឿន ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/283.1** ទំព័រ ១៤ បន្ទាត់ ៨-១០។

ដល់ពេលរកបានអ៊ីចឹងទៅគាត់អ្នក១៧ គាត់ដូចថា គាត់ស្គាល់អ៊ីចឹង គាត់សុំឲ្យបារីមួយ ដល់ថ្ងៃក្រោយឡើង គេកសាងបងខ្ញុំ ស្រាប់យកទៅបាត់ទៅ”[764]។ “មានឯកសារនៅក្រាំងតាចាន់ ហើយទ័ព -- កងទ័ពប៉ុល ពត ហ្នឹងយកមកដាក់ហ្នឹងគាត់រាយការណ៍ប្រាប់ ពូជឹម ហ្នឹងគាត់ប្រាប់ថាឈ្មោះនៅលើគាត់។ ហើយដាក់ឈ្មោះនៅមន្ទីរឃុំឃាំងនៅក្រាំងតាចាន់ មានទៀត”[765]។

***ការស្លាប់របស់ ឪពុកនិងឪពុកមារបស់ អ៊ូ ដាវ***

402. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ បានផ្តល់សក្ខីកម្មថា នៅពេលគាត់ត្រឡប់មកភូមិគាត់ វិញ ស្ត្រីម្នាក់ទទួលខុសត្រូវគុកនៅតំបន់នោះ[766]បានប្រាប់ដើមបណ្តឹងរដ្ឋប្បវេណីថាឪពុករបស់គាត់ត្រូវបានឃុំឃាំងនៅភ្នំឆ្នា[767] រួចហើយធ្វើទារុណកម្មនិងស្លាប់នៅមន្ទីរ សន្តិសុខក្រាំងតាចាន់[768]នៅចុងឆ្នាំ១៩៧៥ឬដើមឆ្នាំ១៩៧៦[769]។ ដើមបណ្តឹងរដ្ឋប្បវេណី បានផ្តល់សក្ខីកម្មថា “ខ្ញុំដឹងថា ខ្ញុំបានបាត់បង់ឪពុកជាទីស្រលាញ់របស់ខ្ញុំចាប់តាំងពីគេជម្លៀសចេញពីតាកែវមកម្លេះ”[770]។ ដើមបណ្តឹងរដ្ឋប្បវេណី បានថ្លែងថា “ខ្ញុំបានសួរមេៗជាច្រើន។ ខ្ញុំបានសួរជាច្រើននាក់ម្តងហើយម្តងទៀតដើម្បីសុំការបញ្ជាក់ ហើយគេប្រាប់ខ្ញុំថាវាជាការពិតដែលថាឪពុករបស់ខ្ញុំត្រូវបានយកទៅធ្វើទារុណកម្ម

---

[764] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សារឿន ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/283.1** ទំព័រ ១៩ បន្ទាត់ ៤-៥។

[765] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សារឿន ប្រតិចារឹក ថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/283.1** ទំព័រ ១៨ បន្ទាត់ ៨-៩។

[766] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ប្រតិចារឹក ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/499.1** ទំព័រ ១៤ បន្ទាត់ ២-៥។

[767] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ប្រតិចារឹក ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/499.1** ទំព័រ ១៣ បន្ទាត់ ៨-១៤។

[768] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ប្រតិចារឹក ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/499.1** ទំព័រ ១០ បន្ទាត់ ២៤ ដល់ទំព័រ ១១ បន្ទាត់ ២ និងទំព័រ ១១ បន្ទាត់ ១៧-២០។

[769] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ប្រតិចារឹក ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/499.1** ទំព័រ ១៣ បន្ទាត់ ១១-១៤។

[770] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ប្រតិចារឹក ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/499.1** ទំព័រ ១០ បន្ទាត់ ២៣-២៤។

នៅក្រាំងតាចាន់ ហើយគាត់ត្រូវបានសម្លាប់នៅទីនោះ។ ខ្ញុំមិនបានឃើញអដ្ឋិធាតុរបស់ គាត់ទេ"[771]។ "គេប្រាប់ខ្ញុំថាគាត់ត្រូវបានធ្វើទារុណកម្មមុនពេលគេសម្លាប់នៅចុងឆ្នាំ១៩៧៥"[772]។

403. ទាក់ទិននឹងឪពុកមារបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលជាអតីតគ្រូបង្រៀនដែលរស់នៅតំបន់មិនរំដោះ[773]។ ដើមបណ្តឹងរដ្ឋប្បវេណីបានរំលឹកថា "ខ្ញុំដឹងថាឪពុកមាបង្កើតរបស់ខ្ញុំម្នាក់ក៏នៅ ទីនោះដែរ" ដោយនិយាយយោងដល់ក្រាំងតាចាន់[774]។

### *ការសម្លាប់ប្រជាជន១៧មេសា ឬអ្នកការពាក់ព័ន្ធនឹងអតីតរបប លន់ នល់*

404. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មទាក់ទិននឹងការសម្លាប់ប្រជាជន១៧មេសា ឬអ្នកទាំងឡាយដែលពាក់ព័ន្ធជាមួយរបបមុន។ ទាក់ទិននឹងការសម្លាប់ គាត់បានផ្តល់សក្ខីកម្មថា "គេទុកអ្នកទោសអ្នកមូលដ្ឋានយូរជាង។ ចំណែកអ្នកផ្សេង សម្រាប់អ្នក១៧មេសា [ឬ]អតីតទាហាន ស័ក្តិ២ ឬស័ក្តិ៣ ពួកគេនឹងឃុំឃាំងមិនយូរជាង១សប្តាហ៍ទេ ហើយចំពោះអ្នកទោស១៧មេសា ពួកគេទុកមួយចំនួនយូរបន្តិច ប៉ុន្តែក្រោយមកក៏ត្រូវសម្លាប់ដែរ"[775]។ "ចំពោះអ្នក១៧មេសា ឧទាហរណ៍ដូចជាមន្ត្រីជាន់ខ្ពស់ ពួកគេនឹងត្រូវនាំទៅដាក់ក្រៅផ្ទះ ហើយបុគ្គលិកផ្សេងទៀតនឹងឱ្យដួងធឹក។ ខ្ញុំឮពី តា ឈឿន និង តា ឆេន ។ ពួកគេត្រូវបានទុកនៅក្រៅ ហើយនឹងបណ្តើរជាជួរឆ្ពោះទៅកន្លែងសម្លាប់ ពួកគេមិនត្រូវបាននាំចូលទៅក្នុងអគារឃុំឃាំងទេ"[776]។

---

[771] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ប្រតិចារឹក ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/499.1** ទំព័រ ១១ បន្ទាត់ ១៧-២០។

[772] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ប្រតិចារឹក ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/499.1** ទំព័រ ១០-១១ បន្ទាត់ ២៥ ១-២។

[773] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ប្រតិចារឹក ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/499.1** ទំព័រ ១២ បន្ទាត់ ១-២។

[774] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ប្រតិចារឹក ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៦ ឯកសារ **E1/499.1** ទំព័រ ១១ បន្ទាត់ ២៣-២៤។

[775] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៨៣ បន្ទាត់ ១៩-២៤។

[776] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៨៤ បន្ទាត់ ២-៩។

405. ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង បានផ្តល់សក្ខីកម្មអំពីការស្លាប់របស់ជីដូនមួយគាត់ឈ្មោះ បង ជា ដែលជាអតីតទាហាន លន់ នល់៖ "គាត់ត្រូវជាកូនរបស់ ពូ យុន និង មីង ម៉ិច។ ពូ យុន គឺជាពូរបស់ខ្ញុំ។ ហើយកូនគាត់ជាអតីតទាហានក្នុងសម័យ លន់ នល់។ គាត់ឈ្មោះ បង ជា។ គាត់ ត្រូវគេចាប់ខ្លួននិងសម្លាប់នៅមន្ទីរសន្តិសុខក្រាំងតាចាន់"[777]។ "កូនមីង ម៉ិច គឺ បងជា។ ហើយ ពូ យុន ត្រូវជាប្តី មីង ម៉ិច"[778]។ ម្នាក់ដែលស្លាប់គឺ បង ជា"[779]។

406. ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង បានពន្យល់ថា "ខ្ញុំដឹងអំពីការសម្លាប់គាត់ក្រោយពីគាត់បាត់ខ្លួនពីមន្ទីរសន្តិសុខ។ ខ្ញុំដឹងថាពិបាកចេញពីមន្ទីសន្តិសុខទាំងរស់ណាស់។ ដូច្នេះពេលខ្ញុំសង្កេតឃើញថាគាត់បានបាត់ខ្លួនពីមន្ទីរ ខ្ញុំដឹងថាគាត់ច្បាស់ជាត្រូវគេសម្លាប់។ ប៉ុន្តែ ខ្ញុំមិនដឹងឬមិនបានចាប់អារម្មណ៍ថាគាត់បាត់ខ្លួនថ្ងៃណា ខែណាឡើយ។ ខ្ញុំមិនបានកត់ត្រាសេចក្តីលំអិតទាំងនោះទេ"[780]។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា "គ្មាននណាប្រាប់ខ្ញុំ[អំពីការស្លាប់របស់គាត់ទេ]។ ពេល គេដោះលែងអ្នកទោសឲ្យទៅធ្វើការផ្នែកខាងក្រៅ ខ្ញុំមិនឃើញគាត់ទេ។ ដូច្នេះ ចាប់ពីពេលនោះមកខ្ញុំមិនឃើញគាត់រហូតដល់គេផ្លាស់ខ្ញុំទៅធញរើការនៅអង្គភាពយោធា"[781]។ តាមរយៈការសង្កេតរបស់ខ្ញុំនៅពេលនណាម្នាក់បាត់ខ្លួនពីភ្នែករបស់យើងបុគ្គលនេះមិនទៅណាក្រៅពីស្លាប់នោះទេ"[782]។

407. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មអំពីការស្លាប់របស់ តា សង្គ្រាច ប៉ាន់ អតីតមន្ត្រីជាន់ខ្ពស់នៃរបប លន់ នល់។ "ខ្ញុំស្គាល់អ្នកធំសម័យមុនដែលត្រូវគេសម្លាប់។ ខ្ញុំស្គាល់ឈ្មោះ

[777] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/282.1** ទំព័រ ៤៦ បន្ទាត់ ១២-១៣។

[778] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/282.1** ទំព័រ ៤៦ បន្ទាត់ ២០។

[779] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/282.1** ទំព័រ ៤៦ បន្ទាត់ ២២។

[780] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/282.1** ទំព័រ ៤៩ បន្ទាត់ ៧-៩ *សូមមើលផងដែរ* បន្ទាត់ ៣-៤។

[781] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/282.1** ទំព័រ ៤៩ បន្ទាត់ ១១-១២។

[782] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង ប្រតិចារឹក ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/282.1** ទំព័រ ៤៩ បន្ទាត់ ១៧-១៨។

ប៉ុន្តែមិនស្គាល់មុខ"[783]។ គាត់ឈ្មោះ ព្រះតេជគុណ ប៉ាញ់។ គាត់គឺជាមន្ត្រីជាន់ខ្ពស់ លន់ នល់ ម្នាក់នៅតាកែវ"[784]។ "ខ្ញុំមិនដឹងតួនាទីគាត់ទេ។ ខ្ញុំកាលនោះនៅក្មេងពេក។ ខ្ញុំដឹងថាគាត់ត្រូវបានគេនាំចូលមន្ទីរសន្តិសុខក្រាំងតាចាន់ ហើយគេចាត់ទុកជាឈ្លើយសឹក។ គាត់ត្រូវបានគេសម្លាប់ក្រោយមក"[785]។

## ៥.៣. ការស្លាប់ដោយលក្ខខណ្ឌនានា

408. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មអំពីការស្លាប់របស់អ្នកទោសដោយសារការបង្អត់អាហារ។ "គេដាំដើមដូងនៅលើផ្នូរកប់ខ្មោចអ្នកទោសដែលស្លាប់ដោយការបង្អត់អាហារ ហើយគេកប់លើផ្នូរមួយៗ"[786]។

409. ចំពោះចំនួនអ្នកស្លាប់ដោយសារការសួរចម្លើយនៅអគារនីមួយៗវិញ ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មថា "ចំនួនខុសៗគ្នា។ អ្នកដែលស្លាប់ ឥឡូវខ្ញុំនិយាយអំពីអ្នកមកថ្មី ពួកគេនឹងត្រូវយកមកសួរចម្លើយនៅកន្លែងសួរចម្លើយ ហើយគេវាយដំ។ ពេលពួកគេដើរមិនរួច គេឱ្យខ្ញុំសែងអ្នកទោសនោះទៅក្នុងអគារ ហើយជួនកាលយើងត្រូវតែសែងអ្នកទោស។ ពួកគេត្រូវបានធ្វើទារុណកម្ម ហើយនៅពេលគេយកចូលក្នុងអគារ ពួកគេនឹងត្រូវដាក់ខ្នោះម្តងទៀត ហើយគេមិនឱ្យហូបបាយឬបបរទេ។ កាលនោះពួកគេរងការចោទប្រកាន់ថា "ក្បត់ជាតិ" ដូច្នេះ ពួកគេមិនបានអាហារហូបទេក្នុងកំលុងពេលនោះ។ ចំពោះអ្នកទោសប្រុស ពួកគេស្លាប់ក្រោយពេលគ្មានអាហារហូបអស់រយៈពេល១៨ថ្ងៃ។ ខ្ញុំសង្កេតឃើញដូច្នេះ ពីព្រោះរៀងរាល់ថ្ងៃ ខ្ញុំបត់ស្លឹកត្នោតទុកចំណាំ ដូច្នេះខ្ញុំបានរាប់ដល់១៨ ពេលអ្នកទោសនោះអត់អាហារនិងស្លាប់។ រួចហើយគេបញ្ជាឱ្យខ្ញុំអូស

[783] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/258.1** ទំព័រ ១៤ បន្ទាត់ ១២-១៤។

[784] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/258.1** ទំព័រ ១៤ បន្ទាត់ ១៦។

[785] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/258.1** ទំព័រ ១៤ បន្ទាត់ ១៩-២១។

[786] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៥៦ បន្ទាត់ ២៣-២៤។

សាកសពចេញទៅក្រៅកប់ក្នុងរណ្ដៅ"[787]។ ទាក់ទិននឹងអ្នកទោសដែលត្រូវបានគេសួរចម្លើយ គាត់បានផ្ដល់សក្ខីកម្មថាបើទោះបីជាអ្នកទោសមិនត្រូវគេយកទៅសម្លាប់ក្ដី "អ្នកទោសដែលត្រូវបានធ្វើទារុណកម្មនិងឃុំឃាំងនៅទីនោះគឺមិនអាចនៅលើសពី១ខែឡើយ"[788]។

410. ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន បានផ្ដល់សក្ខីកម្មថាអ្នកទោសស្លាប់នៅកំលុងពេលឃុំឃាំង។ "ដូច្នេះ អ្នកណាស្លាប់ពេលយប់ គេទុកសាកសពនៅជាប់ខ្នោះ ព្រឹកថ្ងៃបន្ទាប់ ហើយរង់ចាំរហូតដល់ល្ងាច ម៉ោង៣ឬ៤ ពេលនោះគឺយកសាកសពចេញ។ គេមិនយកសាកសព ចេញពេលព្រឹកទេ ពីព្រោះកំលុងពេលនោះគឺអ្នកទោសគេឲ្យចេញធ្វើការក្រៅ ហើយគេមិនចង់ឲ្យ នណាម្នាក់ដឹងថាគេដាក់សាកសពនៅកន្លែងណាឡើយ"[789]។

## ៥.៤. ភស្តុតាងនៃការសម្លាប់ជាទ្រង់ទ្រាយធំ

411. ក្នុងកំលុងពេលស្ដាប់ចម្លើយដោយ ក.ស.ច.ស ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន បានពន្យល់ថាគាត់ "ឃើញអ្នកទោសគេយកចេញទៅសម្លាប់ស្ទើររាល់ថ្ងៃ"[790]។

412. ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន បានផ្ដល់សក្ខីកម្មអំពីទីតាំងនៃកន្លែងសម្លាប់នៅក្រាំងតាចាន់។ កន្លែងសម្លាប់នោះគឺនៅ "តាមបណ្ដោយរបងហើយគេអាចដាំដើមដូងពីលើ។អ្នកទោសដែលស្លាប់រាល់យប់ មួយនាក់ឬពីរនាក់ គេសែងទៅកប់នៅទីនោះនៅវាលស្រែខាងត្បូងដើមអំពិល។ ជម្រៅរណ្ដៅដែលគេកប់សាកសពគឺប្រហែល៦០សង់ទីម៉ែត្រដើម្បីពេលគេរាស់ដីគឺមិនប៉ះសាកសព"[791]។

---

[787] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៤៩ បន្ទាត់ ១២-២៤។

[788] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៥៣ បន្ទាត់ ១០-១១។

[789] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៣៨ បន្ទាត់ ១៦-២០។

[790] កំណត់ហេតុស្ដាប់ចម្លើយ សយ សែន ឯកសារ **E3/5214** ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៨ KH ERN 00223067។

[791] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៣២ បន្ទាត់ ១០-១៤។

ក្រៅពីកន្លែងនេះ "គឺ[មានមួយទៀត]នៅខាងលិចភូមិ និងខាងត្បូងចុងស្រះ។ ផ្នូរសាកសពនៅនៅឡើយទេមកដល់សព្វថ្ងៃ"[792]។

413. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានពន្យល់ថាសាកសពគឺគេដាក់នៅក្នុងរណ្តៅ និង ចាក់ដីពីលើ។ ក្រោយពេលសម្លាប់ គេយកដីកប់លើសាកសពចំនួន២៥នាក់ លើកលែងតែរណ្តៅជ្រៅខ្លាំង។ ឧទាហរណ៍ សាកសព៣០ រណ្តៅនៅជ្រៅពេក លុះ១ថ្ងៃ២ថ្ងៃក្រោយមក ពេលសាកសពឡើងហើមធ្វើឱ្យប្រេះដី។ មានក្លិន ធំក្លិនស្អុយខ្លាំង ដូច្នេះប្រធានហៅខ្ញុំ "សែន" ចូរទៅត្បូងមើល" អញ្ចឹងខ្ញុំយល់ថាគាត់បញ្ជាខ្ញុំទៅ ទៅដាក់ដីពីលើសាកសពដែលស្អុយរលួយនោះ។ ក្រោយមក ពួកគេប្រើរណ្តៅដដែលដើម្បីកប់សាកសព"[793]។ គាត់ផ្តល់សក្ខីកម្មបន្ថែមទៀតថា "តាអាន ប្រធានមន្ទីរសន្តិសុខ និយាយអំពីក្លិនចេញពីរណ្តៅប្រេះដី។ ពេលគាត់ធ្វើកាយវិកាថាធំក្លិនស្អុយ មានន័យថាខ្ញុំគួរទៅលុបរណ្តៅទាំងនោះ ដែលនៅចំហរ។ ខ្ញុំដឹងថាគាត់មកដើម្បីប្រាប់ខ្ញុំឱ្យយកដីថែមលុបស្នាមប្រេះដី ដើម្បីកុំឱ្យជះក្លិនទៅលើគុកដែលគេកំពុងឃុំឃាំងអ្នកទោស"[794]។

414. ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា មានរណ្តៅសាកសពជាច្រើននៅក្រាំងតាចាន់។ "ខ្ញុំមិនអាចរាប់រណ្តៅអស់ទេ ពីព្រោះមានរណ្តៅជាច្រើន។ មានរណ្តៅតូច និង រណ្តៅធំ។ ឧទាហរណ៍ រណ្តៅមួយដាក់បានសាកសព២ឬ៣ប៉ុណ្ណោះ[795]។

415. ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន បានផ្តល់សក្ខីកម្មថា ចាប់ពីឆ្នាំ១៩៧៧ទៅ ចាំបាច់ត្រូវកប់សាកសពអ្នកដែលស្លាប់ក្នុងពេលសម្លាប់ច្រើនគ្នា ឱ្យហួសពីកន្លែងកប់ចំនួន៣ពីមុននៅបរិវេណទី១ ពីព្រោះ "មានកន្លែងកប់សាកសពជាច្រើននៅបរិវេណទី១រួចទៅហើយ ដូច្នេះគេត្រូវតែកប់នៅ

---

[792] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៧២ បន្ទាត់ ១៩-២០។

[793] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៨៧ បន្ទាត់ ៤-១១។

[794] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/282.1** ទំព័រ ៦៩ បន្ទាត់ ១២-១៥។ *សូមមើលផងដែរ* កំណត់ហេតុស្តាប់ចម្លើយ សយ សែន ឯកសារ **E3/5214** ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៨ KH ERN 00223064។

[795] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/258.1** ទំព័រ ៦៦ បន្ទាត់ ១០-១១។

បរិវេណក្រៅ នៅខាងត្បូងចុងស្រះ"[796]។ ពាក់ព័ន្ធនឹងទំហំរណ្តៅខាងក្រៅបរិវេណទី១ គាត់ប៉ាន់ស្មានថា "ខ្ញុំថាយើងជីករណ្តៅប្រហែល១០ទៅ២០ ហើយរណ្តៅនីមួយៗយើងកប់ ពី១០ទៅ៣០ សាកសពអ្នកទោសដែលត្រូវបានសម្លាប់"[797]។ គាត់ក៏បានផ្តល់សក្ខីកម្មទាក់ទិននឹងការប្រែក្លាយផ្ទះចាស់ មន្ទីរចាស់ ទៅជាផ្ទះដាក់សាកសពវិញ[798]។

## ៦. ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ

416. ភ័ស្តុតាងដើមបណ្តឹងរដ្ឋប្បវេណីដែលលើកឡើងនៅក្នុងសវនាការកំណត់ថា ការឃុំឃាំងដើមបណ្តឹងរដ្ឋប្បវេណី សុយ សែន ការសម្លាប់ឪពុករបស់ដើមបណ្តឹងរដ្ឋប្បវេណី សុយ សែន ការសម្លាប់ឪពុករបស់ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន ការសម្លាប់ជីដូនមួយរបស់ដើមបណ្តឹងរដ្ឋប្បវេណី សូត្រ សាំង ឈ្មោះ បង ជា និង ការសម្លាប់របស់ តាសង្គ្រាច ប៉ាន់ គឺជាអំពើធ្វើទុក្ខបុកម្នេញមកលើអតីតទាហាន លន់ នល់ និង រដ្ឋការរបបសាធារណរដ្ឋ[799]។

417. ដូចដែលបានរៀបរាប់នៅក្នុងផ្នែក ខ(៥) ទាក់ទិននឹងការសម្លាប់ប្រជាជន១៧មេសា និង អតីតទាហាន លន់ នល់ ដើមបណ្តឹងរដ្ឋប្បវេណី សុយ សែន បានផ្តល់សក្ខីកម្មថា "គេទុក អ្នកទោសមូលដ្ឋានយូរជាង។ ចំណែកឯ អ្នក១៧មេសា [ឬ] អ្នកអតីតទាហាន ស័ក្តិ២ឬស័ក្តិ៣ ពួកគេនឹងឃុំឃាំងមិនលើសពី១អាទិត្យឡើយ ហើយអ្នកទោស១៧មេសា មានមួយចំនួនពួកគេទុក យូរជាងនេះ ប៉ុន្តែ ក្រោយមកក៏ត្រូវសម្លាប់ដែរ"[800]។ ចំពោះអ្នក១៧មេសា ឧទាហរណ៍មន្ត្រីជាន់ ខ្ពស់ ពួកគេនឹងត្រូវយកមកទុកនៅខាងក្រៅ នៅត្រង់ចំណុចផ្ទះនោះ ហើយបុគ្គលិកដទៃទៀតនឹង ដាក់ទឹកដូងឱ្យផឹក។ ខ្ញុំឮពី តា ឈឿន និង តា ឆេន។ មានជនរងគ្រោះម្នាក់គឺជាមេបញ្ជាការក្នុង របបមុន។

---

[796] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុយ សែន ប្រតិចារិក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៧៣ បន្ទាត់ ១-២។

[797] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុយ សែន ប្រតិចារិក ថ្ងៃទី៥ ខែមីនា ឆ្នាំ២០១៥ ឯកសារ **E1/282.1** ទំព័រ ៦៨ បន្ទាត់ ២៤-២៥។

[798] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុយ សែន ប្រតិចារិក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ២៩ បន្ទាត់ ២២។

[799] *សូមមើល* ផ្នែក ខ (១) ខ (២) និង ខ(៥)។

[800] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុយ សែន ប្រតិចារិក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៨៣ បន្ទាត់ ១៩-២៤។

ដូច្នេះខ្ញុំឮពី តា ឆេន។ ពួកគេត្រូវគេទុកនៅខាងក្រៅ ហើយបណ្ដោជាខ្សែទៅកន្លែង សម្លាប់ ពួកគេ មិនត្រូវបាននាំចូលក្នុងអគារឃុំឃាំងឡើយ”[801]។

418. ដូចដែលបានរៀបរាប់ខាងលើ ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន បានផ្ដល់សក្ខីកម្មថា “តាមការសង្កេតរបស់ខ្ញុំ ប្រសិនបើអ្នកទោសមានវ័យចំណាស់ ឬអាចគេចោទថាមានទំនាក់ទំនងជាមួយ អតីត របប លន់ នល់ ពួកគេនឹងត្រូវធ្វើទារុណកម្ម”[802]។

## គ. ផលប៉ះពាល់

### ១. ផលប៉ះពាល់ផ្លូវកាយ

419. ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន បានផ្ដល់សក្ខីកម្មអំពីផលប៉ះពាល់រាងកាយភ្លាមៗនិងរយៈពេលវែងដែលគាត់ទទួលរងដោយសារការឃុំឃាំងនៅក្រាំងតាចាន់។

420. ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន បានពន្យល់ថាស្នាមនៅលើកជើងគាត់គឺជានិមិត្តរូបនិងរំលឹកដល់ការឈឺចាប់ផ្លូវការនិងផ្លូវអារម្មណ៍របស់គាត់។ “ដូចដែលខ្ញុំបានថ្លែងកាលពីព្រឹកមិញ ហើយតាមការពិតខ្ញុំមិនចង់ឃើញវាម្ដងទៀតទេ។ ប្រសិនបើអ្នកមើលកជើងខ្ញុំ នៅមានស្នាមមួយនៅឡើយ ហើយមានរយៈពេលជាច្រើនឆ្នាំហើយ ហើយវារំលឹកខ្ញុំឲ្យប្រាប់ដល់ចៅនូវអ្វីដែលបានកើតឡើង។ ថាខ្ញុំឈឺចាប់ដោយសារឧក្រិដ្ឋកម្មបែបនេះ”[803]។ គាត់បានពន្យល់ថារបួសនោះឡើងក្លាយនៅពេលគាត់ត្រូវបានឃុំឃាំងនៅក្រាំងតាចាន់[804]។

[801] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ E1/256.1 ទំព័រ ៨៤ បន្ទាត់ ២-៩។

[802] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៥ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ E1/257.1 ទំព័រ ២១ បន្ទាត់ ៨-១០។

[803] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ E1/256.1 ទំព័រ ៧៥ បន្ទាត់ ២២-២៥។

[804] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ E1/256.1 ទំព័រ ៧៦ បន្ទាត់ ៣-៦។

## ២. ផលប៉ះពាល់ផ្លូវចិត្ត

421. ដើមបណ្តឹងរដ្ឋប្បវេណី សុយ សែន បានផ្តល់សក្ខីកម្ម ដោយរំលឹកអំពីបទពិសោធន៍ដែលគាត់ បាន ឆ្លងកាត់ក្នុងកំលុងពេលឃុំឃាំងនៅក្រាំងតាចាន់ថាបន្តធ្វើឱ្យគាត់ឈឺចាប់រយៈពេលយូរ“នៅពេលខ្ញុំ មិនរំលឹកបទពិសោធន៍ ការឈឺចាប់របស់ខ្ញុំនៅពេលនោះ ខ្ញុំសប្បាយចិត្ត។ ប៉ុន្តែពេលខ្ញុំ ព្យាយាម រំលឹកបទពិសោធន៍អតីតកាល ខ្ញុំដេកមិនលក់ស្រួលទេ។ ខ្ញុំនឹកឃើញ ខ្ញុំមានអារម្មណ៍ថា ដូចជាខ្ញុំ នៅក្រាំងតាចាន់វិញអញ្ចឹង ហើយខ្ញុំបានត្រឹមតែឮគេប្រាប់ថាគួរទៅឡើងយកទឹកត្នោត។ ដូច្នេះខ្ញុំមិន ចង់និយាយអ្វីអំពីការឈឺចាប់របស់ខ្ញុំកាលពីពេលនោះទេ។ តាមពិតខ្ញុំឆ្លងកាត់ការឈឺចាប់លំបាក វេទនា ជាច្រើន នៅពេលនោះ ខ្ញុំភ្លេចខ្លះ នៅចាំខ្លះ ពីព្រោះមកដល់ពេលនេះ គឺ៤១ឆ្នាំហើយ”។

422. ដើមបណ្តឹងរដ្ឋប្បវេណី សុយ សែន បានរៀបរាប់ការឈឺចាប់តាមរយៈការយល់សុបិន្តអាក្រក់ ជាលទ្ធផលនៃអ្វីដែលគាត់បានឆ្លងកាត់។ “ខ្ញុំ -- ពីបញ្ហានៅក្រាំងតាចាន់ ដូចថាមិនចង់នឹកឃើញ សោះទាំងអស់រាល់ថ្ងៃ ទោះបីនៅផ្ទះអ៊ីចឹងដែរ។ ជាប់ការងាររកស៊ីបន្តិចបន្តួច មានកាសែតនេះកា សែតនោះទៅសម្ភាសសួរពីនេះ ពីនោះចុះមានឈ្មោះខ្ញុំនៅហ្នឹង។ បើនៅយុវសន្តិភាព គាត់នៅ កសាងរៀបចំនៅកន្លែងហ្នឹង បន្តិចមកដល់ៗ ខ្ញុំអត់ចង់ឃើញ តែឃើញ ពេលយប់ឡើងខ្ញុំស្រមៃនឹក ឃើញ អ៊ឺ! អញដូចនៅជាប់ក្រាំងតាចាន់អ៊ីចេះ។ឃើញប្រធានប្រើទៅធ្វើនេះធ្វើនោះអីអ៊ីចឹងទៅ ឬ ធ្វើអ៊ីចេះធ្វើអ៊ីចុះអី គឺស្រមៃឃើញរហូត។ បានខ្ញុំអត់ចង់ឃើញទេ ហើយអត់ចង់ដឹង អត់ ចង់ឮទៀតរាល់ថ្ងៃហ្នឹង។ ថាចង់ចំណែកបុគ្គលខ្ញុំតែឯង ចង់បិទចោលមិនឱ្យដឹង មិនឱ្យឮតែម្តង ប៉ុន្តែជៀសៗមិនផុត គេចមិនរួចបាទ”[805]។

### *ការឈឺចាប់ដោយសារការឃុំឃាំងសមាជិកគ្រួសារ*

423. ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន បានផ្តល់សក្ខីកម្មអំពីផលប៉ះពាល់ដែលគាត់ទទួលរងទាក់ ទិននឹងការឃើញឪពុកគាត់ជាប់ឃុំឃាំងនៅក្រាំងតាចាន់។ “មិនប៊ានចូលមិនប៊ានអីទៅជិតគាត់

[805] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុយ សែន ប្រតិចារឹក ថ្ងៃទី៤ ខែកុម្ភៈ ឆ្នាំ២០១៥ ឯកសារ **E1/256.1** ទំព័រ ៥៨ បន្ទាត់ ៤-១០។

ទេ។ ខ្លាច យប់ឡើងឮសូរតែមាត់ស្រែក តែមិនដឹងជាអ៊ីគាត់ដែរ ឬមួយយ៉ាងម៉េច បានត្រឹមឮ បានត្រឹមសោកា"[806]។

## ជំពូក ៣. ការដ្ឋានទំនប់ត្រពាំងថ្ម[807]

### ក. ទិដ្ឋភាពរួមនៃភស្តុតាងពីដើមបណ្តឹងរដ្ឋប្បវេណី

424. ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត, មាន លឿយ, ញឹប ណាល់ និង សែន សុផុន បានផ្តល់សក្ខីកម្មអំពីបទពិសោធន៍របស់ខ្លួននៅការដ្ឋានទំនប់ត្រពាងថ្ម[808]។ ពួកគេម្នាក់ៗមានវត្តមាននៅតាមកងខុសៗគ្នា ក្នុងរយៈពេលផ្សេងៗនៅរវាងចុងឆ្នាំ ១៩៧៦ និងចុងឆ្នាំ ១៩៧៧។

---

[806] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៊ុន សារឿន ប្រតិចារឹក ថ្ងៃទី៣ ខែមេសា ឆ្នាំ២០១៥ ឯកសារ **E1/288.1** ទំព័រ ២៥ បន្ទាត់ ១៤-១៥។

[807] អង្គជំនុំជម្រះសាលាដំបូង ត្រូវបានប្តឹងអំពីអង្គហេតុជុំវិញការបង្កើត និងប្រតិបត្តិការការដ្ឋានទំនប់ត្រពាំងថ្ម ដែលមានទីតាំងស្ថិតនៅក្នុងតំបន់៥ នៃភូមិភាគពាយ័ព្យ។ មានការលើកឡើងថាវាត្រូវបានបែងចែកជាកងនានា ដែលប្រតិបត្តិការទាំងមូលស្ថិតនៅក្រោមការគ្រប់គ្រងរបស់តាវ៉ាល់ រហូតដល់ពេលគាត់ត្រូវបានចាប់ខ្លួននៅក្នុងខែមិថុនា ឆ្នាំ១៩៧៧។ ក៏ភស្តុតាងបង្ហាញថា ខៀវ សំផន បានមកទស្សនកិច្ចការដ្ឋាននេះជាមួយប៉ុល ពត។ កម្លាំងពលកម្ម រួមមានកម្មកររាប់ពាន់នាក់មកពីតំបន់៥នៃភូមិភាគពាយ័ព្យ និងប្រជាជនថ្មី មកពីភ្នំពេញ និងសៀមរាប។ អង្គជំនុំជម្រះ ក៏ត្រូវបានប្តឹងផងដែរអំពីអង្គហេតុទាក់ទងនឹងលក្ខខណ្ឌការងារ និងការរស់នៅនៅការដ្ឋានទំនប់ត្រពាំងថ្ម ព្រមទាំងការបាត់ខ្លួន ការចាប់ខ្លួន ការវាយដំ ឬការសម្លាប់កម្មករ ក្រោយស្ថានភាពផ្សេងៗគ្នា។ ការចោទប្រកាន់លើអង្គហេតុ បានកើតឡើងនៅក្នុងបរិបទនៃការអនុវត្តគោលនយោបាយទីមួយក្នុងចំណោមគោលនយោបាយចំនួនប្រាំទាក់ទងនឹង "ការបង្កើត និងការទាញយកផលប្រយោជន៍ពីសហករណ៍ និងពីការដ្ឋាន តាមរយៈគ្រប់មធ្យោបាយចាំបាច់"។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៣២៧-៣៣៣ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៣៣៣ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៣៣៤-៣៤៥ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៣៤៦-៣៤៩។ ដីកាដំណោះស្រាយ ចោទប្រកាន់ជនជាប់ចោទអំពីឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវបានចោទថាបានកើតឡើងនៅការដ្ឋានទំនប់ត្រពាំងថ្ម ក្នុងអំឡុងដើមចាប់ពីឆ្នាំ១៩៧៦ ដល់ចុងក្រោយបំផុតខែឧសភា ឆ្នាំ១៩៧៨៖ ការធ្វើឱ្យទៅជាទាសករ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់នៃការរំលោភផ្លូវភេទ (ក្នុងបរិបទនៃការរៀបការដោយបង្ខំ) និងអំពើអមនុស្សធម៌ផ្សេងៗទៀត ក្រោមទម្រង់ជាការប៉ះពាល់ដល់ សេចក្តីថ្លៃថ្នូររបស់មនុស្ស អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់នៃការរៀបការដោយបង្ខំ និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៣៧៣ ១៣៧៧ ១៣៨១ ១៣៩១ ១៤១៦ ១៤៣៤ ១៤៤២។ សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី។ ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងសំណុំរឿង០០២/០២ ឯកសារ **E301/9/1.1**។

425. ដើមបណ្ដឹងរដ្ឋប្បវេណី សម ស័ក្ត ដែលជាប្រជាជនថ្មីបានធ្វើការងារក្នុងកងចល័តមួយនៅការដ្ឋានទំនប់ត្រពាំងថ្ម នៅក្នុងឆ្នាំ ១៩៧៧ ហើយគាត់បន្តធ្វើការងារនៅក្នុងកន្លែងនេះរហូតដល់ការដួលរលំនៃរបបនេះ[809]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានគូសបញ្ជាក់ថា គាត់បានធ្វើការងារនៅក្នុងការដ្ឋានទំបន់ត្រពាំងថ្មនេះ ក្នុងបីដំណាក់កាល៖ ក្នុងអំឡុងពេលដំណាក់កាលដំបូង គាត់បានធ្វើការនៅក្រោមទំនប់ ដំណាក់កាលទីពីរ គាត់បានធ្វើការនៅឯស្ពានទីមួយ និងក្នុងដំណាក់កាលទីបី គាត់បានធ្វើការនៅទ្វារទឹក ដែលកន្លែងភ្ជាប់ទៅនឹងទំនប់តូចៗ[810]។

426. ទាក់ទងនឹងសមាសភាពនៃពលករនៅក្នុងការដ្ឋាននេះ ដើមបណ្ដឹងរដ្ឋប្បវេណី សម ស័ក្តបានផ្ដល់សក្ខីកម្មថា ពលករភាគច្រើនគឺជាមនុស្សពេញវ័យដែលមានអាយុចាប់ពី ១៦ ឆ្នាំ រហូលដល់ជិត ៤០ ឆ្នាំ ហើយថា ភាគច្រើនបំផុតនៃពលករទាំងនេះដែលធ្វើការងារក្នុងអង្គភាពចល័ត គឺជាប្រជាជន ១៧ មេសា[811]។ គាត់បានបកស្រាយបន្ថែមទៀតថា បើទោះបីជាភាគច្រើននៃប្រជាជនក្នុងអង្គភាពទាំងនេះគឺជាប្រជាជន ១៧ មេសា ក៏ដោយ ក៏មានប្រជាជនមូលដ្ឋានមួយចំនួនដែលមានតួនាទីផ្សេងៗគ្នា ពោលគឺ ពួកគេធ្វើការត្រួតពិនិត្យការនិយាយស្ដី និងសកម្មភាពនៃពលករទាំងនោះ[812]។ ដើមបណ្ដឹងរដ្ឋប្បវេណី សម ស័ក្តបានរៀបរាប់ថា ក្នុងពេលដែលគាត់បានធ្វើការក្នុងកងចល័ត គាត់បានធ្វើការហួសកម្លាំង គាត់មិនបានដេកគ្រប់គ្រាន់ ហើយគាត់មិនធ្លាប់មានអាហារ

---

[808] ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន៩៩នាក់ ត្រូវបានបញ្ជាក់ថាបានទទួលស្គាល់ដោយ ក.ស.ច.ស (ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ៣៥០) ទាក់ទងនឹងការដ្ឋានទំនប់កំពង់ថ្ម។ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន២នាក់ ត្រូវបានទទួលស្គាល់ដោយ អ.ប.ជ។

[809] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ២៩ បន្ទាត់ ៨-១០ ទំព័រ ៣០ បន្ទាត់ ២ ទំព័រ ៣០ បន្ទាត់ ៨។

[810] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៣០ បន្ទាត់ ២-៧។

[811] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ១៧ បន្ទាត់ ១៣-១៧។

[812] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ១៥ បន្ទាត់ ១៥-១៦។

បរិភោគគ្រប់គ្រាន់ឡើយ[813]។ គាត់ពិពណ៌នាថា ស្បៀងអាហារសម្រាប់អង្គភាពចល័តរបស់គាត់ គឺជាបបរគោក ប៉ុន្តែថា នៅរដូវវស្សា ពួកគេមានបាយសម្រាប់បរិភោគ[814]។

427. ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានរៀបរាប់ពីរបៀបដែលប្រធានក្រុមធ្វើការត្រួតពិនិត្យផែនការការងារដោយផ្ដល់សក្ខីកម្មថា ពួកគេគឺជាអ្នកដែលត្រួតពិនិត្យថាតើផែនការការងារត្រូវបានធ្វើដូចម្ដេច[815]។ គាត់បានពន្យល់ទៀតថា ដងចបត្រូវបានប្រើប្រាស់សម្រាប់វាស់ថាតើផែនការការត្រូវបានធ្វើបានជោគជ័យ ឬអត់[816]។ ប្រធានក្រុមត្រួតពិនិត្យពីលក្ខខណ្ឌការងាររបស់ពួកគេ ហើយបានស្ថិតនៅកន្លែងធ្វើការងារដើម្បីមើលពួកគេដើម្បីឲ្យដឹងថា ពលករបានបំពេញការងារ ពោលគឺជីក និងជញ្ជូនដី[817]។ គាត់បានពន្យល់ថា ការដ្ឋានទំនប់ត្រពាំងថ្មត្រូវបានចាត់ថា "សមរភូមិក្ដៅ" ដូច្នេះ គាត់ត្រូវតែខិតខំធ្វើការងារ មិនថាមេឃភ្លៀង ឬមេឃក្ដៅយ៉ាងណាក៏ដោយ[818]។

428. ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ ដែលជាប្រជាជនមូលដ្ឋាន ត្រូវបានបញ្ជូនទៅការដ្ឋានទំនប់ត្រពាំងថ្ម នៅចុងឆ្នាំ ១៩៧៦[819] យ៉ាងហោចណាស់រហូតដល់ចុងឆ្នាំ ១៩៧៧[820] ហើយជាសមាជិក

---

[813] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ១៤ បន្ទាត់ ១២ ទំព័រ ១៤ បន្ទាត់ ២៣។

[814] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ២៨ បន្ទាត់ ១៣-១៥។

[815] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៣៧ បន្ទាត់ ២-៦។

[816] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៣៧ បន្ទាត់ ៩-១២។

[817] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៣៧ បន្ទាត់ ១៥-១៨។

[818] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៨ បន្ទាត់ ១៥-១៧។

[819] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៤៩ បន្ទាត់ ១។

[820] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៥២ បន្ទាត់ ២១-២៥ ទំព័រ ៥៣ បន្ទាត់ ១-៥ (លើកឡើងថាឆ្នាំ១៩៧៧ គឺជាឆ្នាំដែលសមាជិកគ្រួសាររបស់គាត់ត្រូវបានចាប់ខ្លួន និងសម្លាប់នៅទំនប់ត្រពាំងថ្ម)។

នៃកង ១០០ នាក់ ដែលដឹកនាំដោយមិត្ត ថន[821]។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានរៀបរាប់ថា គាត់ក៏ពុំមានអាហារបរិភោគគ្រប់គ្រាន់ដែរ ដោយគាត់បានពន្យល់ថា ពីដំបូង ពលករត្រូវបានផ្ដល់បានឱ្យបរិភោគបាយម្ដងម្កាល ប៉ុន្តែថា ក្រោយមក ពួកគេបានទទួលបបរគោក[822]។ ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ បានផ្ដល់សក្ខីកម្មថា របបអាហារគឺមួយចានគោមតូចមួយ ហើយថា ពលករទាំងនោះខ្សោយ គ្មានកម្លាំងសោះឡើយ[823]។

429. ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ បានរៀបរាប់ពីរបៀបដែលកង ១០០ នាក់របស់គាត់ បានធ្វើការងារនៅជិតស្ពានទីមួយ ហើយបន្ទាប់មក ត្រូវបានផ្លាស់ប្ដូរទៅភាគខាងជាងជើងនៃស្ពានទី ១ និងទៅធ្វើការងារនៅផ្នែកផ្សេងមួយទៀត[824]។ គាត់បានរៀបរាប់ថាតើលក្ខខណ្ឌការងារមានការលំបាកយ៉ាងណា ដោយបានក្រោកពីដេកទៅធ្វើការ នៅពេលព្រឹកព្រលឹម និងបានសម្រាកយ៉ាងខ្លីនៅវេលាម៉ោង ១១.០០[825]។ ផែនការការងារប្រចាំថ្ងៃគឺត្រូវធ្វើ ៣ ម៉ែត្រគូបដីក្នុងមួយថ្ងៃ[826] ហើយផែនការនេះត្រូវបានកំណត់ប្រធានកង ១០០ នាក់[827]។

[821] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៤៩ បន្ទាត់ ២-៤។

[822] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៥០ បន្ទាត់ ១២-១៦។

[823] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៥០ បន្ទាត់ ១២-១៦។

[824] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៤៩ បន្ទាត់ ២-៤។

[825] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៤៩ បន្ទាត់ ១-៧។

[826] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៤៩ បន្ទាត់ ១-៧។

[827] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៤៩ បន្ទាត់ ១-៧។

430. ទាក់ទងនឹងវេនធ្វើការងារពេលយប់ ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ បានពន្យល់ថា ពួកគេបានចាប់ផ្ដើមធ្វើការងារនៅប្រហែលម៉ោង ៦ ល្ងាច និងបញ្ចប់នៅម៉ោង ១០ យប់[828]។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានពន្យល់ថា ផ្នែកខ្លះនៃទំនប់បានបាក់ ដូច្នេះកម្លាំង "គឺសម្រុកមែន" ដើម្បីជួសជុលទំនប់[829] ហើយថា វេនយប់ត្រូវបានរៀបចំឡើង "គឺពេលការងារសម្រុក" តែប៉ុណ្ណោះ[830]។

431. ដើមបណ្ដឹងរដ្ឋប្បវេណី ញឹប ហាល់ ដែលជាប្រជាជនថ្មី ត្រូវបានបញ្ជូនទៅការដ្ឋានទំនប់ត្រពាំងថ្ម នៅខែ មិថុនា ឆ្នាំ ១៩៧៧ ដើម្បីរែកដីនៅជិតស្ពានទី ១ និងគាត់ជាសមាជិកនៃកងយុវជន ១០០ នាក់ នៅថ្នាក់តំបន់ ដែលគាត់បានធ្វើការងារនៅទីនោះអស់រយៈពេលប្រហែល ៦ ខែ[831]។ គ្មានយុវនារី នៅក្នុងកងរបស់គាត់ទេ ហើយសមាជិកទាំងអស់មកពីភូមិផ្សេងៗគ្នា នៅក្នុងតំបន់ ៥[832]។ ដើមបណ្ដឹងរដ្ឋប្បវេណី ញឹប ហាល់ បានរៀបរាប់ថា ប្រធានកងត្រូវរាយការណ៍ទៅប្រធានការដ្ឋានថា ផែនការការងារប្រចាំថ្ងៃត្រូវបានបំពេញដោយជោគជ័យ ដោយបញ្ជាក់ថា ពួកគេបានចុះវាស់វែងថាផែនការនេះត្រូវបានបំពេញរួចរាល់[833]។

432. ដើមបណ្ដឹងរដ្ឋប្បវេណី ញឹប ហាល់ បានរៀបរាប់ថា ពលករម្នាក់ៗត្រូវបានផ្ដល់ឲ្យបង្គី និងចបមួយ[834] ហើយត្រូវកាប់ដីឲ្យបាន ៥ ម៉ែត្រគូបក្នុងមួយថ្ងៃ[835]។ ពួកគេត្រូវដើរប្រមាណជា ៣០ ទៅ

---

[828] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៦៥ បន្ទាត់ ៧-៨។

[829] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៦៥ បន្ទាត់ ៩-១០។

[830] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៦៨ បន្ទាត់ ១៥។

[831] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ញឹប ហាល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ៧ បន្ទាត់ ៥-១០ ទំព័រ ៧ បន្ទាត់ ១៨-១៩ ទំព័រ ៨ បន្ទាត់ ៩-១០ ទំព័រ ១៣ បន្ទាត់ ៨-១០ ទំព័រ ១៣ បន្ទាត់ ២១។

[832] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ញឹប ហាល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ៨ បន្ទាត់ ៩-១០។

[833] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ញឹប ហាល់, ប្រតិចារឹក, ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥, ឯកសារ **E1/336.1,** ទំព័រ ១១ បន្ទាត់ទី ១-៥។

[834] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ញឹប ហាល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ៧ បន្ទាត់ ១៧-១៨។

៥០ ម៉ែត្រពីកន្លែងជីកដី ទៅកន្លែងចាក់ដី[836]។ ប្រធានកង ១០០ នាក់ ត្រូវរាយការណ៍ទៅប្រធានការដ្ឋានសាងសង់អំពីផែនការការងារប្រចាំថ្ងៃ[837]។ ពលករពុំមានម៉ោងធ្វើការងារដែលមានការកំណត់ច្បាស់លាស់ទេ ប៉ុន្តែជាទូទៅ ពេលខ្លះ ត្រូវក្រោកពីដេកនៅម៉ោង ៣ ព្រឹក ហើយត្រូវធ្វើការរហូតដល់បំពេញតាមផែនការកំណត់ ពេលខ្លះ ក្រោយម៉ោង ៤ ឬម៉ោង ៥ ល្ងាច[838]។

433. ដើមបណ្តឹងរដ្ឋប្បវេណី ញ៉ឹប ហាល់ បានរៀបរាប់ពីលក្ខខណ្ឌការងារ ដែលគាត់បានឆ្លងកាត់។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបាននិយាយថា ពលករបានរស់ក្នុងរោងប្រកស្លឹកដោយមានពលករចំនួន ១០០ នាក់ និងមានទីតាំងចំនួនមួយគីឡូម៉ែត្រពីការដ្ឋាន[839]។ ពលករត្រូវបានផ្តល់របបបបរមួយកូនចាននៅថ្ងៃត្រង់ ដែលចំនួនមិនគ្រប់គ្រាន់ឡើយ បើប្រៀបធៀបនឹងលក្ខខណ្ឌការងារ[840] ហើយពួកគេបានទៅលួចទៅជីកម្ទើមរុក្ខជាតិដើម្បីបរិភោគ[841]។ ពលករដែលមានជំងឺត្រូវបានផ្តល់ឱ្យនូវ

---

[835] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ញ៉ឹប ហាល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ៨ បន្ទាត់ ២៤-២៥។

[836] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ញ៉ឹប ហាល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ១៩ បន្ទាត់ ៨-១១។

[837] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ញ៉ឹប ហាល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ១០ បន្ទាត់ ១៤-១៥។

[838] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ញ៉ឹប ហាល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ២៤ បន្ទាត់ ៣-៦។

[839] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ញ៉ឹប ហាល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ៧ បន្ទាត់ ២៣ ដល់ទំព័រ ៨ បន្ទាត់ ៣។

[840] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ញ៉ឹប ហាល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ១១ បន្ទាត់ ១៤-១៥ បន្ទាត់ ២២។

[841] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ញ៉ឹប ហាល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ៨ បន្ទាត់ ទំព័រ ២៥ បន្ទាត់ ២២-២៣។

របបអាហារតិចជាងពលករមិនឈឺ[842]។ ពួកគេពុំមានសម្លៀកបំពាក់សមស្របឡើយ ហើយគេមានតែគ្រែឫស្សីសម្រាប់ដេកតែប៉ុណ្ណោះ[843]។

434. ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ដែលជាប្រជាជនថ្មី ត្រូវបានចាត់តាំងដោយប្រធានសហករណ៍ឱ្យទៅចូលរួមក្នុងកងចល័ត ៧០ នាក់[844] នៅទំនប់ត្រពាំងថ្ម នៅឆ្នាំ ១៩៧៧ ដើម្បីសាងសង់អាងទឹកត្រពាំងថ្ម។ គាត់ស្ថិតនៅក្នុងតំបន់ ៥ ចំណុះភូមិភាគពាយ័ព្យ[845]។ គាត់បានស្នាក់នៅកន្លែងនោះ អស់រយៈពេលពីរខែ មុនពេលគាត់ត្រូវបានចាត់តាំងឱ្យទៅធ្វើការ នៅទីតាំងផ្សេងទៀត[846]។ ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន បានបញ្ជាក់ថា ការដ្ឋានទំនប់ត្រពាំងថ្មមានពលកររាប់ពាន់នាក់[847] ដោយមានបុរស និងស្ត្រីដែលមានអាយុពី ១៨ ទៅ៣០ ឆ្នាំ។

435. ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន បានរៀបរាប់ពីលក្ខខណ្ឌការងារនៅកន្លែងសាងសង់ទំនប់ត្រពាំងថ្ម៖ កងចល័តត្រូវធ្វើការពីម៉ោង ៤ ព្រឹក រហូតដល់ម៉ោង ១១៖៣០ ហើយពីម៉ោង ១៖00 រហូតដល់ម៉ោង ៩៖00 ឬ ១០៖00 យប់[848] ហើយត្រូវជីកតាមផែនការបីម៉ែត្រគូបក្នុងមួយថ្ងៃ។

---

[842] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ញឹប ហល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ១៣ បន្ទាត់ ៤-៦។

[843] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ញឹប ហល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ២២ បន្ទាត់ ២៣-២៥ ទំព័រ ២៣ បន្ទាត់ ១។

[844] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៥៦ បន្ទាត់ ២៣-២៤ ២៥ ដលទំព័រ ៥៧ បន្ទាត់ ១។ កងនោះមានឈ្មោះថា “កង១០០”។

[845] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៥៧ បន្ទាត់ ៨។

[846] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៣៣ បន្ទាត់ ៧-១២ ទំព័រ ៣៥ បន្ទាត់ ៤-៨។

[847] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៤៨ បន្ទាត់ ១៦។

[848] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៣៣ បន្ទាត់ ១៨-២៣។

ប្រសិនបើពួកគេមិនអាចធ្វើការតាមផែនការការងារនេះទេ ពួកគេត្រូវបង្អត់អាហាររហូតដល់ម៉ោង ១០[849]។ សម្ភារៈធ្វើការងារដែលពួកគេមានគឺបង្គី ដងរែក និងចប[850]។

436. ដើមបណ្ដឹងរដ្ឋប្បវេណី សែន សុផុន បានរៀបរាប់ពីស្ថានភាពសុខភាពរបស់ពលករ ដោយបានផ្ដល់សក្ខីកម្មថា ការដ្ឋាននេះពុំមានថ្នាំសម្រាប់ព្យាបាលពលករដែលឈឺឡើយ[851] ហើយថា ពុំមានអាហារ[852] ឬទឹក[853]គ្រប់គ្រាន់សម្រាប់បរិភោគឡើយ។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានពន្យល់ថា ពលករអាចបរិភោគបីពេលក្នុងមួយថ្ងៃ នៅពេលដំបូង ប៉ុន្តែក្រោយមក ពួកគេត្រូវបានអនុញ្ញាតឲ្យបរិភោគតែបបរគោកពីរពេលប៉ុណ្ណោះក្នុងមួយថ្ងៃ[854]។

## ខ. ភ័ស្តុតាងនៅកន្លែងកើតហេតុ ដែលដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់ឲ្យក្នុងពេលសវនាការ

### ១. ការធ្វើឲ្យនៅជាទាសករ

437. ភ័ស្តុតាងពីដើមបណ្ដឹងរដ្ឋប្បវេណីដែលបានលើកឡើងក្នុងសវនាការបង្ហាញថា ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានធ្វើការងារនៅការដ្ឋានទំនប់ត្រពាំងថ្ម បានក្លាយជាជនរងគ្រោះពីការប្រើប្រាស់អំណាចណាមួយ ឬអំណាចទាំងអស់ ដែលរំលោភលើសិទ្ធិផ្ទាល់ខ្លួនរបស់បុគ្គល។

#### ១.១. ការងារដោយបង្ខំ

[849] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៥០ បន្ទាត់ ៨-៩។

[850] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៤៩ បន្ទាត់ ២០។

[851] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៣៦ បន្ទាត់ ៧-៩។

[852] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៣៥ បន្ទាត់ ១២-១៣។

[853] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៣៥ បន្ទាត់ ២០-២២។

[854] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៥៨ បន្ទាត់ ៥-៨។

438. ដើមបណ្ដឹងរដ្ឋប្បវេណី សម ស័ក្ត បានប្រដូចបទពិសោធន៍របស់គាត់នៅការដ្ឋានទំនប់ត្រពាំងថ្មទៅនឹងបទពិសោធន៍របស់សត្វ។ គាត់បានផ្ដល់សក្ខីកម្មថា បើ "ខ្ញុំបើនិយាយពីរឿងផលប្រយោជន៍និងកម្លាំង ជំនាន់នោះខ្ញុំដូចជាសត្វមួយក្បាលទៅចុះ ចាត់ទុកជាសត្វមួយក្បាលទៅចុះ គេប្រើអីធ្វើហ្នឹងៗ។ ចំពោះផលប្រយោជន៍ ដែលថាទំនប់នោះ សម្រេចដោយលទ្ធផល ឬយ៉ាងណានោះ ខ្ញុំអត់ដឹង ផែនការរបស់អង្គការ ខ្ញុំអត់ដឹង ខ្ញុំអត់បានដឹង ប៉ុន្តែខ្ញុំនេះដូចជាសត្វមួយក្បាលដែលគេសម្រាប់ប្រើ មិនដឹងជាថ្ងៃណាស្លាប់ មិនដឹងជាថ្ងៃណារស់ ព្រោះជំនាន់នោះអត់ដឹងទេ អត់ដឹងខ្លួនឯងថ្ងៃស្លាប់ថ្ងៃណា ដឹងៗអានេះរស់ ស្អែកមិនដឹងយ៉ាងម៉េចទេ អត់ដឹង យើងអត់ដឹងមុន ជំនាន់នោះយើងអត់ដឹងមុនទេ អាការស្លាប់នោះអត់ដឹងមុនទេ។ ដឹងថ្ងៃហ្នឹងរស់ ឬមួយល្ងាចស្លាប់ ក៏យើងមើលមិនដឹង អត់ដឹងថាគេតម្រូវការយើងធ្វើរម៉ាន យើងក៏មិនដឹង។ ប៉ុន្តែទំនប់អាងត្រពាំងថ្មខ្ញុំក៏មិនដឹងថាគោលបំណងគេធ្វើហ្នឹងដើម្បីអី ក៏ខ្ញុំមិនដឹង ព្រោះខ្ញុំនៅក្មេង ហើយយើងមិនចាប់អារម្មណ៍ថាគេធ្វើដើម្បីធ្វើអី យើងគេធ្វើនេះដើម្បីធ្វើអី យើងក៏មិនដឹងដែរ អត់ដឹងៗ ដឹងត្រឹមតែថាធ្វើស្រែប្រាំងទៅ ដឹងតែប៉ុណ្ណឹង រឿងស្រែប្រាំងដឹង អារឿងហ្នឹង។ អារឿងផលប្រយោជន៍ទៅមុខទៀត ខ្ញុំអត់ដឹង"[855]។

439. ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ បានផ្ដល់សក្ខីកម្មថា "ចំពោះយើងខ្ញុំផ្ទាល់ ហើយនិងបងប្អូនយើងទាំងអស់ ដែលយើងលើកអាងត្រពាំងថ្ម មិនមានការពេញចិត្ត និងសប្បាយរីករាយទេ ព្រោះថាធ្វើនេះ ធ្វើទៅតាមមាគ៌ាដែលអង្គការហ្នឹងដាក់ទិសចំ។ បើយើងមិនធ្វើ ខ្លាចស្លាប់"[856]។

440. ដើមបណ្ដឹងរដ្ឋប្បវេណី ញ៉ិប ហាល់ បានពន្យល់ថា "ព្រឹកឡើងគឺ គេដាស់ៗឲ្យទៅធ្វើដល់ពេលព្រឹកឡើងដាស់ទៅ។ ជួនកាលម៉ោងបួនទៅ ជួនកាលម៉ោងប្រាំទៅតាមអាដែង និយាយទៅទិសអង្គការគេ ស្រេចគេប្រាប់ឲ្យធ្វើម៉ោងប៉ុន្មាន យើងត្រូវតែទៅឲ្យរួច"[857]។

## ១.២. ការគ្រប់គ្រង

[855] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ១៥-១៦ បន្ទាត់ ១៧-២។

[856] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៥៣ បន្ទាត់ ១៦-១៨។

[857] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ញ៉ិប ហាល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ១១ បន្ទាត់ ២១-២៣។

### i. ការគ្រប់គ្រងផ្លូវចិត្ត

*ការបង្កើតឱ្យមានបរិយាកាសនៃការភ័យខ្លាច*

441. ដើមបណ្តឹងរដ្ឋប្បវេណី ញ៉ឹប ហាល់ បានផ្តល់សក្ខីកម្មថា គាត់បានបំពេញតាមផែនការការងារ ពីព្រោះ "ការខ្លាចនេះ ខ្លាចគេយកទៅសម្លាប់ចោលតែម្តង។ ខ្លាចវិន័យរបស់ទិស របស់អង្គការ "[858]។ គាត់បានពន្យល់ថា គាត់ "ឮតែតាមអង្គការគេថា កង់ប្រវិត្តសាស្ត្រ ដូចថាយើងវិលមិនទាន់គេ។ ពេលប្រជុំហ្នឹង គេចេះតែអប់រំ អំពីការគោរពវិន័យអង្គការចាត់តាំង ប្តេជ្ញាចិត្ត ខ្លាចតាមគេនិយាយបាទ"[859]។

442. ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ បានរៀបរាប់ថាតើពលករត្រូវបានគេថាជាខ្មាំងយ៉ាងណា ប្រសិនបើធ្វើឱ្យបាត់ ឬខូចបង្គី ឬសម្ភារៈពលកម្ម។ គាត់បានផ្តល់សក្ខីកម្មថា "ឧទាហរណ៍ដូចជា បង្គី ដងរែក ចបកាប់ គឺអ្នកត្រូវរក្សាឱ្យបាន។ តែបាត់បង្គីមួយ គេចោទយើងថាខ្មាំង។ បាក់ដងរែក សម្រាប់រែក គេចោទយើងថាខ្មាំង។ ត្រឹមចបកាប់បាក់ ក៏គេចោទថាខ្មាំងដែរ"[860]។ គាត់បានពន្យល់ថា "មានតែមេកងហ្នឹង ជាអ្នកដើរមើល ហើយមេកងជាអ្នកដើរត្រួតពិនិត្យ ដឹងថាចបបាត់ ឬក៏ចបបាក់ បង្គីរហែក បង្គីដាច់ដៃ បាក់ដងរែកមិនធ្វើ។ គេហើយជាអ្នកដើរមើល"[861]។

443. ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ក បានផ្តល់សក្ខីកម្មថាតើគាត់ត្រូវបានត្រឡប់ទៅធ្វើការងារវិញភ្លាម ឬយ៉ាងណា បន្ទាប់ពីធ្លាក់ខ្លួនឈឺ "ខ្លាចថ្នាក់លើចាប់កំហុស ខ្លាចគេថាយើងធ្វើពុត។ ព្រោះយើងគ្រុន យើងហូបបាយបាន ហូបបបរបាន គេមានទ្រឹស្តីគេមួយ ជំនាន់នោះគេមានទ្រឹស្តីគេថាអីចេះ ដល់យើងហូបបាយបាន គេមានទ្រឹស្តីគេថាអីចេះបានខ្ញុំខ្លាច គេថា "គ្រុនញាក់គ្រាន់ញ័រ គ្រុន

[858] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ញ៉ឹប ហាល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ២៦ បន្ទាត់ ១៨។

[859] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ញ៉ឹប ហាល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ២៦ បន្ទាត់ ២០-២១។

[860] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៦៣ បន្ទាត់ ១៥-១៧។

[861] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៦៣ បន្ទាត់ ២០-២២។

អាត្រាក់ទ័រ គ្រុនឡាន គ្រុនបាយបាន គ្រុនសតិអារម្មណ៍” ភាសានេះហើយដែលឲ្យខ្ញុំខ្លាច ខ្ញុំខ្លាចភាសាហ្នឹង។ តែយើងហូបបាយបាន គឺថាយើងគ្រុនសតិអារម្មណ៍ហើយ”[862]។

444. ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ បានអះអាងថា ប្រធានកងបានប្រើប្រាស់ឃ្លាថា “ទុកក៏មិនចំណេញ ដកចេញក៏មិនខាត” នៅការដ្ឋានទំនប់ត្រពាំងថ្ម[863]។ គាត់បានពន្យល់ថា ប្រធានកងនិយាយឃ្លានេះ “ពេលណាដែលមានអ្នកជំងឺឈឺច្រើន”[864] និងថា និយាយឃ្លានៅ “ពេលគេប្រជុំរួមគឺគេនិយាយជាមួយកងចល័តទាំងអស់ហ្នឹង។ ក្នុងកង១០០នាក់ហ្នឹងគេនិយាយឲ្យឮទាំងអស់គ្នាតែម្តង”[865]។

445. ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន បានរំលឹកថា នៅការដ្ឋានទំនប់ត្រពាំងថ្ម ពលករត្រូវបានផ្តល់ព័ត៌មានថា ការមិនគោរពបទបញ្ជាអាចទទួលរងទណ្ឌកម្មស្លាប់។ “មេកងគេប្រជុំ តែនេះគេចាប់ផ្តើមប្រជុំ។ គេប្រជុំថា តើអ្នកណាហ៊ានរឹងទទឹងនឹងអង្គការ យកទៅវ៉ៃចោល”[866]។

446. ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ក បានផ្តល់សក្ខីកម្មថា “ខ្ញុំអត់ភ្លេចទេភាសាសុភាសិតរបស់ជំនាន់នោះ។ សុភាសិតរបស់គេនោះ គេថាអ៊ីចឹង ខ្ញុំខ្លាច។ អ៊ីចឹងបានខ្ញុំខំប្រឹងៗធ្វើទាំងៗឈឺទាំងជាដើម្បីជីវិតៗ ប៉ុន្តែជំនាន់នោះខ្ញុំមិននឹងស្មានថាខ្ញុំបានរស់នៅ រស់រៀនដល់សព្វថ្ងៃទេ ខ្ញុំគ្មានរំពឹងទេដឹងតែរស់ថ្ងៃនេះមួយថ្ងៃ ស្អែកមិនដឹងយ៉ាងម៉េច ខ្ញុំអត់ដឹងទេ អត់ដឹងថាខ្លួនឯងស្អែករស់ មិនរស់អត់ដឹងៗទុកជាមុន អត់ដឹង។ មិនដឹងឈឺស្លាប់ ឬមួយមិនដឹងយើងនិយាយខុស គេយកទៅសម្លាប់ក៏

[862] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ក ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៨ បន្ទាត់ ១២-១៥។

[863] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៦៣ បន្ទាត់ ១១-១២។

[864] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៦៣ បន្ទាត់ ១។

[865] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៦៨ បន្ទាត់ ១-២។

[866] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៥៥ បន្ទាត់ ២៣-២៤។

យើងមិនដឹង ប៉ុន្តែខ្ញុំខ្លាចណាស់ មិនហ៊ាននិយាយស្អីទាំងអស់ ចាត់ទុកដូចជាមនុស្សគអ៊ីចឹង អត់ហ៊ាននិយាយអីទាំងអស់។ បងខ្ញុំផ្តែផ្តាំថា អ្អែងកុំនិយាយអីឲ្យសោះណា ផ្តេសផ្តាសឲ្យសោះ"[867]។

### *ការពិនិត្យតាមដាន និងតួនាទីប្រជាជនមូលដ្ឋាន*

447. ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត បានពន្យល់ថា "កងចល័តត្រពាំងថ្ម គឺថាគេមើលដែរ។ គឺពីមុនយើងទៅធ្វើការ គេមើលយើងដែរ សមត្ថភាពយើងដែរ តើយើងអាចធ្វើកើតដែរអត់ គេមើលដែរ គេមើល។ បាទ គេមើល។ តែរឿងថា ធ្វើមិនហើយហ្នឹងគេធ្វើយ៉ាងម៉េច គឺថាខ្ញុំអត់ដឹងដែរហ្នឹង ពេលហ្នឹងអត់ដឹងៗ។ អត់បានដឹងទេ"[868]។

448. ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន បានផ្តល់សក្ខីកម្មថា "មេក្រុមនៅជាប់នៅហ្នឹងខ្លួន តែមេកងគាត់ដើរទៅដើរមក។ ខ្ញុំមិនសូវឃើញជាប់ទេ ជួនកាល ដើរមកមើលហើយទៅបាត់ៗ"[869]។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានពន្យល់ថា "មេក្រុមជាអ្នកផ្ទៀងផ្ទាត់ ហើយប្រាប់មកមេកង" ហើយថា "គេកាច់ឈើវាស់ វាស់ជាម៉ែត្រៗ"[870]។ ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ក៏បានថ្លែងផងដែរថា "មានមូលដ្ឋានគេមានដែរ មិនអត់ទេមាន តែមូលដ្ឋានហ្នឹងគេយកតែថ្នាក់ គេហៅថាមើលយើង មើលការខុសត្រូវយើង ខុសត្រូវអីគេមើលលើយើង និយាយខុសនិយាយត្រូវអីគេមើលលើយើង ប៉ុណ្ណឹង។ បើយើងពួក១៧មេសានេះ ដូចតែគ្នាទាំងអស់ ចិត្តមិនខុសពីគ្នាទេ"[871]។

### *តួនាទីនៃកិច្ចប្រជុំរៀនសូត្រឡើងវិញ*

---

[867] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៨ បន្ទាត់ ១៥-២១។

[868] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ២០ បន្ទាត់ ៧-៩។

[869] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/324.1** ទំព័រ ២៦ បន្ទាត់ ១៣-១៤។

[870] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/324.1** ទំព័រ ២៦ បន្ទាត់ ១៩-២២។

[871] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ១៦ បន្ទាត់ ១០-១២។

449. ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត បានផ្តល់សក្ខីកម្មពីបទពិសោធន៍របស់គាត់នៅក្នុងកិច្ចប្រជុំទិតៀន និងស្វ័យទិតៀន ដោយបញ្ជាក់ថា "ស្វ័យទិតៀនហ្នឹង ខ្ញុំធ្លាប់ប្រជុំស្វ័យទិតៀនក្នុងកង ក្នុងពួក ក្នុងពួកវាមិនដឹងទេ បាទ មានបីនាក់ ប្រាំមួយនាក់មិនដឹងទេ ខ្ញុំភ្លេចទៅ ខ្ញុំភ្លេច តែខ្ញុំគេមានគេហៅខ្ញុំទិតៀនខ្ញុំ បានខ្ញុំដឹង។ ឧបមាថា ខ្ញុំធ្វើការ ខ្ញុំធ្វើអត់ហើយទេ ខ្ញុំរែកអត់ហើយ អ៊ីចឹងខ្ញុំសល់"[872]។

450. ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ បានបកស្រាយថា "ចំពោះទិតៀន ស្វ័យទិតៀនហ្នឹង គឺមេកងជាអ្នកហៅយើងទៅ ឧទាហរណ៍ថា ក្រុម ១០នាក់ ត្រូវខុសក្នុងថ្ងៃនេះ គឺលើកមិនរួចទេ។ គេហៅទៅប្រជុំលើកទិតៀនអំពីយើងធ្វើមិនប្រឹងប្រែង មិនធ្វើពលកម្ម ហើយយើងត្រូវខំប្រឹង។ បើមិនប្រឹងប្រយ័ត្នអង្គការថា "ទុកក៏មិនចំណេញ ដកចេញក៏មិនខាត"។ ពាក្យទាំងអស់នេះ ឮហើយ ដឹងតែពីខ្លាចហើយ"[873]។ សម្រាប់គាត់ ពាក្យស្លោកនេះមានន័យថា "បុគ្គលនាដែលប្រព្រឹត្ត មិនប្រព្រឹត្តតាមមាគ៌ារបស់អង្គការ គឺថាគេមិនទុកតែម្តង គេយកទៅសម្លាប់ចោល"[874]។

451. "ការធ្វើការនោះហើយ ពេលណាដែលមិនហើយ គេហៅយើងទៅទិតៀន។ ទៅទិតៀនម្តង ពីរដងតែបីដង គឺពិបាក"[875]។ ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ បានបញ្ជាក់ថា "បើសិនណាជាគេទិតៀនម្តង ទៅពីរដង យើងធ្វើមិនរួច យើងមិនអនុញ្ញាតប្រឹងប្រែង មានតែបាត់ខ្លួន។ បាត់ខ្លួន គឺគេយកទៅសម្លាប់ចោល គេយកទៅរៀនសូត្រ"[876]។

## ii. ការគ្រប់គ្រងជីវិតគ្រួសារ

[872] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ១៨ បន្ទាត់ ២២ ដល់ទំព័រ ១៩ បន្ទាត់ ៣។

[873] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៦៣ បន្ទាត់ ៨-១២។

[874] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៦៨ បន្ទាត់ ១០-១១។

[875] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៥២ បន្ទាត់ ១១-១២។

[876] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៥២ បន្ទាត់ ១៦-១៧។

452. ដើមបណ្ដឹងរដ្ឋប្បវេណី សែន សុផុន បានផ្ដល់សក្ខីកម្មថា គាត់មិនត្រូវបានគេអនុញ្ញាតឱ្យទៅលេងផ្ទះ ដោយពន្យល់ថា "ខ្ញុំមិនហ៊ានទៅដោយសារអី ដោយសារខ្លាចស្លាប់ តែយើងរឹងទទឹងនឹងអង្គការ គេយកទៅវ៉ៃចោល"[877]។ គាត់បានដឹងពីបញ្ហានេះ តាមរយៈ "មេកងគេប្រជុំ តែនេះគេចាប់ផ្ដើមប្រជុំ។ គេប្រជុំថា តើអ្នកណាហ៊ានរឹងទទឹងនឹងអង្គការយកទៅវ៉ៃចោល"[878]។

## iii. ការគ្រប់គ្រងលើការរួមភេទ

453. ដូចបានលើកឡើងនៅក្នុងជំពូក ១១ ស្ដីពីអាពាហ៍ពិពាហ៍ដោយបង្ខំ ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ បានផ្ដល់សក្ខីកម្មអំពីបទពិសោធន៍របស់គាត់ដែលគាត់បានរៀបការនៅជិតការដ្ឋានទំនប់ត្រពាំងថ្ម[879]។

## ១.៣. ការប្រព្រឹត្តិមកលើ និងការរំលោភបំពានដោយឃោរឃៅ៖ ការមិនឱ្យបរិភោគជាទម្រង់មួយនៃទណ្ឌកម្ម

454. ដើមបណ្ដឹងរដ្ឋប្បវេណី សម ស័ក្ដ បានពន្យល់ថា "ការងារកងចល័ត គឺថាយើងគ្មានថាតូច គ្មានថាធំទេ។ ការងារបែងចែកស្មើគ្នា។ បើយើងធ្វើឱ្យគេមិនគ្រប់ទេ គេនឹងកាត់របបយើង"[880]។ "ចុះខ្ញុំនៅតូចជាងគេ ខ្ញុំអង្គុយយំៗ។ តូចចិត្តខ្លួនឯងធ្វើអត់ហើយ"[881]។

455. ចំណុចនេះគឺស្របគ្នាទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណី សែន សុផុន ដែលបានផ្ដល់សក្ខីកម្មថា "ខ្ញុំរែកអត់គ្រប់ ៣ម៉ែត្រគូប ខ្ញុំអត់បានបាយហូបទេ។ ខ្ញុំនៅរហូតទាល់តែម៉ោងដប់ បានគេរំសាយឱ្យ

---

[877] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៥៥ បន្ទាត់ ២០-២១។

[878] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៥៥ បន្ទាត់ ២៣-២៤។

[879] *សូមមើល* ជំពូក១១៖ ការដាក់បទបញ្ញាអំពីការរៀបអាពាហ៍ពិពាហ៍។

[880] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សម ស័ក្ដ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ១១ បន្ទាត់ ៦-៧។

[881] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សម ស័ក្ដ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ១១ បន្ទាត់ ១០-១១។

ទៅសម្រាក ម៉ោងដប់យប់"[882]។ គាត់បានបកស្រាយបន្ថែមទៀតថា "អត់មានកម្លាំងទេ អត់មានកម្លាំងធ្វើការទេ ប៉ុន្តែចេះតែទ្រាំ ធ្វើដោយបង្ខំចិត្ត។ ធ្វើបានប៉ុនណា យកប៉ុណ្ណោះ បើថាគេមិនឲ្យបាយស៊ី ក៏សុខចិត្តទ្រាំអត់ ចេះតែធ្វើទៅ ព្រោះអីគេឲ្យធ្វើ"[883]។

456. ដើមបណ្ដឹងរដ្ឋប្បវេណី សម ស័ក្ត បានផ្ដល់សក្ខីកម្មថា "រែក៣ម៉ែត្រគូប ៣ម៉ែត្រដូចគ្នា ២ម៉ែត្រ ២ម៉ែត្រដូចគ្នា។ វាគ្មានឲ្យយើងចេះសាមគ្គីគ្នាទេ អត់ទេ។ បើអ្នកឯងធ្វើមិនហើយ គេកាត់របប"[884]។ គាត់បានពន្យល់ថា "ការងារកងចល័ត គឺថាយើងគ្មានថាតូច គ្មានថាធំទេ។ ការងារបែងចែកស្មើគ្នា។ បែងចែកស្មើគ្នា។ បើយើងធ្វើឲ្យគេមិនគ្រប់ទេ គេនឹងកាត់របបយើង។ ក្នុងក្រុមនោះគេកាត់របបយើង។ ទោះបីមួយចុងស្លាបព្រាក៏ដោយ មួយស្លាបព្រាក៏ដោយ គេកាត់ពីយើងទៅឲ្យអ្នកធ្វើការហើយនោះ គេទៅឲ្យអ្នកដែលធ្វើការជាមួយយើងនោះ ដាក់បន្តិចៗទៅ ឲ្យម៉េចឲ្យដាច់ពាក់កណ្ដាលរបបយើង។ ហើយពេលនោះខ្ញុំមកហើយ អង្គុយយំ។ ចុះខ្ញុំនៅតូចជាងគេ ខ្ញុំអង្គុយយំៗ។ តូចចិត្តខ្លួនឯងធ្វើអត់ហើយ។ ក៏ប៉ុន្តែយូរៗទៅ ខ្ញុំធ្វើដូចគេដូចឯងអ៊ីចឹង ដូចគេដូចឯង"[885]។

457. ដើមបណ្ដឹងរដ្ឋប្បវេណី សែន សុផុន បានផ្ដល់សក្ខីកម្មថា "មានអ្នកខ្ជិល អ្នកខ្ជិលគេអត់ឲ្យហូបបបរទេ គេអត់ឲ្យហូប បើអ្នកឈឺបានគេឲ្យហូប"[886]។

458. ដើមបណ្ដឹងរដ្ឋប្បវេណី ញ៉ិប ហល់ បានផ្ដល់សក្ខីកម្មថា "អ្នកឈឺកាលនោះ គឺគេកាត់បន្ថយខ្លះបាទ។ ឧទាហរណ៍ថា គេវាស់ឲ្យអ្នកធ្វើការពេញទៅ អ្នកឈឺក៏អាចកាចទេ"[887]។

---

[882] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៥៣ បន្ទាត់ ១០-១១។

[883] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៥៤ បន្ទាត់ ១០-១១។

[884] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៩ បន្ទាត់ ២៣-២៤។

[885] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ១១ បន្ទាត់ ២៣ បន្ទាត់ ៦-១១។

[886] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៥៥ បន្ទាត់ ៥។

## ២. អំពើអមនុស្សធម៌ផ្សេងៗទៀត

459. ភ័ស្តុតាងពីដើមបណ្តឹងរដ្ឋប្បវេណីដែលបានធ្វើឡើងនៅពេលសវនាការបង្ហាញថា ទង្វើរបស់អង្គការក្នុងការបង្កើត និងប្រតិបត្តិសហករណ៍ និងការដ្ឋាន ក្នុងនោះរួមទាំងការដ្ឋានទំនប់ត្រពាំងថ្មផង ក្នុងគោលបំណងឲ្យប្រជាពលរដ្ឋធ្វើការងារ ព្រមទាំងតាមដាន អប់រំកែប្រែ និង "កម្ទេច" ខ្មាំង គឺជាការរំលោភបំពានសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការរស់រានមានជីវិត និងសិទ្ធិទទួលបានកម្រិតជីវភាពគ្រប់គ្រាន់ សិទ្ធិក្នុងការមិនប្រឈមទៅនឹងការប្រព្រឹត្តិកាចសាហាវ អមនុស្សធម៌ និងបន្ទាបបន្ថោក និងមិនត្រូវបានចាប់ខ្លួនដោយគ្មានការជំនុំជម្រះ[888]។ ទង្វើទាំងនេះត្រូវបានប្រកាសថាជាសកម្មភាពដែលមានលក្ខណៈ និងស្ថានទម្ងន់ដូចគ្នានឹងឧក្រិដ្ឋកម្មផ្សេងៗទៀតប្រឆាំងនឹងមនុស្សជាតិ និងបណ្តាលឲ្យ ដើមបណ្តឹងរដ្ឋប្បវេណីទទួលរងព្យសនកម្មធ្ងន់ធ្ងរ ឬជាការវាយប្រហារលើសេចក្តីថ្លៃថ្នូរជាមនុស្សរបស់ពួកគេ។

### ២.១. លក្ខខណ្ឌការងារ

460. ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត បានផ្តល់សក្ខីកម្មថា "ធ្វើការឲ្យគេជំនាន់នោះ គឺថាធ្វើៗខ្លាំងមំណាស់ ធ្វើគឺអាងទំនប់ត្រពាំងថ្មអ៊ីចឹង ចាត់ទុកជា។ សមរភូមិក្តៅមួយហើយជំនាន់នោះ សមរភូមិក្តៅ។ ធ្វើមិនដឹងថាភ្លៀង មិនដឹងថាក្តៅ វន្ទះផ្គរវន្ទះ អត់មានគិតអ៊ីចឹង គិតតែដល់ម៉ោងចេញធ្វើៗ។ ព្រឹកឡើងគឺម៉ោងបួនហ្នឹង ម៉ោងបួន ម៉ោងប្រាំហ្នឹង គឺចាប់ផ្តើមគោះហើយ ហៅហើយ ស្រែកហៅហើយ ហៅៗឡើងធ្វើការ។ ពេល*(ឮមិនច្បាស់)* កាប់គឹកគាក់ៗអ៊ីចឹងទៅ ឮតែស្នូរចបអត់ឃើញមនុស្សទេ ពេលដែលធ្វើហ្នឹង ពេលព្រឹកហ្នឹងអត់ឃើញមនុស្សទេ យើងមើលអត់ឃើញ ឮតែស្នូរចបទេ ឮតែស្នូរចប។ រហូតដល់ម៉ោងដប់មួយ បានគេឲ្យយើងសម្រាកៗ ។ សម្រាកបាយបានមួយភ្លែត ប្រហែលជាម៉ោងមួយ គេឲ្យយើងចុះទៅធ្វើទៀត រហូតដល់ម៉ោងប្រាំ ល្ងាចៗប្រាំល្ងាចគេឲ្យឈប់សម្រាក។ អ៊ីចឹងទម្រាំយើងដើរដល់កន្លែងយើងសម្រាកហ្នឹងយូរដែរដើរមកដល់ ទម្រាំហូបបាយហើយក្រិសក្រុសៗ គឺដល់ម៉ោងគេទៀតហើយដល់ម៉ោងចុះទៀតហើយដល់ម៉ោងចុះអ៊ីចឹងទៅ ធ្វើទៀតទៅ ម៉ោងប្រាំឡើងទៅ។ ឡើងមកអ៊ីចឹងទៅ មកងូតទឹកងូតអី

[887] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ញ៉ិប ហល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ១៣ បន្ទាត់ ១៨-១៩។

[888] សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ថ្ងៃទី១០ ខែធ្នូ ឆ្នាំ ១៩៤៨ មាត្រា ២ ៥ ៩ ២៥។

ហូបបាយ ហូបអីហើយអឺចឹង ហូបបបរអឺចឹងទៅ។ ម៉ោងប្រាំពីរ គេហៅចុះទៅធ្វើទៀតហើយ ទាំងយប់ហ្នឹង បាទ។ ធ្វើយប់ហ្នឹង ដល់ម៉ោងដប់បានគេឲ្យយើងមកសម្រាក គឺថាការងារជាទម្ងន់ ធ្វើបាប ចល័តត្រពាំងថ្ម ធ្វើបាបហួស គ្មានយកអ្វីប្រៀបធៀបមិនបាន"[889]។ គាត់បានបញ្ជាក់ថា នៅពេលថ្ងៃ ផែនការការងារគឺបីម៉ែត្រគីប ហើយវេនយប់ ពុំមានការលើកឡើងពីផែនការការងារនោះទេ[890]។

461. ភ័ស្តុតាងពីដើមបណ្តឹងរដ្ឋប្បវេណីបង្ហាញថា ការងារដែលបានផ្តល់ឲ្យគឺតម្រូវការថែ្នកកម្លាំង។ ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ បានពន្យល់ថា "ការតឹងតែងទាំងផ្លូវអារម្មណ៍ ទាំងផ្លូវកាយ គឺតឹងតែងទាំងអស់ ព្រោះថាការទំនប់អាងត្រពាំងថ្មហ្នឹង គឺរែកដីមួយថ្ងៃៗមិនតិចទេ ដូច្នេះម្នាក់ៗខ្នងចង់កោងអស់ហើយ គិតឃើញពេលណា អារម្មណ៍វាមិនជ្រះស្រឡះទេ តឹងតែងរហូត ទាំងផ្លូវកាយ ទាំងផ្លូវចិត្តហើយ"[891]។ ដើមបណ្តឹងរដ្ឋប្បវេណី ញឹប ហល់ បានពន្យល់ថា ពលករត្រូវបានផ្តល់ឲ្យនូវ "ចបកាប់ និងដងរែក"[892] និងថា "គេអត់មានឧបករណ៍ឲ្យទេ គឺរែកនឹងកម្លាំង បាទ។ បង្គីដាក់សុទ្ធតែជាន់ បើមិនជាន់ឲ្យបានច្រើនទេ វាមិនរួចដី។ ដាក់ហើយជាន់ពីលើឲ្យហាប់ក្នុងបង្គីហ្នឹង បើមិនអ៊ីចុះមិនរួចដី ៥ម៉ែត្រគូប"[893]។ គាត់បានពន្យល់ថា "បើនៅប៉ះដីស្ងួតក៏បានច្រើន បើប៉ះដីសើមធ្ងន់ក៏ធ្ងន់ ប៉ះដីសើមបាទ បើដីស្ងួតរាងស្រាលបន្តិច បើប៉ះដីសើម ធ្ងន់ប្រហែលជាហាប់ម្ខាង ២០ គីឡូដែរ"[894]។ ដើមបណ្តឹងរដ្ឋប្បវេណី ញឹប ហល់ បាន

---

[889] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ក ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៨ បន្ទាត់ ២៥ - ទំព័រ ៩ បន្ទាត់ ១២។

[890] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ក ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៤៣ បន្ទាត់ ៧-៨។

[891] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៦៥ បន្ទាត់ ១៩-២១។

[892] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ញឹប ហល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ៨ បន្ទាត់ ៣។

[893] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ញឹប ហល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ១០ បន្ទាត់ ១២-១៣។

[894] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ញឹប ហល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ១០ បន្ទាត់ ១៦-១៧។

ពន្យល់ថា ពលករត្រូវតែចាក់ដីបំពេញខ្នងទំនប់ដែលមានចម្ងាយ ៣០ ទៅ ៥០ ម៉ែត្រពីកន្លែងយកដី ទៅកន្លែងចាក់ដី[895]។

462. ពាក់ព័ន្ធនឹងផែនការការងារប្រចាំថ្ងៃរបស់ ដើមបណ្ដឹងរដ្ឋប្បវេណី ញ៉ឹប ហាល់ គាត់បានផ្ដល់សក្ខីកម្មថា "គេវាស់ឲ្យម្នាក់ៗ ត្រង់ណា៥ម៉ែត្រគូប ស្រេចតែគេបោះបង្គោលត្រង់នោះហើយ យើងរែកឲ្យតែរួចទៅ បាទ ៥ម៉ែត្រគូប"[896]។ គាត់បានពន្យល់ថា "ទៅដំបូងគេឲ្យ៣ម៉ែត្រគូប ៣ ម៉ែត្រគូបរួច ពីថ្ងៃម៉ោងមួយម៉ោងពីររួច ឡើងដល់៥ម៉ែត្រគូប បាទ។ ឡើង ដំឡើងដល់៥ម៉ែត្រគូប"[897]។ នៅពេលមានការចាត់ចែងការងារពិសេស ដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ជាក់ថា "ដឹងតែក្រោកពីម៉ោងបី ម៉ោង បួនព្រឹកហ្នឹង ទល់ម៉ោងប្រាំបានរួច អត់មានពេលសម្រាក់ទេ ហូបបាយក្នុងអន្លង់រែកដី[898]។

463. ដើមបណ្ដឹងរដ្ឋប្បវេណី សែន សុផុន បានផ្ដល់សក្ខីកម្មថា កងរបស់គាត់ត្រូវបាន "ឲ្យលើកក្នុងម្នាក់ ៣ម៉ែត្រគូប"[899]។ គាត់បានពន្យល់ថា "ព្រឹកម៉ោងបួន មេកងគោះរគាំងម៉ឺងៗ ដើម្បីឲ្យចេញរៀបចំទៅលើកដី។ ថ្ងៃត្រង់ម៉ោងដប់មួយកន្លះ ទើបឲ្យសម្រាកហូបបបរ"[900]។ ការងារបានចាប់ផ្ដើមធ្វើ

---

[895] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ញ៉ឹប ហាល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ២០ បន្ទាត់ ២៤។

[896] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ញ៉ឹប ហាល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ៩ បន្ទាត់ ១៤-១៦។

[897] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ញ៉ឹប ហាល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ៩-១០ បន្ទាត់ ២៥-១។

[898] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ញ៉ឹប ហាល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ២៧ បន្ទាត់ ៣-៤។

[899] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៣៥ បន្ទាត់ ១៩។

[900] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៣៥ បន្ទាត់ ២២-២៣។

ឡើងវិញនៅ "ពេលរសៀល ម៉ោងមួយចុះធ្វើ ធ្វើរហូតដល់ម៉ោងប្រាំបួន ម៉ោងដប់ ព្រោះថា ៣ម៉ែត្រគូបធ្វើមិនហើយទ ធ្វើអត់ហើយគេអត់ឱ្យឈប់"[901]។

464. ក្នុងការបំពេញការងារឱ្យបានបីម៉ែត្រគូបក្នុងមួយថ្ងៃ ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន មាន ឧបករណ៍តែ "តែចប ហើយនិងបង្គីប៉ុណ្ណោះ ហើយនិងខ្សែ និងដងរែក" ប៉ុណ្ណោះ[902]។ គាត់បាន ពន្យល់ថា "រែកៗកាប់ រែកកាប់ ដៃជួយកាយ កាយដាក់បង្គីឱ្យរែកៗ"[903]។

465. ដើមបណ្តឹងរដ្ឋប្បវេណី ញឹប ហាល់ បានរៀបរាប់ថាតើគាត់មានការឈឺចាប់យ៉ាងណាពី "ឈឺដើម ទ្រូងកំពុងរែកដីបាទ។ ឈឺដើមទ្រូងដែលធ្វើការធ្ងន់"[904]។

## ២.២. លក្ខខណ្ឌរស់នៅ

### i. កង្វះអាហារ

466. ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត បានរៀបរាប់ពីកង្វះអាហារដែលត្រូវផ្តល់ឱ្យកុមារនៅក្នុងកង កុមារ និងការឈឺចាប់ដែលពួកគេបានជួបប្រទះ ដោយសារកង្វះអាហារ និងលក្ខខណ្ឌរស់នៅរបស់ ពួកគេនៅក្នុងការដ្ឋាន។ គាត់បានបញ្ជាក់ទៀតថា "ចំណែកការហូបចុករបស់គេវិញ គឺឱ្យយើងហូបមួយកំប៉ុងគ្នា ១០នាក់ របបគេឱ្យ។ មុនដំបូងគេឱ្យមួយកំប៉ុង ១០នាក់។ បបររាវ ឃើញអង្ករមួយៗទេ មួយកំប៉ុង១០នាក់។ បន្ទាប់មកទៀតមួយកំប៉ុង ២០នាក់។ បន្ទាប់មក មួយកំប៉ុង ៣០នាក់។ ប៉ុន្តែ មួយកំប៉ុង ៣០នាក់ គេចាប់ផ្តើមលាយត្រកួនហើយ ចាប់ផ្តើម លាយត្រកួន។ គេចិញ្ច្រាំត្រកួនហ្នឹងដាក់ជាមួយបបរហ្នឹង។ គេចិញ្ច្រាំត្រកួនហ្នឹងដាក់ជាមួយអង្ករ មួយកំប៉ុងទៅ ហើយមួយកងកុមារហ្នឹង ៣០នាក់ហ្នឹង ដាក់ឱ្យហូបទៅ ចាក់ចូលពាង ក្នុងពាង

[901] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៣៥-៣៦ បន្ទាត់ ២៥-១។

[902] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៥២ បន្ទាត់ ២២។

[903] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៥៣ បន្ទាត់ ២។

[904] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ញឹប ហាល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ១៣ បន្ទាត់ ២២។

ហើយវែកគេដួសឲ្យ មួយវែកៗ វែកត្រឡោកគេហ្នឹង ត្រឡោកដូងហ្នឹង គេកាប់គេធ្វើជាវែកហ្នឹង ដួសឲ្យយើងមួយវែកៗម្នាក់ បាទ។ រហូតដល់ដាច់ យូរទៅដាក់របបអង្ករហ្នឹង មួយកំប៉ុង ៣០នាក់ ហ្នឹង ដាច់ប៉ិតទៀត។ ហ្នឹងគេចាប់ផ្តើមយកកន្ទក់ឲ្យយើងម្តងហើយ យកកន្ទក់ឲ្យយើងហូបម្តង ហើយ កន្ទក់។ គេដឹកមកកន្ទក់ហ្នឹង កន្ទក់នោះខារ ធុំក្លិនខារ ដង្កូវព័ទ្ធដោយដង្កូវទៀត កន្ទក់ហ្នឹង គ្រាន់តែធុំក្លិនខ្ញុំចង់ក្អួត ប៉ុន្តែបំណាច់ឃ្លានគេបើកឲ្យហើយ បើយើងមិនហូបគឺស្លាប់។ គឺមុននឹងហូបយកទៅលាងសិន លាងអីចឹងហើយបានយកមកខ្ចប់ស្លឹកចេក ខ្ចប់ស្លឹកចេកហើយ បានយកមក អាំង ចម្អិន បានៗយកមកហូបទៅ ហូប"[905]។

467. ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត បានពន្យល់ថា "ខ្ញុំទ្រាំហូបកន្ទក់អត់បាន។ បបរមួយកំប៉ុង៣០នាក់ លាយតែត្រកួន រហូតដល់ដាច់ ឲ្យកន្ទក់ខ្ញុំហូប ខ្ញុំហូបអត់បាន។ ម្ល៉ោះហើយ ក៏ខ្ញុំដាច់ចិត្តទៅធ្វើការឲ្យស្មើនឹងគេមនុស្សធំ ដើម្បីបានបបរឈ្នាលហូបតែប៉ុណ្ណោះទេ"[906]។

468. ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត បានពន្យល់ថា "ក្នុងកងចល័តត្រពាំងថ្មនោះ មានអ្នកឈឺ មិនអត់ទេ។ អ្នកឈឺវាមានហើយ មិនមែនអត់ទេ ទាំងគេ ទាំងខ្ញុំ ព្រោះការហូបវាមិនគ្រប់គ្រាន់។ ដេកក៏មិនបានពេញភ្នែក។ អីចឹងមនុស្ស វាមានជំងឺទ្រុឌទ្រោមហើយ។ ដូចខ្ញុំនិយាយពីខាងដើមថា ក្បាលខ្ញុំដូចបាតលោកអីចឹង ត្រមោងៗ ក្បាលជង្គង់ឡើង ត្រមោងៗ បាទ ទៅជាញាក់ ទៅជាគ្រុនៗហ្នឹង គ្រុនៗចាញ់ផង ក៏មានគ្រុនលស់ ក៏មាន អាគ្រុនលស់ វាគ្រុនដឹងពេល។ ឧបមាថា យើងគ្រុនម៉ោងមួយ ចាប់ផ្តើមម៉ោងមួយ ដឹងតែប្រែឲ្យហើយទៅ អាហ្នឹងញាក់មកហ្នង ចេញពីក្នុងឆ្អឹងមកហ្នង។ ហ្នឹងហើយ គេហៅគ្រុនលស់។ បាទ បើគ្រុនចាញ់នេះ គឺមុខស្លេកស្លាំងអីចឹងទៅ ខ្លួនឡើងហើមទៅ ក្បាលពោះកំពីងៗទៅ ក្បាលជង្គង់ត្រមោងៗទៅ បាទ មានៗ ហើយឈឺស្លាប់ មានឈឺស្លាប់ មាន។ ដូចគ្រុនចាញ់អីចឹង"[907]។ ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា "ហ្នឹងហើយ

[905] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ E1/340.1 ទំព័រ ៧ បន្ទាត់ ៥-១៧។

[906] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ E1/340.1 ទំព័រ ១០-១១ បន្ទាត់ ២៥-១។

[907] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ E1/340.1 ទំព័រ ២១ បន្ទាត់ ១៨-២៥។

ដែលវាខ្វះអាហារហ្នឹងហើយ ធ្វើឱ្យគេឈឺបាក់ទ្រុឌទ្រោមកម្លាំងហ្នឹង។ ក្បាលត្រមោងៗ ក្បាលជង្គង់ត្រមោងៗ ឈឺហើមរហូតដល់គ្នាស្លាប់ហ្នឹង ហ្នឹងហើយ វាជាការខ្វះអាហារ"[908]។

469. ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ បានរៀបរាប់ពីអារម្មណ៍ទន់ខ្សោយ និងឃ្លានថា "កាលនៅអាងត្រពាំងថ្ម គឺហូបមិនគ្រប់គ្រាន់ទេ។ ដើមដំបូង ការចូលដល់ យើងបានមួយកា ម្នាក់ម្តង។ ផ្លាក់ពីរបីថ្ងៃ មានបបរខាប់ ហើយយូរៗទៅ បែរកែប្រែទៅជាមួយចាន់ចង្កឹះក៏មាន។ មិនគ្រប់គ្រាន់ទេ។ ដូច្នេះ កម្លាំងគឺអត់មាន"[909]។

470. ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន បានរៀបរាប់ថាតើរបបអាហារត្រូវបានកាត់បន្ថយយ៉ាងណាក្នុងមួយរយៈពេលក្រោយមក។ "ពេលមុនដំបូង មួយថ្ងៃបីពេល"[910] ប៉ុន្តែ "ដល់យូរៗទៅអស់អង្ករទៅ នៅសល់តែមួយថ្ងៃ ពេលថ្ងៃត្រង់មួយពេលប៉ុណ្ណោះឯង ហើយនិងពេលល្ងាច"[911]។

471. ការផ្តល់សក្ខីកម្មអំពីកង្វះអាហារជារួមនេះ ដើមបណ្តឹងរដ្ឋប្បវេណី ញ៉ិប ហល់ បានបញ្ជាក់ថា "គ្មានរបបពេលព្រឹកទេ អត់ មានតែពេលថ្ងៃតែម្តង អត់មានរបបព្រឹកទេ មានពេលថ្ងៃ"[912] ដោយបានពន្យល់បន្ថែមទៀតថា "ហូបម្នាក់ត្រូវមួយចានត្រាំមាន់ កូនចាន ទ្រើសជាងចានចង្កឹះហ្នឹងឯង។

[908] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៣៣ បន្ទាត់ ១-៣។

[909] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៥៣ បន្ទាត់ ៦-៨។

[910] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៦១ បន្ទាត់ ៧។

[911] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៦១ បន្ទាត់ ១០-១១។

[912] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ញ៉ិប ហល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ១២ បន្ទាត់ ១។

វាស់របបចែក ឆ្អែតមិនឆ្អែតតែប៉ុណ្ណោះឯង"[913]។ ដើម្បីផ្សំជាមួយនឹងបបរ គឺ "គ្មានអ្វីទេ បើមិនព្រលិត គឺត្រកួនប៉ុណ្ណោះ និងច្រាច់ ត្រីឆ្អើរ ស្ងោរម្ជូរ ស្លម្ជូរទៅ"[914]។

### ii. កន្លែងស្នាក់នៅមិនសមរម្យ/កង្វះភាពរីករាយ

472. ដើមបណ្តឹងរដ្ឋប្បវេណី ញ៉ឹប ហាល់ បានផ្តល់សក្ខីកម្មថា "មានតែស្បែកជើងកង់ឡាន។ ខោអាវមានតែមួយកំប្លេ ហើយភួយៗបាវៗពណ៌ល្អឿង បាទ។ មិនមានទេ មិនមានភួយដណ្តប់"[915]។ សម្រាប់ការដេកពួន "មានរនាបឫស្សីជាប់នឹងដី អត់ខ្ពស់ ជាប់នឹងដីដាក់ឈើកល់ទៅ រែងពីរល្វីទៅ"[916]។

473. ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត បានផ្តល់សក្ខីកម្មទាក់ទងនឹងពលករដែលរងការឈឺចាប់នៅក្នុងខែរងារ។ "ធ្វើការ គ្មានពេលសម្រាក ភួយក៏គ្មានដណ្តប់។ ខែកត្តិកដឹងតែបំពក់ភ្នក់អាំង ជួនណាឆេះអស់បាវពោះខៀវហ្នឹង យកមកក្រាលដេក។ ជួនណា ភ្លើងមក អាកម្ទេចភ្លើងហ្នឹងមកទៅ ឆេះទៅ។ រងា។ គ្រុនក៏អាំងភ្លើង អ្នកខ្លះគ្រុនអាំងភ្លើងទៅ ស្លាប់នឹងភ្នក់ភ្លើងក៏មានដែរ។ អាហ្នឹងគ្រុនអាំងភ្លើង"[917]។

474. ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត បានរៀបរាប់ថា "ជំនាន់នោះខ្លួនខ្ញុំ ស្ទើរតែអាវខ្ញុំ ខោខ្ញុំ ចៃឲ្យពេញខ្លួន ឆ្អេះឆ្អាប ដើរទៅជិតគេ ក៏គេថាដែរ ឆ្អេះឆ្អាប យើងទៅជិតគេ ក៏យើងថាគេដែរ ឆ្អេះឆ្អាប គឺចៃសាច់ចេញពេញខ្លួនហ្នឹង។ នៅតាមចង្កេះខោហ្នឹង កៅស៊ូខោហ្នឹងនៅជាប់នឹងចៃសុៗស្កុះ គឺថាគ្មានទេ គ្មានពេលណាសម្អាត គ្មានសាប៊ូអីណា គ្មានអីណាដុស ស្ទើរង្ងូតទឹកសឹងតែរកពេលងូត

---

[913] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ញ៉ឹប ហាល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ១២ បន្ទាត់ ៥-៦។

[914] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ញ៉ឹប ហាល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ១២ បន្ទាត់ ១២។

[915] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ញ៉ឹប ហាល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ២៤ បន្ទាត់ ២០-២១។

[916] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ញ៉ឹប ហាល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ២៤ បន្ទាត់ ២២។

[917] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ១០ បន្ទាត់ ១៦-១៩។

ទឹកមិនបានផង។ ស្ងួប្បីយើងដេកហ្នឹង យើងយកបង្គីធ្វើខ្នើយ បង្គីដែលយើងរែកដី យើងធ្វើជាខ្នើយ។ ចបដែលយើងកាប់ហ្នឹង ធ្វើជាខ្នើយឱប កល់ជើង កល់ដៃ។ ដេកនឹងដី ដេកផ្ទាល់ដី។ ការឈឺចាប់របស់ខ្ញុំ ខ្ញុំខឹងជំនាន់នោះ គឺថាគេធ្វើបាបសម្បើមណាស់ ពួក១៧មេសានេះ។ គេស្អប់ពួក ១៧មេសាតែម្តង។ គេថា ពួកសក្តិភូមិ ពួកនាយទុន។ មកតែមួយចង្កេះទេមក អត់យកអីមកតាមទេ។ គេថាយើងអីចឹង។ ចុះអ្នកណាយកអីទៅតាម បើអស់លោកឃោសនាថាតែបីថ្ងៃ"[918]។

475. នៅពេលរៀបរាប់ពីកន្លែងដេកនៅក្នុងការដ្ឋាន ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន បានផ្តល់សក្ខីកម្មថា "អត់មានមុង អត់មានខ្នើយ ភួយអត់មាន កន្លែងគ្រែងដេកក៏អត់មាន ដេកក្នុងដី អ្នកណាមានអីក្រាលដេកខ្លួនឯង បើមិនអីចឹងដើរយកចំបើងមកក្រាលដេកខ្លួនឯង"[919]។ "អត់មានបន្ទប់ទឹក បន្ទប់អីទេ មានតែដើមអញ្ចាញតូចៗដែលអង្គុយមួយផុតក្បាលប៉ុណ្ណោះឯង ជុះពេញវាលពេញកាលនុំង"[920]។

476. គាត់បាននិយាយថា "មានភ្លៀងធ្លាក់មកៗជួនកាល ដំបូលលិចអស់រងានាំគ្នាអង្គុយញាក់ៗ ហើយព្រលឹមឡើងធ្វើការទៀត"[921]។ "គេមិនឲ្យសម្រាកទេ គេឲ្យធ្វើការតែរហូត"[922]។

### iii. កង្វះទឹកស្អាតសម្រាប់ផឹក និងអនាម័យ

477. ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន បានផ្តល់សក្ខីកម្មថា "ទឹកហូបអត់គ្រប់គ្រាន់ដែរ យកធុងសាំងពីរដាក់លើរទេះទៅដឹកទឹកពីបឹងយកមកឲ្យហូប"[923]។ "ឲ្យតែមានអូរ មានបឹងត្រង់ណា គេទៅដួសពីនោះយកមកហើយ"[924]។ គាត់បានបន្ថែមដោយបញ្ជាក់ថា ទឹក "ល្អក់រល់ មកហូបទៅ"[925]។

---

[918] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ក ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ១០ បន្ទាត់ ៥-១៥។

[919] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៥៦ បន្ទាត់ ២៣-២៤។

[920] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៥៧ បន្ទាត់ ៩-១០។

[921] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៥៧ បន្ទាត់ ៥-៦។

[922] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៥៧ បន្ទាត់ ៧។

478. ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត បានបញ្ជាក់បន្ថែមថា នៅឯការដ្ឋានទំនប់ត្រពាំងថ្ម "គ្មានគេយកទឹកស្អាតឱ្យយើងទេ។ ទឹកនោះល្អក់ គេហៅទឹកល្អក់ គ្មានអនាម័យទេទឹក គ្មានអនាម័យទេ ទឹក។ ពេលយើងកុនណាស់ ពេលណាយើងផឹកទឹក ទាល់តែយកអាវមកដាក់មាត់អីចេះ ដាក់មាត់ ហើយយើងបឺត យើងខ្លាចៗមានសត្វល្អិតចូលក្នុងពោះយើង បាទលាអាវអីចេះមក មានអាវអីចឹងដាក់អីចេះ ហើយយើងដាក់ផឹកទៅ ហ្នឹងរបៀបវិធីផឹកទឹក បាទ ទឹកវាអត់ស្អាត ទឹកវាមានកូនសត្វល្អិត"[926]។ គាត់បានពន្យល់ថា "ទឹកបាយគេជាត់ហើយយកចានទៅត្រង យកឆ្នាំងដាក់ត្រង"[927]។

479. ពាក់ព័ន្ធនឹងអនាម័យ ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន បានផ្តល់សក្ខីកម្មថា "អត់មានបន្ទប់ទឹក បន្ទប់អីទេ មានតែដើមអញ្ចាញតូចៗដែលអង្គុយមួយផុតក្បាលប៉ុណ្ណោះឯង ជុះពេញវាល ពេញកាលនុំង"[928]។ គាត់ក៏បានកត់សម្គាល់ឃើញថា "បើនិយាយពីរុយវិញ រោមបបរឡើងជិតឈឹង"[929]។

## ២.៣. កង្វះការថែទាំវេជ្ជសាស្ត្រ

---

[923] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៣៧ បន្ទាត់ ២០-២១។

[924] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៥៧ បន្ទាត់ ២១។

[925] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៥៧ បន្ទាត់ ២៣។

[926] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ២៣ បន្ទាត់ ១-៥។

[927] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ១១ បន្ទាត់ ១៨។

[928] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៥៧ បន្ទាត់ ៩-១០។

[929] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៥៧ បន្ទាត់ ១២។

480. នៅឯការដ្ឋាន ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន បានពន្យល់ថា "អត់មានថ្នាំពេទ្យ ថ្នាំអីទេ ឈឺដេកនៅក្នុងរោងនោះឯង សូម្បីតែបាយ ក៏អត់ចែកឲ្យហូបផង"[930]។

481. នៅពេលពន្យល់អំពីស្ថានភាពដែលមានកើតមានជារួមនៅក្នុងកងកុមារដែលគាត់ជាសមាជិកផងនោះ ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត បានផ្តល់សក្ខីកម្មថា "ពេលនោះហើយដែលមានជំងឺកើតឡើងទៅជាជំងឺហើម គ្រុនចាញ់ បាទ ជំងឺហើម គ្រុនចាញ់ ចាប់ផ្តើមស្លាប់បណ្តើរៗបន្តបន្ទាប់ស្លាប់ ចាប់ផ្តើមស្លាប់ហើយ ពេលនោះ ហើម។ ហើយគ្មានថ្នាំទេ ព្យាបាល គ្មានហៅយើងទៅមន្ទីរពេទ្យ ថាទៅ "ឈឺហើយទៅមន្ទីរពេទ្យ" អត់មានទេៗ គឺថាយើងគ្រុនអីចឹងគេយកថ្នាំមកឲ្យយើងគឺអាចម៍ទន្សាយសុទ្ធ ចុកពោះក៏អាចម៍ទន្សាយ ឈឺក្បាលក៏អាចម៍ទន្សាយ គ្រុនញាក់គ្រុនញ័រក៏អាចម៍ទន្សាយថ្នាំគេគឺ ថ្នាំគេ បែបពូកែបែប បានគេឲ្យថ្នាំអីចឹងមកឲ្យយើងផឹក។ បាទ ខ្ញុំមានការឈឺចាប់ខ្លាំងណាស់ដល់ពេលធ្វើបានខ្លាំងៗពេក ធ្វើបាបខ្ញុំខ្លាំងពេក"[931]។

482. នៅពេលផ្តល់មតិយោបល់អំពីការមើលថែទាំវិជ្ជសាស្ត្រ និងការផ្គត់ផ្គង់ឱសថ ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ បានបញ្ជាក់ថា "ពេលឈឺម្តងៗ មិនដែលមានពេទ្យទេ យើងគ្រាន់តែរាយការណ៍ឲ្យមេ មេកងហ្នឹងទៅ មេកងគេប្រាប់ពេទ្យ ពេទ្យគេមក ហើយពេទ្យហ្នឹងទៀត ឃើញគេស្លាយសាក់កាដូរបស់គេហ្នឹងថា សមណាំណាស់ ប៉ុន្តែពេលមកគេស្ទាបមើលលិចកើតទៅ មានតែថ្នាំអាចម៍ទន្សាយហ្នឹងឯងឲ្យលេប។ ជំងឺ ១០០មុខ គឺត្រូវតែនឹងអាចម៍ទន្សាយហ្នឹង អត់ដែលមានថ្នាំអីខុសពីថ្នាំហ្នឹងទេ"[932]។

483. ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន បានរំលឹកថា គាត់បានធ្លាក់ខ្លួនឈឺពីរដង ក្នុងអំឡុងពេលដែលគាត់បានស្ថិតនៅក្នុងការដ្ឋានទំនប់ត្រពាំងថ្ម។ "ខ្ញុំគ្រុនពីរដង ឲ្យតែថ្នាំអាចម៍ទន្សាយខ្ញុំបានពីរគ្រាប់

---

[930] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៣៧ បន្ទាត់ ១១-១២។

[931] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៧ បន្ទាត់ ១៦-២២។

[932] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៥៣ បន្ទាត់ ២៤ ដល់ទំព័រ ៥៤ បន្ទាត់ ២២-២៥។

លេប”[933]។ គាត់បានពន្យល់ថា “ប៉ុន្តែអត់មានថ្នាំពេទ្យផង[934]។ ថ្នាំអាចម៍ទន្សាយនោះ គេស្ងូនដុំៗមូលៗដូចអាចម៍ទន្សាយអ៊ីចឹង គេយកមកឱ្យលេប”[935]។

484. នៅក្នុងការឆ្លើយតបទៅសំណួរអំពីការថែទាំវេជ្ជសាស្ត្រដែលគាត់បានទទួល ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន បានឆ្លើយតបថា “អត់មានថ្នាំពេទ្យ ថ្នាំអីទេ ឈឺដេកនៅក្នុងរោងនោះឯង ដេកស្ងួម្បីតែបាយ ក៏អត់ចែកឱ្យហូបផង”[936]។

485. ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត បានផ្តល់សក្ខីកម្មថា មាន “ជំនាន់នោះ គ្មានគ្រូពេទ្យទេ អត់មានគ្រូពេទ្យៗៗទៅមើលថែយើងទេ។ បើយើងសុំថ្នាំគេបាន សុំថ្នាំគេៗឱ្យតាមរយៈមេក្រុមអីទៅគេឱ្យយើង យកមកឱ្យយើងទៅ។ គឺគ្មានថ្នាំពេទ្យទេ គឺថ្នាំអាចម៍ទន្សាយហ្នឹង ដូចខ្ញុំថាអ៊ីចឹង។ ហើយក៏អាចម៍ទន្សាយ គ្រុនក៏អាចម៍ទន្សាយ គឺថាចម្រុះថ្នាំគេពូកែណាស់។ ពូកែមែនថ្នាំនោះ បាទ ”[937]។

## ២.៤. ការបាត់ខ្លួន

486. ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន បានផ្តល់សក្ខីកម្មថា “តែចេះតែបាត់មនុស្ស ក្រុមខ្ញុំយូរៗបាត់ម្តងៗ”[938]។ គាត់ក៏បានរៀបរាប់អំពីការបាត់ខ្លួនរបស់ អឿន ថា “កងខ្ញុំបាត់ ក្រុមខ្ញុំបាត់ អាអឿន

[933] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ E1/323.1 ទំព័រ ៥៨ បន្ទាត់ ៤។

[934] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ E1/323.1 ទំព័រ ៥៨ បន្ទាត់ ៦។

[935] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ E1/323.1 ទំព័រ ៥៨ បន្ទាត់ ៨-១០។

[936] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ E1/323.1 ទំព័រ ៣៧ បន្ទាត់ ១១-១២។

[937] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ E1/340.1 ទំព័រ ១៣ បន្ទាត់ ៨-១១។

[938] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ E1/323.1 ទំព័រ ៣៧ បន្ទាត់ ១៧។

ក៏បាត់គេយកទៅសម្លាប់ចោល"[939]។ ទាក់ទងនឹងការបាត់សមាជិកកងផ្សេងៗទៀត គាត់បានផ្តល់សក្ខីកម្មថា "មានច្រើន ប៉ុន្តែខ្ញុំអត់បានចាំឈ្មោះគេច្បាស់ទេ គេបាត់ ចេះតែបាត់បន្តិចម្តងៗ បាត់ច្រើន"[940]។

487. ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ បានផ្តល់សក្ខីកម្មថា "ចំពោះការបាត់ខ្លួននៅក្នុងកងរបស់ខ្ញុំបាទ គឺថាមាន មិនបានឃើញទេ ប៉ុន្តែមានបាត់ខ្លួនព្រោះមានអ្នកឈឺខ្លះ គ្នាទៅធ្វើការមិនរួច គេថាយើងឈឺសតិអារម្មណ៍។ ស្រាប់តែដល់ពេលយប់ឡើង មេគេហៅទៅណែនាំ បាត់សូន្យមិនឃើញមិនមកវិញ"[941]។

488. ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ក បានរំលឹកថា "ខ្ញុំនៅកងចល័តៗ ពេលដែលព្រឹត្តិការណ៍កើតឡើង គឺមានច្រើនដែរ ច្រើន ដូចជា គេយកមនុស្សទៅសម្លាប់ យកទៅសម្លាប់។ តែពេលនោះ ខ្ញុំអត់ដឹងថាគេខុសអីទេ ខ្ញុំអត់ដឹងដែរ។ គ្រាន់ ថាគេយកទៅសម្លាប់ ហើយពេលយើងទៅធ្វើការយប់ម៉ោងប្រាំពីរយើងចេញទៅអស់ហើយ ស្ងាត់អស់រោង។ មានអ្នកគេដើរមកមើលក្នុងរោង តាមរោងទៀត តើមានអ្នកណានៅក្នុងរោងខ្លះបាទ។ គេដើរមើលតាមរោងហ្នឹងអ៊ីចឹង។ អ៊ីចឹងមានអ្នកគ្រុនមានអ្នកឈឺ មានអ្នកខ្ជាក់មាន់ ពេលនោះ ខ្ញុំតែអ្នកខ្វាក់មាន់ទេ ខ្ញុំដឹង។ អ្នកខ្វាក់មាន់អ៊ីចឹង គេយក - - គេដឹកដៃៗឲ្យចូលទៅបង្គន់អាចម៍ គេពិសោធយើងយកទៅពិសោធ។ គេដឹកដៃអ៊ីចឹង គេមានលុងសាំងគេហ្នឹង គេកាត់ជាលុងសាំង គេដាក់ឈើឲ្យយើងហើយ គេយកបាវហ្នឹងវ័ណ្ឌអ៊ីចឹង ឲ្យយើងបត់ដៃបត់ជើងក្នុងបង្គន់ហ្នឹង។ អ៊ីចឹងការដកពិសោធរបស់គេ គេយកពួកខ្វាក់មាន់ហ្នឹង ដឹកដៃគ្នាអ៊ីចឹងឲ្យដើរឆ្លងកាត់បង្គន់។ អ៊ីចឹងអ្នកដែលមិនខ្វាក់មាន់ធ្វើជាខ្វាក់មាន់ ដល់មាត់បង្គន់នោះគឺហាក់ឆ្ពោ ហាក់ហួសបង្គន់ហ្នឹង ក៏ប៉ុន្តែអ្នកដែលខ្វាក់ពិតប្រាកដធ្លាក់ភ្លូកត្រឹមភ្លៅ។ បាទធ្លាក់ចូលក្នុងបង្គន់ត្រឹមភ្លៅអ៊ីចឹងទៅ។ បាទ ធ្លាក់អ៊ីចឹង រួចខ្លួន ហ្នឹងហើយរួចខ្លួន។ អត់អីទេអាហ្នឹងពិតប្រាកដ ក៏ប៉ុន្តែអ្នកដែលមានពុតត្បុតនឹងអង្គការ គឺបាត់ខ្លួននៅពេលហ្នឹង បាត់ខ្លួន។ ប៉ុន្តែគ្រាន់តែដឹងថាបាត់ខ្លួន

[939] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៦៣ បន្ទាត់ ១៤។

[940] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៦៣ បន្ទាត់ ២៤។

[941] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ក ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៥២ បន្ទាត់ ២១-២៣។

នៅពេលណាទេខ្ញុំអត់ដឹងទេ ខ្ញុំអត់បានតាមដានទេ គេយកទៅម្ដងមួយៗ។ គឺបាត់ខ្លួន បាត់ អត់ដឹង ថាគេយកពីថ្មើរម៉ោន ថ្ងៃណាអីហ្នឹង អត់ដឹង។ គឺថាធ្វើការជាមួយ ដឹងបាត់ៗអ្នកហ្នឹងមួយហ្នុង បាទ"[942]។

489. ដើមបណ្ដឹងរដ្ឋប្បវេណី សម ស័ក្ត បានពន្យល់ថា បើទោះបីជាគាត់មិនបានឃើញផ្ទាល់ភ្នែកពីការស្លាប់មនុស្សនៅឯការដ្ឋានក៏ដោយ ក៏គាត់បានដឹងពីពលករដែលបានបាត់ខ្លួនដោយសារតែការយកទៅសម្លាប់ដែរ "ខ្ញុំអត់បានឃើញ អ្នករែកដីរបួសហ្នឹង ខ្ញុំមិនបានឃើញទេ ប៉ុន្តែការស្លាប់បាត់មនុស្សនេះ ខ្ញុំដឹងថាមាន មានគេយកសម្លាប់ ខ្ញុំដឹង ប៉ុន្តែការខ្ញុំឃើញ ខ្ញុំមិនបាន អត់បានឃើញទេ"[943]។

## ៣. ការធ្វើមនុស្សឃាត និងការសម្លាប់ខ្ចាល

490. ភស្តុតាងពី ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានធ្វើឡើងនៅពេលសវនាការបង្ហាញថា ពលករ បានស្លាប់នៅការដ្ឋានទំនប់ត្រពាំងថ្មដោយសារតែលក្ខខណ្ឌការងារ និងរស់នៅដ៏អាក្រក់។

491. ដើមបណ្ដឹងរដ្ឋប្បវេណី សែន សុផុន បានផ្ដល់សក្ខីកម្មថា គាត់បានឃើញមនុស្សម្នាក់ស្លាប់ ដោយសារការអត់ឃ្លាន។ "ដោយសារអត់ឃ្លាន ខ្ញុំឃើញផ្ទាល់ភ្នែកដែលស្លាប់ ខ្ញុំឃើញផ្ទាល់ភ្នែក។ ខ្ញុំមិនទាន់មកកងចល័ត ខ្ញុំនៅក្នុងកងភ្ជួរខ្ញុំ។ គ្នាអត់ គ្នាស្រែកសុំបាយមួយដុំមក "ខ្ញុំសុំបាយមួយដុំមកៗ" សុំទាល់តែស្លាប់ដាច់ខ្យល់ប៉ិតនៅមុខខ្ញុំអ៊ីចឹងឯង"[944]។

492. ដើមបណ្ដឹងរដ្ឋប្បវេណី សម ស័ក្ត ក៏បានផ្ដល់សក្ខីកម្មថា ដោយសារកង្វះអហារ និងអាហារមិនស្អាតដែលបានផ្ដល់ឲ្យនៅកងកុមារនោះ កុមារជាច្រើននាក់មានជំងឺ ហើយកុមារខ្លះបានស្លាប់

[942] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ១២ បន្ទាត់ ៦-២០។

[943] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៣២ បន្ទាត់ ១៨-២០។

[944] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៥៦ បន្ទាត់ ១៤-១៦។

ដោយសារតែបញ្ហានេះ។ "ពេលនោះហើយដែលមានជំងឺកើតឡើងហើម បាទ ជំងឺហើម គ្រុនចាញ់ ចាប់ផ្តើមស្លាប់បណ្តើរៗបន្តបន្ទាប់ ស្លាប់ ចាប់ផ្តើមស្លាប់ហើយ ពេលនោះ ហើម"[945]។

## ៤. ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ

493. ភ័ស្តុតាងពីដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់ នៅពេលសវនាការបញ្ជាក់ថា ការដាក់ឱ្យមានលក្ខខណ្ឌរស់នៅ និងការងារដ៏អាក្រក់សម្រាប់ប្រជាជនថ្មីគឺជាការធ្វើទុក្ខបុកម្នេញប្រឆាំងនឹងក្រុមនោះ។

494. ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន បានផ្តល់សក្ខីកម្មថា "អាហ្នឹងពួកគេខាងមូលដ្ឋាននោះ គេអត់សូវធ្វើការងារទេ គេសម្រាប់តែប្រើពួក ១៧មេសា ហ្នឹងឯង"[946]។ ទាក់ទងនឹងអាហារដែលបានផ្តល់ឱ្យទៅក្រុមផ្សេងៗ "ហើយការបែងចែកហ្នឹង វាមានអ៊ីចេះ! ខាងប្រជាជនចាស់ គេហូបតែបាយ តែយើងប្រជាជនថ្មីគេដួសបបរឱ្យមួយវែកៗចែកគ្នា"[947]។

495. ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន បានបញ្ជាក់ថា "ប្រជាជន ១៧ មេសា គឺហូបតែបបរទេ ឯប្រជាជនមូលដ្ឋានគឺមានសិទ្ធិហូបបាយ"[948]។ នៅក្នុងការពន្យល់ថាតើការបែងចែកអាហារទាំងនេះអាចដឹងពីភាពខុសគ្នារវាងប្រជាជនថ្មី និងប្រជាជនមូលដ្ឋានយ៉ាងមេចនោះ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានពន្យល់ថា "ប្រជាជនថ្មីទាំងអស់គឺថា ជាកូនក្រុមរបស់គេ ហើយគេជាមេក្រុមជា អ្នកដឹកនាំ គឺថាគេចែកៗអ្នកក្រុមហ្នឹងឯង។ អ្នកដឹកនាំ គេហូបផ្សេងពីគ្នា"[949]។ "ឱ្យតែអ្នកប្រជាជនមូលដ្ឋាន គេគ្រប់គ្រងអ្នកថ្មីហ្នឹងទាំងអស់។ ការគ្រប់គ្រងគេដឹងហើយដឹងថា អ៊ូ!

[945] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៧ បន្ទាត់ ១៦-១៧។

[946] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៦២៩ បន្ទាត់ ១២-១៣។

[947] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/324.1** ទំព័រ ១៦ បន្ទាត់ ២៤-២៥។

[948] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៦២ បន្ទាត់ ៨-៩។

[949] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/324.1** ទំព័រ ១៧ បន្ទាត់ ១៧-១៨។

នេះគេមូលដ្ឋាន គេគ្រប់គ្រងពួកយើងទាំងអស់គ្នា ដឹងនិយាយសំនៀងមកចេញមកអ្នកបាត់ដំបង អ្នកមូលដ្ឋានហ្នឹងឯង។ បានគេថាមានអ្នកចាស់ មានអ្នកថ្មី”[950]។

496. ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ក បានពន្យល់ថា “ការឈឺចាប់របស់ខ្ញុំ ខ្ញុំខឹងជំនាន់នោះ គឺថាគេធ្វើបាបសម្បើមណាស់ ពួក១៧មេសានេះ។ គេស្អប់ពួក១៧មេសាតែម្តង។ គេថាជាពួកសក្តិភូមិ ពួកនាយទុន។ មកតែមួយចង្កេះទេ អត់មានយកអីមកទេ។ គេថាយើងអ៊ីចឹង។ ចុះអ្នកណាយកអីទៅតាម បើអស់លោកឃោសនាថាតែបីថ្ងៃ។ តែពាគីឡូម៉ែត្រចេញពីទីក្រុងភ្នំពេញ។ មានអ្នកណានឹកថាយកអីទៅតាម។ តែមួយចង្កេះឆ្អេះនឹងខ្លួន ច្រើនមានតែពីរកំប្លេតែប៉ុណ្ណោះ”[951]។

## គ. ព្យសនកម្ម

## ១. ព្យសនកម្មផ្នែករាងកាយ

### *ព្យសនកម្មផ្ទាល់៖ ការឃ្លាន និងការអត់អាហារ*

497. ដោយសារតែការឃ្លានដែលមិនអាចអត់ទ្រាំបាន ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ក បានយកឆ្អឹងត្រីនិងស្បែកកង្កែបជាអាហារជំនួយរបស់គាត់។ “ពេលខ្ញុំនៅកុមារ។ ខ្ញុំឃ្លានខ្លាំងណាស់ៗ អត់អីស៊ី។ ពេលដែលថាមួយកំប៉ុង៣០នាក់នោះ ខ្ញុំដាច់ចិត្ត ដើររើសឆ្អឹងត្រីរបស់មូលដ្ឋាន។ រើសឆ្អឹងត្រីខ្ញុំណានិយាយឥតខ្មាស់ ខ្ញុំដើររើសឆ្អឹងត្រីរបស់មូលដ្ឋាន គេស៊ីហើយ សាច់ហើយគេបោះឆ្អឹងចោល ខ្ញុំរើសមកស៊ី។ កង្កែបគេកាត់ក្បាល គេលាត់ចោលស្បែក ខ្ញុំរើសមកស៊ីទៀត។ យកមកស្ងោរស៊ី គឺថាទុក្ខសោករបស់ខ្ញុំយកអ្វីមកប្រៀបធៀបអត់បានទេជំនាន់នោះ។ ហើយខ្ញុំជាអ្នក១៧ មេសា ខ្ញុំមិនដែលទៅហូបអីរបស់អ៊ីចឹងៗ”[952]។

[950] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/324.1** ទំព័រ ១៨ បន្ទាត់ ១-២។

[951] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ក ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ១០ បន្ទាត់ ១២-១៦។

[952] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ក ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ១១ បន្ទាត់ ១២-១៧។

498. ជាលទ្ធផលនៃការគ្មានអាហារបរិភោគគ្រប់គ្រាន់នេះ ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ បាន រៀបរាប់ថា "មិនគ្រប់គ្រាន់ទេ។ ដូច្នេះ កម្លាំងគឺអត់មាន"[953]។

*ព្យសនកម្មដោយប្រយោល៖ របួស និងជំងឺ*

499. ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត បានរៀបរាប់ថា គាត់បានធ្លាក់ខ្លួនឈឺ ដោយសារតែការងារហួសកម្លាំង នៅការដ្ឋានទំនប់ត្រពាំងថ្ម៖ "ពេលនោះហើយខ្ញុំទៅជាបាក់កម្លាំងរែកខ្លាំងពេកទៅជាបាក់កម្លាំង ខ្ញុំឈឺគ្រុន ខ្ញុំគ្រុនៗហ្នឹងគ្រុនលស់ទៀត អាគ្រុនពេលហ្នឹង ចាប់ផ្តើមដល់ម៉ោងវាគ្រុនៗតែអត់ប៉ាននឈប់ទេ ពេលគ្រុនហ្នឹងអត់ប៉ាននឈប់ទេ"[954]។ "ពេលនោះ ខ្ញុំឈឺ ឈឺគ្រុន គ្រុនគ្មានអ្វីទេ គ្មានថ្នាំអ្វីទេ គ្មាថ្នាំសង្កូវអ្វីទេ គេឲ្យអាចម៍ទន្សាយ ក្បាលជង្គង់ខ្ញុំក្បាលឡើងត្រមោងៗ ក្បាលឡើងត្រមោងៗ សក់ឡើងកន្ទ្រើង សក់។ យើងមើលគេ យើងខ្លាចគេ គេមើលយើង គេខ្លាចយើង ព្រោះយើង គ្មានអ្នកណាមានសាច់ឈាមទេ ស្គេកស្គាំងៗ ហើយយើងឈឺគ្រុនញាក់ គ្រុនញ័រហ្នឹង គ្មានអ្នកមកជួយច្របាច់អីណា មកជួយយើងទេ វាអស់ចិត្តវាបាត់ឯង វាអស់ឯង។ គេហៅថាគ្រុនដឹងពេលអាហ្នឹង ពេលហ្នឹង គ្រុនដឹងពេល"[955]។

500. ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត បានរៀបរាប់ពីការឈឺចាប់ផ្នែករាងកាយដែលពួកគេមាន៖ "ខ្ញុំអត់មានខ្វាក់មាន់នឹងគេ អត់បានខ្វាក់មាន់នឹងគេ។ បានតែជំងឺគ្រុនចាញ់ មានតែជំងឺគ្រុនចាញ់តែមួយមុខ និងហើម។ ខ្ញុំហើម ខ្ញុំកើតជំងឺហើម និងគ្រុនចាញ់ នៅខ្មែរក្រហម។ បាទ កើតជំងឺហើមៗជើងដ៏ស្ពឹង។ ដើរទៅអន្ទិលៗៗ ដូចយើងពាក់ស្បែកជើង អាស្បែកជើងច្រកទឹកចូលអ៊ីចឹង ដើរទៅអន្ទិលៗៗអ៊ីចឹង។ ចុច យកដៃចុចអ៊ីចឹងទៅ ចុចប៉ុន្មានទ្រុឌប៉ុណ្ណឹងដៃយើងចុចៗៗអ៊ីចឹង ទ្រុឌ

---

[953] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៥៣ បន្ទាត់ ៨។

[954] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៨ បន្ទាត់ ៩-១១។

[955] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ១០ បន្ទាត់ ១-៥។

ប៉ុណ្ណឹង ចុចទៅ ហ្នឹងហៅជំងឺហើមហ្នឹង។ មុខយើងហើមស្តើង យកដៃចុចអ៊ីចេះទេ ទ្រុឌអ៊ីចឹងទៅ បាទ។ អាហ្នឹងជំងឺហ្នឹង មានតែពីរមុខហ្នឹង ខ្ញុំកើតជំងឺជំនាន់ខ្មែរក្រហម"[956]។

501. ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ បានពន្យល់ថា "ការតឹងតែងទាំងផ្លូវអារម្មណ៍ ទាំងផ្លូវកាយ គឺតឹងតែងទាំងអស់ ព្រោះថាការលើកទំនប់អាងត្រពាំងថ្មហ្នឹង គឺរែកដីមួយថ្ងៃៗមិនមែនតិចទេ ដូច្នេះម្នាក់ៗខ្នងចង់កោងអស់ហើយ គិតឃើញពេលណា អារម្មណ៍វាមិនជ្រះស្រឡះទេ តឹងតែងរហូតទាំងផ្លូវកាយ ទាំងផ្លូវចិត្តហើយ"[957]។

## ២. ព្យសនកម្មផ្លូវចិត្ត

### *ព្យសនកម្មផ្ទាល់៖ ការភ័យខ្លាចសេចក្តីស្លាប់ ឬការដាក់ទណ្ឌកម្ម*

502. ដើមបណ្តឹងរដ្ឋប្បវេណី ញ៉ិប ហាល់ បានផ្តល់សក្ខីកម្មអំពីការភ័យខ្លាចដែលគាត់បានឆ្លងកាត់ ក្នុងពេលគាត់កំពុងបំពេញការងារនៅការដ្ឋានទំនប់ត្រពាំងថ្ម។ "ធ្វើនោះ ធ្វើទាំងខ្លាចស្លាប់តែម្តង។ ធ្វើទាំងកម្លាំងចិត្ត បើកម្លាំងកាយអត់មាន។ គឺកម្លាំងខ្លាចស្លាប់តែម្តង។ មិនហ៊ានតវ៉ាជាមួយអង្គការទេ។ ធ្វើដោយកម្លាំងចិត្ត ធ្វើចិត្តដែលខ្លាចគឺត្រូវតែធ្វើ"[958]។

### *ព្យសនកម្មប្រយោល៖ ភាពក្រៀមក្រំ និងភាពតានតឹងផ្លូវចិត្ត*

503. ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត បានរៀបរាប់ពីព្យសនកម្មផ្លូវចិត្តដែលគាត់មាន ដោយសារតែមិនអាចធ្វើការងារឲ្យបានគ្រប់តាមផែនការការងារពីព្រោះតែវ័យក្មេង។ "ការងារកងចល័ត គឺថាយើងគ្មានថាតូច គ្មានថាធំទេ។ ការងារបែងចែកស្មើគ្នា។ បែងចែកស្មើគ្នា។ បើយើងធ្វើឲ្យគេ មិន

[956] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ១២-១៣ បន្ទាត់ ២៥-៥។

[957] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៦៥ បន្ទាត់ ១៩-២១។

[958] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ញ៉ិប ហាល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ១១ បន្ទាត់ ១៧-១៩។

គ្រប់ទេ គេនឹងកាត់របបយើង។ ក្នុងក្រុមនោះគេកាត់របបយើង”[959]។ “ខ្ញុំនៅតូចជាងគេ ខ្ញុំអង្គុយយំៗ។ តូចចិត្តខ្លួនឯងធ្វើអត់ហើយ”[960]។

*ព្យសនកម្មផ្ទាល់៖ ការបាត់បង់ឆន្ទៈរស់នៅ*

504. នៅពេលរៀបរាប់ពីការបាក់ស្បាតដោយសារតែបទពិសោធន៍របស់ខ្លួននៅការដ្ឋាននេះ ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត លើកឡើងអំពីការនឹកឃើញរូបភាពនៃអាហារចុងក្រោយរបស់គាត់។ “ខ្ញុំនៅក្នុងកងចល័ត ធ្វើការធ្ងន់ ហូបមិនគ្រប់គ្រាន់ ដេកមិនបានពេញភ្នែក គឺថាខ្ញុំ ក្នុងចិត្តខ្ញុំនេះរកអ្វីមកប្រៀបធៀបមិនបាន គឺថាឃ្លានខ្លាំងពេក និយាយជំនុំគ្នាថា “ខ្ញុំឲ្យតែបាយខ្ញុំហូបឲ្យឆ្អែត មាន់ស្ងោរខ្ញុំមួយចាន ដូចពីសង្គមហ្នឹង យកខ្ញុំទៅសម្លាប់ចុះ ខ្ញុំមិនស្តាយជីវិតខ្ញុំទេ ឲ្យតែបានឆ្អែតមួយពេលបានហើយ” ជំនុំគ្នាអ៊ីចឹង។ អ្ហ៎! អ្នកខ្លះទៅគេថា “អញបានគុយទាវមួយចានទឹកកកមួយកែវ គេយកទៅសម្លាប់ ក៏គេមិនស្តាយដូចគ្នា”។ គិតទៅនិយាយតែពីរឿងស៊ី បំណាច់យើងឃ្លានពេកៗ បាទ ហ៊ានយកជីវិតទៅប្តូរការស្លាប់ជំនាន់នោះ ឲ្យតែបានឆ្អែតៗ មួយពេលគេយកទៅសម្លាប់ចោលទៅ អត់មានស្តាយទេ អត់ស្តាយទេ”[961]។

505. ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ បានផ្តល់សក្ខីកម្មថា “ក្នុងការរស់នៅអាងត្រពាំងថ្ម មិនដែលមានសេចក្តីសង្ឃឹមថានឹងរស់នៅបានសព្វថ្ងៃមកដល់សព្វថ្ងៃនេះទេ។ ពេលថ្ងៃបើកភ្នែកឡើងគឺចេញទៅធ្វើការ ដឹងថាពេលនេះមានរស់ តែពេលយប់ដែលមើលមិនឃើញ ខ្លាចក្រែងយើងមានកំហុសអ្វីពីថ្ងៃទៅ ក៏គេយកទៅសម្លាប់ចោល។ ដូច្នេះការសង្ឃឹមមានតែ ខ្លះគេពោលថា “តែយប់ឡើងរស់ថ្ងៃឡើងគឺងាប់”។ ខ្លះគេពោលថា “ថ្ងៃឡើងងាប់យប់ឡើងរស់” សង្ឃឹមតែម្នាក់មួយថ្ងៃៗប៉ុណ្ណឹងឯង”[962]។

---

[959] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ១១ បន្ទាត់ ៧-៨។

[960] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ១១ បន្ទាត់ ១០-១១។

[961] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ១៥ បន្ទាត់ ៨-១៣។

[962] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៦២ បន្ទាត់ ២-៦។

*ព្យសនកម្មផ្ទាល់៖ ការជួបប្រទះនឹងព្រឹត្តិការណ៍ឈឺចាប់ និងអារម្មណ៍ឯកោ*

506. នៅពេល ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត បានរៀបរាប់កុមារដែលបានស្លាប់នៅការដ្ឋាននេះ "ខ្ញុំមានការឈឺចាប់ខ្លាំងណាស់ដល់ពេលធ្វើបានខ្លាំងៗពេក ធ្វើបាបខ្ញុំខ្លាំងពេក"[963]។ គាត់បានផ្តល់សក្ខីកម្ម "ហើយខ្ញុំរស់នៅតែម្នាក់ឯង គ្មានបងប្អូនណានៅជាមួយខ្ញុំទេ"[964]។

*ផលវិបាកសុខភាពផ្លូវចិត្តរយៈពេលវែង*

507. នៅពេលរៀបរាប់ពីឥទ្ធិពលនៃព្យសនកម្មខ្លួននោះ ដើមបណ្តឹងរដ្ឋប្បវេណី ញ៉ឹប ហល់ បានបញ្ជាក់ថា "មាន មាននូវការបាក់កម្លាំង មានការឃើញរបស់ធ្ងន់ៗដូចខ្លាច"[965] ដោយបន្ថែមថា "ព្រោះមិនដឹងទៅសួរនរណាៗ ពិបាកៗតែឯងទៅ"[966]។

508. នៅក្នុងការឆ្លើយតបទៅសំណួរដែលសួរអំពីសុខុមាលភាពផ្លូវចិត្តនៅការដ្ឋានទំនប់ត្រពាំងថ្មនោះ ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ បានផ្តល់សក្ខីកម្មថា "ខ្ញុំមិនដែលមានអារម្មណ៍សប្បាយចិត្តទេ មានតែអារម្មណ៍សោកសង្រេងព្រោះការស្តាយអាល័យ ដែលប្រពន្ធដែលធ្លាប់បានរស់នៅជុំគ្នាទោះបីតិចក្តី ច្រើនក្តីក៏ជាប្តីប្រពន្ធគ្នាដែរ"[967]។

---

[963] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៧ បន្ទាត់ ២២។

[964] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៧ បន្ទាត់ ២២-២៣។

[965] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ញ៉ឹប ហល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ៣៦ បន្ទាត់ ៩។

[966] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ញ៉ឹប ហល់ ប្រតិចារឹក ថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៥ ឯកសារ **E1/336.1** ទំព័រ ៣៦ បន្ទាត់ ១៩។

[967] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៦២ បន្ទាត់ ២២-២៣។

509. ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ ក្រោយមកបានបន្ថែមថា “នៅក្នុងនោះគឺមិនដែលមានថ្ងៃណាថាសប្បាយចិត្តទេ គឺការព្រួយបារម្ភជារៀងរហូត”[968]។

510. នៅពេលរៀបរាប់អំពីផលប៉ះពាល់នៃការចងចាំទាំងនេះលើជីវិតរបស់ខ្លួន ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ បានពន្យល់ថា “រហូតមកដល់សព្វថ្ងៃនេះ គឺថា ពេលណាក៏ជាពេលមួយដែលនឹកឃើញដែរ ប៉ុន្តែពេលធ្វើបុណ្យទាន បានស្តាប់ធម៌ ឬក៏ធ្វើសមាធិអីទៅ ឃើញថា ការកង្វល់ហ្នឹងក៏បាត់បង់ខ្លះ ការកង្វល់ហ្នឹងគឺបាត់បង់ទៅ។ តែបើសិនណាជា មិនបានធ្វើបុណ្យទានគគ្រឹកគគ្រេង មានព្រះសង្ឃ មានអី គឺអារម្មណ៍ពិតជាមានបាទ រៀងរាល់ថ្ងៃ”[969]។

511. នៅពេលនិយាយអំពីផលប៉ះពាល់ដែលនៅតែបន្តមានពីបទពិសោធន៍របស់ខ្លួន ក្នុងអំឡុងពេលនៃរបបនេះលើជីវិតបច្ចុប្បន្នរបស់គាត់ ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន បានប្រកាសថា “នៅមានអារម្មណ៍ជិតជាប់នៅក្នុងខ្លួនរហូត គឺថាអត់ភ្លេចទេ ឲ្យតែរំឭកឡើង តែរំឭក អារឿងហ្នឹងឡើងចង់យំ ស្រក់ទឹកភ្នែករហូត បានអត់ចង់រំឭកឡើងទេ”[970]។

## ៣. ព្យសនកម្មផ្នែកសម្ភារៈ

### *កង្វះឱកាសអប់រំក្នុងអំឡុងពេលនៃរបបនេះ*

512. ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត បានរៀបរាប់ថាតើ “ក្នុងជំនាន់នោះ ខ្ញុំមិនដែលមានការបណ្តុះបណ្តាលកុមារទេ ខ្ញុំមិនដែលឃើញកុមាររៀនសូត្រទេ។ មានតែឲ្យកុមាររៀនសូត្រខាងកាប់ទន្រ្ទានខែត្រ រើសអាចម៍គោមាន។ បើថាឲ្យចូលសាលារៀន គឺគ្មានៗ” យ៉ាងណានោះ[971]។ ក្រោយមក

[968] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៦២ បន្ទាត់ ៩។

[969] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ៦២ បន្ទាត់ ១២-១៥។

[970] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សែន សុផុន ប្រតិចារឹក ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១៥ ឯកសារ **E1/323.1** ទំព័រ ៤៤ បន្ទាត់ ២-៣។

[971] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ១៣ បន្ទាត់ ១៤-១៦។

គាត់បន្ថែមទៀតថា "កុំតែរបបនោះហើយ បំផ្លាញអនាគតរបស់ក្រុមគ្រួសាររបស់ខ្ញុំ ខ្វះការអប់រំ បាទ ខ្វះការអប់រំ ការរៀនសូត្រ ធ្វើឱ្យខ្ញុំនេះមានការឈឺចាប់ខ្លាំងណាស់បាទ"[972]។

## ជំពូក ៤. ការដ្ឋានទំនប់ ១ មករា[973]

### ក. ទិដ្ឋភាពរួមនៃតំណាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី

513. ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៥ នាក់ ពោលគឺ ហ៊ុន សិត្ថានី, អ៊ុន រ៉ន, សៀង សុវីដា, នួន ណារុំ និងចៅ ឡាង បានផ្តល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះអំពីបទពិសោធន៍របស់ពួកគេនៅការដ្ឋានទំនប់ ១ មករា[974]។

---

[972] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សម ស័ក្ត ប្រតិចារឹក ថ្ងៃទី២ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/340.1** ទំព័រ ១៥ បន្ទាត់ ១-៣។

[973] អង្គជំនុំជម្រះសាលាដំបូង ត្រូវបានប្តឹងអំពីអង្គហេតុជុំវិញការបង្កើត និងមុខងាររបស់ទំនប់១មករា នៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ និងដើមឆ្នាំ១៩៧៨ រួមមានទំនប់ និងប្រឡាញជាច្រើន។ ទំនប់នោះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់កែ ពក លេខាភូមិភាគកណ្តាល (ឧត្តរចាស់)។ អង្គជំនុំជម្រះសាលាដំបូង ក៏ត្រូវបានប្តឹងអំពីអង្គហេតុទាក់ទងនឹងលក្ខខណ្ឌរស់នៅ និងការងាររបស់អ្នកធ្វើការនៅទីនោះ ការចាប់ខ្លួន ការបាត់ខ្លួន និងការសម្លាប់អ្នកធ្វើការទីនោះ។ ការចោទប្រកាន់លើអង្គហេតុ បានកើតឡើងនៅក្នុងបរិបទនៃការអនុវត្តគោលនយោបាយទីមួយក្នុងចំណោមគោលនយោបាយចំនួនប្រាំទាក់ទងនឹង "ការបង្កើត និងការទាញយកផលប្រយោជន៍ពីសហករណ៍ និងពីការដ្ឋាន តាមរយៈគ្រប់មធ្យោបាយចាំបាច់"។ លើសពីនេះ មានការចោទថា ប៉ុល ពត អៀង សារី អៀង ធីរិទ្ធិ តាម៉ុក សុន សេន ខៀវ សំផន និង នួន ជា បានមកធ្វើទស្សនកិច្ចនៅការដ្ឋាន។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៣៥១-៣៥៧ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៣៥៨-៣៦៣ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៣៦៤-៣៦៧ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៦៨-១៧០ សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី។ ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងសំណុំរឿង ០០២/០២ ឯកសារ **E301/9/1.1**។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៣៥៧។ ផ្អែកលើការចោទប្រកាន់លើអង្គហេតុទាំងនេះ ជនជាប់ចោទ ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ដែលបានកើតឡើងនៅការដ្ឋានទំនប់១មករា រួមមានការធ្វើឱ្យទៅជាទាសករ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយមូលហេតុជាតិសាសន៍ អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់នៃការរំលោភផ្លូវភេទ (ក្នុងបរិបទនៃការរៀបការដោយបង្ខំ) និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស អំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់នៃការរៀបការដោយបង្ខំ និងអំពើអមនុស្សធម៌ផ្សេងៗទៀតក្រោមទម្រង់ជាការបាត់ខ្លួនដោយបង្ខំ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៣៧៣ ១៣៧៧ ១៣៨១ ១៣៩១ ១៤១៦ ១៤២០ ១៤៣៤ ១៤៤២ ១៤៧០។ សេចក្តីសម្រេចលើការបំបែកកិច្ចដំណើរការនីតិវិធី។ ឧបសម្ព័ន្ធ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលទាក់ទងនឹងសំណុំរឿង០០២/០២ ឯកសារ **E301/9/1.1**។

514. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី ដែលជាប្រជាជនថ្មី មានវត្តមាននៅក្នុងការដ្ឋាននេះ ចាប់ពីខែធ្នូ ឆ្នាំ ១៩៧៦ ដល់ពាក់កណ្តាលឆ្នាំ ១៩៧៧ ហើយជាសមាជិកនៃកងចល័តមួយ[975]។ គាត់បានរៀបរាប់ពីរបៀបដែលពលកររាប់ម៉ឺននាក់មកពីតំបន់ ៤១, ៤២ និង ៤៣ ត្រូវបានចាត់តាំងឱ្យបំបែកថ្ម[976]។ កងរបស់គាត់ មានសមាជិក ៨០ នាក់ ដែលក្នុងនោះ ២០ នាក់ជាប្រជាជនថ្មី និងប្រជាជនមូលដ្ឋានចំនួន ៦០ នាក់[977]។

515. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ដែលជាប្រជាជនថ្មី បានធ្វើការនៅការដ្ឋានទំនប់ ១ មករា ចំនួនពីរដងខុសគ្នា ហើយគាត់ជាសមាជិកនៃកងចល័ត និងរែកដី[978]។ តាមការប៉ាន់ស្មានរបស់គាត់ ការដ្ឋាននេះមានប្រជាជនរាប់ម៉ឺននាក់[979]។ គាត់បានពន្យល់ថា គាត់មិនហ៊ានសួរពីទីតាំងដើមរបស់ពួកគេទេ ពីព្រោះគាត់ខ្លាចគេបញ្ជូនគាត់ទៅរៀនសូត្រ[980]។ ក្នុងនាមជាមនុស្ស ១៧ មេសា ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានពិពណ៌នាថា គាត់មិនហ៊ានសួរអ្វីទាំងអស់[981]។

---

[974] ដើមបណ្តឹងរដ្ឋប្បវេណីចំនួន៤៥នាក់ ត្រូវបានទទួលស្គាល់ដោយ ក.ស.ច.ស ទាក់ទងនឹងការដ្ឋានទំនប់១មករា (ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ៣៦៨)។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន២នាក់ ត្រូវបានទទួលស្គាល់ដោយ អ.ប.ជ។

[975] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី ប្រតិចារឹក ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/305.1** ទំព័រ ៦៦ បន្ទាត់ ១០។

[976] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី ប្រតិចារឹក ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/306.1** ទំព័រ ១៦ បន្ទាត់ ២៣ ដល់ទំព័រ ១៧ បន្ទាត់ ៣។

[977] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី ប្រតិចារឹក ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/306.1** ទំព័រ ២៨ បន្ទាត់ ៣-១៣។

[978] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/307.1** ទំព័រ ៥៥ បន្ទាត់ ១៥-១៦។

[979] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/307.1** ទំព័រ ១២ បន្ទាត់ ១១-១២។

[980] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/307.1** ទំព័រ ១២ បន្ទាត់ ១៦-១៧។

[981] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/307.1** ទំព័រ ១២ បន្ទាត់ ១៦-១៧។

516. ដើមបណ្តឹងរដ្ឋប្បវេណីនេះបានរៀបរាប់ពីការងារដែលគាត់បានចូលរួមធ្វើ នៅក្នុងអំឡុងពេលនីមួយៗ និងបានពន្យល់ពីរបៀបដែលពលករត្រូវដើរក្នុងចម្ងាយផ្លូវឆ្ងាយដើម្បីទៅដល់ការដ្ឋាន[982]។ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន បានរៀបរាប់ថាតើការងារជីកដី និងរែកដី ព្រមទាំងការកាត់ឈើ និងសំអាតព្រៃដែលគាត់បានធ្វើមានលក្ខណៈយ៉ាងណា[983]។ នៅពេលគាត់បានទទួលការងារឱ្យកាត់ និងសំអាតព្រៃនោះ ពលករត្រូវបានប្រគល់ឱ្យនូវពូថៅ និងពុំមានផែនការការងារជាក់លាក់ទេសម្រាប់កិច្ចការនេះ[984]។ ទោះជាយ៉ាងនេះក្តី នៅពេលគាត់ត្រូវបានប្រគល់ការងារឱ្យរែកដី ផែនការការងារចំនួន ៤ ម៉ែត្រគូប ត្រូវបានកំណត់ ហើយគាត់ត្រូវតែរែកដីដើរក្នុងចម្ងាយប្រមាណជា ៤០ ម៉ែត្រ[985]។

517. ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវីដា ដែលជាប្រជាជនថ្មី បានធ្វើការងារនៅកន្លែងមួយនៅតាមបណ្តោយប្រឡាយដែលមានឈ្មោះថាប្រឡាយ ១ មករា នៅតាមស្ទឹងជីនិត ដែលមានចម្ងាយយ៉ាងឆ្ងាយពីផ្លូវធំ។ គាត់ជាសមាជិកក្មេងបំផុតនៃកងចល័ត ដែលនៅពេលនេះគឺមានអាយុ ១១ ឬ ១២ ឆ្នាំ[986]។ គាត់បានធ្វើនៅកន្លែងនោះអស់រយៈពេលប្រមានជាបីខែ[987]។ ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវីដា បានរៀបរាប់ពីរបៀបវាស់ដីឱ្យក្រុមរបស់គាត់សម្រាប់រយៈពេល កន្លះខែ ឬមួយខែ ហើយនៅពេលការងារនេះបានចប់រួចរាល់ ពួកគេទៅធ្វើការងារនៅកន្លែងផ្សេងទៀត[988]។ គាត់បាន

[982] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/307.1** ទំព័រ ១១ បន្ទាត់ ៤-៦។

[983] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/307.1** ទំព័រ ១៣ បន្ទាត់ ៩ ដល់ទំព័រ ១៤ បន្ទាត់ ១៤។

[984] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/307.1** ទំព័រ ទំព័រ ១៣ បន្ទាត់ ៩ ដល់ទំព័រ ១៤ បន្ទាត់ ១៤។

[985] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/307.1** ទំព័រ ១៤ បន្ទាត់ ១១-១៣ ទំព័រ ១៤ បន្ទាត់ ២១-២៣។

[986] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវីដា ប្រតិចារឹក ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **E1/308.1** ទំព័រ ៧ បន្ទាត់ ១២-១៤។

[987] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវីដា ប្រតិចារឹក ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **E1/308.1** ទំព័រ ៦ បន្ទាត់ ១៧-១៨។

[988] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវីដា ប្រតិចារឹក ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **E1/308.1** ទំព័រ ១០ បន្ទាត់ ១៤-២០។

រៀបរាប់ថាតើការដ្ឋានកាន់តែមានចម្ងាយឆ្ងាយទៅៗពីកន្លែងដេករបស់ពួកគេយ៉ាងណា និងតើពួកត្រូវផ្លាស់ទៅរកកន្លែងដេកនៅជិតៗការដ្ឋានដោយរបៀបណា[989]។

518. ទាក់ទងនឹងការងារដែលត្រូវបានចាត់តាំងឲ្យគាត់ធ្វើ ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវីដា បានផ្តល់សក្ខីកម្មថា គាត់បានទទួលការងាររែកដីពីប្រឡាយទៅខ្នងទំនប់ ហើយថា ពលករប្រុសជាអ្នកជីកដី[990]។ ដោយសារតែគាត់មានវ័យក្មេងជាងពលករផ្សេងៗទៀត ពេលខ្លះគាត់ត្រូវបានដាក់ការងារយកទឹកឲ្យពលករផឹក[991]។ គាត់ក៏បានរៀបរាប់ថា បង្គីរបស់គាត់តូចជាបង្គីរបស់ពលករផ្សេងៗទៀត ហើយថា បង្គីនោះក៏មិនត្រូវបានដាក់ដីឲ្យពេញដែរ ដោយសារតែគាត់នៅក្មេង[992]។

519. ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ និង ចៅ ឡាង ដែលជាប្រជាជនថ្មីបានផ្តល់សក្ខីកម្មទាក់ទងនឹងព្យសនកម្មដែលពួកគាត់មាន ដោយសារតែបទពិសោធន៍របស់ខ្លួន។ ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ បានផ្តល់សក្ខីកម្មថា គាត់គឺជាសមាជិកនៃកងចល័តមួយ ហើយត្រូវបានបញ្ជូនទៅការដ្ឋានទំនប់ ១ មករា នៅខែ មករា ឆ្នាំ ១៩៧៧ ដែលកន្លែងនេះ គាត់បានធ្វើការពី ៦ ទៅ ៧ ខែ[993] ហើយដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឡាង គឺជាសមាជិកនៃកងចល័តមួយក្នុងតំបន់ ៤២[994]។

## ខ. ភស្តុតាងនៅកន្លែងកើតហេតុដែលដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់នៅពេលសវនាការ

---

[989] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវីដា ប្រតិចារឹក ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **E1/308.1** ទំព័រ ១១ បន្ទាត់ ១-៥។

[990] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវីដា ប្រតិចារឹក ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **E1/308.1** ទំព័រ ១០ បន្ទាត់ ២១ ដល់ទំព័រ ១១ បន្ទាត់ ៥។

[991] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវីដា ប្រតិចារឹក ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **E1/308.1** ទំព័រ ១០ បន្ទាត់ ២១ ដល់ទំព័រ ១១ បន្ទាត់ ៥។

[992] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវីដា ប្រតិចារឹក ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០១៥ ឯកសារ **E1/308.1** ទំព័រ ១២ បន្ទាត់ ៧-៩។

[993] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ ប្រតិចារឹក ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/339.1** ទំព័រ ១១ បន្ទាត់ ២០។

[994] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឡាង ប្រតិចារឹក ថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០១៥ ឯកសារ **E1/339.1** ទំព័រ ៤៦ បន្ទាត់ ១៤-១៩។

## ១. ការធ្វើឲ្យទៅជាទាសករ

520. ភ័ស្តុតាងពីដើមបណ្តឹងរដ្ឋប្បវេណីដែលបានលើកឡើងក្នុងពេលសវនាការបង្ហាញថា ពលករនៅការដ្ឋានទំនប់ ១ មករា ប្រឈមនឹងការប្រើប្រាស់អំណាចណាមួយ ឬអំណាចទាំងអស់ ដែលប៉ះពាល់ដល់សិទ្ធិផ្ទាល់ខ្លួនរបស់បុគ្គល។

### ១.១. ការងារដោយបង្ខំ

521. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានផ្តល់សក្ខីកម្មថា "គឺមិនអាចមានជម្រើសទេ។ ពាក្យថា "ចាត់តាំង" មួយម៉ាត់ហ្នឹងគឺខ្លាំងក្លាហើយ។ គេអ្នកស្រុកចាស់ គេប៉ានតវ៉ា ចំណែកខ្ញុំអ្នកស្រុកថ្មីហ្នឹង អ្នកថ្មីហ្នឹងគឺគ្មាន គឺគ្មានតែម្តង។ តែតម្រូវឲ្យទៅ គឺទៅដោយមិនប្រកែកបាន ដែលយើងគ្មានសិទ្ធិនោះណា គ្មានសិទ្ធិអីទេ គ្មានសោះសូន្យតែម្តង។ ពិបាកចិត្តហ្នឹងបានត្រឹមតែយំហ្នឹង បានត្រឹមតែគ្រាំគ្រាក្នុងខ្លួន។ តឹងទ្រូងប៉ុនណា ដែលតវ៉ាមិនបាន និយាយមិនកើត អស់លោកដឹងហើយពិបាកប៉ុនណា ក្នុងទ្រូង ក្នុងខ្លួនហ្នឹងវាប៉ុនណាទៅ"[995]។

522. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន បានផ្តល់សក្ខីកម្មថា "អត់មានឲ្យជ្រើសរើសកិច្ចការណាដែលស្រួល ដែលយើងថាអាចធ្វើបានគឺអត់ទេ"[996]។ គាត់មិនធ្លាប់បានទទួលប្រាក់កម្រៃពីការងារនៅឯការដ្ឋាននេះឡើយ[997]។

### ១.២. ការអះអាងពីសិទ្ធិផ្តាច់មុខ

523. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន បានផ្តល់សក្ខីកម្មថា នៅក្នុងក្រុមធំរបស់គាត់ដែលមានសមាជិកប្រមាណជា ១០០ នាក់ "បាន១សិទ្ធិសេរីភាពមកពីណានឹងទទួលខុសត្រូវខ្លួនឯង បើថ្នាំនៅលើគេ ឆ្នាំងបាយលើគេ ចាននៅលើគេ បានអ្វីមកទទួលខុសត្រូវខ្លួនឯង វាគ្មាន"[998]។

---

[995] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី ប្រតិចារឹក ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/306.1** ទំព័រ ២៤ បន្ទាត់ ៤-៨។

[996] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/307.1** ទំព័រ ២០ បន្ទាត់ ៤-៥។

[997] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/307.1** ទំព័រ ១៩ បន្ទាត់ ២០។

## ១.៣. ការគ្រប់គ្រង

### i. ការគ្រប់គ្រងផ្លូវចិត្ត

*ការបង្កើតឱ្យមានបរិយាកាសភ័យខ្លាច*

524. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន បានរៀបរាប់ពីប្រធានកងរបស់គាត់ជាមនុស្សដែល "និយាយថា "ចង់ងាប់ ចង់រស់" ហើយភាគច្រើននិយាយពេលព្រឹក"[999]។ គាត់បាននិយាយដូច្នេះចំនួនពីរ ឬបីដង[1000]។ "មកពីគាត់ប្រើពាក្យហ្នឹងឯង សមាជិកវាបាត់ៗសមាជិកនៅកន្លែងរែកដី ដូចថាវាឈឺច្រើន វាបាត់ៗដោយសារវាឈឺ"[1001] និង "ក្រោយពីថាគំរាមកំហែង មនុស្សធម្មតាគំរាមកំហែងហើយវារាងញ្ញោចដែរ ព្រោះឈឺនោះ បើតាមមើលទៅវាឈឺហេវទេ វាមិនមានថាឈឺដល់ ឈឺដូចយើងសព្វថ្ងៃទេ វាឈឺហេវៗអស់កម្លាំងដែលហូបវាមិនគ្រប់ ដល់ទៅខ្លាំងពេកវាមិនហេវៗទៅសម្រាកខ្លះទៅ។ ដល់ពេលមានប្រធានកង ប្រធានក្រុមអីគេដាស់អ៊ីចឹងឯងទៅ ស្អែកឡើងក៏គ្នាទៅបំពេញការងារវិញទៅ នៅក៏នៅមួយពីរទៅ។ ដល់គេគំរាមខ្លាំងទៅ ក៏ចុះអស់ពីរោងដែរហ្នឹងណា ទៅធ្វើការវិញនោះ ខ្លាចស្លាប់ជីវិតមិនដឹងទេ ដល់ហើយក៏ចេះតែទៅត្រដាបត្រដួសម៉េចក៏ទៅៗ"[1002]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានពន្យល់ថា ប្រធានកងនោះ "ប្រើពាក្យហ្នឹងឯង សមាជិកវាបាត់ៗសមាជិកនៅកន្លែងរែកដី ដូចថាវាឈឺច្រើន វាបាត់ៗដោយសារវាឈឺ។ វាបាត់ៗកម្លាំង វាមិនមែនបាត់ដ៏ពាក់កណ្ដាលទេ ដូចថាវាឈឺមួយកង នៅដល់បួន ប្រាំ ប្រាំមួយនាក់ទៅ ចុះបើបីកងតូចទៅ វាឃើញប៉ុន្មាននាក់ទៅហើយ វា១០នាក់ទៅហើយវាបាត់កម្លាំង ហើយរណ្ដៅគេមិនត្រូវ

[998] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារិក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/307.1** ទំព័រ ៤២-៤៣ បន្ទាត់ ២៥-១។

[999] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារិក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/307.1** ទំព័រ ២៩ បន្ទាត់ ១៣-១៤។

[1000] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារិក ថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៥ ឯកសារ **E1/307.1** ទំព័រ ២៩ បន្ទាត់ ២៤។

[1001] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារិក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ៣០ បន្ទាត់ ៦-៧។

[1002] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារិក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ៣០ បន្ទាត់ ១៤-១៩។

ការហ៊ុនចូលគ្នា ពីនាក់ៗមួយគូៗ ដល់វាបាត់មនុស្សនៅពេលហ្នឹងឯង គេដឹងហើយ។ ចាស ដល់គេដឹងទៅ វាបាត់កម្លាំងនៅពេលនោះឯង វាមិនមែនបាត់ខ្លួនថាយកទៅវៃចោលអី អត់ទេ គ្រាន់តែបាត់កម្លាំងពលកម្ម នៅពេលដែលកំពុងជីកដីហ្នឹងឯងនោះ"[1003]។

525. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន បានពន្យល់ថា អ្នកឈឺមិនហ៊ានប្រាប់ប្រធានកងថា គេឈឺនោះទេ។ "បានតែមិនហ៊ានប្រាប់ខ្លាចគេ ខ្លាចគេយកទៅសម្លាប់ យកទៅកសាង យកទៅអប់រំ"[1004]។

526. ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឡាង បានលើកឡើងថា "គឺដឹងតែពេលណាដែលយើងរែកទៅៗ អារម្មណ៍គិតថា ធ្វើម៉េចខំប្រឹងធ្វើម៉េច ដើម្បីឲ្យចៀសផុតនូវការសម្លាប់នោះ។ អ៊ីចឹងទេ ពុំបានចាប់អារម្មណ៍អ្វីទេ។ លុះធ្វើរែកទៅៗ សម្លឹងទៅសម្លឹងមក ស្រាប់តែបាត់មួយអ៊ីចឹងទៅ អូ៎! មិត្តនោះបាត់ហើយ មិនដឹងបាត់មូលហេតុអីទេ ចាសបាត់ហើយ"[1005]។

527. ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ បានផ្តល់សក្ខីកម្មថា "ធ្វើការទាំងយប់ទាំងថ្ងៃ គឺគ្មានបាន -- ពេលឈឺ ឈប់ គេមិនឲ្យយើងឈប់ទេ។ គេថាឲ្យទៅឈឺ ឲ្យទៅដួលនៅកន្លែងឲ្យដាក់ស្តែង ដួលនៅកន្លែង។ នៅក្នុងអំឡុងធ្វើការហ្នឹង គឺគេសង្កេតការណ៍ជានិច្ច អ្នកណាមានទម្រន់ អ្នកណាមិនសកម្មការងារ គឺត្រូវបាត់។ ពួកសង្កាត់របស់ខ្ញុំ គឺបាត់ច្រើន។ ដូច្នេះនាងខ្ញុំធ្វើការ ទោះបីឈឺជា ក៏ខំទៅ គ្មានពេលសម្រាក"[1006]។

528. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានរៀបរាប់ពីភាពភ័យខ្លាចក្នុងការបង្ហាញពីទុក្ខសោកនៅពេលឪពុករបស់គាត់ស្លាប់ ព្រោះខ្លាចគេចោទថាមានបញ្ហាសតិអារម្មណ៍។ គាត់បានរៀបរាប់ថា "ពេលនោះ យំអត់ចេញទេ សូម្បីតែទឹកភ្នែកមួយដំណក់ក៏អត់មានស្រក់កើតដែរ។ ល្បួងប្អូន "អូនឯងទៅកន្លែងវិញ ខំធ្វើការណាអូនណា ធ្វើម៉េចសុំម៉ារស់ អូនឯងទ្រាំទៅ"។ ពេលនោះ ធ្វើម៉េចក៏

[1003] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ៣០ បន្ទាត់ ៦-១១។

[1004] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ២០ បន្ទាត់ ១៧-១៨។

[1005] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចាវ ឡាង ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ៥៤បន្ទាត់ ១៣-១៦។

[1006] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ១០ បន្ទាត់ ៤-៧។

យំមិនចេញ យំអត់ចេញសោះ។ ខ្ញុំស្រែកយំបាន នៅពេលដែលមានភ្លៀងធ្លាក់ធំទេ ដែលខ្ញុំស្រែកយំ គឺខ្ញុំយំឱ្យអស់ពីក្នុងខ្លួន។ ខ្ញុំយំមួយទំហឹងហើយ ព្រោះខ្ញុំគ្មានពេល គ្មានសិទ្ធិយំទេ ទាល់តែភ្លៀងធំ ផ្គរលាន់ក្នុងៗបានខ្ញុំស្រែកហើយ ពេលណាក៏ខ្ញុំស្រែកយំដែរ ឱ្យតែភ្លៀង។ ខ្ញុំនឹកឃើញរឿងទាំងអស់។ នៅមុខគេខ្ញុំគ្មានសិទ្ធិទេ កុំឱ្យគេថា ខ្ញុំនឹងសតិអារម្មណ៍ គិតអី។ អ៊ីចឹង ខ្ញុំត្រូវតែទ្រាំក្នុងខ្លួន ទ្រាំហ្នឹងពិបាកណាស់ទ្រាំហ្នឹងពិបាកមែនទែន សឹងរហែកដើមទ្រូងងាប់ភ្លាមៗហើយ។ ចុកអស់ហើយក្នុងខ្លួន នេះគឺការអត់ធ្មត់។ ដល់ពេលភ្លៀងខ្លាំងហ្នឹង យើងបានស្រែក បានយំ នឹកឃើញប៉ា នឹកឃើញម៉ាក់ នឹកឃើញប្អូន ដែលបែកបាក់គ្នា។ ហ្នឹងបានយើងមានសិទ្ធិយំៗ កុំឱ្យគេឮ”[1007]។

## *ការពិនិត្យតាមដាន និងតួនាទីប្រជាជនមូលដ្ឋាន*

529. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន បានផ្តល់សក្ខីកម្មផងដែរថា ពលករត្រូវបានត្រួតពិនិត្យ ដើម្បីធានាថា ពួកគេបំពេញការងារឱ្យបានបួនម៉ែត្រគូប ដោយបានពន្យល់ថាគឺជា “ប្រធានកងធំ។ ប្រធានកងធំ ល្ងាចឡើងដើរមើលហើយ”[1008]។

530. ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឡាង បានពន្យល់ថា ពាក់ព័ន្ធនឹងការពិនិត្យតាមដាននេះ “គឺមិនថាតែទំនប់១មករាទេ ទីកន្លែងណាក៏មានទាំងអស់ការតាមដាន។ គ្រប់ពេលគ្រប់វេលា ការនិយាយស្តីក៏ត្រូវប្រយ័ត្ន ការជួបគ្នា ស៊ីញ៉ូគ្នា ឬកេះគ្នា គឺគេតាមមើលគ្រប់ពេលគ្រប់វេលា”[1009]។ គាត់បានផ្តល់សក្ខីកម្មថា “គឺដឹងតែពេលណាដែលយើងរែកទៅៗ អារម្មណ៍គិតថា ធ្វើម៉េចខំប្រឹងធ្វើម៉េចដើម្បីឱ្យចៀសផុតនូវការសម្លាប់នោះ។ អ៊ីចឹងទេ ពុំបានចាប់អារម្មណ៍អ្វីទេ។ លុះរែកទៅៗ សម្លឹងទៅសម្លឹងមក ស្រាប់តែបាត់មួយចឹងទៅ អ្ហូ! មិត្តនោះបាត់ហើយ មិនដឹងបាត់មូលហេតុអីទេ ចាសបាត់ហើយ”[1010]។

---

[1007] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ២៤-២៥ បន្ទាត់ ២០-៣។

[1008] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ១៨ បន្ទាត់ ៤។

[1009] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចាវ ឡាង ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ៦៣ បន្ទាត់ ១-៣។

[1010] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចាវ ឡាង ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ៥៤ បន្ទាត់ ១៣-១៦។

531. ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវីដា បានផ្តល់សក្ខីកម្មពីតួនាទីរបស់ប្រជាជនមូលដ្ឋានថា "នៅក្នុងព្រៃកប្រសព្វហ្នឹង គេចែកចេញជាកង កងហើយចែកចេញជាក្រុម ក្រុមហើយមានជាពួកតូចៗ តែអ្នកក្តោបក្តាប់ហ្នឹង គឺប្រជាជនមូលដ្ឋាន"[1011]។ "ធ្វើការដូចគ្នា ក៏ប៉ុន្តែប្រជាជនថ្មីគ្មានសិទ្ធិទេ ដូចអ្នកទោសអ៊ីចឹង ដូចជាសត្រូវ ហើយពួកប្រជាជនមូលដ្ឋានហ្នឹងគេលើកអ្នកដែលជនក្រីក្រ ឬក៏មានចែកជាពីរហ្នឹងមកកាន់អំណាច"[1012]។

532. ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ បានផ្តល់សក្ខីកម្មថា កងនារីរបស់គាត់នៅក្រោមមេកងពីរនាក់ "មានឈ្មោះមិត្តរ៉ាត ហើយនិង មិត្តលី"[1013]។ "មិត្តពីរនាក់ហ្នឹងមិនមែនជាអ្នកទទួលខុសត្រូវខាងម្ហូបអាហារទេ គ្រាន់តែជាមើលការខុសត្រូវនៅក្នុងការដ្ឋាននារីៗប៉ុន្មាននាក់ហ្នឹងទេ"[1014]។

533. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានរៀបរាប់ពីរបៀបដែលកងឈ្លបធ្វើការគ្រប់គ្រងកន្លែងធ្វើការងារផ្ទាល់របស់ពលករ។ "ពេលម៉ោងធ្វើការហ្នឹង ព្រោះយោធានៅយាមកៀកៗកន្លែងយើងចាក់ដីហ្នឹង"[1015]។

### *តួនាទីនៃកិច្ចប្រជុំអប់រំកែប្រែ*

534. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន បានផ្តល់សក្ខីកម្មថា នៅក្នុងអំឡុងពេលនៃកិច្ចប្រជុំតាមកងតូចៗ ដែលត្រូវធ្វើឡើង ជារៀង បី ឬ បួនថ្ងៃម្តង "... ក៏មានគ្មានអ្វីក្រៅពីជំរុញឲ្យៗដូចជា ឲ្យយើងឲ្យលឿន ឲ្យរហ័ស សម្រុក ផែនការសម្រុក។ កុំឈឺច្រើន តែឈឺច្រើន នៅនឹងរោងច្រើន ខ្លាចគេយក

[1011] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ាង សុវីដា ប្រតិចារឹក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ១២ បន្ទាត់ ១៤-១៥។

[1012] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ាង សុវីដា ប្រតិចារឹក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ៣៩ បន្ទាត់ ១-២។

[1013] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ២៧ បន្ទាត់ ១៣។

[1014] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ២៧ បន្ទាត់ ១៦-១៧។

[1015] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ១១ បន្ទាត់ ១២-១៣។

ទៅកសាងអប់រំ"[1016]។ យើងគ្មានជម្រើសក្នុងការចូលរួមប្រជុំទេ ឬអត់នោះទេ "ព្រោះគេជាប្រធានក្រុមយើង។ បើសិនយើងរឹងទទឹង យើងខ្លាចគេ"[1017]។ "ប្រជុំកងធំ មួយខែប្រជុំម្តង កងធំ"[1018]។

535. ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវីដា ក៏បានផ្តល់សក្ខីកម្មពីការប្រជុំនៅការដ្ឋានទំនប់ ១ មករាថា "ប្រជុំតាមកង តាមភូមិ តាមក្រុមតូចៗ ស្រុកពួកខ្ញុំឧស្សាហ៍ប្រជុំ បើមីទ្ទីង នាងខ្ញុំជួបម្តង ឬក៏ពីរ នាងខ្ញុំអត់ចាំ ប្រហែលជាម្តងហើយ ឬក៏ពីរហ្នឹងអស់ហើយ។ ប្រជុំធំរួមអ្នកទំនប់១មករាទាំងអស់គ្នាហ្នឹង ហ្នឹងមីទ្ទីងធំ។ បើតាមកង ឧស្សាហ៍ប្រជុំណាស់ អត់ខានទេ បើក្រុមតូចៗហ្នឹងប្រជុំញឹកញាប់"[1019]។ គាត់ពន្យល់បន្ថែមទៀតថា "គឺនិយាយពីការងារ ជំរុញការងារធ្វើឲ្យលឿនជាងគេ ធ្វើឲ្យស្រុកយើងបានលឿនជាងគេ ឆាប់ហើយជាងគេ ស្រុកគេណាគេសម្រាក ឬក៏គេធ្វើម៉េចធ្វើយូរ យើងឲ្យបានលឿន។ ចង់ៗដូចថា ឲ្យយើង -- ស្រុកយើងហ្នឹងឈានមុខគេអ៊ីចឹង។ ហើយមួយទៀតគេ – ខ្ញុំសុំនិយាយពីរឿងការភាសានៅរបបនោះ ភាសាខ្មែរក្រហម ទ្រឹស្តីរបស់គាត់ៗចូលចិត្តថា "ស្វ័យទិតៀន" ស្វ័យទិតៀនហ្នឹង គឺឲ្យមើលគ្នាទៅវិញទៅមកដើម្បីកែលម្អ។ តាមពិតគឺចាំចាប់កំហុស ហើយចូលចិត្តប្រើពាក្យ "ភ្នែកម្នាស់ អង្គការភ្នែកម្នាស់ ហើយកងប្រវត្តិសាស្ត្រហ្នឹង គឺវិលៗ បើយើងនេះមិនទាន់ប៉ះដៃគឺដៃ ប៉ះជើងគឺជើង""[1020]។ "ហើយអ្នកឈឺហ្នឹង មានគេហៅឈឺគ្រុនទន្សាយ អីល្មមៗគឺត្រូវឲ្យយើងទៅធ្វើការ កុំឲ្យយើងទម្រន់។ របបនេះគឺអត់មាន ថាយើង

[1016] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ២៥ បន្ទាត់ ១៧-១៩។

[1017] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ២៥ បន្ទាត់ ២២-២៣។

[1018] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ៥៥ បន្ទាត់ ៩។

[1019] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវីដា ប្រតិចារឹក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ២១ បន្ទាត់ ១៨-២០។

[1020] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវីដា ប្រតិចារឹក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ២១-២២ បន្ទាត់ ២៥-៦។

រំដោះបានហើយ គឺអត់មានអ្នកខ្ជិលច្រអូស អ្នកពុករលួយ គេតាមសង្កេតមើលយើង បើយើងខ្ជិល បើយើងម៉េចៗ គេថាយើងនាយទុន សក្តិភូមិអីអ៊ីចឹង"[1021]។

536. ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឡាង បានបញ្ជាក់បន្ថែមពីការរៀបចំអង្គប្រជុំ ហើយបានផ្តល់សក្ខីកម្មថា "មួយរយៈពេល៣ថ្ងៃ មួយអាទិត្យ គេប្រជុំម្តងអ៊ីចឹងទៅចាស គេប្រជុំម្តង គេឲ្យប្តេជ្ញាចិត្ត។ "យើងខ្ញុំទាំងអស់គ្នាប្តេជ្ញាចិត្ត សម្រេចតាមផែនការរបស់អង្គការដាក់ចុះឲ្យបាន១០០ភាគរយ ជយោ! មហាលោតផ្លោះ មហាអស្ចារ្យ!"។ ចាស ប៉ុន្តែការប្រជុំនេះ គេបានព្រមានគេថា "មិត្តទាំងអស់ កង់ប្រវត្តិសាស្ត្រវិលទៅមុខហើយណាមិត្ត អត់ថយក្រោយបានទេ មិត្តណាហ៊ានប្រឆាំង មិត្តណាហ៊ានយកដៃទៅរាំងវា មិត្តហ្នឹងដាច់ដៃ មិត្តណាហ៊ានយកជើងទៅរាំងវា មិត្តហ្នឹងគឺដាច់ជើងហើយ"។ អ៊ីចឹងក្នុងម្នាក់ៗហ្នឹង គឺប្តេជ្ញាៗដាច់ខាតត្រូវតែធ្វើឲ្យបានតាមផែនការរបស់អង្គការដាក់ចុះ"[1022]។

### ii. ការគ្រប់គងលើការធ្វើដំណើរ៖ វិធានការដើម្បីទប់ស្កាត់ ឬបញ្ចៀសការលួចរត់

537. ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវីដា បានពន្យល់ថា "ពុំអាចធ្វើដំណើរតាមចិត្តបានទេ គ្មានសិទ្ធិ។ នៅ៣ខែ ខ្ញុំអត់បានមកផ្ទះទេ។ ទាំងអស់គ្នា មិនមែនតែពួកខ្ញុំទេ។ អ្នកនៅភូមិឫស្សីកែវលើទាំងអស់ អត់មានអ្នកណាបានត្រឡប់មកផ្ទះ ទាល់ដល់គ្រប់គម្រប់៣ខែ"[1023]។

538. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន បានបញ្ជាក់ថា ពលករ "អត់ដើរទៅណាបាន ដើរសេរីបានទេ"[1024]។ "ទៅដើរហើរសេរីខ្លួនឯង គឺគេយកទៅកសាង ឬអប់រំទៀត"[1025]។ គាត់មិនបានឃើញ

---

[1021] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ាង សុវីដា ប្រតិចារឹក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ២២ បន្ទាត់ ១១-១៤។

[1022] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចាវ ឡាង ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ៥៤ បន្ទាត់ ២-៨។

[1023] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ាង សុវីដា ប្រតិចារឹក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ៣៩ បន្ទាត់ ១៦-១៨។

[1024] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ២១ បន្ទាត់ ១៩។

[1025] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/ 307.1** ទំព័រ ២១ បន្ទាត់ ២២។

កងឈ្លប ឬទាហាននៅការដ្ឋានឡើយ[1026]។ ប៉ុន្តែ "បើសិនជារត់ គេចាប់យើងទៅអប់រំ យកទៅកែប្រែ ឬក៏ហេងស៊យអាចយកទៅសម្លាប់ផងក៏អាចថាបានដែរ ព្រោះយើងរត់ យើងមិន -- គេចពីការងារ យើងមិនក្បត់ពីគេ ក្បត់ពីអង្គការ"[1027]។

539. ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ បានពន្យល់ថា "ថ្ងៃមួយនោះ ខ្ញុំឈឺ ខ្ញុំក្តៅខ្លួន ខ្ញុំសុំឈប់ មិត្តម្នាក់ហ្នឹង ក៏គាត់ឈឺ...។ មិត្តហ្នឹងគាត់រែកដីទៅ គឺគាត់ឃើញជួបបងជីដូនមួយប្រុសរបស់គាត់ ឃើញគ្នានៅក្នុងការដ្ឋានរែកដីហ្នឹង។ ហើយយើងបែកគ្នាយូរ ក៏សួរនាំមួយម៉ាត់ពីរនៅកន្លែងណា ថានៅរោងសង្កាត់កំពង់ថ្ម ហើយរោងហ្នឹងនៅចម្ងាយប្រហែល១៥ម៉ែត្រពីរោងដែលនាងខ្ញុំរស់នៅហ្នឹង។ ពេលដែលសម្រាកមួយថ្ងៃដែលឈឺសុំគេឈប់ហ្នឹង មិត្តខ្ញុំក៏ហៅនាងខ្ញុំ បបួលនាងខ្ញុំទៅថា "ទៅរោងបងជីដូនមួយនាងខ្ញុំពីរនាក់មួយភ្លែតទៅ រោងនៅកន្លែងនេះ ជិតគ្នា។ ខ្ញុំជួបនៅកាលកន្លែងរែកដី តែគាត់ប្រាប់ថា រោងគាត់នៅហ្នឹង"។ ពេលទៅក៏ទៅជាមួយគ្នា។ ដល់ពេលមកវិញ ប្រធានកងគេសួរថា "មិត្តឯងមកពីណា?" ហើយ មិត្តវន ហ្នឹងគាត់ឆ្លើយថា "ខ្ញុំជួបបងជីដូនមួយខ្ញុំ ហើយខ្ញុំចង់ គាត់ថារោងគាត់នៅត្រង់ហ្នឹង ខ្ញុំចង់ដើរទៅជួបគាត់មួយភ្លែត"។ តែគេស្តីឱ្យៗគេវ៉ៃ ហើយគេយកកន្សែងដែលគាត់ទទូរហ្នឹងពណ៌ក្រហម ទទូរដូចក្រមាហ្នឹងពណ៌ក្រហមចងគាត់ ចងដៃទៅក្រោយអ៊ីចឹង ហើយនាងខ្ញុំភ័យណាស់។ នាងខ្ញុំអត់មាត់អីទាំងអស់ ព្រោះនាងខ្ញុំទៅដោយសារគេអ៊ីចឹង គេអត់ចងខ្ញុំទេណា។ គេចងមិត្តខ្ញុំហ្នឹង នៅនឹងមុខនាងខ្ញុំហ្នឹង តែនាងខ្ញុំអត់មាត់អីមួយម៉ាត់ទេ។ គេសួរៗតែមិត្តខ្ញុំហ្នឹង គេឆ្លើយទៅ។ គេថា "មិត្តឯងគ្មានសិទ្ធិដើរទៅណាក្រៅពីក្នុងរោងទេ!"។ គេស្តីគេជេរ ហើយគេចង"[1028]។

540. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានផ្តល់សក្ខីកម្មថា "ពេលយាមហ្នឹង គឺគេកាន់អាវុធ។ គេនៅឈរការពារខ្លាចរត់។ ខ្លាចមានអ្នករត់ចោលការដ្ឋាន។ ខ្លាចមានអ្នកទៅលួចសម្ងំខ្ជិលរែកដី។ បើចង់បត់ដៃបត់ជើងអី ចុះទៅ ជួនកាលទៅបត់ជើងនៅមុខគេហ្នឹងហ្នងទៅ។ អើ! មិនដឹងទៅណា

---

[1026] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ E1/ 307.1 ទំព័រ ២២ បន្ទាត់ ២។

[1027] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ E1/ 307.1 ទំព័រ ២៧ បន្ទាត់ ១៦-១៨។

[1028] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/ 339.1 ទំព័រ ២៥ បន្ទាត់ ១០-២៣។

ហើយបើគេឃាម។ យើងហ៊ានទៅណា។ ឈឺបត់ជើងតូចអី ទៅដល់គេឈរអ៊ីចឹង នោមនឹងជើងហ្នឹង មិនដឹងទៅណាហើយ។ ទៅឆ្ងាយពីគេបន្តិចទៅ គេស្រែកឲ្យ ឲ្យមកវិញៗ។ អ៊ីចឹងមិនដឹងទៅណា អ្នកឯងឈរត្រង់ហ្នឹង នោមត្រង់ហ្នឹងទៅ"[1029]។ គាត់បានផ្តល់សក្ខីកម្មថា "ចំពោះអ្នកថ្មី គឺខ្លាចគេណាស់កូន មិនហ៊ានទេ។ បើអ្នកចាស់ គេអាចមានសិទ្ធិ។ បើថាប្រជាជនថ្មី មិនហ៊ានសោះៗតែម្តង។ ខ្លាចណាស់ ខ្លាចៗជាទីបំផុត។ បើអ្នកប្រជាជនចាស់ហ្នឹងគេមានសិទ្ធិជាង អាចទៅសុំទៅ ចេញទៅខុសពីហ្នឹងប្រហែល១០-២០ម៉ែត្រអីបាន អ្នកចាស់។ បើថាអ្នកថ្មី រួញខ្លួនហើយកូន រួញដូចដុកឡឿអ៊ីចឹង មិនហ៊ានទេ។ តែគេហាមត្រឹមណា គឺត្រឹមហ្នឹងហើយ មិនហ៊ានទៅជិតទេ"[1030]។

541. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន បានពន្យល់ថាគេ "ប្រាប់។ ប្រាប់ផ្ទាល់មាត់បណ្តោយ" ដល់ពលករថា បើគេហ៊ានរត់នោះ គេនឹងចាប់យកទៅអប់រំ រៀនសូត្រឡើងវិញ ឬសម្លាប់ចោល[1031]។

### iii. ការគ្រប់គ្រងការនិយាយស្តី

542. ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវីដា បានផ្តល់សក្ខីកម្មថា "អត់បាននិយាយអីច្រើនជាមួយទេ ហើយក៏អត់បានលេងសើចអីច្រើនដែរ គេមិនឲ្យ -- និយាយទៅដូចជាគេហៅថាដាំដើមគ យើងនិយាយអីតែមិនស្រួល យើងមានបញ្ហា អ៊ីចឹងអត់ហ៊ាននិយាយអីច្រើនទេ"[1032]។ "គាត់ប្រជាជន ១៧មេសា គាត់ -- គេមិនឲ្យយើងនិយាយគ្នាទេ"[1033]។

---

1029 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ៨ បន្ទាត់ ៣-៧។

1030 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ៨ បន្ទាត់ ១៣-១៧។

1031 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ **E1/307.1** ទំព័រ ២៧ បន្ទាត់ ១៩-២២។

1032 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ាង សុវីដា ប្រតិចារឹក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ៣២ បន្ទាត់ ២-៤។

1033 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ាង សុវីដា ប្រតិចារឹក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ១៤ បន្ទាត់ ៤-៥។

543. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានបញ្ជាក់ក្នុងសក្ខីកម្មរបស់គាត់ថា ពលករត្រូវបានព្រមាន មិនឱ្យនិយាយជាមួយគ្នាទេ "សូម្បីតែបងប្អូនបង្កើតនឹងគ្នា ក៏មិនអាចឈរនិយាយគ្នាបានដែរ។ តែ គេឃើញ គឺគេប្រាប់ថាគេចាប់អីចឹងតែម្តង គេមិនឱ្យទេ ពេលម៉ោងធ្វើការហ្នឹង ព្រោះឃោធា នៅឃាមកៀកៗកន្លែងយើងចាក់ដីហ្នឹង។ បានជាខ្ញុំដឹងពិតប្រាកដ ព្រោះឃោធាចាប់ពីរនាក់បងប្អូន ហ្នឹង ចាប់លើកទី១ គេថាគ្រាន់តែព្រមានទេ។ មកដល់គេចាប់ដៃពីរនាក់ហ្នឹង កុំឱ្យឈរនិយាយគ្នា "មិត្តឯងមានការអី?" ប្រាប់ថា "ខ្ញុំបងប្អូនបង្កើត" "បងប្អូនបង្កើតក៏ដោយ ចុះទៅឱ្យឆាប់! ចុះទៅ ក្រោម ចុះទៅកន្លែងរែកដី តែមានលើកទី២ អត់បានទេ!"។ ខ្ញុំរែកដីដើរកាត់តាមនុំង គ្រាន់តែឮ ញាក់សាច់អស់ហើយ អ្ហឺ! ចិត្តអាក្រក់ម្លេះ គ្រាន់តែបងប្អូនបង្កើតជួបគ្នានិយាយគ្នាមិនបាន។ អារម្មណ៍ចេះតែគិតថា ទៅថ្ងៃមុខទៀតមិនដឹងយ៉ាងម៉េចទេ តឹងឡើងៗយ៉ាងនេះ"[1034]។

### iv. ការគ្រប់គ្រងលើការរួមភេទ

544. ដូចដែលបង្ហាញនៅក្នុងជំពូក ១១ ទាក់ទងទៅនឹងការចេញបទបញ្ជាលើការរៀបអាពាហ៍ពិពាហ៍ ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឡាង បានផ្តល់សក្ខីកម្មពីការរៀបអាពាហ៍ពិពាហ៍របស់គាត់ក្នុងរបប ខ្មែរក្រហម[1035]។

## ១.៤. ការប្រព្រឹត្តិមកលើ និងការរំលោភបំពានយ៉ាងឃោរឃៅ៖ ការធ្វើទារុណកម្មរាងកាយ និងការបង្អត់អាហារ

545. ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ បានពន្យល់ថា ពលករត្រូវបានពិន័យបើពួកគេឈប់សម្រាក។ គាត់ បានពន្យល់ថា "មានគេធ្វើបាបមិត្តៗពួកខ្ញុំនឹងភ្នែក ដោយសារការឈឺ គ្នាឈឺ សូមឈប់គេមិន ឱ្យឈប់។ គ្នាថា គ្នារាក គ្នាឈឺពោះ គេមិនឱ្យឈប់ទេ។ ប្រាប់ថា ខ្ញុំរាឈឺមែន តមាត់គេ គេរ៉ៃ នៅនឹងភ្នែកនាងខ្ញុំ។ ដល់អីចឹងនាងខ្ញុំមិនហ៊ាន ទោះបីឈឺជាក៏សុខចិត្តទ្រាំ។ រ៉ៃគ្នាហើយ ឱ្យគ្នា រែកដី២ម៉ែត្រ អ្នកថ្មីដូចគ្នាហ្នឹង ជាកូនចៅចិន យកបង្គីឱ្យគ្នាមកធំណាស់ ឱ្យគ្នារែក"[1036]។ "គ្នាឈឺ

---

[1034] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ១១ បន្ទាត់ ១២-១៨។

[1035] *សូមមើល* ជំពូក ១១៖ ការកំណត់អំពីអាពាហ៍ពិពាហ៍។

[1036] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ១២ បន្ទាត់ ២-៥។

ថ្ងៃនុំងគ្នាថាឈឺពោះ រាក គ្នាសុំឈប់មួយថ្ងៃ តែប្រធានកងគេថា ប៉ុណ្ណឹងទៅធ្វើការបាន អត់ឱ្យឈប់ទេ។ ហើយគ្នាតមាត់ថា "ហើយបើខ្ញុំឈឺមែន មិនឱ្យខ្ញុំឈប់" ពេលនោះគេស្រែក ហើយគេវាយ គេយកដងរែកវាយនៅមុខនាងខ្ញុំ។ គេដេញទាល់តែទៅ។ ខ្ញុំចាំនាង មិត្តនុំងឈ្មោះ អេង ជាអ្នកថ្មីដែរ ជាកូនចៅចិន។ ដល់ទៅដល់កន្លែងធ្វើការ គេឱ្យវាស់ដីឱ្យគាត់២ម៉ែត្រ ហើយយកបង្គីអាធំៗ យកមកបោះឱ្យគាត់ពីរ ឱ្យគាត់រែក។ គេថា បើមិនហើយ មិនឱ្យទៅហូបបាយទេ"[1037]។

546. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន បានផ្ដល់សក្ខីកម្មថា "អ្នកឈឺ គេបន្ថយរបបៗ គេឱ្យហូបបបររាវៗជាងយើងនៅធ្វើការធម្មតា ព្រោះយើងឈឺហូបមិនកើតទេ គេថាអ្នកឈឺហូបមិនកើតទេ ហូបបបរបន្ថយបបរ។ ហើយខ្ញុំបានជាថា អត់នៅប្រជុំ ថ្ងៃនោះឯង ឈឺមួយថ្ងៃនេះ អត់បាននៅប្រជុំ គេអត់បានហៅប្រជុំ ប្រធានកងគេអត់នៅដែរ តែបើគេប្រជុំក៏គ្មានការងារអីទេ គ្រាន់តែប្រាប់ថាបន្ថយរបប ទី១។ ទី២ មិត្តឯងកុំឈឺច្រើន ឈឺច្រើនប្រយ័ត្នគេយកទៅអប់រំ យកទៅកែប្រែ ទៅសាលាកែប្រែ"[1038]។

547. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន បានផ្ដល់សក្ខីកម្មថា "បើថាសោខ្លាំង មានតែប្រាប់កុហកគេថាឈឺពោះដេកទទូរក្រមាមួយព្រឹកនេះទៅ។ ជួនកាលគេហៅប្រជុំ បើអត់បានហៅប្រជុំទៅអរទៅ បើគេហៅប្រជុំគេបន្ថយរបបបបរហ្នឹងទៀតហើយ"[1039]។

## ២. អំពើអមនុស្សធម៌ផ្សេងៗទៀត

548. ភស្តុតាងពីដើមបណ្ដឹងរដ្ឋប្បវេណីដែលបានធ្វើឡើងនៅពេលសវនាការបង្ហាញថា ទង្វើរបស់អង្គការក្នុងការបង្កើត និងប្រតិបត្តិសហករណ៍ និងការដ្ឋាន ក្នុងនោះរួមទាំងការដ្ឋានទំនប់ត្រពាំងថ្មផង ក្នុងគោលបំណងឱ្យប្រជាពលរដ្ឋធ្វើការងារ ព្រមទាំងតាមដាន អប់រំកែប្រែ និង "កម្ទេច" ខ្លាំង គឺជាការរំលោភបំពានសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការរស់រានមានជីវិត និងសិទ្ធិក្នុងការរស់នៅ

---

[1037] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី នួន ណារុំ ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/ 339.1 ទំព័រ ២៤ បន្ទាត់ ៩-១៣។

[1038] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ E1/ 307.1 ទំព័រ ៩ បន្ទាត់ ១៧-២១។

[1039] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ E1/ 307.1 ទំព័រ ៦ បន្ទាត់ ១១-១៣។

សមរម្យ សិទ្ធិក្នុងការមិនប្រឈមទៅនឹងការប្រព្រឹត្តិកាចសាហាវ អមនុស្សធម៌ និងបន្ទាបបន្ថោក និងមិនត្រូវបានចាប់ខ្លួនដោយគ្មានការជំនុំជម្រះ[1040]។ ទង្វើទាំងនេះត្រូវបានប្រកាសថាជាសកម្មភាពដែលមានលក្ខណៈ និងស្ថានទម្ងន់ដូចគ្នានឹងឧក្រិដ្ឋកម្មផ្សេងៗទៀតប្រឆាំងនឹងមនុស្សជាតិ និងបណ្ដាលឲ្យ ដើមបណ្ដឹងរដ្ឋប្បវេណីទទួលរងព្យសនកម្មធ្ងន់ធ្ងរ ឬជាការវាយប្រហារលើសេចក្ដីថ្លៃថ្នូរជាមនុស្សរបស់ពួកគេ។

## ២.១. លក្ខខណ្ឌការងារ

549. ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានផ្ដល់សក្ខីកម្មថា "នៅកន្លែងការងារហ្នឹងគឺ រែកដី កាប់ដីប្ដូរគ្នាទៅ កាយដាក់បង្គីខ្លះទៅ ធ្វើម៉េចៗថាកុំឲ្យយើងទំនេរនោះណា។ ធ្វើនឹងប្រណាំងប្រជែងគ្នាតាមភូមិ ប្រឹងអស់ពីសមត្ថភាព ប្រឹងហួសកម្លាំងយ៉ាងម៉េចក៏ដោយ ឈឺក្បាលវិលមុខបន្តិចបន្តួចហៅគ្នាឯងហ្នឹងជួយដកសក់ទៅ លុញខ្លួនទៅ ធ្វើម៉េចឲ្យតែបានងើបទៅធ្វើការកើតទៀត កុំឲ្យតែយើងឈប់។ វាហួសសត្វហួសធាតុហើយកាលនោះ អ្នកដែលទ្រាំរស់បាននោះគឺវាអស្ចារ្យណាស់ជីវិត ញ៉ាំមិនគ្រប់មិនគ្រាន់ក៏ដោយ ត្រូវតែប្រឹងដើម្បីរស់ ទៅធ្វើការទៅ។ បើមិនស៊ូទេ យើងគ្មានថ្ងៃរស់ទេ ទាំងចាស់ទាំងក្មេងទៅដល់កន្លែងនោះហើយ សុទ្ធតែគេពិសោធការងារហើយ យើងទ្រាំបានឬមិនបាន យើងត្រូវតែប្រឹង។ រែកដីតិចខ្លាចចាញ់គេ អ៊ីចឹងខំដាក់ពេញៗបង្គី ខ្លាចចាញ់ភូមិគេ ខ្លាចអង្គការមើលមិនឃើញ។ ឈឺចុកចង្កេះ ចុកខ្នង ខ្ញុំចុកតាំងពីក្មេង តាំងពីជំនាន់រែកដី រហូតដល់សព្វថ្ងៃហ្នឹង ប្រឹងដើម្បីអី ប្រឹងដើម្បីរស់ ខំដើម្បីរស់"[1041]។

550. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន បានបញ្ជាក់ពីការបាក់ដី ដោយបានពន្យល់ថា គាត់ "អត់ឃើញទេ តែឮ។ ឮថា បាក់ដីសង្កត់មនុស្សចំនួនបីនាក់ ដឹងថាស្លាប់មួយ អាពីរនោះ ខ្ញុំអត់ដឹងថាស្លាប់ ថារស់ ដឹងតែស្លាប់មួយ កប់នៅនឹងដី ហើយយកអត់បាន។ ខ្ញុំឮទេ ខ្ញុំអត់បានឃើញនឹងភ្នែកផ្ទាល់។ មានគេទៅមើលទៅ ខ្ញុំសួរគេ ព្រោះនៅឆ្ងាយពីរោងខ្ញុំដែរ"[1042]។

---

[1040] សេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៤៨ មាត្រា ២ ៥ ៩ ២៥។

[1041] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ៤ បន្ទាត់ ៥-១៣។

[1042] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/ 307.1** ទំព័រ ១១ បន្ទាត់ ១២-១៤។

551. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានពន្យល់ថា "ក្នុងការងារហ្នឹងគឺគេមានកំណត់ ព្រោះគេដាក់ស្រីពីរនាក់ ប្រុសម្នាក់។ ស្រីៗអ្នករែកប្រុសៗ អ្នកកាប់។ បីនាក់ហ្នឹង ដូចជាមួយម៉ែត្រ១,៥ ឬក៏២ម៉ែត្រគូបអីចឹង ក្នុងមួយថ្ងៃហ្នឹង។ គឺធ្វើយ៉ាងណាឲ្យយើង ឲ្យសម្រេចផែនការដែលគេដាក់។ ក៏ប៉ុន្តែមិនអាចទៅរួចទេ ព្រោះដីកន្លែងនោះរឹង សុទ្ធតែថ្ម ប្រឹងយ៉ាងណាក៏ទៅមិនរួចដែរ ប្រឹងអស់ពីចិត្ត ពីថ្លើមយ៉ាងណាក៏ទៅមិនរួចដែរ។ ខាងលើថ្មបាយក្រៀមហ្នឹង គឺកាប់ទៅចេញភ្លើង ដាក់ទៅដឹងតែចេញភ្លើងហើយ។ អីចឹង មេក្រុម មេកងហ្នឹង ដាក់ផែនការទៅភូមិឲ្យរកដែកស្បែងយកមកបុក យកចបតាសេះហ្នឹងយកមកកាប់។ ចបកាប់ គ្មានលទ្ធភាពធ្វើអីកើតទេ។ ថ្មបាយក្រៀមខាងលើហ្នឹង កម្រាស់ប្រហែល១ម៉ែត្រ។ ផុតថ្មបាយក្រៀម ទៅដល់ថ្មផុយ ថ្មហ្នឹងរៀងផុយៗ ថ្មនុំង១ម៉ែត្រទៅទៀត ដល់ហើយដល់ថ្មដាហើយ មិនអាចធ្វើកើតទៀតទេ គឺគេចោះ គេដុតផ្លូន គេហៅផ្លូន មិនដឹងគេធ្វើយ៉ាងម៉េច ផ្លូនហ្នឹង ខ្ញុំដឹងថា គេចោះថ្មហើយ គេដាក់ដុតទៅ ផ្ទុះបែកថ្មហ្នឹង។ គេដាក់ផ្លូនហ្នឹង គេមិនដែលប្រាប់ថា "ហ៎! ថយចេញ" គេដាក់ផ្លូនទេ គេចង់ដាក់ថ្មើណា ដាក់ទៅ។ យើងដឹងខ្លួនរត់ឲ្យហើយ។ រត់ចេញពីកន្លែងហ្នឹងឲ្យហើយ ព្រោះគេដាក់ហ្នឹង គេមិនស្រែកថា"ហ៎! បងប្អូនអើយ គេដាក់ផ្លូនអី" គឺគេអត់ប្រាប់ទេ។ គេនឹកឃើញគេដាក់ទៅយើងដឹងខ្លួនមក នាំគ្នារត់រៀងៗខ្លួនទៅ។ ខ្លះទៅ ក៏ផ្លោងត្រូវ បែកក្បាលទៅ។ បើផ្ទះគាត់មួយនៅក្បែរទំនប់១មករា នៅរហូតសព្វថ្ងៃហ្នឹង ដុំថ្មធំធ្លាក់ត្រូវដំបូលផ្ទះគាត់ហ្នឹង បាក់ឈើហ្នឹង ខ្ញុំសួរកូនគាត់ទៅ ថាប៉ាអត់ផ្លាស់ទេ គាត់ទុកៗមើល នៅដល់សព្វថ្ងៃហ្នឹង។ ខ្ញុំទៅជួបកូនគាត់។ សុទ្ធតែថ្មទៅបាតខាងក្រោមហ្នឹង គឺថ្មដាតែម្តង"[1043]។

552. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ក៏បានផ្តល់សក្ខីកម្មពីលក្ខខណ្ឌស្រដៀងគ្នានេះដែរ "ធ្វើការហ្នឹងហាលភ្លៀងនៅលើគោកផងយើងយ៉ាប់ប៉ុនណា ចុះទម្រាំតែភ្លៀង។ ទី១ រែកឡើងអត់រួច រអិលជើងកាប់កូនឈើដាក់កល់ធ្វើជណ្តើរ ដល់តែភ្លៀងខ្លាំងជោកជាំខ្លាំងមែនទែន ទឹកក្រោមជង្គង់ទៅ ភ្លៀងខ្លោកៗ ឧទាហរណ៍ និយាយទៅនិយាយឲ្យអស់"[1044]។ គាត់បានពន្យល់ថា "គ្មានៗជួយសម្រួលអីតែធ្វើយ៉ាងម៉េច កម្មវិធីយ៉ាងម៉េច ឲ្យស្រួល កុំឲ្យរអិលគឺគ្មានដាច់ខាត គ្មានសោះបណ្តោយ។ ដោះ

---

[1043] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ២០-២១ បន្ទាត់ ២០-៩។

[1044] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ៧ បន្ទាត់ ២១-២៣។

ស្រាយម៉េចខ្លួនឯង ធ្វើម៉េចឱ្យបានរួចដីរួច ធ្វើម៉េចធ្វើទៅ ដោះស្រាយម៉េចដោះទៅ។ អង្គុយក៏មិនបានអីក៏មិនបានដែរ។ ដល់ពេលយ៉ាប់ខ្លាំងពេក ដល់ទឹកច្រើន ដូចថា លួចកកាយដីប្រលាយៗឱ្យរាយៗក្នុងហ្នឹងទៅ ឱ្យរហ័សអស់អាម៉ែត្រគូបហ្នឹង ឱ្យអាចម៍ដីវារាបៗហ្នឹងរណ្ដៅហ្នឹង កកាយៗកកេះៗ លួចធ្វើឱ្យវាទៅតាម ស្រពាប រាយៗ រាក់ៗដី។ ឱ្យវាស្រពាបៗហ្នឹងរណ្ដៅហ្នឹងទៅ"[1045]។

553. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន បានផ្ដល់សក្ខីកម្មថាគាត់ "អត់ទេ អត់ដែលឃើញសោះ។ ឃើញតែកម្លាំងមនុស្សជីក រែក។ អាប៊ុល អាអេច អីមិនដែលឃើញទេ"[1046]។

## i. ការសម្រាកបន្តិចបន្តួច ឬគ្មានសម្រាកសោះ

554. ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានលើកឡើងថា "គឺម៉ោងបួនហ្នឹង គឺកញ្ចែដាស់យើងឱ្យស្លៀកពាក់រៀបចំខ្លួន។ កញ្ចែហ្នឹងប្រហែល១៥នាទី ២០នាទី កញ្ចែមួយទៀតគឺត្រូវតែចេញដំណើរទាំងស្រីទាំងប្រុសហ្នឹង គឺចេញដំណើរ ដើរទៅ។ ហើយក្នុងការធ្វើដំណើរហ្នឹង គឺថាម្នាក់ៗងោកងុយ ដើរតោងគ្នា ជួនដួលទៅ អីទៅ។ មេកង មេក្រុម គេស្ដីឱ្យ ថាម៉េចបានដួល។ ចុះបើងោកដួលនាំគ្នាក្រោកទៅ ទៅទៀតទៅ។ អ្នកថាឱ្យចេះតែថាទៅ យើងទៅតែចេះទៅទៀត តោងទៅមុខទៀតទៅ។ ជួនកាលទៅដួលឯមុខហ្នឹងទៀតទៅ ក៏មានដែរ។ ខ្លួនខ្ញុំផ្ទាល់ហ្នឹង ក៏ធ្លាប់ដួលដែរ ធ្វើម៉េចបើដើរភ្លេច តោងគេទៅ ដឹងតែទៅមុខ ចេះតែតោងៗទៅនឹងគេទៅ។ ទាំងស្រីទាំងប្រុសហ្នឹងជួនដួលគេ ជួនដួលយើង។ ដើរទៅជាន់កែងគ្នា។ ម្នាក់ៗសុទ្ធតែសង្វាតភ្លេច។ ងងុយ ម៉ោងបួនហ្នឹងកំពុងតែលក់ស្រួល ហើយដល់ម៉ោងការងារត្រូវតែចេះដំណើរ។ មិនចេញ គឺមិនបាន។ ត្រូវតែទៅ"[1047]។

555. ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានពន្យល់ថា ថ្ងៃធ្វើការមានរយៈពេលយូរ "ប្រាកដហើយបើទៅដល់កន្លែងគឺយើងចាប់ផ្ដើមការងារហើយ។ ដឹងការងាររៀងខ្លួន មានចប មានបង្គី មានដង

---

[1045] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ៨ បន្ទាត់ ២០-២៥។

[1046] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/ 307.1** ទំព័រ ២១-២២។

[1047] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ៣៥ បន្ទាត់ ១៦-២៤។

រែក។ គឺចាប់ផ្ដើមធ្វើការងារហើយ តែទៅដល់កន្លែងហើយ ត្រូវតែចាប់ផ្ដើមហើយ។ គ្មានអ្នកណានៅអែអង់អីបានទេ ដឹងការងាររៀង១ខ្លួន។ អ្នកកាប់ស្រវាចប អ្នករែកស្រវាបង្គីហ្នឹង។ បង្គីហ្នឹងជួនកាលថ្ងៃណា ដូចថាអស់កម្លាំងពេកហ្នឹង យកទៅរកកន្លែងលាក់ទៅ លីទាំងបង្គីហ្នឹងមកកន្លែងវិញ។ គឺថាវាអស់ដៃអស់ជើងពេកទៅ មិចភ្នែកដាក់គ្នាអ៊ីចឹងទៅ យកបង្គីទៅលាក់កន្លែងណាទៅលីទៅទៀត។ អើយ! ចុះម៉ោង១០យប់ ដើរត្រឡប់ទៅវិញ។ អ៊ីចឹង នាំគ្នាលាក់ រកកន្លែងណាលាក់ឲ្យវាមានសុវត្ថិភាព ណាខ្លាចគេលួច ប៉ុនទេបើអស់កម្លាំងពេកទៅហើយ។ អ៊ីចឹង នាំគ្នាយកទៅលាក់ត្រង់នេះ លាក់ត្រង់នោះទៅ។ ហើយបើថ្ងៃណាមានកម្លាំងរាងក្លាហានទៅ ក៏លីចប លីបង្គីរៀងខ្លួន យកទៅទុកឯវត្តត្រពាំងជ្រៃហ្នឹងទៅ។ តែថ្ងៃណាអស់កម្លាំងពេក មិចភ្នែកដាក់គ្នារកកន្លែងលាក់ហើយ យកទៅមិនរួចទេ អស់ ដើរតែអួសដៃ អួសជើងគ្រប់គ្នា។ ម៉ោងដប់ ទម្រាំដើរទៅដល់វត្តនុ៎ង ទម្រាំតែរកទឹកងូត ដូចខ្ញុំជម្រាបលើកមុនអ៊ីចឹង ថាអស់ទៅលក់ទាំងខោអាវហ្នឹងទៅ ព្រលឹមឡើងមកទៀតទៅ"[1048]។

556. ដើមបណ្ដឹងរដ្ឋប្បវេណី សៀង សុវីដា បានផ្ដល់សក្ខីកម្មថា គាត់ "អត់ដែលបានឈប់ទេ ប្រហែលជាចូលឆ្នាំអាចគេឈប់១ថ្ងៃ ឬក៏នាងខ្ញុំចាំអត់សូវច្បាស់ដែរ តែនៅថ្ងៃចូលឆ្នាំប្រហែលជាគេមានប្រជុំគេអ៊ីចឹង នាងខ្ញុំអាចឈប់។ គេកំណត់ថាឲ្យឈប់១ថ្ងៃ២ថ្ងៃ ឬក៏ក្នុង១ខែឈប់ម្ដងអី កន្លែងភូមិខ្ញុំនៅអត់ដែលបានឈប់ទេ ភូមិផ្សេងខ្ញុំអត់ដឹងដែរ តែកន្លែងខ្ញុំអត់ ធ្វើរហូត"[1049]។ គាត់បានពន្យល់ថានៅថ្ងៃដែលគាត់សន្លប់ "ខ្ញុំអស់កម្លាំង ហើយខ្ញុំគេងអត់ឆ្អែត ញ៉ាំអត់ឆ្អែត ហើយសុខភាពនាងខ្ញុំមិនសូវល្អដែរ ពេលនោះ នាងខ្ញុំក៏ដួលសន្លប់ទៅ។ ពេលនោះ គឺគេសែងនាងខ្ញុំទៅរោងសម្រាក"[1050]។

557. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន បានផ្ដល់សក្ខីកម្មថា "បើនិយាយទៅដូចថា ថ្ងៃសៅរ៍ ថ្ងៃអាទិត្យអី គឺគ្មានទេ។ រហូត ការងារជាប់រហូត គ្មានថ្ងៃណាថាសម្រាកទេ។ បើថាសោខ្លាំង មានតែប្រាប់

[1048] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ៣៦ បន្ទាត់ ៩-១៩។

[1049] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ាង សុវីដា ប្រតិចារឹក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ១៨ បន្ទាត់ ៦-៨ ។

[1050] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ាង សុវីដា ប្រតិចារឹក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ១៨ បន្ទាត់ ១២-១៣។

កុហកគេថា ឈឺពោះដេកទទូរក្រមាមួយព្រឹកនេះទៅ។ ជួនកាលគេហៅប្រជុំ បើអត់បានហៅប្រជុំ ទៅអរទៅ បើគេហៅប្រជុំគេបន្ថយរបបបបរហ្នឹងទៀតហើយ។ អត់មានកំណត់ថា អ្ហ៎! សម្រាក សៅរ៍ អាទិត្យ យើងសម្រាកថ្ងៃសៅរ៍អីមួយថ្ងៃ អត់រហូត មួយឆ្នាំទល់មួយឆ្នាំ មួយខែទល់មួយខែ"[1051]។ គាត់បានពន្យល់ថាគេមិនឲ្យគាត់សម្រាកឡើយ "បើសិនជាយើងសម្រាក រែកដីអត់រួចភ្លៀងទៅទាំងភ្លៀងហ្នឹង ធ្វើមិនកើតក៏នៅតែជីកនៅហ្នឹង នៅក្នុងរណ្តៅ នៅចាំហ្នឹងឯង ទៅកេះៗធ្វើៗទៅ។ ក្រែងដូចពាក្យគេថា "អង្រួនតែក្តិតទៅ" ធ្វើកើតមិនកើត អត់មានថាឲ្យចេញឡើងមកជ្រកម្លប់ដើមឈើអី គឺអត់បានដាច់ខាត"[1052]។

### ii. ការងារពេលយប់

558. ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ បានផ្តល់សក្ខីកម្មថា "យើងសម្រាកបានបន្តិច គ្រាន់តែអង្គុយមួយបន្តិច ដល់ម៉ោងយើងទៅធ្វើការ។ ទៅធ្វើការដល់ពេលល្ងាចម៉ោងប្រាំ ត្រូវត្រឡប់មកវិញ។ មកហូបបាយនៅរោង ហូបហើយ យើងត្រូវដើរទៅវិញ ទៅរែកដីវិញ តែមិនដឹងជាម៉ោងប៉ុន្មានទេ ពេលកំពុងតែរែកហ្នឹង គឺយើងងុយ។ ពេលនោះ នាងខ្ញុំអាយុ១៨, ១៩ហើយ គឺរែកមិនដឹងជាម៉ោងប៉ុន្មានទេ"[1053]។

559. ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវីដា បានផ្តល់សក្ខីកម្មថា "ម៉ោងប្រាំបួនម៉ោងដប់ហ្នឹងជួនកាលឈប់ធ្វើការ ហើយទម្រាំដើរទៅដល់កន្លែងគេង នាងខ្ញុំពិបាកស្មានម៉ោងអត់ត្រូវ គ្រាន់តែដឹងថានៅពេលយប់នាងខ្ញុំសម្រាកបាន -- ពេលល្ងាចសម្រាកបានបន្តិចហើយចាប់ធ្វើការ។ ធ្វើការជួនម៉ោងប្រាំបួន ជួនម៉ោងដប់ អ្នកគេនុំងនិយាយថា ម៉ោងយប់ជ្រៅហើយអត់មានម៉ោងមើលអីអ៊ីចឹងណា ប៉ុន្តែនាងខ្ញុំអត់ប៉ាន់ស្មានដឹងទេ។ ប្រហែលជាមកដល់កន្លែងធ្វើ -- មកដល់កន្លែងគេងខ្ទង់ប្រហែលជាម៉ោងដប់ ឬម៉ោងជិតដប់មួយរាល់ថ្ងៃ។ ភូមិគេផ្សេង ខ្ញុំអត់ដឹង តែដឹងកន្លែងពួកខ្ញុំ

---

[1051] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ E1/307.1 ទំព័រ ៦ បន្ទាត់ ១១-១៤ ។

[1052] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ E1/307.1 ទំព័រ ៧ បន្ទាត់ ១២-១៥ ។

[1053] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/339.1 ទំព័រ ១០ បន្ទាត់ ១៩-២២។

គឺធ្វើរាល់ថ្ងៃ។ ជួនកាលមានចន្លុះ ពេលខែភ្លឺ គឺខែភ្លឺ។ ចន្លុះនោះ គឺដុតបំភ្លឺ"[1054]។ គាត់បានបញ្ជាក់ថា "ការងារពេលយប់នោះ សំដៅពេលម៉ោងយប់ល្ងាចម៉ោងប្រាំមួយ ប្រាំពីរយប់ហ្នឹង។ ប្រហែលជាម៉ោងប្រាំមួយកន្លះ ប្រាំពីរហ្នឹងចូលធ្វើរហូតដល់ម៉ោងយប់ ម៉ោងប្រាំបួន ឬក៏ម៉ោងដប់"[1055]។

560. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន បានបញ្ជាក់ថា "ខែភ្លឺៗ គឺវាស់ដីឱ្យរែកយប់ ក្នុងមួយខែវាសឱ្យរែកយប់ម្ដង"[1056]។ នៅពេលនោះ "ក្នុងម្នាក់ថ្ងៃ ៤ម៉ែត្រ យប់២ម៉ែត្រ ៦ម៉ែត្រ។ ក្នុងមួយយប់មួយថ្ងៃពីរនាក់ គឺ១២ ម៉ែត្រគូប"[1057]។ ពលករមិនបានទទួលអាហារបន្ថែមទេ[1058]។

### iii. ពលកម្មកុមារ

561. ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានបញ្ជាក់ថា កុមារដែលធ្វើការនៅការដ្ឋានទំនប់ ១មករា ដោយបានផ្ដល់សក្ខីកម្មថា "កុមារត្រូវគេចាត់នៅកងចល័តទី២" ហើយពួកគេ "អាយុគេពី ៩ឆ្នាំទៅ១៣ឆ្នាំ ចល័តទី២ ហ្នឹង"[1059]។ គាត់បានពន្យល់ថា "កុមារទាំងអស់នោះ គឺគេឱ្យធ្វើការដូចមនុស្សចាស់ ញ៉ាំអីក៏ដូចមនុស្សចាស់។ គេមិនបានគិតគូរពីសិទ្ធិរបស់កុមារអីទេ។ គេមិនខ្វាយខ្វល់ទេ គេដឹងតែប្រើ មានរបបដូចមនុស្សចាស់អ៊ីចឹង។ គេមិនគិតថា ក្មេង អាយុតិច កម្លាំងតិចអី គេមិនគិតទេ រែកដីវាដាក់ប៉ុនណារួច ទៅប៉ុណ្ណឹង។ គេគ្មានការយោគយល់ គេគ្មានការអាណិតអី

[1054] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ាង សុវីដា ប្រតិចារឹក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ១៥ បន្ទាត់ ១៨-២៣។

[1055] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ាង សុវីដា ប្រតិចារឹក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ១៦ បន្ទាត់ ១១-១២។

[1056] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ១៨ បន្ទាត់ ១២។

[1057] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1**ទំព័រ ១៩ បន្ទាត់ ៧-៨។

[1058] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1**ទំព័រ ១៩ បន្ទាត់ ១១។

[1059] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/305.1** ទំព័រ ៧៣ បន្ទាត់ ២៤។

ទេ"[1060]។ "តាមធម្មតា ក្មេងធ្វើការដូចមនុស្សចាស់ គឺគ្នាសុខភាពមិនល្អទេ ចេះតែប្រឹងទៅនឹងគេនឹងឯង។ ឈឺក៏គ្មានអ្នកណាមកសួរនាំអីដែរ ដឹងតែធ្វើម៉េច ឲ្យចេញឲ្យអស់ពីរោង។ ការងារពេលណាក៏ដោយ ដឹងតែសម្រុកទាំងចាស់ទាំងក្មេង។ មីក្រុចាក់ក្តែងៗ គឺសម្រុកៗការងារដឹងតែសម្រុករហូត"[1061]។ "ប្រធានភូមិតែម្តង ជាអ្នកចាត់តាំងឲ្យមកហ្នឹង"[1062]។

## ២.២. លក្ខខណ្ឌរស់នៅ

### i. កង្វះអាហារ

562. ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ បានផ្តល់សក្ខីកម្មថា "មានមិត្តៗខ្លះគេអ្នកប្រជាជនចាស់អ៊ីចឹងគេទៅសុំអំបិលចុងភៅបានបន្តិចមក ចែកគ្នាម្នាក់ពីរបីគ្រាប់ទៅ។ យើងហូបបាយហ្នឹង បានទៅបានពាក់កណ្តាលអ៊ីចឹងទៅ សម្លបានគេផ្អិន បានគេលើកមក តែសម្លគឺនាងខ្ញុំហូបមិនកើត ព្រោះសម្លខ្លះឆ្នោតហើយសម្លដើមចេក ហើយមានខ្លាញ់ជ្រូកអណ្តែតអ៊ីចឹង យើងហូបតែបន្តិចបន្តួចយើងហូបជាមួយអំបិលហ្នឹងទៅ"[1063]។ ដើមបណ្តឹងរដ្ឋប្បវេណី បានពន្យល់ថា "ពេលយប់ យើងហត់ហេវពេក មិត្តខ្ញុំហ្នឹង ប៉ុន្តែគេស្លាប់ហើយ យើងរែកដី ហើយខ្សឹបថាគេហៅអី យើងមិនដែលឃើញ ទេ"[1064]។

563. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន បានផ្តល់សក្ខីកម្មថា អាហារមានលក្ខណៈខុសៗគ្នាអាស្រ័យលើតួនាទីរបស់បុគ្គលម្នាក់ៗ "កូនចៅហូបបបរ ប្រធានកងតូច និងប្រធានកងធំ គឺហូបបាយ។ ជាមួយពេទ្យ ហូបបាយ។ ពេទ្យ ប្រធានកងតូច ប្រធានកងធំហូបបាយ។ កូនចៅសមាជិកទាំងអស់

---

[1060] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ៣ បន្ទាត់ ៦-៩។

[1061] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ៣ បន្ទាត់ ១៤-១៧។

[1062] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ**E1/306.1** ទំព័រ ៤៧ បន្ទាត់ ៤។

[1063] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/ 339.1** ទំព័រ ១០ បន្ទាត់ ១៥-១៩។

[1064] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ១២ បន្ទាត់ ៧-៩។

កូនក្រុមទាំងអស់ហូបបបរ”[1065]។ គាត់បានពន្យល់ថា ពលករមិនត្រូវបានអនុញ្ញាតឱ្យរកអាហារបន្ថែមឡើយ។ “មិនអាចរកអាហារមកបន្ថែមបានទេ។ មានគេឱ្យហូបបបរហ្នឹង គឺនាងខ្ញុំជួនកាលបានសួរស្គាល់មិត្តភក្តិម្នាក់នៅដាំបាយហ្នឹងឯង គេលួចបាយក្តាំងយកមកដាក់លើដំបូលរោងឱ្យ។ បាយក្តាំងហ្នឹង បាយក្តាំងគេដាំឱ្យប្រធានកងធំ ប្រធានកងតូច។ គេដួសបាយទៅ គេយកបាយក្តាំងមកដាក់ចោលនៅរោងទៅ ខ្ញុំក្រោកពីព្រឹកឡើងទទួលយកបាយក្តាំងហ្នឹង វេចនឹងក្រមា ច្របាច់ៗឱ្យបែកៗទៅ វេចនឹងជាយក្រមាទៅ។ ខ្ញុំដើរទៅកន្លែងកាប់ដី អត់មានអាហារឱ្យបន្ថែមទេ”[1066]។

564. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានផ្តល់សក្ខីកម្មថា “អើយ! ពុទ្ធោអើយពុទ្ធោ! ឱ្យតែពេលបាយមានគ្រប់គ្រាន់មានអីស្រស់ស្រូបព្រលឹមឡើងគឺគ្មានទេ ពោះទទេៗសុទ្ធ ឃ្លានណាស់ ប៉ុន្តែមិនដឹងធ្វើយ៉ាងម៉េច។ មានអី មានរបបអី គ្មានទេ។ បើចុងភៅគេដួសបាយក្តាំងដាក់ហាលហ្នឹងទៅលបៗទៅលួចមួយដុំដាក់ហោប៉ៅអាវមក។ មានមិត្តភក្តិអ៊ីចឹងកាច់ចែកគ្នាទៅ ប៉ុនៗមេដៃហ្នឹងបៀមៗក្នុងមាត់ហ្នឹងទៅ។ ហ្នឹងហើយស្រស់ស្រូបពេលព្រឹកបានដោយលួចគេហ្នឹង បើថាឱ្យមានរបបគឺគ្មានទេ គ្មានសោះហើយ។ ឱ្យតែពេលបាយ មានបាយឱ្យហូបឆ្អែត មានម្ហូបហ្នឹងទៅបានហើយ របបព្រឹកគ្មានដែលស្គាល់ជាតិទេ តាំងពីដាច់ ៧៥ រហូតនោះ”[1067]។ គាត់បន្តទៀតថា “បានឃើញចុងភៅហាលបាយក្តាំង អរជាងបានអីទៀត មាសប៉ុនដូងទុំក៏មិនស្មើដែរ”[1068]។

565. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន បានផ្តល់សក្ខីកម្មថា របបអាហារគឺ “ក្នុងមួយពេលបបរពីរវែកក្រឡុម មួយពេល ហើយម្ហូបៗសម្ល ជួនកាលស្លត្រកួន ជួនកាលប្រហុកយើងហ្នឹងឯងយកទៅដាក់ទឹកកន្លះឆ្នាំងខ្ទះទៅ ដាក់ម្លូរទ្រមូងទៅ ដួសមក មួយចានមក គ្នាបីនាក់ មួយចានបីនាក់ៗ

[1065] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ៤ បន្ទាត់ ១២-១៤។

[1066] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ៤ បន្ទាត់ ២០-២៤។

[1067] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ២២ បន្ទាត់ ១៥-២០។

[1068] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ២២ បន្ទាត់ ២៥។

ទៅ"[1069]។ "នៅឃ្លាំងដដែល"[1070]។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ បានពន្យល់ថា "អត់សុំបន្ថែមបានទេ ដឹងតែរបបយើងតែពីរវែកៗហ្នឹងឯង"[1071]។

566. ដើមបណ្ដឹងរដ្ឋប្បវេណី ចៅ ឡាង បានរៀបរាប់ ថា "មួយទៀតការហូបមិនគ្រប់គ្រាន់ធ្វើឱ្យនាងខ្ញុំស្គមស្គាំង ស្លេកស្លាំង"[1072]។

### ii. កន្លែងស្នាក់នៅមិនសមរម្យ/កង្វះភាពរីករាយ

567. ដើមបណ្ដឹងរដ្ឋប្បវេណី សៀង សុវីដា បានផ្ដល់សក្ខីកម្មថា "នាងខ្ញុំពេលទៅហ្នឹង ដូចគេចែកខោអាវឱ្យនាងខ្ញុំបានមួយសម្រាប់ពណ៌ខ្មៅ តែប៉ុណ្ណឹង។ ហើយមានខោអាវខ្លួនឯងចាស់ៗខ្លះទៅ តែខោអាវក៏អត់មានច្រើនដែរ បន្តិចបន្តួចទៅ ហើយសម្អាតខោអាវក៏គ្មានដែរ គឺបោកទឹកទទេ។ ជួនកាលមានសំបកស្ដៅ ឬក៏ស្លឹកស្វាយទៅជំនួសនឹងធ្មេញអីចឹងទៅ។ ហើយខ្លួន នាងខ្ញុំដឹងថាមានននោងសាញពេលណាមានឃើញអីចឹង យើងបេះយកង្កូតលាងខ្លួនដែរ។ ទាំងអស់គ្នាហ្នឹង គ្មានមានអ្នកណាសំអាតទេ ខ្លួនរស់នៅដូចឋានរកអីចឹង គួរឱ្យខ្លាចគួរឱ្យខ្ពើម តែក្រាសសិតសក់ហ្នឹងស្ទើរតែគ្មានផង។ ខោអាវរហែកគ្រប់ៗគ្នាៗ ជួនកាលពូៗ គាត់ឱ្យខ្ញុំដេរម៉ោងសម្រាកអីបន្តិចបន្តួច ខ្ញុំជួយដេរបន្តិចៗបានដែរ។ អំបោះក៏អត់មានដែរ មានបារយើងហ្នឹង អាបារគេហៅបារនីឡុងហ្នឹងហូតពីហ្នឹងមក ឬក៏អាស្លឹកត្នោតមានតែសរសៃម៉េចហ្នឹង គឺដេរអាបារយើង ដូចបារអីហ្នឹង"[1073]។

568. ដើមបណ្ដឹងរដ្ឋប្បវេណី សៀង សុវីដា ក៏បានផ្ដល់សក្ខីកម្មថា "អត់មានចែកស្បែកជើងទេ។ ហ្នឹងចំពោះគេ ខ្ញុំអត់ដឹងថាគេចែក ចំពោះខ្ញុំអត់ដែលបានរបបស្បែកជើងទេ ពេលខ្ញុំទៅពីផ្ទះទៅ ម្ដាយខ្ញុំ

[1069] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ២២ បន្ទាត់ ១១-១៣។

[1070] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ២២ បន្ទាត់ ១៦។

[1071] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ២២ បន្ទាត់ ១៩។

[1072] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ចាវ ឡាង ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ៥៣ បន្ទាត់ ១២-១៣។

[1073] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ាង សុវីដា ប្រតិចារឹក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ២៧ បន្ទាត់ ១-៩។

គាត់យកអ្វីទៅដូរបានរបៀបកៅស៊ូស្បែកម៉ូតូ គាត់ចោះឲ្យពាក់ហ្នឹងទៅ ខ្ញុំពាក់អាដូចកង់ឡានអ៊ីចឹង តែវាអត់មានកង់ឡានទេ មានម៉ូតូ។ គេប្រជាជនមូលដ្ឋាន គេមានស្បែកជើងកង់ឡានហ្នឹងពាក់ ហើយប្រជាជនថ្មីខ្លះក៏អត់មានស្បែកជើងដែរ ខ្ញុំឃើញដើរជើងទទេ ហើយខោអាវរហែក។ ខ្ញុំអត់ដែលបានរបបស្បែកជើង ខ្ញុំបានខោអាវម្តង ពេលមក៧មករាហ្នឹង -- ទំនប់១មករា។ នៅភូមិក៏គេអត់ដែលចែកឲ្យខ្ញុំដែរ ខោអាវ គេថាម៉ាក់ខ្ញុំមានខោអាវឲ្យស្លៀកហើយ ចែកអ្នកអត់ៗ។ ហើយមានមួក ខ្ញុំភ្លេចប្រាប់ពីរឿងមួក។ មួកពេលហ្នឹងប្រើមួកដូន មួកដូនហ្នឹងស្រួចក្បាលអ៊ីចឹងមក រីកអ៊ីចឹង ម៉ាក់ខ្ញុំគាត់យកអាវភ្លៀង យកពីខ្ញុំនៅក្មេងហ្នឹង គាត់ធ្វើមានគេអ្នកស្រុក គេចេះធ្វើ គាត់ដូរអីគេដាក់អាវភ្លៀងហ្នឹងពីលើទៅ ហើយមានដូនហ្នឹងពាក់ធ្វើការ គេពាក់អ៊ីចឹងត្រជាក់”[1074]។

569. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី ក៏បានផ្តល់សក្ខីកម្មពីភ័ស្តុតាងស្រដៀងគ្នាដែលថា “សូម្បីតែអ្នករែកដីហ្នឹងក៏មានតែមួយចង្កេះ ឆ្អេះនឹងខ្លួនដូចតែគ្នា។ អ្នកមានខោពីរហ្នឹងសុទ្ធតែសំណាងហើយ។ សារុងប៉ះ មិនដឹងជាប៉ុន្មានរយបំណះទេ សម្រាប់ស្លៀកគេយប់។ ថ្ងៃគក់ខោទៅ ពេលល្ងាចមកវិញហ្នឹង គឺគក់ទៅ ហាលទៅ។ ញីតែទឹកហ្នឹងឯង មានសាប៊ូមានអីឯណា។ យើងស្អាតបាតពេកគេតិះដៀល វណ្ណៈនាយទុន សក្តិភូមិអី សព្វបែបសព្វយ៉ាងហើយ ឮអស់ហើយ។ មិនដឹងសក្តិភូមិម៉េច នាយទុនអីអាម៉េចទេ លោកអើយលោក។ បើវណ្ណៈគេ គេមានតែពីរទេ គឺវណ្ណៈកម្មករ និងកសិករ តែពីរហ្នឹងឯង ចុះយើងស្អាតបាតអី។ បើឃើញយើងគគ្រិចហ្នឹង បានពេញចិត្តគេ ឃើញយើងស្អាតមិនបានទេ”[1075]។

570. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន បានផ្តល់សក្ខីកម្មថា “រឿងសម្លៀកបំពាក់ គឺខ្វះ។ មានតែពីរកំប្លេគត់ ពីរកំប្លេអាមួយនោះជំនំ មួយកំប្លេទៀតនោះរហែកក្តិត ប៉ះខ្នាស់។ ក្រមាក៏មានតែមួយដែរឡើងទក់ ទក់រហែកខ្លាំង រហូតដល់ពេលយប់ខែរដូវភ្លៀង ធ្លាក់ភ្លៀងមក គ្មានអីផ្លាស់ គ្មានអីស្លៀកប្តូរទេ។ ដាក់សំដិលនឹងរោង ទៅវិញ មកពីធ្វើការវិញផ្លាស់អាសើមខ្លាំងហ្នឹងឯងដាក់ហាលទៅ

---

[1074] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ាង សុវីដា ប្រតិចារឹក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ៤៤ បន្ទាត់ ៥-១៣។

[1075] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ៩-១០ បន្ទាត់ ២៤-៥។

យកអាចទឹកសើមបន្តិចៗនោះយកមកស្លៀកមក គ្របកន្ទេលទៅដេកយប់នោះ”[1076]។ ដើមបណ្ដឹងរដ្ឋប្បវេណី បានពន្យល់ពីផលប៉ះពាល់នៃការស្លៀកពាក់ខោអាវសើម ដោយពន្យល់ថា “ស្លៀកទៅជួនកាលឈឺពោះៗ រួចរហូតដល់ចេញរមាស់ អេះកើតចៃ ចេញចៃតាមសាច់។ អេះមកកើតចៃពកៗអេះក្បាលរមាស់។ គ្មានស្គាល់ជាតិសាប៊ូ គ្មានស្គាល់ជាតិអ្វីទាំងអស់ មួយចប់ខ្មៅក្រហម។ រហូតដល់យកផេះត្រាំទឹក យកទឹកថ្លាៗមកបោកខោអាវម្ដងទៅ ក្រមរឡើងក្ដាំងកអាវ។ បែកញើស សើមបែកញើសរាល់ថ្ងៃ”[1077]។

571. ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានផ្ដល់សក្ខីកម្មពីផលវិបាកនៃកង្វះខាតខោអាវសម្រាប់ពលករស្រី។ គាត់បានផ្ដល់សក្ខីកម្មថា “ខ្ញុំទៅកាលនោះគេឲ្យកំណាត់សម្រាប់កាត់ខោមួយ កាត់អាវមួយ និងខ្លួនឯងមានខោចាស់មួយ និងអាវចាស់មួយសម្រាប់ផ្លាស់ប្ដូរហ្នឹង។ ស្លៀកចាំ ហើយថែជាទីបំផុត ថ្វីត្បិតតែយើងធ្វើការរាល់ថ្ងៃ ខោអាវមានតែពីរកំប្លេហ្នឹងស្លៀកចាំ។ រឿងទុក្ខវេទនាគឺវេទនា -- គិតទៅស្រីៗមានរដូវ មកប្រឡាក់ខោ នៅជិតស្ទឹងនាំគ្នាចុះទឹកស្ទឹង ដើម្បីកុំឲ្យគេឃើញឈាមរដូវហ្នឹងប្រឡាក់ខោនាំគ្នាចុះទឹកស្ទឹង ឡើងមករែកដីទាំងសើម ប្រឡាក់ទៅចុះទៀតទៅ គ្មានអីទ្រាប់ គ្មានអីគិតគូរដល់ខ្លួនឯងទេ ហេតុតែឃើញប្រឡាក់អីចឹងផ្អើះប្រាប់គ្នាទៅ “ខោឯងប្រឡាក់ហើយ” យើងឃើញគេប្រាប់គេទៅនាំគ្នាចុះទឹកស្ទឹងទាំងអស់គ្នាទៅ។ ឡើងមកវិញឃើញទទឹកកកក់ ជម្រះខ្លួនដោយទឹកស្ទឹង ញ៉ាំហ្នឹង ងូតហ្នឹង លាងខ្លួនហ្នឹង”[1078]។

572. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន បានរៀបរាប់ “ធម្មតាមនុស្សស្រីវាតែងតែមានរដូវហូរឈាមដូចអារកមាន់ណាមក តស៊ូទ្រាំខ្លាចគេយកទៅវៃចោល។ ខោខ្លីក៏មិនដែលបើកឲ្យ អាវតូច ក៏មិនដែលមានឲ្យ គេមិនដឹង បើថាចំពោះខ្ញុំនៅមិត្ត នៅជាមួយគ្នាជាមួយខ្ញុំដែលរែកដីជាមួយគ្នា ហែកកន្សែងចែកគ្នាម្នាងម្នាក់ចងក្បិនស្លៀកខោពីក្រៅ ដល់ពេលភ្លៀងមកស្រាយអាក្បិន ហើយបោកដាក់ហាល

---

[1076] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ៥ បន្ទាត់ ១៩-២៣។

[1077] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ៦ បន្ទាត់ ១-៤។

[1078] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ១០ បន្ទាត់ ១១-១៧។

នឹងចុងកូនឈើទៅ ខោទទេរទៅឲ្យវាត្រូវទឹកភ្លៀងទៅ វាហូរទៅ ក្របាមត្រាក់ត្រឹងពេញអារណ្ដៅ ជីកដី។ បាត់អៀន បាត់ខ្មាសអស់ហើយជំនាន់នោះឯង"[1079]។

### iii. កង្វះទឹកស្អាតសម្រាប់ផឹក និងអនាម័យ

573. ដើមបណ្ដឹងរដ្ឋប្បវេណី សៀង សុវីដា បានផ្ដល់សក្ខីកម្មអំពីកង្វះអនាម័យនៅការដ្ឋានទំនប់ ១ មករា។ គាត់បានផ្ដល់សក្ខីកម្មថា "លក្ខខណ្ឌនៅការដ្ឋាន មានទឹកដាំនៅនឹងខ្ទះត្នោត។ ពួកខ្ញុំយកទៅដងទឹកក្ដៅចឹង ញ៉ាំទៅ។ ជួនកាលអស់ ហើយកន្លែងគេងអត់មានទេ អត់ទឹកងូតទេ។ នាងខ្ញុំដើរទៅនាងខ្ញុំងូតទឹកអណ្ដូងនៅជិតភូមិអ្នកស្រុកគេ។ នៅកន្លែងគេងហ្នឹងមានគេធ្វើបង្គន់ តែនៅកន្លែងការដ្ឋានខ្ញុំ បត់ធុងសាំង។ ពេលខ្លះនាងខ្ញុំខ្លាចធុងសាំងខ្ពស់ នាងខ្ញុំទៅបត់ក្នុងព្រៃ តែគេអត់ឲ្យយើងបត់ព្រៃទេ គេឲ្យបត់ធុងសាំង ដើម្បីយកធ្វើជី។ ហើយនៅកន្លែងគេងហ្នឹង ហើយពួកខ្ញុំអត់ដែលមានសាប៊ូ អត់ដែលមានថ្នាំដុះធ្មេញ អត់ដែលមានអ្វីដែលសម្អាតខ្លួនកាយ គឺអត់ដែល គេអត់មានរបបឲ្យយើងទេ"[1080]។

574. ទាក់ទងនឹងការដាំទឹក ដើមបណ្ដឹងរដ្ឋប្បវេណី សៀង សុវីដា បានពន្យល់ថា "គេដាំនោះ គេដាំសម្រាប់ពួកការដ្ឋានទាំងអស់ហ្នឹង ក៏ប៉ុន្តែទឹកហ្នឹង តែខ្ញុំអត់ដឹងថាទឹកអីទេ តែនៅស្រុកហ្នឹងច្រើនយកពីស្រះ ពីស្ទឹង ពីអូរអីចឹងយកមកប្រើ ដូចអត់មានទឹកម៉ាស៊ីនទេនៅស្រុកហ្នឹង។ ទឹកអូរត្រពាំងអីអីចឹងទៅ យកមកដាំទៅមានល្អក់អីចឹងទៅ ខ្លះទៅអីទៅ។ ហើយបើអ្នកខ្លះស្រែកខ្លាំង មានទឹកអីក្រឡុកណា ក៏ខ្ញុំអត់ដឹងដែរយ៉ាងណាម៉េច គេផឹកឬក៏អី ខ្ញុំអត់យល់"[1081]។ ដើមបណ្ដឹងរដ្ឋប្បវេណីនេះក៏បានផ្ដល់សក្ខីកម្មថា "កន្លែងបរិភោគហ្នឹង មិនស្អាតទេ យើងមានទឹកទេ យើងដាក់ចាននៅនឹងក្រោមទៅ បើមានចំបើង ឬស្លឹកឈើអី យើងទ្រាប់ចានយើងទៅ។ បើពេលណាភ្លៀងវិញ ជួនកាល

[1079] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ៧-៨ បន្ទាត់ ២៣-៣។

[1080] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ាង សុវីដា ប្រតិចារឹក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ២៦-២៧ បន្ទាត់ ១៧-១។

[1081] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ាង សុវីដា ប្រតិចារឹក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ៣១ បន្ទាត់ ១០-១៣។

– បើសិនមិនមែនកន្លែងហ្នឹងទេណា កន្លែងផ្សេងទេណា ការដ្ឋានផ្សេងភ្លៀង គឺវាយើងញ៉ាំអឺចឹង។ ហើយអាទឹក អាចានហ្នឹងវាមានអីស្អាត គគ្រិចទាំងអស់ហ្នឹង មានសាប៊ូមានអីលាងទេ"[1082]។

575. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានរៀបរាប់ថា "បើនិយាយរឿងហូបចុកវិញចប់ហើយ។ ដឹងស្រាប់ហើយ ខែ៤ ខែ៥ រុយប៉ុនណា! បាយគេនាំគ្នាសែទៅហ្នឹងគឺរុយតាមអ្វីៗជាងឃ្មុំទៀត។ បាយខាងលើមុខលើហ្នឹង សុទ្ធតែអាចម៍រុយ។ សម្លសែងទៅ ខ្ញុំមិនកុហកទេ ដួសមួយវែកណាក៏រុយដែរ បើយើងឥឡូវនេះមិនដឹងថាស្អីទេ។ កាលនោះឆ្កឹះតែខ្លួនរុយចេញទេ សូម្បីតែដួសឲ្យដោយទឹកសម្លមកជាមួយរុយហ្នឹងក៏គ្មានដែរ ធ្វើម៉េចឆ្កឹះតែរុយចេញ។ ដួសទៅចែកបន្តិចៗម្នាក់ទៅ"[1083]។

576. ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ បានផ្តល់សក្ខីកម្មថា "តែបាយគឺគេចែកម្នាក់មួយចានអឺចឹង គឺនៅក្នុងបាយហ្នឹង គឺមានរុយ មួយចានហ្នឹងគឺមានប្រាំ ប្រាំមួយចឹងទៅ"[1084]។ គាត់បានបន្តទៀតថា "ហើយពេលដែលយើង ពេលយើងកំពុងរែកដីក្តៅអឺចឹង គឺស្រេកទឹក យូរៗឃើញបានគេចាត់មនុស្សឲ្យទៅដងទឹកមកម្តង គេដាក់យោង ហើយគេសែងទឹកមកម្តង ទឹកហ្នឹងគឺល្អក់ តែយើងស្រេកយើងត្រូវតែហូប។ យើងស្រេកមែនទែន រហូតដល់ពេលយប់អី យើងគេង យល់សប្តិបានហូបទឹកកកអឺចឹង ដូចថាយើងខ្វះទាំងអស់"[1085]។

---

[1082] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ាង សុវីដា ប្រតិចារឹក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ៣១ បន្ទាត់ ១៨-២១។

[1083] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ៥៦ បន្ទាត់ ២១-២៥។ សូមមើលផងដែរ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ៦០ បន្ទាត់ ១៥-ទំព័រ ៦១ បន្ទាត់ ១ ("ខ្ញុំពិបាកឆ្លើយសំណួរដែលគេសួរដោយមិនសើច។ ដូចខ្ញុំនិយាយពីព្រឹកមិញ គ្មានសោះទាក់ទងការកម្ចាត់សត្វល្អិត។ ព្រឹកមិញ ខ្ញុំបានប្រាប់ហើយថាសម្ល-ទោះជាមានតិចក្តី ក៏វាពោរពេញដោយសត្វល្អិត ហើយយើងត្រូវយកវាចេញពីចានម្តងមួយ។ គេជួបរឿងនេះគ្រប់គ្នា។ ទោះមានសត្វល្អិតក្នុងសម្លក្តី ក៏យើងត្រូវបរិភោគនិងហុតទឹកសម្លដើម្បីរស់។ កាលណោះ អនាម័យលែងគិតទៀតហើយ។ យើងត្រូវគិតអ្វីដែលយើងអាចបរិភោគបានដើម្បីរស់។ ហើយមនុស្សកើតជំងឺរាគមួលច្រើន។ ជួនកាល ពួកគាត់ត្រូវទៅព្រៃបន្ទោរបង់ជាបន្ទាត់ នោះក៏មកពីកង្វះអនាម័យ")។

[1084] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ១០ បន្ទាត់ ១៤-១៥។

[1085] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ១១ បន្ទាត់ ៧-១១។

577. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន បានផ្ដល់សក្ខីកម្មថា ទឹកផឹកមក "ពីត្រហិកត្រហុក"[1086] ហើយថា "ទឹកហ្នឹង បើតាមមើលមិនស្អាតទេ ព្រោះអណ្ដូងជីកនៅនឹងដីក្បែរចង្ក្រានបាយហ្នឹង ជីកទៅវាចេញ កាលណាយើងទៅងូតទៅអីទៅវាហូរកក្អិកក្អាក់ ចូលអណ្ដូងក៏មាន អីក៏មានដែរ។ ទឹកវាល្អក់ ដង ដួសដាក់កន្ធូមករៀងខ្លួនមក យកមកដាក់ក្បែររោងទៅ ព្រឹកឡើងរង ច្រកនៅនឹងបំពង់ទៅ។ បំពង់ ទឹកត្នោត យកទៅកន្លែងរែកដីរៀងៗខ្លួន"[1087]។ នៅពេលកពលករចង់ទៅបង្គន់ គឺ "គ្មានធ្វើបង្គន់ទេ មានតែជីករណ្ដៅ ជីអន្លង់ៗ ហើយដាក់កល់ឈើជុះទៅ។ ហើយភាគច្រើនដូចជាមិនសូវមានពីណា ជុះនៅក្នុងរណ្ដៅទេ ជុះច្រើនដាក់ពាសវាលពាសកាល។ ហើយអ្នកនៅរោងឈឺ គេឲ្យរើសលាមក នោះហ្នឹងឯងតើ"[1088]។ មានតែ "អត់មានទឹកងូតទេ កន្លែងការដ្ឋាន។ មួយថ្ងៃងូតតែម្ដង មានតែ មករោងវិញពេលល្ងាច"[1089]។ "មួយបុណ្យប៉ុលពតនេះ គឺថាមិនដែលឃើញសាប៊ូ មួយបន្តិច ណាក៏អត់ឃើញទេ។ ខ្ញុំមិនដែលជួបឃើញមានសាប៊ូអី ខ្ញុំបោកខោអាវ ខ្ញុំយកផេះ ដូចខ្ញុំថា ខ្ញុំយកផេះទៅត្រាំឲ្យរងទៅ យកទឹកថ្លាៗមកបោក យូរៗម្ដង។ វាចេញចៃខ្លាំងពេកនោះ។ បើថា ឲ្យស្គាល់ជាតិសាប៊ូ ម៉ាបុណ្យខ្មែរក្រហម គឺទទេសុទ្ធសាធ"[1090]។

578. ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានផ្ដល់សក្ខីកម្មថា "ក្រោយមក ប្រហែលជាដល់ខែ -- ទៅ ដំបូងប៉ុន្មានខែហ្នឹងគឺគ្មានទេ ដល់ខែ ប្រហែលជាចុងខែ៤អីហ្នឹង ឃើញតាមភូមិ គេដាក់ឲ្យទៅធ្វើ បង្គន់ឈើសែងហ្នឹង។ ហើយមានអ្នកទៅធ្វើជីរហ្នឹងយកផេះ យកអីទៅលាយលាមកហ្នឹងសម្រាប់ ធ្វើជីរ យកមកភូមិទៀត។ គេលាយហើយដាក់ហាលលើដីហ្នឹង គេច្រកយកមកភូមិ យកមកបាច ស្រូវនៅឯភូមិ។ ទឹកហូបអី នាំគ្នាហូបទឹកស្ទឹង។ ចម្រុះគ្នារាប់រយរាប់ពាន់នាក់ពីលើមក តែចេះតែ

---

1086 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ២៣ បន្ទាត់ ៥។

1087 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ២៣ បន្ទាត់ ៩-១២។

1088 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ២៣ បន្ទាត់ ១៥-១៧។

1089 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ២៣ បន្ទាត់ ២០។

1090 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ២៣ បន្ទាត់ ២២-២៥។

ហួបទៅ ធ្វើម៉េចបើអត់ហើយ"។ គាត់បានពន្យល់ថា "គ្មានពេលណាទៅដាំទឹកញ៉ាំនោះ មានឆ្នាំង ឯណា មានអុសឯណាដោះស្រាយរៀងៗខ្លួន រកឯណាបានញ៉ាំទៅ គឺគេដោះស្រាយតែបាយហ្នឹង វាពិសេសណាស់ទៅហើយ។ ឆ្នេចភ្នែកណ៎ះ ញ៉ាំទឹកហ្នឹង មិនមែនបើកភ្នែកញ៉ាំកើតទេ គឺឆ្នេចភ្នែក បានញ៉ាំកើត បើកភ្នែកញ៉ាំមិនកើតទេ។ កុំជឿអ្នកណាថាដាំទឹកញ៉ាំអី ខ្ញុំមិនជឿសោះ ព្រោះខ្ញុំ មិនដែលឃើញ"[1091]។

579. ទាក់ទងនឹងអនាម័យស្ត្រី ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានផ្តល់សក្ខីកម្មថា "អ្នកដែលគេ គ្រប់គ្រងយើងហ្នឹងគេមិនដឹងខ្យល់អីទេ គេមិនដឹងអីទេ។ គេមិនដឹងមែន មិនដឹងថាយើងពិបាក យ៉ាងម៉េច អីយ៉ាងម៉េច គឺគ្មានទេ ស្រីៗគឺដូចតែគ្នាហ្នឹង។ កាលពីនៅឆ្ងាយពីស្ទឹង រែកទាំងខោ ប្រឡាក់ហ្នឹង មិនខ្វល់ទេ យើងក៏ដូចគេៗក៏ដូចយើង ទាល់តែបានទៅស្ទឹងហ្នឹងទេ បានពេលប្រឡាក់ ខោនាំគ្នាចុះទៅក្នុងទឹកស្ទឹងហ្នឹងទៅ។ កុំឱ្យវាប្រឡាក់កាន់តែច្រើនឡើងៗដឹងស្រាប់ហើយ ឈាម រដូវមិនដែលមកតិចៗទេ"[1092]។ គាត់បញ្ជាក់ទៀតថា "ចុះមនុស្សប្រុសៗមិនដឹងខ្យល់អីមែន មិនដឹង ពីទុក្ខវេទនាកូនក្រុម កូនចៅហ្នឹងយ៉ាងម៉េចអី គឺមិនដឹងធ្វើម៉េច យកតែរួចខ្លួនរៀងៗខ្លួន មិនយល់ មិនដឹង មិនឮអីទេ ទាល់តែថាឈឺហ្នឹងទៅមិនរួចតែម្តង គ្រាន់ថាទៅមិនរួចបញ្ជូនទៅភូមិ គ្រាន់តែ ប៉ុណ្ណឹង។ បើថាឱ្យទៅមើល ទៅអើត ទៅឈ្លោក ទៅសួរ ទៅនាំ ក៏គ្មានដែរ"[1093]។ "គេមិនដឹង មិនឮទេ មិនដឹងអីតែម្តងទៅ"[1094]។

## ២.៣. កង្វះការថែទាំវេជ្ជសាស្ត្រ

580. ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវីដា បានផ្តល់សក្ខីកម្មថា "នាងខ្ញុំដួលតែម្តងទេ។ នាងខ្ញុំអត់ស្ទូវ ឈឺប៉ុន្មានទេ តែចុងក្រោយនាងខ្ញុំឈឺបន្តិចបន្តួចក្តៅខ្លួនបន្តិចបន្តួច ឬក៏អស់កម្លាំង ឬក៏វិលមុខអី

[1091] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ៦ បន្ទាត់ ១៩-២២។

[1092] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ១០-១១ បន្ទាត់ ២១-១។

[1093] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ១៩ បន្ទាត់ ៩-១២។

[1094] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ១៩ បន្ទាត់ ១៥។

បន្តិចបន្តួច សម្ងំហើយនាងខ្ញុំទៅធ្វើការហើយ។ ពីព្រោះនាងខ្ញុំមិនសូវចេះនៅ ឲ្យតែនាងខ្ញុំធ្វើរួច ដើររួច នាងខ្ញុំទៅរហូត ឲ្យនាងខ្ញុំឈឺធ្ងន់អត់ដែលធ្ងន់ខ្លាំង ថ្ងៃនុំងប្រហែលជាសម្រាក១ថ្ងៃ, ២ថ្ងៃ នាងខ្ញុំត្រឡប់ទៅធ្វើការវិញ។ ពេលនាងខ្ញុំឈឺមានពេទ្យ១ គេនោះពេទ្យអស់ចេះទេ ពេទ្យគេមានតែឲ្យថ្នាំដូចអាចម៍ទន្សាយអ៊ីចឹង ញុំាមិនត្រូវ។ ពេលខ្ញុំឈឺហ្នឹង មានពូម្នាក់ធ្វើការជាមួយខ្ញុំនុំង ខ្ញុំចាំគាត់ឈ្មោះ ពូគង់ គាត់ឲ្យថ្នាំពីភ្នំពេញទៅឲ្យខ្ញុំញ៉ាំមួយគ្រាប់។ គាត់ថា "អ្អែងទាល់តែញ៉ាំថ្នាំហ្នឹង ហើយ អ្អែងក្តៅ អ្អែងនេះអ៊ីចឹង។" ពេលនោះ ខ្ញុំក៏បានធូរស្បើយ ហើយថ្នាំពេទ្យឲ្យរបស់ខាងខ្មែរក្រហមឲ្យខ្ញុំអត់ញ៉ាំ១អត់ត្រូវ ព្រោះមូល១ខ្មៅ១។ ហើយគេអត់មានពិនិត្យមើលអី យើងឈឺអីម៉េច ១ មានមើលឈាម មើលអីអត់ទេ គេដឹងតែចែក១ ហើយអ្នកពេទ្យនោះក៏អត់មានអ្នកចេះដឹងយ៉ាងម៉េចមើលថាម៉េច១ ខ្ញុំអត់យល់ដែរ"[1095]។

581. ដើមបណ្តឹងរដ្ឋប្បវេណីរំឭកពីការព្យាបាលដោយពេទ្យ ដោយបាននិយាយថា "ពេទ្យទាំងអស់នោះអត់មានពេទ្យអីទេដូចជាមានតា១ចាស់១ គាត់ជាគ្រូខ្មែរ ដាំថ្នាំខ្មែរ។ បើនៅ ខ្ញុំដឹងខ្ញុំធ្លាប់គេងនៅវត្តចំបក់ ខាងវត្តចំបក់ហ្នឹង អ្នកប្រធានហ្នឹងឈ្មោះ តាវល្លិ៍ តាហ្នឹងរបៀបគ្រូខ្មែរ រួច តាសន ហ្នឹងអនុ។ ហើយ តាវល្លិ៍ ហ្នឹងគាត់ថ្នាំអ៊ីចឹង ហៅពួកអ្នកជំងឺញ៉ាំអ៊ីចឹងទៅ ហើយពេទ្យ -- បើមានពេទ្យខ្លាំងគេនោះ គេមានទឹកថ្នាំដូចខ្ញុំនិយាយព្រឹកមិញអ៊ីចឹង។ ដូចអត់មានអីឲ្យហួសផង អត់មានអីថ្នាំពិសេសផង ពេទ្យនោះគាត់អត់មានស្លៀកអីជាឯកសណ្ឋានពេទ្យដែរ ស្លៀកពាក់ខ្មៅធម្មតា"[1096]។

582. ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឡាង ដែលមានការងារជាគ្រូពេទ្យយោធាមួយរូបក្នុងរបប លន់ នល់ បានរំលឹកពីឧទាហរណ៍មួយ នៅពេលគ្រូពេទ្យម្នាក់មិនអាចចាក់ថ្នាំឲ្យអ្នកជំងឺ ហើយគាត់បានជួយគ្រូពេទ្យនោះ។ ដើមបណ្តឹងរដ្ឋប្បវេណីបានសុំកុំឲ្យបុគ្គលិកពេទ្យនោះរាយការណ៍ទៅអ្នកគ្រប់គ្រងរបស់គាត់អំពីបទពិសោធន៍ជាគ្រូពេទ្យរបស់គាត់[1097]។ គាត់បានលើកឡើងថា "តាមគំនិតរបស់ខ្ញុំ

[1095] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ាង សុវីដា ប្រតិចារឹក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ១៩ បន្ទាត់ ៥-១៤។

[1096] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ាង សុវីដា ប្រតិចារឹក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ៥២ បន្ទាត់ ៩-១៤។

[1097] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចាវ ឡាង ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ៦២ បន្ទាត់ ៨-១២។

គឺមិនមានអីដែលច្បាស់លាស់នឹងវិជ្ជាពេទ្យទេ ព្រោះអីដោតម្ជុលចង់ងាប់មនុស្សហើយ អត់ចូលផង"[1098]។

583. នៅពេលពលករឈឺ ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន "ចាស មិនដឹងថារោគសញ្ញាអីទេ ប៉ុនដូចថាវាភាគច្រើនជំងឺ ច្រើនតែរាក ឈឺច្រើន រាក។ រាក ហើយនិងគ្រុនក្ដៅឈឺក្បាល។ ភាគច្រើនជាងគេបំផុតគឺរាក"[1099]។ ថ្នាំដែលគេឱ្យមាន "មានថ្នាំប្រចាំកង ថ្នាំអាចមន៍ទន្សាយ ថ្នាំដបទឹកក្រូចអាក្រហមៗនោះ។ រាកក៏លេបអានោះឯង គ្រុនក៏លេបអានោះឯង"[1100]។ គាត់បានបញ្ជាក់ថា ពេលខ្លះមានអ្នកជាសះស្បើយដែរ "ជួនកាលលេបទៅវាមានបាត់ ជួនកាលក៏វាអត់បាត់ទៅ"[1101]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មបន្ថែមទៀតថា គាត់អង្កេតឃើញថាគ្មានថ្នាំទេ ដោយលើកឡើងថា "ថ្នាំវាអត់មានដូចយើង ដូចពេទ្យយើងសព្វថ្ងៃ វាថ្នាំច្រើនប្រភេទ ច្រើនមុខ។ នោះមានពីណា មានតែអាដបទឹកក្រូចពណ៌ក្រហមនោះឯងទៅ ហើយនិងថ្នាំគ្រាប់អាចម៍ទន្សោយ។ វាដូចថា វាអត់មានប៉ារ៉ា វាអត់មានអាម៉ុកស៊ីលីន វាអត់អី វាអត់ដឹងថា មានគេចេះដល់កម្រិតណា ក៏ខ្ញុំមិនដឹងដែរ។ គ្រាន់ថាបើថ្នាំរាកអាចម៍ ក៏ឃើញគេឱ្យអាចម៍ទន្សោយ អាឈឺក្បាល ក៏ឱ្យអាចម៍ទន្សោយ វាដូចៗគ្នា"[1102]។

584. នៅពេលដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ធ្លាក់ខ្លួនឈឺ ជំងឺនោះ "ឈឺហេវអស់កម្លាំង ទៅអត់រួច។ ញ័រជង្គង់ ញ័រជើងពេក សម្រាក ដេកសំកុកធ្វើឈឺទៅ។ ឈឺទៅ សួរពីណាកើតអី? ឈឺពោះ គេឱ្យថ្នាំអាចម៍ទន្សាយលេបមក។ បើថាឱ្យឈឺពិតប្រាកដមិនឈឺទេ វាហេវខ្លាំងពេក ទៅអត់រួចៗ ក៏ដេក

[1098] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ចាវ ឡាង ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ៦២ បន្ទាត់ ១២-១៣។

[1099] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ២៤ បន្ទាត់ ៧-៨។

[1100] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ២៤ បន្ទាត់ ១០-១១។

[1101] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ២៤ បន្ទាត់ ១។

[1102] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ២៥ បន្ទាត់ ៨-១២។

សំកុកដល់ថ្ងៃទៅ គេហៅថាកើតអី? ឈឺពោះ។ ឈឺណា ទៅអត់រួចហើយ"[1103]។ គាត់ក៏បានរៀបរាប់ថាមួយខែក្រោយ គាត់ឈឺកែងជើង និងជង្គង់។ "ហើមជើងក្រោយទៅដើរអត់រួចៗ ខ្ញុំប្រាប់ពេទ្យគេៗមកមើល គេយកអាថ្នាំទឹកដបក្រហមៗ បេ១២អីមកចាក់។ ចាក់ពីរម្ភុលព្រឹកហ្នឹងឯងល្ងាចហ្នឹងឯង។ ចាក់រួចទៅ ចាប់ផ្ដើមអាចាក់ពីព្រឹកហ្នឹងវាហើមត្រគាក ចង់កើតអាប់សែ ៗ ត្រគាក គ្រុន ទៅជាគ្រុន។ រួចពីអានោះទៅ គេឈប់ចាក់អានោះ ព្រឹកស្អែកឡើងទៀត គេយកអាម្ភុលវិទ្យាសាស្ត្រនោះមកត្បាល់ក្បាលជង្គង់និងសរសៃកែងជើងខ្ញុំ។ ក៏ខ្ញុំខ្លាចខ្ញុំ តាំងពីនោះ អាឈឺមិនឈឺៗ ក៏ខ្ញុំចេះតែទៅបន្តិចៗទៅវិញជាទៅ ក៏បាត់ទៅ ខ្ញុំរែកដីអត់កើតទេ។ ខ្ញុំអ្នកកាប់ឲ្យគេអ្នករែកចុះ។ ឈឺពីរដងហ្នឹងឯង"[1104]។

## ២.៤. ការបាត់ខ្លួន

585. ដើមបណ្ដឹងរដ្ឋប្បវេណី នួន ណារុំ បានផ្ដល់សក្ខីកម្មថា "ពេលចប់ការដ្ឋានហើយ មិត្តៗដែលគេដឹងហ្នឹង គេខ្សឹបប្រាប់ខ្ញុំថា សង្កាត់យើងមានបាត់មនុស្សបីបួន នាក់។ បាត់ តែខ្ញុំមានស្គាល់តែម្នាក់ហ្នឹងទេ ឈ្មោះ ដានិច អ្នកថ្មី ឈ្មោះ ដានិច។ នាងហ្នឹងស្អាតណាស់។ នាងហ្នឹង តាមឮតាមមិត្តភក្តិថាជាកូនមេធាវី ស្អាតៗដូចបវរកញ្ញាអីចឹង។ នាងខ្ញុំស្គាល់តែម្នាក់ហ្នឹង គេថាបាត់ពីរបីនាក់ ប៉ុន្តែនាងខ្ញុំអត់ស្គាល់ ស្គាល់តែម្នាក់ហ្នឹង។ ពេលចប់ការងារគឺបាត់ខ្លួន"[1105]។

# ៣. ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល

586. ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានផ្ដល់សក្ខីកម្មនៅសវនការ បញ្ជាក់ថា ទង្វើសកម្ម ឬអកម្មដែលបណ្ដាលឲ្យមនុស្សស្លាប់ ត្រូវបានធ្វើឡើងនៅការដ្ឋានទំនប់ ១ មករា។

## ៣.១. ករណីជាក់លាក់នៃការសម្លាប់មនុស្ស

---

[1103] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ៥០ បន្ទាត់ ៥-៨។

[1104] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ **E1/307.1** ទំព័រ ៥០-៥១ បន្ទាត់ ២១-១។

[1105] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី នួន ណារុំ ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ២៤-២៥ បន្ទាត់ ២៣-១។

587. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានផ្តល់សក្ខីកម្មថា គ្រួសាររបស់គាត់ត្រូវបញ្ជូនឲ្យទៅធ្វើការនៅទំនប់១មករា ហើយក្រោយមក ឪពុករបស់គាត់ត្រូវបានយកទៅសម្លាប់នៅវត្តបារាយណ៍ជាន់ដែក។ "ប្អូនខ្ញុំឃើញនឹងភ្នែក ប្រាប់ថា ហៅយកទៅជួយលីឈើ ទៅជួយសែងឈើគេ យោធាមកហៅ។ ប្អូនខ្ញុំឃើញ ប្អូនខ្ញុំដឹង ខ្ញុំជីកនៅប្តូង់ជាប់ហ្នឹង តែខ្ញុំថ្ងៃនោះ ខ្ញុំមករដូវហ្នឹង ល្ងាចខ្ញុំសម្រាក គឺយប់ហ្នឹងឯង ប្រហែលជាម៉ោងប្រាំពីរយប់ហ្នឹង។ រួចទាល់តែភ្លឺឡើង បានប្អូនខ្ញុំមកប្រាប់ថា "បងគេហៅប៉ាទៅបាត់ហើយ មួយយប់ហើយ អត់ឃើញប៉ាយើងមកវិញទេ""[1106]។

588. ទាក់ទងនឹងរបៀបដែលបងប្អូនរបស់គាត់ដឹងថា ឪពុករបស់ពួកគេត្រូវបានបញ្ជូនទៅវត្តបារាយណ៍ជាន់ដែកនោះ ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា "ធម្មតា កន្លែងគុក កន្លែងសម្លាប់មនុស្សគឺតែងតែប្រជាជនដឹង។ ខ្ញុំដឹង ដឹងតាមរយៈគេប្រាប់បារាយណ៍ជាន់ដែកហ្នឹងជាគុកធំ។ គេចាប់ពីកន្លែងណាៗទៅ មិនមែនចាំបាច់តែនៅ ១មករាទេ អ្នកទោសធ្ងន់ៗ គឺគេយកទៅសម្លាប់នៅទីនោះ។ បានដឹងថាគេយកទៅសម្លាប់ទីនោះ ព្រោះគេមានកន្លែងគេហ្នឹងស្រាប់ហើយ។ ប្អូនខ្ញុំមកប្រាប់ហ្នឹងថា "បងបាត់ប៉ាហើយ គេមុខជាយកទៅសម្លាប់នៅ បារាយណ៍ជាន់ដែក ហ្នឹងឯងគេគ្មានយកទៅណាទេ។ ប៉ាយើងបាត់មួយយប់ហើយ មិនឃើញគាត់ត្រឡប់មកវិញទេបង""[1107]។

589. នៅពេលសួរអំពីហេតុផលដែលឪពុករបស់គាត់ត្រូវបានចាប់ខ្លួន និងសម្លាប់នោះ ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានពិណ៌នាថា "ពេលនោះ គេជាមាត់ទិព្វហើយ គេចង់សម្លាប់អ្នកណាស្រេចតែចិត្តគេ។ ខ្ញុំមើលទៅឪពុកខ្ញុំហាក់ដូចជាគ្មានកំហុសអីទេ ព្រោះឃើញគាត់ទៅរែកដីរាល់តែថ្ងៃ មិនដែលខានថ្ងៃណាទេ។ មិនឃើញគាត់សម្រាកទេ ព្រោះប្តូង់នៅជិតគ្នា។ មិនដឹងជាកំហុសរឿងអី ខ្ញុំរកមូលហេតុមិនឃើញទេ។ ឪពុកខ្ញុំប្រឹងណាស់ ព្រោះគាត់ជាគ្រូបង្រៀន គាត់ដឹងថាគាត់មានខ្លួន គាត់ប្រឹងធ្វើការ គេរុញទៅណាក៏គាត់ទៅនុ៎ង គាត់មិនដែលប្រកែកនឹងគេទេ។ ចុះហេតុអីយកគាត់ទៅសម្លាប់មិនប្រាប់ពីមូលហេតុ គាត់មិនទាំងដឹងខ្លួនផង។ គេហៅទៅ ថាហៅទៅលីឈើ គេហៅទៅឲ្យជួយលីឈើ ទៅបាត់រហូតៗ។ ចាំមើល១ថ្ងៃ ២ថ្ងៃមិនឃើញ ៣ថ្ងៃ ៤ថ្ងៃក៏មិនឃើញ បាត់រហូត។ អ្នកដែលគេដឹង គេប្រាប់ហើយថា គេចាប់ទៅហើយ គឺមិនរួចខ្លួនទេ គេ

---

[1106] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ១៤ បន្ទាត់ ២-៥។

[1107] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ២៤ បន្ទាត់ ១៥-២០។

យកទៅបាគាយណ៍ជាន់ដែកហ្នឹងឯង ទើបតែដាច់មកទេបានខ្ញុំឃើញរណ្ដៅនៅកន្លែងនុំងច្រើនណាស់។ រណ្ដៅជាប់ៗគ្នាហ្នឹង សុទ្ធតែឃើញតែក្បាល ឃើញតែឆ្អឹង។ បានខ្ញុំជឿជាក់ថាឪពុកខ្ញុំប្រាកដជាស្លាប់នៅទីនោះហើយ គ្មានយកទៅណាទេ”[1108]។

590. សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី សៀង សុវីដា បានបញ្ជាក់ពីការសម្លាប់នៅបារាយណ៍ជាន់ដែក។ “ពេលងូតទឹកអណ្ដូង ពួកបងៗថា “កុំទៅជិតវត្តហ្នឹង អត់បានទេ” អត់ឱ្យពួកខ្ញុំទៅទេ ហើយពួកខ្ញុំងូតនៅឆ្ងាយ ពួកបងៗខ្លះគេចាំយូរ អណ្ដូងមួយអ៊ីចឹង ដូចថា ភូមិមួយៗ អណ្ដូងវាវាងឆ្ងាយដែរ គ្នាច្រើននោះ ដល់ចាំគ្នាអ៊ីចឹងទៅ គេក៏ដើរទៅឆ្ងាយហ្នឹង គេហាមអត់ឱ្យទៅនុំងទេ។ តែមានអ្នកខ្លះគេទៅ គេទៅគេឃើញសកម្មភាព តែគេអត់និយាយអី គេថា “កុំទៅ កន្លែងហ្នឹងមិនឱ្យយើងនេះទេ ទៅវិញ”។ គាត់ភ័យញ័រទទ្រាក់ទទ្រើតមកវិញ ហើយពួកខ្ញុំក៏អត់ដែលបានទៅឃើញវត្តហ្នឹង ឬក៏គេធ្វើសកម្មភាពអីហ្នឹង ក៏ខ្ញុំអត់ដែលឃើញដែរ។ ខ្ញុំបានឮដំណឹងតាមបងៗ អត់ឱ្យពួកខ្ញុំទៅងូតហ្នឹង ទ្រាំចាំគេទៅ”[1109]។ “គេថា គេបានឃើញមាន ប្រហែលជាមួយក្រុមប្រាំនាក់បួនដប់នាក់អត់សូវច្រើនទេ តែគេឱ្យធ្វើការ ឃើញកាប់អុស ចងច្រវាក់ជើងហ្នឹងតគ្នាអ៊ីចឹង។ រួចទៅអ្នកខ្លះឃើញគេកាត់ដោះស្រីៗហ្នឹង ព្យួរនៅតាមទ្វារហ្នឹងឈាមកក្លាក់។ រួចថា “កុំទៅ កុំចង់ដឹង” គេខ្សឹបគ្នា គេមិនឱ្យខ្ញុំក្មេងដឹងទេ។ ខ្ញុំគ្រាន់តែបានឮតិចៗ តាមគេប្រាប់គ្នាអ៊ីចឹង ហើយគេថា “កុំចង់ស្ដាប់អូន កុំដឹងអូន កុំ””[1110]។

591. ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានផ្ដល់សក្ខីកម្មថា នៅថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ ១៩៧៧ គាត់បានទទួលព័ត៌មានថា ម្ដាយរបស់គាត់ និងបងប្អូនប្រុសស្រីប្រាំនាក់ ត្រូវបានខ្មែរក្រហមសម្លាប់ចោល ដោយទម្លាក់ចូលទៅក្នុងអណ្ដូងក្នុងចម្ការអណ្ដូង។ គាត់បានរំលឹកថាម្ដាយរបស់គាត់ត្រូវបានហៅទៅប្រជុំ។ “ដល់ពេលម៉ោងប្រហែលជាដប់អីហ្នឹង រទេះគេចេញទៅ នៅក្នុងភូមិខ្ញុំហ្នឹងក៏មាន

---

[1108] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ២៥ បន្ទាត់ ៧-១៦។

[1109] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សៀង សុវីដា ប្រតិចារឹក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ៣០ បន្ទាត់ ១០-១៦។

[1110] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សៀង សុវីដា ប្រតិចារឹក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ៣០ បន្ទាត់ ២០-២៣។

ដឹកទៅដែរ យកចេញទៅហ្នឹង”[1111]។ “ស្រាប់តែល្ងាច មិត្តភក្តិខ្ញុំម្នាក់ឈ្មោះ សារឿន គេៗអ្នកថ្មីតែម៉ែឪគេអ្នកចាស់នៅនោះ។ គេយំមកឱបខ្ញុំ គេថា “នីអើយ! ម៉ាក់នីដែលទៅនឹងគេយកទៅសម្លាប់នៅចម្ការអណ្តូងអស់ហើយ”។ ខ្ញុំមិនជឿទេ ខ្ញុំមិនជឿថាយកមនុស្សទៅសម្លាប់ចោល ខ្ញុំមិនជឿទាល់តែសោះ ព្រោះមនុស្សច្រើនណាស់។ ខ្ញុំថា “សម្លាប់ម៉េចទេ បើទៅពីរបីនាក់ បួនប្រាំនាក់អាហ្នឹងខ្ញុំ បើទៅរាប់សិបរទេះអ៊ីចឹងខ្ញុំមិនជឿទេ” ខ្ញុំមិនជឿមែន។ ទាល់តែកន្លងមកបានប្រហែលជា៥ថ្ងៃ ខ្ញុំឃើញខោអាវប្អូនខ្ញុំ អាវប៉ាក់ដែលម៉ាក់កាត់ឲ្យធ្វើជាអាវទ្រនាប់ គាត់ឲ្យមកខ្ញុំមួយ ឲ្យទៅប្អូនស្រីខ្ញុំមួយ ខ្ញុំឃើញគេហាលអាវ អាវទ្រនាប់ហ្នឹងបានខ្ញុំដឹងប្រាកដ។ ខ្ញុំថាខោអាវហ្នឹងជាខោអាវប្អូនរបស់ខ្ញុំហើយ បានខ្ញុំជឿៗថា ស្លាប់ហើយ ស្លាប់ទាំងអស់គ្នាហើយ”[1112]។

## ៣.២. ការស្លាប់ដោយសារលក្ខខណ្ឌការងារ

### i. លក្ខខណ្ឌការងារយ៉ាងគ្រោះថ្នាក់

592. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន បានផ្តល់សក្ខីកម្មទាក់ទងទៅនឹងការស្លាប់ដោយការបាក់ដី។ “ចាស ឮ អត់ឃើញទេ តែឮ។ ឮថា បាក់ដីសង្កត់មនុស្សចំនួនបីនាក់ ដឹងថាស្លាប់មួយ អាពីរនោះ ខ្ញុំអត់ដឹងថាស្លាប់ ថារស់ ដឹងតែស្លាប់មួយ កប់នៅនឹងដី ហើយយកអត់បាន។ ខ្ញុំឮទេ អត់បានឃើញនឹងភ្នែកផ្ទាល់ទេ។ មានគេទៅមើលទៅ ខ្ញុំសួរគេ ព្រោះនៅឆ្ងាយពីរោងខ្ញុំដែរ”[1113]។ នៅពេលធ្វើការនៅទំនប់នោះ គាត់ឮពីពលករដទៃទៀតដែលនិយាយថា “ទំនប់នោះវាបាក់សង្កត់ មនុស្សខ្ញុំដឹងខ្ញុំឮគេថា”[1114]។ “ខ្ញុំមិនអាចបញ្ជាក់ប្រាប់បានទេ ព្រោះខ្ញុំអត់បានឃើញផ្ទាល់នឹងភ្នែក។

[1111] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ២៨ បន្ទាត់ ៨-៩។

[1112] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ២៨ បន្ទាត់ ១៧-២៤។

[1113] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ១១ បន្ទាត់ ១២-១៤។

[1114] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ៦១ បន្ទាត់ ១៣។

ចុះមានគេទៅមើល ឮគេនិយាយក៏ស្ដាប់គេទៅ ឲ្យខ្ញុំបានឃើញផ្ទាល់នឹងភ្នែកខ្ញុំអត់បានឃើញទេ”[1115]។

593. ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានរៀបរាប់ពីរបៀបដែល “គេលុង ខំលុងដី គឺធ្វើការប្រកួតប្រជែងគ្នា ដើម្បីស្រួតឲ្យការងារហ្នឹងល្អ ការងារហ្នឹងលឿន កើតគំនិតលុងដី ដល់លុងៗទៅវាបាក់ដីសង្កត់”[1116]។ ទោះបីដើមបណ្ដឹងរដ្ឋប្បវេណី ពុំមានវត្តមាននៅការដ្ឋាន ព្រោះគាត់ឈឺ ក៏អ្នកធ្វើការជាមួយគាត់បានប្រាប់គាត់អំពីហេតុការណ៍នោះដែរ[1117]។

## ii. កង្វះការព្យាបាលដល់ពលករដែលឈឺ

594. ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានផ្ដល់សក្ខីកម្មថា “អ្នកមូលដ្ឋានហ្នឹងស្លាប់ ដូចគេថាចាញ់ទឹកចាញ់ដី ហើយពលកម្មហ្នឹងខ្លាំង។ ម្នាក់ៗនុំងធ្វើការ ដូចថា សឹងថាមានម្នាក់ឯង គ្នាប្រឹងនៅលើវ។ ការងារអីក៏ដោយ អ្នកណាប្រើអីគេធ្វើកើតទាំងអស់ ដាប់ថ្ម ពិសេសកន្លែងដាប់ថ្មហ្នឹង និយាយពីប្រឹងជាងគេជាងឯង ចុងក្រោយគឺស្លាប់”[1118]។ គាត់បានកែតម្រូវពីពលករនេះថា “គាត់នុំងមិនមែនបុរសចំណាស់ទេ គ្នានៅលីវទេ អាយុប្រហែលជា២០-២១ ប៉ុណ្ណឹង គ្នានៅលីវ អ្នកមូលដ្ឋានទេ អ្នកច្បាស់លាស់ ធ្វើការងារអត់គិតពីកម្លាំងខ្លួន។ ប្រឹងៗទាល់តែឈឺខក គ្មានបានទៅសម្រាកពេទ្យឯណាទេ ទៅផ្ទះវិញកន្លះខែ គេស្លាប់។ ឪពុកម្ដាយគ្នា មានកូនប្រុសតែពីរ ម្នាក់ហ្នឹងឈ្មោះ រី ជាកូនទី២ហ្នឹង បានស្លាប់ទៅ ទៅដល់ផ្ទះកន្លះខែ ស្លាប់”[1119]។

---

[1115] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ៦១ បន្ទាត់ ១៦-១៧។

[1116] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/305.1** ទំព័រ ៧០ បន្ទាត់ ២១-២៣។

[1117] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/305.1** ទំព័រ ៧១ បន្ទាត់ ៧-៩។

[1118] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ៧ បន្ទាត់ ៥-៨។

[1119] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ៤៤-៤៥ បន្ទាត់ ២៤-២។

595. ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានបញ្ជាក់ថា ពលករដែលបានស្លាប់នោះ រស់នៅក្នុង "ផ្ទះក្បែរគ្នារំលងប្រាំ ប្រាំមួយផ្ទះហ្នឹង ប៉ុន្មានទៅ!"[1120] ហើយ "គ្នាឈឺពីការដ្ឋានមកតើ! ឈឺបន្តិចម្ដងៗ ដែលគ្មានថ្នាំព្យាបាលហ្នឹង បានទៅជាទ្រុឌទ្រោមដល់ថ្នាក់ស្លាប់នេះ។ កាលពីនៅការដ្ឋានហ្នឹង គ្នាដាប់ថ្ម ដាប់អី ធ្វើការធ្ងន់ៗណាស់ លីថ្ម លីអី ហ្នឹង"[1121]។

## ៤. ការធ្វើទុក្ខបុកម្នេញដោយសារនយោបាយ

596. ភ័ស្តុតាងពីដើមបណ្ដឹងរដ្ឋប្បវេណីដែលបានផ្ដល់ក្នុងសវនាការបញ្ជាក់ថា ការបង្កើតលក្ខខណ្ឌរស់នៅ និងលក្ខខណ្ឌការងារដ៏លំបាកលើប្រជាជនថ្មីគឺជាទង្វើធ្វើទុក្ខបុកម្នេញប្រឆាំងនឹងក្រុមនេះ។

### ២.១. លក្ខខណ្ឌការងារ និងរស់នៅខុសៗគ្នា

597. ដើមបណ្ដឹងរដ្ឋប្បវេណី សៀង សុវីដា បានពន្យល់ថា "ធ្វើការដូចគ្នា ក៏ប៉ុន្តែប្រជាជនថ្មីគ្មានសិទ្ធិទេ ដូចអ្នកទោសអ៊ីចឹង ដូចជាសត្រូវ ហើយពួកប្រជាជនមូលដ្ឋានហ្នឹងគេលើកអ្នកដែលជនក្រីក្រ ឬក៏មានចែកជាពីរហ្នឹងមកកាន់អំណាច គឺធ្វើបាបពួកខ្ញុំ។ អ្នកថ្នាក់លើគាត់មិនស្គាល់មុខពួកខ្ញុំ តែពួកក្រោមនេះធ្វើបាបពួក១៧មេសា។ ចាំតែបន្តិចទៀត ពួក១៧មេសាស្លាប់ទាំងអស់ ហើយហាក់ដូចជាគ្នាសត្រូវអី ដូចទុកពួកខ្ញុំហ្នឹងជាសត្រូវស្លូតជាមួយនឹងពួកគាត់។ ធ្វើអីក៏ខុសៗ"[1122]។

598. ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានពន្យល់ថា ប្រជាជនមិនមានសិទ្ធិក្នុងការស្នើកន្លែងធ្វើការទេ ហើយថា ប្រជាជនថ្មី "គ្មានសិទ្ធិធ្វើប្រធានទេ"[1123]។ គាត់បានបន្តបកស្រាយទៀតថា "រឿងនេះគឺថាប្រជាជនចាស់ គេខុសអីបន្តិចបន្តួច គេអាចតវ៉ា គេតតាំងគ្នាទៅ គេអនុគ្រោះឲ្យគ្នាទៅ។ បើអ្នកថ្មីវិញ គឺមិនអាចមានប៉ប៉ុនសរសៃសក់ក៏មិនបានដែរ គឺការគាបសង្កត់ធ្ងន់ណាស់ ធ្ងន់ធ្ងរណាស់

[1120] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារិក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ៤៥ បន្ទាត់ ២១-២២។

[1121] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារិក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ៤៥ បន្ទាត់ ១៤-១៦។

[1122] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ាង សុវីដា ប្រតិចារិក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ៣៩ បន្ទាត់ ១-៥។

[1123] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារិក ថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០១៥ **E1/305.1** ទំព័រ ៣៣ បន្ទាត់ ១៦។

សឹងតែរយៈទ្រូង។ យើងមិនបានប្រព្រឹត្ត គេចោទយើងក៏ដោយ យើងនៅស្ងៀម យើងបៀមក្នុងខ្លួនហ្នឹង។ សុខចិត្តស្ងៀម ស្ងៀមដូចគេចុក ស្ងៀមៗយកមែនហ្នឹងណា ហើយចាញ់គេក៏ដោយឲ្យតែមានជីវិត"[1124]។

599. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានផ្តល់សក្ខីកម្មថា ទោះបីប្រជាជនថ្មី និងប្រជាជនមូលដ្ឋានធ្វើការដូចគ្នា និងមានការកំណត់កាងារដូចគ្នាក៏ដោយ ក៏ "គេអ្នកចាស់គ្រាន់ថាទៅឈរត្រង់នេះត្រង់នោះអីបានបន្តិចបន្តួច គេអនុគ្រោះគ្នាគេ។ រឿងការងារ ធ្វើដូចតែគ្នាហ្នឹង គ្រាន់តែគេមានសិទ្ធិលើយើងបន្តិច"[1125]។ គាត់ពន្យល់ថា "អ្នកចាស់គេប៉ានតមាត់ គេប៉ានប្រកែកប្រណាំងបានព្រោះគ្នាគេ។ យើងអ្នកថ្មីអត់ទេ គេចង្អុលឆ្វេង ឆ្វេង ចង្អុលស្តាំ ស្តាំ។ សុខចិត្តគ្រាំក្នុងខ្លួនទៅ គេថាម៉េចថាទៅ កុំឲ្យតែគេយកទៅសម្លាប់ហ្នឹង ប្រសើរហើយ"[1126]។

600. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានផ្តល់សក្ខីកម្មថា "ចំពោះអ្នកថ្មី គឺខ្លាចគេណាស់កូន មិនប៉ានទេ។ បើអ្នកចាស់ គេអាចមានសិទ្ធិ។ បើថាប្រជាជនថ្មី មិនប៉ានសោះៗតែម្តង។ ខ្លាចណាស់ខ្លាចៗជាទីបំផុត។ បើអ្នកប្រជាជនចាស់ហ្នឹងគេមានសិទ្ធិជាង អាចទៅសុំទៅ ចេញទៅខុសពីហ្នឹងប្រហែល១០-២០ម៉ែត្រអីបាន អ្នកចាស់។ បើថាអ្នកថ្មី រួញខ្លួនហើយកូន រួញដូចដុកឡឿអ៊ីចឹង មិនប៉ានទេ។ តែគេហាមត្រឹមណា គឺត្រឹមហ្នឹងហើយ មិនប៉ានទៅជិតទេ"[1127]។

601. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានផ្តល់សក្ខីកម្មថា "គឺមិនអាចមានជម្រើសទេ។ ពាក្យថា "ចាត់តាំង" មួយម៉ាត់ហ្នឹងគឺខ្លាំងក្លាហើយ។ គេអ្នកស្រុកចាស់ គេប៉ានតវ៉ា ចំណែកខ្ញុំអ្នកស្រុកថ្មីហ្នឹង អ្នកថ្មីហ្នឹងគឺគ្មាន គឺគ្មានតែម្តង។ តែតម្រូវឲ្យទៅ គឺទៅដោយមិនប្រកែកបាន ដែលយើងគ្មានសិទ្ធិនោះណា គ្មានសិទ្ធិអីទេ គ្មានសោះសូន្យតែម្តង។ ពិបាកចិត្តហ្នឹងបានត្រឹមតែយំហ្នឹង

1124 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ៩ បន្ទាត់ ១-៥។

1125 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ៥0 បន្ទាត់ ៨-៩។

1126 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ៥0 បន្ទាត់ ២-៤។

1127 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ៨ បន្ទាត់ ១៣-១៧។

បានត្រឹមតែគ្រាំគ្រាក្នុងខ្លួន។ តឹងទ្រូងប៉ុនណា ដែលតវ៉ាមិនបាន និយាយមិនកើត អស់លោកដឹង ហើយពិបាកប៉ុនណា ក្នុងទ្រូង ក្នុងខ្លួនហ្នឹងវាប៉ុនណាទៅ"[1128]។

## គ. ព្យសនកម្ម

### ១. ព្យសនកម្មផ្នែករាងកាយ

*ព្យសនកម្មផ្ទាល់៖ របួសផ្នែករាងកាយ*

602. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានរៀបរាប់ថា ពេលខ្លះគាត់សន្លប់នៅពេលគាត់ធ្វើការ ហើយ "ហៅគ្នាឯងហ្នឹងជួយដកសក់ទៅ លុញខ្លួនទៅ ធ្វើម៉េចឲ្យតែបានងើបធ្វើការកើតទៀត កុំឲ្យតែយើងឈប់"[1129]។

603. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន បានពន្យល់ថា ការងារនោះគឺ "សោខ្លាំង សោឡើងរមួលក្រពើជើង កំភួនជើង។ រោយចុកជើង រុញឡើង ចុះទៅវិញ ខ្នងទំនប់គ្រាន់ រុញឡើង ទៅមកៗ រួយជើង"[1130]។

604. ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ បានរៀបរាប់ពីការរបកស្បែកនៅស្មាដោយសារការរែកដីធ្ងន់ៗ[1131]។ គាត់បានពន្យល់ថា "វាពិបាក យើងមិនអាចថ្លែងបាន ដោយសារយើងមិនដែលបានធ្វើអីចឹងរែកដី។ ដល់ពេលយើងទៅសម្រុកការងារទាំងយប់ទាំងថ្ងៃអីចឹង ធ្វើឲ្យស្មាយើងឈឺជាំខ្មៅ ហើយរបកៗហើយពេលយើងរែកហ្នឹង គឺយើងដូរស្មាខាងឆ្វេងម្តងទៅ ព្រោះស្មាស្តាំវារបក វាជាំអីចឹងទៅ ប៉ុន្តែរឿងស្មាឆ្វេងហ្នឹងវាមិនសូវៗចេះ។ ដាក់បានតែម្តងៗ ដល់ស្មាស្តាំយើងត្រូវ ឈឺយ៉ាងណាក៏យើងទ្រាំ គឺមានការឈឺ ឈឺខ្លាំង។ ហើយនៅក្នុងការងារប្រចាំថ្ងៃហ្នឹង គឺយើងសម្រុកទាំង

---

[1128] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ២៤ បន្ទាត់ ៤-៨។

[1129] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ៤ បន្ទាត់ ៧-៨។

[1130] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ១៧ បន្ទាត់ ២៤-២៥។

[1131] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ១០ បន្ទាត់ ២២-២៣។

យប់ទាំងថ្ងៃ គឺមានការហាត់ៗនឿយអស់កម្លាំងតែយើងប្រឹងៗ ចិត្តយើងៗខំប្រឹងដើម្បីឱ្យបានរស់"[1132]។

605. ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ បានរៀបរាប់ "រាងកាយក៏ចាប់ផ្តើមចុះស្គម កម្លាំងចាប់ផ្តើមខ្សោយ"[1133]។

606. ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវីដា បានរៀបរាប់ពីការសន្លប់ក្រោយធ្វើការងារហាត់ "ខ្ញុំអស់កម្លាំង ហើយគេងអត់ឆ្អែត ហើយសុខភាពនាងខ្ញុំមិនសូវល្អដែរ ពេលនោះ នាងខ្ញុំក៏ដួលសន្លប់ទៅ។ ពេលនោះ គេសែងនាងខ្ញុំទៅរោងសម្រាក"[1134]។

*ព្យសនកម្មផ្ទាល់៖ ការឃ្លាន និងកង្វះអាហារ*

607. នៅពេលសួរថាតើមានការផ្តល់អាហារឬទេ នៅមុនពេលចាប់ផ្តើមធ្វើ ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានរៀបរាប់ថា "ពោះទទេៗ ឃ្លានណាស់ ប៉ុន្តែមិនដឹងធ្វើយ៉ាងម៉េច"[1135]។

608. ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ បានលើកឡើងថា "ធ្វើការគឺលំបាកខ្លាំង ហើយការហូបចុកក៏គ្មានស្អីហូបចុកត្រឹមត្រូវ គឺ ពិបាកមែនទែន"[1136]។ គាត់បានរៀបរាប់ពីការចូលព្រៃជាមួយនឹងអ្នកធ្វើការជាមួយគ្នាដើម្បីរកចាប់កង្កែប និងអង្រុងហូប[1137]។ "ពេលរាងថ្ងៃ រាងជិតត្រង់បន្តិចយើងហេរ យើងសុំគេទៅបត់ជើងក្នុងព្រៃអ៊ីចឹង យើងឆ្លៀតបេះស្លឹកថ្មីងៗ ដើម្បីដាក់មាត់អីបួនប្រាំសន្លឹក

---

[1132] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ២១ បន្ទាត់ ២២-២៥។

[1133] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ២២ បន្ទាត់ ១៥-១៦។

[1134] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ាង សុវីដា ប្រតិចារឹកថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ១៨ បន្ទាត់ ១២-១៣ *សូមមើលផងដែរ* ទំព័រ ១៩ បន្ទាត់ ៥-១៤។

[1135] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ២២ បន្ទាត់ ១៦។

[1136] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ១០ បន្ទាត់ ២-៣។

[1137] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ១១ បន្ទាត់ ១៦-១៨។

អីអ៊ីចឹងទៅ ចេញមកវិញ។ គឺយើងធ្វើរបៀបហ្នឹងប្រាំមួយប្រាំពីរខែ ដែលយើងរស់នៅ ហើយយើងឃ្លាតពីម្តាយ យើងរស់នៅដូចថា ដោយវេទនា”[1138]។ “នៅពេលយប់ យើងហាត់ហោរពេក..."[1139]។

609. ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឡាង បានផ្តល់សក្ខីកម្មថា “មួយទៀត ការហូបមិនគ្រប់គ្រាន់ធ្វើឱ្យនាងខ្ញុំស្គមស្គាំង ស្លេកស្លាំង”[1140]។ “ស្គមមែនទែន ហើយគ្មានកម្លាំងកំហែងទេ ប្រឹងហ្នឹងប្រឹងដោយសារថា កម្លាំងចិត្តដើម្បីឱ្យជៀសផុតនូវការដែលគេយកទៅសម្លាប់”[1141]។

610. ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ ក៏បានផ្តល់សក្ខីកម្មថា “សូម្បីតែទឹក ក៏នាងខ្ញុំមិនដែលបានទឹកល្អហូប”[1142]។ “ស្រេកទឹកមែនទែនរហូតដល់ពេលយប់ គេងយល់សប្តិបានហូបទឹកកកអីចឹងដូចថាយើងខ្វះទាំងអស់”[1143]។

### *ព្យសនកម្មផ្ទាល់៖ ជំងឺ*

611. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន បានផ្តល់សក្ខីកម្មថា ពេលគាត់ឈឺដំបូង “ឈឺហោរអស់កម្លាំងទៅអត់រួច។ ញ័រជង្គង់ ញ័រជើងពេក សម្រាក ដេកសំកុកធ្វើឈឺទៅ។ ឈឺទៅ សួរពីណាកើតអី? ឈឺពោះ គេឱ្យថ្នាំអាចម៍ទន្សាយលេបមក”[1144]។ ដើមបណ្តឹងរដ្ឋប្បវេណី “ឈឺពីរដង កាលភ្លៀង

[1138] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ១១ បន្ទាត់ ២២-២៥។

[1139] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ១២ បន្ទាត់ ៧-៨។

[1140] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចាវ ឡាង ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ៥៣ បន្ទាត់ ១២-១៣។

[1141] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចាវ ឡាង ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ៤៩-៥០ បន្ទាត់ ២៤-១។

[1142] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ១០ បន្ទាត់ ៧៦-៨។

[1143] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ១១ បន្ទាត់ ១០-១១។

[1144] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ៥០ បន្ទាត់ ៥-៧។

ខ្លាំង គ្រុនម្តង ត្រូវទឹកភ្លៀងខ្លាំងពេក”[1145]។ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ិន រ៉ន បានរៀបរាប់បន្តទៀតថា “ក្រោយឡើងមួយខែជាងទៀត បានខ្ញុំឈឺជាលើកទី២។ ឈឺលើកទី២ ខ្ញុំឈឺក្បាលជង្គង់ ខ្ញុំឈឺហើមកជើង ហើមសរសៃកែងជើងក្រោយ ដើរអត់រួច [...] ខ្ញុំរែកដីអត់កើតទេ។ ខ្ញុំអ្នកកាប់ឲ្យគេអ្នករែកចុះ។ ឈឺពីរដងហ្នឹងឯង”[1146]។

612. ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ បានរៀបរាប់ពីការធ្លាក់ខ្លួនឈឺនៅរដូវភ្លៀង។ “ខ្ញុំឈឺ ខ្ញុំក្តៅខ្លួន ខ្ញុំគ្រុន [...] ពេលនោះខ្ញុំឈឺខ្លាំង គេមិនឲ្យខ្ញុំនៅភូមិទេ គេឲ្យមកងចល័ត ដើម្បីឲ្យទៅសម្រាកនៅពេទ្យ។ គេយកវិហារធ្វើពេទ្យ។ ពេលខ្ញុំឈឺខ្លាំង ខ្ញុំស្គម ហើយខ្ញុំឈឺក្នុងពោះ ខ្ញុំដាក់ទឹកតែបន្តិច ក៏ខ្ញុំចុកឈឺពោះ ហើយក្អួត ក្តៅ ហើយក្អួត។ ខ្ញុំគេឲ្យសម្រាកពេទ្យនៅកន្លែងហ្នឹងប្រហែល២អាទិត្យ អត់បាត់។ អត់បាត់ គេបញ្ជូនទៅពេទ្យស្រុកនៅស្ពឺ”[1147]។

*ព្យសនកម្មផ្នែករាងកាយរយៈពេលវែង*

613. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានផ្តល់សក្ខីកម្មថា “ឈឺចុកចង្កេះ ចុកខ្នង ខ្ញុំចុកតាំងពីក្មេង តាំងពីជំនាន់រែកដីរហូតដល់សព្វថ្ងៃ ប្រឹងដើម្បីអី ប្រឹងដើម្បីរស់ ខំដើម្បីរស់”[1148]។

## ២. ព្យសនកម្មផ្លូវចិត្ត

*ព្យសនកម្មផ្ទាល់៖ ការព្រាត់ប្រាស់ពីគ្រួសារ អារម្មណ៍ឃ្លាតឆ្ងាយពីគ្រួសារ*

614. ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ បានលើកឡើងថា “នឹកម្តាយ សូម្បីតែដំណឹងមិនដែលបានឮដំណឹង ម្តាយនឹកកូន ម្តាយមិនដឹងកូនទៅដល់ណា។ យើងរស់នៅរោងគេហ្នឹងកណ្តាលវាលស្រែ គ្មានផ្ទះគ្មានអីមួយ មិនដឹងគេហៅកន្លែងអីទៀត”[1149]។

---

[1145] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ិន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ៩ បន្ទាត់ ៥។

[1146] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ិន រ៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/307.1** ទំព័រ ៥០-៥១ បន្ទាត់ ២០-១។

[1147] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ១២-១៣ បន្ទាត់ ២១-១។

[1148] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ៤ បន្ទាត់ ១២-១៣។

615. ដើមបណ្ដឹងរដ្ឋប្បវេណី ចៅ ឡាង ប្រាប់អង្គជំនុំជម្រះថា "នៅពេលដែលនាងខ្ញុំឈឺ គ្មានបងប្អូន គ្មានញាតិសន្ដាន ឈឺដោយម្នាក់ឯង ឯកោម្នាក់ឯង មិនសង្ឃឹមថារស់ ចាសមិនសង្ឃឹមថារស់ទេនៅពេលដឹងខ្លួនម្ដងៗ"[1150]។

### *ព្យសនកម្មផ្ទាល់៖ ទុក្ខសោកពីការបាត់បង់សមាជិកគ្រួសារ*

616. ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានរៀបរាប់ព្យសនកម្មផ្លូវចិត្តដោយសារតែឪពុករបស់គាត់បានស្លាប់ថា "ពេលនោះ ធ្វើម៉េចក៏យំមិនចេញ យំអត់ចេញសោះ។ ខ្ញុំស្រែកយំបាន នៅពេលដែលមានភ្លៀងធ្លាក់ធំទេ ដែលខ្ញុំស្រែកយំ គឺខ្ញុំយំឱ្យអស់ពីក្នុងខ្លួន។ ខ្ញុំយំមួយទំហឹងហើយ ព្រោះខ្ញុំគ្មានពេល គ្មានសិទ្ធិយំទេ ទាល់តែភ្លៀងធំ ផ្គរលាន់ក្ដុងៗបានខ្ញុំស្រែកហើយ ពេលណាក៏ខ្ញុំស្រែកយំដែរ ឱ្យតែភ្លៀង។ ខ្ញុំនឹកឃើញរឿងទាំងអស់។ នៅមុខគេខ្ញុំគ្មានសិទ្ធិទេ កុំឱ្យគេថា ខ្ញុំនឹងសតិអារម្មណ៍ គិតអី។ អ៊ីចឹង ខ្ញុំត្រូវតែទ្រាំក្នុងខ្លួន ទ្រាំហ្នឹងពិបាកណាស់ ទ្រាំហ្នឹងពិបាកមែនទែន សឹងរហែកដើមទ្រូងងាប់ភ្លាមៗហើយ។ ចុកអស់ហើយក្នុងខ្លួន នេះគឺការអត់ធ្មត់។ ដល់ពេលភ្លៀងខ្លាំងហ្នឹង យើងបានស្រែក បានយំ នឹកឃើញប៉ា នឹកឃើញម៉ាក់ នឹកឃើញប្អូន ដែលបែកបាក់គ្នា។ ហ្នឹងបានយើងមានសិទ្ធិយំៗ កុំឱ្យគេឮ"[1151]។

617. ក្នុងអំឡុងពេលដែលគាត់ធ្វើការដ្ឋានទំនប់ ១ មករា ដើមបណ្ដឹងរដ្ឋប្បវេណី ចៅ ឡាង បានទទួលការអនុញ្ញាតឱ្យលេងផ្ទះចំនួនមួយថ្ងៃ នៅភូមិអូរកន្សែង និងបានដឹងថា បងស្រី និងកូនរបស់គាត់ត្រូវបានយកទៅសម្លាប់ចោល។ "តើបងស្រីខ្ញុំ និងក្មួយខ្ញុំវេទនាយ៉ាងណានៅមុនពេលនឹងស្លាប់? នៅពេលនោះ ខ្ញុំស្ទើតែសន្លប់បាត់លែងដឹងអ្វីទាំងអស់ បាត់ស្មារតីអស់ហើយ ការតាំងខ្លួនរបស់ខ្ញុំទាំងប៉ុន្មាន គឺអស់រលីងៗទាំងអស់ ទន់ជង្គង់គ្រឹប។ បន្ទាប់មកទៀត មិត្តដែលប្រាប់ខ្ញុំហ្នឹង គាត់ថា "មិត្តឯងឆាប់ទៅវិញទៅ កុំនៅ ប្រយ័ត្នពាក់ព័ន្ធគេយកទៅទៀត"។ ដល់ចំណុចដែលគេប្រាប់ខ្ញុំ ខ្ញុំវិលវិញភ្លាមអត់បាននៅពេញមួយថ្ងៃ ដូចគេឱ្យ កំណត់ឱ្យខ្ញុំទៅលេងទេ។ ខ្ញុំខ្លាចពាក់ព័ន្ធដល់រូប

---

[1149] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី នួន ណារុំ ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ១២ បន្ទាត់ ១១-១២។

[1150] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ចាវ ឡាង ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ៥៣ បន្ទាត់ ១១-១២។

[1151] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ២៤-២៥ បន្ទាត់ ២១-៣។

នាងខ្ញុំទៀត។ ឃើញនាងខ្ញុំយំអ៊ីចឹង ខ្លាចគេមកចោទប្រកាន់ថា យ៉ាងម៉េចយ៉ាងម៉ានោះទៀត កុំឱ្យគេដឹង ខ្ញុំវឹងមកវិញចាស វឹងមកវិញ"[1152]។

*ព្យសនកម្មពីការមិនអាចទៅចូលរួមបុណ្យសព*

618. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានផ្តល់សក្ខីកម្មថា "ម៉ាក់ខ្ញុំផ្តាំមកថាប្អូនស្លាប់បាត់ហើយកប់នៅកន្លែងនុំងបាត់ហើយ។ ធ្វើម៉េចបើអ៊ីចឹងទៅហើយ ចង់ធ្វើបុណ្យក៏មិនបាន ចង់ឧទ្ទិសអីក៏មិនបាន ចង់ទៅមើលប្អូនជាលើកចុងក្រោយក៏មិនបាន។ បែកបាក់ម្តងមួយៗ អស់រលីង"[1153]។

*ព្យសនកម្មផ្ទាល់៖ ការភ័យខ្លាចសេចក្តីស្លាប់ ឬការដាក់ទណ្ឌកម្ម*

619. ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ បានរៀបរាប់ពីការភ័យខ្លាចដាក់ទណ្ឌកម្ម បើគាត់ឈឺ។ "ខ្ញុំអត់ដែលបានគេរ៉ៃទេ ព្រោះខ្ញុំខ្លាច ទោះបីខ្ញុំឈឺតិចតួច ខ្ញុំមិនហ៊ានសុំច្បាប់គេទេ ខ្ញុំសុខចិត្តទៅ។ ខ្ញុំមិនហ៊ានទេ តែប្រាំប្រាំមួយខែហ្នឹង ខ្ញុំឈឺក្តៅខ្លួនជាក់ស្តែងហ្នឹង ឈប់បានប្រហែលជាពីរបីដងអីដែរ។ តែអាការថាអស់កម្លាំងហ្នឹងអ៊ីចឹង គេស្ទាបទៅដឹងថាក្តៅខ្លួនមែន គេឱ្យយើងឈប់មួយថ្ងៃអ៊ីចឹងទៅ។ តែខ្ញុំខ្លាចគេ ខ្ញុំត្រូវធ្វើការឱ្យគ្រប់ មិនដែលមានគេរ៉ៃខ្ញុំទេ។ ដែលតែគេកសាងដូចថាឱ្យយើងប្រឹងអីតទៅទៀតអ៊ីចឹង"[1154]។

*ព្យសនកម្មរយៈពេលវែង៖ ការចង់បានចម្លើយពីអតីតកាល*

620. ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវីដា បានលើកឡើងថា "ខ្ញុំមិនដឹងនិយាយប្រាប់ថាខ្ញុំឈឺប៉ុនណាទេ។ ខ្ញុំ ទឹកភ្នែកស្ទើរសឹងតែរាល់ថ្ងៃ ខ្ញុំនិយាយប្រាប់គេ បើអ្នកណាគេជឿក៏ជឿ។ កូនប្រុសខ្ញុំទេ អ្នកលបមើលឃើញ ឃើញតែខ្ញុំយំបិទទ្វារ។ តែអស់មានអ្នកណាដឹងថាខ្ញុំពិបាកទេ ទាល់តែលបមើលឃើញ បើមិនលបមើលទេ គេអត់ដឹងទេ។ ខ្ញុំសុំឱ្យជួយបកស្រាយនឹងរឿងពិតហ្នឹងឱ្យពួកខ្ញុំ

---

[1152] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចាវ ឡាង ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ៥០ បន្ទាត់ ១២-១៨។

[1153] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ១៥ បន្ទាត់ ៦-៨។

[1154] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ៣០ បន្ទាត់ ១៣-១៨។

ស្លាប់ផង ខ្ញុំអត់ចង់បកស្រាយ និងការដោះសារខ្លួនដើម្បីឲ្យរួចខ្លួនណា។ ជីវិតម្នាក់ៗកើតមកគង់តែដក់ថ្ងៃស្លាប់ទេ មុននឹងស្លាប់ យើងចេះ យើងស្រឡាញ់ប្រជាជន ឲ្យកូនខ្មែរយើងបានដឹងប្រវត្តិសាស្ត្រពិតៗផង។ ខ្ញុំសុំតែប៉ុណ្ណឹងទេ”[1155]។

***ព្យសនកម្មរយៈពេលវែង៖ ផលប៉ះពាល់លើជីវិតបច្ចុប្បន្ន និងជីវិតគ្រួសារ***

621. ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវីដា បានផ្តល់សក្ខីកម្មថា “ខ្ញុំអត់ចង់និយាយអីច្រើនទេ ចង់ថា ទុក្ខសោកដូចគ្នាទាំងអស់ គឺខ្លាំងណាស់ មកលើគ្រួសារខ្ញុំៗដូចបានរៀបរាប់អីចឹង គឺខ្លាំង។ ហើយខ្ញុំៗចង់និយាយ -- នៅពេលត្រឡប់ – ខ្ញុំសូមនិយាយកាត់មកដល់នេះហ្មង ពេលត្រឡប់ពីភ្នំពេញវិញមក ទុក្ខសោកទាំងឡាយមកលើរូបខ្ញុំគឺធំធេងណាស់។ ធំធេងរកអ្វីមិនបាន ហើយកូនតែងតែសួរថា ហេតុអីក៏ម្តាយមិនដែលឃើញសប្បាយចិត្តសោះ? ខ្ញុំប្រាប់គាត់ -- កូនថាម្តាយមិនដឹងសប្បាយយ៉ាងម៉េចទេ បើម្តាយបាត់បង់អ្នកជាទីស្រឡាញ់ អ្នកមានគុណអស់ហើយ ម្តាយ -- ខ្ញុំនិយាយ -- ខ្ញុំចង់ -- អត់ចង់បន្តទៀតទេ ខ្ញុំចេះរំឭកឡើង ខ្ញុំចង់តែវិល ចង់តែដួល។ ខ្ញុំៗគិតថា ប្រវត្តិវាជូរចត់ណាស់ គ្រាន់តែថារឿងកំសត់ រឿងអត់ហូប រឿងគេធ្វើបាប ទារុណកម្មមកលើរៃដំក៏អត់ដែលធ្វើបាបក្នុងតាមផ្លូវចិត្ត និងផ្លូវកាយបង្អត់អាហារ ជាពិសេសឃើចាប់នឹងបង នឹងម្តាយហ្នឹង។ អីចឹងខ្ញុំសូមនេះប៉ុណ្ណឹងចុះ ខ្ញុំដូចជាបន្តទៅទៀត ខ្ញុំអត់សូវស្រួលក្នុងខ្លួនម៉េចទេ”[1156]។

622. នៅពេលរៀបរាប់អំពីវិសាលភាពទូលំទូលាយនៃព្យសនកម្ម ក្នុងនោះរួមទាំងភាពឯកោ ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិត្ថានី បានលើកឡើងថា “ផលវិបាកទាំងអស់ដែលធ្លាក់មកលើរូបខ្ញុំ គឺយើងធ្លាប់រស់នៅជួបជុំគ្រួសារ មានក្តីសុខ ដល់ពេលរបបនោះចូលមក គឺយើងបាត់បង់អស់រលីង គឺបាត់បង់គ្រប់យ៉ាង បាត់បង់ផ្ទះសម្បែង ទ្រព្យសម្បត្តិ ឪពុកម្តាយ បងប្អូន គឺខ្ញុំរស់នៅតែម្នាក់ឯង។ ខ្ញុំបាត់បង់គ្មានសល់ ទុក្ខលំបាកដែលខ្ញុំមិនធ្លាប់ស្គាល់ គឺខ្ញុំស្គាល់អស់ហើយ។ ភាពឯកោហ្នឹងយ៉ាងណា

---

[1155] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ាង សុវីដា ប្រតិចារឹក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ៦៦ បន្ទាត់ ២-៧។

[1156] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ាង សុវីដា ប្រតិចារឹក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ៦៩ បន្ទាត់ ៦-១៥។

អ្នកណាដែលឯកោដូចខ្ញុំ អ្នកនោះនឹងដឹង អ្នកដែលគេមិនឯកោ គឺគេមិនដឹងទេ។ [...] ខ្ញុំខ្លាចណាស់ ខ្ញុំខ្លាចមែនទែន ខ្លាចបាក់ស្បាតអស់ហើយ អ្វីដែលជាទុក្ខសោក រស់នៅគ្មានសិទ្ធិសេរីភាព"[1157]។

*ព្យសនកម្មរយៈពេលវែង៖ ភាពឯកោ និងសោកសៅ*

623. ដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតក៏បានបង្ហាញពីអារម្មណ៍ឯកោ។ ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ បានលើកឡើងថា "ការរស់របស់ខ្ញុំៗដាច់ហើយហ្នឹង ក៏ជីវិតខ្ញុំតែលតោល ខ្ញុំគ្មានគោលដៅ គឺមានការលំបាកខ្លាំង។ យើងគ្មានចេះ ដើរទៅនេះបន្តិច ទៅនោះបន្តិច គ្មានបងប្អូនបង្កើត ហើយមាននៅតែម្នាក់ឯង។ [...] ដូចថាវា ជីវិតវាជូរចត់ពេក រកអីមកប្រៀបធៀបមិនបាន"[1158]។

## ៣. ព្យសនកម្មផ្នែកសម្ភារៈ

624. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សិក្ខានី បានពន្យល់ថាក្រៅពីបាត់បង់ឪពុកម្តាយ និងបងប្អូន គាត់ "គឺបាត់បង់គ្រប់យ៉ាង បាត់បង់ផ្ទះសម្បែង ទ្រព្យសម្បត្តិ។ [...] ធ្លាប់ពីមានរបស់របរប្រើប្រាស់សព្វបែបយ៉ាងមកបាតដៃទទេ វេទនាប៉ុនណា"[1159]។

## ជំពូក ៥. ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង[1160]

[1157] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ៦០-៦១ បន្ទាត់ ១៦-២។

[1158] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នួន ណារុំ ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ១៧ បន្ទាត់ ១១-១៥។

[1159] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុន សេដ្ឋានី ប្រតិចារឹក ថ្ងៃទី ២៧ ខែ ឧសភា ឆ្នាំ ២០១៥ ឯកសារ **E1/306.1** ទំព័រ ៦០ បន្ទាត់ ១៧-២៥។

[1160] អង្គជំនុំជម្រះសាលាដំបូងបានទទួលអង្គហេតុទាក់ទងការបង្កើត និងការបំពេញមុខងារនៃការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង ពីខែ ឧសភា ឆ្នាំ ១៩៧៦ ដល់ខែ មករា ឆ្នាំ ១៩៧៩។ ការដ្ឋានសំណង់នេះត្រូវបានចោទប្រកាន់ថាស្ថិតក្រោមការបង្គាប់របស់កងពល ៥០២ ដែលមាន ស៊ូ ម៉េត ជាប្រធាន និង ល្វៃ ដែលជាអនុប្រធានរបស់គាត់។ ជាពិសេស អង្គជំនុំជម្រះសាលាដំបូងបានដឹងអំពីស្ថានភាពរស់នៅ និងស្ថានភាពការងាររបស់កម្មករ និងមានការចោទថាទីតាំងនេះ "បានបំពេញមុខងារជាមធ្យោបាយមួយក្នុងចំណោមមធ្យោបាយនានានៃការអនុវត្តការបោសសម្អាតសមាជិកRAKដោយហេតុថាវាត្រូវបានប្រើប្រាស់ជាកន្លែងលត់ដំ សម្រាប់សមាជិកRAKដែលត្រូវបានចាត់ទុកជា "សមាសភាពមិនល្អ" ពីកងពល ៥០២ ឬពីកងពល ឬអង្គភាពយោធាដទៃ"។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៣៨៩-៣៩២។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៣៨៧។ ផ្អែកលើការចោទប្រកាន់តាមអង្គហេតុ ជនជាប់ចោទត្រូវបានចោទពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិដូចខាងក្រោម ដែល

## ក. និជ្ជភាពរួមនៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី

625. ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីនាក់ គង់ សៀក, ជុំ សាមឿន និង ផៃ ប៉ាប បានផ្តល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះអំពីបទពិសោធន៍របស់ពួកគេនៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង[1161]។

626. ដើមបណ្តឹងរដ្ឋប្បវេណី គង់ សៀក បានចូលរួមក្នុងជួរកងទ័ព នៅឆ្នាំ ១៩៧៥ និងជាផ្នែកមួយនៃកងពល ៤៥០[1162]។ គាត់គឺជាថ្នាក់ក្រោមនៃកងពល ៤៥០ ហើយកងវរសេនាតូចរបស់គាត់ គឺកងវរសេនាតូច ៥៣[1163]។ កងវរសេនាតូច ៥៣ របស់គាត់នេះ ត្រូវបានគ្រប់គ្រងដោយ ផា និង គត់[1164]។ ពីដំបូង គាត់បានធ្វើការងារនៅមន្ទីរពេទ្យឬស្សីកែវ ដែលក្នុងមន្ទីរពេទ្យនេះ គាត់ជាបុគ្គលិកដាំបាយម្តង និងទៅចាក់ថ្នាំឲ្យយុទ្ធជនម្តងក្នុងមន្ទីរពេទ្យ[1165]។ បន្ទាប់មក ដើមបណ្តឹងរដ្ឋប្បវេណី គង់

ជឿថាបានកើតឡើងនៅព្រលានយន្តហោះកំពង់ឆ្នាំងពីដើមឆ្នាំ ១៩៧៦ ដល់ខែមករា ឆ្នាំ ១៩៧៩៖ ការដាក់ជាទាសករ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ អំពើអមនុស្សធម៌ដទៃទៀតក្នុងទម្រង់នៃអំពើរំលោភសេចក្តីថ្លៃថ្នូរមនុស្សជាតិ (ក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ) អំពើអមនុស្សធម៌ដទៃទៀតក្នុងទម្រង់ជាការវាយប្រហារសេចក្តីថ្លៃថ្នូរមនុស្សជាតិ អាពាហ៍ពិពាហ៍ដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៣៧៣ ១៣៨១ ១៣៩១ ១៤១៦ ១៤៣៤ ១៤៤២។ ឧបសម្ព័ន្ធ៖បញ្ជីកថាខណ្ឌនិងផ្នែកនានានៃដីកាដំណោះស្រាយពាក់ព័ន្ធសំណុំរឿង ០០២/០២ ឯកសារ **E301/9/1.1**។

[1161] ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៩រូបត្រូវបានទទួលស្គាល់ដោយ ក.ស.ច.ស ទាក់ទងការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង (ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៣៩៩)។ ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបត្រូវបានទទួលស្គាល់ដោយអង្គបុរេជំនុំជម្រះ។

[1162] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ២៤-២៥ បន្ទាត់ ២០-៤។

[1163] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ៥៥ បន្ទាត់ ១២-១៣។

[1164] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ៥៥ បន្ទាត់ ១៦។

[1165] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ២៦ បន្ទាត់ ៨។

សៀក ត្រូវបានបញ្ជូនឱ្យទៅធ្វើស្រែ នៅបឹងប្រយ៉ាប នៅជិតទួលគោក ហើយបន្ទាប់មក ទៅអូរបែកក្អម ដែលនៅទីនោះ គាត់បានចូលរួមជាមួយនឹងកង ៧៥[1166]។

627. ដើមបណ្តឹងរដ្ឋប្បវេណី គង់ សៀក បានពន្យល់ថា ឈ្មោះ វិន គឺជាមេបញ្ជាការរបស់គាត់ នៅអូរបែកក្អម ហើយថា វិន និងមនុស្សម្នាក់ទៀត ដែលនាំកងរបស់គាត់ទៅការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង ដែលប្រើប្រាស់រថយន្តចំនួនពីរដឹកពលករស្ត្រីពីកងវរសេនាតូច ៥៣ នៅឆ្នាំ ១៩៧៧[1167] ដែលគាត់បានស្នាក់នៅការដ្ឋាននេះចំនួន ៦ ខែ[1168]។ ការងាររបស់ពួកគេគឺជីកប្រឡាយនៅក្នុងការដ្ឋាន[1169]។ ក្រោយមក ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបញ្ជូនទៅអូរបែកក្អម។ គាត់បានស្នាក់នៅអូរបែកក្អមប្រមានជាពីរខែ មុននឹងត្រូវបានបញ្ជូនទៅកំពង់ត្រឡាចលើ ក្នុងខេត្តកំពង់ឆ្នាំង[1170]។

628. ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន "បានរស់នៅក្នុងកងពល ១១" នៅក្នុងឆ្នាំ ១៩៧៣ នៅពេលគាត់ទើបតែមានអាយុ ១៣ ឆ្នាំ[1171]។ មេបញ្ជាការកងពល ៥០២ មានឈ្មោះថា ម៉េត[1172]។ ដើម

[1166] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ២៦ បន្ទាត់ ២៤-២៥។

[1167] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ៦៤-៦៥ បន្ទាត់ ២៤-៣ ទំព័រ ២៦ បន្ទាត់ ១១ និង ទំព័រ ១៤-១៥, ទំព័រ ២៧ បន្ទាត់ ៤-៥, ទំព័រ ៤៤ បន្ទាត់ ៦-៧, ទំព័រ ៥១ បន្ទាត់ ២១-២២។

[1168] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ៤៤ បន្ទាត់ ៦-៧, ទំព័រ ៥១ បន្ទាត់ ២១-២២។

[1169] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ២៦ បន្ទាត់ ១៤-១៥។

[1170] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ៥១ បន្ទាត់ ២១-២៤។

[1171] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៣៨ បន្ទាត់ ៣-៤។ ដើមបណ្តឹងរដ្ឋប្បវេណីកើតនៅថ្ងៃទី ៤ ខែ មីនា ឆ្នាំ ១៩៦០។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៣៦ បន្ទាត់ ១៥។

[1172] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៤០ បន្ទាត់ ១៤-១៧។

បណ្តឹងរដ្ឋប្បវេណីនេះបានផ្តល់សក្ខីកម្មថា កងទ័ពក្នុងកងពល ១១ មានមូលដ្ឋានក្នុងស្រុកកោះធំ ខេត្តកណ្តាល ហើយថា គាត់ និងមនុស្សប្រាំបួននាក់ផ្សេងទៀត ក្នុងក្រុមរបស់គាត់ ត្រូវបានណែនាំឱ្យជញ្ជូនអង្ករទៅដាក់ជិតសមរភូមិ[1173]។ បន្ទាប់ពីរំដោះភ្នំពេញ ដើមបណ្តឹងរដ្ឋប្បវេណីនេះ និងកងពលរបស់គាត់ ត្រូវបានបញ្ជូនទៅធ្វើស្រែ នៅវត្តក្តុល បន្ទាប់មក គាត់ត្រូវបានផ្លាស់ទៅធ្វើស្រែនៅរោងចក្រ ហើយគាត់ត្រូវបានចាត់តាំងឱ្យធ្វើជី[1174]។ បន្ទាប់មកទៀត ដើមបណ្តឹងរដ្ឋប្បវេណីនេះត្រូវបានផ្លាស់ទៅអូរបែកក្អមដើម្បីធ្វើស្រែ ហើយនៅពេលនោះ កងពល ៥០២ និងកងពល ១១ ត្រូវបានដាក់បញ្ចូលគ្នា[1175]។ ដើមបណ្តឹងរដ្ឋប្បវេណីនេះបានផ្តល់សក្ខីកម្មថា អ្នកគ្រប់គ្រង ឬមេបញ្ជាការរបស់គាត់ដែលមានឈ្មោះដែរ បានទៅសហករណ៍ដើម្បីមើលប្រវត្តិរូបរបស់ ហើយបានប្រាប់គាត់ថា គាត់មានទំនាក់ទំនងជាមួយនឹងរបបមុន ពីព្រោះឪពុករបស់គាត់ជាធ្វើប៉ូលីស ឪពុកចុងធ្វើជាទាហាន[1176]។ ដើមបណ្តឹងរដ្ឋប្បវេណីនេះត្រូវបានកំណត់អត្តសញ្ញាណថាជាអ្នកមានទំនាក់ទំនងជាមួយនឹងរបបមុន[1177] និងបានផ្តល់សក្ខីកម្មថា ជាលទ្ធផល គាត់ត្រូវបានរងទណ្ឌកម្មដោយការបញ្ជូនទៅរែកដីចំនួន ១០ ថ្ងៃ[1178]។ បន្ទាប់មក គាត់ និងអង្គភាពទាំងមូលរបស់គាត់ ត្រូវបានបញ្ជូនទៅកំពង់ឆ្នាំង[1179]។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះពុំបានផ្តល់មូលហេតុ

---

[1173] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៣៨-២៩ បន្ទាត់ ១-១១។

[1174] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៣៩-៤០ បន្ទាត់ ១២-២។

[1175] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៤០ បន្ទាត់ ៣-១០។

[1176] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៤០ បន្ទាត់ ១៨-២៤។

[1177] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៤០-៤១ បន្ទាត់ ២៥-៧។

[1178] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៤០-៤១ បន្ទាត់ ២៥-៧។

[1179] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៤១ បន្ទាត់ ២១-២៤។

ថាហេតុអ្វីបានជាពួកគេត្រូវបញ្ជូនឲ្យទៅធ្វើការងារនៅទីនោះ នៅការដ្ឋានសាងសង់នេះ[1180] និងបានរំលឹកថា ឈ្មោះស្រុន ដែលជាប្រធានកង បានប្រាប់គាត់ថា កន្លែងដែលពួកគេត្រូវបញ្ជូនទៅនោះ គឺព្រលានយន្តហោះកំពង់ឆ្នាំង[1181]។ ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ សាមឿន បានធ្វើការងារនៅព្រលានយន្តហោះកំពង់ឆ្នាំងនេះអស់រយៈពេលពីបីទៅប្រាំខែ[1182]។

629. ដើមបណ្ដឹងរដ្ឋប្បវេណី ឆែ ប៉ាប ដែលបានផ្ដល់សក្ខីកម្មអំពីការចាប់ខ្លួន ការឃុំខ្លួន និងការសម្លាប់បងប្រុសរបស់គាត់មន្ទីរ ស២១ ក៏ត្រូវបានបញ្ជូនទៅកាន់ព្រលានយន្តហោះកំពង់ឆ្នាំងដែរ។ នៅក្នុងឆ្នាំ ១៩៧៥ ដើមបណ្ដឹងរដ្ឋប្បវេណីនេះមានអាយុប្រហែល ១៤ ឆ្នាំ ហើយជាសមាជិកម្នាក់នៃកងកុមារ ដែលស្ថិតនៅក្នុងកងពល ៣១០[1183]។ បន្ទាប់ពីការចាប់ខ្លួនបងប្រុសរបស់គាត់ ឈ្មោះ ឆែ ហេង ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះត្រូវបានបញ្ជូនទៅធ្វើស្រែនៅបឹងកាយ៉ាប ហើយត្រូវបានគេស្នើឲ្យធ្វើប្រវត្តិរូប រួមជាមួយនឹងបងប្រុសម្នាក់ទៀតឈ្មោះ ឆែ ធក[1184]។ ឆែ ធក ត្រូវបានចាប់ខ្លួន និងយកទៅសម្លាប់ បន្ទាប់ពីបានធ្វើប្រវត្តិរូបរួច។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបន្ទាប់មកត្រូវបានបញ្ជូនទៅកន្លែងមួយនៅជិតកងពល ដែលនៅកន្លែងនោះ គាត់បានជួយលាងរបួស និងដេររបួសរបស់ពលករមកពីសមរភូមិកំពង់ឆ្នាំង[1185]។ បន្ទាប់ពី ត្រូវបានចាប់ខ្លួន សោ ភឹម ប្រជាជនចំនួន ៦០ នាក់ ត្រូវបានប្រមូលពីកងកម្លាំងរបស់គាត់ ហើយដាក់បញ្ចូលក្នុងរថយន្តចំនួនពីរគ្រឿង រួច

---

1180 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៦១-៦២ បន្ទាត់ ២៥-២។

1181 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៤២ បន្ទាត់ ២១-២៣។

1182 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៤២ បន្ទាត់ ៩-១២។

1183 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ចេ ប៉ាប ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៦ បន្ទាត់ ១០-១១ (ដើមបណ្ដឹងរដ្ឋប្បវេណីកើតនៅថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ១៩៦១) ទំព័រ ១១ បន្ទាត់ ២-២០។

1184 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ចេ ប៉ាប ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ២១ បន្ទាត់ ២១-ទំព័រ ២៣ បន្ទាត់ ៨។

1185 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ចេ ប៉ាប ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ២៤ បន្ទាត់ ២-១៥។

ដឹកទៅកងពល ៥០២ ក្នុងខេត្តកំពង់ឆ្នាំង ដែលនៅទីនោះ គាត់បានធ្វើការនៅព្រលានយន្តហោះ។ គាត់ត្រូវបានចាត់តាំងឱ្យធ្វើជាប្រធានកង[1186]។

## ខ. ភ័ស្តុតាងដែលជាមូលដ្ឋានឧក្រិដ្ឋកម្មដែលបានផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណី នៅពេលសវនាការ

### ១. ការធ្វើឱ្យនៅជាទាសករ

630. ភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់ក្នុងពេលសវនការបង្ហាញថា ពលករនៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំងក្លាយជាជនរងគ្រោះនៃការអនុវត្តអំណាចណាមួយ ឬអំណាចទាំងអស់ដែលជាសិទ្ធិផ្ទាល់ខ្លួនរបស់គេក្នុងនាមជាបុគ្គលម្នាក់។

#### ១.១. ការអនុវត្តសិទ្ធិផ្តាច់មុខ

631. ដើមបណ្តឹងរដ្ឋប្បវេណី គង់ សៀក បានពន្យល់ថា "ខ្ញុំមិនហ៊ានជ្រើសរើសយកខ្លួនឯងទេ។ គឺការងារនេះសុទ្ធតែគេបញ្ជា យើងទាំងអស់"[1187]។ ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន បញ្ជាក់ថា "អត់មានអ្នកណាមួយហ៊ានប្រកែក"[1188] មិនទៅការដ្ឋានទេ ហើយថា "អត់មានផ្តល់ផលប្រយោជន៍អីទេ[1189]។ ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន បានលើកឡើងថា "គេថាខ្ញុំជាអ្នកទោស" នៅពេលគេបញ្ជូនគាត់ទៅការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំង"[1190]។

#### ១.២. ការគ្រប់គ្រង

[1186] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចេ ប៉ាប ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៣៣ បន្ទាត់ ៥-ទំព័រ ៣៤ បន្ទាត់ ២២។

[1187] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ៤៤ បន្ទាត់ ១១-១២។

[1188] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៥០ បន្ទាត់ ១១។

[1189] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៥០ បន្ទាត់ ៣-៧។

[1190] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៦៦ បន្ទាត់ ១៨-២១។

### i. ការគ្រប់គ្រងផ្លូវចិត្ត

632. ដើមបណ្តឹងរដ្ឋប្បវេណី គង់ សៀក បានពន្យល់ថា "យើងជាយុទ្ធជនធម្មតាឯង តែប្រធានកង ប្រធានក្រុមគេប្រជុំហើយ ទិតៀនយើងហើយ គេថាយើងម៉េច ក៏យើងអត់ហ៊ានតថ្លៃជាមួយគេទេ ទោះបីយើងឈឺយ៉ាងណាបន្តិចបន្តួច ក៏យើងប្រឹងប្រែងទៅទៀតហើយ យើងអត់ហ៊ានឈរជាមួយគេទេ ដូចថាអត់ហ៊ានតជាមួយគេ"[1191]។

633. ដើមបណ្តឹងរដ្ឋប្បវេណី គង់ សៀក បានផ្តល់សក្ខីកម្មថា "នៅក្នុងជីកប្រឡាយហ្នឹង មិនស្រួលប៉ុន្មានទេ។ ការជីក ការធ្វើហ្នឹង គេបង្ខំយើងឲ្យជីកហើយ យើងចេះតែប្រឹងទៅទាំងប៉ុន្មានចេះតែនាំគ្នាខំប្រឹងទៅ ទោះបីតែមិត្តយើង ឬក៏ខ្លួនខ្ញុំក្តីបែកដៃ ពងដៃយ៉ាងណា ក៏ខ្ញុំមិនហ៊ានឈប់ដែរ នៅតែខំប្រឹងធ្វើ។ ជីកមិនហ៊ានឈប់ទេ ប្រឹងប្រែងទោះបីពងដៃ ក៏នៅតែខំប្រឹង ប្រឹងធ្វើប្រឹងលើក"[1192]។

634. គាត់បានបន្តពន្យល់ថា "ប៉ុន្តែខ្ញុំមកនៅអូរបែកក្អមខ្ញុំធ្វើការទៅ ខ្ញុំឮប្រធានវរៈខ្ញុំប្រជុំប្រាប់ខ្ញុំ ប្រាប់ខ្ញុំថា "មិត្តឯងរាល់គ្នានេះឯង សុទ្ធតែជាប់និន្នាការហើយ ពីព្រោះកងពលមិត្តឯងគេចាប់យកទៅដាក់គុកទួលស្លែង ដាក់គុកព្រៃសអស់ហើយ។ ឥឡូវមិត្តឯងនេះ ត្រូវជាប់ឥទ្ធិពលគេហ្នឹងឯង គេក្បត់អស់ហើយ។ ដើមឈើគឺគេ អាធំវាដួលមកហើយ គឺវាសង្កត់អាក្រោមហើយ។ ដូច្នេះមិត្តឯងខំប្រឹងប្រែងធ្វើការទៅ បើមិត្តឯងមិនប្រឹងប្រែងធ្វើការទេ ទោះបីមិត្តឯងអង្គុយបង្ហូរទឹកភ្នែកនឹកម៉ែនឹកឪ នឹកភូមិនឹកស្រុកប៉ុនណា ក៏មិត្តឯងមិនបានជួបម៉ែឪមិត្តឯងដែរ""[1193]។

---

[1191] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ៣៦ បន្ទាត់ ៦-៩។

[1192] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ២៩ បន្ទាត់ ១៨-២១។

[1193] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ២៧ បន្ទាត់ ១២-១៨។

635. ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន បានលើកឡើងថា "គេមិនអនុញ្ញាតឲ្យបដិសេធទេ"[1194] ហើយគេ "ប្រាប់ឲ្យធ្វើការងារឲ្យបានល្អ ដើម្បីឲ្យឆាប់ហើយ"[1195]។ គាត់បញ្ជាក់ផងដែរថា "គេប្រាប់ត្រូវតែគោរពវិន័យបញ្ជាការ។ គេប្រាប់ធ្វើអី យើងត្រូវធ្វើហ្នឹង"[1196]។

636. ដើមបណ្តឹងរដ្ឋប្បវេណី ឆែ ប៉ាប បានផ្តល់សក្ខីកម្មថា "ទៅដល់ គេឲ្យខ្ញុំធ្វើមេក្រុម ជញ្ជូនឥដ្ឋហើយនិងបៀកផ្ទះថ្មគេរៀបទៅ។ ក្រោយមកគេប្រជុំថា ឲ្យរាយការណ៍ អ្នកដែលត្អូញត្អែរ ទម្រន់ស្ពឹកស្រពន់។ មានក្រុមខ្លះគេថាមាន ក្រុមហ្នឹងគឺបាត់។ ខ្ញុំយល់ថាអ្នកណាខំប្រឹងធ្វើការ អង្គការគេទុក។ អាណាគេខ្ជិលច្រអូស គេមិនទុកទេ"[1197]។

## *តួនាទីនៃកិច្ចប្រជុំអប់រំ កែប្រែ*

637. ដើមបណ្តឹងរដ្ឋប្បវេណី គង់ សៀក បានផ្តល់សក្ខីកម្មថា "ក្រុមរបស់ខ្ញុំមានតែប្រជុំទិតៀនគ្នាពីរឿងការងារហ្នឹង គេថាឲ្យយើងខំប្រឹងធ្វើការទៅ។ ទោះបីយ៉ាងណាក៏យើងមិនអាចមិនទៅធ្វើការបានដែរ ដាច់ខាតទៅធ្វើការ ប្រជុំបំពាក់បំប៉នស្មារតីប៉ុណ្ណឹងឯង"[1198]។ គាត់បានពន្យល់ថា "ប្រធានកងប្រធាក្រុម គេប្រជុំហើយ ទិតៀនយើងហើយ គេថាយើងម៉េច ក៏យើងអត់ប៉ានតថ្លៃជាមួយគេទេ។ យើងប្រឹងប្រែងទៅទៀត"[1199] ទោះឈឺក៏ដោយ[1200]។ ពាក់ព័ន្ធនឹងមេបញ្ជាការរបស់គាត់ ដើម

---

[1194] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៦៥ បន្ទាត់ ១៨។

[1195] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៦៥ បន្ទាត់ ២១។

[1196] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៦៦ បន្ទាត់ ៣។

[1197] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចេ ប៉ាប ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៣៤ បន្ទាត់ ១៤-២២។

[1198] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ **E1/318.1** ទំព័រ ៣៥-៣៦ បន្ទាត់ ២៤-១។

[1199] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ **E1/318.1** ទំព័រ ៣៦ បន្ទាត់ ៦-៧។

[1200] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ **E1/318.1** ទំព័រ ៣៦ បន្ទាត់ ៨-៩។

បណ្តឹងរដ្ឋប្បវេណីរូបនេះ បានលើកឡើងថា "គាត់បញ្ហាជាប់ គឺបញ្ហាក្តៅអ៊ីចឹង មិនឱ្យយើងដកថយពីការងារអីទេ ហើយក៏មិនឱ្យយើងរួញរាពីការងារទេ។ ការងារដែលត្រូវធ្វើ គឺគាត់ត្រូវតែឱ្យយើងធ្វើហើយ តែយើងធ្វើអែនអន យើងធ្វើពុត ធ្វើត្បុតហ្នឹងឯង គឺមានបទបញ្ហាហៅប្រជុំហើយប្រជុំទិតៀនថាមិត្តយើងពុតត្បុតម៉េចៗហើយ។ ហ្នឹងរឿងបញ្ហាការ រឿងប្រធាន"[1201]។

638. ដើមបណ្តឹងរដ្ឋប្បវេណី គង់ សៀក បានបន្តផ្តល់សក្ខីកម្មថា "ការងារកាលមិត្តណាធ្វើការមិនបានល្អ ធ្វើមិនពេញដៃពេញជើង អែនអន មានពុតត្បុតអី ទៅលិចទៅកើតហ្នឹងឯង ពេលហ្នឹង តែកាលគាត់មិនទាន់ថាទេនៅការដ្ឋាននោះ ប៉ុនដល់ពេលយប់ឡើងមកដេក មកសម្រាន្តហើយ គាត់ចាប់ផ្តើមអង្គប្រជុំ គាត់ៗទិតៀន គាត់ថាឱ្យហើយ។ គាត់ថា មិត្តឯងនេះធ្វើការមិនៗយកចិត្តទុកដាក់ទេ មិនយកចិត្តទុកដាក់នឹងការងារទេ ឥឡូវមិត្តឯងសូមជួយកែប្រែ ក៏គាត់មិនថាកែប្រែ ឱ្យប្រឹងប្រែងធ្វើការងារ។ គាត់គ្រាន់តែប្រជុំប្រាប់ទិតៀនមិត្តយើង"[1202]។

## ii. ការគ្រប់គ្រងការនិយាយស្តី

639. ដើមបណ្តឹងរដ្ឋប្បវេណី គង់ សៀក បានលើកឡើងថា "កាលហ្នឹងនិយាយគ្នាតែមិត្តក្នុងកងជាមួយគ្នាឯងទេ។ តែកងដទៃសូម្បីតែបងប្អូនបង្កើត ប្រុសបង្កើត ទោះបីញើញមុខគ្នាក៏អត់ហ៊ាននិយាយដែរ"[1203]។ គាត់បានពន្យល់ថា "បានជាខ្ញុំមិនហ៊ានដើរ ពីព្រោះវិន័យរបស់គេតឹងណាស់។ វិន័យរបស់គេៗអត់ឱ្យយើងដើរហើរផ្តេសផ្តាស ហើយគេអត់ឱ្យដើរទាក់ទងគ្នា។ ចាស គេមិនឱ្យដើរទេ គេវិន័យរបស់គេ កាលណាយើងដើរ គេដាក់វិន័យយើងប្រឹបឥឡូវហើយ ឬក៏គេថា យើងសេរី មិនស្តាប់បង្គាប់របស់គេ គេចាប់យើងយកទៅដាក់សន្តិសុខឯណាឯណីទៀតទៅ យើង

[1201] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ **E1/318.1** ទំព័រ ៦៦ បន្ទាត់ ៥-៩។

[1202] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ៦៦ បន្ទាត់ ១៦-២០។

[1203] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ៣៩ បន្ទាត់ ១៦-២០។

ខ្លាចអាហ្នឹង យើងអត់ហ៊ាន តែគេថាយ៉ាងម៉េច គឺយើងនៅហើយ។ ងូតទឹករួចគឺយើង -- បើថាទៅធ្វើការ១ បើឡើងពីធ្វើការវិញ គឺដេកហើយអត់មាននិយាយឲ្យគ្នាទេ អត់ហ៊ានទេ"[1204]។

640. ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន បានពន្យល់ថា "ពេលដើរហើរសេរីទៅណាមកណា គឺអត់បានដែរ។ បានដើរតែពេលទៅធ្វើការតែម្តង"[1205]។ គាត់បានបកស្រាយថាពលករមិនអាចដើរដោយសេរីឡើយ "ពេលយប់ក៏ដើរអត់បានដែរ។ ដឹងតែមកដល់ផ្ទះ ដឹងតែងូតទឹកហើយសម្រាកដេកតែម្តង"[1206]។

### ១.៣. ការប្រព្រឹត្តិ និងការបំពារបំពានយ៉ាងឃោរឃៅ៖ ការបំពារបំពានលើរាងកាយ

641. ដើមបណ្តឹងរដ្ឋប្បវេណី គង់ សៀក បានផ្តល់សក្ខីកម្មថា "អង្កាល់ដែលដែលខ្ញុំឃើញគេឆក់ខ្សែភ្លើងហ្នឹង គឺខ្ញុំបានប្រាប់គាត់រួចហើយ គឺខ្ញុំនៅព្រលានយន្តហោះ ពេលហ្នឹងគឺខ្ញុំឈប់ពីសម្រាកការងារគឺខ្ញុំទៅហូបបាយនៅសហករណ៍ ក៏ខ្ញុំតម្រៀបជួរគ្នាទៅហូបបាយទៅ មិត្តយើងបានគាត់កេះខ្ញុំប្រាប់ខ្ញុំថា គេឆក់ខ្សែភ្លើងមិត្តយើងទៀតហើយនោះ នៅក្រោមដើមស្វាយនោះ។ ដល់ពេលខ្ញុំមើលទៅតាមគាត់ទៅ ឃើញមនុស្សហ្នឹងពីរនាក់ ម្នាក់អង្គុយមួយ ម្នាក់ឈរមួយប៉ុណ្ណឹងឯង"[1207]។ គាត់បានបញ្ជាក់ថា "ខ្ញុំអត់ដឹងពីមូលហេតុគេទេ ពីព្រោះគេជាយុទ្ធជន ហើយនៅកងផ្សេង"[1208]។ គាត់បានឃើញហេតុការណ៍នេះ នៅពេលគាត់ "គ្រាន់តែដើរទៅទៅហូបបាយ"[1209]។

---

[1204] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ៣៩-៤០ បន្ទាត់ ២៣-៣។

[1205] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៤៨ បន្ទាត់ ៤-៥។

[1206] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៤៨ បន្ទាត់ ១០-១១។

[1207] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ៣៨ បន្ទាត់ ៩-១៣។

[1208] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ៣៨ បន្ទាត់ ១៦។

[1209] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ៣៨ បន្ទាត់ ១៧។

## ២. អំពើអមនុស្សធម៌ផ្សេងៗទៀត

642. ភ័ស្តុតាងពីដើមបណ្តឹងរដ្ឋប្បវេណីដែលបានផ្តល់ឱ្យក្នុងពេលសវនាការបង្ហាញថា ទង្វើរបស់អង្គការក្នុងការបង្កើត និងប្រតិបត្តិសហករណ៍ និងការដ្ឋាន[1210] ក្នុងនោះរួមទាំង ការដ្ឋានព្រលានយន្តហោះកំពង់ឆ្នាំ ក្នុងគោលបំណងដើម្បីឱ្យមនុស្សធ្វើការងារ ព្រមទាំងតាមដាន អប់រំរៀនសូត្រ និង "កម្ទិច" ខ្មាំង[1211] ខ្មាំង គឺការរំលោភបំពានសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការរស់រានមានជីវិត និងសិទ្ធិទទួលបានកម្រិតជីវភាពសមរម្យ សិទ្ធិក្នុងការមិនប្រឈមទៅនឹងការប្រព្រឹត្តិកាចសាហាវអមនុស្សធម៌ និងបន្ទាបបន្ថោក និងមិនត្រូវបានចាប់ខ្លួនដោយគ្មានការជំនុំជម្រះ[1212]។ ទង្វើទាំងនេះត្រូវបានប្រកាសថាជាសកម្មភាពដែលមានលក្ខណៈ និងស្ថានទម្ងន់ដូចគ្នានឹងឧក្រិដ្ឋកម្មផ្សេងៗទៀតប្រឆាំងនឹងមនុស្សជាតិ និងបណ្តាលឱ្យដើមបណ្តឹងរដ្ឋប្បវេណីទទួលរងព្យសនកម្មធ្ងន់ធ្ងរ ឬជាការវាយប្រហារលើសេចក្តីថ្លៃថ្នូរជាមនុស្សរបស់ពួកគេ។

### ២.១. លក្ខខណ្ឌការងារ

643. ដើមបណ្តឹងរដ្ឋប្បវេណី គង់ សៀក បានរៀបរាប់ថា ការងារចាប់ផ្តើម "ម៉ោងប្រាំចាប់ផ្តើមនាំគ្នាលីលីហើយគេឱ្យសម្រាក។ ដល់ក្នុងមួយព្រឹកហ្នឹងគេឱ្យសម្រាកតែ១៥នាទីទេ ចាប់ផ្តើមលីទៀតរហូតដល់ម៉ោងដប់មួយបានឈប់។ ថ្ងៃម៉ោងមួយចាប់ផ្តើមធ្វើទៀត រហូតដល់ម៉ោងប្រាំ បានយើងឈប់ដែរ លីស៊ីម៉ង់ត៍ហ្នឹង។ ហើយក្នុងមួយថ្ងៃៗមិនមែនលីបានតិចទេ ច្រើនដែរម្នាក់ៗ ប៉ុនខ្ញុំមិនបានរាប់ មិនបានរាប់ថា យើងម្នាក់គឺលីបានមួយថ្ងៃហ្នឹងបាន២០បេ ឬ៣០បេ ខ្ញុំមិនបានរាប់ទេ ប៉ុន្តែលីមួយថ្ងៃៗ ម្នាក់ៗគឺចូលហើយ ពី១០បេទៅ២០បេ ៣០បេ មួយថ្ងៃៗ"[1213]។ ដើមបណ្តឹងរដ្ឋប្បវេណី គង់ សៀក បានពន្យល់ថា "ចាស ស៊ីម៉ងត៍ក្នុងមួយបេហ្នឹង វាមាន៥០គីឡូ។ ៥០គីឡូហ្នឹងវាមិនថាស្រាលប៉ុន្មានទេ។ ៥០គីឡូ យើងជាស្រី យើងដាក់ទៅដើរទាហើយ។ ចេះតែដើរទាប៉ុនណាក៏យើងខំប្រឹងដែរ ព្រោះយើងនៅការគ្រប់គ្រងរបស់គេ បើយើងមិនប្រឹងប្រែង គឺគេយកយើងទៅសម្លាប់។ យើងខ្លាចអាត្រង់ហ្នឹងឯង ទោះបីយើងដើរទា យើងដើរម៉េច ទោះបីឈឺខ្នង ឈឺចង្កេះ

---

[1210] ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៥៧។

[1211] ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៦៩។

[1212] សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៤៨ មាត្រា ២, ៥, ៩, ២៥។

[1213] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី គង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ៣១ បន្ទាត់ ១៤-១៩។

ឈើសរសៃម៉េច ក៏យើងនៅតែខំប្រឹងដែរ យើងមិនហ៊ានតថ្លៃជាមួយគេទេ”[1214]។ ការងារហ្នឹងធ្វើរយៈពេល ១៤ថ្ងៃ[1215]។

644. ដើមបណ្ដឹងរដ្ឋប្បវេណី គង់ សៀក បានពន្យល់ថា “ការងារជីកប្រឡាយ និងការងារលើកស៊ីម៉ង់ត៍ហ្នឹង គឺវាធ្ងន់ធ្ងរដូចគ្នា មិនជាស្រាល ឬធ្ងន់យ៉ាងណាមួយទេ គឺប្រហែលគ្នា។ លីស៊ីម៉ង់ត៍ក៏វាធ្ងន់ វាគ្រាំគ្រាខ្លួន ហើយទៅជីកប្រឡាយក៏វា១គ្រាំគ្រាខ្លួនដូចតែគ្នាហ្នឹង ពីព្រោះជីកប្រឡាយវាដី ប៉ះត្រង់ណាជ្រាយទៅ ប៉ះត្រង់ណាដីរឹងទៅ។ ជីកបែកដៃបែកជើងហើយទៅ ហើយយើងនាំគ្នាលើកសែងលើកឡើងលើមក វាធ្ងន់ដូចតែគ្នាដែរ”[1216]។

645. ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ សាមឿន បានផ្ដល់សក្ខីកម្មថា “ខ្ញុំធ្លាប់ពិសដៃ។ ដល់តែពេលនោះគេឲ្យខ្ញុំទៅសែងដី។ បើសែងមិនរួចទេ ក៏គេឲ្យខ្ញុំទៅជួយកើបអាចម៍ដីដាក់ឲ្យគេ”[1217]។ គាត់បកស្រាយថា “គេឲ្យថ្នាំអាចម៍ទន្សាយខ្ញុំលេប ហើយខ្ញុំសុំគេឈប់ គេអត់ឲ្យខ្ញុំឈប់ទេ គេថា “ដៃម្ខាងឈឺក៏នៅដៃម្ខាងទៀតដែរ ចឹងទៅធ្វើការទៅ”។ អ៊ីចឹងខ្ញុំខ្លាចគេ ខ្ញុំទៅហើយ”[1218]។

646. ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ សាមឿន បានផ្ដល់សក្ខីកម្មថា “ខ្ញុំអត់បានដឹងម៉ោងវេលាទេ ព្រោះដល់ពេលចេញធ្វើការ មេកងប្រាប់ឲ្យរៀបចំអីវ៉ាន់ចេញទៅធ្វើការ។ ដល់ពេលឡើង គេប្រាប់ថាទុកអីវ៉ាន់ ទុកដាក់ឲ្យស្រួល ហើយត្រឡប់ទៅផ្ទះវិញសម្រាកហូបបាយ។ ដល់ពេលហូបបាយហើយបានបន្តិចក៏គេឲ្យយើងត្រូវទៅធ្វើការវិញពេលយប់វិញ”[1219]។ គាត់បន្តបកស្រាយថា “ពេល

---

[1214] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ៣២ បន្ទាត់ ៨-១២។

[1215] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ៣១-៣២ បន្ទាត់ ២៥-៣។

[1216] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ៣៣ បន្ទាត់ ៦-៩។

[1217] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៤៩ បន្ទាត់ ១៩-២១។

[1218] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៥០ បន្ទាត់ ១-២។

[1219] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៤៤ បន្ទាត់ ១-១៣។

ពីបន្ទាប់ពីហូបបាយល្ងាចហើយ សម្រាកបានបន្តិច ដល់ពេលទៅធ្វើការទៀត ខ្ញុំអត់ដឹងម៉ោងប៉ុន្មានទេ។ ដល់ពេលហើយ គេប្រាប់ថាដល់ម៉ោងហើយទៅផ្ទះ។ ទៅកន្លែងសម្រាកចាស ព្រោះកាលហ្នឹងអត់មានម៉ោង អត់មានអីទេ”[1220]។

647. ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានបន្តរៀបរាប់ពីកង្វះការសម្រាកគ្រប់គ្រាន់ “អត់មានពេលសម្រាកទេ គឺពេលតែសម្រុក គេឲ្យសម្រុក។ ការងារគេអត់ឲ្យឈប់ទេ។ លុះត្រាតែឈឺក្បាល វិលមុខ ឬចុកពោះពេលមករដូវអី ហ្នឹងបានសុំគេសម្រាកមួយថ្ងៃអី បានគេឲ្យសម្រាក។ បើអត់ទេ គេអត់ឲ្យឈប់ទេ”[1221]។ គាត់បានពន្យល់ថា “ពេលសម្រាកអត់មានពេលសម្រាកទេ ដល់ពេលឡើងមកហូបបាយ គឺបានសម្រាកបន្តិច បានត្រឡប់ទៅធ្វើការវិញ”[1222]។

## ២.២. ស្ថានភាពរស់នៅ

### i. កង្វះអាហារ

648. ការផ្តល់សក្ខីកម្មអំពីទិដ្ឋភាពទូទៅពាក់ព័ន្ធនឹងកង្វះអាហារ ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន បានពន្យល់ថា “អាហារពេលព្រឹកគឺអត់មានទេ អាហារថ្ងៃត្រង់គឺបាយលាយពោត ពោត១០កំប៉ុងអង្ករពីរកំប៉ុងចាស។ ហើយហូបអត់បានគ្រប់គ្រាន់ទេ គឺហូបមិនដែលបានឆ្អែតទេ”[1223]។ “មួយកងខ្ញុំកងតូចហ្នឹងគឺមានគ្នា ៣៣នាក់។ អីចឹងវាមានបីក្រុម។ ចឹង ពោត១០កំប៉ុង អង្ករពីរកំប៉ុងហ្នឹងគឺគ្នាខ្ញុំតែ ១១ នាក់ទេ”[1224] និង “អត់មានទេ អាហារពេលយប់”[1225]។

---

[1220] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៤៤ បន្ទាត់ ១៣-១៥។

[1221] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៤៥-៤៦ បន្ទាត់ ២៥-២។

[1222] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៤៦ បន្ទាត់ ៧-៨។

[1223] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៤៤ បន្ទាត់ ២០-២១។

[1224] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៤៥ បន្ទាត់ ៧-៨។

649. ដើមបណ្ដឹងរដ្ឋប្បវេណី គង់ សៀក បានពន្យល់ថា "ទាំងរូបខ្ញុំ ទាំងរូបខ្ញុំទាំងរូបគេ ទាំងនារីយុទ្ធជនទាំងអស់ គឺស្ថានភាពរបស់គាត់ គឺមិនមែនជាធាត់មានសាច់មានឈាមដូចគេទេ គឺសុទ្ធតែស្គមហើយ នៅតែក្បាល ហើយនិងក្បាលជង្គង់ទេ។ ដើររ៉ានៗហើយ ហើយការងារគឺចិត្ត គឺចេះតែប្រឹងខ្លាចស្លាប់ គឺខំនាំគ្នាចេះតែធ្វើហើយ ធ្វើទៅហើយទោះបីបែកដៃបែកជើង ទោះបីគ្រុនឈឺបន្តិចបន្តួចក៏អត់ប៉ានដែរ អត់ប៉ានឈប់ទេ។ ហើយខ្លួនស្គម គឺគ្មានកម្លាំងទេ ទាំងគេទាំងខ្ញុំគឺគ្មានកម្លាំងទេប៉ុនចេះតែទៅ"[1226]។

### ii. កន្លែងស្នាក់នៅមិនសមរម្យ/កង្វះភាពរីករាយ

650. ដើមបណ្ដឹងរដ្ឋប្បវេណី គង់ សៀក បានផ្ដល់សក្ខីកម្មថា "យើងមានទឹកងូត ប៉ុនទឹកល្អក់។ ងូតហើយអីហើយ យើងមកហើយ ងូតក៏គ្មានសាប៊ូគ្មានអីកក់ដែរកាលហ្នឹងនោះ។ ហើយយើងមក -- ងូតទឹកងូតអីរួចដេកទៅ ដេកកន្លែងមន្ទីរហ្នឹងឯង គ្មានមុង គ្មានអីចង ហើយកន្ទេលអីក៏គ្មានដេកគួរសមដែរ កន្ទេលនោះ កន្ទេលកញ្ចាស់រហាក់រហែកទេ នាំគ្នាក្រាលដេក គ្មានមុងគ្មានអីទេ ចេះតែនាំគ្នាក្រាលដេកទៅ ក្រោកឡើងទៅធ្វើការទៀតទៅ ចាសប៉ុណ្ណឹង"[1227]។

651. ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ សាមឿន បានផ្ដល់សក្ខីកម្មថា ពលករដេកនៅក្នុង "រោង ខ្ញុំទៅដល់ឃើញរោងស្រាប់ ដូចរានកន្លែងដេក ហើយគ្មានមុង គ្មានកន្ទេលទេ ដេកដោយលាតរនាបទទេ"[1228]។ ដោយសារតែមានការរំខានពីសត្វមូស គាត់បានពន្យល់ថា "ដល់ពេលសម្រាកនាំគ្នាប្រមូលស្លឹកឈើអីដុតបង្ហុយផ្សែង ដើម្បីកុំឲ្យមានមូសអីមកខាំ"[1229]។

---

1225 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៤៥ បន្ទាត់ ១២។

1226 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ៣៤ បន្ទាត់ ៣-៨។

1227 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ៣០ បន្ទាត់ ១-៥។

1228 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៤៦ បន្ទាត់ ១២-១៤។

1229 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៤៦ បន្ទាត់ ១៨-១៩។

652. ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន បានផ្តល់សក្ខីកម្មថា ពលករនៅ "ពេលនោះធ្វើការទាំងហាលភ្លៀង"[1230] ហើយគេអត់មានឲ្យសម្ភារៈការពារអ្វីទេ "អត់មានអាវភ្លៀង ឬមួកទេ។ មានតែមួកកន្ទឹបមួយ ក៏ពាក់មុខមិនជិតដែរ។ អត់មានអាវភ្លៀង ឬឆត្រ ឬអ្វីដើម្បីការពារខ្លួនពេលធ្វើការហាលភ្លៀងឡើយ"[1231]។

### iii. កង្វះទឹកស្អាតសម្រាប់ផឹក និងអនាម័យ

653. ដើមបណ្តឹងរដ្ឋប្បវេណី គង់ សៀក បានរៀបរាប់ "ស្ថានភាពពេលហ្នឹងដែលខ្ញុំនៅនោះ មិនសូវមានអនាម័យប៉ុន្មានទេ ព្រោះអីបើសិនជាមានអនាម័យ វាអាចមានសាប៊ូមានអីកក់រុះ។ តែកាលហ្នឹងគឺគ្មានអនាម័យគ្មានអី មូសក៏មូស សាប៊ូ ក៏គ្មានកក់ បាយទឹកក៏គេឲ្យហូប គេដួសដាក់នឹងចានដែកទៅ ក៏គ្មានស្អីគ្របស្អីៗដែរ។ ហូបគ្មានអនាម័យដែរទេ"[1232]។ "ពេលដែលខ្ញុំរស់នៅហ្នឹង ជាមួយមិត្ត -- រស់នៅតែជាមួយមិត្តនារីគ្នាខ្ញុំទាំងកងហ្នឹង គឺវាមិនមានអនាម័យអីទេ។ ដល់ៗយើងបានស្អាត បានល្អទេអង្កាល់ហ្នឹង វាគ្មានសាប៊ូហើយ មិត្តនារីយើងមានពេលដើររដូវ ដើរអីមកនោះក៏វាគ្មានអីបោក គ្មានអីគក់ ហើយគ្មានអីបានស្អាត បានធុំល្អទេ ខោអាវអី គឺគ្មានបានធុំល្អទេ គឺស្អុយហើយ"[1233]។

654. ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ក៏បានផ្តល់សក្ខីកម្មថា "ហូបទឹកគឺអត់មានអនាម័យទេ នៅពេលហូបទឹកអូរ"[1234]។ គាត់ថា "ហូបកន្លែងទឹកង្គតហ្នឹងចាស ព្រោះទឹកអូរវាហូរ"[1235]។

---

[1230] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៤៨ បន្ទាត់ ១៦។

[1231] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៤៩ បន្ទាត់ ២-៣។

[1232] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ៣០ បន្ទាត់ ៩-១២។

[1233] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ៣០ បន្ទាត់ ១៦-១៩។

[1234] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៤៥ បន្ទាត់ ១១។

655. ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន បានរៀបរាប់ "ពេលនោះធ្វើការឡើងមកវិញ គឺគ្មានជាសាប៊ូ ឬគ្មានអីដើម្បីដុសសម្អាតកាយទេចាស មានតែអត់ទាំងអស់។ ពេលនោះ ពួកខ្ញុំយកអាដូចជានោងសាញ នោនោងព្រៃហ្នឹងយកមកដុសក្បាលចាស។ ហើយពេលនោះ គ្មានអ្នកណាមួយដែលមានសាប៊ូដុសទេ គឺចៃកើតពេញក្បាលទាំងអស់។ កើតរមាស់ក៏កើតរមាស់ ចៃក៏ចៃដែរចាស"[1236]។

## ២.៣. ការបាត់ខ្លួន

656. ទាក់ទងទៅនឹងការចាប់ខ្លួន និងការបាត់ខ្លួន ដើមបណ្តឹងរដ្ឋប្បវេណី ឆែ ប៉ាប បានផ្តល់សក្ខីកម្មថា "ខ្ញុំអត់ដែលឃើញគេចាប់ខ្លួននៅនឹងមុខទេ ប៉ុន្តែគេថាដូចប្រជុំជួរទៅ ព្រឹកឡើងថាកម្លាំងនេះ ទៅធ្វើការនៅម្តុំត្រង់នេះ ត្រង់នោះទៅ តែល្ងាច អត់ឃើញមានមកវិញ។ ការបាត់ខ្លួន ខ្ញុំអត់ឃើញជាក់ស្តែងទេ។ ខ្ញុំដូចស្គាល់បីនាក់ពីភ្នំពេញ គេថាឲ្យទៅធ្វើនៅព្រលានយន្តហោះពោធិ៍ចិនតុង។ ចឹងបាត់រហូត"[1237]។

## គ. ព្យសនកម្ម

## ១. ព្យសនកម្មផ្នែករាងកាយ

657. ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន បានផ្តល់សក្ខីកម្មពីព្យសនកម្មផ្នែករាងកាយដែលគាត់មាន និងផលប៉ះពាល់ទៅលើគាត់ដែលជាមនុស្សស្រី។ "ពេលខ្ញុំឈឺ កើតពិសដៃក៏គេប្រើខ្ញុំដែរ។ ដល់ពេលខ្ញុំសុំសម្រាក គេមិនឲ្យសម្រាក។ ហេតុនេះសព្វថ្ងៃខ្ញុំគឺខ្សោយបេះដូង និងខូចតម្រង់នោម

---

[1235] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៤៥ បន្ទាត់ ១៩។

[1236] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៤៧ បន្ទាត់ ២-៥។

[1237] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឆែ ប៉ាប ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៣៥ បន្ទាត់ ១-៨។

ដោយការធ្វើការជាទម្ងន់"[1238]។ "ពេលខ្ញុំរាំងរដូវ គេចោទខ្ញុំថា ខ្ញុំពោះធំ ប្រើធ្វើការធ្ងន់គឺខ្ញុំមានអារម្មណ៍ខូចខាតក្នុងខ្លួន"[1239]។

658. នៅពេលសួរពីទម្ងន់របស់គាត់នៅពេលនោះ ដើមបណ្តឹងរដ្ឋប្បវេណី គង់ សៀក បានរៀបរាប់ "ខ្ញុំមិនដែលបានថ្លឹងគីឡូខ្លួនឯងទេ មិនដឹងគីឡូប៉ុន្មានទេ"[1240] ហើយគាត់បានបន្តបកស្រាយទៀតថា "កាលដែលខ្ញុំ គេឲ្យទៅលើស៊ីម៉ង់ត៍ ខ្លួនខ្ញុំតូចទេ ខ្លួនខ្ញុំមិនធាត់ដូចសព្វថ្ងៃនេះ ដូចចាស់សព្វថ្ងៃគឺធាត់អង្កាល់នៅពីក្មេង គឺស្គម ហើយត្រូវនឹងអាហារហូបមិនគ្រប់គ្រាន់ទៀត គឺស្គមមានទី-- ដូចថាស្គមណាស់ មិនអាចនឹងយើងថា សព្វថ្ងៃតស៊ូនឹងការងារហ្នឹងមិនបានទេ បើតាមយើងស្គម ប៉ុន្តែឥឡូវសម័យនោះ បើយើងមិនធ្វើ គឺងាប់"[1241]។

659. ដើមបណ្តឹងរដ្ឋប្បវេណី គង់ សៀក ក៏បានរៀបរាប់ពីព្យសនកម្មដោយផ្ទាល់ និងរយៈពេលវែងផ្នែករាងកាយនៅពេលធ្វើការនៅការដ្ឋាននោះ និងពីផលប៉ះពាល់ទៅលើគុណភាពជីវិតរបស់គាត់មកដល់សព្វថ្ងៃ "ខ្ញុំខំប្រឹងលីៗមិនរួច ខ្ញុំដើរទា គេថាឲ្យខ្ញុំទៀតគេថាមិត្តឯងអីក៏លីមិនរួច ក៏កម្លាំងអីក៏លីមិនរួច។ រហូតដល់ខ្ញុំលីស៊ីម៉ង់ត៍ ខ្ញុំជីកដីហើយ សព្វថ្ងៃក៏ប៉ះពាល់ដល់រាងកាយរបស់ខ្ញុំនេះឈឺដើមទ្រូងខ្ញុំនៅរាល់ថ្ងៃ ហើយចង្កេះខ្ញុំគឺគ្រាំគ្រារាល់ថ្ងៃ ទោះបីខ្ញុំមកសាលាក្តីកន្លែងនេះក៏ខ្ញុំលេបថ្នាំដែរ ខ្ញុំលេបថ្នាំឡើងឈាម ខ្ញុំលេបថ្នាំសរសៃបានខ្ញុំដើររួចបានប៉ុណ្ណេះ"[1242]។

## ២. ព្យសនកម្មផ្លូវចិត្ត

### ២.១. ព្យសនកម្មដោយផ្ទាល់ផ្នែកផ្លូវចិត្ត

[1238] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៦៩ បន្ទាត់ ២០-២២។

[1239] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៧០ បន្ទាត់ ៤-៥។

[1240] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ៤៨ បន្ទាត់ ១៧-១៨។

[1241] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ៤៨-៤៩ បន្ទាត់ ២៣-១។

[1242] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ៧២ បន្ទាត់ ២២-២៥។

660. ដើមបណ្ដឹងរដ្ឋប្បវេណី គង់ សៀក បានពន្យល់ថា គាត់រស់នៅដោយមានការសង្ស័យ និងភ័យខ្លាច ដែលមិនអាចជួបជុំជាមួយនឹងគ្រួសារវិញ។ "ខ្ញុំមកនៅអូរបែកក្អមខ្ញុំធ្វើការទៅ ខ្ញុំឮប្រធានវរៈខ្ញុំប្រជុំប្រាប់ខ្ញុំ ប្រាប់ខ្ញុំថា "មិត្តឯងរាល់គ្នានេះឯង សុទ្ធតែជាប់និន្នាការហើយ ពីព្រោះកងពលមិត្តឯងគេចាប់យកទៅដាក់គុកទួលស្លែង ដាក់គុកព្រៃសអស់ហើយ។ ឥឡូវមិត្តឯងនេះ ត្រូវជាប់ឥទ្ធិពលគេហ្នឹងឯង គេក្បត់អស់ហើយ។ ដើមឈើគឺគេ អាធំវាដួលមកហើយ គឺវាសង្កត់អាក្រោមហើយ។ ដូច្នេះមិត្តឯងខំប្រឹងប្រែងធ្វើការទៅ បើមិត្តឯងមិនប្រឹងប្រែងធ្វើការទេ ទោះបីមិត្តឯងអង្គុយបង្ហូរទឹកភ្នែកនឹកម៉ែនឹកឪ នឹកភូមិនឹកស្រុកប៉ុនណា ក៏មិត្តឯងមិនបានជួបម៉ែឪមិត្តឯងដែរ""[1243]។

661. ដើមបណ្ដឹងរដ្ឋប្បវេណី គង់ សៀក បានផ្ដល់សក្ខីកម្មពីបទពិសោធន៍ធ្វើការក្នុងរបបនោះដែលបានប៉ះពាល់ទៅលើអារម្មណ៍ និងភាពសោកសៅដែលជាលទ្ធផលនៃការព្រាត់ប្រាស់ ឪពុកម្ដាយ។ "តាំងពីខ្ញុំ តាំងពីឆ្នាំ៧៥ ដែលខ្ញុំចូលមកនៅធ្វើយោធា ក្នុងឆ្នាំ៧៥ នេះឯង រហូត ៧៥, ៧៦, ៧៧ មក ខ្ញុំមិនដែលបានទៅជួបម៉ែឪខ្ញុំទេ។ គេមិនឱ្យទៅ ដូចខ្ញុំនិយាយអ៊ីចឹង គឺថាខ្ញុំ គេមិនឱ្យទៅទេ "មិត្តឯងប្រឹងតែធ្វើការទៅ ទោះមិត្តឯងបង្ហូរទឹកភ្នែកក្លាយជាឈាម ក៏គេមិនឱ្យទៅជួបម៉ែឪស្រុកភូមិដែរ" ចាស រហូតខ្ញុំមិនដែលបានជួប រហូតដល់ពេលរត់ ដែលយួនបុកចូលភ្នំពេញមក រហូតដល់រត់ចូលភ្នំ ឡើងភ្នំមក បានក្រោយឡើងទៀត រំសាយគ្នាអស់ហើយ បានចូលស្រុកភូមិវិញ បានឃើញម៉ែឪ"[1244]។

## ២.២. ព្យសនកម្មផ្នែកផ្លូវចិត្ត រាងកាយ និងសម្ភារៈរយៈពេលវែង

662. ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ សាមឿន បានរៀបរាប់ពីព្យសនកម្មពាក់ព័ន្ធនឹងបទពិសោធន៍របស់គាត់ទាំងមូលថា "ពីខ្លួនខ្ញុំផ្ទាល់តាំងពីខ្ញុំចូលបម្រើទ័ពនៅកម្ពុជាប្រជាធិបតេយ្យ គឺខ្ញុំមានប៉ះពាល់អារម្មណ៍របស់ខ្ញុំ ដូចជាខ្ញុំត្រូវគេធ្វើការជាទម្ងន់។ ពេលខ្ញុំឈឺ កើតពិសដៃក៏គេប្រើខ្ញុំ។ ដល់ពេលខ្ញុំសុំឈប់សម្រាក ក៏គេមិនឱ្យសម្រាក។ ហេតុដូច្នេះ អារម្មណ៍របស់ខ្ញុំរាល់ថ្ងៃ គឺខ្លួនខ្ញុំគឺខ្សោយបេះដូង ហើយនិងខូចតម្រងនោម ដោយការធ្វើការជាទម្ងន់។ ដល់ពេលឪពុកម្ដាយ បងប្អូនខ្ញុំក៏ត្រូវ

---

[1243] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី គង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ២៧ បន្ទាត់ ១២-១៨។

[1244] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី គង សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ៤០ បន្ទាត់ ៩-១៤។

គេសម្លាប់ចោល។ ផ្ទះសម្បែងខ្ញុំត្រូវខូចខាតទាំងអស់ ខ្ញុំគ្មានដីធ្លីទាំងអស់។ ទាល់ខ្ញុំរត់មកវិញ គឺមានតែខ្លួនខ្ញុំម្នាក់គត់ គឺនៅកំព្រាឯកា គ្មានអ្នកណាទីពឹងទាំងអស់។ ហេតុដូច្នេះ គឺក្នុងអារម្មណ៍របស់ខ្ញុំ គឺក្តុកក្តួលក្នុងចិត្តតាំងពីនោះ រហូតដល់សព្វថ្ងៃ គឺគ្មានឪពុកម្តាយហៅ ឬបងប្អូនទាំងអស់ សាច់ញាតិក៏គ្មាន។ ហេតុដូច្នេះ គឺខ្ញុំ អារម្មណ៍របស់ខ្ញុំគឺក្តុកក្តួលក្នុងអារម្មណ៍របស់ខ្ញុំ គឺមានជំងឺរហូតដល់សព្វថ្ងៃ។ គឺខ្ញុំរស់នៅជាមួយឪពុកម្តាយខ្ញុំ គេមិនដែលប្រើប្រាស់ខ្ញុំយ៉ាងដូច្នេះ។ ខ្ញុំសុខចិត្តលះបង់ខ្លួនតាំងពីអាយុកុមារភាព ១០ឆ្នាំ ខ្ញុំទៅបម្រើទ័ព ថាខ្ញុំសុខស្រួល បែរមិនសុខស្រួល ប្រើខ្ញុំដូចគោ ដូចក្របី។ អ៊ីចឹងខ្ញុំមានអារម្មណ៍ឈឺចាប់ ខ្លោចផ្សារនៅក្នុងចិត្តរបស់ខ្ញុំ។ ពេលខ្ញុំរាំងរដូវ គេចោទខ្ញុំថាខ្ញុំពោះធំ ប្រើធ្វើការធ្ងន់ គឺខ្ញុំមានអារម្មណ៍ខូចខាតក្នុងខ្លួនរបស់ខ្ញុំ”[1245]។

## ជំពូក ៦. ការប្រព្រឹត្តិលើជនជាតិចាម[1246]

[1245]សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៦៩-៧០ បន្ទាត់ ១៩-៥។

[1246]អង្គជំនុំជម្រះសាលាដំបូងបានដឹងអំពីអង្គហេតុនានាដូចខាងក្រោម ដោយហេតុថាអង្គហេតុទាំងនោះទាក់ទងការប្រព្រឹត្តិទៅលើប្រជាជនចាម ក្នុងនាមជាក្រុមគោលដៅ។ ពីឆ្នាំ ១៩៧៥-១៩៧៧ “សាក្សី (ចាម និងមិនមែនចាម) ពីទូទាំងកម្ពុជានិយាយដោយស៊ីសង្វាក់ថា ប.ក.ក បានហាមឃាត់ការប្រណិប័តន៍សាសនាអ៊ីស្លាម និងបានហាមឃាត់ចាមមិនឱ្យស្លូត្រធម៌បានរិបអូស និងបានដុតគម្ពីរគូរ៉ាន បានបិទ និងបានបំផ្លាញវិហារចាម ឬបានប្រើប្រាស់សម្រាប់គោលបំណងដទៃទៀតដូចជា រោងបាយរួម ឃ្លាំង ឬទ្រុងជ្រូក។ សាក្សីជាច្រើន (លើកលែងតែសាក្សីពរូបក្នុងចំណោមពួកគាត់) និយាយថាចាមត្រូវបានបង្ខំឱ្យបរិភោគសាច់ជ្រូក។ មេដឹកនាំសាសនា និងបញ្ញវ័ន្តអ៊ីស្លាមត្រូវបានចាប់ខ្លួន និង/ឬសម្លាប់។ ស្ត្រីចាមត្រូវបានបង្ខំឱ្យកាត់សក់ និងត្រូវបានហាមឃាត់មិនឱ្យទទូរក្បាល។ ភាសាចាមត្រូវបានហាមឃាត់ សម្លៀកបំពាក់ប្រពៃណីចាមត្រូវបានហាមឃាត់” ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៧៥៦។ អង្គជំនុំជម្រះបានដឹងអំពីអង្គហេតុទាក់ទង “ការបះបោររបស់ប្រជាជនចាមចំនួន ២ ដែលបានកើតឡើងក្នុងរយៈពេលប៉ុន្មានសប្តាហ៍ក្នុងភូមិចំនួនពីរក្នុងស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម៖ ក្នុងភូមិកោះផល (កោះមួយនៅតាមទន្លេមេគង្គ ឃុំពើស ១) និងក្នុងភូមិស្វាយឃ្លាំង (ឃុំស្វាយឃ្លាំង)” “ក្នុងខែកញ្ញា និងខែតុលា ឆ្នាំ ១៩៧៥” ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៧៥៨។ អង្គហេតុទាំងនេះគូសបញ្ជាក់ថា “ក្រោយការបះបោរ ការធ្វើទុក្ខបុកម្នេញទៅលើប្រជាជនចាមបានកើនឡើងគួរឱ្យកត់សម្គាល់។ មនុស្សជាច្រើនត្រូវបានចាប់ខ្លួន ភូមិទាំងមូលត្រូវបានជម្លៀស បំបែកក្នុងចំណោមភូមិខ្មែរ ហើយបុរសដែលជាមេគ្រួសារត្រូវបានសម្លាប់”។ ចំណុចនេះរួមបញ្ចូលចំណុចដែលថា “ក្រោយពេលមានការបះបោររបស់ប្រជាជនចាមក្នុងទីតាំងភូមិភាគបូព៌ា ប្រជាជនចាមជាច្រើនត្រូវបានផ្លាស់ទីពីភូមិកំណើតរបស់ពួកគាត់ក្នុងខេត្តកំពង់ចាម និងត្រូវបានបញ្ជូនទៅតាមភូមិផ្សេងៗក្នុងខេត្តតែមួយ។ ខ្លះត្រូវបានបញ្ជូនទៅដល់ភូមិនានាក្នុងខេត្តក្រចេះ កំពង់ធំ និងបាត់ដំបង” ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៧៥៨ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ២៦៦។ ពីឆ្នាំ ១៩៧៧-១៩៧៩ អង្គជំនុំជម្រះសាលាដំបូងបានដឹងអង្គហេតុជុំវិញថាតើប្រជាជនចាមត្រូវបានធ្វើបាប និង/ឬសម្លាប់ ដែរឬទេ និងថា “ក្នុងអំឡុងឆ្នាំ ១៩៧៧ និងឆ្នាំ ១៩៧៨ សាក្សីជាច្រើនពិពណ៌នាអំពីការឃើញរលកនៃការសម្លាប់ប្រជាជនចាមក្នុង

ភូមិភាគកណ្តាល (ឧត្តរចាស់) និងភូមិភាគបូព៌ា"។ មានការចោទផងដែរថាការសម្លាប់ជាទ្រង់ទ្រាយទៅលើប្រជាជនចាមក្នុងស្រុកក្រូចឆ្មាបានកើតឡើងក្នុងការបះបោរលើកទីបីក្នុងឆ្នាំ ១៩៧៨។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៧៦២ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៧៦៣ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៧៦៧។ អង្គជំនុំជម្រះសាលាដំបូងបានទទួលជាពិសេសនូវអង្គហេតុទាក់ទងការចាប់ខ្លួន ការឃុំឃាំង និងការសម្លាប់ប្រជាជនចាមនៅមន្ទីរសន្តិសុខវត្តអូរត្រកួនពីឆ្នាំ ១៩៧៥ ឬ ១៩៧៦ រហូតដល់យ៉ាងហោចណាស់ឆ្នាំ ១៩៧៧ និងនៅមន្ទីរសន្តិសុខភូមិទ្រាក្នុងពាក់កណ្តាលឆ្នាំ ១៩៧៨។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៧៧៦-៧៨៣។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៧៨៤-៧៨៩។ ផ្អែកតាមការចោទប្រកាន់លើអង្គហេតុទាំងនេះទាក់ទងការប្រព្រឹត្តិទៅលើប្រជាជនចាម ជនជាប់ចោទត្រូវបានចោទពីបទប្រល័យពូជសាសន៍ (តាមរយៈការសម្លាប់) និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់នៃការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការចាប់ដាក់ពន្ធនាគារ ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយហេតុផល (សាសនា) និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់អំពើអមនុស្សធម៌ដទៃទៀត ដូចជាអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៣៣៦-១៣៤២។ *សូមមើលផងដែរ* ឧបសម្ព័ន្ធនៃដីកាសម្រេចលើការបំបែកបន្ថែមនៃសំណុំរឿង ០០២ និងវិសាលភាពនៃសំណុំរឿង ០០២/០២ ឯកសារ **E301/9/1.1** ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១៤ ទំព័រ ៣។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៣៧៣ ១៣៧៨។ *សូមមើលផងដែរ* ឯកសារ **E301/9/1.1** ទំព័រ ៣។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៣៨១ ១៣៨៦។ *សូមមើលផងដែរ* ឯកសារ **E301/9/1.1** ទំព័រ ៣។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៤០២ ១៤០៧។ *សូមមើលផងដែរ* ឯកសារ **E301/9/1.1** ទំព័រ ៣។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៤០៨។ *សូមមើលផងដែរ* ឯកសារ **E301/9/1.1** ទំព័រ ៣។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៤១៩ ១៤២០។ *សូមមើលផងដែរ* ឯកសារ **E301/9/1.1** ទំព័រ ៣។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៤៤២។ *សូមមើលផងដែរ* ឯកសារ **E301/9/1.1** ទំព័រ ៤។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៤៣០។ *សូមមើលផងដែរ* ឯកសារ **E301/9/1.1** ទំព័រ ៤។ ទាក់ទងការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី ២ កំហិតត្រឹមការប្រព្រឹត្តិទៅលើប្រជាជនចាម ជនជាប់ចោទត្រូវបានចោទពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ និងសាសនា និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិក្នុងទម្រង់អំពើអមនុស្សធម៌ដទៃទៀតជាការជម្លៀសដោយបង្ខំ ការបាត់ខ្លួនដោយបង្ខំ ការវាយប្រហារសេចក្តីថ្លៃថ្នូរមនុស្សជាតិ អាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើរំលោភសេពសន្ថវៈក្នុងបរិបទអាពាហ៍ពិពាហ៍ដោយបង្ខំ។ ឯកសារ **E301/9/1.1** ទំព័រ ៤ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៣៨១ ១៣៨៧។ *សូមមើលផងដែរ* ឯកសារ **E301/9/1.1** ទំព័រ ៣។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៤១៦ ១៤១៨ ១៤១៩ ១៤២០។ *សូមមើលផងដែរ* ឯកសារ **E301/9/1.1** ទំព័រ ៣។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៤៤៨ ១៤៥៤ ១៤៥៦ ១៤៦០ ១៤៦២ ១៤៦៨ ១៤៦៩។ *សូមមើលផងដែរ* ឯកសារ **E301/9/1.1** ទំព័រ ៤។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៤៧០ ១៤៧៨។ *សូមមើលផងដែរ* ឯកសារ **E301/9/1.1** ទំព័រ ៤។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៤៣៤ ១៤៣៦ ១៤៤១។ *សូមមើលផងដែរ* ឯកសារ **E301/9/1.1** ទំព័រ ៤។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៤៤២។ *សូមមើលផងដែរ* ឯកសារ **E301/9/1.1** ទំព័រ ៤។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៤៣០។ *សូមមើលផងដែរ* ឯកសារ **E301/9/1.1** ទំព័រ ៤។

## ក. និជ្ជភាពទូទៅនៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី

663. ដើមបណ្តឹងរដ្ឋប្បវេណីជនជាតិចាម ប្រាំនាក់ដោយរួមមាន សុះ មីន នោ សាទះ ម៉ាន ស្លេះ ហ៊ីម ម៉ាន និង ម៉ើ ពៅ បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ ក្នុងអំឡុងពេលជំនុំជម្រះក្តីពាក់ព័ន្ធនឹងការប្រព្រឹត្តចំពោះជនជាតិចាម។ សក្ខីកម្មរបស់ពួកគេ ផ្តោតទៅលើការធ្វើទុក្ខបុកម្នេញដោយមូលហេតុសាសនាប្រឆាំងនឹងជនជាតិចាម ការបះបោរនៅស្វាយឃ្លាំង និងព្រឹត្តិការណ៍ផ្សេងៗក្រោយការបះបោរ ការផ្លាស់ទីលំនៅប្រជាជនដំណាក់កាលទី២ (ដោយសារវាពាក់ព័ន្ធនឹងជនជាតិចាម) និងព្រឹត្តិការណ៍ដែលកើតឡើងនៅវត្តអូរត្រកួន និងភូមិទ្រា ព្រមទាំងព្យសនកម្មទាំងឡាយដែលពួកគេបានទទួលរង[1247]។

### *ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន*

664. ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន បានរស់នៅក្នុងភូមិ៥ ឃុំស្វាយឃ្លាំង ស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម [1248]ដែលជាភូមិជនជាតិចាមមួយ[1249]ដែលត្រូវបាន “រំដោះ” ដោយខ្មែរក្រហម មុនឆ្នាំ១៩៧៥[1250]។ ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន បានផ្តល់សក្ខីកម្មថា មុនឆ្នាំ១៩៧៥ មានព្រះវិហារអ៊ីស្លាមពីរនៅក្នុងឃុំស្វាយឃ្លាំង ប៉ុន្តែបន្ទាប់ពីរំដោះ ខ្មែរក្រហមបានរុះរើព្រះវិហារទាំងនោះ[1251]។ នៅឆ្នាំ១៩៧៤ ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន បានជួយរៀបចំស្ថិតិប្រជាជនសម្រាប់ភូមិ៥ និង

---

[1247] ក.ស.ច.ស បានទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៤៦ រូប ដោយផ្អែកលើការប្រព្រឹត្តិទៅលើប្រជាជនចាម (ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៧៩០) ហើយ អ.ប.ជ បានទទួលស្គាល់ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៩៥ រូប។

[1248] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៦៧ បន្ទាត់ ១៤-១៩ (បច្ចុប្បន្នខេត្តនេះឈ្មោះខេត្តត្បូងឃ្មុំ)។

[1249] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៨៤ បន្ទាត់ ២២-ទំព័រ ៨៥ បន្ទាត់ ៣។

[1250] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៨៥ បន្ទាត់ ១៥ “<ចុង > ឆ្នាំ ១៩៧៣”។

[1251] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៨៧ បន្ទាត់ ២១-ទំព័រ ៨៨ បន្ទាត់ ២។

ភូមិ៦[1252] ហើយគាត់រាប់ឃើញថាមានគ្រួសារជនជាតិចាមចំនួន១២៤២ គ្រួសារដែលរស់នៅទីនោះ[1253]។

665. ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន បានចងចាំអំពីការចូលមកដល់របស់ពួកខ្មែរក្រហមនៅក្នុងភូមិរបស់គាត់ នៅចុងឆ្នាំ១៩៧៣[1254]។ នៅត្រឹមឆ្នាំ១៩៧៥ របបនោះចាប់ផ្តើមកំហិតការគោរពប្រតិបត្តិសាសនារបស់ជនជាតិចាម។ ពួកគេក៏បានបង្ខំឲ្យធ្វើការជាទម្ងន់ និងកំហិតរបបអាហារផងដែរ[1255]។ គាត់បានពន្យល់ថា ប្រសិនបើអ្នកណាម្នាក់មិនគោរពតាមគោលការណ៍ដែលត្រូវបានកំណត់ ដោយពួកខ្មែរក្រហម អ្នកនោះនឹងត្រូវចោទថាជាខ្មាំង ដែលនេះគឺជាមូលដ្ឋានសម្រាប់ការចាប់ខ្លួន និងបាត់ខ្លួន[1256]។ ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន បានផ្តល់សក្ខីកម្មថា ជាទូទៅការចាប់ខ្លួនកើតឡើងនៅពេលយប់ ហើយមនុស្សត្រូវបានគេដឹកតាមរទេះសេះយកចេញទៅបាត់[1257]។ ការចាប់ខ្លួនអាចកើតមានឡើងរហូតដល់ចំនួន២០យប់ នៅក្នុងមួយខែ[1258]។

666. ការចាប់ខ្លួនដែលមានការកើនឡើង និងការដាក់កំហិតលើជនជាតិចាម កើនខ្ពស់បំផុត នៅពេលដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន ទទួលដំណឹងថា "ខ្មាំងដែលលួចជ្រាតចូល" ចំនួន៨០នាក់ នឹងត្រូវ

[1252] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៨៦ បន្ទាត់ ២៣-ទំព័រ ៨៧ បន្ទាត់ ៧។ *សូមមើលផងដែរ* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១៥ **E1/344.1** ទំព័រ ៥៦ បន្ទាត់ ២៣-ទំព័រ ៥៨ បន្ទាត់ ៣។

[1253] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៨៦ បន្ទាត់ ២១។

[1254] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៨៥ បន្ទាត់ ១២-១៥។

[1255] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៧១ បន្ទាត់ ១៤-១៩។

[1256] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៧២ បន្ទាត់ ១០-១២ និងទំព័រ ៧៣ បន្ទាត់ ៤-១៣។

[1257] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៧៣ បន្ទាត់ ៤-១៣។

[1258] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៧៣ បន្ទាត់ ៤-១៣។

701. ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី ពៅ បានផ្តល់សក្ខីកម្មថា៖ "បញ្ញាវ័ន្តសាសនាអ៊ីស្លាម ត្រូវបានគេយកទៅសម្លាប់នៅក្នុងរបបខ្មែរក្រហម ប៉ុន្តែខ្ញុំមិនដឹងថាពួកគេត្រូវបានសម្លាប់នៅទីកន្លែងណា ឬត្រូវបានឃុំខ្លួននៅទីកន្លែងណា នោះឡើយ។ ប៉ុន្តែ អ្វីដែលខ្ញុំបានដឹង គឺថា អ្នកណាក៏ដោយដែលដឹងអំពីរឿងរ៉ាវសាសនាអ៊ីស្លាម ត្រូវបានគេសម្លាប់"[1432]។ គាត់បានពន្យល់ថា៖ "នៅក្នុងសាសនាអ៊ីស្លាម អ៊ីម៉ាំ មានភារកិច្ចទទួលខុសត្រូវដឹកនាំការថ្វាយបង្គំព្រះនៅក្នុងវិហារ។ ជាទូទៅ គាត់ឈរនៅខាងមុខគេ។ ចំណែកឯតួន គឺជាគ្រូសាសនា។ ខ្ញុំបានឮថាពួកគេត្រូវបានជម្លៀស ហើយពួកគេទាំងអស់ត្រូវបានគេសម្លាប់នៅដំរីស។ ខ្ញុំមិនបានឃើញព្រឹត្តិការណ៍នោះ ដោយផ្ទាល់ទេ ប៉ុន្តែខ្ញុំបានឮពីអ្នកដទៃ"[1433]។ ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី ពៅ បានពន្យល់បន្ថែមថា៖ "ខ្ញុំបានបាត់បង់សាច់ញាតិ១៧នាក់ ហើយអ្នកខ្លះគឺជាអ៊ីម៉ាំ និងតួន"[1434]។

### ១.២. ការផ្លាស់ប្តូរគោលបំណងនៃព្រះវិហារ

702. ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន បានផ្តល់សក្ខីកម្មថា៖ "មុនឆ្នាំ១៩៧៥ មានវិហារអ៊ីស្លាមពីរ នៅក្នុងភូមិស្វាយឃ្លាំង ដោយសារមានប្រជាជនចាមច្រើន វិហារពីរត្រូវបានសាងសង់ឡើងដើម្បី

---

[1431] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៥៤ បន្ទាត់ ១១-១៣។

[1432] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មើ ពៅ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៣០ បន្ទាត់ ១២-១៦។

[1433] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មើ ពៅ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៣២ បន្ទាត់ ៥-៩។

[1434] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មើ ពៅ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៣២ បន្ទាត់ ១៣-១៤។

ទទួលសាសនិកជន[1435]។ គាត់បានរៀបរាប់អំពីការបិទព្រះវិហារថា៖ "បន្ទាប់ពីរំដោះ ខ្មែរក្រហម បានរុះរើព្រះវិហារទាំងនោះ"[1436]។

703. ស្រដៀងគ្នានេះដែរ ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ បានផ្តល់សក្ខីកម្មថា៖ "មានព្រះវិហារអ៊ីស្លាមពីរ ហើយនៅក្រោយឆ្នាំ១៩៧៥ នៅពេលយើងត្រូវបានជម្លៀសចេញពីតំបន់នោះ ព្រះវិហារទាំងនេះត្រូវបានវាយបំផ្លាញ និងរុះរើចោល។ នាពេលក្រោយមក នៅពេល ខ្ញុំត្រឡប់មកវិញ លែងមានព្រះវិហារទៀតហើយ គឺមានតែដីទទេតែប៉ុណ្ណោះ ត្រង់កន្លែងដែលធ្លាប់មានព្រះវិហារពីពេលមុន ហើយបន្ទាប់មកគេសាងសង់ព្រះវិហារថ្មី។ ឥឡូវនេះ ខ្ញុំទៅថ្វាយបង្គំព្រះនៅក្នុងព្រះវិហារថ្មីរៀងរាល់ថ្ងៃ[1437]។ ដើមបណ្តឹងរដ្ឋប្បវេណី បានបន្ថែមថា "ក្រោយការជម្លៀស ព្រះវិហារត្រូវបានបំផ្លាញ។ ក្រោយ ប៉ុល ពត ឡើងកាន់អំណាច ពួកគេបានវាយបំផ្លាញព្រះវិហារ។ បន្ទាប់ពីខ្ញុំចាកចេញពីភូមិ ព្រះវិហារត្រូវបានបំផ្លាញ"[1438]។

704. ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ បានផ្តល់សក្ខីកម្មថា៖ "នៅពេលនោះ មិនមានអ្នកណាម្នាក់ទៅថ្វាយបង្គំព្រះនៅក្នុងព្រះវិហារនោះឡើយ ពីព្រោះខ្មែរក្រហមបានហាមឃាត់ពួកយើងមិនឲ្យធ្វើដូច្នោះ ហើយតាមការពិត គោក្របីត្រូវបានដាក់នៅក្នុងព្រះវិហារ ថ្នាំជក់ក៏ត្រូវបានរក្សាទុកនៅក្នុងព្រះវិហារផងដែរ"[1439]។

705. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន បានផ្តល់សក្ខីកម្មថា៖ "តាមពិត ពួកគេបានដាក់ត្បាល់នៅក្នុងព្រះវិហារ។ ស្រូវក៏ត្រូវបានរក្សាទុកនៅក្នុងព្រះវិហារដែរ ពីព្រោះគ្មានអ្នកណាម្នាក់ត្រូវបាន

---

[1435] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៨៧ បន្ទាត់ ២៣-២៤។

[1436] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៨៨ បន្ទាត់ ២។

[1437] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៧៨ បន្ទាត់ ២៣-ទំព័រ ៧៩ បន្ទាត់ ៣។

[1438] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៧៩ បន្ទាត់ ៥-៦។

[1439] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៦៩ បន្ទាត់ ១៩-២២។

អនុញ្ញាតិឲ្យថ្វាយបង្គំព្រះនៅក្នុងព្រះវិហារទៀតនោះឡើយ។ ដូចខ្ញុំបានរៀបរាប់រួចមកហើយ ស្រូវ និងត្បាល់ត្រូវបានដាក់នៅក្នុងព្រះវិហារ ហើយយោងតាមសាសនារបស់យើង ស្ត្រីមិនត្រូវបាន អនុញ្ញាតិឲ្យចូលទៅក្នុងទីកន្លែងគោរពសក្ការៈនោះឡើយ។ ក៏ប៉ុន្តែ គេបានបញ្ជាឲ្យ ស្ត្រីចូលទៅ កិនស្រូវនៅក្នុងព្រះវិហារ”[1440]។

## ១.៣. ការបំផ្លាញគម្ពីរកូរ៉ាន

706. ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន បានផ្តល់សក្ខីកម្មថា៖ “យើងត្រូវបានគេហាមឃាត់មិនឲ្យគោរព បូជា និងថ្វាយបង្គំព្រះ។ គម្ពីរកូរ៉ាន ត្រូវបានគេប្រមូល នឹងយកទៅដាក់នៅក្នុងមន្ទីររបស់ពួកគេ។ ប្រជាជនមិនត្រូវបានអនុញ្ញាតិឲ្យអានគម្ពីរកូរ៉ាននោះឡើយ។ គម្ពីរកូរ៉ានគ្រប់ខ្នាតទាំងអស់ត្រូវបាន ដកហូត”[1441]។

707. ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ បានពន្យល់ថា៖ “នៅឆ្នាំ១៩៧៥ នៅពេលយើងត្រូវគេជម្លៀស ពួកគេបានប្រមូលគម្ពីរកូរ៉ាន ហើយពួកគេបានបោសសម្អាតភូមិ។ យើងមិនត្រូវបានអនុញ្ញាតិឲ្យ រក្សាទុកគម្ពីរកូរ៉ាន នោះឡើយ។ ខ្ញុំមិនដឹងថាពួកគេយកគម្ពីរកូរ៉ានទៅទុកនៅទីកន្លែងណា នោះ

[1440] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/349.1** ទំព័រ ៧៣ បន្ទាត់ ១៤-១៩។ តបទៅនឹងសំណួររបស់មេធាវី នូន ជា ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន បានគូសបញ្ជាក់ថា “មានឆ្នាំនៅវិហារចាមពីព្រោះទីនោះគេមិនអនុញ្ញាតឲ្យធ្វើជាកន្លែងគោរពបូជាឡើយ ហើយអ្នកសម្លៀងកាំបិត ត្រូវបានដាក់នៅក្នុងវិហារនោះ។ មានឆ្នាំ។ ពីព្រោះមានឆ្នាំ ខ្ញុំគិតថាប្រហែលជាមានអាវុធរបស់ឆ្នាំទាំងនោះ ដូច្នេះខ្ញុំក៏បាន សម្រេចចិត្តទៅវិហារដើម្បីស្វែងរកអាវុធ។ ខ្ញុំបានឃើញឆ្នាំនៅវិហារនោះដេកក្នុងវិហារ។ ខ្ញុំប៉ះក្បាលរបស់គាត់ ប៉ុន្តែគាត់មិនដឹង ថាខ្ញុំកំពុងប៉ះក្បាលរបស់គាត់ទេ។ ក្នុងវិហារនោះ ខ្ញុំគ្មានឃើញអាវុធទេ។ ប្រសិនបើមានអាវុធមួយ ឬបី ខ្ញុំនឹងយកវាទៅជួយ ប្រជាជនខ្ញុំ ប្រជាជនចាម” ហើយ “វិហារនេះស្ថិតនៅភូមិតាស្វ៊ូ ជិតពាមជីកង។ វានៅជិត-វាស្ថិតនៅជាប់ពាមជីកង។ ជាថ្មី ទៀត វិហារនោះស្ថិតក្នុងភូមិតាស្វ៊ូ” សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៣១ បន្ទាត់ ៥-១៩។

[1441] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ១០៤ បន្ទាត់ ១៨-២១។

ឡើយ”[1442]។ “គម្ពីរកូរ៉ានត្រូវបានប្រមូលដុតចោល យើងមិនត្រូវបានគេអនុញ្ញាតិឱ្យរក្សាទុកគម្ពីរកូរ៉ាននោះឡើយ”[1443]។

## ១.៤. ការហាមឃាត់ការថ្វាយបង្គំព្រះ

708. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន បានផ្តល់សក្ខីកម្មថា៖ “យើងមិនត្រូវបានគេអនុញ្ញាតិឱ្យថ្វាយបង្គំព្រះ ហើយយើងត្រូវគេបង្ខំឱ្យហូបសាច់ជ្រូក។ យើងមិនត្រូវបានគេអនុញ្ញាតិឱ្យថ្វាយបង្គំព្រះ ឬគោរពបូជា នោះឡើយ ហើយប្រសិនបើអ្នកណាម្នាក់ព្យាយាមលួចធ្វើបែបនោះ ជាសម្ងាត់ ហើយត្រូវគេចាប់បាន អ្នកនោះនឹងបាត់ខ្លួន”[1444]។

709. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន បានពន្យល់អំពីមូលហេតុដែលគាត់គិតថា ប្រជាជនចាមត្រូវបានគេនាំយកទៅវត្តអូរត្រកួន។ “វាពាក់ព័ន្ធនឹងសាសនារបស់ពួកយើង។ សម្រាប់ពួកយើង ពួកយើងថ្វាយបង្គំព្រះអាឡោះ ទោះបីជាមានការហាមឃាត់ដោយពួកខ្មែរក្រហមក៏ដោយ។ យើងធ្វើវាដោយសម្ងាត់។ នៅពេលនោះ ពួកឈ្លបឃ្លាំមើលពួកយើងគ្រប់ពេលវេលា ហើយជាការពិត ពួកគេមិនបានប្រាប់យើងថាអ្នកនេះ ឬអ្នកនោះ ត្រូវបានគេនាំយកចេញទៅ ដោយសារតែគេឃើញថ្វាយបង្គំព្រះអាឡោះ នោះឡើយ ហើយនេះគឺជាការសន្និដ្ឋានរបស់យើងដែលថា យើងត្រូវបានឃ្លាំមើលដោយពួកឈ្លប ហើយប្រសិនបើអ្នកណាម្នាក់ក្នុងចំណោមពួកយើងត្រូវបានរកឃើញថាថ្វាយបង្គំព្រះអាឡោះ នោះជីវិតពួកយើងនឹងមានគ្រោះថ្នាក់ ដោយសារគេអាចមកនាំយកយើងចេញទៅដោយភ្ជង់នឹងកាំភ្លើង នៅពេលហូបបាយ។ ក៏ប៉ុន្តែ នេះគឺជាការសន្និដ្ឋានផ្ទាល់ខ្លួនរបស់ខ្ញុំ ពីព្រោះពួកគេមិនបានប្រាប់យើងអំពីមូលហេតុនោះឡើយ នៅពេលពួកគេមកនាំយកមនុស្សចេញទៅដោយភ្ជង់នឹងកាំភ្លើង ខណៈពេលពួកយើងកំពុងហូបបាយ។ ដូចខ្ញុំបានរៀបរាប់ខាងលើ នៅ

---

[1442] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាខ៖ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៨០ បន្ទាត់ ៤-៧។

[1443] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាខ៖ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ៧៩ បន្ទាត់ ២៣-២៤។

[1444] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៤០ បន្ទាត់ ១៦-១៨។

ពេលនោះ មនុស្សគ្រប់រូបចាំយ៉ាងច្បាស់នូវពាក្យស្លោកដែលថា កង់ប្រវត្តិសាស្ត្រកំពង់វិល ប្រសិនបើអ្នកណារាំងកង់ប្រវត្តិសាស្ត្រនឹងត្រូវកិនខ្ទេច"[1445]។

710. ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ បានផ្តល់សក្ខីកម្មថា នៅពេល "ខ្ញុំត្រូវបានគេចាត់តាំងឱ្យទៅរស់នៅក្នុងតំបន់ខ្សាច់ប្រឆេះលើ ខ្ញុំរស់នៅក្នុងផ្ទះមីង អ៊ួយ។ មានកិច្ចប្រជុំរៀងរាល់ខែ ឬលឿនជាងនេះ ហើយយើងត្រូវបានគេប្រាប់មិនឱ្យនិយាយភាសាចាម។ សាសនារបស់យើងត្រូវបានលុបបំបាត់ ហើយយើងត្រូវបានគេហាមឃាត់មិនឱ្យគោរពប្រតិបត្តិសាសនារបស់យើង ហើយយើងមិនត្រូវបានគេអនុញ្ញាតិឱ្យសូត្រធម៌ នោះឡើយ។ យើងមិនត្រូវបានគេអនុញ្ញាតិឱ្យរៀនធម៌ នោះឡើយ"។[1446]

## ១.៥. ការបង្ខំជនជាតិចាមឱ្យហូបសាច់ជ្រូក

711. ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន បានផ្តល់សក្ខីកម្មថា៖ "នៅឆ្នាំ១៩៧៥ របបនោះចាប់ផ្តើមដាក់កំហិតលើសាសនារបស់យើង បង្ខំឱ្យហូបសាច់ជ្រូក ការថ្វាយបង្គំព្រះនិងការហូបអាហារបួសប្រចាំថ្ងៃ និងរឿងរ៉ាវជាច្រើនផ្សេងទៀតដែលប៉ះពាល់ដល់អត្តសញ្ញាណជនជាតិចាម"[1447]។

---

[1445] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/349.1** ទំព័រ ៣៩ បន្ទាត់ ១៨-ទំព័រ៤០ បន្ទាត់ ៦។ ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ក៏រម្លឹកនៅថ្ងៃនោះថាប្រជាជនចចាមត្រូវបានប្រមូលផ្តុំ "ហើយបន្ទាប់មក ប្រជាជនចាមមិនត្រូវបានអនុញ្ញាតឱ្យទៅធ្វើការនៅស្រែឡើយ ប៉ុន្តែត្រូវស្នាក់នៅក្នុងផ្ទះរៀង១ខ្លួន ចំណែកខ្មែរត្រូវបានអនុញ្ញាតឱ្យធ្វើការនៅស្រែ។ ដូច្នេះ ប្រជាជនចាមដែលសេសសល់ពីការជម្លៀសត្រូវបានប្រាប់ឱ្យនៅផ្ទះ ហើយខ្ញុំឆ្ងល់ថាមានអ្វីកំពុងកើតឡើ ប៉ុន្តែមិនត្រូវបានអនុញ្ញាតឱ្យចេញពីផ្ទះឡើយ។ ហើយតាមពិតពួកគេចាប់ផ្តើមប្រមូលផ្តុំពួកយើងនៅម៉ោង ៣ រសៀល ហើយសមាជិកនៃមនុស្សទាំងនោះជាសមាជិកក្រុមដាវវែង។ ពួកគេពាក់ក្រមាបង់ករ ខ្លះស្លៀកខោ ហើយខ្លះអត់អាវ។ ខ្ញុំស្ថិតក្នុងចំណោមប្រជាជនចាមដែលត្រូវបានប្រមូលផ្តុំនិងនាំទៅកាន់រណ្តៅក្នុងវត្តអូរត្រកួន" សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/349.1** ទំព័រ ៤៤ បន្ទាត់ ២២ – ទំព័រ ៤៥ បន្ទាត់ ៨។

[1446] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៥៣ បន្ទាត់ ៥-១៣។

[1447] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៧១ បន្ទាត់ ១៥-១៧។

712. ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ាន ស្លេះ បានផ្ដល់សក្ខីកម្មថា៖ "យើង ដែលជាជនជាតិចាម ត្រូវបានហាមឃាត់មិនឱ្យហូបសាច់ជ្រូក ប៉ុន្តែនៅពេលពួកគេចំអិនអាហារ ឬដាំបបរ ពួកគេដាក់សាច់ជ្រូកនិងប្រេងនៅក្នុងបបរ។ នៅពេលគេផ្ដល់ឱ្យយើងនូវសាច់ជ្រូកជាមួយបបរ យើងបានព្យាយាមចាក់ទឹកបបរចោលនិងហូបតែគ្រាប់អង្ករ។ អ្នកខ្លះមិនអាចអត់ទ្រាំនឹងក្លិនសាច់ជ្រូក ចំណែកឯអ្នកផ្សេងទៀតបានព្យាយាមហូបដើម្បីរស់។ ខ្ញុំផឹកតែទឹកបបរដើម្បីរស់"[1448]។

713. ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន បានពន្យល់ថា៖ "យោងតាមអត្ថបទដ៏សក្តិសិទ្ធរបស់ព្រះអាឡោះ ចំពោះអាហារដែលយើងមិនត្រូវហូប ក៏ប៉ុន្តែ ប្រសិនបើត្រូវគេបង្ខំដោយភ្លង់នឹងកាំភ្លើងយើងអាចនឹងហូបដើម្បីមានជីវិតរស់ ហើយខ្ញុំជឿថាមានប្រជាជនចាមមួយចំនួនពិតជាបានហូបសាច់ជ្រូក។ នៅពេលនោះ គេគម្រាមយើងថា ប្រសិនបើយើងមិនហូបសាច់ជ្រូក គេនឹងបាញ់សម្លាប់ពួកយើង។ អ្នកខ្លះបានយំនៅពេលហូបសាច់ជ្រូក។ សាច់ដែលខ្ញុំលើកឡើងនៅទីនេះ គឺសាច់ជ្រូក។ ខ្ញុំឆ្លើយបែបនេះ ដោយសារខ្លួនខ្ញុំផ្ទាល់ត្រូវបង្ខំចិត្តហូបសាច់ជ្រូក បើមិនដូច្នោះទេខ្ញុំនឹងត្រូវគេបាញ់សម្លាប់"[1449]។

714. ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន បានពិពណ៌នាថា៖ "ខ្ញុំនៅក្នុងក្រុមមនុស្សនោះ។ ប្រសិនបើខ្ញុំបដិសេធមិនហូបសាច់ជ្រូក ខ្ញុំខ្លាចពួកគេបាញ់ ខ្ញុំអាចនឹងត្រូវគេបាញ់ ឬ ខ្ញុំនឹងត្រូវគេវាយនឹងដំបង។ វាកើតចំពោះអ្នកដ៏ទៃផ្សេងទៀតផងដែរ។ ប្រសិនបើយើងមិនព្រមហូបសាច់ជ្រូក ជីវិត

[1448] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ាន ស្លេះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៦៥ បន្ទាត់ ២០-២៥។

[1449] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/349.1** ទំព័រ ៤១ បន្ទាត់ ១-៨។

ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន បានផ្ដល់សក្ខីកម្មថារយៈកាលនៃការធ្វើបាបនេះគឺ "ខ្ញុំគិតថាវាបានកើតឡើងក្នុងខ្ទង់ឆ្នាំ ១៩៧៦។ ខ្ញុំគិតដូច្នេះ គឺ១៩៧៦។ កាលណោះ យើងមិនមានអ្វីដើម្បីសម្គាល់កាលបរិច្ឆេទ ឬឆ្នាំឡើយ ពីព្រោះនោះជាអ្វីដែលខ្ញុំសន្មតគឺក្នុងឆ្នាំ ១៩៧៦" សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/349.1** ទំព័រ ៤២ បន្ទាត់ ៤-៧។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ក៏បានផ្ដល់សក្ខីកម្មអំពីវិធីដែលគោលនយោបាយកម្ពុជាប្រជាធិបតេយ្យបានប៉ះពាល់មកលើគ្រប់ផ្នែកនៃការរស់នៅរបស់ប្រជាជនចាម។ "ប្រជាជនត្រូវគេបង្ខំឱ្យបរិភោគសាច់ជ្រូក។ សាសនាត្រូវបានលុបបំបាត់។ ហើយយើងត្រូវបានហាមឃាត់មិនឱ្យសូត្រធម៌ ថ្វាយបង្គំព្រះ។ សាច់ជ្រូកគេអោយយើងទាំងអស់គ្នាបរិភោគ" សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ១៤ បន្ទាត់ ២-៤។

របស់យើងនឹងមានគ្រោះថ្នាក់។ យើងត្រូវហូបសាច់ជ្រូកទាំងទឹកភ្នែក។ មានត្រីជាច្រើន ប៉ុន្តែគេបង្ខំឲ្យយើងហូបសាច់ជ្រូក ពីព្រោះគេនិយាយថា មានជាតិខ្មែរតែមួយប៉ុណ្ណោះ នៅក្នុងសម័យនោះ[1450]។

715. ដើមបណ្ដឹងរដ្ឋប្បវេណី នោ សាទះ បានពិពណ៌នាថានៅពេលគាត់ត្រូវបានគេបញ្ជូនឲ្យទៅធ្វើការនៅក្នុងកងចល័តនៅបឹងក្រចាបដើម្បីលើកទំនប់ "យើងត្រូវបានគេបង្ខំឲ្យហូបសាច់ជ្រូក ប៉ុន្តែយើងមិនអាចហូបបាន ខ្ញុំហូបតែបបរជាមួយនឹងអំបិល។ ពួកគេមិនចម្អិនអាហារសម្រាប់ពួកយើងដាច់ដោយឡែកនោះឡើយ។ ពួកគេចម្អិនសម្លលាយជាមួយសាច់ជ្រូក ហើយពួកយើងខ្លះអាចហូបសម្លនោះ ចំណែកអ្នកផ្សេងទៀតមិនហូបនោះឡើយ ខ្លួនខ្ញុំផ្ទាល់មិនអាចហូបបាន ដូច្នេះខ្ញុំហូបអំបិលជាមួយបបរ"[1451]។

716. ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ើ ពៅ បានរម្លឹកបន្ថែមថា៖ "ឪពុករបស់ខ្ញុំបានស្លាប់ដោយសារគាត់គឺជាជនជាតិចាមដែលគោរពប្រត្តិបត្តិសាសនារបស់គាត់យ៉ាងខ្ជាប់ខ្ជួន ហើយគាត់មិនបោះបង់សាសនារបស់គាត់នៅពេលអង្គការបង្ខំគាត់។ ពួកគេបានបង្ខំឲ្យគាត់ហូបសាច់ជ្រូក ប៉ុន្តែគាត់បានប្រកែក ហេតុដូច្នេះ អង្គការបានព្រមានគាត់ជាលើកចុងក្រោយថាគាត់ត្រូវហូបសាច់ជ្រូក ហើយប្រសិនបើគាត់មិនអាចហូបសាច់ជ្រូក នោះគាត់នឹងគ្មានអ្វីហូបទៀតទេ។ ឪពុករបស់ខ្ញុំប្រកែកមិនព្រមហូបសាច់ជ្រូក ហើយគាត់ផឹកតែទឹក។ គាត់ត្រូវលួចស្វែងរកស្លឹកឈើនៅក្នុងព្រៃយកមកហូប ការរស់នៅក្នុងស្ថានភាពបែបនេះ ពិតជាលំបាកសម្រាប់គាត់។ ខ្ញុំគិតថាវាជាការប្រសើរជាង ប្រសិនបើគេសម្លាប់គាត់ ដោយមិនទុកឲ្យគាត់ទទួលរងនូវស្ថានភាពដ៏អាក្រក់បែបនេះ។ ពួកគេប្រើប្រាស់ករណីរបស់គាត់ ធ្វើជាឧទាហរណ៍ដើម្បីបំភ័យប្រជាជនចាមផ្សេងទៀត។ នៅពេលនោះហើយដែលរាងកាយរបស់គាត់បានស្គមស្គាំងខ្លាំង។ គាត់រស់នៅតែម្នាក់ឯង ហើយគាត់បានស្លាប់តែម្នាក់

---

[1450] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ១៥ បន្ទាត់ ៣-៩។

[1451] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៥៤ បន្ទាត់ ១៩-២៣។

ឯងដោយគ្មានវត្តមានសមាជិកគ្រួសារណាម្នាក់។ ខ្ញុំមិនដឹងថាសាកសពរបស់គាត់ត្រូវបានគេកប់នៅទីកន្លែងណាឡើយ"[1452]។

717. ដើមបណ្តឹងរដ្ឋប្បវេណី ឡិប នាង បានរៀបរាប់អំពីការធ្វើការងារនៅសហករណ៍ត្រាំកក់ ដែលនៅទីនោះ គាត់បាន "ហូបបបរជាមួយសាច់ជ្រូក គេឃើញថាពួកខ្ញុំខាងសាសន៍ខ្ញុំគេឲ្យអត់ហូប គេធ្វើខាងហ្នឹងឲ្យហូប គេកាប់អីចឹងទៅ យកមកបបរឲ្យពួកសាសន៍ខ្ញុំហូបទៅ។ ជួនណាស្លជាមួយត្រកួនអីចឹងទៅ ជួនណាបបរដាក់ជាមួយសាច់ហ្នឹងឲ្យពួកខ្ញុំហូបទៅ។ ពួកនាងខ្ញុំអត់ហូបអាហ្នឹង បង្ខំឲ្យខ្ញុំ ពួកនាងខ្ញុំហូបអាហ្នឹង។ បបរទឹកកក្លកដាក់លាយឲ្យពួកនាងខ្ញុំហូប។ ហើយសាសន៍ខ្ញុំអត់ហូប អាហ្នឹង"[1453]។

## ១.៦. ការហាមឃាត់ការទទូរក្បាល និង ការកាត់សក់

718. ដើមបណ្តឹងរដ្ឋប្បវេណី ម៉ើ ពៅ បានផ្តល់សក្ខីកម្មថា៖ "នៅក្នុងឆ្នាំ១៩៧៥ សហករណ៍បានប្រកាសឲ្យប្រជាជនចាមកាត់សក់ខ្លី និងមិនត្រូវទទូរក្បាល ដោយមិនប្រើក្រមាគ្របលើក្បាលរបស់ពួកគេ។ យើងត្រូវបានគេបង្ខំមិនឲ្យរស់នៅជាក្រុម យើងត្រូវបានជម្លៀសពីភូមិមួយទៅភូមិមួយទៀត ឬពីសហករណ៍មួយទៅសហករណ៍មួយទៀត។ នៅពេលនោះ ខ្ញុំបានបាត់បង់ការទំនាក់ទំនងជាមួយនឹងសមាជិកគ្រួសាររបស់ខ្ញុំ"[1454]។

719. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន បានពិពណ៌នាថា នៅពេលជនជាតិចាមត្រូវបានចាប់ខ្លួន "មនុស្សម្នាក់ៗបានកាត់សក់ខ្លីដូចប្រជាជនខ្មែរដែរ។ នៅពេលនោះ ពួកគេនិយាយថាត្រូវមានជាតិ

---

[1452] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ើ ពៅ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ១១ បន្ទាត់ ១២-ទំព័រ ១២ បន្ទាត់ ២។

[1453] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី លីប នាង ប្រតិចារឹក ថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០១៥ ឯកសារ **E1/288.1** ទំព័រ ៨៧ បន្ទាត់ ៥-៩។

[1454] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ើ ពៅ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៨ បន្ទាត់ ២-៧។

តែមួយតែប៉ុណ្ណោះនៅកម្ពុជា។ នៅពេលពួកយើងត្រូវបានគេនាំយកទៅសម្លាប់យ៉ាងច្រើន ពួកយើងបាននាំគ្នាកាត់សក់ខ្លី ហើយយើងមិនត្រូវបានគេអនុញ្ញាតិឲ្យទទូរក្បាលនោះឡើយ”[1455]។

720. ដើមបណ្ដឹងរដ្ឋប្បវេណី សុះ មីន បានផ្ដល់សក្ខីកម្មថា “ការដាក់កំហិតត្រូវបានអនុវត្តចំពោះស្ទើរគ្រប់ទិដ្ឋភាពនៃជីវិតទាំងអស់ ដូចជា អាហារ ការស្លៀកពាក់ និងស្ត្រី ដោយស្ត្រីចាមត្រូវបានគេបង្ខំឲ្យកាត់សក់ខ្លី។ ហេតុដូច្នេះ ជីវិតរបស់យើងពិតជាលំបាកខ្លាំងណាស់”[1456]។

721. ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន បានពន្យល់ថា “យើងត្រូវបានគេប្រាប់ឲ្យកាត់សក់ខ្លីដោយខ្លួនឯង ឬឲ្យគេកាត់សក់ឲ្យ។ យើងត្រូវបានគេហាមឃាត់មិនឲ្យថ្វាយបង្គំព្រះ ឬគោរពបូជា។ នេះគឺជាអ្វីដែលខ្ញុំបានដឹង។ នាពេលក្រោយមក ស្ថានភាពកាន់តែអាក្រក់ជាងនេះ”[1457]។ “យើងត្រូវបានគេហៅឲ្យទៅចូលរួមការប្រជុំមួយ ហើយគេប្រាប់យើងថា យើង ដែលជាជនជាតិចាម ត្រូវកាត់សក់ខ្លី និងមិនត្រូវទទូរក្បាលរបស់យើងដោយក្រមា ឬសូត្រធម៌ប្រចាំថ្ងៃ នោះឡើយ ហើយយើងត្រូវហូបសាច់ជ្រូក។ ពាក់ព័ន្ធទៅនឹងសាសនាអ៊ីស្លាមរបស់យើង គេបានហាមឃាត់យើងមិនឲ្យគោរពប្រណិប័តន៍សាសនារបស់យើងឡើយ[1458]”។

## ១.៧. ការបាត់បង់សិទ្ធិជួបជុំសម្រាប់ប្រជាជនចាម

[1455] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៤០ បន្ទាត់ ២២-ទំព័រ ៤១ បន្ទាត់ ១។ ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ក៏បានផ្ដល់សក្ខីកម្មថា “មុនរបបនេះដួលរលំ យើងមិនអាចស្លៀកសម្លៀកបំពាក់ប្រពៃណីចាមបានឡើយ។ យើងត្រូវស្លៀកពាក់ដូចប្រជាជនខ្មែរ ហើយយើងក៏ត្រូវកាត់សក់ឲ្យដូចប្រជាជនខ្មែរដែរ។ គេមិនអនុញ្ញាតឲ្យយើងសូត្រធម៌ឡើយ ហើយគេបានបង្ខំឲ្យយើងបរិភោគសាច់ជ្រូក។ យើងមិនត្រូវបានអនុញ្ញាតឲ្យសូត្រធម៌ថ្វាយបង្គំព្រះទៀតឡើយ ហើយប្រសិនបើនរណាម្នាក់ ព្យាយាមធ្វើវាដោយសម្ងាត់ ហើយគេចាប់បានអ្នកនោះនឹងបាត់ខ្លួន” សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៤០ បន្ទាត់ ១២-១៨។

[1456] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៧១ បន្ទាត់ ២៥-ទំព័រ ៧២ បន្ទាត់ ៣។

[1457] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ១៤ បន្ទាត់ ៧-៩។

[1458] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/349.1** ទំព័រ ៣៧ បន្ទាត់ ១៧-២១។

722. ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ បានបញ្ជាក់ថា ក្រោយការបះបោរ នៅពេលគាត់ត្រូវបានគេជម្លៀសទៅកាន់ភូមិខ្មែរ "នៅពេលនោះ ពួកយើងមិនត្រូវបានគេអនុញ្ញាតិឱ្យជួបប្រជុំគ្នាជាក្រុមដែលមានគ្នាបី ឬបួននាក់នោះឡើយ លុះត្រាតែមានប្រជាជនខ្មែរម្នាក់នៅក្នុងក្រុមនោះ ប្រសិនបើយើងប៉ានជួបជុំជាក្រុមដែលមានគ្នាបី ឬបួននាក់ដោយគ្មាន ប្រជាជនខ្មែរ នៅក្នុងក្រុមនោះ យើងនឹងត្រូវចាត់ទុកថាជាខ្មាំង"[1459]។

## ១.៨. ការហាមឃាត់ការនិយាយភាសាចាម

723. ដើមបណ្តឹងរដ្ឋប្បវេណី ម៉ើ ពៅ បានផ្តល់សក្ខីកម្មអំពីរបៀបដែល "ពួកយើងត្រូវបានគេបង្ខំឱ្យបោះបង់សាសនារបស់យើង និងមិនឱ្យប្រើប្រាស់ភាសាចាម។ ប្រសិនបើអ្នកណាម្នាក់ និយាយភាសារបស់យើង អង្គការនឹងនាំយកអ្នកនោះទៅសម្លាប់ ហើយពួកយើងមានការភ័យខ្លាច។ យើងគ្មានអ្វីនៅសេះសល់ នោះឡើយនៅក្នុងរបបនោះ"[1460]។

724. ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន ពិពណ៌នាអំពីផលប៉ះពាល់នៃការហាមឃាត់ជនជាតិចាមមិនឱ្យនិយាយភាសាចាមជាមួយកូនៗរបស់ខ្លួន "យើងមិនត្រូវបានគេអនុញ្ញាតិឱ្យនិយាយភាសាចាម។ ហេតុដូច្នេះ កូនក្មេងមិនអាចយល់ភាសាចាម"[1461]។

## ២. គោលនយោបាយមកពីថ្នាក់លើ៖ ជនជាតិចាមត្រូវគេចាត់ទុកថាជាខ្មាំង

725. ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន បានពន្យល់អំពី "គោលការណ៍" ដែលដាក់ចេញដោយអង្គការ "យើងត្រូវបានគេបង្ខំឱ្យហូបអាហារដែលយើងមិនអាចហូបបាន។ ប្រសិនបើយើងមិនហូប

---

[1459] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោះ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៨២ បន្ទាត់ ៤-៨។

[1460] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មើ ពៅ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៧ បន្ទាត់ ១៥-១៨។

ដើមបណ្តឹងរដ្ឋប្បវេណី មើ ពៅ បានរម្លឹកអំពីព្យសនកម្មនៃការបាត់បង់សមត្ថភាពនិយាយភាសាចាម "សម្រាប់ការសន្ទនាប្រចាំថ្ងៃ ខ្ញុំអាចនិយាយភាសាខ្មែរបានល្អជាងភាសាចាម" សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មើ ពៅ ប្រតិចារឹក ឯកសារ **E1/393.1** ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ទំព័រ ២១ បន្ទាត់ ១២-១៣។

[1461] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៩៤ បន្ទាត់ ១-៣។

យើងនឹងត្រូវគេចោទប្រកាន់ថាមិនបោះបង់ការគោរពប្រតិបត្តិសាសនារបស់យើង ហើយយើងអាចនឹងត្រូវគេតាមដាន។ ប្រសិនបើយើងប្រឆាំងនឹងគោលការណ៍ដែលគេបានដាក់ នោះយើងនឹងត្រូវគេចោទថាជាខ្មាំងរបស់អង្គការ"[1462]។ ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន បានពន្យល់បន្ថែមថា៖ "ពួកគេមានគោលការណ៍ និងបទបញ្ជារបស់ពួកគេ។ ហើយនៅពេលណា ពួកគេចង់ដាក់បទបញ្ជាទាំងនោះ គេនឹងហៅយើងទៅប្រជុំ ហើយប្រកាសផ្សព្វផ្សាយបទបញ្ជាទាំងនោះ ដែលនឹងត្រូវអនុវត្តនៅពេលបន្ទាប់មក។ ជាទូទៅ ប្រធានសហករណ៍ ឬ ប្រធានឃុំ នឹងប្រកាសបទបញ្ជាបែបនោះ"[1463]។ ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន បានពន្យល់បន្ថែមថា "គោលនយោបាយ និងសេចក្តីណែនាំ ដែលហាមឃាត់សិទ្ធិ សេរីភាព សាសនា និងសកម្មភាពផ្សេងៗទៀត មិនមែនចេញមកពីប្រធានភូមិ នោះឡើយ ប៉ុន្តែគោលនយោបាយ និងសេចក្តីណែនាំទាំងនោះ សុទ្ធតែចេញមកពីថ្នាក់លើ ដោយរួមមានថ្នាក់ស្រុក ហើយគោលនយោបាយ និងសេចក្តីណែនាំទាំងនោះ ចុះមកតាមថ្នាក់ភូមិ។ ប្រធានភូមិ មិនមានសមត្ថភាពផ្សព្វផ្សាយសេចក្តីណែនាំទាំងនោះ នោះឡើយ។ ជាទូទៅ មនុស្សមកពីថ្នាក់លើ មករៀបចំការប្រជុំ និងផ្សព្វផ្សាយគោលនយោបាយ និងសេចក្តីណែនាំទាំងនោះ"[1464]។

726. ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ បានផ្តល់សក្ខីកម្មថា "គឺអង្គការ។ អង្គការត្រូវបានគេជឿថាមកពីថ្នាក់លើបំផុត។ អង្គការហាមឃាត់យើងទាំងអស់គ្នាមិនឱ្យទទូរក្បាល ឬស្លៀកពាក់សម្លៀកបំពាក់ប្រពៃណី និងគោរពបូជា ហើយយើងត្រូវបានគេបញ្ជាឱ្យកាត់សក់ខ្លី យើងមិនត្រូវបានគេអនុញ្ញាតិឱ្យប្រតិបត្តិ ឬប្រើប្រាស់ គម្ពីរកូរ៉ាន នោះឡើយ អង្គការពីថ្នាក់លើបានបញ្ជាការហាមឃាត់បែបនេះ។ ខ្ញុំមិនដឹងថានណារគឺជាអង្គការ នោះឡើយ ប៉ុន្តែ ខ្ញុំគ្រាន់តែដឹងថា គឺអង្គការ[1465]។ ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ បានពន្យល់បន្ថែមថា៖ "គេប្រាប់យើងនៅក្នុងកិច្ចប្រជុំ

[1462] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/343.1 ទំព័រ ៧២ បន្ទាត់ ៨-១២។

[1463] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/343.1 ទំព័រ ៧២ បន្ទាត់ ១៩-២៣។

[1464] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/344.1 ទំព័រ ១៧ បន្ទាត់ ១៥-២២។

[1465] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/350.1 ទំព័រ ៨១ បន្ទាត់ ៧-១២។

គេហៅយើងទៅប្រជុំ ហើយប្រសិនបើអ្នកណាម្នាក់ហ៊ានប្រកែកមិនគោរពតាមបញ្ជា យើងនឹងត្រូវគេចាត់ទុកថាក្បត់អង្គការ"[1466]។ គាត់ចងចាំថាអ្នកនិយាយនៅក្នុងអង្គប្រជុំ គឺ "ប្រធានឃុំ ប្រធានភូមិ អនុប្រធានភូមិ និងសមាជិកគណៈភូមិ។ ប្រជាជននៅក្នុងភូមិត្រូវបានគេប្រាប់អំពីបទបញ្ជាទាំងនោះ ហើយប្រសិនបើគេមិនគោរពតាមបទបញ្ជា ពួកគេនឹងត្រូវចាត់ទុកថាជាខ្មាំង"[1467]។

727. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន បានផ្តល់សក្ខីកម្មថា៖ "ពួកយើងត្រូវបានគេហៅទៅប្រជុំ ហើយយើងត្រូវបានគេប្រាប់ថា យើង ដែលជាជនជាតិចាម ត្រូវកាត់សក់ មិនត្រូវទទូរក្បាលនឹងក្រមា និងមិនត្រូវសូត្រធម៌ប្រចាំថ្ងៃនោះឡើយ ប៉ុន្តែយើងត្រូវហូបសាច់ជ្រូក។ ចំពោះអ្វីៗគ្រប់យ៉ាងដែលពាក់ព័ន្ធនឹងសាសនាអ៊ីស្លាម យើងត្រូវបានគេហាមឃាត់មិនឲ្យគោរពប្រតិបត្តិសាសនា ហើយនៅពេលនោះ យើងត្រូវបានគេប្រាប់ថា កង់ប្រវត្តិសាស្ត្រកំពុងតែវិល ប្រសិនបើយើងដាក់ដៃ ឬជើងចូលដើម្បីបញ្ឈប់កង់ប្រវត្តិសាស្ត្រ នោះដៃជើងរបស់យើងនឹងត្រូវកាត់ដាច់ដោយកង់ប្រវត្តិសាស្ត្រ"[1468]។

728. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន បានផ្តល់សក្ខីកម្មថា៖ "ពាក្យចចាមអារ៉ាមមួយត្រូវបានផ្សព្វផ្សាយពេញទូទាំងភូមិថា ប្រជាជនចាមគឺជាខ្មាំងទី១ របស់របបនោះ ហើយប្រជាជនខ្មែរ គឺជាខ្មាំងទី២។ នៅពេលនោះ ខ្លួនខ្ញុំផ្ទាល់ ឆ្ងល់អំពីរឿងនោះ ហើយខ្ញុំបានសួរមនុស្សម្នាក់ដែលខ្ញុំមិនចាំឈ្មោះ ហើយគាត់គឺជាជនជាតិខ្មែរ ដោយមិនមែនជាជនជាតិចាមនោះទេ។ ខ្ញុំបានសួរគាត់ថាហេតុអ្វីប្រជាជនចាមត្រូវបានគេចាត់ទុកថាជាខ្មាំងទី១ ហើយគាត់បាននិយាយថាដោយផ្អែកលើសវតាប្រវត្តិសាស្ត្រតាំងពីការចាប់កំណើតព្រះអាឡោះ ប្រជាជនចាម មានចិត្តលោភលន់ក្នុងការធ្វើសឹកសង្គ្រាម ហើយនោះគឺជាអ្វីដែលខ្ញុំបានឮពីប្រជាជនខ្មែរម្នាក់នោះ។ ពាក្យចចាមអារ៉ាមនោះត្រូវបានផ្សព្វផ្សាយពាសពេញភូមិ។ នៅពេលក្រោយមក ខ្ញុំសង្កេតឃើញថា ប្រជាជនចាមត្រូវបានគេចាប់

[1466] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៨១ បន្ទាត់ ១៥-១៧។

[1467] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៨១ បន្ទាត់ ១៨-២២។

[1468] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/349.1** ទំព័រ ៣៧ បន្ទាត់ ១៧-២៤។

ខ្លួន។ ក៏ប៉ុន្តែ នៅក្នុងចិត្តរបស់ខ្ញុំ នៅពេលនោះ ខ្ញុំនៅតែឆ្ងល់ថាហេតុអ្វីបានជាជនជាតិចាមត្រូវបានគេចាត់ទុកថាជាខ្មាំងទី១"[1469]។

## គ. ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងនឹងការបះបោររបស់ប្រជាជនចាមនៅស្វាយឃ្លាំង និងផលវិបាករបស់វា

### ១. ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល

729. ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានបង្ហាញនៅសវនាការ បង្ហាញថាប្រជាជនចាម ត្រូវបានសម្លាប់នៅក្នុងអំឡុងការបះបោរនៅស្វាយឃ្លាំងក្នុងខែ តុលា ឆ្នាំ ១៩៧៥។

730. ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ បានផ្តល់សក្ខីកម្មថាប្រជាជនចាមជាច្រើនបានស្លាប់ក្នុងអំឡុងការបះបោរនោះ។ គាត់បានផ្តល់សក្ខីកម្មថា "ខ្ញុំបានចូលរួមក្នុងការបះបោរនោះ និងប្រដាប់ដោយកាំបិតផ្គាក់ ហើយខ្ញុំបានចូលរួមជាមួយមនុស្សដទៃទៀត ប៉ុន្តែខ្ញុំនៅជួរក្រោយ។ ប្រជាជនជាច្រើនខ្ញុំចង់និយាយថាទាំងពីរភាគី យើង ប្រជាជនចាម និងខ្មែរក្រហម បានស្លាប់ក្នុងអំឡុងពេលបះបោរនោះ ប៉ុន្តែខ្មែរក្រហមមិនសូវស្លាប់ច្រើនឡើយ ពីព្រោះពួកគេមានអាវុធច្រើនជាងពួកយើង"[1470]។

731. ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេស បានផ្តល់សក្ខីកម្មបន្ថែមទៀតថា "ខ្ញុំអាចប្រាប់អ្នកត្រួសៗ។ វាដូចជាសមរភូមិមួយ ដែលទាហានពីរភាគីចូលរួមក្នុងសង្គ្រាម។ ប្រជាជនចាមមានតែកាំបិតផ្គាក់ ឬកាំបិត ដើម្បីបះបោរសម្រាប់ផលប្រយោជន៍របស់អាឡា។ ពួកគាត់ប៉ានបាត់បង់ជីវិតរបស់ពួក

[1469] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/349.1** ទំព័រ ៤២ បន្ទាត់ ១៣-២៥។

ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន បានបង្ហាញមន្ទិលដែលប្រជាជនចាមត្រូវបានចាត់ទុកជាសត្រូវទី១ "ក្រោយមក ប្រជាជនចាមត្រូវបានធ្វើបាបយ៉ាងធ្ងន់ធ្ងរ។

ហើយខ្ញុំមិនយល់មូលហេតុនៃការធ្វើបាបមកលើពួកគាត់និងមូលហេតុដែលគេចោទថាជាខ្មាំងទីមួយ។

ខ្ញុំមិនដឹងមូលហេតុពីក្រោយចំណុចនេះទេ។ ដូច្នេះពេលខ្ញុំបានឮអំពីវា ខ្ញុំឆ្ងល់ថាអ្វីទៅជាចេតនានៅពីក្រោយ។ សូម្បីតែសព្វថ្ងៃខ្ញុំនៅតែមិនយល់អំពីចេតនាពីក្រោយហេតុការណ៍ទាំងនោះ។ វាជារឿងសម្ងាត់របស់ពួកគេ ហើយខ្ញុំគ្មានផ្លូវដឹងទេ" សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៣៨ បន្ទាត់ ៤-១១។

[1470] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៥៦ បន្ទាត់ ៤-៨។

គាត់ បើទោះជាប្រជាជនចាមជាច្រើនបានស្លាប់បាត់ទៅហើយក៏ដោយ។ ស្រដៀងនេះ ខ្មែរក្រហមក៏បានស្លាប់ដែរ ក្នុងចំនួនតិច[1471]"។

732. ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន បានផ្តល់សក្ខីកម្មថា "ក្នុងអំឡុងពេលប្រយុទ្ធគ្នា ឬពេលបះបោរមនុស្សជាច្រើន--ពួកយើងជាច្រើននាក់បានស្លាប់។ ខ្ញុំមិនអាចប្រាប់អ្នកថាពួកយើងស្លាប់ប៉ុន្មាននាក់ឡើយ។ ខ្លះស្លាប់ក្នុងព្រៃក្បែរនោះ"[1472]។ ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន បានបញ្ជាក់លម្អិតថា "កាលណោះ នៅពេល ការប្រយុទ្ធគ្នា បានផ្ទុះឡើង ទាហានខ្មែរក្រហមប្រដាប់ដោយអាវុធផ្សេងៗ ចំណែកប្រជាជនចាមមានតែកាំភ្លើង២ដើម គឺកាំភ្លើងអាកាមួយដើម និងកាំភ្លើងកាប៊ីនមួយដើម។ ហើយបន្ថែមពីលើកាំភ្លើង២ដើមនេះ យើងមានដាវ និងកាំបិត"[1473]។ ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន បានបញ្ជាក់លម្អិតទៀតថា "ពួកគេមិនបានប្រើប្រាស់ត្រឹមតែអាវុធធុនស្រាលប៉ុណ្ណោះទេ គឺពួកគេថែមទាំងមានអាវុធធុនធ្ងន់ ផងដែរ។ សំឡេងផ្ទុះអាវុធបានធ្វើឲ្យត្រចៀករបស់យើងស្តាប់អ្វីមិនឮ។ ប៉ុន្តែខ្ញុំមិនអាចប្រាប់អ្នកថាតើគ្រាប់កាំភ្លើងប៉ុន្មានគ្រាប់ត្រូវបានបាញ់ឡើយ ឬថាតើមានអាវុធប៉ុន្មានប្រភេទដែលត្រូវបានប្រើប្រាស់ឡើយ។ ខ្ញុំមិនអាចសន្និដ្ឋានអំពីអាវុធទាំងនោះ និងចំនួនគ្រាប់កាំភ្លើងដែលបានបាញ់ឡើយ។ វាជាហេតុការណ៍ដ៏ធំមួយ។ យើងអាចឮស្នូរអាវុធទៅគ្រប់ទីកន្លែង"[1474] និងថា "ពួកគេមានសម្ភារៈគ្រប់គ្រាន់រួមបញ្ចូលទាំងនាវាចម្បាំង។ ពួកគេមានអាវុធជាច្រើនប្រភេទ។ កាលណោះ ពួកគេមិនចាំបាច់ប្រើទូកដើម្បីបាញ់មកលើពួកយើងឡើយ ពីព្រោះពួកយើងនៅលើដីដូចគ្នា"[1475]។

[1471] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៨១ បន្ទាត់ ១៧-២២។

[1472] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៨០ បន្ទាត់ ២៥- ទំព័រ ៨១ បន្ទាត់ ២។

[1473] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ១០៦ បន្ទាត់ ១៧-២១។

[1474] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៩៥ បន្ទាត់ ៦-៩។

[1475] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ១០៧ បន្ទាត់ ៥-៨។

## ២. ការចាប់ដាក់ពន្ធនាគារ

733. ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានបង្ហាញនៅសវនាការ បង្ហាញថាប្រជាជនចាមត្រូវបានដកហូតតាមទំនើងចិត្តនូវសេរីភាពរបស់ពួកគាត់ ដោយគ្មាននីតិវិធីត្រឹមត្រូវនៃច្បាប់បន្ទាប់ពីមានការបង្ក្រាបការបះបោរនោះ។

734. ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ បានរៀបរាប់អំពីវិធីដែល "ក្រោយការបះបោរមួយថ្ងៃនិងមួយយប់ ប្រជាជនចាមយើងបានទម្លាក់អាវុធ ហើយយើងបានចាញ់ ហើយខ្មែរក្រហមបានរៀបចំពួកយើងឲ្យចូលទៅក្នុងឡថ្នាំ ចំណែកស្ត្រី និងកុមារត្រូវបានដាក់ក្នុងវត្តដើមជ្រៃ"[1476]។ ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ បានពន្យល់អំពីវិធីដែលភូមិនេះត្រូវបានជម្លៀស៖ "ក្នុងអំឡុងការបះបោរ មានទាហានឯកសណ្ឋានខ្មៅ និងប្រដាប់ដោយអាវុធ។ យើងត្រូវបានជម្លៀសពីភូមិរបស់យើង។ បុរសត្រូវបានដាក់ទៅក្នុងឡថ្នាំ ហើយស្ត្រីត្រូវបានដាក់ក្នុងវត្តដើមជ្រៃ។ ទីតាំងទីពីរនេះស្ថិតនៅចម្ងាយពីគ្នាប្រមាណ ១ គីឡូម៉ែត"[1477]។

735. ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ បានផ្តល់សក្ខីកម្មថានៅពេលស្វាយឃ្លាំងត្រូវបានជម្លៀស "យើងត្រូវបានឃុំឃាំងនៅឃ្លាំងនោះ។ យើងត្រូវបានបញ្ជូនទៅឃ្លាំងបារីពីស្ពានព្រែកចាម។ យើងទាំងអស់គ្នាជាស្ត្រីត្រូវបានឃុំឃាំងក្នុងឃ្លាំងនោះ។ ស្ត្រីដែលបានរៀបការខ្លះ មានកូន ដែលកាលណោះខ្ញុំមានអាយុក្រោម២០ឆ្នាំ។ ខ្ញុំមានអាយុប្រហែល១៧ឆ្នាំ។ កុមារ ទារក ត្រូវបានឃុំឃាំងផងដែរ និងត្រូវបានទុកក្នុងឃ្លាំងនោះ។ ពួកគាត់យំស្រែក។ ពួកគាត់យំឮខ្លាំងដូចកូនបក្សីប្រជុំគ្នាក្នុងសម្បុក។ ពួកគាត់ខ្លះឃ្លានខ្លាំង"[1478]។

736. ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ បានពន្យល់ទៀតថាចំពោះមនុស្សដែលត្រូវបានឃុំឃាំងក្រោយពេលបះបោរ "ខ្ញុំអាចហៅពួកគាត់ថាអ្នកទោស។ អ្នកទោសខ្លះត្រូវបានដាក់នៅតាមទីកន្លែងផ្សេង

---

[1476] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៥៦ បន្ទាត់ ៩-១២។

[1477] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៧៧ បន្ទាត់ ៥-៩។

[1478] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៨៤ បន្ទាត់ ២០-ទំព័រ ២៥ បន្ទាត់ ២។

១។ មនុស្សដទៃ និងខ្ញុំ គឺជាអ្នកទោសទាំងអស់។ អនុញ្ញាតឱ្យខ្ញុំនិយាយដូច្នោះ។ មានមនុស្សនៅក្រុចឆ្មាលើ និងក្រុចឆ្មាក្រោម និងមានដើមពោធិ៍ក្នុងវត្ត ហើយយើងស្នាក់នៅទីនោះ មួយខែបីថ្ងៃក្រោយមកយើងត្រូវបានបញ្ជូនទៅកន្លែងផ្សេង។ អ្នកដែលមិនត្រូវបានចាត់ទុកជាខ្មាំង ពួកគាត់បានមានឱកាសជួបប្តីប្រពន្ធនិងកូន ហើយសម្រាប់អ្នកដែលគេចាត់ទុកជាខ្មាំង ពួកគាត់នឹងត្រូវបានបញ្ជូនចេញទៅ និងបានបាត់ខ្លួន។ ឪពុករបស់ខ្ញុំ និងមនុស្សខ្លះទៀតត្រូវបានចាត់ទុកថាជាប់ខ្សែរយៈភ្នាក់ងារសេអ៊ីអា ដែលមានស័ក្តិបួន ឬស័ក្តិប្រាំ ប៉ុន្តែឪពុកខ្ញុំកាលណោះមិនចេះអានឬសរសេរអក្សរខ្មែរឡើយ ហើយគាត់ត្រូវបានចាត់ទុកជាខ្មាំង និងបានបាត់ខ្លួនរហូតមកទល់សព្វថ្ងៃ”[1479]។

737. ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ បានគូសបញ្ជាក់ថា “ទាក់ទងឪពុករបស់ខ្ញុំ យើងបានកំពុងរស់នៅជាមួយគ្នាមុនពេលបះបោរ។ ក្រោយបះបោរ យើងត្រូវបានប្រាប់ឱ្យចាកចេញ។ នៅពេលយើងបានទៅដល់ស្ពានស្វាយឃ្លាំង ឬស្ពានព្រែកចាមនៃប៉ែកត្រើយម្ខាងទន្លេ យើងត្រូវបានអនុញ្ញាតឱ្យឆ្លងស្ពាននេះ ប៉ុន្តែឪពុករបស់ខ្ញុំត្រូវបានចាប់ខ្លួន និងឃុំឃាំង ហើយខ្ញុំមិនដែលបានឃើញគាត់ត្រឡប់មកវិញឡើយចាប់តាំងពីពេលនោះ”[1480]។ “ខ្ញុំបានឃើញមនុស្សម្នាជាច្រើន ពិសេសយុវជន។ មនុស្សដែលត្រូវបានឃុំឃាំងត្រូវបានចាត់ទុកជាខ្មាំង”[1481]។

## ៣. ទារុណកម្ម

738. ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន បានពិពណ៌នាអំពីវិធីដែលទារុណកម្មត្រូវបានប្រើប្រាស់ក្នុងអំឡុងពេលសួរចម្លើយ។ គាត់បានរម្លឹកថានៅពេលគាត់ត្រូវបានឃុំឃាំងក្រោយពេលមានការបះបោររបស់ប្រជាជនចាមនៅស្វាយឃ្លាំង “ទារុណកម្មបានកើតមាននៅតាមទីកន្លែងទាំងនោះ។ យើងត្រូវបានដាក់នៅតាមកន្លែងទាំងនោះដើម្បីការជ្រើសរើសបន្ថែម។ គ្នាយើងចំនួន ៤០ ឬ ៥០ នាក់ត្រូវបានដាក់ក្នុងបន្ទប់នីមួយៗក្នុងអគារសាលារៀន។ យើងត្រូវបានសួរចម្លើយអំពីរឿងគ្រប់បែបយ៉ាង និងត្រូវបានចាក់នឹងចំពុះទង់ត្រង់បំពង់ករបស់យើង។ យើងត្រូវបានសួរចម្លើយ២ដងក្នុង១

[1479] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៨៥ បន្ទាត់ ២៣-ទំព័រ ៨៦ បន្ទាត់ ១០។

[1480] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៨៤ បន្ទាត់ ៥-១០។

[1481] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៨៤ បន្ទាត់ ១៤-១៦។

ថ្ងៃ។ ទាហានម្នាក់ជាអ្នកសួរចម្លើយយើង ចំណែកម្នាក់ទៀតយកចំពុះទង់ភ្លង់បំពង់ករបស់យើង។ ពួកគាត់បានសួរយើងថានរណាធ្វើអ្វី ហើយនរណាផ្ដួចផ្ដើមការបះបោរ។ យើងត្រូវបានសួរអំពីរឿងរ៉ាវគ្រប់បែបយ៉ាងដែលខ្ញុំមិនអាចចងចាំទាំងអស់បាន។ ប៉ុន្មានថ្ងៃក្រោយពេលសួរចម្លើយមនុស្សចំនួនចន្លោះពី ៣ ទៅ ១០ នាក់ដែលមកពីបន្ទប់នីមួយៗជារៀងរាល់ថ្ងៃ ត្រូវបានយកចេញទៅ។ ជាឧទាហរណ៍ ក្នុងចំណោមប្រជាជនចាមចំនួន ៥០ នាក់ បុរសដែលត្រូវបាននាំយកទៅបន្ទប់នីមួយៗមុនគេ មានតែ៥នាក់ប៉ុណ្ណោះដែលទីបំផុតបានចេញមកក្រៅផុតពីស្លាប់ជាមួយខ្ញុំ"[1482]។

## ៤. អំពើអមនុស្សធម៌ដទៃទៀត

739. ភ័ស្តុតាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលបានបង្ហាញនៅសវនាការបង្ហាញថាទង្វើរបស់ ប.ក.ក ទាក់ទងការប្រព្រឹត្តិទៅលើប្រជាជនចាម មុនពេល ក្នុងអំឡុងពេល និងក្រោយពេលនៃការបះបោរនៅស្វាយឃ្លាំង បានរួមបញ្ចូលការរំលោភសិទ្ធិរស់រានមានជីវិត និងសិទ្ធិទទួលបានបទដ្ឋានគ្រប់គ្រាន់នៃការរស់នៅ សិទ្ធិមិនស្ថិតក្រោមការប្រព្រឹត្តិបែបព្រៃផ្សៃ បែបអមនុស្សធម៌ និងបែបបន្ទាបបន្ថោក និងសិទ្ធិមិនត្រូវបានចាប់ខ្លួនតាមទំនើងចិត្តរបស់ប្រជាជនចាម[1483]។ ទង្វើនោះជាអំពើដែលមានលក្ខណៈនិងស្ថានទម្ងន់ស្រដៀងជាមួយឧក្រិដ្ឋកម្មប្រឆាំង មនុស្សជាតិដទៃទៀត និងបានបង្កព្យសនកម្មធ្ងន់ធ្ងរទៅលើដើមបណ្ដឹងរដ្ឋប្បវេណី និងជាការវាយប្រហារទៅលើសេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិ។

### ៤.១. លក្ខខណ្ឌនៃការឃុំឃាំង

740. ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ាន ស្លេះ បានផ្ដល់សក្ខីកម្មអំពីកង្វះអាហារ និងអនាម័យនៅឡានោះ "នៅឡាថ្នាំនោះមានកន្លែងគ្រប់គ្រាន់ប៉ុន្តែគ្មានអនាម័យទាល់តែសោះ។ ទីកន្លែងនោះពោរពេញទៅដោយអាចមន៍ផ្អែនិងអាចមន៍ឆ្មា ហើយនៅពេលដែលយើងនៅទីនោះ ហើយនៅពេលជាមួយគ្នានោះខ្មែរក្រហមបានយកប្រវត្តិរូបរបស់យើងម្ដងម្នាក់ ហើយមនុស្សចេះតែបាត់ខ្លួនជារៀងរាល់យប់ ហើយ

[1482] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៨១ បន្ទាត់ ១៨-ទំព័រ ៨២ បន្ទាត់ ៥។

[1483] សេចក្ដីប្រកាសជាសាកលស្ដីពីសិទ្ធិមនុស្ស ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៤៨ មាត្រា ២ ៥ ៩ ២៥។

វាជាសំណាងសម្រាប់ខ្ញុំដែលបានគេចផុតពីសេចក្ដីស្លាប់”[1484]។ គាត់បានផ្ដល់សក្ខីកម្មបន្ថែមទៀតថា “កាលណោះ យើងត្រូវបានគេបង្អត់អាហារ។ គេផ្ដល់ឲ្យយើងតែបបរាវមួយកូនចាន ប៉ុណ្ណោះក្នុងមួយថ្ងៃ។ យើងស្លេកស្លាំងខ្លាំង។ ហើយក្នុងអំឡុងពេលដែលខ្ញុំត្រូវបានឃុំឃាំង ខ្ញុំបាននឹកសមាជិកគ្រួសារនិងបងប្អូនរបស់ខ្ញុំដែលត្រូវបានឃុំឃាំងនៅវត្ត។ ខ្ញុំមិនដឹងថាពេលនោះ ពួកគាត់រងទុក្ខវេទនាយ៉ាងណាឡើយ។ ប្រហែលពួកគាត់រងទុក្ខវេទនាដូចខ្ញុំដែរនៅពេលនោះ។ យើងត្រូវបានបំបែកពីគ្នាក្រោយពេលបះបោរ”[1485]។ ដើមបណ្ដឹងរដ្ឋប្បវេណី នោ សាទះ បានផ្ដល់សក្ខីកម្មថា “ម្នាក់ៗអាចទទួលបានបបរមួយកូនវែក ដោយគ្មានរសជាតិអ្វីទាល់តែសោះ រសជាតិសាបណាស់”[1486]។

### ៤.២. ការបាត់ខ្លួន

741. ដើមបណ្ដឹងរដ្ឋប្បវេណី នោ សាទះ បានផ្ដល់សក្ខីកម្មអំពីការបាត់ខ្លួនអ្នកភូមិមួយចំនួនមុនការបះបោរដោយបានពន្យល់ថា “នៅពេលនោះ រៀងរាល់យប់ មនុស្ស ២០-៣០ ត្រូវបានចាប់ខ្លួន និងនាំយកចេញទៅដោយខ្មែរក្រហម”[1487]។

742. ដើមបណ្ដឹងរដ្ឋប្បវេណី នោ សាទះ បានផ្ដល់សក្ខីកម្មថា “វាជាបញ្ហាស្ដីពីខ្មែរ ស ដែលមនុស្សម្នាក្នុងភូមិនេះត្រូវបានចោទថាជាខ្មែរ ស ភ្នាក់ងារសេអ៊ីអាអាមេរិក។ ហើយសម្រាប់ហេតុផលនោះ ពួកគាត់ត្រូវបានចាប់ខ្លួន។ មនុស្សម្នាត្រូវបានចាប់ខ្លួន និងដាក់ទៅលើរទេះសេះ ហើយវាតែងបានកើតមាននៅម៉ោងប្រហែល ៧ ឬ ៨ យប់។ ហើយអ្នកដែលត្រូវបានចាប់ខ្លួន មិនដែលបានវិលត្រ

---

[1484] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ាន ស្លេះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៥៦ បន្ទាត់ ២៤-ទំព័រ ៥៧ បន្ទាត់ ៤។

[1485] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ាន ស្លេះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៥៦ បន្ទាត់ ១៣-១៩។

[1486] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៨៥ បន្ទាត់ ២-៣។

[1487] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/351.1** ទំព័រ ៦ បន្ទាត់ ១២-១៣។

ឡប់មកវិញឡើយ”[1488]។ ដើមបណ្តឹងរដ្ឋប្បវេណី ណូ សាទះ បានផ្តល់សក្ខីកម្មថានៅពេលស្វាយឃុំាំងត្រូវបានជម្លៀស "តាមការចាំរបស់ខ្ញុំ អ្នកជិតខាងខ្ញុំខ្លះបានបាត់ខ្លួននិងមិនបានវិលត្រឡប់មកវិញឡើយ ប៉ុន្តែខ្លះបានវិលត្រឡប់មកវិញ។ ឪពុករបស់ខ្ញុំបានបាត់ខ្លួន ហើយគាត់បានបាត់ខ្លួនចាប់តាំងពីពេលនោះមក”[1489]។

743. ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន ក៏បានផ្តល់សក្ខីកម្មថាមនុស្សដែលត្រូវបានឃុំឃាំងក្រោយពេលបះបោរ “ខ្ញុំគ្រាន់តែបានដឹងថាទាហានទាំងនោះជាទាហានដែលមកចាប់ប្រជាជន។ ខ្ញុំបានឃើញឈ្លបឃុំឬមន្ត្រីសន្តិសុខស្រុកបានមកចាប់មនុស្ស ប៉ុន្តែខ្ញុំមិនបានចាប់អារម្មណ៍ថាពួកគេចាប់មនុស្សយកទៅសម្លាប់។ ពួកគេបាននិយាយថាពួកគេយកមនុស្សទាំងនោះទៅឃុំឃាំងនៅឯមន្ទីរសន្តិសុខស្រុក។ ខ្ញុំបានដឹងដោយផ្ទាល់អំពីរឿងនេះ។ ប៉ុន្តែខ្ញុំមិនអាចអះអាងជាក់លាក់ថា មនុស្សទាំងនោះត្រូវបានយកទៅសម្លាប់ឡើយ។ ប៉ុន្តែប្រសិនបើមនុស្សទាំងនោះមិនត្រូវបានសម្លាប់ ពួកគាត់នឹងបានវិលត្រឡប់មកវិញហើយ។ ខ្ញុំមិនដែលបានឃើញពួកគាត់ម្តងទៀតឡើយ”[1490]។ គាត់បានបន្ថែមថានៅពេលដែលគាត់កំពុងត្រូវបានឃុំឃាំងនៅឡនោះ “ក្រោយពេលសួរចម្លើយពីរបីថ្ងៃ គ្នាយើងចំនួន ៣ ឬ ១០ នាក់ ដែលមកពីបន្ទប់រៀនផ្សេងគ្នា ត្រូវបានយកចេញទៅ។ ជាឧទាហរណ៍មានបន្ទប់មួយដែលមានប្រជាជនចាមចំនួន៥០នាក់ក្នុងបន្ទប់នោះ ហើយមានតែពីរបីនាក់ប៉ុណ្ណោះដែលនៅសល់ ដោយសារអ្នកឯទៀតត្រូវបានយកចេញទៅ”[1491]។

744. ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ ត្រូវបានចាប់ខ្លួនព្រមជាមួយឪពុករបស់គាត់ និងបានផ្តល់សក្ខីកម្មអំពីការបាត់ខ្លួនមនុស្សចំនួន ៥ នាក់ ដោយរួមបញ្ចូលឪពុករបស់គាត់ ដែលជាជំនួយការទីពីរ

---

[1488] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/351.1** ទំព័រ ៥ បន្ទាត់ ១២-១៧។

[1489] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៥០ បន្ទាត់ ១៧-១៩។

[1490] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៧៤ បន្ទាត់ ១០-១៨។

[1491] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៧៣ បន្ទាត់ ៦-១០។

របស់ហាគីម[1492]។ "យើងត្រូវបានចាប់ខ្លួនក្នុងចម្ការ។ បន្ទាប់មក យើងត្រូវបានចង និងដាក់ក្រោមផ្ទះរបស់ប្រជាជនខ្មែរ។ ប្រហែលមួយអាទិត្យក្រោយមក យើងត្រូវបានដោះលែង ហើយមនុស្ស៥នាក់ប៉ុណ្ណោះត្រូវបានចង និងដាក់លើរទេះសេះ និងត្រូវបានយកចេញទៅ ហើយឪពុករបស់ខ្ញុំស្ថិតក្នុងចំណោមមនុស្សទាំង៥នាក់នោះ"[1493]។ ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេស បានពន្យល់ថាក្នុងចំណោមមនុស្សទាំងនេះ "មនុស្ស៥នាក់ក្នុងចំណោមពួកគាត់ត្រូវបានចាប់ខ្លួន ហើយឪពុក របស់ខ្ញុំស្ថិតក្នុងចំណោមក្រុមនោះ។ ពួកគាត់មិនដែលបានវិលត្រឡប់មកវិញក្រោយពេលចាប់ខ្លួនឡើយ"[1494]។

## ៥. តំណាងទាក់ទងការប្រព្រឹត្តិ

745. ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ បានផ្តល់សក្ខីកម្មថាទាហានស្រុក ទាហានមកពីថ្នាក់ឃុំ និងឈ្លបបានចូលរួមក្នុងការកម្ចាត់ការបះបោរ៖ "កាលណោះមានទាហាន ទាហានស្រុក និងទាហានឃុំ និងមានឈ្លបដែរ នៅថ្នាក់ភូមិ។ ដូច្នេះ មានកម្លាំងប្រដាប់អាវុធនៅថ្នាក់ផ្សេងៗក្នុងតំបន់នេះ។ ពួកគេត្រូវបានពង្រាយនៅតាមភូមិនានាទូទាំងស្រុកនេះ។ ចំពោះទាហានពួកគេស្លៀកពាក់ឯកសណ្ឋានខៀវ ចំណែកបុរសដែលធ្វើការនៅឃុំស្លៀកសម្លៀកបំពាក់ខ្មៅដោយមានកន្សែងបង់ក"[1495]។

746. ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ បានផ្តល់សក្ខីកម្មថា "ក្នុងអំឡុងពេលបះបោរ មានទាហានឯកសណ្ឋានខ្មៅ ហើយពួកគេប្រដាប់ដោយអាវុធ"[1496] និងថា "មានតែ ប៉េង ហេង និង ឡុង ប៉ុណ្ណោះ

---

[1492] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៧១ បន្ទាត់ ៨-ទំព័រ ៧២ បន្ទាត់ ១៧។

[1493] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៧១ បន្ទាត់ ២០-២៤។

[1494] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៧២ បន្ទាត់ ១៦-១៧។

[1495] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក. ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E/351.1** ទំព័រ ១០ បន្ទាត់ ២៣-ទំព័រ ១១ បន្ទាត់ ៤។

[1496] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៧៧ បន្ទាត់ ៥-៦។

បានកំពុងធ្វើការក្នុងភូមិនេះ។ កាលណោះ ទាហានភូមិភាគកណ្ដាលបានមកភូមិ នេះ។ ពួកគាត់ទាំង២នាក់នឹងត្រូវបានសម្លាប់ប្រសិនបើទាហានភូមិភាគបូព៌ាបានមកភូមិរបស់ខ្ញុំ"[1497]។

## ឃ. ភស្ដុតាងដើមបណ្ដឹងរដ្ឋប្បវេណីទាក់ទងការជម្លៀសប្រជាជនដំណាក់កាលទី២ (ចាម)

### ១. អំពើអមនុស្សធម៌ដទៃទៀត

747. ភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណីដែលបានបង្ហាញនៅសវនាការ បង្ហាញថាទង្វើរបស់ ប.ក.ក ទាក់ទងគោលនយោបាយផ្លាស់ទីលំនៅប្រជាជន បានរួមបញ្ចូលការរំលោភសិទ្ធិរស់រានមានជីវិត របស់ប្រជាជនចាម សិទ្ធិទទួលបានលក្ខខណ្ឌគ្រប់គ្រាន់នៃការរស់នៅ សិទ្ធិមិនទទួលបានការប្រព្រឹត្តិបែបព្រៃផ្សៃ បែបអមនុស្សធម៌ បែបបន្ទាបបន្ថោក[1498]។ ទង្វើនោះជាអំពីដែលមានលក្ខណៈ និងស្ថានទម្ងន់ស្រដៀងនឹងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដទៃទៀត និងបានបង្កព្យសនកម្មធ្ងន់ធ្ងរ ទៅលើដើមបណ្តឹងរដ្ឋប្បវេណី ឬជាការវាយប្រហារទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្សជាតិ។

### ១.១. ការជម្លៀសទៅកាន់តំបន់ផ្សេងៗក្នុងកំពង់ចាម

748. ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន បានពិពណ៌នាថា "ក្រោយពេលខ្ញុំរួចផុតពីការឃុំឃាំង ខ្ញុំត្រូវបានអនុញ្ញាតឱ្យជួបជុំជាថ្មីជាមួយគ្រួសាររបស់ខ្ញុំ។ ប៉ុន្តែអ្នកភូមិស្វាយឃ្លាំងទាំងស់ ដែលត្រូវបានឃុំឃាំង ពុំត្រូវបានអនុញ្ញាតឱ្យចូលភូមិម្តងទៀតឡើយ។ យើងត្រូវបានជម្លៀសតាមទូក ទៅរស់នៅកន្លែងផ្សេង ដោយរួមបញ្ចូល ស្ទឹងត្រង់ បារាយ តំបែរ និងកន្លែងជាច្រើនទៀត ដែលខ្ញុំមិនអាចចាំអស់ ប៉ុន្តែពុំវិលត្រឡប់ទៅភូមិកំណើតរបស់យើងវិញឡើយ"[1499]។

749. ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន បានផ្តល់សក្ខីកម្មថានៅពេលគាត់ និងគ្រួសាររបស់គាត់ត្រូវបានជម្លៀសទៅតំបែរ "យើងត្រូវបានដាក់នៅលើទូកមួយ ហើយយើងត្រូវអុំទូកនោះដោយខ្លួនឯង។ ហើយជាឧទាហរណ៍ ក្នុងចំណោម ៥០ ទូក យើងត្រូវអុំត្រង់ជួរ។ ប្រសិនបើទូកទៅឆ្វេង ឬទៅស្តាំ

[1497] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៧៧ បន្ទាត់ ១៩-២៣។

[1498] សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៤៨ មាត្រា ២ ៥ ៩ ២៥។

[1499] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៨៩ បន្ទាត់ ២២-ទំព័រ ៩០ បន្ទាត់ ២។

ទូកនោះនឹងត្រូវបាញ់ពីក្រោយ"[1500]។ "ការធ្វើដំណើរតាមទូកនោះមានរយៈពេលពេញមួយយប់ និងកន្លះថ្ងៃ"[1501]។ ដើមបណ្ដឹងរដ្ឋប្បវេណី សុះ មីន បានបន្តថា "មនុស្សទាំងអស់នៅលើទូកជាប្រជាជនចាម។ គ្មានខ្មែរទេ"[1502]។ ដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះបានពន្យល់ថាទូកនីមួយៗ "អាចដាក់មនុស្ស ២០ ឬ ៣០ នាក់។ ហើយចំពោះទូកធំ វាអាចដាក់មនុស្សរហូតដល់ ៥០ នាក់"[1503]។

750. គាត់បានផ្ដល់សក្ខីកម្មថា "យើងមិនត្រូវបានអនុញ្ញាតឲ្យសម្រាកទាល់តែសោះក្នុងអំឡុងពេលធ្វើដំណើរតាមទូក។ យើងអស់កម្លាំងណាស់ និងអត់ឃ្លាន ប៉ុន្តែយើងត្រូវតែអុំទូក។ ហើយតាមពិតនៅពេលយើងបានទៅដល់ច្រាំង យើងត្រូវដើរពេញមួយថ្ងៃមុនពេលយើងអាចទៅដល់ភូមិដែលជាគោលដៅរបស់យើង ដែលយើងនឹងស្នាក់នៅ"[1504]។ ដើមបណ្ដឹងរដ្ឋប្បវេណី សុះ មីន បានបន្ត "យើងពុំបានធ្វើដំណើរដោយស្ម័គ្រចិត្តពីសំណាក់ក្រុមរបស់យើងដែលជាប្រជាជនចាមឡើយ ប៉ុន្តែយើងត្រូវបានបង្ខំឲ្យធ្វើដំណើរ។ យើងត្រូវបានគេឃ្លាំមើលតាមផ្លូវ ហើយមានទាហានប្រហែល ១០ ទូកដែលបានឆ្កកពួកយើងខណៈពេលដែលយើងធ្វើដំណើរតាមទូក ហើយយើងត្រូវធ្វើតាមការណែនាំរបស់ពួកវា។ ពួកវាបានឆ្កកយើងតាមផ្លូវរហូតដល់យើងបានទៅដល់ភូមិ"[1505]។

751. ដើមបណ្ដឹងរដ្ឋប្បវេណីបានពិពណ៌នា "នៅពេលយើងបានមកដល់តំបែរ យើងត្រូវបានអនុញ្ញាតឲ្យស្នាក់នៅស្វាយកាំបិត ភូមិស្វាយកាំបិត ឃុំសេដា ក្នុងស្រុកតំបែរ ហើយយើងត្រូវបានណែនាំឲ្យ

[1500] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុស មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៩០ បន្ទាត់ ៥-៨។

[1501] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុះ មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៧២ បន្ទាត់ ៧-៩។

[1502] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុះ មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៧២ បន្ទាត់ ១៨។

[1503] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុះ មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៧២ បន្ទាត់ ១២-១៤។

[1504] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុះ មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៧២ បន្ទាត់ ២៣-ទំព័រ ៧៣ បន្ទាត់ ៣។

[1505] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុះ មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៧៣ បន្ទាត់ ៦-៩។

រស់នៅលាយឡំជាមួយប្រជាជនខ្មែរ។ នោះជាកន្លែងដែលខ្ញុំរស់នៅ"[1506]។ ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន បានចងចាំ "ថាខ្ញុំបានរស់នៅទីនោះអស់រយៈពេលចំនួនជាង២ឆ្នាំ"[1507]។

752. ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ បានផ្តល់សក្ខីកម្មថាបន្ទាប់ពីការឃុំឃាំងគាត់ "ខ្ញុំត្រូវបានបញ្ជូនទៅរស់នៅខ្សាច់ប្រឆេះលើ ហើយខ្ញុំនៅទីនោះរហូតដល់កម្មាភិបាលភូមិភាគនិរតី ចូលមកដល់"[1508] ជាង ២ ឆ្នាំក្រោយ។ គាត់បានពន្យល់ថា "កម្មាភិបាលនិរតីបានវាយប្រហារភូមិភាគបូព៌ា។ នៅពេលពួកគេមកដល់ យើងត្រូវបានប្រមូលផ្តុំ។ ខ្ញុំបានរស់នៅខ្សាច់ប្រឆេះលើអស់រយៈពេលចំនួនជាង២ឆ្នាំ ជិត៣ឆ្នាំ។ ខ្ញុំរស់នៅទីនោះក្នុងឆ្នាំ ១៩៧៥, ១៩៧៦ និងប្រហែលឆ្នាំ ១៩៧៧ ដែលអំឡុងពេលនោះស្ថានភាពមានភាពតានតឹង។ មនុស្សត្រូវបានយកចេញទៅនិងត្រូវបានសម្លាប់ដោយឥតរើសមុខ"[1509]។

## ១.២. ការផ្លាស់ទីលំនៅទីភូមិទ្រា

753. បន្ទាប់ពីបានរស់នៅខ្សាច់ប្រឆេះអស់ពេល២ឆ្នាំ ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ បានពិពណ៌នាអំពីការផ្លាស់ទីលំនៅលើកទី២ក្នុងឆ្នាំ ១៩៧៧[1510] បន្ទាប់ពីកម្មាភិបាលភូមិភាគនិរតីមកដល់[1511]។ គាត់បានផ្តល់សក្ខីកម្មថា "ពួកគេបាមកបោសសម្អាតប្រជាជនចាម ប្រជាជនចាមទាំងអស់ត្រូវបានប្រមូលផ្តុំ ហើយយើងត្រូវបានប្រាប់ថាយើងត្រូវផ្លាស់ទីលំនៅទៅស្ទឹងត្រង់មួយរយៈ ពីព្រោះ

---

[1506] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៧៤ បន្ទាត់ ៩-១១។

[1507] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៧៥ បន្ទាត់ ១-៣។

[1508] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៤២ បន្ទាត់ ៤។

[1509] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៤២ បន្ទាត់ ៥-៧។

[1510] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៤៤ បន្ទាត់ ២៤ - ទំព័រ ៤៥ បន្ទាត់ ៥ និងទំព័រ ៤៦ បន្ទាត់ ៣-៧។

[1511] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៤២ បន្ទាត់ ៤-៧។

ស្ទឹងត្រង់មានអាហារគ្រប់គ្រាន់ ស្រូវអង្ករម្រាប់ហូប និងមានការងារច្រើននៅស្ទឹងត្រង់។ មនុស្ស ដែលត្រូវបានបញ្ជូនទៅស្ទឹងត្រង់ មិនដែលបានវិលត្រឡប់មកវិញឡើយ"[1512]។

754. ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ បានផ្តល់សក្ខីកម្មថា "កម្មាភិបាលនិរតីបានបញ្ជាឱ្យប្រធានភូមិ ឬមនុស្សដទៃទៀតដែលធ្វើការនៅតាមស្រុក ឬភូមិ កំណត់អត្តសញ្ញាណប្រជាជនចាម និងប្រជាជនដែលមិនមែនចាម ហើយបញ្ជីឬរបាយការណ៍នឹងត្រូវបានបញ្ជូនទៅកម្មាភិបាលនិរតី។ ពួកគេបានសរសេរបញ្ជីឈ្មោះប្រជាជនចាមដើម្បីបញ្ជូនទៅកម្មាភិបាលនិរតី"[1513]។ ដើមបណ្តឹងរដ្ឋ ប្បវេណី នោ សាទះ បានរៀបរាប់បន្ថែមទៀតអំពីវិធីដែល "ប្រជាជនចាមទាំងអស់ដោយរួមទាំងបុរសចាម ត្រូវបានប្រមែប្រមូល និងបញ្ជូនចេញទៅ។ បុរសគឺដំបូងគេ បុរសចាមជាមនុស្សដំបូងគេដែលត្រូវប្រមែប្រមូល ហើយពួកគេបាននិយាយថាពួកគេត្រូវតែបញ្ជូន បុរសចាមទៅមុនដើម្បីសង់ផ្ទះឱ្យស្ត្រីចាម ដែលនឹងត្រូវបញ្ជូនទៅតាមក្រោយ។ ដូច្នេះជាឧទាហរណ៍ បុរសចាមនឹងត្រូវប្រមែប្រមូលមួយថ្ងៃ មុនពេលការចាប់ខ្លួន ឬការប្រមែប្រមូលស្ត្រីចាម។ មនុស្សប្រុសស្រី ចាស់ក្មេងត្រូវបានយកចេញទៅ"[1514]។ ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ បានបន្តថាស្ត្រីចាមមកពីខ្សាច់ប្រឆេះលើ "ពួកគាត់ត្រូវបានកោះហៅ និងអញ្ជើញឱ្យទៅប្រជុំ។ ពួកគាត់ទាំងអស់ត្រូវបានអញ្ជើញ ហើយពួកគាត់ត្រូវបានប្រាប់ថាពួកគាត់ត្រូវផ្លាស់ទីលំនៅទៅតាមកន្លែងផ្សេងៗ។ ប្រធានភូមិជាអ្នកទទួលខុសត្រូវចំពោះការប្រមែប្រមូល និងការអញ្ជើញស្ត្រីចាមទាំងអស់នោះទៅប្រជុំ"[1515]។

755. ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ នៅទីបំផុតត្រូវបានផ្លាស់ទីលំនៅទៅភូមិទ្រា ព្រមជាមួយប្រជាជនចាមដទៃទៀត៖ "ប្រធានភូមិបានប្រាប់ទាហានថាយើងជាប្រជាជនចាម ហើយបន្ទាប់មក ទាហានបានមកណែនាំយើងថាយើងត្រូវតែផ្លាស់ទីលំនៅ។ ប្រធានភូមិត្រូវបានស្នើសុំឱ្យប្រមូល ស្ថិតិ

[1512] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៦៧ បន្ទាត់ ២៤- ទំព័រ ៦៨ បន្ទាត់ ៣។

[1513] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៦៨ បន្ទាត់ ៦-៩។

[1514] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៦៨ បន្ទាត់ ១៣-១៦។

[1515] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៦៨ បន្ទាត់ ១៩-២១។

និងប្រមូលផ្ដុំប្រជាជនចាម"[1516]។ គាត់បានពន្យល់ថាទាហានដែលបាននាំគាត់ទៅភូមិទ្រា "ទាហានបានផ្ដកយើង។ ពួកគេប្រដាប់ដោយអាវុធ"[1517]។

756. ដើមបណ្ដឹងរដ្ឋប្បវេណី នោ សាទះ បានរម្លឹកថានៅពេល "ខ្ញុំត្រូវបានផ្លាស់ទីលំនៅទៅភូមិទ្រា ហើយយើងបានចាកចេញនៅម៉ោង ១ រសៀល ហើយយើងបានមកដល់ភូមិទ្រានៅម៉ោង ៦ ឬ ៧ យប់។ មេឃភ្លៀង យើងអស់កម្លាំង ដោយសារគ្មានអាហារហូបទាល់តែសោះ ហើយបន្ទាប់មក យើងបានសម្រាកនៅក្នុងផ្ទះនោះ។ ហើយអ្នកភូមិនៅទីនោះបានសម្លឹងមកពួកយើងមួយភ្លែត ហើយពួកគាត់ពុំហ៊ានសម្លឹងមើលពួកយើងឡើយ ហើយខ្ញុំអាចឮសំឡេង កជើង ឬជើងរបស់ពួកគេដែលកំពុងត្រូវបានដាក់ច្រវ៉ាក់នៅក្នុងផ្ទះនោះ"[1518]។

757. ដើមបណ្ដឹងរដ្ឋប្បវេណី នោ សាទះ បានពន្យល់ថាស្ត្រីជាច្រើនត្រូវបានចាប់ខ្លួន ហើយនាំយកទៅភូមិ ទ្រា "ចំណុចជួបជុំគឺនៅភូមិខ្សាច់ប្រឆេះកណ្ដាល។ ហើយនៅពេលយើងបានមកដល់ភូមិទ្រា យើងបានឃើញស្ត្រីដទៃទៀតដែលមកពីភូមិផ្សេងៗ បានមកដល់ទីនោះដែរ។ ពួកគាត់បានមកពីពើសលេខ ១ ពើសលេខ ២ ជាឧទាហរណ៍"[1519]។

## ១.៣. ការផ្លាស់ទីលំនៅទៅស្ទឹងត្រង់

[1516] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/351.1** ទំព័រ ៣៦ បន្ទាត់ ៣-៤។

[1517] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/351.1** ទំព័រ ៣៦ បន្ទាត់ ៤។

[1518] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៤៦ បន្ទាត់ ៣-៩។

[1519] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/351.1** ទំព័រ ៣២ បន្ទាត់ ២៥-ទំព័រ ៣៣ បន្ទាត់ ១។

ដើមបណ្ដឹងរដ្ឋប្បវេណី នោ សាទះ បានបន្តបញ្ជាក់ទៀតថា ("គេប្រមូលផ្ដុំពួកខ្ញុំហ្នឹង មួយក្រុម ៤០នាក់ហ្នឹង ភូមិខ្សាច់ប្រឆេះទៅភូមិទ្រា ទៅដល់ហ្នឹងឃើញគេនៅជួបជុំគ្នានៅកន្លែងមន្ទីរពួកខ្មែរក្រហមហ្នឹង។ សុទ្ធតែមកពីពើស ១ ពើស ២ ពើស ៣ សុទ្ធតែអ្នកភូមិសាយ។ ពីរបីភូមិ ពើស១ ពើស ២ និងអីខ្លះ ខ្ញុំចាំមិនបាន ស្វាយឃ្លាំងហ្នឹង ហើយនិងក្រូចឆ្មារហ្នឹង សុទ្ធតែនារីតែម្ដង។ សក្ខីកម្មផ្ទាល់មាត់របស់ នោ សាទះ ប្រតិចារឹក ឯកសារ ឯកសារ **E1/351.1** ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ទំព័រ ៣៣ បន្ទាត់ ៤-៨។

758. ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ បានរម្លឹកអំពីការផ្លាស់ទីលំនៅរបស់គ្រួសារគាត់ពីខ្សាច់ប្រឆេះទៅស្ទឹងត្រង់។ "បន្ទាប់ពីខ្ញុំបានចាកចេញ ខ្ញុំត្រូវបានប្រាប់ដោយមនុស្សដទៃទៀត ថាម្តាយរបស់ខ្ញុំដែលស្ថិតក្នុងចំណោមប្រជាជនចាម ត្រូវបានដាក់ទៅលើសាឡាង ធំៗ នោះគឺប្រជាជនចាមទាំងអស់ ក្នុងស្រុកក្រូចឆ្មា ត្រូវបានប្រមូលផ្តុំ និងដាក់លើសាឡាងធំនោះ ហើយចុះចតនៅស្រុកស្ទឹងត្រង់ នៅត្រើយម្ខាងទន្លេ"[1520]។ សមាជិកនានានៃគ្រួសារដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ដែលត្រូវបានដាក់នៅលើទូក គឺ "បងប្រុសរបស់ខ្ញុំ ម្តាយរបស់ខ្ញុំ ប្អូនស្រី៣នាក់របស់ខ្ញុំ និងជីដូន របស់ខ្ញុំ"[1521]។

759. ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ ក៏ត្រូវបានបញ្ជូនទៅស្ទឹងត្រង់ ក្រោយពីបានជួបជុំជាមួយគ្រួសាររបស់គាត់។ "ក្រោយពេលយើងបានជួបគ្នា យើងត្រូវបានបញ្ជូនទៅរស់នៅក្នុងស្រុកស្ទឹងត្រង់ ភូមិស្វរភៀស។ ប្រពន្ធរបស់ខ្ញុំ និងខ្ញុំព្រមទាំងកូនតូចអាយុ៣ខែ នៅជុំគ្នា"[1522]។

## ១.៤. ការបាត់ខ្លួនរបស់សាច់ញាតិនៃដើមបណ្តឹងរដ្ឋប្បវេណី ក្នុងអំឡុងពេលផ្លាស់ទីលំនៅប្រជាជនទៅស្ទឹងត្រង់

760. ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ បានរម្លឹកថាម្តាយ ជីដូន និងប្អូនរបស់គាត់ ២ នាក់ ត្រូវបានបញ្ជូនទៅស្ទឹងត្រង់ និងមិនដែលត្រូវបានឃើញម្តងទៀតឡើយ។ នៅពេលកម្មាភិបាលនិរតី មកដល់ក្នុងឆ្នាំ ១៩៧៦ និង ១៩៧៧ "ពួកគាត់ទាំងអស់ត្រូវបានប្រមូលផ្តុំ ដោយរួមបញ្ចូលមនុស្សស្រីប្រុស ប្អូនប្រុសខ្ញុំ២នាក់ ប្អូនស្រីខ្ញុំ ជីដូនខ្ញុំ ម្តាយខ្ញុំ ដែលពួកគាត់ត្រូវបាន ប្រមូលផ្តុំជាក្រុម ព្រមជាមួយអ្នកភូមិដទៃទៀត ហើយពួកគាត់ត្រូវបានបញ្ជូនចេញទៅ"[1523]។ នៅពេលដែលត្រូវបានសួរថាតើ

[1520] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/350.1 ទំព័រ ៤៥ បន្ទាត់ ៨-១១។

[1521] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/350.1 ទំព័រ ៤៥ បន្ទាត់ ២៣-២៤។

[1522] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ E1/393.1 ទំព័រ ៤៥ បន្ទាត់ ១៥-១៧។

[1523] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/350.1 ទំព័រ ៦៩ បន្ទាត់ ១៤-១៦។

គាត់ដែលបានឃើញពួកគេម្តងទៀតដែរឬទេ គាត់បានឆ្លើយថា “ទេ! ពួកគាត់បានបាត់ខ្លួនចាប់តាំងពីពេលនោះមក”[1524]។

### ១.៥. ការជម្លៀសពីភូមិ សាច់ស្ង៉

761. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន បានរម្លឹកថាក្នុងឆ្នាំ ១៩៧៦[1525] ក្នុងចំណោមប្រជាជនចាមចំនួន៣០គ្រួសារដែលនៅរស់នៅក្នុងភូមិនេះ ដោយសារប្រជាជនចាមជាច្រើនត្រូវបានជម្លៀសចេញរួចហើយ”[1526] គាត់បានពន្យល់ថានៅពេល “មានការជម្លៀស គ្នាយើងមួយចំនួនធំត្រូវបានជម្លៀសហើយពួកគាត់ត្រូវបានបញ្ជូនទៅផ្នែកខាងលើនៃតំបន់នេះ ដើម្បីបញ្ចប់ការបំបែកជាតិសាសន៍ និងបានរស់នៅក្នុងចំណោមអ្នកស្រុកនៅទីនោះ។ ខ្ញុំមិនបានដឹងអំពីចេតនានៃការផ្លាស់ទីលំនៅរបស់ប្រជាជនចាមឡើយ ហើយខ្ញុំអាចនិយាយបានថាប្រជាជនចាមចំនួនពាក់កណ្តាលដែលមកពីភូមិនេះ ត្រូវបានផ្លាស់ទីលំនៅនៅពេលនោះ។ ខ្ញុំមិនបានដឹងថាតើពួកគេត្រូវបានយកទៅទិសដៅណាជាក់លាក់ឡើយ។ ខ្ញុំមិនបានដឹងអំពីជោគវាសនារបស់ពួកគាត់ឡើយ។ ប៉ុន្តែខ្ញុំបានឮថាពួកគាត់កំពុងត្រូវបានដាក់នៅតាមភូមិដ្ឋាននានា ដើម្បីរស់នៅជាមួយអ្នកភូមិនៅទីនោះ”[1527]។

## ២. ការធ្វើមនុស្សឃាត និងការសម្លាប់រង្គាល

762. ភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានបង្ហាញនៅសវនាការ បង្ហាញថាប្រជាជនចាមបានស្លាប់ពីអំពើសកម្មឬអំពើអកម្មរបស់ ប.ក.ក ក្នុងបរិបទនៃការផ្លាស់ទីលំនៅប្រជាជន។

---

[1524] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៦៩ បន្ទាត់ ១៨។

[1525] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/349.1** ទំព័រ ៣១ បន្ទាត់ ៨-៩។ ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន បានផ្តល់សក្ខីកម្មថា “ខ្ញុំប្រហែលដែរទេ កើតនៅអំឡុងឆ្នាំ ១៩៧៦ ឆ្នាំ ១៩៧៦ហ្នឹងហើយ”។

[1526] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/349.1** ទំព័រ ២៨ បន្ទាត់ ១៩-២០។

[1527] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/349.1** ទំព័រ ៥២ បន្ទាត់ ១-៦។

763. ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន បានពិពណ៌នាអំពីវិធីដែល "ក្នុងអំឡុងការធ្វើដំណើរតាមទូក ជាសំណាងមិនល្អ មេឃភ្លៀងពេញមួយយប់។ ហើយ កុមារ និងទារកខ្លះ ហើយពួកគេខ្លះបានខ្លះ"[1528]។ ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន បានបញ្ជាក់បំភ្លឺថា "អ្វីដែលខ្ញុំនិយាយជាការពិត។ ហើយអ្វីដែលខ្ញុំបាននិយាយគឺជាអ្វីដែលខ្ញុំបានឃើញនៅលើទូករបស់ខ្ញុំ។ ខ្ញុំមិនអាចប្រាប់អ្នកអំពីអ្វី ដែលបានកើតឡើងនៅលើទូកដទៃទៀតឡើយ ប៉ុន្តែខ្ញុំអាចនិយាយត្រឹមតែអំពីអ្វីដែលបានកើតឡើង នៅលើទូកដែលខ្ញុំស្ថិតនៅ។ ហើយសម្រាប់ហេតុផលនេះ ខ្ញុំបានសន្និដ្ឋានថាមនុស្សចំនួន ៣ នាក់ ក្នុងចំណោមពួកគេបានស្លាប់"[1529]។

764. ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន ក្រោយមកបានផ្តល់សក្ខីកម្មថាមនុស្សចំនួន ១៣ គ្រួសារ បានស្លាប់ដោយសារភាពអត់ឃ្លាន និងមូលហេតុដទៃទៀត ដោយបានបញ្ជាក់ថា "ក្នុងចំណោមប្រជាជនចាមដែលត្រូវបានជម្លៀសជាមួយយើង មាន២០គ្រួសារ និងអនុញ្ញាតឲ្យខ្ញុំនិយាយចំណុចនេះ គឺថាមានតែ៧គ្រួសារប៉ុណ្ណោះនៅសល់ពីស្លាប់ដោយសារលទ្ធផលនៃជំងឺគ្រុនចាញ់ ឬភាពអត់ឃ្លាន"[1530]។ គាត់បានបញ្ជាក់បំភ្លឺថា "ខ្ញុំដឹងអំពីការពិតពីព្រោះខ្ញុំបានកំពុងរស់នៅទីនោះក្នុងចំណោមគ្រួសារទាំងនោះ ហើយគ្រួសារខ្លះបានស្លាប់។ ខ្ញុំបានមើលថែទាំងមនុស្សខ្លះនៅទីនោះផងដែរ ហើយខ្ញុំក៏បានចូលរួមកប់មនុស្សទាំងនោះខ្លះដែរ។ ហើយខ្ញុំនៅចងចាំទីតាំងដែលការកប់នោះបានកើតមាន"[1531]។

765. ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ បានផ្តល់សក្ខីកម្មថាបន្ទាប់ពីគាត់ និងប្រពន្ធរបស់គាត់ត្រូវបានជម្លៀសពីស្វាយឃ្លាំង ហើយម្តាយនិងបងប្អូនរបស់គាត់ ត្រូវបានបញ្ជូនទៅរការខ្មុរ គាត់បានឮពីអ្នកភូមិ "ខ្ញុំត្រូវបានប្រាប់ថាម្តាយនិងបងប្អូនរបស់ខ្ញុំត្រូវបានបញ្ជូនទៅស្លាប់នៅកន្លែង មួយឈ្មោះ

[1528] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/343.1 ទំព័រ ៧២ បន្ទាត់ ២៣-២៥។

[1529] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/343.1 ទំព័រ ៧៣ បន្ទាត់ ១៤-១៦។

[1530] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន ប្រតិចារឹក ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/344.1 ទំព័រ ៤ បន្ទាត់ ១៩-២១។

[1531] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន ប្រតិចារឹក ថ្ងៃទី ៩ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/344.1 ទំព័រ ៤ បន្ទាត់ ២៥-ទំព័រ ៥ បន្ទាត់ ២។

បឹងកាចូតក្នុងស្រុកស្ទឹងត្រង់ ដែលមិនឆ្ងាយពីទីប្រជុំជនស្ទឹងត្រង់"[1532]។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានពន្យល់ថា "អ្នកភូមិទាំងនោះពុំបាននិយាយច្រើនជាមួយខ្ញុំឡើយ ពីព្រោះពួកគេខ្លាច។ ពួកគេបាននិយាយថាម្តាយ និងបងប្អូនខ្ញុំ ត្រូវបានបញ្ជូនទៅស្រុកស្ទឹងត្រង់ដើម្បីសម្លាប់។ ពួកគេត្រូវបាននាំទៅតាមកាណូត ហើយការសម្លាប់បានកើតឡើងនៅបឹងកាចូត"[1533]។ "ខ្ញុំមិនដឹងអំពីវិធីនៃការសម្លាប់ឡើយ។ ខ្ញុំត្រូវបានប្រាប់ថាម្តាយនិងបងប្អូនខ្ញុំ៣នាក់ ត្រូវបានបញ្ជូនចេញពីភូមិនេះទៅស្រុកស្ទឹងត្រង់ ហើយទីតាំងជាក់លាក់នៃការសម្លាប់ គឺបឹងកាចូត។ អ្នកភូមិទាំងនោះមិនបាននិយាយថាម្តាយនិងបងប្អូន៣នាក់របស់ខ្ញុំ ត្រូវបានសម្លាប់ដោយការបាញ់នឹងកាំភ្លើង ឬដោយវិធីណាឡើយ"[1534]។

## ខ. ភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាក់ទងវត្តអូរត្រកួន

### ១. អំពើប្រល័យពូជសាសន៍ (តាមរយៈការសម្លាប់)

#### ១.១. ការសម្លាប់ជនរងគ្រោះចាម

766. ភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានបង្ហាញនៅសវនាការបង្ហាញថាប្រជាជនចាមជាច្រើនគ្រួសារត្រូវបានសម្លាប់នៅវត្តអូរត្រកួន ក្នុងពាក់កណ្តាលឆ្នាំ ១៩៧៧។ ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន បានផ្តល់សក្ខីកម្មថាក្រុមដាវវែង ជាអ្នកទទួលខុសត្រូវការប្រមែប្រមូល និងការចាប់ខ្លួនគ្រួសារចាម ដែល "ប្រជាជនចាមចំនួន ២០ ឬ ៣០ គ្រួសារត្រូវបានប្រមែប្រមូល និងចាប់ខ្លួន"[1535]។ "មានក្រុមចំនួនពីរ៖ សមាជិកក្រុមដាវវែងដែលកំពុងឃ្វាលប្រជាជនចាម និងក្រុមប្រ

[1532] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ E1/393.1 ទំព័រ ៦១ បន្ទាត់ ១៦-១៨។

[1533] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ E1/393.1 ទំព័រ ៦១ បន្ទាត់ ២២-២៣។

[1534] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ E1/393.1 ទំព័រ ៦២ បន្ទាត់ ១-៣។

[1535] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/349.1 ទំព័រ ៥៦ បន្ទាត់ ២៤-ទំព័រ ៥៧ បន្ទាត់ ១។

ដាប់អាវុធមួយទៀតដែលបានកំពុងយាមនៅចុងភូមិ ដើម្បីកុំឲ្យមានការរត់គេចខ្លួន។ ជីកស្មៅ ត្រូវជីកទាំងឫស"[1536]។

767. ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន បានរម្លឹកថានៅពេលដែលចាមត្រូវបានប្រមែប្រមូលដោយឈ្លបដាវវែង គាត់បានរត់គេចខ្លួន "ខ្ញុំមានផែនការលាក់ខ្លួនក្នុងស្រះ។ ប៉ុន្តែដោយសារខ្ញុំខ្លាច ឈ្លបឃើញខ្ញុំ ខ្ញុំបានសម្រេចលាក់ខ្លួនជាមួយប្រពន្ធរបស់ខ្ញុំក្នុងគុម្ពពោត។ ខ្ញុំនឹងស្ថិតក្នុងស្ថានភាព គ្រោះថ្នាក់ប្រសិនបើខ្ញុំសម្រេចចិត្តរត់ទៅកន្លែងផ្សេងក្រៅពីគុម្ពពោត ដោយសារភូមិនេះត្រូវបានកំពុងឡោមព័ទ្ធ"[1537]។

768. ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន បានផ្តល់សក្ខីកម្មថា "ខ្ញុំបានដឹងអំពីអ្វីដែលបានកើតឡើងនៅ ពេលនោះ ពីព្រោះខ្លួនខ្ញុំផ្ទាល់បានស្ថិតក្នុងស្ថានភាពនោះ។ ខ្ញុំផ្តេកខ្លួននៅក្នុងគុម្ពពោត ហើយខ្ញុំបានបន្តនៅទីនោះរហូតដល់មេឃងងឹត ហើយប្រហែលម៉ោង ៧ យប់ បន្ទាប់មកប្រជាជនចាម --ពួកគេបានចាប់ផ្តើមសម្លាប់ប្រជាជនចាម ហើយហេតុអ្វីខ្ញុំអាចនិយាយដូច្នោះ ពីព្រោះកន្លែងដែលខ្ញុំលាក់ខ្លួនស្ថិតនៅប្រហែល ១០០ ម៉ែត្រ ពីរណ្ដៅដែលពួកគេបានកំពុងសម្លាប់ប្រជាជនចាម។ ខ្ញុំបានឮសម្រែក ខ្ញុំបានផ្តេកខ្លួនក្នុងគុម្ពពោតជាមួយប្រពន្ធរបស់ខ្ញុំ ហើយយើងបានឮសម្រែកទាំងនោះ។ យើងថែមទាំងបានឮសំឡេងពីមនុស្សដែលកំពុងត្រូវបានវាយដំ។ យើងបានឮមនុស្សស្រែកហៅឲ្យព្រះអាឡាជួយ។ ពួកគេបានស្រែក "ឱព្រះអាឡាជាម្ចាស់" ហើយជាទូទៅ មនុស្សដែលមិនមែនមូស្លីមមិនស្រែកដូច្នោះទេ លើកលែងតែសាច់ញាតិរបស់ខ្ញុំ ឪពុកម្ដាយរបស់ខ្ញុំ អ្នកភូមិ និងអ្នកជិតខាងរបស់ខ្ញុំ ប្រជាជនចាម ដែលពួកគេបានជួបជុំគ្នានៅពេលដំណាលគ្នាបន់ព្រះអាឡា។ ខ្ញុំនៅទីនោះលាក់ខ្លួនក្នុងគុម្ពពោតពីព្រោះខ្ញុំមិនអាចរត់គេចពីភូមិនេះបានឡើយ ដោយសារមានខ្មែរក្រហមមួយផ្នែកទៀតកំពុងយាមភូមិនេះ"[1538]។

---

[1536] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/349.1** ទំព័រ ៣៣ បន្ទាត់ ២៥-ទំព័រ ៣៤ បន្ទាត់ ១។

[1537] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/349.1** ទំព័រ ៣៨ បន្ទាត់ ៨-១០។

[1538] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/349.1** ទំព័រ ៣៨ បន្ទាត់ ១២-១៨។

769. ក្រោយពេលយប់ដែលដើមបណ្តឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន បានឮសម្រែកទាំងនោះ គាត់បានលាក់ខ្លួនក្នុងស្រះមួយក្បែរវត្ត។ "ជួនកាលខ្ញុំអាចធុំក្លិនស្អុយក្លិនមិនល្អ។ ក្លិនស្អុយក្លាយជាក្រអូប។ ច្រមុះរបស់ខ្ញុំលែងអាចបែងចែកបានទៀតហើយ។ តាមពិតប្រសិនបើសាកសពមនុស្សបានអណ្តែតមកកាន់ទិសដៅរបស់ខ្ញុំ ខ្ញុំនឹងហែកជាចំណែកៗហើយយកមកហូប ដោយសារឃ្លាន។ [...] ច្រមុះរបស់ខ្ញុំពុំដឹងក្លិនស្អុយទៀតឡើយ ប៉ុន្តែធុំក្លិនក្រអូបដែលមកពីរណ្តៅ ដែលឪពុកម្តាយរបស់ខ្ញុំត្រូវបានកប់។ រណ្តៅទាំងនោះនៅជិតកន្លែងរបស់ខ្ញុំ"[1539]។

770. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន បានផ្តល់ភ័ស្តុតាងអំពីរណ្តៅសាកសពនានានៅក្បែរមន្ទីរសន្តិសុខវត្តអូរត្រកួន[1540]។ "ក្រោយឆ្នាំ ១៩៧៩ ខ្លួនខ្ញុំ និងអ្នកភូមិដទៃទៀត បានទៅមើលរណ្តៅសាកសព ដែលអ្នកភូមិបានជីកដើម្បីស្វែងរកមាស។ ក្លិននៅទីនោះគួរឲ្យខ្ពើមរអើម។ មានឆ្អឹងជាច្រើនប៉ុន្តែគ្មានសាច់នៅលើឆ្អឹងទាំងនោះឡើយ។ សាកសពខ្លះមានសម្លៀកបំពាក់ ខ្លះទៀតគ្មានសម្លៀកបំពាក់"[1541]។ គាត់បានផ្តល់សក្ខីកម្មថា "ខ្ញុំដឹងថាឪពុកម្តាយរបស់ខ្ញុំត្រូវបានសម្លាប់នៅទីនោះ។ នោះជាកន្លែងដែលពួកគាត់ត្រូវបានសម្លាប់ ហើយខ្ញុំថែមទាំងបានឮសម្រែកពួកគាត់ទៀតផង។ វាមិនអាចទៅរួចឡើយដែលថាមនុស្សអាចមិនត្រូវបានសម្លាប់នៅទីនោះ។ វាមិនអាចទៅរួចសោះឡើយពីព្រោះក្រោយមក មនុស្សបានទៅជីករណ្តៅទាំងនោះនិងបានប្រទះឃើញគ្រឿងអលង្ការនិងមាស។ ដូច្នេះ ខ្ញុំជឿថាឪពុកម្តាយរបស់ខ្ញុំត្រូវបានសម្លាប់នៅទីនោះ។ ប្រសិនបើពួកគាត់មិនត្រូវបានសម្លាប់ ពួកគាត់ច្បាស់ជាបានវិលត្រឡប់មកភូមិរបស់យើងវិញជាក់ជាមិនខាន"[1542]។

## ១.២. ចេតនាជាក់លាក់

[1539] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/349.1 ទំព័រ ៤៤ បន្ទាត់ ៨-១១។

[1540] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/349.1 ទំព័រ ៤៨ បន្ទាត់ ២១-ទំព័រ ៥០ បន្ទាត់ ៩។

[1541] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/349.1 ទំព័រ ៥០ បន្ទាត់ ១-៤។

[1542] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/349.1 ទំព័រ ៥០ បន្ទាត់ ៥-៩។

771. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន បានពិពណ៌នាអំពីវិធីដែល "ប្រជាជនចាមត្រូវបានបង្ខំឲ្យបរិភាគសាច់ជ្រូក។ សាសនាត្រូវបានលុបបំបាត់។ ហើយយើងមិនត្រូវបានអនុញ្ញាតឲ្យសូត្រធម៌ ធ្វើសក្ការៈ។ សាច់ជ្រូកត្រូវបានផ្តល់ឲ្យយើងបរិភោគ ហើយយើងត្រូវបានប្រាប់ឲ្យកាត់សក់ខ្លី និងដើម្បីក្លាយជាជាតិតែមួយ នោះគឺជាតិខ្មែរ។ គ្មានជាតិដទៃទៀតត្រូវបានអនុញ្ញាតនៅក្នុងប្រ ទេសនេះឡើយ។ មានតែជាតិខ្មែរមួយគត់"[1543]។

772. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ក៏រម្លឹកអំពីថ្ងៃដែលប្រជាជនចាមត្រូវបានប្រមែប្រមូល "ជាបន្តបន្ទាប់ ប្រជាជនចាមមិនត្រូវបានអនុញ្ញាតឲ្យទៅធ្វើការនៅស្រែឡើយ ប៉ុន្តែត្រូវស្នាក់នៅក្នុងផ្ទះរបស់ពួកគាត់រៀងៗខ្លួន ចំណែកប្រជាជនខ្មែរត្រូវបានអនុញ្ញាតឲ្យធ្វើការនៅស្រែ។ ដូច្នេះ ប្រជាជនចាមដែលនៅសេសសល់ពីការជម្លៀសត្រូវបានណែនាំឲ្យបន្តស្ថិតនៅផ្ទះ ហើយខ្ញុំបានឆ្ងល់ថាមានអ្វីកំពុងកើតឡើង ហេតុអ្វីយើងមិនត្រូវបានអនុញ្ញាតឲ្យចាកចេញពីផ្ទះ។ ហើយតាមពិត ពួកគេបានចាប់ផ្តើមប្រមែប្រមូលពួកយើងនៅម៉ោង៣រសៀល ហើយសមាជិករបស់ប្រជាជនទាំងនោះជាសមាជិកក្រុមដាវវែង។ ពួកគេស្លៀកក្រមា ខ្លះស្លៀកខោ ស្លៀកអត់ពាក់អាវ។ ខ្លួនខ្ញុំផ្ទាល់គឺស្ថិតក្នុងចំណោមប្រជាជនចាមដែលកំពុងត្រូវបានប្រមែប្រមូល និងត្រូវបាននាំទៅកាន់រណ្តៅនៅវត្តអូរត្រកួន"[1544]។

773. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន បានពិពណ៌នាអំពីវិធីដែល "បន្ទាប់ពីប្រជាជនចាមទាំងអស់ ត្រូវបានជម្លៀស ហើយគាត់ត្រូវបាននាំយកទៅកាន់ជង្រុកពោត មនុស្សម្នាបានកំពុងនិយាយអំពី ប្រជាជនចាម២នាក់ដែលរួចពីស្លាប់ក្នុងភូមិនេះ ប៉ុន្តែអ្នកភូមិទាំងនេះនៅទីនោះពិតជាចូលចិត្តខ្ញុំ។ អ្នកភូមិថែមទាំងបានដាក់ឈ្មោះខ្មែរឲ្យខ្ញុំ ដើម្បីកុំឲ្យមានបន្សល់អត្តសញ្ញាណចាមតទៅទៀត។ ឈ្មោះខ្មែររបស់ខ្ញុំគឺ លីម ហើយឈ្មោះខ្មែររបស់ប្រពន្ធខ្ញុំគឺ ណា ដើម្បីបង្ហាញថាគ្មានចាមរស់នៅក្នុងភូមិនេះទៀតឡើយ"[1545]។

---

[1543] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ១១ បន្ទាត់ ១៦-១៨។

[1544] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/349.1** ទំព័រ ៣៣ បន្ទាត់ ៤-១២។

[1545] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ីម ម៉ាន ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/349.1** ទំព័រ ៤៦ បន្ទាត់ ១០-១៣។

## ២. ការចាប់ដាក់ពន្ធនាគារ

774. ភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានបង្ហាញនៅសវនាការបង្ហាញថាដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុម ម៉ាន ត្រូវបានដកហូតតាមទំនើងចិត្តនូវសេរីភាពរបស់គាត់ដោយគ្មាននីតិវិធីត្រឹមត្រូវនៃច្បាប់។ ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុម ម៉ាន បានផ្តល់សក្ខីកម្មថាបន្ទាប់គាត់បានចាកចេញពីស្រះនោះ គាត់ត្រូវបានឃុំឃាំងនៅក្នុងជង្រុកពោតមួយ។ "ពួកវាវាយខ្ញុំនឹងដំបង យកខ្ញុំចេញទៅ និងទុកខ្ញុំក្នុងជង្រុកពោតមួយ។ ជង្រុកពោតនោះតាមពិតជាគុកដោយសារវាត្រូវបានរៀបចំដោយសមាជិកក្រុមដាវវែង។ ពួកវារស់នៅជាន់ក្រោម ខ្ញុំជាប់ឃុំនៅខាងលើ។ ជង្រុកនោះត្រូវបានបិទបាំងយ៉ាងល្អ។ វាត្រូវបានសន្មតថាជាកន្លែងដែលមនុស្សត្រូវបានទុកមួយ រយៈមុនពេលត្រូវបានគេយកទៅសម្លាប់នៅវត្តអូរត្រកួន"[1546]។

## ច. ភ័ស្តុតាងដើមបណ្តឹងរដ្ឋប្បវេណីដែលបានបង្ហាញនៅភូមិទ្រា

## ១. ការចាប់ដាក់ពន្ធនាគារ

775. ភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានបង្ហាញនៅសវនាការបង្ហាញថាស្ត្រីចាមត្រូវបានដកហូតតាមទំនើងចិត្តនូវសេរីភាពរបស់ពួកគាត់ ដោយគ្មាននីតិវិធីត្រឹមត្រូវតាមច្បាប់ ក្នុងភូមិទ្រានៅពាក់កណ្តាលឆ្នាំ ១៩៧៨។

[1546] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុម ម៉ាន ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/349.1** ទំព័រ ៥៤ បន្ទាត់ ៣-ទំព័រ ៥៥ បន្ទាត់ ១០។ ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុម ម៉ាន បន្តឲ្យល់ពីរបៀបដែលគាត់រួចផុតជិវិតពីការជាប់ឃុំ ("បងប្អូននៅហ្នឹងគេទៅពិភាក្សាជាមួយ កាន ថាឲ្យទុកខ្ញុំ ខ្ញុំគ្មានទៅទាក់ទងជាមួយពីណាទេ។ នៅរស់នៅក្នុងផ្លុកបឹងបានគេឲ្យខ្ញុំរស់។ ហើយចៅហ្វាយស្រុកកានហ្នឹង ថា មនុស្សវាហ្នឹងអស់ហើយ នៅសល់ចាមពីរទៅឲ្យវានៅទៅ។ នៅទៅពីព្រោះពួកហ្នឹងចេះមុជទឹក ហើយចេះរំលាយស្ពាបព្រា វាចេះរំលាយដែក។ ពួកហ្នឹងឯកភាពឲ្យខ្ញុំនៅ។ តាមចៅហ្វាយស្រុកកានហ្នឹង វាថាឲ្យទុកនៅម្នាក់នេះគ្មានទាក់ទងពីណា នៅក្នុងផ្លុកក្របី ក្នុងបឹងហ្នឹង។ ចឹងវាឲ្យខ្ញុំរស់ទៅ ដោយសារខ្ញុំចេះមុជទឹកៗបាតទន្លេ ដោះមងលឹងត្រីទៅក៏វាអស់ហើយចាមៗអ្នកមុជទឹកអស់ហើយនៅសល់តែខ្ញុំម្នាក់ទេ។ ចឹងវាទុកខ្ញុំ ហើយអ្នករំលាយដែកហ្នឹង ធ្វើស្ពាបព្រា ធ្វើផាលអី ខ្ញុំអ្នករំលាយដែក។ វាទុកខ្ញុំរស់ដល់សព្វថ្ងៃ។ មានរឿងរ៉ាវដែលត្រូវរស់ហ្នឹងច្រើនណាស់។ វាទុកដោយសារខ្ញុំចេះមុជទឹក ចេះស្លដែក ធ្វើស្ពាបព្រា អ្វើអីឲ្យវាប្រើ") សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ុម ម៉ាន ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/349.1** ទំព័រ ៤៥ បន្ទាត់ ១១-២០។

776. ដើមបណ្ដឹងរដ្ឋប្បវេណី នោ សាទះ បានផ្ដល់សក្ខីកម្មថានៅពេលគាត់បានមកដល់ភូមិទ្រាជាមួយស្ត្រីមួយក្រុមដែលមានគ្នា៤០នាក់ ពីភូមិខ្សាច់ប្រឆេះ[1547] "ខ្ញុំអស់កម្លាំងក៏គេងលក់យ៉ាងលឿន ប៉ុន្តែប្រហែល ២០ នាទីក្រោយ យើងបានភ្ញាក់ដោយវត្តមានរបស់គណៈស្រុកឈ្មោះ ហ៊ូ ដែលត្រូវបានឆ្អកដោយទាហាន២នាក់ដែលម្នាក់ជាស្ត្រីដោយមានខ្សែអង្រឹងចងជាប់ដៃ ហើយគណៈស្រុក ហ៊ូ បាននិយាយមកកាន់យើងថា "ក្មួយស្រីក្រោកឡើងឱ្យពូចង"។ យើងពុំបានមានប្រតិកម្មឡើយដោយសារហេតុផលខ្លះ។ ដូច្នេះ ពួកគេបានចងយើង និងដាក់យើង ក្នុងជួរដ៏វែងមួយ។ យើងមានគ្នាប្រហែល ៣០០ ឬ ៤០០ នាក់ក្នុងផ្ទះនោះ។ បន្ទាប់ពីពួកគេបានចង និងដាក់យើងជាជួរ ពួកគេបានសួរយើងថាតើយើងជាជនជាតិចាមឬខ្មែរ។ បន្ទាប់មក បើមាននរណាម្នាក់ឆ្លើយថាខ្លួនជាចាម គាត់នឹងយកអ្នកនោះចេញពីជួរ..."[1548]។

777. ដើមបណ្ដឹងរដ្ឋប្បវេណី នោ សាទះ បានពន្យល់ថា "ខ្ញុំត្រូវបានឃុំឃាំងនៅទីនោះជាមួយស្ត្រីផ្សេងទៀតចំនួន ៩ ថ្ងៃ។ បន្ទាប់មក ពួកគេបានដោះលែងយើង ហើយមុនពេលនោះពួកគេបានធ្វើពិធីជប់លៀងដែលពួកគេបានសម្លាប់ជ្រូកមួយក្បាលដើម្បីធ្វើម្ហូបសម្ភារីសម្រាប់ពួកយើង។ ថ្ងៃនោះ ខ្ញុំត្រូវតែបង្ខំខ្លួនឯងឱ្យបរិភោគសាច់ជ្រូក។ ដូច្នេះ ខ្ញុំបានបរិភោគសាច់ជ្រូកពីរបីដុំដើម្បីរួចពីស្លាប់ ដើម្បីឱ្យពួកគេជឿថាខ្ញុំមិនមែនជាជនជាតិចាម។ បីថ្ងៃក្រោយ យើងត្រូវបានចាត់តាំងជាថ្មីឱ្យធ្វើការនៅតាមប៉ែកនានាក្នុងភូមិទ្រា"[1549]។

## ២. អំពើប្រល័យពូជសាសន៍តាមរយៈ (ការសម្លាប់)

### ២.១. ការសម្លាប់ប្រជាជនចាមនៅភូមិទ្រាក្នុងឆ្នាំ ១៩៧៨

[1547] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/351.1** ទំព័រ ៣១ បន្ទាត់ ១៨-២០។

[1548] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៤៦ បន្ទាត់ ១១-១៧។

[1549] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៤៨ បន្ទាត់ ៦-១១។

778. ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ បានពិពណ៌នាថា "បន្ទាប់ពីពួកគេបានចងនិងដាក់យើងជាជួរ ពួកគេបានសួរយើងថាតើយើងជាចាមឬខ្មែរ"[1550] ហើយអ្នកណាឆ្លើយថាចាម ត្រូវបានយកចេញទៅដោយមនុស្សម្នាក់ដែលកាន់កាំបិត និងកាំភ្លើងស្វាយបត់ ។ ហើយមនុស្សម្នាក់នោះជាទាហាន"[1551]។ គាត់បានពន្យល់ថាស្ត្រីចាម "ត្រូវបានប្រាប់ឲ្យចាកចេញពីផ្ទះ ហើយពួកគាត់ត្រូវបាននាំយកចេញទៅ"[1552] ហើយ "ពួកគាត់បានបាត់ខ្លួនចាប់ពីពេលនោះមក។ គ្មាននរណាម្នាក់បានត្រឡប់មកវិញឡើយ"[1553]។ គាត់បានបញ្ជាក់អះអាងថាស្ត្រីដែលបានឆ្លើយថាខ្លួនជាជនជាតិចាម ត្រូវបានយកចេញទៅ ហើយតាមការប៉ាន់ស្មានរបស់គាត់ ស្ត្រីទាំងនោះមានចំនួនប្រហែល ២៧០ នាក់[1554]។ "ពួកគេបានសួរស្ត្រីទាំងនោះដែលជាចាមនិងដែលមកពីភូមិដទៃទៀត។ ដូច្នេះគ្រប់គ្នាដែលបាននិយាយថាគាត់ជាចាម នឹងត្រូវយកចេញពីផ្ទះ ឆ្កកដោយទាហានដែលប្រដាប់ដោយកាំភ្លើងអាកា ៤៧ ស្វាយបត់ និងកាំបិតផ្គាក់"[1555]។

## ២.២. ចេតនាជាក់លាក់

779. ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ បានផ្តល់សក្ខីកម្មអំពីតួនាទីរបស់ ហ៊ូ គណៈស្រុកក្នុងការពិនិត្យការសួរចម្លើយ និងការសម្លាប់ជនរងគ្រោះចាមជាច្រើននាក់។ គាត់បាននិយាយថា "ហ៊ូ ស្ថិត

[1550] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/350.1 ទំព័រ ៤៦ បន្ទាត់ ១៥-១៦។

[1551] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/350.1 ទំព័រ ៥៦ បន្ទាត់ ១៤-១៦។

[1552] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/350.1 ទំព័រ ៥៦ បន្ទាត់ ១០-១១។

[1553] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/350.1 ទំព័រ ៥៦ បន្ទាត់ ១៥-១៦។

[1554] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/350.1 ទំព័រ ៥៩ បន្ទាត់ ៤-៩។

[1555] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/351.1 ទំព័រ ៣៤ បន្ទាត់ ២១-២៤។

នៅទីនោះ ហើយគាត់ទទួលខុសត្រូវរួមនៅកន្លែងនោះ។ ដូច្នេះ មានវត្តមានរបស់ ហ្វូ គណៈស្រុក ហើយបន្ទាប់មកក៏មានឃោឌាដែរ"[1556]។

780. ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ បានផ្តល់សក្ខីកម្មថា ហ្វូ "បានសួរពួកយើងម្នាក់ៗ។ ទាំងអស់ជាស្ត្រីចាម។ ពួកគេបានសួរទៅស្ត្រីទាំងនោះថានរណាជាចាម និងមកពីភូមដទៃ។ ដូច្នេះ អ្នកដែលនិយាយថាគាត់ជាចាម នឹងត្រូវយកចេញពីផ្ទះ ឆ្កុកដោយទាហាន ដែលប្រដាប់ដោយកាំភ្លើងអាកា ៤៧ ស្ពាយបត់ និងកាំបិតផ្គាក់មួយ"[1557]។

781. ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ បានរម្លឹកថាបន្ទាប់ពីគាត់ត្រូវបានសួរចម្លើយដោយ ហ្វូ "បន្ទាប់មកពួកគេបានយកមនុស្សទាំងអស់នោះចេញទៅ ដែលបានឆ្លើយថាពួកគេជាចាម ហើយមានគ្នាយើងប្រហែល ៣០ នាក់ ហើយបន្ទាប់មកពួកគេស្រាយចំណងពួកយើង ហើយពួកគេបាននិយាយថាយើងមានសំណាង ដោយសារគាត់នៅទីនោះដើម្បីសួរពួកយើង ហើយថាពួកយើងជាខ្មែរ។ បើមិនដូច្នោះ យើងទាំងអស់គ្នានឹងត្រូវបានយកចេញទៅ"[1558]។ ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ បានផ្តល់សក្ខីកម្មថា "គាត់បាននិយាយថាយើងមានសំណាង ដែលវាគឺដោយសារគាត់សួរសំណួរដែលយើងរួចពីស្លាប់។ ប៉ុន្តែនោះពុំពិតទេ។ យើងបានកំហុកគាត់។ ប៉ុន្តែគាត់ជឿ។ យើងបានប្រាប់គាត់ថាយើងជាខ្មែរ ទោះជាយើងមិនមែនខ្មែរក៏ដោយ។ ប៉ុន្តែកាលណោះ យើងនិយាយភាសាខ្មែរដោយគ្មានរដឹនទាល់តែសោះ"[1559]។

---

[1556] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៥៩ បន្ទាត់ ២៣-២៤។

[1557] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/351.1** ទំព័រ ៣៤ បន្ទាត់ ២៣-២៤។

[1558] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៤៧ បន្ទាត់ ១-៣។

[1559] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/351.1** ទំព័រ ៣៨ បន្ទាត់ ១-៤។

782. គាត់បានរម្លឹកបន្ថែមទៀតថា "នៅពេលព្រឹក ពួកគេបានប្រាប់យើងឱ្យសរសេរប្រវត្តិរូបម្តងទៀត។ ខ្ញុំត្រូវបានគេសួរអំពីឈ្មោះឪពុកម្តាយ និងបងប្អូន ហើយខ្ញុំបានប្រាប់ពួកគេថាខ្ញុំឈ្មោះ មុត ឆេង អាន ពុំមែន នោ សាទះ ទេ"[1560]។

783. ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានផ្តល់សក្ខីកម្មថានៅពេលត្រូវបានឃុំឃាំងនៅភូមិទ្រា និងបន្ទាប់ពីគាត់បានលាក់បាំងថាគាត់មិនមែនជាចាម "មានតែក្រុមយើងប៉ុណ្ណោះ ក្រុមស្ត្រីដែលមានគ្នាចំនួន ៣០ នាក់ ត្រូវបានណែនាំឱ្យបរិភោគសម្លសាច់ជ្រូក។ ហើយ ហូ ពុំបានហូបសម្លនោះជាមួយយើងឡើយ។ ប៉ុន្តែគាត់មានទាហាននៅទីនោះ ឃ្លាំមើលយើង ហើយមើលថតើយើងកំពុងបរិភោគសម្លសាច់ជ្រូក ឬអត់។ ប្រសិនបើយើងមិនបរិភោគសម្លសាច់ជ្រូកនោះទេ ពួកគេនឹងដឹងថាយើងជាចាម។ ដូច្នេះយើងត្រូវតែបង្ខំចិត្តបរិភោគសម្លនោះ។ ហើយនោះគឺជាលើកទីមួយដែលខ្ញុំបានបរិភោគសាច់ជ្រូក"[1561]។

### ៣. ការធ្វើមនុស្សឃាត

*ការសម្លាប់ បង ថូ*

784. ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ បានផ្តល់សក្ខីកម្មថា បន្ទាប់ពីត្រូវបានឃុំឃាំងនៅភូមិទ្រាចំនួន ៩ថ្ងៃក្នុងឆ្នាំ ១៩៧៨ "ខ្ញុំត្រូវបានចាត់តាំងឱ្យធ្វើការនៅក្នុងភូមិនេះតាមបណ្តោយច្រាំងទន្លេ។ មនុស្សត្រូវបានសម្លាប់ និងទម្លាក់ចូលក្នុងទន្លេ។ ខ្ញុំបានឃើញសាកសពកុមារអាយុពី១ឆ្នាំ ទៅ ៦ ខែ ក្នុងបាវដែលត្រូវបានចង និងបណ្តែតក្នុងទន្លេ។ ខ្ញុំពិតជាបានចំណាំបងថូពីខ្សាច់ប្រឆេះក្រោម។ គាត់បានធ្វើការជាមួយយុវជនឃុំក្នុងសហករណ៍នោះ។ បំពង់ករបស់គាត់ត្រូវបានអារ ហើយសាកសពរបស់គាត់អណ្តែតក្នុងទន្លេ។ តាមពិត សាកសពរបស់គាត់ពុំហូរតាមទឹកទេ គឺហូរជារង្វង់

[1560] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/350.1 ទំព័រ ៤៧ បន្ទាត់ ១៣-១៦។

[1561] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/350.1 ទំព័រ ៦០ បន្ទាត់ ១៧-២០។

ហើយវាមិនបានលិចទេ។ វាអណ្តែតចុះឡើង។ វាហាក់ដូចជាព្រលឹងមិនចង់ទៅឆ្ងាយ ហើយចង់ស្នាក់នៅទីនោះ។ មនុស្សដែលខ្ញុំស្គាល់គឺថូ"[1562]។

## ឆ. ព្យសនកម្ម

### ១. ព្យសនកម្មលើរូបរាងកាយ

### ១.១. ព្យសនកម្មលើរូបរាយកាយដោយផ្ទាល់

785. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន បានពិពណ៌នាថានៅពេលគាត់បានកំពុងលាក់ខ្លួនក្នុងស្រះក្បែរវត្តអូរត្រកួន ដើម្បីបញ្ចៀសការចាប់ខ្លួនពីសំណាក់ឈ្លប "ខ្ញុំគ្មានចំណីអាហារ គ្មានបាយបរិភោគអស់រយៈពេល ៣ ខែ ២៩ ថ្ងៃ។ សំណាងល្អ សាកសពទាំងនោះមិនបានហូរមកកាន់ទិសដៅរបស់ខ្ញុំ។ ប្រសិនបើសាកសពមួយ ឬពីរ បានហូរចូលមកកាន់ទិសដៅរបស់យើង ខ្ញុំនិងប្រពន្ធច្បាស់ជាហូបសាកសពទាំងនោះ។ ខ្ញុំឃ្លានណាស់ ប្រពន្ធខ្ញុំក៏ឃ្លានដែរ។ ច្រមុះរបស់ខ្ញុំលែងហិតដឹងក្លិនទៀតហើយ ក្រៅពីក្លិនក្រអូបប្រហើរពីរណ្តៅដែលឪពុកម្តាយរបស់ខ្ញុំត្រូវបានកប់"[1563]។

786. បន្ទាប់ពីត្រូវបានឃុំឃាំង និងវាយដំក្នុងជង្រុកពោត ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន បានពិពណ៌នាថា "តាមពិត បើទោះជាខ្ញុំស្តើង ទ្រូងរបស់ខ្ញុំត្រូវបានពង្រីក។ យោងតាមការវាស់វែងរបស់ខ្ញុំ ទ្រូងរបស់ខ្ញុំមានទទឹងប្រហែល ៧ ហាត់ ហើយកជើង របស់ខ្ញុំតូចដូចនេះ។ ខ្ញុំមានចេតនាធាក់ជង្រុកនោះដោយសង្ឃឹមថាខ្ញុំអាចធ្វើវាបានដោយងាយស្រួល។ បន្ទាប់ពីបានមើលខ្លួនឯងម្តងទៀត និងបានដឹងថាខ្ញុំស្តើងពេក ខ្ញុំបានបោះបង់គំនិតនោះចោល"[1564]។

787. ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី ពៅ បានរម្លឹកក្នុងសក្ខីកម្មរបស់គាត់ថា "ពួកគេបានភ្ជង់ខ្ញុំនឹងកាំភ្លើងដោយបានចោទខ្ញុំថាក្បត់អង្គការ។ ពួកគេមានកាំភ្លើងអាកា ៤៧ ចំនួន ៣ ដើម និងកាំភ្លើង អ៊ឹម១៧

[1562] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/350.1 ទំព័រ ៤៩ បន្ទាត់ ៧-១៥។

[1563] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/349.1 ទំព័រ ៤៤ បន្ទាត់ ១១-១៦។

[1564] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/349.1 ទំព័រ ៤៥ បន្ទាត់ ៧-១០។

ចំនួន ២ ដើមតម្រង់មករកខ្ញុំ ថាខ្ញុំត្រូវបានចោទថាជាជនក្បត់របស់អង្គការ ដោយសារខ្ញុំបានលួចស្រូវ។ តាមពិត ខ្ញុំគ្មានកំហុសទេ។ ពួកគេបានវាយខ្ញុំដោយសេរី ដោយគ្មានអាណិត ហើយខ្ញុំនៅទទួលរងរបួសរហូតដល់បច្ចុប្បន្ន។ ដៃរបស់ខ្ញុំត្រូវបានចងទៅក្រោយខ្នង ហើយខ្ញុំត្រូវបានទាញដោយសេះ។ ហើយប្រសិនបើខ្ញុំមិនអាចរត់ទាន់សេះ ខ្ញុំត្រូវបានវាយដំ។ ទីបំផុតខ្ញុំត្រូវបានបញ្ជូនទៅត្រាច់ក្រោល ដែលនៅទីនោះខ្ញុំបានរងការធ្វើបាប រងការដាក់ពន្ធនាគារ និងមិនបានទទួលអាហារ"[1565]។

## ២. ព្យសនកម្មផ្លូវចិត្ត

### ២.១. ព្យសនកម្មផ្លូវចិត្តដោយផ្ទាល់

*អារម្មណ៍ភ័យខ្លាចជាប់ជាប្រចាំ*

788. ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន បានលាក់ខ្លួនដើម្បីគេចពីការយកទៅសម្លាប់នៅវត្តអូរត្រកួន៖ "យើងបានប្រមៀលខ្លួនចូលក្នុងស្រះទឹកមួយ និងបាននៅក្នុងស្រះនោះ។ នៅព្រឹកបន្ទាប់ ពួកគេបានប្រើប្រាស់អាវុធ អ៊ឹម៧៩, បេ៤០ និង អាកា បាញ់មកលើយើងក្នុងស្រះនោះ។ ពួកវាបានបាញ់អាវុធប្រភេទទាំងនេះមករកខ្ញុំក្នុងស្រះនោះ។ ហើយគ្រាប់កាំភ្លើងពុំបានប៉ះខ្ញុំនិងប្រពន្ធខ្ញុំឡើយ ប៉ុន្តែខ្ញុំអាចដឹងអំពីរំញ័រដែលកើតឡើងដោយសារគ្រាប់កាំភ្លើងធំៗទាំងនោះ។ យើងជ្រមុជទឹក និងគ្របក្បាលរបស់យើងជាមួយរុក្ខជាតិ។ ដោយសារការភ័យខ្លាច ប្រពន្ធរបស់ខ្ញុំចង់ងើបពីទឹក ប៉ុន្តែពេលនោះខ្ញុំបានប្រាប់គាត់ឱ្យនៅជ្រមុជក្នុងទឹក ដោយសារគាត់អាចត្រូវបានគេសម្លាប់។ ខ្ញុំបានប្រាប់គាត់ថាពួកគេគ្មានធម៌មេត្តាទេ ហើយគាត់នឹងត្រូវបានសម្លាប់នៅពេលគាត់ងើបពីទឹក។ ខ្ញុំបានប្រាប់ប្រពន្ធខ្ញុំកាលណោះថាពួកគេបានកំពុងបាញ់ស្រោចមកលើយើង។ ពួកគេពុំមែនកំពុងបាញ់សំដៅទៅរកគោលដៅតែមួយឡើយ។ ហើយប្រពន្ធរបស់ខ្ញុំបានស្ដាប់តាមខ្ញុំ ដោយបន្តស្ថិតនៅក្រោមទឹកតទៅទៀតនៅពេលនោះ"[1566]។

---

[1565] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី ពៅ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៧ បន្ទាត់ ១៩-២៥។

[1566] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន ប្រតិចារឹក ថ្ងៃទី ១៧ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/349.1** ទំព័រ ៣៩ បន្ទាត់ ១៩-ទំព័រ ៤០ បន្ទាត់ ២។

### *ការបំបែកពីគ្រួសារ/ការអាណិតសមាជិកគ្រួសារ*

789. ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ាន ស្លេះ បានផ្ដល់សក្ខីកម្មថានៅពេលគាត់ត្រូវបានចាប់ខ្លួន និងឃុំឃាំង បន្ទាប់ពីមានការបះបោរនៅស្វាយឃ្លាំង "កាលណោះ យើងបានជាប់អន្ទាក់របស់ពួកគេ។ ខ្ញុំលែងគិតអំពីខ្លួនឯងទៀតហើយ។ ខ្ញុំព្រួយបារម្ភអំពីសមាជិកគ្រួសាររបស់ខ្ញុំ ដែលត្រូវបានឃុំឃាំងនៅវត្ត និងជាពិសេសប្រពន្ធរបស់ខ្ញុំដែលទើបតែបានសម្រាលបុត្របាន៣ខែ ហើយខ្ញុំព្រួយបារម្ភខ្លាំងអំពីគាត់ និងសមាជិកគ្រួសាររបស់ខ្ញុំ។ ខ្ញុំមានតែយំដោយសារភ័យខ្លាចថា ពួកគាត់អាចទទួលរងការធ្វើបាបដូចដែលខ្ញុំបានកំពុងទទួលរង"[1567]។

790. ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ាន ស្លេះ បានផ្ដល់សក្ខីកម្មថាដោយសាររបបនេះបានបន្ត "ខ្ញុំត្រូវបានបំបែកពីសមាជិកគ្រួសារដទៃទៀតរបស់ខ្ញុំ ខ្ញុំត្រូវបានបង្ខំឲ្យធ្វើការហួសកម្រិត ហើយខ្ញុំត្រូវបានផ្ដល់ឲ្យអាហារបន្តិចបន្តួចដើម្បីបរិភោគ។ ចំណែកប្រពន្ធរបស់ខ្ញុំ ខ្ញុំមិនដែលត្រូវបានអនុញ្ញាតឲ្យជួបគាត់នៅពេលថ្ងៃ ហើយមានតែនៅពេលយប់ប៉ុណ្ណោះ ដែលខ្ញុំអាចជួបប្រពន្ធរបស់ខ្ញុំយូរៗម្ដង។ វាដូចគ្នាចំពោះកូនរបស់ខ្ញុំ ហើយនោះជាពេលដែលខ្ញុំមានអារម្មណ៍ខ្ចិចខ្ចាំ។ ខ្ញុំអាណិតកូននិងប្រពន្ធខ្ញុំ"[1568]។

791. ដើមបណ្ដឹងរដ្ឋប្បវេណី នោ សាទះ បានពិពណ៌នាអំពីវិធីដែល "នៅពេលខ្ញុំក្រឡេកមើលគ្រួសារដទៃដែលសាច់ញាតិរបស់ពួកគាត់នៅរស់ ខ្ញុំអាណិតខ្លួនឯង ជួនកាលខ្ញុំអង្គុយស្ងាត់ស្ងៀម និងយំនៅពេលនឹកឃើញឪពុកម្ដាយខ្ញុំ។ ខ្ញុំហាក់ដូចជាមនុស្សឆ្កួតនៅពេលនោះ។ ខ្ញុំអាណិតប្អូនៗខ្ញុំ។ ខ្ញុំពិតជាអាណិតពួកគាត់ណាស់។ ខ្ញុំចងចាំថានៅពេលពួកគាត់គ្មានអាហារបរិភោគ ពួកគាត់បានផ្ដេកខ្លួនលើដី ហើយពួកគាត់ខ្សោយណាស់ ខ្ញុំត្រូវចេញទៅស្វែងរកអាហារ បន្លែ ឬស្លឹកឈើដើម្បី

---

[1567] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ាន ស្លេះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ E1/393.1 ទំព័រ ៤៥ បន្ទាត់ ១០-១២។

[1568] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ាន ស្លេះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ E1/393.1 ទំព័រ ៥១ បន្ទាត់ ២៥- ទំព័រ ៥២ បន្ទាត់ ៣។

ឲ្យពួកគាត់បរិភោគ។ ពួកគាត់ស្គមស្គាំងណាស់។ ជួនកាលខ្ញុំចង់សម្លាប់ខ្លួនឯង។ ខ្ញុំមិនចង់ឃើញសភាពវេទនាដែលបងប្អូនខ្ញុំជួបប្រទះ”[1569]។

792. ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ បានរម្លឹកថា “រាល់ពេលដែលខ្ញុំរម្លឹកអំពីអ្វីដែលបានកើតឡើងកន្លង មក វាហាក់ដូចជាចិត្តរបស់ខ្ញុំមិនស្ថិតក្នុងខ្លួនរបស់ខ្ញុំទៀតឡើយ ហើយគឺកូនរបស់ខ្ញុំ ដោយសារពួកគាត់ជួនកាលបានលួងលោមខ្ញុំប៉ុន្តែសម្រាប់ខ្ញុំការចងចាំនៅរស់រវើកក្នុងចិត្តរបស់ខ្ញុំ។ ខ្ញុំនឹងប្តូរជីវិត របស់ខ្ញុំដើម្បីអាហារសម្រាប់បងប្អូនខ្ញុំ ហើយខ្ញុំតែសួរខ្លួនឯងថាហេតុអ្វីបងប្អូនខ្ញុំ រួមទាំងម្តាយខ្ញុំ ត្រូវបានគេយកទៅ និងមិនដែលបានវិលត្រឡប់មកវិញ”[1570] ?

*ការគ្មានលទ្ធភាពធ្វើបុណ្យសពរបស់សាច់ញាតិ*

793. ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី ពៅ បានផ្តល់សក្ខីកម្មថានៅពេលគាត់បានដឹងថាឪពុករបស់គាត់ បានស្លាប់ “ខ្ញុំបានឮដំណឹងអំពីការស្លាប់របស់គាត់ ហើយខ្ញុំបានសុំការអនុញ្ញាតពីអង្គការដើម្បីទៅមើលសាកសពរបស់គាត់ ប៉ុន្តែខ្ញុំត្រូវបានប្រាប់ថា “សមមិត្ត ឪពុករបស់អ្នកបានស្លាប់ហើយ”[1571]។

794. ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី ពៅ បានពិពណ៌នាអំពីផលប៉ះពាល់នៃកង្វះពិធីបុណ្យក្រោយពេលឪពុករបស់គាត់ស្លាប់ “បន្ទាប់ពីពេលគាត់ស្លាប់ គ្មានសាច់ញាតិណាម្នាក់បានទៅធ្វើពិធីបុណ្យណាមួយសម្រាប់ការស្លាប់របស់ឪពុកខ្ញុំ។ ក្នុងអំឡុងរបបនោះ គ្មានសាសនា គ្មានការធ្វើបុណ្យសម្រាប់មនុស្សស្លាប់ឡើយ។ ហើយខ្ញុំស្ថិតនៅកន្លែងធ្វើការ ដូច្នេះមានអង្គភាពមួយដែលទទួលបន្ទុកការកប់សាកសព។ សាច់ញាតិរបស់ខ្ញុំខ្លះមិនបានដឹងថាឪ ពុករបស់ខ្ញុំបានស្លាប់ឡើយ។ យើងត្រូវបានបំបែកចេញពីគ្នា។ វាជាទុក្ខវេទនាមួយ”[1572]។

---

[1569] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/351.1 ទំព័រ ៥៥ បន្ទាត់ ២០ -ទំព័រ ៥៦ បន្ទាត់ ៣។

[1570] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ E1/351.1 ទំព័រ ៥៦ បន្ទាត់ ៣-១១។

[1571] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ E1/393.1 ទំព័រ ៩ បន្ទាត់ ៩-១១។

[1572] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ E1/393.1 ទំព័រ ៩ បន្ទាត់ ១៧-២១។

*ព្យសនកម្មទាក់ទងនឹងការបានឃើញអំពើហិង្សា*

795. ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី ពៅ បានពិពណ៌នាអំពីផលប៉ះពាល់ដែលនៅមានអត្ថិភាពនៃអំពើហិង្សាដែលត្រូវបានប្រើប្រាស់ដើម្បីបំភិតបំភ័យនិងត្រួតត្រាគាត់នៅមន្ទីរឃុំឃាំងត្រាចក្រោល។ "ខ្ញុំត្រូវបានឃុំឃាំងនៅមន្ទីរឃុំឃាំងត្រាចក្រោល។ ហើយនៅទីតាំងនោះ ខ្ញុំបានឃើញការសម្លាប់ស្ត្រីម្នាក់។ ស្ត្រីនោះត្រូវបានគេចោទថាបានប្រព្រឹត្តកំហុសសីលធម៌។ គាត់ត្រូវបានគេបញ្ជាឱ្យដោះសម្លៀកបំពាក់របស់គាត់ ហើយខ្លួនរបស់គាត់ត្រូវបានគេវះពីឃោនីដល់ស្បូន។ កាលណោះខ្ញុំជាអ្នកទោស ហើយគេបានបញ្ជាឱ្យខ្ញុំឈរមើលការសម្លាប់ស្ត្រីនោះ។ ហើយកាលណោះ ខ្ញុំមិនអាចមើលឃើញថាតើស្ត្រីនោះមានផ្ទៃពោះឬអត់ឡើយ។ មានឈាមគ្រប់កន្លែងបន្ទាប់ពីខ្លួនរបស់គាត់ត្រូវបានគេវះ។ ថ្លើមត្រូវបានយកចេញពីខ្លួន ហើយថ្លើមនោះត្រូវបានយកទៅស្ងួដើម្បីបរិភោគ។ ពួកគេបានបន្លាចខ្ញុំថាប្រសិនបើខ្ញុំក្បត់ ថ្លើមរបស់ខ្ញុំ នឹងត្រូវគេយកទៅស្ងួធ្វើម្ហូបដែរ។ ខ្ញុំខ្លាចខ្លាំងណាស់នៅពេលនោះពីព្រោះកាលណោះខ្ញុំជាក្មេងតូច"[1573]។

## ២.២. ព្យសនកម្មផ្លូវចិត្តក្នុងរយៈពេលយូរ

### i. ការបាត់បង់សមាជិកគ្រួសារ

*ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន*

796. ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន បានផ្តល់សក្ខីកម្មថា "ខ្ញុំបានបាត់បង់ប្អូនស្រីម្នាក់ដោយសារជំងឺ។ គាត់បានកើតជំងឺគ្រុនចាញ់ខណៈពេលកំពុងរស់នៅក្នុងព្រៃ។ គាត់បានស្លាប់ដោយសារជំងឺគ្រុនចាញ់។ ទាក់ទងនឹងសាច់ញាតិរបស់ខ្ញុំ ខ្ញុំបានបាត់បង់ ៧ គ្រួសារ។ គ្មាននរណាម្នាក់ក្នុងគ្រួសារទាំងនោះបានរួចផុតពីស្លាប់ឡើយ"[1574]។

*ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន*

[1573] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី ពៅ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ១០ បន្ទាត់ ១១-១៨។

[1574] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុះ មីន ប្រតិចារឹក ថ្ងៃទី ៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/343.1** ទំព័រ ៧៦ បន្ទាត់ ៩-១១។

797. ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន បានផ្តល់សក្ខីកម្មក្នុងចម្លើយរបស់គាត់អំពីទុក្ខវេទនាជូនអង្គជំនុំជម្រះថា "នាពេលបច្ចុប្បន្ន ខ្ញុំនៅរងទុក្ខវេទនាពីអ្វីដែលបានកើតឡើងក្នុងអំឡុងរបបនោះ។ ខ្ញុំបានបាត់បង់សេចក្តីសង្ឃឹមទាំងអស់របស់ខ្ញុំ ដោយសារខ្ញុំបានបាត់បង់សាច់ញាតិបង្កើត និងសាច់ញាតិសាច់ឆ្ងាយ ព្រមទាំងទ្រព្យសម្បត្តិ បើទោះជាខ្ញុំមិនចង់និយាយអំពីទ្រព្យសម្បត្តិក៏ដោយ"[1575]។

***ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ***

798. ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ បានពិពណ៌នាថា "នៅពេលខ្ញុំទៅដល់ក្រូចឆ្មា ខ្ញុំមិនបានឃើញសាច់ញាតិ ឬឪពុកម្តាយឡើយ ហើយខ្ញុំបានកត់សម្គាល់ឃើញថាមានប្រជាជនចាមចំនួន ២ ឬ ៣ គ្រួសារនៅទីនោះនៅពេលខ្ញុំមកដល់។ ខ្ញុំបានសួរតើមនុស្សទាំងនេះបានឃើញសាច់ញាតិរបស់ខ្ញុំ ឪពុកម្តាយរបស់ខ្ញុំ និងបងប្អូនរបស់ខ្ញុំដែរឬទេ ប៉ុន្តែពួកគាត់បានឆ្លើយថាទេ។ គ្រប់ពេលដែលខ្ញុំមើលទូរទស្សន៍ និងបានឃើញការផ្សាយអំពីខ្មែរក្រហម អំពីការប្រព្រឹត្តិក្នុងអំឡុង របបនោះ ខ្ញុំយំ។ ខ្ញុំនឹងឪពុកម្តាយខ្ញុំ សាច់ញាតិខ្ញុំ បងប្អូនខ្ញុំ ដែលបានស្លាប់។ ជួនកាលខ្ញុំទៅទីវាលដើម្បីស្រែកខ្លាំងៗដើម្បីបន្ធូរអារម្មណ៍។ គ្រប់ពេលដែលខ្ញុំទៅដាំស្រូវ ខ្ញុំស្រែកច្រៀងដើម្បីបន្ធូរអារម្មណ៍ដូចមនុស្សឆ្កួត ហើយមនុស្សម្នាជួនកាលសួរខ្ញុំហេតុអ្វីខ្ញុំស្រែកនិងយំ ហើយខ្ញុំបានប្រាប់ពួកគាត់ថាទេ ខ្ញុំកំពុងតែមានសកម្មភាពដូចធម្មតា។ ខ្ញុំបានកំពុងទទួលរងទុក្ខវេទ នាចាប់តាំងពីពេលនោះមក។ ខ្ញុំបានរងទុក្ខវេទនាគ្រប់គ្រាន់ហើយ ហើយគ្មានអ្វីអាចប្រៀបធៀបជាមួយទុក្ខវេទនានេះបានឡើយ។ ក្រោយពេលមកដល់ផ្ទះរបស់ខ្ញុំនៅភូមិកំណើត ខ្ញុំបានរៀបការ ហើយក្រោយមកខ្ញុំមានកូន ហើយខ្ញុំអាចមានអារម្មណ៍ធូរស្រាលទៅតាមពេលវេលា។ ប៉ុន្តែខ្ញុំមិនអាចបំភ្លេចហេតុការណ៍នេះបានឡើយ ដែលជាបទពិសោធន៍ដ៏អាក្រក់ដែលខ្ញុំបានជួបប្រទះ"[1576]។

799. គាត់បានបន្ត "ខ្ញុំជាអ្នកនៅរស់តែម្នាក់គត់នៃគ្រួសាររបស់ខ្ញុំ។ កាលណោះ ខ្ញុំមិនទាន់រៀបការទេ។ ខ្ញុំពិតជាអាណិតពួកគាត់ ហើយខ្ញុំមិនសប្បាយចិត្តជាខ្លាំងជាមួយអ្វីដែលបានកើតឡើងចំពោះពួកគាត់។ ខ្ញុំសុខចិត្តស្លាប់ប្រសើរជាងបាត់បង់សមាជិកគ្រួសាររបស់ខ្ញុំ ពីព្រោះកាលណោះខ្ញុំមិនទាន់

---

[1575] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៣៤ បន្ទាត់ ១៤-១៧។

[1576] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ៥១ បន្ទាត់ ២៣-ទំព័រ ៥២ បន្ទាត់ ១៦។

រៀបការប្តីខ្ញុំឡើយ ហើយខ្ញុំបានគិតអំពីការធ្វើអត្តឃាតដោយលោតចូលក្នុងទឹកឱ្យលង់ស្លាប់។ ប៉ុន្តែ ខ្ញុំបានគិតថាប្រសិនបើខ្ញុំស្លាប់ គ្មាននរណាបន្តគ្រួសាររបស់ខ្ញុំឡើយ។ ខ្ញុំក៏បានគិតដែរថាប្រសិនបើខ្ញុំត្រូវរៀបការប្តី និងមានកូន ខ្ញុំនឹងមិនអនុញ្ញាតឱ្យប្តី និងកូនៗរបស់ខ្ញុំ រស់នៅជីវិតលំបាកវេទនាដូច្នោះឡើយ"[1577]។

### *ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី ពៅ*

800. ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី ពៅ បានផ្តល់សក្ខីកម្មថា "ខ្ញុំបានបាត់បង់សមាជិកគ្រួសារជាច្រើន រួមទាំងឪពុក ជីតា ពូមីង និងសាច់ញាតិរបស់ខ្ញុំសរុប ១៧ នាក់។ ខ្ញុំមិនដែលបានឃើញគាត់ម្តងទៀតឡើយ។ ខ្ញុំក៏បានបាត់បង់ក្មួយប្រុសស្រីជាទីស្រឡាញ់របស់ខ្ញុំក្នុងអំឡុងរយៈកាលនោះដែរ។ ហើយវាធ្វើឱ្យខ្ញុំឈឺចាប់ណាស់ ហើយការឈឺចាប់និងទុក្ខវេទនានេះស្ថិតនៅជាមួយខ្ញុំរហូតបច្ចុប្បន្ន"[1578]។ ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី ពៅ បានបញ្ជាក់បំភ្លឺថា "ក្នុងចំណោមមនុស្ស១៧ នាក់ ខ្លះបានស្លាប់ដោយខ្វះអាហារ។ ខ្លះបានស្លាប់ដោយជំងឺគ្រុនចាញ់ ចំណែកខ្លះទៀតត្រូវបាន សម្លាប់ ដោយវះពោះប្រឡាក់អំបិល"[1579]។

### *ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ*

801. ដើមបណ្តឹងរដ្ឋប្បវេណី ម៉ាន ស្លេះ បានពិពណ៌នាអំពីអារម្មណ៍ដែលបាត់បង់គ្រួសារទាំងនៅវ័យក្មេង "ខ្ញុំបានបាត់បង់ឪពុករបស់ខ្ញុំ ហើយក្រោយមកទៀត ខ្ញុំបានបាត់បង់ម្តាយ និងប្អូន៣នាក់ ហេតុដូច្នេះ វាជាការប៉ះពាល់បន្ថែមពីលើការបាត់បង់ឪពុករបស់ខ្ញុំ។ នៅពេលខ្ញុំត្រឡប់ទៅតំបន់នេ

---

[1577] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី នោ សាទះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/351.1** ទំព័រ ៥៥ បន្ទាត់ ១៦-១៩។

[1578] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី ពៅ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៨ បន្ទាត់ ១៨-២១។

[1579] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី ពៅ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៣៤ បន្ទាត់ ១៩-២០។

សាទរបស់ខ្ញុំ ខ្ញុំបានលួចយំ ហើយសហសេវិករបស់ខ្ញុំបានសួរថាខ្ញុំ កើតអ្វី ហើយខ្ញុំបានកុហកពួកគាត់ថាខ្ញុំឈឺពោះ។ ខ្ញុំយំដូចកូនក្មេង"[1580]។

### ii. ព្យសនកម្មផ្លូវចិត្តទាក់ទងការបាត់បង់សាសនា

802. ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី ពៅ បានផ្ដល់សក្ខីកម្មអំពីវិធីដែល "យើងត្រូវបានបង្ខំឱ្យបោះបង់សាសនារបស់យើង និងមិនឱ្យប្រើប្រាស់ភាសាចាម។ ប្រសិនបើនរណានិយាយភាសារបស់យើង អង្គការនឹងយកអ្នកនោះទៅសម្លាប់ ហើយវាបានធ្វើឱ្យយើងភ័យខ្លាច។ យើងគ្មានអ្វីត្រូវពឹងពាក់ក្នុងអំឡុងរបបនោះឡើយ"[1581]។

803. ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី ពៅ បានផ្ដល់សក្ខីកម្មថា "ខ្មែរក្រហមបានបង្ខំឱ្យចាមបរិភោគសាច់ជ្រូក និងបង្ខំឱ្យប្រជាជនចាមធ្វើអ្វីដែលប្រជាជនខ្មែរបានធ្វើ។ ហើយនោះជារឿងពិបាកបំផុតសម្រាប់ប្រជាជនចាម ពីព្រោះយើងបានបាត់បង់អត្តសញ្ញាណ បាត់បង់សាសនារបស់យើង"[1582]។

804. ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី ពៅ បានពិពណ៌នាថា "នេះហើយហៅថាការភ័យខ្លាច ការរន្ធត់ដែលខ្ញុំនៅតូចផង។ អ៊ីចឹងហើយពេលនោះអ្វីៗក៏ខ្ញុំលះបង់ដែរ។ ប្រហែលតែឈ្មោះខ្លួនឯង ក៏ខ្ញុំប្ដូរអស់ដែរ គឺកាលពីមុនខ្ញុំឈ្មោះ អែល មហាម៉ាត់ តែចុងក្រោយមក ខ្ញុំដាក់ឈ្មោះ ម៉ី ពៅ។ អ៊ីចឹងអាឈ្មោះនេះ គឺខ្ញុំរស់លាក់ប្រវត្តិ ខ្ញុំខ្លាចអង្គការ គេតាមដានដឹង ព្រោះអីខ្ញុំជាពិរុទ្ធជនរបស់គេ។ បើគេដឹងថាខ្ញុំចាមទៅទៀត រឹតតែពួកគេវាធ្វើបាបខ្ញុំ។ អ៊ីចឹងពេលនោះហើយ ខ្ញុំអ្វីៗក៏ខ្ញុំលះបងអស់ សូម្បីតែអ្វីក៏ដោយ ឱ្យតែជីវិតបានរស់ ទ្រាំរស់"[1583]។

---

[1580] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ាន ស្លេះ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៤៩ បន្ទាត់ ១៤-១៧។

[1581] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី ពៅ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៦ បន្ទាត់១៧-២០។

[1582] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី ពៅ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៧ បន្ទាត់ ១៣-១៦។

[1583] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី ពៅ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ១០ បន្ទាត់ ១៨-២៣។

805. ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ាន ស្លេះ បានពិពណ៌នាបន្ថែមទៀតអំពីផលប៉ះពាល់នៃរបបនេះ មកលើការបន្តភាសា និងសាសនាចាមទៅមនុស្សជំនាន់ក្រោយ "នៅពេលរបបខ្មែរក្រហមដួលរលំ មនុស្សចាស់ៗនៃសាសនាក៏បានស្លាប់ដែរ ដូច្នេះកុមារបានទៅរៀននៅតាមបណ្ដាប្រទេសអារ៉ាប់ ឬម៉ាឡេស៊ី ដែលបានបន្តការប្រណិប័តន៍សាសនារបស់ពួកគាត់ និងបន្ទាប់មកមានជនជាតិចាមដែលប៉ុន្តែមានទូន ដែលជាគ្រូបង្រៀនភាសាចាមដែលបានចាប់ផ្ដើមបង្រៀន ភាសា និងភាសាខ្មែរ និងអង់គ្លេសទៅកាន់ប្រជាជនទាំងនោះ"[1584]។

## ៣. ព្យសនកម្មសម្ភារៈ

### *ព្យសនកម្មដោយសារកង្វះការអប់រំ*

806. ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី ពៅ បានពិពណ៌នាអំពីផលវិបាកដែលគាត់ជួបប្រទះ ដោយសារកង្វះការអប់រំជាផ្លូវការ "យើងពុំបានទទួលការអប់រំឡើយ ដោយសារហេតុនេះ វាបានប៉ះពាល់មកលើគ្រួសាររបស់ខ្ញុំ និងសង្គមទាំងមូលក្រោយឆ្នាំ ១៩៧៩។ ហើយខ្ញុំសោកស្ដាយ ដែលខ្ញុំមិនបានទទួលព័ត៌មាន ហើយវាប៉ះពាល់-វាប៉ះពាល់ខ្លាំងមកលើជីវភាពរបស់ខ្ញុំដោយសារ គ្មានការអប់រំ។ ទោះយើងព្យាយាមយ៉ាងណា ទោះយើងធ្វើអ្វីក៏ដោយ យើងគ្មានជីវិតដែលប្រសើរ ឡើយ បើប្រៀបធៀបនឹងអ្នកដទៃដែលបានទទួលការអប់រំ។ ដោយសារគ្មានការអប់រំ ការរស់នៅប្រចាំថ្ងៃជួបការលំបាក"[1585]។

### *ព្យសនកម្មដោយសារការបាត់បង់ទ្រព្យសម្បត្តិ*

807. ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី ពៅ បានផ្ដល់សក្ខីកម្មអំពីព្យសនកម្មដែលគាត់បានជួបប្រទះ នៅពេលត្រូវបានបង្ខំឱ្យផ្លាស់ទីលំនៅពីភូមិរបស់គាត់។ "យើងត្រូវបានប្រាប់ឱ្យចាកចេញពីភូមិកំណើតរបស់យើង។ យើងត្រូវបោះបង់កម្មសិទ្ធិរបស់យើង ផ្ទះ ដីរបស់យើង។ យើងត្រូវម្ចាស់ការលើខ្លួនឯងដោយគ្មានអ្វីទាំងអស់ ដូច្នេះកម្មសិទ្ធិ និងទ្រព្យសម្បត្តិទាំងអស់ដែលឪពុកម្ដាយខ្ញុំបានទុក

[1584] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ាន ស្លេះ ប្រតិចារិក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៥៣ បន្ទាត់ ២២-២៥។

[1585] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី ពៅ ប្រតិចារិក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ១៣ បន្ទាត់ ៥-១១។

សម្រាប់ពួកយើងទាំងអស់គ្នា សម្រាប់គ្រួសាររបស់ខ្ញុំ ត្រូវបានរឹបអូសទាំងអស់ដោយខ្មែរក្រហម។ ដូច្នេះវាបានបង្កឱ្យមានការលំបាក និងប៉ះពាល់មកលើខ្ញុំ និងសាច់ញាតិរបស់ខ្ញុំ ដូច្នេះខ្ញុំ មិនបាន ទទួលមរតកអ្វីពីឪពុកម្ដាយរបស់ខ្ញុំឡើយដោយសាររបបនេះ"[1586]។ "យើងត្រូវបានប្រាប់ឱ្យបោះបង់ទ្រព្យសម្បត្តិ។ អ្នកដែលមិនបោះបង់កម្មសិទ្ធិរបស់ខ្លួន និងមិនចាកចេញពីភូមិរបស់ខ្លួន នឹងត្រូវអង្គការសម្លាប់"[1587]។ "យើងត្រូវបានប្រាប់ឱ្យបោះបង់ទ្រព្យសម្បត្តិ និងរបស់របរគ្រប់យ៉ាងរបស់យើង"[1588]។

## ជំពូក ៧. ការប្រព្រឹត្តិលើជនជាតិវៀតណាម[1589]

[1586] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី ពៅ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ១៣ បន្ទាត់ ១៨-២៣។

[1587] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី ពៅ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ១៤ បន្ទាត់ ២៤-ទំព័រ ១៥ បន្ទាត់ ១។

[1588] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី ពៅ ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ១៤ បន្ទាត់ ៥។

[1589] ក្នុងបរិបទនៃការប្រព្រឹត្តិលើជនជាតិវៀតណាម ដីកាដំណោះស្រាយចាត់ទុកថា វៀតណាមជាក្រុមជាតិសាសន៍ ជាតិពន្ធុ និងពូជសាសន៍មួយ។ ផ្នែកមួយនៃគោលនយោបាយ "ដើម្បីអនុវត្ត និងការពារ ដំវត្តសង្គមនិយមរបស់ ប.ក.ក. តាមរយៈការកំណត់គោលដៅលើក្រុមជាក់លាក់មួយ តាមមធ្យោបាយទាំងអស់តាមការចាំបាច់"។ ក.ស.ច.ស. បានទទួលការប្ដឹងពីការប្រព្រឹត្តិ "លើជនជាតិវៀតណាមនៅខេត្តព្រៃវែង និងខេត្តស្វាយរៀងនៅភូមិភាគបូព៌ា និងនៅអំឡុងពេលវាយលុកចូលក្នុងប្រទេសវៀតណាម"។ ទាក់ទងនឹងការប្រព្រឹត្តិលើជនជាតិវៀតណាម "គោលនយោបាយនេះមានអត្ថិភាពមុនឆ្នាំ ១៩៧៥ ហើយបន្តរីករាលដាល នៅទូទាំងរបបកម្ពុជាប្រជាធិបតេយ្យ" ដោយមានការបណ្ដេញចេញជនជាតិវៀតណាម ដែលបានកើតមានតាំងពីឆ្នាំ ១៩៧០ និងបានបន្តដោយ ក.ប.ប. ពីឆ្នាំ ១៩៧៣ និងបន្តពីឆ្នាំ១៩៧៥ និងឆ្នាំ ១៩៧៦"។ មានការអះអាងថា "ចាប់ពីខែមេសា ឆ្នាំ១៩៧៧ ប.ក.ក. មានគម្រោងបន្តធ្វើគោលនយោបាយនេះដោយបំផ្លាញក្រុមជនជាតិវៀតណាមនេះទាំងមូល ឬជាផ្នែក" និង "ពីឆ្នាំ ១៩៧៧ទៅ ការសម្លាប់ទ្រង់ទ្រាយធំដែលមានគោលដៅលើប្រជាជនវៀតណាមបានកើតឡើង ទូទាំងខេត្តព្រៃវែង និងខេត្តស្វាយរៀង នៅភូមិភាគបូព៌ា"។ មានការអះអាងបន្ថែមទៀតថា "មានភ័ស្តុតាងបន្ថែមពីការកំណត់គោលដៅ និងសម្លាប់ប្រជាជនវៀតណាម នៅទូទាំងប្រទេសកម្ពុជា ដូចបានលើកឡើង ក្នុងដីកាដំណោះស្រាយ ទាក់ទាងនឹង ការកត់សម្គាល់លើអង្គហេតុ អំពីឧក្រិដ្ឋកម្មនានា ជាពិសេស នៅភូមិភាគឥសាន និងភូមិភាគឧត្តរ"។ គោលនយោបាយ ដែលបានកំណត់ជាគោលដៅនេះ ត្រូវបានអះអាងថាធ្វើឡើងដោយឈរលើមូលដ្ឋាននៃ "ទ្រឹស្ដីនៃអ្នកមានទំនាក់ទងគ្រួសារ" និង "ត្រូវបានអនុវត្ត ទូទាំងខេត្តព្រៃវែង និងខេត្តស្វាយរៀង ក៏ដូចជាតាមផ្នែកខ្លះៗទៀតនៃប្រទេសផងដែរ"។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៧៩១។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ២០៥។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ២០៦។ ដីកាដំណោះស្រាយ ឯកសារ **D472** កថាខណ្ឌ ២១៣។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ២១៣។ ដីកា

## ក. និជ្ជភាពទូទៅនៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី

808. ដើមបណ្តឹងរដ្ឋប្បវេណីចំនួន២នាក់ ចឹង យាំងថៃត និងប្រាក់ ខឿន បានផ្តល់សក្ខីកម្មក្នុងអំឡុងពេលនៃការជំនុំជម្រះទាក់ទងនឹងជនជាតិវៀតណាមអំពីបទពិសោធន៍របស់ពួកគេនៅក្នុងខេត្តកំពង់ឆ្នាំង

---

ដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ២១៤។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ២១៤។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ២១៤។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ២១៥។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ២១៥។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៧៩១។

ក្នុងបរិបទនេះ អង្គជំនុំជម្រះសាលាដំបូងទទួលបានអង្គហេតុដែលទាក់ទងទៅនឹង (i) និយមន័យនៃក្រុមគោលដៅ (ii) ភស្តុតាងប្រជាសាស្ត្រដែលពន្យល់ពីចំនួនជនជាតិវៀតណាមដែលត្រូវបានបណ្តេញ ឬសម្លាប់នៅចន្លោះឆ្នាំ ១៩៧៥ និង១៩៧៩ (iii) ដំណើររបស់ជនជាតិវៀតណាមពីប្រទេសកម្ពុជាទៅវៀតណាមនៅឆ្នាំ ១៩៧៥ និងឆ្នាំ១៩៧៦ ពីខេត្តព្រៃវែង និងខេត្តស្វាយរៀង និងទូទាំប្រទេសកម្ពុជា (iv) ការសម្លាប់ប្រជាជនវៀតណាមនៅខេត្តព្រៃវែង និងខេត្តស្វាយរៀងនៅឆ្នាំ ១៩៧៧ ១៩៧៨ និង ១៩៧៩ (v) ការសម្លាប់ប្រជាជនវៀតណាមនៅក្រៅខេត្តព្រៃវែង និងខេត្តស្វាយរៀង ជាពិសេសការកំណត់ការសម្លាប់រង្គាលនៃជនជាតិវៀតណាមនៅឆ្នាំ ១៩៧៨ និងទូទាំងប្រទេសកម្ពុជា រួមមាន ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តមណ្ឌលគិរី ខេត្តកំពត ខេត្តតាកែវ ខេត្តក្រចេះ ខេត្តកោះកុង ក្រូចឆ្មារ និងខ្សាច់កណ្តាល (vi) ការឃុំខ្លួន និងការសម្លាប់ប្រជាជនវៀតណាម នៅមន្ទីរសន្តិសុខនានា ជាពិសេស ស-២១ គ្រាំងតាចាន់ ព្រៃដំរីស្រុត កោះខ្សង គោកក្តួច និងមន្ទីសន្តិសុខអូរកន្សែង ដែល កងទ័ពវៀតណាមចារាយចំនួន ២០៩ នាក់ ត្រូវបានចាប់ខ្លួន និងសម្លាប់នៅ ខែ មិថុនា នៃឆ្នាំ ១៩៧៧ និង (vii) ការប្រព្រឹត្តិលើជនជាតិខ្មែរដែលមានប្តី ឬប្រពន្ធជាជនជាតិវៀតណាម និងក្មេងដែលមានឪពុក ឬម្តាយ ដែលជាជនជាតិវៀតណាម។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៧៩១។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៧៩២-៧៩៣។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៧៩៤-៧៩៦។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៧១៩-៨០១។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៨០៣។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៨០៤។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៨០៥-៨១៣។ អង្គជំនុំជម្រះសាលាដំបូងក៏បានទទួលអង្គហេតុទាក់ទងនឹងសង្គ្រាមប្រឆាំងជនជាតិវៀតណាម និងការឃោសនាបោសសម្អាត។ ដីកាសម្រេចស្តីពីការបំបែកសំណុំរឿង មិនរួមបញ្ចូលឧក្រិដ្ឋកម្មដែលប្រព្រឹត្ត ដោយកងទ័ពបដិវត្តន៍កម្ពុជានៅលើទឹកដីវៀតណាមក្នុងវិសាលភាពនៃអង្គជំនុំជម្រះនេះឡើយ។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៨១៤-៨១៨។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៨១៩-៨១៣។ ដោយផ្អែកលើមូលដ្ឋានអង្គហេតុដែលបានអះអាងខាងលើទាក់ទៅនឹងការប្រព្រឹត្តិលើជនជាតិវៀតណាម ជនត្រូវចោទត្រូវបានចោទប្រកាន់ពី៖ អំពើប្រល័យពូជសាសន៍ តាមរយៈការសម្លាប់ ការធ្វើឃាត (អ្នកដែលមិនព្រមនិរទេសនៅឆ្នាំ ១៩៧៥-១៩៧៦ រួចមកកើតឡើងយ៉ាងទូលំទូលាយនៅដើមឆ្នាំ ១៩៧៧) ការសម្លាប់រង្គាល (នៅដើមខែ មេសា ឆ្នាំ ១៩៧៧) ការនិរទេស (នៅខេត្តព្រៃវែង ខេត្តស្វាយរៀង និងនៅតាមសហករណ៍ត្រាំកក់ បន្ទាប់ពី ប.ក.ក. ឡើងកាន់អំណាចរហូតដល់ឆ្នាំ ១៩៧៦) ការធ្វើទុក្ខបុកម្នេញពូជសាសន៍ (ខេត្តព្រៃវែង ខេត្តស្វាយរៀង និងនៅសហករណ៍ត្រាំកក់) និងអំពើអមនុស្សធម៌ដទៃទៀតតាមរយៈការបាត់ខ្លួន។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៣៤៣-១៣៤៩ ១៣៨១ ១៣៨៥។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៣៧៣ ១៣៧៨។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៣៨១ ១៣៨៧។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៣៩៧-១៤០១។

និងដើមបណ្ដឹងរដ្ឋប្បវេណីចំនួន២នាក់ គឺឡាច គ្រី និង ដួង អឿន បានផ្ដល់សក្ខីកម្មអំពីការបាត់បង់សាច់ញាតិរបស់ពួកគេនៅក្នុងភូមិពោធិ៍ចិន្ដាំ ក្នុងខេត្តព្រៃវែង។ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន៣នាក់ ឈ្មោះ សៀង ចាន់ធី, ខូង មួយ និង អ៊ុច សាន់ឡាយ បានផ្ដល់សក្ខីកម្មអំពីព្យសនកម្មដែលពួកគេបានទទួលរងជាលទ្ធផលនៃការប្រព្រឹត្តិលើជនជាតិវៀតណាម ក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ[1590]។

809. ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំងចែត គឺជាជនជាតិភាគតិចវៀតណាម ហើយឪពុកម្ដាយរបស់គាត់ជាជនជាតិភាគតិចវៀតណាម[1591]។ គាត់កើតនៅក្នុងប្រទេសកម្ពុជានៅក្នុងឫស្សីដង្កួច ក្នុងស្រុកកំពង់លែង, ខេត្តកំពង់ឆ្នាំង ដូចឪពុកម្ដាយរបស់គាត់ដែរ[1592]។ គាត់បានផ្ដល់សក្ខីកម្មថាគាត់ត្រូវបានយកទៅប្រទេសវៀតណាមក្នុងឆ្នាំ ១៩៧៥ ហើយនៅពេលដែលហេតុការណ៍កើតឡើងនោះ គាត់មានអាយុ១៣ ឬ១៤ឆ្នាំ[1593]។

810. ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំងចែត បានពិពណ៌នាអំពីដំណើរការនៃការបញ្ជូនគាត់ចេញពីឫស្សីដង្កួច, ស្រុកកំពង់លែង, ខេត្តកំពង់ឆ្នាំង ទៅកាន់ប្រទេសវៀតណាម។ ដើមបណ្ដឹងរដ្ឋប្បវេណីបានពន្យល់ថា នៅពេលនោះមានក្រុមគ្រួសារវៀតណាមចំនួន៣០ រស់នៅក្នុងភូមិរបស់គាត់ ហើយមាន "ក្រុមគ្រួសារខ្មែរច្រើនជាង" ដែលរស់នៅក្នុងភូមិ និងឃុំនោះ ក៏ប៉ុន្តែដើមបណ្ដឹងរដ្ឋប្បវេណីពុំអាចប៉ាន់ស្មានចំនួនបានទេ[1594]។ គាត់បានផ្ដល់សក្ខីកម្មថា ក្រុមគ្រួសាររបស់ គាត់ត្រូវបាន

---

[1590] ក.ស.ច.ស. ទទួលស្គាល់ ដើមបណ្ដឹងរដ្ឋប្បវេណី ៦៨នាក់ ពាក់ព័ន្ធនឹងការប្រព្រឹត្តិលើលើជនជាតិវៀតណាម (ដីកាដំណោះស្រាយ ឯកសារ D427 កថាខណ្ឌ ៨៤១) ហើយ ១៥នាក់ទៀត ត្រូវបានទទួលស្គាល់ដោយ អ.ប.ជ។

[1591] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ២៩ បន្ទាត់ ២០-២៥។

[1592] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ២៦ បន្ទាត់ ១៦ និងទំព័រ ២៨ បន្ទាត់ ២២-២៣។ ឈ្មោះភូមិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានបកប្រែមិនស្របទៅជា ស្រែតាគុយ និង ឫស្សីដង្កួច។ ដើម្បីជាការបញ្ជាក់ ឫស្សីដង្កួចត្រូវបានយកមកប្រើ ដោយសារវាជាភូមិដែលធ្លាប់បានកំណត់អត្តសញ្ញាណនៅក្នុងផ្នែកទាំងនេះនៃប្រតិចារឹកដែលបានកែតម្រូវ។ *សូមមើលផងដែរ* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៣១ បន្ទាត់ ១៦-១៧, ទំព័រ ៦១ បន្ទាត់ ៥-១១។

[1593] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៣០ បន្ទាត់ ២០-២១, ទំព័រ ៣២ បន្ទាត់ ១៥-១៨, ទំព័រ ៥៧ បន្ទាត់ ១៨-២០។

[1594] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៣២ បន្ទាត់ ១-២។

ខ្មែរក្រហមធ្វើបាបនៅក្នុងភូមិរបស់គាត់ និងបាននិយាយថា ប្រសិនបើពួកគេបន្តរស់នៅទីនោះ ពួកគេទាំងអស់នឹងត្រូវស្លាប់[1595]។ ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា ពួកគេ រួមទាំងដើមបណ្តឹងរដ្ឋប្បវេណី និងគ្រួសាររបស់គាត់បានភៀសខ្លួនទៅនៅជិតក្រុងកំពង់ឆ្នាំង[1596] ក្នុងឆ្នាំ ១៩៧៥[1597] ដោយសារពួកគេមានការភ័យខ្លាច។ គាត់បានថ្លែងថា គ្រប់ៗគ្នាមានក្រុមគ្រួសារវៀតណាម ក្រុមគ្រួសារខ្មែរ និងក្រុមគ្រួសារចាម បានមករស់នៅក្នុងភូមិកណ្តាល ក្នុងខេត្តកំពង់ឆ្នាំង[1598]។ គាត់បានផ្តល់សក្ខីកម្មថា គ្រួសារគាត់រស់ នៅក្នុងភូមិកណ្តាល អស់រយៈពេលលើសមួយខែបន្តិច មុននឹងពួកគេត្រូវបានជម្លៀសទៅភូមិដដែលមានចម្ងាយប្រហែល១៥ ទៅ២០គីឡូម៉ែត្រពីភូមិកណ្តាល[1599] និងបានពន្យល់ថា ការប្តូរទីតាំងទៅភូមិដា គឺត្រូវបានបង្ខំ ហើយផ្ទះដែលពុំមានមនុស្សរស់នៅត្រូវបានដុតចោល[1600]។ ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំងចែត បានផ្តល់សក្ខីកម្មថា ប្រជាជនចំនួន១០០០គ្រួសារ ត្រូវបានបញ្ជូនពីភូមិកណ្តាលទៅកាន់ភូមិដា ដែលមានទីតាំងនៅក្នុងស្រុក១៨ផងដែរ។ ទោះយ៉ាងនេះក្តី គាត់ពុំចងចាំអំពីសមាសភាពជាតិពន្ធុនៃក្រុមគ្រួសារទាំងនោះទេ ប៉ុន្តែគាត់បានថ្លែងថា ទំនងជាមានក្រុមគ្រួសារវៀតណាមច្រើនជាង[1601]។ ដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ជាក់ថា ចំពោះក្រុមគ្រួសារដែលត្រូវបានបញ្ជូនជាមួយគាត់ទៅកាន់ភូមិដា គ្រួសារទាំងអស់នោះ ជាគ្រួសារវៀតណាម ហើយមួយក្រុមទៀត គឺមានលាយឡំរវាងក្រុម

---

[1595] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៣១ បន្ទាត់ ២១-២៣។

[1596] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៣១ បន្ទាត់ ២១-២៣។

[1597] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៣២ បន្ទាត់ ១៧-១៨។ ដើម្បីដឹងពីរយៈពេល *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៣២ បន្ទាត់ ១៦-១៧។

[1598] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៣២ បន្ទាត់ ៦-៧។

[1599] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៣១ បន្ទាត់ ១៦-១៧ និងទំព័រ ៣២ បន្ទាត់ ១៧-១៨។

[1600] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៣២ បន្ទាត់ ២៤-ទំព័រ ៣៣ បន្ទាត់ ១។

[1601] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៣២ បន្ទាត់ ១-៧។

គ្រួសារខ្មែរ និងក្រុមគ្រួសារវៀតណាម[1602]។ ដើមបណ្តឹងរដ្ឋប្បវេណី និងគ្រួសាររបស់គាត់បានរស់នៅក្នុងភូមិដដាអស់រយៈពេលជាងមួយខែបន្តិច[1603]។

811. ដើមបណ្តឹងរដ្ឋប្បវេណី បានពិពណ៌នាអំពីការបញ្ជាឲ្យចេញពីផ្ទះដោយក្រុមតាពាង ដែលមានគ្នាចំនួន៨នាក់ប្រដាប់ដោយអាវុធ៨ដើម, ពូថៅមួយ និងពីងពុង និងស្លៀកពាក់ខ្មៅជាមួយនឹងក្រមាចងក[1604] ហើយសមាជិកគ្រួសាររបស់គាត់ម្នាក់ៗ ត្រូវបានចាប់ចង[1605]។ សមាជិក៤នាក់នៃគ្រួសារនៅផ្ទះជាប់គ្នា ដែលក៏ជាជនជាតិភាគតិចវៀតណាម[1606] ក៏ត្រូវបានចាប់ចង ហើយយកចេញទៅ[1607]។ ដើមបណ្តឹងរដ្ឋប្បវេណី បានពិពណ៌នាអំពីវិធីដែលពួកគេត្រូវបានដាក់នៅកន្លែងនៅជិតរណ្តៅមួយ ហើយពួកគេម្នាក់ៗត្រូវបានបណ្តើរទៅរណ្តៅ ហើយត្រូវបានសម្លាប់[1608]។ គាត់បានដឹងហេតុការណ៍នេះ ពីព្រោះនៅពេលដែលដល់វេនគាត់ គាត់បានឃើញសាកសពឪពុកម្តាយរបស់គាត់ និងបងប្អូនបង្កើតរបស់គាត់នៅក្នុងរណ្តៅ[1609]។ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្ម

---

[1602] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៣២ បន្ទាត់ ៨-១១។

[1603] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៣២ បន្ទាត់ ១៥-១៨។

[1604] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ឯកសារ **E1/363.1** ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ទំព័រ ៣៥ បន្ទាត់ ១៧-២២។

[1605] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/364.1** ទំព័រ ២២ បន្ទាត់ ២៥ ទំព័រ ២៣ បន្ទាត់ ១។

[1606] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ **E1/363.1** ទំព័រ ៣៧ បន្ទាត់៨-១១។

[1607] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/364.1** ទំព័រ ២៣ បន្ទាត់ ១-២។

[1608] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/364.1** ទំព័រ ៣ បន្ទាត់ ២-៣។

[1609] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/394.1** ទំព័រ ២៣ បន្ទាត់ ៣-៤។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ឯកសារ **E1/363.1** ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ទំព័រ ៣៦ បន្ទាត់ ១-២។

ថា នៅពេលនោះ គាត់ត្រូវបានវាយបីពូថៅចំកញ្ចឹងករបស់គាត់ បាក់ឆ្អឹងមួយ[1610]។ កម្មាភិបាលចំនួន៨នាក់នៅទីនោះ ហើយពួកគេស្មានថាគាត់បានស្លាប់ហើយ។ ពួកគេស្រាយចំណងគាត់ ដោះខ្សែចំណងចេញ និងបានចាកចេញ[1611]។

812. គាត់បានរៀបរាប់ថា បន្ទាប់ពីបានរួចជីវិតពីការសម្លាប់ នៅម៉ោងប្រហែលម៉ោង៤ នៅពេលថ្ងៃ គាត់បានដឹងខ្លួនឡើងវិញ ហើយឈឺចាប់យ៉ាងខ្លាំងនៅករបស់គាត់។ គាត់បានបង្ខំចិត្តដើរទាំងយប់ទាំងថ្ងៃទៅកាន់ឃុំជើងគ្រោះ ហើយគាត់បានទៅផ្ទះតាលីនៅក្នុងភូមិនោះ[1612]។ តាលីត្រូវបានក្រុមតាពាងចាត់ឱ្យរស់នៅក្នុងភូមិអណ្តែតទឹកមួយដើម្បីរកត្រី និងធ្វើប្រហុក[1613]។ គាត់នៅចាំថាគាត់ចំណាយពេលមួយថ្ងៃនិងមួយយប់មុនពេលគាត់ទៅដល់ផ្ទះ[1614]។ គាត់បានផ្តល់សក្ខីកម្មថា បន្ទាប់ពីបានមកដល់ផ្ទះតាលី ពួកគេបានជួយគាត់និងផ្តល់ឱសថសម័យ និងបុរាណដល់គាត់[1615]។

813. ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំងចែត បានរៀបរាប់ពីរបៀបដែលគាត់បានស្នាក់នៅផ្ទះរបស់តាលី រយៈពេលមួយខែ មុនពេលដែលគេបានប្រាប់ពួកគេថាជនជាតិវៀតណាមត្រូវចាកចេញតាមទន្លេទៅកាន់ប្រទេសវៀតណាម[1616]។ នៅពេលនោះ តាលី បានប្រាប់ដើមបណ្តឹងរដ្ឋប្បវេណីឱ្យ

---

[1610] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៣៦ បន្ទាត់ ១៥-១៧។

[1611] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៣៧ បន្ទាត់ ១៣-១៤។

[1612] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៣៩ បន្ទាត់ ៩-១២។

[1613] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៣៩ បន្ទាត់ ២៤ -២៥។

[1614] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/364. 1** ទំព័រ ២៦ បន្ទាត់ ១២-១៣។

[1615] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៣៩ បន្ទាត់ ២៤-២៥ ទំព័រ ៤០ បន្ទាត់ ១-២។

[1616] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៤៧ បន្ទាត់ ១០-១៤។

852. គាត់បានផ្តល់សក្ខីកម្មថា "ខ្ញុំឮថាវៀតណាមគេឡើង គេនិយាយមុខខ្ញុំអីចឹងដែរ គេថា "ខ្ញុំរស់នឹងអង្ករអំបិលហ្នឹងហើយ ខ្ញុំដូរអស់លោកឯងទៅស្រុកយួនហ្នឹងហើយ"[1775]។ ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា "ខ្ញុំនៅ *(ឮមិនច្បាស់)* នៅៗហ្នឹងគេរុញឱ្យខ្ញុំឡើងសាលារៀន *(ឮមិនច្បាស់)*។ ហើយគេចិញ្ចឹមខ្ញុំ៧ថ្ងៃនៅសាលារៀនហ្នឹង គេបានគេស៊ីញ្ញេសំបុត្រអី គេបានបញ្ជូនទៅទឹកជូរ ទឹកផឹកមិនបាន ទឹកហ្នឹងគេហៅថាទឹកជូរ។ ហើយគេឱ្យនៅហ្នឹង"[1776]។

### *ការជម្លៀសជនជាតិភាគតិចវៀតណាម*

853. ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំងចែត បានផ្តល់សក្ខីកម្មទាក់ទងនឹងការជម្លៀសប្រជាជនវៀតណាមពីប្រទេសកម្ពុជាទៅប្រទេសវៀតណាម ដែលធ្វើដំណើរនៅលើទូកជាមួយគាត់ ឬនៅលើទូកផ្សេងទៀតតាមដងទន្លេ។ ទាក់ទងនឹងការធ្វើដំណើរតាមទូកតាលីទៅភ្នំពេញ គាត់បានថ្លែងថា "...ទៅតាមផ្លូវទឹកហ្នឹង ខ្ញុំឃើញប្រហែលចូល៥០, ៦០អី ទូកចេញដំណើរទៅភ្នំពេញ"[1777]។ បន្ទាប់ពីបានមកដល់ភ្នំពេញ និងចាកចេញពីតាលី គាត់បានផ្តល់សក្ខីកម្មថា គាត់ពុំដឹងថាតើអ្នកនៅលើទូកផ្សេងទៀត ឡើងជិះសាឡាង់ជាមួយគាត់ដែរឬទេ[1778]។ នៅពេលគាត់មកដល់អ្នកលឿង

---

[1774] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ E1/363.1 ទំព័រ ៥៤ បន្ទាត់ ២-៤។

[1775] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ E1/363.1 ទំព័រ ៥៦ បន្ទាត់ ២៥ - ទំព័រ ៥៧ បន្ទាត់ ១។

[1776] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ E1/364.1 ទំព័រ ៣៦ បន្ទាត់ ១៧-១៩។

[1777] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ E1/363.1 ទំព័រ ៦៨ បន្ទាត់ ២៣-២៤។

[1778] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ E1/364.1 ទំព័រ ៣៦ បន្ទាត់ ៧-១០។

តាមទូកនោះ គាត់បានលើកឡើងថា "បាទ មានឃើញ។ ប៉ុន្តែខ្ញុំចំណាំ ច្រើនតិច ខ្ញុំមិនចំណាំមិនបាន ប្រហាក់ប្រហែល២០ទូក៣០ទូកអីហ្នឹង បានមកពីក្រោយខ្ញុំហ្នឹង"[1779]។

854. ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឌឿន បានផ្តល់សក្ខីកម្មថានៅពេលដែលគាត់រស់នៅកោះតាម៉ូវ ពីឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៧[1780] "ខ្ញុំបាទក៏បានឮសួរសម្តីប្រធានកងថា កម្លាំងដែលគេត្រូវប្រមូលបងប្អូនប្រជាជនវៀតណាមហ្នឹង ដើម្បីឱ្យធ្វើដំណើរទៅប្រទេសខ្លួនវិញ។ គេក៏ប្រកាសដែរ គេប្រកាសប្រាប់ថា បើអ្នកណាចង់ទៅ ឆាប់ទៅឱ្យហើយ បាទអីចេះ។ តែដោយសារប្រពន្ធខ្ញុំថា មិនព្រមទៅទេ នៅងាប់ជាមួយប្តីហ្នឹង ក៏សុខចិត្តនៅងាប់មែន ដូចពាក្យដែលប្រពន្ធខ្ញុំបាទថា"[1781]។ "ខ្ញុំបាទជម្រាបជូន ឃើញគេប្រមូលក្នុងទូកដំបូលមួយ ដែលខ្ញុំបានឃើញភ្នែកផ្ទាល់ដែលបរ ដែលបើកទៅតាមទន្លេ ព្រែក ដែលខ្ញុំបាទឃើញនៅសហករណ៍ខ្ញុំបាទហ្នឹង ខ្ញុំបានឃើញមួយជាក់ស្តែងមួយមែន តែចំនួនប្រហែល២០-៣០នាក់ តែព្រែកហ្នឹងវាមានច្រើន ចំនួនដល់បីបួនដប់ព្រែកឯណោះ មិនដឹងគេទៅប្រឡោះណាទេ ដែលគេមកពីទន្លេសាបក្តី គេមកពីខាងកំពង់លួងក្តី មកខាងផ្លូកទ្រូក្តី"[1782]។

855. ដើមបណ្តឹងរដ្ឋប្បវេណី បានផ្តល់សក្ខីកម្មថា "ស្គាល់តែមួយទេ គឺមិត្តអែម ដែលធ្លាប់រស់នៅពីសង្គមសីហនុ ហើយស្គាល់តែមួយនេះទេ ហើយបានចង្អុលប្រាប់ខ្ញុំថា បាយៗ គឺខ្ញុំបាទថា ប្រាកដជាបាយៗហ្នឹងហើយ ប្រាកដជាលាយើងទៅស្រុកហើយ"[1783]។

---

[1779] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/364.1** ទំព័រ ៣៦ បន្ទាត់ ៥-៦។

[1780] នៅពេលដែលសួររយៈពេលដែលគាត់រស់នៅកោះតាម៉ូវប្រហែលជាមួយឆ្នាំ ពី ខែ ធ្នូ ១៩៧៦ ដល់ ខែ ធ្នូ ១៩៧៧ ហើយគាត់បានឆ្លើយតបថាគាត់ច្រឡំខែ។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឌឿន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/361.1** ទំព័រ ៥១ បន្ទាត់ ១៣-១៥។

[1781] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឌឿន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/361.1** ទំព័រ ៤៨ បន្ទាត់ ១១-១៤។

[1782] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឌឿន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/361.1** ទំព័រ ៤៨ បន្ទាត់ ១៧-២១។

[1783] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឌឿន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/361.1** ទំព័រ ៤៩ បន្ទាត់ ១-៣។

856. ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឌឿន បានបញ្ជាក់ថា "ខ្ញុំបាទគឺស្គាល់ច្បាស់ ប្រាកដជាជនជាតិវៀតណាមទាំងអស់តែម្តង ប៉ុន្តែខ្ញុំមើលពីចម្ងាយទៅ វាព្រិលបន្តិច បើមីមួយហ្នឹងវាពាក់អាវក្រហមបង្កង់ ខ្ញុំស្គាល់វាច្បាស់តែម្តង"[1784]។

## ២. អំពើប្រល័យពូជសាសន៍ (តាមរយៈការសម្លាប់) នៅព្រៃវែង និងស្វាយរៀង ក្នុងឆ្នាំ ១៩៧៧ នៅក្រចេះ ក្នុងឆ្នាំ ១៩៧៨

### ២.១. ការសម្លាប់ជនជាតិភាគតិចវៀតណាម

#### i. ការសម្លាប់នៅភូមិពោធិ៍ចិន្តាំ ខេត្តព្រៃវែង

857. សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅអំឡុងពេលសវនាការ បានបង្ហាញថាជនជាតិភាគតិចវៀតណាមទាំងអស់ដែលបន្តរស់នៅពោធិ៍ចិន្តាំក្នុងឆ្នាំ ១៩៧៧ ត្រូវបានកំណត់គោលដៅ និងត្រូវបានសម្លាប់។ ឆ្លើយតបទៅនឹងសំណួរថាតើមានជនជាតិវៀតណាម នៅក្នុងភូមិពោធិ៍ចិនតាមក្នុងអំឡុងរបបខ្មែរក្រហមដែរឬទេ ក្រៅពីប្តីរបស់គាត់ឈ្មោះ ង៉ាង និងប្រពន្ធរបស់ ឡាច នី ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន បានថ្លែងថា "អត់មានទេ មានតែប៉ុននុងគ្រួសារទេ អត់មានលើសពីនុងទៀតទេ។ ខ្ញុំដឹងតែប៉ុណ្ណឹង ត្រង់ពីណាទៀត ខ្ញុំអត់ដឹងទេ"[1785]។

858. ស្រដៀងគ្នានេះដែរ ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី បានផ្តល់សក្ខីកម្មថា "ខ្ញុំបានដឹងនៅក្នុងភូមិពោធិ៍ចិន្តាំ មានវៀតណាមបីគ្រួសារ"[1786]។ គាត់បានពន្យល់ថា "ទីមួយ ឈ្មោះវ៉ាន់ ង៉ាង ឪពុកវៀតណាម ម្តាយក៏វៀតណាម។ ទី២ ឈ្មោះ ជុយ, បាទ ជុយ នុងគឺប្រពន្ធខ្មែរ។ ហើយទី៣ ហ្នឹងគឺប្រពន្ធ ឡាច នី ហ្នឹង"[1787]។

---

[1784] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឌឿន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/361.1** ទំព័រ ៤៩ បន្ទាត់ ១១-១២។

[1785] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃ៥ ទី ២ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ៣១ បន្ទាត់ ១០-១១។

[1786] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៤៩ បន្ទាត់ ៣។

[1787] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៤៩ បន្ទាត់ ៧-៨ ។

859. ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន បានផ្តល់សក្ខីកម្មថាក្រោយរបបខ្មែរក្រហមដួលរលំ គ្រួសារវៀតណាម ពុំបានត្រឡប់មករស់នៅពោធិ៍ចិន្តាំវិញទេ[1788]។

***ការសម្លាប់ សុន សាន និងកូនស្រីគាត់ចំនួនប្រាំនាក់***

860. ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី បានផ្តល់សក្ខីកម្មថា "ក្នុងឆ្នាំ៧៧ ហ្នឹង ខែ១១ៗ គេត្រូវចាប់ប្រពន្ធ ឡាច នី ឈ្មោះ សាន ហ្នឹងហើយ ព្រមទាំងកូន កូនប្រាំនាក់ ហើយប្រពន្ធនោះមួយទៅ ក្នុងខែ ១១"[1789]។ គាត់បានដឹងអំពីករណីនេះពីព្រោះគាត់ "កំពុងច្រូតស្រូវនៅក្បែរផ្ទះ ឡាច នី ហ្នឹង នៅក្បែរនៅក្រោយផ្ទះខ្ញុំហ្នឹង គេចាប់"[1790] ហើយ "មានឈ្លបបីនាក់មក ឈ្លប។ បាទឈ្លប ខ្ញុំបាទស្គាល់ឈ្មោះច្បាស់គឺ អួង ង៉ុយ តែឈ្លបហ្នឹង ប្រធានឈ្លបឃុំ ឈ្មោះ អួង ង៉ុយ។ ហើយពីរនាក់ទៀតខ្ញុំបាទអត់ស្គាល់ទេ"[1791]។ ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី បានពន្យល់ថា ឈ្លប "ហៅ... សាន ឱ្យទៅរៀនសូត្រ។ គេអញ្ជើញគាត់ហ្នឹងទៅឡើងរទេះសេះនោះ ចេះតែឆ្ងល់ មូលហេតុអ្វីបានជាត្រូវហៅ សាន ហ្នឹងឡើងរទេះសេះ។ បាទ ខ្ញុំបានមើលឃើញច្បាស់ផ្ទាល់នឹងភ្នែកតែម្តង"[1792]។

861. ពាក់ព័ន្ធនឹង ឡាច នី និងកូនរបស់សាន ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី បានពន្យល់ថា "ពេលគេចាប់ សាន ហ្នឹងទៅឱ្យឡើងរទេះសេះ បានកូនៗទាំងអស់ហ្នឹងឡើងរទេះសេះចំនួនបួននាក់ កូនហ្នឹងអត់ទាន់យក មីបងទៅនៅធ្វើការឆ្ងាយ ហើយឱ្យឈ្លបទៅយកមីបងហ្នឹងឱ្យមកៗ។ ហើយ សាន ហើយនឹងកូនបួននាក់ហ្នឹង គឺដាក់រទេះសេះទៅមុន។ ហើយកូនដែលនៅ២គឺឡូដីហ្នឹងឈ្លបទៅយក

---

[1788] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ៣៥ បន្ទាត់ ១២។

[1789] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៥១ បន្ទាត់ ៦-៧។

[1790] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៥១ បន្ទាត់ ១៤-១៥។

[1791] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៥១ បន្ទាត់ ១៦-១៨។

[1792] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៥១ បន្ទាត់ ២១-២៤។

ទៅតាមកក្រោយ"[1793]។ "ខ្ញុំបាទឃើញ គឺឈ្លបឈ្មោះ ង៉ុយ ហ្នឹង ឈ្មោះ ង៉ុយ អ្នកទៅយក ហើយពីរនាក់ដែលខ្ញុំបាទអត់ស្គាល់ហ្នឹងគឺអ្នកនាំរទេះសេះទៅ។ ហើយឈ្មោះ ង៉ុយ ហ្នឹងអ្នកទៅយកកូនបងហ្នឹង កូនបងឱបៗឯក់ ឱបកង់មក ហើយតាមក្រោយ។ ប៉ុន្តែ (ឮមិនច្បាស់) ប្រហែលជាទៅឆ្ងាយហើយ បានកូនទៅៗតាមក្រោយ។ ឃើញច្បាស់ បាទខ្ញុំបានឃើញច្បាស់"[1794]។

862. ឡាច គ្រី ពន្យល់ថា អ្នកបររទេះសេះគឺជាអ្នកភូមិឈ្មោះទ្រីដែលបានប្រាប់គាត់ថា "ទៅដល់ព្រៃនុងសន្តិសុខនុងមកទទួល គ្នាពីរនាក់មកទទួលៗឈ្មោះ សាន ហើយនិងកូនហ្នឹង ហើយគាត់ក៏វិលត្រឡប់មកផ្ទះវិញ។ ប៉ុន្តែ ត្រង់កូននុងមិនដឹងយកទៅឯណា ត្រង់ណា គឺគាត់អត់បានដឹងដែរ"[1795]។ ព្រៃនោះមានឈ្មោះព្រៃត្រពាំងព្រីង[1796]។

863. ក្នុងចំណោមជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី បានពន្យល់ថា ឡាច នី និង សុន សាន មានកូនស្រីប្រាំនាក់៖ "បាទ កូនបងទី១ ឈ្មោះ ដាលីត។ ដាលីត កាលទៅនោះអាយុ ១៤ ឆ្នាំ ដាលីត។ ហើយ ដាឡា នោះអាយុ១២ឆ្នាំ កូនទី២។ កូនទី៣ ឈ្មោះស្រីម៉ៅៗ អាយុប្រាំ៧ឆ្នាំ។ ហើយបើកូនទី៤ នោះ អាយុ វាអាយុ៣ឆ្នាំៗ កូនទី៤។ កូនទី៥ ២ ឆ្នាំ កូនតូចនេះតូច នៅកំពុងបៅ"[1797]។

864. ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី បានផ្តល់សក្ខីកម្មថា ពាក់ព័ន្ធនឹង សុន សាន និងកូនគាត់ប្រាំនាក់ "ខ្ញុំអត់ដឹងទេ ដាក់រទេះសេះទៅបាត់ៗតែម្តង"[1798] ហើយ "មិនដែលឃើញទេ អត់ឃើញ"[1799]។

---

[1793] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៥២ បន្ទាត់ ៣-៦។

[1794] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៥៨ បន្ទាត់ ១៧-២០។

[1795] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៥៥ បន្ទាត់ ៤-៦។

[1796] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៥៥ បន្ទាត់ ៩។

[1797] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៧៥ បន្ទាត់ ២៣-២៥។

[1798] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៥៤ បន្ទាត់ ២១។

ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន បានបញ្ជាក់ថា "ស្រាប់តែគាត់បាត់តាំងពីថ្ងៃហ្នឹងទៅដែរ។ បាត់ខ្លួនតាំងពីថ្ងៃហ្នឹងទៅ។ ព្រោះគេយកគាត់ទៅដែរ ទាំងកូនទាំងចៅទាំងអស់នុង នៅតែប្តីម្នាក់ឯងហ្នុង"[1800]។

*ការកាប់សម្លាប់ ទេព ជុយ*

865. ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន បានផ្តល់សក្ខីកម្មថា ប្តីរបស់គាត់ ទេព ជុយ "បាត់ខ្លួន គេឱ្យគាត់ទៅកាប់រំពាក់ បានបាត់ខ្លួន អត់មានឃើញមកវិញទេ ទៅតែម្តង"[1801]។ គាត់បានពន្យល់ថា ការបាត់ខ្លួនប្តីគាត់បានកើតឡើងនៅក្នុងឆ្នាំ ១៩៧៧[1802] "ខ្ញុំចាំជារដូវ ចាំជារដូវច្រូត ខ្ញុំទៅច្រូត។ ហើយដល់មកផ្ទះវិញ គេយកប្តីទៅបាត់ទៅ ខ្ញុំអត់ដឹងទេ។ មិនដឹងគេយកទៅណាទៅណី ខ្ញុំមិនដឹងដែរ"[1803]។

866. ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន បានពន្យល់ថា "យកប្តីខ្ញុំទៅហ្នឹង ម៉ែទេ ម៉ែខ្ញុំគាត់ប្រាប់។ ថាមើលអែង គេយកប្តីអែងទៅហើយ មិនដឹងទៅខាងណាខាងណីទេ។ អញមិនដឹងទេ។ គ្រាន់តែខ្ញុំថាអីចឹងទៅ ខ្ញុំឡប់ទៅស្រែវិញទៅ"[1804]។ តាមម្តាយរបស់គាត់ "ដែលគាត់នៅផ្ទះនៅពេលហេតុ

[1799] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/379.1 ទំព័រ ៥៥ បន្ទាត់ ១៨ ទំព័រ ៧២ បន្ទាត់ ១៩-២០។

[1800] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/381.1 ទំព័រ ៣០ បន្ទាត់ ១១-១២។

[1801] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/381.1 ទំព័រ ១០ បន្ទាត់ ២០។

[1802] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/381.1 ទំព័រ ២៣ បន្ទាត់ ១៨។

[1803] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/381.1 ទំព័រ ១០ បន្ទាត់ ២៤-២៥។

[1804] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/381.1 ទំព័រ ១១ បន្ទាត់ ៣-៤។

ការណ៍នោះកើតឡើង"[1805] គាត់បានដឹងថា "គេអត់មានចងប្ដីគាត់នោះទេ"[1806] ហើយ "អត់បានឃើញទេ ឃើញតែម្នាក់ទេ មិនច្រើនគ្នាទេ។ ឃើញគេបណ្ដើរគាត់ទៅតែម្នាក់ទេ"[1807]។

867. ដើមបណ្ដឹងរដ្ឋប្បវេណី ឡាច គ្រី បានបញ្ជាក់ថា "ខ្ញុំបាទដឹងឈ្មោះៗ ជុយ។ គាត់ ជុយ ហ្នឹងមិនខុសប្លែកពី វ៉ាន់ ង៉ាង ទេ។ រយៈពេល វ៉ាន់ ង៉ាង ទៅប្រហែលមួយខែក្រោយមក បានគេហៅ ជុយ ឈ្មោះ ជុយ ហ្នឹង។ ជុយ ហ្នឹងទៅៗទៀតដើម្បីទៅរកកាប់ឈើកាប់ព្រៃអីចឹង។ កាលហ្នឹង ជុយ ហ្នឹងគេឲ្យទៅកាប់ផ្ទៀរនង្គ័ល គេហៅយាមនង្គ័ល កាប់យាមនង្គ័លអីៗនៅព្រៃក្របៅហ្នឹងដែរ។ បាទមិនខុសពី វ៉ាន់ ង៉ាងទេ ដូច វ៉ាន់ ង៉ាង អីចឹង ប្រធានភូមិទៅហៅដូចគ្នាអីចឹង។ ហើយដល់នេះគ្រួសារ ជុយ ហ្នឹងគឺគាត់នៅក្នុងក្រុមជាមួយខ្ញុំៗដើម្បីបង្កបង្កើនផល ប៉ុន្តែដឹងៗថាប្ដីរបស់គាត់ហ្នឹងប្រធានភូមិគាត់ហៅទៅកាប់ឈើបាត់ហើយ។ ហ្នឹងប្រពន្ធនិយាយប្រាប់ខ្ញុំផ្ទាល់អីចឹង"[1808]។

868. ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន បានផ្ដល់សក្ខីកម្មថា នៅពេលប្ដីរបស់គាត់ត្រូវបានគេយកចេញទៅ "ម្ដាយរបស់គាត់និយាយថា ថាទៅកូនអើយ ត្រឡប់មកវិញមក ទៅកុំនៅយូរពេក ឆាប់មកវិញ។ ហើយគាត់ថាម៉ែអើយ ខ្ញុំដល់ខ្ញុំនេះ ខ្ញុំត្រឡប់មកវិញហើយ។ ស្រាប់តែបាត់តាំងពីហ្នឹងមករហូតទៅ មានត្រឡប់មកវិញឯណា"[1809]។ គាត់បានពន្យល់ថា "ខ្ញុំនឹកក្នុងចិត្តខ្ញុំថាអីចឹង ថាទៅកាប់រពាក់មិនមកវិញទេទៅហើយ ហើយទៅបាត់ទាល់តឡូវហ្នឹងទៅមានឃើញស្អីមកវិញ។ តែអីចឹងទាំងអស់គ្នាហ្នឹង"[1810]។ នៅពេលសួរអំពីហេតុផលដែលគាត់គិតថាគាត់នឹងមិនត្រឡប់មក

---

[1805] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/381.1 ទំព័រ ២៤ បន្ទាត់ ១០-១១។

[1806] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/381.1 ទំព័រ ១១ បន្ទាត់ ៧-៨។

[1807] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/381.1 ទំព័រ ២៤ បន្ទាត់ ១៧-១៨។

[1808] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/379.1 ទំព័រ ៥៩ បន្ទាត់ ១-៧។

[1809] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/381.1 ទំព័រ ១១ បន្ទាត់ ១៤-១៦។

[1810] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/381.1 ទំព័រ ២៧ បន្ទាត់ ១៧-១៩។

វិញ ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន បានពន្យល់ថា "ខ្ញុំតែងនិយាយទៅ ខ្ញុំថាតែទៅហើយបាត់ហើយមិនមកវិញទេ។ ខ្ញុំនឹកក្នុងចិត្តខ្ញុំថា តែទៅប៉ុណ្ណឹងហើយមិនមកវិញទេ ហើយមិនឃើញអ្នកណាមកមួយមែន បាត់ទាំងអស់គ្នា ទៅទាំងប៉ុន្មាន បាត់ទាំងប៉ុណ្ណឹង"[1811]។ ដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ជាក់នៅពេល ជុយ "ទៅកាប់ឈើៗ ទៅបាត់តែម្តង"[1812]។

*ការសម្លាប់ ង៉ាង*

869. ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី បានផ្តល់សក្ខីកម្មថា "នៅដើរឆ្លងកាត់ដើម្បីទៅច្រូតស្រូវនៅឆ្ងាយពីផ្ទះខ្ញុំប្រហែលជាបីបួនរយម៉ែត្រ។ ដល់ឃើញ វ៉ាន់ ង៉ាង ដើរទៅ ខ្ញុំបាទក៏សួរៗប្រធានភូមិហ្នឹងសួរថា អេ! ពួកគេទៅណា? គេថាពួកយើងទៅម្នាក់ដែរ ឈ្មោះ វ៉ាន់ ង៉ាង ទៅគេឲ្យកាប់រពាក់។ ខ្ញុំសួរប្រធានភូមិហ្នឹង ប្រធានភូមិគាត់ទៅមកៗជួបតែគ្នារាល់ថ្ងៃ បានមិនចាប់អារម្មណ៍ថាគេយក វ៉ាន់ ង៉ាង ទៅណាៗ ខ្ញុំមិនដឹងទេ ប៉ុន្តែការពិតហ្នឹងគឺយកទៅកាប់រពាក់ទៅបាត់ទាល់ឥឡូវទៅ"[1813]។

870. ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន បានផ្តល់សក្ខីកម្មថា "ឈ្មោះ ង៉ាង។ ង៉ាង យកទៅមុនគេទៅកាប់រពាក់ ស្រាប់តែបាត់ទៅ ទាល់ហ្នឹងឥឡូវទៅ វាមិនឃើញទេ មិនវិលមកវិញទេ។ ហ្នឹងវៀតណាមដែរ"[1814]។ គាត់បានពន្យល់ថា "អត់ទេ នៅផ្ទះទាំងអស់។ យកតែឪទៅទេ"[1815]។ ប្រពន្ធ

---

[1811] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ៣៥ បន្ទាត់ ២៣-២៥។

[1812] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៦៧ បន្ទាត់ ៩-១០។

[1813] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៥៨ បន្ទាត់ ១៨-២៣។

[1814] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ១២ បន្ទាត់ ១៨-១៩។

[1815] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ១២ បន្ទាត់ ២១។

របស់គាត់គឺជា "ខ្មែរ ខ្មែរសុទ្ធ។ ប្រពន្ធក៏មិនដែលនៅស្រុកដែរ ឥឡូវ មិនដឹងទៅនៅណានៅណីទេ"[1816]។

871. ពាក់ព័ន្ធនឹង ង៉ាង ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន បានលើកឡើងថា គាត់ "ទៅមុន។ វាមានមកវិញឯណា ទៅហ្នុង"[1817]។ ដើមបណ្ដឹងរដ្ឋប្បវេណី ឡាច គ្រី ក៏បានលើកឡើងផងដែរថា "ក្រោយពេលនោះមក គាត់បានបាត់ខ្លួន..." [1818]។

## ii. ការកាប់សម្លាប់ជនជាតិវៀតណាមពីរគ្រួសារមកពីភូមិឫស្សីព្រៃ[1819] ខេត្តស្វាយរៀង ក្នុងឆ្នាំ១៩៧៧

872. ដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ធី បានផ្ដល់សក្ខីកម្មថា ក្រោយមក នៅក្នុងឆ្នាំ ១៩៧៧[1820] "គ្រួសារវៀតណាមនៅក្នុងភូមិខ្ញុំ មានបីគ្រួសារទាំងគ្រួសារខ្ញុំ គេយកគ្រួសារទី១ទៅ កូនសក្តិ ៤ ដែលម្ដាយគាត់ជាជនជាតិវៀតណាម។ ពេលនោះហើយដែលប៉ាខ្ញុំគាត់ពិបាកចិត្ត ព្រោះគាត់បានឃើញគេចាប់រំលោភកូនស្រីទាំងពីររបស់គ្រួសារវៀតណាមដែលគេយកទៅនោះ។ គាត់មកខ្សឹបប្រាប់ម្ដាយខ្ញុំថា ឯងអើយ ខ្ញុំឃើញគេចាប់រំលោភកូនសក្តិ ៤ ផុន។ ដូច្នេះ ខ្ញុំមិនចង់រស់ទេ។ ខ្ញុំសាច់ឈាមមិនដូចគេទេ សាច់ឈាមខុសគេ ខ្ញុំមិនឱ្យគេយកទៅទេ ព្រោះគេ យកទៅទេព្រោះគេយកទៅសម្លាប់ឃើណាស់។ ខ្ញុំប្រហែលជាធ្វើអត្តឃាតហើយ"[1821]។ គាត់បានពន្យល់ថា "គេថាកូនសក្តិ ៤ ផុន១ ប៉ុន្តែគ្រួសារហ្នឹងមានកូនស្រីពីរនាក់ ម្ដាយមួយ និងកូនប្រុសបីនាក់។ បង សាអុន

---

[1816] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ២៩ បន្ទាត់ ១៥-១៦។

[1817] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ២៩ បន្ទាត់ ១១-១៣។

[1818] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹក ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៥៨ បន្ទាត់ ១-៣។

[1819] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ធី ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/394.1** ទំព័រ ៨ បន្ទាត់ ១៣។

[1820] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ធី ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៧២ បន្ទាត់ ៦ (ភ្ជាប់ពេលវេលាជាមួយនឹងពេលក្រោយមកទៀតនៅឆ្នាំ ១៩៧៧ ក្រោយការចាប់ខ្លួនបងប្រុសគាត់)។

[1821] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ធី ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៧៤ បន្ទាត់ ១២-២៣។

ហ្នឹង គេយកទៅសម្លាប់ថ្ងៃជាមួយបង ចាន់ ថន ខ្ញុំនៅទួលស្លួន។ ហើយប្រពន្ធគាត់ប្រហែលជាមួយអាទិត្យ ឬ ១០ ថ្ងៃ ខ្ញុំអត់ចាំទេណា គ្រាន់តែថាគេលួចខ្សឹបប្រាប់គ្នាថា "ហ៊ឺ! ប្រពន្ធ សាអុន គេយកទៅទៀតហើយ"។ គាត់មានកូនពីរនាក់ កូនប្រុសមួយ ស្រីមួយ"[1822]។

873. ពាក់ព័ន្ធនឹងគ្រួសាររបស់ សាអុន វិញ ដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ថី បានផ្ដល់សក្ខីកម្មថា "ប្រពន្ធគាត់ជាជនជាតិវៀតណាម។ គេយកទៅសម្លាប់ ប្ដីគាត់គេយកទៅសម្លាប់ថ្ងៃជាមួយបងខ្ញុំ បងប្រុស ចាន់ថន ហ្នឹង។ បានក្រោយមក ប្រហែលជាមួយអាទិត្យ ឬ ១០ ថ្ងៃ ខ្ញុំអត់ចាំ អត់ដឹងទេណា បានគេយកប្រពន្ធហើយ ហើយនឹងកូនទៅតាមក្រោយ ថាឲ្យទៅតាមប្ដី។ តែប្ដី គេយកទៅសម្លាប់ចោលជាមួយបងខ្ញុំ ថ្ងៃជាមួយបងខ្ញុំ បងចាន់ថន ហ្នឹង"[1823]។ ចំពោះគ្រួសារ ថន "គឺគាត់ស្លាប់ទាំងអស់គ្នាហ្នឹង។ គេយកទៅវៃចោលទាំងអស់គ្នាហ្នឹង ទាំងគ្រួសារហ្នឹង។ គេយកទៅវៃចោលទាំងអស់គ្នាហ្នឹង ទាំងគ្រួសារហ្នឹងស្លាប់ទាំងអស់ហ្នឹង មានបានរស់រានមានជីវិតទេ ស្លាប់ទាំងអស់ហ្នឹង។ កូនស្រីត្រូវគេរំលោភទាល់តែស្លាប់ ហើយកូនប្រុសបីនាក់ទៀត គេយកទៅវៃចោលនុង"[1824]។

874. គាត់បានផ្ដល់សក្ខីកម្មថា "បើអ្នកឃើញអ្នកចាប់រំលោភហ្នឹង គឺប៉ាខ្ញុំផ្ទាល់ហ្នឹង បានគាត់មកខ្សឹបប្រាប់ខ្ញុំ បានគាត់ភ័យខ្លាចហ្នឹង។ ហើយបើបងប្រុស ហើយនឹងម្ដាយគាត់ហ្នឹង ខ្ញុំគ្រាន់តែឮអ្នកភូមិគេខ្សឹបប្រាប់គ្នាថា "ហ៊ឺ! កូនគ្រួសារសក្ដិ៤ ថុន គេយកទៅវៃចោលហើយ"[1825]។ គាត់បានបកស្រាយលម្អិតថា "ជនរងគ្រោះពីរនាក់នុង គាត់ម្ដាយគាត់ជាវៀតណាម ហើយគាត់រស់នៅក្នុងភូមិជាមួយគ្នាខ្ញុំ ហើយគាត់ទាំងពីរនាក់ធ្វើការរែកដីជាមួយខ្ញុំ។ ពេលដែលគេចាប់ គាត់យកទៅខ្ញុំអត់បានដឹងទេ ប៉ុន្តែគ្រាន់ថាបាត់គាត់ពីកន្លែងធ្វើការ ខ្ញុំក៏សួរមិត្តភក្ដិហ្នឹងខ្សឹបសួរ មិនមែន សួរឮៗទេ ខ្សឹបសួរគ្នាថា "បងស្រអែមឌី ហើយនឹងស្រីទូចទៅនាហើយ? គេថាគេយកទៅវៃចោល

[1822] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ថី ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/394.1 ទំព័រ ១៣ បន្ទាត់ ១១-១៦។

[1823] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ថី ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/394.1 ទំព័រ ២៤ បន្ទាត់ ១៣-១៦។

[1824] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ថី ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/394.1 ទំព័រ ២៣ បន្ទាត់ ១៩-២១។

[1825] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ថី ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/394.1 ទំព័រ ២៤ បន្ទាត់ ៥-៩។

ហើយ។" ដល់ពេលហ្នឹង ខ្ញុំមកផ្ទះ មកផ្ទះពេលយប់ បានឮសួរប៉ាខ្ញុំខ្សឹបប្រាប់ខ្ញុំទៀត គាត់ថា កូនអើយក្នុងភូមិយើងគ្រួសារ សាក់ប៊ុនថុន ហ្នឹងគេយកទៅវៃចោលអស់ហើយ។ ដូច្នេះ ប៉ាខ្លាច"[1826]។

875. ចំពោះបញ្ហាអត្តសញ្ញាណ និងចំនួនជនរងគ្រោះ ដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ធី បានពន្យល់ថា "គ្រួសារ ស័ក្ដិ៤ ថុន មានប្រាំមួយនាក់ ហើយនិងបងមាក់ អាក្អែល ហ្នឹងមានបងស្រីហ្នឹងដែលជនជាតិវៀតណាមហ្នឹង ហើយកូនគាត់ប្រុសមួយ ស្រីមួយបីនាក់"[1827]។ ទោះបីជាគាត់ពុំចងចាំត្រកូលរបស់កូនស្រី ថន ក៏ដោយ ក៏គាត់បានរៀបរាប់ឡើងវិញថា "គ្រាន់តែថា ពួគេហៅ ដូចបងស្រី បងស្រអែម វ៉ាន់ឌី ហ្នឹង ហើយស្រីទូចៗ ហ្នឹង ធ្វើការរែកដីជាមួយគ្នាខ្ញុំពីរនាក់ស្រីៗហ្នឹង។ ហើយបើបង បងគី បងគោ ហើយនិងម៉ៅនោះ"[1828]។

876. នៅពេលសួរថាតើគាត់បានជួបសមាជិកគ្រួសារទាំងពីរម្ដងទៀតទេ ដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ធី បានឆ្លើយថា "បានអីជួប បើគេយកទៅវៃចោលបាត់អស់ហើយ"[1829]។

### iii. ការកាប់សម្លាប់នៅខេត្តក្រចេះក្នុងខែ កញ្ញា ឆ្នាំ ១៩៧៨

#### *ការកាប់សម្លាប់សមាជិកគ្រួសារ អ៊ុំច ស៊ុនឡាយ*

877. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំច ស៊ុនឡាយ បានផ្ដល់សក្ខីកម្មថា "នៅក្នុងខែកញ្ញា ឆ្នាំ១៩៧៨ ហ្នឹងហើយដែល ពួក ប៉ុល ពត នាំប្រពន្ធកូនខ្ញុំហ្នឹងទៅសម្លាប់ គឺរដូវទឹកជំនន់នុងបាទ។ សូមអស់យោបល់"[1830]។

---

[1826] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ធី ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/394.1 ទំព័រ ៤ បន្ទាត់ ១៨-២៤។

[1827] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ធី ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/394.1 ទំព័រ ១៣ បន្ទាត់ ២០-២១។

[1828] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ធី ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/394.1 ទំព័រ ២៣ បន្ទាត់ ២៤-ទំព័រ ២៤ បន្ទាត់ ២។

[1829] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ធី ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/394.1 ទំព័រ ១៤ បន្ទាត់ ២២-២៣។

878. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយបានផ្តល់សក្ខីកម្មថា ខ្មែរក្រហមបានចាប់ខ្លួនប្រពន្ធចំណែកប្តីត្រូវបានគេចាត់ឲ្យទៅកាប់ដើមឈើ "មឿន និងគណៈសហករណ៍ហ្នឹងបានចាត់តាំងពួកក្រុមដែលមានប្រពន្ធជាកូនកាត់វៀតណាម ចៅកាត់វៀតណាមនោះឲ្យទៅកាប់ឫស្សីបង្គោងត្នោតនៅឯអូរឡុងដែលមានរយៈពេលធ្វើដំណើរហ្នឹងមិនតិចពីពីរយប់ទេតាមរយៈការចែវទូក។ ខ្ញុំបាទក៏ទៅជាមួយនឹងគេហ្នឹង ក៏ប៉ុន្តែដែលក្តុកក្តួលខ្លាំងមែនទែននោះគឺពេលដែលត្រឡប់មកវិញ គណៈសហករណ៍ បានហៅ អ្នកទាំងនោះរួមទាំងខ្ញុំបាទផងដើម្បីមកទទួលការអប់រំសតិអារម្មណ៍។ ពេលនោះដែលឈ្មោះ មឿន គណៈសហករណ៍បានក្រោកឡើងនិយាយថា៖ "សមមិត្តមានគុណសម្បត្តិខ្ពស់ណាស់ជាមួយនឹងបក្សវណ្ណៈកម្មករយើង សមមិត្តបានខិតខំបំពេញការងារកម្ចាត់ធាតុដើមលះបង់ខ្ពស់ជូនបក្សវណ្ណៈកម្មករ កសិករ តែប្រពន្ធកូនរបស់មិត្ត យើងខ្ញុំបានប្រមូលទៅទុកម្តុំហើយ សូមសមមិត្តកាត់សាច់ស្អុយនេះចេញចុះ!"[1831]។ "នៅពេលគេសម្លាប់កូនក្មេងនោះ កូនខ្ញុំបាទនោះមានបីនាក់គឺប្រុសពីរនាក់ ស្រីមួយនាក់។ កូនច្បងឈ្មោះ សុធីរ៉ា អាយុ ៨ ឆ្នាំ កើតឆ្នាំ៧០ មកទល់នឹង ៧៨។ កូនបន្ទាប់ឈ្មោះ សុធីរៈ កើតឆ្នាំ ១៩៧៥។ រីឯកូនប្អូនឈ្មោះ សុធីតា ប្រហែលជាជាង ១ ខួប ប៉ុណ្ណោះទេបាទ ជាស្រី។ សូមអស់យោបល់"[1832]។ "ដោយឡែកប្រពន្ធរបស់ខ្ញុំឈ្មោះ សា គឹមនី និង សា គឹមណា និងកូនតូចឈទាំងបី គឺវាជម្លៀសពី ក-៥ មកដាក់នៅកណ្តាលកោះ គឺកោះទ្រុងមុខវត្តក្រចេះបច្ចុប្បន្នហ្នឹងបាទ ហើយវែសម្លាប់នៅក្នុងរណ្តៅមួយក្រោមដើមគ្គុលតែក្រោយមកទឹកទន្លេមេគង្គបានជន់ជោរហូរហៀរ ដើមគ្គុលនុងក៏បានបាក់ធ្លាក់ក្នុងទឹកពុំមានសេសសល់នៅ ហៅថា ឆ្អឹងសាកសពនៃឧក្រិដ្ឋកម្មហ្នឹងឡើយ។ តែអ្នកស្រុកបានប្រាប់ថាអាណោចអាធមណាស់ កូនគ្រូឡាយឯងនេះ វារត់ពេញទក់ស្មៅទាំងអស់ហ្នឹង ដោយពីព្រោះពួកវាដេញចាប់ ដើម្បីនឹងចាប់បោកផ្ទប់នឹងគល់គ្គុលហ្នឹង"[1833]។

---

[1830] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/394.1** ទំព័រ ៧២ បន្ទាត់ ២០-២១។

[1831] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/394.1** ទំព័រ ៦៥ បន្ទាត់ ២០ - ទំព័រ ៦៦ បន្ទាត់ ៤។

[1832] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ ប្រតិចារឹក ថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/395.1** ទំព័រ ៤ បន្ទាត់ ២-៥។

[1833] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/394.1** ទំព័រ ៦៥ បន្ទាត់ ១៣-១៨ ។

879. គាត់បានផ្តល់សក្ខីកម្មថា គាត់បានដឹងអំពីមរណភាពរបស់ប្រពន្ធ និងកូនគាត់ សុទ្ធវ៉ា។ "អ្នកភូមិមិនមែនតែម្នាក់ទេ ប៉ុន្តែអ្នកភូមិដែលនៅរស់បច្ចុប្បន្ននេះឈ្មោះលោក តាថុល។ លោក តាថុល បច្ចុប្បន្នជាអាចារ្យវត្តនៅកោះទ្រុង ឃុំកោះទ្រុង សង្កាត់កោះទ្រុង ស្រុកក្រចេះ ខេត្តក្រចេះ"[1834]។ "អ្នកភូមិមិនបានឃើញឬមើលទិដ្ឋភាពនេះទេ ពីព្រោះកងឈ្លបគេឃាត់ឃាំង គេប្រាប់អស់ហើយថាអត់មាននរណាទៅតាមទេក្រៅតែពីប្រពន្ធពួកប្រពន្ធៗ និងកូនពួកអ្នកដែលទៅកាប់ឫស្សី ព្រោះត្រូវយកអ្នកទាំងអស់នេះឲ្យទៅជួបប្តីៗគេវិញ នៅត្រើយម្ខាងទន្លេមេគង្គឯណោះ។ ដូច្នេះ មានតែឈ្មោះ ថុល ហ្នឹងមួយទេដែលនៅជិតដល់ ចាំ និងឃើញ និងដឹងឮផ្ទាល់ភ្នែក។ បាទ សូមអស់យោងបល់"[1835]។ "អ្នកភូមិម្នាក់ហ្នឹងឈ្មោះ ថុល ជាអ្នកដែលបរទេះគោដឹកក្រុមគ្រួសារ ចៅកាត់វៀតណាមនេះទៅកន្លែងពិឃាត។ គាត់ក៏បានឃើញគាត់មានការញ៉េរចំប្រប់ គាត់បានលបលួចលួចមើល មិនបានមើលពេញទាំងអស់ទេដោយពួកប្រធានកងឈ្លបមានឈ្មោះ អ៊ុក តាំងហ៊ីនដេញអត់ឲ្យមើលបានអស់ឡើយ។ ដូច្នេះ កូនក្មេងទាំងអស់នោះ ត្រូវពួកមេពេជ្ឈឃាដដេញចាប់ប្រដាប់ពភីង ទក់វាលព្រៃស្មៅ និងព្រៃងទាំងអស់នោះដើម្បីចាប់បោក សម្លាប់ចោលនៅក្នុងរណ្តៅក្រោមដើមក្តុល នៅក្បាលកោះទ្រង់ ឃុំកោះទ្រង់ សង្កាត់កោះទ្រង់ ខេត្តក្រចេះ គឺទល់មុខខេត្តក្រចេះ។ ខ្ញុំបាទបានទទួលព័ត៌មានតែពីលោក ថុល ហ្នឹង បានតែប៉ុននុងទេ"[1836]។

880. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ បានផ្តល់សក្ខីកម្មបន្ថែមទៀតអំពីមរណភាពម្តាយក្មេករបស់គាត់ យាយបេ ហើយបានផ្តល់ភស្តុតាងចចាមអារ៉ាមថា មានករណីខ្លះដែលជនជាតិវៀតណាមត្រូវបានគេប្រមូលផ្តុំ "បញ្ជូនត្រឡប់ទៅវៀតណាម"។ "ពាក់ព័ន្ធនឹងការសម្លាប់ជនជាតិវៀតណាម គេអត់និយាយផ្លូវត្រង់អីទេ។ គេថាអង្គការឲ្យជួបជុំនៅវត្តគគរនុង ឡានទៅរង់ចាំត្រង់ហ្នឹង គឺដឹកជញ្ជូនបងប្អូនដែលជាអាណិកជនវៀតណាមបញ្ជូនទៅប្រទេសវៀតណាមដើមវិញ។ ក្នុងនោះ គឺមានច្រើនគ្នា មានឈ្មោះ ហ្គុង ឈ្មោះ មីង គឺមកា ឈ្មោះ តាបា ឈ្មោះ យាយហឿង ហើយនឹង យាយបេ - យាយ ធីបេ ដែលជាម្តាយក្មេកខ្ញុំបាទនោះដែរ។ ខ្ញុំមិនបាន មិនជូនទេ ពី

---

[1834] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/394.1** ទំព័រ ៧៣ បន្ទាត់ ១-៣។

[1835] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/394.1** ទំព័រ ៧៤ បន្ទាត់ ១៨-២២។

[1836] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ ប្រតិចារឹក ថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/395.1** ទំព័រ ៣ បន្ទាត់ ១៦-២៣។

ព្រោះគេអត់មានឱ្យជូនទេ គេឱ្យដឹកនាំខ្លួនទៅ"[1837]។ "ខ្ញុំបាទដឹងតែប៉ុណ្ណឹងថាៗឡើងឡានទៅ កាត់តាមភ្នំព្រិចតម្រង់ទៅវៀតណាមបាទ។ គេអត់មានផ្សាយថា អ្នកឯងហ្នឹងជាវៀតណាមមិនអាចនៅបានទេ អ្នកឯងមានប្ដី មានប្រពន្ធ កូនប្រសារជាកម្ពុជាក៏ដោយ អត់មាននិយាយប្រាប់ទេ គឺយើងអត់បានដឹងរឿងហ្នឹងទេបាទ"[1838]។ "ឆ្នាំដែលគេចាប់ម្ដាយក្មេកខ្ញុំយកទៅនេះ គឺក្នុងឆ្នាំ១៩៧៨"[1839]។ "ក្នុងចន្លោះខែ១០ ទៅខែ១១ ឆ្នាំ១៩៧៨"[1840]។ "ព័ត៌មានបន្ថែមពីម្ដាយក្មេកខ្ញុំបាទឈ្មោះ រៀង ធីបេ នេះគឺក្រោយថ្ងៃ ០៧ មករា ប្រហែលជាបីបួនខែក្រោយបានដឹង។ បានដឹងថាគេហៅឈ្មោះកូនកាត់វៀតណាមហ្នឹង មកជុំគ្នានៅវត្ត ហើយបង្ខំឱ្យឡើងឡានទៅទាំងអស់គ្នា។ យកទៅសម្លាប់ចោលនៅខាងភ្នំព្រិច ផ្លូវទៅវៀតណាម ផ្លូវពីក្រចេះទៅឡុកនិញ។ ដោយវិធីណាក៏មិនដឹងទេ ប៉ុន្តែអ្វីទាំងអស់ត្រូវចប់ត្រឹមហ្នឹងហើយដោយសារមនុស្សបំផុតនៅស្លាប់ហ្នឹងហើយ ដែលអស់។ នេះគឺដឹងក្រោយតាមរយៈតៃកុងឡានឈ្មោះ អាង គាត់ថា ម៉ែក្មេកគ្រូឡាយឯងអីហ្នឹង គឺនៅហ្នឹងទាំងអស់។ ពួកខ្ញុំដឹកទៅដល់ភ្លាមដេញគេឱ្យចុះព្រួសៗ។ ពួកទាហានកម្ពុជាប្រជាធិបតេយ្យហ្នឹងមកភ្លង់ភ្លាម ឱ្យឡានបត់មកវិញភ្លាម ហើយបណ្ដើរពួកហ្នឹងឡើងទៅលើភ្នំព្រិច ដឹងធ្វើយ៉ាងម៉េចទៀត។ គាត់បានប្រាប់តែប៉ុណ្ណឹង នៅក្រោយរំដោះហើយទេបានដឹង។ សូមអស់ សូមចប់យោបល់"[1841]។

881. ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មថា គាត់បានដឹងអំពីការកាប់សម្លាប់ម្ដាយក្មេកគាត់ពីអ្នកបើកឡាន។ "គឺពិតប្រាកដអីចឹងមែន។ ពួកឈ្លប ប៉ុល ពត បានហៅឱ្យទៅជួបជុំគ្នាឡើងឡាននៅក្នុងវត្តក្រគរ ហើយដឹកចេញពីវត្តក្រគរ តម្រង់ទិសទៅខាងប្រទេសវៀតណាម ពីព្រោះមានផ្លូវ

[1837] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/394.1 ទំព័រ ៦៨ បន្ទាត់ ២៤ -ទំព័រ ៦៩ បន្ទាត់ ៣។

[1838] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/394.1 ទំព័រ ៦៩ បន្ទាត់ ៣-៦។

[1839] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ ប្រតិចារឹក ថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/395.1 ទំព័រ ១៦ បន្ទាត់ ២២។

[1840] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ ប្រតិចារឹក ថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/395.1 ទំព័រ ១៦ បន្ទាត់ ២៥។

[1841] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ ប្រតិចារឹក ថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/395.1 ទំព័រ ៨ បន្ទាត់ ២-១០។

មួយពីក្រចេះកាត់តាមឡុកនិញទៅវៀតណាម តាំងពីដើមមករហូតដល់បច្ចុប្បន្ននេះ។ តែទៅឈប់ត្រង់ណា យកចេញបណ្ដើរពីត្រង់ណា ខ្ញុំបាទមិនបានដឹងទៀតទេ។ ហើយការដឹងហ្នឹងសូមបញ្ជាក់ជូនថា តាមរយៈអ្នកបើករថយន្តនោះ ដែលក្រោយមកគាត់បានមកនិយាយប្រាប់អីចឹង។ សូមចប់ សូមអស់យោបល់"[1842]។

## *ការកាប់សម្លាប់ជនជាតិវៀតណាមផ្សេងទៀតនៅខេត្តក្រចេះក្នុងខែកញ្ញា ឆ្នាំ១៩៧៨*

882. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ បានផ្ដល់សក្ខីកម្មថា មានជនជាតិវៀតណាមផ្សេងទៀតដែលត្រូវបានចាប់ខ្លួននៅក្នុងពេលតែមួយជាមួយនឹងប្រពន្ធ និងកូន។ "មិនមែនមានតែប្រពន្ធកូនខ្ញុំប៉ុណ្ណោះទេ ដែលត្រូវបានដាក់ទិសទៅនៅកោះទ្រុង ដើម្បីគេយកសម្លាប់នោះគឺមានប្រពន្ធកូនអ្នកដទៃ បីបួនគ្រួទៀត មានជាអាទិ៍ប្រពន្ធកូនរបស់លោក យិន យឹម ឈ្មោះនាង អឹម ម៉ាឡែននិងកូនពីរនាក់ គឺអាបាវាំង និងស្រីវិច បាទ។ ប្រពន្ធកូនរបស់ តុត ញ៉េវ ប្រពន្ធកូនរបស់ ប៉ាន់ ហ្លួនសេង ប្រពន្ធកូនរបស់មនុស្សដទៃទៀត ដូចជា ពូសៀងជាដើម។ល។ ដែលជម្លៀសចេញហើយឱ្យប្ដីទៅកាប់ឫស្សីបង្កោងឆ្នោតសម្រាប់ធ្វើឆ្នោតចេញពីមុខពីមាត់។ អាហ្នឹងគឺជាល្បិចកលដ៏ពិសពុលរបស់ពួក ប៉ុល ពត ហ្នឹងឯង។ សូមអស់"[1843]។ "ពិតប្រាកដហើយ ជាចៅកាត់វៀតណាម"[1844]។

## ២.២. ចេតនាជាក់លាក់

### *ការដឹងជាទូទៅ*

883. ភ័ស្តុតាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលបង្ហាញនៅក្នុងពេលជំនុំជម្រះបង្ហាញថា គេបានដឹងជាទូទៅថានរណាជាជនជាតិវៀតណាម។

---

[1842] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ ប្រតិចារឹក ថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/395.1** ទំព័រ ៩ បន្ទាត់ ៧-១២។

[1843] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/394.1** ទំព័រ ៧១ បន្ទាត់ ១៧ -២២។

[1844] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/394.1** ទំព័រ ៧១ បន្ទាត់ ២៥។

884. ដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ថី បានផ្ដល់សក្ខីកម្មថា "ពេលគេប្រជុំហ្នឹង គេប្រធានសហករណ៍គឺវាបានដឹងច្បាស់ហើយថា គ្រួសារណាវៀតណាម គ្រួសារណាមិនមែនវៀតណាម គឺវាដឹងច្បាស់អីចឹង វាកំណត់សម្គាល់អីចឹង វាស្គាល់ដឹងច្បាស់ហើយ ព្រោះអីដូចគ្រួសារខ្ញុំអីចឹង គេដឹងថា ជីតាខ្ញុំអីចឹង វៀតណាមអីចឹង គេដឹង។ បើអីចឹង គេមិនបាច់សួរអីទៀត គេដឹង គេស្គាល់ហើយ"[1845]។ គាត់បានបកស្រាយថា "គេមិនជជីកសួរអីទេព្រោះដូចថា គេស្គាល់ពីដើមមកអីចឹងថា អ្នកណាជាកូនកាត់វៀតណាម គ្រួសារវៀតណាម គឺគេស្គាល់"[1846]។

885. ដើមបណ្ដឹងរដ្ឋប្បវេណី ប្រាក់ ខឿន បានពន្យល់ថា កម្មាភិបាលនៅក្នុងភូមិ "ថា ប្រពន្ធមិត្តឯងខ្មែរឬក៏វៀតណាម? ខ្ញុំឆ្លើយទៅវាបំភាន់មតិខ្លះ បើឆ្លើយថាខ្មែរ ម្ដាយក្មេកដែលនៅជាមួយបានន័យថាខ្ញុំហ្នឹងបំភាន់មតិ ខ្លាចគេយកខ្ញុំហ្នឹងទៅវ៉ៃចោល។ ខ្ញុំពិចារណាសិនមុននឹងឲ្យគំនិតទៅគេ ដល់ពេលដែលខ្ញុំគិតឃើញថា ឆ្លើយខាងណាក៏ជាប់ៗ ខ្ញុំក៏ឆ្លើយតាមត្រង់ថា ប្រពន្ធហ្នឹងកូនរបស់គាត់គឺកូនវៀតណាម"[1847]។

886. ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំងចែត បានផ្ដល់សក្ខីកម្មថា នៅពេលខ្មែរក្រហមបានមកដល់តំបន់របស់គាត់នៅក្នុងឆ្នាំ ១៩៧៥ "កាលសម័យហ្នឹងគេប្រើ "ឡាំងតាយ" ហ្នឹង – ឡាំងតាយហ្នឹងដូចកត់សម្គាល់ខ្លួនយើងហ្នឹង បានគេប្រើយកតាមពាក្យហ្នឹង គេយកហ្នឹង។ ដូចសៀវភៅគ្រួសារសព្វថ្ងៃឥឡូវអ៊ីចឹង"[1848] ហើយ "ដូចខ្ញុំនិយាយអំមិញដែរថា ពីព្រោះហ្នឹង កាលហ្នឹងប្រើក្រដាសឡាំងតាយហ្នឹង ដល់គេដឹងថាដូចថាក្រដាសហ្នឹង ហើយយើងក្រដាសគ្រួសារ បញ្ជីគ្រួសាររបស់

[1845] សក្ខីកម្មផ្ទាល់មាត់របស់ សៀង ចាន់ថី ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/394.1** ទំព័រ ១៥ បន្ទាត់ ១-៤។

[1846] សក្ខីកម្មផ្ទាល់មាត់របស់ សៀង ចាន់ថី ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/394.1** ទំព័រ ១០ បន្ទាត់ ១៦-១៨។

[1847] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប្រាក់ ខឿន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/361.1** ទំព័រ ៤៦ បន្ទាត់ ៧-១០។

[1848] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៦២ បន្ទាត់ ១៩-២១។

យើងហ្នឹង"[1849]។ "គេដឹង គេដឹងណា វៀតណាមក៏ដឹង ដឹងខ្លះខ្មែរ"[1850]។ នៅក្នុងតំបន់របស់គាត់ ខ្មែរក្រហម "មើលទាំងអស់ខាងយៀកណាម មើលទាំងអស់ ឡាំងតាយហ្នឹងមើលទាំងអស់"[1851]។

887. "កាលពេលខ្ញុំនិយាយហើយអំបាញ់មិញ ដល់ឥឡូវនិយាយថា កាលពេលនៅកំពង់ឆ្នាំងៗហ្នឹង គេៗសួរយើងដូចថា ឡាំងតាយហ្នឹង គេមើលអី? គេមើលគ្រួសារប៉ុន្មាននាក់ គេធ្វើអាហ្នឹងហើយ គេធ្វើដូចថាគ្រួសារយើងឈ្មោះអី គេដាក់ឈ្មោះហ្នឹង កូនចៅឈ្មោះអីគេដាក់ហ្នឹងហើយ។ អាហ្នឹង គេកាន់លើដៃគេហើយ គេកាន់លើដៃគេ គេមិនឲ្យយើងដឹងទេ។ គ្រាន់យើងប្រាប់ហ្នឹង ឡាំងតាយគេឲ្យវិញហើយយើងទុកនៅផ្ទះ។ ដល់គេបណ្ដេញយើងចេញហ្នឹង គេបញ្ជូនយើងទៅគេដេញចេញ គេដុតផ្ទះហ្នឹងចោលបាត់ហើយ"[1852]។

## *រូបរាងកាយ និងពណ៌សម្បុរ*

888. ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន បានផ្ដល់សក្ខីកម្មថា គាត់អាចប្រាប់បានថា ង៉ាងគឺជាជនជាតិវៀតណាម "បើមើលតាមមុខ និងរាងរៅ"[1853]។ ដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ធី បានផ្ដល់សក្ខីកម្មថា "ចាស គេដឹង ព្រោះប៉ាខ្ញុំ គាត់ដូចវៀតណាម ព្រោះគាត់ស។ គាត់សៗដូចវៀតណាម គេដឹង គេស្គាល់ៗថា គាត់ជាជនជាតិវៀតណាម"[1854]។ គាត់ក៏បានពិពណ៌នាអំពីឪពុករបស់គាត់បានប្រាប់គាត់ថា "បើគាត់ស្លាប់ទៅ គ្រាន់នឹងមានកូនឃើញផ្នូរ ហើយកូនភ្នែកខ្មៅៗទាំងប្រាំមួយ

---

[1849] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៦៣ បន្ទាត់ ២១-២២។

[1850] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៦៣ បន្ទាត់ ២២-២៣។

[1851] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៦៤ បន្ទាត់ ២៥។

[1852] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/364.1** ទំព័រ ២២ បន្ទាត់ ១៧ -២២។

[1853] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ១៣ បន្ទាត់ ១០-១១។

[1854] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ធី ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/394.1** ទំព័រ ១០ បន្ទាត់ ៧-៨។

នាក់ហ្នឹង ក្រែងបានរស់នៅជាមួយគេ ច្រឡំសាច់ៗឈាម ច្រឡំគេ ច្រឡំឯង ភ្នែកខ្មៅៗ បើខ្ញុំស្លាប់ទៅ កូនអាចនៅរស់"[1855]។

889. ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឡឿន បានផ្តល់សក្ខីកម្មថា ប្រពន្ធរបស់គាត់ "ខ្ញុំបាទនឹងជម្រាបជូន។ ប្រពន្ធខ្ញុំធាត់ល្មម សាច់សហើយទាប ធាត់ក្រអាញ "[1856]។ "បាទ ខ្ញុំបានជម្រាបជូន មុខគាត់ដូចខ្មែរអីចឹង ប៉ុន្តែទាស់សាច់គាត់ស"[1857]។

890. ចំពោះប្រជាជនខ្មែរវិញ ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ុំងចែត បានពន្យល់ថា "ដើម្បីគេដឹងហើយគេមុខ ខ្មែរគេក៏ដឹង"[1858]។

*ខ្មែរស្រឡាយគ្រួសារ*

891. ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី បានផ្តល់សក្ខីកម្មថា សាន បានប្រាប់គាត់ថា "ឪពុកគាត់ខ្មែរហើយម្តាយគាត់វៀតណាម"[1859]។ ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន បានពន្យល់ថា ទេព ជុយ "គាត់ជនជាតិវៀតណាមដែរ ឪពុកម្តាយគាត់ បងប្អូនកូនក្មួយគាត់"[1860]។ គាត់ក៏បានផ្តល់សក្ខីកម្ម

---

[1855] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សៀង ចាន់ធី ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ E1/393.1 ទំព័រ ៧៣ បន្ទាត់ ២៥ - ទំព័រ ៧៤ បន្ទាត់ ២។

[1856] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឡឿន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ E1/361.1 ទំព័រ ៣៤ បន្ទាត់ ២៥។

[1857] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឡឿន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ E1/361.1 ទំព័រ៣៥ បន្ទាត់ ១៥។

[1858] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ុំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ E1/363.1 ទំព័រ ៥២ បន្ទាត់ ១១-១២។

[1859] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/379.1 ទំព័រ ៤៨ បន្ទាត់ ២៥- ទំព័រ ៤៩ បន្ទាត់ ១។

[1860] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/381.1 ទំព័រ ៨ បន្ទាត់ ៧។

ផងដែរថា "ម៉ែឪវៀតណាម។ បានខ្ញុំដឹង ត្រង់វានិយាយ ឬ មិននិយាយ ខ្ញុំមិនដឹងទេ។ ប៉ុន្តែដឹងម៉ែឪវាវៀតណាមហើយ"[1861]។

892. ដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ធី បានពន្យល់ថា "ម្ដាយខ្ញុំខ្មែរសុទ្ធ ឪពុកខ្ញុំ ជីតាខ្ញុំ យាយខ្ញុំវៀតណាមនៅស្រុកខ្មែរ។ ដូច្នេះ ប៉ាខ្ញុំជាជនជាតិវៀតណាម"[1862]។ ពាក់ព័ន្ធនឹងគាត់ និងបងប្អូនបង្កើតគាត់ "គេនិយាយថាកូនកាត់យួន ភាសាហ្នឹង គេនិយាយថា "ហ៊ឺ! កូននុង កូនកាត់យួន"[1863]។

893. ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន បានផ្ដល់សក្ខីកម្មថា "បាទ ខ្ញុំបាទ ជម្រាបជូន គឺថាប្រពន្ធខ្ញុំជនជាតិវៀតណាម"[1864]។ គាត់កើតនៅក្នុងខេត្តកំពង់ឆ្នាំងក្នុងភូមិតែមួយជាមួយនឹងដើមបណ្ដឹងរដ្ឋប្បវេណី[1865]។ "តែខ្ញុំបាទជម្រាបជូន ម្ដាយនោះគឺកាត់បានទៅវៀតណាម តែឪពុកនោះមិនទាជីវ"[1866]។ ចំពោះឪពុកម្ដាយរបស់គាត់ "បាទ សុទ្ធតែម្ដង ស្លៀកខោអាវ ពាក់អាវ គាត់ប្ដូងសក់ពីក្រោយជនជាតិវៀតណាមតែម្ដង ហើយគាត់និយាយភាសាជាខ្មែរ អត់បានច្បាស់ទេ"[1867]។

### *ភាសា និងសំលៀកបំពាក់*

894. នៅពេលសួរថាតើប្រជាជនដឹងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យថា សាន ជាជនជាតិវៀតណាម ដោយរបៀបណា ដើមបណ្ដឹងរដ្ឋប្បវេណី ឡាច គ្រី បានឆ្លើយតបថា "បាទ ដែលគេដឹងគ្រប់គ្នា

[1861] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/381.1 ទំព័រ ១៣ បន្ទាត់ ៤-៥។

[1862] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ធី ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/394.1 ទំព័រ ៩ បន្ទាត់ ១៦-១៧។

[1863] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ធី ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/394.1 ទំព័រ ១១ បន្ទាត់ ២២។

[1864] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប្រាក់ ឌឿន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ E1/361.1 ទំព័រ ៣៤ បន្ទាត់ ១២។

[1865] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប្រាក់ ឌឿន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ E1/361.1 ទំព័រ ៣៤ បន្ទាត់ ១៨-២២។

[1866] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប្រាក់ ឌឿន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ E1/361.1 ទំព័រ ៣៥ បន្ទាត់ ១៧។

[1867] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប្រាក់ ឌឿន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ E1/361.1 ទំព័រ ៣៥ បន្ទាត់ ២៣ - ទំព័រ ៣៦ បន្ទាត់ ២។

ហ្នឹង ដោយសារគាត់មកនៅក្នុងភូមិពោធិ៍ចិន្តាំហ្នឹង គាត់រកស៊ីលក់បន្លែៗ លក់ត្រី ហើយប្ដីលក់ទឹកកក ឡាច នី លក់ទឹកកក។ ដូច្នេះហើយក្នុងការនិយាយស្ដីអី ពេលណាវៀតណាមទៅទិញបន្លែទិញអី គាត់ច្រើននិយាយវៀតណាម។ បានប្រជាជនទាំងអស់ហ្នឹង គេអាចដឹងថា គាត់សន្និដ្ឋានថាគាត់វៀតណាម ពីព្រោះគាត់ចេះនិយាយវៀតណាម ហើយនិយាយប៉ៃឡាំរបៀបវៀតណាម”[1868]។

895. ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន បានផ្ដល់សក្ខីកម្មថា ប្ដីរបស់គាត់ ទេព ជុយ “គាត់និយាយវៀតណាមច្បាស់ ខ្មែរគាត់មិនសូវច្បាស់ទេ”[1869]។

896. ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន បានផ្ដល់សក្ខីកម្មថា គាត់អាច “ដឹងថាវាវៀតណាម បើវានិយាយមិនច្បាស់ដែរ និយាយខ្មែរវាមិនច្បាស់”[1870]។

897. ពាក់ព័ន្ធនឹងគ្រួសារគាត់ ដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ថី បានផ្ដល់សក្ខីកម្មថា “អត់ចេះទេ បងប្អូនខ្ញុំអត់ចេះវៀតណាមទេ ចេះតែប៉ាខ្ញុំម្នាក់ឯង”[1871]។

898. ដើមបណ្ដឹងរដ្ឋប្បវេណី ប្រាក់ ឌឿន បានផ្ដល់សក្ខីកម្មថា ប្រពន្ធរបស់គាត់ “បាទ គឺចេះភាសាវៀតណាម តែអត់ប្រើទេក្នុងសង្គមនោះ ប្រើភាសាខ្មែរ និងភាសាបារាំងបាទ”[1872]។

---

[1868] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៧៥ បន្ទាត់ ៦-១០។ *សូមមើលផងដែរ* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ១២ បន្ទាត់ ១២ (ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន បានផ្ដល់សក្ខីកម្មថាសាន “និយាយមិនច្បាស់ទេ”)។

[1869] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ៩ បន្ទាត់ ១៥។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៦៧ បន្ទាត់ ៣-៥។ ( ដើមបណ្ដឹងរដ្ឋប្បវេណី ឡាច គ្រី ក៏បានលើកឡើងទៀតថា ទេព ជុយ “និយាយភាសាអត់ច្បាស់ដូចខ្មែរ ប៉ៃឡាំ ភាសាវៀតណាមប៉ៃឡាំៗ។ បានខ្ញុំបាទដឹងគាត់ថាវៀតណាម ហើយគាត់ការពិតច្រើននិយាយវៀតណាមមែន”)។

[1870] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ១៣ បន្ទាត់ ១០-១១។

[1871] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ថី ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/394.1** ទំព័រ ៩ បន្ទាត់ ២៣។

899. ចំពោះម្ដាយក្មេករបស់គាត់ ដើមបណ្ដឹងរដ្ឋប្បវេណី ប្រាក់ ឌឿន បានផ្ដល់សក្ខីកម្មថា "ម្ដាយនេះជាជនជាតិវៀតណាម និយាយមិនច្បាស់ទេ [...] ម្ដាយក្មេកនិយាយអត់ច្បាស់ ដែលនៅរួមដំណើរគ្រួសារ ដែលនៅយុវវ័យនៅឡើយនោះ ដែលទម្រាំតែបានខ្ញុំ គាត់និយាយរហូតទាល់តែចប់ខ្មែរក្រហមហ្នឹងយកទៅវ៉ៃចោល"[1873]។

900. ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំងចែត បានចាកចេញពីកម្ពុជាទៅវៀតណាមនៅក្នុងឆ្នាំ ១៩៧៥[1874]។ "បាទ ខ្ញុំបាននៅត្រង់ហ្នឹង គេរើស រើសថាអ្នកណាវៀតណាម ពីណាចិន ពីណាខ្មែរ។ អីចឹងដើម្បីយើងនិយាយហ្នឹង ពាក្យវៀតណាមហ្នឹង--ឥឡូវ ខ្ញុំនិយាយខ្មែរអីចឹង វារឹង ពាក្យវាមិនច្បាស់លាស់"[1875]។

### *ការប្ដូរឈ្មោះ*

901. ដើមបណ្ដឹងរដ្ឋប្បវេណី ប្រាក់ ឌឿន បានពិពណ៌នាអំពីការភ័យខ្លាចដែលគាត់មានលើកូនស្រីម្នាក់របស់គាត់ ដែលនាំឱ្យគាត់សម្រេចចិត្តប្ដូរឈ្មោះនាងដើម្បីសុវត្ថិភាព។ "បាទ ខ្ញុំប្រើឈ្មោះផ្សេង ខ្ញុំបាទបើហៅឈ្មោះពីដើមកំណើតបានន័យថា វាចាប់អារម្មណ៍ថាខ្ញុំ កូនខ្ញុំជាកូនវៀតណាម។ អីចឹងបំភាន់មតិដាក់ឈ្មោះកូនហ្នឹងបំបែកមួយតែឈ្មោះមីកំបាក់ មីកំពុក បាទ"[1876]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ជាក់បំភ្លឺថា "ឈ្មោះកូនទី៤ ហៅ គៀម ហ្នឹង ពីដើមឈ្មោះហៅ ដូចថាហៅលេងអីចឹង ដ៏ពេលមកដល់ជំនាន់អាពត គេចេះសួររកឈ្មោះហ្នឹងខ្លាំងពេក ខ្ញុំឱ្យសំណូមពរទៅឱ្យក្មេងដែលប្រចាំការនៅកន្លែងកងកន្លែងក្រុមហ្នឹងថា មិនមែនឈ្មោះហ្នឹងទេ។ ឈ្មោះវាពីដើមមក

[1872] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប្រាក់ ឌឿន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/361.1** ទំព័រ ៣៥ បន្ទាត់ ១០-១១។

[1873] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប្រាក់ ឌឿន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/361.1** ទំព័រ ៤៥ បន្ទាត់ ២២ -ទំព័រ ៤៦ បន្ទាត់ ៤។

[1874] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/364.1** ទំព័រ ៣៦ បន្ទាត់ ២៣ - ទំព័រ ៣៧ បន្ទាត់ ៧។

[1875] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៥២ បន្ទាត់ ៩-១២។

[1876] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប្រាក់ ឌឿន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/361.1** ទំព័រ ៤០ បន្ទាត់ ៦-៨។

ឈ្មោះវា មីកំបាក់ មីកំពុក។ ខ្លាចគេរកកូនហ្នឹងខ្ញុំឃើញ គេយកទៅសម្លាប់ទាំងអស់"[1877]។ គាត់បានប្តូរឈ្មោះពីព្រោះ "កងហ្នឹងវាស្គាល់ថាមីហ្នឹងឈ្មោះតែឈ្មោះអីចឹង កូនវៀតណាមហើយ កូនតាឡឿន ហ្នឹងហើយ។ ហើយខ្ញុំបាទក៏ភ័យញ័រខ្លាំងពេក ក៏ផ្សាយៗប្រាប់តាមអ្នកកុមារដែលនៅក្រុមកងជាមួយថាមិនមែនទេ អ្នកឯងកុំហៅឈ្មោះវាអីចឹង។ ខ្ញុំបានទៅជួប ដើរតាមក្បែរៗហ្នឹង ក៏លួចទៅជួប ខ្ញុំប្រាប់ថា ឈ្មោះវា មីកំបាក់ មីកំពុកទេ"[1878]។ "ស្លុតខ្លាំងពេកខ្លាចបាត់បង់ដល់កូនទៀត ម្លោះហើយខ្ញុំមានសេចក្តីចាប់អារម្មណ៍ បានខ្ញុំជម្រាបជូនតុលាការ នៃបញ្ហាហ្នឹងបើទុកឈ្មោះនៅដដែលបានន័យថាកូនខ្ញុំត្រូវបាត់បង់ជីវិតហើយ។ អីចឹងឲ្យកាឡៃឈ្មោះហ្នឹងឲ្យកូនអ្នកកុមារដែលនៅជំនាន់ប្រល័យពូជសាសន៍ហ្នឹងជួហៅថាវា មីកំបាក់ មីកំពុកទៅ"[1879]។

902. ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន បានពិពណ៌នាអំពីការភ័យខ្លាចគាត់ធ្លាប់ឆ្លងកាត់ដែលបណ្តាលឲ្យគាត់ប្តូរឈ្មោះកូនគាត់ពី គីម វ៉ា ទៅ កាំមាន ក្រោយខ្មែរក្រហមបានមកដល់ឃុំរបស់គាត់[1880]។ "ត្រកូលឪវាហ្នឹង គេដាក់ត្រកូលឪហ្នឹងទៅ"[1881]។ "ខ្ញុំបញ្ជាក់បាន។ អង្គាល់ហ្នឹង ខ្លាចពួកហ្នឹងវាយកទៅវ៉ៃចោល ខ្ញុំដាក់ឈ្មោះវាចឹងទៅ។ គេប្រាប់ថា កុំដាក់ឈ្មោះវា គីម វ៉ា ដាក់ឈ្មោះវាមីកាំមាន ទៅ។ ហើយក៏ខ្ញុំដាក់តាមគេទៅ"[1882]។ "ចាស ខ្ញុំខ្លាចអីចឹងបានខ្ញុំដាក់ឈ្មោះវា មីកាំមានទៀតទៅ ខ្លាចគេយកទៅវ៉ៃចោលដូចឪវាចឹងទៅ"[1883]។

---

[1877] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឡឿន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/361.1** ទំព័រ ៤០ បន្ទាត់ ១០-១៣។

[1878] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឡឿន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/361.1** ទំព័រ ៤០ បន្ទាត់ ២២-២៥។

[1879] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឡឿន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/361.1** ទំព័រ ៤១ បន្ទាត់ ១៦-១៩។

[1880] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ១៧ បន្ទាត់ ៦-៧។

[1881] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ៩ បន្ទាត់ ១៦។

[1882] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ៩ បន្ទាត់ ២០-២១។

[1883] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ១៧ បន្ទាត់ ១១-១២។

## *គោលនយោបាយពាក់ព័ន្ធនឹងខ្មែរស្រឡាយខាងម្ដាយ*

903. ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មអំពីអត្ថិភាពនៃគោលនយោបាយ ដែលមានគោលបំណង កំណត់គោលដៅ និងកាប់សម្លាប់ជនរងគ្រោះដែលមានដើមកំណើតវៀតណាម និងកូនចៅរបស់ពួកគេ។

904. ដើមបណ្ដឹងរដ្ឋប្បវេណី ឡាច គ្រី បានផ្ដល់សក្ខីកម្មថា "អាចដឹងៗថា បើសិនជាប្ដីហ្នឹងខ្មែរ គឺអត់មានយកកូនទៅជាមួយៗទេ អត់មានទេ។ ហើយបើប្រពន្ធនឹងវៀតណាម គឺទាំងកូន ទាំងប្រពន្ធយកទៅ។ ហើយបើសិនជាប្ដីហ្នឹងវៀតណាម ប្រពន្ធនុងខ្មែរ គឺយកតែប្ដីទេ អត់មានយកកូនទេ"[1884]។

905. ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន បានបញ្ជាក់ថា "យកទៅកូនចៅកាលហ្នឹងប្រាំ ប្រាំមួយនាក់ ទាំងម៉ែហ្នឹង"[1885]។ "នៅសល់តែ [ឡាច នី] មួយទេ"[1886]។ គាត់បានពន្យល់ថា "ថាម៉ែយួន គេយកទៅនុង។ ឲ្យតែម៉ែយួន គេយកទៅហើយ។ តែមួយគេមិនទុកឲ្យផង"[1887]។

906. ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន បានពន្យល់ថា កូនរបស់គាត់ "មិនចាប់មែន កាលនុងអត់មានអ្នកណាយកទៅទេ ស្មានតែកូនខ្មែរ អ! ម៉ែខ្មែរ កូនខ្មែរអត់យកទៅទេ គេយកទៅតែឪពុកទេ។ បានជាកូនខ្ញុំនៅហ្នឹងនោះ បើគេយកទៅ ទៅទាំងអស់ហើយ។ ចេះតែលាក់លៀម ចេះតែបិទបាំង

[1884] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៦០ បន្ទាត់ ២-៥។

[1885] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ១២ បន្ទាត់ ២-៣។

[1886] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ១១ បន្ទាត់ ២៣។

[1887] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ៣០ បន្ទាត់ ១៨។

អីចឹងដែរ"[1888]។ គាត់បានបកស្រាយថា "ជនជាតិវៀតណាមហ្នឹងយកទៅទាំងអស់ហើយ វាមិនទុកទេ ជំនាន់នុងនោះ។ ទាល់តែម៉ែខ្មែរ គេយកតែប្តីទៅៗ"[1889]។

907. ពាក់ព័ន្ធនឹងការកាប់សម្លាប់ប្រពន្ធរបស់គាត់ដែលជាប់វៀតណាម និងកូនរបស់គាត់ម្នាក់[1890] ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឌៀន បានផ្តល់សក្ខីកម្មថា "ក្រុមដូចថា ក្រុមដែលប្រពន្ធខ្ញុំហ្នឹងជាក្រុមវៀតណាមហ្នឹង គេឲ្យកូនទៅនៅជាមួយ។ ដែលក្រុមខ្មែរហ្នឹង គេកូន--គេឲ្យទុកមកនៅជាមួយម្តាយ បាទតែប៉ុណ្ណឹង។ បើនិយាយឲ្យចំគេឲ្យម្តាយ ថាម្តាយខ្មែរកូនគេឲ្យទៅ។ បើម្តាយវៀតណាមត្រូវវៀតណាមនេះយកទៅហ្នុង គេអត់ឲ្យនៅទេ។ បានន័យថាទៅសម្លាប់ទាំងអស់គ្នា"[1891]។ ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា "ជនជាតិវៀតណាម គេធ្វើយកប្តីទៅសម្លាប់។ តែបើជនជាតិខ្មែរយើង គេម្តាយនៅរស់អីចឹង ដែលគេអត់ឲ្យទៅជាមួយកូនហ្នឹងក៏នៅរស់ដែរ បាទ"[1892]។

908. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ បានពន្យល់ថា ប្រពន្ធ និងកូនរបស់គាត់ត្រូវបានគេសម្លាប់ចោលដោយសារមានដើមកំណើតជាជនជាតិវៀតណាម។ "ខ្ញុំបាទហ្នឹងច្បាស់ហើយថាប្រពន្ធ និងកូនជាវៀតណាម ដូច្នេះកូនហ្នឹង គឺជាចៅកាត់វៀតណាម ពីព្រោះទ្រឹស្តីរបស់មេដឹកនាំជាន់ខ្ពស់និងអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង បានផ្សព្វផ្សាយទៅដល់ថ្នាក់ក្រោមទាំងអស់ថា ជីកស្មៅ ត្រូវជីកទាំងឫស បានន័យថា បើយកប្រពន្ធនិងកូនដែលជាចៅកាត់

---

[1888] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/381.1 ទំព័រ ២៥ បន្ទាត់ ៤-៦។

[1889] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/381.1 ទំព័ ២៥ បន្ទាត់ ៩-១០។

[1890] ទាក់ទងនឹងវិសាលភាពនៃសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី *សូមមើល* "សូមអរគុណលោកប្រធាន។ ជាដំបូងពាក់ព័ន្ធនឹងការជំទាស់របស់មេធាវីការពារក្តីលោក នួន ជា អង្គជំនុំជម្រះកត់សម្គាល់ឃើញថាការជំទាស់នេះយឺតពេលទៅហើយ។ ដូច្នេះយើងបដិសេធការជំទាស់នេះ។ ដោយសារអង្គជំនុំជម្រះយល់ឃើញថាសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមានសារៈសំខាន់ អាចឲ្យយើងវាយតម្លៃ ថាតើមានគោលនយោបាយនៅថ្នាក់ជាត់ ឬក៏អត់ ពាក់ព័ន្ធនឹងវិធានការជាក់លាក់ទៅលើជនជាតិវៀតណាម"។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឌៀន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ E1/361.1 ទំព័រ ៦៦ បន្ទាត់ ១៨-២២។

[1891] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឌៀន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ E1/361.1 ទំព័រ ៦០ បន្ទាត់ ២២-២៥។

[1892] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឌៀន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ E1/361.1 ទំព័រ ៨២ បន្ទាត់ ៦-៧។

វៀតណាម អាចៅទួត ចៅឈួត ចៅអីក៏ដោយ ក៏ជាវៀតណាម ជាខ្សែកា.ហ្យេ.បេ ទាំងអស់ដែរ។ នេះគឺដឹងច្បាស់ យល់ច្បាស់ដោយមើលឃើញ និងការតាមដានសាវតារជាតិរបស់ពួកកងឈ្លប នៅក្នុងសហករណ៍ ក-១ រហូតដល់ ក-៥ ហ្នឹងគឺអ៊ីចឹង"[1893]។

## គ. ព្យសនកម្ម

### ១. ព្យសនកម្មលើរូបរាងកាយ

909. ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំងចែត បានពិពណ៌នាអំពីការឈឺចាប់លើរូបរាងកាយគាត់បានទទួលរង នៅពេលគាត់ និងគ្រួសាររបស់គាត់ត្រូវបានគេបណ្ដើរនាំទៅកាន់មាត់រណ្ដៅ៖ "លើកទម្លាក់ អំបាញ់មិញខ្ញុំនិយាយដែរ ខ្ញុំថា ឲ្យខ្ញុំលុតជង្គង់ ឲ្យខ្ញុំលុតជង្គង់ចុះទៅ។ ដល់ពេលខ្ញុំលុតជង្គង់រួចហើយ ចាប់ជើងខ្ញុំទាញទៅក្រោយ បានខ្ញុំដួលក្បាលខ្ញុំផ្ទាកទៅមុខ ទៅមុខអ៊ីចឹងបានយកដៃគេស្ទាបលើក្បាលខ្ញុំ បានយកពូថៅគេវាយលើក្បាលខ្ញុំ បីខ្នងពូថៅ រួចបានគេស្រាយខ្សែចេញ រួចរុញខ្ញុំចូលរណ្ដៅ"[1894]។ នៅពេលគាត់ដឹងខ្លួនវិញ ដើមបណ្ដឹងរដ្ឋប្បវេណីបានពិពណ៌នាថា "ឡើងក៏មិនរួចដែរ កខ្ញុំហើមដូចហើមកក្របីបាត់ហើយ ដើរក៏មិនរួចដែរ ដើរក្បាលធ្ងន់ជាងគេទៅមុខទាំងអស់ បានខ្ញុំខំទៅដល់ចូលមកឃុំជើងគ្រោះហ្នឹង ដើរមកទាំងយប់ទាំងថ្ងៃ ដើរកាត់ព្រៃ ទាំងយប់ទាំងថ្ងៃដើរទៅមក យប់ហ្នឹង ដើរមក ដល់ឃុំជើងគ្រោះ បានចូលផ្ទះតាលី"[1895]។

910. ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំងចែត បានពន្យល់ថា គាត់បានបន្តរងគ្រោះនឹងការបាត់ការចងចាំដោយសារលទ្ធផលនៃរបួសក្បាលនៅពេលកម្មាភិបាលវាយដំគាត់៖ "ខ្ញុំឥឡូវចាំមិនបាន។ អារឿងភ្លេចភ្លាំងហ្នឹង ត្រឹមការណាវាពិបាកខ្លួនខ្ញុំភ្លេចហើយ។ កាលណាដូចថា ខ្ញុំឈឺ ខ្ញុំអត់ចំណាំ

[1893] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ ប្រតិចារឹក ថ្ងៃទី ២ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/395.1** ទំព័រ ៥ បន្ទាត់ ១៤-១៩។

[1894] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៣៩ បន្ទាត់ ៣-៦។

[1895] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៣៩ បន្ទាត់ ៩-១២។

បាននៅប្រទេសខ្មែរអីចឹងបាន។ បើថា កាលណាខ្ញុំឈឺចាប់ ខ្ញុំដាក់នៅក្នុងចិត្តហើយ ខ្ញុំត្រូវនិយាយចេញទាំងអស់ប៉ុណ្ណឹង"[1896]។

911. ពាក់ព័ន្ធនឹងផលវិបាកលើរូបរាងកាយរយៈពេលវែងដោយសាររបួសរបស់គាត់ ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ុងចែត បានពន្យល់ថា៖ "ការខ្ញុំធ្វើការខ្លាំង ធ្ងន់ធ្ងរ ហាត់ វាឡើងតឹងសរសៃកខ្ញុំតែម្តង តឹងតែម្តង រឹងសរសៃក ហើយវិលមុខតែម្តង អត់ឃើញអី ងងឹតបណ្តោយ"[1897]។ គាត់បានពន្យល់ថា "បញ្ហាហ្នឹងខ្ញុំត្រូវបីខ្នងពូថៅហ្នឹងហើយ។ រឿងបញ្ហាអីចឹងតែម្តង អត់មានបញ្ហាអីទេ"[1898]។

## ២. ព្យសនកម្មផ្លូវចិត្ត

### ២.១. ការភ័យខ្លាចដែលបានឆ្លងកាត់ដោយអ្នកមានជាប់សាច់ឈាមវៀតណាម

912. ដើមបណ្តឹងរដ្ឋប្បវេណី សៀង ចាន់ធី បានផ្តល់សក្ខីកម្មអំពីការតក់ស្លុតដែលកើតមានលើគាត់ ក្រោយបានដឹងពីឪពុកគាត់បានឃើញការរំលោភសេពសន្ថវៈអ្នកជិតខាងជាជនជាតិវៀតណាមពីរនាក់៖ "ប៉ាខ្លាច។ ខ្លាចៗ កូនយើងគេយកទៅចាប់រំលោភ គេមុនយកវ៉ៃចោល គេចាប់រំលោភទៀត។ ពេលដែលឮសូរប៉ាខ្ញុំនិយាយ ខ្ញុំភ័យតក់ស្លុតជាខ្លាំងព្រោះអី ខ្ញុំនឹកឃើញថា ថ្ងៃណាមួយពេលណាមួយខ្ញុំនឹងៗគេយកទៅដូចគ្នា។ ព្រោះខ្ញុំជាកូនកាត់វៀតណាមដូចគ្នា។ ខ្ញុំតែងតែគិតរហូត"[1899]។

913. ដើមបណ្តឹងរដ្ឋប្បវេណី សៀង ចាន់ធី បានពិពណ៌នាការរស់នៅក្នុងសភាពភ័យខ្លាចរហូត៖ "ពេលហ្នឹងអ្នកស ពេលព្រឹក ខ្ញុំបានរស់បានមួយព្រឹក ពេលដល់ពេលថ្ងៃរសៀលម៉ោងពីរ ម៉ោងបី

[1896] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ុង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ E1/363.1 ទំព័រ ៥៩ បន្ទាត់ ៧-៩។

[1897] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ុង ចែត ប្រតិចារឹក ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ E1/364.1 ទំព័រ ១១ បន្ទាត់ ២៥ - ទំព័រ ១២ បន្ទាត់ ១។

[1898] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ុង ចែត ប្រតិចារឹក ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ E1/364.1 ទំព័រ ១២ បន្ទាត់ ៥។

[1899] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សៀង ចាន់ធី ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/394.1 ទំព័រ ៤ បន្ទាត់ ២៣ - ទំព័រ ៥ បន្ទាត់ ១។

ខ្ញុំចាប់ផ្តើមភ័យព្រួយបារម្ភ ព្រោះខ្លាចគេយកទៅវាយចោល។ ការភ័យខ្លាចរបស់ខ្ញុំគឺជាប់រហូត។ រហូតដល់ពេលប៉ាខ្ញុំគាត់ដាច់ចិត្តធ្វើអត្តឃាត ដូចខ្ញុំរៀបរាប់ប្រាប់អង្គតុលាការទាំងមូលពីម្សិលមិញ អីចឹង។ ការភ័យខ្លាចរបស់ខ្ញុំ ភ័យរហូតៗទាល់តែគេរំដោះបាន បានខ្ញុំឈប់ភ័យ។ នេះជារឿងពិត"[1900]។

## ២.២. អារម្មណ៍អាប់អួរ និងការភ័យខ្លាចដែលបានទទួលរង ដោយអ្នកដែលមានសមាជិកគ្រួសារវៀតណាមជាជនជាតិវៀតណាម

914. ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឌឿន បានពិពណ៌នាថាគាត់បានលាក់អារម្មណ៍មិនឱ្យប្រពន្ធគាត់ដឹង។ "ហើយខ្ញុំបាទក៏ជម្រាបជូនដែរថា ធ្វើដំណើរទៅ ខ្ញុំបាទក៏ឈប់មាត់ ឈប់ក ហើយកងទ័ពហ្នឹងក៏ត្រូវដើរហួសទៅ ដើរហួសទៅប្រពន្ធកូនខ្ញុំត្រូវមានការចាប់អារម្មណ៍គាត់ដែរ។ ដល់ពេលយប់ស្ងាត់ដែលរួមដំណេកជាមួយគ្នា គាត់ក៏ឱ្យយោបល់ខ្ញុំថា គាត់ឯងសង្ស័យតែមុខជាព្រាត់ប្រាស់គ្នាហើយ ខ្ញុំមើលទៅបើមិនទៅវៀតណាម មុខតែគេសម្លាប់ខ្ញុំហើយ។ ហើយខ្ញុំក៏មានសេចក្តីដូចថារន្ធត់ស្លុតស្មារតីហ្នឹងគិតគូរពីបញ្ហាហ្នឹង ប៉ុន្តែមិនឱ្យប្រពន្ធដឹងទេ ក្នុងគំនិតអីដែលគិតគូរប្រហែលជាអីចឹងមែន ហើយប្រាកដដែលក្នុងគំនិតខ្ញុំបែងចែកទៅប្រាកដជាប្រពន្ធទៅចោលខ្ញុំឬក៏មួយក៏គេយកទៅសម្លាប់ហើយ។ ដល់ពេលនោះមែន ដែលខ្ញុំគិតឃើញក៏ខ្ញុំអត់បានទៅជម្រាបជូនប្រពន្ធតទៅទៀតទេ គ្រាន់តែប៉ុណ្ណឹងខ្ញុំមានគំនិតទុក កុំឱ្យប្រពន្ធភ័យញាប់ញ័រ។ ហើយមិននឹកស្មាន ដល់ពេលគេយកគឺមែនយកទៅទាំងប្តីទាំងប្រពន្ធមែន"[1901]។

## ២.៣. ទុក្ខសោកនៅពេលបាត់បង់សមាជិកគ្រួសារជនជាតិវៀតណាម

### *ដើមបណ្តឹងរដ្ឋប្បវេណី សៀង ចាន់ធី*

915. ដើមបណ្តឹងរដ្ឋប្បវេណី សៀង ចាន់ធី បានពិពណ៌នាអំពីផលប៉ះពាល់ភ្លាមៗ និងយូរអង្វែងដោយសារអត្តឃាតរបស់ឪពុកគាត់។ គាត់បានផ្តល់សក្ខីកម្មថា "ដល់ពេលហើយម្តាយខ្ញុំថា "អូ!

---

[1900] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សៀង ចាន់ធី ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/394.1 ទំព័រ ៥ បន្ទាត់ ៣-៨។

[1901] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឌឿន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ E1/361.1 ទំព័រ ៥៣ បន្ទាត់ ៣-១១។

ប៉ាស្លាប់ហើយកូន។" ពេលដែលម្តាយខ្ញុំប្រាប់ថា ប៉ាស្លាប់ហើយកូន ខ្ញុំណាបងទើបតែស្លាប់ថ្មីៗ ខ្ញុំពេលហ្នឹងយំអត់ចេញ។ ពាក្យថា "យំមិនចេញ" គឺខ្ញុំឆ្លងកាត់ហើយ លោកតុលាការទាំងមូល។ អត់មានទឹកភ្នែកយំទេ យំអត់ចេញ មិនដឹងយំថាយ៉ាងម៉េច ស្រែកថាម៉េច ឲ្យចេញទឹកភ្នែកមក អត់ទេ គឺខ្ញុំគាំង ខ្ញុំនៅស្ងៀម ខ្ញុំអត់ដឹង យំថាម៉េច ម្តាយខ្ញុំចេះតែយំបោកខ្លួន ខ្ញុំឱបម្តាយខ្ញុំ។ ដល់ពេលព្រលប់ៗងងឹតៗ ទៅម្តាយខ្ញុំគាត់ហុចៗដែកកេះឲ្យខ្ញុំ។ ហុចដែកកេះឲ្យខ្ញុំថា "កូនណេះ យកដែកកេះទៅអុចចន្លុះទៅឲ្យភ្លឺផ្ទះ"។ ពេលដែលម៉ែខ្ញុំហុចដែកកេះមកឲ្យខ្ញុំ បានខ្ញុំយំចេញព្រោះ ខ្ញុំថា រាល់ថ្ងៃប៉ាខ្ញុំហុចឲ្យខ្ញុំ រាល់ថ្ងៃគាត់ប្រើ "នែអាម៉ែ អ្អែងយកដែកកេះទៅអុជចង្កៀងទៅកូនឲ្យ អុជចន្លុះទៅឲ្យភ្លឺ"។ ពេលម្តាយខ្ញុំហុចដែកកេះឲ្យខ្ញុំៗ នឹកឃើញថា ចាប់ពីពេលនេះទៅ ខ្ញុំអត់មាន ឪពុកនឹងគេទៀតហើយ ខ្ញុំអស់ឪពុកហើយ ខ្ញុំជាកូនកំព្រាឪពុក។ ភាពភ័យខ្លាចរបស់ខ្ញុំ ខ្ញុំជាកូនកាត់វៀតណាម មិនដឹងថ្ងៃណាគេយកខ្ញុំទៅទៀត ព្រោះខ្ញុំរស់មួយថ្ងៃ ព្រឹកឡើងថ្ងៃរះ ខ្ញុំដឹង តែខ្ញុំរស់ ហើយពេលថ្ងៃរសៀលម៉ោងពីរទៅម៉ោងបី ខ្ញុំដឹងថា ខ្ញុំភ័យខ្លាច ខ្លាចគេយកទៅវាយ ចោល"[1902]។

916. "ខ្ញុំគ្រាន់តែជាប់សាច់ជាប់ឈាមបន្តិច ខ្ញុំមិនទាំងដែលចេះវៀតណាមមួយម៉ាត់ផង។ ការរស់នៅ ជំនាន់ ប៉ុល ពត ខ្ញុំរស់ទាំងភ័យខ្លាច អារម្មណ៍ជិតដាម ខ្លាចតែគេយកទៅវាយចោល។ ហើយ នៅពេលដែលខ្ញុំថ្លែងទុក្ខប្រាប់អស់លោកទាំងអស់គ្នាស្តាប់ ប្រៀបដូចជារឿងហ្នឹងនៅថ្មី នៅមុខខ្ញុំ ប្រៀបដូចជាខ្សែវីដេអូមួយដែលចាក់បញ្ចាំងរឿងឈឺចាប់ទាំងប៉ុន្មាន ដែលខ្ញុំមានឆ្លងកាត់ពីជំនាន់ ប៉ុល ពត មក ដែលខ្ញុំព្រាត់ប្រាស់ឪពុកជាទីស្រលាញ់ បងប្រុសទាំងពីររបស់ខ្ញុំដែលគេធ្វើទារុណកម្ម"[1903]។

### *ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ*

917. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ បានផ្តល់សក្ខីកម្មថា គាត់មានអារម្មណ៍ចង់សម្លាប់ខ្លួន ដោយសារមរណភាពនៃសមាជិកគ្រួសាររបស់គាត់។ "ពាក់ព័ន្ធនឹងអារម្មណ៍របស់ខ្ញុំផ្ទាល់ ខ្ញុំបាទ

[1902] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សៀង ចាន់ធី ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៧៦ បន្ទាត់ ១២-២៤។

[1903] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សៀង ចាន់ធី ប្រតិចារឹក ថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០១៦ ឯកសារ **E1/393.1** ទំព័រ ៧៧ បន្ទាត់ ៤-១០។

អស់ក្តីសង្ឃឹមរលីងអស់"[1904]។ "ពីព្រោះក្រុមគ្រួសារដែលជាបង្អែករបស់ខ្លួនស្លាប់បាត់បង់ជីវិត។ ឪពុក លោកអ្នកដែលមានគុណក៏ស្លាប់បាត់បង់ជីវិតដែរ។ ដឹងថាតែបាត់ខ្លួន គឺស្លាប់ហ្នឹងហ្មង។ ហើយឪពុកក្មេក ក៏អស់។ ដូច្នេះ ពេលខ្លះ ខ្ញុំនឹកថាអាត្មាអញគួរតែសម្លាប់ខ្លួនតាមទៅ ដើម្បីឱ្យវិញ្ញាណក្ខន្ធជាតិក្រោយបានជួបគ្នា ឬ យ៉ាងម៉េច ប៉ុន្តែនឹកឃើញដល់ពាក្យសុភាសិតបារាំងដែលបានធ្លាប់រៀនសូត្រ យល់ដឹងកន្លងមកថា ជីវិតគឺជាការតស៊ូ ជីវិតជាការតស៊ូ ត្រូវតែតស៊ូ ទោះបីខ្លួនឯងបាន មិនបាន កើតមិនកើត សម្រេចមិនសម្រេច ជោគជ័យ ឬ មិនជោគជ័យក៏ដោយក៏នៅតែចេះតែទ្រាំអឺចឹងទៅ ទ្រាំមើលជីវិតហ្នឹង បាទដើម្បីនឹងតស៊ូជាចុងក្រោយ"[1905]។

### *ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន*

918. ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន បានផ្តល់សក្ខីកម្មអំពីការនឹកគិតដល់ប្តីគាត់ក្រោយពេលប្តីរបស់គាត់ត្រូវបានគេយកទៅកាប់រពាក់។ "ខ្ញុំតែងនិយាយទៅ ខ្ញុំថាតែទៅហើយបាត់ហើយមិនមកវិញទេ។ ខ្ញុំនឹកក្នុងចិត្តខ្ញុំថា តែទៅប៉ុណ្ណឹងហើយមិនមកវិញទេ ហើយមិនឃើញអ្នកណាមកមួយមែន បាត់ទាំងអស់គ្នា ទៅទាំងប៉ុន្មាន បាត់ទាំងប៉ុណ្ណឹង"[1906]។ "ខ្ញុំថីមិននេះ ខ្ញុំនឹកឃើញសព្វគ្រប់គេយកប្តីទៅវាយចោល។ ខ្ញុំនឹកស្តាយសោកសង្រេង ប្រៀបពុំបានទេ គ្មានសល់អីទេ"[1907]។

### *ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី*

919. ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី បានពិពណ៌នាអំពីប្រតិកម្មភ្លាមៗ ក្រោយពេលបានឃើញការចាប់ខ្លួន សុន សាន។ "បាទ ចំណែកខ្ញុំ ក៏ដូចជាបងខ្ញុំ ក៏ដូចជាអ្នកជិតខាងទាំងអស់ដែលឈរមើល

---

[1904] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/394.1 ទំព័រ ៦៩ បន្ទាត់ ១២-១៣។

[1905] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/394.1 ទំព័រ ៦៩ បន្ទាត់ ១៣-១៩។

[1906] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/381.1 ទំព័រ ៣៥ បន្ទាត់ ២៣-២៥។

[1907] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ E1/381.1 ទំព័រ ១៥ បន្ទាត់ ២១-២២។

ហ្នឹង គឺមានការភ្ញាក់ផ្អើលបំផុតដោយស្មានមិនដល់ថា គេចាប់ហ្នឹងដោយមានមូលហេតុអី អត់ដឹង"[1908]។

920. នៅពេលពិពណ៌នាអំពីការសម្តែងទុក្ខសោករបស់បងគាត់ក្រោយពេលបាត់បង់កូន និងប្រពន្ធ ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី បានផ្តល់សក្ខីកម្មថា "ខ្ញុំអាចរៀបរាប់អំពីបងឈ្មោះ ឡាច នី ហ្នឹងបាន។ ព្រោះ ឡាច នី ហ្នឹងដល់ដួលសន្លប់ហើយ គាត់ដើរប្រហែល ២ គីឡូ ដល់យប់ប្រហែលជាម៉ោងប្រាំមួយល្ងាច គាត់វិលត្រឡប់មកវិញ មកផ្ទះវិញ។ មកផ្ទះគាត់ហ្នឹង ទៅជាហៅថាវិកលចរិត។ វិកលចរិតអស់រយៈ ៥ ខែ ក៏វិកលចរិត ហើយដើរឱបតែប្រពន្ធគេ ដើរឱបតែកូនគេ។ គាត់ឆ្កួតគាត់ គាត់អត់ដឹងឯណាលិចកើតទេ។ ដូច្នេះ ឡាច នី ហ្នឹងគឺថារយៈពេល ៥ ខែ គឺត្រូវវិកលចរិត ៥ ខែ"[1909]។ "ដើរអីចេះ គឺពេលដែលគាត់នឹកពេក កូន ចេះតែហៅកូនៗ។ ប្រពន្ធគេអូន ប្រពន្ធអីចឹង។ ហើយកូន កូនៗអីចឹង ប៉ុន្តែពួកនោះគេដឹងៗ គេមិនប្រកាន់គាត់ទេ ព្រោះដឹងថាគាត់វិកលចរិត វិកលអីព្រោះគេយកប្រពន្ធកូនទៅអស់ហើយ គាត់ចង់វិកលចរិត។ ដូច្នេះហើយ គឺថាគេមិនប្រកែប្រកាន់គាត់ទេចំពោះ ឡាច នី ហ្នឹង"[1910]។

921. ពេលក្រោយមកក្នុងអំឡុងរបបនោះ អង្គការ បានរៀបចំរៀបការឲ្យ ឡាច នី "ពេលដែលការហើយហ្នឹង គាត់ក៏នៅអាឡោះអាល័យកូនប្រពន្ធរបស់គាត់ខ្លាំងណាស់ គឺក្នុងការយកប្រពន្ធក្រោយហ្នឹង គឺស្រឡាញ់ដែរ ប៉ុន្តែស្រឡាញ់ប្រហែល៧០ភាគរយ ប៉ុណ្ណឹងទេ។ គាត់នៅអាឡោះអាល័យប្រពន្ធដើមរបស់គាត់ និងកូនណោះ មិនទាន់អស់មិនទាន់ហើយផង"[1911]។

---

[1908] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៥២ បន្ទាត់ ២៤-២៥។

[1909] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៥៥ បន្ទាត់ ២៣ -ទំព័រ ៥៦ បន្ទាត់ ២។

[1910] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៥៦ បន្ទាត់ ៥-៨។

[1911] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹកថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៥៧ បន្ទាត់ ៩-១១។

922. ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី បានផ្តល់សក្ខីកម្មថា គាត់បានបាត់បង់សមាជិកគ្រួសារចំនួន១១នាក់។ "១១នាក់ហ្នឹងគឺកូន ឡាច នី ហ្នឹងប្រាំនាក់ ប្រពន្ធមួយទៀត ប្រាំមួយនាក់។ ម្តាយឪពុកខ្ញុំនេះពីរនាក់ទៀត វាប្រាំបីនាក់។ ខាងខ្ញុំពីរនាក់ទៀត វា១០នាក់ ហើយប្អូនខ្ញុំមួយទៀត"[1912]។

### *ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឡឿន*

923. ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឡឿន បានផ្តល់សក្ខីកម្មថា គាត់នៅតែមានការប៉ះពាល់ផ្លូវចិត្តពីការពិភាក្សាអំពីការបាត់បង់សមាជិកគ្រួសាររបស់គាត់។ "ពួកយើងមួយចំនួនពិភាក្សាអំពីការបាត់បង់សមាជិកគ្រួសារ ហើយពេលខ្លះ ខ្ញុំមានអារម្មណ៍មិនល្អ បន្ទាប់ពីបានស្តាប់កាតពិភាក្សាអំពីការបាត់បង់សមាជិកគ្រួសារ"[1913]។ "ខ្ញុំក៏បានឈឺចាប់បាត់បង់ស្មារតីមួយចំនួនដែលខ្ញុំបានគិតគូរ គឺថាបញ្ហាតែពេលខ្ញុំដេកគេងយប់ទៅ ឃើញស្រម័យតែប្រពន្ធកូននៅមុខៗ។ ខ្ញុំក៏គិតឃើញអារម្មណ៍ហ្នឹងបែងចែកកើតទៅជាមានឈឺ រោគព្យាធិហ្នឹងប្រចាំកាយតែម្តងរហូតដល់ទល់ឥឡូវ"[1914]។

### *ដើមបណ្តឹងរដ្ឋប្បវេណី ខូង មួយ*

924. ដើមបណ្តឹងរដ្ឋប្បវេណី ខូង មួយ បានផ្តល់សក្ខីកម្មអំពីព្យសនកម្មផ្លូវចិត្ត ដែលគាត់បានទទួលរងជាផលវិបាកនៃការបាត់បង់សមាជិកគ្រួសាររបស់។ "ដល់ម្តាយខ្ញុំ គេវៃចោល ប្អូន ក្មួយ ប្រាំមួយនាក់ ហើយបងស្រីទៀតប្រាំបីនាក់។ ខ្ញុំក៏បានយំសោកស្តាយម្តាយឪពុកខ្ញុំ ខំថែរក្សាខ្ញុំតាំងពីតូច រហូតដល់សព្វថ្ងៃហ្នឹង ខ្ញុំនៅនឹករឭកម្តាយខ្ញុំ។ ខំឮគេប្រាប់ថា ម៉ាក់អ្អែងយំពេញផ្លូវ គេវៃផង ស្រែកផង ស្រែកអូយ!ៗ ពេញផ្លូវ។ គាត់ប្រាប់ខ្ញុំ ខ្ញុំយំស្តាយម៉ាក់ខ្ញុំ ខ្ញុំខំថែរក្សាខ្ញុំ ថ្នាក់ថ្នមខ្ញុំស្រឡាញ់។ ដល់សព្វថ្ងៃ ខ្ញុំកំព្រា អត់ឪពុកម្តាយ បងប្អូនទាំងអស់ជាង១០នាក់ ស្លាប់អស់"[1915]។

[1912] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹកថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៦១ បន្ទាត់ ១៥-១៦។

[1913] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឡឿន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/361.1** ទំព័រ ៦៧ បន្ទាត់ ២០-២២។

[1914] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឡឿន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/361.1** ទំព័រ ៧៧ បន្ទាត់ ២-៥។

[1915] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ខូង មួយ ប្រតិចារឹក ឯកសារ **E1/394.1** ទំព័រ ៣២ បន្ទាត់ ១២-១៩។

925. “ខ្ញុំឈឺចុកចាប់ណាស់រាល់ថ្ងៃ ខ្ញុំពេលសែនម្ដងៗ សែនហៅម៉ែឪបងប្អូន សែនខាងក្នុងផ្ទះផង នៅក្រៅផ្ទះផង បងប្អូនអត់មានជើងធូប ខ្ញុំកូនចិនកាត់យួន។ សែនតែម៉ែឪមានជើងធូប ចេះតែហៅ ចេះតែនឹករឭកម៉ែខ្ញុំ សព្វថ្ងៃខ្ញុំនៅតែខ្លួនមួយ កំព្រា។ ខ្ញុំយកអីប្រៀបមិនបានទេ អីចឹងបានខ្ញុំចេះតែ នឹកឃើញរាល់ថ្ងៃ ដល់នឹកឃើញយំ នឹកឃើញយំឡើងហើមភ្នែកអស់ហើយ។ កំសត់ណាស់ខ្ញុំ ឈឺចាប់យ៉ាងខ្លាំង រកអីប្រៀបមិនបាន មាសប៉ុនដួងទុំក៏ដូរជីវិតម៉ែឪខ្ញុំក៏មិនបានដែរ មាសអីគេយក ទៅអស់ហើយ។ កំព្រាម៉ែ ដល់គេរំដោះទៅខ្ញុំក៏បានទៅ -- គេរំដោះហើយ គេហៅឡើងភ្នំ ខ្ញុំមិនទៅទេ ខ្ញុំទៅរកអ៊ំនៅភូមិ។ ទៅឃើញអ៊ំ ហើយខ្ញុំក៏យំថែមទៀត យំដល់សព្វថ្ងៃហ្នឹង នៅតែយំ ឲ្យឃើញគេកំព្រាម៉ែកំព្រាឪ ខ្ញុំយំតែរហូត អត់មាន នឹកឃើញការឈឺចាប់ការឈឺចាប់យ៉ាងខ្លាំង ហើយខ្ញុំកំសត់ណាស់ កើតមួយជីវិតហ្នឹង ខុសគេ កំព្រាម៉ែកំព្រាឪ តាំងពី ហើយម៉ែឪខ្ញុំខំតែ រៀតណាម ខំធ្វើការ គេនៅតែយកទៅវ៉ៃចោលទៀត មិនហ៊ានឈប់ទេ”[1916]។

***ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំងចែត***

926. ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំងចែត បានពិពណ៌នាអំពីព្យសនកម្មដោយផ្ទាល់នៃការមើល ឃើញសាកសពសមាជិកគ្រួសារគាត់ថា “ខាងប្អូននាក់ហ្នឹងខ្ញុំអត់ឃើញ ឃើញតែប្រហែលម៉ែឪខ្ញុំ បងប្អូនខ្ញុំសង្កត់លើអីចឹងមិនដឹងបើថារណ្ដៅហ្នឹងពេញតែម្ដង ទាំងម៉ែ ទាំងបង ទាំងឪខ្ញុំទាំងអស់ នៅក្នុងរណ្ដៅហ្នឹង ខ្ញុំឃើញច្បាស់ពីព្រោះខ្ញុំចុងក្រោយគេ”[1917]។ ដើមបណ្ដឹងរដ្ឋប្បវេណី បាន រៀបរាប់ថា “នៅពេលដែលលុតជង្គង់នៅរណ្ដៅ ខ្ញុំងងឹតភ្នែកអស់”[1918]។

927. ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំងចែត បានរៀបរាប់ថា “ផ្ទាល់ភ្នែកខ្ញុំហ្នឹង ថ្ងៃហ្នឹងម៉ែឪងាប់ បងប្អូនសម្លាប់ងាប់ទៅ ផ្ទាល់ភ្នែកខ្ញុំនៅៗខ្ញុំនៅនឹងងាប់នៅមុខហ្នឹងដែរ” “ប៉ុន្តែសំណាងលោកតា

---

[1916] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ខូង មួយ ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/394.1** ទំព័រ ៣៣ បន្ទាត់ ១១-២០។

[1917] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៣៨ បន្ទាត់ ១៧-១៩។

[1918] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៣៨ បន្ទាត់ ២២-២៣។

លោកយាយ ឬអីជួយខ្ញុំទេ វាយខ្ញុំបីខ្នងពូថៅនៅបាក់ឆ្អឹងមួយនៅហ្នឹង មើលនៅៗបាក់ត្រឹមហ្នឹង ប៉ុន្តែដល់ខែត្រជាក់ ខ្ញុំឡើងវេទនាខ្ញុំណាស់ វេទនាណាស់"[1919]។

## ៣. ការបាត់បង់ទ្រព្យសម្បត្តិ

928. ដើមបណ្តឹងរដ្ឋប្បវេណី ខូង បានផ្តល់សក្ខីកម្មថា "នាងខ្ញុំសម័យនុង អត់បានរៀនផង ដឹងតែធ្វើការ ធ្វើទំនប់ ជីកប្រឡាយរហូតដល់រំដោះ៧៩ ខំធ្វើការខ្លាចគេយកទៅវ៉ៃចោល"[1920]។

929. ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន បានផ្តល់សក្ខីកម្មថា "ខ្ញុំឈឺចិត្តឆ្អែតត្រង់ហ្នឹង ព្រោះកូនព្រោះប្តីខ្ញុំបាត់អត់រលីងហើយ ខ្ញុំឈឺចាប់"[1921]។ "ថ្ងៃអីទៅ នឹកតែឃើញ អីទៅនឹកតែឃើញប្តីកូនប្រពន្ធសព្វបែប សព្វយ៉ាង។ ណាមួយទៀតអត់ពីប្តីទៅ វេទនា នៅម្នាក់ឯង រកស៊ីចិញ្ចឹមកូន។ ស្ទួរតែមានទៅ ឯងហ្នឹងក្រទៀត"[1922]។ "ថាបន្ថែម មិនដឹងឲ្យវាជួយខ្ញុំខ្លះផង ព្រោះខ្ញុំក្រីក្រណាស់សព្វថ្ងៃ។ បានព្រឹកខ្វះល្ងាច បានល្ងាចខ្វះព្រឹក។ ចាស់ហើយទៅរកអី? ទៅលក់ដូរអី មិនកើតគេ ដើរតែខ្លួនមិនរួច[1923]"។ "គេធ្វើបាបខ្ញុំឲ្យខ្ញុំរែកដី ឲ្យខ្ញុំលីសែង ដកស្ទូង ធ្វើបាបខ្ញុំ ឥឡូវខ្ញុំឈឺពេញខ្លួនទាំងអស់ តាំងពីនុងមកដល់ហ្នឹង ព្រោះខ្ញុំធ្វើការធ្ងន់ៗពេក។ ទៅដល់ចាស់នៅទ្រុឌទ្រោមដែរ"[1924]។

---

[1919] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៧ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/363.1** ទំព័រ ៥៩ បន្ទាត់ ២២-២៥។

[1920] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ខូង មួយ ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/394.1** ទំព័រ ៣៧ បន្ទាត់ ១២-១៣។

[1921] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹកថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ៥៤ បន្ទាត់ ៩-១០។

[1922] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ៥៤ បន្ទាត់ ១៥-១៦។

[1923] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ៥៤ បន្ទាត់ ១៨-១៩។

[1924] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ដួង អឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/381.1** ទំព័រ ៥៣ បន្ទាត់ ៥-៦។

930. ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំងចែត បានពន្យល់ថានៅពេលដែលគ្រួសាររបស់គាត់ ត្រូវបានជម្លៀសចេញពីភូមិ។ "គេដុតផ្ទះហ្នឹងចោលអស់បាត់ហើយជាមួយសៀវភៅគ្រួសាររបស់យើង"[1925]។ "របស់របរនៅនឹងផ្ទះ ហ្នឹងដុតចោលអស់ហើយ នៅអីទៀត"[1926]។

## ជំពូក ៨. ការបោសសម្អាតនៅភូមិភាគបូព៌ា[1927]

### ក. និដ្ឋភាពទូទៅនៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី

931. ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន, ម៉ី សារឿន និងយុន ប៊ីន បានផ្តល់សក្ខីកម្មអំពីការបោសសម្អាតនៅភូមិភាគបូព៌ាក្នុងអំឡុងសវនាការ[1928]។

---

[1925] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ឯកសារ **E1/364.1** ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/364.1** ទំព័រ ២១ បន្ទាត់ ២០-២២។

[1926] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជឿង យ៉ាំង ចែត ប្រតិចារឹក ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/364.1** ទំព័រ ២៩ បន្ទាត់ ២០។

[1927] អង្គជំនុំជម្រះសាលាដំបូងទទួលបានបណ្តឹងអំពីអង្គហេតុទាក់ទងទៅនឹងអត្ថិភាព និងការអនុវត្តគោលនយោបាយ "ក្នុងការអនុវត្ត និងការពារបដិវត្តសង្គមនិយម ប.ក.ក. តាមរយៈការរៀនសូត្រឡើងវិញនៃ "សមាសភាពអាក្រក់" និងសម្លាប់ "ខ្មាំង" ទាំងក្នុង និងក្រៅថ្នាក់ដឹកនាំបក្ស តាមមធ្យោបាយគ្រប់យ៉ាង តាមការចាំបាច់" ដែលក្នុងនោះរួមទាំងការបោសសម្អាតភូមិភាគបូព៌ា។ ការបោសសម្អាតនៅភូមិភាគបូព៌ា "ចាប់ផ្តើមនៅពាក់កណ្តាលឆ្នាំ ១៩៧៦" ដោយមានការចាប់ខ្លួនអតីតលេខាប្រចាំតំបន់ ២៤ និងអតីតកម្មភិបាលនៃកងពល ១៧០។ ការចាប់ខ្លួន និងការធ្វើទារុណកម្មនៅខែ កញ្ញា ឆ្នាំ ១៩៧៦ បានបង្កើតឱ្យមានការសង្ស័យក្នុងចំណោមថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យថាជា "ភ្នាក់ងារសេអ៊ីអា កាហ្សេបេ និងវៀតណាម" ដែលកំពុងធ្វើប្រតិបត្តិការណ៍នៅភូមិភាគបូព៌ា។ ការចាប់ខ្លួន និងសួរចម្លើយនៅ ស-២១ និងការសម្លាប់កងទ័ពនៅភូមិភាគបូព៌ាបានបន្តក្នុងឆ្នាំ ១៩៧៧ ដោយមានកំណើននៃសង្ស័យថាជាខ្មាំងនៅក្នុងថ្នាក់ដឹកនាំកម្ពុជាប្រជាធិបតេយ្យ។ មានការកើនឡើងនៃការបោសសម្អាតដែលគួរឱ្យកត់សម្គាល់បានកើតឡើងក្រោយខែ មីនា ឆ្នាំ ១៩៧៨ ដោយមានការបោសសម្អាតនៅតំបន់ ២៣ នៅខេត្តស្វាយរៀង ហើយបន្ទាប់មកទៀតមានការចាប់ខ្លួន និងសម្លាប់បន្ថែមនៅខែ មិថុនា ឆ្នាំ ១៩៧៨ ពីតំបន់ផ្សេងៗនៃភូមិភាគបូព៌ា។ នៅពេលនោះ សោ ភឹម ដែលជាលេខាភូមិភាគបូព៌ា បានធ្វើអត្តឃាត ដើម្បីបញ្ចៀសការចាប់ខ្លួន។ ការកំណត់គោលដៅលើកម្មភិបាលភូមិភាគបូព៌ា ទោះបីលែងមានភូមិភាគបូព៌ា និងមន្ត្រីមួយចំនួន នៅបន្តរហូតដល់ចុងបញ្ចប់នៃរបបនេះ ហើយធ្វើឡើងតាមរយៈ៖ ការបញ្ជូនទៅ "រៀនសូត្រឡើងវិញ" នៅការដ្ឋាន ដូចជាព្រលានយន្តហោះកំពង់ឆ្នាំង ការសម្លាប់នៅការដ្ឋាន ឬត្រូវបញ្ជូនទៅ ស-២១។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៧៨ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៩២។ ក.ស.ច.ស. បានកំណត់ការបោសសម្អាតផ្ទៃក្នុងថាជា "បោសសម្អាត" ដែលមានន័យថា ការបន្សុទ្ធផ្នែកនយោបាយតាមរយៈការធ្វើទណ្ឌកម្មផ្សេងៗ ចាប់ពីការទម្លាក់ថ្នាក់ ឬការរៀនសូត្រឡើងវិញ រហូតដល់ការកម្ទេច"។ ដីកាដំណោះស្រាយ ឯកសារ ដីកាដំណោះស្រាយ ឯកសារ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៩៩-២០១។

932. មុនឆ្នាំ ១៩៧៥ ដើមបណ្ដឹងរដ្ឋប្បវេណី ឈុន សាម៉ន បានរស់នៅក្នុងភូមិថ្មី, ឃុំក្បែត, ឃុំកំពង់រោទិ៍, ខេត្តស្វាយរៀង និងមានអាយុប្រហែល១៨ឆ្នាំ នៅពេលដែលខ្មែរក្រហម ឡើងកាន់អំណាច[1929]។ គាត់បានចូលរួមជាមួយខ្មែរក្រហម ក្នុងខែ ឧសភា ឆ្នាំ ១៩៦៥ ហើយពេលដំបូង ជានីរសាឲ្យកង៧៥[1930]។ គាត់ត្រូវបានបញ្ជូនទៅតំបន់២៣ (ភូមិភាគបូព៌ា) ក្នុងកងស៊ើបការណ៍ពិសេស ង១១២ នៅដើមឆ្នាំ ១៩៧៦[1931]។ គាត់បានចូលរួមក្នុងការប្រយុទ្ធយ៉ាងខ្លាំងក្លាជាមួយទាហានវៀតណាមនៅតាមព្រំដែនក្នុងឆ្នាំ ១៩៧៦ ហើយបន្ទាប់មក ការប្រយុទ្ធនោះ មានសភាពកាន់តែស្វិតស្វាញក្នុងឆ្នាំ ១៩៧៧[1932]។

933. ក្នុងឆ្នាំ ១៩៧៧ ដើមបណ្ដឹងរដ្ឋប្បវេណី ឈុន សាម៉ន បានឮថាកម្មាភិបាល ត្រូវបានហៅឲ្យទៅរៀន ហើយពួកគេបានបាត់ខ្លួនម្ដងម្នាក់ៗ[1933]។ នៅចុងឆ្នាំ ១៩៧៧ កងទ័ពខ្លះ ត្រូវបាន “ហៅឲ្យមករៀនសូត្រ” ហើយបានបាត់ខ្លួន[1934]។ នៅពេលដែលពួកគេបានចាប់ទាហានភូមិភាគបូព៌ា “គេថាពួកភូមិភាគបូព៌ាហ្នឹងក្បត់បក្ស គេហៅថាក្បាលយួន ខ្លួនខ្មែរ”[1935]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មថា “តែតាមពិត ពួកខ្ញុំជាកងទ័ពនោះ អត់មានដឹងអីទាំងអស់។ ដឹងតែពីស្រឡាញ់

---

[1928] ក.ស.ច.ស. បានទទួលស្គាល់ដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ១១៦ នាក់ ពាក់ព័ន្ធនឹងការបោសសម្អាតផ្ទៃក្នុង (ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ២០៤) និងដើមរដ្ឋប្បវេណី ៣នាក់ត្រូវបានទទួលស្គាល់ដោយ អ.ប.ជ.។

[1929] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/445.1** ទំព័រ ២៧ បន្ទាត់ ៦-៩។

[1930] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/445.1** ទំព័រ ៨ បន្ទាត់ ២០-២១។

[1931] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/445.1** ទំព័រ ១០ បន្ទាត់ ១៣ -២២ និងទំព័រ ៥៣ បន្ទាត់ ១៧-២៤។

[1932] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/445.1** ទំព័រ ១៥ បន្ទាត់ ៩-១០។

[1933] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/445.1** ទំព័រ ១៦ បន្ទាត់ ១៧-១៩។

[1934] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/445.1** ទំព័រ ១៥ បន្ទាត់ ១៨-២១។

[1935] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/445.1** ទំព័រ ៥៥ បន្ទាត់ ២១-២៣។

ខ្មែរ និងគោរពខ្មែរ ការពារបូរណភាពដែនដីរបស់ខ្មែរ មិនឱ្យយួនយកបាន តែប៉ុននុង។ តែទៅចុងក្រោយទៅ ដល់គាត់បានចោទប្រកាន់អីចឹងទៅ"[1936]។

934. ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន ត្រូវបានចាប់ខ្លួន ក្នុងខែ សីហា ឆ្នាំ ១៩៧៨[1937]។ គាត់ចងចាំថា "គេហៅចាប់ចងម្តងពីរនាក់ៗ ទៅគេយកខ្សែដោតតាមក្លៀកតាមអីហ្នឹង។ បានគេដកហូតខោអាវអីទៅបានយើងដឹងថា អ! ប្រហែលជាមិនរស់ទេ ប្រហែលជាគេយកទៅវ៉ៃចោលហើយ"[1938]។ ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន បានពិពណ៌នាថា បន្ទាប់ពីគាត់ត្រូវបានខ្លួន "គេស្រាយបួននាក់ យកទៅសម្លាប់ចោលហ្នឹង[1939]។ ដឹងថាគេយកទៅសម្លាប់ចោលអីចឹង"។ ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន ចងចាំថាបានលឺ "ស្រែកឃំ គឺវាវ៉ៃយកទៅបណ្តោយ។ បាទហើយសម្លាប់ហ្នឹង ហើយបានមកយកពួកខ្ញុំហ្នឹង"[1940]។ "ពួកខ្ញុំក៏ភ័យស្ទុះរត់ហ្នឹង ក៏អ្នកពួកវាហ្នឹងក៏ស្ទុះបាញ់ងាប់ទាំងអស់តែម្តងទៅបាទ។ ហើយនៅពេលនោះ យើងពុំមានសម្លៀកបំពាក់លើខ្លួនទេ"[1941]។ គាត់បានផ្តល់សក្ខីកម្មថា "បន្ទាប់មក ពួកគេបានបាញ់យើង។ ដូច្នេះយើងបានគេចខ្លួន

[1936] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/445.1** ទំព័រ ៥៨ បន្ទាត់ ១១-១៥។

[1937] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/445.1** ទំព័រ ២៩ បន្ទាត់ ១៥-១៧ និងទំព័រ ៣៥ បន្ទាត់ ៦-១០។

[1938] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/445.1** ទំព័រ ៦១ បន្ទាត់ ២២- ទំព័រ ៦២ បន្ទាត់ ២។

[1939] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/445.1** ទំព័រ ៦៩ បន្ទាត់ ១០-១២។

[1940] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/445.1** ទំព័រ ៦៩ បន្ទាត់ ១៦ – ២២។

[1941] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/445.1** ទំព័រ ៦១ បន្ទាត់ ១០-១២។

បន្ទាប់ពីបានឮសំឡេងប្អូននាក់ស្រែកក្រោយពីត្រូវបានសម្លាប់។ យើងភ័យរន្ធត់”[1942]។ ដើមបណ្តឹងរដ្ឋប្បវេណី ថ្លែងថា “ពួកយើងបីនាក់រត់គេចខ្លួនបាន ប៉ុន្តែអ្នកផ្សេងត្រូវបានសម្លាប់”[1943]។

935. បន្ទាប់មក ដើមបណ្តឹងរដ្ឋប្បវេណី បានរត់ភៀសខ្លួនទៅកាន់ប្រទេសវៀតណាម[1944] នៅចុងឆ្នាំ ១៩៧៨។ គាត់បានបន្តប្រយុទ្ធរំដោះប្រទេសកម្ពុជាពីខ្មែរក្រហមក្នុងឆ្នាំ ១៩៧៨ និងឆ្នាំ ១៩៧៩[1945]។ គាត់បានបាត់បង់បងប្រុស ដែលជាកងទ័ពកម្ពុជាប្រជាធិបតេយ្យ នៅពេលដែលបងប្រុសគាត់បានបាត់ខ្លួន ក្រោយពេលទៅរៀនសូត្រ[1946]។

936. ដើមបណ្តឹងរដ្ឋប្បវេណី ម៉ុ សារឿន[1947] បានចូលរួមក្នុងកងទ័ពរំដោះជាតិ ថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៨ បន្ទាប់មកបានបោះទីតាំងនៅភូមិកោះកែវ, ស្រុកល្វាឯម, ខេត្តកណ្តាល[1948]។ ដើមបណ្តឹងរដ្ឋប្បវេណី បានស្ថិតនៅក្នុងកងឃោធា ក១៤៨, ក១ និងក៣ ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ភូមិភាគបូព៌ា[1949]។ ក្រោយពេលរំដោះក្រុងភ្នំពេញ អាវុធរបស់ដើមបណ្តឹងរដ្ឋប្បវេណី និងអាវុធក្នុងកងរបស់គាត់ ត្រូវបានដកហូត ហើយពួកគេត្រូវបានបញ្ជូនឲ្យទៅធ្វើការនៅស្រែ បន្ទាប់មកឲ្យជីក

[1942] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/445.1** ទំព័រ ៦៩ បន្ទាត់ ២១- ទំព័រ ៧០ បន្ទាត់ ២។

[1943] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/445.1** ទំព័រ ៧០ បន្ទាត់ ៧។

[1944] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/445.1** ទំព័រ ២០ បន្ទាត់ ៣-៦ និងទំព័រ ២២ បន្ទាត់ ២៥- ទំព័រ ២៣ បន្ទាត់ ១ និងទំព័រ ៣៥ បន្ទាត់ ៦-១០។

[1945] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/445.1** ទំព័រ ៧៦ បន្ទាត់ ៧-២៥។

[1946] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/446.1** ទំព័រ ១១ បន្ទាត់ ២-៧។

[1947] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ុ សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ៣ បន្ទាត់ ១៧-២២។

[1948] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ុ សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ៦ បន្ទាត់ ៦-៧។

[1949] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ុ សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ៦ បន្ទាត់ ២៥ -ទំព័រ ៧ បន្ទាត់ ១។

ប្រឡាយ, សាងសង់ផ្លូវ និងសាងសង់ប្រព័ន្ធភ្លឺស្រែនៅការដ្ឋានឈ្មោះវាលកសិដ្ឋាន នៅខេត្តព្រៃវែង[1950]។

937. ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី សារឿន បានពិពណ៌នាអំពីស្ថានភាពចលាចលចំពោះកងទ័ពភូមិភាគបូព៌ា ពីឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៨។ មុនពេលដែលដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី សារឿន ត្រូវបានបញ្ជូនទៅពោធិសាត់ក្នុងឆ្នាំ ១៩៧៨ ដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានចាប់ខ្លួនឃុំនៅក្នុងស្រុកមេសាង (ខេត្តព្រៃវែង)។ នៅទីនោះ គាត់ត្រូវបានបង្ខំឱ្យជីកដី[1951]។ បន្ទាប់មកដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានចាប់ខ្លួនខណៈដែលនៅពាក់ឯកសណ្ឋានកងទ័ព[1952] នៅវត្តក្រញូង[1953] ហើយបានជាប់ឃុំឃាំងនៅក្បែរនោះ[1954]។ គាត់ត្រូវបានអូសពីក្រោយកង់ វាយដំ និងត្រូវបានសួរចម្លើយ[1955] មុនពេលត្រូវបានដោះលែង[1956]។ ដើមបណ្ដឹងរដ្ឋប្បវេណី បានផ្ដល់សក្ខីកម្មថា អ្នកផ្សេងទៀតដែលបានសារភាពក្នុងពេលសួរចម្លើយត្រូវបានសម្លាប់[1957]។ ដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានចាប់ខ្លួនម្ដងទៀតជាមួយម្ដាយរបស់គាត់នៅខេត្តស្វាយរៀង ប៉ុន្តែបានរត់គេចពីការឃុំឃាំងក្នុងគុក

[1950] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ៧ បន្ទាត់ ១១-១៨។

[1951] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ១៤ បន្ទាត់ ៤-១២។

[1952] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ១៦ បន្ទាត់ ៦។

[1953] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ១៦ បន្ទាត់ ១៤-១៥។

[1954] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ១៦ បន្ទាត់ ១៥-១៦។

[1955] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ១៧ បន្ទាត់ ៥-១១ និងទំព័រ ១៧ បន្ទាត់ ២០-ទំព័រ ១៨ បន្ទាត់ ១។

[1956] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ១៨ បន្ទាត់ ៧ - ១៨ ។

[1957] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ១៨ បន្ទាត់ ២២-២៤។

ដែលមានឈ្មោះថាគុកក្ដីរំដួល ពីព្រោះការប្រយុទ្ធជាមួយវៀតណាម បានផ្ទុះឡើង[1958]។ ដើមបណ្ដឹងរដ្ឋប្បវេណី បានរៀបការនៅក្នុងភូមិចែងមែង, សហករណ៍ព្រៃឈរ ក្នុងខេត្តព្រៃវែង ដោយមានដឹងអំពីការរៀបការនោះមួយថ្ងៃមុនប៉ុណ្ណោះ[1959]។

938. ក្នុងឆ្នាំ ១៩៧៨ ដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានបញ្ជូនតាមរថភ្លើងទៅកាន់ខេត្តពោធិ៍សាត់ ប៉ុន្តែបានចុះនៅស្ថានីយ៍បឹងខ្នារ[1960]។ នៅតាមផ្លូវទៅពោធិ៍សាត់ "យើងត្រូវបានបញ្ជូនទៅអ្នកលឿង។ នៅទីនោះ គេឱ្យឡើងជិះទូក ជាមួយនឹងសម្លៀកបំពាក់មួយចំនួន ហើយនៅច្បារអំពៅ គេឱ្យសម្លៀកបំពាក់ខ្លះ និងក្រមា ដើម្បីងាយស្រួលចំណាំ"[1961]។ ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ុ សារឿន បានផ្ដល់សក្ខីកម្មថាអ្នកនៅពោធិ៍សាត់ "គឺគេសម្គាល់ទៅតាមសម្លៀកបំពាក់ មានក្រមា ហើយនិងអាវ។ ខោអាវគឺខៀវហ្នឹង ដែខ្លីហ្នឹងគែបែកចែកពីនេះទៅភ្នំពេញទៅតែម្ដង គឺឱ្យទៅនុង គឺគេដឹងតែឃើញតែក្រមាខៀវហ្នឹង គឺដឹងថាប្រជាជននៅភូមិភាគបូព៌ាហ្នឹងហើយ ពួគេថាបែងចែកមិនឱ្យច្របូកច្របល់ដែរ[1962]។

939. បីថ្ងៃបន្ទាប់ពីដើមបណ្ដឹងរដ្ឋប្បវេណី បានចុះនៅស្ថានីយ៍បឹងខ្នារ "គេបញ្ចូលទៅក្រោល"[1963]។ ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ុ សារឿន ចងចាំបានថានៅពេលដែលពួកគេបានជាប់ឃុំឃាំងនៅក្នុងក្រោលគោ "គឺមានក្រុមគេនៅក្នុងហ្នឹង គឺគេមានប្រដាប់ដោយដំបង ហើយមានកាំបិតសម្រាប់វាយ

---

[1958] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ុ សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ១៨ បន្ទាត់ ២០ -ទំព័រ ១៩ បន្ទាត់ ២។

[1959] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ុ សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ១៩ បន្ទាត់ ៦-១៧។

[1960] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ុ សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ២០ បន្ទាត់ ២២-២៣។

[1961] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ុ សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ២០ បន្ទាត់ ១៩-២២។

[1962] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ុ សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ៥៥ បន្ទាត់ ២១-ទំព័រ ៥៦ បន្ទាត់ ២។

[1963] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ុ សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ២១ បន្ទាត់ ៤-៥។

យើង"[1964]។ "គឺគេរៀបចំកងជិះសេះខ្លះ ហើយដេញបាញ់អ្នករស់ចេញរួច"[1965]។ ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ុ សារឿន បានថ្លែងថាពួកគេសំណាងល្អ[1966] ពីព្រោះពួកគេ "រត់ចេញផុតពីក្រោលហ្នឹងហើយ ក៏បានជួបកម្លាំងដែលរត់ចេញទៅនៅពេលក្រៅ ចេញក្រៅក្រោលហ្នឹងឆ្ងាយដែរ បានជួបអ្នករត់ចេញបានរួចហ្នឹង ក៏រត់សំដៅមកខេត្តពោធិ៍សាត់ទៀត[1967]។ ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ុ សារឿន បានផ្ដល់សក្ខីកម្មថា នៅពេលនោះ "គឺនិយាយរួមទៅ គឺថាកន្លែងណាក៏សម្លាប់ដែរ គឺឱ្យតែប្រជាជនបូព៌ាហ្នឹងដែល--"[1968]។

940. បន្ទាប់ពីគេចពីក្រោលគោ នៅតាមផ្លូវទៅពោធិ៍សាត់ ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ុ សារឿន បានធ្វើដំណើរតែពេលយប់ប៉ុណ្ណោះដើម្បីកុំឱ្យគេឃើញ[1969]។ ក្នុងអំឡុង "ពេលធ្វើដំណើររយៈពេល ១០ថ្ងៃ ១០យប់" ដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានចាប់ខ្លួនវិញនៅព្រៃស្លឹក ខាងកើតខេត្តពោធិ៍សាត់ ហើយគាត់ត្រូវបានបង្អត់អាហារ និងទឹក ហើយ "ចង់ដាច់ខ្យល់ហើយ"[1970]។ ពួកគេត្រូវបានយកទៅទីតាំងមួយនៅក្បែរនោះ និងត្រូវបានបញ្ជាឱ្យអង្គុយចុះ។ នៅពេលនោះ ដើមបណ្ដឹងរដ្ឋប្បវេណី បានដឹងថា "គេយកមកសម្លាប់ទៀតហើយ"[1971]។ ដើមបណ្ដឹងរដ្ឋប្បវេណី បានឆ្លៀតឱកាស

---

[1964] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ុ សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ២១ បន្ទាត់ ១០-១២។

[1965] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ុ សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ២១ បន្ទាត់ ១៤-១៦។

[1966] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ុ សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ២១ បន្ទាត់ ១៦-១៨។

[1967] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ុ សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ២២ បន្ទាត់ ១-៣។

[1968] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ុ សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ២១ បន្ទាត់ ១៩-២១។

[1969] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ុ សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ២២ បន្ទាត់ ៣-៦។

[1970] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ុ សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ២២ បន្ទាត់ ១០-១៦។

[1971] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ុ សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ២២ បន្ទាត់ ១០-១៦។

រត់គេចខ្លួន និងបានចាប់ផ្តើមរត់ ប៉ុន្តែត្រូវបានបាញ់ចំដៃខាងឆ្វេង ក្នុងអំឡុងពេលរត់គេចខ្លួនទៅស្រុកបាកាន[1972]។

941. ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន បានផ្តល់សក្ខីកម្មថា "មនុស្សមកពីភូមិភាគបូព៌ាទាំងអស់ហ្នឹង គឺសម្លាប់ទៅ ដែលមកជាមួយខ្ញុំហ្នឹងគឺនៅស្ថិតនៅក្នុងស្រុកបាកានទាំងអស់"[1973]។ "អ្នកទាំងអស់នោះដែលមកហ្នឹងគឺ គេត្រូវសម្លាប់ជារៀងរហូត គឺដោយគេយកគោលការណ៍មួយ ផ្លាស់សមរភូមិទៅទីនេះ ទៅនោះ ទៅអីចឹងទៅ គឺថាអង្គការយើងឲ្យផ្លាស់សមរភូមិ។ យកម្តងពីរគ្រួសារ បីគ្រួសារទៅទាំងអស់ៗ។ ហើយជួនពេលខ្លះគឺថា អង្គការយើងឲ្យទៅរៀនសូត្រ ដឹកដោយទៅរទេះគោខ្លះ ហើយនិងទៅតាមរយៈដើរខ្លះ គឺបាត់ៗឈឹងអត់ដែលឃើញត្រលប់មកវិញ"[1974]។

942. ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន បានបាត់បង់សាច់ញាតិជាង៥០នាក់នៅពោធិ៍សាត់ រួមទាំងម្តាយ និងបងស្រីរបស់គាត់[1975]។

943. ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន បានរស់នៅភូមិទួលមាន, ឃុំព្រះធាតុ, ស្រុកអូររាំងឪ, ខេត្តត្បូងឃ្មុំ អតីតខេត្តកំពង់ចាម នៅភូមិភាគបូព៌ា[1976]។ បន្ទាប់ពីភ្នំពេញ ត្រូវបានរំដោះនៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន និងអ្នកភូមិគាត់ ត្រូវបានប្រមូលឲ្យចូលក្នុងកងចល័ត ហើយត្រូវបានបញ្ជូនទៅកោះទន្សាយ[1977]។ ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន ត្រូវ

[1972] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ២៣ បន្ទាត់ ២៣-២។

[1973] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ៦២ បន្ទាត់ ១០-១១។

[1974] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ៦២ បន្ទាត់ ១៥-១៩។

[1975] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ២៣ បន្ទាត់ ២០-២៤ ។

[1976] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ២ បន្ទាត់ ២។

[1977] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៥ បន្ទាត់ ៦។

បានចាត់ឲ្យកាប់ឆ្ការព្រៃ និងដកស្ទូងដើម្បីផលិតស្រូវបានបីតោនក្នុងមួយហិចតា[1978]។ ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ឹន គឺជាអនុប្រធានកងចល័ត នៅពេលដែលគាត់ត្រូវបានកោះហៅឲ្យទៅរៀនជាមួយមនុស្សពីរនាក់នៅក្នុងកងរបស់គាត់ ដោយប៉ុកដែលជាឈ្លប[1979]។ កាលពីថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ១៩៧៨[1980] ពួកគេត្រូវបានមេឃុំ ឈ្មោះ លាវ បញ្ជាឲ្យទៅមន្ទីរព្រះធាតុ ដែលមានយុវជន៦នាក់ទៀតមកពីភូមិក្បែរនោះ[1981]។ ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ឹន បានរំឭកថាបីបួនខែក្រោយមុនពេលនោះ អនុប្រធានកងចល័ត "សាម៉េត" ត្រូវបានយកទៅសម្លាប់[1982]។ ពួកគេត្រូវបានប្រាប់ថា "យកមករៀនសូត្រតែបួនប្រាំថ្ងៃនឹងវិលត្រឡប់ទៅផ្ទះវិញហើយ[1983]"។

944. ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ឹន និងមនុស្ស៥នាក់ទៀត បានមកដល់ពាមជាំង ជាកន្លែងដែលគាត់បានឃើញអ្នកមកពីនិរតីជាមួយច្រើននាក់[1984]។ ពួកគេត្រូវបានដាក់នៅក្នុងរថយន្តមួយជាមួយនឹងមនុស្ស៤០នាក់ទៀត ហើយចំណាយពេល១៥នាទីទៅដល់កន្លែងមានរណ្តៅ[1985]។ នៅពេលរថយន្តបានមកដល់ ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានបណ្តើរទៅទិសខាងត្បូង ហើយ "ក៏វាដាក់ក្បាលខ្ញុំមួយពូថៅ ដួលសន្លប់លោតទៅ ព្រោះមានទឹកថ្លុកឈាមមួយនៅពីឃ្នើង ក៏ផុតនុងទៅ ក៏ខ្ញុំក៏សន្លប់

---

[1978] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ឹន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៥ បន្ទាត់ ១១។

[1979] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ឹន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ៥ បន្ទាត់ ១៥-១៧។

[1980] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ឹន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ២១ បន្ទាត់ ៥-៦។

[1981] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ឹន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៦ បន្ទាត់ ១-៥។

[1982] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ឹន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ១៦ បន្ទាត់ ២៤-ទំព័រ ១៧ បន្ទាត់ ៨។

[1983] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ឹន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៧ បន្ទាត់ ១-៣។

[1984] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ឹន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៦ បន្ទាត់ ២០-២១។

[1985] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ឹន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៨ បន្ទាត់ ១៥-១៩។

ទៅ[1986]"។ នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណី បានភ្ញាក់ដឹងខ្លួនវិញ គាត់ដឹងថាគាត់ស្ថិតនៅក្នុងរណ្តៅជាមួយ "បីបួននាក់នៅលើខ្នង[1987]"។ គាត់បានឮសំឡេង "ភូស ព្រឹសៗ ហើយទម្លាក់មកមកលើខ្ញុំ" នៅពេលការសម្លាប់កំពុងត្រូវបានបន្ត[1988]។

945. ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន បានពិពណ៌នាអំពីការលូនចេញពីរណ្តៅ ដែលអ្នកផ្សេងទៀតបានស្លាប់អស់[1989] នៅ"ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ១៩៧៨"[1990]។ គាត់បានបន្តពិពណ៌នាអំពីការគេចជៀសពីការឃាមល្បាត និងអ្នកផ្សេងទៀតនៅក្នុងតំបន់នោះ ដើម្បីធ្វើដំណើរត្រឡប់មកលាក់ខ្លួន[1991] នៅផ្ទះឪពុកគាត់[1992]។ ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន បានពិពណ៌នាអំពីការលាក់ខ្លួនរបស់គាត់នៅក្នុងព្រៃ ជាមួយឪពុកគាត់ បន្ទាប់ពីគាត់បានត្រលប់មកវិញ ប៉ុន្តែក្រោយមក ឪពុករបស់គាត់បានធ្លាក់ខ្លួនឈឺ ហើយបានស្លាប់[1993]។

---

1986 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៩ បន្ទាត់ ៤-៦។

1987 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៩ បន្ទាត់ ៨-៩។

1988 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៩ បន្ទាត់ ១២-១៤។

1989 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ១០ បន្ទាត់ ៣-២១ ។

1990 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ១៤ បន្ទាត់ ១-៣ និងទំព័រ ១៧ បន្ទាត់ ១៦-១៩។

1991 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ១១ បន្ទាត់ ២៥ -ទំព័រ ១៣ បន្ទាត់ ១៤។

1992 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ១៣ បន្ទាត់ ១៤-១៥។

1993 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ១៤ បន្ទាត់ ៤-៥។

## ខ. តួនាទីរបស់កម្មាភិបាលភូមិភាគនិរតី

946. សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី បង្ហាញអំពីតួនាទីសំខាន់របស់កម្មាភិបាលមកពីនិរតីក្នុងការអនុវត្តការបោសសម្អាតនៅក្នុងភូមិភាគបូព៌ា។

947. ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន បានផ្តល់សក្ខីកម្មថា "វាមានកម្លាំងគេមកប្រាប់ថា ឥឡូវកងទ័ពយើងនៅហ្នឹងឱ្យរំសាយទៅតាមគ្រួសារសិនទៅ។ ហ្នឹងកងទ័ពខាងប្រហែលជាមិនមែនកងទ័ពបូព៌ាទេ អ្នកគេមកប្រាប់ហ្នឹងកងទ័ពខាងនិរតី ខាងមជ្ឈិមហើយ ព្រោះគាត់និយាយរអឺនណាស់បាទ។ គាត់មកប្រាប់ គាត់ជិះម៉ូតូមកប្រាប់ ប្រាប់តៗគ្នាហ្នឹងទៅ ថាឱ្យកងទ័ពហ្នឹងវិលទៅតាមគ្រួសារវិញ ចាំអង្គការយើងហៅទៅចូលកងទ័ព ចូលជួរវិញ *ក្រោយពេលអង្គការបោសសម្អាតសមាសភាពមិនល្អ គឺក្បាល "យួន" ខ្លួនខ្មែរ*។ នាំគ្នារំសាយអីមកតាមគ្រួសាររៀងៗខ្លួនតាមភូមិ ស្រុក ឃុំ តាមរៀងខ្លួនទៅ។ ក៏រំសាយតែប៉ុននុង រំសាយចេញពីវាលតាប្រុញហ្នឹងមកទៅ"[1994]។ នៅពេលដែលពួកគេបានមកដល់ភូមិ "ទៅហៅបញ្ជូនឱ្យកងមជ្ឈិមហ្នឹងវិញ ឱ្យកងនិរតីហ្នឹងវិញទៅ។ ដល់ពេលយកកងនិរតីហ្នឹងវិញ គេយកទៅកត់ឈ្មោះកត់អីទៅ។ មានហេតុកើតយកទៅសម្លាប់ចោលតែម្តងទៅ"[1995]។

948. ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន បានផ្តល់សក្ខីកម្មទាក់ទងនឹងពីការណ៍ដែលកម្មាភិបាលភូមិភាគនិរតី "គេឡោមព័ទ្ធទៅហ្នឹង គឺតាមរយៈលោក សោ ភឹម ហ្នឹងក៏គាត់បានចលនាហ្នឹង គឺថាគឺកងទ័ពបូព៌ាហ្នឹងគឺក្បត់ ចូលដៃជើងយួន គឺចូលដៃជើងយួន។ អានេះគឺជាគេហៅថាមិនដឹងជាល្បិចកលរបស់គេ ដើម្បីកម្ចាត់កងទ័ពបូព៌ា ឬមួយក៏យ៉ាងម៉េចទេ គឺខ្ញុំមិចយល់។ ក៏ចាប់មេកងពលកងទ័ពបូព៌ាហ្នឹង គឺសម្លាប់ទាំងអស់ដែលមេៗកងពលហ្នឹង។ គេឃោសនាឱ្យមកប្រជុំហ្នឹង រួចហើយក៏គេសម្លាប់ចោលបាត់តែម្តង បាត់ៗទាំងអស់តែម្តង"[1996]។

---

[1994] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/445.1** ទំព័រ ២០ បន្ទាត់ ៩-១៦។

[1995] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/445.1** ទំព័រ ២១ បន្ទាត់ ២២-២៤។

[1996] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ៣៥ បន្ទាត់ ២២-ទំព័រ ២៦ បន្ទាត់ ១។

949. ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន បានផ្តល់សក្ខីកម្មថាកម្មាភិបាលនិរតី បានមកដល់ភូមិភាគបូព៌ា "បីបួនខែ មុនពេលដែលគេយកខ្ញុំទៅ"[1997]។ ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន បានផ្តល់សក្ខីកម្មថា គាត់ដឹងថាពួកគេគឺជាកងទ័ពនិរតី ពីព្រោះ "ពួកនោះ និយាយសុទ្ធតែរដឺន។ បាទ ស្តាប់អីចឹង សុទ្ធតែរដឺន ព្រោះអីអត់និយាយដូចពួកខ្ញុំអីនោះទេបាទ។ ព្រោះរដឺន ខ្ញុំមិនដឹងដែរ មិនដឹងទៅខាងណា និរតីៗ ប៉ុន្តែតែពួករដឺន ពួកនិរតីហើយ"[1998]។ "ខ្ញុំដឹងត្រង់វាយកខ្ញុំទៅសម្លាប់ចោលហ្នឹងបាទ ឃើញពួកវាហ្នឹងនិយាយជាមួយខ្ញុំ សុទ្ធតែរដឺនអីចឹង ដឹងត្រឹមហ្នឹងទេ"[1999]។

## គ. ព្យសនកម្ម

## ១. ព្យសនកម្មលើរាងកាយ

### *ការរងរបួសលើរាងកាយ - ផលវិបាករយៈពេលខ្លី និងរយៈពេលវែង*

950. ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន បានរៀបរាប់ថា បន្ទាប់ពីគាត់ត្រូវបានយកទៅកន្លែងសម្លាប់ ពួកគេបានប្រាប់គាត់ថា "អ្វែងអង្គុយចុះ! ខ្ញុំអង្គុយចោងហោងចុះ ក៏វាដាក់ក្បាលខ្ញុំមួយពូថៅ ដួលសន្លប់លោតទៅ ព្រោះមានទឹកថ្លុកឈាមមួយនៅពីមុខហ្នឹង ក៏ផុតនុងទៅ ក៏ខ្ញុំក៏សន្លប់ទៅ"[2000]។

951. ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន ពិពណ៌នាអំពីផលប៉ះពាល់លើរាងកាយបណ្តាលមកពីការវាយប្រហារនេះ។ "បាទ នៅរបួសទាល់សព្វថ្ងៃនេះនៅបីកន្លែង មួយកន្លែងចង់បែកលលាដ៍ហ្នឹងបាទ នៅពីលើក្បាលខ្ញុំ"[2001]។ គាត់បានពិពណ៌នាថា "ស្លាកស្នាមខ្ញុំនៅនឹងក្បាលបីកន្លែង"[2002] ហើយ

---

[1997] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ១៧ បន្ទាត់ ៨។

[1998] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ២៣ បន្ទាត់ ៧-៩។

[1999] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ២៥ បន្ទាត់ ៣-៤។

[2000] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៩ បន្ទាត់ ៤-៦។

[2001] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ១៤ បន្ទាត់ ២៤-២៥។

"ឈាមក៏នៅតែប្រឹងឡើងនៅតែហូរ ខ្ញុំក៏បូតស្លឹកទ្រាសនោះ ហាមាត់ ហាបាន ប៉ុន្តែថ្គាមហារឹងទាំងអស់ ដាក់ស្លឹកទ្រាសគ្រាន់តែលេប"[2003]។ ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន បានផ្តល់សក្ខីកម្មថាបន្ទាប់ពីគាត់ត្រូវបានវាយនឹងពូថៅ និងបានដឹងខ្លួនវិញ "ពេលនោះហើយខ្ញុំកំណត់ឡើងតែបីដងទេ បើបីដងមិនរួច ខ្ញុំជេរវា ខ្ញុំហៅវាឈរឲ្យវាបាញ់ ឲ្យវាចោលគ្រាប់បែកសម្លាប់ចុះព្រោះនៅនុះ ទីកន្លែងនោះ រស់នៅតែខ្ញុំម្នាក់ឯង។ ក៏សន្សាអីចឹងមើលទៅខ្ញុំចាប់ឡើងកាងដៃវាផុតៗដៃ។ ដូច្នេះខ្ញុំក៏សម្រេចចិត្តលើកដៃពីរទៅមុខ ជើងពីរទៅក្រោយផ្កាប់មុខ ហើយខ្លួនបិតនឹងអាវនឹងជញ្ជាំងដៃឲ្យជាប់ខ្លាំង។ ពេលឡើងទី១ ឡើងទៅដល់ប្រហែលជា៤ទៅ៥ម៉ែត្រ ក៏បានធ្លាក់ទៅវិញ។ ខ្ញុំនឹកថា ខ្ញុំអស់សង្ឃឹមហើយ"[2004]។

952. ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន បានធ្វើដំណើរទៅផ្ទះរបស់គាត់ដោយមានរបួសជាប់ខ្លួន។ គាត់ចាំបានថានៅតាមផ្លូវ "ក្បាលខ្ញុំហ្នឹង ដង្កូវវារុក រើកៗ ខ្ញុំចេះឆ្ងល់ រួចចុះក្បាលខ្ញុំម៉េចក៏រុកអីច្រើនម្ល៉េះ ក៏លូកដៃស្ទាប។ ស្ទាបទៅ ចាប់មក អត់ដឹងថាដង្កូវទៀត ព្រោះយប់ ខ្ញុំច្របាច់ទន់ៗ វែងៗបានខ្ញុំថា អូ!នេះពិតជាដង្កូវហើយ។ ខ្ញុំក៏ប្រឹងដើរ ដឹងថា ខ្ញុំបើយប់នេះ មិនទៅដល់ផ្ទះទេ ប្រាកដជាខ្ញុំងាប់តាមផ្លូវហើយ"[2005]។ ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន បានផ្តល់សក្ខីកម្មថា "នៅរបួសទាល់សព្វថ្ងៃនេះនៅបីកន្លែង"[2006]។

953. ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន បានរងរបួស ខណៈដែលព្យាយាមរត់ចេញពីព្រៃស្លឹក។ គាត់បានផ្តល់សក្ខីកម្មថា "ខ្ញុំក៏នឹកឃើញថារត់ រត់បណ្តោយទៅ។ ដល់រត់បានឆ្ងាយ ខ្ញុំក៏ដួលប្រហែលជា ប្រហែលនឹងខ្ពង់១៥ម៉ែត្រហ្នឹងមើលទៅ មើលឃើញច្បាស់នៅជិត។ អីចឹងខ្ញុំក៏ងើប

[2002] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ១១ បន្ទាត់ ២៥។

[2003] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ១២ បន្ទាត់ ៤-៥។

[2004] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ១១ បន្ទាត់ ៧-១១។

[2005] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ១៣ បន្ទាត់ ៧-១០។

[2006] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ១៤ បន្ទាត់ ២៤-២៥។

ឡើងរត់ទៀត រត់ប្រហែលកបានប្រហែល៥ម៉ែត្រ ត្រូវដៃបណ្ដោយ។ ត្រូវដែរបួសដៃបាក់ឆ្អឹង ដកសរសៃមួយចំហៀងវាចងអីចេះទៅ វាបណ្ដោយដៃអីចេះ មកកូតសណ្ដកសរសៃបាក់ខ្ទេចឆ្អឹងសន្លាក់ហ្នឹង ដៃមួយចំហៀងខាងឆ្វេង”[2007]។

954. ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ុ សារឿន បានពិពណ៌នាការព្យាបាលរបស់គាត់ពីសំណាក់កម្លាំងភូមិភាគនិរតីថា “គឺដែលគេចងខ្ញុំយកចាប់បានចងយកទៅបាញ់ចោលនោះ ដែលធ្វើឲ្យខ្ញុំត្រូវរបួសពិការភាព បាក់ដៃរហូត និងវាយដំនឹងស្វាយកាំភ្លើង គឺត្រាំត្រាខ្លួនដែលមកដល់សព្វថ្ងៃនេះ ដែលខ្ញុំដើរព្យាបាលតាមពេទ្យឯកជន តាមពេទ្យរដ្ឋ ហើយបាត់បង់កម្លាំងពលកម្ម ការរកទទួលទានមិនកើត។ តើឲ្យលោកប្រធានសួរទៅជនជនចោទ តើអ្នកណាទទួលខុសត្រូវទៅលើបញ្ហាដែលខ្ញុំមានជីវប្រវត្តិដូច្នេះ ហើយនឹងមានជំងឺ និងរបួសពិការដោយបាក់ឆ្អឹងដៃមួយចំហៀង និងដកសរសៃដាច់សរសៃដូចជាសរសៃសត្វធាតុអីចឹង គឺឲ្យអ្នកណាទទួលខុសត្រូវ? ខ្ញុំសូមឲ្យលោកប្រធានសំណូមពរទៅសួរជនជាប់ចោទឲ្យគាត់ឆ្លើយ”[2008]។

955. ដើមបណ្ដឹងរដ្ឋប្បវេណី ឈុន សាម៉ន បានផ្ដល់សក្ខីកម្មថានៅពេលដែលគាត់ត្រូវបានដឹកជញ្ជូនជាមួយនឹងមនុស្ស៩នាក់ទៀតមកពីកងរបស់គាត់ “អ្នកដែលត្រូវរបួសគឺអ្នករត់ទៅជាមួយខ្ញុំទេ។ ដែលខ្ញុំនេះគឺគេវ៉ៃនឹងស្វាយកាំភ្លើង វាត្រូវពិការដៃស្ដាំនេះបាទ។ អ្នកដែលរបួសហ្នឹង អ្នករត់ជាមួយខ្ញុំទេ ដែលអ្នកត្រូវរបួសបាទ។ វាអីចេះទេបាទហ្នឹងហើយ។ អ្នកដែលរត់ជាមួយខ្ញុំបានត្រូវរបួស តែខ្ញុំគេវ៉ៃនឹងស្វាយកាំភ្លើងពេលខ្ញុំតវ៉ានោះ គេវ៉ៃនឹងស្វាយកាំភ្លើង ត្រូវខូចដៃស្ដាំយើង”[2009]។

### *ព្យសនកម្មលើរាងកាយ ដោយសារការប្រព្រឹត្តិដោយសាហាវឃោរឃៅ និងអមនុស្សធម៌*

956. ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ុ សារឿន បានផ្ដល់សក្ខីកម្មថានៅពេលដែលគាត់ត្រូវបានឃុំខ្លួននៅ វត្តក្រាំងហង្ស “ក៏គេចងយើងនៅលើវិហារហ្នឹង។ ចាប់ហៅម្ដងពីរម្ដងបួនឡើងលើហ្នឹង។ ពេល

---

[2007] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ុ សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ២២-២៣ បន្ទាត់ ២៤-២។

[2008] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ុ សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ៧១-៧២ បន្ទាត់ ២០-១។

[2009] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក ថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/445.1** ទំព័រ ៦៧ បន្ទាត់ ៩-១៣។

ដែលបណ្ដើរទៅចងឃ្លុំមុខហើយ គេវើបណ្ដើរទៅអង្គុយនៅលើវិហារហ្នឹង មិនដឹងបែរមុខទៅណា គឺគេវើនឹងស្វាយកាំភ្លើង ចង់ឲ្យទៅត្បូង គឺគេវើជើងអីចឹងទៅ កាំភ្លើងអាកា។ ដល់គេចង់ទៅខាងជើង យើងដើរខុសមិនទាន់ដល់ផ្លូវហ្នឹង គឺគេវើពីត្បូងអីចឹងទៅ វើឲ្យទៅជើង គឺគេបញ្ឆោនឹងស្វាយកាំភ្លើងហ្នឹងតែម្ដង វើមកលើរូបខ្ញុំ។ រូបខ្ញុំផ្ទាល់ គ្រាន់តែទម្រាំនឹងដល់ផ្លូវហ្នឹង គឺខ្ញុំវាការចងចាំ វាចង់ភ្លេចដែរហើយដែលយូរ ចូលប្រហែល១០ស្វាយកាំភ្លើង បានដល់កន្លែងគេឲ្យអង្គុយៗហ្នឹង គឺខ្ញុំគ្រាំគ្រាមករហូតទល់សព្វថ្ងៃ"[2010]។

957. ដើមបណ្ដឹងរដ្ឋប្បវេណី បានផ្ដល់សក្ខីកម្មថា នៅវិហារ "ចងដៃទៅក្រោយហើយហ្នឹង ដោតខ្សែកណ្ដាល ចងកង់អូសរត់ចាប់តាំងពីម៉ោងបីថ្ងៃល្ងាច ប្រហែលទេ មិនបានជាពិតថាម៉ោងប៉ុន្មានទេកាលហ្នឹង វាគ្មានមូលដ្ឋានអីសម្រាប់សំអាងម៉ោងពេល គឺមើលទៅតាមថ្ងៃ។ ហើយក៏ឲ្យរត់ទៅតាមកង់គេហ្នឹង ដោតខ្សែកណ្ដាលនៅហ្នឹង។ រត់ទៅ ចេះតែរត់ទៅ រត់មិនទាន់កង់ ហើយក៏គេយកដំបងវើ។ ខ្ញុំគ្រាន់តែរត់តាមកង់មិនទាន់ហ្នឹង គេវើត្រូវបែកក្បាលហូរឈាមអត់ដឹង អត់ដឹងថាឈាម ពីព្រោះសុំទឹកគេផឹក ក៏មិនឲ្យផឹក សូមបាយហូបក៏មិនឲ្យហូប វាអស់កម្លាំងហេវ មិនមានបាយហូបផងមួយថ្ងៃ មួយថ្ងៃហ្នឹង"[2011]។

958. ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី សាវឿន បានផ្ដល់សក្ខីកម្មថាបន្ទាប់ពីបានរត់គេចខ្លួនពីក្រោលគោ "ពេលដែលសភាពការណ៍កើតឡើងតាមផ្លូវហ្នឹង គឺ១០យប់ ១០ថ្ងៃគត់ ដែលខ្ញុំចេញមកហ្នឹង គឺជាន់ខ្សែត្រៀមរបស់កងទ័ពខ្មែរក្រហម ឬក៏មេសហករណ៍ មេកងធំ មេឈ្លបរបស់វាហ្នឹង គឺចំនួនពីរខ្សែត្រៀមហ្នឹង បានដល់កន្លែងដែលគេចាប់ភ្ជង់ចង។ ចងខ្ញុំមួយសារទៀតយកបង្អត់អាហារ ដាក់ហាលថ្ងៃក្ដៅហ្នឹងនៅនឹងព្រៃស្លឹក ខាងកើតខេត្តពោធិ៍សាត់ហ្នឹង។ បានដល់ត្រង់នោះហើយ បានគេមិនឲ្យបាយមិនឲ្យហូបទឹកទេ គឺថាទៅបន្តិចគេបញ្ជូនទៅហើយ គឺគេនៅហូបបាយនៅកន្លែងគេហ្នឹងរួច បានមានកម្លាំងគេពីរនាក់។ ខ្ញុំហ្នឹងក៏ចង់ដាច់ខ្យល់ហើយ ហាលក្ដៅផង"[2012]។

---

[2010] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី សាវឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ១៦ បន្ទាត់ ១៦-២២។

[2011] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី សាវឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ១៧-១៨ បន្ទាត់ ២០-១។

[2012] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី សាវឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ២២ បន្ទាត់ ១០-១៥។

## ២. ព្យសនកម្មផ្លូវចិត្ត

### *ព្យសនកម្មផ្លូវចិត្តរយៈពេលវែង - ទុក្ខក្រៀមក្រំ បន្ទាប់ពីការបាត់បង់សមាជិកគ្រួសារ*

959. ដើមបណ្ដឹងរដ្ឋប្បវេណី យន់ ប៊ីន ក៏បានរម្លឹកអំពីអ្នកដែលត្រូវបានសម្លាប់ "ខ្ញុំមានម្ដាយចុង។ បាទ ប្អូនខ្ញុំគាត់ដែលគេយកទៅសម្លាប់ជាមួយខ្ញុំ បងគាត់ក៏គេយកទៅសម្លាប់។ ហើយខ្ញុំប្រាប់ថា ឱ្យគាត់ទៅប្រាប់ថា មិនបាច់ឱ្យទៅទេ ព្រោះគេយកទៅសម្លាប់ហើយ។ គាត់ទៅប្រាប់ ហើយ បងគាត់ៗក៏ថាបក្សយើងមិនដែលយកមនុស្សទៅសម្លាប់ចោលទេបាទ។ ក៏គាត់យកទៅ ឥឡូវបាត់ ទល់សព្វថ្ងៃ"[2013]។

960. ដើមបណ្ដឹងរដ្ឋប្បវេណី យន់ ប៊ីន បានផ្ដល់សក្ខីកម្មថា "ឪពុកខ្ញុំក៏ធ្លាក់ខ្លួនឈឺទៅ កន្លងទៅ ដល់ខ្ញុំ បើខ្ញុំទៅតាំងពីថ្ងៃទី-- វិលត្រឡប់ពីកន្លែងវៃចោល តាំងពីថ្ងៃ២៥ ខែ៥ ១៩៧៨ ជិតដល់១៩៧៩។ នៅចុងឆ្នាំ៧៨ ពួកគេក៏ជម្លៀសក្នុងភូមិខ្ញុំហ្នឹងទៅ-- ក្នុងភូមិខ្ញុំហ្នឹង ជម្លៀសទៅកំពង់ធំទាំងអស់។ ពួកខ្ញុំ ភូមិខ្ញុំ ភាគច្រើន គេរត់ចូលព្រៃរនាមទាំងអស់ នៅសល់ខ្លះដែលទៅកំពង់ធំ ហើយខ្ញុំក៏ទៅ នៅជាមួយគាត់នៅក្នុងព្រៃ។ ពេលនោះ គាត់ឈឺរផងអីផង គាត់ក៏ស្លាប់នៅក្នុងព្រៃ"[2014]។

961. ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី សារឿន បានផ្ដល់សក្ខីកម្មថា "ម្ដាយខ្ញុំ បងប្អូនខ្ញុំគឺបានស្លាប់អស់ហើយ ទាំងជីដូនមួយ ទាំងធំ មីងមាមិនក្រោមតិចពី៥០នាក់ទេ គឺអត់មានបានវិលត្រឡប់ទៅស្រុកវិញទេ គឺដោយរស់នៅនៅខេត្តពោធិ៍សាត់ហ្នឹងតែម្ដង បើទៅស្រុក គឺឃើញតែដី ឃើញតែផ្ទះហ្នឹង គឺអាណោចអាធមខ្លាំង នឹកឃើញអនុស្សាវរីយ៍ដែលនៅជួបជុំគ្នាទាំងអស់។ អីចឹងគឺមិនមាន អារម្មណ៍អីចង់ទៅស្រុក អត់ស្រុកកំណើតវិញទេ"[2015]។

962. ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី សារឿន បានផ្ដល់សក្ខីកម្មថា "ខ្ញុំសព្វថ្ងៃ គឺខ្ញុំមានអារម្មណ៍ក្ដុកក្ដួល ខ្លាំងណាស់ ដោយសារបាត់បង់សាច់ញាតិសន្ដានអស់ ហើយរស់នៅតែបងប្រុសមួយគត់ គឺបង

---

[2013] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី យន់ ប៊ីន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ១៣ បន្ទាត់ ១៦-១៩។

[2014] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី យន់ ប៊ីន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ១៤ បន្ទាត់ ១-៥។

[2015] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ២៣ បន្ទាត់ ២០-២៣។

ប្រុសដែលជាបងបង្អស់នៅខេត្តពោធិ៍សាត់ហ្នឹង គឺហើយម្ដាយឪពុករបស់គេគឺនៅរស់ តែម្ដាយរបស់គេគឺនៅរស់ តែម្ដាយឪពុកបងប្អូនរបស់ខ្ញុំគឺត្រូវបាត់បង់អស់ អត់មាននៅបានសេសសល់ជួបជុំសប្បាយនឹងគេ។ ពេលខ្លះខ្ញុំមានអារម្មណ៍ដេកមិនលក់ ដើរទៅអត់ដឹងថារូបកាយរបស់ខ្ញុំនៅគឺអត់ដឹង”[2016]។

963. ដើមបណ្ដឹងរដ្ឋប្បវេណី ឈុន សាម៉ន បានរៀបរាប់ថា “ចំពោះទុក្ខសោកធ្ងន់ធ្ងរមួយទៀត គឺការបាត់បង់សាច់ញាតិ មួយបងប្រុសត្រូវជាបងថ្លៃគាត់ជាប្រជាជនថ្មី ត្រូវអង្គការហៅឲ្យទៅដឹកទឹកត្រីមកឲ្យសហករណ៍ក្នុងឆ្នាំ ១៩៧៦ ត្រូវគេចាប់ខ្លួនបាត់រហូតទល់សព្វថ្ងៃ”[2017]។

964. ដើមបណ្ដឹងរដ្ឋប្បវេណី បានបន្តថា “គឺបងប្រុសរបស់ខ្ញុំបង្កើត ដែលមានការស្មោះស្ម័គ្រចំពោះអង្គការបដិវត្តន៍ដែលបានដឹកនាំគាត់ចូលធ្វើបម្រើកងទ័ពពីឆ្នាំ៧០ គឺឈ្មោះ ឈុន ដារី ហៅ សុខចន្ថា ភេទប្រុស ចូលបម្រើកងទ័ពកម្ពុជាប្រជាធិបតេយ្យក្នុងឆ្នាំ៧០ និងជាតួនាទីជាសេនាធិការភូមិភាគ ត្រូវអង្គការហៅរៀនសូត្រនៅឆ្នាំ ១៩៧៧ បាត់ខ្លួនរហូតទល់សព្វថ្ងៃ”[2018]។

### *ព្យសនកម្មផ្លូវចិត្តរយៈពេលវែង- អារម្មណ៍នៃការទទួលរងនូវការក្បត់*

965. ដើមបណ្ដឹងរដ្ឋប្បវេណី ឈុន សាម៉ន បានបញ្ជាក់ថា “ខ្ញុំបានចូលបម្រើកងទ័ពបដិវត្តន៍កម្ពុជាប្រជាធិបតេយ្យ នៅខែ៥ ឆ្នាំ ១៩៧៥ ពេលនោះ រូបខ្ញុំបាទមានការជឿជាក់នឹងអង្គការថ្នាក់លើដឹកនាំពិតប្រាកដ ហ៊ានលះបង់អាយុជីវិតដើម្បីប្រទេសជាតិ និងមាតុភូមិ និងប្រជាជនពិតៗ ដោយអស់ពីកម្លាំងកាយចិត្តមិនខ្លាចពលីជីវិតឡើយ។ ខ្ញុំបាទគោរពតាមផែនការរបស់បក្ស អនុវត្តវិន័យបានត្រឹមត្រូវ និងចុះប្រឡូកជាមួយគ្រាប់រំសេវ ប្រយុទ្ធជាមួយខ្មាំងទាំងយប់ទាំងថ្ងៃ គ្មាន ថ្ងៃខ្លះដាច់ស្បៀងអាហារ២ថ្ងៃទៅ៣ថ្ងៃ ជួនអត់ទឹកផឹកក៏មានដែរ គឺមានការលំបាកណាស់ លោកប្រធាន។ ប៉ុន្តែជាលទ្ធផលរូបខ្ញុំបាទ និងក្រុមទាហានបូព៌ាជាច្រើននាក់ទៀត ត្រូវបានអង្គការចោទប្រកាន់ថា

---

[2016] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ២៤ បន្ទាត់ ៣-៧។

[2017] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/446.1** ទំព័រ ១០ បន្ទាត់ ២៣-២៥។

[2018] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/446.1** ទំព័រ ១១ បន្ទាត់ ២-៥។

ក្បត់បក្ស និងចាប់យកទៅសម្លាប់ចោលទៅវិញ ធ្វើឱ្យខ្ញុំមានការតក់ស្លុតជាខ្លាំង។ ខ្ញុំពិតជាហួស នឹងរបបនុងនៅណាស់”[2019]។

966. ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន បានផ្តល់សក្ខីកម្មថា នៅពេលដែលគាត់បានរស់រានមានជីវិតពីការវាយនឹងពូថៅ ហើយបានព្យាយាមតោងឡើងចេញពីរណ្តៅ “ហើយក៏ខ្ញុំសូមស្បថ និងឱ្យពួកមិត្តៗដែលស្លាប់ទៅ ជួយធ្វើម៉េចឱ្យខ្ញុំ ឱ្យតែបានខ្ញុំរស់ ធ្វើម៉េចជួយខ្ញុំឡើងរួច ខ្ញុំនឹងធ្វើបុណ្យ ហើយនឹងរកយុត្តិធម៌ឱ្យពួកវាប្រាប់យកមករៀនសូត្រ។ តើខ្ញុំមានទោសអី បានជាវាប្រាប់ថាយកមករៀនសូត្រ បែរជាយកទៅសម្លាប់។ ខ្ញុំប្រាប់ពួកមិត្តដែលស្លាប់ទាំងអស់នៅក្នុងរណ្តៅនោះ ឱ្យតែខ្ញុំឡើងរួច ខ្ញុំនឹងរកយុត្តិធម៌ និងប្តឹងរកយុត្តិធម៌”[2020]។

967. ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន បានពិពណ៌នាថា “ដើរទៅអត់ដឹងថារូបកាយរបស់ខ្ញុំនៅគឺអត់ដឹង ដោយសារសុខភាពគ្រាំគ្រា ទុរន់ទុរាដែលគេធ្វើបាប បាញ់ វ៉ៃដំច្រំធាក់ ប្រើដូចសត្វធាតុ។ ហេតុអ្វីក៏ខំតស៊ូធ្វើកងទ័ពរំដោះជាតិកន្លងមក ដល់ចុងក្រោយទៅជាបានទទួលរងគេធ្វើទារុណកម្មដល់ថ្នាក់នេះ”[2021]។

***អារម្មណ៍ភ័យខ្លាចរយៈពេលវែង***

968. ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន បានផ្តល់សក្ខីកម្មថា “បាទ ពេលដែលខ្ញុំរួច នៅក្នុងភូមិហើយពេលនោះ ដល់គេស្រុក ១៩៧៩ រួចហើយ គេក៏ឱ្យខ្ញុំថាទៅមើលរណ្តៅកន្លែងសម្លាប់ ខ្ញុំពុំហ៊ានដើរទៅមើលទេ។ ក៏ខ្ញុំចង់ដួលសន្លប់នៅលើនោះដែរ ព្រោះជាហេតុការណ៍របស់ខ្ញុំ។ ឃើញថា ខ្ញុំទៅមើលមិនអាច ព្រោះអារម្មណ៍ខ្ញុំទប់មិនបាន ព្រោះខ្ញុំគេសម្លាប់ទាំងអស់ នៅរស់តែខ្ញុំម្នាក់។ ដោយអារម្មណ៍ក្តុកក្តួល ហើយវារន្ធត់យ៉ាងខ្លាំង ពេលដែលខ្ញុំត្រូវការភ័យ។ ដល់កន្លែងហ្នឹង ខ្ញុំនឹកថា

2019 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/446.1** ទំព័រ ១០ បន្ទាត់ ១-៨។

2020 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ១១ បន្ទាត់ ៣-៦។

2021 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ២៤ បន្ទាត់ ៧-៩។

ខ្ញុំបានរស់រានមានជីវិតមកវិញនេះ ដោយឆ្លងកាត់កន្លែងសម្លាប់ កន្លែងជ្រក ព្រោះខ្ញុំមិនអាចទៅមើលបានទេ ព្រោះខ្ញុំនៅភ័យនៅខ្លាចរហូត”[2022]។

### *ការបាត់បង់ទ្រព្យសម្បត្តិ*

969. ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន បានផ្តល់សក្ខីកម្មថា “ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទ្រព្យសម្បត្តិដែលមានទាំងប៉ុន្មាន ត្រូវអូសរឹបចូលក្នុងកងសហករណ៍បណ្តាលឲ្យខូចបាត់បង់អន្តរាយរហូតដល់ទល់បច្ចុប្បន្ននេះ”[2023]។ លើសពីនេះ គាត់បានពិពណ៌នាអំពីការស្លាប់របស់បងថ្លៃប្រុសគាត់ថា “ធ្វើឲ្យប្រពន្ធព្រាត់ប្តី កូនកាត់បីនាក់ត្រូវកំព្រាឪពុក ដែលបន្ទុកក្នុងគ្រួសារនេះធ្លាក់មកលើរូបខ្ញុំបាទ”[2024]។

970. ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន បានផ្តល់សក្ខីកម្មថាក្នុងឆ្នាំ ១៩៧៨ “ពេលដែលខ្ញុំរៀបការហើយទៅដល់ គេបញ្ជូនទៅដល់កន្លែងផែអ្នកលឿងហ្វឹង គឺគេដកសម្ភារៈទាំងអស់ គោ ក្របី រទេះអី ឆ្កែ មាន់ ទាអីហ្វឹងគឺដាក់នៅកន្លែងហ្នឹង គឺឲ្យឡើងតែខ្លួន និងខោអាវឡើងកប៉ាល់ទៅ[2025]”។

## ជំពូក ៩÷ មន្ទីរសន្តិសុខភ្នំក្រោល[2026]

[2022] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យន់ ប៊ីន ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ១៤ បន្ទាត់ ១៤-២០។

[2023] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/446.1** ទំព័រ ១១ បន្ទាត់ ៥-៧។

[2024] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឈុន សាម៉ន ប្រតិចារឹក ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/446.1** ទំព័រ ១០-១១ បន្ទាត់ ២៥-១។

[2025] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ២០ បន្ទាត់ ១៩-២១។

[2026] អង្គជំនុំជម្រះសាលាដំបូងបានទទួលអង្គហេតុពាក់ព័ន្ធនឹងការបង្កើត និងការបំពេញមុខងាររបស់មន្ទីរសន្តិសុខភ្នំក្រោលក្នុងស្រុកកោះញែក និងការចាប់ខ្លួន ឃុំឃាំង សួរចម្លើយ និងសម្លាប់អ្នកទោសនៅទីនោះ។ ដីកាដំណោះស្រាយ ឯកសារ **D427** (កែតម្រូវ ៣) កថាខណ្ឌ ៦៣៤-៦៤២។ មន្ទីរសន្តិសុខភ្នំក្រោលគឺជាមន្ទីរសន្តិសុខនៃតំបន់ ១០៥ ដែលរួមមានគុកភ្នំក្រោល និងមានទំនាក់ទំនងជាមួយនឹងមន្ទីរ ក-១១ នៃតំបន់ ១០៥ ដែលនៅជិតនោះ និងលេខាតំបន់ ១០៥ ដែលមានមន្ទីរ ក-១៧។ ត្រពាំងព្រីងគឺជាកន្លែងសម្លាប់មនុស្សរបស់មន្ទីរសន្តិសុខភ្នំក្រោល។ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែងរបស់ ក.ស.ច.ស ពាក់ព័ន្ធនឹងមន្ទីរ ក-១១ ក-១៧ ភ្នំក្រោល និងត្រពាំងព្រីង រៀបរាប់ពីទីតាំងរបស់ទីកន្លែងនីមួយៗ។ ដូចដែលផែនទីទាំង ២ នេះ

## ក. និជ្ជភាពទូទៅនៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី

971. ដើមបណ្តឹងរដ្ឋប្បវេណីពីររូបគឺ សុន វុត និង កុល ណែម បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង អំពីបទពិសោធន៍របស់ពួកគាត់ នៅក្នុងស្រុកកោះញែក ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ[2027]។ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូម ម៉ុល បានផ្តល់សក្ខីកម្មនៅចំពោះមុខ ការិយាល័យសហចៅក្រមស៊ើបអង្កេត។ គាត់ត្រូវបានសហព្រះរាជអាជ្ញាស្នើសុំជាដំបូង ឱ្យមកផ្តល់

---

ពន្យល់ប្រាប់ "ទីកន្លែងទាំងបីនេះស្ថិតនៅចម្ងាយប្រមាណ ១ គីឡូម៉ែត្រពីគ្នា ចំណែកឯត្រពាំងព្រីង ឬរណ្តៅសាកសពរួមទួលខ្មោច មានចម្ងាយ ៤ គីឡូម៉ែត្រទៅទិសខាងលិច"។ ដីកាដំណោះស្រាយ ឯកសារ **D427** (កែតម្រូវ ៣) កថាខណ្ឌ ៦២៥ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៦២៧ កថាខណ្ឌ ៦៤២ របាយការណ៍ស្តីពីការកំណត់អត្តសញ្ញាណទីកន្លែង ឯកសារ **E3/8057** (កែតម្រូវ ១) ចុះថ្ងៃទី ២១ ខែ កក្កដា ឆ្នាំ ២០០៩ ERN (KH) 00371406។ មានការលើកឡើងថា "គុកភ្នំក្រោលធ្វើពីឈើ ក្រាលរនាបឬស្សី មានដំបូលប្រក់ស្បូវ។ មន្ទីរ ក-១៧ ជាអគារមានកម្ពស់ពីរជាន់ជញ្ជាំងក្តារ ប្រក់ស័ង្កសី។ មន្ទីរនេះដំណើរការជាកន្លែងធ្វើការរបស់លេខាតំបន់ ១០៥ និងធ្លាប់ជាកន្លែងឃុំខ្លួនបណ្តោះអាសន្នមួយរយៈពេលផងដែរ។ មន្ទីរ ក-១១ ស្ថិតនៅចម្ងាយប្រហែល ១ គីឡូម៉ែត្រភាគឦសានពីគុកភ្នំក្រោល ដែលដំណើរការជាមន្ទីរឃុំឃាំង និងជាកន្លែងធ្វើការរបស់កងទ័ព។ មន្ទីរនេះធ្វើអំពីឈើ មានដំបូលប្រក់ស្បូវ ជញ្ជាំងឬស្សី និងក្រាលរនាបក្តារ"។ ដីកាដំណោះស្រាយ ឯកសារ **D427** (កែតម្រូវ ៣) កថាខណ្ឌ ៦២៦។ បទឧក្រិដ្ឋដែលរងការចោទប្រកាន់ បានកើតឡើងក្នុងបរិបទនៃគោលនយោបាយនេះ "ដើម្បីសម្រេចបាន និងការពារបដិវត្តន៍សង្គមនិយម គឺការលត់ដំនូវ "សមាសភាពមិនល្អ" និងការសម្លាប់ "ខ្មាំង" ទាំងនៅក្នុងជួរបក្ស និងក្រៅជួរបក្ស។" ដីកាដំណោះស្រាយ ឯកសារ **D427** (កែតម្រូវ ៣) កថាខណ្ឌ ១៧៨។ ផ្អែកតាមការចោទប្រកាន់លើអង្គហេតុទាំងនេះ ដីកាដំណោះស្រាយ ចោទប្រកាន់ជនជាប់ចោទនូវឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែលរងការចោទប្រកាន់ថាបានកើតឡើងនៅមន្ទីរសន្តិសុខភ្នំក្រោល ដូចជា ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើឱ្យទៅជាទាសករ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ អំពើអមនុស្សធម៌ផ្សេងទៀតតាមរយៈការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស អំពើអមនុស្សធម៌ផ្សេងទៀតនៃការបាត់ខ្លួនដោយបង្ខំ និងអំពើអមនុស្សធម៌ផ្សេងទៀតនៃអាពាហ៍ពិពាហ៍ដោយបង្ខំ ដីកាដំណោះស្រាយ ឯកសារ **D427** (កែតម្រូវ ៣) កថាខណ្ឌ ១៣៧៣ កថាខណ្ឌ ១៣៨១ កថាខណ្ឌ ១៣៩១ កថាខណ្ឌ ១៤០៨ កថាខណ្ឌ ១៤១៦ កថាខណ្ឌ ១៤៣៤ កថាខណ្ឌ ១៤៤២។ ឧបសម្ព័ន្ធ ៖ បញ្ជីកកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០២ ឯកសារ **E301/9/1**។

[2027] ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ០៨ នាក់ (ប្រាំបីនាក់) ត្រូវបានប្រកាសទទួលស្គាល់ពាក់ព័ន្ធនឹងមន្ទីរសន្តិសុខភ្នំក្រោល (ដីកាដំណោះស្រាយ ឯកសារ **D427** (កែតម្រូវ ៣) កថាខណ្ឌ ៦៤៣)។

សក្ខីកម្មអំពីហេតុការណ៍នៅភ្នំក្រោល ប៉ុន្តែសហព្រះរាជអាជ្ញាបានដឹងនៅពេលក្រោយមកថា ដើមបណ្តឹងរដ្ឋប្បវេណី អ្នូម ម៉ុល បានស្លាប់ទៅហើយ[2028]។

972. ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត បានផ្តល់សក្ខីកម្មថា គាត់ត្រូវបានអង្គការតម្រូវ ឱ្យចូលកងទ័ពនៅក្នុងឆ្នាំ១៩៧៤[2029]។ ក្រោយពេលរំដោះទីក្រុងភ្នំពេញក្នុងឆ្នាំ ១៩៧៥ ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត បានពន្យល់ថា អង្គការបានបញ្ជូនកងពលធំ៩២០ ឱ្យទៅការពារព្រំដែនជាប់វៀតណាម[2030] នៅស្រុកកោះញែក មណ្ឌលគិរី[2031]។ បន្ទាប់មកដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានចាត់តាំងជាប្រធានកងអនុសេនាធំ[2032]។

973. នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណី ឈរជើងនៅមណ្ឌលគិរី មេដឹកនាំរបស់គាត់ត្រូវបានគេកោះហៅ ឱ្យចូលរួមវគ្គរៀនសូត្រហើយឮថា ពួកគាត់ទាំងនោះត្រូវបានសម្លាប់ ដោយសារការចោទប្រកាន់ថាក្បត់អង្គការ[2033]។ សម្រាប់កងពលធំ៩២០ តាឈិន តាសយ សមមិត្តកុល សមមិត្តណុន

[2028] ឧបសម្ព័ន្ធ I ៖ បញ្ជីឈ្មោះកែសម្រួលរួមរបស់សហព្រះរាជអាជ្ញាពាក់ព័ន្ធនឹងសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញសម្រាប់សំណុំរឿង ០០២/០២ ក្នុងលំដាប់ស្នើសុំសម្រាប់វគ្គជំនុំជម្រះទោស និងការបង្ហាញខ្លួន (ខែ កក្កដា ឆ្នាំ ២០១៤) ឯកសារ **E307/3/2.2** ERN (EN) 01003004។ សំណើរបស់សហព្រះរាជអាជ្ញាសុំឱ្យកោះហៅសាក្សីបន្ថែមនៅក្នុងវគ្គនៃអំឡុងសវនាការស្តីពីមន្ទីរសន្តិសុខភ្នំក្រោល ឯកសារ **E390** កថាខណ្ឌ ២។ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៨៧ (៤) នៃវិធានផ្ទៃក្នុង សុំឱ្យកោះហៅសាក្សីបន្ថែមម្នាក់ និងដើមបណ្តឹងរដ្ឋប្បវេណីបន្ថែមម្នាក់ នៅក្នុងវគ្គអំឡុងវគ្គសវនាការមន្ទីរសន្តិសុខភ្នំក្រោល ឯកសារ **E390/3** ចុះថ្ងៃទី ១១ ខែ កក្កដា ឆ្នាំ ២០១៦ កថាខណ្ឌ ២។

[2029] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៤៤ បន្ទាត់ ១២។

[2030] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៤៥ បន្ទាត់ ៦-៧។

[2031] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៤៥ បន្ទាត់ ១២-១៧។

[2032] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៤៧-៤៦ បន្ទាត់ ២៤-១។

[2033] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៤៦ បន្ទាត់ ២១-២២។

និងសមមិត្តយ៉េង ត្រូវបានចាប់ខ្លួននិងបាត់ខ្លួន[2034]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានឮថា ពួកគាត់ត្រូវបានគេបញ្ជូនទៅគុកទួលស្លែង[2035]។ អ្នកមកចាប់ខ្លួនពួកគាត់ គឺមកពីកងពលធំ៨០១ ដែលដឹកនាំដោយតាសារឿន[2036]។ នៅក្នុងខែវិច្ឆិកា ឬធ្នូ ឆ្នាំ១៩៧៧ ក្នុងរដូវកាលច្រូតកាត់[2037] ដើមបណ្ដឹងរដ្ឋប្បវេណីក៏ត្រូវបានគេចាប់ឃុំខ្លួន ដោយចោទប្រកាន់ថាក្បត់អង្គការដែរ។ គាត់ត្រូវបានគេចងមុខដោយក្រមា ហើយបណ្ដើរយកទៅ[2038]។ ដោយសារតែគេចងមុខគាត់ ទើបដើមបណ្ដឹងរដ្ឋប្បវេណីមិនអាចមើលឃើញថាគេយកគាត់ទៅទីណាទេ។ ប៉ុន្តែនៅពេលគេស្រាយមុខគាត់វិញ គាត់អាច "បានដឹងខ្លះ"[2039]។ គាត់បានផ្ដល់សក្ខីកម្មថា ត្រូវបានគេយកទៅដាក់គុកមួយ នៅក្បែរផ្លូវទៅក្រចេះ ប្រហែលកន្លះគីឡូម៉ែត្រពីមន្ទីរកងពលធំ និងនៅភាគខាងត្បូងកោះញែក ក្បែរកូនភ្នំ និងអូរមួយឈ្មោះអូរច្បារ[2040]។

---

[2034] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៤៧ បន្ទាត់ ១៦-១៨។

[2035] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៤៧ បន្ទាត់ ១៨។

[2036] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៤៨ បន្ទាត់ ១-៣។

[2037] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៦៧-៦៨ បន្ទាត់ ១៧-១។

[2038] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៤៨ បន្ទាត់ ៥-៩។

[2039] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៤៨ បន្ទាត់ ១៥-១៦។

[2040] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៤៨-៤៩ បន្ទាត់ ១៥-២។ *សូមមើលផងដែរ* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៥៩ បន្ទាត់ ៤-១២ (ដើមបណ្ដឹងរដ្ឋប្បវេណីបានពន្យល់ថា អូរនោះគឺអូរច្បារ និងមានការភាន់ច្រលំក្នុងទម្រង់ព័ត៌មានជនរងគ្រោះរបស់គាត់ (**E3/6760**) ដែលគាត់បានកំណត់ឈ្មោះអូរនេះខុសថាជាអូរល្ពៅ)។ *សូមមើលផងដែរ* (សាក្សីម្នាក់បានរៀបរាប់ពី មន្ទីរ ក-១៦ និងមន្ទីរ ក-១៧ ថា "តាំងពីចាប់ផ្ដើមធ្វើកសាងនៅកោះញែក ឆ្នាំ ៧៥ ហ្នឹង គេបានលើកមន្ទីរ ក-១៧ ទៅដាក់លើភ្នំក្រោលដែលបច្ចុប្បន្ននេះបាទ ហើយ ក-១៦ គេដាក់កន្លែងចាស់ដែលនៅជាប់អូរច្បារនេះបាទ។ ហើយត្រូវឆ្លងទឹកអូរច្បារនៅខែភ្លៀង អត់មាននេះទេ អត់មានផ្លូវឡានឆ្លងបានទេបាទ"។ សក្ខីកម្មផ្ទាល់មាត់របស់សាក្សី ចាន់ ប៊ុនលីត ប្រតិចារឹក ថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/409.1** ទំព័រ ១១ បន្ទាត់ ១៨-២១) ("មន្ទីរសន្តិសុខ

974. ដើមបណ្ដឹងរដ្ឋប្បវេណី សុន វុត បានផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះថា អគារនោះមានបណ្តោយប្រវែង១០ម៉ែត្រ និងទទឹងប្រហែល៥ទៅ៦ម៉ែត្រ ហើយមានបីបន្ទប់ ដែលបន្ទប់នីមួយៗមិនធំទេ គឺអាចដាក់អ្នកទោសបានប្រហែលប្រាំនាក់[2041]។ អគារនោះសង់ដោយប្រើសសរឈើធំៗ ហើយមានដំបូលមួយកំណាត់ធ្វើពីស្បូវ និងមួយកំណាត់ទៀតធ្វើពីស្លឹកប្រចេង[2042]។ ជញ្ជាំងធ្វើពីក្តារដែលមិនបានវាយជាប់ស្រួលទេ ដែលអ្នកទោសអាចមើលឃើញតាមប្រឡោះក្តារនោះ[2043]។ បន្ទប់ឃុំខ្លួនដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ត្រូវបានចាក់សោរ[2044]។

---

ហ្នឹង ជិតបំផុតហ្នឹងគឺ ក-១១ ហ្នឹងហើយ។ ហើយ ក-១៧ ហ្នឹងទៅមុខបន្តិចទៀត ប្រហែលជា ៥០០ ម៉ែត្រទៀត។ ហើយនៅជុំហ្នឹង ខាងជើង ខាងត្បូងឆៀងត្បូងហ្នឹង ខាងលិចឆៀងត្បូងហ្នឹងគឺកម្មករ កន្លែងគេផលិតគ្រឿងចក្រអីហ្នឹង គេមានម៉ាស៊ីនក្រឡឹង គេមានស្មិតគេទៅ គេអារឈើអីនៅហ្នឹង។ អ៊ីចឹងទេ ជុំវិញភ្នំក្រោលហ្នឹងគឺសុទ្ធតែទីតាំងរបស់គេ។ អ៊ីចឹងគុកហ្នឹងគេដាក់ចំកណ្តាលតែម្តង។ ហើយជាប់អែបនឹងទំនប់ហ្នឹងតែម្តង ក្បែរទឹកទំនប់។ ឯចំណែក ក-១១ នេះ គាត់នៅត្រើយម្ខាង អូរច្បារខាងណោះប្រហែលជា ២ គីឡូម៉ែត្រទៅទៀត ទៅ ២ គីឡូកន្លះជាង។ អ៊ីចឹងត្រូវឆ្លងទឹកទៀត មិនមែនជិតទេ"។ សក្ខីកម្មផ្ទាល់មាត់របស់សាក្សី ចាន់ ប៊ុនលឺត ប្រតិចារឹក ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/410.1** ទំព័រ ២៨ បន្ទាត់ ៧-១៣) (ក.ស.ព បានដាក់បញ្ចូលអត្ថបទដកស្រង់ទៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីដើមបណ្តឹងរដ្ឋប្បវេណី នូ សួយ ឯកសារ **E3/7705** ERN (KH) 00236724 ដែលរៀបរាប់ថា "គុកនៅភ្នំក្រោល គេធ្វើពីឈើមូល ដូចទ្រុងជ្រូក ដំបូលប្រក់ស្បូវ ហើយអ្នកទោសទាំងអស់គេដាក់ខ្នោះជើងធ្វើពីឈើ ពេលថ្ងៃគេលែងអ្នកទោសស្រាលៗឲ្យធ្វើការនៅក្នុង និងនៅក្រៅបរិវេណគុក ដូចជា អារឈើ ធ្វើតុ ធ្វើទូ ធ្វើគ្រែ ដោយមានអ្នកយាម។ គេមិនឲ្យអ្នកទោសទាំងនោះដើរឆ្ងាយពីរង្វង់ដែលគេកំណត់នោះទេ។ ចំពោះអ្នកទោសដែលគេចាត់ទុកថាជាអ្នកទោសធ្ងន់ គេមិនលែងទេ។

[2041] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៤៩ បន្ទាត់ ១-៥។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/412.1** ទំព័រ ៤២ បន្ទាត់ ១៥-១៦។

[2042] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៤៩ បន្ទាត់ ១៥-២២។

[2043] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៤៩ បន្ទាត់ ២២-២៤។

[2044] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/412.1** ទំព័រ ៣៨ បន្ទាត់ ១៦-១៧។

975. ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត បានពន្យល់ថា មិនមានផ្ទះនៅក្បែរគុកនោះ ឡើយ ប៉ុន្តែមានរោងសម្រាប់អ្នកយាម និងមានរោងតូចមួយនៅខាងត្បូងគុក ជាកន្លែងសួរចម្លើយ[2045]។ ដើមបណ្តឹងរដ្ឋប្បវេណីក៏បានបញ្ជាក់ផងដែរថា គាត់អាចស្តាប់ឮសម្លេងអ្នកជាប់ឃុំជាស្ត្រី ប៉ុន្តែគាត់មិនអាចស្មានដឹងថា មានអ្នកទោសនារីប៉ុន្មាននាក់ឡើយ[2046]។

976. ក្នុងពេលជាប់ឃុំ ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត បានផ្តល់សក្ខីកម្មថា ដៃជើងរបស់គាត់ត្រូវជាប់ខ្នោះឃ្នាង[2047] ហើយគាត់ត្រូវជាប់ឃុំនៅក្នុងបន្ទប់ជាប់សោរមួយ ជាមួយអ្នកជាប់ឃុំពីរនាក់ផ្សេងទៀត ដែលចូលមកពីរថ្ងៃក្រោយគាត់[2048]។ ដើមបណ្តឹងរដ្ឋប្បវេណីបានគេចខ្លួនរួច ហើយរត់ចូលព្រៃរហូតដល់ឆ្នាំ១៩៨៦[2049]។

977. ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម បានចូលរួមជាមួយខ្មែរក្រហម ដោយធ្វើជាកងទ័ព នៅមុនពេលភ្នំពេញដួលរលំ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[2050]។ ដើមបណ្តឹងរដ្ឋប្បវេណីបានទៅមណ្ឌលគីរីមួយរយៈខ្លី នៅក្នុងឆ្នាំ១៩៧៥ ហើយបានត្រឡប់មកភ្នំពេញវិញ មុនពេលត្រូវបានបញ្ជូនទៅក្រចេះ[2051]។ ជាចុងក្រោយគាត់ត្រូវបានបញ្ជូនទៅកងពលតូចរបស់ ឈិន សយ នៃកងពល

[2045] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៥០ បន្ទាត់ ៣-៤។

[2046] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៥០ បន្ទាត់ ៥-៦។

[2047] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/412.1** ទំព័រ ៥២ បន្ទាត់ ៥-៦។

[2048] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៤៩ បន្ទាត់ ៣-៤។

[2049] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៥៣ បន្ទាត់ ១។

[2050] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៧៥-៧៦ បន្ទាត់ ២៤-១។

[2051] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៦៨ បន្ទាត់ ១៦-១៨។

ទីពីរ[2052]។ ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា ឈិន សយ ដែលជាមេបញ្ជាការត្រូវបានចាប់ខ្លួន ហើយបន្ទាប់ពីនោះមក ដើមបណ្តឹងរដ្ឋប្បវេណីបានទៅតំបន់ ជាមួយលោក សភា[2053]។ ការនេះ បណ្តាលឲ្យដើមបណ្តឹងរដ្ឋប្បវេណី ត្រូវនៅជាមួយអ្នកទទួលខុសត្រូវ លើយោធាខេត្តនៅក-១១[2054]។ ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម បានផ្តល់សក្ខីកម្មថា គាត់នៅទីនោះមួយរយៈខ្លី[2055]។ គាត់បានប្រាប់អំពីការរៀបអាពាហ៍ពិពាហ៍របស់គាត់ នៅក-១១ ដែលគាត់ត្រូវបានគេបញ្ជូនទៅ ជាការដាក់ទណ្ឌកម្ម ក្រោយពេលមេបញ្ជាការកងពលរបស់គាត់ ត្រូវបានគេចាប់ខ្លួន[2056]។ នៅ ក-១១ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានចាត់តាំង ឲ្យធ្វើស្រែនិងចូលរួមក្នុងការសាងសង់[2057]។ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា ភ្នំក្រោលស្ថិតក្រោមការគ្រប់គ្រងរបស់ឡេង ហើយនៅមិនឆ្ងាយប៉ុន្មានពីក-១១ឡើយ[2058]។ គាត់មិនដឹងថានរណាខ្លះ ដែលត្រូវបានឃុំខ្លួននៅទីនោះឡើយ ដោយអ្នកខ្លះមកពីកងពល ហើយអ្នកខ្លះជាប្រជាជនស៊ីវិល ឯគាត់មិនមានសិទ្ធិអំណាចចូលទីនោះឡើយ[2059]។ ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម បានឃើញមនុស្សមួយចំនួន

[2052] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៦៨ បន្ទាត់ ១៨-១៩។

[2053] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៦៨ បន្ទាត់ ១៩-២០។

[2054] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៦៨ បន្ទាត់ ២១-២២។

[2055] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៦៨ បន្ទាត់ ២២។

[2056] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៧៣ បន្ទាត់ ៨-១៦។

[2057] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៧៣ បន្ទាត់ ៨-១០។

[2058] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៧៩ បន្ទាត់ ៥-៧។

[2059] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៧៩ បន្ទាត់ ៧-៩។

ដែលគាត់ធ្លាប់ធ្វើការជាមួយ នៅទីបញ្ជាការកងពលធំ ប៉ុន្តែគាត់មិនបានសួរនាំពួកគេ មិនបានមើលមុខ ឬរាប់ចំនួនថាមានប៉ុន្មាននាក់នៅទីនោះឡើយ[2060]។

978. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូម ម៉ុល បានផ្តល់សក្ខីកម្មនៅចំពោះមុខ ការិយាល័យសហចៅក្រមស៊ើបអង្កេត ហើយបានផ្តល់នូវសក្ខីកម្មជាលាយលក្ខណ៍អក្សរដោយបានស្បថ កាលពីថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០០៨។ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូម ម៉ុល បានផ្តល់សក្ខីកម្មថា នៅក្នុងឆ្នាំ ១៩៧៥ គាត់គឺជាយុទ្ធជនខ្មែរក្រហម ដែលពីដំបូងគាត់ស្ថិតក្នុងកងពល ដែលស្ថិតក្រោមបញ្ជាការរបស់តា ហ៊ារ និងតា ណាត ហើយនៅក្នុងកងពលដែលដឹកនាំដោយតា ឈិន និងតា សយ នៅមណ្ឌលគីរី ហើយបន្ទាប់មកផ្លាស់មកមន្ទីរក-១១ នៅកោះញែក[2061]។ គាត់បានផ្តល់សក្ខីកម្មអំពីការចាប់ខ្លួន និងការឃុំខ្លួនគាត់ នៅមន្ទីរក-១១ ព្រមទាំងព្យសនកម្មដែលគាត់បានទទួលរង ដោយសារបានឃើញនូវហេតុការណ៍គួរឱ្យរន្ធត់នានា[2062]។

## ខ. ភស្តុតាងផ្អែកលើឧក្រិដ្ឋកម្ម ដែលដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ នៅក្នុងពេលសវនាការ

### ១. ការដាក់ក្នុងមន្ទីរឃុំឃាំង

979. ភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានលើកឡើងនៅក្នុងសវនាការ បានបង្ហាញថាអ្នកទោសនៅភ្នំក្រោល ត្រូវបានគេដកហូតតាមអំពើចិត្ត នូវសេរីភាពរបស់ពួកគេ ដោយមិនមានដំណើរការផ្លូវច្បាប់សមស្របឡើយ។

***ការដកហូតតាមអំពើចិត្តនូវសេរីភាព***

[2060] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារិក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៧៥ បន្ទាត់ ១៦-២១។

[2061] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ូម ម៉ុល ឯកសារ **E3/7700** ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៨ ERN (KH) 00236695។

[2062] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ូម ម៉ុល ឯកសារ **E3/7700** ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៨ ERN (KH) 00236695-00236696។

980. ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ត្រូវបានចាប់ខ្លួននៅកោះញែក ជាមូលដ្ឋានឃោធាដែលគាត់ឈរជើងនៅក្នុង [ខែវិច្ឆិកាឬខែធ្នូ ឆ្នាំ១៩៧៧][2063]។ គាត់បានផ្តល់សក្ខីកម្មពីការចាប់ខ្លួន "គេភ្ជង់ខ្ញុំចាប់ខ្ញុំចងរួចក៏គេនាំទៅ គេបិទភ្នែកខ្ញុំរួចក៏នាំមិនដឹងថាដើរទៅឯណា ដែលវាជិតភ្នែកអស់។ ដល់រុញច្រានខ្ញុំជំពប់ដួលជាប់ចំណងគេផង ហើយគេរុញទៅ ខ្ញុំអញថា អ៊ូ! ខ្ញុំមិនដឹងថាយកទៅឯណា ទៅឯណី ខ្ញុំក៏មិនទាន់ដឹងដែរ"[2064]។ "ខ្ញុំមិនបានដឹងខ្លួនអីបន្តិចក៏មិនដឹង។ ដល់ហុចកាំភ្លើងមកបីនាក់មកភ្ជង់។ "ចុះមិត្តឯងមកភ្ជង់ខ្ញុំធ្វើអី? ទេ មិត្តឯងក្បត់អង្គការ។ ហ៊ឺ! ចុះខ្ញុំមានបានដឹងរឿងក្បត់ឯណា?" គេភ្ជង់បាន គេរុញបុកខ្ញុំនឹងកាំភ្លើងទៅ ខ្ញុំក៏នឹកឃើញ ចុះមិត្តឯងធ្វើម៉េចអីចេះ? ទៅគេឲ្យលើកដៃ ខ្ញុំក៏លើកដៃទៅ។ លើកដៃប៉ាប់ គេយកក្រមាចងមុខពីប។ ចងមុខ ដឹក ក៏មិនដឹងគេដឹកទៅខាងណាដែរ"[2065]។ ដើមបណ្តឹងរដ្ឋប្បវេណីពន្យល់ថា នៅពេលដែលគេចាប់ខ្លួនគាត់ "ខ្ញុំវាទៅមកៗពីសមរភូមិទៅ ដល់ពេលគេចាប់ ពេលខ្ញុំមកពីសមរភូមិ ក៏មិនដឹងរឿងអី ក៏គេចាប់បណ្តោយ"[2066]។

981. ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត បានផ្តល់សក្ខីកម្មថា គុកនោះមានការយាមការពារ។ "អ្នកយាមឃើញមកតែបីនាក់បាទ ជួនណាក៏បួននាក់ ជួនណាក៏បីនាក់ យាមបាទ មិនបានច្រើនទេ"[2067]។

982. ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា មានអ្នកទោសដទៃទៀត នៅក្នុងពេលដែលគាត់ត្រូវបានឃុំខ្លួន ប៉ុន្តែគាត់មិនបានដឹងពីប្រវត្តិរបស់អ្នកទោសដទៃទៀតឡើយ ដោយសារតែគាត់ "គេចងមុខទៅ ក៏ខ្ញុំអត់ដឹង ដល់នៅក្នុងគុក ក៏វាមើលមិនស្គាល់ វាបាំងជញ្ជាំង បាំងមួយខណ្ឌៗទៅ អត់

[2063] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/412.1** ទំព័រ ៣៥-៣៦ បន្ទាត់ ២១-១។

[2064] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/412.1** ទំព័រ ៣៧ បន្ទាត់ ១៣-១៥។

[2065] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៤៨ បន្ទាត់ ៥-៩។

[2066] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/412.1** ទំព័រ ៣៦ បន្ទាត់ ៤-៥។

[2067] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៧២ បន្ទាត់ ១០-១១។

មើលគ្នាឃើញទេ”[2068]។ គាត់បានបញ្ជាក់ថា "ស្គាល់តែខ្ញុំដែលនៅជាមួយខ្ញុំ បានខ្ញុំ ដែលរួមមកនឹងខ្ញុំ នេះបានខ្ញុំស្គាល់បាទ"[2069]។

983. ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត បានផ្តល់សក្ខីកម្មបន្ថែមថា គាត់បានឮ “មិត្តនារី មាត់មិត្តនារីជាប់ដែរ ប៉ុន្តែមិនដឹងប៉ុន្មាននាក់ អត់ដឹងដែរ"[2070]។

984. ចំពោះបន្ទប់ដែលគាត់ជាប់ឃុំឃាំង គាត់បានបញ្ជាក់ថា "បន្ទប់ចាក់សោរ"[2071]។ ដើមបណ្តឹងរដ្ឋប្បវេណី អាចរត់គេចបានដោយសារតែគាត់ "បានដែកមួយគាស់ បានទៅ អានេះស្មើនឹងថាវារបស់ជួយ ជីវិតខ្ញុំបានរស់”[2072]។ ដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់ថា "គុកនេះវាមិនបានជាធ្វើត្រឹមត្រូវទេ គឺធ្វើដោយមនុស្សអាចរត់បាន បានខ្ញុំថាគុកវាមិនបានយូរឆ្នាំ"[2073]។

985. ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត បានបញ្ជាក់ថា គាត់ត្រូវបានឃុំខ្លួនប្រហែលបី ទៅប្រាំខែ[2074]។

986. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូម ម៉ុល បានបញ្ជាក់ថា “ខ្ញុំត្រូវបានគេចាប់ដាក់គុក ក្នុងមន្ទីរក-១១”[2075]។ “គុកដែលគេដាក់ខ្ញុំនោះ ធ្វើអំពីឈើប្រក់ស្បូវ ជញ្ជាំងផ្តៅ ហើយមានក្រាលក្តារខ្ពស់ផុតពីដី ដូចផ្ទះទាម”[2076]។

---

[2068] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៧២ បន្ទាត់ ៥-៦។

[2069] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៧២ បន្ទាត់ ៧។

[2070] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៥០ បន្ទាត់ ៥។

[2071] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/412.1** ទំព័រ ៣៨ បន្ទាត់ ១៦-១៧។

[2072] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/412.1** ទំព័រ ៥៣ បន្ទាត់ ១៤-១៥។

[2073] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/412.1** ទំព័រ ៣៩ បន្ទាត់ ២៣-២៤។

[2074] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៦០ បន្ទាត់ ១៦-១៧។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៧២ បន្ទាត់ ១។

987. "នៅក្នុងគុកនោះ ខ្ញុំបានឃើញអ្នកទោសនៅជាមួយខ្ញុំប្រហែល២០នាក់ ហើយត្រូវបានដាក់ខ្នោះវែងធ្វើអំពីឈើជាប់គ្នា ខ្នោះ មួយដាក់៥នាក់។ ប្រហែលពីរអាទិត្យម្ដង នៅពេលដែលមានផ្លាស់ប្ដូរអ្នកថ្មីចូលមក នោះនឹងមានការរឹតខ្នោះកាន់តែខ្លាំង។ តាវ៉ន ក៏ជាកម្មាភិបាលគ្រប់គ្រងគុក នៅមន្ទីរក-១១ដែរ (សព្វថ្ងៃមិនដឹងស្លាប់ឬរស់ ហើយបើរស់ មិនដឹងនៅទីណា)។ មានស្ត្រីជាប់គុកជាច្រើននៅជាមួយខ្ញុំ ឯបុរសៗគេដាក់កន្លែងផ្សេង គឺគុកដែលនៅទំនប់ភ្នំក្រោល ដែលនៅជាប់នឹងភ្នំក្រោលប៉ែកខាងត្បូង ហើយអ្នកទាំងនោះត្រូវបានគេចាប់ មកពីភូមិពាមជីមៀត និងណាងឃិលិក និងកន្លែងផ្សេងៗទៀតនៅក្នុងខេត្តមណ្ឌលគីរី ដោយចោទថា ជាសេអ៊ីអា ឬជាខ្សែក្បត់។ ខ្ញុំមិនច្បាស់ថាមាននារីនៅក្នុងគុកភ្នំក្រោលនោះទេ ព្រោះខ្ញុំមិនធ្លាប់ទៅ"[2077]

## ២. ការដាក់ឲ្យនៅជាទាសករ

988. ភស្តុតាងដើមបណ្ដឹងរដ្ឋប្បវេណី ដែលលើកឡើងនៅក្នុងសវនាការ បានបង្ហាញថាអំណាចដែលភ្ជាប់ជាមួយសិទ្ធិជាម្ចាស់ ត្រូវបានប្រើទៅលើកុល ណៃម និងអ៊ូម ម៉ុល។

989. ដើមបណ្ដឹងរដ្ឋប្បវេណី កុល ណៃម បានផ្ដល់សក្ខីកម្មថា "ខ្ញុំត្រូវបានគេបញ្ជូនពីកងពលទៅ បានៗគេយកទៅនៅក-១១ហ្នឹងបាទ នៅធ្វើធម្មតា ធ្វើគេឲ្យទៅស្ទូងខ្លះ ធ្វើផ្ទះខ្លះ ធ្វើអីខ្លះ។ ប្រពន្ធខ្ញុំមួយគេខាងស្ទូងស្រែទៅ ខ្ញុំនេះធ្វើដូចថាជួយធ្វើផ្ទះគេ មន្ទីរពេទ្យមន្ទីរអី តាមខេត្តតាមស្រុកអីចឹងទៅបាទ។ មានធ្វើអីទេ ខ្ញុំធ្វើប៉ុណ្ណឹងបាទ បានៗទៅដល់ហ្នឹង បានៗគេរៀបការហ្នឹង។ ខ្ញុំមានតែប៉ុណ្ណឹង មានអីទៀតបាទ"[2078]។

990. ដើមបណ្ដឹងរដ្ឋប្បវេណីបានពន្យល់ថា "គេដាក់ទណ្ឌកម្មហើយ បើមេកងពលគេចាប់ហើយ បានគេរុញយើងទៅហ្នឹង ប៉ុន្តែយើងនឹងសន្និដ្ឋាន ប៉ុនគេមិនថាយើងទេ គេគ្រាន់តែប្រាប់ថាមេហ្នឹងគេចាប់

---

[2075] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ូម ម៉ុល ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៨ ឯកសារ **E3/7700** ERN (KH) 00236695។

[2076] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ូម ម៉ុល ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៨ ឯកសារ **E3/7700** ERN (KH) 00236696។

[2077] កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី អ៊ូម ម៉ុល ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៨ ឯកសារ **E3/7700** ERN (KH) 00236696។

[2078] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី កុល ណៃម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៧៣ បន្ទាត់ ៨-១១។

ហើយ។ បើយើងដឹងថាគេដាក់ទណ្ឌកម្ម បាទយើងខ្លាចអត់ហ៊ាននិយាយជាមួយគេទេបាទ គេឲ្យធ្វើអីយើងធ្វើហ្នឹងបាទ"[2079]។

991. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូម ម៉ុល បានរៀបរាប់ថា "នៅពេលដែលខ្ញុំជាប់គុកនោះ ខ្ញុំត្រូវបានដោះខ្នោះឲ្យចេញទៅធ្វើការ ដកស្ទូង លើកទំនប់ ទាំងដៃខ្ញុំនៅជាប់ចំណងខ្សែអង្រឹង ហើយមានអ្នកយាមកាន់កាំភ្លើងផង។ ដូច្នេះខ្ញុំខ្លាចគេឯងដែលមើលមកខ្ញុំ"[2080]។

## ៣. ការធ្វើទារុណកម្ម

992. ភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានលើកឡើងនៅក្នុងសវនាការ បានបង្ហាញថាដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ទទួលរងនូវអំពើដែលបណ្តាលឲ្យមាន ការឈឺចាប់ឬព្យសនកម្មធ្ងន់ធ្ងរ ដែលធ្វើឡើងក្នុងគោលបំណងចង់បានព័ត៌មាន នៅពេលដែលគាត់ជាប់ឃុំនៅភ្នំក្រោល។

### *អំពើដែលបណ្តាលឲ្យមានព្យសនកម្ម ឬការឈឺចាប់ធ្ងន់ធ្ងរ*

993. ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត បានផ្តល់សក្ខីកម្មថា "ដែលចាប់ខ្ញុំទៅក៏គេធ្វើទារុណកម្មខ្ញុំគឺសំខាន់ណាស់"[2081]។ "ដែលគេហៅខ្ញុំទៅ ក៏គេយកទៅកន្លែងខ្ទមនោះឯង កន្លែងខ្ទមសម្ងាត់នោះបាទ។ សួរចម្លើយមុនដំបូងគេដាក់ឆក់ខ្សែភ្លើងបាទ ឆក់ខ្សែភ្លើងខ្ញុំ ក៏ខ្ញុំវាដូចថាបាត់ស្មារតីអស់ ឲ្យខ្ញុំឆ្លើយៗ ថាខ្ញុំមិនឆ្លើយទៅគេឆក់ទៀតទៅ ដល់ឆក់ទៅខ្ញុំដូចថាវាសន្លប់ គឺអត់ដឹងខ្លួនឯង វាដូចថា ដឹងថាខ្លួនស្លាប់មានតែប៉ុណ្ណឹងខ្ញុំ។ បានខ្ញុំដឹងខ្លួនប៉ាច់វាសួរទៀតៗ វាឈប់ឆក់ គេរើបណ្តោយ គេរើ ថាឆក់ទៅខ្លាចខ្ញុំមិនបានឆ្លើយសំណួរឲ្យបាន ឲ្យគេបានអស់ ក៏គេឈប់ឆក់ គេរើ ដល់រើវាអាចយើងឆ្លើយបាន"[2082]។

---

[2079] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៧៣ បន្ទាត់ ១៤-១៦។

[2080] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ូម ម៉ុល ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៨ ឯកសារ **E3/7700** ERN (KH) 00236696។

[2081] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៤៨ បន្ទាត់ ៥។

[2082] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៥០ បន្ទាត់ ១២-១៦។

994. “មានគ្នាដែលស្នួរចម្លើយខ្ញុំ ជួនណាក៏មានបីនាក់ ជួនណាក៏មានបួននាក់។ ស្នួរចម្លើយគឺមានវាឆក់ ខ្ញុំវាឆក់បានពីរដង។ ឆក់បានពីរដង វាផ្អាកឆក់ៗទៅ ខ្ញុំវាវាងសន្លប់ទៅ វាមិនបានចម្លើយ ដល់មិនបានចម្លើយគេឈប់ឆក់ គេវ៉ៃៗ ម៉ាល្មមអ៊ីចឹងទៅ ម៉ាអន់ ម៉ាឈឺទៅ វាទ្រោមទៅ យើងអាចឆ្លើយបាន។ ប៉ុន្តែខ្ញុំមិនដឹងមនាពាក្យអីនឹងឆ្លើយ"[2083]។

995. “ដែលខ្ញុំដែលឆក់ខ្ញុំៗបានដឹងខ្លួន គឺអាគុយមិនឆក់នឹងម៉ាស៊ីនអីទេ គឺនឹងអាគុយបាទ។ អាគុយយើងនោះប្រហែលជាអាគុយ១០០អំពែ ឬអាគុយ៧០អំពែប៉ុណ្ណោះឯងបាទ។ មិនមានម៉ាស៊ីនអីនឹងធំសម្រាប់សាគួរថាឆក់”[2084]។ “ដែលឆក់នោះគឺវាស្នួរចម្លើយគឺយូរដែរបាទ។ ជួនណាថ្ងៃណានោះមួយថ្ងៃម្តងទៅ ជួនថ្ងៃណាគឺម្តង ជួនថ្ងៃណានោះគឺពីរដង ជួនថ្ងៃណាណោះវាបានខានខ្លះបាទ វាមិនបានរាល់ថ្ងៃរហូតទេ មានបន្ទូរខ្លះបាទ អត់មានបានស្នួរចម្លើយរាល់ថ្ងៃទេ។ ជួនណាវាបទបញ្ជាមកពីមេ វាប្រាប់ខ្ញុំថា “មេឲ្យបញ្ជាអ្ហែងនេះឲ្យឆ្លើយ បើហ្អែហាមិនឆ្លើយអ្ហែងត្រូវតែងាប់ បាទ បើអ្ហែងឆ្លើយអង្គការអត់សម្លាប់អ្ហែងចោលទេ គេថាអ៊ីចឹង”[2085]។

996. ចំពោះអំពើហិង្សាលើរូបកាយ ដែលដើមបណ្តឹងរដ្ឋប្បវេណី សុន វុត បានទទួលរង គាត់បានផ្តល់សក្ខីកម្មថា "បាទដែលវ៉ៃខ្ញុំនោះ គឺដំបងយើងគឺវាធំដែរបាទ ធំប៉ុនកដៃនេះ គេវ៉ៃបាទ វ៉ៃល្មមតែយើងពីរបីដំបង ក៏វាបាត់ស្មារតីដឹងខ្លួន វាសន្លប់ ខ្ញុំសន្លប់ វាវ៉ៃម្តងសន្លប់ ពីរដងក៏សន្លប់ សន្លប់តែវាមិនបានយូរ វាចាប់កន្ត្រាក់ វាស្នួរចម្លើយទៀត ក៏អាចដឹងខ្លួនមួយភ្លែតទៅវិញទៅបាទ។ បើខ្ញុំមិនឆ្លើយទៅវា វ៉ៃផ្តាច់ទៀត វាវ៉ៃយកងាប់ អញដាក់អ្ហែងយកងាប់ វាថា។ មិនបានឆ្លើយហើទៅ វ៉ៃឯងឲ្យងាប់តែម្តង។ ខ្ញុំក៏អត់ដឹងដែរ ក៏វាវ៉ៃខ្លាំងទៅ វាចូលអាបាត់បង់សតិវិញ្ញាណ ក៏សន្លប់មិនបានដឹងអី នឹងឆ្លើយនិយាយកើតវាអស់។ ដំបងធំៗបាទ”[2086]។

---

[2083] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៧៤-៧៥ បន្ទាត់ ២៣-១។

[2084] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៧៥ បន្ទាត់ ២១-២៣។

[2085] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៧៦ បន្ទាត់ ៤-៨។

[2086] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៧៧ បន្ទាត់ ១៥-២០។

997. នៅពេលជាប់ឃុំនៅក-១១ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូម ម៉ុល បានបញ្ជាក់ថា "ថ្ងៃមួយនៅក្នុងគុកនោះ នៅពេលដែលខ្ញុំនិងស្ត្រីផ្សេងៗទៀតកំពុងជាប់ខ្នោះ កូនប្រុសរបស់ស្ត្រីម្នាក់ដែលមានអាយុប្រហែល ៨ឆ្នាំ ត្រូវបានពួកនារីយាមគុក ចងព្យួរជើងឡើងលើ ហើយបង្ខំឲ្យពួកខ្ញុំនិងម្តាយក្មេងនោះ មើលសកម្មភាពចងព្យួរនោះ។ កូនក្មេងនោះត្រូវបានវ៉ៃ ហើយចងព្យួរទុកទាល់តែស្រក់ឈាមពេញភ្នែក ទើបដាក់ចុះមកវិញ។ មួយរយៈពេលយូរទើបក្មេងនោះដឹងខ្លួន។ អ្នកវាយកូនក្មេងនោះបង្ខំឲ្យខ្ញុំមើល តែខ្ញុំមិនហ៊ានមើលព្រោះវាពិបាកពេក។ ឪពុករបស់ក្មេងនោះ ត្រូវបានចាប់ដាក់គុកនៅទំនប់ភ្នំក្រោល"[2087]។

998. ពាក់ព័ន្ធទៅនឹងបញ្ហាថានរណាជាអ្នកទទួលខុសត្រូវ លើការសួរចម្លើយដើមបណ្តឹងរដ្ឋប្បវេណី សុន វុតនោះ គាត់បានផ្តល់សក្ខីកម្មថា "បាទអ្នកក្នុងគុកវាអ្នកបញ្ចេញ ប៉ុន្តែវាសួរផង ហើយមានមកពី ៨០១ គេសួរបាទ មកពីតាបង តាសារឿន កងពល៨០១ តា០៥ គេហៅថាតា០៥បាទ។ មិនដឹងថាមេបញ្ជាការ មិនដឹងថាគេប្រើអំណាចខុសពីមេ ក៏ខ្ញុំមិនដឹងដែរបាទ"[2088]។

999. គាត់ក៏បានផ្តល់សក្ខីកម្មថា "ពួកអាផេង និងអាបែនេះវាអ្នកសម្លាប់។ នេះវាពួកមហាឃោរឃៅពិភពគុន។ វាពីដើមមិញ វានៅជាមួយខ្ញុំទេ ប៉ុនដល់គេថាខ្ញុំក្បត់ទៅ គេបានមកកងពល៨០១ មកក្តោបក្តាប់នៅកងពល៩២០ទៅ គេបានបំពាក់បំប៉នស្មារតីយ៉ាងម៉េច បានគេមកធ្វើបាបគ្នាឯងទៅវិញបាទ ដែលខ្ញុំជាក្តោបក្តាប់វាពីដើមបាទ។ បានខ្ញុំ អាដែងថាអីណាគេចាប់ទៅហើយ វានៅក្នុងដៃគេហើយថាយើងក្បត់ ខ្ញុំក៏មិនហ៊ានប្រកែក ទោះបីគេវ៉ៃក៏ខ្ញុំសុខចិត្តថា មិត្តឯងធ្វើបាបអីខ្ញុំ ខ្ញុំគ្រាន់ថា មានវិចារទៅវិញតែប៉ុណ្ណឹងបាទ"[2089]។

## ៤. អំពើអមនុស្សធម៌ដទៃទៀត

### *ស្ថានភាពឃុំឃាំង*

---

[2087] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ូម ម៉ុល ឯកសារ **E3/7700** ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៨ ERN (KH) 00236695-00236696។

[2088] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៧៥ បន្ទាត់ ១៥-១៧។

[2089] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៥២ បន្ទាត់ ៨-១៣។

1000. ភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានលើកឡើងនៅក្នុងសវនាការ បានបង្ហាញថាការប្រព្រឹត្ត របស់អង្គការ ក្នុងការបង្កើតនិងប្រតិបត្តិមន្ទីរសន្តិសុខភ្នំក្រោល បានគ្របដណ្តប់ទៅលើការរំលោភ បំពាន ទៅលើសិទ្ធិក្នុងការរស់រានមានជីវិត របស់អ្នកជាប់ឃុំ និងសិទ្ធិទទួលបានបទដ្ឋានរស់នៅ ដោយសមស្រប សិទ្ធិមិនទទួលរងការធ្វើបាបដោយសាហាវយង់ឃ្នង អមនុស្សធម៌ និងបន្ទាប បន្ថោក ព្រមទាំងសិទ្ធិមិនត្រូវបានចាប់ខ្លួនតាមអំពើចិត្ត[2090]។ អំពើទាំងនោះបង្កើតបានជាអំពើ ដែលមានលក្ខណៈនិងស្ថានទម្ងន់ប្រហែលគ្នា និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ក្នុងទម្រង់ដទៃ ទៀត ហើយបានបណ្តាលឲ្យដើមបណ្តឹងរដ្ឋប្បវេណី ទទួលរងនូវព្យសនកម្មធ្ងន់ធ្ងរ ឬបង្កើតបានជា ការប៉ះពាល់ ដល់សេចក្តីថ្លៃថ្នូរបស់មនុស្ស។

1001. ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត បានផ្តល់សក្ខីកម្មអំពីស្ថានភាព នៃការឃុំឃាំងខ្លួនគាត់ ដែលគាត់ ទទួលរងប្រហែល៣ទៅ៦ខែ[2091]។ គាត់បានបញ្ជាក់ថា បន្ទាប់ពីគាត់មកដល់គុក "ដាក់ខ្នោះដាក់ ជើងផង ដៃ។ ជើងទាំងពីរ ដៃទាំងពីរដែរ។ ជាប់ទាំងអស់"[2092]។ គាត់បញ្ជាក់ថា "បាទខ្នោះៗនោះ វាឈើ វាចំនួនប៉ុននេះ គេខ្ទង គេដាក់មួយប្រឡោះជើងបាទ។... បានចំនួនមួយអាទិត្យ បានគេ ស្រាយដៃ គេទុកដៃមួយ ទុកជើងមួយបាទ"[2093]។ គេប្រើខ្នោះនោះដើម្បី "ដាក់យើងកុំឲ្យរត់រួច" ហើយគេចាប់ខ្នោះជាមួយបង្គោលឈើធំៗ[2094]។ លើសពីនេះទៀត ខ្នោះឈើទាំងនោះមានស៊ីមធ្វើ ពីដែក[2095]។ "ចំពោះអ្នកជាប់ឃុំពីរនាក់ទៀត ពួកគេដាក់ខ្នោះជើងតែម្ខាងៗប៉ុណ្ណោះ"[2096]។

---

[2090] សេចក្តីប្រកាសស្តីពីសិទ្ធិមនុស្ស ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៤៨ មាត្រា ១ មាត្រា ៥ មាត្រា ៩ មាត្រា ២៥។

[2091] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៦០ បន្ទាត់ ១៦-១៧។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៧២ បន្ទាត់ ១។

[2092] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៤៩ បន្ទាត់ ៨។

[2093] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៤៩ បន្ទាត់ ១០-១២។

[2094] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៤៩ បន្ទាត់ ១៨-១៩។

[2095] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/412.1** ទំព័រ ៥២ បន្ទាត់ ១។

1002. ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្ម អំពីបរិមាណអាហារដែលផ្តល់ឱ្យគាត់ ដោយមិនគ្រប់គ្រាន់។ "ដែលចាប់ខ្ញុំមុនដំបូងគឺ ក្នុងមួយយប់នោះ ក្នុងមួយថ្ងៃគឺអត់បាន អាហារចូលពោះទេខ្ញុំ។ រំលងស្អែកទៀត រំលងផុតពីដែលគេចាប់នោះទៅ បានគេឱ្យបាយមួយបន្តិច ប្រហែលជាប៉ុនកដៃខ្ញុំនិយាយឱ្យត្រង់ទៅចុះ ស្មោះត្រង់ប៉ុនកដៃ។ ហើយដាក់ទឹកនឹងត្រឡោកឱ្យមកបន្តិច។ បាទតែប៉ុណ្ណឹងឯងខ្ញុំបាទ"[2097]។

1003. ពេលនៅក-១១ ដើមបណ្តឹងរដ្ឋប្បវេណី អួម ម៉ុល បានបញ្ជាក់ថា "ថ្ងៃមួយនៅពេលដែលខ្ញុំមានផ្ទៃពោះ គេបានឱ្យខ្ញុំទៅដកសំណាប ហើយសែងយកទៅដាក់ស្រែទាំងភ្លៀងរលឹម ធ្វើឱ្យខ្ញុំរអិលដួលរលូតកូន។ ពេលនោះខ្ញុំបានសុំស្រាមួយពែង និងថ្នាំត្រាំស្រាពីតាសូភាមកហូប។ ខ្ញុំបានធូរស្រាលបន្តិចម្តងៗ តែឈាមនៅតែបន្តហូររហូត ប្រហែលមួយអាទិត្យទើបជាសះស្បើយ។ ដោយសារការធ្វើការទាំងជាប់ខ្នោះនោះ ខ្ញុំបានជាប់គ្រគៀករហូតដល់សព្វថ្ងៃ"[2098]។

## គ. ព្យសនកម្ម

### *អារម្មណ៍ត្រូវគេក្បត់ និងការឈឺចាប់ផ្លូវចិត្តរយៈពេលវែង*

1004. ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត បានផ្តល់សក្ខីកម្មអំពីការឈឺចាប់ផ្លូវចិត្តរបស់គាត់ ដែលបណ្តាលមកពីបទពិសោធន៍របស់គាត់។ "ប៉ុន្តែខ្ញុំនឹងឃើញ វាឈឺចាប់ដែរ វាគួរណាដែលខ្ញុំវាបានក្បត់ ខ្ញុំនឹកឃើញអ៊ីចឹងរហូតទល់បច្ចុប្បន្ន។ ខ្ញុំនឹងឃើញគឺថា វាកំសត់ ជូរចត់ បម្រើបក្សហើយ បក្សមិនទុកចិត្តទៀត ហើយខ្ញុំស្មោះត្រង់ មើលគេចាប់ខ្ញុំទៅបាន"[2099]។ "ខ្ញុំមិនបានគេច មិនបានដឹង ហើយថាខ្ញុំស្មោះត្រង់នឹងអង្គការ។ បើខ្ញុំរត់ក៏ផុតដែរ តែខ្ញុំមិនដឹងរឿងថា ស្មោះនឹងអង្គការហើយ ខ្ញុំវាមាន

[2096] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៥២ បន្ទាត់ ២-៣។

[2097] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៥១ បន្ទាត់ ១១-១៤។

[2098] កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អួម ម៉ុល ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៨ ឯកសារ **E3/7700** ERN (KH) 00236696-00236697។

[2099] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៤៨ បន្ទាត់ ៩-១១។

អ្នកចោទប្រកាន់។ បើមេក៏មិនដែលមាននិយាយបំពាក់បំប៉នឲ្យខ្ញុំថា "លោកឯង មិត្តឯង ត្រូវតាមខ្ញុំ អីចេះៗ" ខ្ញុំអត់ដឹងដែរ"[2100]។ "អង្គការថាឯងក្លាហាន ថាសមមិត្តឯងធ្វើការល្អ គោរពអង្គការ បាទ។ ដល់ទឹកបញ្ចប់មកវិញ មើលចោទប្រកាន់ខ្ញុំថា ខ្ញុំក្បត់ពីអង្គការទៅវិញ។ ខ្ញុំក៏មានដឹងស្អីដែល អ្នកណា លោកណាដែលមកបញ្ចេះ បណ្ដឹងខ្ញុំឲ្យក្បត់ទៅនេះទៅនោះ វៃអង្គការវិញ ខ្ញុំមិនដែលមាន សោះ។ ដល់គេចាប់វៃសួរចម្លើយខ្ញុំ ខ្ញុំដឹងឆ្លើយយ៉ាងម៉េច វាអស់ផ្លូវ ឆ្លើយប្រាប់ថាក្បត់ក៏នៅតែគេ វៃចោល មិនប្រាប់ក៏គង់តែគេវៃ ម្ល៉េះហើយខ្ញុំនឹកឃើញខ្លួនខ្ញុំវាឈឺចាប់ដែរ ត្រង់ចំណុចនេះ សំខាន់ ណាស់ខំធ្វើការបម្រើជាតិ។ ខ្ញុំមិនដឹងថាអ្នកណាទេ មកវៃខ្ញុំ"[2101]។

1005. "ដល់ឪពុកម្ដាយ បងប្អូនគេសម្លាប់ចោលអស់ តើខ្ញុំវាឈឺចាប់ នោះខ្ញុំវាចិត្តល្អណាស់ ឬមួយយ៉ាង ណា។ ទៅអស់លោកណាដែលចិត្ត បានថាបើចិត្តមិនល្អវាអាក្រក់ដូចតែគ្នា។ តែបើយើងទៅសម្លាប់ បងប្អូនដូចជាកាន់កាប់ ខ្លួនឯងធ្វើជាមេអីចឹងបើគេសម្លាប់ខឹងទេ? ខឹងដូចគ្នា"[2102]។ "ខ្ញុំក៏នឹកឃើញ ថាឈឺចាប់ដែរខ្ញុំ ខំតស៊ូដើម្បីការពារប្រទេសជាតិ បម្រើបក្ស បម្រើអង្គការ ប៉ុន្តែអង្គការមកចោទ ប្រកាន់ មើលមួយពូជខ្ញុំស្លាប់អស់ ចុះបើខ្ញុំធ្វើសម្រាប់ការពារប្រទេសជាតិ ហើយឲ្យវៃបងប្អូនម៉ែ ឪចោលចុះ តើខ្ញុំអ្នកបម្រើអង្គការទៅការពារព្រំដែន ខ្ញុំវាចិត្តល្អ ខ្ញុំវាឈឺចាប់របៀបម៉េច"[2103]។ "ឪពុកម្ដាយបងប្អូនខ្ញុំ គេសម្លាប់ចោលអត់មានមូលហេតុអ្វីសោះ ប៉ុន្តែឪពុកម្ដាយខ្ញុំគាត់កាលដាច់ ភ្នំពេញ៧៥។ ពីសម័យនោះគាត់បានធ្វើជំទប់លេខ១មេឃុំ គេហៅថាជំទប់លេខ១ ពីសម័យ សាធារណរដ្ឋផងបាទ។ ដល់នៅឆ្នាំ១៩៧៥ ពេលខ្ញុំនៅមណ្ឌលគីរី ធ្វើជាកងទ័ពនោះ ខ្ញុំលែងនៅជា មួយឪពុកម្ដាយហើយ។ នៅដើមដំបូងខ្ញុំមិនដឹងពីវាសនាឪពុកម្ដាយទេ ដោយខ្ញុំគិតតែបម្រើជាតិ

---

[2100] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/411.1 ទំព័រ ៤៧ បន្ទាត់ ១៩-២០។

[2101] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/411.1 ទំព័រ ៤៧ បន្ទាត់ ៦-១១។

[2102] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/411.1 ទំព័រ ៧៦-៧៧ បន្ទាត់ ២៥-២។

[2103] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/411.1 ទំព័រ ៥៤ បន្ទាត់ ១១-១៥។

បម្រើបក្ស។ ទើបក្រោយមកទេខ្ញុំដឹងពីគាត់ ថាពួកគាត់ត្រូវគេសម្លាប់។ វាឈឺចាប់ណាស់ដែលបាន ដឹងរឿងនេះ”[2104]។

## ជំពូក ១០÷ មន្ទីរសន្តិសុខស-២១[2105]

### ក. និដ្ឋភាពទូទៅនៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី

[2104] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/412.1** ទំព័រ ៥៤-៥៥ បន្ទាត់ ២៥-៧។

[2105] អង្គជំនុំជម្រះសាលាដំបូងបានទទួលយកអង្គហេតុដែលពាក់ព័ន្ធនឹងការបំពេញមុខងារ និងប្រតិបត្តិការរបស់មន្ទីរសន្តិសុខ ស-២១ ដូចជា ការចាប់ខ្លួនអ្នកទោស និងស្ថានភាពនៃការឃុំឃាំង ការសួរចម្លើយ និងការសម្លាប់អ្នកទោស ការសម្លាប់នៅជើងឯក ការសម្លាប់នៅ ឬជិតមន្ទីរ ស-២១ និងការបូមឈាមពីអ្នកជាប់ឃុំ។ ដីកាដំណោះស្រាយ ឯកសារ **D427** (កែតម្រូវ ៣) កថាខណ្ឌ ៤២៣-៤៤៧។ ដីកាដំណោះស្រាយ ឯកសារ **D427** (កែតម្រូវ ៣) កថាខណ្ឌ ៤៤៨-៤៥៦។ ដីកាដំណោះស្រាយ ឯកសារ **D427** (កែតម្រូវ ៣) កថាខណ្ឌ ៤៦០-៤៦២។ ដីកាដំណោះស្រាយ ឯកសារ **D427** (កែតម្រូវ ៣) កថាខណ្ឌ ៤៦៣-៤៦៧។ ដីកាដំណោះស្រាយ ឯកសារ **D427** (កែតម្រូវ ៣) កថាខណ្ឌ ៤៦៨-៤៧២។ ដីកាដំណោះស្រាយ ឯកសារ **D427** (កែតម្រូវ ៣) កថាខណ្ឌ ៤៧៣-៤៧៥។ ផ្អែកតាមការចោទប្រកាន់លើអង្គហេតុទាំងនេះ ជនជាប់ចោទត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើឱ្យទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុនយោបាយ ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុពូជសាសន៍ និងអំពើអមនុស្សធម៌ផ្សេងទៀតនៃការវាយប្រហារលើសេចក្តីថ្លៃថ្នូររបស់មនុស្ស អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភផ្លូវភេទក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំ។ ជនជាប់ចោទត្រូវបានផ្តន្ទាទោសបន្ថែមទៀតចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ។ ដើមបណ្តឹងរដ្ឋប្បវេណីមិនបានផ្តល់សក្ខីកម្មចំពោះបទឧក្រិដ្ឋទាំងនេះឡើយ ហើយពួកគេក៏មិនត្រូវបានលើកឡើងក្នុងផ្នែកនេះដែរ។ *សូមមើល*ដីកាដំណោះស្រាយ ឯកសារ **D427** (កែតម្រូវ ៣) កថាខណ្ឌ ១៤៨១-១៥២០។ ដីកាដំណោះស្រាយ ឯកសារ **D427** (កែតម្រូវ ៣) កថាខណ្ឌ ១៣៧៣ កថាខណ្ឌ ១៣៧៦។ ដីកាដំណោះស្រាយ ឯកសារ **D427** (កែតម្រូវ ៣) កថាខណ្ឌ ១៣៨១ កថាខណ្ឌ ១៣៨៥។។ ដីកាដំណោះស្រាយ ឯកសារ **D427** (កែតម្រូវ ៣) កថាខណ្ឌ ១៣៩១។ ដីកាដំណោះស្រាយ ឯកសារ **D427** (កែតម្រូវ ៣) កថាខណ្ឌ ១៤០២។ ដីកាដំណោះស្រាយ ឯកសារ **D427** (កែតម្រូវ ៣) កថាខណ្ឌ ១៤០៨។ ដីកាដំណោះស្រាយ ឯកសារ **D427** (កែតម្រូវ ៣) កថាខណ្ឌ ១៤១៦ កថាខណ្ឌ ១៤១៧។ ដីកាដំណោះស្រាយ ឯកសារ **D427** (កែតម្រូវ ៣) កថាខណ្ឌ ១៤១៦ កថាខណ្ឌ ១៤១៧។ ដីកាដំណោះ ស្រាយ ឯកសារ **D427** (កែតម្រូវ ៣) កថាខណ្ឌ ១៤២២។ ដីកាដំណោះស្រាយ ឯកសារ **D427** (កែតម្រូវ ៣) កថាខណ្ឌ ១៤៣៤។ ដីកាដំណោះស្រាយ ឯកសារ **D427** (កែតម្រូវ ៣) កថាខណ្ឌ ១៤៤២។ ដីកាដំណោះស្រាយ ឯកសារ **D427** (កែតម្រូវ ៣) កថាខណ្ឌ ១៤៣០-១៤៣៣។

1006. ដើមបណ្តឹងរដ្ឋប្បវេណីដប់រូប ទាំងជាជនរងគ្រោះផ្ទាល់ និងជាជនរងគ្រោះដោយប្រយោល ពីឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ថាប្រព្រឹត្ត នៅមន្ទីរសន្តិសុខស-២១ នោះ បានមកផ្តល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះ ក្នុងអំឡុងពេលជំនុំជម្រះ[2106]។ សាក្សីផ្ទាល់មួយរូបគឺ ជុំ ម៉ី បានផ្តល់សក្ខីកម្មអំពីការចាប់ខ្លួន ការសួរចម្លើយ ការឃុំខ្លួន និងការដោះលែងជាចុងក្រោយ ពីមន្ទីរសន្តិសុខស-២១។ សាក្សីដោយប្រយោលប្រាំបីរូប បានផ្តល់សក្ខីកម្ម នៅចំពោះមុខអង្គជំនុំជម្រះ អំពីការឃុំខ្លួននិងការសម្លាប់មនុស្សជាទីស្រឡាញ់របស់ពួកគាត់ នៅមន្ទីរសន្តិសុខស-២១។ សក្ខីកម្មរបស់ពួកគាត់ត្រូវភ្ជាប់ជាមួយ នូវបញ្ជីឈ្មោះអ្នកទោស ប្រវត្តិរូប រូបថត និង/ឬសៀវភៅកំណត់ត្រា ដែលមាននៅក្នុងសំណុំរឿង ហើយត្រូវបានបង្ហាញជូន ដើមបណ្តឹងរដ្ឋប្បវេណីនីមួយៗ នៅក្នុងពេលដែលគាត់មកផ្តល់សក្ខីកម្ម។ ភស្តុតាងបន្ថែមត្រូវបាន ឌុច ផ្តល់ឲ្យ ទាក់ទងសាច់ញាតិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឃីម និង Timothy Scott Deeds [2107]។

1007. ឧបសម្ព័ន្ធ ច មាននូវបញ្ជីដើមបណ្តឹងរដ្ឋប្បវេណី និងសាច់ញាតិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានកត់ត្រាក្នុងបញ្ជីស-២១ របស់ក.ស.ច.ស និងត្រូវបានកត់ត្រានៅក្នុងកំណត់ត្រាសហសម័យ របស់មន្ទីរសន្តិសុខស-២១ ថាបានចូល និង/ឬត្រូវបានសម្លាប់នៅមន្ទីរស-២១[2108]។ ដើមបណ្តឹងរដ្ឋប្បវេណី ឬសាច់ញាតិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចំនួនហុកសិបប្រាំបួននាក់ ត្រូវបានបញ្ជាក់អះអាងថា បានចូលមន្ទីរស-២១។ សាច់ញាតិ៣២នាក់ ត្រូវបានកត់ត្រាថាបានសម្លាប់ ហើយដើមបណ្តឹងរដ្ឋប្បវេណីប្រាំនាក់បន្ថែមទៀត មានសាច់ញាតិដែលមានឈ្មោះ នៅក្នុងឯកសារសហសម័យ ប៉ុន្តែមិនមាននៅក្នុងបញ្ជីស-២១ របស់ក.ស.ច.ស[2109]។

---

[2106] ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១២៨ នាក់ (មួយរយម្ភៃប្រាំបីនាក់) ត្រូវបានប្រកាសទទួលស្គាល់ដោយ ក.ស.ច.ស (ដីកាដំណោះស្រាយ ឯកសារ **D427** (កែតម្រូវ ៣) កថាខណ្ឌ ៤៧៥) ថាពាក់ព័ន្ធនឹងព្យសនកម្មដែលទទួលរងពីបទឧក្រិដ្ឋដែលរងការចោទប្រកាន់នៅមន្ទីរ ស-២១ ហើយដើមបណ្តឹងរដ្ឋប្បវេណី ១០ នាក់ (ដប់ នាក់) ត្រូវបានទទួលស្គាល់ដោយ អ.ប.ជ។

[2107] សក្ខីកម្មផ្ទាល់មាត់របស់សាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច ប្រតិចារឹក ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/435.1**។ សក្ខីកម្មផ្ទាល់មាត់របស់សាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច ប្រតិចារឹក ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/436.1**។

[2108] ឧបសម្ព័ន្ធ ច ៖ ដើមបណ្តឹងរដ្ឋប្បវេណី និងសាច់ញាតិរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលបានចូលទៅ ឬត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខ ស-២១។

[2109] *ដូចជើងទំព័រខាងលើ*។

1008. ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី[2110] បានផ្តល់សក្ខីកម្មអំពីការចាប់ខ្លួន ការសួរចម្លើយ និងការឃុំខ្លួនគាត់នៅ មន្ទីរសន្តិសុខស-២១។ គាត់ត្រូវបានចាប់ខ្លួននៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៨ ពីកងកាត់ដេររដ្ឋ ដែលគាត់គឺជាសមាជិករបស់ កងអនុសេនាធំ[2111]។ ប្រពន្ធនិងកូនស្រីរបស់គាត់ មិនបានដឹងអំពីការចាប់ខ្លួនគាត់ ឬអំពីការបញ្ជូនគាត់ទៅមន្ទីរស-២១ឡើយ[2112]។ ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ត្រូវបានឃុំខ្លួន និងសួរចម្លើយអស់រយៈពេល១២ថ្ងៃ[2113] ហើយស្ថានភាពរបស់គាត់ត្រូវបានផ្លាស់ប្តូរ ហើយគេតម្រូវឱ្យគាត់ទៅជួសជុល អង្គុលីលេខវិញ[2114]។ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា គាត់ត្រូវបានគេបណ្តើរចេញពីគុក ជាមួយមនុស្ស១៨នាក់ផ្សេងទៀត នៅថ្ងៃទី៧ ខែ

---

[2110] ដើមបណ្តឹងរដ្ឋប្បវេណីនេះក៏ជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងសំណុំរឿង០០១ផងដែរ។ គាត់បានផ្តល់សក្ខីកម្មដល់ ក.ស.ច.ស នៅថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៨ (កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ឯកសារ **E3/5163** ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០០៨ ERN (KH) 00163411-00163416) និង បានចូលរួមក្នុងការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុ និងការតទល់មុខគ្នា ដែលធ្វើឡើងដោយ ក.ស.ច.ស (កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុនៅទួលស្លែង ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៨ ឯកសារ **E3/5765** ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៨ ERN (KH) 00181328-00181346។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ ១៖ កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់កន្លែងកើតហេតុនៅទួលស្លែង ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៨ ឯកសារ **E3/9431** ចុះថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៨ ERN (KH) 00181395-00181448។ កំណត់ហេតុនៃការតទល់មុខគ្នា ឯកសារ **E3/5769** ចុះថ្ងៃទី ២៩ ខែ កុម្ភៈ ឆ្នាំ ២០០៨ ERN (KH) 00166588-00166599 និង ផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ នៅថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៩ (កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច" ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៩ ឯកសារ **E3/7451** ERN (KH) 00347916-00347995)។ អង្គជំនុំជម្រះសាលាដំបូងក្នុងករណីនោះយល់ថា "ក្នុងចំណោមដើមបណ្តឹងរដ្ឋប្បវេណីចំនួន ០៨ នាក់ ដែលអះអាងថាជាអ្នករស់រានមានជីវិតពីមន្ទីរ ស-២១ ឬ ស-២៤ អង្គជំនុំជម្រះយល់ឃើញថា ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបួននាក់ ខាងក្រោមបានបង្ហាញព័ត៌មានអំពីអំណះអំណាងនេះ និងបានបង្ហាញភ័ស្តុតាងថា កាំង ហ្គេកអ៊ាវ ហៅ ឌុច ទទួលខុសត្រូវដោយផ្ទាល់ចំពោះព្យសនកម្មដែលពួកគាត់បានទទួលរង ៖ ...ជុំ ម៉ី..."(សាលក្រមសំណុំរឿង ០០១ ឯកសារ **E188** (កែតម្រូវ ២) កថាខណ្ឌ ៦៤៥)។

[2111] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ១៧-១៨ បន្ទាត់ ២៤-១។ ទំព័រ ៣៥ បន្ទាត់ ១៩-២៣។

[2112] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ៥៤ បន្ទាត់ ៤-៩។

[2113] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ២៣ បន្ទាត់ ៥-១៤។

[2114] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ៣១ បន្ទាត់ ១៦-២២ ។

មករា ឆ្នាំ១៩៧៩ នៅពេលដែលវៀតណាមមកដល់[2115]។ កំណត់ត្រា និងចម្លើយសារភាពរបស់គាត់ ទាក់ទងការឃុំខ្លួនគាត់ គឺមាននៅក្នុងសំណុំរឿង ហើយនឹងត្រូវពិភាក្សានៅផ្នែកខាងក្រោម[2116]។

1009. ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ស្ថិតនៅផ្សារអូរឬស្សី ហើយត្រូវបានគេចាត់តាំងឱ្យ ដើរប្រមូលម៉ាស៊ីនដេរយកទៅជួសជុល នៅកងកាត់ដេរ[2117]។ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៨ ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ត្រូវបានគេស្នើឱ្យទៅវៀតណាម ដើម្បីជួសជុលយានយន្ត ប៉ុន្តែគាត់បែជាត្រូវបានគេបញ្ជូនទៅទួលស្លែង ជាមួយមិត្តទ្រី និងមិត្តទឹមទៅវិញ[2118]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានរំឭកថា ប្រធានចាស់របស់គាត់បីនាក់ ត្រូវបានគេយកទៅបាត់ ហើយថានៅពេលដែលគេយកគាត់ទៅទួលស្លែង ប្រធានរបស់គាត់គឺឈ្មោះ វ៉ាន់[2119]។ ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី បានរៀបរាប់ថា គាត់មិនត្រូវបានគេចាប់ខ្លួនឡើយ គឺគេគ្រាន់តែស្នើឱ្យគាត់ឡើងលើឡាំប្រឺតាទៅ[2120]។ ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី បានរំឭកថា គាត់ចង់យកឧបករណ៍របស់គាត់តាមខ្លួន ប៉ុន្តែគេប្រាប់គាត់ថា គាត់មិនត្រូវ

[2115] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ៣២ បន្ទាត់ ៦-២០។

[2116] បញ្ជីឈ្មោះអ្នកទោសចូលថ្ងៃទី ២៨.១០.១៩៧៨ ឯកសារ **E3/8551** ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៧៨ ERN (KH) 00086991 (ដែល ជុំ ម៉ី ស្ថិតនៅលេខរៀងទី ៧ អាយុ ៤៧ ឆ្នាំ "សមាជិកកងធំ កាត់ដេរ គ.៩"។ ឈ្មោះអ្នកទោស ផ្នែកកងពល ២០៧ "អតីត ៣១០" ឯកសារ **E3/9898** (គ្មានកាលបរិច្ឆេទ) ERN (KH) 01011228 (ជុំ ម៉ី ស្ថិតក្នុងផ្នែកកាត់ដេររដ្ឋ លេខរៀងទី ១ អាយុ ៤៧ ឆ្នាំ "ប្រធានកងពលធំ សមាជិកកងពលធំ" ចូលនៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៧៨)។ ឈ្មោះអ្នកទោសប្រចាំខែ តុលា ឆ្នាំ ១៩៧៨ ឯកសារ **E3/10205** ERN (KH) 01016477 (ជុំ ម៉ី ស្ថិតនៅលេខរៀងទី ៦ អាយុ ៤៧ ឆ្នាំ សមាជិកកងធំ ចូលនៅថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៧៨។ ចម្លើយសារភាពរបស់ ជុំ ម៉ាញ ឯកសារ **E3/9253** ឯកសារចុះថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨ ERN (KH) 00170541-00170585។ កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្ដី "ឌុច" ថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ២០០៩ ឯកសារ **E3/7451** ERN (KH) 00347916-00347995។

[2117] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ១៥-១៦ បន្ទាត់ ២៣-៦។

[2118] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ១៧-១៨ បន្ទាត់ ២២-១។

[2119] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ១៨ បន្ទាត់ ១១-១៨។

[2120] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ១៨ បន្ទាត់ ២២-២៥។

ការឧបករណ៍ទាំងនោះទេ គឺគេនឹងបញ្ជូនវាទៅតាមក្រោយ[2121]។ ឡុំប្រីតាបានឈប់នៅកន្លែងមួយ ដែលដើមបណ្តឹងរដ្ឋប្បវេណីមិនស្គាល់ឈ្មោះ ដែលនៅទីនោះគាត់និងអ្នកដទៃទៀតពីរនាក់ ត្រូវបានគេដាក់ខ្នោះនិងចងមុខ[2122]។ អ្នកដែលដាក់ខ្នោះគាត់គឺសុទ្ធតែជាមនុស្សប្រុស រួមទាំងសមមិត្តលីម[2123]។ ពួកគេមានកាំភ្លើងខ្លី[2124]។ គាត់ត្រូវគេដេរប្រមាថ និងគម្រាមកំហែង[2125]។

1010. ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី បានផ្តល់សក្ខីកម្មថា នៅពេលដែលគាត់មកដល់មន្ទីរស-២១ គាត់ត្រូវបានគេបញ្ជូនទៅបន្ទប់មួយ ដែលនៅទីនោះគេវាស់កម្ពស់គាត់ ថតរូបគាត់ ដោះសម្លៀកបំពាក់គាត់ និងដាក់ខ្នោះគាត់[2126]។ បន្ទាប់មកគាត់ត្រូវគេបញ្ជូនទៅបន្ទប់០២២[2127]។ បន្ទប់នេះមានទំហំ១ម៉ែត្រកន្លះ គុណពីរម៉ែត្រ[2128]។ សហចៅក្រមស៊ើបអង្កេតបានទៅពិនិត្យមើលបន្ទប់នោះ ហើយរូបថតមាននៅក្នុងកំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេត ដល់ទីកន្លែងកើតហេតុ[2129]។ បន្ទប់នេះគឺ

[2121] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ១៨ បន្ទាត់ ២២-២៥។

[2122] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ១៩ បន្ទាត់ ១០-១៥។

[2123] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ១៩ បន្ទាត់ ១៧-២០។

[2124] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ១៩ បន្ទាត់ ២១។

[2125] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ២០ បន្ទាត់ ២- ៥។

[2126] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ២០ បន្ទាត់ ១០-១៣។

[2127] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ២០ បន្ទាត់ ១២-១៣។

[2128] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ២១ បន្ទាត់ ២-៥។

[2129] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ២១ បន្ទាត់ ៥-៧។

ល្មមសម្រាប់តែមនុស្សម្នាក់ប៉ុណ្ណោះ[2130]។ គាត់លែងត្រូវគេចង់មុខ ហើយគេឱ្យកេសគ្រាប់តូចមួយមកគាត់ សម្រាប់បន្ទោរបង់[2131]។ ដើមបណ្ដឹងរដ្ឋប្បវេណី ទទួលបានបបរវាវមួយវែក នៅពេលព្រឹកនិងពេលល្ងាច ហើយនឹងទឹកបន្តិចបន្តួចប៉ុណ្ណោះសម្រាប់ផឹក[2132]។

1011. ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី បានរៀបរាប់ថា គាត់ត្រូវបានគេវាយ និងសួរចម្លើយអស់រយៈពេល ១២ថ្ងៃ ១២យប់ ចាប់ពីម៉ោង៧ព្រឹកដល់១១ព្រឹក និងពីម៉ោង១រសៀល ដល់ម៉ោង៥រសៀល និងពីម៉ោង៦ល្ងាចដល់ម៉ោង១០ល្ងាច[2133]។ បន្ទប់ដែលគេសួរចម្លើយគាត់គឺនៅជាន់លើ នៅខាងត្បូងបន្ទប់ឃុំខ្លួនគាត់[2134]។ នៅពេលក្រោយមកទើបគាត់ដឹងថា បន្ទប់នោះគេហៅថាបន្ទប់លេខ៤[2135]។ ក្នុងពេលសួរចម្លើយ ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានគេសួរថា គាត់គឺជាខ្សែបណ្ដាញរបស់សេអ៊ីអា ឬកាហ្សេបេមែនទេ។ គាត់ត្រូវគេវាយ ដែលបណ្ដាលឱ្យបាក់ម្រាមដៃ ក្រចកជើងគាត់ត្រូវបានគេដក ហើយអ្នកសួរចម្លើយបានឆក់ខ្សែភ្លើងគាត់ពីរដង ដែលធ្វើឱ្យគាត់សន្លប់លែងដឹងខ្លួន[2136]។ ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី បានពន្យល់ថា ភ្នែកគាត់ម្ខាងមើលមិនច្បាស់ទេ ហើយត្រចៀកម្ខាងក៏ស្ដាប់មិនឮច្បាស់ដែរ តាំងពីពេលដែលគេឆក់ខ្សែភ្លើងគាត់មក[2137]។

---

[2130] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ២២ បន្ទាត់ ១៥។

[2131] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ២២ បន្ទាត់ ២០-២៤។

[2132] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ២៣ បន្ទាត់ ៥-៨។

[2133] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ២៣ បន្ទាត់ ៩-១៤។

[2134] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ២៣ បន្ទាត់ ១៦-១៩។

[2135] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ២៣ បន្ទាត់ ២០។

[2136] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ២៦ បន្ទាត់ ២-១៣។

[2137] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ២៦ បន្ទាត់ ១៤-២១។

1012. បន្ទាប់មកដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានឃុំខ្លួននៅក្នុងបន្ទប់ធំមួយនៅអគារ គ ជាមួយអ្នកជាប់ឃុំដទៃទៀតជាច្រើន[2138]។ នៅពេលដែលគាត់ត្រូវបានឃុំខ្លួននៅទីនោះ អ្នកជាប់ឃុំត្រូវបានគេដាក់ឃ្នាង[2139]។ ពួកគេទទួលបានត្រឹមបបរមួយវែក នៅពេលព្រឹកនិងពេលល្ងាច ហើយនឹងអារដៃវែង[2140]។ អ្នកជាប់ឃុំដេកផ្ទាល់លើកម្រាល ហើយកេសគ្រាប់ត្រូវបានគេផ្ដល់ ទៅឱ្យអ្នកជាប់ឃុំដើម្បីបន្ទោរបង់ ហើយគេតម្រូវឱ្យអ្នកជាប់ឃុំនៅស្ងៀមស្ងាត់[2141]។

1013. ដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានសមមិត្តសួស ធី ចាត់តាំងឱ្យជួសជុលម៉ាស៊ីនដេរ នៅខាងក្រោយនិងខាងលិចអគារ ដែលគាត់ជាប់ឃុំនោះ[2142]។ ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី បានរៀបរាប់អំពីការដែល សួស ធី ចាត់តាំងគាត់ និងការដែលគេហាមគាត់មិនឱ្យរត់[2143]។ នៅព្រឹកបន្ទាប់ សួស ធី បានត្រឡប់មកវិញហើយប្រគល់ខោអាវឱ្យគាត់ស្លៀកពាក់ ហើយយកគាត់ទៅអគារក្រោយ ដើម្បីជួសជុលម៉ាស៊ីនដេរ[2144]។ បន្ទាប់មកគាត់ត្រូវបានគេចាត់តាំង ឱ្យទៅជួសជុលអង្គុលីលេខ[2145]។

---

[2138] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ២៨-២៩ បន្ទាត់ ១៥-៥។

[2139] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ២៨-២៩ បន្ទាត់ ១៨-៥។

[2140] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ២៩ បន្ទាត់ ៦-៩។

[2141] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ២៩-៣០ បន្ទាត់ ១៧-១។

[2142] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ៣០ បន្ទាត់ ៩-១៣។

[2143] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៧ ឯកសារ E1/418.1 ទំព័រ ៣៨ បន្ទាត់ ៤-៩។

[2144] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៧ ឯកសារ E1/418.1 ទំព័រ ៣៨ បន្ទាត់ ៩-២១។

[2145] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ៣០ បន្ទាត់ ៣-៦។

ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មថា គាត់មិនត្រូវរត់គេចទេ បើមិនដូច្នេះទេគេនឹងបាញ់គាត់[2146]។

1014. ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី បានផ្ដល់សក្ខីកម្មថា គាត់អាចរស់បានដោយសារតែ ជំនាញរបស់គាត់ក្នុងការជួសជុលអង្គុលីលេខ ហើយនិងការមកដល់របស់កងទ័ពវៀតណាម[2147]។ ដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានគេដោះលែងពីមន្ទីរស-២១ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩[2148]។

1015. បន្ថែមពីលើសក្ខីកម្មផ្ទាល់របស់ ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី អំពីបទពិសោធន៍របស់គាត់ ដែលរួចផុតជីវិតពីមន្ទីរស-២១នោះ ដើមបណ្ដឹងរដ្ឋប្បវេណីប្រាំបីនាក់ទៀត បានអះអាងពីវត្តមានសមាជិកគ្រួសាររបស់ពួកគាត់ ដែលត្រូវបានឃុំខ្លួន ហើយបន្ទាប់មកត្រូវបានសម្លាប់នៅទីនោះ។

1016. ដើមបណ្ដឹងរដ្ឋប្បវេណី ឆែ ហ៊ាប ដែលស្ថិតនៅក្នុងកងកុមារ នៃកងពល៣១០ បានផ្ដល់សក្ខីកម្មអំពីការឃុំខ្លួន និងការសម្លាប់បងប្រុសរបស់កាត់ ឈ្មោះ ឆែ ហេង នៅមន្ទីរសន្តិសុខស-២១។ ឆែ ហេង ស្ថិតនៅក្នុងកងពលធំ៣១០ ហើយគាត់ត្រូវបានគេចោទប្រកាន់ថាក្បត់អង្គការ។ ឈ្មោះរបស់ ឆែ ហេង ត្រូវបានកត់ត្រានៅក្នុងបញ្ជី អ្នកទោសដែលត្រូវបាននាំយកមកមន្ទីរស-២១ នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅត្រង់លេខរៀងទី១៥[2149] ហើយប្រវត្តិរូបនៅមន្ទីរស-២១របស់គាត់ស្ថិតនៅក្នុងសំណុំរឿង ដែលកត់ត្រាថាគាត់ត្រូវបានឃុំខ្លួន នៅថ្ងៃ ទី១២ ខែកុម្ភៈ ឆ្នាំ១៩៧៧[2150]។ រូបថតរបស់ ឆែ ហេង មាននៅលើឯកសារច្បាប់ដើម[2151]។

[2146] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ៣០ បន្ទាត់ ៧។

[2147] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ៣១-៣២ បន្ទាត់ ២៤-៥។

[2148] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ៣២ បន្ទាត់ ១៤-២០។

[2149] បញ្ជីឈ្មោះអ្នកទោសចូលថ្ងៃ ១-២៨/២/៧៧ ឯកសារ **E3/10266** ERN (KH) 01016893។

[2150] ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំងនៅគុក ទួលស្លែង ឆែ ហេង ឯកសារ **E3/2989** គ្មានកាលបរិច្ឆេទ ERN (KH) 00211264-00211264។

[2151] ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំងនៅគុក ទួលស្លែង ឆែ ហេង ឯកសារ **E3/2989** គ្មានកាលបរិច្ឆេទ ERN (KH) 00211264-00211264។

1017. ដើមបណ្តឹងរដ្ឋប្បវេណី បានផ្តល់សក្ខីកម្មថា នៅលើកទីពីរដែលគាត់មកលេង បងប្រុសរបស់គាត់នោះ តាហាន ដែលជាអ្នកបើកឡានបានប្រាប់គាត់ថា ផៃ ហេង ត្រូវបានអង្គការចាប់ខ្លួន ហើយថាគាត់គឺជាប្អូនប្រុសជនក្បត់[2152]។ ដើមបណ្តឹងរដ្ឋប្បវេណី ផៃ ប៉ាប បានផ្តល់សក្ខីកម្មបន្ថែមថា ក្រោយពេលដែលបងប្រុសគាត់បាត់ខ្លួន សមាជិកដទៃទៀតនៅកងពល៣១០ ក៏បានបាត់ខ្លួនផងដែរ។ ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា នៅពេលតាញ៉ មកជំនួសតាអឿន ដែលបានបាត់ខ្លួនដែរនោះ[2153] "គេ"និយាយថា កងពលបានក្បត់អង្គការ ហើយពួកគេត្រូវបញ្ជូនទៅរៀនសូត្រ នៅក្បែរវត្តភ្នំ ព្រោះពួកគេត្រូវបានចោទប្រកាន់ថា បានរៀបចំប្រុងបះបោរ[2154]។ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា ការចាប់ខ្លួនធ្វើទៅដោយជោគជ័យ ដោយចាប់ខ្លួនម្តងមួយៗ[2155]។ ដើមបណ្តឹងរដ្ឋប្បវេណី ផៃ ប៉ាប បានផ្តល់សក្ខីកម្មថា គាត់មិនបានដឹងអំពីផែនការបះបោរណាមួយ ឬបានគាំទ្រដល់ការធ្វើរដ្ឋប្រហារឡើយ[2156]។

1018. ដើមបណ្តឹងរដ្ឋប្បវេណី ភ្លូង យ៉ាត បានផ្តល់សក្ខីកម្មអំពីអង្គហេតុ នៃបងទាំងបួននាក់របស់គាត់គឺ ភ្លូង អ៊ីម ភ្លូង វ៉េត ភ្លូង ផុន និង ភ្លូង ផែន ដែលគាត់បានបែកតាំងពីឆ្នាំ ១៩៧៥។ ដើមបណ្តឹងរដ្ឋប្បវេណី បានផ្តល់សក្ខីកម្មថា ពីឆ្នាំ១៩៧៥ បងរបស់គាត់បានចូលធ្វើកងទ័ពនៅស្វាយទាប។ បងគាត់ពីរនាក់បានបាត់ខ្លួន ហើយបងស្រីរបស់គាត់ឈ្មោះ ភ្លូង អ៊ឹម ត្រូវបានគេប្រាប់ឱ្យទៅ

---

[2152] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ផៃ ប៉ាប ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ២១-២២ បន្ទាត់ ២១-១។

[2153] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ផៃ ប៉ាប ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ២១ បន្ទាត់ ៤-១០។

[2154] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ផៃ ប៉ាប ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ២១ បន្ទាត់ ១១-១៦។

[2155] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ផៃ ប៉ាប ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ២១ បន្ទាត់ ១៩។

[2156] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ផៃ ប៉ាប ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៣០ បន្ទាត់ ១៥-១៩។

ភ្នំពេញ ហើយដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា គាត់លែងបានទទួលព័ត៌មានអ្វី ពីបងស្រីរបស់គាត់ទៀត[2157]។

1019. គាត់បានពន្យល់ថា ស្ត្រីម្នាក់ឈ្មោះវ៉េត បានប្រាប់ម្តាយរបស់គាត់នៅក្រោយឆ្នាំ១៩៧៩ថា បងស្រីរបស់គាត់រស់នៅភ្នំពេញ ហើយមានកូនពីរនាក់[2158]។ ដើមបណ្តឹងរដ្ឋប្បវេណីគ្រាន់តែបានដឹងថា ប្តីរបស់បងស្រីគាត់គឺជាកម្មាភិបាលនៅភ្នំពេញ ដោយស្ថិតនៅក្នុងកងជាងអគ្គីសនី ហើយថាបងស្រីរបស់គាត់នៅក្នុងអង្គភាពកាត់ដេរ ហើយថាបងស្រីរបស់គាត់បាត់ខ្លួន ដោយលែងមានព័ត៌មានអ្វីទៀត[2159]។ ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត បានពន្យល់ថា ក្រោយឆ្នាំ១៩៧៩ ក្មួយរបស់គាត់បានទៅភ្នំពេញ ហើយបានប្រាប់គាត់ថា បងរបស់គាត់បានស្លាប់នៅទួលស្លែង[2160]។ ដើមបណ្តឹងរដ្ឋប្បវេណីបានទៅទួលស្លែង ហើយបានឃើញរូបថតរបស់ពួកគាត់ ត្រូវគេដាក់តាំងបង្ហាញ[2161]។ ចំពោះកូនស្រីពីរនាក់របស់ ភួង អ៊ុម វិញ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា គាត់មិនបានដឹងថាមានអ្វីកើតឡើង ចំពោះពួកគេនោះឡើយ ដោយគាត់គ្រាន់តែដឹងថា បងស្រីរបស់គាត់មានកូនស្រីពីរនាក់ ហើយពួកគេបានបាត់ខ្លួន ហើយថាក្រុមគ្រួសាររបស់គាត់ មិនបានទទួលព័ត៌មានអ្វីពីពួកគេឡើយ[2162]។

1020. ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត បានអះអាងនៅក្នុងពេល ផ្តល់សក្ខីកម្មរបស់គាត់ អំពីឈ្មោះរបស់បងគាត់ពីរនាក់គឺ ភួង អ៊ុម និង ភួង ផុន នៅក្នុងបញ្ជីឈ្មោះអ្នកទោសទួលស្លែង។ ភួង អ៊ុម

---

[2157] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៣៦ បន្ទាត់ ១៥-២០។

[2158] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៣៦-៣៧ បន្ទាត់ ២១-១។ ទំព័រ ៤៥ បន្ទាត់ ១១-១៤។

[2159] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៤៥ បន្ទាត់ ១៦-២១។

[2160] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៣៧ បន្ទាត់ ២-៨។

[2161] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៣៧ បន្ទាត់ ២-៨។

[2162] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៤៦ បន្ទាត់ ២-៦។

ត្រូវបានឃុំខ្លួននៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧៨ ហើយសម្លាប់នៅថ្ងៃ១១ ខែធ្នូ ឆ្នាំ១៩៧៨[2163]។ ភួង ផុន ត្រូវបានឃុំខ្លួននៅថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៧៧ ហើយសម្លាប់នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៧៧[2164]។ ដើមបណ្ដឹងរដ្ឋប្បវេណី ភួង យ៉ាត បានកំណត់ពីរូបថតបងគាត់ ដែលថតនៅមុនរបប និងរូបថតពួកគេមកពីមន្ទីរស-២១[2165]។

1021. ដើមបណ្ដឹងរដ្ឋប្បវេណី រស់ ជួរស៊ីអ៊ី ដែលបានវិលត្រឡប់មកប្រទេសកម្ពុជាពីប្រទេសបារាំងជាមួយនឹងស្វាមីរបស់គាត់ រស់ សារិន និងកូនស្រីបីនាក់នៅថ្ងៃទី៦ ខែសីហា ឆ្នាំ១៩៧៦[2166] បានផ្ដល់សក្ខីកម្មអំពីការបាត់ខ្លួនស្វាមីរបស់គាត់ពីបឹងត្របែក និងអំពីការរកឃើញរូបថតគាត់នៅសារមន្ទីរទួលស្លែងក្រោយពេលដួលរលំរបបនោះ[2167]។ គាត់បានផ្ដល់សក្ខីកម្មថា នៅប្រហែលពាក់កណ្ដាលខែធ្នូ ឆ្នាំ១៩៧៦ នៅក្នុងវគ្គរៀនសូត្រនយោបាយនៅបឹងត្របែក ស្វាមីរបស់គាត់បានប្រញាប់ប្រញាល់មកប្រាប់គាត់ថា ស្វាមីគាត់ត្រូវបានអង្គការឲ្យធ្វើបំពេញការងារ។ ដើមបណ្ដឹងរដ្ឋប្បវេ

---

[2163] បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ ក.ស.ច.ស ឯកសារ **E3/10604** ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ERN 01222901 (យោងទៅ 00086769-00086769)។ បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស២១ (កែសម្រួល) (ក.ស.ព) ឯកសារ **E3/342** ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ ERN (EN-KH) 00329929។ ឧបសម្ព័ន្ធ ២៧៧ ៖ បញ្ជីឈ្មោះអ្នកទោសដែលត្រូវបានសួរចម្លើយនៅមន្ទីរ ស-២១ ឯកសារ **E3/8555** ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ១៩៧៨ ERN (KH) 01460938។

[2164] បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ ក.ស.ច.ស ឯកសារ **E3/10604** ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ERN 01222434 (យោងទៅ 01019293-01019436)។ បញ្ជីឈ្មោះអ្នកទោសដែលចូលចាប់ពីថ្ងៃ ១៧/២-១៧/៤/៧៧ ឯកសារ **E3/10506** ERN (KH) 01019316។ បញ្ជីឈ្មោះអ្នកទោសដែលចូលក្នុងខែ មីនា ឆ្នាំ ១៩៧៧ ឯកសារ **E3/9845** ERN (KH) 01010288។ បញ្ជីឈ្មោះអ្នកទោសកំទេចនៅឆ្នាំ ១៩៧៧ ឯកសារ **E3/2286** ERN (KH) 00873451។ បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ (កែសម្រួល) (ក.ស.ព) ឯកសារ **E3/342** ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ ERN (EN-KH) 00329929។

[2165] ព័ត៌មានបន្ថែមរបស់អ្នកសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ឯកសារ **D22/3397b** (កែតម្រូវ ១) ERN (KH) 00594299-00594310។ រូបថតរបស់ ភួង យ៉ាត ក្នុង ERN (KH) 00594310។ រូបថតបងស្រីរបស់ ភួង យ៉ាត ដែលបានថតក្នុងសម័យសង្គមរាស្ត្រនិយម ក្នុង ERN (KH) 00594302។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៣៧-៣៨ បន្ទាត់ ៩-៧។ រូបថតរបស់ ភួង ផុន នៅមន្ទីរ ស-២១ ក្នុង ERN (KH) 00594301។ *សូមមើល*សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៤១ បន្ទាត់ ៦-១៩។

[2166] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី រស់ ជួរស៊ីអ៊ី ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៦២ បន្ទាត់ ១-២។

[2167] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី រស់ ជួរស៊ីអ៊ី ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៦៨ បន្ទាត់ ២៣-១០។

ណីបានពន្យល់ថា នៅពេលគាត់សួរថាតើគេឱ្យស្វាមីគាត់ទៅណា ស្វាមីគាត់ប្រាប់គាត់ថា វាជាការសម្ងាត់ ហើយអង្គការពុំប្រាប់គាត់ថាគាត់នឹងទៅណានោះទេ។ មុនពេល រស់ សារិន ចាកចេញ គាត់បានប្រាប់ភរិយាគាត់ឱ្យខំប្រឹងធ្វើការងារ ឱ្យមើលថែខ្លួន និងកូន ហើយបានប្រាប់ភរិយាគាត់កុំឱ្យបារម្ភ ហើយពួកគេនឹងបានជួបគ្នាវិញក្នុងពេលឆាប់ៗខាងមុខ[2168]។

1022. ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះបានបញ្ជាក់លើរូបថតស្វាមីរបស់គាត់នៅ ស-២១ ដែលបានដាក់ភ្ជាប់ជាមួយនឹងពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់[2169]។ ដើមបណ្តឹងរដ្ឋប្បវេណី រស់ ជួរស៊ីអ៊ី ត្រូវបានឱ្យមើលឈ្មោះស្វាមីរបស់គាត់ក្នុងចំណោមបញ្ជីឈ្មោះអ្នកទោសដែលវិលត្រឡប់មកពីប្រទេសបារាំងវិញ[2170]។ ឈ្មោះនេះមាននៅក្នុងលេខរៀងទី៦ ហើយបានបញ្ជាក់កាលបរិច្ឆេទចូល ស-២១ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៦[2171]។ ឈ្មោះរបស់គាត់ឃើញមាននៅក្នុងបញ្ជីឈ្មោះអ្នកទោសផ្សេងទៀតដែលត្រូវបានកំទេចនៅទួលស្លែងនៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧៧[2172]។ ឈ្មោះស្វាមីគាត់ឃើញនៅក្នុងលេខរៀងទី៥៦[2173]។

1023. ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ទរ៉ា បានផ្តល់សក្ខីកម្មអំពីការឃុំខ្លួន និងការកាប់សម្លាប់បងរបស់គាត់ឈ្មោះ ជឹម ឡាង និងបងថ្លៃស្រីឈ្មោះ ឱម យិនដូនី នៅ ស-២១ នៅក្នុងឆ្នាំ១៩៧៦។ គាត់បាន

---

[2168] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រស់ ជួរស៊ីអ៊ី ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៦៣ បន្ទាត់ ៩ -១៣។

[2169] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រស់ ជួរស៊ីអ៊ី ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៦៧-៦៨ បន្ទាត់ ១៣-៤។ *សូមមើលផងដែរ* **E3/5040** ERN (KH) 00807825។

[2170] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រស់ ជួរស៊ីអ៊ី ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៦៨ បន្ទាត់ ៥-២២។ *សូមមើលផងដែរ* បញ្ជីឈ្មោះអ្នកទោសមកពីប្រទេសបារាំង ឯកសារ **E3/9853** ERN (KH) 01010573។

[2171] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រស់ ជួរស៊ីអ៊ី ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៦៨-៦៩ បន្ទាត់ ១៩-២។ *សូមមើលផងដែរ* បញ្ជីឈ្មោះអ្នកទោសមកពីប្រទេសបារាំង ឯកសារ **E3/9853** ERN (KH) 01010573។

[2172] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រស់ ជួរស៊ីអ៊ី ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៧២ បន្ទាត់ ៩-២៥។ *សូមមើលផងដែរ* បញ្ជីឈ្មោះអ្នកទោស ឯកសារ **E3/2285** ERN (KH) 00009179។

[2173] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រស់ ជួរស៊ីអ៊ី ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៧២ បន្ទាត់ ៩-២៥។ *សូមមើលផងដែរ* បញ្ជីឈ្មោះអ្នកទោស ឯកសារ **E3/2285** ERN (KH) 00009179។

ផ្តល់សក្ខីកម្មថា បងគាត់គឺជាវិស្វករអគ្គិសនីដែលធ្វើការនៅទីតាំងផ្សារតូច[2174] ហើយបងថ្លៃស្រីរបស់គាត់ក៏ធ្វើការនៅក្នុងនាយកដ្ឋានអគ្គិសនីជាមួយគ្នាដែរ[2175]។ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា គាត់បានដឹងជាមុនថា ពួកគេនឹងត្រូវបាននាំទៅកាន់ផ្សារតូច ប៉ុន្តែគាត់ពុំបានដឹងថាគេនឹងបញ្ជូនពួកគេទៅទួលស្លែងនៅពេលណានោះទេ[2176]។ នៅក្រោយពេលរបបខ្មែរក្រហមបានដួលរលំទើបគាត់បានដឹងពីសាច់ញាតិម្នាក់ថា ពួកគេត្រូវបានគេបញ្ជូនទៅទួលស្លែង[2177]។ ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ធរ៉ា បានពិពណ៌នាថាក្រោយមកគាត់បានទៅទួលស្លែង និងបានឃើញកាលបរិច្ឆេទដែលពួកគេបានចូលទីនោះកត់ត្រាទុកនៅក្នុងសៀវភៅមួយក្បាល[2178]។

1024. នៅក្នុងសក្ខីកម្មរបស់គាត់ ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ធរ៉ា បានបញ្ជាក់ឈ្មោះបងប្រុសគាត់ ជឹម ឡាង នៅក្នុងលេខរៀងទី៣០ ក្នុងបញ្ជីឈ្មោះអ្នកទោសពីផ្នែកអគ្គិសនីតាខ្មៅចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧៦[2179]។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះត្រូវបានបង្ហាញបញ្ជីឈ្មោះអ្នកទោសដែលមានចុះឈ្មោះ ឱម យិនដូនី នៅត្រង់លេខរៀងទី៤២ ដែលជាប្រពន្ធរបស់ ជឹម ឡាង ហើយចូល ស-២១ នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៧៦[2180]។ ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា នេះគឺជាឈ្មោះ

---

[2174] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ធរ៉ា ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៤១ បន្ទាត់ ១៩-២០។

[2175] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ធរ៉ា ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៤៨ បន្ទាត់ ៦-១៩។ ។

[2176] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ធរ៉ា ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៤៧ បន្ទាត់ ១៣-១៤។

[2177] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ធរ៉ា ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៤៧ បន្ទាត់ ១៤-១៥។

[2178] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ធរ៉ា ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៤៧ បន្ទាត់ ១៥-១៧។

[2179] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ធរ៉ា ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៤១ បន្ទាត់ ១០-២២។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ ៩ ៖ ឈ្មោះអ្នកទោត្រូវយកពីតាខ្មៅ ផ្នែក "អគ្គិសនី" ឯកសារ **E3/8607** ERN (KH) 0088716។

[2180] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ធរ៉ា ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៤២ បន្ទាត់ ១-១៦។ *សូមមើលផងដែរ* បញ្ជីឈ្មោះអ្នកទោសដែលចូលមកចាប់ពី ០១-១៥.១១.៧៦ ឯកសារ **E3/10061** ERN (KH) 01012805។

ឱម យិនដូនី[2181]។ ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ទរ៉ា បានបញ្ជាក់ថា ឈ្មោះរបស់បងថ្លៃស្រីគាត់ឃើញមាននៅក្នុងបញ្ជីឈ្មោះអ្នកទោសចូលនៅក្នុងឆ្នាំ១៩៧៦[2182] ថែមទៀត ហើយបានបញ្ជាក់បន្ថែមលើរូបថត និងប្រវត្តិរូប ស-២១ របស់បងថ្លៃស្រីគាត់ទៀត ព្រមទាំងការឃុំខ្លួនបងថ្លៃស្រីនៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៧៦[2183]។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់លើឈ្មោះ ឱម យិនដូនីនៅក្នុងបញ្ជីឈ្មោះអ្នកទោសដែលបានសម្លាប់ចោលនៅក្នុងឆ្នាំ១៩៧៦ ដោយបានបញ្ជាក់ថា គាត់ត្រូវបានគេសម្លាប់ចោលនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៧៦[2184]។

1025. ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ទរ៉ា បានផ្តល់សក្ខីកម្មអំពីការឃុំខ្លួន និងការកាប់សម្លាប់បងរបស់គាត់ឈ្មោះ ចៅ សេង នៅ ស-២១។ ដើមបណ្តឹងរដ្ឋប្បវេណីបានពិពណ៌នាប្រវត្តិរូបនយោបាយរបស់ ចៅ សេង ថា បងប្រុសរបស់គាត់កាន់មុខនាទីថ្នាក់ខ្ពស់ៗជាច្រើននៅក្នុងជួររដ្ឋាភិបាលចាប់ពីឆ្នាំ១៩៥៨ ហើយជិតស្និទ្ធនឹងសម្តេចសីហនុ[2185]។ ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឃឹម បានផ្តល់

---

[2181] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ទរ៉ា ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៤២ បន្ទាត់ ១៦។

[2182] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ទរ៉ា ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៤២ បន្ទាត់ ១-១៦។ *សូមមើលផងដែរ* បញ្ជីឈ្មោះអ្នកទោសដែលចូលមកមន្ទីរ ស-២១ ក្នុងឆ្នាំ ១៩៧៦ ឯកសារ **E3/9842** ERN (KH) 01009935។

[2183] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ទរ៉ា ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៤៣ បន្ទាត់ ២-១៣។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ ៥ ៖ ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំងនៅគុកទួលស្លែង អោម យិនដូននី ឯកសារ **D22/18/5** ERN (KH) 00211408។

[2184] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ទរ៉ា ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៤៨ បន្ទាត់ ៦-១៩។ *សូមមើលផងដែរ* បញ្ជីឈ្មោះអ្នកទោសកំទេចឆ្នាំ ១៩៧៦ ឯកសារ **E3/3187** ERN (KH) 00008844។

[2185] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឃឹម ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៥៤ បន្ទាត់ ៣-១១។ ("ឆ្នាំ ១៩៥៨ ជាប្រធានការិយាល័យគណៈរដ្ឋមន្ត្រី សេហ្វដឺកាប៊ីនេ អូប្រេស៊ីដង់ ឡឺកុងសី។ រួចតំណាងរាស្ត្រភ្នំពេញ ជាអនុប្រធានរដ្ឋសភា។ ឆ្នាំ ១៩៥៨ ទៅ ៦០ ជារដ្ឋលេខាធិការក្រសួងអប់រំ។ ឆ្នាំ ១៩៦០ ទៅ ៦២ ជារដ្ឋមន្ត្រីក្រសួងឃោសនាការ។ ពងី ៦២ ទៅ ៦៤ ជារដ្ឋមន្ត្រីពាណិជ្ជកម្ម--កសិកម្ម។ ពី ៦៤ ទៅ ៦៦ ជាប្រធានការិយាល័យសម្តេចសីហនុ ព្រះមុខរដ្ឋ--សេហ្វដឺកាប់ប៊ីនេ ដឺសម្តេចសីហនុ សេហ្វ ដឺឡេតា។ ១៩៦៧ ជាទេសរដ្ឋមន្ត្រីក្រសួងកសិកម្ម--អ! ពាណិជ្ជកម្ម និងសេដ្ឋកិច្ចពីឆ្នាំ ១៩៥៨ ទៅ ៦២។ រួចពី ៦២ ទៅ ៦៦ គាត់បានជាប់ជាតំណាងរាស្ត្រពីរអាណត្តិ។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឃឹម ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៥៤ បន្ទាត់ ១៤-១៦ ("ដល់ឆ្នាំ ៦៨ ទៅ ៧០ គាត់បានភៀសខ្លួនទៅប្រទេសបារាំង ដោយសារមានការគំរាមកំហែងពី លន់ នល់។ ពី ៧៥--

សក្ខីកម្មថា គាត់បានរកឃើញឯកសារជាច្រើននៅ ស-២១ និងមជ្ឈមណ្ឌលឯកសារកម្ពុជាពាក់ព័ន្ធនឹងបងប្រុសគាត់។ ដើមបណ្ដឹងរដ្ឋប្បវេណី ចៅ ឃីម បានបញ្ជាក់ថា ចម្លើយសារភាពរបស់ ចៅ សេង មាននៅក្នុងសំណុំរឿង ត្រូវបានបង្ហាញជាឯកសារនៅក្នុងតុលាការ ហើយគាត់បានទទួលស្គាល់សំណេររបស់បងប្រុសគាត់[2186]។ ចម្លើយសារភាពនេះបញ្ជាក់ថា ចៅ សេង បានវិលត្រឡប់មកប្រទេសកម្ពុជាវិញនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៥ ហើយគាត់ត្រូវបានគេចាប់ខ្លួននៅក្នុងខែវិច្ឆិកា ឆ្នាំ១៩៧៧[2187]។

1026. គាត់បានផ្ដល់សក្ខីកម្មថា ចៅ សេង ត្រូវបានសម្ដេច ប៉ែន នុត ហៅត្រឡប់មកប្រទេសកម្ពុជាវិញ ដើម្បីជួយចាត់ចែងការតស៊ូប្រឆាំងនឹង លន់ នុល ក្រោយពេលរដ្ឋប្រហារបានកើតឡើងនៅក្នុងឆ្នាំ១៩៧០[2188]។ ក្រោយមក គាត់ត្រូវបានគេបញ្ជូនទៅភូមិភាគបូព៌ា[2189]។ នៅក្នុងខែសីហា ឆ្នាំ១៩៧៦ គាត់ត្រូវបានគេបញ្ជូនទៅផ្នែកសេដ្ឋកិច្ចក្រោមការត្រួតពិនិត្យរបស់ក្រសួងការបរទេសនៅពេលគាត់បានក្លាយជាអនុប្រធាន[2190]។ គាត់បានលើកឡើងថា ចៅ សេង "ជាប់នៅធ្វើរដ្ឋមន្ត្រីរហូត១០ឆ្នាំ ហើយគាត់បានធ្វើច្រើន ជួយច្រើន។ ...គាត់បង្កើតសាលាដើម្បីបង្ហាត់បង្រៀន ប្រហែលសិរ ពួកនែ ពួកសាស្ត្រាចារ្យ ហើយគាត់ខាង -- កាលគាត់នៅកសិកម្ម គាត់បានធ្វើកិច្ចការច្រើន គាត់

---

៧០ ទៅ ៧៥ គាត់ជារដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេសរបស់រដ្ឋាភិបាលរណសិរ្សរួបរួមជាតិកម្ពុជា ក្រោមការដឹកនាំរបស់សម្ដេចសីហនុ")។

[2186] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ចៅ ឃីម ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៦៤-៦៥ បន្ទាត់ ២៥-២៣។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ ៖ ចម្លើយសារភាពរបស់អ្នកទោសនៅមន្ទីរ ស-២១ ចិន សួន (ចៅ សេង) ឯកសារ **E3/10609** ERN (KH) 00246843។

[2187] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ចៅ ឃីម ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៦៤-៦៥ បន្ទាត់ ២៥-២៣។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ ៖ ចម្លើយសារភាពរបស់អ្នកទោសនៅមន្ទីរ ស-២១ ចិន សួន (ចៅ សេង) ឯកសារ **E3/10609** ERN (KH) 00246843។

[2188] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ចៅ ឃីម ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៥៧ បន្ទាត់ ២-៣។

[2189] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ចៅ ឃីម ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៥២-៥៣ បន្ទាត់ ២៥-១។

[2190] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ចៅ ឃីម ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៥២-៥៣ បន្ទាត់ ២៥-១-៥។

ធ្វើបានច្រើនណាស់"[2191]។ នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៧ គាត់ត្រូវបានគេបញ្ជូនទៅបឹងត្របែក[2192]។ ក្រោយមក គាត់ត្រូវបានចាប់ខ្លួនបញ្ជូនទៅ ស-២១[2193] ហើយសម្លាប់ចោលនៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៨[2194]។

1027. ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឃឹម បានពន្យល់ថា បងរបស់គាត់បានចូលរួមចំណែកជាមួយនឹងចលនាខ្មែរក្រហមដោយសារគាត់បានទៅប្រទេសនានាថ្លែងក្នុងនាមចលនានេះ[2195]។ ពាក់ព័ន្ធនឹងទំនាក់ទំនងរវាង ចៅ សេង និងមេដឹកនាំខ្មែរក្រហម ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា ចៅ សេង គឺជាមិត្តភ័ក្តិជិតស្និទ្ធិជាមួយនឹង ខៀវ សំផន ហើយពួកគេបានជួបគ្នានៅពេលពួកគេរៀនច្បាប់នៅក្នុងសាកលវិទ្យាល័យជាមួយគ្នានៅទីក្រុងម៉ុងប៉េលីយេក្នុងឆ្នាំ១៩៥៨[2196]។

1028. ដើមបណ្តឹងរដ្ឋប្បវេណី ខៀវ នាប បានផ្តល់សក្ខីកម្មអំពីការចាប់ខ្លួន និងការសម្លាប់ប្តីរបស់គាត់ឈ្មោះ ខេង ជី ហៅ ជីន[2197] និងសមមិត្តរបស់គាត់ឈ្មោះ យ៉េ និង រុន នៅ ស-២១។ ដើមបណ្តឹង

---

[2191] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឃឹម ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៥៨ បន្ទាត់ ១៨-២១។

[2192] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឃឹម ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៥៣ បន្ទាត់ ៤-៥។

[2193] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឃឹម ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៥៤-៥៥ បន្ទាត់ ២០-៧។

[2194] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឃឹម ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៥៣ បន្ទាត់ ១២-១៤។

[2195] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឃឹម ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៥៧ បន្ទាត់ ៣-៦។

[2196] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឃឹម ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៦៧ បន្ទាត់ ២១-២២។ ។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឃឹម ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៦៨ បន្ទាត់ ២-៥។

[2197] ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា "ឈ្មោះពីកំណើតមក ខេង ជឿន ជីតាគាត់ឈ្មោះ គង់។ អូ! សូមទោស ខេង ជី-ខេង ជី ចូលបដិវត្តន៍គេហៅ ខេង ជីន តែជីតាគាត់ឈ្មោះ គង់-គង់ ជី" (សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ខៀវ នាប ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៣៤ បន្ទាត់ ១២-១៣។ *សូមមើលផងដែរ* ទំព័រ ៥៤ បន្ទាត់ ៨-៩)។ ប្រធានអង្គជំនុំបានថ្លែងសង្ខេបថា "ឈប់! ឈប់! ឥឡូវខ្មែរបើខ្ញុំសរុបមក គ្រប់គ្រាន់ហើយ។ ឈ្មោះ គង់ ហ៊្នឹង គឺឈ្មោះជីតា ឈ្មោះ ខេង ហ៊្នឹង ឈ្មោះឪពុកបង្កើតរបស់ប្តីគាត់ ដែលគាត់ភ្ជាប់ជាមួយនឹងឈ្មោះឪពុក--ជាមួយប្តីគាត់ទេ បាន

រដ្ឋប្បវេណីរូបនេះបានបញ្ជាក់ឈ្មោះប្ដីរបស់គាត់ និងបុគ្គលបីនាក់ទៀតនៅក្នុងបញ្ជីឈ្មោះអ្នកទោសដែលត្រូវបានសម្លាប់ចោលនៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨[2198]។ បញ្ជីនេះបញ្ជាក់ថា ពួកគេត្រូវបានចាប់ខ្លួននៅក្នុងខែធ្នូ ឆ្នាំ១៩៧៨ ហើយដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ជាក់ឈ្មោះប្ដីរបស់គាត់នៅត្រង់លេខរៀងទី ១៤[2199]។ ស្វាមីរបស់ដើមបណ្ដឹងរដ្ឋប្បវេណីឃើញនៅត្រង់លេខរៀងទី ១២៨៣១ ក្នុងបញ្ជីឈ្មោះអ្នកទោសរបស់ ក.ស.ច.ស[2200]។ ដើមបណ្ដឹងរដ្ឋប្បវេណី ខៀវ នាប បានផ្ដល់សក្ខីកម្មថា ស្វាមីរបស់គាត់ធ្វើការងារជញ្ជូនសម្ភារៈផ្គត់ផ្គង់ជូនក្រសួង ៨៧០ ដែលទទួលការងារចែកចាយបន្លែ សាច់ និងអង្ករ[2201]។ គាត់បានផ្ដល់សក្ខីកម្មថា ស្វាមីរបស់គាត់ត្រូវបានចាប់ខ្លួននៅពេលគាត់ពុំបានធ្វើអ្វីខុសសោះនោះ[2202]។

1029. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ សុផានី ដែលបានផ្ដល់សក្ខីកម្មពាក់ព័ន្ធនឹងសហករណ៍ត្រាំកក់ ហើយភ័ស្ដុតាងរបស់គាត់ឃើញបង្ហាញនៅក្នុងជំពូក ១ បានផ្ដល់សក្ខីកម្មអំពីការចាប់ខ្លួន និងការសម្លាប់បងរបស់គាត់ឈ្មោះ ស៊ូ ណៃម ហៅ ស៊ូ សត នៅ ស-២១។ បងរបស់គាត់គឺជាវេជ្ជបណ្ឌិតដែលទើបវិលត្រឡប់ចូលប្រទេសកម្ពុជាពីការសិក្សានៅប្រទេសបារាំង។ ដើមបណ្ដឹងរដ្ឋប្បវេណី

---

ទៅជាអ៊ីចឹងនោះ។ អ៊ីចឹងឈ្មោះចុងក្រោយនេះ ឈ្មោះប្ដីរបស់គាត់។ អ៊ីចឹងម្ដងយកត្រកូលឪពុក ម្ដងយកត្រកូលជីតា"។ (សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ខៀវ នាប ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៤៩-៥០ បន្ទាត់ ២៥-៣)។

[2198] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ខៀវ នាប ប្រតិចារឹក ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/503.1** ទំព័រ ៦៧-៦៨ បន្ទាត់ ២៣-១៨។ *សូមមើលផងដែរ* ឈ្មោះអ្នកទោសកំទេចថ្ងៃ ២.១២.៧៨ ឯកសារ **E3/10454** ERN (KH) 01018812។

[2199] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ខៀវ នាប ប្រតិចារឹក ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/503.1** ទំព័រ ៦៧-៦៨ បន្ទាត់ ២៣-១៨។ *សូមមើលផងដែរ* ឈ្មោះអ្នកទោសកំទេចថ្ងៃ ២.១២.៧៨ ឯកសារ **E3/10454** ERN (KH) 01018812។ *សូមមើលផងដែរ* បញ្ជីឈ្មោះអ្នកទោស ក.ស.ច.ស ឯកសារ **E3/10604** លេខ ១២៨៣១ ERN 01222855 (យោងតាម 01018811-01018815)។

[2200] បញ្ជីឈ្មោះអ្នកទោស ក.ស.ច.ស ឯកសារ **E3/10604** លេខ ១២៨៣១ ERN 01222855 (យោងតាម 01018811-01018815)។

[2201] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ខៀវ នាប ប្រតិចារឹក ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/503.1** ទំព័រ ៦៤ បន្ទាត់ ១៧-២០។

[2202] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ខៀវ នាប ប្រតិចារឹក ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/503.1** ទំព័រ ៦៧ បន្ទាត់ ២០-២១។

បានបញ្ជាក់ឈ្មោះបងរបស់គាត់នៅក្នុងបញ្ជីឈ្មោះអ្នកទោស ស-២១ ដោយបានបញ្ជាក់ថា ស៊ូ សត ហៅ ស៊ូ ណែម ដែលជាវេជ្ជបណ្ឌិតមកពីខេត្តបាត់ដំបងបានចូល ស-២១ នៅថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៥ ហើយគាត់ត្រូវបានគេសម្លាប់ចោលនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៦[2203]។

1030. ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម បានផ្តល់សក្ខីកម្មអំពីការចាប់ខ្លួន និងមរណភាពឪពុករបស់គាត់ឈ្មោះ ស្វ ជឹម ហៅ ចេត និងពូរបស់គាត់ឈ្មោះ រស់ ម៉ៅ ហៅ សាយ នៅ ស-២១។ គាត់បានផ្តល់សក្ខីកម្មថា ឪពុក និងពូរបស់គាត់ត្រូវបានចាប់ខ្លួននៅក្នុងពេលតែមួយក្នុងខែមិថុនា ឆ្នាំ ១៩៧៧ ហើយគាត់ត្រូវបានចាប់ខ្លួនបី ឬ បួនខែក្រោយមកនៅក្នុងខែកញ្ញា ឬ ខែតុលា ឆ្នាំ ១៩៧៧[2204]។ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា គាត់បានឮពីកងការពារម្នាក់មកពីមន្ទីរ ៥៦០ ថា ប្រជាជនមកពីក្រុងភ្នំពេញបានចាប់ខ្លួនឪពុករបស់គាត់ និងពូគាត់[2205]។ ពាក់ព័ន្ធនឹងមុខតំណែងរបស់ឪពុកគាត់ ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា នៅពេលនោះ គាត់ទទួលការងារដឹកនាំកម្មករឲ្យដាំខ្មៅ និងផលិតបារី[2206]។

1031. នៅក្នុងពេលផ្តល់សក្ខីកម្ម ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម បានបញ្ជាក់លើឈ្មោះឪពុកគាត់ ស្វ ជឹម ហៅ ចេត ប្រធានរោងចក្រវាយណភណ្ឌក្នុងខេត្តបាត់ដំបងនៅក្នុងបញ្ជីឈ្មោះអ្នកទោសចូល ស-២១ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ១៩៧៧[2207]។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបង្ហាញឯកសារទីពីរគឺបញ្ជីគ្រប់គ្រងអ្នកទោសសម្រាប់ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៧៧។ ឯកសារនេះរួមមាន

---

2203 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ប្រតិចារិក ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/251.1** ទំព័រ ៦០-៦១ បន្ទាត់ ៥-២ ដោយដកស្រង់ឯកសារ បញ្ជីឈ្មោះអ្នកទោស និងកាលបរិច្ឆេទសម្លាប់ (បើត្រូវបានសម្លាប់) ឯកសារ **E3/3973** ERN (KH) 00006623។

2204 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារិក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/500.1** ទំព័រ ១៦ បន្ទាត់ ១៥-១៧ និងទំព័រ ២៩ បន្ទាត់ ៦-៨។

2205 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារិក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/500.1** ទំព័រ ១៩ បន្ទាត់ ២២-២៣ និងទំព័រ ២០ បន្ទាត់ ១។

2206 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារិក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/500.1** ទំព័រ ១៥ បន្ទាត់ ៦-៨។

2207 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារិក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/500.1** ទំព័រ ១៧ បន្ទាត់ ៧-១៩។ *សូមមើលផងដែរ* បញ្ជីអ្នកទោសចូលប្រចាំថ្ងៃ ចុះថ្ងៃទី ២៨ ខែ មុថុនា ឆ្នាំ ១៩៧៧ ឯកសារ **E3/9646** ERN (KH) 01017058។

កំណត់ត្រាសរសេរដោយដៃបង្ហាញថា ឪពុករបស់គាត់បានស្លាប់ដោយសារជំងឺរាកមួល និងរបួសធ្ងន់ធ្ងរលើខ្នង ហើយគាត់ត្រូវបានគេព្យាបាលរយៈពេលមួយខែ[2208]។

1032. ដើមបណ្តឹងរដ្ឋប្បវេណី គង់ សៀក បានផ្តល់ភ័ស្តុតាងថា អ្នកដាំបាយឈ្មោះ រ៉ន មកពីកងពលរបស់គាត់នៅព្រលានយន្តហោះកំពង់ឆ្នាំងត្រូវបានចាប់ខ្លួន និងដាក់គុកនៅទួលស្លែង។ គាត់បានដឹង និងបានឃើញថា រូបថតរបស់ រ៉ន ឃើញនៅក្នុងមន្ទីរសន្តិសុខ[2209]។

## ខ. ភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងឧក្រិដ្ឋកម្ម

### ១. ការដាក់ក្នុងមន្ទីរឃុំឃាំង

1033. ភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលបាននៅពេលជំនុំជម្រះបង្ហាញថា ប្រជាជនដែលជាប់ឃុំនៅមន្ទីរសន្តិសុខ ស-២១ ត្រូវបានគេដកហូតសេរីភាពតាមទំនើងចិត្តដោយពុំបានឆ្លងកាត់ដំណើរការត្រឹមត្រូវតាមផ្លូវច្បាប់។

#### *ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី*

1034. បញ្ជីឈ្មោះអ្នកទោសចូល ស-២១ នៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៨ បង្ហាញថា ជុំ ម៉ី នៅត្រង់លេខរៀងទី ៧ បានចូល ស-២១ នៅក្នុងថ្ងៃខាងលើ[2210]។ ឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ឃើញនៅក្នុងបញ្ជីឈ្មោះអ្នកទោសយកមកពីកន្លែងកាត់ដេររដ្ឋនៅក្នុងបញ្ជីឈ្មោះអ្នកទោសជាច្រើន

[2208] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/500.1** ទំព័រ ១៧-១៨ បន្ទាត់ ២១-៩។ *សូមមើលផងដែរ* បញ្ជីក្តាប់កម្លាំងអ្នកទោសប្រចាំថ្ងៃ ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៧ ឯកសារ **E3/9996** ERN (KH) 01012304។

[2209] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី គង់ សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ៣៨-៣៩ បន្ទាត់ ២១-១ និងទំព័រ ៣៩ បន្ទាត់ ៤-៩។

[2210] ឧបសម្ព័ន្ធ ២៦៥៖ បញ្ជីឈ្មោះអ្នកទោសចូល ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៧៨ ឯកសារ **E3/8551** ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៧៨ ERN (KH) 00086991។

នាក់មកពីកងពល ២០៧ (អតីតកងពល ៣១០) និងកងពល ៧០៣[2211]។ ឈ្មោះរបស់គាត់ឃើញមាននៅក្នុងបញ្ជីឈ្មោះអ្នកទោសដែលបានចូលនៅក្នុងខែតុលា ឆ្នាំ១៩៧៨[2212]។

1035. ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា ក្រោយពេលគាត់មកដល់ ស-២១ "អាបន្ទប់០២២ហ្នឹង វាយកទៅ វាបញ្ចូលខ្ញុំនៅហ្នឹង ដល់ហើយ វាថាឲ្យអង្គុយចុះ ឲ្យយើងអង្គុយចុះ។ ខ្ញុំអង្គុយចុះហើយ វាដាក់អាខ្នោះជើងយើង យកអាខ្នោះហ្នឹង មកដាក់ខ្នោះជើងយើង។ ដាក់ខ្នោះជើងរួច បានវាដោះអាខ្នោះដៃចេញ។ ដោះខ្នោះដៃចេញ បានស្រាយមុខ។ ស្រាយមុខហើយ វាចេញក្រៅ វាដាក់អាក្រណាត់បាំងត្រង់មាត់ទ្វារហ្នឹង"[2213]។ នៅក្នុងរយៈពេល ១២ ថ្ងៃ ១២ យប់នៅចន្លោះពេលចូល ស-២១ និងផ្តល់ចម្លើយសារភាព ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី បានផ្តល់សក្ខីកម្មថា គេបានឃុំគាត់នៅក្នុងបន្ទប់តូចមួយ "អាបន្ទប់០២២ហ្នឹង គឺថាវាប្រហែលជាតែ១,៥០ម៉ែត្រ។ បាទហើយបណ្តោយប្រហែលជា២ម៉ែត្រប៉ុណ្ណឹងទេ។ ពេលនុ៎ងលោកចៅក្រមស៊ើបអង្កេតបានទៅមើលអាកន្លែងហ្នឹងដែរ ទៅមើលអាកន្លែងហ្នឹង ហើយបានសួរ ឌុច នៅកន្លែងហ្នឹង ថាកន្លែងហ្នឹង កន្លែងលោកតា ជុំ ម៉ី មែនអត់ យ៉ាងម៉េច អីយ៉ាងម៉េច។ ពេលនុ៎ង ឌុច ថាកន្លែងហ្នឹង កន្លែងលោកតា ជុំ ម៉ី ហើយបាទ"[2214]។ "នៅក្នុងបន្ទប់ គេដាក់អ៊ីហ្នឹង ដាក់បានតែម្នាក់ទេ គេមិនអាចដាក់បានពីរនាក់ទេ"[2215]។ រូបថតដែលបានថតបន្ទប់នោះមាននៅក្នុងសំណុំរឿង[2216]។ ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី

---

[2211] ឈ្មោះអ្នកទោសផ្នែកកងពល ២០៧ "អតីត ៣១០" និងផ្នែកកងពល ៧០៣ ឯកសារ **E3/9898** ERN (KH) 01011228។

[2212] ឈ្មោះអ្នកទោសចូលប្រចាំខែ តុលា ឆ្នាំ ១៩៧៨ ឯកសារ **E3/10205** ERN (KH) 01016477 (ថ្ងៃអះអាង៖ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៧៨)។ ឯកសារ **E3/10205** ERN (EN) 01222351 (យោងពី 01016472-01016480)។

[2213] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ២០ បន្ទាត់ ២២-២៥។

[2214] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ២១ បន្ទាត់ ៤-៧។

[2215] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ២២ បន្ទាត់ ១៥។

[2216] ឧបសម្ព័ន្ធ ១៖ កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់ទីកន្លែង ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៨ (ទួលស្លែង) ឯកសារ **E3/9431** រូបថត ៤៥ និង ៤៦។

បានលើកឃោបល់ថា បង្គួច "បន្ទប់នេះ ពេលដែលនេះហ្នឹង គឺថាគេបិទជិតឈឹងតែម្ដង អត់មាន ពន្លឺថ្ងៃចូលទេ អត់មានពន្លឺថ្ងៃចូលទេ"[2217]។

1036. ពុំមានពេលណាមួយក្នុងពេលផ្ដល់សក្ខីកម្មដែលដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី បានលើកឡើងអំពី អត្ថិភាពនៃនីតិវិធីច្បាប់ ឬ នីតិវិធីតុលាការបើកផ្លូវឲ្យគាត់តវ៉ាលើការឃុំខ្លួនគាត់នោះទេ។ គាត់បាន ផ្ដល់សក្ខីកម្មថា "គេយកខ្ញុំទៅអាបន្ទប់មួយ គឺថាក្នុងបន្ទប់ហ្នឹង វាមានអាប្រដាប់គេវាស់កម្ពស់ គេវាស់កម្ពស់យើងហើយ គេថតរូប។ ថតរូបហើយ បានគេដោះអាវយើងចេញ ដោះខោវែងចេញ នៅតែខោខ្លី គេដាក់ខ្នោះដៃទៅក្រោយ គេយកក្រមាមកចងមុខខ្ញុំ បានគេបញ្ជូនទៅអាបន្ទប់ ០២២ហ្នឹង។ បន្ទប់គេដាក់អ៊ីហ្នឹង"[2218]។

1037. ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ពុំដែលត្រូវបានគេជូនដំណឹងជាក់លាក់អំពីហេតុផលនៃការចាប់ខ្លួន និងឃុំខ្លួននោះទេ។ គាត់បានផ្ដល់សក្ខីកម្មថា "ក្នុងរយៈពេល១២ថ្ងៃ ១២យប់ហ្នឹង ខ្ញុំដេកគិតផង អង្គុយគិតផង ប្រហែលជាមាននរណាឆ្លើយដាក់ខ្ញុំបានគេយកខ្ញុំមកវាយហ្នឹង គឺខ្ញុំអត់ដឹងទេ បាទ"[2219]។

### *បងប្រុសរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ផែ ប៉ាប ឈ្មោះ ផែ ហេង*

1038. ដើមបណ្ដឹងរដ្ឋប្បវេណី ផែ ប៉ាប បានផ្ដល់សក្ខីកម្មនៅក្នុងពេលសវនាការលើព្យសនកម្មពាក់ព័ន្ធ នឹងមន្ទីរសន្តិសុខ និងទីតាំងកាប់សម្លាប់អំពីការចាប់ខ្លួន និងការបាត់ខ្លួនបងប្រុសរបស់គាត់ឈ្មោះ ផែ ហេង។ ដើមបណ្ដឹងរដ្ឋប្បវេណី ផែ ប៉ាប បានផ្ដល់សក្ខីកម្មថា "បាទ មានឯកសារនៅក្នុងគុក

[2217] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ៣៨ បន្ទាត់ ២២-២៣។ សូមមើលផងដែរ ឧបសម្ព័ន្ធ ១៖ កំណត់ហេតុនៃការចុះធ្វើការស៊ើបអង្កេតដល់ទីកន្លែង ថ្ងៃទី ២៧ ខែ កុម្ភៈ ឆ្នាំ ២០០៨ (ទួលស្លែង) ឯកសារ E3/9431 រូបថត ៤៥ និង ៤៦។

[2218] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ២០ បន្ទាត់ ១០-១៣។

[2219] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ២៧ បន្ទាត់ ១-២។

ទួលស្លែង គេដាក់ជាប់។ គេដាក់អ្នកទោស មន្ទីរឃុំឃាំង រូបថត ឯកសារប្រវត្តិរូប បើនិយាយឲ្យខ្លី ប្រវត្តិរូប។ ពីសម័យនោះ គេនិយាយអ៊ីចឹង។ ប្រវត្តិរូប ឃើញនៅក្នុងគុកទួលស្លែង”[2220]។

1039. ដើមបណ្តឹងរដ្ឋប្បវេណី ផៃ ប៉ាប បានភ្ជាប់ឯកសារមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់គាត់ រួមមាន ប្រវត្តិរូបនៅ ស-២១ របស់ ផៃ ហេង រួមជាមួយនឹងរូបថតរបស់គាត់ ហើយបានបញ្ជាក់លើឯកសារទាំងនេះនៅក្នុងតុលាការ[2221]។ ការ ឃុំខ្លួនរបស់ ផៃ ហេង ត្រូវបានកត់ត្រានៅក្នុងឯកសារ *ប្រវត្តិរូបអ្នកទោសនៅទួលស្លែងរបស់លោក ផៃ ហេង*[2222]។ ប្រវត្តិរូបនេះកត់ត្រាថា ផៃ ហេង “សមាជិកមន្ទីរកងពល ៣១០” ត្រូវបានគេឃុំ នៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៧៧ នៅពេលគាត់មានអាយុ ៣១ ឆ្នាំ[2223]។ រូបថតរបស់ ផៃ ហេង ឃើញនៅក្នុងឯកសារដើមជាភាសាខ្មែរ[2224]។ ដើមបណ្តឹងរដ្ឋប្បវេណី ផៃ ប៉ាប បាន ផ្តល់សក្ខីកម្មថា “បាទ ឃើញ។ តាមឯកសារហ្នឹង ឯកសារថ្ងៃខែហ្នឹងមែន។ ថ្ងៃហ្នឹងឯងដែលខ្ញុំទៅលេង ៧៧ ហ្នឹងឯង”[2225]។

### *បងប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឃឹម ឈ្មោះ ចៅ សេង*

1040. ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឃឹម ត្រូវបានបង្ហាញចម្លើយសារភាពរបស់ ជិន សួន ហៅ សាន នៅ ស-២១ ដែលបានបញ្ជាក់ថា គាត់បានចូល ស-២១ នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៧៧[2226]។ ដើម

[2220] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ផៃ ប៉ាប ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ១៤ បន្ទាត់ ១-៣។

[2221] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបសើ ផៃ ប៉ាប 08-VU-01013 ឯកសារ **E3/6427** ERN (KH) 00544248. សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ផៃ ប៉ាប ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ១៤-១៥ បន្ទាត់ ១-៩។

[2222] ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង ផៃ ហេង នៅគុកទួលស្លែង ឯកសារ **E3/2989** ERN 00211264 (KH)។

[2223] ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង ផៃ ហេង នៅគុកទួលស្លែង ឯកសារ **E3/2989** ERN 00211264 (KH)។

[2224] ប្រវត្តិរូបអ្នកទោសជាប់ឃុំឃាំង ផៃ ហេង នៅគុកទួលស្លែង ឯកសារ **E3/2989** ERN 00211264 (KH)។

[2225] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ផៃ ប៉ាប ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ២២ បន្ទាត់ ៩-១០។

[2226] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឃឹម ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៦៤-៦៥ បន្ទាត់ ២៥-២៤។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ៖ ស-២១ ចម្លើយសារភាពរបស់ ជិន សួន (ចៅ សេង) ឯកសារ **E3/10609** ERN (KH) 00246843។

បណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មថា "ឯកសារទាំងអស់នេះ ខ្ញុំបានយកពី ឌី.កាំ ខ្ញុំបានយកមកពិភាក្សា គឺឯកសារនេះគឺពិតជារបស់គាត់មែន គឺគ្មាន មិនអាចឆ្លើយបាន ព្រោះអក្សរនេះគាត់ខ្ញុំស្គាល់ច្បាស់ អក្សរគាត់ហ្នឹងប្រហែលនឹងអក្សររបស់ខ្ញុំ។ ហេតុនេះ គឺថា អានេះគាត់បានៗសរសេរខ្លួនគាត់ទាំងអស់ទៅនេះហ្នឹង គឺវាឱ្យសរ-សេរទាំងអស់ ខ្ញុំយកមកវា ២០០ទំព័រ។ បានហើយវាឱ្យចោទគាត់ ខ្ញុំមើលដែរ ប៉ុន្តែថាឃើញវាចោទគាត់ហ្នឹងវាគ្មានៗន័យគ្មានអីទាំងអស់ គាត់ចង់ដកថយចេញពីយើងដែរ ប៉ុន្តែគ្រាន់ថា ការធ្វើបដិវត្តន៍គឺថាត្រូវទៅមុខ មិនឱ្យថយក្រោយព្រោះគាត់ដឹងដែរ គាត់ថាគាត់មកហ្នឹងវានេះ គាត់ចង់ថយក្រោយវិញ ប៉ុន្តែថានេះជាមួយ"[2227]។

1041. ដើមបណ្ដឹងរដ្ឋប្បវេណី ចៅ ឃឹម ត្រូវបានសាកសួរអំពីចម្លើយរបស់ ឌុច[2228]។ ពាក់ព័ន្ធនឹងពេលវេលាចាប់ខ្លួន ចៅ សេង ដើមបណ្ដឹងរដ្ឋប្បវេណី ចៅ ឃឹម បានផ្ដល់សក្ខីកម្មថា "ប៉ុនថ្ងៃចាប់ហ្នឹងវាខុសពី ឌុច ថាថ្ងៃខែ១៨ ខែសីហា។ តាមក្នុងឯកសារនេះវាថាខែ១១ ខែវិច្ឆិកា ទៅវិញ។ បាទអ៊ីចឹងបានជាខ្ញុំមាន -- ក្រែង ឌុច មិនសូវចាំរឿង*ងាវ* ព្រោះតែៗដល់ ១១ វាសមហេតុសមផលជាមួយនឹងឯកសារ និងគាត់ធ្វើសារភាព បាទ"[2229]។

1042. សាក្សី កាំង ហ្គេកអ៊ាវ បានផ្ដល់សក្ខីកម្មថា "នៅពេលឆ្នាំ១៩៧៧ បងសុន សេន ហៅខ្ញុំប្រាប់ថាឥឡូវបក្សសម្រេចឱ្យចាប់ ចៅ សេង។ ប៉ុន្តែ ចៅ សេង ល្បីលើឆាកអន្តរជាតិ។ ដូច្នេះមិត្តកុំសរសេរឈ្មោះដាក់ថា ចៅ សេង ឱ្យដាក់ឈ្មោះថា ចិន សួន។ ដូច្នេះអញ្ជើញមើលនៅក្នុងបញ្ជីអ្នកទោស ស-២១ ទៅពិតជានឹងឃើញឈ្មោះ ចិន សួន អត់ឃើញឈ្មោះ ចៅ សេង ទេ។ (...)។ ដល់ក្រោយមក ខាងលើតឿនឱ្យខ្ញុំកម្ទេចទៅ។ នេះខ្ញុំនិយាយបានប៉ុណ្ណឹង។ រឿងរ៉ាវ បងចៅ សេង។

---

[2227] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ចៅ ឃឹម ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៦៥ បន្ទាត់ ១៤-១៩។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ៖ ស-២១ ចម្លើយសារភាពរបស់ ចិន សួន (ចៅ សេង) ឯកសារ **E3/10609** ERN (KH) 00246843។

[2228] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ចៅ ឃឹម ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៦៦-៦៧ បន្ទាត់ ១-៧ ដោយដកស្រង់កំណត់ហេតុនៃសួរចម្លើយ កាំង ហ្គេកអ៊ាវ ឯកសារ **E3/60** ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០០៨ ERN (KH) 00195595។ ប្រតិចារឹក ថ្ងៃទី ២ ខែ មេសា ឆ្នាំ ២០១២ ឯកសារ **E1/57.1** ទំព័រ 103 បន្ទាត់ 3-9។

[2229] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ចៅ ឃឹម ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៦៧ បន្ទាត់ ៥-៧។

សកម្មភាពក្បត់យ៉ាងម៉េច ស្អីយ៉ាងម៉េច ខ្ញុំមិនដឹងទេ ប៉ុន្តែគឺមានការបញ្ជាឲ្យចាប់ ហើយឲ្យក្មេងឈ្មោះអ៊ីចឹង។ ឯចំណែកខ្ញុំនៅតែដឹងគុណ បងចៅ សេង ជានិច្ច"[2230]។

## *ស្វាមីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ខៀវ នាប ឈ្មោះ ខេង ជឿន*

1043. ដើមបណ្តឹងរដ្ឋប្បវេណី ខៀវ នាប ត្រូវបានបង្ហាញបញ្ជីឈ្មោះអ្នកទោសរបស់ ក.ស.ច.ស[2231] ហើយនឹងបញ្ជីឈ្មោះអ្នកទោសសម្លាប់នៅថ្ងៃទី២ ខែធ្នូ ឆ្នាំ១៩៧៨[2232]។ ដើមបណ្តឹងរដ្ឋប្បវេណី បានបញ្ជាក់ថា "ចាស លេខរៀងទី១៤។ ប្តីខ្ញុំ ខ្ញុំដឹងថា ខេង ជឺ, ខេង ជឿន តែជីតាគាត់ ឈ្មោះ គង់ ជឺ, គង់ ជឿន តែគាត់ដាក់ឈ្មោះជីតារបស់គាត់។ នេះអាយុគាត់ពីឆ្នាំ ចូលឆ្នាំ៧៨នេះ ត្រូវអាយុគាត់ដល់ ២៥ឆ្នាំហើយ។ ខ្ញុំបានប្រាកដថាជាគ្រួសារខ្ញុំហើយ នេះឯងនេះ ឈ្មោះនេះឯងនេះ។ ហើយរួមជាមួយអ្នកដែលមកជាមួយនេះ លេខរៀងទី១៣ គឺ គង់ យ៉េ ដែលខ្ញុំនៅជាមួយ ហៅ គង់ ញ៉េ -- កង ញ៉េ។ លេខរៀងទី១៥ គឺឈ្មោះ រុន គឺខ្ញុំមិនដឹងត្រកូលគាត់ទេ ប៉ុនឈ្មោះ រុន នេះ រុន ច្បាស់ហើយ។ នៅជាមួយគ្នាបីនាក់ មកទាំងបីនាក់នេះឯងហើយ។ ថ្ងៃចេញមក ពេលវេលាជាមួយគ្នា។ ចាស សូមអរគុណ"[2233]។ "ចាស ប្តីខ្ញុំដែលនៅនឹងទីកន្លែងផ្សាររដ្ឋនោះ ក៏នៅជាមួយនឹងខ្ញុំដែរ ដែលពេលគេចាប់ខ្លួនយកទៅ គឺបើខ្ញុំអង្គាល់នោះ វាមិនចាំ តែនេះគឺមានភស្តុតាងឯកសារនេះ នៅក្នុងខែ១២ ថ្ងៃទី១១។ ចាថ្ងៃ -- ខែទី១០ អំ ទី១២ គឺខ្ញុំមិនបានចាំច្បាស់ទេដែរ ប៉ុន្តែថ្ងៃមួយនោះ គឺគេចាប់ទៅ មានគ្នាបីនាក់។ ឈ្មោះ ប្តីខ្ញុំហ្នឹងឈ្មោះ គង់ ជឺ ហៅ ជឿន តែឈ្មោះមួយទៀត ហៅ យ៉េ, រុន ទៅទាំងបីនាក់នេះឯង។ នេះបានឃើញឯកសារនៅលើកន្លែងនេះ

---

[2230] សក្ខីកម្មផ្ទាល់មាត់របស់សាក្សី កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/435.1** ទំព័រ ៤៩-៥០ បន្ទាត់ ១៧-១។

[2231] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ខៀវ នាប ប្រតិចារឹក ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/503.1** ទំព័រ ៧០-៧១ បន្ទាត់ ២៣-១០។ បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ របស់ ក.ស.ច.ស ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E3/10604** ERN 01222855 (លេខរៀង ១២៨៣១)។

[2232] ឈ្មោះអ្នកទោសកម្ទេចថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ១៩៧៨ ឯកសារ **E3/10454** ERN (KH) 01018811-01018815។

[2233] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ខៀវ នាប ប្រតិចារឹក ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/503.1** ទំព័រ ៦៨ បន្ទាត់ ១៣-១៥។

ខ្ញុំទើបនឹងឃើញច្បាស់នេះឯង"[2234]។ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា "ចាស ខ្ញុំអត់មានបានដឹងដំណឹងអីសោះ ទាល់តែបាត់ស្វន្យ ទាល់តែឃើញឯកសារនេះតែម្តង"[2235]។

***សមមិត្តមកពីក្រសួង៨៧០របស់ប្តីដើមបណ្តឹងរដ្ឋប្បវេណី ខៀវ នាប***

1044. ដើមបណ្តឹងរដ្ឋប្បវេណីបានបន្តថា សមមិត្តរបស់ប្តីគាត់ ដែលមានឈ្មោះគង់ យ៉េ និងរុន ក៏មានឈ្មោះនៅក្នុងឯកសារ ដូចបានបង្ហាញពីខាងលើដូចគ្នាផងដែរ។ "ហើយរួមជាមួយអ្នកដែលមកជាមួយនេះ លេខរៀងទី១៣គឺ គង់ យ៉េ ដែលខ្ញុំនៅជាមួយហៅ គង់ ញ៉េ កង ញ៉េ។ លេខរៀងទី១៥គឺឈ្មោះ រុន គឺខ្ញុំមិនដឹងត្រកូលគាត់ទេ ប៉ុនឈ្មោះរុននេះ រុនច្បាស់ហើយ។ នៅជាមួយគ្នាបីនាក់មកទាំងបីនាក់នេះឯងហើយ។ ថ្ងៃចេញមកពេលវេលាជាមួយគ្នា។ ចាស សូមអរគុណ"[2236] "ចំណែក រុន អត់ទាន់មានគ្រួសារទេ។ បើបងយ៉េ នោះមានហើយឈ្មោះ ណាត តែឈ្មោះដើមគេដឹងឈ្មោះអីទេ ប៉ុន្តែនៅក្នុងក្រុមជាមួយគ្នានេះឈ្មោះ ណាត"[2237]។ "ចាស ដល់ពេលគេឲ្យខ្ញុំ ពួកខ្ញុំចេញទៅ ប្រពន្ធយ៉េនោះឯង ដែលឈ្មោះ ណាត នេះ ចេញទៅថ្ងៃជាមួយខ្ញុំនេះឯង"[2238]។ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា គាត់ស្គាល់យ៉េ និងរុនដោយសារតែ "ធ្វើការជាមួយគ្នាហូបចុកជាមួយគ្នា តែខ្ញុំអ្នកដាំស្លនេះឯង"[2239]។ "ចាសអ្នកពីរនាក់នេះដែលគេចាប់ប្តី អំចាប់ទៅ

---

[2234] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ខៀវ នាប ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ១៦ បន្ទាត់ ១២-១៦។

[2235] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ខៀវ នាប ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ១៧ បន្ទាត់ ៤-៥។

[2236] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ខៀវ នាប ប្រតិចារឹក ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/503.1** ទំព័រ ៦៨ បន្ទាត់ ១៥-១៨។

[2237] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ខៀវ នាប ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ១៨ បន្ទាត់ ៥-៦។

[2238] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ខៀវ នាប ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ១៨ បន្ទាត់ ៩-១០។

[2239] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ខៀវ នាប ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៣៧ បន្ទាត់ ៦។

ជាមួយប្តីខ្ញុំនេះ បើនិយាយពីស្គាល់ តាំងពីខ្ញុំចូលមកនៅ មកចូលឆ្នាំ៧៨នេះឯង ខ្ញុំស្គាល់រហូតទាល់ពីបែកពីខ្ញុំទៅ ជាមួយនឹងប្តីខ្ញុំ"[2240]។

***បងប្អូនរបស់ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត***

1045. ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត បានបញ្ជាក់ពីអត្តសញ្ញាណ ប្រាប់អង្គជំនុំជម្រះ អំពីបងគាត់ពីរនាក់គឺ ភួង អ៊ឹម និងភួង ផុន ដែលមានឈ្មោះនៅលើបញ្ជីស-២១ និងបញ្ជីវិភាគ។ ភួង អ៊ឹម ត្រូវបានឃុំខ្លួននៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧៨ ហើយសម្លាប់នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៧៨[2241]។ ភួង ផុន ត្រូវបានឃុំខ្លួននៅថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៧៧ ហើយសម្លាប់នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៧៧[2242]។ គាត់បានអះអាងបន្ថែមទៅលើ រូបថតបងគាត់ទាំងពីរនាក់ តាំងពីមុនរបប និងរូបថតរបស់ពួកគាត់ទាំងពីរនាក់នៅមន្ទីរស-២១[2243]។

---

[2240] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ខៀវ នាប ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៣៧ បន្ទាត់ ៣-៥។

[2241] បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ របស់ ក.ស.ច.ស ឯកសារ **E3/10604** ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ERN 01222901 (យោង 00086769-00086769)។ ការពិនិត្យឡើងវិញបញ្ជីអ្នកទោសនៅមន្ទីរ ស-២១ ឯកសារ (OCP) ឯកសារ **E3/342** ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ ERN (EN-KH) 00329929។ ឧបសម្ព័ន្ធ ២៧៧៖ បញ្ជីអ្នកទោសនៅមន្ទីរ ស-២១ ដែលមានឈ្មោះអ្នកទោសដែលត្រូវសួរចម្លើយនៅមន្ទីរ ស-២១ ឯកសារ **E3/8555** ERN (KH) 00086769។

[2242] បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ របស់ ក.ស.ច.ស ឯកសារ **E3/10604** ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ERN 01222434 (យោង 01019293-01019436)។ បញ្ជីឈ្មោះអ្នកទោសដែលចូលចាប់ពីថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៧៧ ដល់ ១៧ ខែ មេសា ឆ្នាំ ១៩៧៧ ឯកសារ **E3/10506** ERN (KH) 01019316]។ បញ្ជីឈ្មោះអ្នកទោសដែលចូលក្នុងខែ មីនា ឆ្នាំ ១៩៧៧ ឯកសារ **E3/9845** ERN (KH) 01010228។ បញ្ជីឈ្មោះអ្នកទោសកម្មេចឆ្នាំ ១៩៧៧ ឯកសារ **E3/2286** ERN (KH) 00091258។ ការពិនិត្យឡើងវិញបញ្ជីអ្នកទោសនៅមន្ទីរ ស-២១ (OCP) ឯកសារ **E3/342** ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ ERN (EN-KH) 00329929។

[2243] ឯកសារបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឯកសារ **D22/3397b** ERN (KH) 00594299-00594310។ រូបថតរបស់ ភួង អ៊ឹម ពីមន្ទីរ ស-២១ មាននៅ ERN (KH) 00594310។ រូបថតរបស់ប្អូនស្រីគាត់ ដែលថតនៅអំឡុងសម័យសង្គមរាស្ត្រនិយម មាននៅ ERN (KH) 00594302។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៣៧-៣៨ បន្ទាត់ ៩-៧។ រូបថតរបស់ ភួង ផុន ពីមន្ទីរ ស-២១ មាននៅ ERN (KH) 00594301។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៤១ បន្ទាត់ ៥-១៩។

1046. ចំពោះបងរបស់គាត់ឈ្មោះ ភួង អ៊ុម ដើមបណ្ដឹងរដ្ឋប្បវេណីបានរៀបរាប់ថា “បានឃើញរូបថតបងស្រីខ្ញុំ នៅគុកទួលស្លែងឡើងភ្នែកស្លក់ មិនដឹងគេវៃធ្វើបាបគាត់យ៉ាងណាយ៉ាងណីទេ"[2244]។ “ឃើញរូបថតបងវេន ខ្ញុំ បងផុន បងផែន បងៗប្រុសខ្ញុំទាំងអស់គ្នា នៅគុកទួលស្លែងទាំងអស់”[2245]។ គាត់បានបញ្ជាក់បំភ្លឺថា "ឃើញបង វេន បងផុន បងផេន ហ្នឹង ហើយថៃខ្ញុំហ្នឹង ប្អូននាក់ហ្នឹង"[2246]។ ដើមបណ្ដឹងរដ្ឋប្បវេណីមិនបានដឹងថា បងគាត់រូបណាត្រូវបានគេចាប់ខ្លួនមុនគេនោះទេ។ "ខ្ញុំអត់ដឹង ដឹងតែបងវេន គាត់និយាយតែប៉ុណ្ណឹង។ គាត់ថាមកភ្នំពេញ គេហៅគាត់មកប្រជុំនៅភ្នំពេញហ្នឹង។ ខ្ញុំដឹងតែប៉ុណ្ណឹង"[2247]។ ទោះបីជាឈ្មោះនៅលើរូបថតនៅទួលស្លែង មិនអាចមើលឃើញច្បាស់ក៏ដោយ តែដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មថា "ខ្ញុំចំណាំបងខ្ញុំ ខ្ញុំស្គាល់បងខ្ញុំពិតប្រាកដ"[2248]។ “ចំណាំមុខគាត់ច្បាស់ បងប្រុសវេន គាត់រាងឆកក្បាល ហើយបបូរមាត់រាងធំ។ បើបងផេនហ្នឹងបបូរមាត់គាត់ស្ដើង។ បើបងផុត គាត់រាងសស្អាតជាងគេ បងមួយហ្នឹង។ ខ្ញុំចំណាំច្បាស់ប្រាកដបងប្អូនខ្ញុំ"[2249]។ “អត់ប្រែប្រួលទេ គ្រាន់តែខុសគាត់ស្គម ហើយភ្នែកស្លេកស្លាំង”[2250]។

***ឪពុកនិងពូរបស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន ឯម ដែលមានឈ្មោះ សួ ជឹម និងរស់ ម៉ៅ***

[2244] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៣៩ បន្ទាត់ ៣-៤។

[2245] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៣៩ បន្ទាត់ ៨-៩។

[2246] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៤២ បន្ទាត់ ១០។

[2247] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៤៦-៤៧ បន្ទាត់ ២៥-១។

[2248] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៥៣ បន្ទាត់ ២។

[2249] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៥៣ បន្ទាត់ ៥-៧។

[2250] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៥៣ បន្ទាត់ ១០-១១។

1047. ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម បានបញ្ជាក់អំពីឈ្មោះឪពុកគាត់គឺ សូ ជឹម ហៅ ចែត ជាប្រធានរោងចក្រតម្បាញនៅបាត់ដំបង ដែលមាននៅក្នុងបញ្ជីឈ្មោះអ្នកទោស ចូលមន្ទីរស-២១ នៅថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ១៩៧៧[2251] និងពូរបស់គាត់ឈ្មោះ រស់ ម៉ៅ នៅលើបញ្ជីអ្នកទោសដែលចូលមន្ទីរ ស-២១ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ១៩៧៧មន្ទីរស-២១[2252]។

***បងប្រុស និងបងថ្លៃស្រីរបស់ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ធរ៉ា ដែលមានឈ្មោះ ជឹម ឡាង និងឱម យិនដូនី***

1048. ចំពោះការចាប់ខ្លួន និងការឃុំខ្លួនបងប្រុសរបស់គាត់ឈ្មោះ ជឹម ឡាង និងបងថ្លៃស្រីឈ្មោះ ឱម យិនដូនីនោះ ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ធរ៉ា ត្រូវបានផ្តល់នូវបញ្ជីមកពីមន្ទីរស-២១ ដែលមានចំណងជើងថា "អ្នកទោសដែលត្រូវយកពីផ្នែកអគ្គីសនីនៅតាខ្មៅ ថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៧៦" ដែលក្នុងបញ្ជីនេះមានឈ្មោះបងប្រុសរបស់គាត់[2253]។ ដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់ថា "ចាស ខ្ញុំទើបឃើញដែរ។ ភ្ញាក់ផ្អើល..."[2254]។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបង្ហាញ ឯកសារមួយដែលមានចំណងជើងថា "បញ្ជីអ្នកទោសដែលត្រូវបានសម្លាប់ ពីថ្ងៃទី០១ វិច្ឆិកា ឆ្នាំ១៩៧៦ ដល់ថ្ងៃទី១៥ វិច្ឆិកា ឆ្នាំ១៩៧៦" ហើយត្រូវបានគេសួរថាតើ ដើមបណ្តឹងរដ្ឋប្បវេណីបានដឹងថាបងថ្លៃស្រីរបស់គាត់ ចូលមន្ទីរស-២១នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៧៦ និងត្រូវបានសម្លាប់នៅថ្ងៃបន្ទាប់គឺថ្ងៃទី៩ ខែ

---

[2251] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/500.1** ទំព័រ ១៧ បន្ទាត់ ៧-១៩។ *សូមមើលផងដែរ* បញ្ជីអ្នកទោសចូលប្រចាំថ្ងៃ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ១៩៧៧ ឯកសារ **E3/9646** ERN (KH) 01017058។

[2252] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/500.1** ទំព័រ ១៩ បន្ទាត់ ១០-១៦ ដោយដកស្រង់ឧបសម្ព័ន្ធ ២៖ បញ្ជីអ្នកទោស ស-២១ ចូលប្រចាំថ្ងៃ ខែ មិថុនា ឆ្នាំ ១៩៧៧ ឯកសារ **E3/9646** ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ១៩៧៧ ERN (KH) 01017054។ បញ្ជីឈ្មោះអ្នកទោសកម្មេច ឯកសារ **E3/2285** ERN (KH) 00009304 (ឈ្មោះអ្នកទោសកម្មេច ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៧៧ ដែលជាចំណងជើងនៅ ERN (KH) 00009303)។ ឯកកសារបញ្ជីឈ្មោះអ្នកទោសដែលបានទទួលនៅខែ តុលា ឆ្នាំ ១៩៧៧ ឯកសារ **E3/10089** ERN (KH) 01014002។

[2253] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ធរ៉ា ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៤៧ បន្ទាត់ ១៩-២៤ ដោយដកស្រង់ឯកសារ **E3/8607** [ERN (KH) 00088716]។

[2254] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ធរ៉ា ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៤៧បន្ទាត់ ២៥។

វិច្ឆិកា ឆ្នាំ១៩៧៦ដែរឬទេ[2255]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មថា "ចាស អត់ដឹងផង។ ប៉ុន្តែដឹងដែរថា យកបានមួយថ្ងៃ ស្អែកឡើងបានវាសម្លាប់ ខ្ញុំមើលដឹងដែរ"[2256]។

***អ្នកធ្វើការជាមួយដើមបណ្ដឹងរដ្ឋប្បវេណី គង់ សៀក***

1049. ដើមបណ្ដឹងរដ្ឋប្បវេណី គង់ សៀក បានផ្ដល់សក្ខីកម្មថា "ឈ្មោះរ៉ន កាលដែលខ្ញុំធ្វើការជាមួយកងពល៤៥០ហ្នឹង គាត់នៅដាំបាយឲ្យខ្ញុំហូបអីចឹង។ នៅដាំបាយឲ្យខ្ញុំហូប ដល់ពេលនេះទៅគេចាប់គាត់ យកទៅគុកទួលស្លែង ខ្ញុំអត់បានដឹងគេចាប់ទេ ប៉ុន្តែដល់ក្រោយឡើងមក មិត្តម៉េត ដែលគាត់ឡើងបកស្រាយអង្គាល់មុននោះ គាត់នាំខ្ញុំទៅគុកទួលស្លែង មើលគុកទួលស្លែងគាត់ប្រាប់ខ្ញុំទេ គ្រាន់បានប្រាប់ខ្ញុំថា "នេះបងរ៉នកងយើង ដែលកងយើងគាត់ដាំបាយឲ្យយើងហូប ឥឡូវគេចាប់គាត់មកគុកទួលស្លែងហើយ" គ្រាន់គាត់ប្រាប់ខ្ញុំទេ។ ខ្ញុំគ្រាន់តែឃើញរូបថតហ្នឹងនៅគុកទួលស្លែងហ្នឹងទេចាស"[2257]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានពន្យល់ថា "បងរ៉នហ្នឹងគាត់នៅកងពល៤៥០ហ្នឹង គាត់នៅក្នុងអំឡុងរបបខ្មែរក្រហមហ្នឹងឯង គាត់នៅដាំបាយឲ្យខ្ញុំហូប ខ្ញុំធ្វើទ័ព គាត់ក៏ទ័ព ប៉ុន្តែខ្ញុំធ្វើស្រែគាត់ដាំបាយ។ ចាស ដល់ក្រោយឡើងខ្ញុំបែកគ្នាមក ហើយមិនដឹងបងរ៉នហ្នឹងគាត់ទៅណា តែដល់ខ្ញុំមកសាលាក្ដីនេះឯង ដល់ពេលជិះឡានដើរមើលគុក តាមគុកទួលស្លែងអីចឹងទៅ មិត្តម៉េតហ្នឹងគឺមិត្តអង្គភាព៤៥០ដូចខ្ញុំដែរ ក៏គាត់ប្រាប់ខ្ញុំថា "នេះបងនេះបងរ៉ន គេចាប់មកដាក់គុកទួលស្លែងហ្នឹងឯង"។ គាត់ដឹងប្រវត្តិ បងរ៉ន ហ្នឹង គាត់ថា "នេះរូបថត គាត់" គឺខ្ញុំបានឃើញអាហ្នឹងមែន រូបថតគាត់ ១បង្ហាញខ្ញុំ។ តែប៉ុណ្ណោះឯង ខ្ញុំអត់មានដឹងអីណាទៀតទេ"[2258]។

***ដើមបណ្ដឹងរដ្ឋប្បវេណី និង/ឬសាច់ញាតិរបស់ពួកគាត់ ដែលត្រូវបានកត់ត្រាថាបានចូលមន្ទីរស-២១***

---

[2255] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី កាន់ សុទ្ធា ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៤៨ បន្ទាត់ ៦-១៥ ដោយដកស្រង់ឯកសារ **E3/3187** [ERN (KH) 00008844]។

[2256] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី កាន់ សុទ្ធា ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៤៨ បន្ទាត់ ១៦។

[2257] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី គង់ សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ៣៨-៣៩ បន្ទាត់ ២១-១។

[2258] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី គង់ សៀក ប្រតិចារឹក ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/318.1** ទំព័រ ៣៩ បន្ទាត់ ៤-៩។

1050. ឧបសម្ព័ន្ធ ច បង្ហាញថា ដើមបណ្តឹងរដ្ឋប្បវេណី និង/ឬសាច់ញាតិរបស់គាត់៧០នាក់ បានចូលមន្ទីរ ស-២១ នៅក្នុងអំឡុងយុត្តាធិការលើពេលវេលារបស់ អ.វ.ត.ក។ ឧបសម្ព័ន្ធបានផ្តល់នូវកាលបរិច្ឆេទ នៃការចូលរបស់ពួកគាត់ និងឯកសារយោងទៅរក កំណត់ត្រាសហសម័យ ដែលកត់ត្រាពីវត្តមានរបស់ពួកគាត់[2259]។

## ២. ការធ្វើទារុណកម្ម

1051. ភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានដាក់ជូននៅក្នុងសវនាការ បានបង្ហាញថាអ្នកដែលជាប់ឃុំនៅមន្ទីរស-២១ ត្រូវទទួលរងការឈឺចាប់ឬព្យសនកម្មធ្ងន់ធ្ងរ ដើម្បីអាចយកបាននូវចម្លើយសារភាព។

1052. នៅថ្ងៃទីមួយដែលគាត់មកដល់មន្ទីរស-២១ ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី បានផ្តល់សក្ខីកម្មថា "យើងនៅក្នុងអាបន្ទប់តូចហ្នឹង គឺថាវាវ៉ៃ វាសួរចម្លើយ វាវ៉ៃ១២ថ្ងៃ១២យប់។ វាវ៉ៃពេលព្រឹកហ្នឹងពីម៉ោងប្រាំពីរព្រឹក រហូតដល់ម៉ោងម៉ាដណ្តប់ ម៉ោងមួយរហូតដល់ម៉ោងប្រាំ ពីម៉ោងប្រាំមួយរហូតដល់ម៉ោងដប់យប់។ ១២ថ្ងៃ១២យប់នៅក្នុងបន្ទប់ហ្នឹង។ ដល់សួរចប់ហើយៗ បានវាយកទៅដាក់នៅឯលើណោះ៤ខែ"[2260]។ គាត់បានពន្យល់ថា "នៅអាបន្ទប់០២២ហ្នឹង គេយកទៅវ៉ៃសួរចម្លើយនៅអគារឯត្បូងណោះ នៅលើនៅបន្ទប់លើនោះ តាមខ្ញុំដឹងថាក្រោយមកទេ ដែលខ្ញុំមើលឃើញហើយអាបន្ទប់ហ្នឹងលេខ៤ ដោយសារថ្ងៃក្រោយទេណា ខ្ញុំមើលឃើញបន្ទប់ហ្នឹងលេខ៤ បន្ទប់គេវ៉ៃខ្ញុំហ្នឹង"[2261]។

1053. “ពេលនោះគឺថាគេវាអឺសួរថា "គ្នាអែ្ហងមានប៉ុន្មាននាក់ចូល សេអ៊ីអា ចូលកាហ្សេបេ?" ហើយយើងប្រាប់គេថា "ខ្ញុំអត់ស្គាល់សេអ៊ីអា កាហ្សេបេទេពេលនោះ"[2262]។ ដើមបណ្តឹងរដ្ឋប្បវេណីបាន

[2259] ឧបសម្ព័ន្ធ ចៈ ដើមបណ្តឹងរដ្ឋប្បវេណី និងសាច់ញាតិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលចូល ឬត្រូវបានសម្លាប់នៅមន្ទីរ ស-២១។

[2260] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ២៣ បន្ទាត់ ១១-១៤។

[2261] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ២៣ បន្ទាត់ ១៨-២០។

[2262] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ២៦ បន្ទាត់ ២-៤។

ពន្យល់ថា នៅពេលដែលគេវាយគាត់ "ពេលវាយខ្ញុំយកដែរងអ៊ីចឹង បាក់អាកូនដៃហ្នឹងមួយ។ ហើយ បន្ទាប់មកវាយកអាដង្កាប់ មួលអាក្រចកជើង មេជើងហ្នឹង ទាញផ្តាច់បាទ ទាញផ្តាច់បាទ"[2263]។ "យើងឆ្លើយថាយើងអត់ស្គាល់ សេអ៊ីអា កាហ្សេបេហ្នឹងទេ។ ពេលនុំងគឺថាវាវាយថែមទៀត គឺថា វាយហើយ វាយកអាខ្សែភ្លើងមកញាត់ស្លឹកត្រចៀកយើងហ្នឹង ញាត់ឆាច់អ៊ីចឹងទៅ ប៊ីង ដូចរយះ ដូចបែកអំពិលអំពែកអ៊ីចឹង យើងសន្លប់មួយសន្ទុះធំ"[2264] "ឆក់ខ្សែភ្លើងហ្នឹង មានពីរដងជម្រាប លោកមេធាវី ឆក់ពីរដងបាទ។ ត្រចៀកម្ខាងហ្នឹង ភ្នែកម្ខាងហ្នឹង ឥឡូវប្រើការអត់កើតទេ។ អាត្រចៀកស្តាប់ទៅអត់ឮទេ ភ្នែកមើលឃើញព្រិលៗទេ បានតែមួយខាងនេះទេ"[2265]។ ដើម បណ្តឹងរដ្ឋប្បវេណីចាប់ផ្តើមមានបញ្ហាត្រចៀកនិងភ្នែក "ពេលដែលវាដាក់ខ្សែភ្លើងឲ្យឆក់អ៊ុំហ្នឹង គឺ ថាចាប់ពេលនុំងមក ឆក់ខ្សែភ្លើងហ្នឹង"[2266]។

1054. ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី បកស្រាយអំពីការអនុវត្តជាក់លាក់ ដែលត្រូវបានប្រើដើម្បីទាញយក ចម្លើយសារភាពពីគាត់។ គាត់បានផ្តល់សក្ខីកម្មថា សេង "ពេលនោះវាអង្គុយលើក្បាល ហើយវា យកអារំពាត់ហ្នឹង វ៉ៃក្បាលជង្គង់ខ្ញុំ។ អាចុយម៉ាយអ្វែងមិនឆ្លើយ។ បាទ វាថាអ៊ីចឹង"[2267]។ "ចំពោះ វប្បធម៌ខ្មែរហ្នឹង គឺថាជម្រាបលោកព្រះរាជអាជ្ញា គេប្រកាន់ណាស់រឿងក្បាលហ្នឹង គេប្រកាន់ ណាស់ ខ្មែរយើងមិនឲ្យពីណាអង្គុយលើក្បាលអ៊ីចឹងទេ"[2268]។

[2263] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ២៦ បន្ទាត់ ៧-៨។

[2264] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ២៦ បន្ទាត់ ១១-១៣។

[2265] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ២៦ បន្ទាត់ ១៥-១៨។

[2266] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ២៦ បន្ទាត់ ១៩-២១។

[2267] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ៤១ បន្ទាត់ ១៣-១៤។

[2268] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ៤១ បន្ទាត់ ១៧-១៨។

1055. ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ទទួលរងការដកក្រចកជើងចំនួនពីរ។ “ការដកក្រចកជើង គឺថាវាដក ទាំងពីរ ប៉ុន្តែអាមួយវាដុះមក វាអត់មាន វាអត់នេះទេ ដុះមកស្អាតតែម្ដង។ ហើយអាមួយ ដុះមក អត់ស្អាតតែម្ដង"[2269]។ “បាទវាគ្រាន់តែយកអាល់កុលមកចាក់តែប៉ុណ្ណឹងទេ អត់មានលាបថ្នាំលាប អីទេបាទ"[2270]។ “ពេលនោះ យើងអត់ហ៊ានស្រែកខ្លាំងទេ យើងខ្លាចវាវៃថែម យើងអត់ហ៊ានស្រែក ទេ យើងសុខចិត្តធ្មេចភ្នែកខាំមាត់យើង"[2271]។

1056. ចំពោះការឆក់ខ្សែភ្លើង ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី បានរៀបរាប់ថា "ការឈឺចាប់ឆក់ខ្សែភ្លើងហ្នឹង វាឈឺចាប់ភ្លាម វាឈឺចាប់ខ្លាំង ទាល់យើងសន្លប់អត់ដឹងខ្លួនចំនួនពីរដង សន្លប់ពីរដងអត់ដឹង ខ្លួន"[2272]។

1057. ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មថា គេប្រើទារុណកម្មដើម្បីយកចម្លើយសារភាពរបស់ គាត់។ ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី បានពន្យល់ថា គាត់នឹងមិនឆ្លើយសារភាពទេ ប៉ុន្តែចំពោះការ ឈឺចាប់ដែលគាត់បានទទួលរង "ការដែលខ្ញុំឆ្លើយការពិតមួយចំនួន ហើយឆ្លើយការមិនពិតនោះ មួយចំនួន។ មួយចំនួនដែលវាវៃឲ្យខ្ញុំឆ្លើយថាខ្ញុំជា សេអ៊ីអា កាហ្សេបេ ហ្នឹង អាហ្នឹងគឺថាមិនមែន ពិតទេ ព្រោះខ្ញុំអត់ដែលស្គាល់សេអ៊ីអា កាហ្សេបេហ្នឹងទេ។ ដល់វាវៃខ្លាំងពេក ដាក់ខ្សែភ្លើងខ្លាំង ពេក ម្ល៉ោះហើយខ្ញុំទ្រាំអត់បាន ខ្ញុំចេះតែឆ្លើយទៅដែរ"[2273]។ ដើមបណ្ដឹងរដ្ឋប្បវេណីពន្យល់ថា "ខ្ញុំ ប្រឌិតឡើងដើម្បីដោយសារគេឆក់ខ្សែភ្លើងខ្លាំងពេក ខ្ញុំទ្រាំអត់បានម្ល៉ោះហើយខ្ញុំចេះតែឆ្លើយទៅ បាទ។ ត្រង់ហ្នឹងហើយដែលពួកវាសួរទៅខ្ញុំថា អើបើអ្អែងឆ្លើយអ៊ីចឹងយូរណាស់ អញម៉េចនឹងវៃ

[2269] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ៤១ បន្ទាត់ ២២-២៣។

[2270] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ៤២ បន្ទាត់ ២។

[2271] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ៤២ បន្ទាត់ ៦-៧។

[2272] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ៤២ បន្ទាត់ ១២-១៣។

[2273] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ៤៧ បន្ទាត់ ២-៥។

អ្អែង។ អាត្រង់ហ្នឹងហើយ អាសេង វានិយាយអ៊ីចឹង។ ហើយការពិតនោះ ខ្ញុំអត់ស្គាល់មែន អត់ស្គាល់សេអ៊ីអា អាហ្នឹងស្អី កាហ្សេបេហ្នឹងស្អី ទើបស្គាល់ក្រោយទេ"[2274]។

1058. ដោយសារតែការវាយដំដែល ដើមបណ្ដឹងរដ្ឋប្បវេណីបានទទួលរង ទើប ជុំ ម៉ី "ពេលនោះគឺថា យើងឆ្លើយដាក់ហ្នឹង គឺថាឆ្លើយដាក់ពាសទឹកពាសដីទេ យើងអត់បានថាអ្ន សំដៅអ្នកនេះអ្នកនោះទេ ខ្ញុំនឹងស្មានប្រហែលគេឆ្លើយដាក់ខ្ញុំហើយ។ អ៊ីចឹងខ្ញុំសន្មតថា ខ្ញុំធ្វើត្រូវនិយាយឆ្លើយពាសទឹកពាសដី ដូចគេដូចឯងអ៊ីចឹងដែរបាទ"[2275]។ "ពេលនោះអាសេង វាមកវាយយើង វាយសួរហើយសួរទៀត សួរហើយសួរទៀត។ ដល់ហើយវាថា អាចុយម៉ាយ អ្អែងបើឆ្លើយអ៊ីចឹងយូរណាស់ អញមិនវាយ អ្អែងដល់ប៉ុណ្ណឹងអ្ហេ! ប៉ុន្តែអ្អែងអត់ព្រមឆ្លើយ បាទ"[2276]។ ក្រោយពេលដែលគាត់ឆ្លើយសារភាព ឈ្មោះហើយ ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី លែងត្រូវគេវាយទៀតហើយ[2277]។

1059. នៅពេលដែលគាត់ឆ្លើយសារភាព ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី បានផ្តល់សក្ខីកម្មថា "គេអត់មានអានឲ្យយើងស្ដាប់អីទេក្មួយ គ្រាន់តែគេឲ្យផ្ដិតមេដៃហើយ ហើយៗ"[2278]។ ចម្លើយសារភាពមាននៅក្នុងសំណុំរឿង[2279]។

## ៣. អំពើមនុស្សឃាត និងការសម្លាប់រង្គាល

---

[2274] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ៤៧ បន្ទាត់ ១៨-២២។

[2275] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ២៧ បន្ទាត់ ៩-១១។

[2276] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ២៧ បន្ទាត់ ២១-២៣។

[2277] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ២៧-២៨ បន្ទាត់ ២៤-១។

[2278] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ២៨ បន្ទាត់ ១៣។

[2279] ចម្លើយសារភាពរបស់ ជុំ ម៉ាញ ឯកសារ **E3/9253** ឯកសារ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ១៩៧៨ ERN (KH) 00170541-00170585។

1060. ភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលបានបង្ហាញនៅក្នុងសវនាការ បានកំណត់ថាអំពើសកម្ម ឬអំពើអកម្ម ដែលបានប្រព្រឹត្តនៅមន្ទីរសន្តិសុខស-២១ បានបណ្តាលឱ្យស្លាប់មនុស្ស។

## ៣.១. ករណីជាក់ស្តែងនៃការសម្លាប់

### *បងប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី ផៃ ប៉ាប ឈ្មោះ ផៃ ហេង*

1061. ដើមបណ្តឹងរដ្ឋប្បវេណី ផៃ ប៉ាប ដែលភស្តុតាងរបស់គាត់ មានជាប់ទាក់ទងនឹងការចាប់ខ្លួន និងការឃុំខ្លួនបងប្រុសរបស់គាត់ ហើយត្រូវបានលើកមកពិភាក្សានៅផ្នែកខាងលើ ត្រូវបានបង្ហាញដោយមានឯកសារ ដែលកត់ត្រាការសម្លាប់បងប្រុសរបស់គាត់។ ឯកសារនៅក្នុងសំណុំរឿងមានចំណងជើងថា "បញ្ជីឈ្មោះអ្នកទោសដែលបានសម្លាប់នៅក្នុងឆ្នាំ១៩៧៧ បានកត់ត្រា "ផៃ ហេង" នៅលេខរៀង៦៨ ថាត្រូវបានសម្លាប់នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ១៩៧៧[2280]។

### *បងប្អូនរបស់ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត ឈ្មោះ ភួង ផុន និងភួង អ៊ីម*

1062. ឧបករណ៍វិភាគដែលផ្អែកលើឯកសារ មកពីកំណត់ត្រាទួលស្លែង បានផ្តល់នូវព័ត៌មានលម្អិតបន្ថែម អំពីការចាប់ខ្លួន ការឃុំខ្លួន និងការសម្លាប់បងប្អូនរបស់ ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត ដែលមានឈ្មោះ ភួង អ៊ីម និងភួង ផុន។ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា "ឯកសារគេយកឱ្យម្តងដែរ យកទៅផ្ទះខ្ញុំហ្នឹង រួចទៅខ្ញុំផ្តិតមេដៃអីយកមកឱ្យវិញ។ ឱ្យប្រធានភូមិប្រធានអីប្រធានឃុំផ្តិតមេដៃយកមកឱ្យឯហ្នឹងវិញ កន្លែងតុលាការហ្នឹងវិញ ឯកសារបងៗខ្ញុំស្លាប់ហ្នឹង"[2281]។ ភួង អ៊ីម ត្រូវបានឃុំខ្លួននៅថ្ងៃទី៨ ខែធ្នូ ឆ្នាំ១៩៧៨[2282]។ ភួង ផុនត្រូវបានកត់ត្រាថាជា

[2280] បញ្ជីឈ្មោះអ្នកទោសកម្ទេចឆ្នាំ ១៩៧៧ ឯកសារ **E3/3858** ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ១៩៧៧ ERN (KH) 00009195 00009196។ ការពិនិត្យឡើងវិញបញ្ជីអ្នកទោសនៅមន្ទីរ ស-២១ ឯកសារ (OCP) ឯកសារ **E3/342** ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩។ ERN (EN-KH) 00329635។ បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ របស់ ក.ស.ច.ស ឯកសារ **E3/10604** ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ERN 01222420 (យោង 01016882-01016917)។

[2281] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៤៧ បន្ទាត់ ១៧-១៩។

[2282] បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ របស់ ក.ស.ច.ស ឯកសារ **E3/10604** ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ERN 01222901 (យោង 00086769-00086769)។ ការពិនិត្យឡើងវិញបញ្ជីអ្នកទោសនៅមន្ទីរ ស-២១ ឯកសារ (ក.ស.ព) ឯកសារ **E3/342** ចុះថ្ងៃទី ១៩ ខែ ឧសភា ឆ្នាំ ២០០៩ ERN (EN-KH) 00329929។ ឧបសម្ព័ន្ធ ២៧៧៖ បញ្ជីអ្នកទោសនៅមន្ទីរ ស-២១

"អនុវរតូច" ត្រូវបានឃុំខ្លួននៅថ្ងៃទី៥ ខែមីនា ឆ្នាំ១៩៧៧ ហើយសម្លាប់នៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ១៩៧៧[2283]។ ទាក់ទងទៅនិង ភួង អ៊ឹម ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា "រួចទៅបាត់ដំណឹងសូន្យឈឹង ឈ្មោះ ភួង អ៊ឹមហ្នឹង"[2284]។

### *ចៅ សេង បងប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឃឹម*

1063. ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឃឹម បានផ្តល់សក្ខីកម្មអំពីមរណភាព បងប្រុសរបស់គាត់ឈ្មោះ ចៅ សេង នៅមន្ទីរស-២១។ សាក្សី កាំង ហ្កេកអ៊ាវ បានគាំទ្រដល់សក្ខីកម្មរបស់ ចៅ ឃឹម។ គាត់បានផ្តល់សក្ខីកម្មថា "ខ្ញុំសូមជម្រាបថា ការដែលគេបញ្ជូនបង ចៅ សេង ទៅដល់មន្ទីរស-២១នោះ គឺក្នុងខែ៧ សុំទោសគឺក្នុងខែ៨ ឆ្នាំ១៩៧៧។ មុននឹងបង សុន សេន គាត់រៀបចំចេញទៅហ្នឹង គាត់បញ្ជាឲ្យខ្ញុំរៀបចំអ៊ីចឹង បងចៅ សេង មក។ ដល់បងសុន សេន អញ្ជើញទៅកាន់កាប់ទីតាំងសមរភូមិមុខទៅ នៅបងនួន ជា ចុះមកដឹកនាំខ្ញុំដោយផ្ទាល់។ ខ្ញុំទុកចៅ សេង យូរណាស់។ បានថាថ្ងៃក្រោយមកពូនួនគាត់សួរ "ចៅ សេង ម៉េចហើយ? ខ្ញុំថានៅទុកប្រើ។ គាត់ថា កម្ទេចទៅ""[2285]។

### *រស់ សារិន ប្តីរបស់ដើមបណ្តឹងរដ្ឋប្បវេណី រស់ ជួរស៊ីអ៊ី*

1064. ដើមបណ្តឹងរដ្ឋប្បវេណី រស់ ជួរស៊ីអ៊ី ត្រូវបានបង្ហាញនូវបញ្ជីឈ្មោះ អ្នកទោសនៅមន្ទីរស-២១ ហើយបានអះអាងថាឈ្មោះប្តីរបស់គាត់ មាននៅក្នុងចំណោមឈ្មោះអ្នកទោស ដែលមកពីប្រទេស

---

ដែលមានឈ្មោះអ្នកទោសដែលត្រូវសួរចម្លើយនៅមន្ទីរ ស-២១ ឯកសារ **E3/8555** ចុះថ្ងៃទី ០៤ ខែ ធ្នូ ឆ្នាំ ១៩៧៨ ERN (KH) 00086769។

[2283] បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ របស់ ក.ស.ច.ស ឯកសារ **E3/10604** ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ERN 01222434 (យោង 01019293-01019436)។ បញ្ជីឈ្មោះអ្នកទោសដែលចូលចាប់ពីថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ១៩៧៧ ដល់ ១៧ ខែ មេសា ឆ្នាំ ១៩៧៧ ឯកសារ **E3/10506** ERN (KH) 010119316។ បញ្ជីឈ្មោះអ្នកទោសដែលចូលក្នុងខែ មីនា ឆ្នាំ ១៩៧៧ ឯកសារ **E3/9845** ERN (KH) 01010228។ បញ្ជីឈ្មោះអ្នកទោសកម្ទេចឆ្នាំ ១៩៧៧ ឯកសារ **E3/2286** ERN (KH) 00091258។

[2284] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៣៦ បន្ទាត់ ១៧-២០។

[2285] សក្ខីកម្មផ្ទាល់មាត់របស់សាក្សី កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០១៦ **E1/435.1** ទំព័រ ៥០ បន្ទាត់ ១៥-១៩។

បារាំង[2286]។ មានការកត់ត្រាថាគាត់បានចូលមន្ទីរស-២១ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ១៩៧៦[2287]។ នៅក្នុងបញ្ជីមួយទៀតដែលមានចំណងជើងថា ឈ្មោះអ្នកទោសកម្ទេចថ្ងៃ ១៨.៧.៧៧ ១៩៧៧ ឈ្មោះ រស់ សារិន នៅលេខរៀង៥៦។ គាត់ត្រូវបានគេកត់ត្រាថា "រស់ សារិន" ហៅម៉ៅ មកពីបារាំង ធ្វើការនៅ "ក្រុមហ៊ុនអាកាសចរណ៍" ថ្ងៃចូល១២ ធ្នូ ១៩៧៦ និងសម្លាប់នៅថ្ងៃ១៨ មីនា ១៩៧៧[2288]។ ឯកសារចុះហត្ថលេខាដោយ ហ៊ី[2289]។

*បងថ្លៃស្រីរបស់ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ទរ៉ា*

1065. ចំពោះការសម្លាប់ ឱម យិនដូនី ដែលជាបងថ្លៃរបស់ ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ទរ៉ា នោះដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបង្ហាញនូវ បញ្ជីឈ្មោះអ្នកទោសសម្លាប់នៅក្នុងឆ្នាំ ១៩៧៦ ហើយគាត់បានបញ្ជាក់ថា បងថ្លៃស្រីរបស់គាត់ត្រូវបានសម្លាប់ នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៧៦[2290]។ នៅពេលដែលសាកសួរដើមបណ្តឹងរដ្ឋប្បវេណី ថាតើគាត់ដឹងថាបងថ្លៃរបស់គាត់ ធ្វើការនៅផ្នែក

---

2286 ឈ្មោះអ្នកទោសមកពីស្រុកបារាំងមិនទាន់សួរ ឯកសារ **E3/9853** ERN (KH) 01010573។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រស់ ជួរ ស៊ីអ៊ី ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៦៨ បន្ទាត់ ៥-២២។

2287 ឈ្មោះអ្នកទោសមកពីស្រុកបារាំងមិនទាន់សួរ ឯកសារ **E3/9853** ERN (KH) 01010573។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រស់ ជួរ ស៊ីអ៊ី ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៦៨-៦៩ បន្ទាត់ ២៣-១០។

2288 បញ្ជីឈ្មោះអ្នកទោសកម្ទេច ឯកសារ **E3/2285** ERN (KH) 00009177, 00009179 (រស់ សារិន ហៅ ម៉ៅ មកពីប្រទេសបារាំង ក្រុមហ៊ុនអាកាសចរណ៍ មកដល់នៅថ្ងៃទី ១២ ខែធ្នូ ឆ្នាំ ១៩៧៦ នៅក្នុងបញ្ជីឈ្មោះអ្នកទោសកម្ទេចនៅថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៧៧)។

2289 បញ្ជីឈ្មោះអ្នកទោសកម្ទេច ឯកសារ **E3/2285** ERN (KH) 00009183 (ធ្វើនៅថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៧៧ ដែលចុះហត្ថលេខាដោយ ហ៊ី)។

2290 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ទរ៉ា ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៤៨ បន្ទាត់ ៦-១៥ ដោយដកស្រង់ បញ្ជីឈ្មោះអ្នកទោសកម្ទេចឆ្នាំ ១៩៧៦ ឯកសារ **E3/3187** ERN (KH) 00008844។

អគ្គីសនី ដូចបងប្រុសរបស់គាត់ដែរឬអត់នោះ[2291] គាត់បានផ្តល់សក្ខីកម្មថា "ចាស អត់ដឹងផង។ ប៉ុន្តែដឹងដែរថា យកបានមួយថ្ងៃ ស្អែកឡើងបានវាសម្លាប់ ខ្ញុំមើលដឹងដែរ"[2292]។

### *ស៊ូ ណែម បងប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី*

1066. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី បានផ្តល់សក្ខីកម្មអំពីការចាប់ខ្លួន និងការសម្លាប់បងប្រុសរបស់គាត់ឈ្មោះ ស៊ូ ណែម ហៅ ស៊ូ សូត្រ នៅមន្ទីរស-២១។ "បងថ្លៃទី៥ឈ្មោះ ស៊ូ ណែម ហៅ ស៊ូ សូត្រ ជាវេជ្ជបណ្ឌិតបានគេ ត្រូវគេសម្លាប់នៅគុកទួលស្លែង បោះពុម្ពដោយក្រសួងឃោសនាការ និងវប្បធម៌ ទំព័រទី៣៧"[2293]។ បងប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី បង្ហាញនៅលើបញ្ជីអ្នកទោសត្រូវបានសម្លាប់ មកពីផ្នែកសុខាភិបាល ដោយកត់ត្រាថា ស៊ូ សូត្រ ហៅ ស៊ូ ណែម ជាវេជ្ជបណ្ឌិតមកពីបាត់ដំបង ត្រូវបានសម្លាប់នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៧៦[2294]។

### *រស់ ម៉ៅ ជាពូរបស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម*

1067. ចំពោះការសម្លាប់ រស់ ម៉ៅ ដែលជាពូរបស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម គាត់ត្រូវបានបង្ហាញនូវបញ្ជីអ្នកទោស ដែលបានចូលមន្ទីរស-២១ នៅក្នុងខែមិថុនា ឆ្នាំ១៩៧៧ និងបញ្ជីអ្នកទោសដែលត្រូវបានកម្ទេច នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៧៧[2295]។ គាត់ត្រូវបានគេសាកសួរថាតើឈ្មោះ "រស់

---

[2291] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ទរ៉ា ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៤៨ បន្ទាត់ ១៤-១៥។

[2292] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ទរ៉ា ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៤៨ បន្ទាត់ ១៦-១៩។

[2293] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/250.1** ទំព័រ ៦០ បន្ទាត់ ៥-៨។

[2294] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ សុផានី ប្រតិចារឹក ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/251.1** ទំព័រ ៦០-៦១ បន្ទាត់ ២៣-២ ដោយដកស្រង់ឯកសារ បញ្ជីឈ្មោះអ្នកទោស និងកាលបរិច្ឆេទសម្លាប់ (បើត្រូវបានសម្លាប់) ឯកសារ **E3/3973** ERN (KH) 00006623 (អ្នកទោសផ្នែកសុខាភិបាលដែលត្រូវកម្ទេចហើយ)។

[2295] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/500.1** ទំព័រ ១៩ បន្ទាត់ ១០-១៨ ដោយដកស្រង់ ឧបសម្ព័ន្ធ ២៖ បញ្ជីអ្នកទោស ស-២១ ចូលប្រចាំថ្ងៃ ខែ មិថុនា ឆ្នាំ ១៩៧៧ ឯកសារ **E3/9646** ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ១៩៧៧ [ERN (KH) 01017054]។ បញ្ជីឈ្មោះអ្នកទោសកម្ទេច ឯកសារ **E3/2285** ERN (KH) 00009304 (ឈ្មោះអ្នកទោសកម្ទេច ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៧៧ ដែលជាចំណងជើងនៅ ERN (KH) 00009303)។

ម៉ៅ ហៅសាយ" ជាពូរបស់គាត់ឈ្មោះ សាយមែនឬមិនមែន។ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា "បាទពិតជាគាត់មែន"[2296]។ នៅលើបញ្ជីដែលមានចំណងជើងថា "ឈ្មោះអ្នកទោសកម្ទេចនៅថ្ងៃ ១៨.១០.១៩៧៧" ឈ្មោះរបស់ រស់ ម៉ៅ បង្ហាញនៅលេខរៀង ៣៥។ គាត់ត្រូវបានគេកត់ត្រាថា "រស់ ម៉ៅ" ហៅសាយ មកពីពាយ័ព្យ និងមានតួនាទី "ប្រធានមន្ទីរភូមិភាគ" ថ្ងៃចូល ១០ ខែកក្កដា ឆ្នាំ១៩៧៦ និងសម្លាប់នៅថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩៧៧[2297]។

***Michael Scott Deeds ដែលជាបងប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី Timothy Scott Deed***

1068. សាក្សី កាំង ហ្គេកអ៊ាវ ត្រូវបានសាកសួរអំពីករណី Michael Scott Deeds បងប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី Timothy Scott Deed ដែលត្រូវបានកត់ត្រាថាបានចូលមន្ទីរស-២១ នៅថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ពីខេត្តកំពង់សោម ដែលមានតួនាទីកត់ត្រាថា "ហាវ៉ៃ" និងដែលបានចូលជាមួយនឹងជនជាតិអាមេរិកម្នាក់ទៀតឈ្មោះ Edward Delance[2298]។ Michael Scott Deeds ក៏មានឈ្មោះផងដែរនៅក្នុងបញ្ជីឈ្មោះអ្នកទោស ក.ស.ច.ស នៅត្រង់លេខ ១២ ៧២០[2299]។

1069. សាក្សី កាំង ហ្គេកអ៊ាវ បានបញ្ជាក់ថា "នៅសំណុំរឿងលេខ ០០១ មានពីរនាក់មកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីហើយ។ នេះមកពីរនាក់ថ្មីទៀត ខ្ញុំសូមជម្រាបថា ពួកអស់នេះសុទ្ធតែបានទទួលការសួរចម្លើយ ហើយយកទៅកម្ទេច។ កម្ទេចនេះមានការណែនាំដាច់ខាត ឲ្យដុតនឹងកៅស៊ូកង់ឡានឲ្យអស់ កុំឲ្យសល់ឆ្អឹង"[2300]។ គាត់បានពន្យល់ថា "ជនជាតិអាមេរិកាំងនេះ ចាប់បញ្ជូនដោយកងពលសមុទ្រ ពីកំពង់សោមមកភ្នំពេញ គឺបញ្ជូនមកគណៈមជ្ឈិម ហើយមជ្ឈិមបញ្ជូនទៅឲ្យស-

[2296] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/500.1** ទំព័រ ១៩ បន្ទាត់ ១៨។

[2297] បញ្ជីឈ្មោះអ្នកទោសកម្ទេច ឯកសារ **E3/2285** ERN (KH) 00009304 (ឈ្មោះអ្នកទោសកម្ទេច ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ១៩៧៧ ដែលជាចំណងជើងនៅ ERN (KH) 00009303)។

[2298] បញ្ជីរាយនាមអ្នកទោស ៧ នាក់ដែលជាជនជាតិអាមេរិចកាំង និងវៀតណាមដែលត្រូវបានចាប់ខ្លួននៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ១៩៧៨ ឯកសារ **E3/1553** ERN (KH) 00088752។ សក្ខីកម្មផ្ទាល់មាត់របស់សាក្សី កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/435.1** ទំព័រ ៥៦ បន្ទាត់ ២-២៣។

[2299] បញ្ជីឈ្មោះអ្នកទោសនៅមន្ទីរ ស-២១ របស់ ក.ស.ច.ស ឯកសារ **E3/10604** ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ លេខរៀងទី 12720។

[2300] សក្ខីកម្មផ្ទាល់មាត់របស់សាក្សី កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/435.1** ទំព័រ ៥៦ បន្ទាត់ ១៧-២៣។

២១ សួរចម្លើយ និងកម្ទេច។ ដូច្នេះបទគឺរំលោភដែនទឹកខ្មែរ ចូលយកការណ៍។ ហើយយើងខ្ញុំសួរ ហើយកម្ទេច ដូចបានជម្រាបរួចហើយ។ ដូច្នេះអត់មានបាននេះទេ អត់សល់ស្អីទេ"[2301]។

1070. សាក្សី កាំង ហ្កេកអ៊ាវបានពន្យល់ទៅលើ កំណត់ហេតុស្តាប់ចម្លើយកន្លងមក ដែលក្នុងកំណត់ហេតុនោះគាត់បានបញ្ជាក់ថា ពួកលោកខាងលិចទាំងអស់នេះ ត្រូវបានសម្លាប់និងដុតចោល បន្ទាប់ពីមានបញ្ជាពី នួន ជា ដោយដុតចោលនៅក្បែផ្លូវម៉ៅសេទុង និងផ្លូវ១៦៣ នៅក្នុងទីក្រុងភ្នំពេញ គឺនៅទីកន្លែងមួយដែលធ្លាប់ជាត្រពាំង[2302]។ សាក្សីពន្យល់ថា "គាត់ហៅខ្ញុំទៅធ្វើការ កន្លែងធ្វើការហ្នឹងគឺនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ដល់ទៅគាត់ប្រាប់ថា ពួកអាច្រមុះស្រួចកម្ទេច ហើយដុតវាឱ្យឆេះសុះទៅកុំឱ្យសល់ យើងមិនធ្វើដូចគុយបាទេ។ គុយបាគេទុកទាហានអាមេរិកាំង ដើម្បីដូរយកត្រាក់ទ័រ យើងមិនធ្វើទេ។ ដុតឱ្យសុះឱ្យអស់ទៅ កុំឱ្យវាសល់ភ័ស្តុតាង។ នេះគឺគាត់ប្រាប់ខ្ញុំដោយផ្ទាល់មាត់ នៅពេលដែលហៅខ្ញុំទៅធ្វើការជាមួយនឹងគាត់"[2303]។

1071. ក្នុងពេលពន្យល់ថាហេតុអ្វីចាំបាច់ដុត ពយកបស្ទឹមប្រទេសនោះ សាក្សី កាំង ហ្កេកអ៊ាវ បានផ្តល់សក្ខីកម្មថា "ការដុតកម្ទេចឱ្យអស់កុំឱ្យសល់ គឺកុំឱ្យមានភ័ស្តុតាងស្លាកស្នាម ថាមានជនបស្ចឹមប្រទេសមក យើងបានចាប់ហើយយើងបានកម្ទេច។ ហើយគាត់និយាយថែមទៀតថា ខ្ញុំសូមនិយាយម្តងទៀតចុះ ថាយើងមិនធ្វើដូចគុយបាទេ គុយបាគេទុកទាហានអាមេរិកាំង ដើម្បីដូរយកត្រាក់ទ័រ ឯចំណែកយើងអត់ទេ។ យើងដុតឱ្យអស់អ៊ីចឹង។ នេះជាបទបញ្ជាដាច់ណាត់ ដែលខ្ញុំត្រូវតែធ្វើតាម"[2304]។

---

2301 សក្ខីកម្មផ្ទាល់មាត់របស់សាក្សី កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/435.1** ទំព័រ ៥៧ បន្ទាត់ ១-៤។

2302 សក្ខីកម្មផ្ទាល់មាត់របស់សាក្សី កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/435.1** ទំព័រ ៥៧ បន្ទាត់ ៦-១៥ ដោយដកស្រង់កំណត់នៃការសួរចម្លើយរបស់ កាំង ហ្កេកអ៊ាវ ឯកសារ **E3/1570** ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០០៧ ERN (KH) 00154224។

2303 សក្ខីកម្មផ្ទាល់មាត់របស់សាក្សី កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/435.1** ទំព័រ ៥៧ បន្ទាត់ ១៦-២០។

2304 សក្ខីកម្មផ្ទាល់មាត់របស់សាក្សី កាំង ហ្កេកអ៊ាវ ប្រតិចារឹក ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/435.1** ទំព័រ ៥៧-៥៨ បន្ទាត់ ២៤-៣។

1072. សាក្សី កាំង ហ្គេកអ៊ាវ បានពន្យល់អំពីទីតាំង និងកាលៈទេសៈនៃការស្លាប់របស់ជនជាតិអាមេរិក។ "ដើមឡើយភ្នំពេញមិនមានផ្ទះថ្មអី ច្រូងច្រាងដូចពេលនេះទេ។ កន្លែងនោះនៅសល់គុម្ពោតព្រៃរដិបរដុបច្រើន ហើយមានត្រពាំងមួយធំបន្តិច។ ទៅថតឆាកដែលយួនចូលស្រុកខ្មែរ ហើយលើកដែក៏ទៅថតនៅនុ៎ង ហើយយកពួកបស្ចឹមប្រទេសប៉ុន្មាននាក់ហ្នឹង យកទៅកម្ទេចក៏កម្ទេចនៅនុ៎ង ហើយដុតនឹងកង់ឡានឲ្យអស់"[2305]។ "គ្មានមនុស្សអ៊ូអែទេ គ្មានសំរាម គ្មានអាចម៍នោមអីទៅចូលនុ៎ងបានទេ អត់ទេ។ មានតែព្រៃគុម្ពោតៗ។ យើងអាចលាក់ខ្លួនធ្វើសកម្មភាពស្ងៀៗ អ៊ីចឹងបានស្រួល"[2306]។

*សាច់ញាតិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលត្រូវបានកត់ត្រាថាបានសម្លាប់នៅមន្ទីរស-២១*

1073. ឧបសម្ព័ន្ធ ឆ បង្ហាញថា សាច់ញាតិចំនួនសាមសិបពីរនាក់ របស់ដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានកត់ត្រាថាបានសម្លាប់នៅមន្ទីរស-២១ ក្នុងអំឡុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក។ ឧបសម្ព័ន្ធបានផ្ដល់នូវកាលបរិច្ឆេទនៃការសម្លាប់ និងការយោងទៅរកកំណត់ត្រាសហសម័យ ដែលកត់ត្រាពីការសម្លាប់ពួកគេ[2307]។

## ៣.២. ការស្លាប់ដោយសារស្ថានភាព

1074. ចំពោះការស្លាប់របស់ឈ្មោះ ស៊ូ ជឹម ដែលត្រូវជាឪពុករបស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន ឯម គាត់ត្រូវបានបង្ហាញនូវឯកសារដែលមានចំណងជើងថា "បញ្ជីឈ្មោះអ្នកទោសចូលថ្ងៃ២៨ មិថុនា ១៩៧៧" និងឯកសារដែលមានចំណងជើងថា "បញ្ជីក្ដាប់កម្លាំងអ្នកទោសប្រចាំថ្ងៃ ៣០/៧/៧៧" ដែលឯកសារទាំងពីរត្រូវបានបង្ហាញ ជូនដើមបណ្ដឹងរដ្ឋប្បវេណីដើមបណ្ដឹងរដ្ឋប្បវេណី[2308]។

---

[2305] សក្ខីកម្មផ្ទាល់មាត់របស់សាក្សី កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/435.1** ទំព័រ ៥៨ បន្ទាត់ ៨-១១។

[2306] សក្ខីកម្មផ្ទាល់មាត់របស់សាក្សី កាំង ហ្គេកអ៊ាវ ប្រតិចារឹក ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០១៦ ឯកសារ **E1/435.1** ទំព័រ ៥៨ បន្ទាត់ ១៦-១៩។

[2307] ឧបសម្ព័ន្ធ ចៈ ដើមបណ្ដឹងរដ្ឋប្បវេណី និងសាច់ញាតិរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដែលចូល ឬត្រូវបានសម្លាប់នៅមន្ទីរ ស-២១។

[2308] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/500.1** ទំព័រ ១៦-១៧ បន្ទាត់ ២៤-១៧ ដោយដកស្រង់ ឧបសម្ព័ន្ធ ២ៈ បញ្ជីអ្នកទោស ស-២១ ចូលប្រចាំថ្ងៃ ខែ មិថុនា ឆ្នាំ ១៩៧៧ ឯកសារ **E3/9646** ERN (KH) 01017058។ បញ្ជីក្ដាប់កម្លាំងអ្នកទោសប្រចាំថ្ងៃ ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៧ ឯកសារ **E3/9996** ERN (KH) 01012304។

"បាទពិតហើយ គាត់គឺជាឪពុកខ្ញុំ"[2309]។ បញ្ជីនេះបានកត់ត្រាថា "ស្វ ជឹម ហៅចែត ប្រធានរោងចក្រតម្បាញបាត់ដំបង ងាប់ដោយជំងឺរាកមួល ដំបៅខ្នងខ្លាំង (បានព្យាបាលរយៈពេលមួយខែ)"[2310]។

## ៤. ការដាក់ឲ្យនៅជាទាសករ

1075. ភស្តុតាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានលើកឡើងនៅក្នុងសវនាការ បានកំណត់ថាអ្នកជាប់ឃុំមួយចំនួននៅមន្ទីរស-២១ ត្រូវទទួលរងនូវប្រើប្រាស់ អំណាចខ្លះឬទាំងអស់ ដែលជាសិទ្ធិនៃភាពជាម្ចាស់ ទៅលើមនុស្សម្នាក់។

1076. ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី បានផ្តល់សក្ខីកម្មថា បន្ទាប់ពី១២ថ្ងៃនៅ មន្ទីរសន្តិសុខស-២១រួចមក "ឈ្មោះ ស្ងួស ធី ហ្នឹង វាសួរអាណាចេះជួសជុលម៉ាស៊ីនដេរ នៅពីអូរឫស្សីហ្នឹង អ្អែងចេះជួសជុលម៉ាស៊ីនដេរ អញ ស្អែកយកខោអាវឲ្យអ្អែងស្លៀកពាក់ តែអ្អែងកុំរត់ តែរត់បាញ់អ្អែងចោលហើយ"[2311]។

1077. "ពេលនុ៎ងវាឲ្យយើងជួសជុលម៉ាស៊ីនដេរខាងក្រោយហ្នឹង គឺថាជាងជួសជុលបាន១0គ្រឿង ជួសជុលម៉ាស៊ីនដេរហ្នឹង។ បន្ទាប់មកវាឲ្យយើងជួសជុលអង្គុលីលេខ។ អាអង្គុលីលេខហ្នឹង កាលណាវាវ៉ៃអ្នកទោស វាប្រើអាអង្គុលីលេខហ្នឹង ដល់អាហ្នឹងខូច អត់មានពីណាចេះជួសជុលអាហ្នឹងទេ មានតែខ្ញុំចេះជួសជុលអាហ្នឹង។ អ៊ីចឹងវាឲ្យយើងជួសជុលអាហ្នឹង បានបីគ្រឿង បន្តមកវាឲ្យយើងជួសជុលអាម៉ាស៊ីនបូមទឹកទៀត"[2312]។

1078. នៅអំឡុងពេលនោះ ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ត្រូវបានឃុំខ្លួនក្នុង "បន្ទប់ធំ" ក្នុងអគារ គ។ "នៅពេលនុ៎ង យើងឃើញថា វានៅក្នុងបន្ទប់ហ្នឹងយើងមើលឃើញ ប្រហែលជា៤0នាក់បាទ ៤0នាក់

[2309] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/500.1** ទំព័រ ១៧ បន្ទាត់ ១៩។

[2310] បញ្ជីក្តាប់កម្លាំងអ្នកទោសប្រចាំថ្ងៃ ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ ១៩៧៧ ឯកសារ **E3/9996** ERN (KH) 01012304។

[2311] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ៣០ បន្ទាត់ ៥-៧។

[2312] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ៣១ បន្ទាត់ ១៩-២៣។

ប៉ុន្តែសុទ្ធតែដាក់ខ្នោះជើង អាខ្នោះវែងៗនោះក្លួយ ខ្នោះវែងៗនោះ”[2313]។ “ពេលនុំងគេលែងឲ្យយើងហូបទឹកបបរទៀតហើយ គេហៅញុំាបបរប៉ិៗបាទ ញុំាបបរប៉ិៗ ហើយស្លៀកពាក់ធម្មតា ស្លៀកពាក់ខោវែង អាវដៃវែងអ៊ីចឹងបាទ"[2314]។ “គេឲ្យយើងនៅស្ងៀម កុំឡូឡា”[2315]។

1079. ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា "គេទុកយើងប្រៀបដូចជាសត្វអ៊ីចឹង ប្រៀបដូចជាសត្វអ៊ីចឹង។ ទាំងការហូបចុក ទាំងការនិយាយស្តីស្អីៗ គឺថាគេ គឺថាយើងអត់មានសិទ្ធិសេរីភាពអីនិយាយរកគ្នាទេ"[2316]។

## ៥. អំពើអមនុស្សធម៌ដទៃទៀត

1080. ភ័ស្តុតាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានលើកឡើងនៅក្នុងសវនាការបានបង្ហាញថា ការប្រព្រឹត្តរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានកំណត់និងដំណើរការមន្ទីរសន្តិសុខស-២១ បានគ្រប់ដណ្តប់ទៅលើការរំលោភបំពាន សិទ្ធិរបស់អ្នកជាប់ឃុំ ក្នុងការទទួលបានការរស់រានមានជីវិត និងទទួលបានបទដ្ឋានសមស្របមួយ សម្រាប់ការរស់នៅ សិទ្ធិមិនទទួលរងការប្រព្រឹត្តអមនុស្សធម៌ បន្ទាបបន្ថោក និងកាចសាហាវ ព្រមទាំងសិទ្ធិមិនត្រូវបានចាប់ខ្លួនតាមអំពើចិត្ត[2317]។ ការប្រព្រឹត្តនោះបង្កើតបានជា អំពើដែលមានលក្ខណៈនិងស្ថានទម្ងន់ប្រហែលគ្នានឹង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដទៃទៀត ហើយបានបង្កនូវព្យសនកម្មធ្ងន់ធ្ងរ ឬបង្កើតបានជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូ របស់ដើមបណ្តឹងរដ្ឋប្បវេណី។

### *ស្ថានភាពនៃការឃុំឃាំង*

---

[2313] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ២៩ បន្ទាត់ ៤-៥។

[2314] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ២៩ បន្ទាត់ ៨-៩។

[2315] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ៣០ បន្ទាត់ ២។

[2316] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ៣៩-៤០ បន្ទាត់ ២៥-២។

[2317] សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៤៨ មាត្រា ២ មាត្រា ៥ មាត្រា ៩ មាត្រា ២៥។

1081. បន្ទាប់ពីគាត់ត្រូវបានគេវាយ ហើយមានរបួសស្នាមរួចមក ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី បានផ្តល់សក្ខីកម្មថា "នៅស-២១អត់មានពេទ្យព្យាបាលទេ ជម្រាបលោកព្រះរាជអាជ្ញា អត់មានពេទ្យព្យាបាលទេ"[2318]។

1082. "គេឱ្យយើងដេកនៅនឹងឥដ្ឋហ្នឹង អត់មានមុង អត់មានស្មើទេក្មួយ ដេកនៅនឹងឥដ្ឋហ្នឹង"[2319]។ "ពេលនោះយើងកុំនិយាយពីរឿងសង្កើច រឿងពីស្រមោច គិតតែខ្លួនហ្នឹងហើមពេញហ្នឹងតែទាំងអស់ទៅហើយ"[2320]។

1083. ចំពោះបញ្ហាអនាម័យវិញ ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី បានរៀបរាប់ថា "ការងូតទឹក ខ្ញុំជាប់រយៈ៤ខែ ១២ថ្ងៃហ្នឹង យើងបានគេបាញ់ទឹកឱ្យតែម្តងទេ"[2321]។ "ពេលគេយកធុងទឹកមកដល់ហ្នឹង គេឱ្យយើងស្រាតខោខ្លីហ្នឹងចេញ ហើយយើងស្រាត យើងស្រាតចេញអត់រួច ខោខ្លីហ្នឹង យើងស្រាតចេញអត់រួច ព្រោះយើងវាជាប់ខ្នោះ។ អ៊ីចឹងវាឱ្យយើងបន្តិចចេញតាមអានេះខ្នោះហ្នឹង បន្តិចចេញបន្តិចៗទៅ កុំឱ្យវាទទឹកខោហ្នឹង ដាក់ខោឡើងលើទៅ។ អាហ្នឹងខ្ញុំត្រូវប៉ុន្មានរំពាត់ដែរ ប៉ុន្តែខ្ញុំអត់រាយការណ៍ជូនឯកឧត្តមទេ គឺថាដោយសារយើងស្រាតខោអត់ចេញ ដល់វាបង្ហាញ វាវ៉ៃ"[2322]។

1084. ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី បានរៀបរាប់ថា "គេឱ្យយើងបត់ជើងតូចនៅអាប៊ីដុងហ្នឹង ហើយបត់ជើងធំនៅអាកេសគ្រាប់ហ្នឹង"[2323]។ គាត់បន្តផ្តល់សក្ខីកម្មថា "ពេលនោះកាលណាយើងបត់ជើងធំកាលណាកំពប់វាឱ្យយើងលិឍ។ បត់ជើងតូចក៏អ៊ីចឹងដែរ កាលណាកំពប់សើមអី ទទឹកអី វាឱ្យ

---

[2318] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ៤១ បន្ទាត់ ៩-១០។

[2319] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ២៩ បន្ទាត់ ១៩។

[2320] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ២៩ បន្ទាត់ ២១-២២។

[2321] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ៣៩ បន្ទាត់ ៨។

[2322] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ៣៩ បន្ទាត់ ១១-១៥។

[2323] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ២៩ បន្ទាត់ ២៥។

យើងលិឍឲ្យស្អាត"[2324]។ "ខ្ញុំលិឍបាទ។ ពេលយើងបត់ជើងអត់ចំហ្នឹង វាខ្លាយ យើងលិឍឲ្យស្អាតទៅ។ បើមិនលិឍម៉េច យើងខ្លាចវាវ៉ៃ"[2325]។ ដើមបណ្តឹងរដ្ឋប្បវេណីពន្យល់ថា "លាមកហ្នឹងដែលខ្លាយពីអាកេសហ្នឹង វាឲ្យយើងលិឍឲ្យស្អាតបាទ។ តែកាលនាលិឍមិនស្អាត វាវ៉ៃយើងទៀត។ ទឹកនោមអ៊ីចឹងដែរ កាលណាយើងលិឍមិនស្អាត វាវ៉ៃយើងទៀត"[2326]។

1085. ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី បានរៀបរាប់ពីផលប៉ះពាល់ ដែលគាត់ទទួលរងបណ្តាលមកពីអាហារមិនគ្រប់គ្រាន់នៅមន្ទីរស-២១។ "ក្នុង១២ថ្ងៃ១២យប់ហ្នឹង គឺថាពេលព្រឹកខ្ញុំបានតែទឹកបបរមួយវែកទេលោកប្រធាន ទឹកបបរសុទ្ធ។ ពេលថ្ងៃល្ងាចមួយវែកទៀត ក្នុងមួយថ្ងៃបានតែពីរវែកទេ ខ្ញុំមានកម្លាំងអីបើទឹកបបរពីរវែក អត់មានគ្រាប់អង្ករមួយគ្រាប់ណាទេ ទឹកបបរសុទ្ធបាទ ទឹកបបរសុទ្ធ ហើយខ្ញុំពិចារណាខ្លួនឯងថា ខ្ញុំថាប្រហែលគេឲ្យខ្ញុំហូបទឹកបបរនឹង ប្រហែលគេមិនចង់ឲ្យខ្ញុំតតាំងនឹងគេហើយ បានគេឲ្យទឹកបបរហ្នឹង កាលណាគេឲ្យបាយទៅ ក្រែងខ្ញុំមានកម្លាំងតតាំងនឹងគេ។ ខ្ញុំគ្រាន់តែនឹកក្នុងចិត្តអ៊ីចឹងទេលោកប្រធានបាទ"[2327]។

## គ. ព្យសនកម្ម

### ១. ព្យសនកម្មរូបរាងកាយ

*ព្យសនកម្មរូបរាងកាយភ្លាមៗ*

1086. នៅក្នុងការរៀបរាប់អំពីការឈឺចាប់ភ្លាមៗ ដែលគាត់បានទទួលរងនៅពេលសួរចម្លើយនោះ ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី បានផ្តល់សក្ខីកម្មថា "វាដកក្រចកមេជើងយើងម្ខាង បាទដកក្រចកមេជើងម្ខាង វាដកទាញអត់ដាច់វាកន្ត្រាក់ៗអ៊ីចឹង យើងចង់សន្លប់ អាជើងម្ខាងវាដកដែល តែដកអត់

---

[2324] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ៣០ បន្ទាត់ ២២-២៣។

[2325] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ៣១ បន្ទាត់ ២-៣។

[2326] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ **E1/417.1** ទំព័រ ៣១ បន្ទាត់ ១៣-១៤។

[2327] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៧ ឯកសារ **E1/418.1** ទំព័រ ៣៧ បន្ទាត់ ១៦-២១។

រួចបាទ។ ក្រោយមកបានវាយកអាខ្សែភ្លើងដាក់ក្នុងរុនត្រចៀកខ្ញុំ ដាក់ឆាច់ រ៉ុង! អ៊ីចឹងយើងសន្លប់ អត់ដឹងខ្លួនទេ"[2328]។ "ការឈឺចាប់ឆក់ខ្សែភ្លើងហ្នឹង វាឈឺចាប់ភ្លាម វាឈឺចាប់ខ្លាំងទាល់តែយើងសន្លប់ អត់ដឹងខ្លួនចំនួនពីរដង សន្លប់ពីរដងអត់ដឹងខ្លួន"[2329]។

1087. ចំពោះផលវិបាកនៃការសួរចម្លើយចំនួន១២ថ្ងៃ ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មថា "យើងអត់មានកម្លាំងទេ ពេលនោះយើងហត់ហេវ ណាមួយហូបអត់គ្រប់គ្រាន់ ណាមួយយើងដេកនៅនឹងឥដ្ឋ ព្រោះអាដេកនៅនឹងឥដ្ឋហ្នឹងហើយ ដែលវាខ្សោះយើង វាអត់នេះអត់មាននេះ វាខ្សោះយើងម៉្លោះហើយយើងអត់កម្លាំងទេ"[2330]។

***ព្យសនកម្មរូបរាងកាយនៅរយៈពេលវែង***

1088. ជាលទ្ធផលនៃការឆក់ខ្សែភ្លើង និងការវាយក្នុងពេលសួរចម្លើយ ដែលដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី បានទទួលរងនៅមន្ទីរសន្តិសុខស-២១នោះ ដើមបណ្ដឹងរដ្ឋប្បវេណីបានរៀបរាប់ថា "ម្ខាងហ្នឹងឥឡូវប្រើការអត់កើតទេលោកប្រធានអត់បានទេ។ គោះអ៊ីចឹងដូចទឹកចូលអ៊ីចឹង ទឹងៗបាទ ហើយបិទម្ខាងនេះស្រែកម៉េចក៏អត់ឮដែរ។ អាពេលហ្នឹងដែលខ្ញុំឃើញនេះអ៊ីចឹង គឺថាខ្ញុំមានតែស្លាប់តែម្ដង ពីព្រោះអត់ដឹងខ្លួនទាល់តែសោះ"[2331]។

---

[2328] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៧ ឯកសារ E1/418.1 ទំព័រ ៣៧ បន្ទាត់ ៦-៩។

[2329] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៧ ឯកសារ E1/417.1 ទំព័រ ៤២ បន្ទាត់ ១២-១៣។

[2330] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៦ ឯកសារ E1/417.1 ទំព័រ ៣៩ បន្ទាត់ ៣-៥។

[2331] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៧ ឯកសារ E1/418.1 ទំព័រ ៣៧ បន្ទាត់ ៩-១១។

1089. ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី បានផ្តល់សក្ខីកម្មថា "វាពិបាកនោះ បញ្ហាពិបាកៗហើយ ព្រោះទី១គឺកម្រិតវប្បធម៌ខ្ញុំ វាមិនបានខ្ពង់ខ្ពស់ទេ ហើយពេលឥឡូវនេះ គឺថាភ្នែករបស់ខ្ញុំក៏អត់បានភ្លឺច្បាស់ដែរ ដោយសារគេដាក់ខ្សែភ្លើង អាភ្នែកខាងនេះប្រើអត់កើតទេ"[2332]។

## ២. ព្យសនកម្មផ្លូវចិត្ត

*ព្យសនកម្មផ្លូវចិត្តដែលទទួលរង ដោយជនរងគ្រោះផ្ទាល់ឈ្មោះ ជុំ ម៉ី*

1090. នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ត្រូវបានចាប់ខ្លួនដំបូង គាត់មានអារម្មណ៍បារម្ភអំពីគ្រួសារគាត់។ "ខ្ញុំបានផ្តែផ្តាំថា ឲ្យសុំជួយមើលកូនប្រពន្ធខ្ញុំផង ហើយយើងដើរមកដល់ពាក់កណ្តាលថ្នល់ ខ្ញុំផ្តែផ្តាំអ៊ីចឹង វាធាក់ខ្ញុំមួយជើងដួលផ្កាប់មុខទៅ វាចាប់ទាញសក់ក្បាលឡើង វាជេរខ្ញុំទៀត "អាចុយម៉ាយ អ្អែងនៅផ្តាំផ្ញើរដល់ណាទៀត" វារុញខ្ញុំចូលសារមន្ទីរទួលស្លែងទៅ"[2333]។ នៅពេលសាកសួរអំពីការឈឺចាប់ ដែលបណ្តាលមកពីការមិនអាច ប្រាប់ដល់គ្រួសាររបស់គាត់នោះ "ខ្ញុំពេលនោះខ្ញុំមានការឈឺចាប់ខ្លាំងណាស់។ យើងអត់ដឹងថា វាសនារបស់ខ្ញុំទៅជាយ៉ាងម៉េចអីយ៉ាងម៉េច យើងអត់ដឹងបាទ"[2334]។ នៅពេលនោះប្រពន្ធរបស់គាត់មានផ្ទៃពោះ។ "ពេលនោះខ្ញុំបារម្ភមែនទែន បារម្ភខ្លាំង ដោយសារយើងមិនដឹងស្លាប់ ឬរស់ យើងអត់ដឹង"[2335]។

---

2332 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១៧ ឯកសារ E1/418.1 ទំព័រ ១៥-១៦ បន្ទាត់ ២៥-២។

2333 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៧ ឯកសារ E1/417.1 ទំព័រ ៣៦ បន្ទាត់ ១៥-១៧។

2334 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៧ ឯកសារ E1/417.1 ទំព័រ ៣៧ បន្ទាត់ ៣-៤។

2335 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៧ ឯកសារ E1/417.1 ទំព័រ ៣៧ បន្ទាត់ ៨។

1091. "ថ្ងៃ០៧ មករាហ្នឹង គឺថាថ្ងៃជីវិតខ្ញុំរស់ៗបាន ជំនាន់ពេលនុំង កុំមានថ្ងៃ០៧មករា ខ្ញុំអត់បានជួបមុខក្មួយៗទាំងអស់គ្នាទេ គេសម្លាប់ខ្ញុំបាត់ហើយ។ ខ្ញុំវេទនាណាស់។ ស្លាប់គ្រួសារអស់ បងប្អូនប្រាំបីនាក់ សល់តែពីរនាក់ វាសម្លាប់អស់រលីង"[2336]។

1092. នៅពេលរៀបរាប់ពីអារម្មណ៍របស់គាត់ ក្នុងពេលជាប់ឃុំឃាំង ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី បានរៀបរាប់ថា "យើងភ័យណាស់ យើងបារម្ភចេះតែនឹកភ័យ ខ្ញុំមិនដឹងថ្ងៃណានឹងស្លាប់ ទោះបីគេមិនសម្លាប់ឱ្យតែជាប់នៅហ្នឹងយូរ ក៏ត្រូវតែស្លាប់ដែរ"[2337]។

1093. នៅពេលសាកសួរថាគាត់យល់ឃើញយ៉ាងណាអំពីអនាគត នៅពេលដែលគាត់ជាប់ឃុំនៅមន្ទីរសន្តិសុខស-២១ នោះ ដើមបណ្តឹងរដ្ឋប្បវេណីបានឆ្លើយតបថា "ពេលនោះយើងមានការឈឺចាប់ខ្លាំងណាស់បាទ ឈឺចាប់ខ្លាំងមែនទែន។ យើងនឹកថាខ្ញុំទៅថ្ងៃក្រោយ ខ្ញុំនឹងជម្រាបប្រាប់ពិភពលោកឱ្យគេបានដឹងការពិត"[2338]។

***ព្យសនកម្មផ្លូវចិត្តដែលទទួលរង ដោយជនរងគ្រោះមិនផ្ទាល់***

1094. ដើមបណ្តឹងរដ្ឋប្បវេណី ឆែ ប៉ាប បានផ្តល់សក្ខីកម្មអំពីការដែលគាត់ បានដឹងថាបងប្រុសគាត់ត្រូវបានឃុំខ្លួននៅស-២១ និងបានរៀបរាប់ពីការឈឺចាប់របស់គាត់។ "ខ្ញុំនៅផ្ទះ តែឮគេផ្សាយវ៉ាដ្យូដែរប៉ុន្តែខ្ញុំគ្មានថវិការមកមើលទួលស្លែង។ តែក្រោយមកឃើញអង្គការឯកសារកម្ពុជា យកឯកសាររូបថតបងខ្ញុំនេះ ទៅសួរដល់ស្រុកភូមិខ្ញុំហ្នឹង ទៅសួរចំគេអ្នកដទៃ។ ទៅដល់គេប្រាប់ថាផ្ទះខ្ញុំ។ ខ្ញុំឃើញរូបថតៗហ្នឹងយំម៉្ងៃ។ អាណិតបងគេធ្វើបាបមុននឹងសម្លាប់ ហើយឃើញស្គម។ ដែលខ្ញុំតែង

[2336] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៧ ឯកសារ E1/417.1 ទំព័រ ៣២ បន្ទាត់ ១៩-២១។

[2337] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៧ ឯកសារ E1/417.1 ទំព័រ ៣៩ បន្ទាត់ ២០-២១។

[2338] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ប្រតិចារឹក ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០១៧ ឯកសារ E1/417.1 ទំព័រ ៤២ បន្ទាត់ ១៧-១៨។

តែនៅជាមួយ ទៅលេង ខ្ញុំឃើញគាត់សាច់ឈាមគ្រាន់ ដល់ឃើញស្គមហើយ ឃើញអ្នកជាប់ឃុំឃាំងទៀត ខ្ញុំស្រក់ទឹកភ្នែករហូត"[2339]។

1095. ចំពោះផែ ហេង ដែលជាបងប្រុសរបស់ដើមបណ្តឹងរដ្ឋប្បវេណី ផែ ហ៊ាប មិនមានពិធីបញ្ចុះសពនោះឡើយ ហើយសមាជិកគ្រួសារគាត់ដទៃទៀតក៏មិនមានពិធីដែរ។ "បើនិយាយរឿងធ្វើបុណ្យអត់មានថវិការធ្វើទេសព្វថ្ងៃហ្នឹងនោះ ម្តាយខ្ញុំខំទុកសក់ទាល់តែវែង ចាំកូនទៅៗសឹមកោរ ដល់តាហានគាត់សារភាពទៅ ដល់ខ្ញុំទៅថា "ហ៊ឺ! គ្មានសង្ឃឹមទេគាត់កោរទៅ" ឆ្នាំហ្នឹងគាត់ស្លាប់បាត់ទៅមិនដែលបានធ្វើបុណ្យទេ"[2340]។ ដើមបណ្តឹងរដ្ឋប្បវេណី ផែ ហ៊ាប បានរៀបរាប់ពីផលប៉ះពាល់ ពីការបាត់បង់របស់គាត់ ដែលមានជារៀងរហូតថា "បើនិយាយពីរឿងទុក្ខព្រួយវិញ មិនជឿសួរគ្រួសារខ្ញុំទៅ ពេលខ្ញុំទាញហ្នឹងមើលហើយ ទឹកភ្នែកហូររហូត ដោយសារអី ដោយសារស្រណោះខ្លួន កើតចំសង្គមពិបាក"[2341]។

1096. នៅពេលរំឭកអំពីជោគវាសនារបស់បងប្រុសគាត់ ដើមបណ្តឹងរដ្ឋប្បវេណី ផែ ហ៊ាប បានពន្យល់ថា "បងប្អូនខ្ញុំនេះតស៊ូហើយគេសម្លាប់ទៀត បាទខ្ញុំឆ្អែតចិត្តហ្មង។ ខ្ញុំឆ្អែតដោយសារអីចឹង ខំតស៊ូហើយគេយកទៅសម្លាប់ទៀត"[2342]។

1097. ដើមបណ្តឹងរដ្ឋប្បវេណី ខៀវ នាប បានផ្តល់សក្ខីកម្មអំពីព្យសនកម្ម ដែលគាត់បានទទួលរងក្នុងនាមជាស្ត្រីមានផ្ទៃពោះ ហើយមានកូននៅតូចទៀត ក្រោយពេលដែលប្តីគាត់បានបាត់ខ្លួន។ "ចាសនាងខ្ញុំគឺមានតែការទុក្ខសោក ពីសម័យបីឆ្នាំ គឺខ្ញុំគឺការទុក្ខសោកវាច្រើនដណាក់ ដូចថានៅជាមួយគ្រួសារវាមានការលំបាក ចំពោះដែលខ្ញុំមានផ្ទៃពោះ ធ្វើដំណើរចេញ។ គេឲ្យខ្ញុំចេញដំណើរទៅពីភ្នំពេញទៅតាមផ្លូវជាតិលេខប៉ុន្មានទេ ទៅបាត់ដំបង ពោធិ៍សាត់នោះ ខ្ញុំចេះតែដើរតាមគេទៅ ណាមានផ្ទៃ

[2339] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ផែ ហ៊ាប ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ១៤ បន្ទាត់ ៨-២២។

[2340] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ផែ ហ៊ាប ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ១៩ បន្ទាត់ ១៨-២០។

[2341] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ផែ ហ៊ាប ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ១៩ បន្ទាត់ ២៣-២៤។

[2342] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ផែ ហ៊ាប ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ១៨-១៩ បន្ទាត់ ២៥-២។

ពោះ ណាកូនតូច។ ហើយខ្ញុំចេះតែដើរទន្ទឹងរកមើលប្តី ក៏មិនឃើញ ឃើញតែគេ ក៏ចេះតែរសាត់ទៅដល់បាត់ដំបង។ ចេញពីបាត់ដំបងមកវិញ ក៏ខ្ញុំចេះតែរកមើល។ រកមើលមិនឃើញ ហើយរហូតដល់ខ្ញុំហ្នឹង មកកើតកូននៅនឹងមោងឬស្សី។ ហើយក៏ខ្ញុំកើតបានតែ៣ថ្ងៃទេ ខ្ញុំស្ពាយកូនដើរដល់ផ្ទះ បានដល់៣ខែ ដើរសម្រាក ដើរសម្រាក"[2343]។

1098. ដើមបណ្តឹងរដ្ឋប្បវេណី រស់ ជួរស៊ីអ៊ី ដែលត្រឡប់ពីប្រទេសបារាំង មកប្រទេសកម្ពុជាវិញ ជាមួយប្តីនិងកូនស្រីគាត់បីនាក់ នៅក្នុងខែសីហា ឆ្នាំ១៩៧៦ បានផ្តល់នូវសក្ខីកម្មលម្អិត អំពីទុក្ខព្រួយ ការបារម្ភ ក្តីសង្ឃឹម និងការអស់សង្ឃឹម នៅពេលដែលប្តីគាត់ឈ្មោះ រស់ សារិន បាត់ខ្លួនពីបឹងត្របែក៖ "តាំងពីពេលនោះមកហ្នឹង ចិត្តខ្ញុំហ្នឹងចម្បែងរាល់ថ្ងៃ រាល់យប់ ចេះតែរង់ចាំដំណឹងពីប្តី។ ចាំបាត់១១ ពីមួយថ្ងៃទៅមួយថ្ងៃ គ្មានឃើញសញ្ញាអ្វីសោះ។ ហើយថ្ងៃមួយមានបុរសម្នាក់ជិះម៉ូតូចូលទៅក្នុងជំរំនោះ ជំរំបឹងត្របែកហ្នឹង...ក៏ប៉ុន្តែនៅតែរង់ចាំអ៊ីចឹង គឺថាចេះតែធ្វើការបណ្តើរ រង់ចាំមើលផ្លូវហ្នឹង ឲ្យតែមានឡានណាចេញចូលនៅនុ៎ង ស្មានតែគេដឹកគាត់ឲ្យយកទៅជួបខ្ញុំវិញ នៅពេលហ្នឹង។ ហើយដល់អ៊ីចឹងទៅ ក៏ចាំបាច់១១ទៀតហ្នឹង អ្ហ៊ឺ! មិនដឹងថ្ងៃណាទេ ក្នុងខ្លួនហ្នឹងចេះតែមានអារម្មណ៍ហ្នឹង គឺថាព្រួយជាប់ជានិច្ច។ ដល់បាត់ឈឹងៗអ៊ីចឹង អើចេះតែខំធ្វើការ ទ្រាំជាមួយបងប្អូនយើងតាមហ្នឹងទៅចាស"[2344]។

1099. ក្រោយពេលដែលផ្លាស់ទៅដីក្រហមវិញ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា "ជួនកាលកំពុងជម្រះស្មៅ នៅក្នុងចម្ការសណ្តែក ឮសូរយន្តហោះនៅលើអាកាស ធ្វើឲ្យខ្ញុំស្រាប់តែទឹកភ្នែក។ ដោយនឹកឃើញដែលកាលនៅសម័យជួបជុំគ្នាហ្នឹង បានជិះកប៉ាល់ហោះជាមួយគ្នា"[2345]។ "ឃើញ

---

[2343] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ខៀវ នាប ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៥៤-៥៥ បន្ទាត់ ២៣-៤។

[2344] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រស់ ជួរ ស៊ីអ៊ី ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៦៣-៦៤ បន្ទាត់ ១៨-៤។

[2345] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រស់ ជួរ ស៊ីអ៊ី ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៦៤ បន្ទាត់ ១១-១២។

គេចេញបាន ជួយអរគេ ឯខ្លួនឯងហ្នឹង គឺថា ហ៊ឺ! មិនដឹងយ៉ាងម៉េចបានជាអង្គការមិនព្រម ឲ្យមកជួបជុំគ្នាវិញ។ ធ្វើឲ្យចិត្តហ្នឹងកាន់តែស្មុគស្មាញៗ ចំបែងនៅក្នុងចិត្តថែមទៀតណា"[2346]។

1100. ដើមបណ្តឹងរដ្ឋប្បវេណី រស់ ជួរស៊ីអ៊ី បានរៀបរាប់ថា "ទុក្ខព្រួយប្រចាំកាយហ្នឹង គឺថាក្តីកង្វល់ហ្នឹងវាមានជាប់ជានិច្ច។ ហើយយូរៗម្តងនៅដីក្រហមហ្នឹង ឃើញឡានមានឡានគេដឹកមនុស្សយកទៅដាក់។ ហើយខ្ញុំនេះចេះតែខំនឹកអរបន្តិច លួចមើលថាប្រហែលជាប្តីមកហើយក៏មិនដឹង អង្គការយកមកឲ្យជួបហើយ។ ហើយកូនៗក៏អ៊ីចឹងដែរ ខំនឹកស្មានថា ប្រហែលជាបានជួបមុខឪពុកគេហើយ។ ប៉ុន្តែដល់ចុះអស់មកគឺថា នៅតែគ្មានឃើញសម្រោលប្តីទាល់តែសោះ។ ដូច្នេះទុក្ខព្រួយហ្នឹងគឺថា វាអត់មានបានរសាយពេលណាសោះ"[2347]។ "ចិត្តខ្ញុំហ្នឹងពេលហ្នឹងក៏កណ្តែងកណ្តោចទៀតហើយ គឺថាទុក្ខព្រួយរហូតគ្មានបានស្រាកស្រាន្តទេ ក្នុងបេះដូងទេចាស ដូចជានឹកថាខ្លួនឯងហ្នឹង មករស់នៅហ្នឹងក៏វេទនា អីក៏វេទនាម្ល៉េះ នៅប្រទេសគេសុខៗ សុខស្រួលគ្មានខ្វះអី មកត្រដាបត្រដួសរបៀបហ្នឹង"[2348]។

1101. បន្ទាប់ពីភ្នំពេញត្រូវបានរំដោះ ដើមបណ្តឹងរដ្ឋប្បវេណី រស់ ជួរស៊ីអ៊ី បានផ្តល់សក្ខីកម្មថា "ចិត្តខ្ញុំនៅតែសោកសៅជានិច្ច ដូចថារស់នៅដូចជាស្ត្រីមេម៉ាយអ៊ីចឹង ជាមួយនឹងកូនស្រីបីនាក់ នៅក្នុងបន្ទុកទាំងស្រុង ក្តីសង្ឃឹមថាបានមកជួបប្តីហ្នឹង ក៏រលាយបាត់បន្តិចម្តងៗ ហេតុហ្នឹងហេតុនេះហើយ ក៏ចេះតែខំតាំងចិត្ត ពង្រឹងស្មារតីតស៊ូទៅ ឲ្យសម្រាប់អនាគតកូនៗទៅមុខទៀត"[2349]។

1102. នៅពេលដែលទៅទស្សនកិច្ចនៅទួលស្លែង ក្រោយពេលប្រទេសត្រូវបានរំដោះនោះ ដើមបណ្តឹងរដ្ឋប្បវេណី រស់ ជួរស៊ីអ៊ី បានរៀបរាប់អំពីការដែលគាត់បានដឹង ពីជោគវាសនារបស់ប្តីគាត់គឺ រស់ សារិន។ "ខ្ញុំដើរមើលគ្រប់បន្ទប់ កន្លែងធ្វើទារុណកម្ម ប្រដាប់ប្រដារធ្វើទារុណកម្ម មានសព្វគ្រប់

---

2346 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រស់ ជួរ ស៊ីអ៊ី ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៦៤ បន្ទាត់ ១៦-១៨។

2347 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រស់ ជួរ ស៊ីអ៊ី ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៦៤-៦៥ បន្ទាត់ ២៣-៣។

2348 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រស់ ជួរ ស៊ីអ៊ី ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៦៥ បន្ទាត់ ១៧-២០។

2349 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី រស់ ជួរ ស៊ីអ៊ី ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៦៥-៦៦ បន្ទាត់ ២៤-២។

ហើយ ខ្ញុំមិនចង់និយាយឡើងវិញបានទេចាស។ ហើយទៅមើលកន្លែង ទីបំផុតហើយទៅមើលកន្លែងតាំងរូបថតអ្នកទោស។ នៅពេលហ្នឹងហើយដែលខ្ញុំ ជីពចរខ្ញុំវាកាន់តែលោតខ្លាំងឡើងៗ ខ្ញុំខំសំឡឹងរកមើលគ្រប់រូបថត ហើយឃើញមានរូបអ្នកដែលខ្ញុំស្គាល់ខ្លះៗ ហើយទីបំផុតទៅ ឃើញរូបថតប្ដីខ្ញុំតែម្ដង។ ពេលនោះខ្ញុំស្ទើរនឹងស្រែកទ្រហោយំ។ ស្ទើរបាត់ស្មារតី សន្លប់ តែមានសំឡេងមួយបានមកប្រាប់ខ្ញុំ ដូចមកជួយដាស់តឿនថា កុំៗយំអី តាំងចិត្តឲ្យរឹង កុំសន្លប់ដួលនៅនឹងមុខពួកហ្នឹង។ ដល់អ៊ីចឹងទៅខ្ញុំដូច ហាក់ដូចជាមានកម្លាំងចិត្តបន្តិចឡើងវិញ ដោយខំតាំងស្មារតីឡើងវិញ។ រួចតាំងពីពេលនោះមក ខ្ញុំក៏នឹកថា ខ្ញុំមិនអាចរស់នៅក្នុងប្រទេសរបៀបហ្នឹងទេ។ ហើយធំបំផុតហ្នឹងគឺថាខ្ញុំត្រូវរកអនាគតឲ្យប្ដី ឲ្យកូនៗខ្ញុំហើយ ព្រោះថាអត់ពីឪពុកកែទៅហ្នឹង ខ្ញុំថាខ្ញុំជាម្ដាយមេម៉ាយមែនពិត តែខ្លាំងត្រូវខំចិត្តឲ្យរឹងមាំ ដើម្បីចិញ្ចឹមកូនតទៅទៀត។ ពេលនោះដល់មើលចប់អីទៅ ក៏ម្នាក់ៗហ្នឹង វាមានចិត្តស្រងូតស្រងាត់។ តែចំពោះខ្លួនខ្ញុំផ្ទាល់ ដែលបានឃើញរូបគាត់មកគឺថាខ្ញុំដូចថាចេះតែរឹងរ៉ែក្នុងខ្លួនណាស់ ហើយខ្ញុំក៏សម្រេចចិត្តថា រករត់ចេញមកប្រទេសបារាំង"[2350]។

1103. ដើមបណ្ដឹងរដ្ឋប្បវេណី រស់ ជួរស៊ីអ៊ី មានប្រតិកម្មចំពោះការរកឃើញ ឈ្មោះប្ដីរបស់គាត់នៅក្នុងបញ្ជីឈ្មោះអ្នកទោស នៅមន្ទីរស-២១ និងឃើញរូបថតរបស់ប្ដីគាត់នៅទួលស្លែង បានរំឭកថា "គ្រាន់តែឃើញចុងក្រោយហ្នឹងដឹងថា គាត់មកនៅស-២១ហើយ គឺថាគ្មានក្ដីអីសង្ឃឹមទៀតទេចាស ដូចថាវានៅក្នុងចំណោមអ្នកដែលត្រូវគេសម្លាប់ ដោយអយុត្តិធម៌ ដោយឃោរឃៅអ៊ីចឹងហើយ។ ហើយខ្ញុំមិនដឹង ខ្ញុំមិននឹកស្មានថា ពេលគាត់មុននឹងសម្លាប់ហ្នឹង មិនដឹងជាគេយកគាត់ទៅធ្វើអ្វីខ្លះទេ។ បើតាមឃើញសម្ភារៈទារុណកម្មហ្នឹង ហាក់ដូចជាសាហាវឃោរឃៅណាស់ មានទាំងដកក្រចក ជ្រមុជទឹក មិនដឹងជាធ្វើអីខ្លះទេ។ តាំងពីឃើញរូបថតគាត់ហ្នឹងមក គឺថាខ្ញុំស្រមៃឃើញថាប្រហែលជាគាត់ វេទនារបៀបណាទេលោក ព្រោះខ្ញុំអត់បានឃើញផ្ទាល់ ឃើញតែប្រដាប់ប្រដារគេធ្វើទារុណកម្មហ្នឹង ធ្វើឲ្យខ្ញុំហ្នឹងសឹងតែបាត់ព្រលឹងទៅហើយ ពេលឃើញរូបថតគាត់នៅនុំងទៀតនោះចាស"[2351]។

---

[2350] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី រស់ ជួរ ស៊ីអ៊ី ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៦៦ បន្ទាត់ ៨២២។

[2351] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី រស់ ជួរ ស៊ីអ៊ី ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៦៩ បន្ទាត់ ៣-១០។

1104. ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ធរ៉ា បានផ្តល់សក្ខីកម្មអំពី ព្យសនកម្មផ្លូវចិត្តដែលគាត់បានទទួលរង ដោយសារតែការស្លាប់របស់បងប្រុសគាត់។ "ដល់ពេលក្រោយរបប ប៉ុល ពត យើងបែក៧៩ បាន ប្រហែលជាមួយខែ បានឮដំណឹងថាបងខ្ញុំហ្នឹងត្រូវគេសម្លាប់នៅទួលស្លែង បានដំណឹងថាគាត់ស្លាប់ នៅទួលស្លែង។ ពេលដែលបានទទួលដំណឹងហ្នឹង គឺពេលបាយល្ងាច។ ចាសទទួលទានបាយលែង កើតហើយ ទឹកភ្នែកហូរបេះដូងមិនដឹងធ្លាក់ដល់ណាទេ ថ្លើមប្រមាត់អីហ្នឹង។ ហើយស្អែកឡើងក៏ នាងខ្ញុំខំដើរពីស្រែ ដែលចម្ងាយ១៦គីឡូ បានឡើងមកដល់ខេត្តកំពង់ស្ពឺហ្នឹង។ ឡើងមកដល់ខេត្ត ហើយ ក៏សុំឡានគេជិះឡើងមកមើលនៅគុកទួលស្លែង។ ហើយក៏បានជួបមិត្តភក្តិនៅគុកទួលស្លែង ហ្នឹង គេក៏ជូនដើររក ក៏ឃើញរូបថតបងប្រុសនាងខ្ញុំ ហើយនឹងបងថ្លៃស្រីដាក់ពីលើពីក្រោមគ្នា ហ្នឹង។ ប៉ុន្តែក្មួយគាត់ពីរនាក់តូចៗ ដែលយកមកធ្វើជាកូនមកភ្នំពេញជាមួយគាត់ហ្នឹង អត់ឃើញ ទេ។ ចាស អារម្មណ៍នាងខ្ញុំនៅតែនឹងឃើញបងប្រុសហ្នឹង ពីព្រោះគាត់ជាបងមួយដ៏ស្លូតបូត គាត់ មើលថែប្អូន ហើយគាត់ជាអ្នកចូលចិត្តគ្រឿងតន្ត្រី។ គ្រាន់តែឮស្នូរភ្លេងតន្ត្រីសម័យនុ៎ង គឺថានាងខ្ញុំ ទឹកភ្នែកហូរ។ មានតែការសោកស្តាយគាត់ ដែលមិនបានរស់នៅបន្តបានយូរនឹងគេ។ ឃើញបងគេ នឹកបងឯង ឃើញឪពុកម្តាយគេ នឹកឃើញឪពុកម្តាយឯង។ អារម្មណ៍នាងខ្ញុំនៅតែឈឺចាប់រហូត ទល់នឹងសព្វថ្ងៃចាស"[2352]។

1105. ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត បានផ្តល់សក្ខីកម្មអំពីព្យសនកម្មរបស់គាត់ ទាក់ទងនឹងបងស្រី ឈ្មោះ ភួង អ៊ីម។ ដើមបណ្តឹងរដ្ឋប្បវេណីបានរំឭកថា "កាលពីសម័យសម្តេចឪនៅ បងខ្ញុំហ្នឹងគាត់ ធ្វើកងរក្សាស្ម័គ្រ រួចទៅផុតហ្នឹងដល់ពេលសម័យលន់ នល់ គាត់នៅដេរនៅផ្ទះ ជីវិតបងប្រុសខ្ញុំ បីនាក់ទៀត គាត់ឡើងត្នោត រស់ជីវិតផ្ញើលើចុងត្នោត យកជីវភាពស្ករត្នោត យកមកលក់នៅកំពង់ ចាម គាត់ស្រឡាញ់ប្អូន គាត់ទៅណាមកណាគាត់យកខ្ញុំទៅជាមួយ។ បងស្រីខ្ញុំហ្នឹងគាត់អ្នកលក់ ស្ករ យកស្ករទៅលក់ឯកំពង់ចាម ផ្សារកំពង់ចាម រួចជីវិតបងប្រុសខ្ញុំបីនាក់ទៀត គាត់ឡើងត្នោត លើចុងត្នោត ផ្ញើជីវិតនៅលើចុងត្នោត"[2353]។ "ខ្ញុំស្រឡាញ់គាត់ គាត់នៅគ្រប់គ្រងប្អូនថែទាំ ងូតទឹក ងូតភក់ឱ្យ ថែប្អូន ម្តាយខ្ញុំធ្វើការបាត់ទៅ គាត់នៅផ្ទះថែទាំប្អូនចុះទៅណា ក៏គាត់នាំប្អូនទៅ គាត់ខ្លាច

---

[2352] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កាន់ សុន្ធរ៉ា ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៣៩ បន្ទាត់ ១២-២៣។

[2353] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៣៨ បន្ទាត់ ១៣-១៧។

កាលហ្នឹងទាហាន លន់ នល់ បើគាត់នៅក្រមុំចុះដើរទៅ គាត់ចាប់ ទាហានចាប់ហើយ គាត់ទុកខ្ញុំនៅជាមួយគាត់អត់ឱ្យទៅណាទេ គាត់ចុះទៅតែដងទឹកក៏គាត់យកខ្ញុំទៅដែរ ព្រោះខ្លាចគេចាប់។ ខ្ញុំអាណិតអាសូរគាត់ ដល់ពេលគាត់បាត់ដំណឹងឈឹងទៅ ដឹងតែគាត់ស្លាប់នៅទួលស្លែង ដឹងពិបាកវេទនាយ៉ាងណា គេចងវៃទាល់សន្លប់ដឹងស្អី"[2354]។ "បានឃើញរូបថតបងស្រីខ្ញុំ នៅគុកទួលស្លែង ឡើងភ្នែកល្អក់ មិនដឹងគេវៃធ្វើបាបគាត់យ៉ាងណាយ៉ាងណីទេ"[2355]។

1106. នៅទួលស្លែង ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត បានរៀបរាប់ពីការឈឺចាប់ ដោយសារបានដឹងអំពីជោគវាសនា របស់បងប្រុសគាត់ទាំងបីនាក់។ "ឃើញរូបថតបងវេនខ្ញុំ បងផុន បងផែន បងៗប្រុសខ្ញុំទាំងអស់គ្នា នៅគុកទួលស្លែងទាំងអស់"[2356]។ "ខ្ញុំ អារម្មណ៍ក្តុកក្តួល ខ្ញុំឃើញរូបថតគាត់ ខ្ញុំរកនិយាយមិនរួច ខ្ញុំគិតតែពីយំៗឡើងចង់បាត់ស្មារតី"[2357]។ "ខ្ញុំរន្ធត់ចិត្តឃើញគេចងហើយស្លាបសេកហើយមើលទៅ បានជាទ្រូងគាត់ពើងយ៉ាងហ្នឹង។ ខ្ញុំរន្ធត់ចិត្តបងៗខ្ញុំគាត់នៅពីជាមួយម៉ែឪគាត់ខំយកជីវិតឡើងចុងត្នោត ផ្ញើជីវិតនៅលើចុងត្នោត ចិញ្ចឹមគ្រួសារខ្ញុំ ខ្ញុំនៅតូចៗ។ បងខ្ញុំខំប្រឹងចិញ្ចឹមបងប្អូន ម៉ែឪខ្ញុំក្រ"[2358]។

1107. ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត ពន្យល់ថា "ខ្ញុំនឹកដល់បងៗទាំងអស់ ទាំងអស់គ្នាហ្នឹង ខ្ញុំនឹក នឹកឃើញ។ បើសិនណាជាបងៗខ្ញុំនៅទាំងអស់គ្នាហ្នឹង ខែភ្ជុំបិណ្ឌអី បើបងៗនៅទាំងអស់គ្នា មានហ៊ឹកហ៊ាក់ ប៉ុន្តែស្លាប់បងបាត់អស់ទៅហ្នឹង គេហ៊ឹកហ៊ាក់ ខ្ញុំកណ្តោចកណ្តែងនៅតែពីរបីនាក់បងប្អូន

2354 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៣៨ បន្ទាត់ ២០-២៤។

2355 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៣៩ បន្ទាត់ ៣-៤។

2356 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៣៩ បន្ទាត់ ៨-៩។

2357 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៣៩ បន្ទាត់ ១២-១៣។

2358 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៤២ បន្ទាត់ ១៦-១៨។

គ្មានញាតិមិត្តបងប្អូនណាមកនឹងគេ”[2359]។ ដែល១ទៅវត្ត ទៅអីទៅចូលឆ្នាំ ចូលអី យើងទៅចូសីល ថ្ងៃអីទៅវត្ត ទៅអី នឹកឃើញទៅយកបាយសម្លទៅជូន ប្រគេនលោកឱ្យដល់បង១ ដែលស្លាប់ទៅវេទនាហ្នឹង កុំឱ្យជាតិណា១គាត់វេទនាដូចជាតិហ្នឹងទៀត”[2360]។

1108. ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឃឹម បានផ្តល់សក្ខីកម្មអំពីព្យសនកម្មផ្លូវចិត្ត ដែលគាត់បានទទួលដោយសារ ការបាត់បង់បងប្រុសរបស់គាត់ឈ្មោះ ចៅ សេង នៅមន្ទីរស-២១។ “ក្នុងនាមខ្ញុំជាប្អូនបង្កើតរបស់ ចៅ សេង ការសម្លាប់គាត់ដោយឥតមានទោសពៃ ធ្វើឱ្យមានការឈឺចាប់ឥតឧបមា។ ខ្ញុំបានស្វែងរកការពិតគ្រប់ទីកន្លែង”[2361]។

1109. ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មពី ការស្នេហាជាតិ និងភាពគ្មានទោសកំហុស របស់បងប្រុសគាត់ ដែលរួមចំណែកធ្វើឱ្យគាត់មានអារម្មណ៍ថាត្រូវគេបោកប្រាស់ និងទួញសោកចំពោះការកំណត់គោលដៅលើបញ្ញាវន្ត។ “បើតាមយោបល់ខ្ញុំ គឺថាគាត់អត់បានដឹងទេ រឿងបើគាត់ដឹងថាគេក្បត់គាត់ គាត់អត់មានអត់ចាត់មកទេបាទ គាត់ចាំបន្តិចទៀត គាត់បានមក ប៉ុន្តែថាគាត់វាគ្មានអានុំងតែម្តង គឺថាមកវាស្មោះត្រង់ដើម្បីមកហ្នឹង មកដើម្បីជួយគេត្រូវការអ្នកចេះ អ្នកដឹងដើម្បីជួយ ពួកនៅក្នុងជួរខ្មែរក្រហម អ្នកចេះដឹងតិចណាស់ គឺបានពីស្រុកបារាំងមកហ្នឹង គឺវាប់រយនាក់ដែលមកហ្នឹង គឺមកជួយ ប៉ុនខ្មែរក្រហមមិនដឹងអាម៉េច មិនទុកចិត្តពួកអាពួកស្រុកបារាំងទៅ១យកពួកអ្នកស្រុកបារាំងជាអ្នកក្បត់ទៅវិញ។ ខ្ញុំអាហ្នឹងខ្ញុំមិនយល់ អាហ្នឹងចង់សួរទៅលោកនួន ជា ហើយនិងលោក ខៀវ សំផន”[2362]។

1110. ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឃឹម បានពន្យល់បញ្ជាក់ថា “ចំពោះខ្ញុំនឹងគ្រួសារ ការបាត់បង់បងប្រុស ចៅ សេង ដូចជាការបាត់បង់ឪពុកទី២។ បាត់បង់បង្គោលគ្រួសារ គ្រួសារត្រូវរងទុក្ខវេទនាដ៏

---

[2359] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៤២ បន្ទាត់ ២១-២៤។

[2360] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត ប្រតិចារឹក ថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/455.1** ទំព័រ ៤៣ បន្ទាត់ ១-៣។

[2361] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឃឹម ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៥៤ បន្ទាត់ ១៨-២០។

[2362] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឃឹម ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៦៣ បន្ទាត់ ១-៦។

ក្រៃលែង ធំធេងដែលមិនអាចរកអ្វីមកប្រៀបបាន។ គ្រួសារចុះក្រីក្រអស់ទីពឹង អស់អ្នក អស់អនាគត អស់អ្នកគ្រប់គ្រង អស់ការគ្រប់គ្រងគ្រប់បែបយ៉ាង។ ចំណែកគ្រួសាររបស់ ចៅ សេង គ្រួសារគាត់ជាគ្រួសារបារាំង និងកូននៅស្រុកបារាំង គាត់ដឹង។ គាត់តែងតែចាំជានិច្ចថា ចៅ សេង អត់ស្លាប់ទេ គឺគាត់មានទុក្ខវេទនារកអ្វីប្រៀបមិនបាន”[2363]។

## ជំពូក ១១. ការចេញបទបញ្ជាអំពីការរៀបអាពាហ៍ពិពាហ៍[2364]

[2363] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឃឹម ប្រតិចារឹក ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/457.1** ទំព័រ ៥៣ បន្ទាត់ ១៥-២០។

[2364] អង្គជំនុំជម្រះសាលាដំបូងបានទទួលបណ្តឹងអំពីអង្គហេតុជុំវិញការអនុវត្តគោលនយោបាយទីប្រាំស្តីពី “ការដាក់កំហិតលើការរៀបអាពាហ៍ពិពាហ៍” ដោយ ប.ក.ក នៅពេលខ្លួនបានកាន់កាប់ជាបន្តបន្ទាប់លើតំបន់មួយចំនួននៅក្នុងទឹកដីប្រទេសកម្ពុជា ហើយគោលនយោបាយនេះត្រូវបានអនុវត្ត ទោះប្រើ “មធ្យោបាយចាំបាច់ណាក៏ដោយ”។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ២១៦។ គោលនយោបាយនៃការដាក់កំហិតលើការរៀបអាពាហ៍ពិពាហ៍ត្រូវបានចោទប្រកាន់ថាត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីគ្រប់គ្រងអន្តរកម្មរវាងបុគ្គល ការបង្កើនចំនួនប្រជាជន និងការបង្កើតឡើងវិញនូវទស្សនៈនៃការរៀបអាពាហ៍ពិពាហ៍នៅក្នុងសង្គមកម្ពុជា ដើម្បីជំរុញបដិវត្តន៍សង្គមនិយមយ៉ាងឆាប់រហ័សនៃបក្សកុម្មុយនីស្តកម្ពុជា។ គោលដៅនេះត្រូវបានគេសន្មតថាអាចសម្រេចបានដោយការផ្សំផ្គុំប្រជាជនតាមការជ្រើសរើសរបស់ ប.ក.ក ដែលជាទូទៅធ្វើឡើងនៅតាមទីតាំងផ្លូវការនានា ការដាក់កំហិតលើស្ថានភាពអាពាហ៍ពិពាហ៍ដល់គូស្វាមីភរិយា ការលុបបំបាត់ចោលទំនៀមទម្លាប់ និងពិធីបុណ្យនានាជុំវិញការរៀបអាពាហ៍ពិពាហ៍ក្នុងសង្គមកម្ពុជា និងការទប់ស្កាត់ការចូលរួមរបស់ឪពុកម្តាយក្នុងការជ្រើសរើស និងក្នុងពិធីរៀបអាពាហ៍ពិពាហ៍។ អង្គជំនុំជម្រះសាលាដំបូងបានទទួលបណ្តឹងអំពីអង្គហេតុពាក់ព័ន្ធនឹងការពន្លឿនការអនុវត្តគោលនយោបាយដាក់កំហិតលើការរៀបអាពាហ៍ពិពាហ៍ក្រោយខែ កញ្ញា ឆ្នាំ ១៩៧៧ ដោយមានពិធីរៀបអាពាហ៍ពិពាហ៍ជាច្រើនដង ដែលបានរៀបចំឡើងជា “ក្រុមក្នុងពេលតែមួយ”។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ២១៧ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៨៤២-៨៦០ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ២១៨។ អង្គជំនុំជម្រះសាលាដំបូង ក៏បានទទួលបណ្តឹងផងដែរអំពីការចោទប្រកាន់លើអង្គហេតុទាក់ទងនឹងស្ថានភាពបង្ខិតបង្ខំ ដែលគោលនយោបាយនេះត្រូវបានអនុវត្ត រួមទាំងការគំរាមកំហែង ឬការដាក់ទណ្ឌកម្មដោយអាជ្ញាធរ ប.ក.ក ដែលបង្កើតបរិយាកាសភ័យខ្លាច ដើម្បីរារាំងប្រជាជនមិនឱ្យប្រឆាំងបទបញ្ជារបស់អង្គការ។ ការចោទប្រកាន់លើអង្គហេតុទាំងនេះ រួមបញ្ចូលទាំងគោលនយោបាយដាក់កំហិតលើការរៀបអាពាហ៍ពិពាហ៍ ដូចជា ប្រជាជនត្រូវបានសម្លាប់ ឬបញ្ជូនទៅអប់រំ ដោយសារតែពួកគេបដិសេធមិនរៀបការ ឬដោយសារតែពួកគេមិន “ចុះសម្រុងនឹង” ប្តីដែលត្រូវបានជ្រើសរើសឱ្យពួកគេ។ ជាចុងក្រោយ អង្គជំនុំជម្រះសាលាដំបូង បានទទួលបណ្តឹងអំពីការចោទប្រកាន់លើអង្គហេតុទាក់ទងនឹងការរួមបវេណីដោយបង្ខំ ដែលត្រូវបានដាក់កំហិតដល់ប្តីប្រពន្ធដើម្បីបង្កើតកូនជូនបដិវត្តន៍។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៨៤៩-៨៥៣ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៨៤៩-៨៥០ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៨៥៨-៨៦០។ ផ្អែកលើមូលដ្ឋាននៃការចោទប្រកាន់លើអង្គហេតុទាំងនេះជុំវិញការអនុវត្តគោលនយោបាយនៃការដាក់កំហិតលើការរៀបអាពាហ៍ពិពាហ៍ ដីកាដំណោះស្រាយបានចោទប្រកាន់ជនជាប់

## គ. សេចក្តីសង្ខេបនៃភស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី

1111. ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១២ នាក់ បានផ្តល់សក្ខីកម្មនៅក្នុងអំឡុងវគ្គសវនាការស្តីពីការចេញបទបញ្ជាអំពីការរៀបអាពាហ៍ពិពាហ៍ ពាក់ព័ន្ធនឹងបទពិសោធន៍រៀបអាពាហ៍ពិពាហ៍របស់ពួកគាត់នៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៨ នាក់ ផ្សេងទៀត បានផ្តល់សក្ខីកម្មនៅក្នុងអំឡុងវគ្គសវនាការពិនិត្យលើភស្តុតាងនៃសំណុំរឿង ០០២/០២ និងបានផ្តល់នូវភស្តុតាងសង្ខេបអំពីការរៀបអាពាហ៍ពិពាហ៍ផ្ទាល់ខ្លួនរបស់ពួកគាត់ ហើយដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៥ នាក់ ទៀត បានផ្តល់ភស្តុតាងពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍សាច់ញាតិ ជិតស្និទ្ធ[2365]។

1112. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន បានរៀបការរួចហើយមុនរបបកម្ពុជាប្រជាធិបតេយ្យ[2366] នៅក្នុងឆ្នាំ ១៩៧៨[2367] អ្នកស្រីត្រូវបានបង្ខំឱ្យរៀបការជាមួយនឹងទាហានពិការម្នាក់ឈ្មោះ ញៀន[2368]។ ពិធីរៀបការបានប្រារព្ធធ្វើឡើងនៅក្នុងភូមិ ២ ភូមិចំការអណ្តូង[2369] ដែល ជាផ្នែក

---

ចោទពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៃអំពើអមនុស្សធម៌ផ្សេងទៀត ដែលត្រូវបានចោទប្រកាន់ថាបានធ្វើឡើងនៅទូទាំងប្រទេស និងជាពិសេសនៅទំនប់ ១ មករា សហករណ៍ត្រាំកក់ និងការដ្ឋានទំនប់ត្រពាំងថ្ម។ ជនជាប់ចោទ ក៏ត្រូវបានចោទប្រកាន់ផងដែរ ទាក់ទងនឹងការប្រព្រឹត្តចំពោះពុទ្ធសាសនិកចាប់ពីថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ រហូតដល់ថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៧៩។ ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ១៤៤២-១៤៤៧ ឧបសម្ព័ន្ធ ៖ បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/២ ឯកសារ **E301/9/1.1**។

[2365] ដើមបណ្តឹងរដ្ឋប្បវេណីចំនួន ៦៦៣ នាក់ ត្រូវបានទទួលយកដោយ ក.ស.ច.ស ពាក់ព័ន្ធនឹងការដាក់កំហិតលើការរៀបអាពាហ៍ពិពាហ៍ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ (ដីកាដំណោះស្រាយ ឯកសារ **D427** កថាខណ្ឌ ៨៦១) និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន ១១៦ នាក់ ត្រូវបានទទួលយកដោយអង្គបុរេជំនុំជម្រះ។

[2366] ប្តីទីមួយរបស់គាត់បានចូលធ្វើជាកងទ័ពបដិវត្តន៍ និងបានស្លាប់។ ពួកគាត់មានកូនម្នាក់ជាមួយគ្នា។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/461.1** ទំព័រ ៧១-៧២ បន្ទាត់ ១៣-២។

[2367] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ២៧-២៨ បន្ទាត់ ២៤-២។ *សូមមើលផងដែរ* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៣២ បន្ទាត់ ២១-២៣ ទំព័រ ៣៣ បន្ទាត់ ៧-៩។

[2368] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/461.1** ទំព័រ ៧៣ បន្ទាត់ ១៩។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៤ បន្ទាត់ ២។

នៃភូមិភាគកណ្តាល។ នៅពេលរៀបអាពាហ៍ពិពាហ៍លើកទីពីរ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន មានអាយុ ២៣ ឬ ២៤ ឆ្នាំ ហើយប្តីរបស់គាត់ឈ្មោះ ញៀន អាយុ ៤៧ ឬ ៤៨ ឆ្នាំ[2370]។ នៅក្នុងថ្ងៃនោះ មានការរៀបការចំនួន ១២ គូ[2371]។ ញៀន គឺជាជនជាតិខ្មែរភាគតិច និយាយរដឹនៗ[2372] និងអន់ភ្នែក ហើយជើងដើរអត់ត្រង់ទេ[2373]។ ដើមបណ្តឹងរដ្ឋប្បវេណី មិនបានស្គាល់ប្តីរបស់គាត់ទេមុនពិធីរៀបការនោះ[2374] អ្នកស្រីមិនស្រលាញ់គាត់ និងបានពិពណ៌នាអំពីរូបសម្បត្តិប្តីរបស់គាត់ថា "អត់សូវស្អាត"[2375]។ អ្នកស្រីបានតវ៉ាមិនព្រមរៀបការទេ ប៉ុន្តែគេប្រាប់ថាអ្នកស្រីត្រូវតែទៅរៀបការ ពីព្រោះជាបញ្ជារបស់អង្គការ[2376]។

1168. ដើមបណ្តឹងរដ្ឋប្បវេណីប្រាំនាក់ បានផ្តល់ភ័ស្តុតាងនៅក្នុងផ្នែកដទៃទៀត នៃសវនាការក្នុងសំណុំរឿង០០២/០២ អំពីដំណើរការរៀបអាពាហ៍ពិពាហ៍ និងអំពីព្យសនកម្មដែលទទួលរង ដោយសារតែការរៀបការរបស់សាច់ញាតិពួកគេ។ ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវិដា បានផ្តល់ភ័ស្តុតាងអំពីការរៀបការរបស់បងស្រីគាត់ នៅក្នុងផ្នែកសវនាការអំពីទំនប់មួយមករា។ ដើមបណ្តឹងរដ្ឋប្បវេណី ឡាច ត្រី បានផ្តល់សក្ខីកម្មអំពីការរៀបអាពាហ៍ពិពាហ៍របស់បងប្រុសគាត់ នៅក្នុងផ្នែកសវនាការអំពីការប្រព្រឹត្តិទៅលើជនជាតិវៀតណាម។ ដើមបណ្តឹងរដ្ឋប្បវេណី សៀង ចាន់ថី បានផ្តល់សក្ខីកម្មអំពីការរៀបអាពាហ៍ពិពាហ៍របស់បងស្រីគាត់ នៅក្នុងផ្នែកសវនាការអំពីការប្រព្រឹត្តិទៅលើជនជាតិវៀតណាម។ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ បានផ្តល់ភ័ស្តុតាងអំពីការរៀបអាពាហ៍ពិពាហ៍របស់ឪពុកក្មេកគាត់ នៅក្នុងផ្នែកសវនាការអំពីការប្រព្រឹត្តិទៅលើជនជាតិវៀតណាម។ ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ខឿន បានផ្តល់សក្ខីកម្មអំពីការរៀបចំពិធីអាពាហ៍ពិពាហ៍ នៅក្នុងខេត្តកំពង់ឆ្នាំង នៅក្នុងផ្នែកសវនាការអំពីការប្រព្រឹត្តិទៅលើជនជាតិវៀតណាម។ ដើមបណ្តឹងរដ្ឋប្បវេណី ភួង យ៉ាត បានផ្តល់ភ័ស្តុតាងអំពីការរត់គេចរបស់បងស្រីគាត់ ដែលត្រូវបានគេរៀបចំឱ្យរៀបការ។ ព័ត៌មានទាក់ទងជនរងគ្រោះដោយប្រយោលទាំងអស់នេះមាននៅក្នុងឧបសម្ព័ន្ធ ឆ[2745]។

---

ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា "មេកងខ្ញុំហៅខ្ញុំបួនប្រាំនាក់ទៅពិន័យធ្វើបង្គីច្រូតស្បូវក្នុងទៅ។ ខ្ញុំភ័យខ្លាចដែរដល់បានទៅហ្នឹងខ្ញុំអត់ គេរកអត់ឃើញអី ខ្ញុំចេះតែគេផ្លាស់ទៅហ្នឹង ទៅតានៃវិញ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ខូង មួយ ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/394.1 ទំព័រ ៥៨ បន្ទាត់ ២០-២២។

[2743] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ខូង មួយ ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/394.1 ទំព័រ ៥៨ បន្ទាត់ ២០-២២ និងបន្ទាត់ ១៦-១៨។

[2744] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ខូង មួយ ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ E1/394.1 ទំព័រ ៣៨ បន្ទាត់ ១៩-២៤។

[2745] *មើលឧបសម្ព័ន្ធ ឆ៖* កម្មវិធីនៃការបង្ហាញភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសវនាការ ដែលជាជនរងគ្រោះដោយប្រយោលនៃបទបញ្ញាអាពាហ៍ពិពាហ៍។

## ខ. ទិន្នន័យរួមអំពីភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី

## ១. ឆ្នាំនៃការរៀបអាពាហ៍ពិពាហ៍

1169. ដើមបណ្តឹងរដ្ឋប្បវេណីបីរូបគឺ ជា ឌៀប[2746] មុំ វុន[2747] និង សយ ណារឿន[2748] បានរៀបការនៅក្នុងឆ្នាំ១៩៧៥។ ដើមបណ្តឹងរដ្ឋប្បវេណី សា ឡៃហ៊ាង បានរៀបការនៅក្នុងឆ្នាំ១៩៧៦[2749]។ ដើមបណ្តឹងរដ្ឋប្បវេណីមួយរូបឈ្មោះ សុន វុត[2750] បានផ្តល់សក្ខីកម្មថាបានឃើញ ពិធីរៀបអាពាហ៍ពិពាហ៍ នៅក្នុងឆ្នាំ១៩៧៦។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំមួយរូប ស៊ូ សុធារី[2751] កុល ណែម[2752] សេង សឿន[2753] ព្រាប សុឃឿន[2754] ចៅ ឡាង[2755] និង ហ៊ឹម ម៉ាន[2756] បានពន្យល់ថាពិធីរៀប

---

[2746] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/467.1** ទំព័រ ៣២ បន្ទាត់ ២៣-២៥។

[2747] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៤២ បន្ទាត់ ៨។

[2748] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ២៧ បន្ទាត់ ១៤ និងបន្ទាត់ ១៧។

[2749] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ១០ បន្ទាត់ ៤។

[2750] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/412.1** ទំព័រ៥ បន្ទាត់ ១៥។

[2751] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៦៥ បន្ទាត់ ៤-៦។

[2752] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៧៦ បន្ទាត់ ៣។

[2753] បទសម្ភាសន៍ជាមួយដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន **E3/5643** ថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០០៦ ERN (KH) 00059382 ។

[2754] កំណត់ហេតុនៃការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ឯកសារ **E3/9820** ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ERN (KH) 01029954។

[2755] ទំរង់បែបបទសុំព័ត៌មានបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឡាង ឯកសារ **E3/5965a** ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩ ERN (KH) 00586027។

[2756] ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន ឯកសារ **E3/4706** ថ្ងៃទី ២២ ខែ ធ្នូ ឆ្នាំ ២០០៩ ERN(KH) 00369051។

អាពាហ៍ពិពាហ៍របស់ពួកគាត់ ត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ១៩៧៧។ ដើមបណ្ដឹងរដ្ឋប្បវេណី សៀង សុវិដា[2757] បានរំឭកអំពីពិធីរៀបអាពាហ៍ពិពាហ៍ របស់បងស្រីគាត់ដែលបានធ្វើឡើង នៅក្នុងឆ្នាំ ១៩៧៧ផងដែរ។ ដើមបណ្ដឹងរដ្ឋប្បវេណីចំនួនប្រាំបីនាក់គឺ អ៊ុំ យឿន[2758], យស់ ផល[2759] ង៉ែត ចាត[2760] ជុំ សាមឿន[2761] អ៊ុច ស៊ុនឡាយ[2762] ម៉ី សារឿន[2763] មាន លឿយ[2764] និងប៉ែន សុចាន់[2765] បានរៀបការនៅក្នុងឆ្នាំ ១៩៧៨។ ដើមបណ្ដឹងរដ្ឋប្បវេណី ប្រាក់ ឌឿន បានផ្ដល់សក្ខីកម្មថា បាន ចូលរួមពិធីរៀបអាពាហ៍ពិពាហ៍ ដែលបានធ្វើឡើងនៅក្នុងឆ្នាំ ១៩៧៧ និងឆ្នាំ១៩៧៨[2766]។ ដើម បណ្ដឹងរដ្ឋប្បវេណីពីររូបផ្សេងទៀត បានផ្ដល់សក្ខីកម្មថា ការរៀបការដោយបង្ខំរបស់បងប្អូន

---

[2757] ដើមបណ្ដឹងរដ្ឋប្បវេណី សៀង សុវិដា បានផ្ដល់សក្ខីកម្មថា បងស្រីបស់គាត់រៀបការនៅចុងឆ្នាំ ១៩៧៦ ឬ ដើមឆ្នាំ ១៩៧៧។ *សូមមើល* ទំរង់បែបបទសុំព័ត៌មានបន្ថែមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី សៀង សុវិដា ឯកសារ **E3/6518a** ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤ ERN(KH) 01003357។ ដើមបណ្ដឹងរដ្ឋប្បវេណី បានបញ្ជាក់ថា ការរៀបការធ្វើឡើងនៅដើមឆ្នាំ ១៩៧៧។ *សូមមើល* ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះរបស់ដើមបណ្ដឹងរដ្ឋប្បវេណី សៀង សុវិដា ឯកសារ **E3/6518** ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤ ERN(KH) 005552159។

[2758] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ២៧ បន្ទាត់ ២០-២១ ទំព័រ ៣២ បន្ទាត់ ២១-២៣។

[2759] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ៩ បន្ទាត់ ១៣។

[2760] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៥ បន្ទាត់ ៥-៨។

[2761] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៥១ បន្ទាត់ ៧-៨។

[2762] ទំរង់បែបបទសុំព័ត៌មានបន្ថែមរបស់ ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ ឯកសារ **E3/4845** ថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០១០ ERN (KH) 00613037។

[2763] ទំរង់បែបបទសុំព័ត៌មានបន្ថែមរបស់ ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី សារឿន ឯកសារ **E3/6859a** ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ២០១០ ERN (KH) 00584804។

[2764] ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះរបស់ ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ **E3/4889** ថ្ងៃទី ៧ ខែ មិថុនា ឆ្នាំ ២០០៩ ERN (KH) 00540646។

[2765] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/483.1** ទំព័រ ៥៨ បន្ទាត់ ៧-៩។

[2766] ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ប្រាក់ ឌឿន **E3/4989** ERN (KH) 00556217-00556218។

ពួកគាត់ ត្រូវបានធ្វើឡើងនៅក្នុងឆ្នាំ១៩៧៨ ដែលក្នុងនោះមាន ឡាច នី[2767] បងប្រុសរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឡាច គ្រី និងបងស្រីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ធី[2768]។

## ២. ទីតាំងនៃពិធីរៀបអាពាហ៍ពិពាហ៍

1170. ដើមបណ្ដឹងរដ្ឋប្បវេណីបួននាក់គឺ អ៊ុំ យឿន[2769] ព្រាប សុយឿន[2770] ហ៊ឹម ម៉ាន[2771] និងចៅ ឡាង[2772] បានរៀបការនៅក្នុងភូមិភាគកណ្ដាល។ ពិធីរៀបអាពាហ៍ពិពាហ៍របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី សារឿន[2773] និងពិធីរៀបអាពាហ៍ពិពាហ៍របស់បងប្រុស ដើមបណ្ដឹងរដ្ឋប្បវេណី ឡាច គ្រី[2774] រៀបចំឡើងនៅក្នុងភូមិភាគបូព៌ា។ ដើមបណ្ដឹងរដ្ឋប្បវេណី ប្រាក់ ឌឿន[2775] បានឃើញពិធី

---

[2767] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៥៦-៥៧ បន្ទាត់ ២១-៥។

[2768] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សៀង ចាន់ធី ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/394.1** ទំព័រ ១៥ បន្ទាត់ ១២-១៣។

[2769] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/461.1** ទំព័រ ៧៤ បន្ទាត់ ១៥ ទំព័រ ៧៣ បន្ទាត់ ៩-១១ ទំព័រ ៧៣ បន្ទាត់ ១៥-១៦។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៣៣ បន្ទាត់ ៧-៩ ដើម បណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន បានបញ្ជាក់ថា គាត់បានរៀបការនៅចុងឆ្នាំ ១៩៧៨ និងថា គាត់ប្រហែលច្រឡំនៅក្នុងសក្ខីកម្មរបស់គាត់ក្នុងឯកសារ E3/6011A ដែលមាន ERN ជាភាសាខ្មែរលេខ 01003356 ជាភាសាអង់គ្លេសលេខ 01137890 និងជាភាសាបារាំងលេខ 01030293។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៣៧ បន្ទាត់ ២៥-ទំព័រ ៣៨ បន្ទាត់ ២។

[2770] កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុយឿន ឯកសារ **E3/9820** ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ERN (KH) 01029954។

[2771] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ១៣ បន្ទាត់ ២០-២៤។

[2772] ទំរង់បែបបទសុំព័ត៌មានបន្ថែមរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ចៅ ឡាង ឯកសារ **E3/5965a** ថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩ ERN (KH) 00586026។

[2773] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ១៩ បន្ទាត់ ១២-១៤ ទំព័រ ៥២ បន្ទាត់ ១៦-២០។

[2774] មើលឧបសម្ព័ន្ធ ឆ៖ កម្មវិធីនៃការបង្ហាញភ័ស្តុតាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងសវនាការ ដែលជាជនរងគ្រោះដោយប្រយោលនៃបទបញ្ញាអាពាហ៍ពិពាហ៍ ។

រៀបអាពាហ៍ពិពាហ៍ នៅក្នុងភូមិភាគបូព៌ា។ ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម[2776] បានរៀបការនៅក្នុងភូមិភាគពាយ័ព្យ ហើយដើមបណ្តឹងរដ្ឋប្បវេណីមួយរូបទៀតគឺ មុំ វុន[2777] បានរំឭកឡើងថា ពិធីរៀបអាពាហ៍ពិពាហ៍របស់គាត់ បានធ្វើឡើងនៅក្នុងភូមិភាគឧត្តរ។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីរូបគឺ ប៉ែន សុចាន់[2778] ង៉ែត ចាត[2779] និង មាន លឿយ[2780] បានរៀបការនៅក្នុងភូមិភាគពាយ័ព្យ។ ដើមបណ្តឹងរដ្ឋប្បវេណីបីរូបគឺ ស៊ូ សុធារី[2781] យស់ ផល[2782] និងសេង សឿន[2783] បានផ្តល់សក្ខីកម្មថាពួកគាត់បានរៀបការ នៅក្នុងភូមិភាគនិរតី។

1171. ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប[2784] និង ជុំ សាមឿន[2785] បានរៀបការនៅក្នុងតំបន់ស្វយ័តទីក្រុងភ្នំពេញ។ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ[2786] និងដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវិដា[2787]

---

[2775] ទំរង់បែបបទសុំព័ត៌មានបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឌឿន ឯលសារ **E3/5632** ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១០ ERN (KH) 00901538។

[2776] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៧៣ បន្ទាត់ ៨ ១០-១១ និង ១៤-១៦។

[2777] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៤២ បន្ទាត់ ២៣-២៤។

[2778] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៥១ បន្ទាត់ ១៥។

[2779] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៩ បន្ទាត់ ៨-៩។

[2780] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/340.1** ទំព័រ ៥៤ បន្ទាត់ ៩-១០។

[2781] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៦៤ បន្ទាត់ ២៣ ២៥-ទំព័រ ៦៨ បន្ទាត់ ២៧-។

[2782] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ៨ បន្ទាត់ ២៤-២៥ ទំព័រ ៩ បន្ទាត់ ៣-៤ និង ៧-៨ ទំព័រ ១៦ បន្ទាត់ ៤-៨។

[2783] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/465.1** ទំព័រ ២០ បន្ទាត់ ២៩-២០ និងទំព័រ ២៩ បន្ទាត់ ២១-២៤។

[2784] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥៣ បន្ទាត់ ២១។

បានផ្តល់សក្ខីកម្មអំពី ពិធីរៀបអាពាហ៍ពិពាហ៍របស់ ឪពុកក្មេកគាត់ និងបងស្រីរបស់គាត់ ដែលបានធ្វើឡើងនៅក្នុងតំបន់៥០៥ ដែលជាផ្នែកមួយនៃតំបន់ស្វយ័តក្រចេះ។ ដើមបណ្តឹងរដ្ឋប្បវេណី សា ឡៃប៉ាង[2788] បានផ្តល់សក្ខីកម្មថា ពិធីរៀបអាពាហ៍ពិពាហ៍របស់គាត់ បានធ្វើឡើងនៅក្នុងតំបន់៥០៥ នៅភូមិភាគឦសាន ដែលតំបន់នេះជាផ្នែកមួយនៃតំបន់ស្វយ័តនៅពេលនោះ។ ជាចុងក្រោយដើមបណ្តឹងរដ្ឋប្បវេណី សុន វុត[2789] បានឃើញពិធីរៀបអាពាហ៍ពិពាហ៍ ដែលបានធ្វើឡើងនៅក្នុងតំបន់ស្វយ័តមណ្ឌលគីរី។

1172. ដើមបណ្តឹងរដ្ឋប្បវេណី បាននិយាយអំពីពិធីរៀបអាពាហ៍ពិពាហ៍ ដែលបានធ្វើឡើងនៅតាមទីតាំងផ្សេងៗគ្នា រួមទាំងតាមសហជីព[2790] មន្ទីរស្រុក[2791] រោងចក្រ្កាន[2792] ផ្សារ[2793] ការដ្ឋាន[2794] កងចំការកប្បាស[2795] និងតាមវត្ត[2796]។

---

[2785] ទំរង់បែបបទសុំព័ត៌មានបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ឯកសារ **E3/4807** ថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១០ ERN (KH) 00578979។

[2786] ទំរង់បែបបទសុំព័ត៌មានបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុច ស៊ុនឡាយ ឯកសារ **E3/4845** ថ្ងៃទី ៣ ខែ កញ្ញា ឆ្នាំ ២០១០ ERN (KH) 00613036។

[2787] ទំរង់បែបបទព័ត៌មានអំពីជនរងគ្រោះរបស់ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវិដា ឯកសារ**E3/6518** ថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០១៤ ERN (KH) 00552159។

[2788] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃប៉ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ១០ បន្ទាត់ ១៩ ទំព័រ ៥៣ បន្ទាត់ ១១-១៣។

[2789] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/412.1** ទំព័រ ៥ បន្ទាត់ ១០-១៣។

[2790] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/461.1** ទំព័រ ៧២ បន្ទាត់ ១៥។

[2791] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/465.1** ទំព័រ ២៩ បន្ទាត់ ២១-២៥។

[2792] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ៥២ បន្ទាត់ ១៦-២០។

[2793] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥៣ បន្ទាត់ ២១។

[2794] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៤៣ បន្ទាត់ ១២-១៣។ ទំរង់បែបបទសុំព័ត៌មានបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ថៅ ឡាង ឯកសារ **E3/5965a** ថ្ងៃទី ២៨ ខែ

## ៣. ចំនួនគូស្រករដែលបានរៀបអាពាហ៍ពិពាហ៍

1173. ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន[2797] ម៉ី សាវឿន[2798] និងសយ ណាវឿន[2799] បានផ្ដល់សក្ខីកម្មថា មានគូស្រករចំនួន៦០គូ បានរៀបការនៅថ្ងៃដែលពួកគេបានរៀបការ។ ប្រហែលគ្នានេះដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ បញ្ជាក់ថាគូស្រករចំនួន៦៣គូ បានរៀបការនៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍របស់គាត់ដែរ[2800]។ ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន បានរំឭកថាមានចំនួន៥០គូ[2801] ហើយដើមបណ្ដឹងរដ្ឋប្បវេណី កុល ណៃម បានរំឭកថាមានទាំងអស់ចំនួន៣០គូ[2802]។

---

ឧសភា ឆ្នាំ ២០០៩ ERN (KH) 00586027។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/340.1** ទំព័រ ៥៤ បន្ទាត់ ៩-១០។

[2795] កំណត់ហេតុនៃការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន ឯកសារ **E3/9820** ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ERN (KH) 01029954។

[2796] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ១៣ បន្ទាត់ ២០-២២។

[2797] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៤៣ បន្ទាត់ ១៥-១៦ បន្ទាត់ ២៣-២៤។

[2798] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី សាវឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ១៩ បន្ទាត់ ១២-១៤។

[2799] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណាវឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ២៩ បន្ទាត់ ៣។

[2800] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/340.1** ទំព័រ ៥៤ បន្ទាត់ ១២-១៣។ ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មថា "ពេលនោះពិធីរៀបការចាប់ផ្ដើម គេប្រកាសឱ្យអ្នកទាំងអស់គ្នាដឹងថាថ្ងៃនេះអង្គការរៀបការឱ្យអ្នកទាំងអស់គ្នាហើយ ទាំងអស់មាន ៦៣គូ តែអ្នកត្រូវប្រព្រឹត្តទៅតាមមាគ៌ារបស់អង្គការ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/340.1** ទំព័រ ៥៤ បន្ទាត់ ២៣-២៥។

[2801] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ១៣ បន្ទាត់ ២២-២៤។

[2802] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី កុល ណៃម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៧៨ បន្ទាត់ ៩-១០។ ដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងឯកសារ E3/6570A បានផ្ដល់សក្ខីកម្មថា មាន ២០គូ តែក្រោយមកបញ្ជាក់ថា គាត់ច្រឡំ ហើយតាមពិតមាន ៣០គូ។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី កុល ណៃម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៨២ បន្ទាត់ ២០-២២ ទំព័រ ៨៣ បន្ទាត់ ៦-៧។

1174. ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី បានកត់សម្គាល់ថា គាត់បានរៀបការនៅក្នុង ពិធីរៀបអាពាហ៍ពិពាហ៍មួយ ដែលមានគូស្រករដទៃជាងមួយរយគូ។ គាត់បានផ្តល់សក្ខីកម្មថា សរុបទាំងអស់មាន ១១៧គូ[2803] តាមការប្រកាសដែលបានធ្វើឡើង នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍នោះ[2804]។

1175. ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន បានរៀបការនៅក្នុង ពិធីរៀបអាពាហ៍ពិពាហ៍ដែលមានចំនួនប្រាំគូ[2805] ហើយដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត ចាត បានរៀបការនៅក្នុង ពិធីរៀបអាពាហ៍ពិពាហ៍ដែលមានចំនួន១០គូ[2806]។ ចំណែកដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ជាគូស្រករមួយ ក្នុងចំណោមគូស្រករ១៥គូ[2807] ដែលបានរៀបការនៅក្នុង ពិធីរៀបអាពាហ៍ពិពាហ៍របស់គាត់។

1176. ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន គឺស្ថិតក្នុងចំណោមគូស្រករបីគូ[2808] ហើយដើមបណ្តឹងរដ្ឋប្បវេណីបីនាក់ទៀតគឺ អ៊ុំ យឿន[2809]ជា ឌៀប[2810] និងប៉ែន សុចាន់[2811] បានរៀបការនៅក្នុង ពិធីរៀបអាពាហ៍ពិពាហ៍ជាក្រុមមួយ ដែលមានចំនួន១២គូ[2812]។

---

[2803] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/463.1** ទំព័រ ៣៣ បន្ទាត់ ១២-១៤។

[2804] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/463.1** ទំព័រ ៣៣ បន្ទាត់ ១២-១៤។

[2805] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៥១ បន្ទាត់ ៧-៨។

[2806] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៩៤ បន្ទាត់ ២៤។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ១០ បន្ទាត់ ១៥។

[2807] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៧០ បន្ទាត់ ៨-៩។

[2808] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/465.1** ទំព័រ ២០ បន្ទាត់ ១៦-១៨។

[2809] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/461.1** ទំព័រ ៧៤ បន្ទាត់ ២២។

[2810] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥៤ បន្ទាត់ ១៧-១៨។

1177. ដើមបណ្តឹងរដ្ឋប្បវេណី សា ឡៃហ៊ាង បានផ្តល់សក្ខីកម្មថា មានតែមួយគូគាត់ប៉ុណ្ណោះ ដែលរៀបការនៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍របស់គាត់[2813]។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ មានតួនាទីជាគណៈឃុំនៅមូលដ្ឋាន[2814]។

1178. ដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំមួយរូប បានផ្តល់ភ័ស្តុតាងអំពីចំនួនគូស្រករ ដែលបានរៀបការនៅក្នុង ពិធីរៀបអាពាហ៍ពិពាហ៍ ដែលពួកគាត់មិនមែនជាអ្នកត្រូវរៀបការឡើយ។

1179. ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានផ្តល់សក្ខីកម្មអំពីពិធីរៀបអាពាហ៍ពិពាហ៍ចំនួនបី ដែលបានធ្វើឡើងនៅមុនពេល ពិធីរៀបអាពាហ៍ពិពាហ៍ទីបួន ដែលគាត់ផ្ទាល់ត្រូវគេបង្ខំឲ្យរៀបការ។ គាត់បានផ្តល់សក្ខីកម្មថា មានគូស្រករ៥០គូ នៅក្នុងពិធីរៀបអាពាហ៍ពិពាហ៍ទីមួយ[2815] ហើយពិធីរៀបអាពាហ៍ពិពាហ៍បន្ទាប់ មានគូស្រករប្រមាណ៣០ទៅ៤០គូដែលបានរៀបចំឲ្យរៀបការ[2816]។ ពិធីទីបីបន្ទាប់មានចំនួន១២គូ សុទ្ធតែជាមេម៉ាយ និងពោះម៉ាយ[2817]។

[2811] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី បែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៥១ បន្ទាត់ ៨។

[2812] ដើមបណ្តឹងរដ្ឋប្បវេណី ជា ឡៀប ស្គាល់តែប្រាំមួយនាក់ ព្រោះមិត្តនារីផ្សេងទៀតមកពីកងខុសៗគ្នា។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឡៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៧៤ បន្ទាត់ ២០-២២។ ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ បានផ្តល់សក្ខីកម្មថា “កាលនោះ ខ្ញុំនៅវ័យក្មេង មានការភ័យខ្លាច ខ្ញុំអត់ទាន់ស្គាល់ពួកបងៗនោះទេ។ តែគ្រាន់ខ្ញុំចាំ ១២គូ”។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី បែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៥១ បន្ទាត់ ១២-១៣។

[2813] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ៤៦ បន្ទាត់ ១០។

[2814] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ៤១ បន្ទាត់ ១៨។

[2815] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៧៦ បន្ទាត់ ២៥។

[2816] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៧៧ បន្ទាត់ ៣-៤។

[2817] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៧៧ បន្ទាត់ ៥-៧។

1180. ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត បានផ្តល់សក្ខីកម្មថា បានឃើញពិធីរៀបអាពាហ៍ពិពាហ៍ ដែលរៀបចំឡើងនៅតំបន់ស្វយ័តមណ្ឌលគីរី ដែលក្នុងពិធីនោះ មានគូស្រករ៧គូបានរៀបការ[2818]។ ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី បានផ្តល់សក្ខីកម្មអំពី ពិធីរៀបអាពាហ៍ពិពាហ៍បងប្រុសគាត់ ដែលក្នុងពិធីនោះមានគូស្រករ២០គូបានរៀបការ[2819]។ ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវិដា បានផ្តល់ភ័ស្តុតាងចចាមអារាម អំពីពិធីរៀបអាពាហ៍ពិពាហ៍របស់បងស្រីគាត់ ដែលមានចំនួន២១គូបានរៀបការ[2820]។ ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឌឿន បានផ្តល់សក្ខីកម្មអំពី ការចូលរួមក្នុងពិធីរៀបអាពាហ៍ពិពាហ៍ ដែលមានចំនួន២៥គូ[2821] ហើយក្រៅពីពិធីរៀបអាពាហ៍ពិពាហ៍ ដោយបង្ខំរបស់រូបគាត់ផ្ទាល់នោះ ដើមបណ្តឹងរដ្ឋប្បវេណី សយ ណារឿន បានផ្តល់សក្ខីកម្មអំពី ពិធីរៀបអាពាហ៍ពិពាហ៍របស់ប្អូនស្រីគាត់ ដែលមានគូស្រករ៦០គូបានរៀបការ[2822]។

## ៤. អាយុរបស់គូស្រករដែលបានរៀបអាពាហ៍ពិពាហ៍

### ៤.១. នារីមានអាយុ២០ឆ្នាំឡើង និងបុរសមានអាយុ២៥ឆ្នាំឡើង

1181. ភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីបានបង្ហាញថា ទោះបីជានារីៗបានរៀបការនៅក្នុងវ័យ ចាប់ពី២០ឆ្នាំបន្តិចបន្តួច ទៅដល់២៥ឆ្នាំនោះ បុរសៗរៀបការនៅក្នុងវ័យ យ៉ាងហោចណាស់២៥ឆ្នាំដែរ។ ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធាវី ជាបុរសដែលប្តូរភេទទៅជាស្ត្រីនោះ បានរំឭកថា ប្រហែល "៣០ជាង" ចំណែកប្រពន្ធរបស់គាត់មានអាយុ "ប្រហែល២០ឆ្នាំ" នៅពេលដែលពួក

[2818] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/412.1** ទំព័រ ៥ បន្ទាត់ ១០-១១ បន្ទាត់ ១៥។

[2819] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ឡាច គ្រី ប្រតិចារឹក ថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០១៦ ឯកសារ **E1/379.1** ទំព័រ ៥៧ បន្ទាត់ ៤-៥។

[2820] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវិដា ប្រតិចារឹក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ៣៤-៣៥ បន្ទាត់ ២១-៨។

[2821] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឌឿន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/361.1** ទំព័រ ៧៩ បន្ទាត់ ២០។

[2822] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៣៨ បន្ទាត់ ១២។

គាត់បានរៀបការ[2823]។ គូស្រករមួយទៀតបានផ្តល់សក្ខីកម្មថា គាត់ក៏រៀបការនៅក្នុងវ័យដូចគ្នានេះដែរ[2824]។ ការនេះត្រូវបានគាំទ្រដោយ ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន ដែលបញ្ជាក់ថា "អាយុចន្លោះពី២៥ឆ្នាំ ទៅជាង៣០ឆ្នាំ"[2825]។ បុរសៗយ៉ាងហោចណាស់ត្រូវមានអាយុ២៥ឆ្នាំ ហើយប្រពន្ធពួកគេត្រូវមានអាយុក្មេងជាង ប្រហែលពីរទៅបីឆ្នាំ[2826]។ ដើមបណ្តឹងរដ្ឋប្បវេណី យស់ ផល បានអះអាងថា ចន្លោះអាយុអ្នកដែលត្រូវរៀបការ គឺចន្លោះពី២៣ ទៅ២៥ឆ្នាំ[2827] ហើយដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន បានបញ្ជាក់ដូចគ្នាថា គូស្រករមានអាយុប្រហែល២០ ទៅ២៧ឆ្នាំ[2828]។

1182. នៅពេលដែលគេបង្ខំឲ្យគាត់រៀបការ ដើមបណ្តឹងរដ្ឋប្បវេណី សា ឡៃហ៊ាង បានផ្តល់សក្ខីកម្មថា គាត់មាន "អាយុ២៥ឆ្នាំ"[2829]។ ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណីប្រាំរូបដទៃទៀតគឺ ជា ឌៀប, កុល ណែម, ង៉ែត ចាត, សៀង ចាន់ថី និង ម៉ី សារឿន បានកត់សម្គាល់យ៉ាងច្បាស់ថា ប្រពន្ធជាទូទៅស្ថិតក្នុងវ័យ២០ឆ្នាំតិចតួច នៅពេលដែលពួកគេរៀបការ។ ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប បានពន្យល់ថា គាត់មានអាយុប្រហែល "១៩ឬ២០ឆ្នាំ"[2830] ចំណែកប្តីរបស់គាត់មានអាយុ២៦ឆ្នាំ[2831]។

---

[2823] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធាវី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៧៣ បន្ទាត់ ៧-៩។

[2824] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធាវី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៧៤ បន្ទាត់ ៦-៩។

[2825] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/465.1** ទំព័រ ១៤ បន្ទាត់ ១៥-១៦។

[2826] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/465.1** ទំព័រ ១៦ បន្ទាត់ ១៣-១៤។

[2827] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ២០ បន្ទាត់ ១៧-២០។

[2828] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៤៥ បន្ទាត់ ៦-៧។

[2829] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ៤៥ បន្ទាត់ ២៥។

[2830] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/467.1** ទំព័រ ១៩ បន្ទាត់ ១៦-១៨។

ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម បានប៉ាន់ប្រមាណថាប្រពន្ធរបស់គាត់មានអាយុ "ប្រហែល ២០ឆ្នាំ ឬលើសតិចតួច"[2832]។ ដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត ចាត មានអាយុ២០ឆ្នាំ នៅពេលដែលគាត់រៀបការ ហើយប្តីរបស់គាត់មានអាយុ ប្រហែលជិតពីរដងអាយុគាត់[2833]។ ដើមបណ្តឹងរដ្ឋប្បវេណី សៀង ចាន់ធី បានផ្តល់សក្ខីកម្មថា បងស្រីរបស់គាត់ស្ថិតក្នុងវ័យជាង២០ឆ្នាំ នៅពេលដែលគាត់ត្រូវគេបង្ខំឱ្យរៀបការ[2834]។ ប្រហែលគ្នានេះដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សាវឿន បានរំឭកថាគាត់មានអាយុប្រហែល២៥ឆ្នាំ[2835] ចំណែកប្រពន្ធរបស់គាត់មានអាយុ ក្មេងជាងគាត់ប្រហែល៥ឆ្នាំ[2836]។

## ៤.២. ស្ត្រីដែលរៀបអាពាហ៍ពិពាហ៍ នៅអាយុ១៦ឆ្នាំ ឬតិចជាងនេះ

1183. ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ បានពន្យល់ថា "ខ្ញុំនៅវ័យក្មេង។ គេបានតម្រូវឱ្យខ្ញុំរៀបការកាលសម័យខ្មែរក្រហម តាំងពីខ្ញុំអត់ទាន់គ្រប់អាយុ"[2837]។ "កាលនោះខ្ញុំចាំបាន ប្រហាក់ប្រហែលអាយុខ្ញុំ ប្រហែលជា១៥ ទៅ១៦ឆ្នាំប៉ុណ្ណោះ"[2838]។ "អាយុគេខ្ញុំដឹង គឺ២៥ឆ្នាំ លោកប្រធាន គឺខ្ញុំ

[2831] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឡៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥៦ បន្ទាត់ ១៩-២០។

[2832] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៧៧ បន្ទាត់ ១៩-២០។

[2833] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៩៥ បន្ទាត់ ២៣-២៤។

[2834] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សៀង ចាន់ធី ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/394.1** ទំព័រ ១៥ បន្ទាត់ ៩-១៣។

[2835] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សាវឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ៦៤ បន្ទាត់ ២៣។

[2836] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សាវឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ៦៥ បន្ទាត់ ៣។

[2837] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៥០ បន្ទាត់ ២៣-២៤។

[2838] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៥១ បន្ទាត់ ៣-៤។

អាយុប្រហែលជា១៥ ១៦ឆ្នាំប៉ុណ្ណោះឯង"[2839] គឺគាត់បានបញ្ជាក់ឡើងវិញថានៅពេលបន្ទាប់។ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា អាជ្ញាធរនៅពេលដែលគាត់រៀបការនោះ "មិនបានសួរថាខ្ញុំអាយុប៉ុន្មានទេ"[2840]។ បងស្រីរបស់ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវិដា ត្រូវបានគេបង្ខំឱ្យរៀបការ នៅពេលដែលគាត់មានអាយុប្រហែល១៥ ឬ១៦ឆ្នាំ៖ "បន្ទាប់មកបងស្រីខ្ញុំត្រូវបានគេបង្ខំឱ្យរៀបការ។ នៅពេលនោះគាត់មានអាយុប្រហែល១៥ ឬ១៦ឆ្នាំ..."[2841]។

## គ. ភ័ស្តុតាងអំពីឧក្រិដ្ឋកម្ម ដែលដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់ នៅក្នុងផ្នែកសវនាការទាក់ទងអំពើអមនុស្សធម៌ដទៃទៀត

1184. ភ័ស្តុតាងដើមបណ្តឹងរដ្ឋប្បវេណី ដែលបានលើកឡើងនៅក្នុងសវនាការបង្ហាញថា ការប្រព្រឹត្តរបស់អង្គការ ក្នុងការគ្រប់គ្រងទៅលើការរៀបអាពាហ៍ពិពាហ៍ បានគ្រប់ដណ្តប់ទៅលើ ការរំលោភបំពានទៅលើសិទ្ធិរបស់ប្រជាជន ក្នុងការសម្រេចចិត្តរៀបអាពាហ៍ពិពាហ៍ តាមការយល់ព្រមទាំងស្រុងនិងដោយសេរី សិទ្ធិក្នុងការមិនទទួលរង ការប្រព្រឹត្តអំពើអមនុស្សធម៌ កាចសាហាវយង់ឃ្នង ឬបន្ទាបបន្ថោក ព្រមទាំងសិទ្ធិក្នុងការមិនទទួលរង ការជ្រែកជ្រែកតាមអំពើចិត្ត ទៅលើឯកជនភាពរបស់ពួកគេ និងក្រុមគ្រួសាររបស់ពួកគេ[2842]។ ការប្រព្រឹត្តនេះបង្កើតបានជា អំពើដែលមានលក្ខណៈ និងស្ថានទម្ងន់ប្រហាក់ប្រហែលគ្នា ជាមួយឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដទៃទៀត ដែលបង្កឱ្យមានព្យសនកម្មធ្ងន់ធ្ងរ និងបង្កើតបានជាការប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់មនុស្ស។

### ១. ការសម្រេចចិត្តរៀបអាពាហ៍ពិពាហ៍

### ១.១. បរិយាកាសនៃការភ័យខ្លាចជាទូទៅ

[2839] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី បែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៧៦ បន្ទាត់ ១៩-២០។

[2840] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី បែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/483.1** ទំព័រ ៥ បន្ទាត់ ១០-១២។

[2841] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សៀង សុវិដា ប្រតិចារឹក ថ្ងៃទី ២ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/308.1** ទំព័រ ៦ បន្ទាត់ ២៣-២៤។

[2842] សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ ១៩៤៨ មាត្រា ៣, មាត្រា ៥, មាត្រា ១២, មាត្រា ១៦។

1185. ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានពន្យល់ថា "កាលក្នុងរបបហ្នឹង គ្មានមនុស្សណាហ៊ានប្រឆាំងនឹងអង្គការបក្សទេ បើគេថាឲ្យធ្វើអីយើងធ្វើហើយ ទោះបីជាយើងត្រូវគ្នា មិនត្រូវគ្នា យើងលាក់លួចនៅក្នុងអារម្មណ៍ទៅ។ បើសិនជាយើងហ៊ានបញ្ចេញ មានតែសេចក្តីស្លាប់ ព្រោះត្បិតអីសម័យនុ៎ងគេមិនដែលយោគយល់ថា ម៉ែឪ ដូចម៉ែឪរៀបចំឲ្យ បើអ្នកឯងមិនស្រឡាញ់ទេ អាចលែងគ្នាបាន សម័យនុ៎ងគ្មានឲ្យលែងបានទេ។ បើអ្នកឯងមិនស្រឡាញ់ មិនពេញចិត្ត មិនគោរពតាមអង្គការវិន័យ គេនឹងសម្លាប់មិនឲ្យយើងឃើញម៉ែឪទៀតអ៊ូ សម្លាប់ចោលដូចសត្វដូចធាតុអ្វីចឹង"[2843]។

1186. ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន បានពន្យល់ថា គ្មាននរណាម្នាក់ហ៊ានបដិសេធមិនព្រមរៀបការឡើយ៖ "គូដែលត្រូវបដិសេធវាមានដូចគ្នា ក៏ប៉ុន្តែមិនអាចបដិសេធបាន ក៏ត្រូវតែធ្វើដូចតែគ្នាហ្នឹង។ បើសិនជាខាងស្រីបដិសេធ ខាងស្រីនឹងស្លាប់ បើខាងប្រុសបដិសេធ ខាងប្រុសនឹងស្លាប់។ វាដូចតែគ្នាគូវាទាំងពីរនេះ វាដើរស្មើគ្នាទាំងអស់។ ដោយមិនហ៊ានប្រកែក មិនហ៊ានតវ៉ា គឺខ្លាចតែរឿងមួយហ្នឹង គឺខ្លាចតែរឿងស្លាប់ហ្នឹងតែម្តង"[2844]។

1187. ដើមបណ្តឹងរដ្ឋប្បវេណី សា ឡៃហ៊ាង បានផ្តល់សក្ខីកម្មថា "ពួកយើងត្រូវតែទទួលយល់ព្រមទៅតាមការចាត់តាំងរបស់អង្គការដើម្បីសុវត្ថិភាព គឺអាយុជីវិតរបស់ខ្លួនម្នាក់ៗ ហើយយើងត្រូវធ្វើខ្លួនឲ្យចុះសម្រុងនឹងប្តីរបស់ខ្លួន ដែលអង្គការផ្គូរផ្គងឲ្យ។ បើពុំដូច្នោះគេនឹងមានបញ្ហាសុវត្ថិភាពជីវិតផ្ទាល់ខ្លួន"[2845]។

1188. ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធាវី បានរៀបរាប់ថា "បានបងថ្ងៃមួយ...គាត់ថាយើងអស់ហើយ បើប្អូននៅប្រកែកគេទៀត គង់ថ្ងៃណាមួយប្អូនគេយកទៅសម្លាប់។ ខ្ញុំនៅតែស្ងៀមមិនព្រមតវ៉ា ខ្ញុំ

---

[2843] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៦៤ បន្ទាត់ ២៥ -ទំព័រ ៦៥ បន្ទាត់ ៥។

[2844] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៤០ បន្ទាត់ ១៦-១៩។

[2845] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ៨២ បន្ទាត់ ២-៦។

ប្រកែករហូតមិនព្រមរៀបការ ព្រោះខ្ញុំគ្មានកូនចិត្តនឹងស្រឡាញ់ស្រីទេ ខ្ញុំមានចិត្តតែស្រឡាញ់ប្រុសគ្នាឯង បើធម្មជាតិខ្ញុំបង្កើតមកអ៊ីចឹងទៅហើយ ឲ្យខ្ញុំកែប្រែធម្មជាតិម៉េចកើត"[2846]។

1189. ដើមបណ្តឹងរដ្ឋប្បវេណី យស ផល បានផ្តល់សក្ខីកម្មថា "និយាយឲ្យពិតត្រង់ទៅ នៅពេលហ្នឹងប្រសិនបើយើងសុទ្ធតែពេលកំពុងតែភ័យ នៅក្នុងរបបខ្មែរក្រហមគឺថាភ័យខ្លាច។ អ៊ីចឹងយើងត្រូវគ្រាន់តែមាននិយាយថា យើងត្រូវនិយាយថាស្រឡាញ់គ្នា។ អត់មាននិយាយថា បើសិនជានិយាយថា រើបម្រះរកផ្លូវបែកគ្នាហ្នឹង អាហ្នឹងប្រហែលជាបែកក្បាលទាំងពីរនាក់ហើយ មិនបែកក្បាលអីទេ បែកក្បាលគឺងាប់តែម្តង។ អ៊ីចឹងយើងអត់មានហ៊ានថាលែងលះគ្នាទេ។ មានតែនិយាយគ្នាដោយស្រួល ដោយសន្តិវិធីថាយើងស្រឡាញ់គ្នា យើងរស់ជាមួយគ្នាដោយស្រួល"[2847]។

1190. ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប បានពន្យល់អំពីមូលហេតុ ដែលគាត់ឈប់បដិសេធមិនព្រមរៀបការ៖ "ចាស ខ្ញុំខ្លាចដែរហ្នឹង ខ្លាចមានរឿងចោទប្រកាន់មក ក្រែងលោដឹងរឿងសីលធម៌រឿងអី ថាខ្ញុំក្បត់ខ្ញុំអីទៀតទៅ។ អាហ្នឹងខ្ញុំវាមិនហ៊ានសន្និដ្ឋានដែរ បានខ្ញុំមិនហ៊ានតវ៉ាជាមួយគេតទៅទៀតហ្នឹង"[2848]។

1191. ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន បានផ្តល់សក្ខីកម្មថា "អារឿងសម័យនោះ ខ្ញុំវាពិបាកនឹងជម្រាបថា ខ្លាចអីរឿងអី ព្រោះមួយក្រោមការដឹកនាំរបស់គេ ហើយសម័យនោះពិបាកណាស់ស្រួលមិនស្រួលហ្នឹង ងាប់ បាត់ខ្លួន មិនដឹងជាស្អីៗអាហ្នឹងមិនថា ឋានៈអីថ្នាក់អីទេ តែមិនស្រួលបាត់។ ហើយអ៊ីចឹងចេះតែគិតអីអ៊ីចឹង អំ! ថាឲ្យយកក៏យកទៅអាហ្នឹង។ ខ្ញុំបានគិតឃើញតែអ៊ីចឹងទេ សម័យនោះ"[2849]។

---

[2846] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធាវី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៦៦ បន្ទាត់ ១-៥។

[2847] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ២៣ បន្ទាត់ ២៣-ទំព័រ ២៤ បន្ទាត់ ៣។

[2848] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/467.1** ទំព័រ ២៩ បន្ទាត់ ៧-៩។

[2849] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/465.1** ទំព័រ ២១ បន្ទាត់ ១៣-១៦។

1192. ដើមបណ្ដឹងរដ្ឋប្បវេណី កុល ណែម បានផ្ដល់សក្ខីកម្មថា៖ "ខ្ញុំខ្លាចអីជំនាន់ហ្នឹង ត្រូវតែខ្លាចហ្នឹង ហើយ ពីណាក៏ដឹងដែរជំនាន់ហ្នឹង ព្រោះហើយខ្ញុំចេញពីកន្លែងកងពលគេបញ្ជូនមក ខ្ញុំដឹងថាមេគេចាប់ហើយហ្នឹងហើយ។ ឈិន សយ គេចាប់ហើយ។ មកដល់នេះទៀត គេកៀបទៀត មិនដឹងយ៉ាងម៉េចគេធ្វើយ៉ាងម៉េច។ បានខ្លាចទាំងអស់គ្នាអ្នកណាក៏ខ្លាចដែរ។ មិនតែខ្ញុំម្នាក់ទេ ត្រូវគោរពគេទាំងអស់។ ហ្នឹងហើយយោបល់ខ្ញុំប៉ុណ្ណឹង បើមិនខ្លាចគេការធ្វើអី បើយើងនេះ ប៉ុន្តែយើងខ្លាចគេសុខចិត្តយើងស្រុះបាទ"[2850]។ "បើមិនចេញពីគំនិតណា បើទម្លាប់អីចឹងរហូតហើយ ឃើញថាឲ្យតែមានបញ្ហាខុសបន្តិចបន្តួច គឺគេចាប់ទៅតែម្ដង ចាប់ទៅច្រើនណាស់"[2851]។

1193. នៅថ្ងៃគាត់រៀបការ ពេលដែលគេហៅគាត់ឲ្យចូលរួម ក្នុងពិធីរៀបអាពាហ៍ពិពាហ៍ នៅឯវត្តអូរត្រកួននោះ ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន "ទៅតម្រង់កន្លែងការ តុហ្នឹងតែម្ដង តុដែលខ្ញុំអង្គុយហ្នឹង អត់មានដើរទៅណាខ្វេរខ្វល់តាមណាទេ ព្រោះចេះតែខ្លាចបាទ ខ្លាច ចេះតែប្រយ័ត្នជាប់អីចឹង។ ដើរទៅនេះទៅនោះហ្នឹង វាថាយើងអីចេះអីចុះ ម្ល៉ោះហើយត្រង់តែលើតុដែលខ្ញុំអង្គុយហ្នឹង"[2852]។

## ១.២. ការមិនអាចបដិសេធលើការរៀបអាពាហ៍ពិពាហ៍

1194. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន បានពន្យល់ថា "ពេលណាដែលវាចង់ចាប់យើង ចង់ឲ្យបង្ខិតបង្ខំយើងរៀបគ្រួសារ គឺបង្ខិតបង្ខំតែម្ដង ចុងក្រោយបំផុតហ្នឹង គឺអត់មានអ្នកណានេះទេគ្រូ។ ពីដំបូងអីចឹងមែន គេថាឲ្យក្រិត្យក្រមតាមអង្គការស្នើ អីអីចឹងមួយ ជំនាន់ខ្ញុំផ្ទាល់តែម្ដង គឺបង្ខំតែម្ដង បង្ខំ

---

[2850] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៨២ បន្ទាត់ ១៨-២២។

[2851] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៨២ បន្ទាត់ ២៤-២៥។

[2852] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហ៊ឹម ម៉ាន ប្រតិចារឹក ថ្ងៃទី ២៨ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/350.1** ទំព័រ ១៤ បន្ទាត់ ២៤-ទំព័រ ១៥ បន្ទាត់ ១។

រៀបគ្រួសារត្រូវតែរៀប បើមកម៉ោងប៉ុន្មាន ត្រូវរៀបម៉ោងប៉ុណ្ណឹងតែម្តង"[2853]។ ដើមបណ្តឹងរដ្ឋប្បវេណីបន្តបញ្ជាក់ថា "ខ្ញុំបានតវ៉ា គាត់ថាត្រូវតែទៅ ព្រោះអង្គការកំណត់ចាស"[2854]។

1195. ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធាវីបានពន្យល់ថា "មិនអាចប្រកែកបានទេពេលហ្នឹង គឺពេលដំណាក់កាលដែលគេត្រូវស្ទៃយកចុង យកដើមហើយពេលហ្នឹង។ ដឹងគំនិតថា ខ្ញុំធ្លាប់តែដឹងឮពីមុនមក គេរៀបការក្នុងឆ្នាំ៧៦ ដើមឆ្នាំ៧៧ ខ្ញុំឃើញថាមានគេយកទៅវ៉ៃចោលច្រើនគួណាស់ យកទៅរៀនសូត្រ"[2855]។ គាត់បានពន្យល់ថា "គ្មានអ្នកណាក្រៅពីប្រធានកងទេ បង្ខំរៀបការ គំរាមកំហែងសម្លាប់ផង គំរាមកំហែងយកទៅរៀនសូត្រផង"[2856]។

1196. ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន ត្រូវបានបង្ខំឱ្យរៀបការ ជាមួយប្អូនជីដូនមួយរបស់ សៅ ផុន ជាប្រធានគណៈស្រុក៖ "បងសៅ ផុនហ្នឹងគាត់ថា "ស្អែងល្មមយកប្រពន្ធហើយ"។ ខ្ញុំចេះតែប្រកែក ១ គាត់ឱ្យបងស្រីមួយស្រុកកំណើត នៅជិតដំណាក់សេកដែរ គាត់ខ្ញុំភ្លេចឈ្មោះគាត់ដែរ គាត់ធ្វើអនុប្រធានពេទ្យស្រុកហ្នឹង។ ចេះមកសួរខ្ញុំម្តង ខ្ញុំថា អូ! ខ្ជិលណាស់ ដឹងយកអីទេ។ គឺថារាប់លើកទីបី អ្អ! ឯាកសួរ១ម្ល៉េះ គ្រប់បីដងហើយ សួរឱ្យយកប្រពន្ធ ខ្ញុំថា "អ្អ! អ៊ីចឹងព្រមក៏ព្រមទៅ"។ ក៏បងផុនរៀបការឱ្យខ្ញុំទៅ។ ប្អូនខ្ញុំកាលហ្នឹងរៀបការឱ្យខ្ញុំ គឺជាប្អូនជីដូនមួយរបស់ សៅ ផុន គណៈ

---

[2853] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៣១ បន្ទាត់ ២៥ - ទំព័រ ៣២ បន្ទាត់ ២។

[2854] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៣២ បន្ទាត់ ៦។ "រឿងតវ៉ាហ្នឹងមិនមែនបានរាល់តែពេលទេ" ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា "ពេលតវ៉ាហ្នឹងគឺនិយាយតែមួយម៉ាត់គឺឱ្យទៅតែម្តង អត់បានសួរពីថ្ងៃមុនទេ តែហៅថ្ងៃហ្នឹងចុចទៅថ្ងៃហ្នឹងហ្នង។ សម័យ ប៉ុល ពត ចឹង"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៣២ បន្ទាត់ ១០-១៣។

[2855] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធាវី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៧១ បន្ទាត់ ១៩-២១។

[2856] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធាវី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៦៥ បន្ទាត់ ១១-១៣។

ស្រុកហ្នឹង អាហ្នឹងរឿងខ្ញុំផ្ទាល់។ ខ្លាចគេថាផង ហើយនឹងចិត្តមិនចង់ មិនចង់ផង ដល់ថាចុះថាឡើងទៅ អ្អើ យកក៏យក”[2857]។

1197. ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប បានផ្តល់សក្ខីកម្មថា “អ្នកដែលគិតគូផ្តួចផ្តើម ឲ្យខ្ញុំរៀបគ្រួសារ គឺប្រធានរបស់ខ្ញុំឈ្មោះ ពូ ផាន់។ គាត់ជាប្រធានគ្រប់មុខព្រួញរបស់ខ្ញុំផ្ទាល់តែម្តង”[2858]។ ក្រោយពេលគាត់បដិសេធជាលើកទីពីរ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានគេបង្គាប់ ឲ្យទៅមន្ទីរគ៦នៅផ្សារអូរឫស្សី[2859]។ នៅឯផ្សារអូរឫស្សី ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ត្រូវបានគេប្រាប់ថា "មិត្តជាកូនអង្គការ បើមិននៅជាមួយម៉ែឪ មិត្តគោរពម៉ែឪ។ មិត្តនៅជាមួយអង្គការ មិត្តគោរពអង្គការ។ ដូច្នេះត្រូវធ្វើតាមអង្គការចាត់តាំង។ ដល់ខ្ញុំប្រកែកម្តងពីរដងហើយមិនបាន លើកទីបីខ្ញុំថាធ្វើម៉េចក៏ធ្វើទៅ ស្រេចតែចិត្តទៅ បើខ្ញុំប្រកែកមិនបានហើយ។ តែប៉ុណ្ណឹង។"[2860]។

1198. ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន បានរៀបរាប់អំពីការបដិសេធ ជាលើកទីពីររបស់គាត់ ក្នុងការមិនព្រមរៀបការត្រូវបានគេបដិសេធ ថា៖ “កាលដែលប្តីខ្ញុំគេហៅរៀនផុត កន្លងផុតប្រហែលជាពីរខែ ឬក៏បីខែ មិត្តគេបានបង្ខំឲ្យខ្ញុំរៀបការ។ បង្ខំឲ្យរៀបការហើយ ខ្ញុំប្រកែកថា ខ្ញុំអត់រៀបការទេ ខ្ញុំខ្លាចប្តីខ្ញុំមកវិញ។ អត់ការក៏ត្រូវតែការដែរ គេនិយាយបែបនេះ”[2861]។ បើទោះបីជាគាត់ប្រកែកក៏ដោយ តែគេប្រាប់គាត់ថាគាត់មិនមានជម្រើសឡើយ[2862]។ “មេកងប្រធានខ្សែគេឈ្មោះ មិត្តស៊ា គេ

[2857] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/465.1** ទំព័រ ១៩ បន្ទាត់ ២០-ទំព័រ ២០ បន្ទាត់ ១។

[2858] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥៣ បន្ទាត់ ២-៣។

[2859] “ពេលដែលគាត់ហៅខ្ញុំសរលើកទី១ ខ្ញុំឆ្លើយថា ខ្ញុំអត់យកទេ គិតតែគួចាស់ៗសិនទៅ ខ្ញុំមិនទាន់រៀបទេ ព្រោះនៅក្មេងណាស់ អាចបម្រើអង្គការបានយូរទៀត។ លើកទី២ ខ្ញុំប្រកែកបាន ដល់លើកទី៣ គាត់ឲ្យខ្ញុំមកមន្ទីរ គ៦ នៅផ្សារអូរឫស្សី”។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥៣ បន្ទាត់ ៨-១២។

[2860] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥៣ បន្ទាត់ ១២-១៥។

[2861] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៣៦ បន្ទាត់ ៩-១១។

[2862] “ខ្ញុំប្រកែកថា ខ្ញុំអត់រៀបការទេ ខ្ញុំខ្លាចប្តីមកវិញ ព្រោះទើបតែហៅប្តីខ្ញុំទៅ។ ឲ្យខ្ញុំរៀបការម៉េចបាន បើប្តីខ្ញុំទើបនឹងទៅសោះ ហើយហៅខ្ញុំមករៀបការ ខ្ញុំអត់រៀបការទេ។ ហើយគេឆ្លើយមកវិញថា មិនរៀបការ ក៏ត្រូវតែរៀបការដែរ”។ *សូមមើល*

ប្រាប់ខ្ញុំឲ្យរៀបការហ្នឹង។ គេហៅខ្ញុំមកសួរ ត្រូវតែរៀបការហ្នឹង គេប្រាប់ហើយគេដើរចេញទៅ។ ហើយខ្ញុំក៏ចេះតែភ័យហើយ ថាទៅការឯណា បើប្តីទើបតែទៅបាត់មួយថ្ងៃណោះ ហើយតែដល់វិលមកវិញអីទៅ មិនកើតរឿងរ៉ាវធំហើយ អ៊ីចឹងចេះ តែដល់នេះទៅនៅស្ងៀមទៅ"[2863]។

1199. ចំពោះការប្រកែកមិនព្រមរៀបការ តាមការរៀបចំរបស់គេនោះ ដើមបណ្តឹងរដ្ឋប្បវេណី សា ឡៃហ៊ាង បានបញ្ជាក់ថា៖ "ការប្រកែកនេះមានចំនួនបីដង ជាលើកទី៣។ ហើយលើកទី៣នេះ មានពាក្យផ្តាំផ្ញើមកថា នាងខ្ញុំក្បាលរឹង ដូចថាមិនព្រមទៅតាមបទបញ្ជារបស់គេអ៊ីចឹងណា។ ដល់ហើយឮពាក្យហ្នឹងក៏សម្រេចថា ទទួលអ៊ីចឹងទៅ កុំឲ្យវាមានបញ្ហាវែងឆ្ងាយតទៅទៀត"[2864]។

1200. ដើមបណ្តឹងរដ្ឋប្បវេណី សា ឡៃហ៊ាង បានយល់ព្រមតាមការរៀបចំ បន្ទាប់ពីគាត់ត្រូវគេចោទប្រកាន់ថាក្បាលរឹង៖ "ចាស ពេលនុ៎ង នាងខ្ញុំបានប្រកែកជាច្រើនលើកជាច្រើនសា ដែលគេមកសួរ។ តែចុងក្រោយគេមានពាក្យមួយនិយាយថា គណៈតំបន់ថាឲ្យថា "មិត្តឯងមិត្តរឹងណាស់ មុខរឹងណាស់" អ៊ីចឹងណា ហើយគេនិយាយច្រើនទៀត តែគេអត់បានបញ្ចេញប្រាប់។ មិនដឹងជានិយាយរបៀបម៉េច។ ដល់អ៊ីចឹងនាងខ្ញុំក៏មានការព្រួយបារម្ភ ភ័យខ្លាចអ៊ីចឹងទៅ"[2865]។ ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា "ការចាត់តាំងនៅពេលនោះ គឺតម្រូវការទៅតាមការចាត់តាំងរបស់គេ គឺខ្លួនគ្មានសិទ្ធិប្រកែកប្រណាំងអីជាមួយគេទេ។ គឺឲ្យទៅច្រកណា គឺទៅច្រកហ្នឹងហ្មង សម័យហ្នឹង។ ទៅអ្នកណា ទោះជាខ្វាក់ខ្វិនយ៉ាងម៉េច ក៏ត្រូវតែទទួលដែរ ចាស"[2866]។

---

សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៣៧ បន្ទាត់ ២-៤។

[2863] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៣៧ បន្ទាត់ ៨-១១។

[2864] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ៤៥ បន្ទាត់ ៦-៨។ "ប្រហែលជាជាងកន្លះឆ្នាំ ប្រាំ ឬប្រាំមួយខែ។ ម្តងហើយមតងទៀត បានគេចោទពាក្យថា មុខរឹង ក្បាលរឹងណាស់" ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ៤៥ បន្ទាត់ ១១-១២។

[2865] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ១១ បន្ទាត់ ១០-១៣។

[2866] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ១១ បន្ទាត់ ៣-៥។

1201. ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ បានពន្យល់ពីការដែលគាត់ ត្រូវបានគេប្រាប់ថា គាត់មិនមានជម្រើសអ្វីផ្សេង ក្រៅពីការព្រមរៀបការឡើយ៖ " គាត់ថាមិត្តឯងមិនរៀបការ ក៏ត្រូវតែរៀបការដែរ ព្រោះមិត្ត អឿន ដាក់កំណត់មកឲ្យមិត្តឯងហើយ។ កង់ប្រវត្តិសាស្ត្រ គេវិលទៅមុខគេមិនវិលថយក្រោយទេ។ អ្នកឯងមិនរៀបការ ប្រយ័ត្នគេចាប់ទៅកសាង។ ដល់ពេលខ្ញុំឮសូរសំឡេងកសាង ក៏ខ្ញុំចូលខ្លួនទៅឲ្យគេស្លៀកសំពត់ ចងសង្វាចេក ទៅអង្គុយជួរនឹងគេ លោកប្រធាន"[2867]។ "ខ្ញុំព្យាយាមរត់ ខ្ញុំព្យាយាមសុំអង្វរលោកប្រធានមេកងហ្នឹង ហើយនិងបងអ៊ុំហ្នឹង គឺសុំគេអត់បាន គេថាកង់ប្រវត្តិសាស្ត្រវិលទៅមុខ គេបញ្ជាក់ម្ដងហើយម្ដងទៀត តែប៉ុណ្ណឹងលោកប្រធាន"[2868]។

1202. ដើមបណ្ដឹងរដ្ឋប្បវេណី កុល ណែម បានផ្ដល់សក្ខីកម្មថា៖ "បើយើងមិនការ ត្រូវគេវិន័យដាក់ទណ្ឌកម្មយើង។ ធ្វើយើង ធ្វើយ៉ាងម៉េចឲ្យបានរស់មួយគ្រាហ្នឹងទៅចុះ"[2869]។ ដើមបណ្ដឹងរដ្ឋប្បវេណី កុល ណែម បញ្ជាក់ថា "ខ្ញុំមិនមែនគិតតែខ្លួនឯងទេ វាបានគេ ដូចថាគេលួចកេះលួចអី ប៉ុន្តែមិនហ៊ាននិយាយ មិនថាស្រី មិនថាប្រុស។ ប៉ុន្តែគ្រាន់តែគេថា កុំយើងកុំនិយាយ ទុកដើម្បីរស់យើង។ ហ្នឹងហើយ។ យើងតវ៉ាជាមួយគេ យើងដឹងហើយ យើងឃើញហើយ"[2870]។

1203. ដើមបណ្ដឹងរដ្ឋប្បវេណី ង៉ែត ចាត បានផ្ដល់សក្ខីកម្មថា ប្ដីរបស់គាត់មានអាយុច្រើនជាងគាត់ជិតពីរដង[2871] ប៉ុន្តែ "អត់ហ៊ានប្រឆាំងទេ ខ្លាចគេបញ្ជូនទៅលើ។ ព្រោះអីប្ដីគេអូសយកទៅ ទើបប្រទាញ់

[2867] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៥៤ បន្ទាត់ ១-៣។

[2868] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៥៤ បន្ទាត់ ៥-៦។

[2869] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៨៥ បន្ទាត់ ២៤-ទំព័រ ៨៦ បន្ទាត់ ២។ដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ជាក់ថា "ខ្ញុំសន្និដ្ឋានថាគេហ៊ានការទៅចុះ ព្រោះគេខ្លាចដូចគ្នា។ ខ្ញុំអះអាង បើចឹងគេម៉េចហ៊ានការ ព្រោះគិត សុទ្ធតែគេអ្នកបង្ខំទាំងអស់"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៨៦ បន្ទាត់ ៧-៩។

[2870] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៨៦ បន្ទាត់ ១៣-១៧។

[2871] "គេថាឲ្យចាប់អារម្មណ៍ ចាប់ជាគូ។ ខ្ញុំងាកមើលទៅ អីក៏ចាស់ម្ល៉េះ អាយុតើប ២០ជាង គាត់៤០ជាងហើយ បងខ្ញុំឡើង ១៨ឆ្នាំ។ ខ្ញុំថាប្រកែកក៏មិនដឹងប្រកែកម៉េច និយាយទៅខ្លាចគេបញ្ជូនទៅលើ។ គេថាបើមិត្តតថ្លៃគេបញ្ជូនទៅលើ។ ខ្ញុំអត់ដឹងឮគេថាទៅចឹង។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៨៥ បន្ទាត់ ២៣- ទំព័រ ៨៦ បន្ទាត់ ១។

ប្រទង់គ្នា យកទៅវ៉ៃចោលមិនទាន់បាត់យំស្រួលបួលផង គេចាប់យកទៅរៀន អត់ហ៊ាននិយាយ ខ្ញុំខ្លាចងាប់។ គេថាបញ្ជូនទៅលើ ខ្ញុំខ្លាចងាប់ចោលកូនខ្ញុំ"[2872] "ខ្ញុំខ្លាចបណ្ដោយ។ ព្រោះអីថាទៅលើហ្នឹងមានទៅណា មានទៅងាប់ទៀតហ្នឹងឯង"[2873]។

1204. ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន បានពន្យល់ថា ពេលដែលគាត់ប្រកែកជាលើកទីពីរ មិនព្រមរៀបការនោះ "ខ្ញុំប្រកែកដែរ តែដល់ពេលថ្នាក់លើគេថា "កង់ប្រវត្តិសាស្ត្រកំពុងតែវិល អ្នកណាលូកដៃដាច់ដៃ អ្នកណាលូកជើងដាច់ជើង។ អង្គការជាភ្នែកម្នាស់ អ្នកឯងធ្វើអីក៏មិនផិតដែរ"[2874]។

1205. ដើមបណ្ដឹងរដ្ឋប្បវេណី ចៅ ឡាង បានផ្ដល់សក្ខីកម្មថា គាត់ត្រូវបានប្រធានកង និងប្រធានក្រុមព្រមាន មិនឱ្យប្រកែកមិនព្រមរៀបការ[2875]៖ "នៅពេលដែលស្នាដៃចប់នេះហើយ ដែលគេហៅទៅរៀបការនោះដោយបង្ខំ ដោយនាងខ្ញុំពុំបានពេញចិត្ត ឬក៏បានថា មានការទំនាក់ទំនងនោះទេ។ គេថាកំពុងតែនេះហ្នឹង គេថា "នែ!មិត្តនារី! មិត្តឯងរៀបចំខ្លួនប្រាណទៅ!" ហ្នឹងមកពីរែកដីវិញ គេកោះមកថា "មិត្តនារីទៅៗកន្លែងមួយភ្លែតទៅ" ខ្ញុំថា "ទៅមានការអីមិត្ត?" "ថ្ងៃហ្នឹងគេរៀបចំគ្រួសារឱ្យមិត្តឯងហើយ"។ ខ្ញុំថា "អ្ហឺ! រៀបចំគ្រួសារម៉េចទៅ បើខោអាវអត់មានផងហ្នឹង?" "មិន

---

[2872] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៩៥ បន្ទាត់ ២៤-២៥។

[2873] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៩៥ បន្ទាត់ ២៤-ទំព័រ ៩៦ បន្ទាត់ ១។

[2874] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៣៦ បន្ទាត់ ១៤-១៦។ "នាងខ្ញុំបានប្រកែកជាលើកទី ២" ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿនបានពន្យល់ "តែប្រធានកងគាត់ប្រាប់ថា កុំឱ្យនិយាយអ្វីក៏ដោយ ក៏កុំឱ្យនិយាយាដែ។ នាងខ្ញុំប្រកែកថា ហេតុអ្វីក៏បានជាយកមករៀបការចឹងអត់មានបានដឹងមុនចឹង អត់មានស្គាល់គ្នា។ ទៅប្រធានកងធ្លាប់ក្ដោបក្ដាប់នាងខ្ញុំគ្រប់ការដ្ឋាននិយាយថា អង្គការឱ្យធ្វើអីធ្វើទៅមិនឯងកុំប្រកែក។ ដល់ត្រង់ហ្នឹងហើយ ខ្ញុំអាចយល់ត្រង់ថា ខ្ញុំប្រកែកលើកទី១ គឺខ្ញុំប្រកែកដោយមិនដឹងខ្លួន។ ដល់លើកទី២នេះក៏បានប្រកែកហ្នឹងចឹងទៀត តែដល់គេនិយាយាប្រាប់ចឹងខ្ញុំនឹកឃើញថា បើសិនជាខ្ញុំនៅរឹងរូសស្រែកដូចជាលើកទី១ គឺខ្ញុំមានផលវិបាក"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៤១ បន្ទាត់ ២១-ទំព័រ ៤២ បន្ទាត់ ២។

[2875] អ្នកដែលប្រមានគាត់កុំឱ្យប្រកែកការរៀបការរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ចៅ ឡាង បញ្ជាក់ថា "គឺមេកង មេក្រុម"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ចៅ ឡាង ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ៥៩ បន្ទាត់ ១០។

អីទេ ចាំអង្គការយើងឲ្យមួយកំប្លេ ស្លៀកពេលរៀបចំហ្នឹង ប៉ុន្តែមិនឯងកុំប្រកែក! មិត្តឯងប្រកែកចប់ហើយមិត្តអើយ អត់បានទេ""[2876]។

1206. ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន បានផ្តល់សក្ខីកម្មថា គាត់ត្រូវគេគំរាមកំហែង នៅពេលគាត់ព្យាយាមប្រកែកមិនព្រមរៀបការ៖ "ពេលគេបង្ខំខ្ញុំឲ្យរៀបការ ខ្ញុំប្រកែកគេ។ គេប្រាប់ខ្ញុំថា "បើអ្នកឯងមិនរៀបការទេ អ្នកឯងទៅញញឹមដាក់បុរសណាក៏អត់បានដែរ។ បើញញឹមដាក់បុរសណាគេឃើញ នោះអ្នកនឹងត្រូវប្រយ័ត្នងាប់" គេថាអ៊ីចឹង"[2877]។

## *ការធ្វើអត្តឃាតដើម្បីគេចពីការរៀបអាពាហ៍ពិពាហ៍*

1207. ដើមបណ្តឹងរដ្ឋប្បវេណី សា ឡៃហ៊ាង បានផ្តល់ភ័ស្តុតាងចចាមអារាម[2878] អំពីអ្នកដែលធ្វើអត្តឃាតដោយសារតែប្រឈមមុខជាមួយការរៀបការ៖ "ចំពោះអ្នកដែលមិនធ្វើតាម ប្រកែក រឹងទទឹង គឺគេហៅមកព្រមាន ប៉ុន្តែនាងខ្ញុំមិនបានឮថា គេព្រមានរបៀបម៉េចទេចាស។ ប៉ុន្តែដឹងថាគេហៅទៅព្រមាន។ ក្រោយពេលដែលចេញមកវិញ ជួនកាលមានអ្នកខ្លះគឺលេបថ្នាំសម្លាប់ខ្លួន ឬក៏ទៅលោតទឹកសម្លាប់ខ្លួនក៏មានដែរ"[2879]។ ចំពោះអ្នកដែលធ្វើអត្តឃាត "មូលហេតុគឺមកពីការបង្ខំ នៃការរៀបការដោយខ្លួនមិនបានស្ម័គ្រចិត្ត។ ដល់អ៊ីចឹង ត្រូវការព្រមានថែមទៀត ដល់ភ័យខ្លាច គាត់សម្រេចចិត្តទៅអ៊ីចឹងទៅ"[2880]។

---

[2876] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឡាង ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ៥៤ បន្ទាត់ ២៥- ទំព័រ ៥៥ បន្ទាត់ ៦។

[2877] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៥១ បន្ទាត់ ១១-១៣។

[2878] "នាងខ្ញុំមិនបានឃើញនឹងភ្នែកទេ" ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង បានកត់សម្គាល់ថា "តែមានបណ្តាមិត្តដទៃទៀតដែលគេបានឮតៗគ្នាប្រាប់ថា មិត្តនេះស្លាប់ហើយដោយសារមូលហេតុនេះ នោះ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ១៦ បន្ទាត់ ៣-៤។

[2879] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ១៥ បន្ទាត់ ១៨-២០។

[2880] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ១៥ បន្ទាត់ ២៤-២៥។

1208. ដើមបណ្ដឹងរដ្ឋប្បវេណី សា ឡៃហ៊ាង ក៏បានផ្ដល់សក្ខីកម្មអំពីអ្នកដែលធ្វើអត្តឃាត បន្ទាប់ពីបានរៀបការហើយ៖ "អ្នកខ្លះរៀបការហើយ នៅមិនចុះសម្រុងគ្នា ចឹងទៅពេលខ្លះពួកគេសម្លាប់ខ្លួនដើម្បីឱ្យរួចផុតពីបញ្ហា"[2881]។

1209. ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធារី បានផ្ដល់ភ័ស្ដុតាងចចាមអារាម អំពីមនុស្សភេទទីបីផ្សេងទៀតដែលសម្លាប់ខ្លួនបន្ទាប់ពីគេបញ្ជាឱ្យរៀបការ៖ "ខ្ញុំអត់អាចចាំទេ ព្រោះវានៅកងខុសគ្នា ហើយឃុំខុសគ្នាទៀត។ គ្រាន់តែដឹងថា អ្នកនេះប្រភេទដូចខ្ញុំ អ្នកនោះប្រភេទដូចខ្ញុំ"[2882]។ ដើម្បីពន្យល់ថាតើគាត់ដឹងព័ត៌មាន អំពីការសម្លាប់ខ្លួននេះដោយរបៀបណានោះ ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធារី បានផ្ដល់សក្ខីកម្មថា "វា"ព្រោះខ្ញុំបានជម្រាបហើយថា ធ្វើការជិតគ្នា រឿងអីដែលធ្វើការជិតគ្នាតែងតែដឹងបន្តិចបន្តួច"[2883]។ "គេនិយាយប្រាប់តៗគ្នា។ គេនិយាយប្រាប់គ្នា។ ខ្ញុំដឹងពីអ្នកទាំងនោះ"[2884]។

## ១.៣. ការដាក់ទណ្ឌកម្មចំពោះការប្រកែកមិនព្រមរៀបអាពាហ៍ពិពាហ៍

### *ការចាប់រំលោភផ្លូវភេទ ទៅលើដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន*

1210. ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន បានផ្ដល់សក្ខីកម្មថា "នៅតែពីរថ្ងៃទៀតទេ នឹងរៀបការ ប៉ុន្តែនៅពេលយប់ម៉ោងប្រាំពីរហ្នឹង មានពួកមិត្ត គេមកហៅខ្ញុំទៅកន្លែងឃ្លាំងអង្ករហ្នឹង ប្រាំនាក់ហើយខ្ញុំអត់ស្គាល់មុខគេ វាងងឹត ម៉ោងប្រហែលប្រាំពីរហើយ ធ្វើម៉េចមើល មានភ្លើងឯណានឹងមើលឃើញគេ។ គេហៅទៅ ទៅដល់គេប្រាប់ខ្ញុំថា មិត្តឯងនៅតែពីរថ្ងៃទៀតទេរៀបការហើយ។ ឥឡូវឡើងមកចេះមក ខ្ញុំថាឡើងទៅអី។ ខ្ញុំអត់មានឡើងទេ ខ្ញុំវិលទៅវិញ។ ដល់មួយនៅនឹងដីនោះ គេ

[2881] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ៣៣ បន្ទាត់ ១៦-១៩។

[2882] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/463.1** ទំព័រ ២២ បន្ទាត់ ១៤-១៥។

[2883] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/463.1** ទំព័រ ២២ បន្ទាត់ ២៤-២៥។

[2884] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/463.1** ទំព័រ ២៣ បន្ទាត់ ៥-៨។

ឆក់ដៃខ្ញុំឡើងទៅហើយ គេមានវិធានការនឹងធ្វើបាបខ្ញុំ មុនពេលដែលខ្ញុំរៀបការហ្នឹង។ គ្នាគេប្រាំនាក់ហ្នឹង គេនឹងចាប់រំលោភខ្ញុំ។ ម្នាក់ម្ដង ម្នាក់ម្ដងហើយ"[2885]។

1211. ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា "ក្នុងដែលគេមករំលោភខ្ញុំហ្នឹង ដល់គេរំលោភហើយ ខ្ញុំត្រូវរៀបការ។ ដល់រៀបការហើយអ្នកដែលរំលោភខ្ញុំហ្នឹង គេនិយាយថា គិតទៅមនុស្សយកប្រពន្ធតែដដែលគេ។ ខ្ញុំឮខ្ញុំខឹង ខ្ញុំឈឺចាប់ ខ្ញុំសឹងតែនឹងសម្លាប់ខ្លួន ដែលវារំលោភហើយ វានិយាយថាអ៊ីចឹង ខ្ញុំសឹងតែនឹងសម្លាប់ខ្លួន។ ប៉ុន្តែខ្ញុំអាណិតកូនខ្ញុំ ខ្ញុំមិនអាចសម្លាប់ខ្លួនបាន"[2886]។

1212. ទោះបីជាមានរឿងបែបនេះកើតឡើងក៏ដោយ "ខ្ញុំនៅតែរៀបការ ព្រោះគេគំរាមខ្ញុំថា ត្រូវតែរៀបការ ហើយរឿងរ៉ាវដែលកើតឡើងនោះ គេថាបើសិនជាខ្ញុំនិយាយក៏ស្លាប់។ ខ្ញុំមិនរៀបការក៏ស្លាប់ ខ្ញុំខ្លាចស្លាប់ ដើម្បីកូនខ្ញុំ ខ្ញុំសុខចិត្តរៀបការទាំងទឹកភ្នែកហ្នឹងតែម្ដង"[2887]។

### *ការរំលោភ និងសម្លាប់ ហេង វន្នី ដែលជាបងប្អូនជីដូនមួយរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន*

1213. មុនពេលដែលគាត់ត្រូវរៀបការនោះ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន បានពន្យល់ថា "មានប្អូនស្រីជីដូនមួយឈ្មោះ ហេង វន្នី ហៅ រឿន ហ្នឹង វាគេឲ្យវារៀបបង្ខិតបង្ខំឲ្យមានគ្រួសារ ប៉ុន្តែវាប្រកែកអត់យក មួយលើកជាពីរលើក ដល់ទៅគេយកវាទៅវៃចោលទៅ"[2888]។ "មុនពីយើងខ្ញុំរៀបអាពាហ៍ពិពាហ៍ហ្នឹង វាតែងនិយាយប្រាប់ថា ម្ដាយវាហ្នឹងគេយកទៅសម្លាប់។ ដល់ពេលខ្ញុំទៅ ដល់ពេលវា

[2885] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៣៧ បន្ទាត់ ២០- ទំព័រ ៣៨ បន្ទាត់ ២។

[2886] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៦៤ បន្ទាត់ ៥-៩។ ចំពោះជនល្មើសវិញ ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន បានលើកឡើងថា "គាត់អត់ដឹងថា មុខគេជាអ្នកណាទេ ព្រោះងងឹតមើលអត់ឃើញ ប៉ុន្តែមនុស្សនោះតាមស្មានដែលមកនៅជិតខ្លួនខ្ញុំ ខ្ញុំស្មានថាមនុស្សត្រឹម ២៦ ២៧ ប៉ុណ្ណោះ ទាំងអស់គ្នា។ ដោយមុខគេខ្ញុំអត់មើលឃើញទេ ព្រោះយប់នោះ កន្លែងឃ្លាំងអង្ករនោះ ជញ្ជាំងគេជិត ធ្វើម៉េចស្គាល់មុខគេ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៣៨ បន្ទាត់ ១២-១៤។

[2887] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៣៨ បន្ទាត់ ១៨-២០។

[2888] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៦ បន្ទាត់ ១៧-១៨។

មានខ្សែរយៈដែរ គេថាវាក្បត់។ រួចទៅគេឱ្យវាហ្នឹងរៀបគ្រួសារទៅ ប៉ុន្តែវា១ ថាថាវាអត់រៀបទេ ប៉ុន្តែវារៀបមុនខ្ញុំ ចាស។ ហើយគេយកវាទៅហ្នឹង រយៈប្រហែលជាពីរបីថ្ងៃហ្នឹង បានដឹងថា វាយកទៅសម្លាប់ ហើយគេចាប់គ្នារំលោភសិន ពីរបីនាក់ហ្នឹង"[2889]។

1214. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន បានពន្យល់អំពីការដែលគាត់ដឹងថា បងជីដូនមួយរបស់គាត់ឈ្មោះ ហេង វន្នី ត្រូវបានគេយកទៅសម្លាប់៖ "ពេលយកទៅហ្នឹង ខ្ញុំដឹងថាគេ ឮគេប្រាប់ថាមនុស្សហ្នឹង បាត់ខ្លួនទៅបាត់ហើយ ប៉ុនដល់ពេលគេប្រជុំនេះ ខ្ញុំឃើញសមមិត្តម្នាក់ពាក់អាវ អាវហ្នឹងពីជំនាន់ប៉ុលពតហ្នឹង សូមជម្រាបថា មនុស្សរាប់រយរាប់ពាន់នាក់ ទាល់តែសរសេរជាអក្សរលាយលក្ខណ៍អក្សរ ដាក់នៅក្នុងហោប៉ៅអាវអីចឹងទៅ បានស្គាល់លេខស្គាល់ឈ្មោះហ្នឹង។ អីចឹងពេលបាត់ខ្លួនវា ឃើញដល់ពេលគេប្រជុំទៅ ឃើញគេពាក់អាវហ្នឹង។ ចាស ខ្ញុំស្គាល់តែប៉ុណ្ណឹង។ ខ្ញុំដឹងថា អូ! ប្អូនខ្ញុំស្លាប់ហើយ"[2890]។ គឺនៅ "ចុងឆ្នាំ៧៧ ដើម៧៨ ដែលពេលគេយកវាទៅហ្នឹង គេឈ្មោះផាន់ ហ្នឹង ព្រោះខ្ញុំឧស្សាហ៍ថ្ងៃណាមួយនុំង ខ្ញុំទៅតាមរយៈផ្លូវហ្នឹង រួចគេថា អ្ហ៎! មិត្តប្អូនហ្នឹងគេយកទៅបាត់ហើយ។ រួចខ្ញុំសួរថាមានរឿងអី? ហើយគេថា គេយកទៅហ្នឹងប៉ុន្មានថ្ងៃទៅហើយ មុននឹងយកទៅហ្នឹងគេធ្វើបាបទៀត រួចបានគេសម្លាប់ចោល។ រួចសួរថាពីអ្នកណាអ្នកយកទៅ? សួរថា ឡានតាផាន់ហ្នឹងគេយកទៅ។ ឡានសមមិត្តផាន់ហ្នឹងចាស។ ឈ្មោះហ្នឹងស្លាប់ពិតប្រាកដ ហើយ គេធ្វើបាបពិតប្រាកដ ចាស។ ព្រោះអ្នកនិយាយហ្នឹងក៏ច្បាស់ ហើយខ្ញុំក៏នៅជាយៗហ្នឹង អាចដឹងហើយ ព្រោះដើរឆ្លងកាត់ទៅតាមហ្នឹង។ ឆ្លងកាត់តាមហ្នឹងទៅយកម្ហូបយកអីហ្នឹង ពេលដល់ម៉ោង ដល់វេនគេ យើងដាក់វេនគ្នាទៅយកម្ហូបកន្លែង១ នុំងមក គេនិយាយទៅ ប៉ុនលបខ្សឹបខ្សៀវគ្នាទៅ ចាស។ ហ្នឹងដឹងតាមដំណើរអីចឹង ប៉ុន្តែប្អូនខ្ញុំស្លាប់ពិតប្រាកដ ទាល់តែសព្វថ្ងៃនេះគឺគ្មានឃើញទេ”[2891]។

### *ការសម្លាប់បុគ្គលដែលជាប់ទាក់ទង ជាមួយការប្រកែកមិនព្រមរៀបអាពាហ៍ពិពាហ៍*

---

[2889] សត្ថិកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ១៦ បន្ទាត់ ១៧-២០។

[2890] សត្ថិកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៥១ បន្ទាត់ ១-៥។

[2891] សត្ថិកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៥១ បន្ទាត់ ២៣-ទំព័រ ៥២ បន្ទាត់ ៦។

1215. ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន បានផ្ដល់សក្ខីកម្មថា "មួយឈ្មោះមិត្តចុល មួយឈ្មោះមិត្តអ៊ិន គាត់អត់ព្រមរៀបការទេ គាត់សុខចិត្តស្លាប់។ ដល់ពួកខ្ញុំ៦០គូនោះ ឃើញគំរូហ្នឹងហើយ ការទៅទាំងអស់គ្នា ប្រយ័ត្នងាប់។ បើយើងមិនការទេ ដឹងតែងាប់ហើយគ្មានរស់ទេ។ វាឃើញគំរូស្រេចទៅហើយ មានតែប៉ុណ្ណឹងទេ ពីរឈ្មោះពីរនាក់ហ្នឹងឯង ដែលរឹងទទឹងមិនព្រមរៀបការទេ"[2892]។

*ការបាត់ខ្លួនបុគ្គលដែលជាប់ទាក់ទង ជាមួយការប្រកែកមិនព្រមរៀបអាពាហ៍ពិពាហ៍*

1216. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន បានផ្ដល់សក្ខីកម្មថា ទោះបីថាដំបូងគាត់បដិសេធ មិនព្រមរៀបការក៏ដោយ តែគាត់ឈប់តវ៉ាទៀត៖ "នាងខ្ញុំបានប្រកែក នាងខ្ញុំមិនព្រមថាអត់យកទេ ប៉ុន្តែមានសមមិត្តឃោធាហ្នឹងឈ្មោះ មិត្ត ផាន់ ហ្នឹង គេថាត្រូវតែយកត្រូវតែរៀប។ ហើយយើងខ្ញុំអត់ហ៊ាននិយាយទេ ព្រោះកន្លងមកខ្ញុំមានការខ្លាច ព្រោះនៅនុ៎ងតែប្រកែក អត់បានដឹងតែបាត់ខ្លួន"[2893]។ "ភាគច្រើនគេប្រាប់ថា ទៅបាត់ខ្លួនហ្នឹងគេហៅទៅ ជូនកាលគេហៅទៅបែកចានអីចឹងទៅ គេហៅទៅ៤១អីចឹងទៅ ទៅបាត់រហូតដល់សព្វថ្ងៃទៅ"[2894]។

## ២. ដំណើរការចាប់គូ

### ២.១. គ្មានសិទ្ធិក្នុងការជ្រើសរើសដៃគូរបស់ខ្លួនឡើយ

1217. ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានផ្ដល់សក្ខីកម្មថានៅក្នុងរបបនោះ "កន្លងមកមានៗដូចជាថា កំណាន់ចិត្តអីចឹងទៅ ធ្វើការទៅស្គាល់គ្នាអីចឹង សុំរៀបការជាមួយ ប៉ុន្តែអង្គការគេបដិសេធមិនឲ្យយើងរៀបការជាមួយគូកំណាន់ចិត្តទេ ព្រោះត្បិតអីគេមិនឲ្យយើងជ្រើសរើសខ្លួនឯង ស្ម័គ្រចិត្តដោយខ្លួនឯងនោះទេ។ អង្គការថាឲ្យយើងតែគោរពវិន័យទេ មិនឲ្យយើងជ្រើសរើសសិទ្ធិខ្លួនឯង

---

[2892] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៨១ បន្ទាត់ ២-៥។

[2893] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/461.1** ទំព័រ ៧៤ បន្ទាត់ ១-៣។

[2894] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/461.1** ទំព័រ ៧៤ បន្ទាត់ ៦-៧។

ទេ។ ដល់អ៊ីចឹងដូចថាមានយកទៅរៀបការឲ្យហ្នឹងទៅ បង្ខំខាងបុរសហ្នឹងឲ្យរៀបការ ជាមួយស្រ្តី ស្រ្តីដែលគាត់មិនពេញចិត្តអ៊ីចឹង មានបញ្ហាដែរចាស"[2895]។

1218. ដើមបណ្តឹងរដ្ឋប្បវេណី យស ផល មានគូដណ្តឹងនៅមុនរបបកម្ពុជាប្រជាធិបតេយ្យ។ បន្ទាប់ពីឮថាបងប្រុសគូដណ្តឹងគាត់ ត្រូវបានអង្គការកម្ទេចនោះ ប្រធានកងរបស់គាត់ឈ្មោះ រី បានពន្យល់ប្រាប់គាត់ថាៈ "បើមានអង្គការកម្ទេចអ៊ីចឹង មិត្តឯងមិនអាចរៀបការជាមួយនារីហ្នឹងបានទេ ព្រោះថ្ងៃក្រោយទៅមិត្តឯង នឹងស្លាប់តាមបងប្អូនរបស់នារីហ្នឹងហើយ ព្រោះនារីហ្នឹងស្ថិតនៅក្នុងការតាមដានរបស់អង្គការ។ អ៊ីចឹងបើកាលនាសម្លាប់នារីហ្នឹង ក៏សម្លាប់មិត្តឯងដែរ។ អ៊ីចឹងមិត្តឯងត្រូវដូរចិត្ត ធ្វើម៉េច ឥឡូវខ្ញុំឲ្យមិត្តឯងធ្វើជាកូនអង្គការ។ មិត្តឯងយល់យ៉ាងម៉េច ពិចារណាមើល ចង់ងាប់ហើយចង់រស់? បើយកនារីហ្នឹងមានតែងាប់ហើយ គឺការកម្ទេចដកស្មៅទាំងឫស"[2896]។ "ខ្ញុំហ្នឹងសុខចិត្តហើយ បើខ្ញុំមិនសុខចិត្តធ្វើតាមទេ... ខ្ញុំមិនដឹងត្រូវប្រហែលជាទៅមន្ទីរឧក្រិដ្ឋកម្មណាមួយបាត់ហើយ។ បើខ្ញុំឆ្លើយអ៊ីចឹងទៅ គឺខ្ញុំបានរួចខ្លួន"[2897]។

## ២.២. ដំណើរការផ្សំផ្គុំដែលត្រួតត្រាដោយអង្គការ

### *បញ្ជាមកពីថ្នាក់លើ*

1219. ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន ដែលធ្វើការជាប្រធានមន្ទីរស្រុក នៅស្រុកស្អាង បានពន្យល់ថា "សិទ្ធិប្រគល់ឲ្យតាមឃុំមួយៗអស់ហើយ។ អ៊ីចឹងឃុំមួយៗត្រូវជ្រើសរើស និងរៀបការឲ្យយុវជន យុវនារីរបស់ឃុំ តាមឃុំរៀងខ្លួន។ បើឯនៅស្រុកជុំវិញរបស់សាលាស្រុកហ្នឹង គឺពិសេស

[2895] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៩ បន្ទាត់ ១១-១៥។

[2896] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ១៣ បន្ទាត់ ១៤-១៩។

[2897] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ១៣ បន្ទាត់ ២៥ ទំព័រ ១៤ បន្ទាត់ ៤។

មានច្រើនណាស់ មានកងចល័ត ដល់អ៊ីចឹងវាមានខាងប្រុស និងខាងស្រី បានកើតមានជារៀបការ ឲ្យកងចល័តប្រុសស្រីហ្នឹង មកនៅមន្ទីរស្រុកស្អាង អាហ្នឹងដែលបានខ្ញុំចូលរួមបានពីរដងដែរ"[2898]។

1220. នៅក្នុងតួនាទីរបស់គាត់ជាប្រធានមន្ទីរស្រុក ដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន "ខ្ញុំបានទទួលបញ្ជារបស់គណៈស្រុក គឺបង សៅ ផុន គាត់ជាគណៈស្រុក គាត់ចាត់តាំងឲ្យខ្ញុំយកប្រវត្តិរូប របស់យុវជន និងរបស់នារីរបស់កងចល័តស្រុក ដើម្បីរៀបការ។"[2899]។ គាត់ពន្យល់ថា "ខ្ញុំធ្វើបានពីរសារ ប៉ុន្តែមិនដឹងចាំណា ពេលណា ហើយភ្លេចចំនួនទៀត ប៉ុន្តែដឹងថា ក្នុងមួយរៀបការមួយសារអ៊ីចឹង ប្រហែលជា២០ទៅ៣០គូ។ ពេលនោះខ្ញុំបានជាដឹង បង ផុន គាត់ធ្វើគណៈស្រុក គាត់ណែនាំឲ្យខ្ញុំថា ឲ្យមេកងចល័តទាំងប្រុសទាំងស្រីហ្នឹង យកប្រវត្តិរូបមក ហើយអ្វែងចាំធ្វើអ៊ីចេះ ផ្គុំស្រីនិងប្រុសនៅភូមិ នៅក្នុងឃុំជាមួយគ្នា"[2900]។ "ផុនចាត់តាំងខ្ញុំឲ្យផ្គុំពួកគេទាំងនោះ ផ្អែកលើកន្លែងរស់នៅ និងអាយុរបស់ពួកគេ ហើយប្រុសៗត្រូវមានអាយុច្រើនជាស្រីៗ បីទៅប្រាំឆ្នាំ ហើយខ្ញុំធ្វើតែប៉ុណ្ណឹង"[2901]។

1221. ចំពោះរបាយការណ៍ដែលបង្ហាញពីតួលេខកំណើត និងតួលេខរៀបការ ដែលធ្វើឡើងនៅក្នុងភូមិភាគ ឬតំបន់ណាមួយ នៅក្នុងរយៈពេលមួយខែ ដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន បានពន្យល់ថា "ឃុំរាយការណ៍ទៅស្រុក ហើយខ្ញុំបានទទួលរបាយការណ៍នោះ តែខ្ញុំមិនចាំតួលេខជាក់លាក់ក្នុងរបាយការណ៍នោះទេ"[2902]។

---

[2898] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៣៧ បន្ទាត់ ១២-១៦។

[2899] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/465.1** ទំព័រ ១៦ បន្ទាត់ ៨-១១។

[2900] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/465.1** ទំព័រ ១៦ បន្ទាត់ ១០-១៥។ ដើមបណ្ដឹងរដ្ឋប្បវេណីបាននិយាយម្ដងទៀតថា "រៀបចំឲ្យពីរសារ" ហើយថាក្រោយមក "ត្រូវផ្លាស់ទៅ ក្រចេះ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/465.1** ទំព័រ ១៦ បន្ទាត់ ១៤-១៥។

[2901] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៣៨ បន្ទាត់ ៣-៥។

[2902] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/465.1** ទំព័រ ៣៩ បន្ទាត់ ៨-៩។

1222. ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន បានពន្យល់ថាឈ្មោះរ៉ុម ហៅថន ដែលនៅជាមួយខាងស្រុក ដែលទទួលខុសត្រូវលើការជ្រើសរើស អ្នកដែលសមស្របអាចរៀបការបាន ហើយស៊ា ទទួលខុសត្រូវលើការចាប់គូ។ ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មថា ទាំងរ៉ុម និងស៊ា បានចេញបញ្ជាទៅពួកកងឈ្លប៖ "មិត្តរ៉ុម អ្នកជ្រើសរើស មិត្តស៊ាគេជាអ្នកចាប់ដាក់រៀបការ"[2903]។ គាត់គឺ "កម្មាភិបាលនៅក្ដាប់ នៅកន្លែងការដ្ឋានហ្នឹង"[2904] ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មថា គាត់និយាយ "ថាពីថ្នាក់លើមក គេឲ្យត្រូវតែឲ្យមិត្តឯងទាំងអស់គ្នានេះរៀបការ។ ដល់រួចហើយបានគេប្រាប់មិត្ត ស៊ា ហ្នឹងឲ្យដើរប្រាប់អ្នកដែលមានគូរៀបការទាំងអស់នោះ ឲ្យប្រាប់ទាំងអស់គ្រប់គូហ្នឹងតែម្ដង"[2905]។ ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន បន្ថែមថា រ៉ុម "ជាប់ជាមួយនឹងស្រុក។ ស្រុកបញ្ជាគាត់ឲ្យមកប្រាប់ គាត់ធ្វើ"[2906]។ ចំពោះរ៉ុមវិញ ដើមបណ្ដឹងរដ្ឋប្បវេណីមុំ វុន បានបញ្ជាក់ថា៖

---

[2903] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៦០ បន្ទាត់ ១៧-១៨។ នៅពេលចាំពីថ្ងៃរៀបការរបស់គាត់ ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន បានផ្ដល់សក្ខីកម្មថា "នៅកន្លែងរៀបការហ្នឹង ដោយពួកក្រុមស្រី មិត្តនារីហ្នឹងឈរដោយឡែក។ ដល់គេហៅឈ្មោះឡើងគូណាត្រូវនឹងគូណា គេឲ្យយើងអង្គុយតាមជាគូ។ តែក្នុងមួយជួរ ១៥គូ បួនជួរ៦០គូ។ គូដែលស្រឡាញ់គឺគេហៅឈ្មោះ ចាប់ដៃអង្គុយ អត់មានកៅអីអង្គុយចឹងទេ យកស្បែកជើងទ្រាប់អង្គុយ គណៈអធិបតីគេក៏នៅខាងមុខទៅ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៤៣ បន្ទាត់ ១៤-១៨។ "ខ្ញុំគូទី ៦ ដែលគេហៅមកឲ្យអង្គុយនៅគូទី ៦ រៀបចំអង្គុយខ្លួនឯង"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៤៣ បន្ទាត់ ២០។ "ចាស គេប្អូសហៅឈ្មោះតើ។ គេហៅឈ្មោះ អ៊ុន ធិន ជាគូនឹងមិត្តនារី មុំ វុន គេហៅចឹង។ ដល់ហើយមកចាប់ដៃគ្នា ហើយក៏រៀបចំដាក់អង្គុយទៅ យកស្បែកជើងទ្រាប់អង្គុយទៅ។ ជាគូហ្នឹងទៅ ហើយបានគេហៅគូផ្សេង"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៤៣ បន្ទាត់ ២៥-ទំព័រ ៤៤ បន្ទាត់ ២។

[2904] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៦០ បន្ទាត់ ២១។

[2905] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៦០ បន្ទាត់ ២៥-ទំព័រ ៦១ បន្ទាត់ ២។

[2906] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៦១ បន្ទាត់ ៧។

"ចាស មិត្តរ៉ុមហ្នឹងខ្លះណាគេហៅមិត្តរ៉ុម ខ្លះណាគេហៅមិត្ត ថន ឈ្មោះគេមែនទែនឈ្មោះ ថន ដល់ឈ្មោះគេនៅក្នុងបដិវត្តហ្នឹង គេឈ្មោះរ៉ុម"[2907]។

1223. ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឌៀប បានផ្ដល់សក្ខីកម្មថា គាត់មិនអាចពិភាក្សាជាមួយក្រុមគ្រួសារគាត់បានឡើយ ក្រោយពេលដែលគេប្រាប់គាត់ អំពីពិធីរៀបអាពាហ៍ពិពាហ៍របស់គាត់៖ "ក្រោយពីសួរខ្ញុំ មេហ្នឹងសួរខ្ញុំរួចទៅ រយៈកាលនុំង គេប្រាប់ថាបីថ្ងៃទៀត ខ្ញុំត្រូវទៅរៀបការ"[2908] ហើយដើមបណ្ដឹងរដ្ឋប្បវេណីបន្ថែមថា គាត់ "មិនដែលបានពិភាក្សាជាមួយ ម៉ែឪបងប្អូនទេព្រោះនៅឆ្ងាយ។ ទោះបីសុំគេទៅ ក៏គេមិនឲ្យទៅដែរ គឺស្រេចតែអង្គការតែហ្នងហ្នឹង"[2909]។ ដើមបណ្ដឹងរដ្ឋប្បវេណីក៏បានចង្អុលបញ្ជាក់ថា ចំពោះគូស្រករដែលត្រូវរៀបការ នៅថ្ងៃជាមួយគ្នានោះ "នៅពេលខ្ញុំឃើញពួកគេ ហើយបានជជែកគ្នានោះ គេថាគេមិនបានសួរនាំម៉ែឪបងប្អូនអីទេ។ គូទាំង១២គូហ្នឹងមិនដែលទៅជួបម៉ែឪ បងប្អូនសាច់ញាតិ សុំយោបល់អីហ្នឹងនោះទេ"[2910]។

1224. ដើមបណ្ដឹងរដ្ឋប្បវេណី សា ឡៃហ៊ាង បានពន្យល់ថា ពិធីរៀបអាពាហ៍ពិពាហ៍របស់គាត់ ត្រូវបានរៀបចំឡើងដោយគណៈតំបន់៖ "ចាស ពេលនុំងឪពុកម្ដាយនេះ គឺមិនបានសម្រេចចិត្តទេចាស។ តែអ្នកគ្រប់គ្រងគេរៀបចំផ្គូផ្គងឲ្យ"[2911]។ "ចាស ខាងគណៈតំបន់[អ្នករៀបចំការរៀបការ]"[2912]។ ដើមបណ្ដឹងរដ្ឋប្បវេណីបន្តបញ្ជាក់បំភ្លឺថា "ក្នុងគណៈតំបន់ហ្នឹងគេសម្រេចទាំងអស់គ្នា មានឈ្មោះ

---

[2907] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៦២ បន្ទាត់ ១៣-១៤។

[2908] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥៤ បន្ទាត់ ១-២។

[2909] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥៤ បន្ទាត់ ១០-១១។

[2910] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/467.1** ទំព័រ ១៩ បន្ទាត់ ៦-៨។

[2911] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ១០ បន្ទាត់ ៩-១០។

[2912] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ១០ បន្ទាត់ ១៣។

យី"[2913]។ ដើមបណ្ដឹងរដ្ឋប្បវេណីបញ្ជាក់ថា ចំពោះឈ្មោះយីនេះ "គាត់ពីដើមឡើយគាត់ជាអ្នកទទួលតួនាទីជាខាងសេដ្ឋកិច្ច។ ពេលមុននឹងបន្តិចហ្នឹង គឺមានលោក យៃន។ ឈ្មោះយៃនជាប្រធាន។ ដល់ដកលោក យៃន ទៅទូតក្លូវ៉េ លោក យី ឡើងជាប្រធានវិញ ចាស"[2914]។ ដើមបណ្ដឹងរដ្ឋប្បវេណីពន្យល់ថា "នៅពេលដែលខ្ញុំការនោះ យីមានតួនាទីជាប្រធានតំបន់"[2915]។

1225. ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ នៅពេលដែលជជែកជាមួយឈ្មោះ អឿន បានដឹងថា បញ្ជាឱ្យរៀបចំការរៀបការគឺទទួលមកពីថ្នាក់ស្រុក៖ "គាត់ថា "បើអ្ហែងចង់ដឹងណាស់ អ្ហែងទៅសួរមេកងទៅសួរចៅហ្វាយស្រុកទៅ មានឡានមានអីចឹងជិះទៅសួរគេទៅ ព្រោះអញក៏គេចាត់ចែងមកដែរ"[2916]។ ដើមបណ្ដឹងរដ្ឋប្បវេណីបកស្រាយថា "ចាសកាលហ្នឹងគាត់ចៅហ្វាយស្រុក គាត់កាន់ក្ដាប់ច្រើនៗសហករណ៍ចាស។ គាត់ក្ដាប់១០សហករណ៍លើគាត់តែឯង គាត់ចៅហ្វាយស្រុកខ្មែរក្រហមលោកប្រធាន"[2917]។

---

2913 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ១០ បន្ទាត់ ១៦។

2914 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ១០ បន្ទាត់ ២៣-២៥។

2915 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ២៩ បន្ទាត់ ១៥-១៦។

2916 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៥៩ បន្ទាត់ ១២-១៤។

2917 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៥៩ បន្ទាត់ ១៩-២០។ ដើមបណ្ដឹងរដ្ឋប្បវេណីបានពន្យល់ថា "គាត់ចៅហ្វាយស្រុកទៅ ខ្ញុំអត់ដឹងថាគេឃុំណាគេក្ដោបទេ។ ប៉ុន្តែគ្រាន់តែដឹងថាគេហ្នឹងជាចៅហ្វាយស្រុក គឺនីរសារគេមានប្អូន សេះប្អូន។ ហើយគេបានមកកាន់ក្ដាប់នៅក្នុងឃុំសហករណ៍នាងខ្ញុំនៅខ្នារទទឹងហ្នឹង"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៥៩ បន្ទាត់ ២៣-២៥។ ខ្នារទទឹងនោះពេលនោះគឺជា "ស្រុកបាកាន ខេត្តពោធិ៍សាត់"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៤៨ បន្ទាត់ ១៩-២០។

1226. ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា អតីតប្រធានស្រុកបាកាន "គាត់ថាគាត់ទទួលពីតាអ៊ីចេះ តាម៉ុក។ ចង់ដឹងគាស់ខ្មោចទៅសួរ តាម៉ុក"[2918]។ គាត់ក៏ "ឆ្លើយមកកាន់នាងខ្ញុំថា គេឲ្យរៀបការមកពីថ្នាក់លើ ឲ្យទៅសួរតាម៉ុកហ្នឹង។ គាត់ថាគេឲ្យយើងរៀបការនេះ ដើម្បីយកកូនជូនអង្គការ។ ប៉ុន្តែវាអត់មានឃើញកូនជូនអង្គការ មានតែឃើញស្លាប់ អត់បានឃើញទេលោកប្រធាន"[2919]។

1227. ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿនបានផ្តល់សក្ខីកម្មថា "មេកងខ្ញុំឈ្មោះ ម៉េត ជាអ្នករៀបការឲ្យខ្ញុំ"[2920]។ "គាត់ជាអ្នកចាប់គូខ្ញុំនិងប្តីខ្ញុំ"[2921]។

1228. ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម បានផ្តល់សក្ខីកម្មថា ប្រធានឃោធាខេត្តបានរៀបចំ ពិធីរៀបការរបស់គាត់ ហើយថាគាត់ឈ្មោះ "សភាជនជាតិចារាយ។ បាទ សភា ហើយនិងចាំ ឈ្មោះគេហ្នឹង ប៉ុន្តែចាំ មិនដឹងជនជាតិអី ជនជាតិដែរ។ ខ្ញុំចាំតែសភាហ្នឹង គេប្រធានឃោធាខេត្តតែម្តងបាទ"[2922]។

***ការប្រើប្រាស់ប្រវត្តិរូប ក្នុងការជ្រើសរើសគូស្រករ***

---

[2918] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី បែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៦០ បន្ទាត់ ១៩-២០។ ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ បានបកស្រាយថាពេលដែលគេទៅជួបគាត់ គាត់ "ថាបើចង់ដឹងច្បាស់លាស់ ចំពោះរៀបការ និងការចាប់បង្ខំ ក្រោមខ្មែរក្រហមហ្នឹង គាត់មិនបានចាត់ចែងទៅណាទេ ព្រោះមានគេចាត់ចែងមកឲ្យគាត់។ គាត់ចាត់ចែងទៅនុងវិញ។ ហើយក៏ខ្ញុំបានបញ្ជាក់គាត់ថា មកសួរបងដោយត្រឹមត្រូវព្រោះខ្ញុំជនរងគ្រោះ។ គាត់ថាបើចង់ដឹងច្បាស់ ទៅសួរខ្មោច តាម៉ុក រឿងនៅរស់ មិនរស់គាត់អត់ដឹងទេ។ ចំពោះការរៀបការហ្នឹងគេធ្វើចឹង"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី បែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៦១ បន្ទាត់ ៤-៨។

[2919] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី បែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៦១ បន្ទាត់ ១៤-១៦។

[2920] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៥៣ បន្ទាត់ ២៤។

[2921] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៥៤ បន្ទាត់ ២។

[2922] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៧៦ បន្ទាត់ ១៤-១៦។ ចម្លើយសារភាពរបស់ ហួត កែ ហៅ សូភា ពីមន្ទីរសន្តិសុខ ស-២១ អាចរកបាននៅឯកសារ **E3/2593**។

1229. ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន បានពន្យល់ថា "គេយកប្រវត្តិរូបខាងនារី ខាងបុរសនៅកងចល័តហ្នឹង គេជូនទៅគណៈស្រុក បានគណៈស្រុកគាត់ប្រើគេ ឲ្យយកមកឲ្យខ្ញុំ"[2923] "អត់ទេ អត់បានជួប បាននិយាយទេ [ជាមួយប្រធានកងចល័តខាងបុរស ខាងនារី]។ ខ្ញុំសរសេរផ្ទផ្គងតែម្នាក់ខ្ញុំទេ ហើយដល់ពេលគេត្រូវប្រកាសទៅ ខ្ញុំយកបញ្ជីឈ្មោះហ្នឹងទៅឲ្យ បងគណៈស្រុកហ្នឹងទៅ"[2924]។

1230. នៅពេលរៀបរាប់ថាតើគេផ្សំផ្គុំគូស្រករដោយរបៀបណានោះ ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន បានផ្តល់សក្ខីកម្មថា "គ្រាន់តែឲ្យហៅឈ្មោះ "ក" ជាមួយឈ្មោះ "ខ" អ៊ីចឹងទៅ។ ខាង "ក"ហ្នឹងប្រុសអ៊ីចឹងទៅ ឡើងឈរមួយភ្លែតអ៊ីចឹង ហើយខាង "ក" ហ្នឹងស្រីគឺឡើងមួយភ្លែតអ៊ីចឹងទៅ។ មិនចាប់អារម្មណ៍ថាថាំមុខនរណាៗផង អត់ចាំមុខគឺមិនចង់ច្បាស់ទៀត រឿងគូស្រករទាំងសងខាងហ្នឹង។ ហើយគឺគេជ្រើសរើសរកប្រវត្តិរូបដូចគ្នា បានអាចរៀបចំបាន គឺមេកងចល័ត និងមេកងធំហ្នឹង គឺគេយកប្រវត្តិរូបជាមុនស្រេចទៅហើយ"[2925]។ គាត់បានបន្តថា "បើជាខាងយោធារំសាយខាងទ័ពបូព៌ាអ៊ីចឹងទៅ គឺទាល់តែមានខាងស្រីហ្នឹង មានបងប្អូនមានជាប់ទាក់ទាម ជាមួយកងទ័ពហ្នឹងដូចគ្នា បានអាចយកបាន"[2926]។ ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន បន្តពន្យល់ថា "ហើយខ្ញុំហ្នឹងគឺមានឈ្មោះ ប្រវត្តិដូចខ្ញុំបានរាយការណ៍ខាងដើមហ្នឹង គឺខ្ញុំមិនហ៊ាន មិនហ៊ានធ្វើអ្វីឲ្យខុសពីផែនការរបស់គេ គឺខ្លាចគេចោទថាខ្មាំង ថែមកំហុសមួយជាន់ទៀត។ ហ្នឹងវាខ្ញុំចេះតែនៅទ្រាំទ្រតាមផែនការរបស់គេហ្នឹង"[2927]។

---

[2923] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/465.1** ទំព័រ ៥៩ បន្ទាត់ ៧-៨។

[2924] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/465.1** ទំព័រ ៥៩ បន្ទាត់ ១១-១២។

[2925] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ៤៩ បន្ទាត់ ៤-៥។

[2926] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ៤៩ បន្ទាត់ ៥-៧។

[2927] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ៥០ បន្ទាត់ ៣-៤។

1231. ដើមបណ្តឹងរដ្ឋប្បវេណី យស ផល បានពន្យល់អំពីសារៈសំខាន់ នៃការមានប្រវត្តិរូបល្អ នៅពេលដែលគាត់ផ្តល់សក្ខីកម្មថា ទោះបីថាមានគូស្រករខ្លះហាក់ដូចជា ត្រូវបានគេផ្សំផ្គុំជាមួយអ្នកដែលខ្លួនស្រឡាញ់ក្តី គាត់ខ្លួនគាត់ផ្ទាល់មិនបានសុំរៀបការ ជាមួយគូដណ្តឹងរបស់គាត់ទេ ព្រោះគាត់ត្រូវបានគេចាត់ទុកថាជាពួក១៧មេសា៖ "នៅក្នុង៥០គូហ្នឹង ដូចខ្ញុំមិនបានដឹងថាមានបុរសនារីណា គេទាក់ទងគ្នាខ្ញុំអត់ដឹងទេ ខ្ញុំអត់ដឹង។ គ្រាន់តែមានអ្នកខ្លះថាគូដណ្តឹងគេ វាមានប្រវត្តិរូបគេល្អ គេតែខ្ញុំដល់រៀបការហើយបានដឹង កាលពីពេលកំពុងរៀបការ ខ្ញុំអត់បានដឹង ហើយខ្ញុំក៏គ្មានបានដើរទំនាក់ទំនងគេ ព្រោះខ្ញុំអ្នកថ្មីបានដើរទំនាក់ទំនងអីចឹង គេថាគិញហ្នឹងកុនទៀត"[2928]។

## *ប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន មិនអាចផ្សំផ្គុំជាមួយគ្នាបានទេ*

1232. ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន បានបញ្ជាក់ថា "ហ្នឹងគឺពិតជារបស់ផែនការរបស់គណៈស្រុកដែលណែនាំប្រាប់ខ្ញុំថា អាថ្មីដាក់ដោយថ្មី មូលដ្ឋានចាត់តាមមូលដ្ឋាន។ អាហ្នឹងខ្ញុំនៅចាំច្បាស់ដែរ ក៏វាភ្លេចពីមុនទៅ ឥឡូវបាននឹកឃើញ"[2929]។

1233. ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី បានពន្យល់ថា "អ្នក១៧គេរៀប១៧ អ្នក១៨គេរៀប១៨"[2930]។ "ប្រជាជនចាស់គេរៀបប្រជាជនចាស់ ប្រជាជនថ្មីរៀបប្រជាជនថ្មី"[2931]។ ដោយហេតុនេះហើយទើប "ពួកចាស់គេមួយជួរគ្នាទៅ ពីរជួរគ្នាគេទៅ។ ពួកខ្ញុំថ្មី ឈរពីរជួរពួកខ្ញុំថ្មីៗ"[2932]។

---

[2928] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ២១ បន្ទាត់ ២-៦។

[2929] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/465.1** ទំព័រ ១៧ បន្ទាត់ ២២-២៣។

[2930] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/463.1** ទំព័រ ១៥ បន្ទាត់ ១៦-១៧។

[2931] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/463.1** ទំព័រ ១៦ បន្ទាត់ ២៤-២៥។

[2932] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/463.1** ទំព័រ ១៧ បន្ទាត់ ៦។ ដោយដឹងពីការរៀបការ ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី បានរៀបចំគ្រោងទុកជាមួយនឹងនារីម្នាក់ឈ្មោះ អៀម រដ្ឋា "ជានារីកំព្រា អត់មានម៉ែឪទេ គ្មានបងប្អូន។ ចឹងហើយខ្ញុំក៏គ្មានបងប្អូន គ្មានម៉ែឪ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៦៩ បន្ទាត់ ១៦-

1234. ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ បានពន្យល់ថា "ក្នុងចំណោម៦៣គូហ្នឹង មានមូលដ្ឋាន ហើយមានបងប្អូនយើងជម្លៀសពីទីក្រុងភ្នំពេញទៅ" ប៉ុន្តែ "ស្ងួម្បីតែអ្នកមូលដ្ឋានចង់បានអ្នកជម្លៀសអី គេដណ្តឹងខ្លះក៏អត់ឲ្យការដែរ"[2933]។

### *ការរៀបអាពាហ៍ពិពាហ៍ជាមួយកងទ័ពពិការ*

1235. ក្នុងពេលរៀបការដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប យុទ្ធជននារីត្រូវរៀបការជាមួយ យុទ្ធជនបុរសពិការ។ គាត់បានពន្យល់ថា "ក្នុងគ្រួសារទាំង១២គូរៀបហ្នឹង គឺថាផ្នែកនារីក៏សុទ្ធតែនារីកងស្នែង និងយោធាដែរ។ ចំណែកយុទ្ធជនសុទ្ធតែយោធាទាំងអស់។ ប៉ុនពួកយុទ្ធជនទាំងអស់ហ្នឹង សុទ្ធយុទ្ធជនពិការ ព្រោះពិការវ៉ៃខ្លាំងមិនកើត គេយកមកដាក់មួយកន្លែង។ ដាក់កន្លែងដល់ពេលរៀបការហ្នឹង គេយកសុទ្ធជនពិការហ្នឹងមករៀប។ ប៉ុនពិការមិនពិការខ្លាំងទេ ខ្លះក៏កំបុតដៃមួយចំហៀង ខ្លះខ្វះ ខ្លះខ្វាក់ភ្នែកមួយចំហៀង ខ្លះទៀតគ្រាន់តែដូចថា ខូចដៃបន្តិចជើងបន្តិច អីទៅគ្រាន់ថាដើរកើតប៉េលប៉ោលអីបន្តិចៗអ៊ីចឹងៗទៅ"[2934]។ ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប បានពន្យល់ថា គាត់គ្រាន់តែដឹងថានារីៗត្រូវបានគេ រៀបចំឲ្យរៀបការជាមួយបុរសពិការ នៅថ្ងៃគាត់រៀបការតែប៉ុណ្ណោះ[2935] ហើយគាត់កត់សម្គាល់ថា "គ្រួសាររបស់ខ្ញុំផ្ទាល់ គឺពិការជើងដែរ ប៉ុន្តែគ្រាន់តែជើងហ្នឹង ដើរប៉ែលៗមិនកំបុងមិនអីទេ គ្រាន់ដើរទៅប៉ែលៗមួយចំហៀង"[2936]។

---

១៧។ ដើមបណ្តឹងរដ្ឋប្បវេណី បានពន្យល់ថា "ខ្ញុំបានស្គាល់គ្នាយូរហើយ តែមិនដែលនិយាយរឿងអីជាមួយទេ គ្រាន់បានម៉ាសើចដាក់គ្នា។ តែដល់ថ្ងៃហ្នឹង ខ្ញុំក៏ហ៊ាននៅនិយាយជាមួយគាត់។ និយាយនេះ និយាយលេងទេ អត់ដឹងថាថ្ងៃរៀបការ ទាល់តែគេចូលជួរប្រកាស បានដឹងថារៀបការ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធាវី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៦៩ បន្ទាត់ ១៧-១៩។

[2933] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/340.1** ទំព័រ ៥៤ បន្ទាត់ ១៣-១៥។

[2934] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥៥ បន្ទាត់ ១១-១៦។

[2935] ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប បានផ្តល់សក្ខីកម្មថា "គាត់អត់ដឹងថាអ្នករៀបហ្នឹងសុទ្ធតែពិការ ស្រាប់ដល់ពេលថ្ងៃរៀបការបានចូលទៅឃើញ ស្គាល់ខ្លះដែលពេលដែលគាត់មកដឹកជយភណ្ឌនោះ គាត់មកតាមឡាន។ ទាល់ថ្ងៃរៀបហើយបានឃើញពីមុនមកអត់ដឹងថា យុទ្ធជនដែលត្រូវរៀបហ្នឹង សុទ្ធតែពួកពិការ អត់ដឹងផង"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/467.1** ទំព័រ ២០ បន្ទាត់ ១៩-២៤។ "ខ្ញុំអត់ដឹងថាប្រយុទ្ធកើតមិនកើតទៀតមិនដឹងទេ ប៉ុន្តែឃើញពួកហ្នឹងមកនៅកន្លែងមន្ទីរពិការ។ ហើយដល់ស្រាប់ដល់ពេលថ្ងៃរៀប ឃើញសុទ្ធ

1236. ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានរៀបការជាមួយបុរសពិការម្នាក់ឈ្មោះ កែវ។ "ចាស ថ្ងៃការខ្ញុំឃើញពិការជើង។ ដល់ក្រោយមកបានដឹងថា គាត់ពិការដៃផង ពិការភ្នែកផងចាស។ ដៃគាត់ក្រងេម្រាមដៃអីចេះ ហើយភ្នែកគាត់ងងឹតមួយចំហៀងដែរ។ អីចឹងខ្ញុំឃើញភាពពិតតែតូចចិត្តនឹងគេដែលគេផ្គូផ្គងឲ្យខ្ញុំហ្នឹងចាស"[2937]។ គាត់បានពន្យល់ថា កែវពិការ "ដែលក្នុងសង្គ្រាម គាត់ឡើងវ៉ៃសមរភូមិ" ហើយមិនអាចធ្វើការធ្ងន់បាន[2938]។

1237. ដើមបណ្តឹងរដ្ឋប្បវេណីក៏បានផ្តល់សក្ខីកម្មថា "កាលសម័យនោះ គេគ្មាននិយាយពីការរៀបការ ជាមួយជនពិការឲ្យខ្ញុំដឹងថា មិត្តឯងត្រូវរៀបជាមួយឈ្មោះ មិត្តកែវ ជាជនពិការដៃពិការជើង ពិការភ្នែក គាត់អត់បានប្រាប់ បើបានប្រាប់ ខ្ញុំរត់ៗឲ្យស្លាប់បាត់តាំងពីនោះម្ល៉េះ ប៉ុន្តែខ្ញុំអត់ដឹង"[2939]។ "ដល់ពេលថ្ងៃរៀបការហើយ បានពេលរៀបហ្នឹង ក៏មិនទាន់ដឹងដែរ ដល់ពេលការហើយ បានពិនិត្យឃើញដៃគាត់ខ្វេរ ជើងគាត់កង្វេរ ភ្នែកគាត់ងងឹត បានដឹងទើបក្រោយរៀបការនេះទេ។ បើឲ្យខ្ញុំដឹង ថ្ងៃមុនរៀបការ ខ្ញុំរត់បាត់ហើយ ខ្ញុំសុខចិត្តស្លាប់"[2940]។

---

តែពួកពិការហ្នឹងមករៀបការ។ ពិការហ្នឹងម៉េច ខ្ញុំអត់ដឹងទេ។ ប៉ុន្តែថាពិការហ្នឹង ខ្ញុំដឹងថាសុទ្ធពិការខាងមកពីភូមភាគឧត្តរទាំងអស់ យោធានៅតាមក្រសួង តាមវរៈនីមួយៗ អ្នកណាប្រយុទ្ធមិនកើត គឺយកមកដាក់តែមួយកន្លែងហ្នឹងម្តង។ តែប៉ុណ្ណឹងក៏មិនទាន់អស់ដែរ នៅទៀត យុទ្ធជនពិការនៅច្រើនទៀត"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឡៀប ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/467.1** ទំព័រ ២១ បន្ទាត់ ៦-១១។

[2936] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឡៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥៥ បន្ទាត់ ២១-២២។

[2937] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៦៤ បន្ទាត់ ១៩-២១។

[2938] "ក្រោយមកដែលបានខ្ញុំឃើញច្បាស់ គាត់ជាជនពិការមួយ ដែលក្នុងសង្គ្រាម គាត់ឡើងវ៉ៃសមរភូមិ ចឹងគាត់ត្រូវគ្រាប់។ ដៃគាត់ពិការម្រាមនេះបី ហើយភ្នែកគាត់ បើសិនជាធ្វេចទៅ គាត់ត្រូវងងឹតមើលអត់ឃើញ។ ជើងគាត់ ភ្នែកគោរនេះជ្រុះបាត់ គាត់ខ្វេរជើង។ ដល់ចឹងគាត់ជាមនុស្សពិការធ្ងន់ធ្ងរ។ គាត់ធ្វើការងារធ្ងន់មិនបានទេ។" *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៧៤ បន្ទាត់ ២១-២៥។

[2939] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៧ បន្ទាត់ ១៣-១៥។

[2940] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៧ បន្ទាត់ ១៥-១៧។

1238. នៅពេលរៀបរាប់អំពីរូបរាងកាយរបស់ប្ដីគាត់ ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន បានបញ្ជាក់ថា "រូបរាងគាត់អាក្រក់ ហើយគាត់និយាយរដីនៗ របៀបដូចជនជាតិ ហើយគាត់ខ្មៅតែម្ដង។ ហើយមនុស្សហ្នឹងរបៀបដូចនៅធ្វើយោធា គួរឲ្យខ្ញុំខ្លាចហើយខ្ញុំអត់ចូលចិត្ត ខ្ញុំស្អប់"[2941]។ "ដៃជើងរាងដើរមិនសូវជាត្រង់ទេ ភ្នែករាងអន់"[2942]។ ដើមបណ្ដឹងរដ្ឋប្បវេណីមិនបានដឹង ថាតើប្ដីគាត់ពិការនៅលើសមរភូមិឬយ៉ាងណានោះទេ"[2943]។

1239. ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធារី បានផ្ដល់សក្ខីកម្មថា បានឃើញពិធីរៀបអាពាហ៍ពិពាហ៍ របស់កងទ័ពពិការ៖ "កាលពីនៅឃុំត្រឡាច ស្រុកទ្រាំង ខេត្តតាកែវ ឃើញគេគូដែរ។ មូលដ្ឋានជនពិការដែលមកពីកងទ័ព ពិការដៃពិការជើងអីចឹងទៅ មករៀបការជាមួយនារីជាមូលដ្ឋានទេ អត់មាន១៧មេសាទេ។ ប៉ុន្តែគេរៀបចំប្ដេជ្ញា គេមានតុអង្គុយមានអី ខុសពី១៧មេសា"[2944]។ ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធារី បានពន្យល់ថា "អត់មានរៀបការជាមួយនារីពិការទេ។ នារីហ្នឹងគឺនារីគេស្មោះត្រង់នឹងបក្ស រៀបការជាមួយយុទ្ធជនពិការ។ តែនារីអត់មានពិការទេ នារីនៅសមរភូមិក្រោយទេ ជាប្រធានសហករណ៍ ជាស្មៀនជាគ្រូអី ជាពេទ្យអី នៅតាមសហករណ៍ទេ។ ដល់កងទ័ពមកពីមុខអីចឹងមក មកពិការដៃពិការជើង គេឲ្យអ្នកហ្នឹងរៀបការជាមួយ អត់ប៉ានប្រកែកទេ ទុក១៨ ក៏អត់ប៉ានប្រកែកដែរ។ មូលដ្ឋានចាស់ហ្នឹង"[2945]។

1240. ចំពោះការរៀបចំអាពាហ៍ពិពាហ៍ របស់កងទ័ពពិការនៅតាខ្មៅ ជាមួយនារីៗមកពីចំការម្រេចនៅកំពត ដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន បានពន្យល់ថា "ពេលនោះខ្ញុំក្រោមការដឹកនាំ ណែនាំប្រាប់មកថា "ពួកអស់ហ្នឹងគេចាស់ៗអស់ហើយ រកប្រពន្ធឲ្យវា"។ អាហ្នឹងតាម៉ុក គាត់បញ្ជាមក

---

[2941] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/461.1** ទំព័រ ៧៦ បន្ទាត់ ៧-៩។

[2942] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/461.1** ទំព័រ ៧៦ បន្ទាត់ ១២។

[2943] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ១៣ បន្ទាត់ ១៧-១៨។

[2944] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៨០ បន្ទាត់ ៨-១០។

[2945] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៨០ បន្ទាត់ ១៨-២១។

ហើយខ្ញុំស្ដាប់បន្ត គ្រាន់តែពីផ្ទាល់ទេ គឺវាមានប្រធានគេអ្នកផ្ទាល់ គាត់មកស្ដាប់ឮអ៊ីចឹងមក អា រឿងដែលរៀបការហ្នឹង ព្រោះឲ្យតែពិការ គឺរៀបការឲ្យទាំងអស់ អាហ្នឹងខ្ញុំស្ដាប់មិនដឹងគាត់បន្តគ្នា ទេ"[2946]។ "រឿងនារីៗដែលយកមករៀបការសម័យនុ៎ង អត់មានទេ នៅសុទ្ធតែជានៅតាមភូមិ ហើយនិងយកនៅចម្ការប្រេចណោះទេ។ អត់មានអី នារីយោធាអីមករៀបការទេ អត់មាន ទេ"[2947]។

1241. ដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន បានពន្យល់ថា "រឿងតាម៉ុកហ្នឹង គាត់មានមកអី *(ឮមិនច្បាស់)* ប្រាប់ពួកខាងក្រោមនេះទេ គ្រាន់តែបញ្ជាទៅគណៈតំបន់ទេ ហើយគណៈតំបន់ទទួល ផែនការមកៗស្រុក អ៊ីចឹងស្រុកត្រូវអនុវត្តតាមផែនការឲ្យរៀបការ ព្រោះយុវជន នារីឥឡូវហ្នឹងវា ចាស់ៗច្រើនហើយ ទៅរៀបការឲ្យគេ"[2948]។

## ៣. ពិធីរៀបការ

### ៣.១. ផ្ដល់ដំណឹងតិចតួច ឬមិនផ្ដល់ដំណឹងមុនថ្ងៃរៀបការ

1242. ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធារី បានរៀបរាប់ថា "អត់មានបានប្រាប់ថារៀបចំការ នៅថ្ងៃណា ថ្ងៃណីទេ ស្រាប់តែដល់ពេលហៅតែម្ដង កំពុងធ្វើការ កំពុងតែវ៉ៃថ្មហ្នឹង គេហៅមក។ ដល់មកទៅ ថ្ងៃហ្នឹងគេប្រាប់ថារៀបចំគ្រួសារ"[2949]។ "ដល់ពេលម៉ោងប្រាំមួយល្ងាច ចាប់ផ្ដើមមកជួបជុំគ្នាអស់

---

[2946] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/465.1** ទំព័រ ១៤ បន្ទាត់ ៥-៨។

[2947] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/465.1** ទំព័រ ១៥ បន្ទាត់ ៤-៥។ ដើមបណ្ដឹងរដ្ឋប្បវេណីកត់សម្គាល់ថាគាត់មិនយោធាដែលរៀបការរួចទេ "ខ្ញុំមិនអាចស្គាល់ដឹងទាំងអស់ទេ ខ្ញុំគ្រាន់ធ្លាប់ស្គាល់កាលនៅមន្ទីរពិការភូមិភាគនិរតី គេមានប្រពន្ធនៅកំណើតរបស់គេ ហើយពេលប្រមូលមកនៅមន្ទីរពិការ ជាអ្នកស្រែ តាមភូមិ តាមឃុំទេ។ ខ្ញុំមិនដឹងឈ្មោះអីទេ ភ្លេចឈ្មោះអស់ហើយ ស្គាល់ដែរ ប៉ុន្តែស្គាល់មិនអស់សម័យនោះ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/465.1** ទំព័រ ១៥ បន្ទាត់ ១០-១៤។

[2948] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/465.1** ទំព័រ ១៤ បន្ទាត់ ៦-៨។

[2949] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/462.1** ទំព័រ ៦៧ បន្ទាត់ ១១-១២។

មកសព្វគ្រប់ទាំងអស់ ទាំងប្រធានកង ប្រធានឃុំ ប្រធានភូមិអី មកទាំងអស់ ក៏ចាប់ផ្ដើម ពេលហ្នឹងតែម្ដងទៅ"[2950]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានរម្លឹកឡើងវិញថា មេកងជាអ្នកហៅពួកគេឲ្យទៅចូលរួមពិធី[2951]។

1243. ដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន បានពន្យល់ថា "សាមីខ្លួនដែលត្រូវរៀបការយុវជន យុវនារីទាំងអស់ហ្នឹង គ្មានដឹងខ្លួនអីទេ ស្រេចលើប្រធានទេ គេជិតដល់ថ្ងៃហ្នឹងហើយ គេហៅទៅ ឈ្មោះនេះឈ្មោះនោះមកនៅជួបជុំនៅមន្ទីរស្រុក។ រហូតដល់ -- អាហ្នឹងបើនិយាយអ៊ីចឹងថា គ្មានដឹងខ្លួនទេ ទាំងប្រុសទាំងស្រី ស្រាប់តែដល់ថ្ងៃហ្នឹងគេហៅ ក្រែងទៅរៀនសូត្រ អីក៏ប្រជុំ ក៏មិនដឹងអីទេ ស្រាប់តែទៅដល់ល្ងាច"[2952]។

1244. ដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន បានផ្ដល់សក្ខីកម្មថា ប្អូនជីដូនមួយគាត់ដែល "បងផុនរៀបការឲ្យខ្ញុំហ្នឹង។ តាមខ្ញុំដឹង ខាងស្រីក៏មិនដឹងខ្លួនដែរ ហើយខ្ញុំក៏មិនដឹងថាអ្នកណាដែរ គេចេះថាមក! អ្នែងយកប្រពន្ធទៅ។ ថាពីរបីដងហ្នឹង បានខ្ញុំព្រមហ្នឹង បានយកមកឲ្យជួបមុខទៅ បានដឹងត្រឹមពេលហ្នឹងទៅទេខ្ញុំ អត់មានបានទាក់ទងអី ទៅស្រឡាញ់អីមុន អត់សោះ"[2953]។

---

[2950] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធាវី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/462.1** ទំព័រ ៦៧ បន្ទាត់ ២១-២៣។

[2951] "ពេលគេទៅហៅទៅហ្នឹង ប្រធានកង ប្រធានអីតាមក្រុមនានាហ្នឹង ទាំងប្រធាននារី ទាំងប្រធានយុវជនហ្នឹង គេកោះហៅមកដើរព្រោងព្រាតគ្រប់គ្នាមក។ គេដើរប្រាប់អ៊ីចឹង។ មកតាមគេប្រាប់អ៊ីចឹងមក។ អត់មានអ្នកណាទៅប្រាប់យើងផ្ទាល់អីណាន៎ !អ្នកឯងត្រូវទៅរៀបការ រៀបអី។ គេអត់មានប្រាប់ដំណឹងថារៀបការទេ គេឲ្យមកជួបជុំគ្នានៅទួលស្វាយខម ហៅស្វាយក្រោមហ្នឹង ជាមួយគ្នាហ្នឹងទាំងអស់។ កន្លែងហ្នឹងកន្លែងគេ ទួលហ្នឹងគឺគេសម្រាប់តែប្រជុំថ្នាក់ដឹកនាំ ហើយពេលស៊ីបាយស៊ីទឹកអីរៀបចំបុណ្យទានអី គេបាយទឹកនៅហ្នឹង"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធាវី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/462.1** ទំព័រ ៦៨ បន្ទាត់ ២-៧។

[2952] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/465.1** ទំព័រ ១៧ បន្ទាត់ ១២-១៥។

[2953] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/465.1** ទំព័រ ២៧ បន្ទាត់ ២២-២៥។

1245. ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន បានផ្តល់សក្ខីកម្មថា គាត់ត្រូវបាន "គេឱ្យដំណឹងពីរថ្ងៃ ដល់ថ្ងៃរៀប"[2954]។ "មេកង មិត្តស៊ា ហ្នឹងអ្នកឱ្យៗដំណឹង ថ្ងៃរៀបការនៅពីរថ្ងៃទៀតរៀបការ"[2955]។

1246. ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ បានផ្តល់សក្ខីកម្មថា "គូដែលចាប់តែពីរគូទាំងនាងខ្ញុំនោះ គឺគ្មានអ្នកណាមួយបានដឹងខ្លួនទុកជាមុនទេ ព្រោះបើដឹងខ្លួនមានខ្សឹបគ្នា មាននិយាយគ្នាប្រហែលជានាងខ្ញុំឮ ព្រោះធ្វើការជាមួយគ្នា"[2956]។ ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ បានពន្យល់ថា "សម័យនោះ គេអត់មានឱ្យយើងដឹងខ្លួនទេ ក៏គេមិនបានសួរដែរចាស"[2957]។

1247. ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានរៀបរាប់ពី "ថ្ងៃដែលគេហៅទៅការហ្នឹង ខ្ញុំអត់បានដឹងព័ត៌មានថា គេហ្នឹងអញ្ជើញខ្ញុំទៅរៀបការទេ។ អ៊ីចឹងខ្ញុំអត់បានបដិសេធទេ ព្រោះគេហៅចូលរួម ចាសចូលរួមកម្មវិធីគេធ្វើអី ធ្វើអ៊ីចឹង ខ្ញុំអត់បានទទួលព័ត៌មានថា មិត្តឯងថ្ងៃហ្នឹងត្រូវរៀបការជាមួយអ្នកនេះអ្នកនោះទេ"[2958]។ "ពេលចែកខោអាវ គេឱ្យខោអាវយកទៅ បានដឹងៗថាគេឱ្យ

---

[2954] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៤១ ទំព័រ ២១។

[2955] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៤១ ទំព័រ ២៣។

[2956] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹកឯកសារ ២០១៦ខែ តុលា ឆ្នាំ ១២ថ្ងៃទី **E1/482.1** ទំព័រ ៨១ បន្ទាត់ ១-២។

[2957] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/483.1** ទំព័រ ៥ បន្ទាត់ ១៦។

[2958] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ២២ បន្ទាត់ ១៤-១៦។ ចំពោះថ្ងៃរៀបការ ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានផ្តល់សក្ខីកម្មថា "ខ្ញុំមិនចាំច្បាស់ទេ ព្រោះសម័យនោះ វាមិនបានគិតថ្ងៃខែឆ្នាំទេ ប៉ុន្តែខ្ញុំដឹងថា នៅរដូវកាលហ្នឹងកប្បាសហ្នឹង វាផ្លែចាស់ហើយ ហើយគេប្រើខ្ញុំទៅធ្វើព្រៃ។ ដល់ថ្ងៃមួយហ្នឹង គេប្រើនីរសារហ្នឹង ឱ្យទៅហៅខ្ញុំពីចម្ការ រសៀល មិនដឹងម៉ោងប៉ុន្មានទេ ថ្ងៃជ្រេហើយ។ ហៅឱ្យខ្ញុំមក មកក៏ មិត្តលី ហ្នឹង មិត្តនី លី ហ្នឹង គាត់បានហៅខ្ញុំទៅសួរ។ ថាមិត្តឯងរស់នៅសព្វថ្ងៃ រស់នៅសព្វថ្ងៃហ្នឹង គោរពអង្គការវិន័យដែរឬទេ? ខ្ញុំក៏ឆ្លើយថា ខ្ញុំរស់ក្រោមការដឹកនាំរបស់អង្គការ គឺខ្ញុំគោរពគ្រប់ពេលវេលា។ ខ្ញុំឧទាហរណ៍ទៀតថា បើសិនជាឱ្យខ្ញុំចូលរន្ធក្តាម បើអង្គការចូលរួច ក៏ខ្ញុំចូលតាមដែរ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៥៦ បន្ទាត់ ២២ - ទំព័រ ៥៧ បន្ទាត់ ២។ ដើមបណ្តឹងរដ្ឋប្បវេណីបានរម្លឹកឡើងវិញថា "ខ្ញុំគេគ្រាន់តែសួរហើយ គេមិនប្រាប់ថា ត្រៀមខ្លួនរៀបការទេ គេអត់បានប្រាប់ថា ស្អែកត្រូវរៀបការខ្ញុំ ឬក៏ព្រឹកហ្នឹងរៀបការខ្ញុំទេ គេអត់បានប្រាប់ខ្ញុំទេ។ ខ្ញុំមិនបានចាប់អារម្មណ៍ការសួរពាក្យសម្តីទាំងអស់

ទៅរៀបការ ប៉ុន្តែនៅអារម្មណ៍គិតខ្លាចថា ក្រែងគេៗហ្នឹងភរយើង គេទៅសម្លាប់ គេប្រមូលគ្នាទៅតាមបណ្តាញខ្សែអីចឹងក៏មិនដឹង ខ្ញុំនឹកអារម្មណ៍អីចឹងទេ"[2959]។ គាត់បាននិយាយបន្តថា "ចឹងខ្ញុំអត់បានចាប់អារម្មណ៍ថា ខ្ញុំទៅការហ្នឹងខ្ញុំបានដឹងច្បាស់លាស់ ឬបដិសេធហ្នឹងខ្ញុំអត់បានប្រកែកដោយសារខ្ញុំអត់បានដឹងចាស។ ដល់ពេលទៅដល់កន្លែងហ្នឹងទៅវាហួសចិត្ត ក៏នាំគ្នាយំ"[2960]។

1248. ដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត ចាត បានផ្តល់សក្ខីកម្មថា ប្រហែលមួយអាទិត្យក្រោយពេលប្តីគាត់បាត់ខ្លួន "ថ្ងៃមួយកម្មាភិបាលម្នាក់មកប្រាប់ខ្ញុំថា "មិត្តចាត ថ្ងៃនេះមិនបាច់ទៅធ្វើការទេ ពេលល្ងាចនេះ"។ ខ្ញុំក៏អត់ទៅ។ អត់ទៅ ដល់ពេលនេះក៏គេហៅខ្ញុំ តោះមិត្តទៅសមរភូមិ ក្រោយជាមួយខ្ញុំ។ ខ្ញុំក៏មិនដឹងទៅណាដែរ ខ្ញុំចេះតែដើរៗមកតាមគេអីចឹងមក ទៅដល់កន្លែងបឹងខ្សារនោះ ស្រាប់តែខ្ញុំឃើញ មានមិត្តនារីអីច្រើនម្ល៉េះ ហើយពូៗច្រើនម្ល៉េះ ជាគូៗ។ ខ្ញុំថា ច្បាស់ជារៀបគ្រួសារឲ្យខ្ញុំហើយ។ ដល់ពេលមកដល់ ក៏គេថា អី! រៀបគ្រួសារ ងាប់ហើយ ខ្ញុំមិនដឹងមួយណាទេ"[2961]។

1249. ដើមបណ្តឹងរដ្ឋប្បវេណី សយ ណារឿន ត្រូវមេកងហៅឲ្យប្រមូលផ្តុំគ្នានៅអូរថ្ម។ នៅពេលទៅដល់កន្លែង "...ខ្ញុំក៏សួរថា សួរមិត្តកងថា "គេធ្វើអីច្រើនម្ល៉េះមិត្ត?" ហើយគាត់ឆ្លើយថា "បន្តិចទៀតមិត្តឯងដឹងហើយ ថ្នាក់លើចុះមកធ្វើអង្គមីទ្ទិង"។ នាងខ្ញុំក៏ទៅ ចូលទៅឃើញមិត្តបុរសហ្នឹងអង្គុយមួយជួរ នារីអង្គុយមួយជួរ។ នាងខ្ញុំឆ្ងល់ដែរ តែមិនៗហ៊ានសួរគេទៀតទេ"[2962]។ ប្តីរបស់ដើម

ហ្នឹង"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៥៧ បន្ទាត់ ៧-៩។

[2959] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ២២ បន្ទាត់ ១៧-១៩។

[2960] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ២២ បន្ទាត់ ១៩-២០។

[2961] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៩៤ បន្ទាត់ ១៨-២២។

[2962] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ២៧ បន្ទាត់ ២៤ - ទំព័រ ២៨ បន្ទាត់ ១។

បណ្ដឹងរដ្ឋប្បវេណី សយ ណាវឿន ក៏មិនបានដឹងពីការរៀបការដែរ៖ “គាត់បាននិយាយប្រាប់ខ្ញុំក្រោយមកទៀតហ្នឹង គាត់ថាពេលដែលគេហៅគាត់ទៅប្ដេជ្ញាចិត្ត គឺគាត់អត់បានដឹងដែរ”[2963]។

1250. ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី សាវឿន បានផ្ដល់សក្ខីកម្មថា “ដោយខ្ញុំបានទទួលដំណឹងពីប្រធានកងធំនិងកងចល័តហ្នឹង គឺគាត់បានប្រាប់ថា មុនមួយថ្ងៃដែលថ្ងៃរៀបការហ្នឹង គឺថាឈ្មោះខ្ញុំហ្នឹងគឺអង្គការបានរៀបចំរៀបការឲ្យ។ បានដឹងប៉ុណ្ណឹង”[2964]។

1251. មុនពេលគាត់រៀបការ ដើមបណ្ដឹងរដ្ឋប្បវេណី យស ផល បានពន្យល់ថា “គ្រាន់តែហៅគ្នាខ្ញុំប្រុស ១ហ្នឹង ប្រហែលយុវជនហ្នឹងប្រហែលជាបីបួននាក់។ ថា “មិត្តឯងបីបួននាក់នេះ ខ្ញុំនឹងឲ្យមិត្តឯងមានគូស្រករហើយ ព្រោះឃើញមិត្តឯងហ្នឹងចាស់ៗហើយ មិត្តឯងធ្វើការងារល្អ” ... គេមិនដែលប្រជុំថាម៉េចទេ ព្រោះគេរវល់ឲ្យយើងពង្រាបដី លើកភ្លឺស្រែ ធ្វើការជីកប្រឡាយខ្លាំងណាស់ អ៊ីចឹងគេអត់មាននៅប្រជុំទេ គេគ្រាន់តែប្រាប់ប៉ុណ្ណឹងហើយថា “មិត្តឯងចាំ! តិចទៀតយើងឲ្យមិត្តឯងមានគូស្រករហើយ””[2965]។

## ៣.២. ពុំបានស្គាល់ប្ដី/ប្រពន្ធរបស់ខ្លួនមុនថ្ងៃរៀបការ

1252. ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណាវឿន បានផ្ដល់សក្ខីកម្មថា “នាងខ្ញុំមានអារម្មណ៍ឈឺចាប់ណាស់ ឈឺចាប់ត្រង់ថា ហេតុអីក៏ចាប់មនុស្សបញ្ចូកដូចជាសត្វគោ ចាប់យកទៅទឹម ដោយមិនបានស្គាល់មុខ មិនបានស្គាល់គ្នាថា បុរសជាប្ដីនោះ មានចរិតបែបណា មានវង្សត្រកូលយ៉ាងម៉េច តើមនុស្សនុំងល្អ ឬអាក្រក់? ដោយមិនបានដឹងជាមុន ហើយក៏មិនបានស្គាល់គ្នាតាំងពីណាណីមក មិនដែលបានស្គាល់គ្នាសោះ មកដល់ពេលហ្នឹង មកចាប់ខ្ញុំទឹមដូចគោ ដូចក្របី”[2966]។

[2963] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណាវឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៣៥ បន្ទាត់ ២៤-២៥។

[2964] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី សាវឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ៤៨ បន្ទាត់ ៤-៦។

[2965] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ១៤ បន្ទាត់ ១០-១៤។

[2966] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណាវឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ២៩ បន្ទាត់ ៧-១១។ ចំពោះអារម្មណ៍របស់គាត់ចំពោះប្ដីគាត់នៅពេលនោះ ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណា

1253. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន មិនបានស្គាល់ប្ដីដែលគេស្នើឱ្យរៀបការនោះ មុនថ្ងៃរៀបការទេ៖ "អត់មានទេ លោកគ្រូ អត់មាន។ អត់មានប្រាប់ថា ឈ្មោះអី ឈ្មោះអីទេ"[2967]។ គាត់បានស្គាល់អត្តសញ្ញាណប្ដីគាត់ "ទាល់តែពេលចូលកម្មវិធីបានគេប្រកាសប្រាប់"[2968]។

1254. ដើមបណ្ដឹងរដ្ឋប្បវេណី យស ផល បានរៀបរាប់អំពីការជួបជាមួយប្រពន្ធគាត់ជាលើកដំបូងថា៖ "មិនដែលឃើញនាងហ្នឹងទេ ពេលដែលអើ ពេលដែលត្រូវមកប្ដេជ្ញា គេមករៀបគូខ្ញុំចុងក្រោយទី៥០ហ្នឹង ខ្ញុំគូទី៤២ហ្នឹង មិនបានឃើញមុខនាងហ្នឹងផង នាងហ្នឹងមកឈរក្បែរខ្ញុំ ក៏ខ្ញុំមិនហ៊ាន គឺថាយើងឈរមើលទៅមុខ មើលតែមុខមេកង មិនដឹងនាងរបៀបម៉េចៗផង ខ្ញុំមិនស្គាល់។ តាំងពីអត្តសញ្ញាណរូបរាងរបៀបម៉េច ក៏ខ្ញុំអត់ដឹងដែរ ខ្ញុំអត់បានមើលទេ អត់ហ៊ានមើលទេ មិនដឹងមើលម៉េច ព្រោះខ្ញុំខ្លាចប្រធានកងខ្លាំងណាស់"[2969]។

1255. ដើមបណ្ដឹងរដ្ឋប្បវេណី យស ផល បានពន្យល់ថា "ពេលដែលខ្ញុំកំពុងតែរៀបការ និងប្ដេជ្ញាហ្នឹង ខ្ញុំអត់ស្គាល់ទេ។ បើស្គាល់គ្នា ស្គាល់មុខគ្នា គឺនៅពេលដែលមេកងនារីហ្នឹង ឈ្មោះនារី ប៉ែត ហ្នឹងបាននាំយកមកជួបខ្ញុំនៅពេលព្រលប់ៗហ្នឹង ខ្ញុំបានឃើញគាត់។ ដល់ព្រឹកឡើង ភ្លឺច្បាស់ហ្នឹងបានយើងបានឃើញគាត់ស្គាល់គ្នាដែរ ប៉ុន្តែយើងចេញទៅធ្វើការរៀងៗខ្លួន ហូបបាយរៀងៗខ្លួន"[2970]។

1256. ចំពោះប្ដីគាត់ ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឌៀប បានផ្ដល់សក្ខីកម្មថា "មិនដែលស្គាល់ មិនដែលឃើញមុខម៉េចទេ ទល់តែថ្ងៃរៀបតែហ្នងហ្នឹង បានជួបគ្នាតែហ្នងហ្នឹង មិនដែលស្គាល់ប្រវត្តិ

---

រឿន បានលើកឡើងថា៖ "ឱ្យខ្ញុំពេញចិត្តអាម៉េច បើមនុស្សមិនទាំងដែលស្គាល់គ្នាផង។ មនុស្សយើងពេញចិត្តនឹងគ្នា រៀបការនឹងគ្នា អាស្រ័យតែយើងបានទាក់ទងគ្នា និយាយរកគ្នា ហ្នឹងបានមានចិត្តស្រលាញ់គ្នា។ តែនេះចាប់ខ្ញុំបញ្ច្រុកទឹមអ៊ីចឹង តើមានចិត្តឯណានឹងពេញទៅលើបុរសនោះជាប្ដី ខ្ញុំអត់មានពេញទេ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារិក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ២៩ បន្ទាត់ ១៤-១៦។

[2967] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារិក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/461.1** ទំព័រ ៧៣ បន្ទាត់ ២។

[2968] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារិក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/461.1** ទំព័រ ៧៣ បន្ទាត់ ៥។

[2969] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី យស ផល ប្រតិចារិក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ១២ បន្ទាត់ ១៩-២៣។

[2970] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី យស ផល ប្រតិចារិក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ២១ បន្ទាត់ ១០-១៣។

ស្គាល់អី ត្រង់ណា ត្រង់ណី អត់បន្តិចសោះ”[2971]។ “ដឹងមួយណា ដឹងគូមួយណាទេ ទាល់គេហៅឈ្មោះ គេដឹកដៃដាក់ហៅឈ្មោះ ដឹកដៃដាក់ទៅ បានដឹងគូណាៗ។ ដល់ពេលចូលទៅដល់អីចឹងទៅក៏អង្គការគេផ្ដែផ្ដាំ ដូចថាឲ្យគោរពអង្គការវិន័យ”[2972]។

1257. ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន បានផ្ដល់សក្ខីកម្មថា “កាលណាដែលគេហៅខ្ញុំទៅ គេអត់មានប្រាប់ថា ឈ្មោះណាមួយ គឺអត់មានទេ។ គេបង្ខំឲ្យខ្ញុំរៀបការនោះ គឺអ្នកកងចល័តដូចគ្នា ប៉ុន្តែមិនដឹងថាមុខមួយណាផង អត់ដែលខ្ញុំស្គាល់គ្នារលីងសោះ។ ប៉ុន្តែគេថាត្រូវតែរៀបការហើយ បើមិនរៀបការទេ ខ្លាចស្លាប់។ ម្ល៉ោះហើយក៏ខ្ញុំសុខចិត្តថា រៀបការចុះ។ រៀបការដោយបង្ខំចិត្តតែម្ដង”[2973]។

1258. អំពីប្ដីរបស់គាត់ ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ បានផ្ដល់សក្ខីកម្មថា “មិនដែលឃើញមុខហើយក៏មិនដែលឃើញគាត់ធ្វើការនៅកន្លែងណា ក៏មិនដែលស្គាល់ដែរ”[2974]។ “ក្នុងពេលនោះ គេមិនបានថាឲ្យយើងស្រឡាញ់គ្នា ហើយក៏ខ្ញុំក៏អត់បានស្គាល់គ្នា”[2975]។ គឺអត់បានស្គាល់គ្នាហើយក៏មិនបានពេញចិត្ត ហើយក៏គេមិនបានមកប្រាប់យើងថាមិត្តឯងនេះបានរៀបការជាមួយមិត្តនេះ។ ហើយមិត្តចាន់ បានរៀបការជាមួយមិត្ត តក់ សាត នេះ។ តើអ្នកឯងព្រមឬអត់”[2976]។

---

[2971] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឡៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥៤ បន្ទាត់ ១៧-១៨។

[2972] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឡៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥៦ បន្ទាត់ ២-៤។

[2973] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៣៧ បន្ទាត់ ១៤-១៧។

[2974] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៧៦ បន្ទាត់ ២៣-២៥។

[2975] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៦១ បន្ទាត់ ២១-២២។ ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មបន្ថែមថា “ក្នុងខ្សែវីដេអូហ្នឹង ខ្ញុំបានទៅជួបបងគាត់ដែរថាសួរបញ្ជាក់ថា ខ្ញុំមិនបានស្រឡាញ់ទេ។ ហេតុអីបានប្អូនបងឯងមករៀបការជាមួយខ្ញុំ? គាត់ថា អត់ដឹងដែរ គឺមិត្តអ៊ុំ មិត្តអឿនហ្នឹងគេរៀបការ គាត់អត់ដឹង”។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៦១ បន្ទាត់ ២២-២៤។

[2976] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៨៦ បន្ទាត់ ១០-១២។

1259. ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានពន្យល់ថា "ពេលចូលទៅក្នុងគេប្រជុំហ្នឹង ខ្ញុំមិនបានចាប់អារម្មណ៍ថាគេហ្នឹងផ្គូផ្គងទៅបុរសណាទេ គេហៅឱ្យចូលអង្គុយ នារីមួយចំហៀង បុរសមួយចំហៀង ហើយតុគេរៀបតុគូដាក់ហ្នឹងនៅកណ្តាល"[2977]។ គាត់បានពន្យល់ថា "គេគ្មានប្រាប់គូយើងថា ខ្ញុំត្រូវជាគូជាមួយបុរសណាផង ព្រោះត្បិតអី ពេលហ្នឹងគេហៅខ្ញុំទៅការ ដល់ពេលគេផ្គូផ្គុំទៅ ខ្ញុំឱនទៅក្រោមឃើញជើងគាត់ធំៗ ហើយពិការ ខ្ញុំមានបានមើលមុខមើលអីទេ។ ដល់ឃើញអីចឹងទៅ ខ្ញុំរឹតតែតូចចិត្តថែមទៀត ធ្វើឱ្យអារម្មណ៍ខ្ញុំហ្នឹងក្តុកក្តួល ចេះតែយំ"[2978]។

1260. ដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត ចាត បានពន្យល់ថា "គាត់គ្រាន់តែថា មិត្ត ចាត ទៅសមរភូមិក្រោយជាមួយខ្ញុំ។ ខ្ញុំក៏ទៅតាម ដើរទៅតាមគាត់អីចឹងទៅ គាត់នាំទៅដល់បឹងខ្នារហ្នឹង បានឃើញជាមានប្រុស មានស្រី ចំណាស់ៗខ្ញុំហ្នឹងនៅអង្គុយព្រាតហ្នឹង។ ហើយខ្ញុំក៏អត់មានចាប់អារម្មណ៍ថា គូខ្ញុំមួយណា ខ្ញុំអត់ដឹងដែរ"[2979]។

1261. ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ បានផ្តល់សក្ខីកម្មថា "ក្នុងការរៀបការហ្នឹងទៀត មានអ្នកខ្លះមិនដែលស្គាល់មុខគ្នា រៀបការឃើញមុខគ្នាពេលចាប់ដៃ ដល់ពេលចេញមកវិញបាត់គ្នាក៏មានដែរ"[2980]។

1262. ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន "ខ្ញុំអត់បានស្គាល់បុរសនោះទេ។ ដល់ពេលគេឱ្យខ្ញុំទៅអង្គុយជាជួរ ថាឱ្យមើលគ្នាម្ខាងៗម្នាក់"[2981]។

---

[2977] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ២២ បន្ទាត់ ២៤ - ទំព័រ ២៣ បន្ទាត់ ១។

[2978] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៦៤ បន្ទាត់ ៩-១២។

[2979] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៩៥ បន្ទាត់ ២-៥។

[2980] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/340.1** ទំព័រ ៥៥ បន្ទាត់ ៤-៦។

[2981] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៥១ បន្ទាត់ ៨។

1263. ស្រដៀងគ្នាដែរ ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន បានរៀបរាប់ថា “ពីមុនមកខ្ញុំអត់ស្គាល់ពីព្រោះខ្ញុំទើបចេញមកពីយោធា ដែលទៅច្របាច់ជាមួយនឹងកងចល័តហ្នឹងគឺថ្មី ខ្ញុំអត់បានដឹង។ តែដល់មុនការមួយថ្ងៃហ្នឹង បានប្រធានកងចល័តហ្នឹង គេប្រាប់។ បានខ្ញុំតាមឈ្មោះហ្នឹង ថាខ្ញុំហ្នឹងបានរៀបជាមួយនឹងគូ ជាមួយឈ្មោះ គង់ សុផាត ហ្នឹង”[2982]។

1264. ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ដែលបានឃើញការរៀបការនៅស្រុកកោះញែក[2983] បានពន្យល់ថា៖ “រៀបការហ្នឹងគឺថាគ្មានស្ម័គ្រចិត្តថានឹងស្រលាញ់គ្នាទេ គឺអត់ដឹង បើនិយាយរួមអត់ដឹងតែម្តង គឺថានៅភ្នំពេញមីមួយ មិត្តខ្លះក៏នៅសៀមរាបអ៊ីចឹងទៅ វាចាប់មកផ្គូ ដល់ពេលក៏ថា ប៉ុន្មានប្រាំពីរគូចុះក៏យកពីនោះមក ពីនេះមក ក៏ដកបញ្ចូលគ្នាទៅអ្នកណាត្រូវគូណា គូណាក៏មុខទល់គ្នាទៅបាទ មានតែប៉ុណ្ណឹងឯង អត់មានការស្រលាញ់អីទេ”[2984]។

1265. ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី បានផ្តល់សក្ខីកម្មថា គូស្រករត្រូវគេផ្សំផ្គុំដោយស្មានៗ៖ “ពេលហ្នឹង អត់មានចាត់គូអ៊ីចឹងថា ស្ត្រីនេះទៅការជាមួយបុរសនោះ បុរសនោះទៅការជាមួយស្ត្រីនេះទេ អត់មានប្រាប់ទេ។ ឈរតម្រាបជួរហ្នឹង ខាងស្រីមួយជួរ ខាងប្រុសមួយជួរអ៊ីចឹងមក។ ឈរកៀកៗគ្នាអ៊ីចឹងហើយ។ គេលេងល្បែងមួយថា ដូចល្បែងបិទពួនអ៊ីចឹង គឺគេពន្លត់ភ្លើងអគ្គិសនីនោះគ្រប់ឲ្យយើងទាំងអស់គ្នាហ្នឹងចាប់រាវគ្នា។ ខ្ញុំគម្រោងពីថ្ងៃមក គឺស្មានមិនខុស”[2985]។

---

[2982] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ៥០ បន្ទាត់ ១៩-២២។

[2983] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៦០ បន្ទាត់ ៩។

[2984] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/411.1** ទំព័រ ៦០ បន្ទាត់ ៣-៦។

[2985] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/462.1** ទំព័រ ៦៩ បន្ទាត់ ២៤ - ទំព័រ ៧០ បន្ទាត់ ២។

1266. ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឌឿន ដែលបានជួយរៀបចំការរៀបការក៏បានពន្យល់លម្អិតផងដែរថា គូស្រករដែលគេផ្សំផ្គុំឱ្យរៀបការ មិនបានស្គាល់គ្នាមុនថ្ងៃរៀបការទេ[2986]។ គាត់បានពន្យល់ថាគូស្រករមិនបានស្គាល់ប្តី/ប្រពន្ធរបស់ខ្លួនទេ ហើយជាទូទៅកម្មាភិបាលជាអ្នកផ្សំផ្គុំ[2987]។

## ៣.៣. ពិធីរៀបការដែលអង្គការជាធ្វើអធិបតី ពុំមានវត្តមានសមាជិកគ្រួសារ

1267. ពិធីរៀបការរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន មានការចូលរួមពីសមមិត្ត ផាន់ រួមជាមួយមនុស្សមកពីអង្គភាពផ្សេងទៀត៖ "សមមិត្ត ផាន់ ហើយក្រៅទៀត មានអង្គភាពផ្សេងៗចូលរួម ខ្ញុំមិនអាចស្គាល់"[2988]។ "ឪពុកម្តាយនាងខ្ញុំមិនបានដឹងទេ រៀបការក៏មិនដឹង ស្អីក៏មិនដឹងដែរ ព្រោះគាត់នៅផ្ទះគាត់ឯណោះ រួចគាត់នៅខាងសហករណ៍ គេមិនឱ្យយើងទៅហៅម្តាយហៅឪពុក ហៅបងប្អូនញាតិមិត្តអីទៅ អត់មានទេ"[2989]។

1268. ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី បានផ្តល់សក្ខីកម្មថា "ខ្ញុំមិនដឹងថាជាអ្នកណាជាអីទេ ប៉ុនគ្រាន់តែដឹងថា ប្រធានឃុំដែលខ្ញុំធ្លាប់ស្គាល់តែមិនស្គាល់ឈ្មោះខ្ញុំហៅថា មិត្តអ៊ំៗ អ៊ីចឹងទៅ។ ស្រុកគេហ្នឹងហៅថា អ៊ំអ៊ីចេះ អ៊ំអ៊ីចុះ ពូអ៊ីចេះ ពូអ៊ីចុះ តែរឿងគេហ្នឹងតួនាទីអីក៏មិនដឹងដែរ។ ប៉ុន្តែឃើញតាមេឃុំហ្នឹងមកជាមួយប្រធានកង សូម្បីតែក្នុងនាមដៃគូខ្ញុំការជាមួយគ្នាក៏ប្រធានកង១៧មេសាដែរ។ គាត់តួនាទីគាត់ប្រធានកងមើលការខុសត្រូវ ១៧មេសា។ ផ្នែកគេមានគ្រប់ផ្នែកទាំងអស់ ឃើញមូលគ្នាទាំងស្ត្រី ទាំងបុរស គេមកសុទ្ធតែខោអាវគេស្អាតៗ"[2990]។

---

[2986] សក្ខីកម្មបន្ថែមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឌឿន ឯកសារ **E3/5632** ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១០ ERN 00901538។

[2987] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឌឿន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/361.1** ទំព័រ បន្ទាត់ ២៣-២៥, ទំព័រ ៨០ បន្ទាត់ ៩។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ ឆ៖ កាលបរិច្ឆេទនៃការដាក់បង្ហាញភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលជាជនរងគ្រោះដោយប្រយោលនៃការរៀបការដោយបង្ខំនៅពេលសវនាការ។

[2988] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/461.1** ទំព័រ ៧៤ បន្ទាត់ ២០។

[2989] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៣២ បន្ទាត់ ១៧-១៩។

[2990] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/462.1** ទំព័រ ៧២ បន្ទាត់ ៩-១៣។

1269. ក្នុងពិធីរៀបការ ដើមបណ្ដឹងរដ្ឋប្បវេណី យស ផល បានរៀបរាប់ថា "ក្រឡេកទៅមើលជុំវិញ គ្មានបងប្អូនទេ មានតែមេកងឃោរឃៅចាំតែលើកដំបង ចាំតែលើកកាំបិតប្រហារជីវិត"[2991]។

1270. ដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន បានពន្យល់ថា "ការរៀបចំទាំងពីរវគ្គហ្នឹង គឺលើ បងផុន –សៅ ផុន– ហ្នឹងគាត់ជាគណៈស្រុក។ ឯអ្នកមកចូលរួមគឺគណៈឃុំ គ្រប់ឃុំក្នុងស្រុកស្អាងមកចូលរួម។ ចូលរួម ហើយទទួលយកគូដែលរៀបការហ្នឹង ..."[2992]។

1271. នៅពេលសួរថា តើឪពុកម្ដាយ ឬសាច់ញាតិរបស់ប្ដី/ប្រពន្ធបានមកចូលរួមពិធីរៀបការ ឬទេ ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឡៀប ឆ្លើយថា "អត់មានទេ។ ទូទៅគ្មានម្នាក់សោះហើយ"[2993]។ "ម្ដាយឪពុក បងប្អូនរបស់ខ្ញុំ អត់បានចូលរួមទេ មានតែអង្គការទេដែលចូលរួម"[2994]។ ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឡៀប បានផ្ដល់សក្ខីកម្មថា "អត់មានម៉ែឪបងប្អូនជីដូនជីតាណាមកជាមួយទេ"[2995]។

1272. ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន បានរម្លឹកថា ការរៀបការរបស់គាត់មានការចូលរួមពី "មានកម្មាភិបាលមាន មិត្តរ៉ុម, មិត្តសន និងមិត្តស៊ា, បី ខុសពីនោះសុទ្ធតែក្រុមកងការពារគេទាំងអស់។ ពួកមិត្តៗគេនៅអង្គុយនៅនោះទាំងអស់គ្នា។ ហើយខុសពីនោះសុទ្ធតែគូដែលរៀបការនោះឯង ៦០ គូ មានតែប៉ុណ្ណឹងទេ អត់មានម៉ែមានឪអីទៅចូលរួមទេ"[2996]។

---

[2991] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ១៨ បន្ទាត់ ២២-២៣។

[2992] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/465.1** ទំព័រ ២៩ បន្ទាត់ ១២-១៥។

[2993] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឡៀប ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/467.1** ទំព័រ ២២ បន្ទាត់ ២។

[2994] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឡៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥៤ បន្ទាត់ ១៤។

[2995] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឡៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥៦ បន្ទាត់ ៥-៦។

[2996] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៤៤ បន្ទាត់ ៥-៧។

1273. ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ បានផ្តល់សក្ខីកម្មថា "ការរៀបការនោះ គ្មានបង គ្មានប្អូន គ្មានសាច់ញាតិណោហិតណា ដែលដឹងថាយើងរៀបការយ៉ាងម៉េចទេ"[2997]។ "គ្មានញាតិមិត្ត ឬ មិត្តសម្លាញ់ណាបានដឹងឮទេ មានតែសមមិត្ត អឿន ហ្នឹង ហើយនិងសមមិត្ត អ៊ុំ ហើយនិងឈ្លប គេប្រាំនាក់"[2998]។

1274. ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ក៏បានរៀបរាប់ផងដែរថា "កាលការនុំង ញាតិសណ្តាន ម៉ែឳមិនបានចូលរួមទេ មានតែក្នុងកងធំៗដែលតំណាងឲ្យដែលនារីដែលយើងត្រូវទៅរៀបការហ្នឹង គេតំណាងឲ្យគូៗហ្នឹងមានបុរសហ្នឹង គឺតំណាងក្នុងកងហ្នឹង នារីក៏ក្នុងកងហ្នឹងដែរ"[2999]។ "គេ រៀបការឲ្យហ្នឹងមានតែអ្នកការ ហើយនិងប្រធានកង អត់មានភ្ញៀវផង"[3000]។

1275. ចំពោះមនុស្សដែលបានចូលរួមការរៀបការរបស់គាត់ ដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត ចាត បានផ្តល់ ចម្លើយថា៖ "ពូស៊ុន ហ្នឹងយកខ្ញុំមកអ៊ីចឹង ហើយបើគូណាៗ ខ្ញុំអត់បានស្គាល់គេផង ប៉ុន្តែខ្ញុំដឹងថា គេប្រជុំប្រាប់ថា ១០គូរៀបថ្ងៃហ្នឹង"[3001]។ គាត់បានពន្យល់ថា ពូ ស៊ុន "គេអ្នកដឹកនាំ គេប្រជុំ អ្វីខ្ញុំ ដូចគណៈសមរភូមិអ៊ីចឹង គេប្រជុំដូចថា ធំជាគេត្រូវទៅណាមកណាអ៊ីចឹង គេហៅទៅអ៊ីចឹងទៅ។ ឃើញតែពូ ស៊ុន ហ្នឹងគេអ្នកចុះឡើង ចុះឡើង ញឹកញាប់ជាងគេអ៊ីចឹង"[3002]។ "បងខ្ញុំនៅខ្មាវទទឹង នុំងដែរ ប៉ុន្តែអត់ទៅផង ទៅតែខ្ញុំម្នាក់ឯង អត់មានដឹងថា ទៅរៀបគ្រួសារផង។ សមរភូមិរៀង

[2997] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៥៥ បន្ទាត់ ៥-៦។ ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងថា "សាច់ញាតិគឺអត់មានបានដឹង បងប្អូន មីងមាគ្មាន អត់ដឹង ទាំងអស់លោកប្រធាន។ របបផ្តាច់ការ គឺអត់មានបងប្អូនចូលរួមទេ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៥៥ បន្ទាត់ ១០-១១។

[2998] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៥៥ បន្ទាត់ ១៨-១៩។

[2999] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៥៩ បន្ទាត់ ១០-១២។

[3000] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៧៦ បន្ទាត់ ១៤-១៥។

[3001] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៤ បន្ទាត់ ៤-៥។

[3002] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៤ បន្ទាត់ ៨-១០។

ខ្លួនៗ អត់មានបងណាស្គាល់ ម៉ែណាស្គាល់ថា កូនរៀបគ្រួសារអីអត់ទេ អត់ដឹងផង។ ខ្ញុំក៏អត់មានបានថា ម៉ែអើយ! ខ្ញុំរៀបគ្រួសារថ្ងៃនេះ អត់។ អត់មានបានទៅនិយាយជាមួយគាត់ ម៉ែឪខ្ញុំប្រាប់អីអត់ទេ អត់ដឹងទេ។ យកនេះ យកដោយចិត្តឯង អង្គការកំណត់ឲ្យយកអីចឹង ចេះតែយកអីចឹងទៅ"[3003]។

1276. ចំពោះមនុស្សដែលជាអធិបតីក្នុងការរៀបការរបស់គាត់ ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន បានពន្យល់ថា មាន "ថ្នាក់ស្រុកឈ្មោះ មិត្តមឿន"[3004] "ប្រធានក្រសួងស-៦២ ឈ្មោះ មិត្តយន។ ប្រធានឃុំឈ្មោះ មិត្តចេន។ ប្រធានកងខ្ញុំឈ្មោះ មិត្តរី។ សុទ្ធតែបុរស ស្ត្រីតែ មិត្តរី ម្នាក់"[3005]។ ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន បានពន្យល់ថា "ពេលដែលគេហៅខ្ញុំឡើងប្ដេជ្ញាចិត្តនុ៎ងគឺគ្មានឪពុកម្ដាយក្រុមគ្រួសារ ញាតិមិត្ត បងប្អូនទេ។ គេហៅតែខ្ញុំនៅតាមការដ្ឋាន ធ្វើម្ដេចគាត់ដឹងនៅតែអី គាត់នៅតែក្នុងសហករណ៍"[3006]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានរៀបរាប់អំពីការឈឺចាប់ដោយសារការរៀបការដោយគ្មានវត្តមានក្រុមគ្រួសាររបស់គាត់[3007] និងបានពន្យល់ថា នៅពេលឪពុកម្ដាយនិងសាច់ញាតិគាត់ដឹងថាគាត់បានរៀបការ "គាត់មានអារម្មណ៍ចុកចាប់នៅក្នុងខ្លួនគាត់

[3003] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ង៉ែត ចាត ប្រតិចារិក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៤ បន្ទាត់ ១៨-២២។

[3004] "មិត្តមឿន ហ្នឹងគឺជាប្រធាននៅស្រុក។ ធំជាងគេនៅស្រុកនុ៎ង"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារិក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៤២ បន្ទាត់ ១៥-១៦។ ចំពោះថ្នាក់ស្រុកវិញ ដើមបណ្ដឹងរដ្ឋប្បវេណីរម្លឹកថា "គេហៅថា យើងមកនៅនេះកន្លែងក្រសួង ស-៦២ នៅស្រុកស-៦២ ឃុំអូរន្ទួង"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារិក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៤២ បន្ទាត់ ២១-២២។

[3005] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារិក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៤២ បន្ទាត់ ១១-១២។

[3006] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារិក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ២៨ បន្ទាត់ ២១-២២។

[3007] "ដូច្នេះហើយដែលនាងខ្ញុំថា មានការឈឺចាប់ មូលហេតុមកពីនាងខ្ញុំនៅធ្វើការនៅការដ្ឋាន ហៅនាងខ្ញុំមកប្ដេជ្ញាចិត្តដើម្បីមានគ្រួសារ។ សួរថា ជីវិតនាងខ្ញុំ ឪពុកម្ដាយនាងខ្ញុំ ដែលគាត់ខំចិញ្ចឹមខ្ញុំតាំងពីតូចរហូតមក ហើយដល់ពេលខ្ញុំមានគ្រួសារ ហេតុអីក៏ឪពុកម្ដាយមិនដឹង? គាត់មិនបានដឹងទេ មិនបានដឹងថា ខ្ញុំហ្នឹងទៅរៀបការទេ ព្រោះខ្ញុំទៅធ្វើការទៅតាមការដ្ឋាន"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារិក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ២៨ បន្ទាត់ ២២ - ទំព័រ ២៩ បន្ទាត់ ១។

គាត់មានអារម្មណ៍សោកស្តាយ ដោយសារកូនដែលគាត់ខំចិញ្ចឹមហើយ ពេលរៀបការសូម្បីតែខ្លួនគាត់ជាម្តាយឪពុកមិនបានទៅមើលមុខ មើលកូនដែលកូនរៀបការមានគូស្រករ ក៏គាត់នឹកឡើងគាត់ឈឺចាប់ណាស់។ គាត់ទៅជាឈឺអត់បាយក្រហាយទឹក។ គាត់ទទួលយកអត់បានទេ"[3008]។

1277. ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ បានរម្លឹកឡើងវិញថា "អ្នករៀបចំហ្នឹងគឺជាតំណាងឲ្យសហករណ៍ ឬក៏តំណាងមកពីស្រុកក៏មិនដឹង ព្រោះខ្ញុំមិនស្គាល់ ស្គាល់តែតំណាងឲ្យសហករណ៍"[3009]។

## ៣.៤. ការប្តេជ្ញាចិត្តចំពោះអង្គការ

1278. ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី បានផ្តល់សក្ខីកម្មថា ក្នុងពេលគាត់រៀបការ "ឡើងប្តេជ្ញាជាងគេ។ ប្តេជ្ញាថា "ដើរតាមអង្គការដ៏មានគុណ ដែលបានរៀបចំគ្រួសារឲ្យខ្ញុំ ខ្ញុំនឹងដឹកដៃគ្នាឲ្យមានកូនមានចៅ ដូចអង្គការចង់បាន"។ ខ្ញុំប្តេជ្ញាអ៊ីចឹង តែប៉ុណ្ណឹង ឯង។ ខ្ញុំដឹងប្តេជ្ញាអីទៀត ហើយក៏គេទះដៃអបអរសាទរ"[3010]។

---

[3008] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៣១ បន្ទាត់ ២២-២៥។

[3009] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/340.1** ទំព័រ ៥៤ បន្ទាត់ ១៩-២១។

[3010] "គេហៅអ្នកមូលដ្ឋានពីរនាក់ហើយ និងអ្នក១៧មេសា ហ្នឹងមកបួននាក់ទៀត។ អ៊ីចឹងវាប្រាំមួយគូហើយ ដល់នេះ គេនៅខ្វះ ឃើញខ្ញុំនៅឈរមុខគេ គេហៅចូលមួយគូទៀត។ បានទាំងអស់ប្រាំពីរគូ ទាំងគូខ្ញុំហ្នឹង។ ហើយខ្ញុំក៏ចាំគូច្បាស់ថា ជាគូទី៧។ ដល់ពេលគេហៅចូលប្តេជ្ញា ក៏គូទី៧ដែរ។ ហើយមុខៗគេប្តេជ្ញា តែពាក្យសម្តីគេខ្ញុំមិនចាំ តែខ្ញុំចាំច្បាស់នឹងពាក្យខ្ញុំប្តេជ្ញាដែរ។ ខ្ញុំបានចេញពាក្យថា ប្តេជ្ញាថាដើម្បីកុំឲ្យខ្លួនស្លាប់ ប្តេជ្ញាដើម្បីឲ្យគេជឿជាក់ ប្តេជ្ញាដើម្បីឲ្យគេថាយើងពិតប្រាកដជាស្រលាញ់គ្នា។ ខ្ញុំបានប្តេជ្ញាថា "ដើរតាមអង្គការដ៏មានគុណ ដែលបានរៀបចំគ្រួសារឲ្យខ្ញុំ ខ្ញុំនឹងដឹកដៃគ្នាឲ្យមានកូន មានចៅ ដូចអង្គការចង់បាន"។ ខ្ញុំប្តេជ្ញាអ៊ីចឹង តែប៉ុណ្ណឹង ឯង។ ខ្ញុំដឹងប្តេជ្ញាអីទៀត ហើយក៏គេទះដៃអបអរសាទរ ខ្ញុំក៏ឈប់ទៅ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៧០ បន្ទាត់ ៩-១៦។

1279. ដើមបណ្ដឹងរដ្ឋប្បវេណី យស ផល បានផ្ដល់សក្ខីកម្មថា ក្នុងពេលគាត់រៀបការ "មកដល់ពេលខ្ញុំប្ដេជ្ញា ខ្ញុំប្ដេជ្ញាខ្លី ខ្ញុំមិនដឹងនិយាយថាម៉េច ខ្ញុំថា "សូមគោរពអង្គការជាឪពុកម្ដាយដ៏ល្អ អ៊ីចឹងហើយអង្គការឱ្យខ្ញុំធ្វើអី ខ្ញុំគោរពតាមអង្គការជារៀងរហូត" ខ្ញុំប្ដេជ្ញាខ្លីតែប៉ុណ្ណឹង"[3011]។

1280. ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឌៀប បានរម្លឹកឡើងវិញថា ក្រោយពេលចាប់គូរួចហើយ "សាមីខ្លួនហ្នឹងប្ដេជ្ញាចិត្ត។ ហើយកន្លែងប្ដេជ្ញាចិត្តហ្នឹង គ្មានស្អីទេ មានតែកណ្ដៀវ ហើយនិងកម្រងកួរស្រូវកន្លែងប្ដេជ្ញាហ្នឹង"[3012]។ "អង្គការគ្រាន់តែណែនាំថា ឱ្យគោរពអង្គការវិន័យ កុំឱ្យដល់រៀបគ្រួសារឱ្យហើយ កុំឱ្យធ្វើឱ្យអង្គការពិបាកអ៊ីចឹងទៅ ឱ្យចេះស្រឡាញ់គ្នា ហើយចេះខំប្រឹងកសាង ខំប្រឹងធ្វើការងារកសាងប្រទេសជាតិឱ្យរីកចម្រើនអ៊ីចឹងទៅ"[3013]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានពន្យល់ថាដោយសារចំណាយពេលយូរពេល ក្រោយពេលរៀបការ មានតែ "ពីរគូ បីគូហ្នឹង តំណាងឱ្យទាំង ១២គូហ្នឹងតែម្ដង"[3014] ត្រូវគេតម្រូវឱ្យឡើងឈរ ប្ដេជ្ញាចិត្ត[3015]។

1281. ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន បានផ្ដល់សក្ខីកម្មថា ក្នុងពេលគាត់រៀបការ "គេហៅគូ គូៗដែលប្ដីប្រពន្ធ ប្ដីប្រពន្ធដែលរៀបហ្នឹង ឱ្យឡើងមានការចាប់អារម្មណ៍ឱ្យគេស្ដាប់"[3016]។ ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន បានបន្ថែមថា "ចំណែកខ្ញុំវិញ ក៏ឡើងទៅ ក៏និយាយដូចតែគ្នា អត់មាននិយាយខុសគ្នាទេ។ ប្រឹងនិយាយថា ខ្ញុំខំប្រឹងធ្វើការងារ ដើម្បីធ្វើស្រែឱ្យបានច្រើន ១ហិកតាឱ្យបាន៣តោន

---

[3011] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ១៧ បន្ទាត់ ៤-៥។

[3012] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥៦ បន្ទាត់ ៤-៥។

[3013] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥៦ បន្ទាត់ ១០-១២។

[3014] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៧៨ បន្ទាត់ ៦។

[3015] ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឌៀប បានរម្លឹកឡើងវិញថា "ពេលរៀបការរួចហ្នឹង គេឱ្យឡើងមួយគូម្ដងៗ ប៉ុន្តែមិនឡើងទាំងអស់ទេ។ គ្រាន់ថា មានតំណាង ពីរគូបីគូអីៗអ៊ីចឹងទេ។ បើឡើងទាំងអស់ វាយូរ។ ម៉្លោះហើយ សុខចិត្តឡើងតែពីរគូបីគូអីហ្នឹងចប់ហើយ ចប់កម្មវិធីហើយ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៧៧ បន្ទាត់ ២៤ - ទំព័រ ៧៨ បន្ទាត់ ១។

[3016] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៤៤ បន្ទាត់ ១៤។

ឲ្យអស្ចារ្យ មហាលោតផ្លោះក្នុងសម័យនោះ។ ហើយខ្ញុំក៏បានប្ដេជ្ញាចិត្តថា ខ្ញុំនឹងឲ្យមានកូនឲ្យបានច្រើន ដើម្បីធ្វើកងទ័ពបដិវត្ត ឲ្យបានច្រើនទៀត”[3017]។

1282. ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន បានផ្ដល់សក្ខីកម្មថា ក្នុងពេលពិធីរៀបការ ក្រោយពេលទទួលការណែនាំ និងថាតាមការណែនាំ*ក្នុងចំណោមនោះគឺ* ឲ្យធ្វើតាមអង្គការ ខិតខំធ្វើការ និងបង្កើតកូនចៅឲ្យអង្គការ[3018] “ថ្នាក់លើគាត់ ... ឲ្យពួកខ្ញុំហ្នឹងឡើងប្ដេជ្ញាចិត្ត ...”[3019]។

1283. ដើមបណ្ដឹងរដ្ឋប្បវេណី ចៅ ឡាង បានរៀបរាប់ថា នៅថ្ងៃគាត់រៀបការ “រឿងរៀបការនេះ គឺគេឲ្យប្ដេជ្ញាចិត្ត។ ប្ដេជ្ញាចិត្តទៅវិញទៅមក គឺឲ្យប្ដេជ្ញាចិត្តទទួលស្គាល់គ្នាជាគ្រួសារ ជាប្ដីប្រពន្ធ ហើយនិងយើងនឹងខិតខំទាំងអស់គ្នា ដើរតាមមាគ៌ារបស់អង្គការ តាមដែលអ្វីដែលអង្គការដាក់ទិសឲ្យនោះ ដូចជាយើងលើកទំនប់ ជីកប្រឡាយ គឺយើងប្ដេជ្ញាចិត្តនឹងធ្វើតាមឲ្យបានៗគម្រប់តាមផែនការរបស់អង្គការដាក់ចុះតាម ការប្ដេជ្ញាចិត្តរបស់ប្ដីប្រពន្ធ”[3020]។ “បានប្ដេជ្ញាចិត្តតែរឿងការងារទេ ជូនអង្គការតែប៉ុណ្ណោះ”[3021]។

[3017] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៤៤ បន្ទាត់ ២១-២៤។

[3018] ដើមបណ្ដឹងរដ្ឋប្បវេណី សយ សារឿន បានរម្លឹកឡើងវិញថា “អង្គការទាំងនោះបានហៅមួយគូៗឡើងប្ដេជ្ញាចិត្ត មុននឹងប្ដេជ្ញាចិត្ត គេបានថា បើត្រូវធ្វើតាមអង្គការកំណត់ ត្រូវនិយាយតាមអង្គការដាក់ឲ្យ ឲ្យអ្នកទាំងពីរនាក់ប្ដេជ្ញាចិត្ត ឲ្យស្រលាញ់គ្នាចាប់ពីពេលនេះតទៅ បង្កបង្កើនផលឲ្យបានច្រើនពីមួយហិកតាប៉ុន្មានតោនទៅប៉ុន្មានតោនតាមកំណត់របស់អង្គការ ឲ្យបង្កបង្កើតជាមនុស្សឲ្យបានច្រើនដោយតម្រូវទៅតាមអង្គការត្រូវការ មនុស្សច្រើនដើម្បីការពារទឹកដី។ មុននឹងខ្ញុំប្ដេជ្ញាគឺថ្នាក់លើបានណែនាំឲ្យខ្ញុំនិយាយអ៊ីចឹង និយាយឲ្យដូចគេថាអ៊ីចឹង”។*សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៣១ បន្ទាត់ ៤-៩។

[3019] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ២៨ បន្ទាត់ ៥-៦។

[3020] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ចៅ ឡាង ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ៥៩ បន្ទាត់ ២៤ - ទំព័រ ៦០ បន្ទាត់ ២។

[3021] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ចៅ ឡាង ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ៦០ បន្ទាត់ ៨-៩។

1284. ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ បានផ្ដល់សក្ខីកម្មថា ក្រោយពេលប្រកាសការរៀបការ "គេឲ្យយើងចាប់ដៃគ្នា បាទ ចាប់ដៃគ្នាមួយគូៗទៅ បានគេឲ្យអ្នកកណ្ដាលហ្នឹង គេឡើងប្ដេជ្ញាដើម្បីអនុវត្តទៅតាមមាគ៌ារបស់អង្គការ ធ្វើយ៉ាងណាមួយហិកតាឲ្យបានបីតោនទៅបួនតោន"[3022]។

1285. ដើមបណ្ដឹងរដ្ឋប្បវេណី សុន វុត, សៀង ចាន់ធី និង ប្រាក់ ឌឿន បានផ្ដល់ភ័ស្ដុតាងបន្ថែមទៀតពាក់ព័ន្ធនឹងការប្ដេជ្ញាចិត្តចំពោះអង្គការ[3023]។

***ពាក់ព័ន្ធនឹងកំណើនប្រជាជន ការបង្កើតកូនជូនអង្គការ***

1286. ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ បានរម្លឹកឡើងវិញថា ក្នុងពិធីរៀបការ មិត្ត អឿន និង មិត្ត អ៊ុំ តម្រូវឲ្យប្ដីប្រពន្ធក្រោកឈរកាន់ដៃគ្នា[3024] ហើយបន្ទាប់មក "គេមានយោបល់ថា ប្រាប់ថា អ្នកណាមិនពេញ ក៏ត្រូវពេញចិត្ត។ ត្រូវប្ដេជ្ញាចិត្តជូនអង្គការ។ ក៏ចប់បងអ៊ុំ ហ្នឹងទៅ ក៏ដល់លោក ពូ អឿន ហ្នឹង ក៏គេថ្លែងឡើង គេថា សមមិត្ត ណាក៏ដូចគ្នា ត្រូវការប្រកែកយ៉ាងណា ក៏ប្រកែកមិនរួចដែរ ព្រោះអង្គការបានចាត់តាំងសមមិត្តឯងគ្រប់គ្នានេះ រៀបការដើម្បីបង្កើតកូនជូនអង្គការ ហើយក៏គេស្រែកឲ្យយើងឡើងឈរចាប់ដៃ"[3025]។

1287. ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធារី បានពន្យល់ថា ក្នុងពិធីរៀបការគាត់ "មានគេឡើងថ្លែង។ គេប្រាប់ថា អង្គការដឹងគុណអ្នកឯង រៀបការប្រពន្ធឲ្យអ្នកឯង រៀបការប្ដីឲ្យអ្នកឯង។ ក្នុងពេលនេះដើម្បីតបស្នងសងគុណអង្គការវិញទៅ គឺកូនចៅ។ អង្គការគេនិយាយសំខាន់បំផុត គឺថាចង់បានតែ

---

[3022] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/340.1** ទំព័រ ៥៥ បន្ទាត់ ១-៣។

[3023] *សូមមើល* ឧបសម្ព័ន្ធ ឆ៖ កាលបរិច្ឆេទនៃការដាក់បង្ហាញភ័ស្ដុតាងរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលជាជនរងគ្រោះដោយប្រយោលនៃការរៀបការដោយបង្ខំនៅពេលសវនាការ។

[3024] ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ បានផ្ដល់សក្ខីកម្មថា "ទាំងពីររូបហ្នឹង គេបាន បានមើលក្រដាស ប្រហែលជាគេបានមកពីណាមក ក៏ខ្ញុំអត់ដឹងដែរ។ ក៏គេដាក់អានឲ្យយើងថា ឲ្យយើងទាំងពីរ ទាំង១២គូហ្នឹង ឡើងឈរចាប់ដៃឡើង។ ហ្នឹង គេមានផ្ដៃមីក្រូមួយ។ គេឲ្យចាប់ដៃគូមុខ គឺគេចាប់គូមុខ លោកប្រធាន។ ហើយចាប់ហើយ ក៏ចេញ។ គេថ្លែងការណ៍នឹងជាមួយនឹងសមមិត្ត អ៊ុំហ្នឹង គឺមានពីរនាក់ និងឈ្លប ប្រាំនាក់"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៥៥ បន្ទាត់ ២៣ - ទំព័រ ៥៦ បន្ទាត់ ១។

[3025] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៥៦ បន្ទាត់ ៥-៨។

កូនចៅប៉ុណ្ណឹងទេ ប្រជាជនយើងមិនសូវមាន”[3026]។ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា នៅក្នុងការថ្លែងការណ៍មួយក្នុងចំណោមនោះ គេនិយាយ “ថា អង្គការមានគុណលើអ្នកឯងអ៊ីចឹង អ៊ីចឹងទៅ បានរៀបការឲ្យយុវជន យុវនារីអ៊ីចឹង ហើយតើអ្នកឯងសងគុណអង្គការវិញម៉េច របៀបម៉េច ឲ្យមានកូនចៅច្រើន ឲ្យមានអីដើម្បីបន្តវេន”[3027]។

1288. ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន បានរម្លឹកឡើងវិញថា ក្នុងពិធីរៀបការ “កម្មាភិបាលដែលគេរៀបការឲ្យទាំង៦០គូហ្នឹង គេមានភារកិច្ចគេឡើងប្រកាសប្រាប់ថា គូស្រករដែលរៀបថ្មីជាប្តីប្រពន្ធហើយនេះ ត្រូវចេះស្រឡាញ់គ្នា មើលថែរក្សាគ្នា ហើយខំបង្កបង្កើនផលឲ្យបានច្រើន ដើម្បីយើងយកសេដ្ឋកិច្ចនេះ ដើម្បីកម្ទេចខ្មាំងកុំឲ្យមានសល់ ហើយនិងខំបង្កបង្កើតផលកូនឲ្យបានច្រើនឲ្យអង្គការ”[3028]។

1289. ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ បានរៀបរាប់អំពីឃ្លាប្រយោគដែលជំរុញការបង្កើតកូនជូនអង្គការ។ “ឃ្លាដែលសម័យនោះពួកឈ្លបនិយាយ កាលខ្ញុំរៀបការក៏គេថាឲ្យការយកកូនជូនអង្គការ។ ដល់ពេលគេតាមដានយើង យើងដេកនៅជាមួយគ្នាឈ្លបហ្នឹងក៏គេនិយាយថា ធ្វើអ៊ីចឹងល្អ យកកូនជូន អង្គការ។ ប៉ុន្តែចិត្តខ្ញុំថាដូចគ្មានឃើញកូនណាជូនអង្គការទេលោកប្រធាន គឺមួយគូបាត់

---

[3026] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/463.1** ទំព័រ ១៧ បន្ទាត់ ១០-១២។ ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី បានពន្យល់ថា “ពេលអារៀបការហ្នឹង មានគេឡើងស្តីអាហ្នឹងមកគេចេញវោហាស័ព្ទមកប្រាប់ថារឿងពីគោលការណ៍អីគេហ្នឹង គេថាត្រូវអង្គការដឹងគុណអ្នកឯង ការប្រពន្ធឲ្យអ្នកឯក តើអ្នកឯងដឹកគុណអង្គការវិញ ដោយបង្កើតកូនបង្កើតចៅឲ្យបានច្រើន។ ខ្ញុំបាននិយាយអ៊ីចឹងមែន ប៉ុន្តែដូចខ្ញុំបានជម្រាបអ៊ីចឹងថា ខ្ញុំអត់ស្គាល់ច្បាស់ថាអ្នកណាជាគណៈឃុំ អ្នកណាគណៈស្រុកទេ។ ខ្ញុំមុនដំបូង ខ្ញុំឆ្លើយថា មិនដឹងជាអ្នកណាគណៈឃុំ គណៈស្រុកទេ មិនដឹងអ្នកណាមេភូមិ មេស្រុកទេ។ ខ្ញុំឆ្លើយថាអត់មាន។ ប៉ុន្តែដល់ពេលគេនេះមក និយាយអ៊ីចឹង គេឆ្លើយ ខ្ញុំនឹកឃើញ គេថា អ៎! អាហ្នឹងឆ្លើយថាគណៈស្រុក ខ្ញុំឆ្លើយតាម។ អ៊ីចឹងអាការងារក្រោយដែលថាខ្ញុំមានគេចូលរួមច្រើននេះ អាហ្នឹងជាការពិត”។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/463.1** ទំព័រ ៤២ បន្ទាត់ ២០ - ទំព័រ ៤៣ បន្ទាត់ ១។

[3027] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/463.1** ទំព័រ ៤៣ បន្ទាត់ ៤-៦។

[3028] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៤៤ បន្ទាត់ ១០-១៣។

ទៅ ពីរគូបាត់ទៅ យូរៗអស់ពីកងក៏មានលោកប្រធាន អត់ឃើញបានអ្នករៀបការហ្នឹងបង្កើតកូនជូនអង្គការទេ ក៏គេយកទៅដាក់បង្កើតត្រង់ណា ក៏ខ្ញុំអត់ដឹងទេកាលនោះ"[3029]។

1290. ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានផ្តល់សក្ខីកម្មថា "ថ្ងៃរៀបការហ្នឹង ខ្ញុំឮខាងមេបក្ស គាត់បានលើកឡើងថា អង្គការយើងត្រូវការបង្កើនកម្លាំង។ អ៊ីចឹងអង្គការយើង នឹងអនុញ្ញាតឱ្យគូស្រករដើម្បីបង្កើតកូនឱ្យបាន ពង្រីកកម្លាំងប្រជាពលរដ្ឋ"[3030]។ "អ៊ីចឹងត្រូវធ្វើម៉េច យើងត្រូវរៀបការ យើងត្រូវរួមរស់នៅជាមួយគ្នា ចេះស្រលាញ់គ្នា កសាង និងបង្កើតកូនឱ្យបក្ស។ ដល់អ៊ីចឹង ខ្ញុំឆ្ងល់ កាលហ្នឹងខ្ញុំអត់ដឹងថា គេបង្កើតកូនរបៀបម៉េចអីរបៀបម៉េច ខ្ញុំចេះតែយំ"[3031]។

1291. ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានពន្យល់ថា "អង្គការគេបានលើកឡើងថា ឱ្យយើងបង្កើតកូនជាកម្លាំង កម្លាំងបដិវត្តន៍ ឱ្យកើនឡើងដើម្បីកសាងប្រទេស"[3032]។ ដើមបណ្តឹងរដ្ឋប្បវេណីរម្លឹកឡើងវិញថា នេះជាសារដែលបានបញ្ជូនបន្តក្នុងពិធីរៀបការ៖ "កាលដែលគាត់និយាយពាក្យទាំងអស់ហ្នឹងគឺ មិត្តសូ ជាប្រធានសហជីពទាំងមូល ដែលគាត់បានលើកឡើងឱ្យយើងនៅក្នុងសហជីពហ្នឹង ឱ្យបានក្នុងមង្គល ពេលវារៀបការហ្នឹង ឱ្យយើងដឹងថា ដើម្បីបង្កើនកម្លាំងបដិវត្តកសាងមហាលោតផ្លោះ មហាអស្ចារ្យនោះ"[3033]។ "ការនិយាយនេះ គឺនៅពេលប្រជុំ ឬក៏ពេលអ្នកដែលរៀបការមុនៗ ដែលគេបានមកនិយាយប្រាប់ខ្ញុំថា បក្សត្រូវការកម្លាំង។ អ៊ីចឹងគេរៀបការ

---

[3029] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៧០ បន្ទាត់ ៨-១២។

[3030] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៧៣ បន្ទាត់ ១៣-១៤។

[3031] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៧៣ បន្ទាត់ ១៥-១៧។

[3032] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៧៣ បន្ទាត់ ២៥ - ទំព័រ ៧៤ បន្ទាត់ ១។

[3033] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៧៤ បន្ទាត់ ៥-៧។ ក្រោយមក ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា "មិត្តសូ នោះគាត់លើកឡើងថា អង្គការត្រូវការបង្កើនកម្លាំងដើម្បីកសាងអភិវឌ្ឍប្រទេសជាតិ។ គាត់និយាយអ៊ីចឹង។ អ៊ីចឹងយើងរៀបការហ្នឹង ដើម្បីឱ្យកើតកូនគ្រប់ៗគ្នាមក ដើម្បីបង្កើនកម្លាំងបក្ស"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៧៤ បន្ទាត់ ៩-១១។

យើង ឱ្យបង្កើតកម្លាំងហ្នឹង។ អាហ្នឹងខ្ញុំឮតែទៅតាមពេលប្រជុំ បក្សហ្នឹង ពេលប្រជុំអាការងារ គេហៅក្រុមទៅប្រជុំ ហើយនិងអ្នកដែលបានការមុនហ្នឹង គាត់និយាយថា គេត្រូវការកម្លាំង បានគេរៀបការយើង ឱ្យយើងមានកូន"[3034]។

1292. ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម បានពន្យល់ថា ពួកគាត់ "ត្រូវគេប្រាប់ថាបង្កើតកូនឱ្យអង្គការឱ្យបាន"[3035]។ គាត់បានផ្តល់សក្ខីកម្មថា ក្នុងពិធីរៀបការ "គេគ្រាន់និយាយថា បើសិនមិនបង្កើតកូនឱ្យអង្គការបានទេ គឺអ្នកឯងត្រូវខុសច្បាប់។ ប៉ុន្តែគ្រាន់តែខ្ញុំវាអត់មាន បើរលូតរហូតគេដឹងហើយតែខ្ញុំមានម៉េចទេបើគេឃើញរលូតអ៊ីចឹងហើយ ដល់អ៊ីចឹងគេមានដាក់វិន័យអី"[3036]។

1293. ដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត ចាត បានផ្តល់សក្ខីកម្មថា ក្នុងពិធីរៀបការ "គេបានឱ្យរួមដំណេកថា ខំប្តេជ្ញាចិត្តយកគ្នាទៅ ខំបង្កកើតកូនឱ្យបានច្រើន ឱ្យបានមានកូនមានអីទៅ។ ខ្ញុំមានកូនទៅ បើមនុស្សស្គមហូបតែបបរ បានអីមានកូន បើអត់មានកម្លាំងកំហែងអីផង ប៉ុន្តែមិនហ៊ានថាទេ"[3037]។ "គាត់ថាឱ្យយកទៅបម្រើអង្គការ ឱ្យបានច្រើន កុំឱ្យខ្វះខាត។ ដូចជាយើងហូបបបរថ្ងៃនេះ ខំបង្កបង្កើនផលឱ្យបានច្រើន"[3038]។

1294. ក្នុងការឆ្លើយតបទៅនឹងសំណួរថា តើគាត់បានទទួលការណែនាំដោយផ្ទាល់ឱ្យរួមដំណេក ឬយ៉ាង ដើមបណ្តឹងរដ្ឋប្បវេណី សយ ណារឿន បានពន្យល់ថា "គឺមិនបានបញ្ចិតបញ្ចៀងអីទេ ព្រោះបាន

---

[3034] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៧៤ បន្ទាត់ ១៤-១៧។

[3035] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៨១ បន្ទាត់ ១៩។

[3036] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៧៨ បន្ទាត់ ១៦-១៨។

[3037] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ១០ បន្ទាត់ ៣-៥។

[3038] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ១០ បន្ទាត់ ៩-១០។

ថាអ៊ីចឹង បានគាត់ឡើងប្រកាសឲ្យថា ឲ្យខ្ញុំប្ដេជ្ញាចិត្តថាតាមគាត់ "គឺបង្កបង្កើតមនុស្សឲ្យបានច្រើន បង្កបង្កើនកូនឲ្យបានច្រើន ដើម្បីអង្គការត្រូវការមនុស្ស ដើម្បីការពារទឹកដី""[3039]។

## ៣.៥. ការមិនប្រារព្ធពិធីរៀបការតាមប្រពៃណីខ្មែរ

1295. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន បានពន្យល់ថា ក្នុងពេលគាត់រៀបការ ពុំមានភ្លេងប្រពៃណីខ្មែរ ពុំមានបាចផ្កាស្លា ហើយពុំមានឪពុកម្ដាយបានចូលរួមក្នុងពិធីទេ[3040]។ ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន បានពន្យល់ថា លើរោងពុំមានផ្កាតុបតែងលំអទេ[3041]។ ផ្ទុយទៅវិញ "តុគេ មានដូចតុកូនក្មេងរៀន"[3042]។ នៅខាងក្រោយរោង "គេដាក់រូបកណ្ដៀវ ដាក់មានកណ្ដៀវមួយ"[3043]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានរម្លឹកឡើងបន្ថែមថា ក្នុងពិធីរៀបការ គេរៀប "មិនមែនម្ហូបដូចយើងសព្វថ្ងៃ ម្ហូបនៅជំនាន់ ប៉ុល ពត ម្ហូបវាមាន ១ម្ហូបអី បាយលាយអីហ្នឹង ហូបធម្មតា ប៉ុន្តែមិនចាំថាម្ហូបអីខ្លះ"[3044]។

1296. ដើមបណ្ដឹងរដ្ឋប្បវេណី យស ផល បានរម្លឹកឡើងវិញថា គាត់ "គ្មានខោអាវសមរម្យ បើនិយាយឲ្យចំទៅ ប្រេតតិរច្ឆានសុទ្ធ ដែលការ ខោអាវក៏ដាច អាវក៏ដាច កន្សែងក៏ដាច សក់កន្ទ្រឹងកន្ទ្រើង ភ្នែកសស្លុះ ស្លក់ដូចត្រីចង់ងាប់អ៊ីចឹង"[3045]។ ក្រោយមក គាត់បានបន្ថែមថា ខ្លួនគាត់ផ្ទាល់ "គ្មានខោ

[3039] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៣៦ បន្ទាត់ ២៤ ដល់ ទំព័រ ៣៧ បន្ទាត់ ១។

[3040] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/461.1** ទំព័រ ៧៤ បន្ទាត់ ២៤ - ទំព័រ ៧៥ បន្ទាត់ ១។

[3041] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/461.1** ទំព័រ ៧៥ បន្ទាត់ ១១-១៣។

[3042] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/461.1** ទំព័រ ៧៥ បន្ទាត់ ៧។

[3043] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/461.1** ទំព័រ ៧៥ បន្ទាត់ ១៦។

[3044] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/461.1** ទំព័រ ៧៥ បន្ទាត់ ២០-២១។

[3045] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ១៩ បន្ទាត់ ១៥-១៦។

អាវស្ទៀកទេ ខោអាវមួយកំប្លេប្រលាក់សុទ្ធតែដី ដាចទៀត ខោក៏ដាច អាវក៏ដាច កន្សែងក៏ដាច ខ្លួនក៏ស្គម"[3046]។

1297. ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី បានផ្តល់សក្ខីកម្មថា "ពិធីការនេះមិនមែនជាការរៀបចំតាមប្រពៃណីខ្មែរយើងដែលមានកូនក្រមុំ កូនកំលោះ សម្អាងការ ឬក៏ធ្វើបុណ្យសូត្រមន្តអីថ្វាយបង្គំព្រះអីទេ។ ពិធីការជំនាន់ខ្មែរក្រហម ជំនាន់ប៉ុលពតនេះ គឺថាផ្តាច់ការតែម្តង។ គឺមានតែការបង្ខំអត់មានរៀបចំអីបានស្រួលបួលជាត្រឹមត្រូវទេ។ សូម្បីតែមីក្រូចាក់ឲ្យឆ្លើលគេឆ្លើលឯងក៏មិនចាក់ផង មានមីក្រូតូចមួយហ្នឹងសម្រាប់និយាយ បញ្ជាទៅអ្នកដែលត្រូវរៀបការហ្នឹងធ្វើម៉េចៗហ្នឹងស្តាប់សឹងតែមិនឮផង"[3047]។

1298. ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប បានបញ្ជាក់ថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ "គ្មានផ្ទឹម គ្មានអីបាចផ្កាស្លាអីទេ។ មានគ្រាន់តែហៅទៅ ហៅឈ្មោះដាក់គូណាៗអីចឹងទៅ បញ្ចូលតាមគូទៅ ហើយអង្គការណែនាំបន្តិចបន្តួច អីចឹងទៅ ក៏គោរពទង់បក្សអីចឹងទៅ គឺរួចជាស្រេចទៅហើយ។ ហើយឡើងប្តេជ្ញាចិត្តគោរពទង់បក្ស អីចឹងទៅ។ ធ្វើមិនបានមួយម៉ោងផងហ្នឹង"[3048]។

1299. ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន បានរៀបរាប់ថា "មុននឹងសម្រេចចិត្តរៀបការ គឺអត់មានប្រាប់ម៉ែឪកូនចៅ បងប្អូនណា ក៏អត់មានដឹងដែរ ព្រោះគេបង្ខំឲ្យរៀបការនេះ គេចាប់ដាក់រៀបការតែម្តង ព្រោះអ្នកដែលសាមីខ្លួនខាងប្រុសក៏ខ្ញុំអត់បានស្គាល់គេ ហើយខ្ញុំ -- គេខាងណោះក៏អត់មានស្គាល់ខ្ញុំ។ ហើយរៀបការនេះមិនមាន ៗច្បាប់ទម្លាប់អីសមរម្យនឹងរៀបការទេ ព្រោះអត់មានរៀបការនៅកន្លែងផ្ទះសម្បែងអីផង ការនៅកន្លែងការដ្ឋានសោះហ្នឹង"[3049]។

---

[3046] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ១៨ បន្ទាត់ ២១-២២។

[3047] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/462.1** ទំព័រ ៧១ បន្ទាត់ ១៩-២៣។

[3048] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៦១ បន្ទាត់ ៩-១២។

[3049] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៣៩ បន្ទាត់ ៨-១២។

1300. ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន បានរម្លឹកឡើងវិញថា នៅថ្ងៃគាត់រៀបការ "អត់មានភ្លេងភ្លាត់អីទេ។ មានតែពួកមិត្តទាំងអស់គ្នា ដែលរៀបការហ្នឹងឯង អត់មានភ្លេង អត់មានអាចារ្យ អត់មានលោក មានអីទេ។ ៦០គូ ទៅរកលោកមកពីណាមក បើមួយជំនាន់នោះ អត់មានលោកផង ទៅការឯណា មានលោកនោះ។ បើការមួយគូ មួយគូទៅ វាមានលោក"[3050]។

1301. ដើមបណ្តឹងរដ្ឋប្បវេណី មុី សារឿន បានផ្តល់ចម្លើយថា ដោយនៅចាំពីថ្ងៃដែលគាត់រៀបការ ថា "ពេលម៉ោងបីហ្នឹង គឺគេចាប់ផ្តើមអញ្ជើញទៅកន្លែងរៀបមង្គលការហ្នឹង គឺមានតែផ្កាឈូកពីរគត់ នៅម៉ោងបីរសៀលហ្នឹង គឺគេចាប់ផ្តើមឲ្យតម្រង់ជួរហ្នឹង គឺ៦១គូហ្នឹងគឺមានបុរសហ្នឹងពីរជួរ ឲ្យអង្គុយជាជួរនៅក្នុងរោងបាយរបស់គេហ្នឹង ហើយពីរជួរទៀត គឺជាខាងកងចល័តស្រីៗ។ ហើយក៏គេគ្រាន់តែលើកបំពាក់បំប៉នពីរឿងថាអង្គការយើងឲ្យរៀបចំអាពាហ៍ពិពាហ៍ តាមរយៈ ដែលថាអង្គការឲ្យរៀបចំឲ្យមានគូស្រករ គឺថ្នាក់លើគឺឲ្យធ្វើអីចឹង"[3051]។

## ៤. ទំនាក់ទំនងជាប្តីប្រពន្ធ ពិធីក្រោយពេលរៀបការ

### ៤.១. ការរៀបចំផ្សំដំណេកសម្រាប់ប្តីប្រពន្ធរៀបការថ្មីថ្មោង ក្រោយពិធីរៀបការ

1302. ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានពន្យល់ថា "កាលហ្នឹងគេធ្វើផ្ទះល្វែងហ្នឹង គេធ្វើទុក សម្រាប់តែអ្នកដែលរៀបការទេ។ រៀបការបើពួកនៅនឹងសហជីពហ្នឹងការរួច គេឲ្យទៅជួបគ្នាមួយ ខែបីដងដូចគ្នា បីថ្ងៃដូចគ្នា។ អ្នកគ្រួសារនៅឆ្ងាយក៏ជួបដូចគ្នា។ ដល់កំណត់ណាត់ បើគេអ្នកយល់ ចិត្តគ្នា ដល់កំណត់ណាត់ គេកាត់ទៅកន្លែងគេស្រេចទៅ។ បើដូចយើងអត់ត្រូវចិត្តគ្នាអីចឹង គេមក យើងអត់ចង់ទៅ"[3052]។

---

[3050] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៤៥ បន្ទាត់ ១២-១៥។

[3051] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ៤៨ បន្ទាត់ ២១ ដល់ ទំព័រ ៤៩ បន្ទាត់ ១។

[3052] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៦៦ បន្ទាត់ ៨-១១។

1303. ដើមបណ្ដឹងរដ្ឋប្បវេណី ង៉ែត ចាត បានផ្ដល់សក្ខីកម្មថា “ពេលរៀបហើយហ្នឹងក៏នាំគ្នាដើរមកទាំងយប់អ៊ីចឹង [...] គេធ្វើផ្ទះគេខ្ទមគេតូចៗដូចថាល្មមតែឱ្យយើងដេកមួយគ្រួសារៗអ៊ីចឹងទៅ”[3053]។ “អត់ដឹងបានប្រហែលជាប៉ុន្មានថ្ងៃ។ ខ្ញុំអត់ស្ងូវ ខ្ញុំអត់បានចំណាំដែរ ប៉ុន្តែដេកហ្នឹង បានសម្រាកហ្នឹងបានប្រហែលពីរបីថ្ងៃចុះ”[3054]។

1304. ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន បានផ្ដល់សក្ខីកម្មថា “នាងខ្ញុំប្ដេជ្ញាចិត្តរួចហើយ គេបានឱ្យនាងខ្ញុំទៅដេកតាមរោងបន្ទប់ មួយបន្ទប់ៗហ្នឹង គឺមានច្រើនបន្ទប់ គេឱ្យពួកខ្ញុំអ្នកប្ដេជ្ញាចិត្តហ្នឹងទៅសម្រាកនៅក្នុងបន្ទប់រោងតូចៗមួយហ្នឹង។ រោងហ្នឹងបាំងជញ្ជាំងដោយស្បូវ ប្រក់ដោយស្បូវ”[3055]។ ក្រោយពេលរៀបការរួច ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន និងប្ដីគាត់រស់នៅជាមួយគ្នាបានបីថ្ងៃ[3056]។

1305. ដើមបណ្ដឹងរដ្ឋប្បវេណី សុន វុត ដែលជាយុទ្ធជនក្នុងរបបនោះ បានពន្យល់ថា “ដែលការរៀបការមុនដំបូងអ៊ីចឹង គឺគេចំកន្លែងឱ្យ គឺគេអនុញ្ញាតឱ្យចូលក្នុងសម្រាកក៏ដោយ គឺម៉ោង គេកំណត់ម៉ោងទៀត អង្កាល់នោះគឺខ្ញុំចំណាំបាន គេកំណត់ម៉ោង តែម៉ោងប្រាំបី គេឱ្យចូល។ អានេះដែលគេអ្នកតាមដានដឹង”[3057]។

1306. ដើមបណ្ដឹងរដ្ឋប្បវេណី យស ផល បានផ្ដល់សក្ខីកម្មថា ក្រោយពេលរៀបការ “ចែកហើយគេបញ្ជាថាឱ្យរៀបចំកន្លែងដេកទៅ [...] ចូលដេកចូលអីក្នុងថែបទៅ អត់មានឈរនៅខាងក្រៅទេ។ ហើយខ្ញុំបាទហ្នឹងក៏ ថែបហ្នឹងវាចង្អៀតដែរ ប៉ុន្តែចេះតែចូលដេកតាមគេទៅ បើយើងមិនចូលដេកធ្វើ

---

3053 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៩៦ បន្ទាត់ ១៤-១៦។

3054 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៣ បន្ទាត់ ១០-១១។

3055 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ២៩ បន្ទាត់ ២១-២៣។

3056 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៣១ បន្ទាត់ ១៣។

3057 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/412.1** ទំព័រ ៨ បន្ទាត់ ៩-១១។

តាមមេកងហ្នឹងទេ អាហ្នឹងវាមានវិធានការទៀតហើយ។ ខ្ញុំចេះតែចូលដេកទៅជាមួយគ្នាអ៊ីចឹងទៅ ដូចជាបងជាប្អូនទៅ មិនមែនជា មិនទាន់ប្រព្រឹត្តអ្វីខុសឆ្គងទេ”[3058]។

1307. ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន បានរម្លឹកឡើងវិញថា “ហើយខ្ញុំភ័យក៏ខ្ញុំ – ទុកខ្ញុំមិនបានស្រឡាញ់បុរសនោះ – ក៏ខ្ញុំត្រូវតែរៀបការដែរចាស ដើម្បីខ្ញុំខ្លាចៗស្លាប់។ ដល់ពេលគេការហើយគេបង្ខំឱ្យខ្ញុំទៅរៀងៗខ្លួន។ ខ្ញុំក៏ទៅបន្ទប់ហ្នឹងក៏ខ្ញុំញ័រដូចកូនកណ្តុរអ៊ីចឹងចាស។ ពេលដែលគេនេះហើយ ក៏ខ្ញុំអត់បានប្រាប់អ្នកដែលស្រឡាញ់ខ្ញុំថា “ពូអើយអាណិតខ្ញុំទៅ ពូឯងកុំអាលធ្វើអីខ្ញុំ ខ្ញុំខ្លាចណាស់”។ ដល់ហើយអ្នកនោះក៏គេអត់បានធ្វើអ្វីខ្ញុំដែរ។ ដល់ពេលនោះក៏មាន មិនដឹងជាឈ្លបគេ ឬគេអ្វីឮសូរស្នូរជើងគេដើរនៅខាងក្រៅហ្នឹង ខ្ញុំក៏ភ័យញ័រ ខ្ញុំខ្លាចៗគេចាស”[3059]។

## ៤.២. ការរៀបចំឱ្យប្តីប្រពន្ធបានជួបគ្នា

### *ពុំមានការរួមរស់ជាអចិន្ត្រៃយ៍ជាប្តីប្រពន្ធទេ*

1308. ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង បានផ្តល់សក្ខីកម្មថា “អ្នកត្រូវ ឬក៏មិនត្រូវក៏ដោយ ដល់រួចទៅនៅអង្គភាពផ្សេងគ្នា គឺវិលទៅកន្លែងរៀងខ្លួនអ៊ីចឹងទៅ នៅដាច់ដោយឡែកឆ្ងាយពីគ្នាអ៊ីចឹងទៅ។ ដូចជាប្តីរបស់នាងខ្ញុំ គាត់ទៅខាងក្រសួងគមនាគមន៍ទៅ។ ឯខ្ញុំគឺនៅតាមមូលដ្ឋានភូមិឃុំហ្នឹងទៅ”[3060]។ “បានតែពីរថ្ងៃ គឺគាត់ទៅអង្គភាពរបស់គាត់វិញទៅ ខ្ញុំនៅអង្គភាពរបស់ខ្ញុំហ្នឹងទៅ”[3061]។

---

[3058] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ១៧ បន្ទាត់ ២០-២៥។

[3059] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៥១ បន្ទាត់ ១៣-១៨។

[3060] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ១៦ បន្ទាត់ ១៣-១៥។

[3061] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ១៦ បន្ទាត់ ២៥ - ទំព័រ ១៧ បន្ទាត់ ១។

1309. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន និងប្តីគាត់ត្រូវគេបញ្ជូនទៅទីកន្លែងខុសគ្នា ក្រោយពេលរៀបការបានមួយរយៈខ្លី៖ "គេនៅក្នុងអង្គភាពយោធាដដែល ចំណែកខ្ញុំគេឱ្យមកអង្គភាពលេខ ៧ វិញ"[3062]។ "រយៈពេល១០ថ្ងៃទៅ ប្រហែលជា១៥ថ្ងៃអ៊ីចឹង បានគេឱ្យមកជួបគ្នាម្តង"[3063]។

1310. នៅពេលពិភាក្សាអំពីរយៈពេលប៉ុន្មានយប់ក្រោយពិធីរៀបការគាត់ ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប បានរម្លឹកឡើងវិញថា "យប់ទី១ យប់ទី២ យប់ទី៣ គឺថាគេឱ្យតែនៅតែបីនាក់ទេ -- បីថ្ងៃទេ ជាមួយគ្រួសារ។ ប៉ុនក្នុងបីថ្ងៃហ្នឹងគឺឈ្លបតាមដានរាល់យប់ ខ្ញុំដេកស្តាប់ រួចទៅទាំងគ្រួសារទាំងខ្ញុំផ្ទាល់គឺថាខ្លាចគេដែរ ចេះតែនាំគ្នាសម្ងំមិនហ៊ានមាត់មិនហ៊ាននិយាយទេ។ ដល់ពេលបីថ្ងៃហ្នឹងក៏បែកគ្នា។ បែកគ្នាត្រួតត្រាតែប្រហែលជាមួយអាទិត្យ ឬ១០ថ្ងៃទេ បានខ្ញុំមកជួបគ្នាម្តងទៀត គេឱ្យមកជួបគ្នា ទើបខ្ញុំព្រមប្រគល់ខ្លួនឱ្យគ្រួសារខ្ញុំ។ ខ្ញុំមិនបានចាំខែចាំថ្ងៃ"[3064]។

1311. ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ក៏បានផ្តល់សក្ខីកម្មផងដែរ អំពីការណ៍ដែលគាត់ត្រូវគេបំបែកចេញពីប្តី ក្រោយពេលរៀបការមួយរយៈខ្លី៖ "ខ្ញុំឃើញគ្នារយៈ៣ថ្ងៃ"[3065]។ "ការហើយមិនបានរស់នៅជាមួយគ្នាទេ ចេញធ្វើការគេទៅខាងភ្នួរ ខ្ញុំទៅខាងរែកអាចម៍ ជីអាចម៍ និងអាចម៍គោដាក់ពាង។ គាត់ធ្វើផ្សេង គាត់ដេកផ្សេងអ៊ីចឹងទៅ កាលណាក៏គាត់មកកន្លែង គឺយើងអត់បានរស់នៅទេ រយៈតែ៣ថ្ងៃហ្នឹង គឺខ្ញុំអត់បាននៅធ្វើការនៅភូមិដើមរកាហ្នឹងតទៀតទេ"[3066]។

1312. ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានផ្តល់សក្ខីកម្មថា "សម័យហ្នឹង អត់មានបាននៅជាមួយគ្នាទេ។ ដល់មកនៅសហករណ៍ហ្នឹង គេឱ្យប្តីខ្ញុំនៅចិញ្ចឹមទា នៅកន្លែង ត្រង់នុំងគេហៅសង្កាត់ដែរ

---

[3062] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៧ បន្ទាត់ ៥។

[3063] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៧ បន្ទាត់ ៧។

[3064] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៧៩ បន្ទាត់ ៥-៩។

[3065] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/483.1** ទំព័រ ៤២ បន្ទាត់ ២៣។

[3066] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/483.1** ទំព័រ ៤២ បន្ទាត់ ២០-២២។

ពីដំបូងហ្នឹងគេឲ្យនៅចិញ្ចឹមទា នុ៎ង។ ខ្ញុំគេឲ្យនៅសហករណ៍ហ្នឹង គេឲ្យទៅធ្វើបាយ កាលនុ៎ងគ្មានអង្ករអីច្រើនទេ មានតែពោត [...] អត់នៅជុំគ្នាដែរ នៅដោយឡែកពីគ្នា"[3067]។

1313. ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានពន្យល់ថា "ការរួចគាត់ទៅកន្លែងគាត់បាត់ទៅ ខ្ញុំនៅកន្លែងសហជីពហ្នឹងទៅ។ ដល់ពេលគាត់ គេឲ្យគាត់មកបានគាត់មកដែរ។ មកទៅគាត់ត្រូវទៅជួប មិត្តសូ ហ្នឹងសិន។ មិត្តសូ ហ្នឹងត្រូវនាំព័ត៌មានមកឲ្យខ្ញុំដឹង បានខ្ញុំទៅជួប"[3068]។ ទោះបីជាយ៉ាងណាក្តី ក្រោយមក សហជីពរបស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ត្រូវបានរំសាយ[3069] បន្ទាប់មកគាត់បានទៅរស់នៅជួបជុំជាមួយប្តីគាត់នៅសហករណ៍របស់ប្តី[3070]។

1314. ក្រោយពេលគាត់រៀបការ ដើមបណ្តឹងរដ្ឋប្បវេណី សយ ណារឿន និងប្តីគាត់បានចំណាយពេលបីថ្ងៃជាមួយគ្នា៖ "ក្រោយពីជួប -- ឲ្យនៅជួបគ្នា៣ថ្ងៃហើយ គេឲ្យបែកទៅតាមការដ្ឋានរៀងខ្លួន ក្រោយមកមួយអាទិត្យគេឲ្យជួបគ្នាម្តងនៅផ្ទះ នៅផ្ទះម្តាយខ្ញុំ"[3071]។

1315. ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឡាង បានផ្តល់សក្ខីកម្មថា "បានតែបីយប់ហ្នឹងទេ ដែលគេឲ្យជួបគ្នា គេឲ្យយើងនៅដោយឡែកពីគ្នារហូត។ បុរសនៅមួយចំហៀង នារីនៅមួយចំហៀង ដាំកប្បាស គេយកទៅដាំកប្បាសទៀតហើយ។ រៀបចំហើយហ្នឹង គេនាំទៅដាំកប្បាសនុ៎ងហើយ។ គ្រួសារ

---

3067 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៦៣ បន្ទាត់ ៨-១២។

3068 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៦៦ បន្ទាត់ ២៣-២៥។

3069 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៦២ បន្ទាត់ ៧។

3070 "គាត់សុំខ្ញុំឲ្យទៅនៅជាមួយគាត់ទៅ ព្រោះត្បិតអីខ្ញុំបានលង់ខ្លួនជាមួយគាត់។ គាត់សុំទទួលស្គាល់ថា គាត់ហ្នឹងគ្រប់គ្រងខ្ញុំអីចឹងទៅ លួងលោមខ្ញុំ ខ្ញុំក៏តាមគាត់ចេញពីសហជីពទៅនៅសហករណ៍ នៅភូមិតាពយ ឃុំតាំងក្រាំង ស្រុកបាធាយ ចាសខ្ញុំទៅនុ៎ង។ ពេលខ្ញុំទៅនុ៎ង... "។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៦២ បន្ទាត់ ៧-១០។

3071 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៣១ បន្ទាត់ ១៦-១៧។

ធ្វើកន្លែងមួយចំហៀង ប្តីធ្វើកន្លែងមួយចំហៀង ប្រពន្ធធ្វើកន្លែងមួយចំហៀង ដាក់កប្បាស អត់ឱ្យជួបគ្នាទេ”[3072]។

1316. ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ បានផ្តល់សក្ខីកម្មថា ក្រោយពេលរៀបការ “គេឱ្យនៅផ្ទះប្រាំពីរថ្ងៃ បានគេឱ្យលើកប្រព័ន្ធភ្លឺស្រែ នៅស្ពានទី៣ទៀត នៅអាងត្រពាំងថ្មហ្នឹងឯង ចុះពីខាងលិចស្ពានទី៣ ទៅទល់នឹងភូមិតាវង បាទ លើកប្រព័ន្ធប្រឡាយ។ លើកប្រព័ន្ធប្រឡាយហ្នឹង គេឱ្យអ្នកដែលរៀបការទាំង ៦៣គូហ្នឹងទៅទាំងអស់។ ពេលទៅដល់កន្លែងការដ្ឋានលើកប្រព័ន្ធប្រឡាយស្រែប្រាំងហ្នឹង គេឱ្យនៅជាមួយគ្នា ប៉ុន្តែដល់ពេលការស្នាក់នៅវិញ ដេកនៅវិញគឺស្រីតាមកងស្រី ប្រុសតាមកងប្រុស អត់មានដេកលាយឡំគ្នាបានទេ ថ្វីត្បិតតែរៀបការឱ្យមែន។ បាទ រយៈពេលខ្ញុំបាទនឹងបានលើកប្រព័ន្ធប្រឡាយរួច ហើយប្តីប្រពន្ធ គឺបានជួបគ្នាតែពេលបាយទេ ពេលបាយមើលមុខគ្នាបាន តែពេលយប់ អត់មើលមុខគ្នាបានទេ ព្រោះគេកំណត់ថាមិនឱ្យដេកជុំគ្នា។ បាទ ស្រីដេកតាមស្រី ប្រុសដេកតាមប្រុស”[3073]។

1317. ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន បានរម្លឹកឡើងវិញថា “ខ្ញុំការបាន៣ថ្ងៃ ក៏បែកគ្នារហូត”[3074]។ គាត់បានពន្យល់ថា “អត់មានបានលែងលះទេ។ ពេល៣ថ្ងៃក្រោយ គឺបែកគ្នាធ្វើការរៀងៗខ្លួន”[3075]។ “គេអនុញ្ញាតឱ្យបែកគ្នា ធ្វើការរៀងៗខ្លួនអ៊ីចឹង”[3076]។

***ការជួបជុំប្តីប្រពន្ធដែលអង្គការបានរៀបចំ***

---

[3072] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឡាង ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ៥៥ បន្ទាត់ ១៤-១៧។

[3073] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/340.1** ទំព័រ ៥៥ បន្ទាត់ ៨-១៦។

[3074] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៥១ បន្ទាត់ ២២។

[3075] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៦៤ បន្ទាត់ ៦។ គាត់បានបញ្ជាក់ម្តងទៀតថា “ខ្ញុំមិនថាលែងលះទេ។ ពេល៣ថ្ងៃក្រោយ គឺមានការបែកគ្នាធ្វើការរៀងៗខ្លួន”។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៦៤ ទំព័រ ៧។

[3076] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៦៤ បន្ទាត់ ២២។

1318. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន បានពន្យល់ថា "រយៈពេល១០ថ្ងៃទៅ ប្រហែលជា១៥ថ្ងៃអ៊ីចឹង បានគេឲ្យមកជួបគ្នាម្ដង"[3077]។ គាត់បានពន្យល់ថា ក្នុងពេលជួបគ្នា "បានរួមដំណេក បើសិន ជាយើងមិនរួមខ្លាចគេយកយើងទៅធ្វើបាប ព្រោះគេមានមកហ្នឹងមានគ្នាប្រាំពីរ ឬប្រាំបីនាក់មក យាមកាមជុំវិញហ្នឹង"[3078]។ ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន បានរម្លឹកឡើងវិញថា "រួម ដំណេកហ្នឹង តាមតែគេមួយដំណើរមកជួបម្ដងៗ គេរួមដំណេកច្រើនពេល ច្រើនវេលាដែរ ប៉ុន្តែ នាងខ្ញុំនៅតែមិនទាន់អស់ចិត្ត នៅតែតូចចិត្ត នៅតែភ័យខ្លាចហ្នឹងនេះហ្នឹងទៅ រួចចំណែកប្ដីនាងខ្ញុំ ហ្នឹង រៀងរបៀបល្ងង់ដែរមិនសូវនេះទេ ឲ្យតែគេបញ្ជាធ្វើអី គឺធ្វើតាមចិត្តរបស់ខ្លួនឯងហ្នឹង"[3079]។

1319. ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធារី បានពន្យល់ថា "ក្រោយពីរៀបការហ្នឹងហើយមក ក្រោយបាន រួមរក្សគ្នាម្ដងពេលស្រវឹងហ្នឹង។ ក្រោយមកគេក៏បំបែកគ្នា ប្រហែលជាគេស៊ើបការណ៍ទៅដឹងថា បានសម្រេចជោគជ័យ ព្រោះអាថ្ងៃស្រវឹងហ្នឹង កន្លែងពិសេសរបស់គេ កន្លែងរៀបការហ្នឹង គេយកទៅដាក់ក្នុងបន្ទប់ហ្នឹង មិនដឹងគេលបមើលប៉ុន្មាននាក់ អីប៉ុន្មាននាក់ យើងអត់បានចាប់ អារម្មណ៍ទេ ប៉ុន្តែដឹងថាយើងបានគេងនៅជាមួយគ្នា គេក៏លែងសួរ គេក៏បំបែកខ្ញុំឲ្យទៅនៅទួក ភ្នំទំពែកវិញ អ៊ែថ្ន អ៊ែអីទៅ ១០ថ្ងៃអ៊ីចឹងទៅបានឲ្យមកជួបគ្នាម្ដង"[3080]។

1320. ទោះជាយ៉ាងណាក្តី នៅពេលជួបជុំគ្នា ប្ដីប្រពន្ធមិនបានរួមដំណេកជាមួយគ្នាទេ ម្យ៉ាងដោយសារពុំ មានអាហារទទួលទាន និងធ្វើការតាមផែនការ៖ "តែខ្ញុំអត់ដែលបានដេកទេ ខ្ញុំមកម៉ោង ដើរមកពី ហ្នឹងមក ប្រាំពីរ ប្រាំបីម៉ោងដែរ មកដល់ហ្នឹងទៅ អស់កម្លាំងហើយ អង្គុយនិយាយលេងគ្នា បន្តិចបន្តួចអ៊ីចឹងទៅ អីទៅអត់ចាប់អារម្មណ៍ថាប្រពន្ធហ្នឹងមានផ្ទៃពោះផង អង្គុយជជែកលេងគ្នា អ៊ីចឹងហើយ ដល់ម៉ោងប្រាំមួយល្ងាច "មីងសុខជា ខ្ញុំទៅវិញហើយ អស់កម្លាំងណាស់ ស្អែកធ្វើការ ទៀត"។ ប្រពន្ធខ្ញុំគេយល់ចិត្តខ្ញុំ "ថាទៅចុះ"។ បើមើលទៅប្ដីក្បាលជង្គង់ធំជាងក្បាលលើហើយ

---

[3077] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៧ បន្ទាត់ ៧។

[3078] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៧ បន្ទាត់ ៨-១០។

[3079] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៧ បន្ទាត់ ២២-២៤។

[3080] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/462.1** ទំព័រ ៧៤ បន្ទាត់ ២៣ - ទំព័រ ៧៥ បន្ទាត់ ២។

ទៅប្រឹងគិតអីអារឿងពីបញ្ហាការរស់នៅជាមួយគ្នា ឲ្យតែបានមួយជោគជ័យមួយរយៈ ឲ្យតែបានរស់"[3081]។

1321. ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឡៀប បានពន្យល់ថា "ពេលរៀបការរួច គេឲ្យមកសម្រាកនៅនឹងកន្លែងបានតែបីថ្ងៃទេ ទៅគេចែកកន្លែងដូចថា ប្ដីនៅណាឲ្យទៅនុំង។ ចំណែកខ្លួនខ្ញុំៗនៅធ្វើការកន្លែងខ្ញុំទៅ ចំណែកប្ដីខ្ញុំទៅធ្វើការកន្លែងគេផ្សេងទៅ។ គ្រប់គូទាំងអស់ ធ្វើអីចឹងដូចគ្នាទាំងអស់"[3082]។ បន្ទាប់ពីនោះមក "ពី១០ថ្ងៃទៅកន្លះខែបានគេឲ្យមកជួបគ្នាម្ដង ពេលនោះក៏ធម្មតាប្ដីប្រពន្ធទាល់តែយូរហើយឃើញថាជួបជុំគ្នាក៏រួមរក្សទៅ"[3083]។

1322. ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឡៀប បានពន្យល់ថា "នៅក្នុងរបបនោះមិនថារូបខ្ញុំផ្ទាល់ក៏ជាអ្នកណាទេ គឺថារយៈកាលយ៉ាងរហ័សហើយត្រឹមមួយអាទិត្យឲ្យជួបម្ដង មានកន្លះខែ ទៅមួយខែ បើគ្រួសារទៅធ្វើការឆ្ងាយទៀតមានតែមួយខែពីរខែបានៗជួបគ្នាម្ដង។ ដូចគ្រួសារខ្ញុំជាដើម ពេលរៀបរួចមិនបានប៉ុន្មានផងគេបញ្ជូនទៅឲ្យនៅខាងភ្នំគិរីរម្យ ទៅរកបន្លែ ទៅរកម្ហូបមកផ្គត់ផ្គង់កន្លែង។ ម្ល៉ោះហើយគ្មានបានជួបគ្នា មួយខែពីរខែទើបឃើញមកដល់ម្ដងអីទេ"[3084]។

1323. ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានផ្ដល់សក្ខីកម្មថា "ក្រោយពីរៀបការរួច មិត្តសូ ហ្នឹងគេប្រជុំ មានវេទិកាមួយអីចឹង គេប្រាប់ថា អ្នកដែលបានរៀបការហើយ គឺមិនបានរស់នៅជាមួយគ្នាស្ថិតថេរទេ គេឲ្យមានរបបជួបគ្នា ថា១ខែត្រូវជួបគ្នាពាយប់ បើអ្នកណាហួសកម្រិត ក៏គេដាក់

---

[3081] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធាវី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/462.1** ទំព័រ ៧៥ បន្ទាត់ ២-៨។

[3082] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឡៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥៨ បន្ទាត់ ៣-៥។

[3083] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឡៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥៨ បន្ទាត់ ៨-៩។

[3084] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឡៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥៨ បន្ទាត់ ២៥ - ទំព័រ ៥៩ បន្ទាត់ ៤។

ពិន័យដែរ។ ដល់អ៊ីចឹង ក្រោយៗមកក៏អ្នកការ ដែលក្រោយៗទៀតហ្នឹង ក៏គេអត់ដាក់ពិន័យតាមហ្នឹងដែរ"[3085]។

1324. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន បានបញ្ជាក់ថា "គេបង្ខំខ្ញុំទៅហ្នឹង ពេលមកដល់ពេលមួយខែទៅអ៊ូនែ! ១០ថ្ងៃ ទៅ១៥ថ្ងៃហ្នឹង បើសិនជាខ្ញុំមិនសម្រេចខ្លួនថាឱ្យពេលហ្នឹងម្តងទេ ក៏គេនៅហៅខ្ញុំទៅនេះទៀត។ អ៊ីចឹង ខ្ញុំសម្រេចថា ពេលហ្នឹងដែលបានជួបគ្នាម្តងហ្នឹង ក៏មិនមែនបានជួបជារាល់ថ្ងៃ ដែរ។ ប្អូនដប់ថ្ងៃទៅមួយខែ មួយខែទៅពីរខែ បានជួបគ្នា"[3086]។ "អត់មានប្រកែកគ្នាអត់មានស្អីទេ សំងំរៀងខ្លួន ព្រោះសុទ្ធតែខ្លាចរៀងខ្លួន ចាស។ គាត់យល់យោធាមែន ប៉ុន្តែក៏គាត់ខ្លាច អាចុងក្រោយហ្នឹង ឮគេថានេះអ៊ីចឹង សំងំរៀងខ្លួន អត់មានតវ៉ាស្អីគ្នាទេ ហើយក៏អត់មានបាននិយាយដែរ ព្រលឹមឡើង ហើយក៏ទៅកន្លែងគេវិញទៅ។ ដល់ពេលប្អូន ប្រហែលមួយខែអ៊ីចឹងទៀតទៅ បានគេមកជួបម្តងទៀតទៅ ជួបចុងក្រោយហ្នឹង ក៏អាចបានទំនាក់ទំនងគ្នាបានម្តាក់ម្តងអ៊ីចឹងដែរតើ"[3087]។

1325. ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ បានពន្យល់ថា "ព្រោះថាការមិនដឹងនោះ គឺមិនដែលបានកំណត់ពេលវេលារស់នៅជាមួយគ្នាបានជារៀងរាល់ថ្ងៃ។ អ៊ីចឹង ក្នុងរយៈកាលពេលណាទៅ មួយខែអីបានបានមកលេងផ្ទះម្តង បានជាមិនដឹង"[3088]។

## ៤.៣. ការតាមដានប្តីប្រពន្ធ

1326. ទាក់ទិននឹងការតាមដានប្តីប្រពន្ធ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន បានរម្លឹកឡើងវិញថា "[អ្នកយាម]មកធ្វើការនៅជុំអង្គភាពហ្នឹងផង ហើយដល់ពេលយប់ឡើង ... [ពួកគេ]មកមើលតើរួមដំណេកឬអត់ បើសិនជាអត់មានរួមដំណេកទេ គេអាចមានធ្វើវិធានការផ្សេងទៀត។ ហើយ

---

3085 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៦៦ បន្ទាត់ ២០-២៣។

3086 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៣៨ បន្ទាត់ ៩-១២។

3087 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៣៩ បន្ទាត់ ២៥ - ទំព័រ ៤០ បន្ទាត់ ៤។

3088 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/340.1** ទំព័រ ៦១ បន្ទាត់ ១៣-១៤។

នាងខ្ញុំព្រមទៅ ចាស នាងខ្ញុំចូលមកបត់ជើងតូច ទៅឃើញមានពួកទាហានហ្នឹង ពួកយោធាគេហ្នឹង នៅជុំវិញហ្នឹង"[3089]។ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន បានពន្យល់ថា នៅពេលគាត់ចេញក្រៅទៅបត់ជើងតូច ពួកយោធាគេ "ហ្នឹងនៅជុំវិញហ្នឹង"[3090] ដើម្បីលបស្តាប់[3091]។ "ចម្ងាយហ្នឹងប្រហែលជាល្បាក់ក្បែរៗហ្នឹង អត់មានទៅឆ្ងាយ ប្រហែលប្អូនដប់ម៉ែត្រអី អត់មានទេលោកគ្រូ នៅក្បែរៗហ្នឹងទេ នៅក្បែរជុំវិញផ្ទះហ្នឹង យើងចុះមកយើងឃើញ ប៉ុន្តែឃើញក៏ធ្វើមិនដឹងទៅ យើងឡើងទៅលើផ្ទះវិញទៅចាស។ គេក៏មិនសួរនាំយើង យើងក៏មិនសួរនាំគេ ចាស ព្រោះអ្នកមកហ្នឹងក៏មិននេះដែរ ព្រោះមិនមែនមានមេវាមកទេ មានតែអ្នកកូនៗក៏វាមិនឃោរឃៅអីប៉ុន្មានដែរ គ្រាន់តែស្តាប់ទៅ ស្តាប់យើងនិយាយ ក៏វាមិនយកការងារ ហ្នឹង អីឲ្យសំខាន់ដែរ ប៉ុន្តែគ្រាន់តែឃើញវាមកនៅក្បែរក្រោមផ្ទះហ្នឹងមិនឆ្ងាយពីគ្នាប៉ុន្មានទេ"[3092]។

1327. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន បានពន្យល់ថា "ក្រោយមកខ្ញុំបាន ពេលរួមភេទហ្នឹង វាប្រហែលជាមួយខែពីរខែកន្លងមក ប្រសិនជាខ្ញុំមិនព្រមរួមភេទទេ គេនៅយាមល្បាតនៅក្រោមផ្ទះ ហើយនិងសងខាងហ្នឹង។ ខ្ញុំមិនអាចនេះទៀតទេ ខ្លាចគេហៅទៅណែនាំ ហើយខ្លាចគេវ៉ៃចោលទៀត"[3093]។

1328. ក្រោយពេលពិធីរៀបការ ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធាវី បានរម្លឹកឡើងវិញថា "ខ្ញុំផ្ទះបងថ្លៃខ្ញុំហ្នឹង" ដែល "អត់សូវខ្ពស់ប្រវែងម៉ានទេ"។ ហើយនៅពេលល្ងាច នៅពេលគាត់និយាយជាមួយប្រពន្ធ និងបងថ្លៃគាត់ ពួកគេ "មើលទៅក្រោមផ្ទះហ្នឹង ស្រមោលខ្មៅចូលមកហើយៗ។ អ៊ីចឹងមិន

[3089] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៧ បន្ទាត់ ១៥-១៩។

[3090] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៤ បន្ទាត់ ៧។

[3091] "ក៏ខ្ញុំមិនចេះនិយាយគ្នាពេលដេកដែរ ខ្ញុំអត់ដែលចេះនិយាយទេ។ នៅហ្នឹង ប៉ុន្តែវាលបស្តាប់ យើងក៏គ្មានលបបទៅនេះ វាទៅលបស្តាប់យើងស្តាប់មែន ប៉ុន្តែអត់មានហេតុការណ៍អីឲ្យបានចាប់យើងបាន"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៤០ បន្ទាត់ ៩-១១។

[3092] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៤០ បន្ទាត់ ១៥-២០។

[3093] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៤៣ បន្ទាត់ ២២-២៤។

ដឹងជាអ្នកណា មិនដឹងជាអ្នកណាទេ។ ដល់ពេលព្រលឹមឡើង យើងឃើញលួនក្រោមផ្ទះហ្នឹង ដូច ជានពស់ថ្លាន់លូនអ៊ីចឹង។ ហើយខ្ញុំនេះ នឹកឃើញថារឿងនេះ មិនខុសពីរឿងយើងការមិនទាន់រៀប ការទេ គេចង់ដឹងអ្នកណាកា.ហ្សៀ.បេ, ចង់ដឹងថាអ្នកណា សេ.អ៊ី.អា គេលួនក្រោមផ្ទះស្តាប់សិន អ៊ីចឹង។ ម្ល៉ោះហើយខ្ញុំក៏ស្រមើស្រមៃ ពេលដែលនៅមិនទាន់រៀបការហ្នឹងថា ច្បាស់ជាគេមកស្តាប់ យើង។ ពេលដែលយើងរៀបការហើយដេកនៅជាមួយគ្នា ឬក៏មិនដេក"[3094]។

1329. ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី បានផ្តល់សក្ខីកម្មថា "វាល់ដង ពីរបីថ្ងៃគេមកតាមដាន [...] តែក្រោយពីថ្ងៃរៀបការហ្នឹង លួនទៅហ្នឹង វាមានស្នាកស្នាមមករួចហើយ"[3095]។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់អំពីពួកឈ្លបដែលស្ពាយកាំភ្លើងអូសដី[3096] ជា "កុមារ" ដែលមានអាយុប្រហែល ១២ ឬ ១៣ ឆ្នាំ[3097]។

1330. ដើមបណ្តឹងរដ្ឋប្បវេណី យស ផល បានផ្តល់សក្ខីកម្មថា "កាលខ្ញុំនៅកងចល័ត ខ្ញុំរៀបការហើយ នារីប៉ែត ហ្នឹងបាននាំទៅជួបហ្នឹង ក៏មាននីរសាររបស់ រី, នីរសាររបស់ ពុត តែងតែមកឈ្លបជាប្រចាំ"[3098]។ ដើមបណ្តឹងរដ្ឋប្បវេណីបាននិយាយបន្តថា "រហូតដល់ខ្ញុំចេញពីកងចល័តហ្នឹង ទៅនៅសហករណ៍ នៅខាងកើតងតាកែវហ្នឹង ក៏មានឈ្លបសហករណ៍ហ្នឹង គេតាមដានយើងទៀតដែរ

[3094] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/462.1** ទំព័រ ៧៣ បន្ទាត់ ១៤-២២។

[3095] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/463.1** ទំព័រ ៣៤ ទំព័រ ២៥ - ទំព័រ ៣៥ បន្ទាត់ ១។

[3096] ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី បានបញ្ជាក់ថា "ទោះជាខ្ញុំ វាមិនប្រាប់អាយុពីរបីដណ្តប់ឆ្នាំ ក៏ខ្ញុំមើលទៅរូបរាងវា អាយុតែប៉ុណ្ណឹងដែរ ព្រោះវាស្ពាយកាំភ្លើងអត់ផុតពីជើងផង ឱ្យខ្ញុំឆ្លើយថាម៉េចទៅ បើវានៅអូសផង អីផង។ មើលពីលើផ្ទះតាមប្រហោងរនាបទៅ វាឃើញទាបៗ លួនចូលអ៊ីចឹងហើយ។ ហ្នឹងឱ្យខ្ញុំឆ្លើយវាអាយុហាហុកសិប ម៉េចទៅកើត ខ្ញុំថាក្មេងទៅ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/463.1** ទំព័រ ៤១ បន្ទាត់ ២១-២៤។

[3097] "រូបរាងអ្នកអស់ទាំងហ្នឹង ក្នុងនាមដែលខ្ញុំមើលទៅហ្នឹង សុទ្ធតែមនុស្សពេញវ័យ។ ប៉ុន្តែគ្រាន់ខ្ញុំហៅក្មេងៗនោះ គឺជាវាក្មេងមែនទែន មិនមែនក្មេងតូចនៅបៅដោះទេ អានេះគឺៗក្មេងធំ ប៉ុន្តែខ្ញុំគ្រាន់ថា ដាក់ក្មេងធំ វាមិនចាំបាច់ក្មេងធំ ក្មេងតូចទេ គ្រាន់ថាក្មេង កងឈ្លបច្រើនតែអាយុពីរបីដណ្តប់ហ្នឹង"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/463.1** ទំព័រ ៤១ បន្ទាត់ ១៦-១៩។

[3098] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ២៣ បន្ទាត់ ៧-៨។

ប៉ុន្តែហាក់ដូចជា គេតាមដានបានម្ដងពីរដងដែរ"[3099]។ "គ្នាមកពីអស់កម្លាំងចង់ងាប់ បានប្រព្រឹត្ត អីទៅ រាងសុទ្ធតែឆ្អឹងអ៊ីចឹង ដើរវណ្ឌជើងគ្នាហើយទៅប្រព្រឹត្តយ៉ាងម៉េចទៅ"[3100]។

1331. ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឌៀប បានរម្លឹកឡើងវិញពីសំដីរបស់ប្ដីគាត់ដែលបាននិយាយថា ប្រសិនបើពួកគាត់ "នៅតែមិនព្រមត្រូវគ្នាហ្នឹង ក៏នាំឲ្យ វរៗ គេដឹងគេឮ គេធ្វើបាបគេ។ ម្ល៉ោះហើយគាត់និយាយតែប៉ុណ្ណឹង គាត់អត់មាននិយាយអីទេ"[3101]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានពន្យល់ថា "គាត់ដឹងតាមពេលដែលសម្រាកថ្ងៃដំបូងដែលរៀបការរួច ថ្ងៃដំបូងហ្នឹង គាត់សម្រាករឿងដឹងគេតាមដានហ្នឹង។ បើគាត់អង្គុយស្ដាប់ដែរ គាត់អង្គុយស្ដាប់ឮសម្រិបជើងដើរ សម្រិបជើងឡើងលើផ្ទះ សម្រិបជើងចុះ គាត់ដឹងតែទាំងអស់ហើយ។ គាត់ដឹងដោយខ្លួនគាត់ដែរនុ៎ង ប៉ុន្តែខ្ញុំ ក៏គេបានប្រាប់ខ្ញុំឲ្យដឹងខ្លួនមុនដែរ"[3102]។ "ងងឹតឈឹង មានទៅហ៊ានបើកទ្វារមើលផង គិតតែសំងំឡើងញ័រ រួញខ្លួនណោះ មានបានមើលទេ មានហ៊ានបើកធ្វើផងហ្នឹង អត់ដឹងអ្នកណា ជាអ្នកតាមដានផង"[3103]។

---

[3099] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ២៣ បន្ទាត់ ៨-១០។

[3100] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ២៣ បន្ទាត់ ៧-៨។ ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មពីការខ្វះខាតស្បៀងអាហារ និង សុខភាពរូបរាងកាយរបស់គាត់ថា "អ្នកដែលគេនៅសហករខាងក្រោយនេះ គេមានសាច់ មានឈាម ដល់ឃើញខ្ញុំមកអ៊ីចឹងអ្នកនៅតាមសហករណ៍មានអ្នកថ្មី មានអ្នកចាស់អ៊ីចឹង គេតែងថាឲ្យខ្ញុំដែរ។ ប្អូនឯងខំរកអីហូបឲ្យបានច្រើនទៅឲ្យមានកម្លាំង។ ហើយខ្ញុំមិនដឹងទៅរកឯណាទេ ដើររកខុសបែបខុសបទហ្នឹង មានតែទៅញ្ជូរស្រែហ្នឹង ចាប់បានកង្កែប ចាប់បានក្ដាមអីយកមកស្ងោហូប មានតែប៉ុណ្ណឹងទេ។ មិនដឹងទៅរកស្អីក្រៅពីហ្នឹង រកក្រៅពីហ្នឹងខុសបែបបទ ប្រធានសហករហ្នឹងអាច ឬនាំឲ្យឈ្លបហ្នឹងចាប់យើងយកទៅអប់រំទៀត។ អ៊ីចឹងអត់អាចធ្វើអីបាន"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ២២ បន្ទាត់ ១២-១៦។

[3101] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/467.1** ទំព័រ ២៣ បន្ទាត់ ១៣-១៤។

[3102] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/467.1** ទំព័រ ២៣ បន្ទាត់ ១៧-១៨។

[3103] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/467.1** ទំព័រ ២៤ បន្ទាត់ ១៣-១៤។

ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ក៏បានរម្លឹកឡើងវិញផងដែរថា ស្ត្រីម្នាក់ត្រូវបានគេព្រមានឱ្យប្រយ័ត្នខ្លួន ព្រោះត្រូវគេ "តាមដាន"[3104]។

1332. ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន បានផ្តល់សក្ខីកម្ម ដោយរៀបរាប់អំពីយប់ដែលពួកឈ្លបបង្ខំឱ្យគាត់រួមដំណេកជាមួយប្តីគាត់ថា "តែគេតាមដានខ្ញុំហ្នឹង មិនមែនតាមតែមួយយប់ហ្នឹងទេ។ គេតាមមួយយប់ហ្នឹង យើងបានសម្រេចហើយ ថ្ងៃស្អែកក៏គេមកទៀត។ គេមកហើយ ពួកខ្ញុំដឹងថាពួកគេមក ខ្ញុំដេកឱបគ្នា។ ដល់ដេកឱបគ្នាហើយ "ថាឥឡូវវាព្រមគ្នាហើយ យើងទៅខាងនោះទៀត" ប៉ុន្តែអត់ដឹងទៅខាងណាទេ គេថាតែទៅខាងនោះ។ ដល់គេទៅបាត់ហើយ ក៏នាំគ្នាដេកទៅស្ងាត់ស្ងៀម"[3105]។ ដើមបណ្តឹងរដ្ឋប្បវេណីបានរម្លឹកឡើងវិញថា "ដល់បីយប់មកទៀត បីយប់មកទៀត ឆ្លលពីជណ្តើរមើលទៅ ឃើញតែដេកឱប។ ម្ល៉ោះហើយថា "ឥឡូវស្រុះស្រួលហើយ យើងទៅទៀត" វាថាស្រុះស្រួលហ្នឹង អាឆ្លលពិលបីយប់ហ្នឹង វាមករួចហើយ។ ដល់ក្រោយមកទៀតបីយប់ទៀតហ្នឹង វាមកស្តាប់នៅក្រោមផ្ទះ តើព្រមឬក៏អត់។ ដល់មកដេកស្ងាត់ស្ងៀម វាថា "អត់អីទេទៅ យើងទៅវិញ ទៅកន្លែងផ្សេងទៀត"។ អានេះនិយាយពីរឿងដែលយើងរៀបចំរួចហើយ វាបានសម្រេចរបស់បំណងរបស់វាហើយ វាតាមដានយើង វាឈប់"[3106]។ គាត់បានពន្យល់ថា កងឈ្លបឈប់តាមដាននៅពេលពួកគេដឹងថា ពួកគាត់បានរួមដំណេកជាមួយគ្នា[3107]។

---

[3104] "បងស្រីដាំបាយនៅប្រចាំកន្លែងហ្នឹងតែម្តងហ្នឹង។ បងស្រីហ្នឹងគាត់ដាំបាយនៅនឹងកន្លែងមុខព្រួយខ្ញុំហ្នឹង។ រួចទៅគាត់ប្រាប់ខ្ញុំថា "មិត្តអ្នា ប្រយ័ត្នខ្លួនណ៎ា ព្រោះគេតាមហើយ ពួកមិត្តនោះ ថាពួកមិត្តហ្នឹងអត់ពេញចិត្តនឹងគ្រួសារទេ" និយាយប្រាប់អ៊ីចឹង។ ដល់អ៊ីចឹងទៅ ដល់យប់ឡើងខ្ញុំចាប់ស្តាប់មើល អ៊ីចឹងមែន។ សម្រិបជើងដើរទៅ ជណ្តើរប៉ុន្មានកាំ ខ្ញុំឮទាំងអស់។ ខ្ញុំរាប់មើល ឮទាំងអស់។ ទៅដល់សំងំអ៊ីចឹង ខ្ញុំសំងំចាំស្តាប់។ សំងំអ៊ីចឹងទៅ ខ្ញុំអង្គុយចាំស្តាប់មើល។ សំងំមួយសន្ទុះធំអ៊ីចឹងទៅ បានស្រាប់ឮសូរសម្រិបជើងដើរចុះមកវិញ។ គឺខ្ញុំរាប់តាមកាំជណ្តើរ ដឹងទាំងអស់ សម្រិបជើង" ។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/467.1** ទំព័រ ២៤ បន្ទាត់ ៤-១០។

[3105] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៤៦ បន្ទាត់ ១៥-១៨។

[3106] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៤៦ បន្ទាត់ ១៩-២៣។

[3107] "គេតាមដានខ្ញុំរួចហើយ ដែលខ្ញុំដេកជាមួយគ្នារួចហើយ បានគេថា "ឥឡូវវាសម្រេចហើយ យើងទៅខាងនោះទៀត"។ គេទៅតាមតែរហូតហ្នឹងឯង បើគេថាគេទៅ ចប់ពីខាងណេះហើយ គេទៅខាងនោះទៀត គេតាមតែរហូតហ្នឹងឯង"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៤៧ បន្ទាត់ ១៧-១៩។

1333. ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ បានពន្យល់ពីរបៀបដែលគាត់ដឹងថា កងឈ្លបកំពុងតាមដានគាត់ ដោយរៀបរាប់ថា "ខ្ទមហ្នឹងធ្វើមិនបានខ្ពស់ទេ មិនចូលពីក្រោមទេ គឺនៅឈរពីជញ្ជាំងហ្នឹង វាធ្លាក់ រហែករហែកពេញហ្នឹង។ យើងមិនបានថាប្រុងប្រយ័ត្នយ៉ាងណានឹងបិទបាំង។ គេឃើញ គឺក្រឡេកទៅ គឺឃើញហើយ"[3108]។

1334. ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានពន្យល់ថា "ការហើយគេតាមដាន គេនៅពី គេអើត មើលតាមបង្អួច គេឈរពីចំហៀង គេតាមដានយើងគ្រប់ជំហាន ឲ្យយើងការរួចឲ្យយើងរស់នៅជាមួយគ្នា។ គេតាមពិនិត្យគ្រប់បែបយ៉ាង គឺថាបើយប់ហ្នឹងគឺទល់តែភ្លឺ យើងចេញមកគេជួប ចេញមកក្រៅអីចឹងគឺជួបតែម្តង ដើរចេញក្រៅមកជួប។ គេ បើគេឃើញយើងចេញញឹកពេកគេសួរថា មិត្តឯងទៅណា? ខ្ញុំកាលហ្នឹង ខ្ញុំអត់មានអារម្មណ៍អីចេះស្រលាញ់ ហើយនិងពេញចិត្តអីនឹងអ្នករៀបការជាមួយ ខ្ញុំប្រាប់គាត់ថា ខ្ញុំចេញមកបត់ជើងអីចឹងទៅ ខ្ញុំភូតគាត់អីចឹងទៅ។ ខ្ញុំចេញមកសំកុកខាងក្រៅទៅ កុំឲ្យនៅក្បែរបុរសហ្នឹង"[3109]។

1335. ដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត ចាត បានផ្តល់សក្ខីកម្មថា ប្តីប្រពន្ធដែលទើបនឹងរៀបការត្រូវគេនាំទៅខ្ទមតូចមួយ ដើម្បីសម្រាកពេលយប់៖ "នាំគ្នាដេកគិតគ្នាថា បើយើងរើបម្រះទៅខ្លាចគេឮ ម្ល៉ោះ ហើយចេះតែនាំគ្នាដេកស្ងួកៗអីចឹង ទៅ មានឈ្លបគេតូចៗ គេលបចាំស្តាប់មើល គេដើរ។ មិនដឹងគេចាំស្តាប់ចាំអី ប៉ុន្តែគេដើរធ្វើទៅមកៗតាមអាផ្លូវយើង ដូចថាផ្ទះនេះមួយល្វែងៗ ប្រឡោះកណ្តាលអីចេះ គេដើរទៅដើរមកអីចឹង មិនដឹងគេដើរមានការអី ខ្ញុំអត់ដឹងដែរ ចេះតែនាំគ្នាដេកស្ងួកៗអីចឹងទៅ គិតគ្នា អត់ហ៊ាននិយាយជាមួយគ្នា សូម្បីតែខ្សឹបគ្នា ក៏មិនហ៊ាននិយាយដែរ។ ព្រោះអីយកទៅវ៉ៃ យកទៅវាងដូចស្រស់ៗពេក ខ្លាចអត់ហ៊ាននិយាយបណ្តោយ"[3110]។

1336. ដើមបណ្តឹងរដ្ឋប្បវេណី សយ ណារឿន បានរៀបរាប់ពីការតាមដានរបស់កងឈ្លប និងមានអារម្មណ៍ភ័យខ្លាច៖ "ឈ្លបគេនាំនាងខ្ញុំទៅ ចូលទៅបន្ទប់តូចៗនៅតាមរោងហ្នឹង។ ក្រោយមក

---

[3108] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៨២ បន្ទាត់ ២១-២៣។

[3109] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៥៩ បន្ទាត់ ២១ - ទំព័រ ៦០ បន្ទាត់ ២។

[3110] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៩៦ បន្ទាត់ ២០-២៥។

ទៀត នាងខ្ញុំអង្គុយឡោញក្បាលជង្គង់ គាត់ក៏សម្រាកទៅ តែនាងខ្ញុំអង្គុយឡោញក្បាលជង្គង់។ ស្រាប់តែឮសូរសម្រឹបជើងដើរព្រឹបៗចុះឡើងៗ នាងខ្ញុំភ័យខ្លាច ហែកជញ្ជាំងស្បូវលបមើល ឃើញកងឈ្លបដើរចុះដើរឡើង ប្រហែលជាប្រាំមួយ ប្រាំពីរនាក់"[3111]។ ដើមបណ្តឹងរដ្ឋប្បវេណី បានរម្លឹកឡើងវិញថា "ដោយយប់ងងឹតនាងខ្ញុំមិនបានរាប់អស់ទេ តែយ៉ាងច្រើន ប្រហែលជា ប្រាំមួយនាក់ប៉ុណ្ណោះឯង។ នាងខ្ញុំឃើញកងឈ្លបដើរមកដល់ជិតរោងនាងខ្ញុំ នាងខ្ញុំក៏បិទជញ្ជាំងហ្នឹងទៅ ហើយនាងខ្ញុំក៏ប្រះដេក ខ្លាចលោឈ្លបមកអើតមើលទៅឃើញនាងខ្ញុំអង្គុយ ខ្លាចមានបញ្ហា។ ក្រោយមកទៀត នាងខ្ញុំឮសូរសម្រឹប ដូចជារត់បន្តិច ដូចជាដើរលឿនបន្តិច នាងខ្ញុំក៏ហែកស្បូវជញ្ជាំងស្បូវមើលទៀត ស្រាប់តែក្រឡេកទៅឃើញបន្ទប់ ប្រហែលជា ចម្ងាយប្រហែលជា ៥០ ម៉ែត្រពីបន្ទប់របស់នាងខ្ញុំ"[3112]។

1337. បន្ទាប់ពីពិធីរៀបការ ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឡាង និងប្តីគាត់ត្រូវគេតាមដាន៖ "យប់ទី១ ពេលជួបគ្នានោះ ពុំបាននិយាយអ្វីទាំងអស់ ដោយសារអី? ឈ្លបៗ ហែកជញ្ជាំងខ្ទេចខ្ទីអស់ហើយ ដូចកណ្តៀរកាត់ជញ្ជាំងអ៊ីចឹង លាន់រសឹបអស់ហើយ។ ណាមួយភ័យខ្លាចគេសម្លាប់ និយាយអីមិនស្រួលខ្លាចគេយកទៅទាំងយប់ អ៊ីចឹងអត់ហ៊ាននិយាយអីទាំងអស់។ គ្រាន់តែគេង ស្ងៀមទៅទាំងអស់គ្នាតែម្តង មិនហ៊ានកម្រើកខ្លួនតែម្តង"[3113]។

1338. ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន បានផ្តល់សក្ខីកម្មថា គាត់ក៏ត្រូវគេតាមដានដែរ៖ "មានឈ្លបគេតាមដានហ្នឹង គេៗអត់បានចង់ធ្វើអីទេ ព្រោះខ្ញុំអត់បានដឹងគេកាន់អាវុធឬអីទេ ព្រោះខ្ញុំឮតែសម្រឹបជើងដើរចាស"[3114]។ "គេចង់ដឹងថាយើងចុះសម្រុងអត់"[3115]។

[3111] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ២៩ បន្ទាត់ ២៤ - ទំព័រ ៣០ បន្ទាត់ ២។

[3112] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៣០ បន្ទាត់ ២-៦។

[3113] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ចៅ ឡាង ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ៥៥ បន្ទាត់ ១១-១៤។

[3114] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៥២ បន្ទាត់ ២៤-២៥។

1339. ដើមបណ្តឹងរដ្ឋប្បវេណី សុន រុត បានផ្តល់សក្ខីកម្មអំពីការតាមដានប្តីប្រពន្ធក្រោយពេលរៀបការ ដោយពន្យល់ថា៖ "មានគេតាមដាន ដើម្បីយើងរួមដំណេកជាមួយគ្នាទៅវាស្រួលមិនស្រួល អានេះ នឹងរបាយការណ៍ទៅឱ្យគេខាងលើទៀត"[3116]។ គាត់បានធ្វើការកត់សម្គាល់ ដោយបន្ថែមថា "ដឹង តែតាមគេអ្នកតាមដាន ខ្ញុំគេសួរ -- ខ្ញុំសួរគេ គេតាមដាន គេប្រាប់ខ្ញុំថាអ៊ីចឹងដែរ។ ឱ្យតាមដាន បើយើងមិនស្រឡាញ់គ្នា ឱ្យរាយការណ៍ទៅថ្នាក់លើវិញ"[3117] "ដែលរៀបការនោះ គឺក្នុងចំណោម យោធា ហើយអ្នកអង្គភាពយោធានេះឯង គេអ្នកតាមដាន ដែលអ្នកគេជិតស្និទ្ធជាមួយមេអីទៅ គេឱ្យតាមដាន មានក្រុមគេអ្នកតាមដាន ពីរនាក់ទៅ គេចាំតាមដានពេលយើងរួមដំណេក មានផ្ទះ ខ្ទមអី មិនសូវធំប៉ុន្មានទេ ប៉ុន្តែគ្រាន់ធ្វើជាប់គ្នាទៅមួយចន្លោះៗគេឱ្យដេក ក៏ឱ្យយើងអ្នកតាមដាន យប់ទៀត។ យើងមិនស្រឡាញ់គ្នា មិនស្រឡាញ់គ្នាទៅ គេនឹងរបាយការណ៍រាយការណ៍មកថ្នាក់ លើ។ ថាយើងមិនគោរពតាមអង្គការ យើងមិនស្រឡាញ់ អង្គការរៀបឱ្យហើយយើងមិនស្រឡាញ់ គឺយើងប្រឆាំងជាមួយអង្គការ"[3118]។

1340. ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន បានផ្តល់សក្ខីកម្មពីការដែលគេតាមដានគាត់ថា៖ "ពេលនោះ គឺឱ្យតែចាប់ផ្តើមមេកងធំ និងមេកងចល័ត មេកងតូចហ្នឹង គឺគេរៀបចំហើយ គឺគេដាក់ភ្នាក់ងារ ឈ្លបហ្នឹងគឺតាមដាន។ តាមដានគ្រប់គូទាំងអស់ គឺគេមានឈ្មោះនៅក្នុងបញ្ជីរបស់គេ គឺ បែកចែកកម្លាំងចុះ។ បើយើងមិនរស់នៅជាមួយគ្នាទេ គេនឹងមានៗផែនការល្បិចកលយ៉ាងម៉េចទេ ខ្ញុំមិនហ៊ានប្រឆាំងដែរ"[3119]។ គាត់បាននិយាយបន្តថា "គ្រាន់តែគ្រាន់ថា ការរស់នៅនៅក្នុងយប់ទី១

---

[3115] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៥៣ បន្ទាត់ ២។

[3116] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន រុត ប្រតិចារឹក ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/412.1** ទំព័រ ៤ បន្ទាត់ ១១-១២។

[3117] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន រុត ប្រតិចារឹក ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/412.1** ទំព័រ ៤ បន្ទាត់ ១៦-១៧។

[3118] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន រុត ប្រតិចារឹក ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/412.1** ទំព័រ ៤ បន្ទាត់ ២១ - ទំព័រ ៥ បន្ទាត់ ១។

[3119] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ៤៩ បន្ទាត់ ១៦-១៨។

ហ្នឹង ក៏ខ្ញុំមិនបានជាប៉ះពាល់អីដែរ នៅយប់ទី២ក៏អត់បានប៉ះពាល់ដែរ រហូតទាល់តែដល់ទៅថ្ងៃយូរខាងមុខទៀត ទើបនឹងហៅថា បានមានចិត្តស្រឡាញ់ មានចិត្តអាណិត"[3120]។

1341. ដើមបណ្ដឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង បានពន្យល់ថា មនុស្សដែលគេចាត់តាំងឱ្យមកតាមដានប្ដីប្រពន្ធ "គឺអ្នកនៅក្នុងក្រុមរបស់ខ្លួនហ្នឹង គឺគេឱ្យស៊ើប យ៉ាងនេះយ៉ាងនោះ អ៊ីចឹងទៅ ឱ្យប្រាប់គេអ៊ីចឹងទៅណ៎ា។ មានហេតុផលរបៀបម៉េចៗ ប្រតិកម្មម៉េចកើតឡើង អ៊ីចឹង។ ដល់ពេលគេទទួលបានហេតុការណ៍ហ្នឹងហើយ គេក៏ហៅសាមីខ្លួនទៅព្រមាន ទៅអប់រំ ទៅណែនាំ អ៊ីចឹងទៅ"[3121]។ "និយាយរួមទៅ គឺអ្នកនៅក្នុងហ្នឹងហ្នុង។ គេឱ្យស៊ើបៗមើល ហើយសួរនាំជាពាក្យពេចន៍អ៊ីចឹងតៗគ្នាអ៊ីចឹងទៅ"[3122]។ ក្រៅពីនេះ "គ្រាន់តែឱ្យដំណឹងទៅគេ ជាព័ត៌មានទៅដល់ប្រធានគេហ្នឹងទៅខាងលើហ្នឹងទៅ គេចាត់ការតាមហ្នឹងទៅទៀតទៅ"[3123]។ "ក្នុងកងមួយៗវាមានមេកងគេអ៊ីចឹងទៅ មានអ្នកគ្រប់គ្រងអ៊ីចឹងទៅ។ អ្នកគ្រប់គ្រងហ្នឹងជាអ្នកឱ្យស៊ើប ហើយអ្នកគ្រប់គ្រងហ្នឹងជាអ្នកហៅមកអប់រំណែនាំម្ដងពីរដងអាហ្នឹងចូលព្រមានហើយ។ ទី១ គឺអប់រំ ទី២ ចាប់ផ្ដើមព្រមាន"[3124]។

---

[3120] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ម៉ី សាវឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ៤៩ បន្ទាត់ ១៩-២១។

[3121] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ៤៧ បន្ទាត់ ១៨-២១។

[3122] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ៤៨ បន្ទាត់ ១-២។

[3123] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ៤៨ បន្ទាត់ ៦-៧។

[3124] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ៤៨ បន្ទាត់ ១៣-១៥។ ពាក់ព័ន្ធនឹងមូលហេតុដើម្បីធ្វើការតាមដាន ដើមបណ្ដឹងរដ្ឋប្បវេណីបានលើកឡើងថា៖ "គេតម្រូវថា បើគេផ្គូផ្គងអ្នកណាហើយ ត្រូវតែទទួលអ៊ីចឹងណ៎ា ហើយការ ដូចថាគេចង់ឱ្យត្រូវរ៉ូវគ្នា តែបែរជាមិនត្រូវវិញ។ គេក៏មានវិធានការជាការអប់រំ ឬជាការព្រមាននៅពេលណាដែលមានការរឹងទទឹងខ្លាំងអ៊ីចឹងទៅ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ៤៨ បន្ទាត់ ១៩-២១។

1342. ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឌឿន ដែលបានទទួចថាបានរៀបចំពិធីរៀបការ ក៏បានបញ្ជាក់ដែរថា ប្តីប្រពន្ធត្រូវគេតាមដាន ដើម្បីចង់ដឹងថាតើពួកគេរួមដំណេកជាមួយគ្នាឬទេ[3125]។ អ្នកខ្លះត្រូវបាន ចាប់ខ្លួន ឬយកទៅរៀនសូត្រ ទោះបីនាពេលនេះ ដើមបណ្តឹងរដ្ឋប្បវេណីមិនដឹងថា ក្រោយមក អ្នក ទាំងនេះជួបវាសនាដូចម្តេចក៏ដោយ[3126]។

## ៤.៤. បរិយាកាសនៃការភ័យខ្លាច ពាក់ព័ន្ធនឹងការរួមដំណេក

1343. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន បានពន្យល់ថា "ខ្ញុំមិនបានស្រែក ហើយខ្ញុំមិនបានតវ៉ាតទៅ ទៀតទេ ព្រោះពេលនេះ ខ្ញុំខ្លាច។ ហើយចប់គ្នានៅត្រឹមហ្នឹងតែម្តងទៅ ឲ្យបានជួបគ្នាត្រឹមហ្នឹងតែ ម្តងទៅ ព្រោះឲ្យថាខ្ញុំស្រឡាញ់តែរហូតហ្នឹង ខ្ញុំនេះទេ គ្រាន់តែថា នៅគុំទុក្ខក្តៅជីវិតនៅក្នុងខ្លួនខ្ញុំ ខ្ញុំក្តាញ់ក្នុងចិត្តខ្ញុំ ខ្ញុំឈឺចិត្តណាស់ ដែលពេលថា គេចាប់បង្ខិតបង្ខំឲ្យរៀបគ្រួសាររហូតមកទល់ ពេលហ្នឹងហើយ ដល់ពេលសួររឿង រឿងលោកគ្រូសួរអ៊ីចឹងទៀត រឹតតែចិត្តខ្ញុំ រឹតតែខ្លោចផ្សាជា ទីបំផុត ព្រោះពេលនុំង ពេល១លំបាក ពេលវេទនាជាទីបំផុតដែលចិត្តខ្ញុំមិនស្រលាញ់"[3127]។ ដើម បណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន បានពន្យល់ថា "បើមិនបានរួមរស់ជាមួយគ្នាហ្នឹង អាពេល គេនិយាយពេលហ្នឹង គឺប្តីយើងទៅប្រាប់គេហើយ បើវាមិនបានដេកជាមួយយើង យើងមិនទៅ ប្រាប់គេ។ ប្រាប់គេថា ខ្ញុំអត់បានរួមរស់ជាមួយនឹងសមមិត្តហ្នឹងទេ។ ពីដើមគេមិនមែន អូន-បង ទេ ហៅសមមិត្តហ្នឹងទេ"[3128]។

1344. ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប បានផ្តល់សក្ខីកម្មថា "នាងខ្ញុំខ្លាចមែននុំង បើមិនខ្លាចណា បើគេ បង្ខំហើយ ហើយដល់រៀបការហើយនៅតែមិនព្រមទៀត ក៏ខ្លាចដែរនុំង។ ដឹងគេយកសម្លាប់ យក

[3125] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឌឿន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/361.1** ទំព័រ ៨០ បន្ទាត់ ២១-២៥។

[3126] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប្រាក់ ឌឿន ប្រតិចារឹក ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៥ ឯកសារ **E1/361.1** ទំព័រ ៨១ បន្ទាត់ ៣-៧។ *សូមមើលផងដែរ* ឧបសម្ព័ន្ធ ឆ៖ កាលបរិច្ឆេទនៃការដាក់បង្ហាញភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែល ជាជនរងគ្រោះដោយប្រយោលនៃការរៀបការដោយបង្ខំនៅពេលសវនាការ។

[3127] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៤៥ បន្ទាត់ ១២-១៧។

[3128] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៤៨ បន្ទាត់ ២២-២៤។

ធ្វើអីអត់ដឹង ប៉ុន្តែចេះតែខ្លាចទៅ"[3129]។ "ខ្លាចឈ្លប ខ្លួនខ្ញុំផ្ទាល់ណាខ្លាចប្តី មួយទៀតខ្លាចឈ្លបទៀត ម្ល៉ោះហើយសុខចិត្តនាំគ្នាសម្ងំ អត់ហ៊ានមាត់ ហ៊ានកអីទាំងអស់"[3130]។ នៅពេលនិយាយពីការរួមដំណេកជាលើកដំបូង ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប បានផ្តល់សក្ខីកម្មថា "ជាជម្រើសរបស់ខាងបុរស"[3131] ដោយពន្យល់ថា "បើសិនជាឈ្លបតាមដានបានដឹងគូណាមិនត្រូវគ្នា គឺគេយកទៅកសាង។ គឺគេហៅយើងទៅកសាងតែម្តងអាហ្នឹង ឲ្យតែឈ្លបគេដឹង"[3132]។

1345. ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន បានរៀបរាប់ថា "កាលដែលកាលណារួមភេទនឹងគាត់ ដូចជាបង្ខំចិត្តខ្លួនឯងដែរ។ បើសិនជាយើងរើរុះ វានាំឲ្យមានរឿងហេតុ ម្ល៉ោះហើយក៏សុខចិត្តទៅ។ ក្នុងបីខែកន្លះហ្នឹង គេមក ហើយគេចូលមករួមភេទជុំយើង"[3133]។

1346. ដើមបណ្តឹងរដ្ឋប្បវេណី សយ ណារឿន បានពន្យល់ពីរបៀបដែលគាត់ "ក្រឡេកទៅឃើញកងឈ្លបខាងមុខពីរ ខាងក្រោយមិនដឹងជាប៉ុន្មានទេ ច្រើន នាំមួយគូដើរចេញពីរោងសម្រាកហ្នឹងចេញទៅ។ ទៅឆ្ងាយណាស់ ដល់ពេលកងឈ្លបហ្នឹងជូនមួយគូហ្នឹងចេញពីរោងទៅបាត់ នាងខ្ញុំអង្គុយចាំមើលគឺយូរ ប្រហែលជាកន្លះម៉ោងក្រោយមក បានឃើញពួកឈ្លបត្រឡប់មកវិញ តែអត់ឃើញអ្នកដែលគូប្តេជ្ញាពីក្បាលព្រលប់ហ្នឹងទេ។ នាងខ្ញុំគិតសន្និដ្ឋានថា អ្នកគូនោះប្រហែលជាមិនចុះសម្រុងគ្នា ឬយ៉ាងម៉េចបានជា គេនាំចេញពីខ្ទមហ្នឹង។ ក្រោយមកទៀត ឈ្លប ពួកឈ្លបនៅតែដើរឈ្លបដដែល។ មិនបានប៉ុន្មាននាទីផង ក៏នាំមួយគូទៅទៀត។ ដល់ត្រង់នេះខ្ញុំមានអារម្មណ៍ថា ជីវិតខ្ញុំថ្ងៃទៅមុខទៀត ខ្ញុំក៏សុខចិត្ត នឹកគិតថា ខ្លួនញ៉ាំទទ្រាក់ដូចកូនសត្វយ៉ាងម៉េចក៏ដោយចុះ ខ្ញុំក៏សុខចិត្តព្រម

[3129] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៨០ បន្ទាត់ ២០-២១។

[3130] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥៧ បន្ទាត់ ២៥ - ទំព័រ ៥៨ បន្ទាត់ ១។

[3131] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥៨ បន្ទាត់ ១៥។

[3132] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥៨ បន្ទាត់ ២០-២១។

[3133] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៦៦ បន្ទាត់ ២៤ - ទំព័រ ៦៧ បន្ទាត់ ១។

ប្រគល់ខ្លួនឱ្យប្ដីនាងខ្ញុំនៅយប់ទី១ ដោយសារនាងខ្ញុំឃើញឈ្លបបណ្ដើរចេញពីរោង ដល់ទៅពីរគូ នាងខ្ញុំភ័យណាស់ នាងខ្ញុំមានអារម្មណ៍ខ្លាច"[3134]។

1347. ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន បានរៀបរាប់ថា "នាងខ្ញុំមានអារម្មណ៍ញ័រ មានអារម្មណ៍ចុកណែនក្នុងខ្លួនដើមទ្រូងរបស់ខ្ញុំ ចង់គាំងបេះដូងដុំៗ ដោយមួយជីវិតខ្ញុំ តាំងពីខ្ញុំដឹងក្ដីមក ខ្ញុំពុំដែលជួបប្រទះ ខ្លួនខ្ញុំជាស្ត្រីខ្មែរមួយរូប អ្វីៗក៏វាមិនសំខាន់ដល់ស្មើនឹងខ្លួនរបស់នាងខ្ញុំដែរ។ តែនាងខ្ញុំសុខចិត្តញ័រញាក់ ដូចកូនសត្វយ៉ាងណាក៏ដោយ ក៏នាងខ្ញុំសុខចិត្តថានៅស្ងៀម ដើម្បីឱ្យប្ដីបម្រើទៅតាមចំណង់ចំណូលចិត្តរបស់គាត់រួមភេទ ព្រោះគាត់បានប្ដេជ្ញាចិត្តនៅមុខអង្គការ។ នាងខ្ញុំមានអារម្មណ៍ឈឺចាប់ណាស់"[3135]។

1348. ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ បានពន្យល់ថា គាត់ "បានសិក្សាខាងគុណធម៌ច្រើន អ៊ីចឹងទោះបីល្អ អាក្រក់យ៉ាងម៉េច ចាប់ដៃគ្នាហើយគឺត្រូវតែស្រឡាញ់"[3136] និង "បាទ យើងព្រម [រួមដំណេក]"[3137]។

1349. ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ សាមឿន បានពន្យល់ពីមូលហេតុដែលគាត់ចាត់ទុកជារឿងសម្ងាត់ដែលថា គាត់មិនបានរួមដំណេកជាមួយប្ដីគាត់៖ "ព្រោះខ្លាចគេដឹងចាស។ ត្រូវតែលាក់ការណ៍ ខ្លាចដឹងព្រោះខ្ញុំ និង -- ខ្ញុំត្រូវ -- គេថាឪពុកខ្ញុំជាប៉ូលិស ឪពុកចុងជាទាហាន គឺគេថាខ្ញុំ១៧មេសា។ អ៊ីចឹងខ្ញុំត្រូវតែលាក់ការណ៍សម្ងាត់រឿងនេះ កុំឱ្យគេដឹង ខ្លាចគេយកខ្ញុំទៅធ្វើបាប"[3138]។ គាត់បានបំភ្លឺបន្ថែមថា "អត់បានរួមដំណេកទេ ព្រោះខ្ញុំខ្លាច ខ្ញុំធម្មតា ស្រីយើងមិនមែនការភ្លាម រឹបភ្លាមទេ។ ខ្ញុំ

---

[3134] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៣០ បន្ទាត់ ៧-១៥។

[3135] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៣០ បន្ទាត់ ១៩-២៣។

[3136] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/340.1** ទំព័រ ៥៦ បន្ទាត់ ៣-៤។

[3137] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មាន លឿយ ប្រតិចារឹក ថ្ងៃទី ២ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/340.1** ទំព័រ ៥៦ បន្ទាត់ ៧។

[3138] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៥៣ បន្ទាត់ ៦-៨។

ញ៉ូរដៃញ៉ូរជើងណាស់ ខ្ញុំខ្លាច ខ្ញុំឲ្យប្ដីខ្ញុំលាក់ការណ៍ថា ឲ្យលាក់ការណ៍ឲ្យជិតទៅ"[3139]។ គាត់បាននិយាយបន្តថា "ខ្ញុំអត់ដឹងមានអ្វីកើតឡើងទេ បើគេដឹងចាស។ កាលហ្នឹងខ្ញុំប្រាប់ប្ដីខ្ញុំថា ខ្ញុំភ័យណាស់ទើបតែការហើយអ៊ីចឹង ខ្ញុំខ្លាចណាស់ កុំប៉ះពាល់ខ្ញុំ។ អ៊ីចឹងនាំគ្នាលាក់ការណ៍សិនទៅកុំឲ្យគេដឹង"[3140]។

1350. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន បានពន្យល់ថា "ពេលរឿងរួមដំណេក រួមអីហ្នឹង បើសិនជានៅស្រែក នៅតែថាមិនទេអីមិនទេ ក៏គេយកខ្ញុំសម្លាប់ចោល ទៅធ្វើម៉េច"[3141]។

1351. ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធារី បានពន្យល់ថា "វិធានការគេមាន។ គេហៅទៅកសាងពីរបីសារាប់មិនអស់មិនហើយហ្នឹង គេថាត្រូវតែសម្លាប់ចោល បើមិនព្រមធ្វើគ្នា"[3142]។ នៅទីបំផុត ចំណុចនេះធ្វើឲ្យគាត់យល់ព្រមរួមដំណេក ដោយផឹកស្រាឲ្យស្រវឹង៖ "គេឲ្យស្រាមក ខ្ញុំផឹកពីរនាក់ប្ដីប្រពន្ធខ្ញុំទៅ ក៏បានទៅជាមួយគ្នាទៅ"[3143]។ ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធារី បានសង្កត់ធ្ងន់ដោយពន្យល់ថា គាត់រួមដំណេក "ខ្ញុំគ្មាននិស្ស័យជាមួយស្រីញីទេ ... ខ្លាចងាប់តែប៉ុណ្ណឹងទេ"[3144]។

1352. ចំពោះផលវិបាកនៃការបដិសេធមិនព្រមរួមដំណេក ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ បានពន្យល់ថា គាត់បានទៅសួរមេកង "គាត់ថា៖ "បើសិនជារៀបការហើយ គេកសាង មិត្តឯង ទៅជាមួយដង យប់ទី១ យប់ទី២ គេកសាង តែយប់ទី៣ គឺគេសម្លាប់មិត្តឯងចោលហើយ" ហ្នឹង

---

[3139] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៥៣ បន្ទាត់ ១១-១៣។

[3140] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជុំ សាមឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ ២០១៥ ឯកសារ **E1/321.1** ទំព័រ ៥៣ បន្ទាត់ ១៩-២០។

[3141] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៤៥ បន្ទាត់ ៦-៧។

[3142] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/463.1** ទំព័រ ២២ បន្ទាត់ ៣-៤។

[3143] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/463.1** ទំព័រ ២២ បន្ទាត់ ៤-៥។

[3144] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/463.1** ទំព័រ ២១ បន្ទាត់ ៩-១១។

មាន"[3145]។ ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ បានពន្យល់បន្ថែមថា ក្នុងរបបនោះ "ឃ្លាសម័យនុំង គឺដូចគាត់និយាយអីចឹង បើមិនស្រឡាញ់ គឺមិនដេក គេសម្លាប់ក្នុងពេលហ្នឹង គេធ្វើបាបទារុណកម្ម"[3146]។

1353. ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម បានផ្តល់សក្ខីកម្មថា "មានតែគេចាំតាមដានយើង។ បើយើងអត់បានរួមដំណេកជាមួយហ្នឹង គឺគេតាមដានយើងរហូតហ្នឹង។ ហ្នឹងហើយ មានតែប៉ុណ្ណឹងយើងខ្លាចគេ ដូច្នេះ យើងត្រូវរួមដំណេក បាន៣ថ្ងៃ បានរួមដំណេក យូរដែរ។ បាទ មិនមែនថា អូ! ភ្លាមៗរួមដំណេកទេ នៅគិតច្រើន បាទ នៅគិតច្រើន។ ៣ថ្ងៃបានៗរួមដំណេក។ បើមិនរួម គេមក។ មានអ្នកតាមដានមករហូត"[3147]។ "យើងត្រូវគោរពគេ។ បើយើងមិនគោរព មានតែស្លាប់ ឬមួយយ៉ាងម៉េច គេធ្វើទារុណកម្មយើង"[3148]។

1354. ដើមបណ្តឹងរដ្ឋប្បវេណី សយ ណារឿន បានពន្យល់ថា "នាងខ្ញុំគិតថា បើសិនខ្ញុំមិនរួមរស់ជាមួយប្តី គឺនាងខ្ញុំមិនដឹងជាទៅដល់ដំណាក់កាលណាទេ គេយកនាងខ្ញុំទៅសម្លាប់ចោលក៏មិនដឹងទេ ព្រោះនាងខ្ញុំប្រកែកម្តង ជាពីរដងហើយអីចឹង។ ដល់ពេលអីចឹង ហើយណាមួយ ខ្ញុំឃើញឈ្លបនាំទាំងគូៗទៅ នឹងភ្នែកៗខ្ញុំ"[3149]។

## ៤.៥. ការគំរាមកំហែងបើសិនមិនរួមដំណេក

1355. ដើមបណ្តឹងរដ្ឋប្បវេណី ស៊្វ សុធារី បានផ្តល់សក្ខីកម្មថា "យប់ដំបូងហ្នឹង គឺអត់បានរួមដំណេកជាមួយប្រពន្ធដែរ ខានរហូតទាល់តែគេយកទៅរៀនសូត្ររាប់ៗ ថាសឹងតែថារាប់អាទិត្យ

---

[3145] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៦៤ បន្ទាត់ ១០-១២។

[3146] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៦៦ បន្ទាត់ ៨-៩។

[3147] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៧៧ បន្ទាត់ ៤-៧។

[3148] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៧៧ បន្ទាត់ ១៣-១៤។

[3149] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៣៧ បន្ទាត់ ៥-៧។

ហើយ"[3150]។ "គេខាងនារីៗ គេនិយាយគ្នាគេ។ ខាងខ្ញុំឯណោះ ថាបើអ្នែងមិនព្រមដេកទេ គង់តែថ្ងៃណាមួយស៊ើបការណ៍ដឹង កម្មេចអ្នែងចោល"[3151]។ "មានថ្ងៃមួយ ប្រធានភូមិដែលគាត់ស្រឡាញ់ខ្ញុំរាប់អានខ្ញុំទុកដូចជាបងប្អូនកូនក្មួយគាត់ហើយ គាត់ឱ្យស្រាខ្ញុំ ពីរនាក់ប្ដីប្រពន្ធខ្ញុំហ្នឹងយកមកអង្គុយផឹកទល់មុខគ្នា បានស្រវឹងជប់ៗទៅ។ ថា រដ្ឋា ថ្ងៃនេះ បើយើងមិនរួមដំណេកជាមួយគ្នាទេ យើងពិបាកនឹងរស់ហើយ យើងមិនដឹងងាប់ថ្ងៃណាទេ គេតាមដានរាល់ថ្ងៃ យើងកុហកគេ វាអស់ពាក្យកុហកហើយ។ ប្រពន្ធក៏ឆ្លើយតបវិញថា ពូសុខជា ធ្វើម៉េចធ្វើចុះឱ្យតែបានរស់។ ពេលស្រវឹងហ្នឹងហើយ ដែលខ្ញុំភ្លេចភ្លាំងស្មារតី ដូចពាក្យចាស់លោកថា ទឹកប្ដូរអារម្មណ៍អ៊ីចឹង ពេលហ្នឹងលែងដឹងថាប្រុសថាស្រីហើយ ក៏បានហើយយប់ហ្នឹងម្ដងទៅ"[3152]។

1356. ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន និងប្ដីគាត់បានពិភាក្សាគ្នាធ្វើពុតជាចុងសម្រុងនឹងគ្នា ហើយថាក្រោយមក ប្រសិនបើពួកគាត់មិនយល់ព្រម ពួកគាត់អាចបែកគ្នាបាននៅពេលកម្ពុជាមានសន្តិភាពឡើងវិញ៖ "ដល់ល្ងាច គេឮសូរថាអ៊ីចឹង គេឡើងភ្លែតមក ស្រមកបីនាក់បណ្ដោយ។ ឡើងមកបីនាក់ហើយ គេថា មិនព្រមទៀត នៅចាំបែកគ្នាដល់ណាទៀត។ រួចមក គេយកកាំភ្លើងមកភ្ជង់ ដោះអាវ ខាងប្រុសក៏ដោះអាវ ខាងស្រីក៏ដោះអាវឱ្យអស់ ដើម្បីរួមដំណេកជាមួយគ្នា"[3153]។ "គេល្ពបគេមានពិល ដល់ហើយ ទាំងពីរនោះក៏ដោះអាវ ដោះខោទៅតាមគេ ចុះគេមានកាំភ្លើង យើងអត់ទៅស៊ូនឹងម៉េចរួច។ ហើយដោះខោដោះអាវហើយ។ ដល់រួចហើយមិនព្រមនឹងដេកជុំគ្នាទេ។ ដល់រួចហើយ ដល់វាថាឱ្យឆាប់ដេកជាមួយគ្នា។ រួចហើយវាឆ្លុលពិល វាឆ្លុលពិល មើលយើងហើយវាចាប់ប្រដាប់ប្រដាមនុស្សប្រុសដាក់មកជាមួយយើង។ វាដូចចាប់ដាក់បាយជ្រូកអ៊ីចឹង។ ខ្ញុំមាន

---

3150 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធាវី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/462.1** ទំព័រ ៧៤ បន្ទាត់ ១-២។

3151 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធាវី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/462.1** ទំព័រ ៧៤ បន្ទាត់ ៦-៨។

3152 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធាវី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/462.1** ទំព័រ ៧៤ បន្ទាត់ ៩-១៥។

3153 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៤៦ បន្ទាត់ ១-៤។

សេចក្តីខ្មាសអៀនយ៉ាងខ្លាំង"[3154]។ ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន បានផ្តល់សក្ខីកម្មថា "ក្នុងពេលនោះមក ខ្ញុំមានអារម្មណ៍អៀនខ្មាស ចុកចាប់ក្នុងចិត្តខ្ញុំ ចុកចាប់ខ្លាំងមែនទែន ប៉ុន្តែខ្ញុំចង់តវ៉ាជុំគេដែរ ប៉ុន្តែខ្ញុំអត់ហ៊ាន ខ្លាចគេសម្លាប់ចោល។ ម្ល៉ោះហើយការខ្មាសអៀនទាំងអស់នេះ ខ្ញុំឆាចោលថាក្តីអាម៉ាស់របស់ខ្ញុំនេះ ក្នុងមួយជីវិតខ្ញុំនេះ សំណាងអាក្រក់ដែលមកជួបហេតុការណ៍បែបនេះ"[3155]។

1357. ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ បានផ្តល់សក្ខីកម្មថា "[សមមិត្ត អ៊ុំ] ប្រាប់ខ្ញុំថាមានឈ្លបលបចាំមើលនៅខាងមុខ ហើយអ្នកឯងអត់បានដេកជាមួយគ្នាទេ គេដឹងទៀត..."[3156]។ បន្ទាប់មក "គាត់ថា បានយប់ទី១ និងយប់ទី២ យប់ទី៣ ប្រយ័ត្នស្លាប់ខ្លួន"[3157]។

1358. ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត បានពន្យល់ថា "អានេះគេតាមថ្នាក់លើ គេយកទៅអប់រំ។ បើស្រីមិនស្រឡាញ់ ប្រុសស្រឡាញ់ អានេះគេអប់រំ អប់រំស្រី។ ថាយើងមិនគោរពទៅតាមអង្គការ បទបញ្ជាការរៀបចំ គូ ប្រគូឲ្យគឺយើងមិនគោរព គឺគេអប់រំ ឲ្យយើងស្តាប់បទបញ្ជារបស់អង្គការ"[3158]។

1359. ដើមបណ្តឹងរដ្ឋប្បវេណី ជា ឡៅប បានរម្លឹកឡើងវិញថា "បីគូនៅជាមួយខ្ញុំ នៅជាមួយខ្ញុំបីគូ ខ្ញុំឃើញគូមួយៗអត់ត្រូវគ្នាដែរ ប៉ុន្តែពេលដែលឈ្លបតាមដាន គាត់ចេះសំងំដែរ គាត់អត់ហ៊ានមាត់

[3154] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៥៦ បន្ទាត់ ៤-៨។ ដើមបណ្តឹងរដ្ឋប្បវេណីបានរម្លឹកឡើងវិញថា "ដល់ក្មេងអាយុប៉ុណ្ណឹងហើយ វាហ៊ានធ្វើប្រព្រឹត្តមកលើយើងអាយុច្រើនជាងវា។ ដល់អាកាលណាវាបំណងវាបានធ្វើរួចសម្រេចហើយ វានិយាយថា "ទៅ! យើងទៅតាមអាខាងនោះទៀត អាខាងនេះវាចុយគ្នាបានហើយ យើងទៅខាងនោះទៀត។" នេះខ្ញុំសូមប្រាប់ភាពអាម៉ាស់នេះ ខ្ញុំចាំមួយជីវិត ខ្ញុំចងចាំទាល់តែខ្ញុំស្លាប់ ក៏ខ្ញុំអត់ភ្លេចដែរ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៥៦ បន្ទាត់ ៨-១២។

[3155] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៦៣ បន្ទាត់ ៦-៩។

[3156] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៦៧ បន្ទាត់ ៨-១០។

[3157] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៦៧ បន្ទាត់ ១៤។

[3158] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន វុត ប្រតិចារឹក ថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/412.1** ទំព័រ ៥ បន្ទាត់ ៦-៨។

ដែរ។ គាត់សំងំទាំងអស់គ្នាអត់ហ៊ានមាត់ហ៊ានកអីទេ។ ដល់ថ្ងៃក្រោយមក ដល់គេ -- គាត់ ប្ដី គាត់មិនពេញចិត្តប្រពន្ធ ប្ដីជាជនជាតិភាគតិច ប្រពន្ធខ្មែរ។ ដល់ពេលគាត់មិនពេញចិត្តអ៊ីចឹងទៅ ថ្ងៃក្រោយមកយូរខែយូរថ្ងៃដែរ យូរថ្ងៃដែរ បានប្រពន្ធគាត់ហ្នឹងរាយការណ៍ប្រាប់អង្គការ។ ប្រាប់អង្គការទៅ អង្គការយកគាត់ទៅអប់រំ អប់រំម្ដងជាពីរដងអ៊ីចឹង។ អប់រំពីរបីដង គាត់នៅតែមិនព្រមយក គាត់មិនស្រឡាញ់មនុស្សស្រីហ្នឹងទេ គាត់ប្រុសទេ អត់ស្រឡាញ់ស្រីនោះ។ ដល់ពេលយូរទៅដល់ញយដងពេក ខាងប្រុសហ្នឹង គាត់ឆ្លើយថាប្រដាប់គាត់ងាប់។ ដល់ឆ្លើយថាប្រដាប់គាត់ងាប់ ពេទ្យហ្នឹងយកទៅព្យាបាលនៅត្រង់ គ-៩ ហ្នឹង នៅមន្ទីរ គ-៩ ហ្នឹង យកទៅព្យាបាលនៅហ្នឹង ហើយឱ្យប្រពន្ធហ្នឹងទៅនៅប្រើ ទៅបម្រើដឹងប៉ុន្មានថ្ងៃ ខ្ញុំមិនបានដឹងទេ គ្រាន់តែដឹងថា គាត់ទៅដេកពេទ្យហ្នឹងទាំងប្ដីទាំងប្រពន្ធហ្នឹង។ ដល់ក្រោយមកទៀត ក៏ប្ដីហ្នឹងគេអប់រំច្រើនដងទៀត គាត់ក៏ព្រមយកប្រពន្ធហ្នឹងទៅ។ ហ្នឹងតាមខ្ញុំដឹង។ យកប្រពន្ធហ្នឹងទៅ ក្រោយមកគាត់មានកូន ពោះធំៗ បានកូនមួយ កូនប្រុស។ រយៈកូនហ្នឹងមិនទាន់ចេះដើរផង ប្រពន្ធនុ៎ងក៏ស្លាប់ទៅ”[3159]។

1360. ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានផ្ដល់សក្ខីកម្មថា គេបញ្ជូនទាំងប្ដីទាំងប្រពន្ធទៅអប់រំ ក្រោយពេលប្ដីប្រកែកមិនព្រមរួមដំណេក៖ “កាលនុ៎ង បងអឿន គេឱ្យរៀបការជាមួយ បងមាន។ បងមាន ហ្នឹងគាត់ធាត់ មាឌធំ អត់សមរម្យ គាត់ថា គាត់អត់ស្រឡាញ់ បងអឿន គាត់ស្អាត។ ដល់អ៊ីចឹង គេរៀបឱ្យៗរៀបជាមួយ បងមាន ហ្នឹង។ ដល់ បងមាន ហ្នឹង គាត់ស្រឡាញ់បុរសហ្នឹង ព្រោះគេរៀបឱ្យ គាត់មានអារម្មណ៍ស្រឡាញ់ ក៏ប៉ុន្តែបុរសហ្នឹងមិនស្រឡាញ់គាត់ ដូចថា តែតាមខ្ញុំស្ដាប់ព័ត៌មានពី បងមាន គាត់និយាយ គាត់ថា បើគេឱ្យទៅដេកជាមួយ គាត់ចងអង្រឹងដេក។ ហើយ បងមាន គាត់ដេកនៅនឹងរោងហ្នឹងទៅ គាត់ចងអង្រឹងដេកតាមសសរចម្រឹងហ្នឹងទៅ។ អ៊ីចឹងគាត់ពីរនាក់ហ្នឹង អត់បានត្រូវគ្នាទេ។ ដល់ក្រោយមក អង្គការដឹងទៅ គេហៅអប់រំ”[3160]។

## ៤.៦. ទណ្ឌកម្មចំពោះការប្រកែកមិនព្រមរួមដំណេក

---

[3159] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឡៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៧៩ បន្ទាត់ ២០ - ទំព័រ ៨០ បន្ទាត់ ៧។

[3160] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៩ បន្ទាត់ ២០ - ទំព័រ ១០ បន្ទាត់ ១។

### *ការរំលោភផ្លូវភេទជាទណ្ឌកម្មចំពោះការប្រកែកមិនព្រមរួមដំណេក - ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន*

1361. បន្ទាប់ពីគាត់ប្រកែកមិនព្រមរួមដំណេកនៅលើកដំបូង ប្ដីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន "ចេញមកប្រាប់ប្រធាន"[3161] គឺ សមមិត្ត ផាន់[3162]។ "គេទៅប្ដឹងថា នាងខ្ញុំហ្នឹងអត់រួមដំណេកជាមួយ ហើយគេទៅប្ដឹងទៅ នែ! សមមិត្ត ផាន់ ហ្នឹង ហៅខ្ញុំទៅ"[3163]។ បន្ទាប់ពីប្ដីគាត់ទៅប្ដឹងដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មថា "ហៅទៅចូលបន្ទប់មួយរៀងស្ងាត់តែឯង។ ដល់ទៅហៅនាងខ្ញុំទៅដល់ វា ទៅដល់សួរថា "ម៉េចបានមិនព្រមយកគេអ៊ីចឹង?" ហើយគេគ្មានសួរអីវែងទេ វាប្រតាយប្រតប់ជាមួយខ្ញុំ ចាប់ខ្ញុំរំលោភនៅហ្នឹងនៅឯង។ វាធ្វើបាបរាងកាយរបស់នាងខ្ញុំយ៉ាងផ្អែត។ ធ្វើឲ្យខ្ញុំតូចចិត្តទាល់តែថ្ងៃហ្នឹងឯង"[3164]។ "គេនិយាយថា បើសិនជាគេចាប់ហើយ បើសិននិយាយតទៅផ្សេងទៀត គេអាចបំបិទមាត់យើងចេញ គេបាញ់យើងគ្រវាត់ចោល ហើយគេវៃចោលអ៊ីចឹងទៅ។ ចំណែកប្ដីត្រូវតែយកវិញ។ ឲ្យរៀបការជាមួយប្ដីហ្នឹងហើយ ហើយឲ្យយកប្ដីហ្នឹងថែមវិញទៅ អត់មាននេះទេ គេចាប់រំលោភហើយ កុំឲ្យនិយាយប្រាប់អ្នកណាឲ្យសោះ"[3165]។ "ប្រើពាក្យខ្លាំងៗ របៀបប្រើពាក្យឃោធាអ៊ីចឹង ដល់ពេលប្រើទៅ យើងមិនអាចប៉ានតទៅទៀតព្រោះយើងខ្លាច។ អ៊ីចឹងទ្រាំទៅ អាចយកចិត្តខ្លួនឯងខាំមាត់សង្កត់ចិត្តសុខចិត្តយំ ខាំមាត់ខ្លួនឯង

---

[3161] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៥ បន្ទាត់ ៧។

[3162] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៥ បន្ទាត់ ៩។

[3163] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៥ បន្ទាត់ ១៥-១៦។

[3164] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៥ បន្ទាត់ ២២-២៤។

[3165] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៦ បន្ទាត់ ៤-៧។

ដើម្បីសម្រេចថាកុំឲ្យវាមានបញ្ហា កុំឲ្យ-- ខ្លាចគេវៃចោលអ៊ីចឹង ព្រោះមួយជំនាន់ហ្នឹង បើសិនជាខ្ញុំមាត់ ឡូឡា គឺអត់បានទេ”[3166]។

***ប្ដីជាអ្នករំលោភផ្លូវភេទ ក្រោយពេលប្រកែកមិនព្រមរួមដំណេក - ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន***

1362. ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានផ្ដល់សក្ខីកម្មថា “កាលដែលគាត់បង្ខំឲ្យខ្ញុំរួមរក្ស គាត់ពេលហ្នឹងគាត់ ថ្ងៃហ្នឹង ... ដល់ដេកលក់ទៅ គាត់ឱបខ្ញុំ ដល់ខ្ញុំរើបម្រះ រករត់រកអី អ៊ីចឹងទៅ គាត់ចាប់ខ្ញុំរំលោភ ដូចថា បើនេះទៅគាត់ដោះអាវ ដោះខោខ្ញុំទៅ គាត់ហែកខោខ្លីខ្ញុំហ្នឹងទៅ ហើយទៅគាត់ទាញបណ្ដាច់ឡេវអាវខ្ញុំ ខ្ញុំខំយកដៃខ្ទប់អ៊ីចេះ គាត់ថា ប្ដីប្រពន្ធសោះ នែ៎អង្គការសម្លាប់ចោលងាប់ទាំងអស់គ្នា។ គាត់សម្លុតខ្ញុំដែរ គាត់គំរាមខ្ញុំដែរ”[3167]។ “ខ្ញុំក៏យំ ខ្ញុំស្រែកទៅ។ គាត់ថា កុំស្រែកខ្មាស់គេ យើងប្ដីប្រពន្ធទេ។ អាហ្នឹងលើកទី១ ដំបូង”[3168]។

1363. ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានរៀបរាប់ថា “ខ្ញុំយំផងអីផងទៅ ខ្ញុំថា ឪខ្ញុំមិនឲ្យគេធ្វើអ៊ីចឹងទេ ព្រោះត្បិតអី ឪខ្ញុំហាមណាស់ ខ្ញុំស្រី មិត្តឯងប្រុស មកធ្វើអីខ្ញុំអ៊ីចឹង។ គាត់ថា អត់ទេ អានេះគឺទិសដៅរបស់អង្គការទេ អ៊ីចឹងគាត់ត្រូវធ្វើទៅតាមទិសដៅអង្គការ។ ខ្ញុំយំរហូតទល់តែភ្លឺ”[3169]។

---

[3166] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៦ បន្ទាត់ ១១-១៤។

[3167] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៦៧ បន្ទាត់ ៤-៨។

[3168] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៦១ បន្ទាត់ ២៤។

[3169] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៦៧ បន្ទាត់ ៨-១០។ ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានពន្យល់ថា គាត់ “មិនដឹងថា អង្គការគេអ្នកឲ្យធ្វើឬអត់ទេ ព្រោះកាលណាដែលគាត់ទៅធ្វើលើខ្ញុំហ្នឹង ដូចយើងមនុស្សកំរោលដែរហ្នឹង គាត់ទៅបំពារបំពានលើខ្ញុំដើម្បីសម្រាប់គោលបំណងគាត់ដែរ។ ប៉ុន្តែខ្ញុំមិនបានដឹង ប៉ុន្តែដល់ពេលខ្ញុំយំស្រែក គាត់ថា ទិសដៅរបស់អង្គការ គេឲ្យយើងរស់នៅអ៊ីចឹង។ បើយើងនៅតែមិនអ៊ីចឹង យើងគឺត្រូវតែស្លាប់ទាំងអស់គ្នា។ អ៊ីចឹងខ្ញុំមិនដឹងថា អង្គការគេប្រើគាត់ធ្វើ ឬក៏គាត់ធ្វើខ្លួនគាត់

1364. ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មអំពីការឈឺចាប់ផ្លូវកាយ និង ផ្លូវចិត្ត ដោយសារការរំលោភផ្លូវភេទ និងការរៀបការដោយបង្ខំ៖ "ពេលហ្នឹងខ្ញុំឈឺចាប់ទាំងផ្លូវចិត្ត ទាំងផ្លូវកាយ។ ទី១ ការរួមរស់ដែលយើងមិនដែលធ្លាប់ ធ្វើឲ្យចុកចាប់នៅលើរាយកាយរបស់ខ្លួន។ ហើយទី២ ចុកចាប់លើផ្លូវចិត្តដែលខ្ញុំមិនមានបំណងកសាងអនាគតប្ដីសីសោះ។ ដល់អីចឹងខ្ញុំមានតែសេចក្ដីយំស្រែក ស្ដាយ។ ណាមួយគឺថាក្បត់នឹងបណ្ដាំឪពុកផង អីចឹងធ្វើឲ្យអារម្មណ៍ខ្ញុំហ្នឹងណា ឈឺចាប់ក្នុងការរួមរក្សហ្នឹងផង ឈឺចាប់ផ្លូវចិត្តផង ធ្វើឲ្យខ្ញុំដេកមិនលក់ ហូបបាយមិនឆ្ងាញ់។ ដល់អីចឹង វាឲ្យប្រែអាកាសធាតុខ្ញុំទៅជាស្លេកស្លាំង"[3170]។

### *ការរំលោភផ្លូវភេទ និង ការធ្វើបាបក្រោយពេលពិធីរៀបការ - ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់*

1365. ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ បានរម្លឹកឡើងវិញនូវព្រឹត្តិការណ៍នានាដែលបានលាតត្រដាងរយៈពេលបីយប់ ក្រោយពេលពិធីរៀបការរបស់គាត់។ នៅយប់ដំបូង ដើមបណ្ដឹងរដ្ឋប្បវេណីត្រូវបានគេកសាង[3171] និងបានស្ដាប់ឮពួកឈ្លបណែនាំប្ដីគាត់ឲ្យរួមដំណេក[3172]។ "គេបានចាប់ដៃខ្ញុំគក់ខ្ញុំ ហែកខោហែកអាវនាងខ្ញុំ ប៉ុន្តែថ្ងៃនុំង ខ្ញុំបានស្លៀកខោពីរជាន់មានលោកប្រធាន ហើយអាវគេ

ទេ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៦៧ បន្ទាត់ ១៤-១៨។

[3170] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៦៧ បន្ទាត់ ២០-២៤។

[3171] ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ បានផ្ដល់សក្ខីកម្មថា "យប់ទី១ គេកសាងខ្ញុំ"។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៦៦ បន្ទាត់ ៩។

[3172] ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មថា "យប់ទី១ ឈ្លបប្រាំនាក់ណែនាំប្ដីនាងខ្ញុំឲ្យធ្វើបាបខ្ញុំ និងរួមដំណេកទាំងបង្ខំ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៦៦ បន្ទាត់ ១៧, ទំព័រ ៨២ បន្ទាត់ ២-៥។ "កាលនោះ ខ្ញុំភ័យខ្លាចពេក ខ្ញុំស្ដាប់ឮខ្លះ អត់ខ្លះ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៨២ បន្ទាត់ ១០។ គាត់បានឮគេនិយាយ "...ថាបើចាប់ដៃគ្នាហើយ គេមិនបានប្រើពាក្យរៀបការទេ លោកប្រធាន គេគ្រាន់តែថាបានចាប់ដៃគ្នា គឺប្ដីប្រពន្ធហើយ ត្រូវតែចាប់រំលោភឲ្យបាន ខ្ញុំឮតែប៉ុណ្ណឹងលោកប្រធាន ហើយក៏ខ្ញុំភ័យញាក់ដូចកូនកណ្ដុរបាត់ហើយ ខ្ញុំនៅតូចដែរ ព្រោះយើងចាំម៉ោងចាំពេលអត់បាន"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៨២ បន្ទាត់ ១៣-១៥។

ហែកអស់ហើយចាស។ ហ្នឹងយប់ទី១”[3173]។ នៅយប់ដំបូង ពួកគាត់មិនបានរួមដំណេកទេ “ខ្ញុំបាន -- ខ្ញុំ នាងខ្ញុំបានសំពះអង្វរគេ ក្រោកឡើងអង្គុយសំពះអង្វរគេអ៊ីចឹងទៅ ក៏គេដេកលក់ទៅចាស ហើយក៏ម៉ោងពីរ គេផ្ទុកញ្ញែ នាងខ្ញុំក៏ចុះទៅតម្រង់ជួរមុនគេចាស”[3174]។

1366. គាត់បាននិយាយបន្តថា “នោះដល់យប់ទី២ គេធ្វើបាបតទៀត”[3175]។ “នៅយប់ទី២ មានទៀត មានកើតឡើងចំពោះរូបខ្ញុំ គេវ៉ៃតប់ ហែកខោហែកអាវទៀត ក៏ខ្ញុំសុំអង្វរគេ ក៏គេមិនស្តាប់ដែរ។ ក៏យប់មួយ យប់ហ្នឹង ក៏មានពូខ្ញុំ គាត់រៀបការសម័យហ្នឹងដែរ គាត់ដេកទន្ទឹមខ្ញុំ”[3176]។ “យប់ទី២ ឲ្យខ្ញុំរត់ទៅបានពូជួយ តែយប់ទី៣ ខ្ញុំដឹងថា ខ្លួនខ្ញុំពេលនេះបែកម៉ែបែកឪហើយ ខ្ញុំថាខ្ញុំស្លាប់ហើយ”[3177]។ ពូគាត់បានមកអង្វរប្តីគាត់ឲ្យមានចិត្តមេត្តា ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ បានផ្តល់សក្ខីកម្មថា បើកុំតែបានពូកគាត់ កុំអីគាត់ប្រហែលជាមិនរស់ទេនៅយប់នោះ[3178]។ “ខ្ញុំទ្រាំញាក់ ដេកនៅក្នុងបន្ទប់នោះ”[3179]។

---

[3173] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៦៦ បន្ទាត់ ២០-២១។ បន្ទាប់មក ដើមបណ្តឹងរដ្ឋប្បវេណីបានបំភ្លឺថា “យប់ទី១ គេមិនបានចងខ្ញុំទេចាស គ្រាន់តែបានវ៉ៃ ហែកខោ វ៉ៃហែកអាវចោល ក៏ខ្ញុំមានប្រសាសន៍នៅខាងហ្នឹងហើយ ខ្ញុំគ្រាន់តែថាគេបានចាប់ហែកអាវខ្ញុំ ខ្ញុំឡើងអង្គុយ សំពះគេទៅ ក៏បានប្រតាយប្រតប់គ្នាហ្នឹង យប់យូរ ប្រហែលជាម៉ោងពីរ ក៏គេផ្ទុកញ្ញែ ខ្ញុំទៅឈរតម្រង់ជួរទៅធ្វើការទៅ ខ្ញុំអត់ទាំងបាយ អត់ទាំងបានដេក ចាស ថ្ងៃហ្នឹង”។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៨១ បន្ទាត់ ២២-២៥។

[3174] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៦៦ បន្ទាត់ ២៥ - ទំព័រ ៦៧ បន្ទាត់ ១។

[3175] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៦៧ បន្ទាត់ ៥។

[3176] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៦៨ បន្ទាត់ ១-៣។

[3177] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៦៦ បន្ទាត់ ៨-១០។

[3178] “គាត់មកសុំអង្វរប្តីខ្ញុំហ្នឹងថា កុំឲ្យធ្វើបាបវា។ ចុះបើវានៅតូចយ៉ាងហ្នឹង បើអ្អែងវ៉ៃវាល់តែយប់ អ៊ីចឹងងាប់ហើយ។ ខ្មែរដូចគ្នា កុំធ្វើបាបវាអីអូន។ ហ្នឹងបានមួយយប់ទៀតទៅ ខ្ញុំទៅដេកជាមួយពូ។ ប្រហែលជាគាត់រាយការណ៍ទៅឲ្យឈ្លបហើយ បានយប់ទី៣ហ្នឹងគេធ្វើបាបខ្ញុំ”។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៦៨ បន្ទាត់ ៣-៥។ ដើមបណ្តឹងរដ្ឋប្បវេណីបានបំភ្លឺថា “ដើម្បីរួមរ៉ៃខ្ញុំ រួមដំណេកជាមួយ។

1367. នៅយប់ទីបី "ប្ដីខ្ញុំនោះ គ្រប់យប់ទី៣ គឺគេមកធ្វើបាបខ្ញុំ។ ចាប់នាងខ្ញុំចងដៃ ហែកខោខ្ញុំអស់"[3180]។ "ចូលដល់យប់ទី៣ សម្ដីសមមិត្តប្រធាន អ៊ុំ ក៏ខ្ញុំចងចាំថា យប់ទី៣ គឺយប់ដែលខ្ញុំត្រូវស្លាប់ ដល់ពេលនោះ ខ្ញុំក៏ចូលរួមដំណេក ដេកនឹងគេ ក៏ខ្ញុំមិនព្រមដែរ លោកប្រធាន។ ខ្ញុំគ្រាន់តែចូលទៅ ខ្ញុំស្លៀកខោពីរជាន់។ ដល់ពេលហើយ ឈ្លបមកបីនាក់។ ឈ្លបមកបីនាក់ គេឈរឲ្យចងដៃខ្ញុំទៅជាប់នឹងសសរ សសររោងហ្នឹងទៅក្រោយទៅ ហើយក៏គេចាប់សម្រាតខោ សម្រាតអាវខ្ញុំអស់ នៅយប់ទី៣ ចាស។ គេរំលោភខ្ញុំបានសម្រេច រួចហើយក៏ខ្ញុំធ្លាក់ឈាមជាប់ជាងមួយខែជាង"[3181]។

1368. ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ បានពន្យល់ថា "ព្រោះនោះ គេកសាងខ្ញុំយប់ទី២ -- យប់ទី១មកដល់យប់ទី២ ដល់យប់ទី៣ខ្ញុំអាចនឹកឃើញថាថ្ងៃហ្នឹងហើយជាថ្ងៃខ្ញុំស្លាប់ បើអ៊ីចឹងទេ ខ្ញុំមានសិទ្ធិរើដែរ ប៉ុន្តែខ្ញុំអត់បានឃើញឈ្លប ដល់ខ្ញុំរើ អ៊ីចឹង គេទះកំផ្លៀងខ្ញុំ ក៏គេជ្រែងខ្ញុំពីលើគ្រែង ក៏ដៃខ្ញុំគេចងទៅនឹងសសរទៅ នឹងជញ្ជាំងទៅ ហើយក៏គេសម្រាតខោ សម្រាតអាវខ្ញុំអស់នៅពេលហ្នឹង ពេលសម្រេចបាន។ ហើយក៏ឈ្លបឆ្លើយដូចខ្ញុំនិយាយពីមុនអ៊ីចឹង"[3182]។ ឈ្លបទាំងនោះឈរក្បែរ

---

តែយប់ទី២ គាត់អត់បានខ្លួនខ្ញុំដែរ បានពូគាត់អង្វរថា បើអ្វែងរើវាតែយ៉ាងនេះងាប់ហើយ ធ្វើការយប់ផង ថ្ងៃផង"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៨៣ បន្ទាត់ ៦-៧។ "[ប្ដីគាត់] មិត្តតក់ សាត ហ្នឹងក៏គេបានស្លាប់។ គាត់ក៏បានដេកជាមួយ តក់ សាត ហ្នឹងមួយយប់។ ខ្ញុំមកដេកជាមួយប្រពន្ធគាត់បានមួយយប់ រួចខ្លួនបានយប់ទី២"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៨៣ បន្ទាត់ ៧-៩។

[3179] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៦៦ បន្ទាត់ ១០-១១។

[3180] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៦៦ បន្ទាត់ ១១-១២។

[3181] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៦៨ បន្ទាត់ ១៥-១៩។ ដើមបណ្ដឹងរដ្ឋប្បវេណីបានពន្យល់ថា "ឈ្លបទាំងប្រាំនាក់ហ្នឹងដដែល គេប្រចាំការនៅតាមកងអ៊ីចឹង គេចល័ត កងនេះ កងនោះ មួយថ្ងៃកងនេះ មួយថ្ងៃកងនោះ គេចល័តយប់ឡើងគេចល័តតាមដាន។ គឺៗជាល្បែងលេងសើចរបស់គេ ដើរលប ដើរស្ដាប់តែអ្នកដេកនៅជាមួយគ្នាអ៊ីចឹងឯងជាទូទៅ ជារឿងរបស់គាត់"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៦៨ បន្ទាត់ ២៣-២៥។

[3182] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៧១ បន្ទាត់ ២-៦។

"គ្មានគេនិយាយក្រៅពីរឿងអាសភាសហ្នឹង គេថាធ្វើអីចឹងបានល្អ ពួកឯងធើកូនជូនបក្ស"[3183]។ ពួកគេសើច[3184] ហើយ "ពួកគេស្រែកឲ្យយើងថាយើងត្រូវបង្កើតកូនជូនអង្គការ"[3185]។

1369. គាត់បានបន្តថា "នៅយប់ទី៤ ក៏ខ្ញុំរត់ទៅរកម្ដាយ [ហើយ] ខ្ញុំប្រាប់គាត់ថា ខ្ញុំធ្លាក់ឈាម ..."[3186]។ "ម្ដាយក៏បានតបមកវិញថា បើកូនរត់មករកម៉ែៗជួយម៉េចបាន បើគេការ ម៉ែក៏មិនដឹង ដល់ពេលកូនរត់មក កូនឃើញអត់? បងប្អូនដេករញ្ជង់ឃ្លានគ្មានអីស៊ី ហើយកូនបន្ថែមមកម្នាក់ទៀត បើសិនជាគេតាមមកសម្លាប់កូន គេសម្លាប់មួយពូជហើយ"។

1370. ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ បានផ្តល់សក្ខីកម្មពីការឈឺចាប់ដែលគាត់បានទទួលរងក្នុងរបបនោះ៖ "ខ្ញុំមានទុក្ខលំបាកជាច្រើនកើតមកជាកូនខ្មែរ កើតមកជាស្រីនឹងគេដែរ តែមិនបានពេញលក្ខណៈរៀបការត្រឹមត្រូវ មានតែគេចាប់បង្ខំ។ រំលោភរាងកាយខ្ញុំ គេរំលោភហើយ ធ្លាក់ឈាមមួយខែជាង"[3187]។ ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ បានពន្យល់ថា នៅពេលគាត់រៀបការ "កាលនោះខ្ញុំនៅក្មេង អត់ដឹងថាមករដូវនោះយ៉ាងម៉េច គ្រប់រដូវនោះយ៉ាងម៉េច"[3188]។ "ដល់ពេល

---

[3183] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៦៩ បន្ទាត់ ៨-៩។

[3184] ឈ្លបដែលមើលព្រឹត្តិការណ៍ ពុំមានបំណងលួចលាន់ និងការពារគាត់ទេ។ "គេឈរមើល គេសើច ហើយគេដើរចេញទៅលោកប្រធាន គឺអីចឹងមែន។ គេស្រែកថា "អើអីចឹងបានធ្វើកូនបានជូនបក្ស" ហើយក៏គេសើចដើរចេញទៅ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៨៤ បន្ទាត់ ១០-១១។

[3185] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/483.1** ទំព័រ ៥៦ បន្ទាត់ ៨។

[3186] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៦៩ បន្ទាត់ ៥-៦។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/483.1** ទំព័រ ៤៣ បន្ទាត់ ៩។ ដើមបណ្តឹងរដ្ឋប្បវេណីបានរម្លឹកថា "យប់ទី២បានពូជួយ យប់ទី៣គ្មានអ្នកណាជួយខ្ញុំទេ ដល់គេកំណត់ហើយ ដល់យប់ទី៤ ខ្ញុំរត់ទៅរកម្តាយខ្ញុំឲ្យម្តាយជួយ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៧១ បន្ទាត់ ១៣-១៤។

[3187] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/483.1** ទំព័រ ៥៥ បន្ទាត់ ១១-១៣។

[3188] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៧២ បន្ទាត់ ២-៣។

នោះ ខ្ញុំអត់មានរដូវអីនឹងមានដូចសម័យនេះ គឺខ្ញុំអត់មានទេ កាលនុ៎ង។ គេរំលោភខ្ញុំហើយ ខ្ញុំធ្លាក់ឈាមប្រហែលជាមួយខែជាង"[3189]។

*ការបាត់ខ្លួន ឬ ការសម្លាប់អ្នកដែលបដិសេធមិនព្រមរួមដំណេក ឬ រក្សាទំនាក់ទំនងជាប្តីប្រពន្ធ*

1371. ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី បានផ្តល់សក្ខីកម្មថា ប្តីប្រពន្ធដែលបែកគ្នា "គេយកទៅរៀនសូត្រជាបន្តបន្ទាប់។ ទៅហើយអត់ឃើញមកភូមិវិញទេ ឃុំមកវិញទេ។ នេះគេថា ហ៍! យកទៅរៀនសូត្រ។ មិនដឹងជារៀនសូត្រអី ដឹងទៅការងារអី ទៅអត់ឃើញត្រឡប់មកវិញ ការជាមួយខ្ញុំហ្នឹងស្ទើរសឹងទាំងអស់ហើយ"[3190]។ "អ្នកលែងលះចុះ ៧៩ ទេបានមានចិត្តលែងលះគ្នា ចែកផ្លូវគ្នាដូចខ្ញុំអ៊ីចឹង។ តែបើរឿងជំនាន់ខ្មែរក្រហម គ្មានលែងលះទេ បាត់ខ្លួនទាំងស្រីទាំងប្រុសទៅតែម្តងទៅរៀនសូត្រ។ គេឲ្យទៅរៀនសូត្រ ថាផ្លាស់ទៅនេះ ផ្លាស់ទៅនោះ តែទីចុងបញ្ចប់នុ៎ង វានៅតែទួលក្បែរៗអស់នោះ"[3191]។

1372. ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន បានផ្តល់ភ័ស្តុតាងស្តីពីការបាត់ខ្លួនប្តីប្រពន្ធដែលប្រកែកមិនព្រមរួមដំណេកជាមួយគ្នា៖ "គូខ្លះក៏មានជំទាស់ដែរ គូខ្លះក៏អត់ហ៊ានជំទាស់ ខ្លាចស្លាប់។ ប៉ុន្តែពីរគូដែលជំទាស់នោះ ឃើញគេហៅទៅនោះ អត់ដឹងថាទៅណាទេ ពីរគូនោះ។ ក្នុង៦០នោះ គេហៅពីរគូទៅនោះ អត់ដឹងថាទៅណាទេ។ គេផ្លាស់ចល័តផ្សេងក៏មិនដឹង គេហៅទៅណាក៏មិនដឹងដែរ ព្រោះជំទាស់ជាមួយគេ ៗហៅទៅ ខ្ញុំអត់ដឹងដែរ"[3192]។ ដើមបណ្តឹងរដ្ឋប្បវេណីបានរម្លឹកឡើងវិញថា "មិត្តថុល នោះដែលគាត់រឹងរូស គាត់សុខចិត្តស្លាប់នោះ គាត់ថាគាត់អត់ព្រមស្រឡាញ់។ គាត់អត់ព្រមស្រឡាញ់គេ គាត់ជំទាស់រហូតហ្នឹង។ ដល់ឃើញគំរូហ្នឹងហើយ បានខ្លាច ខ្លាចស្លាប់ មិនហ៊ាន

[3189] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៧២ បន្ទាត់ ៣-៤។

[3190] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/462.1** ទំព័រ ៧៦ បន្ទាត់ ៦-៨។

[3191] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/462.1** ទំព័រ ៧៦ បន្ទាត់ ១៣-១៥។

[3192] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៦៥ បន្ទាត់ ៣-៦។

ជំទាស់។ សុខចិត្តទៅការ ដើម្បីកូន"[3193]។ ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន បានដឹងអំពីជោគវាសនារបស់មិត្តថុល មុនពេលគាត់រៀបការ ហើយ "ឃើញគំរូអាក្រក់ហ្នឹងហើយ បានខ្លាច។ សុខចិត្តតែស៊ូទ្រាំ ដើម្បីរស់ហ្នឹង ខ្លាចវាទៅដូចគ្នា"[3194]។

1373. ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ បានរម្លឹកឡើងវិញថា មួយថ្ងៃក្រោយពេលរៀបការ ប្តីប្រពន្ធមួយគូឈ្មោះ ខុម និង មុត ត្រូវគេកោះហៅ៖ "ពេលគេមកហៅ គឺគាត់យំឱបខ្ញុំហើយ គាត់ថា បងដល់ពេលគេសម្លាប់ហើយ ព្រោះបងមិនបានដេកចូលគ្នាទេ។ ហើយខោអាវហ្នឹង ដេកជាមួយគ្នា។ ដេកជាមួយខ្ញុំហ្នឹង ដល់ពេលហើយ អត់ឃើញមកយកខោអាវហ្នឹងវិញ"[3195]។ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា ក្រោយពេល ខុម និង មុត បាត់ខ្លួន ប្តីប្រពន្ធមួយគូទៀតបាត់ខ្លួនរវាង៣-៤ថ្ងៃម្តង ហើយមានពាក្យចចាមអារាមថា ពួកគេត្រូវបានបញ្ជូនទៅកសាងនៅវាលខ្វាង[3196]។

1374. ដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត ចាត បានផ្តល់សក្ខីកម្មអំពីបងប្អូនសាច់ថ្លៃរបស់គាត់ ដែលស្ថិតក្នុងកងយុវជន "មក វាអត់ចុះដំណេកទៅ វាប្រទូស្តប្រទាំង វាមិនដឹងជាម៉េចអីម៉េច ខ្ញុំក៏អត់បានតាមដានវា ព្រោះអីវានៅ អង្គភាពជាមួយគ្នាដែរ ដេកជិតដែរ ប៉ុន្តែដូចខ្ញុំហ៊ានតាមដានវា។ ថា ខ្ញុំចេះថាអូនអើយ! អូនឯងខំកសាងខ្លួនទៅ។ ស្អីៗ ខ្ញុំចេះតែនិយាយវាច្រើនអីចឹងទៅ ដល់ហើយក៏បន្តទៅមុខ

---

[3193] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៦៥ បន្ទាត់ ១៦-១៨។

[3194] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៦៥ បន្ទាត់ ២២-២៣។

[3195] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៧៧ បន្ទាត់ ២១-២៣។

[3196] ហើយ "...គឺ៣ថ្ងៃហ្នឹង បាត់មួយគូ, ៤ថ្ងៃ គឺបាត់មួយ, ៥ថ្ងៃ គឺបាត់មួយគូ។ អីចឹងបានខ្ញុំថា ប្រហែលជាគេទៅណា ក៏ខ្ញុំមិនដឹង។ គេថា ចេះតែទៅកសាង ទៅវាល ខ្វាង។ ខ្ញុំសួរបងអ៊ុំ ហ្នឹង គាត់ឆ្លើយខ្ញុំ ទៅវាលខ្វាង"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/482.1** ទំព័រ ៧៧ បន្ទាត់ ២៤ - ទំព័រ ៧៨ បន្ទាត់ ១។

ទៀត ក៏មិនវាយ៉ាងម៉េច គេយកទៅបាត់អស់អ៊ីចឹងទៅ ប្អូនខ្ញុំ។ ប្អូនថ្លៃខ្ញុំ គេយកទៅបាត់អស់ហើយ សម្លាប់ ទៅវ៉ៃស្អីចោលអស់”[3197]។

1375. ដើមបណ្តឹងរដ្ឋប្បវេណី ខូង មួយ បានរៀបរាប់ថា “ខ្ញុំក៏ឮគេថាអ៊ីចឹង ខ្ញុំក៏ភ័យរន្ធត់ក្នុងខ្លួនយ៉ាងខ្លាំង។ ហើយក៏បានប៉ុន្មានថ្ងៃ គេផ្លាស់ខ្ញុំទៅតានៃទៅ ទៅធ្វើបង្គី ច្រូតស្រូវ ច្រូតអីនៅនោះទៅ។ ខ្ញុំក៏នៅតែភ័យខ្លាចរហូតដល់គេរំដោះហើយ ៧៩ហ្នឹង”[3198]។ ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា ចំពោះប្តីប្រពន្ធបួនឬប្រាំគូដែលត្រូវគេបញ្ជូនទៅទទួលលទណ្ឌកម្ម “នាងខ្ញុំអត់ដឹងដែរ ខ្ញុំទៅផ្លាស់ទៅតានៃហើយ អត់ដឹង មានដល់ពេល ថ្ងៃខ្ញុំមិនទាន់ទៅឮគេថា យកទៅវ៉ៃចោល ខ្លះអត់ត្រូវគ្នា”[3199]។

1376. ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានផ្តល់សក្ខីកម្មបែបចចាមអារាម ពាក់ព័ន្ធនឹងជោគវាសនារបស់ព្រះសង្ឃមួយអង្គ៖ “គេទៅផ្សឹកនៅសហជីពហ្នឹង គាត់ គ្រូសូត្រទេ គាត់ចាស់ហើយ ក៏រៀបការឲ្យគាត់។ ហ្នឹងក៏គេយកគាត់ទៅសម្លាប់ដែរ។ ដល់យកប្រពន្ធទៅសម្លាប់ទៅ ប្តីនៅ ដល់ប្តីហ្នឹង ចេះតែដើរច្រៀងបទគំនូចហ្នឹងទៅ ដល់ក្រោយមកបានគេសម្លាប់ទាំងគូៗតែម្តង។ ចាស កាលមុនគេសម្លាប់តែមួយទេ ពីដំបូង សម្លាប់អ្នកដែលមិនត្រូវគ្នាហ្នឹង គេសម្លាប់តែនារីទៅ នៅប្តី។ ចាស ដល់ប្តីហ្នឹង ចេះតែច្រៀងស្រណោះស្រណោកអ៊ីចឹងទៅ ឲ្យកម្មករហ្នឹងស្តាប់។ ដល់ក្រោយមក ក៏ពាក្យហ្នឹងចចាមអារ៉ាមដល់អង្គការទៅ ក្រោយទៀត បើមិនត្រូវគ្នា គេសម្លាប់ទាំងគូៗតែម្តង”[3200]។ ប្រពន្ធ “គេសម្លាប់មុនប្តី ប្តីគាត់ហ្នឹង គាត់ដូចថា អត់ត្រូវរ៉ូវគ្នាអ៊ីចឹងទៅ គេយកស្រីហ្នឹងសម្លាប់មុន។ ដល់ទៅ ប្តីគាត់ហ្នឹងចេះតែច្រៀង “កុកហើរតែឯង””[3201]។ ដើមបណ្តឹងរដ្ឋប្បវេណី

[3197] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ១០ បន្ទាត់ ២៤ - ទំព័រ ១១ បន្ទាត់ ២។

[3198] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ខូង មួយ ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/394.1** ទំព័រ ៣៨ បន្ទាត់ ២២-២៣។

[3199] 3199 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ខូង មួយ ប្រតិចារឹក ថ្ងៃទី ១ ខែ មីនា ឆ្នាំ ២០១៦ ឯកសារ **E1/394.1** ទំព័រ ៥៩ បន្ទាត់ ៨-៩។

[3200] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ១១ បន្ទាត់ ៥-១១។

[3201] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ១១ បន្ទាត់ ១៨-១៩។

បានរម្លឹកថា “ទៅគេសួរថា ម៉េចបានអ៊ីចឹង? ថា អើយ! គេសម្លាប់គូហើយ វាមិននៅតែឯង។ គាត់និយាយសើចអ៊ីចឹង ចាស។ ដល់ពេលក្រោយមកបាន បើមានគូណាមិនស្ម័គ្រស្មោះគ្នាមិនរួមរក្សអង្គការហ្នឹង ដាក់ផែនការយកទាំងគូៗទៅតែម្តង”[3202]។

## ៤.៧. ការក្លែងធ្វើជា “ចុះសម្រុងនឹងគ្នា” ដើម្បីជៀសវាងទណ្ឌកម្ម

1377. ដើមបណ្តឹងរដ្ឋប្បវេណី យស ផល និងប្រពន្ធគាត់ក្លែងធ្វើជាស្រឡាញ់គ្នា និងរួមដំណេកជាមួយគ្នា ដោយសារ បើពុំដូច្នោះទេ “យើងប្រាប់គេថា អ៊ីចឹងមែនតែយើងហ្នឹង អត់ស្រឡាញ់គ្នា គេយកទៅសម្លាប់ចោលហើយ។ បើយើងប្រាប់គេថា យើងបានស្រឡាញ់គ្នា រួមភេទគ្នា រស់នៅជាមួយគ្នាសុខទុក្ខធម្មតា អាហ្នឹងយើងបានរួចខ្លួន”[3203]។ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា គាត់ចាត់ទុកប្រពន្ធគាត់ដូចជាប្អូនបង្កើត តែដើម្បីរស់ ពួកគេសម្តែងដូចជាប្តីប្រពន្ធ[3204]។

---

[3202] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ១១ បន្ទាត់ ២០-២២។ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា “មានរៀបការ ប៉ុន្តែខ្ញុំមិនបានដឹង ព្រោះដ្បិតអី វានៅក្រសួងដោយឡែកៗពីគ្នា។ គេនៅកងធំផ្សេង ខ្ញុំនៅកងធំផ្សេង។ ដល់អ៊ីចឹង ខ្ញុំមិនបានចាប់អារម្មណ៍ដឹងថា អ្នកណាខ្លះនោះទេ ប៉ុនបើខ្ញុំដឹងច្បាស់ តែបងហ៊ិន ហើយនិងបងមួយទៀតដែលខ្ញុំបាននិយាយអំមិញហ្នឹង គាត់បានរៀបជាមួយព្រះសង្ឃមែន។ កាលនុ៎ង គេយកទៅផ្សឹកនៅនឹងសហាជីពហ្នឹង”។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ១២ បន្ទាត់ ២-៥។

[3203] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ២៨ បន្ទាត់ ១១-១៣។

[3204] ដើមបណ្តឹងរដ្ឋប្បវេណី យស ផល បានផ្តល់សក្ខីកម្មថា “ហើយយើងចេះតែរស់នៅជាមួយគ្នាដូចជាបងប្អូនអ៊ីចឹង គ្រាន់តែប្រាប់គ្នាថា បើលោកមេឃុំ ឬប្រធានសហករណ៍គាត់សួរ យើងថាត្រូវនិយាយថា យើងស្រឡាញ់គ្នាណាស់ ដេកនៅជាមួយគ្នាត្រឹមត្រូវហើយ។ បើមិននិយាយអ៊ីចឹងទេ យើងទាំងពីរនាក់ប្រហែលជាមិនដឹងងាប់នៅគុម្ពោតណា ឬត្រង់កន្លែងណាទេ”។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ២២ បន្ទាត់ ៤-៧។ គាត់បានបំភ្លឺបន្តថា “ខ្ញុំនិយាយនេះ ខ្ញុំអត់បាននិយាយប្រាប់ដល់មនុស្សទូទៅទេ។ ខ្ញុំនិយាយតែពីនាក់គូ -- ពីរនាក់ប្តីប្រពន្ធខ្ញុំដែលរៀបការហ្នឹងទេ បើមានគេសួរយើងពីរឿងការរួមភេទគ្នា ឬការនៅរស់នៅជាមួយគ្នា យើងត្រូវនិយាយ ប៉ុន្តែបើគេគ្មានសួរទេ យើងមិនបាច់និយាយទេ ប៉ុន្តែគ្រាន់តែយើងសម្តែងលក្ខណៈយើងជាប្តីប្រពន្ធឱ្យគេឃើញថាយើងស្រឡាញ់គ្នា។ មានតែប៉ុណ្ណឹងទេ ខ្ញុំមិនបានប្រាប់ ដើរប្រាប់ដល់មនុស្សដែលនៅក្បែរៗខ្ញុំហ្នឹងថាម៉េចៗទេ ប៉ុន្តែគេឃើញយើងខ្ញុំរាងស្តមអ៊ីចឹង ហើយឃើញទំនាក់ទំនងនិយាយគ្នា គេក៏អាចដឹងថាខ្ញុំហ្នឹងស្រឡាញ់គ្នាហើយ”។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ២៨ បន្ទាត់ ១-៦។

1378. ក្រោយពេលរៀបការ ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានផ្ដល់សក្ខីកម្មថា មានពាក្យចចាមអារាមថា អ្នកណាដែលមិនធ្វើតាមអង្គការនឹងត្រូវបញ្ជូនទៅដេកនៅ "កន្លែងសុប"[3205]។ ដោយសារតែហេតុនេះ និងក្នុងចំណោមប្រការផ្សេងទៀត ដើមបណ្ដឹងរដ្ឋប្បវេណីមានអារម្មណ៍ភ័យខ្លាច ដែលបណ្ដាលឱ្យគាត់ក្លែងធ្វើជាចុះសម្រុងជាមួយប្ដីគាត់៖ "ខ្ញុំនៅតែលាក់គំនិតរហូតបើគេមក កាលហ្នឹងវាមួយខែមកម្ដង"[3206]។ "ខ្ញុំក្រោយពីរៀបការរួច អារម្មណ៍ខ្ញុំភ័យខ្លាច គិតដេកមិនលក់ ស៊ីមិនឆ្ងាញ់ ទៅធ្វើការងារហើយទាំងលំបាក ការងារផង មកវិញហូបចុកមិនគ្រប់គ្រាន់ផង អារម្មណ៍ភ័យខ្លាចគេសម្លាប់ផង។ ដល់អ៊ីចឹងគឺថាអារម្មណ៍ខ្ញុំហ្នឹង គិតតែពីសេចក្ដីស្លាប់មួយមុខ គិតឃើញថាបើសិនជារឿងរ៉ាវដែលខ្ញុំធ្វើនេះដឹងដល់អង្គការ គេនឹងសម្លាប់ខ្ញុំ។ ប៉ុន្តែខ្ញុំខំកែប្រែចរិត ធ្វើឱ្យល្អ មិនឱ្យមិត្តក្នុងរួមការងារជាមួយនឹងអត់ឱ្យដឹង ទោះអ្នកណាក៏គេ ខ្ញុំមិនដែលនិយាយប្រាប់គេថាខ្ញុំមិនត្រូវរូវគ្នាដែរ"[3207]។

---

[3205] ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានបរិយាយថា "កាលនុ៎ងដែលខ្ញុំរៀបរួចទៅ ដូចថាអាពាក្យចចាមអារ៉ាមគេដឹងល្បើៗទៅ គេនិយាយថា មិត្តឯង! តែបើមិនគោរពអង្គការវិន័យទេ មិត្តឯងមុខជាទៅនៅដេកកន្លែងសុបហើយ គេប្រាប់ខ្ញុំអ៊ីចឹង។ ហើយខ្ញុំធ្វើអារម្មណ៍នឹងនរ ខ្ញុំធ្វើថាដូចត្រូវរូវគ្នាទៅ ខ្ញុំមានទៅផ្លាស់ប្ដូរឱ្យគេដឹងចរិតអី ខ្ញុំចេះតែថា ទៅនៅសុបអីបើដេកជាមួយគ្នារាល់យប់ ទៅនៅឯណា បើខ្ញុំមកខ្ញុំដែលទៅដេកឯណា ខ្ញុំមានមកដេកកន្លែងណា ខ្ញុំដេកតែជាមួយគាត់ដែរ។ ខ្ញុំបាននិយាយប្រាប់គាត់អ៊ីចឹង អ៊ីចឹងក៏គាត់តាមដានដឹងថាខ្ញុំ សួរមិត្តនៅកន្លែងអ៊ីចឹងទៅ សួរថាមិនដែលឃើញមកដេកមែនពេលគ្រួសារមក។ ដល់អ៊ីចឹងគេជឿ នៅសហជីពហ្នឹងគេជឿខ្ញុំ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៦៥ បន្ទាត់ ៨-១៥។

[3206] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៦៥ បន្ទាត់ ២១-២២។ ក្រៅពីនេះ ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានរម្លឹកឡើងវិញថា "កាលហ្នឹងវាមួយខែមកម្ដង រួចខ្ញុំចង់ភ្លេចប្ដីបាត់ទៅហើយ បានគេឱ្យជួបម្ដងទៀត។ ដល់ពេលទៅជួបហ្នឹងវាភ្លេចមុខភ្លេចមាត់អស់ ដល់អ៊ីចឹងទៅគេសួរថា អ្ហ៎! គ្រួសារមកហើយ ប៉ុន្តែវាមិនចាំថាមុខហ្នឹងជាគ្រួសាររបស់ខ្ញុំ។ ដល់ទៅគេសួរថា មិត្តនេះឡើឡឺៗ ប្ដីមកដើរហួសទៅហួសមក។ ប៉ុន្តែខ្ញុំភ្លេច ខ្ញុំភ្លេចថា ប្ដីហ្នឹងមុខខ្ញុំ មិនបានមើលមុខគាត់ច្បាស់ ដល់អ៊ីចឹងខ្ញុំអត់ដឹងថា គាត់ហ្នឹងមុខអ៊ីចឹង។ ដល់អ៊ីចឹងខ្ញុំមិនដឹងមួយណាប្ដីខ្ញុំ បើបុរសគេអង្គុយគ្រែដែរ ខ្ញុំអត់ស្គាល់។ ដល់តែទៅ គេបានគេឱ្យ គេជូនខ្ញុំថា ទៅនាំគ្រួសារទៅកន្លែង។ ដល់ពេលទៅ មានប្រធានកងហ្នឹងគាត់នាំខ្ញុំមក បានគាត់ដើរតាមមក បានខ្ញុំដឹងថាគាត់ជាប្ដីរបស់ខ្ញុំ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៦៥ បន្ទាត់ ២២ - ទំព័រ ៦៦ បន្ទាត់ ៣។

[3207] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៦៥ បន្ទាត់ ១៧-២១។

1379. ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន បានផ្តល់សក្ខីកម្មថា គាត់ និងប្រពន្ធគាត់មិនដែលនិយាយពីអារម្មណ៍របស់ខ្លួនពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍របស់ពួកគេទេ៖ "ចឹងគឺបានរៀបការហើយហ្នឹង គឺធ្វើម៉េចយើងមិនស្រឡាញ់គ្នាក៏ដោយ ក៏ចេះតែរួមរស់នៅជាមួយទៅតាមអង្គការទៅ គឺមានការភ័យខ្លាចខ្លួនឯងដែរ ខ្លាចអង្គការគេចោទថាខ្មាំង ថាអីមិនហ៊ានប្រកែក មិនហ៊ានធ្វើខុសអំពីផែនការរបស់អង្គការគេនុ៎ងទេ"[3208]។

## ៥. ការមានផ្ទៃពោះ និងការរលូតកូន

1380. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន "មានផ្ទៃពោះ បើមិនឆ្នាំ៧៧, ៧៨ហ្នឹង មានតែពាក្យប៉ុណ្ណឹងទេចាស។ សម្រាប់ពេលកូនហ្នឹង វាកើតមក នៅក្នុងឆ្នាំ៧៨ហ្នឹង"[3209]។ ចំពោះកំណើតកូនស្រីគាត់ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន បានពន្យល់ថា "...ចុងឆ្នាំ៧៧ ដើមឆ្នាំ៧៨ៗហ្នឹង ដល់តែពេលមកចុងឆ្នាំ៧៨ហ្នឹង ខ្ញុំកើតបានកូនមួយ។ ហើយខ្ញុំមិនបានចាំថា ពេលណាដែលខ្ញុំរួមភេទនៅថ្ងៃជាមួយគ្នា ខ្ញុំភ្លេច"[3210]។

[3208] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ៥១ បន្ទាត់ ២៥ - ទំព័រ ៥២ បន្ទាត់ ២។

[3209] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៨ បន្ទាត់ ៨-៩។ ចំពោះខែដែលកូនស្រីគាត់កើត ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន បានឆ្លើយថា "អត់ចាំទេ ដល់កើតមកឥឡូវហ្នឹង ដាក់ឆ្នាំព្រាវៗទេចាស ខ្ញុំដាក់ឆ្នាំព្រាវៗ ខ្ញុំយកឆ្នាំ ដាក់ឆ្នាំម្សាញ់ ព្រោះខ្ញុំយកព្រាវៗ។ រួចខ្លះណាគេថាដាក់ឆ្នាំមមី ខ្ញុំអត់ដឹងយកឆ្នាំអីទេ ព្រោះកូនហ្នឹង អត់ដឹងចាំឆ្នាំទេ ព្រោះកាលនុ៎ង គ្មានបានមានស្អីៗ បានមើលអីគេទេ។ កូនហ្នឹងមួយហ្នឹង ដឹងតែ គេសួរខ្ញុំថា កើតអង្កាល់អីអង្កាល់ ខ្ញុំថា ដឹងតែត្រូយអំពិលលាស់ ព្រោះអត់ដឹងខែណាខែណា ព្រោះអត់ដឹង។ នៅមួយជំនាន់នេះ មិនបានចេញមកសួរ ជួបអ្នកស្រុកអីណាផង ភូមិផងរបងជាមួយអី អត់មានទេ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៤៦ បន្ទាត់ ១៥-១៩។

[3210] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៤៦ បន្ទាត់ ៨-១០។

1381. មុនពេលដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន និងប្រពន្ធគាត់បែកគ្នា "ប្រពន្ធគេប្រាប់ថា នេះគេមានកូន២ខែហើយ គ្រាន់តែបាន តែខ្ញុំគ្រាន់តែនិយាយប្រាប់ទេណា រួចមកក៏ខ្ញុំទៅក្រចេះអីចឹងទៅ"[3211]។

1382. ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន មាន "កូនបួននាក់នៅរបបខ្មែរក្រហម" រួមមានកូនភ្លោះពីរចំនួនពីរដងជាមួយប្តីដែលគេបង្ខំឱ្យគាត់រៀបការជាមួយ[3212]។ ដើមបណ្តឹងរដ្ឋប្បវេណីដែលមានកូនសរុបចំនួន ១៤ នាក់[3213] បានផ្តល់សក្ខីកម្មថា "កូនដែលស្លាប់នៅក្នុងរបបខ្មែរក្រហមពីរនាក់"[3214] "ដោយសារអត់មានថ្នាំលេប ហើយអាហារហូបអត់គ្រប់គ្រាន់"[3215]។ ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន បានបញ្ជាក់បំភ្លឺថា "កូនខ្ញុំស្លាប់ក្នុងរបបខ្មែរក្រហមហ្នឹង គឺស្លាប់ពីរនាក់ស្លាប់បន្តបន្ទាប់គ្នា ..."[3216]។

---

[3211] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/465.1** ទំព័រ ៦៣ បន្ទាត់ ១-២។

[3212] "៧៦ខ្ញុំមានកូនពីរ ព្រោះកូនភ្លោះ ដល់ឆ្នាំ៧៧ពីរទៀត ភ្លោះទៀត ហើយក្នុងបួននោះ ស្លាប់មួយ នៅសល់បី"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៤៨ បន្ទាត់ ៤-៥។

[3213] ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា "បើសរុបទៅដែលកើតឆ្នាំ៨២ សរុបទាំងអស់១៤នាក់"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៤៨ បន្ទាត់ ៩។

[3214] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៤៨ បន្ទាត់ ២១។

[3215] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៤៨ បន្ទាត់ ២៤។ "ឆ្លងទន្លេលើកទី១ ពី១៩៧៦ ចុងឆ្នាំ កើតពីរ កូនភ្លោះ ស្រីមួយ ប្រុសមួយ។ កូនទី២ កើតចុងឆ្នាំ១៩៧៧ ភ្លោះប្រុសទាំងអស់ចាស។ ហើយដល់ឆ្លង អាហ្នឹងនិយាយសរុបទាំងអស់ណា ក្នុងកូនលើកទី៣ ភ្លោះទៀត កើតក្នុងឆ្នាំ១៩៨២ហ្នឹង ស្លាប់ទាំងអស់ កើតហើយស្លាប់។ ព្រោះកាលណាកាលនេះ សុខភាពខ្ញុំវាអត់ល្អ កាលណាដល់រួចមក វាកើតស្លាប់តែម្តង"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៧៦ បន្ទាត់ ១៩-២២។

[3216] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/477.1** ទំព័រ ៤ បន្ទាត់ ២១-២២។

1383. ក្រោយពេលគាត់រួមដំណេករួច ដើមបណ្តឹងរដ្ឋប្បវេណី សយ ណារឿន "ខ្ញុំមានកូន ហើយខ្ញុំចាញ់កូន។ ទោះបីខ្ញុំចាញ់កូនធ្វើការទាំងចាញ់កូន ទាំងគ្មានអាហារហូបគ្រប់គ្រាន់ ពេលធម្មតាស្ត្រីយើងដែលមានផ្ទៃពោះគឺនឹកឃ្លាន របស់អ្វីក៏មិនបានហូបចុកដែរ។ ហើយប្រើខ្ញុំឱ្យធ្វើទាំងចាញ់ឈឺស្គមស្គាំង មើលមិនយល់ ដោយសារខ្ញុំមានកូនចាញ់កូនខ្លាំងពេកក៏ចេះតែធ្វើការរាល់ថ្ងៃ តែប្តីនៅតាមការដ្ឋានដោយឡែកពីគ្នា"[3217]។ នៅពេលរៀបរាប់ពីអារម្មណ៍ពេលមានផ្ទៃពោះ ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា វាពុំមែនជាជម្រើសរបស់គាត់ទេ ហើយគាត់បានផ្តល់សក្ខីកម្មពីអារម្មណ៍អស់សង្ឃឹម និងមិនច្បាស់លាស់ថានឹងមានអ្វីកើតឡើងក្រោយពេលកូនកើតរួច[3218]។ ដើមបណ្តឹងរដ្ឋប្បវេណីបានរលូតកូន "ក្រោយមកកូនច្បងបានស្លាប់ទៅ នាងខ្ញុំមានទម្ងន់កូនមួយទៀតកើតនៅឆ្នាំ៧៧ រស់នៅទល់សព្វថ្ងៃ"[3219]។

1384. ដើមបណ្តឹងរដ្ឋប្បវេណី សយ ណារឿន បានផ្តល់សក្ខីកម្មថា "កូនខ្ញុំទី២ កើតនៅឆ្នាំ៧៧ គ្មាន -- សុខភាពគ្មាសព្វថ្ងៃមិនបរិបូរទេ ស្គមស្គាំង មូលហេតុដែលគ្នាកើតមកបានប៉ុន្មានខែ ខ្ញុំទៅដើរចោលធ្វើការតាមការដ្ឋាន អត់បានបៅ អត់បានអីទេ។ កូននៅនឹងយាយៗសិប្បកម្ម។ ពេលយប់ម៉ោងដប់មួយកន្លះយប់ ឬម៉ោងដប់ពីរ ទើបមកដល់ផ្ទះ បានឱ្យកូនបៅ។ ដូច្នោះហើយ កូនខ្ញុំទី២ កំសត់ណាស់នៅក្នុងរបបនោះ។ ត្រង់ហ្នឹងហើយដែលខ្ញុំគិតថា មិនចង់ឱ្យមានកូនទេ របបនេះសាហាវណាស់ តែធ្វើម៉េចជំនាន់នោះគ្មានអ្វីការពារសម្រាប់រូបខ្ញុំទេ"[3220]។

---

[3217] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៣២ បន្ទាត់ ៤-៧។

[3218] "ខ្ញុំមានកូន គឺមិនមែនតាមចិត្តខ្ញុំចង់ចាឱ្យមានទេ តែនេះជាទិសដៅរបស់គេ គេថាត្រូវតែមានកូន ត្រូវតែបង្កើតកូនឱ្យអង្គការ។ ពេលណា នេះខ្ញុំនឹកគិតថាជីវិតកូនខ្ញុំដល់កើតមក មិនដឹងទៅជាយ៉ាងម៉េចទេ។ ខ្ញុំមិនចង់ឱ្យមានទេលោកប្រធាន តែមិនដឹងធ្វើម៉េចទៅតាមធម្មជាតិ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៣២ បន្ទាត់ ១០-១២។

[3219] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៣៣ បន្ទាត់ ១៩-២០។

[3220] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៣៣ បន្ទាត់ ២៤ - ទំព័រ ៣៤ បន្ទាត់ ៣។

## ៦. ការបន្តជីវិតជាប្តីប្រពន្ធ ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ

1385. ក្រោយពេលរបបកម្ពុជាប្រជាធិបតេយ្យដួលរលំ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន និងប្តីគាត់ "រត់ចែកគ្នា"[3221]។ បីឆ្នាំក្រោយមក ដើមបណ្តឹងរដ្ឋប្បវេណីនិងប្តីគាត់បានជួបគ្នាវិញ[3222] ក្រោយពេល "ចាស់ទុំ ម៉ែក្មេក បង្កើត ម៉ែក្មេក -- ម៉ែខ្លួនឯងហ្នឹង ហើយចាស់ៗទុំ បងប្អូនចេះតែថា បើបានជាកូន បានជាចៅហើយ ជុំគ្នាវិញទៅ។ ដល់ជុំគ្នាបានតែ៣ឆ្នាំ ក៏គាត់ស្លាប់ទៅៗ"[3223]។ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន បានផ្តល់សក្ខីកម្មថា "រយៈពេលជួបគ្នាបាន៣ឆ្នាំកន្លងមកហ្នឹង ខ្ញុំវាក្នុងទុក្ខ ក្នុងខ្លួនហ្នឹង មានចិញ្ចឹមកូនផង អត់មានទុក្ខសប្បាយអីទេ ទើបតែឥឡូវនេះ បានកូនធំអីចឹងទៅ បានរាងសប្បាយចិត្តមួយបន្តិច។ និយាយរួមអង្គការខាង ធី.ភី.អូ ហ្នឹង ឧស្សាហ៍មកអារម្មណ៍ សតិអារម្មណ៍ខ្ញុំ នាងខ្ញុំហ្នឹង បំប៉នសតិអារម្មណ៍ខ្ញុំហ្នឹង បានរាងសប្បុះសប្បាយមក ត្រឹមខាងក្រោយមកទៀតហ្នឹង"[3224]។

1386. ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធាវី បានបាត់ទំនាក់ទំនងជាមួយប្រពន្ធគាត់ ក្រោយពេលឆ្លងទន្លេរួចភ្លាម "ដាច់ទំនាក់ទំនង ទាល់ពេលប្រពន្ធខ្ញុំជិតឆ្លងទន្លេ ហ្នឹងដាច់ទំនាក់ទំនងគ្នារហូតដល់ថ្ងៃឆ្លងទន្លេ

---

[3221] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ១១ បន្ទាត់ ១៣។ គាត់បានពន្យល់ថា "ដល់តែពេលត្រឡប់មកវិញ ត្រាក់ទ័រគេបើកមកដល់ចំការលើហ្នឹង ក៏ខ្ញុំរកមើលប្តីអត់ឃើញ ក៏ខ្ញុំឱបកូនហ្នឹងឡើងលើឡានជាមួយនឹងក្មួយចេញមកតែម្តងមកក្នុងត្រាក់ទ័រគេហ្នឹង រកប្តីអត់ឃើញទេ បែកគ្នាប្រហែលជារយៈ៣ឆ្នាំបានជួបគ្នាវិញ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ១១ បន្ទាត់ ១៣-១៥។ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន បានរម្លឹកឡើងវិញថា "វៀតណាមចូលមកស្រុក ប្រទេសខ្មែរយើងហ្នឹង ចូលមកហ្នឹង មានរថក្រោះ មានអីហ្នឹង មិនពួកខ្ញុំហ្នឹងគេនាំរត់ទៅដល់ខាងកំពង់ធំ។ ចាស ដល់រត់ទៅដល់កំពង់ធំហ្នឹង ខ្ញុំមានកូនហើយ។ ដល់តែពេលអីចឹងទៅ រត់ត្រឡប់មកវិញហ្នឹងទៅ ប្តីគេលីអីវ៉ាន់ផ្សេងទៅ ខ្ញុំដើរផ្សេងទៅ បែកគ្នាត្រឹមហ្នឹង។ គេចូលមក មានរថក្រោះមានអីហ្នឹង ឡានតូច ឡានធំគេហ្នឹង មានវៀតណាម មានអីមកហ្នឹង មួយឆ្នាំ មួយប្រាំបួនរយ-- ចុង៧៨ ទៅ៧៩"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ១១ បន្ទាត់ ១៧-២១។

[3222] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ១១ បន្ទាត់ ២៥។

[3223] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ១២ បន្ទាត់ ៤-៥។

[3224] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ១២ បន្ទាត់ ១០-១៣។

។ ខ្ញុំមិនដែលមកផ្ទះ ព្រោះខ្ញុំអត់មានអី មានកម្លាំងទៀតទេ វៃថ្មមិនបានសម្រេចឱ្យគេ គេមិនឱ្យបាយស៊ី នៅដេក នៅស៊ីបាយ*(ឮមិនច្បាស់)*ហ្នឹង មិនបានជាទាំតួ ថាមកឱ្យជួបប្រពន្ធរហូតដល់កូនកើតទេ”[3225]។

1387. ដើមបណ្តឹងរដ្ឋប្បវេណី យស ផល និងប្រពន្ធគាត់រួមរស់ជាមួយគ្នាក្រោយរបបនោះ មួយផ្នែកដោយសារសម្ពាធគ្រួសារ “ដល់ពេល៧៩នោះ សម័យនោះគឺជាថ្ងៃរំដោះហើយ ក្នុងគ្រួសារខ្ញុំនៅជួបជុំគ្នាបាត់តែឪពុក ហើយនិងបងប្អូនមាមីងមួយចំនួន។ អ៊ីចឹងនាងប្រពន្ធដែលរៀបការជាមួយខ្ញុំតែងតែតាមមកជាមួយបងប្អូនខ្ញុំ គ្រួសារខ្ញុំ និងរូបខ្ញុំ។ អ៊ីចឹងខ្ញុំអត់ទាន់មាន នៅតែជួបគ្នារហូតហើយយើងក៏និយាយឱ្យចំទៅដល់ពេលនៅទីនោះយូរទៅដោយសម្ពាធពីបងប្អូន ពីឪពុកម្តាយនិយាយលួងលោមខ្ញុំថា៖ “កូនអើយ! បងអើយ! បានជួបគ្នាហើយ យើងសុទ្ធតែកូនអ្នកមានពូជមានអំបូរ អ្នកកាន់សីលកាន់ទាន ប្រព្រឹត្តតែអំពើល្អ សាងតែកុសលល្អ កូនឯង បងឯងស្រឡាញ់គ្នាទៅ កុំពង្រាត់បង្រាស ហើយគាត់ជាក្មេងកំព្រា កូនកំព្រា គ្មានបង គ្មានប្អូនទេ ហើយយើងក៏កំព្រា យើងរស់នៅជាមួយគ្នាទៅ”[3226]។ ទោះជាយ៉ាងក្តី ក្រោយមក ប្រពន្ធគាត់បានធ្លាក់ខ្លួនឈឺដែលមិនអាចមានកូនទៀតបាន។ ប្តីប្រពន្ធនេះបានបែកផ្លូវគ្នា ហើយចុងក្រោយ ដើមបណ្តឹងរដ្ឋប្បវេណី យស ផល បានរៀបការជាមួយស្ត្រីម្នាក់ទៀត[3227]។

---

[3225] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធាវី ប្រតិចារឹក ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/463.1** ទំព័រ ៣៧ បន្ទាត់ ៧-១០។

[3226] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ២៤ បន្ទាត់ ៨-១៥។ ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា “ដល់ចិតក្នុងការពិចារណាច្រើនថ្ងៃយូរថ្ងៃដែរទៅ ខ្ញុំក៏នឹកឃើញហើយឃើញប្រពន្ធខ្ញុំតែងតែប្រព្រឹត្តតែល្អៗជាមួយបងប្អូនខ្ញុំនិងរូបខ្ញុំ ខ្ញុំក៏មានការអាណិតស្រឡាញ់គាត់ទៅ ហើយក៏ស្រឡាញ់គ្នាហ្នឹងយើងក៏មានកូនចៅខ្លះដែរ”។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ២៤ បន្ទាត់ ១៥-១៧។

[3227] “ហើយមកដល់ក្រោយមកប្រពន្ធខ្ញុំក៏មានជំងឺឈឺ ជំងឺៗឈឺធ្ងន់ធ្ងរ ពេទ្យបានតែហៅខ្ញុំទៅបង្គាប់ថា លោកមិនអាចរស់នៅជាមួយគាត់បានទេ អ៊ីចឹងត្រូវតែឱ្យមើលឱ្យគាត់ជា ហើយរស់ជាមួយគាត់តទៅទៀតទៅ មិនអាចរស់ជាមួយគាត់ដូចមុនបានជាកូនជាចៅបានទៀតទេ ព្រោះគាត់មានជំងឺផ្សេងមួយ។ អ៊ីចឹងខ្ញុំសុំលាក់អត្តសញ្ញាណជំងឺផ្សេងនោះ។ អ៊ីចឹងខ្ញុំក៏សុំបែកគ្នាទៅៗ ហើយខ្ញុំក៏មានគ្រួសារមួយទៀតដែរ”។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ២៤ បន្ទាត់ ១៧-២១។

1388. ក្រោយពេលរៀបការបានប្រហែលបីខែ ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន ត្រូវបានបញ្ជូនចេញពីស្រុកស្អាងទៅខេត្តក្រចេះ។ ទោះបីគេប្រាប់គាត់ថា ស្ត្រីនឹងត្រូវគេបញ្ជូនទៅតាមក្រោយក៏ដោយ[3228] តែគាត់លែងបានជួបប្រពន្ធគាត់ជារៀងរហូត[3229]។

1389. ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន បានពន្យល់ថា "ខ្ញុំការប្ដីទី២ ដែលមនុស្សយើងអត់ស្រឡាញ់គ្នាហ្នឹង ខ្ញុំនៅរស់រហូតដល់៧៩។ ៧៩ ហើយឆ្លងទៅដល់ឆ្នាំ៨២ ខ្ញុំកើតកូនពីរទៀត ដល់រួចហើយខ្ញុំកើតកូនហើយ ដល់៨៤គេសុំបែកមែន បែករហូតទាល់សព្វថ្ងៃ"[3230]។ គាត់មិនបានទទួលដំណឹងពីប្ដីគាត់ចាប់តាំងពីពេលនោះមក[3231]។

1390. ក្រោយរបបនោះ ដើមបណ្តឹងរដ្ឋប្បវេណី សយ ណារឿន និងប្ដីគាត់សម្រេចចិត្តរួមរស់ជាមួយគ្នាដើម្បីកូន។ "ក្រោយពីឆ្នាំដាច់មកហ្នឹង ខ្ញុំបានជាខ្ញុំរួមរស់ជាមួយគ្រួសារជាប្ដីប្រពន្ធរហូតមកដល់សព្វថ្ងៃ ដោយខ្ញុំគិតថាខ្ញុំអាណិតកូន កើតក្នុងសម័យសង្គ្រាម កូនមិនបានពេញលេញទេ។ ហើយណាមួយខ្លួនខ្ញុំជាស្ត្រីខ្មែរ ខ្ញុំមិនចង់ឲ្យកូនមានឪមួយ ឪពីរ ប្ដីមួយ ប្ដីពីរទេ ខ្ញុំសុខចិត្តតែទ្រាំនៅរួមរស់ជាមួយគាត់រហូតមកដល់បច្ចុប្បន្នកាលនេះ ក៏ខ្ញុំនៅតែមានភាពឈឺចាប់ដែរចំពោះគ្រួសារ

---

[3228] ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា "ក្រោយមក រៀបការរួច ខ្ញុំរយៈពេលបានមិនពេញ៣ខែស្រួលបួលទេ ត្រូវទាំងផុន ទាំងខ្ញុំហើយនិងពីរនាក់ទៀតនៅស្រុកស្អាងជាមួយខ្ញុំហ្នឹង ផ្លាស់ទៅក្រចេះ ទាំងគាត់ ទាំងខ្ញុំហ្នឹងទៅ ប៉ុន្តែខ្ញុំឲ្យស្រីៗនៅនេះទៅ ចាំយកតាមក្រោយ កាលហ្នឹង"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/465.1** ទំព័រ ២០ បន្ទាត់ ២៥ - ទំព័រ ២១ បន្ទាត់ ២។

[3229] "ខ្ញុំមកនៅក្រចេះណោះរហូត។ ចូលៗយួនមកហើយ ខ្ញុំឡើងភ្នំដងរែក ចុះមកវិញមកទៀត លែងបានទៅណា ទៅយកប្រពន្ធក្នុងជួរហ្នឹងទៀត។ ក៏បងផុន ហ្នឹងរៀបការឲ្យទៀត ហើយប្រពន្ធ អើមកនៅស្រុកស្អាង អំស្រុកស្រែក្នុងហ្នឹង ដូងភូមិភូមិនៅ ! – ជាមួយបងមុតឯនេះទៅនោង គាត់បងផុន ហ្នឹតែស៊ើបសួរ សួរចេះ ថាទៅនៅគាត់ ក៏ជ្រាបបងផុន ហ្នឹង ដែលបានឮដំណឹងអត់អស់ទេណោះ គ្រាន់ដំណឹង តែមិនបានដឹងនេះណោះ ប៉ៃលិន សំឡូតឯជិតឯៗម្តុំមាស មុត នៅ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សេង សឿន ប្រតិចារឹក ថ្ងៃទី ២៩ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/465.1** ទំព័រ ២១ បន្ទាត់ ៥-១០។

[3230] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៤៧ បន្ទាត់ ២៤ - ទំព័រ ៤៨ បន្ទាត់ ១។

[3231] "ដល់មកការជាមួយខ្ញុំហ្នឹង ដល់រួចមកបែកជាមួយខ្ញុំហ្នឹង អត់ដឹងថាគាត់ទៅណា ទៅម៉ែឪបងប្អូនវិញ ក៏មិនដឹងថាទៅណាទេ ព្រោះអត់មានម៉ែឪនោះ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៧៥ បន្ទាត់ ២៤-២៥។

របស់ខ្ញុំ តែខ្ញុំសុខចិត្តទ្រាំ ដោយសារកូន បានជាកូនហើយ ខ្ញុំមិនចង់ឱ្យកូនបែកបាក់ទៅខាងណាមក ខាងណាទេ។ ខ្ញុំក៏ទ្រាំរស់ទាំងការឈឺចាប់រហូតមកដល់សព្វថ្ងៃ"[3232]។

1391. ក្រោយរបបនោះ ដើមបណ្តឹងរដ្ឋប្បវេណី ថៅ ឡាង និងប្តីគាត់មានកូនបីនាក់[3233]។ ទោះជាយ៉ាង នេះក្តី ប្តីប្រពន្ធនេះបានលែងលះគ្នា[3234] ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា ដោយសារក្រុម គ្រួសារប្តីគាត់ចង់ឱ្យគាត់រៀបការជាមួយអ្នកមាន[3235]។

## ឃ. ព្យសនកម្ម

### ១. ព្យសនកម្មផ្លូវកាយ

***ព្យសនកម្មផ្លូវកាយដែលស្ត្រីមានផ្ទៃពោះ និង ស្ត្រីដែលមានកូនដំបូងបានទទួលរង***

---

[3232] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៣៩ បន្ទាត់ ២-៧។

[3233] "នាងខ្ញុំ កូនទី១កើតឆ្នាំ៨០ កូនទី២ឆ្នាំ៨៣ កូនទី៣ឆ្នាំ៨៥"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ថៅ ឡាង ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ៦៤ បន្ទាត់ ១៩។

[3234] គាត់បានពន្យល់ថា "នាងខ្ញុំលែងលះគ្នានេះ ដោយសារតែការរៀបការដោយបង្ខំសម័យខ្មែរក្រហម គឺឪពុកម្តាយខាងប្តីខ្ញុំហ្នឹង គាត់មិនពេញចិត្ត។ មកសម័យនេះ ឃើញខ្ញុំជាមនុស្សអត់បងអត់ប្អូនអត់ម៉ែឪ អត់មានភូមិករ ដីធ្លី ជាមនុស្ស គេចាត់ទុកថាជាមនុស្សមួយអត់មានគោលដៅ។ អ៊ីចឹងម្តាយក្មេកខ្ញុំ គាត់ៗស្វែងរកចង់ឱ្យកូនគាត់មានគ្រួសារអ្នកដែលមានឪពុកម្តាយ អ្នកដែលមានភូមិ ដីស្រែចម្ការចាស។ មូលហេតុទាំងអស់នេះហើយធ្វើឱ្យខ្ញុំដាច់ចិត្តលះលែងប្តីរបស់នាងខ្ញុំ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ថៅ ឡាង ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ៦៤ បន្ទាត់ ២៥ - ទំព័រ ៦៥ បន្ទាត់ ៤។

[3235] "យើងមិនៗធ្វើការសម្រេចចិត្តលែងលះ មិនមែនជាការសម្រេចបានទេ ដោយសារថាពេលនោះមិនទាន់ដឹងថា យើងទៅដល់ទីដៅរបស់យើង ស្រុកទេសរបស់ខាងគាត់នោះ ឬក៏ខាងខ្ញុំនេះវាអាចជួបអ្នកណា ឬក៏យ៉ាងម៉េច ឬក៏ជួបគ្រួសារ ឬក៏ជួបយ៉ាងណានោះ វាពុំទាន់ដឹង។ ណាមួយយើងពុំបានរកកន្លែងទីដៅពិតប្រាកដរបស់គាត់ ពួកគាត់។ នៅពេលដែលយើងរកឃើញភូមិអ្នកលឿងរបស់គាត់នោះ ជាភូមិស្រុកកំណើតរបស់គាត់ យកគាត់ទៅទុកដាក់ទីនោះហើយនោះ បានធ្វើផ្ទះជូនគាត់ហើយនោះ ទើបគាត់មានគំនិតថា ចង់រកប្រពន្ធដែលមានផ្ទះមានសម្បែងមានដីធ្លីមានស្រែចម្ការ ចាសពេលនោះ។ ហើយក៏មិនមែនថា យើងនឹងងាយនឹងសម្រេចចិត្តថា លែងបានទេ ដោយសារថាប្តីប្រពន្ធនាងខ្ញុំពុំមានអ្វីដែលជាទំនាស់ ឬមានការឈ្លោះទាស់ទែងគ្នានោះទេ ខំប្រឹងតែរកទេ។ តែដោយសារថាម្តាយរបស់គាត់មិនពេញចិត្ត ខ្ញុំតូចចិត្តខ្លួនឯង គឺខ្ញុំចុះចេញ លែងលះពីគាត់ហ្នឹង"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ថៅ ឡាង ប្រតិចារឹក ថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០១៥ ឯកសារ **E1/339.1** ទំព័រ ៦៥ បន្ទាត់ ២៥ - ទំព័រ ៦៦ បន្ទាត់ ៨។

1392. កូនរបស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន កើតនៅ "ចុងឆ្នាំ ១៩៧៨"[3236]។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់អំពីការឈឺចាប់ដែលបានទទួលរងដោយការចាញ់កូន។ "ចាញ់កូន ខ្ញុំតាំងចាប់ពីតាំងពីមួយខែទៅខ្ញុំចាញ់រហូត រហិតរហៃដៃជើង ហើយណាមួយហូរទឹកមាត់ធ្វើការបណ្តើរចាញ់ហ្នឹងបណ្តើរ ជួនកាលវិលទៅ ដាក់ឱបដើមកៅស៊ូទៅចៀរជ័រ សាជ័រចានអ៊ីចឹងទៅ រហូតខ្ញុំរស់នឹងបានស្លឹកបាស យកមកដល់ដុតទៅ អាំងទៅអ៊ីចឹងទៅនៅក្នុងគំនរសំរាម អាស្លឹកកៅស៊ូហ្នឹងទៅបានហូបមួយពេលៗហ្នឹងទៅ បាយមិនសូវនេះទេ ព្រោះចាញ់រហិតរហៃរហូត ដល់តែធ្វើការយូរទៅ កូនហ្នឹងអត់មានបង្រះទេ រហូតដល់កូនហ្នឹងប្រាំពីរខែ"[3237]។

1393. ក្នុងអំឡុងពេលមានផ្ទៃពោះ "សុំឈប់ដែរ ប៉ុនគេមិនឲ្យឈប់ យើងចេះតែធ្វើអបៗតាមគេទៅវិញទៅចាស អត់មាននេះទេ អត់មានសម្រាកទេ ព្រោះឃើញយើងដើរជើងទៅរាងយើងរាងនេះដែរទៅ គេអត់ឲ្យឈប់ទេ ទាល់តែពេលយើងឡើងជិតដល់ឆ្លងទន្លេ បានគេឲ្យឈប់។ ទៅពិនិត្យគេទៅគេថាកូនហ្នឹងខ្សោយ គ្រាន់តែប្រាប់តែប៉ុណ្ណឹង"[3238]។ "កើតរួចមកបានប្រហែលជា ១០ថ្ងៃទៅ ១៥ថ្ងៃហ្នឹង បានៗប៉ុណ្ណឹងចេញធ្វើការទៀត"[3239]។

1394. បន្ទាប់ពីឆ្លងទន្លេរួច ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន មិនមានទឹកដោះឲ្យកូនបៅ ដែលកូននោះមានសុខភាពទន់ខ្សោយទៅហើយនោះ៖ "សុខភាពកូនទុំង ព្រោះវាមិនសូវជាមិនសុខភាពល្អទេ។

[3236] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៨ បន្ទាត់ ៤-៥។

[3237] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ទំព័រ ៨ បន្ទាត់ ១៥-១៩។

[3238] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ២១ បន្ទាត់ ២០-២៣។ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា គាត់ ១៥ថ្ងៃទៅ ១០កើតរួចមកបានប្រហែលជា "ងចេញធ្វើការទៀតថ្ងៃហ្នឹង បានៗប៉ុណ្ណឹ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ទំព័រ ២១ បន្ទាត់ ១៥។

[3239] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ២១ បន្ទាត់ ១៥។ ដើមបណ្តឹងរដ្ឋប្បវេណីបានពិពណ៌នាថាបានសម្រាករយៈពេលខ្លីក្រោយពេលឆ្លងទន្លេរួច។ " បានមួយអាទិត្យទៅកន្លះខែហ្នឹង បានមួយអាទិត្យទៅពីអាទិត្យហ្នឹង មិនដល់ផង។ គេឲ្យទៅក្រុងស្បូវ គេឲ្យទៅជម្រះស្មៅអ៊ីចឹងទៅ។ កូនហ្នឹងចងអង្រឹងជាប់នឹងរោងគេហ្នឹងទៅ។ បើយំទៅ យើងមកឲ្យវាអឺមវិញទៅ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ១១ បន្ទាត់ ៦-៨។

រួចដល់តែពេលទៅ ខ្ញុំហ្នឹងក៏អត់មានទឹកដោះដែរ ព្រោះហូបមិនបានដិកដល់ ក្នុងមន្ទីរក៏ដោយ ចេញមកក្រៅ ប៉ុន្តែចំពោះខ្ញុំផ្ទាល់ អត់មានទឹកដោះទេ សូម្បីតែនេះក៏អត់មានទឹកដោះដែរ ព្រោះទឹកដោះចេញមកតិចៗ។ កូនបៅចេះតែតាមធម្មតាទៅ។ វាចេះតែកាច វាចេះតែយំទៅ"[3240]។

1395. ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន បានផ្តល់សក្ខីកម្មថាពុំបានទទួលរបបអាហារគ្រប់គ្រាន់ ខ្វះថ្នាំពេទ្យ និងបន្ទុកការងារដែលកំណត់ចំពោះស្ត្រីមានផ្ទៃពោះ[3241] បានរៀបរាប់ថា ក្រោយពេលឆ្លងទន្លេបាន មួយរយៈខ្លី ត្រូវគេឱ្យទៅធ្វើការទៀត[3242] និងទទួលការចាត់តាំងឱ្យធ្វើការងារផ្សេងៗ ក្រោយពេលកូនគាត់ស្លាប់[3243]។

---

[3240] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ១០ បន្ទាត់ ១៩-២២។

[3241] "អ្នកដែលមានផ្ទះពោះក៏ឱ្យធ្វើការ ចាប់ពីមានកូនមួយខែទៅដល់ប្រាំខែ គេឱ្យធ្វើការ៦ម៉ែត្រពេញ។ ៦ម៉ែត្រពេញ ដល់កូនទម្ងន់បាន៦ខែទៅ៧ខែ អានោះគេបន្ថយឱ្យ៤ម៉ែត្រ។ ៤ម៉ែត្ររហូតទៅដល់៩ខែ បានគេឱ្យសម្រាក ឱ្យទៅកិនស្រូវវិញ។ គេអត់ឱ្យមានសម្រាកនេះទេ ហើយរឿងអាហារហូបចុក អត់មានទេ។ ហូបធម្មតាដូចតែអ្នកធ្វើការធម្មតា បបរហូបដូចតែគ្នា។ សហករណ៍គេវ៉ៃជួងទៅ យើងកាន់ចានទៅដល់នេះទៅ ក៏កាន់តែស្លាបព្រាចានទៅ ក៏ទៅហូបនឹងសហករណ៍ហ្នឹងទៅ។ មានអីហូប ក៏ហូបនឹងសហករណ៍ហ្នឹងទៅ។ បើអត់ក៏អត់នឹងសហករណ៍ហ្នឹងទៅ។ អត់មានយកមកហូបនឹងផ្ទះបានទេ។ នៅលើផ្ទះឱ្យតែអង្ករតែកន្លះកំប៉ុង យប់នេះបាត់ហើយ អត់មានមនុស្សនៅផ្ទះទេ។ យើងលាក់អង្ករស៊ីងកជន ស៊ីស្ទូនតួ គេយកទៅសម្លាប់ហើយ គេអត់មានទុកទេ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៦៦ បន្ទាត់ ៤-១១។

[3242] "កាលដែលខ្មែរក្រហមចូលមកគេឱ្យខ្ញុំធ្វើការ ហើយដែលខ្ញុំកូនខ្ចី គេឱ្យកិនស្រូវ។ ហើយពីមុនដំបូងមក គេល្អជាមួយយើង តែទៅចូលដល់ គិតត្រឹមតែមួយខែ គេប្រមូលទ្រព្យសម្បត្តិយើងដាក់រួមទាំងអស់ អត់មានឱ្យសល់ទេ។ សូម្បីតែគោរក្របី មាស ប្រាក់អីគេប្រមូលទាំងអស់ អត់មានទុកទេ។ ហើយគេប្រើឱ្យកិនស្រូវ ប្រើឱ្យប្តីឡើងត្នោតនៅក្នុងសហករណ៍"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៣៥ បន្ទាត់ ២-៥។

[3243] "កាលដែលកូនខ្ញុំនៅតូច គេឱ្យនៅកិនតែស្រូវហ្នឹងឯង។ អត់មានឱ្យទៅណាទេ នៅក្នុងសហករណ៍សិន។ លុះដល់កូនខ្ញុំស្លាប់ បានគេឱ្យខ្ញុំចល័តទៅលើកភ្លឺស្រែ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៣៥ បន្ទាត់ ៨-៩។

1396. ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានផ្ដល់សក្ខីកម្មថា មួយរយៈខ្លីក្រោយពេលគាត់ឆ្លងទន្លេរួច គេបានបង្ខំឱ្យគាត់ធ្វើការរហូតគាត់ "ធ្លាក់ខ្លួនឈឺ និងមិនអាចដើររួច"[3244]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានពន្យល់ថា "ធ្ងន់បំផុតសម្រាប់មនុស្សស្ត្រីដែលសរសៃខ្ចី ព្រោះកាលណាលើកពីរនាក់វាធ្ងន់ហើយ បើនិយាយរួមទៅ សម្រាប់តែបុរសទេ ប៉ុន្តែពេលហ្នឹងគេប្រើយើងអត់គិតពីបុរស ឬស្ត្រីទេ។ គេគិតតែធ្វើម៉េចឱ្យយើងធ្វើ ស្លាប់ក៏គេមិនស្ដាយដែរ"[3245]។

1397. ដោយសារការងារធ្ងន់ ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន ពុំមានទឹកដោះឱ្យកូនបៅទេ។ "ក្រោយពីធ្វើការងារ ខ្ញុំមានជំងឺទាស់សរសៃទៅ ធ្វើឱ្យខ្ញុំអត់មានទឹកដោះឱ្យកូនបៅទេ។ ដល់អ៊ីចឹងកូនខ្ញុំហ្នឹង វាធ្លាក់ខ្លួនទៅជាស្គមរីងរៃ ដូចគេបង្អត់បាយអ៊ីចឹង។ ទៅសុំទឹកបបរគេបញ្ចុកកូន។ អ៊ីចឹងធ្វើឱ្យកូនខ្ញុំស្គមស្លេកស្លាំង។ នាងខ្ញុំឆ្អែតហើយ ខ្ញុំនិយាយអត់ចង់ចេញទេ ខ្ញុំនិយាយពីរឿងកូនខ្ញុំ ឆ្អែត"[3246]។

1398. ក្រោយពេលគាត់មានផ្ទៃពោះ ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន បានរៀបរាប់ថា "កាលណាខ្ញុំមានផ្ទៃពោះ ខ្ញុំលំបាក ហូបបបរមិនបាន បបរលាយមកហើយ ហុតតែទឹកបន្តិចៗទៅ ក្លួតចង្អោរអស់។ មិនបានឱ្យបានស្រួលទេ ពេលខ្ញុំមានផ្ទៃពោះ វេទនាណាស់ ខ្ញុំស្គមសល់តែក្បាល ធ្វើការទាំងស្គមស្គាំងហ្នឹង ដោយគេមិនឱ្យយើងឈប់សម្រាកទេ។ សម័យនោះ គេមិនឱ្យយើងសម្រាកទេ តែនរណាឈឺ គឺឈឺសតិអារម្មណ៍ហើយ គេមិនឱ្យយើងឈប់ទេ"[3247]។

---

3244 "ក្រោយសម្រាលកូនបាន២ខែ គេឱ្យទៅកាប់ស្លឹកត្នោត ទូលបាច់ គេចងបាច់ឱ្យស្រេច ប៉ុនៗណេះ។ ឱ្យទូលយកមកដេរប្រក់រោងបាយ។ អ៊ីចឹងខ្ញុំទៅធ្វើទាំងសរសៃខ្ចី ធ្វើរហូតដល់ខ្ញុំទាស់ ដើរលែងរួច"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៨១ បន្ទាត់ ៥-៧។

3245 គាត់បានពន្យល់លម្អិតថា គាត់ "ប្រឹងលើកពីរនាក់ យាយ យន់។ យាយ យន់ ហ្នឹង គឺគាត់នៅជាមួយខ្ញុំហ្នឹង គាត់ចាស់។ រួចគេប្រើចាស់ និងក្មេង ហើយគាត់ចាស់ ខ្ញុំក្មេង ប៉ុន្តែខ្ញុំសរសៃខ្ចី។ ឱ្យទៅទូល ក្នុងស្លឹកត្នោតមួយដើមហ្នឹង ទូលពីរនាក់គាត់ មានតែបីជើងឯណោះ បានអស់។ រួចចងបាច់ឱ្យធំៗ លើកឱ្យណែនផ្ទះ។ អ៊ីចឹងការងារនេះ គឺធ្ងន់ធ្ងរបំផុតសម្រាប់រូបខ្ញុំ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៨១ បន្ទាត់ ១៣-១៤។

3246 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៨១ បន្ទាត់ ២០-២៣។

3247 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៣៧ បន្ទាត់ ២២-២៥។

1399. ដោយសារកាលៈទេសៈ និងការស្លាប់កូនដំបូងរបស់គាត់ ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន បានពន្យល់ថា "ភ័យ។ ភ័យហើយមានកូនលើកទី២ហ្នឹង នាងខ្ញុំធ្វើការធ្ងន់ជាងលើកទី១ទៀត។ ធ្វើការធ្ងន់ ហើយនឹកបារម្ភ ព្រួយបារម្ភរាល់ថ្ងៃ នឹកគិតថា ខ្លាចលោកូនហ្នឹងកើតមកស្លាប់ដូចជាកូនទី១"[3248]។

## *កង្វះថ្នាំពេទ្យ និងជំនួយផ្នែកពេទ្យបណ្ដាលឱ្យមានការលំបាកឆ្លងទន្លេ/រលូតកូន*

1400. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន បានពន្យល់ថា ពេលគាត់មានផ្ទៃពោះដល់ខែទី៧ "អត់មានបង្រះ ហើយដល់ទៅគេឱ្យទៅពេទ្យម្ដង ពេទ្យគេថាកូនហ្នឹងវាខ្សោយ ហើយគេឱ្យមកវិញធ្វើការតាមធម្មតាវិញដដែល"[3249]។ ក្រោយពេលគាត់ឆ្លងទន្លេរួច កូននោះតូចណាស់[3250] ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន បានរម្លឹកថា "មានតែពេទ្យហ្នឹងសម្រាលកូនរួចទៅ យើងដើរមកដល់កន្លែងគ្រែអាំងភ្លើងហ្នឹងទៅ គ្រែហ្នឹងធ្វើរោង គ្រែរបៀបដូចយើងគ្រែដេកនៅលេងក្រោមផ្ទះអ៊ីចឹង។ ប៉ុនគ្រែហ្នឹងធ្វើមិនស្អាតទេ។ នៅដេកនៅហ្នឹងទៅ គេដាក់ភ្លើងដាក់អីហ្នឹងទៅ អាំងនៅហ្នឹងទៅ។ អត់មានអ្នកណាទៅបម្រើទេ"[3251]។ "មានអាថ្នាំដបទឹកក្រូចហ្នឹង បន្លោង។ បើសិនជាយើងអត់ស្រួលខ្លាំងអី គេទៅបន្ដោងសេរ៉ូមមួយដបទឹកក្រូចហ្នឹងឱ្យទេ អត់មានអានេះ ចាក់ថ្នាំក៏ចាក់ថ្នាំអាដបទឹកក្រូចហ្នឹងដែរ។ ហើយដល់លេប បើឱ្យថ្នាំលេប ក៏ថ្នាំអាចម៍ទន្សាយហ្នឹងដែរ គ្មាននេះអីទេ។ ហើយមន្ទីរពេទ្យគេហ្នឹង អត់មានអគារអីណាធំទេ ធ្វើរោងទាល់របៀបដូចយើងរោងហាលពោតអ៊ីចឹង"[3252]។ "អត់មានទេ អារឿងសំឡីអនាម័យ រឿងសំឡីអីហ្នឹង គឺគ្មានទេ។ កំណាត់កូនគឺ

---

[3248] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៣៨ បន្ទាត់ ៥-៦។

[3249] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៩ បន្ទាត់ ១-២។

[3250] ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មថា "កូនហ្នឹងកើតមកតូចហ្នឹង។ ប៉ុននៅជំនាន់នុំងគ្មានជញ្ជីងអី គ្មានអីថ្លឹងទេ ចាស។ មានអីថ្លឹង មួយជំនាន់នុំង ដែលមានពីណាមើលថ្នាក់ថ្នមស្អី"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ១០ បន្ទាត់ ៧-៨។

[3251] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ៩ បន្ទាត់ ១៧-២០។

[3252] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ១០ បន្ទាត់ ១-៤។

ខ្ញុំ នាងខ្ញុំមកលេង មកសុំគេមកលេងផ្ទះជិតសម្រាលអ៊ីចឹងទៅ បានកំណាត់ ហែកកំណាត់កញ្ចាស់ៗពីផ្ទះយើងទៅដាក់ ទៅទុកប្អូនដប់ទៅ ត្រង់ឲ្យមានច្រើន គឺគ្មានទេ ព្រោះនៅនុំង ចែកខោអាវក្នុងម្នាក់ បានតែមួយខែពីរខែអ៊ីចឹង។ ជួនណាបានមួយកំប្លេ ជួនកាលអស់សោះទេ អត់មានស្អីគ្រប់គ្រាន់ទេ”[3253]។

1401. ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន បានផ្តល់សក្ខីកម្មថា ក្នុងពេលគាត់មានផ្ទៃពោះ “អត់ដែលមានថ្នាំអីទេ។ ពេលកើតហើយ ក៏ដាំកាប់តែដើមឈើហ្នឹងយកមកស្ងោរដែលត្រូវថានឹងកូន ខ្ញីក៏យកមកស្ងោរហូប អត់មានថ្នាំអីចែកទេ អត់មានទទួលខុសត្រូវទេ។ បើគេប្រើគេប្រើ ដល់ទទួលខុសត្រូវនឹងថ្នាំសង្កូវដែលយើងសម្រាល ឬក៏មានផ្ទៃពោះ អត់មានទេ អត់មានឲ្យទេ”[3254]។

1402. ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានពន្យល់ថា “បើនិយាយជីវិតអ្នកឆ្លងទន្លេសម័យនុំងវិញផ្សងព្រេងគ្មានពេទ្យ គ្មានឆ្មបជំនាញទេកើតដោយអ្នកចេះបន្តិចបន្តួច។ បើខ្ញុំ ៗកើតហ្នឹងអ្នកជិតខាងគាត់នៅក្បែរនុំងក្មេងដែរ ប៉ុន្តែដល់ពេលយើងគ្មានទៅ គាត់ថាមិនអីទេចាំខ្ញុំបង្កើតឲ្យ។ អ៊ីចឹងក៏គាត់មកបង្កើតទៅ បានសុខស្រួលដែរ អត់មានបញ្ហាអីទេ”[3255]។

1403. ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានផ្តល់ចម្លើយថា “បានឪពុកខ្ញុំគាត់ផ្សំថ្នាំខ្មែរទុកឲ្យផឹក។ ដូចថាទម្លាក់ឈាមក្នុងខ្លួនឲ្យអស់ កុំឲ្យវាកកដុំអ៊ីចឹងគាត់ដាំថ្នាំឲ្យផឹក។ បើសិនជារឿងថ្នាំពេទ្យ ឬក៏មានអ្នកជំនាញខាងបង្កើតហ្នឹង គ្មានសោះហើយ សង្គមហ្នឹងគឺគ្មានតែម្តង កើតទៅតាមយថាកម្មទេ”[3256]។

---

[3253] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/462.1** ទំព័រ ១០ បន្ទាត់ ១២-១៥។

[3254] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៦៦ បន្ទាត់ ១៥-១៨។

[3255] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៦៩ បន្ទាត់ ១៣-១៦។

[3256] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៦៩ បន្ទាត់ ១៦-១៨។

## ២. ព្យសនកម្មផ្លូវចិត្ត

*ព្យសនកម្មផ្លូវចិត្តភ្លាមៗ ដោយសារការរៀបការ*

1404. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន បានផ្តល់សក្ខីកម្មថា "ខ្ញុំពិបាកចិត្ត ហើយខ្ញុំអត់ចង់បានគ្រួសារហ្នឹងផង"[3257]។ "ខ្ញុំអត់ពេញចិត្ត ហើយនិងគេបង្ខិតបង្ខំខ្ញុំ ហើយខ្ញុំនឹកអន់ចិត្តខ្លួនខ្ញុំ ខ្ញុំអត់អាចហួបកើត"[3258]។ ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន បានពន្យល់ថា គាត់អន់ចិត្ត និងមិនពេញចិត្តនៅពេលនោះ "មនុស្សដែលអត់ស្គាល់គ្នា។ មនុស្សខ្ញុំអត់ពេញចិត្ត"[3259]។

1405. ដើមបណ្តឹងរដ្ឋប្បវេណី ជា ឡៀប បានផ្តល់សក្ខីកម្ម គាត់មិនចង់បានប្តីទេ តែគាត់គ្មានជម្រើសណាផ្សេង[3260]។ "ខ្ញុំគ្មានសប្បាយចិត្តអីម៉ាបន្តិចណាទេ ខ្ញុំមានតែទឹកភ្នែករហូតហ្នឹង។ តាំងពីមិនទាន់ចូលផ្ទឹមរហូតផ្ទឹម ផ្ទឹមរួចទៀត ខ្ញុំយំរាល់តែថ្ងៃ មិនថាយប់ មិនថាថ្ងៃទេ ព្រោះខ្ញុំ ខ្ញុំឈឺចិត្តណាស់ ប៉ុន្តែមិនដឹងធ្វើម៉េច"[3261]។

1406. ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន បានផ្តល់សក្ខីកម្មថា នៅថ្ងៃគាត់រៀបការ "អារម្មណ៍របស់ខ្ញុំអត់មានសប្បាយ គឺខ្ញុំភ័យហើយខ្ញុំខ្លាច ហើយខ្ញុំខ្លាចប្តីវិលមកវិញ។ ដល់ថ្ងៃរៀបការហ្នឹង ខ្ញុំអត់មានសប្បាយចិត្តទេ ព្រោះខ្ញុំអត់ស្រឡាញ់ ខ្ញុំអត់សប្បាយទេ ព្រោះបង្ខំខ្ញុំឲ្យរៀបការតែម្តង"[3262]។ ដើម

---

[3257] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/461.1** ទំព័រ ៧៥ បន្ទាត់ ២៤។

[3258] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/461.1** ទំព័រ ៧៦ បន្ទាត់ ២។

[3259] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ុំ យឿន ប្រតិចារឹក ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/461.1** ទំព័រ ៧៦ បន្ទាត់ ៣។

[3260] "មិនពេញចិត្តទេ ខ្ញុំក៏មិនចង់ទាន់ចង់បានប្តីដែរ ប៉ុន្តែបើអង្គការរៀបហើយ ដូចខ្ញុំបាននិយាយ ធ្វើម៉េច ថាគេដូចខ្ញុំនិយាយទៅថាទៅតាមដំណើរទៅ បើអង្គការឲ្យរៀបការហើយ បើខ្ញុំប្រកែក ក៏ប្រកែកមិនបាន ម្ល៉ោះហើយមានទៅតាមដំណើរដែលអង្គការរៀបការឲ្យ ទៅតាមហ្នឹងទៅ មិនដឹងធ្វើម៉េច ប្រកែកម៉េចទៀត បើទៅហើយ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឡៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៦០ បន្ទាត់ ២០-២៣។

[3261] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឡៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៦១ បន្ទាត់ ១-៣។

[3262] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៤៣ បន្ទាត់ ២-៤។

បណ្ដឹងរដ្ឋប្បវេណីបានពន្យល់ថា ប្ដីប្រពន្ធទាំងអស់នៅឯពិធីរៀបការរបស់គាត់ត្រូវបានបង្ខំឲ្យរៀបការ គ្មាននរណាម្នាក់ពេញចិត្តនឹងការរៀបចំទេ ប្ដីប្រពន្ធទាំង ៦០ គូសុទ្ធតែយំ[3263]។

1407. ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានផ្ដល់សក្ខីកម្មថា នៅកន្លែងរៀបការ "ខ្ញុំក៏ទៅៗក៏បានឃើញនារីៗនៅនុំងទៅ ស្គាល់ខ្លះ មិនស្គាល់ខ្លះ។ ក៏ឃើញគេយំ ខ្ញុំក៏យំនឹងគេទៅ ខ្ញុំមានបានដឹងថា ការហ្នឹង វាមានរបៀបជោគជ័យសប្បាយអី ខ្ញុំអត់ដឹង ដឹងតែពីសេចក្ដីសោកទុក្ខព្រួយខ្ញុំ"[3264]។ ក្នុងពេលពិធីរៀបការ "ខ្ញុំអង្គុយខាងហ្នឹងជាមួយនារីៗហ្នឹងទៅ ដល់គេហៅអ៊ីចឹង យើងមិនបានចាប់អារម្មណ៍ថាយើងហ្នឹងរៀបការរៀបអី គិតតែយំ សោកសង្រេង ស្ដាយខ្លួន ស្ដាយម៉ែឪដែលគាត់អត់បានដឹង"[3265]។

1408. ដើមបណ្ដឹងរដ្ឋប្បវេណី កុល ណៃម បានផ្ដល់សក្ខីកម្មថា នៅថ្ងៃគាត់រៀបការ "ខ្លួនខ្ញុំដែរ ក៏យើងគោរពគេហើយយើងទៅ តែក្នុងចិត្តនៅក្ដុកក្ដួល នៅលំបាក។ បាទ សុខចិត្តទៅទាំងទ្រាំ ទាំងមុខស្ងួតទៅទាំងគ្រាំគ្រាបាទ"[3266]។

1409. ដើមបណ្ដឹងរដ្ឋប្បវេណី ង៉ែត ចាត បានរៀបរាប់ថា "អារម្មណ៍បេះដូងខ្ញុំចង់គាំងបន្តិច ញ័របន្តិច។ មើលទៅឃើញគេ ខ្ញុំយំអត់ហ៊ានឲ្យគេឃើញទេ ខ្ញុំបិទភ្នែកយំធ្វើហៀរទឹកភ្នែក ខ្ញុំអត់ហ៊ានយំ

---

[3263] "បានជាខ្ញុំដឹងថា គេចាប់បង្ខំទាំងអស់គ្នា ព្រោះគូភាគីដែលរៀបការនឹង៦០គូនោះ សុទ្ធតែយំទាំងអស់ យំទាំងអស់។ មកឈរជុំគ្នាយំទាំងអស់ ទាល់តែពួកគេមកដល់ បាននាំគ្នាជូតទឹកភ្នែកហើយ ឈប់យំ។ ចាំគេហៅដាក់តម្រៀបជួរគ្នាទៅ។ អត់មានអ្នកណាស្ម័គ្រចិត្តមួយទេ។ ៦០គូនោះ ជីដូនជីតាណាដែលរៀបការ៦០គូម្ដងនោះ បើមិនយំទេ ហួសពេក។ ទាំងខ្ញុំទាំងគេ យំតែទាំងអស់គ្នាហ្នឹងឯង មិនថាមេម៉ាយ មិនថាក្រមុំអីទេ យំតែទាំងអស់ហ្នឹង។ ណាមួយមិនស្ដាយខ្លួន មិនមានសួរម៉ែប្រាប់ម៉ែមួយម៉ាត់ផង វាមានច្បាប់អី សូម្បីតែចំណុចមួយអក្សរមួយអង្គអី មានច្បាប់សុំពីម៉ែឪមករៀបការឯណាក៏គ្មាន ចាប់ដាក់ ចាប់ដាក់ស្រេចតែនឹងអំពើចិត្តដែលបានធ្វើនោះ។ អាកន្លែងត្រង់ណោះហើយ ដែលយំនោះ យំទាំងអស់គ្នា អត់មាននេះទេ។ មកជុំគ្នាទាំង៦០នាក់ហ្នឹងយំមើលមុខគ្នាបណ្ដោយទៅ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៨០ បន្ទាត់ ១៦-២៣។

[3264] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៥៧ បន្ទាត់ ២៣-២៥។

[3265] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៥៨ បន្ទាត់ ២១-២៣។

[3266] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី កុល ណៃម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៧០ បន្ទាត់ ៤-៥។

ខ្ញុំចេះតែក្លាហាន គេនិយាយប្រាប់ថា ប្ដេជ្ញាចិត្ត ចេះតែស្រែកនឹងគេ នឹងឯងអីចឹង។ ប៉ុន្តែអារម្មណ៍នោះ វាញ័រអស់ ចង់សន្លប់បន្តិចអីបន្តិច”[3267]។

1410. ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន បានរៀបរាប់ពីអារម្មណ៍ភ័យខ្លាច និងច្របូកច្របល់ នៅពេលគាត់ដឹងថា គាត់នឹងត្រូវរៀបការ៖ “ខ្ញុំភ័យពេក មិនដឹងធ្វើម៉េច ចេះតែនៅអង្គុយតែស្ងៀមតែក្នុងខ្លួនហ្នឹង ដូចចង់ទៅជាគ្រុនចាញ់ហើយ”[3268]។

***ព្យសនកម្មដែលភ្ជាប់ទៅនឹងការពុំមានរៀបចំពិធីបែបប្រពៃណី***

1411. ដើមបណ្ដឹងរដ្ឋប្បវេណី យស ផល បានរម្លឹកថា ក្នុងរបបនោះ ដែលគាត់ហៅថា “សម័យតិរច្ឆាន” ពិធីរៀបការត្រូវបានធ្វើឡើងខុសគេ។ ពុំមានសម្លៀកបំពាក់រៀបការសមរម្យទេ[3269] ហើយ “ក្រឡេកទៅមើលជុំវិញ គ្មានបងប្អូនទេ មានតែមេកងឃោរឃៅចាំតែលើកដំបង ចាំតែលើកកាំបិតប្រហារជីវិត។ រួចសម័យមុនមានបងប្អូននៅជុំវិញឲ្យពរ ឲ្យជ័យ ញញឹមញញែម បើសម័យខ្មែរក្រហមមានតែដំបង មានតែកាំបិត ចាំតែឲ្យតែធ្វើមិនត្រឹមត្រូវមិនដើរតាមអង្គការ កម្ទេចចោល”[3270]។ “ណាស់ ខ្ញុំមិនចង់បានរបបខ្មៅកខ្វក់ហ្នឹងមកទៀតទេ ស្អប់ណាស់”[3271]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានគូសបញ្ជាក់ថា “ពិធីមង្គលការនេះវា ពីមុនមក ហើយមកដល់សម័យកាល

---

[3267] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ង៉ែត ចាត ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៥ បន្ទាត់ ១៣-១៥។

[3268] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ២៨ បន្ទាត់ ៩-១០។

[3269] ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មថា “សម័យរបបប៉ុលពត របបខ្មែរក្រហម ដូចជាព្រៃផ្សៃណាស់ ចាប់បង្ខំឲ្យរៀបការចំពោះខ្ញុំវិញ ខ្លួនខ្ញុំតែម្ដងគ្មានខោអាវស្លៀកទេ ខោអាវមួយកំប្លេប្រលាក់សុទ្ធតែដី ដាចទៀត ខោក៏ដាច អាវក៏ដាច កន្សែងក៏ដាច ខ្លួនក៏ស្គម”។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ១៨ បន្ទាត់ ២០-២២។

[3270] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ១៨ បន្ទាត់ ២២ - ទំព័រ ១៩ បន្ទាត់ ១។

[3271] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ១៩ បន្ទាត់ ២។

ឥឡូវនេះ ចូលដូចពីមុនវិញ ល្អណាស់។ ហើយអាសម័យ ៣ឆ្នាំ ៨ខែ ២០ថ្ងៃហ្នឹង តួអង្គខ្ញុំហ្នឹង ប្រេតតិរច្ឆានសុទ្ធតែម្តង"[3272]។

1412. ដោយប្រៀបធៀបទម្លាប់រៀបការមុន និងក្រោយរបបខ្មែរក្រហម ដើមបណ្តឹងរដ្ឋប្បវេណី ជា ឡៀប បានផ្តល់សក្ខីកម្មថា "គឺថាខុសគ្នាដាច់។ ដូចសម័យខ្មែរក្រហមរៀបការតែហៅដាក់ៗ ម្តងបួនដប់គូ ម្តង បួនប្រាំគូ ម្តង១០០គូ ក៏មានដែរ។ រួចចុះចំណែកសម័យឥឡូវនេះ គេរៀបការម្តងតែមួយគូៗ ហើយមានភ្លេងមានភ្លាត់ មានម៉ែមានឪ មានយាយតា ជីដូនជីតា បងប្អូន ហើយ មានហែជំនួន ហែផ្កាស្លា បាចផ្កាស្លា បើប្រៀបធៀបខុសគ្នា មិនដឹងប្រដូចទៅនឹងស្អីទេនេះ បើប្រៀបដូចមេឃនិងដីទៅ ក៏វាមិនតិចជាង ផង។ បានថាខ្ញុំតូចចិត្តដែរហ្នឹង ដល់ឃើញសព្វថ្ងៃមកឃើញសម័យឥឡូវនិងសម័យពីដើម តូចចិត្តនឹងវាសនាខ្លួនឯង"[3273]។

1413. ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានផ្តល់ចម្លើយថា "ការហ្នឹងវាមានលក្ខណៈខុសគ្នាទៀត ការពីរដងហ្នឹង។ កាលសម័យ ប៉ុល ពត គេមិនបានសួរចិត្តសួរថ្លើមយើង មិនបានលើកហេតុផលពីអ្វីឲ្យយើងស្តាប់ទេ ... ពេលការទៀតយើងអត់មានសេចក្តីសប្បាយចិត្តដោយសារ ការនេះគ្មានម៉ែឪ គ្មានសាច់ញាតិ គ្មានបងប្អូន អ្នកស្រុកភូមិផងរបងជិតខាងអី គេមកអបអរសាទរមង្គលទេ គឺការនេះការតែគ្នាឯង ការនឹងអ្នកគូៗការហ្នឹង ហើយអង្គការដែលគេអ្នករៀបចំ ប្រធានកង ប្រធានអីដែលគេបានមកឈររៀបចំយើងទេ"[3274]។ "ការនេះគេគ្មានចាក់ភ្លេងខ្មែរ សែនចងដៃ កាត់សក់ បុកល័ក្ត ចាក់ចេកដេកអង្ករៀប គ្មានទេ។ ការសម័យហ្នឹងដូចគេហៅទៅលេងបៃឡូបៃឡុក ផ្គូផ្គងកូនក្រមុំដប អ៊ីចឹង គេមិនបានឲ្យទៅក្រាបសំពះផ្ទឹម មានអាចារ្យ មានមហាមេបា អីអត់មានទេ"[3275]។

---

[3272] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ១៩ បន្ទាត់ ១៣-១៥។

[3273] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឡៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៦១ បន្ទាត់ ១៨-២៣។

[3274] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ១៣ បន្ទាត់ ១៤-២១។

[3275] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ១៣ បន្ទាត់ ២១-២៣។

## ព្យសនកម្មផ្លូវចិត្តពាក់ព័ន្ធនឹងការរៀបការដែលគេមិនចង់បាន

1414. ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី បានពន្យល់ថា គាត់ និងប្រពន្ធគាត់ "និយាយតែក្អកហ្នឹងក៏មិនហ៊ានក្អកដែរ។ សុខចិត្តទឹកភ្នែក ទឹកសម្បោរមកជាមួយ ពេលដែលខុសទៅហើយក៏អត់ហ៊ាននិយាយទេ តែនិយាយបាត់ខ្លួនហើយ"[3276]។

1415. ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប បានរៀបរាប់អំពីទំណាក់ទំនងរបស់គាត់ជាមួយប្តីគាត់ "ខ្ញុំមានគ្រួសារខ្ញុំផ្ទាល់ តាមតែខ្ញុំមិនពេញចិត្ត ប៉ុន្តែខ្ញុំរក មិនរក -- មិនដឹងធ្វើដូចម្តេចតាមការឈឺចាប់របស់ខ្លួននោះ ឈឺចាប់ហើយ ឈឺចាប់នឹងអង្គការបង្ខំឱ្យរៀបការ។ ប៉ុន្តែដល់ពេលដែលថាបើសិនជាខ្ញុំហើយរៀបការរួចហើយ ទោះបីខ្ញុំក្រឡេសម៉េច ក៏ទៅមិនរួច បើខ្ញុំរត់ទៅពួនណា ក៏ពួនមិនជិតដែរ បើអង្គការភ្នែកម្នាស់យ៉ាងនេះ រួចមិនដឹងទៅពួនត្រង់ណា ទៅនៅត្រង់ណា ម្ល៉ោះហើយបើថា បើនិយាយទៅថាទ្រាំតាមដំណើរ។ និយាយឆាប់ចប់តែម្តងអ៊ីចឹងទៅ"[3277]។

1416. ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប បានផ្តល់សក្ខីកម្មថា មនោសញ្ចេតនាអវិជ្ជមានលេចឡើងរាល់ពេលដែលគាត់រម្លឹកឡើងវិញពីការរៀបការរបស់គាត់ "ពេលណាខ្ញុំនឹកឃើញ ពេលដែលខ្ញុំមិនពេញចិត្តនឹងគ្រួសារ មិនពេញចិត្តនឹងអង្គការរៀបគ្រួសារ គឺថាក្នុងចិត្តក្តុកក្តួលឈឺចាប់ចុកណែនប៉ុនមិនដឹងនិយាយថាម៉េច ឆ្លើយថាម៉េចទៀត មានតែប៉ុណ្ណឹង"[3278]។

---

[3276] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/462.1** ទំព័រ ៧៥ បន្ទាត់ ៦-៧។

[3277] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៦០ បន្ទាត់ ១០-១៤។

[3278] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៦២ បន្ទាត់ ៤-៦។ ដោយពិពណ៌នាពីការឈឺចាប់របស់គាត់ ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប បានផ្តល់ចម្លើយថា "ការឈឺចាប់របស់ខ្ញុំ គឺមានច្រើនលើពេលរៀបអាពាហ៍ពិពាហ៍ ការឈឺចុកចាប់ដែលខំថែខ្លួនតាំងពីក្មេង រហូតដល់ពេលធំវ័យ។ អ៊ីចឹងហើយបានជាខ្ញុំនិយាយថា បើសិនជាខ្ញុំលាម៉ែលាឪមកធ្វើបដិវត្តន៍ដើម្បីកសាងប្រទេសជាតិ ផ្ទុយស្រឡះមកយកគ្រួសារដោយម៉ែឪមិនដឹង នេះ"ខ" ទី១។ "ខ"ទី២ ចំពោះខ្លួនខ្ញុំផ្ទាល់ ក៏ខ្ញុំឈឺចុកចាប់..."។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/467.1** ទំព័រ ៥៥ បន្ទាត់ ២០-២៣។

1417. ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន បានរៀបរាប់ពីអារម្មណ៍អៀនខ្មាសអំពីការរៀបការដោយបង្ខំរបស់គាត់[3279] និងបានផ្តល់សក្ខីកម្មពីការឈឺចាប់ ដែលគាត់បានទទួលរងដោយសារការរៀបការនេះ។ "ដល់រៀបៗរួចហើយនេះ កាលណាដែលយើងធ្វើការងារ នៅគេបង្ខំចិត្តរួមដំណេក ការរំលោភ ការមើលងាយ មើលថោក ឲ្យយើងឈឺចាប់។ ឈឺចាប់យ៉ាងខ្លាំងនៅក្នុងជីវិតរបស់ខ្ញុំនេះ ថាគ្មានប្រៀបផ្ទៀបបានទេ។ ទោះបីជាខ្ញុំស្លាប់ ក៏ខ្ញុំនៅការចងចាំចំពោះរបបដែលបានធ្វើអំពើឧក្រិដ្ឋកម្មចំពោះរូបខ្ញុំ"[3280]។

1418. ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានពន្យល់ថា គាត់មិនស្រឡាញ់ប្តីគាត់ទេ កម្រដេកក្បែរគាត់ និងមិនចង់រួមដំណេកជាមួយគាត់ទេ[3281]។ គាត់បានរម្លឹកឡើងវិញថា នៅថ្ងៃមួយ "អស់កម្លាំងហត់នឿយនឹងការងារផង គាត់មក ខ្ញុំក៏ប្រាស់ដេក ដល់ដេកទៅ លក់។ ដឹងខ្លួនឡើងគាត់ដាក់ដៃលើខ្លួនខ្ញុំអ៊ីចឹង ខ្ញុំក៏ចាប់ដៃគាត់ខាំ គាត់ក៏ ខ្ញុំក៏ប្រាប់គាត់ថាកុំដាក់លើខ្លួនខ្ញុំ ព្រោះខ្ញុំមិនអាចបុរសណាប៉ះខ្លួនខ្ញុំបានទេ ព្រោះខ្ញុំតាំងចិត្តតាមឪពុកខ្ញុំគាត់បានអប់រំថា យើងខ្លួនជាស្រី មិនត្រូវការឲ្យប្រុសប៉ះដៃប៉ះជើងទេ។ អ៊ីចឹងខ្ញុំកាន់ពីឪពុកបាន ខ្ញុំអត់ដឹងថាការហ្នឹង ប្រពៃណីរបស់សង្គមផង។ ខ្ញុំអត់ទទួលស្គាល់គាត់ជាប្តីទេ ចាសកាលហ្នឹង។ អ៊ីចឹងខ្ញុំត្រូវមានប្រតិកម្មជាមួយគាត់ ខាំគាត់ឲ្យមានរបួស"[3282]។

---

[3279] ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន បានពន្យល់ថា "ព្រោះបានជាខ្ញុំអត់ប៉ានិយាយ ព្រោះខ្ញុំខ្មាសគេ។ រឿងរ៉ាវដ៏អាក្រក់នេះ ខ្ញុំអត់ប៉ាននិយាយប្រាប់គេហើយ កាលណាដល់ គេហៅមកប្រជុំនៅភ្នំពេញ កន្លែង ធី.ភី.អូនោះ ហើយក្មេងនោះ គេក្មេងជាងខ្ញុំផង គេប៉ាននិយាយលាតត្រដាងរឿងហ្នឹង ហើយដល់ខ្ញុំ គេឮសួរថា អ្នកណាដែលគេបង្ខំរៀបការខ្លះ។ ខ្ញុំក៏លើកដៃថា ខ្ញុំ គេបង្ខំចិត្តឲ្យរៀបការដែរ។ ទៅ គេកត់ឡើងមក បានចូលមកកន្លែងនេះទៀត"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៣៦ បន្ទាត់ ១៦-២០។

[3280] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ២០ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/477.1** ទំព័រ ១៩ បន្ទាត់ ២០-២៣។

[3281] "ខ្ញុំគ្មានអារម្មណ៍ទៅរួមរក្សជាមួយបុរសដែលខ្ញុំអត់ពេញចិត្ត។ ខ្ញុំ គាត់ដេកទៅ ខ្ញុំអង្គុយទៅ គាត់ក្រោកខ្ញុំចេញមក ខ្ញុំខ្លាចគាត់ចាប់ខ្ញុំដែរ។ កាលនៅហ្នឹងសហជីពហ្នឹង ខ្ញុំចេះចេញដើរផុតៗដែរ ខ្ញុំអត់បានទៅដេកជាមួយផង"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៦០ បន្ទាត់ ៩-១១។

[3282] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៦០ បន្ទាត់ ១១-១៦។

1419. ក្នុងការឆ្លើយតបទៅនឹងសំណួរមួយដែលសួរថា តើគាត់ស្រឡាញ់ សុផាត ជាស្ត្រីដែលគាត់ត្រូវរៀបការជាមួយនោះ ឬទេ ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន បានឆ្លើយតបថា៖ "ខ្ញុំអត់មានពេញចិត្តទេលោកមេធាវី ពីព្រោះខ្ញុំអត់មានកម្លាំងពលំអី ដើម្បីហៅថាមានស្រឡាញ់នារីណាទេ គឺពេលនោះ គឺគេឱ្យធ្វើការងារហួសកម្លាំង ហើយវាគ្មានអារម្មណ៍អីចង់បានប្រពន្ធ ឬក៏ស្រឡាញ់រៀបការតាមផែនការរបស់គេ។ ប៉ុន្តែជាល្បិចកលរបស់គេ គឺគេចំណោទខ្ញុំថាចោទថាជាជនបម្រុងគេដាក់គុកហើយ ក៏ខ្ញុំមិនហ៊ានប្រកែកជាមួយគេទាំងអស់ គេឱ្យធ្វើអី ខ្ញុំធ្វើហ្នឹងទាំងអស់"[3283]។

1420. ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម បានរៀបរាប់ថា "ខ្ញុំចង់ៗបែកដែរ ប៉ុនបែកវាមិនរួច យើងបានការហើយ ក៏យើងមិនហ៊ាន យើងខ្លាច ដូចថា ម្តាយយើង ក៏ស្រី គេក៏ស្រី"[3284]។

### *ព្យសនកម្មដែលបណ្តាលមកពីការចាប់ខ្លួន/ការបាត់ខ្លួនប្តីឬប្រពន្ធ*

1421. ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានរៀបរាប់អំពីរបៀបដែល "ក្រោយពេលគេចាប់ប្តីសម្លាប់ទៅ គេដាក់ជាប់និន្នាការ ថាខ្ញុំហ្នឹងជាប្រពន្ធអាក្បត់។ អ៊ីចឹងគេតាមដាន គេគំរាមកំហែងគេសម្លុតគ្រប់ពេលវេលា ថាខ្ញុំរស់នៅគ្មានសេចក្តីសុខ"[3285]។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ពីអារម្មណ៍ភ័យខ្លាច ដោយសារ "គេនិយាយពីនិន្នាការផង ដល់អ៊ីចឹងប្តីខ្ញុំក៏បាត់ ដល់ខ្លួនឯងហ្នឹងត្រូវជាប់និន្នាការប្តីទៀត។ អ៊ីចឹងខ្ញុំហ្នឹងត្រូវទុក្ខសោកជាមួយកូនរហូត រហូតទល់តែដល់សព្វថ្ងៃ បើនិយាយរួមទៅ ខ្ញុំនឹកឃើញឡើង ខ្ញុំឆ្អែតទល់សព្វថ្ងៃរឿងទុក្ខសោករបស់ខ្ញុំ"[3286]។

1422. ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានឆ្លងទន្លេ ១០ថ្ងៃ ក្រោយពេលចាប់ខ្លួន និងបាត់ខ្លួនប្តីគាត់។ ប្រហែលមួយខែក្រោយមក គាត់ត្រូវគេគំរាមថា កូនគាត់គួរត្រូវគេយកទៅសម្លាប់

---

[3283] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ២០ បន្ទាត់ ៨-១១។

[3284] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៧៤ បន្ទាត់ ៥-៦។

[3285] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៨០ បន្ទាត់ ៤-៥។

[3286] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៦៩ បន្ទាត់ ២៤ - បន្ទាត់ ៧០ បន្ទាត់ ១។

ដោយសារជាកូនមនុស្សក្បត់[3287]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មថា "ក្រោយពីគេនិយាយពាក្យហ្នឹងមកលើខ្ញុំមក ធ្វើឱ្យអារម្មណ៍ខ្ញុំហ្នឹងតក់ស្លុត ភ័យខ្លាចចេះតែយំក្ដុកក្ដួល ណែនទ្រូង ចង់ស្ទះ ចង់សន្លប់អីចឹងទៅ ព្រោះកាលហ្នឹងខ្ញុំនៅសរសៃខ្ចី។ ទៅឪខ្ញុំហ្នឹងគាត់មក គាត់ចេះថាតាំងចិត្តទៅកូន កុំភ័យអី រឿងស្លាប់ជៀសមិនផុតទេ។ គាត់ចេះតែនិយាយលួងលោមខ្ញុំអីចឹង។ ហើយខ្ញុំចេះតែយំទៅ"[3288]។

1423. ក្រោយពេលគាត់ដឹងពីការចាប់ខ្លួន និងការបាត់ខ្លួនប្ដីគាត់ ដើមបណ្ដឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង បានតស៊ូ ជាពិសេសក្រោយពេលគាត់ផ្ដាក់ខ្លួនឈឺ៖ "នៅត្រង់ចំណុចនេះហើយ ដែលនាងខ្ញុំមានភាពលំបាកក្នុងការរៀបរាប់។ មិនអាចដូចថាមិនអាចនិយាយចេញ ការបាត់បង់មនុស្សម្នាក់ ទោះជាពេលមុនស្រឡាញ់ឬមិនស្រឡាញ់ក៏បានរួមរស់នៅជាមួយគ្នាហើយ ផ្ដល់ភាពកក់ក្ដៅជាមួយគ្នាហើយ ក៏តែងតែមានមនោសញ្ចេតនាជារៀងរហូតទៅអីចឹង។ ដូច្នេះពេលហ្នឹងគឺមានការតក់ស្លុតខ្លាំងណាស់ ហើយក្នុងពេលនោះគឺនាងខ្ញុំទើបសរសៃខ្ចីបានពីរខែចាស ធ្វើឱ្យទាស់គ្រុនញាក់ ដោយមិនមានមេរោគគ្រុនចាញ់ទេ គឺចាប់ញាក់ទទេៗអីចឹងទៅ ទាស់សរសៃអីចឹងទៅ។ លួចយំមិនឱ្យ

---

[3287] "ដល់ខ្ញុំឆ្លងទន្លេ កូនខ្ញុំហ្នឹងប្រហែលជាបានជិតមួយខែមើលទៅ ព្រោះកាលហ្នឹងគេមិនទាន់ហៅទៅធ្វើការទេ នៅផ្ទះនៅឡើយ។ ដល់ទៅ មិត្តយ៉េន ហ្នឹងគាត់ឡើងទៅ គាត់ទៅពិនិត្យលើផ្ទះខ្ញុំ ក្រែងលួចលាក់ ដូចថាយើងដាំរបស់ជុំវិញផ្ទះ មានល្ពៅ មានដំឡូង មានត្រប់អីចឹងទៅ ក្រែងយើងលួចបេះយកមកទុកហូបអីចឹង គាត់ទៅពិនិត្យ។ ដល់ពេលពិនិត្យលើផ្ទះខ្ញុំគ្មានឃើញអីក៏គាត់មកអើតមើលកូនខ្ញុំ ក៏គាត់ពោលពាក្យមកថា "កូនអាក្បត់ គួរតែឱ្យគេកម្ទេចចោលទៅ ទុកធ្វើអី។ មិត្តឯងទុកធ្វើអី""។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៧៨ បន្ទាត់ ៩-១៤។ "មិត្តយ៉េន គាត់និយាយមកម៉ាត់ៗដាក់ខ្ញុំអីចឹង។ ខ្ញុំថា "បងយ៉េន អ្ហា! កូនខ្ញុំនេះ វានៅក្នុងបើនិយាយទៅនៅនាមជាទារកមានតែភ្នែកខ្មៅក្រឹបទេ មិនទាន់ចេះអីពីគោលនយោបាយរបស់បក្សទេ។ រឿងអីចង់សម្លាប់កូនខ្ញុំ បើសម្លាប់កូន ខ្ញុំសម្លាប់ខ្ញុំទៅ"។ ខ្ញុំនិយាយទាំងយំប្រាប់គាត់អីចឹង។ បើខ្ញុំស្លាប់ទៅ វាកូនខ្ញុំក៏ស្លាប់ទៅជាមួយដែរ កុំឱ្យខ្ញុំរស់នៅនាំតែវេទនា។ ទៅក៏គាត់និយាយបានប៉ុន្នានម៉ាត់ប្រាប់ខ្ញុំ ខ្ញុំយំផងអីផងអីចឹងទៅ ក៏គាត់ចុះចេញទៅ មិត្តយ៉េន ហ្នឹងនោះ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៧៨ បន្ទាត់ ១៤-១៨។

[3288] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៧៨ បន្ទាត់ ២១-២៤។

គេឃើញទៀតចាស។ កុំឱ្យគេចោទយើងថា មាននិន្នា -- ជាប់និន្នាការក្បត់។ នៅស្រណោះ ស្រណោកអ្នកក្បត់អ៊ីចឹងណា"[3289]។

1424. ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង បានពន្យល់ថា នៅពេលរបបនោះមិនទុកចិត្តយើង យើង ត្រូវស្ថិតក្រោមការតាមដាន[3290]។ គាត់បានពន្យល់ថា ប្រពន្ធទាំងអស់ដែលប្តីត្រូវគេចោទប្រកាន់ ថាជាមនុស្សក្បត់ "ត្រូវគេប្រមូលដាក់ភូមិ ហើយផ្តាច់ការទាក់ទងមិនឱ្យអ្នកដទៃជុំវិញខ្លួនមក ប្រាស្រ័យទាក់ទង សួរសុខទុក្ខ ប្រាជ្ញប្រាកលេងអីជាមួយគ្នា គឺគ្មានសិទ្ធិទេ គឺនៅតែឯងអ៊ីចឹងទៅ ហើយយើងក៏គ្មានសិទ្ធិទៅឱ្យដើរទៅគេដែរ។ ទោះបីជាអ្នកធ្លាប់ស្គាល់យ៉ាងម៉េចក៏ដោយ"[3291]។

1425. ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មពីស្ថានភាពរស់នៅ និងធ្វើការនៅឯការដ្ឋាន របបអាហារ មិនគ្រប់គ្រាន់ និងជីវិតដ៏លំបាកលំបិនដែលគាត់ទទួលរងជាមួយកូន៖ "ចំពោះដែលមានការលំបាក វេទនា កូនតូច គេ -- ហូបបបរ ចាំ ហូបបបរក្នុងម្នាក់ ដែលបួននាក់ មួយកំប៉ុង គឺបួននាក់ ក្នុង ពេលហ្នឹងបួននាក់ ឱ្យទៅធ្វើការទៅ ហើយកូនតូចៗហ្នឹង ដែលទើបនឹងកើតហ្នឹង គឺឱ្យម៉ែដោះ ពីរនាក់ គ្រប់គ្រងក្មេងទារកហ្នឹង១០នាក់អ៊ីចឹង ដល់អ៊ីចឹងវាមានភាពលំបាកវេទនាណាស់"[3292]។

---

[3289] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ១៩ បន្ទាត់ ១-៧។ ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង បានផ្តល់សក្ខីកម្មថា "ក្រោយពីការបាត់បង់ប្តីទៅ គឺ មិនដឹងថាប្តីហ្នឹងទៅស្លាប់ទេ។ ថាទៅរៀន ទៅរៀនមួយអាទិត្យ ចាំមួយអាទិត្យក៏មិនឃើញមកវិញ។ រហូតដល់ ១០ថ្ងៃក៏មិន ឃើញមកវិញ កន្លះខែក៏មិនឃើញមកវិញ ទើបស៊ើបៗជាក្មេងដែលនៅធ្វើការជាមួយគាត់ ទើបយើងប្រាប់ថាពួកគេចាប់ហើយ។ ដូច្នេះ ភាពរន្ធត់ក្នុងលក្ខណៈដែលខ្លួនកំពុងតែសរសៃខ្ចីក៏មានភាពលំបាក លំបាកលំបិនណាស់សម័យហ្នឹង"។ *សូមមើល* សក្ខីកម្ម ផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ២១ បន្ទាត់ ៧-១១។

[3290] "គេពិនិត្យយើង ពិនិត្យពីពាក្យសម្តីនិងឫកពារបស់យើងក្នុងការរស់នៅប្រចាំថ្ងៃអ៊ីចឹងណា។ គេមើលអ៊ីចឹងទៅ ដល់ក្រោយ មក ទើបគេដករូបនាងខ្ញុំយកទៅដាក់នៅការដ្ឋានមួយ គឺនៅភូមិសំរ៉ង នៅស្រុកស្នួល។ ជាការដ្ឋានដែលជាប្រពន្ធរបស់អ្នកដែល គេចោទថាជាក្បត់ជាតិទាំងអស់ហ្នឹង"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ២២ បន្ទាត់ ១៦-១៩។

[3291] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ២២ បន្ទាត់ ២៣-២៥។

[3292] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ១៧ បន្ទាត់ ២២-២៥។ "គាត់ម្នាក់ មិនអាចបំបៅកូនប្រាំម្នាក់ៗបានទេ ទាំងកូនរបស់ខ្លួនគាត់ទៀត។ ដល់អ៊ីចឹង ធ្វើឱ្យកូននេះវេទនា វាឃំ វាស្រែកពេញទឹកពេញដី លួងមួយ ដាក់មួយលើកមួយៗ ធ្វើឱ្យលំបាកវេទនាណាស់។ ឯនាងខ្ញុំគឺគេ

ហើយ "ការហូបចុកនៅក្នុងសហករណ៍វាគ្មានជីវជាតិគ្រប់គ្រាន់សម្រាប់ទ្រទ្រង់ដល់ទារក ដល់ខ្លួនឯង។ ដល់មានសភាពបែបនេះទៀត បានធ្លាក់ខ្លួនទៅជាឈឺ ទាស់សរសៃញាក់សស្លាក់សស្លើត អស់រយៈពេលជាយូរហូតដល់ស្គមរីងរៃរកទឹកដោះឲ្យកូនគ្មានអ៊ីចឹង"[3293]។ ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ក៏បានផ្តល់សក្ខីកម្មផងដែរអំពីការខ្វះខាតសេរីភាពក្នុងការធ្វើដំណើរការ និងបានពន្យល់ថា របបអាហារនឹងត្រូវបានកាត់បន្ថយ ប្រសិនបើម្តាយ ឬកូនធ្លាក់ខ្លួនឈឺ ហើយមិនអាចធ្វើការបាន[3294]។

1426. ស្តីពីការឈឺចាប់ដែលគាត់បានទទួលរងក្នុងរបបនោះ ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង បានផ្តល់សក្ខីកម្មថា "ចំពោះរូបនាងខ្ញុំវិញ នាងខ្ញុំបានទទួលរងទុក្ខវេទនាឥតស្រាកស្រាន្ត បន្ទាប់ពីប្តីរបស់នាងខ្ញុំ ដែលអង្គការផ្គូផ្គងឲ្យនោះ ត្រូវបានចាប់ខ្លួនយកទៅបាត់។ នាងខ្ញុំត្រូវបានជាប់ចោទថាជាសាច់ញាតិជនក្បត់។ នាងខ្ញុំត្រូវបានគេដកហូតសិទ្ធិប្រជាជនធម្មតា ឲ្យរស់នៅក្នុងភាពជាប្រជាជនបញ្ញើ។ នាងខ្ញុំត្រូវបានគេបង្ខំឲ្យធ្វើការសព្វបែប សព្វយ៉ាង ទាំងសសៃខ្ចី និងមិនឲ្យអាហារហូបចុកគ្រប់គ្រាន់ រួមទាំងស្ថិតនៅក្នុងការឃ្លាំមើលតាមដានគ្រប់ពេលវេលាពីអង្គការភ្នែកម្នាស់។ នាងខ្ញុំត្រូវតែបង្ខំចិត្តធ្វើការទាំងត្រដរឲ្យគ្រប់ទៅតាមផែនការដែលអង្គការចាត់តាំងឲ្យ"[3295]។

### *ការបាត់បង់ព្រហ្មចារី - ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុហឿន*

---

ឲ្យទៅដម្រុះជើងពោត ជើងស្រូវ ចម្ការនៅចម្រុះតាមចម្ការ។ ទើសថ្ងៃម៉ោងដប់មួយ បានមកដល់ឃើញកូនវារនៅរដូករណែលពេញរនាប គ្មានកន្ទេល គ្មានខ្នើយអីទេចាស"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ១៧ បន្ទាត់ ២៥ - ទំព័រ ១៨ បន្ទាត់ ៤។

[3293] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ២១ បន្ទាត់ ១១-១៣។

[3294] "នៅក្នុងសភាពបែបនេះ ដែលពួកគេប្រមូលទៅដាក់ម៉្លឹងនេះ លក្ខខណ្ឌការងារ និងលក្ខខណ្ឌក្នុងការហូបចុក ក្នុងការរស់នៅគឺវាមានច្រើនបែបច្រើនបទណាស់។ ទី១ គឺហាមមិនឲ្យយើងដើរចេញទៅណា ក្រៅពីការដែលគេមានបទបញ្ជាឲ្យទៅធ្វើការតែប៉ុណ្ណោះ។ ហើយម្យ៉ាងទៀតការហូបចុកក៏កំណត់បួននាក់ក្នុងអង្ករមួយកំប៉ុង ឲ្យហូបបួននាក់។ ហ្នឹងចំពោះអ្នកដែលបាន ដែលចេញពលកម្មក្នុងមួយថ្ងៃ តែបើអ្នកដែលមិនបានចេញពលកម្មក្នុងមួយថ្ងៃទេ នៅសម្រាកដោយសារខ្លួនឈឺ ឬក៏កូនឈឺ នៅមើលកូន អ្នកនោះឯងត្រូវហូបទទួលរបបមួយកំប៉ុង ហូបប្រាំមួយនាក់ ហូបចុកប្រាំមួយនាក់។ រាវៗឃើញអង្ករមួយគ្រាប់ៗនៅក្នុងខ្ទះត្នោតអ៊ីចឹង"។ "*សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ២៣ បន្ទាត់ ៦-១២។

[3295] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ៨២ បន្ទាត់ ៦-១២។

1427. ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានរៀបរាប់ថា "សេចក្ដីបរិសុទ្ធខ្ញុំកាលពីក្មេងហ្នឹង ខ្ញុំស្ដាយៗសេចក្ដីបរិសុទ្ធខ្ញុំទល់សព្វថ្ងៃ ព្រោះខ្ញុំក្មេងស្រីមួយដែលគោរពទៅតាមប្រពៃណី គោរពឪពុកម្ដាយ ពាក្យចាស់លោកថា "បើមុននឹងប្រគល់ខ្លួនឱ្យទៅបុរសណាម្នាក់ ទាល់តែឪពុកម្ដាយអង្គុយក្បាលកន្ទេល"។ ដល់ពេលនោះ ខ្ញុំអត់មានឪពុកម្ដាយអង្គុយក្បាលកន្ទេលផង ខ្ញុំត្រូវអស់ក្ដីបរិសុទ្ធរបស់ខ្លួនខ្ញុំ។ ដល់អ៊ីចឹងខ្ញុំសោកស្ដាយបំផុតទាល់សព្វថ្ងៃហ្នឹង ខ្ញុំនៅតែនឹកសោកស្ដាយថាមិនគួរណាអស់សេចក្ដីបរិសុទ្ធមុនឪពុកម្ដាយអង្គុយក្បាលកន្ទេល កាលសម័យនុំងគាត់ចង់បានយើងអង្គុយក្បាលកន្ទេល រៀបចំទៅតាមប្រពៃណីត្រឹមត្រូវ មានភ្លេងភ្ជាត់ មានអាចារ្យ មានភ្ញៀវកុះករ"[3296]។

### *សម្ពាធឱ្យរៀបការម្ដងទៀត - ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន*

1428. ប្ដីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានបាត់ខ្លួននៅឆ្នាំ ១៩៧៩។ ក្រោយពេលរបបនោះដួលរលំ នៅឆ្នាំ ១៩៨៤[3297] ម្ដាយគាត់បានលួងលោមឱ្យគាត់រៀបការម្ដងទៀត[3298]។

1429. ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន បានរៀបរាប់អំពីអារម្មណ៍ភ័យខ្លាចពីការរៀបការម្ដងទៀត។ "ខ្ញុំនៅនឹកឃើញអនុស្សាវរីយ៍លំបាកពីប្ដីមុន ខ្ញុំមិនចង់យកទៀត។ ខ្ញុំចេះថា "ហ៊ឺ! ម៉ែ

---

[3296] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៧៦ បន្ទាត់ ៨-១៤។ ក្រោយពេលគាត់ត្រូវបានគេរំលោភរួច ប្ដីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន "ចេះតែលួងលោមខ្ញុំថា វាអស់សេចក្ដីបរិសុទ្ធអីណា គាត់ចេះនិយាយ គាត់ចេះនិយាយច្រើន គាត់ថាទោះបីយ៉ាងណា ក៏វាគ្មានសេចក្ដីបរិសុទ្ធទៅឱ្យឪម៉ែយើងវិញដែរ គាត់ចេះនិយាយលួងលោមខ្ញុំអ៊ីចឹង។ គាត់ចេះតែប្រាប់ គាត់ចេះតែលួងលោមទៅ ៗបានខ្ញុំនឹកថា ខ្ញុំខកចិត្ត ហួសពេលខ្ញុំហ្នឹងទៅ ក៏ខ្ញុំបណ្ដោយទៅតាមយថាកម្មខ្ញុំទៅ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/487.1** ទំព័រ ៧៥-៧៦ បន្ទាត់ ២៤-២។

[3297] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ១៣ បន្ទាត់ ៤-៥។

[3298] ដើមបណ្ដឹងរដ្ឋប្បវេណីបានពន្យល់ថា "កាលម៉ែខ្ញុំគាត់ឱ្យខ្ញុំមានប្ដីក្រោយនេះ គាត់សួរខ្ញុំដែរ។ គាត់សួរថា "ម៉ែឱ្យកូនឯងមានប្ដីហើយ កុំឱ្យនៅម្នាក់ឯង គេមើលងាយ" គាត់អង្វរ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ១៣ បន្ទាត់ ៤-៥។

ម៉ែឯងឱ្យខ្ញុំទៅ តិចពិបាក ប៉ះអ្នកដែលគេមិនស្មូវការងារ ហើយខ្លាចប៉ះសម័យហ្នឹង កើតអ្នកលេងល្បែង អ្នកអីទៀត។ ខ្ញុំចេះក្រែងខ្លាច""[3299]។

1430. ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា ចុងក្រោយគាត់បានយល់ព្រម ដោយសារម្តាយគាត់បានលើកឡើង "ហេតុផលច្រើនពេក"[3300] ហើយដោយសារ ការរៀបការ "ប្រពៃណី នេះម៉ែខ្ញុំឱ្យរៀបការ ទោះបីខ្ញុំមេម៉ាយកូនមួយក៏ដោយ ម៉ែខ្ញុំរៀបការ មានអាចារ្យ មានមេបា មហា មកអង្គុយនិយាយក្បាលកន្ទេលពីបុរាណកាលឱ្យខ្ញុំស្តាប់។ អ៊ីចឹងគឺថាមានហែស្លាកំណាត់ មានកាត់សក់មានសំពះផ្ទឹម បើកបាយអន បាចផ្កាស្លា កាត់ខាន់ស្លា។ ចាស អ៊ីចឹងហើយធ្វើឱ្យអារម្មណ៍ខ្ញុំហ្នឹងត្រេកអរនឹងការម៉ែរៀបចំឱ្យដែរ ព្រោះម៉ែខ្ញុំគាត់រៀបការទៅតាមប្រពៃណី"[3301]។

1431. ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា "អ៊ីចឹងធ្វើឱ្យអារម្មណ៍ខ្ញុំនឹងទទួលស្គាល់នឹងមង្គលដែលម៉ែបង្ខំឱ្យរៀបការ"[3302] "បើសម័យអាពត ខ្ញុំអត់មានសប្បាយចិត្តបន្តិចទេ ខ្ញុំមានតែទឹកភ្នែកទឹកភ្នែករហូតទល់សព្វថ្ងៃ ខ្ញុំនឹកឃើញឡើងខ្ញុំឆ្អែតពេលដែលខ្ញុំមានកូន ពេលខ្ញុំកូនកើត គេមកសម្លុត គេមកសម្លុតគំរាមខ្ញុំ ឱ្យខ្ញុំនេះប្រគល់កូនឱ្យគេសម្លាប់។ អ៊ីចឹងហើយជីវិតខ្ញុំ ខ្ញុំឆ្អែតៗទល់សព្វថ្ងៃចាសជម្រាប"[3303]។

***ព្យសនកម្មដោយសារគ្មានជម្រើសក្នុងការជ្រើសរើសគូស្រករ - ដើមបណ្តឹងរដ្ឋប្បវេណី យស ផល និងដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម***

---

[3299] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ១៣ បន្ទាត់ ៥-៧។

[3300] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ១៣ បន្ទាត់ ១៣។

[3301] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ១៣ បន្ទាត់ ២៤ - ទំព័រ ១៤ បន្ទាត់ ៣។

[3302] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ១៤ បន្ទាត់ ៤។

[3303] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប សុឃឿន ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ១៤ បន្ទាត់ ៤-៧។

1432. ដោយរៀបរាប់អំពីទំនាក់ទំនងរបស់គាត់ជាមួយគូដណ្តឹង ដើមបណ្តឹងរដ្ឋប្បវេណី យស ផល បានពន្យល់ថា "ខ្ញុំក៏ស្រឡាញ់។ ហើយខ្ញុំក៏មានសេចក្តីស្នេហ៍ដល់ឪពុកម្តាយនាង បងប្អូននាង។ ហើយនៅក្នុងហ្នឹង ឪពុកម្តាយនាង បងប្អូននាងក៏យល់ព្រមឲ្យខ្ញុំ ហើយខ្ញុំក៏មានការចាប់អារម្មណ៍ស្រឡាញ់គ្នាជាគូរដណ្តឹងដោយស្មោះស្ម័គ្រអស់ពីដួងចិត្ត ស្រឡាញ់គ្នាណាស់"[3304]។

1433. ក្នុងការប្រជុំមួយជាមួយមេកងគាត់ឈ្មោះ មិត្ត រី ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានគេប្រាប់ថា គាត់នឹងត្រូវគេសម្លាប់ប្រសិនបើគាត់រៀបការជាមួយគូដណ្តឹង ដោយសារបងប្រុសរបស់គូដណ្តឹងនោះត្រូវបានអង្គការកម្ទេច។ បន្ទាប់មក រី បាននិយាយឃ្លាដដែលថា "ការកម្ទេចដកស្មៅទាំងឫស" និងបានសួរគាត់ថា តើជាកូនអង្គការ ឬមិនមែន[3305]។ ដើមបណ្តឹងរដ្ឋប្បវេណី យស ផល បានផ្តល់សក្ខីកម្មថា "ដោយខ្ញុំខ្លាចស្លាប់ទាំងនារីជាគូដណ្តឹង ដោយខ្ញុំខ្លាចស្លាប់នឹងខ្លួនខ្ញុំ ដោយនឹកឃើញដោយខ្លាចស្លាប់ដល់បងប្អូនច្រើនទៀត ខ្ញុំសុខចិត្តឆ្លើយថា "ជាកូនអង្គការ""[3306]។ "ដើម្បីរួចរស់ជីវិតត្រូវតែឆ្លើយអញ្ចឹង"[3307]។

---

[3304] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ១១ បន្ទាត់ ១-៣។ គាត់បានរម្លឹកថា "យើងមានចំណីអីសំខាន់សម្រាប់គូរដណ្តឹងខ្ញុំទុកឱ្យ គឺទុកចែកគ្នាហូបដោយសប្បាយរីករាយ។ យើងសង្ឃឹមថាថ្ងៃអនាគត យើងនឹងបានជាប្តីប្រពន្ធគ្នាដ៏ល្អ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ១១ បន្ទាត់ ៤-៥។

[3305] មិត្ត រី បានសួរគាត់ថា៖ "គូដណ្តឹងហ្នឹងមានបងប្អូនអង្គការកម្ទេចឬទេ?" ហើយគាត់បានឆ្លើយថា "មាន១បងប្រុសគាត់មួយត្រូវអង្គការកម្ទេច"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ១៣ បន្ទាត់ ១៣-១៤។ ដើមបណ្តឹងរដ្ឋប្បវេណីបានរម្លឹកថា រី បាននិយាយថា៖ ""បើមានអង្គការកម្ទេចអ៊ីចឹងមិត្តឯងមិនអាចរៀបការជាមួយនារីហ្នឹងបានទេ ព្រោះថ្ងៃក្រោយ ទៅមិត្តឯងនឹងស្លាប់តាមបងប្អូនរបស់នារីហ្នឹងហើយ ព្រោះនារីហ្នឹងស្ថិតនៅក្នុងការតាមដានរបស់អង្គការ។ អ៊ីចឹងបើកាលណាសម្លាប់នារីហ្នឹង ក៏សម្លាប់មិត្តឯងដែរ។ អ៊ីចឹងមិត្តឯងត្រូវដូរចិត្ត ធ្វើម៉េច ឥឡូវខ្ញុំឲ្យមិត្តឯងធ្វើជាកូនអង្គការ។ មិត្តឯងយល់យ៉ាងម៉េច ពិចារណាមើល ចង់ងាប់ ហើយចង់រស់? បើយកនារីហ្នឹងមានតែងាប់ហើយ គឺការកម្ទេចដកស្មៅទាំងឫស" មេកងហ្នឹងនិយាយថាអ៊ីចឹង"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ១៣ បន្ទាត់ ១៤-១៩។

[3306] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ១៣ បន្ទាត់ ២៣-២៤។

[3307] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ១៣ បន្ទាត់ ២៥ - ទំព័រ ១៤ បន្ទាត់ ១។

1434. ដើមបណ្តឹងរដ្ឋប្បវេណី យស ផល បានរៀបរាប់ថា "ខ្ញុំសោកស្តាយត្រង់ថា គូដណ្តឹងរបស់ខ្ញុំហ្នឹងត្រូវបានគ្នាជាប្តីប្រពន្ធទៅអនាគត ហើយមិនបានគ្នាដូចជាផ្លែឈើកំពុងតែពេញហើយ បេះដាច់មិតមកដូចផ្លែស្វាយស្រក់ជ័រ អាខ្ញុំពេលហ្នឹងនៅប្រធានកងហ្នឹងផ្តាច់មនោសញ្ចេតនាខ្ញុំ ហើយខ្ញុំគ្មានសិទ្ធិតវ៉ាអី"[3308]។ "មានតែចុកទ្រូង ចុកថ្លើម ពិបាកក្នុងចិត្ត។ សព្វថ្ងៃឲ្យតែនឹកឃើញរឿងហ្នឹង ខ្ញុំដូចថាវាហួសចិត្តតែម្តង។ ខ្ញុំនឹកថាកើតមកវាជាតិនេះ ហើយចំសម័យអីវេទនាខ្លាំងម្ល៉េះ"[3309]។ "ការស្រឡាញ់របស់ខ្ញុំធំធេងណាស់លោកប្រធាន។ ខ្ញុំបានដើរលេងជាមួយគ្នា ហូបចុកជាមួយគ្នា ទៅបុណ្យជាមួយគ្នា កាន់លុយចូលបុណ្យជាមួយគ្នា និងអ្វីផ្សេងៗច្រើនណាស់ អនុស្សាវរីយរបស់ខ្ញុំវាមានជាលក្ខណៈមួយដល់ល្អសម្រាប់គូដណ្តឹងរបស់ខ្ញុំ ប៉ុន្តែដល់អត់បាន។ ឥឡូវនេះគឺថាខ្ញុំមានគ្រួសារហើយ ក៏ប៉ុន្តែនឹកនៅស្តាយ ចុះហេតុអ្វីបានជាគេធ្វើបាបខ្ញុំម្ល៉េះ។ អស់ពីខ្ញុំរៀបអាពាហ៍ពិពាហ៍ហើយ ក៏មិនបានស្រឡាញ់គ្នាទៀត"[3310]។

1435. ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម ក៏បានភ្ជាប់ពាក្យដែរ។ ដើមបណ្តឹងរដ្ឋប្បវេណីយល់ព្រមរៀបការជាមួយស្ត្រីផ្សេងដើម្បីរស់ និងបានរៀបរាប់ពីអារម្មណ៍មិនស្ងប់អំពីការរៀបការជាមួយស្ត្រីដែលមិនមែនជាគូដណ្តឹងគាត់។

1436. ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម បានរៀបរាប់ថា "ខ្ញុំក៏គិត ៣ថ្ងៃហូបបាយក៏មិនចូលដែរ អាហ្នឹងហើយផ្លូវចិត្តរបស់ខ្ញុំបាទ។ ព្រោះខ្ញុំមានគូដណ្តឹងនៅស្រុក បាទខ្ញុំគិតអ៊ីចឹង។ ដល់នឹកគិតយូរៗបាន ៣ថ្ងៃខ្ញុំថាបើគិតវែងខ្លីវែងពេកមិនបាន សុខចិត្តបាន ៣ថ្ងៃក៏គេមកសួរ ទៀត។ ដល់គេសួរខ្ញុំក៏ឯកភាពមួយគេថា ការក៏ការទៅធ្វើម៉េចទេ។ ប៉ុន្តែក្នុងចិត្តនៅៗដដែលបាទ នៅក្តៅដដែល គេបង្ខំព្រោះយើងមានគូដណ្តឹងនៅស្រុកបាទ។ ដូច្នេះ ប៉ុន្តែក្នុងចិត្តថា ការក៏ការចុះក្រែងលោបានរស់ បានឃើញមេឃឃើញផ្កាយឃើញហ្នឹងគេ ក្រែងលោបានដឹងសាច់រឿងសាច់ហេតុ អាហ្នឹងក្នុងចិត្ត

[3308] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ៤៦ បន្ទាត់ ៥-៧។

[3309] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ៤៦ បន្ទាត់ ៧-៩។

[3310] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី យស ផល ប្រតិចារឹក ថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/464.1** ទំព័រ ៤៦ បន្ទាត់ ១០-១៤។

របស់ខ្ញុំ ខ្ញុំនិយាយត្រង់។ បានខ្ញុំពិបាកផ្លូវចិត្តបានខ្ញុំដាក់ពាក្យប្ដឹងមកតុលាការ ដើម្បីឱ្យជួយនៅផ្លូវចិត្តខ្ញុំខ្លះ"[3311] - គាត់នៅតែមានអារម្មណ៍មិនស្ងប់ "រហូតដល់សព្វថ្ងៃ"[3312]។

***ការត្រួតត្រាទៅលើទំនាក់ទំនងក្នុងគ្រួសារ ការបំបែកគ្រួសារ***

1437. ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន បានពន្យល់ពីរបៀបដែលរបបនោះមានឥទ្ធិពលទៅលើទំនាក់ទំនងក្នុងគ្រួសារថា៖ "នៅរបបខ្មែរក្រហម គេបំបែកតើ ប្ដីទៅផ្សេង ប្រពន្ធទៅផ្សេង កូនទៅផ្សេង អត់មាននៅជុំគ្នាទេ។ កូននៅកងចល័តផ្សេងទៅ ម៉ែនៅខាងចល័តផ្សេង ឪពុកខាងចល័តផ្សេង។ អាតូចៗនៅជាមួយយាយៗ ដែលដាំបាយដាំបន្លែអី ឱ្យមើលក្មេងៗដែលតូចៗហ្នឹង។ ម៉ែៗ ជម្លៀសអស់ -- ចល័តអស់ហើយ អត់មាននៅទេ"[3313]។

1438. ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន បានពន្យល់ថា ក្រោយពេលគាត់មានផ្ទៃពោះ គេបានបំបែកគាត់ពីប្ដី និង "គេបំបែកឱ្យទៅធ្វើការផ្សេង ឆ្ងាយៗពីយើង មិនឱ្យនៅជិតគ្នាទេ"[3314]។ ចំពោះកុមារវិញ

---

[3311] *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៦៨ បន្ទាត់ ១០-១៨។

[3312] "ប្រពន្ធហ្នឹងអត់ៗលែងទេ ខ្ញុំអត់លែងដែរនៅតែយក។ ព្រោះខ្ញុំគិតវែងថា បើម៉ែឯងក៏ស្រីគេក៏ស្រីយើង ម៉ែយើងក៏ស្រីគេក៏ស្រី ខ្ញុំគិតក្នុងខ្លួនខ្ញុំអ៊ីចឹង។ ដូច្នេះ ខ្ញុំសុខចិត្តខ្ញុំទៅស្រុកខ្ញុំទៅជួបគូដណ្ដឹងគេអត់ទាន់យកប្ដីដែរគេនៅចាំបាទ។ ហើយខ្ញុំក៏ឱ្យគេសូមទោសគេ បាទធ្វើម៉េចបើខ្ញុំយកនេះហើយ ខ្ញុំលែងទៅ ក៏គ្នាខូចកិត្តិយសដែរហ្នឹងហើយ។ ដូច្នេះក៏គេអត់ថាអីដែរហ្នឹងហើយ ប៉ុន្តែក្នុងចិត្តខ្ញុំនៅតែអន់រហូត"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី កុល ណែម ប្រតិចារឹក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៦៩ បន្ទាត់ ១៨-២២។

[3313] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៥៩ បន្ទាត់ ១០-១៣។ ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់ចម្លើយថា "រឿងដែលគេបំបែកចេញពីគ្នានេះ ខ្ញុំអត់ដឹងមូលហេតុទេ។ ឱ្យគេឱ្យទៅណា ក៏ទៅណោះ ដែលហ៊ានប្រកែកទេ។ គេឱ្យទៅស្ទូង គេប្រាប់ឱ្យទៅចល័ត ទៅខាងណោះ ក៏ទៅ។ ប្ដីទៅណោះទៅ ប្រពន្ធក៏ទៅខាងណោះទៅ អត់ដឹងផែនការថាគេបំបែកនោះ គេបំបែករបៀបណាទេ។ ហើយបំបែកនោះ មិនមែន កូនៗក៏បំបែក អត់បានវិលមកផ្ទះវិញទេ ទៅសម្រាកនៅការដ្ឋាន កន្លែងនោះឯងទៀត។ ប្ដីក៏ដូចគ្នា។ ហើយខ្ញុំដែលមានកូននៅតូច ល្ងាចគេឱ្យមកវិញ។ គ្រាន់តែចល័តទៅថា ដូចជាមួយភូមិ ប្អូនប្រាំគីឡូអ៊ីចឹងទៅ យើងទៅៗ ល្ងាចឡើងវិលមកជួបកូនវិញ។ ចាស ដល់កូនធំលែងបៅដោះហើយនោះ គេចល័តមែនទែនហើយនោះ គេឱ្យទៅឆ្ងាយៗ យើងអាចទៅសម្រាកនៅខាងនោះបាន គេអត់ឱ្យមកវិញទេ។ ក្នុងពីរខែ បានគេឱ្យមកផ្ទះម្ដង ឬមួយខែកន្លះអី បានគេឱ្យមកជួបកូនម្ដង"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៥៩ បន្ទាត់ ១៦-២៣។

[3314] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៦៧ បន្ទាត់ ៥-៦។

ពួកគេត្រូវបានចាត់ទុកជាកូនអង្គការ ត្រូវបានបំបែកចេញពីម្ដាយ ហើយអង្គការជាអ្នកគ្រប់គ្រង[3315]។

1439. ប្រពន្ធរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធារី ឆ្លងទន្លេបានកូនស្រីម្នាក់ក្នុងរបបនោះ។ ដើមបណ្ដឹងរដ្ឋប្បវេណីដែលមិនអាចទៅមើលកូនទើបនឹងកើត ឬមានវត្តមាននៅពេលឆ្លងទន្លេបាន[3316] បានរៀបរាប់ពីការឈឺចាប់ដោយសារការបំបែកចេញពីកូនរបស់ខ្លួន។ "ថាខ្ញុំថ្វីដ្បិតតែខ្ញុំជាប្រភេទទី៣ មានកូននឹងគេដែរ ជាចៃដន្យអីព្រាត់ប្រាសគ្នាយ៉ាងនេះ។ ចិត្តវារន្ធត់ណាស់ទៅហើយ ទុកជាខ្ញុំគ្មានអារម្មណ៍ជាស្រើញ គ្មានអារម្មណ៍អី ក៏ខ្ញុំនឹកឃើញថារឿងមានកូន"[3317]។ ចំពោះប្រពន្ធគាត់វិញ ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធារី បានពន្យល់ថា "គេហៅទៅព្រមានកសាងជាមួយគ្នា ខ្ញុំមានអារម្មណ៍តក់ស្លុតណាស់ ប៉ុន្តែដោយខ្ញុំរកអត់ឃើញ។ ខ្ញុំស្វែងណាស់ ប៉ុន្តែរកមិនឃើញ តាំងពីខ្លួននៅជា រហូតដល់ខ្លួនឈឺ នៅតែដេកគិតនឹកឃើញ ពីអារម្មណ៍របស់ខ្ញុំថា ខ្ញុំមានការឈឺចាប់ខ្លាំងមែនទែន"[3318]។

1440. ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធារី បានពន្យល់ថា ចាប់តាំងពីរបបនោះដួលរលំទៅ គាត់មិនបានទាក់ទងជាមួយប្រពន្ធ និងកូនស្រីគាត់ទេ។ "តាំងពីកូនហ្នឹងកើតរហូតមកទល់សព្វថ្ងៃនេះ មិនដែល

---

[3315] "គេថា មានកូនអីទៀត នេះជាកូនរបស់អង្គការទេ។ ហើយម្យ៉ាងទៀតឱ្យខ្ញុំនេះកូន មានកូនឱ្យច្រើនទៅដើម្បីបម្រើអង្គការ គេនិយាយថាអ៊ីចឹង។ កូនៗរបស់ខ្ញុំទាំងអស់នោះក៏អត់មែនកូនខ្ញុំដែរ ព្រោះវាបែកចេញទៅអស់ហើយ មានតែអង្គការអ្នកកាន់កាប់ ។ ម៉្លោះហើយដែលកូនតូចៗនៅពីរបីឆ្នាំ អានោះវានៅជុំនឹងយាយៗ ហើយខ្ញុំក៏អត់មានកូនទៀតដែរ ទៅចល័តឆ្ងាយៗដែរ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី មុំ វុន ប្រតិចារឹក ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/475.1** ទំព័រ ៦៧ បន្ទាត់ ១១-១៥។

[3316] "ប្រពន្ធខ្ញុំមានផ្ទៃពោះ ខ្ញុំមិនដឹងរហូតដល់ឆ្លងទន្លេ តែបងថ្លៃខ្ញុំទេ អ្នកមកប្រាប់ថា ប្រពន្ធអ្ហែង ឆ្លងទន្លេងហើយ បានកូនស្រីស្អាតណាស់។ បានមកត្រឹមដឹងដំណឹងអ៊ីចឹងទេ។ ខ្ញុំអត់មានពេលដើរចេញពីភ្នំទំពែកទេ ព្រោះសកម្មភាពគេឱ្យរ៉ែថ្ម ក្នុងមួយថ្ងៃបាន១ម៉ែត្រគូប ខំប្រឹងរ៉ែឱ្យបានបាយស៊ី។ ថ្ងៃហ្នឹង ថ្ងៃបុណ្យក៏លែងចង់មកទៀតទេ ដើរវាអត់រួច។ ចិត្តចង់មកមើលមុខកូនហ្នឹងរបៀបម៉េចដែរ មកវាមិនរួច។ មិនមែនជិតគ្នា ស្រែកហៅគ្នាឮណា ឆ្ងាយ។ បើអ៊ីចឹង ខ្ញុំមិនដែលបានដឹងទេ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/462.1** ទំព័រ ៧៥ បន្ទាត់ ២១-២៥។

[3317] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/462.1** ទំព័រ ៧៧ បន្ទាត់ ៩-១១។

[3318] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊ូ សុធារី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/462.1** ទំព័រ ៧៧ បន្ទាត់ ១១-១៤។

ទទួលបានដំណឹង និងព័ត៌មានអីទេ"[3319]។ "ចំណែកប្រពន្ធខ្ញុំ អត់មានដឹងដំណឹងរស់ ឬស្លាប់អីទេ មិនដឹងសព្វថ្ងៃនេះ មិនដឹងជារស់នៅទីណា ចិត្តខ្ញុំនេះ ដ្បិតតែមិនស្រឡាញ់ស្រីមែន ប៉ុន្តែនឹកឃើញ យើងវាបានជ្រុលជ្រួសទៅហើយ តាមដើររកមើលកូនដែរ វាប៉ុន្មានហើយ តាមរកប្រពន្ធហ្នឹង វារាងអៀវរបៀបម៉េច ប៉ុន្តែតាមរកមិនឃើញ ៣០ឆ្នាំហើយ តាំងពីបែកគ្នា ចិតសិបជាងហ្នឹង ប៉ែតសិបជាងរហូតដល់ ៧៩ហ្នឹង តាមដើររកដែរ មិនមែនថាមិនតាមទេ មិនអន្សុតិរ្ទិយ រហូតថ្នាក់កូនឯងក៏មិនរាប់អាន ប្រពន្ធក៏មិនរាប់អាន ថ្វីដ្បិតចិត្តគំនិតយើងជាប្រភេទទី៣មែន តែតាមរកអត់ឃើញសោះ"[3320]។

## *ការតម្រង់ទិសផ្លូវភេទ និង អត្តសញ្ញាណយេនឌ័រ - ដើមបណ្ដឹងរដ្ឋប្បវេណី ស៊្វ សុធារី*

1441. ដើមបណ្ដឹងរដ្ឋប្បវេណី ស៊្វ សុធារី បានផ្ដល់សក្ខីកម្មថា "ខ្ញុំអត់ស្រឡាញ់ទេស្រី កុំតែជំនាន់អាពត បើជំនាន់ដូចឥឡូវមានសិទ្ធិសេរីភាពបរិបូណ៌ ខ្ញុំអត់យកទេ។ អ៊ីចឹងខ្ញុំមិនមែននៅម្នាក់ឯង មានការឈឺចាប់ ឈឺយប់ព្រលប់អី ដែលខ្ញុំអត់យកស្រី ម៉េចក៏ខ្ញុំមិនរក។ រឿងបញ្ហាហ្នឹងហើយថា ខ្ញុំអត់មានអារម្មណ៍រួមភេទទេ ដោយសារខ្លាចងាប់ទេ បានប្រថុយប្រថានម្ដងទៅ ដោយសារជាតិស្រាផង"[3321]។

1442. អំពីព្យសនកម្មដែលគាត់បានទទួលរងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដើមបណ្ដឹងរដ្ឋប្បវេណី ស៊្វ សុធារី បានពន្យល់ថា "អ្នកណាក៏ជួប អ្នកណាក៏ស្គាល់ អ្នកណាក៏ឃើញ អ្នកណាក៏ឮដែរ តែខ្ញុំឈឺចាប់តាំងពីការបង្ខំរៀបការ គេគំរាមកំហែង គេមើលងាយ មានសព្វគ្រប់ទាំងអស់ លើការបៀតបៀននូវផ្លូវភេទដែលខ្ញុំជាប្រភេទទី៣"[3322]។

---

3319 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊្វ សុធារី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/462.1** ទំព័រ ៧៦ បន្ទាត់ ១៩។

3320 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊្វ សុធារី ប្រតិចារឹក ថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/462.1** ទំព័រ ៧៦ បន្ទាត់ ២៣ - ទំព័រ ៧៧ បន្ទាត់ ៣។

3321 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊្វ សុធារី ប្រតិចារឹក ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/463.1** ទំព័រ ៣៦ បន្ទាត់ ១៦-១៩។

3322 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស៊្វ សុធារី ប្រតិចារឹក ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/463.1** ទំព័រ ៥៣ ១៦-១៨។ គាត់បានបញ្ជាក់ថា "រកអ្វីមកសងនូវការឈឺចាប់ខ្ញុំមិនបានទេ។ ដោយឡែកខ្ញុំចង់បង្ហាញទុក្ខសោកនេះ គ្រាន់ថាជាការឈឺចាប់របស់ខ្ញុំប៉ុណ្ណឹងបានហើយ ខ្ញុំមិនអាចនិយាយតទៅមុខទៀតបាន ព្រោះខ្ញុំវាអស់ហើយ អាយុ៧៨ ឲ្យវានាចោល

### *ព្យសនកម្មផ្លូវចិត្តដោយសារការបាត់បង់កូន/រលូតកូនដោយសារស្ថានភាពនានាដែលអង្គការបានដាក់មកលើ*

1443. ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ក៏បានរៀបរាប់ផងដែរពីការពុំមានមធ្យោបាយក្នុងការមើលថែទាំកូនគាត់៖ "នាងខ្ញុំ ពុំមានសិទ្ធិសេរីភាព និងពុំមានពេលវេលាសម្រាប់ផ្តល់ការថែទាំ និងភាពកក់ក្តៅ ដល់កូនជាទីស្រឡាញ់របស់ខ្ញុំទេ។ កូនរបស់ខ្ញុំមានសុខភាពខ្សោយណាស់ រាងកាយរបស់គាត់ស្គមស្គាំង ឧស្សាហ៍ឈឺក្អួត រាក ព្រោះមិនបានទទួលនូវការបំបៅដោះ ឬអាហារគ្រប់គ្រាន់ទេ"[3323]។ ក្រោយមក កូនគាត់បានស្លាប់ដែលធ្វើឱ្យគាត់កាន់តែមានការឈឺចាប់ថែមទៀត។ "រហូតក្រោយមកកូនរបស់ខ្ញុំបានត្រូវស្លាប់ ក្នុងរយៈពេលក្រោយឆ្នាំ១៩៧៩ ដោយសារជំងឺគ្រុនចាញ់។ ព្រោះសុខភាពរបស់កូនខ្ញុំខ្សោយតាំងពីតូចមកម្ល៉េះ"[3324]។

1444. ដើមបណ្តឹងរដ្ឋប្បវេណី កុល ណែម បានផ្តល់សក្ខីកម្មពីការឈឺចាប់ដែលគាត់បានទទួលរង ក្នុងនាមជាឪពុកដែលនឹងមានកូនដំបូង ក្រោយពេលប្រពន្ធគាត់រលូតកូន៖ "កូនខ្ញុំកូនមែន ប៉ុន្តែវាអត់គ្រប់ខែ វាបានតែ ដូចថា៥ខែ ឬ ៦ខែទៅវារលូតទៅវិញទាំងអស់ បាទ។ ខ្ញុំមិនមែនមិនខឹងទេ ខឹងដែរ តែយើងអត់ហ៊ានទៅជំនាន់គេហ្នឹង ដឹងស្រាប់ហើយបាទ ខ្ញុំខឹងដែរ។ ប៉ុន្តែយើងខឹងក្នុងចិត្ត យើងក្តៅក្នុងចិត្ត ក្តៅទាំងក្បាល ក្តៅទាំងខ្លួន ប៉ុនយើងមានសិទ្ធិអីនឹងនិយាយដូចបច្ចុប្បន្ននេះ បាទ បច្ចុប្បន្នជំនាន់ប៉ុលពល ដឹងស្រាប់ហើយ។ ខ្ញុំក៏មិនហ៊ានតវ៉ាគេដែរ សុខចិត្តយកកូន យកទៅកប់ទៅ រលូតយ៉ាងម៉េចក៏ដោយ ប្រពន្ធនៅដេកនៅមន្ទីរពេទ្យ ហ្នឹង សុខចិត្តយើងយកកូនទៅកប់ចោល ផ្តេសផ្តាសទៅ យើងអត់ហ៊ាននិយាយ យើងធ្វើស្ងៀម។ បាទ ខ្ញុំអស់ប៉ុណ្ណឹង ខ្ញុំមានស្អីទៀត ខ្ញុំ

---

មួយជីវិតទៅចុះ ថាអំពើទុក្ខសោកទាំងអស់នេះ ជាខ្ញុំអ្នកទទួលកម្មផលដែលខ្ញុំបានសាងពីជាតិមុនតែប៉ុណ្ណោះ"។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស៊ូ សុធាវី ប្រតិចារឹក ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ ២០១៣ ឯកសារ **E1/463.1** ទំព័រ ៥៣ បន្ទាត់ ២១-២៤។

[3323] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ៨២ បន្ទាត់ ១២-១៥។

[3324] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ហេង ឡៃហ៊ាង ប្រតិចារឹក ថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៦ ឯកសារ **E1/476.1** ទំព័រ ៨២ បន្ទាត់ ១៥-១៧។

និយាយប៉ុណ្ណឹង”[3325]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានរៀបរាប់ពីអារម្មណ៍ខឹងផង និងអស់សង្ឃឹមផង[3326]។

1445. ក្រោយពេលវៀតណាមរំដោះប្រទេស ប្រពន្ធរបស់ដើមបណ្ដឹងរដ្ឋប្បវេណី កុល ណៃម បានរលូតកូនមួយទៀត[3327]។ “ខ្ញុំចោទ ខ្ញុំមានអី មានតែក្នុងបញ្ហាធ្វើការធ្ងន់ធ្ងរ ឬខូចសរសៃសរស្ទូងអីមិនដឹង បើតាំងពីជំនាន់ ប៉ុល ពត ក៏រលូតអស់ពីរដែរ។ ដល់ពេលក្រោយមកទៀតជំនាន់វៀតណាមរំដោះហើយ ក៏រលូតទៀតដែរបាទ។ ហ្នឹងខ្ញុំចោទចំណុចហ្នឹង គេប្រើការហួសពេលវេលា បាក់កម្លាំង ឬមួយយ៉ាងម៉េចក៏ខ្ញុំមិនដឹងដែរបាទ”[3328]។ “បើថាយើងខ្ញុំសរុបតាំងពីមុនហ្នឹងមក គឺបាក់កម្លាំងតាំងពីមុនមកមិនដឹងយ៉ាងម៉េច។ បើរលូតពីមុនក៏រលូតអស់ពីរដែរ។ ក្រោយមកទៀតរលូតទៀតអីចឹងមែន គេថាទម្លាប់ហ្នឹងវាត្រូវរលូតរហូតវារហូតហ្នឹងហើយបាទៗ”[3329]។

1446. ដើមបណ្ដឹងរដ្ឋប្បវេណី សយ ណារឿន បានផ្ដល់សក្ខីកម្មពីការបាត់បង់កូន ក្រោយពេលគាត់មានជំងឺគ្រុនចាញ់ និងពីការឈឺចាប់ដែលគាត់បានទទួលរង ដោយសារការរលូតកូន៖ “កូនខ្ញុំមិនបានរស់រានមានជីវិតទេ លោកប្រធាន។ ខ្ញុំពពោះកូនបាន៦ខែ នៅក្នុងពោះ៦ខែ ខ្ញុំកើតជំងឺគ្រុនចាញ់ គ្មានថ្នាំសង្កូវ គ្មានអ្វីព្យាបាល គ្មានអ្វីពិនិត្យសុខភាពកូនទេ។ កូន ដល់ពេលខ្ញុំពពោះ ៩ខែ ១០ថ្ងៃ

---

[3325] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី កុល ណៃម ប្រតិចារិក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៧១ បន្ទាត់ ៥-១១។

[3326] ដើមបណ្ដឹងរដ្ឋប្បវេណីបានពន្យល់ថា “ខ្ញុំដឹង [មូលហេតុដែលកូនមិនរស់] ប៉ុន្តែមិនហ៊ាននិយាយ យើងវាដូចថា ខូចសរសៃសរស្ទូងអីទៅវាបាក់កម្លាំង គេប្រើខ្លាំងពេកអីចឹងវាបាក់កម្លាំង។ ដូច្នេះយើងត្រូវមានការលំបាកអីចឹង។ ប៉ុនយើងខឹង ក៏យើងមិនដឹងធ្វើយ៉ាងម៉េចគេ”។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី កុល ណៃម ប្រតិចារិក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៧១ បន្ទាត់ ១៧-១៩។

[3327] ដើមបណ្ដឹងរដ្ឋប្បវេណីបានពន្យល់ថា “ជំនាន់វៀតណាមរំដោះហើយនេះ ខ្ញុំមានដែរ រលូតដែរ ខ្ញុំចុងបញ្ចប់ ខ្ញុំត្រូវចប់ត្រឹមហ្នឹង ខ្ញុំឱ្យពេទ្យគេបញ្ឈប់ទៅ កុំឱ្យមានវាពិបាក ត្រូវឈប់អស់រលីង អត់មានកូនមួយទេឥឡូវ មានតែក្មួយទេ ប្រើសព្វថ្ងៃហ្នឹងបាទ។ រៀនសូត្រអីក៏ខំបង្រៀនក្មួយថា ឱ្យខំរៀនទៅ អញគ្មានកូនទេ មានតែអ្នែងទេ អ្នកតំណាងរបស់អញហ្នឹង”។ *សូមមើល* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី កុល ណៃម ប្រតិចារិក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៧១ បន្ទាត់ ២៥ - ទំព័រ ៧២ បន្ទាត់ ៣។

[3328] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី កុល ណៃម ប្រតិចារិក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៨៧ បន្ទាត់ ៦-៩។

[3329] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី កុល ណៃម ប្រតិចារិក ថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/488.1** ទំព័រ ៨៧ បន្ទាត់ ១៣-១៥។

កូនខ្ញុំកើតមក កូនខ្ញុំកើតបានស្លាប់។ កូនខ្ញុំទី១ស្លាប់ ដោយសារជំនាន់ដ៏ខ្មៅងងឹត កូនខ្ញុំស្លាប់ ខ្ញុំមិនបានឃើញមុខកូនខ្ញុំសូម្បីតែបន្តិច ដោយសារអ្វី ដោយសារខ្ញុំគ្រុនចាញ់ គ្មានថ្នាំសង្កូវ ដើម្បីព្យាបាលជីវិតកូនខ្ញុំ ទារកដែលនៅក្នុងផ្ទៃទេ មានតែសុំថ្នាំគេ គេឲ្យតែថ្នាំអាចម៍ទន្សាយយកមកលេប។ ជីវិតកូនខ្ញុំកើតមក ខ្ញុំមិនបានឃើញមុខកូនសូម្បីតែបន្តិច មិនដឹងជាកូនខ្ញុំស្លាប់ពីថ្ងៃណា ទៅថ្ងៃណាទេ។ ខ្ញុំឈឺចាប់ណាស់ លោកប្រធាន ដោយមូលហេតុថា ថ្វីត្បិតតែខ្ញុំមិនចង់បានមែន តែទឹកចិត្តជាម្តាយ ចង់កាលណាកូនមានហើយ អាណិតស្រឡាញ់កូន ទីបញ្ចប់គឺខ្ញុំមិនបានឃើញមុខកូនខ្ញុំសូម្បីតែបន្តិច។ នេះហើយ ដែលជាភាពខ្ញុំឈឺចាប់ណាស់ នៅក្នុងចិត្តខ្ញុំ ដែលខ្ញុំមិនអាចបំភ្លេចបានទេ”[3330]។

## ៣. ព្យសនកម្មផ្នែកសម្ភារៈ

### *ការបាត់បង់ឱកាសរៀនសូត្រ/ការងារ/ការរស់នៅ*

1447. ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ បានពន្យល់ថា “សម័យផ្តាច់ការ ខ្ញុំលំបាកអស់ហើយ មកសម័យនេះ ក៏ខ្ញុំជួបនឹងប្តីខ្ញុំទៀត”[3331]។ ដើមបណ្តឹងរដ្ឋប្បវេណីបានពន្យល់ថា ព្រឹត្តិការណ៍នានាដែលគាត់បានជួបប្រទះនៅតែមានឥទ្ធិពលអវិជ្ជមានមកលើជីវិត និងសុខុមាលភាពរបស់គាត់ទៀត៖ “ខ្ញុំជាស្រីមេម៉ាយ មានកូនប្រាំមួយនាក់ សព្វថ្ងៃខ្ញុំនៅរស់ស៊ីស្រុកគេទេ។ ខ្ញុំទើបនឹងមកភ្នំឆ្នាំនេះម្តង ខ្ញុំបានទៅរកគេ ស្រុកគេ២ឆ្នាំហើយ។ ខ្ញុំវេទនា គ្មានផ្ទះ គ្មានសម្បែង កូន”[3332]។

1448. ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន បានពន្យល់ថា “ពេលដែលខ្ញុំរៀបការហើយទៅដល់ គេបញ្ជូនទៅដល់កន្លែងផែអ្នកលឿងហ្នឹង គឺគេដកសម្ភារៈទាំងអស់ គោ ក្របី រទេះអី ឆ្កែ មាន់ ទាអី

---

[3330] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សយ ណារឿន ប្រតិចារឹក ថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/489.1** ទំព័រ ៣២ បន្ទាត់ ១៦-២៤។

[3331] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/483.1** ទំព័រ ៥៥ បន្ទាត់ ១៩-២០។

[3332] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ប៉ែន សុចាន់ ប្រតិចារឹក ថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ២០១៦ ឯកសារ **E1/483.1** ទំព័រ ៥៦ បន្ទាត់ ៣-៥។

ហ្នឹងគឺដាក់នៅកន្លែងហ្នឹង គឺឱ្យឡើងតែខ្លួន និងខោអាវឡើងកប៉ាល់ទៅ។ ទៅដល់កន្លែងច្បារអំពៅ គឺគេបែងចែកខោអាវនូវនឹងក្រមានៅទីនោះ។ មានអាវ និងក្រមាជាចំណាំរបស់គេ”[3333]។

## ជំពូក ១២. តួនាទីរបស់ជនជាប់ចោទ

### ក. ទិដ្ឋភាពទូទៅនៃភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី

1449. ដើមបណ្តឹងរដ្ឋប្បវេណីចំនួនប្រាំរូប ត្រូវបានកោះហៅមកផ្តល់សក្ខីកម្មស្តីពីតួនាទីរបស់ជនជាប់ចោទ។ ដើមបណ្តឹងរដ្ឋប្បវេណីចំនួនបីរូបបានផ្តល់នូវភ័ស្តុតាងនៃអំពើនិងការប្រព្រឹត្តិរបស់ ខៀវ សំផន ឬ នួន ជា។

### ១. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ

1450. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ គឺជាព្រះសង្ឃនៅវត្តច្រាប ក្នុងភូមិអូររំចេក ឃុំម្រុំ ស្រុកបន្ទាយមាស ខេត្តកំពត នៅក្នុងឆ្នាំ ១៩៧០[3334]។ នៅក្នុងឆ្នាំ ១៩៧១ នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណី មានអាយុ១៥ឆ្នាំ[3335] ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះត្រូវបានបង្ខំឱ្យផ្សឹក ហើយបញ្ចូលទៅក្នុងកងទ័ព "បដិវត្តអង្គការ"[3336]។ ដើមបណ្តឹងរដ្ឋប្បវេណីទទួលបានការហ្វឹកហ្វាត់យោធា

---

[3333] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ម៉ី សារឿន ប្រតិចារឹក ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/459.1** ទំព័រ ២០ បន្ទាត់ ១៩-២២។

[3334] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ ប្រតិចារឹក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៦១ បន្ទាត់ ៤-៧។

[3335] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ ប្រតិចារឹក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៦១ បន្ទាត់ ២៣។

[3336] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ ប្រតិចារឹក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៦១ បន្ទាត់ ១៧-១៨។

"ដើម្បីវាយប្រយុទ្ធចុងក្រោយទៅលើទីក្រុងភ្នំពេញ ក្នុងដើមឆ្នាំ ១៩៧៥"[3337] ហើយគាត់បានឈរជើងនៅក្រៅព្រលានយន្តហោះពោធិ៍ចិនតុង នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[3338]។

1451. នៅក្នុងឆ្នាំ ១៩៧៥ និងឆ្នាំ ១៩៧៦ ដើមបណ្ដឹងរដ្ឋប្បវេណីបានចាំថា បានស្ដាប់ឮខៀវ សំផន ថ្លែងសុន្ទរកថាតាមវិទ្យុដើម្បីគាំទ្រដល់បដិវត្តន៍[3339]។ ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ ដារ ក៏បានឃើញមេបញ្ជាការកងពលធំ មកដល់ពោធិ៍ចិនតុងផងដែរ ដូចជា តា ម៉ុក, ស៊ូ ម៉េត និង មាស មុត ហើយពួកគេបានចេញបញ្ជាផ្សេងៗ[3340]។ នៅពោធិ៍ចិនតុង ដើមបណ្ដឹងរដ្ឋប្បវេណីស្វែងរកបងប្រុសរបស់គាត់ ដើម្បីប្រាប់គាត់ឱ្យដោះឯកសណ្ឋានអាកាសយានិកចេញ ព្រោះគាត់បានឮពីប្រធានកងថា គេនឹងសម្លាប់អាកាសយានិកទាំងអស់[3341]។ ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ ដារ បានបំពេញការងារជា "ប្រធានកងពិសេសស៊ើបព័ត៌មានសម្ងាត់ នៅក្នុងសមរភូមិ ដែលស្ថិតក្រោមកងវរសេនាតូច ១៨០" ហើយគាត់បានឃើញការជម្លៀសចេញពីទីក្រុងភ្នំពេញ[3342]។ នៅក្នុងអំឡុងថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ១៩៧៥[3343] ដើមបណ្ដឹងរដ្ឋប្បវេណី និងកងវរសេនាតូចលេខ១៨០ ត្រូវបាន

[3337] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ ដារ ប្រតិចារិក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៦៣ បន្ទាត់ ៣-៤។

[3338] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ ដារ ប្រតិចារិក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៦៣ បន្ទាត់ ៩-១០។

[3339] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ ដារ ប្រតិចារិក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៨៤ បន្ទាត់ ៩-១៨។

[3340] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ ដារ ប្រតិចារិក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៦៤ បន្ទាត់ ១-៤។

[3341] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ ដារ ប្រតិចារិក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៧៩ បន្ទាត់ ១១-១៥។

[3342] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ ដារ ប្រតិចារិក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៦៣ បន្ទាត់ ១៦-១៧។

[3343] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ ដារ ប្រតិចារិក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៦៥-៦៦ បន្ទាត់ ២៥-១។ ដើមបណ្ដឹងរដ្ឋប្បវេណី បានឆ្លើយតបពាក់ព័ន្ធនឹងកងវរៈសេនាតូច ១៨០ ថា "បាទ គេបញ្ជូនមួយវរៈសេនាតូច គ្នាប្រហែល ៤០០ ទៅ ៥០០ នាក់"។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុំ ដារ ប្រតិចារិក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៦៦ បន្ទាត់ ២៤។

បញ្ជូនទៅកំពង់សោម ហើយនៅទីនោះកងវរសេនាតូចត្រូវបានរំសាយ ហើយដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានបញ្ជូនទៅកងទ័ពជើងទឹក[3344]។

1452. បន្ទាប់ពីនៅលើនាវាអស់រយៈពេលប្រាំខែ[3345] ដើមបណ្តឹងរដ្ឋប្បវេណីបានទទួលសំណើឱ្យចូលរួមក្នុងការប្រជុំមួយនៅកោះស្តេច[3346]។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានចាប់ខ្លួន ជាមួយមនុស្សប្រាំបួននាក់ផ្សេងទៀត នៅពេលពួកគេមកដល់[3347] ហើយពួកគាត់ត្រូវបានគេចោទថាជាខ្មាំងបង្កប់[3348]។ គាត់ត្រូវបានគេធ្វើទារុណកម្ម[3349] ហើយឱ្យធ្វើពលកម្មប្រហែល១២ ទៅ១៣ខែ នៅក្នុងរោងចក្រត្រីខកំប៉ុងនៅលើកោះស្តេច[3350]។ នៅឆមាសទីពីរឆ្នាំ ១៩៧៧[3351] ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបញ្ជូនទៅប្រជុំ នៅបុរីកីឡាក្នុងទីក្រុងភ្នំពេញ ជាមួយមនុស្សប្រហែលមួយពាន់នាក់ផ្សេងទៀត[3352]។ នៅបុរីកីឡាដើមបណ្តឹងរដ្ឋប្បវេណីបានឃើញ នួន ជា, សុន សេន និង តា ម៉ុក ជំរុញ

[3344] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ ប្រតិចារឹក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៦៧ បន្ទាត់ ២-៤។

[3345] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ ប្រតិចារឹក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៦៧ បន្ទាត់ ៨-១១។

[3346] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ ប្រតិចារឹក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៦៧ បន្ទាត់ ១៤-១៨។

[3347] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ ប្រតិចារឹក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៦៧ បន្ទាត់ ២៥។

[3348] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ ប្រតិចារឹក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៦៧-៦៨ បន្ទាត់ ២៥-១។

[3349] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ ប្រតិចារឹក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៦៧-៦៨ បន្ទាត់ ២៥-៤។

[3350] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ ប្រតិចារឹក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៦៨ បន្ទាត់ ៤-៦ និង បន្ទាត់ ១៧។

[3351] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ ប្រតិចារឹក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៨១-៨២ បន្ទាត់ ២៥-១។

[3352] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ ប្រតិចារឹក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៧២ បន្ទាត់ ២២-២៥។

ឲ្យកងទ័ពវាយប្រយុទ្ធជាមួយវៀតណាម[3353] ហើយគាត់បានឮ នួន ជា និយាយថា "ដាច់ខាតមិនអនុញ្ញាតឲ្យអាខ្មាំងយួនរំលោភឈ្លានពានបានទៀតជាដាច់ខាត"[3354]។

1453. ក្រោយការប្រជុំ ក្រុមនេះត្រូវបានបំបែក ហើយបញ្ជូនជាពីរផ្លូវ "មួយចំនួនទៅឆ្លងអ្នកលឿង ឆ្លងសាឡាង់អ្នកលឿង ហើយពួកខ្ញុំប្រហែលបួនរយនាក់ហ្នឹង គេឲ្យឆ្លងសាឡាង់នៅខាងជើងស្ពានជ្រោយចង្វារ ហើយនិងទៅឆ្លងទន្លេបិទ សាឡាង់នៅទន្លេបិទទៀត"[3355]។ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបញ្ជូន ទៅវាយប្រយុទ្ធជាមួយវៀតណាម[3356] នៅភូមិភាគបូព៌ា[3357] ហើយនៅទីនោះដើមបណ្តឹងរដ្ឋប្បវេណី ជាមេបញ្ជាការរងកងអនុសេនាធំលេខ១[3358]។ នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណី មកដល់ទីបញ្ជាការនៃមេបញ្ជាការរង នៅភូមិភាគបូព៌ា នៅប្រហែលម៉ោង ៩ ឬ១០ព្រឹកនោះ ពួកគាត់បានឃើញ សុន សេន[3359] និងទីប្រឹក្សាចិនពីរនាក់ទៀត ដែលរៀបចំពួកគាត់ជាកង[3360]។

---

[3353] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ប្រតិចារឹក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៧៤-៧៥ បន្ទាត់ ១៨-៣។

[3354] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ប្រតិចារឹក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៧៥ បន្ទាត់ ១-៣។

[3355] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ប្រតិចារឹក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៧៦ បន្ទាត់ ៦-៨។

[3356] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ប្រតិចារឹក ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ**E1/499.1** ទំព័រ ៣ បន្ទាត់ ២១-២៣។

[3357] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ប្រតិចារឹក ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ**E1/499.1** ទំព័រ ៤ បន្ទាត់ ៧-៩។

[3358] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ប្រតិចារឹក ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/499.1** ទំព័រ ៤ បន្ទាត់ ២៣-២៤។

[3359] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ប្រតិចារឹក ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/499.1** ទំព័រ ៦ បន្ទាត់ ៦-១០។

[3360] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ប្រតិចារឹក ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/499.1** ទំព័រ ៤ បន្ទាត់ ១៣-១៦។

1454. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ បានបាត់បង់សមាជិកគ្រួសារគាត់ទាំងអស់ ជាងម្ភៃនាក់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[3361]។ នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណីមកដល់ភូមិរបស់គាត់វិញ គាត់បានដឹងពីនារីម្នាក់ដែលគ្រប់គ្រងលើគុក[3362] ថាឪពុករបស់គាត់ត្រូវគេធ្វើទារុណកម្ម និងបានស្លាប់នៅក្នុងមន្ទីរសន្តិសុខក្រាំងតាចាន់[3363] នៅចុងឆ្នាំ ១៩៧៥ ឬដើមឆ្នាំ ១៩៧៦[3364]។ ពូរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលជាអតីតគ្រូបង្រៀនដែលរស់នៅក្នុងតំបន់មិនទាន់រំដោះនោះ ក៏ត្រូវបានបញ្ជូនទៅក្រាំងតាចាន់ផងដែរ[3365]។ ដើមបណ្តឹងរដ្ឋប្បវេណីក៏បានបាត់បង់បងប្រុសបីនាក់ ដែលបងប្រុសគាត់ម្នាក់ជាទាហានសាធារណរដ្ឋខ្មែរ[3366] ហើយគាត់ក៏បាត់បង់ម្តាយរបស់គាត់ ដែលត្រូវបានគេចាត់ទុកថាជា "សមាជិកគ្រួសារខ្មាំង"[3367] ផងដែរ។

## ២. ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ឆុន

1455. ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ឆុន គឺជាទាហានលន់ នល់ នៅក្នុងកងពលធំលេខ៤១០ នៅឃុំបាសាក់ ខេត្តស្វាយរៀង[3368]។ ដើមបណ្តឹងរដ្ឋប្បវេណីបានចូលរួមនៅក្នុងឆ្នាំ ១៩៧១[3369] ប៉ុន្តែមក

[3361] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ ប្រតិចារឹក ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/499.1** ទំព័រ ១៥ បន្ទាត់ ២២-២៥។

[3362] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ ប្រតិចារឹក ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/499.1** ទំព័រ ១៤ បន្ទាត់ ២-៥។

[3363] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ ប្រតិចារឹក ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/499.1** ទំព័រ ១០-១១ បន្ទាត់ ២៤-២ និងទំព័រ ១១ បន្ទាត់ ១៧-២០។

[3364] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ ប្រតិចារឹក ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/499.1** ទំព័រ ១៣ បន្ទាត់ ១១-១៤។

[3365] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ ប្រតិចារឹក ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/499.1** ទំព័រ ១១-១២ បន្ទាត់ ២៣-២។

[3366] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ ប្រតិចារឹក ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/499.1** ទំព័រ បន្ទាត់ ១-៣។

[3367] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ ប្រតិចារឹក ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/499.1** ទំព័រ ១៦ បន្ទាត់ ៦៧។

[3368] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ឆុន ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ**E1/504.1** ទំព័រ ៦០ បន្ទាត់ ១០-១១។

ធ្វើការងារស៊ីវិលវិញបន្ទាប់ពីរងរបួស[3370]។ នៅថ្ងៃទី ១៤ ខែ មេសា ឆ្នាំ ១៩៧៥ ខ្មែរក្រហមបានចូលដល់ស្វាយរៀង[3371]។ នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[3372] ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប ឆុន ត្រូវបានជម្លៀសជាមួយបងប្អូនប្រុសស្រីរបស់គាត់ រួមជាមួយឪពុកម្ដាយរបស់គាត់ ទៅភូមិតាដៃ ឃុំកំពង់ចម្លង ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង ដើម្បីទុកឱ្យកងទ័ពបោសសម្អាត ទាហានវៀតណាម[3373]។ គេទុកពួកគាត់នៅភូមិតាដៃអស់រយៈពេលមួយខែ ហើយនៅពេលនោះបងប្រុសរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប ឆុន ត្រូវបានគេបញ្ជូនទៅរៀនសូត្រនៅវត្តគ្រួស ដោយសារតែគេចោទថាគាត់ជាអតីតទាហាន លន់ នល់[3374]។ បងប្រុសរបស់ដើមបណ្ដឹងរដ្ឋប្បវេណី បានបាត់ខ្លួនតាំងពីពេលនោះមក[3375]។ បងថ្លៃប្រុសរបស់ដើមបណ្ដឹងរដ្ឋប្បវេណី គឺជាអតីតទាហាន ហើយគាត់ត្រូវបានគេសម្លាប់នៅកោះដាច់។ ប្រពន្ធរបស់គាត់ដែលជាបងស្រីរបស់ ដើមបណ្ដឹងរដ្ឋប្បវេណី ក៏បានបាត់ខ្លួនតាំងពីពេលនោះមកដែរ[3376]។

[3369] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប ឆុន ប្រតិចារឹក ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារ **E1/505.1** ទំព័រ ៣ បន្ទាត់ ១៦។

[3370] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប ឆុន ប្រតិចារឹក ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារ **E1/505.1** ទំព័រ ៣ បន្ទាត់ ១៧-២០។

[3371] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប ឆុន ប្រតិចារឹក ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារ **E1/505.1** ទំព័រ ៤-៥ បន្ទាត់ ២៥-៦។

[3372] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប ឆុន ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៦១ បន្ទាត់ ២៥។

[3373] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប ឆុន ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៦០ បន្ទាត់ ១៥-១៩។

[3374] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប ឆុន ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៦១ បន្ទាត់ ១-៤។

[3375] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប ឆុន ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៦១ បន្ទាត់ ៤-៥។

[3376] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប ឆុន ប្រតិចារឹក ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារ **E1/505.1** ទំព័រ ៣៤ បន្ទាត់ ៨-១២។

1456. ពីរសប្តាហ៍ក្រោយមក ឪពុករបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានគេយកទៅរៀនសូត្រនៅវត្ត តាដៃ ដោយសារតែគេចោទថាគាត់ជាសមាជិក "កងស្វ័យត្រាណប្រឆាំងបដិវត្ត"[3377]។ ប្រហែល ពីរសប្តាហ៍ក្រោយ ដើមបណ្តឹងរដ្ឋប្បវេណីត្រូវបានបញ្ជូនទៅរៀនសូត្រ នៅវត្តតែមួយដូចគ្នា ដែល នៅក្នុងវត្តនោះគាត់បានឃើញអ្នកទោសប្រហែល៥០០នាក់ ដែលអ្នកខ្លះគាត់ធ្លាប់ស្គាល់ថាជា យោធា[3378]។ ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ផុន ត្រូវបានគេឱ្យធ្វើការងារធ្ងន់ធ្ងរ ដោយគ្មានអាហារ គ្រប់គ្រាន់ នៅពេលគាត់ជាប់ឃុំឃាំង[3379]។ ដើមបណ្តឹងរដ្ឋប្បវេណីជាប់ឃុំឃាំងអស់រយៈពេល ៩ខែ ហើយនៅពេលក្រោយមកដើមបណ្តឹងរដ្ឋប្បវេណី និងឪពុករបស់គាត់ត្រូវបានគេដោះលែង ហើយអនុញ្ញាតឱ្យត្រឡប់ទៅក្រុមគ្រួសារ និងសហករណ៍របស់ពួកគេ[3380]។

1457. នៅខែ មិថុនា ឆ្នាំ ១៩៧៦ ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ផុន ត្រូវបានជម្លៀសទៅស្រុកពាមជរ ខេត្តព្រៃវែង ហើយគាត់ត្រូវបានបំបែកចេញ ពីឪពុកម្តាយនិងបងប្អូន ដោយពួកគេទាំងនោះត្រូវ បានបញ្ជូនទៅ ភូមិតាដៃ ឃុំកំពង់ចម្លង ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង[3381]។ នៅក្នុងឆ្នាំ ១៩៧៧ ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ផុន ត្រូវបានជម្លៀសជាលើកទីពីរ ទៅសហករណ៍ព្រែកជីក ឃុំ ស្នាយសំពណ៍ ក្នុងខេត្តបាត់ដំបង[3382]។ ក្នុងពេលធ្វើដំណើរទៅទីនោះ ដើមបណ្តឹងរដ្ឋប្បវេណីបាន

---

3377 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ផុន ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៦១ បន្ទាត់ ៥-៩។

3378 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ផុន ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៦១ បន្ទាត់ ៩-១៣។

3379 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ផុន ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៦១ បន្ទាត់ ១២-១៤។

3380 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ផុន ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៦១ បន្ទាត់ ១៧-២១។

3381 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ផុន ប្រតិចារឹក ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារ **E1/505.1** ទំព័រ ៣៤ បន្ទាត់ ១-៨។ ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់លម្អិតអំពីសមាជិកគ្រួសាររបស់គាត់ "ដែលរួមទាំងគ្រួសារខ្ញុំៗ ឪពុក ម្តាយ បងប្រុស បងស្រី ប្អូនប្រុស ប្អូនស្រី ដែលមានចំនួនប្រាំនាក់"។

3382 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ផុន ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៨០ បន្ទាត់ ៥-១១ និងសក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ផុន ប្រតិចារឹក ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារ **E1/505.1** ទំព័រ ៣៤-៣៥ បន្ទាត់ ១៤-១៨ ទំព័រ ៣៦ បន្ទាត់ ១-៤។

ឈប់សម្រាកនៅផ្សារច្បាអំពៅ (នៅទីក្រុងភ្នំពេញ)[3383] ដែលនៅទីនោះដើមបណ្តឹងរដ្ឋប្បវេណី បានចូលរួមជាមួយអ្នកត្រូវគេជម្លៀសជាច្រើនផ្សេងៗទៀត មកពីភូមិភាគបូព៌ា (ព្រៃវែង ស្វាយរៀង និងកំពង់ចាម)[3384]។ អ្នកត្រូវគេជម្លៀសត្រូវគេភ្ជង់កាំភ្លើង ដើម្បីរារាំងមិនឱ្យពួកគាត់ អាចរត់គេចត្រឡប់ទៅស្រុកកំណើតវិញ[3385]។

1458. ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា គាត់បានឮខៀវ សំផន ថ្លែងសុន្ទរកថា[3386] ហើយបានឃើញគាត់ចែកសម្ភារៈនៅផ្សារច្បាអំពៅ[3387]។ ដើមបណ្តឹងរដ្ឋប្បវេណីបានផ្តល់សក្ខីកម្មថា គាត់បានដឹងថាជាខៀវ សំផន នៅពេលដែលគាត់បានឃើញ ខៀវ សំផន នៅផ្សារ ព្រោះកងទ័ពបានចាក់បញ្ចាំងភាពយន្ត នៅក្នុងភូមិរបស់គាត់ មុនពេលគេជម្លៀសពួកគាត់ ហើយមនុស្សបានបញ្ជាក់ថាជាខៀវ សំផន[3388]។ ដើមបណ្តឹងរដ្ឋប្បវេណីបន្តរំឭកថា "លោកខៀវ សំផន គាត់អញ្ជើញមកនៅប្រហែលម៉ោងប្រាំបីព្រឹក។ គាត់អញ្ជើញមកមានសហការីគាត់ ប្រហែលជា១០នាក់ជាង ព្រោះខ្ញុំក៏មិនបានរាប់ដែរ ព្រោះថាខ្ញុំប៉ាន់ស្មានមើលទៅប្រហែលប៉ុណ្ណឹង"[3389]។ ក្រោយថ្លែងសុន្ទរកថា ដើមបណ្តឹងរដ្ឋប្បវេណីក៏បានឃើញ ខៀវ សំផន ចែកសម្លៀកបំពាក់ និងសម្ភារៈផ្សេងៗទៀត ទៅ

---

[3383] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ឆុន ប្រតិចារឹក ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារ**E1/505.1** ទំព័រ ៩ បន្ទាត់ ១៥-១៧។

[3384] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ឆុន ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៦២ បន្ទាត់ ២១-២៣ និងសក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ឆុន ប្រតិចារឹក ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារ**E1/505.1** ទំព័រ ៩ បន្ទាត់ ១៥-១៧។

[3385] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ឆុន ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៨១ បន្ទាត់ ៨-៩។

[3386] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ឆុន ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៦៩ បន្ទាត់ ៩-១១។

[3387] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ឆុន ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៦៣ បន្ទាត់ ៣-៥។

[3388] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ឆុន ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៦៩ បន្ទាត់ ២៤-២។

[3389] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ឆុន ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៦៨ បន្ទាត់ ១៤-១៧។

ឱ្យអ្នកត្រូវគេជម្លៀស[3390] រួមទាំងដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ[3391]។ នៅពេលគេជម្លៀសដើមបណ្ដឹងរដ្ឋប្បវេណីទៅបាត់ដំបង គាត់មិនទទួលបានអាហារគ្រប់គ្រាន់ឡើយ ហើយគាត់ត្រូវធ្វើការងារធ្ងន់[3392]។

1459. ដើមបណ្ដឹងរដ្ឋប្បវេណីធ្លាក់ខ្លួនឈឺ នៅសហករណ៍ព្រែកជីក ដោយសារតែស្ថានភាពរស់នៅនិងធ្វើការ[3393] ហើយគាត់ចូលសម្រាកនៅពេទ្យគុជដី អស់រយៈពេលពីរសប្ដាហ៍[3394]។ នៅពេលបន្ទាប់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប ឆុន ត្រូវបានគេបង្ខំឱ្យជម្លៀស ទោះបីជាគាត់កំពុងឈឺក៏ដោយ ដោយសារតែវៀតណាមវាយប្រហារ[3395]។ បងប្រុស[3396] បងស្រីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងប្ដីរបស់គាត់ ត្រូវបានគេសម្លាប់ បន្ទាប់ពីគេសម្រេចថា គាត់គឺជាអតីតទាហានលន់ នល់[3397]។ ឪពុក ម្ដាយ ប្អូនប្រុស និងប្អូនស្រីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ក៏ត្រូវបានគេសម្លាប់ផងដែរ នៅបាក់ចិញ្ចៀន[3398]។

---

[3390] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប ឆុន ប្រតិចារិក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៦៣ បន្ទាត់ ៣-៥។

[3391] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប ឆុន ប្រតិចារិក ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារ **E1/505.1** ទំព័រ ៣១ បន្ទាត់ ២។

[3392] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប ឆុន ប្រតិចារិក ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារ **E1/505.1** ទំព័រ ៣៦-៣៧ បន្ទាត់ ១៧-៧។

[3393] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប ឆុន ប្រតិចារិក ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារ **E1/505.1** ទំព័រ ៣៧ បន្ទាត់ ៦-៧។

[3394] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប ឆុន ប្រតិចារិក ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារ **E1/505.1** ទំព័រ ៣៧ បន្ទាត់ ២០-២២។

[3395] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប ឆុន ប្រតិចារិក ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារ **E1/505.1** ទំព័រ ៣៧-៣៨ បន្ទាត់ ២៣-៥។

[3396] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប ឆុន ប្រតិចារិក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៦១ បន្ទាត់ ១-៤។

[3397] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប ឆុន ប្រតិចារិក ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារ **E1/505.1** ទំព័រ ៣៤ បន្ទាត់ ៨-១២។

[3398] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប ឆុន ប្រតិចារិក ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារ **E1/505.1** ទំព័រ ៣៧ បន្ទាត់ ១៥-១៧។

1460. ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប ឌុន បានរំឭកថាបានឮ "តាមអ្នកនៅរស់ថា គាត់ប្រាប់ខ្ញុំបានប្រហែលជារយៈកាលប្រហែល ជាពីរបីខែប្រហែលប៉ុណ្ណឹងយ៉ាង គេយកឪពុកខ្ញុំទៅសម្លាប់។ ប្អូនស្រីខ្ញុំពីរនាក់វានៅកុមារ គេហៅពីកន្លែងកុមារមក យកទៅសម្លាប់ជុំគ្នាម៉ែកូន ឪកូន។ គិតទៅស្លាប់នៅបាក់ចិញ្ចៀនហ្នឹង"។ ខ្ញុំមានការសោក ទុក្ខវេទនា ព្រាត់ប្រាស់ឪពុកម្ដាយ បងប្អូន។ ខ្ញុំស្គមអស់បាទតក់ស្លុក។ ចំណែកបង គេសម្លាប់នៅឯស្រុកនោះមួយទៀត គេសម្លាប់នៅព្រៃវែង[3399]។

## ៣. ដើមបណ្ដឹងរដ្ឋប្បវេណី សុន ឯម

1461. ដើមបណ្ដឹងរដ្ឋប្បវេណី សុន ឯម រស់នៅស្រុកបាកាន ខេត្តពោធិ៍សាត់[3400]។ បន្ទាប់ពីរំដោះថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥ ដើមបណ្ដឹងរដ្ឋប្បវេណីរស់នៅបាត់ដំបង ហើយគាត់ជានីរសារ[3401] ហើយនិងទទួលភ្ញៀវនៅសាកលវិទ្យាល័យបាត់ដំបង ដែលមករៀនសូត្រ[3402]។ ដើមបណ្ដឹងរដ្ឋប្បវេណី សុន ឯម បន្តនៅសាកលវិទ្យាល័យនោះរហូតដល់ដើមឆ្នាំ ១៩៧៧ ហើយបន្ទាប់មកគាត់បានចូលមន្ទីរ ៥៦០ នៅខេត្តបាត់ដំបង ដែលនៅទីនោះគាត់ទទួលខុសត្រូវលើការទទួលភ្ញៀវ និងបញ្ជូនឯកសារទៅមន្ទីរ ៨៧០[3403]។ ឪពុករបស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន ឯម គ្រប់គ្រងផ្នែកឧស្សាហកម្ម នៅក្នុងភូមិភាគពាយ័ព្យ ហើយបានចូលរួមក្នុងការប្រជុំ នៅមន្ទីរភូមិភាគ ៥៦០ ជាមួយអ៊ុំរបស់គាត់ឈ្មោះ សាយ[3404]។ អ៊ុំរបស់ដើមបណ្ដឹងរដ្ឋប្បវេណី គឺជាប្រធានមន្ទីរ ៥៦០ ហើយ

---

3399 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ព្រាប ឌុន ប្រតិចារឹក ថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារ **E1/505.1** ទំព័រ ៣៧ បន្ទាត់ ១០-១៩។

3400 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/500.1** ទំព័រ ៥ បន្ទាត់ ២២។

3401 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/500.1** ទំព័រ ៦ បន្ទាត់ ២-៥។

3402 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/500.1** ទំព័រ ៦ បន្ទាត់ ៤-៥ និងទំព័រ ៨ បន្ទាត់ ១៩-២១។

3403 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/500.1** ទំព័រ ៩ បន្ទាត់ ១៥-២៤។

3404 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ**E1/500.1** ទំព័រ ១១ បន្ទាត់ ១៨-២៤។

គាត់គ្រប់គ្រងដើមបណ្ដឹងរដ្ឋប្បវេណី[3405]។ ឪពុកដើមបណ្ដឹងរដ្ឋប្បវេណី ធ្លាប់ធ្វើការជាមួយ នួន ជា[3406] ហើយស្គាល់ខៀវ សំផននៅទីក្រុងភ្នំពេញ ក្នុងអំឡុងទសវត្សឆ្នាំ១៩៥០ និង១៩៦០[3407]។ ម្ដាយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ធ្លាប់រស់នៅជាមួយ នួន ជា ក្នុងអំឡុងទសវត្សឆ្នាំ១៩៥០[3408]។ ដើមបណ្ដឹងរដ្ឋប្បវេណី សុន ឯម បានផ្ដល់សក្ខីកម្មអំពីការបោសសម្អាតលើកទីមួយ នៅភូមិភាគឧត្ដរ នៅដើមឆ្នាំ ១៩៧៧ ហើយបន្ទាប់មកគឺការបោសសម្អាតភូមិភាគពាយ័ព្យ[3409]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានរំឮកថា កម្មាភិបាលមកពីភូមិភាគនិរតី បានមកដល់បាត់ដំបងនៅពេលនោះ ហើយកាន់កាប់តួនាទីរបស់កម្មាភិបាលថ្នាក់ក្រោម[3410]។ ឪពុកដើមបណ្ដឹងរដ្ឋប្បវេណី និងអ៊ុំដើមបណ្ដឹងរដ្ឋប្បវេណី ត្រូវបានគេចោទប្រកាន់ថាជាជនក្បត់ ហើយត្រូវគេសម្លាប់នៅស-២១ ក្នុងខែ មិថុនា ឆ្នាំ ១៩៧៧[3411]។

1462. ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មថា នួន ជា បានចោទប្រកាន់អ៊ុំរបស់គាត់ "អាសាយ" ថាជាជនក្បត់របស់បក្សកុម្មុយនីស្ដកម្ពុជា[3412] ក្នុងអំឡុងពេលប្រមូលផ្ដុំមនុស្សរាប់រយនាក់ ដែលមកពី

[3405] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/500.1** ទំព័រ ១១ បន្ទាត់ ១៣-១៩។

[3406] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/501.1** ទំព័រ ៨ បន្ទាត់ ៦-៨។

[3407] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/501.1** ទំព័រ ២៥ បន្ទាត់ ១៥-១៧។

[3408] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/501.1** ទំព័រ ៤ បន្ទាត់ ៦-៧។

[3409] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/500.1** ទំព័រ ២៥ បន្ទាត់ ១៤-១៧។

[3410] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/500.1** ទំព័រ ២៥ បន្ទាត់ ១៧-១៩។

[3411] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/500.1** ទំព័រ ១៧ បន្ទាត់ ៧-១៩ និង ទំព័រ ១៨-១៩ បន្ទាត់ ២៣-១៨។

[3412] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/500.1** ទំព័រ ១២ បន្ទាត់ ២-៤។

ភូមិភាគពាយ័ព្យ នៅក្នុងទីក្រុងភ្នំពេញក្នុងឆ្នាំ ១៩៧៧[3413]។ ដើមបណ្តឹងរដ្ឋប្បវេណីបានរំឭកថា មានមនុស្សប្រហែល៤០០ ទៅ៥០០នាក់ មកពីកងរបស់គាត់ នៅឯកិច្ចប្រជុំក្នុងទីក្រុងភ្នំពេញ ហើយថា "មនុស្សបន្តបាត់ខ្លួន"[3414]។ ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម មិនជឿថា ពួកទាំងនោះគឺសំដៅទៅរកឪពុក និងអ៊ុំរបស់គាត់ឡើយ[3415]។

1463. បន្ទាប់ពីប្រជុំ ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ត្រូវបានបញ្ជូនពីភ្នំពេញទៅវត្តតាកែវ ដែលនៅក្បែរវត្តជ័យឧត្តម"[3416] ដែលនៅទីនោះគេឱ្យគាត់ធ្វើការធ្ងន់ ហើយគ្មានអាហារគ្រប់គ្រាន់[3417]។ ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម បានផ្តល់សក្ខីកម្មថា ក្នុងរបបនោះគាត់ត្រូវបានបំបែកចេញពីឪពុកម្តាយ បងប្អូន និងសាច់ញាតិ ហើយគាត់បាត់បងឪពុក និងអ៊ុំរបស់គាត់នៅស-២១ ហើយគាត់មិនបានទទួលការអប់រំទាល់តែសោះ[3418]។ ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម បានផ្តល់សក្ខីកម្មថា "មកដល់ថ្ងៃនេះសាច់ញាតិឪពុករបស់គាត់ ពួកគាត់ស្លាប់ទាំងអស់ គ្មាននរណាម្នាក់នៅរស់ឡើយ"[3419]។ ដើមបណ្តឹងរដ្ឋប្បវេណីក៏បានផ្តល់សក្ខីកម្មថា ការផ្លាស់ទីលំនៅរបស់គាត់មកភ្នំពេញ ធ្វើឱ្យគាត់មិនមានដីធ្លីអ្វីសោះ ហើយគាត់ពិបាកក្នុងការរស់នៅ[3420]។

[3413] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/500.1** ទំព័រ ១២ បន្ទាត់ ២-១៤។

[3414] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/501.1** ទំព័រ ៣២ បន្ទាត់ ១៩-២១។

[3415] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/500.1** ទំព័រ ១២ បន្ទាត់ ៩-១៤ និងទំព័រ ៣១ បន្ទាត់ ៦-៩។

[3416] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/501.1** ទំព័រ ៣២ បន្ទាត់ ២១-២២។

[3417] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/501.1** ទំព័រ ២៧ បន្ទាត់ ២-៤។

[3418] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/501.1** ទំព័រ ៣៥ បន្ទាត់ ៣-៧។

[3419] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E/500.1** ទំព័រ ២៩ បន្ទាត់ ១៤។

[3420] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/501.1** ទំព័រ ៣៥ បន្ទាត់ ៧-១០។

## ៤. ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន

1464. ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន ត្រូវបានជ្រើសរើសឱ្យធ្វើជាអ្នកបើកបរនៅក-១២[3421] ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់មជ្ឈឹមបក្ស ៨៧០[3422]។ ស្នាក់ការធំក-១២ គឺជាទីកន្លែងទទួលប្រធានាធិបតី និងភ្ញៀវបរទេស ហើយដើម្បីទទួលទីប្រឹក្សាបច្ចេកទេក អ្នកជំនាញការ និងវិស្វករមកពីប្រទេសផ្សេងៗ[3423]។ ទីតាំងនេះក៏ជាកន្លែងចតយានយន្តរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យដូចជា ប៉ុល ពត, នួន ជា និង ខៀវ សំផន[3424]។ ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន បានផ្តល់សក្ខីកម្មថា គាត់បានដឹកភ្ញៀវបរទេសជាច្រើន ដែលមកធ្វើទស្សនកិច្ចនៅកម្ពុជា ពីព្រលានយន្តហោះពោធិ៍ចិនតុងមក[3425]។ ដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់ថា ខៀវ សំផន ដែលជាប្រធាននៃគណៈប្រធានរដ្ឋកម្ពុជាប្រជាធិបតេយ្យ[3426] ជាទូទៅមកទទួលស្វាគមន៍ប្រតិភូប្រធានាធិបតី មក

---

[3421] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន ប្រតិចារឹក ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/497.1** ទំព័រ ២៣ បន្ទាត់ ៦-៩។

[3422] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន ប្រតិចារឹក ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/497.1** ទំព័រ ២៥ បន្ទាត់ ៨-១០។

[3423] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន ប្រតិចារឹក ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/497.1** ទំព័រ ២៤ បន្ទាត់ ១៥-២១។

[3424] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន ប្រតិចារឹក ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/497.1** ទំព័រ ២៤ បន្ទាត់ ១៥-១៧។

[3425] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន ប្រតិចារឹក ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/497.1** ទំព័រ ២៦-២៧ បន្ទាត់ ២៤-១ និងទំព័រ ២៩ បន្ទាត់ ៩-១១។ ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន ក៏បានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ផងដែរថា "បើនិយាយពីការដឹកនាំភ្ញៀវបរទេសវិញ ច្រើនណាស់ ១ អាទិត្យៗភ្ញៀវមកទស្សនកិច្ចនៅស្រុកយើងហ្នឹងច្រើនណាស់ បើថ្នាក់ការបរទេសហ្នឹង ខ្ញុំរៀបដែលខ្ញុំនៅចាំ បានដូចជាប្រទេស យូហ្គោស្លាវីអីៗអ៊ីចឹង ប៉ុន្តែវាច្រើនប្រទេសពេក ខ្ញុំមិនចាំបានទេ ដែលចាំបានធំៗនោះ គឺគណៈប្រតិភូ ថ្នាក់ប្រធានាធិបតីហ្នឹង គឺមានប្រទេសភូមា ប្រទេសឡាវ និងលេខាបក្សកុម្មុយនីស្តចិន ឈ្មោះ ឆឹង យីងគួយ ហៅ តាចាយ ហ្នឹង"។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន ប្រតិចារឹក ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **E1/185.1** ទំព័រ ១៧ បន្ទាត់ ២-៦។

[3426] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន ប្រតិចារឹក ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/497.1** ទំព័រ ២៧ បន្ទាត់ ១១-១២។ ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន ក៏បានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១ ផងដែរថា "អ៊ុំ ខៀវ សំផន គាត់មានតួនាទីជាប្រធានគណៈប្រធានរដ្ឋនៃកម្ពុជាប្រជាធិបតេយ្យ។ បើយើងឥឡូវ គេហៅប្រធានាធិបតីហើយ។ ព្រោះ អ៊ុំណោះវិន គាត់ប្រធានាធិបតី ឋានៈគាត់ប្រធានាធិបតីហើយគាត់ទៅទទួលហ្នឹង"។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស សារិន ប្រតិចារឹក ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **E1/185.1** ទំព័រ ២០ បន្ទាត់ ៨-១១។

ពីបណ្ដាប្រទេសនានា[3427]។ ដើមបណ្ដឹងរដ្ឋប្បវេណី បានលើកឧទាហរណ៍អំពី ខៀវ សំផន ដែលមកទទួលប្រតិភូមកពីប្រទេសភូមា[3428] និងប្រទេសឡាវ[3429]។

1465. ដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន លើកឡើងថា គាត់បានចូលរួមវគ្គរៀនសូត្រនយោបាយ ជាវគ្គទីមួយនៅចុងឆ្នាំ ១៩៧៥ នៅសាលាបច្ចេកទេសសូវៀត ក្នុងទីក្រុងភ្នំពេញ[3430]។ ត្រឹមតែជាងមុនឆ្នាំក្រោយ គឺនៅខែ មេសា ឆ្នាំ ១៩៧៧ ដើមបណ្ដឹងរដ្ឋប្បវេណីបានចូលរួមវគ្គរៀនសូត្រ សម្រាប់ព្រឹត្តិការណ៍ថ្ងៃជ័យជម្នះ នៅបុរីកីឡា[3431]។ នៅទីនោះគាត់បានស្ដាប់ឮ នួន ជា និងខៀវ សំផន និយាយអំពីគោលនយោបាយ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ[3432]។ វគ្គរៀនសូត្រធ្វើឡើងប្រហែលមួយសប្ដាហ៍ មុនពេលប្រារព្ធខួបជ័យជម្នះថ្ងៃ ១៧ មេសា[3433]។ ដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន បានផ្ដល់សក្ខីកម្មថា ទាហាន លន់ នល់ ត្រូវរបបកម្ពុជាប្រជាធិបតេយ្យ ចាត់ទុកថាជាខ្មាំង ហើយទាហានទាំងនោះត្រូវបានគេបញ្ជូនទៅរៀនសូត្រ ហើយបានបាត់ខ្លួន[3434]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មថា នៅក្នុងឆ្នាំ ១៩៧៨ គាត់បានដឹកជញ្ជូនគ្រឿងសព្វាវុធ ដើម្បីផ្គត់ផ្គង់ដល់ភូមិ

---

[3427] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន ប្រតិចារឹក ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/497.1** ទំព័រ ២៩ បន្ទាត់ ៩-១១។

[3428] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន ប្រតិចារឹក ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/497.1** ទំព័រ ២៦-២៧ បន្ទាត់ ២៤-៦។ *សូមមើលផងដែរ* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន ប្រតិចារឹក ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **E1/185.1** ទំព័រ ១៩-២០ បន្ទាត់ ២៣-១ និងទំព័រ ២១ បន្ទាត់ ១២-១៨។

[3429] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន ប្រតិចារឹក ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/497.1** ទំព័រ ២៩-៣០ បន្ទាត់ ២៣-៦។ *សូមមើលផងដែរ* សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន ប្រតិចារឹក ថ្ងៃទី ២៩ ខែ មេសា ឆ្នាំ ២០១៣ ឯកសារ **E1/185.1** ទំព័រ ២២ បន្ទាត់ ៦-៩។

[3430] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន ប្រតិចារឹក ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/497.1** ទំព័រ ៣០ បន្ទាត់ ១២-១៦។

[3431] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន ប្រតិចារឹក ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/497.1** ទំព័រ ៣០ បន្ទាត់ ១២-១៦។

[3432] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន ប្រតិចារឹក ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/497.1** ទំព័រ ៣១-៣២ បន្ទាត់ ២៥-៦។

[3433] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន ប្រតិចារឹក ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/497.1** ទំព័រ ៤២ បន្ទាត់ ២៤-២៥។

[3434] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន ប្រតិចារឹក ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/497.1** ទំព័រ ៥០ បន្ទាត់ ១១-១៩។

ភាគបូព៌ា ភូមិភាគកណ្ដាល និងភូមិភាគពាយ័ព្យ[3435] ប៉ុន្តែបន្ទាប់ពី សោ ភឹម ធ្វើអត្តឃាតនៅក្នុងខែមិថុនាវួចមក គាត់លែងអាចទៅភូមិភាគបូព៌ាបានទៀតហើយ[3436]។

1466. ដើមបណ្ដឹងរដ្ឋប្បវេណីមិនត្រឡប់មកវិញ តាមការគ្រោងទុកនៅថ្ងៃទីពីរ នៃការផ្ដល់សក្ខីកម្មរបស់គាត់ដល់អង្គជំនុំជម្រះសាលាដំបូងឡើយ ហេតុដូច្នេះសក្ខីកម្មរបស់គាត់បានបញ្ចប់ មុនពេលបញ្ចប់ការសួរដេញដោលដោយភាគីទាំងអស់[3437]។

## ៥. ភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណីដទៃទៀត

1467. ដើមបណ្ដឹងរដ្ឋប្បវេណី ខៀវ នាប ដែលមកផ្ដល់សក្ខីកម្មនៅក្នុងសវនាការ អំពីផលប៉ះពាល់នៃមន្ទីរសន្តិសុខ និងទីតាំងសម្លាប់ បានផ្ដល់សក្ខីកម្មថា គាត់បានឃើញ ខៀវ សំផន ប្រហែលនៅក្នុងអំឡុងឆ្នាំថ្មីឆ្នាំ ១៩៧៨ ជាមួយប្ដីរបស់គាត់ នៅផ្សារថ្មីក្នុងទីក្រុងភ្នំពេញ[3438]។ គាត់បានពន្យល់ថាគឺប្ដីរបស់គាត់ ដែលជាអ្នកប្រាប់គាត់ថាជាខៀវ សំផន[3439]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់

---

[3435] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន ប្រតិចារឹក ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/497.1** ទំព័រ ៤៤ បន្ទាត់ ៧-១០។

[3436] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន ប្រតិចារឹក ថ្ងៃទី ៨ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/497.1** ទំព័រ ៤៤ បន្ទាត់ ១១-១៣។

[3437] ក្នុងការឆ្លើយតបទៅនឹងសំណើសុំការបំភ្លឺរបស់អង្គជំនុំជម្រះសាលាដំបូង សហមេធាវីនាំមុខបានពន្យល់ថា ដើមបណ្ដឹងរដ្ឋប្បវេណីមិនអាចត្រូវបានបង្ខំឲ្យផ្ដល់សក្ខីកម្មបានឡើយ ដោយសារតែគាត់សម្រេចរក្សាឋានៈរបស់គាត់ជាដើមបណ្ដឹងរដ្ឋប្បវេណី (សវនាការផ្ទាល់មាត់ ប្រតិចារឹក ថ្ងៃទី ១៣ ខែ ធ្នូ ឆ្នាំ ២០១៦ ឯកសារ **E1/512.1** ទំព័រ ៣ បន្ទាត់ ៥-៧)។ នៅថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១៦ សហមេធាវីនាំមុខបានលើកឡើងថា សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ស សារិន នៅតែជាផ្នែកមួយនៃកំណត់ត្រាសវនាការជាសាធារណៈដដែល ហើយអាចត្រូវបានអង្គជំនុំជម្រះសាលាដំបូងធ្វើការពិចារណានៅពេលវាយតម្លៃភ័ស្តុតាងទាំងអស់នៅក្នុងសំណុំរឿង ០០២ (សារណារបស់សហមេធាវីនាំមុខពាក់ព័ន្ធនឹងការស្នើសុំប្រើប្រាស់សក្ខីកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម 2-TCCP-237 ចុះថ្ងៃទី ២០ ធ្នូ ឆ្នាំ ២០១៦ ឯកសារ **E453/2** កថាខណ្ឌ ២២ កថាខណ្ឌ ២៦)។

[3438] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ខៀវ នាប ប្រតិចារឹក ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/503.1** ទំព័រ ៦៥-៦៦ បន្ទាត់ ២១-១។

[3439] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ខៀវ នាប ប្រតិចារឹក ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/503.1** ទំព័រ ៦៦ បន្ទាត់ ៥-៨។

សក្ខីកម្មថា ឌៀវ សំផន បានចែកសម្ភារៈដូចជាក្រមាឌៀវ ក្រមា ស ជាដើម[3440]។ ក្រោយមកប្ដីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឌៀវ នាប ត្រូវបានគេចាប់ខ្លួន ហើយសម្លាប់[3441]។

1468. ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឌៀប បានផ្ដល់សក្ខីកម្មនៅក្នុងផ្នែកការរៀបការដោយបង្ខំ។ ដើមបណ្ដឹងរដ្ឋប្បវេណីស្នាក់នៅក្នុងទីក្រុងភ្នំពេញ បន្ទាប់ពីគាត់បានចូលទីក្រុង នៅថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ១៩៧៥[3442]។ គាត់បានផ្ដល់សក្ខីកម្មថាគាត់បានឃើញ ឌៀវ សំផន ចំនួនពីរដង នៅមុនពេលគាត់រៀបការនៅចុងឆ្នាំ ១៩៧៥[3443]។ លើកទីមួយគាត់ឃើញនៅពេលចូលរួមប្រជុំនៅបុរីកីឡា ហើយលើកទីពីរនៅវត្តឧណ្ណាលោម ដែលនៅទីនោះគាត់បង្រៀនវគ្គរៀនសូត្រមួយ អស់រយៈពេលមួយថ្ងៃពេញ សម្រាប់យុវជនមកពីកងចល័ត ដែលត្រូវទៅធ្វើការនៅក្រសួងពាណិជ្ជកម្ម[3444]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានរៀបរាប់ថា "ទោះបីជាខ្ញុំមិនដែលស្គាល់គាត់ពីមុនក៏ដោយ តែខ្ញុំប្រហែលមុខគាត់ ព្រោះខ្ញុំធ្លាប់ឃើញគាត់ក្នុងភាពយន្តឯកសារ ដែលគាត់ទៅទស្សនកិច្ចប្រទេសកូរ៉េ ហើយគេចាក់បញ្ចាំងឱ្យយើងមើល។ ខ្ញុំជួបគាត់បានតែម្ដង"[3445]។ "នៅពេលខ្ញុំឃើញគាត់ ខ្ញុំដឹងថាគាត់គឺ ឌៀវ សំផន។ នៅពេលនោះគាត់មានមាឌតូចទេ។ គាត់ស្គម ហើយនៅក្នុងរបបខ្មែរក្រហម គាត់ពាក់ខោខ្មៅ និងអាវដៃខ្លីពណ៌ខ្មៅ"[3446]។

---

3440 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ឌៀវ នាប ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៧ បន្ទាត់ ២២-២៣។

3441 *សូមមើល* ជំពូក ១០ ៖ មន្ទីរសន្តិសុខ ស-២១។

3442 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥០ បន្ទាត់ ៧-៨ ទំព័រ ៥១ បន្ទាត់ ៧។

3443 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/467.1** ទំព័រ ៣៤ បន្ទាត់ ១៤។

3444 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/467.1** ទំព័រ ៣ បន្ទាត់ ១០-១៣។

3445 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៨៦ បន្ទាត់ ១៤-១៦។

3446 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៨៦-៨៧ បន្ទាត់ ២៤-៣។

1469. ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន និង អ៊ឹម សារឿន បានផ្ដល់សក្ខីកម្មក្នុងផ្នែកសហករណ៍ត្រាំកក់។ ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន បានផ្ដល់សក្ខីកម្មថា គាត់បានឃើញ ខៀវ សំផន និង នួន ជា នៅការដ្ឋានដែលគាត់ដឹកប្រឡាយ នៅក្នុងរដូវប្រាំងឆ្នាំ ១៩៧៧[3447]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានពន្យល់ថា គាត់បានដឹងថាអ្នកមកធ្វើទស្សនកិច្ចនោះ គឺជាខៀវ សំផន និង នួន ជា ដោយសារតែប្រធានកងរបស់គាត់ប្រាប់[3448] ហើយគាត់ស្គាល់ថាជាខៀវ សំផន ដោយសាររូបថតដែលគាត់ធ្លាប់ឃើញ[3449]។

1470. ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ឹម សារឿន បានផ្ដល់សក្ខីកម្មថា នួន ជា និងខៀវ សំផន បានមកមើលការដ្ឋានរបស់គាត់នៅត្រាកក់ នៅក្នុងឆ្នាំ ១៩៧៧[3450]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មថា ប្រធានកងរបស់គាត់[3451] ប្រាប់គាត់ថា នួន ជា ខៀវ សំផន និងប៉ុល ពត បានមកមើលការដ្ឋានរបស់គាត់នៅត្រាំកក់ តែគាត់ "មិនស្គាល់ពួកគាត់ទេ"[3452]។

## ខ. ភស្តុតាងដែលផ្តល់ដោយដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសវនាការ

### ១. ភស្តុតាងទាក់ទងនឹង នួន ជា

#### ១.១. ការដឹងឮទូទៅ/ការចុះពិនិត្យមើលសហករណ៍ត្រាំកក់ (ឆ្នាំ១៩៧៧)

---

[3447] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/252.1 ទំព័រ ៤៨-៤៩ បន្ទាត់ ២៤-៨។

[3448] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/252.1 ទំព័រ ៥២-៥៣ បន្ទាត់ ២៥-៣។

[3449] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ E1/252.1 ទំព័រ ៥២ បន្ទាត់ ១៥-២០។

[3450] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ E1/283.1 ទំព័រ ៧ បន្ទាត់ ២១-២៤។

[3451] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ E1/283.1 ទំព័រ ៣២ បន្ទាត់ ១៧។

[3452] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ E1/283.1 ទំព័រ ៨ បន្ទាត់ ៧-៨។

1471. ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡួន បានផ្តល់សក្ខីកម្មថា "នៅក្នុងសង្គមកម្ពុជាប្រជាធិបតេយ្យខ្មែរក្រហម តាម៉ុកគាត់បានអមមេដឹកនាំខ្មែរក្រហមបីរូប ដែលមានជិះរថយន្តទៅឈប់នៅទីនោះ លោក ប៉ុល ពត, ខៀវ សំផន, នួន ជា ហើយនិងតា ម៉ុក។ តា ម៉ុក គាត់ជិះឡានគាត់ដោយខ្លួន។ គាត់ទៅទស្សនកិច្ចនៅការដ្ឋានប្រឡាយ កន្លែងជីកប្រឡាយអូរចំបក់ ដើម្បីបូមទឹកនៅបឹងអូរចំបក់ ចុះទៅស្ពានីយ ចុះទៅខាងលិចថ្នល់រទេះភ្លើង ដើម្បីធ្វើស្រែឲ្យបានបីដងក្នុងមួយឆ្នាំ"[3453]។ គាត់បានបញ្ជាក់ថា ឡានរបស់ពួកគេ "ឈប់នៅកន្លែងស្ពានីយគល់ស្ពានអូរចំបក់ហ្នឹង គាត់ចុះដើរមើលពួកខ្ញុំរែកដី ដើរចឹងទៅលិចទៅ ហើយមេកង មេគណៈឃុំអីទៅតាមទាំងអស់។ ដើទៅតាមជាមួយគាត់ទាំងអស់"[3454]។

1472. ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡួន បានរៀបរាប់ថា គាត់ដឹងថាជានួន ជា ដោយសារតែប្រធានកងគាត់ប្រាប់ "ចាស អ្នកមូលដ្ឋាន គេអ្នកចាស់ មេកងគេធ្លាប់ចេញចូលប្រជុំជាមួយ បានគេស្គាល់ចាស។ គេមេកង គណៈស្រុក គណៈឃុំ ហើយគេស្គាល់ គេនិយាយប្រាប់មេកង។ មេកងខ្ញុំស្គាល់និយាយប្រាប់ខ្ញុំថាៈ ប្រមុខរដ្ឋកម្ពុជាចុះមកទស្សនកិច្ច។ ព្រោះគាត់ជាប្រមុខរដ្ឋដឹកនាំប្រទេសកម្ពុជា កាច់ចង្កូតនាវាប្រទេសកម្ពុជា អ្វីៗគឺគាត់ជាអ្នកនាំមុខ"[3455]។

1473. ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡួន បានរៀបរាប់ពីការឃើញ នួន ជា និង ខៀវ សំផន នៅការដ្ឋានថា "ការខ្ញុំជីកប្រឡាយនៅ ១៩៧៧ហ្នឹង ហើយខ្ញុំឈរមើលគាត់ គាត់ដើរគ្នាគាត់បីនាក់ហ្នឹង ហើយតា ម៉ុក ម្នាក់ទៀត បួននាក់ចាស។ ឃើញគាត់នៅពេលហ្នឹង ហើយគាត់ក៏ឈរនិយាយថា ឲ្យពួកយើងអ្នកជីកប្រឡាយហ្នឹង ពលករហ្នឹង ជីកសម្រុក ដើម្បីបូមទឹកពីស្ពានីយអូរចំបក់ហ្នឹង ពីបឹងអូរចំបក់ហ្នឹង ទៅធ្វើស្រែនៅម្តុំខាងលិចថ្នល់រទេះភ្លើង មួយហិកតាបីទៅប្រាំមួយតោន ឲ្យសម្រុក

[3453] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡួន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/252.1** ទំព័រ ៥១-៥២ បន្ទាត់ ២៥-៤។

[3454] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡួន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/252.1** ទំព័រ ៤៩ បន្ទាត់ ២២-២៣។

[3455] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡួន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/252.1** ទំព័រ ៥២-៥៣ បន្ទាត់ ២៥-៣។

ពលកម្ម។ ហើយដើម្បីឈានធ្វើស្រូវបានល្អ ដើម្បីឈានទៅរកភាពសម្បូររុងរឿង ហូបបាយស្រួយៗ សម្បូររុងរឿង ដើម្បីបានៗមានកម្លាំងពលំ"[3456]។

1474. ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន បានរំឭកថា នៅពេលដែលគាត់ឮនួន ជា ខៀវ សំផន និងប៉ុល ពតនិយាយ "ចាស ស្តាប់ឮទាំងអស់។ គាត់ថា៖ "ខំសម្រុកជីកប្រឡាយឲ្យបានជ្រៅ របស់បំផុត ដើម្បីបង្ហូរទឹកពីបឹងអូរចំបក់ តាមស្ពានីយហ្នឹងទៅខាងស្រែ វាយស្រែខាងលិចថ្នល់រទេះភ្លើង ទៅដល់វាលសំរោងទៅដល់លាយបូរ ធ្វើស្រែបានមួយហិកតា បីតោនទៅប្រាំមួយតោន"[3457]។ "គេនិយាយគ្នាគេ តែតា ម៉ុក និយាយមកកាន់ប្រជាពលករដែលកំពុងធ្វើការ ហើយនិងមេកង"[3458]។

1475. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម សារឿន បានផ្តល់សក្ខីកម្មថា "ចាសឆ្នាំ៧៧ ប៉ុន្មានមិនដឹងខែប៉ុន្មានទេ ខ្ញុំអត់ចងចាំ។ ខ្ញុំពលកម្ម ខ្ញុំធ្វើប្រឡាយហ្នឹង ខ្ញុំរែកដីធ្វើស្ពានីយអូរចំបក់ហ្នឹង នៅវ៉ាហ្នឹង ខ្ញុំបែរមុខទៅកើត ហើយខ្ញុំឃើញឡានហ្នឹងបែរមុខមកលិច ប៉ុន្តែខ្ញុំស្គាល់ តា ម៉ុក គាត់ជិះឡានហ្ស៊ីប ហើយឃើញឡានមួយទៀត ខ្ញុំមិនដឹងឡានម៉ាកអីៗ ខ្ញុំអត់ស្គាល់។ ដល់ពេលក្រោយគាត់អញ្ជើញទៅវិញអស់ បានមិត្តយឿនហ្នឹង គាត់ខ្សឹបប្រាប់ឈ្មោះតាៗ"[3459]។ "គាត់ប្រាប់ថាឈ្មោះ តា នួន ជា, ខៀវ សំផន ហើយនឹងតា ប៉ុល ពត។ ប៉ុន្តែខ្ញុំអត់ចងចាំទេណា ខ្ញុំអត់ស្គាល់គាត់ទេ"[3460]។ យឿន "ជាមេកងលេខ៣ ជាអ្នកមូលដ្ឋាន"[3461]។

---

3456 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/252.1** ទំព័រ ៤៩ បន្ទាត់ ៥-១០។

3457 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/253.1** ទំព័រ ៤ បន្ទាត់ ៧-៩។

3458 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជូ គឹមឡូន ប្រតិចារឹក ថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/253.1** ទំព័រ ៤ បន្ទាត់ ១៥-១៦។

3459 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ៧ បន្ទាត់ ២១-២៤។

3460 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ៨ បន្ទាត់ ៧-៨។

3461 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ៣២ បន្ទាត់ ១៧។

1476. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹម សារឿន បានរៀបរាប់អំពីដំណើរទស្សនកិច្ចរបស់មេដឹកនាំដោយបញ្ជាក់ថា "ចាស ខ្ញុំឃើញទ័ពទៅទទួល ហើយនិងមេឃុំ ហើយនិងតំណាងកងគាត់ឡើងមកទទួល។ នាងខ្ញុំរែកដីឡើងចាក់ទំនប់ប្រឡាយហ្នឹង ខាងស្តាំដៃ ៤-៥ម៉ែត្រពីនាងខ្ញុំ ៥-៦ម៉ែត្រអីហ្នឹង ខាងស្តាំដៃ"[3462]។ "នាងខ្ញុំឃើញគាត់ហ្នឹង នៅចម្ងាយខាងស្តាំដៃហ្នឹង ចំនួនជា ៥-៦ ម៉ែត្រពីនុងជិតថ្នល់ជាតិហ្នឹង ខ្ញុំនៅខាងក្រោម គាត់នៅលើថ្នល់ជាតិហ្នឹង"[3463]។

## ១.២. ការឃោសនា វគ្គអប់រំ និងវគ្គបណ្តុះបណ្តាលជាសាធារណៈ

1477. ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម បានផ្តល់សក្ខីកម្មថា នៅបាត់ដំបង នៅពេលដែលដើមបណ្តឹងរដ្ឋប្បវេណី ធ្វើការនៅសាកលវិទ្យាល័យបាត់ដំបង មុនពេលគេបញ្ជូនមកភ្នំពេញនៅឆ្នាំ ១៩៧៧[3464] ពេលនោះ នួន ជា ដឹកនាំវគ្គអប់រំរៀនសូត្រ[3465]។ "នួន ជា មកដឹកនាំកិច្ចប្រជុំ នៅសាកលវិទ្យាល័យបាត់ដំបង ហើយខ្ញុំបានឃើញគាត់ផ្ទាល់។ គាត់ពាក់អាវពណ៌ស ខោពណ៌ខ្មៅ"[3466]។

## ១.៣. ការប្រជុំនៅទីក្រុងភ្នំពេញ ជាមួយប្រជាជនមកពីភូមិភាគពាយ័ព្យ (ឆ្នាំ១៩៧៧)

1478. បន្ទាប់ពីគេយកដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ពីខេត្តបាត់ដំបងមកទីក្រុងភ្នំពេញ "នៅក្នុងឆ្នាំ ១៩៧៧ ខ្ញុំបានទទួលដំណឹងពីលោក នួន ជា ដែលបាននាំខ្លួនខ្ញុំមកដល់ភ្នំពេញនោះ គាត់បានប្រាប់ថា "អាសាយជាជនក្បត់បក្ស" អីចឹងមានន័យថាសាយ ត្រូវជាអ៊ំរបស់ខ្ញុំ អីចឹង នួន ជា គាត់បាន

---

[3462] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ E1/283.1 ៩ ទំព័រ បន្ទាត់ ៥-៦។

[3463] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ឹង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ E1/283.1 ទំព័រ ២៥ បន្ទាត់ ៥-៦។

[3464] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ E1/500.1 ទំព័រ ៧ បន្ទាត់ ៨-១១។

[3465] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ E1/500.1 ទំព័រ ៧ បន្ទាត់ ១០-១១។ សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ E1/501.1 ទំព័រ ៥-៦ បន្ទាត់ ២៥-៣។

[3466] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ E1/500.1 ទំព័រ ២៨ បន្ទាត់ ២-៣។

ចោទប្រកាន់ថា សាយ ត្រូវបានក្បត់បក្សកុម្មុយនីស្តកម្ពុជា"[3467]។ ដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់ថា "នួន ជា គាត់ប្រាប់ខ្ញុំនេះ គឺគាត់បានអញ្ជើញពួកខ្ញុំរាប់រយនាក់មកពីខេត្តភូមិភាគពាយ័ព្យហ្នឹងឱ្យមកស្តាប់គាត់ប្រាប់ គាត់ពន្យល់ថានៅតាមបណ្តាភូមិភាគពាយ័ព្យហ្នឹង មេដឹកនាំក្បត់។ អីចឹងបក្សយកសមមិត្តទាំងអស់មកនេះ ដើម្បីឱ្យរួចផុតពីពួកក្បត់ ហេតុនេះហើយបានខ្ញុំដឹងថាលោក នួន ជា និយាយថា អ៊ុំសាយរបស់ខ្ញុំជាជនក្បត់ ហើយមនុស្សទាំងអស់ដែលរស់នៅ ក្រោមការដឹកនាំរបស់ភូមិភាគហ្នឹង សុទ្ធសឹងជាអ្នកដែលត្រូវបានជនក្បត់ធ្វើទុកបុកម្នេញ សម្លាប់ធ្វើបាបអីចឹងទៅ។ ពេលនោះតា នួន ជា បាននិយាយថា បក្សយកសមមិត្តទាំងអស់នេះ ដើម្បីឱ្យរួចផុតពីការសម្លាប់របស់ពួកក្បត់ នៅតាមបណ្តាខេត្តហ្នឹង"[3468]។

1479. ដើមបណ្តឹងរដ្ឋប្បវេណីបានអះអាងថា "ឃើញលោក នួន ជា បានឡើងមកកន្លែងវេទិកាហ្នឹង គាត់និយាយរឿងរ៉ាវទាំងអស់ហ្នឹងប្រាប់ពួកខ្ញុំ"[3469]។

1480. ដើមបណ្តឹងរដ្ឋប្បវេណីបញ្ជាក់ថា "ខ្ញុំបានឮលោក នួន ជា និយាយប្រាប់នៅក្នុងសិក្ខាសាលាមួយក្នុងចន្លោះឆ្នាំ៧៧ គាត់បានថា សាយ ដែលត្រូវជាអ៊ុំធំខ្ញុំនោះ គាត់បានរស់នៅជានីរសារជំនិតរបស់តា ទូ សាមុត។ អីចឹងសាយ នោះ ត្រូវបានផ្តល់ព័ត៌មានទៅឱ្យអ្នកខាងក្រៅ ដែលមិនពេញចិត្តនឹងតា ទូ សាមុត នោះ ត្រូវបានតា ទូ សាមុត ចេញពីផ្ទះទៅធ្វើកិច្ចការងារ មិនដឹងគាត់ធ្វើអ្វីខ្លះទេ ត្រូវបានបាត់ខ្លួនទៅពេលនោះទៅ"[3470]។ ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម បានផ្តល់សក្ខីកម្មបន្ថែមថា "ខ្ញុំបានចាំច្បាស់ នៅពេលដែលគាត់និយាយថា ពិសេសគឺឈ្មោះ អ៊ំសាយ និងកម្មាភិបាល

---

[3467] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/500.1** ទំព័រ ១២ បន្ទាត់ ២-៤។

[3468] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/500.1** ទំព័រ ១២ បន្ទាត់ ៨-១៤។

[3469] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/500.1** ទំព័រ ១៤ បន្ទាត់ ១-២។

[3470] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/501.1** ទំព័រ ៥-៦ បន្ទាត់ ២៥-៣។

ភូមិភាគហ្នឹង ត្រូវបានក្បត់នឹងបក្ស អីចឹងបក្សចាប់គាត់យកមក។ ហើយកម្មាភិបាលទាំងអស់នោះ បានសម្លាប់មេបក្សដូចជា តា ទូ សាមុត អីចឹង ហ្នឹងគាត់និយាយអីចឹង”[3471]។

1481. ដើមបណ្តឹងរដ្ឋប្បវេណីមិនជឿថាអ្វីដែល នួន ជា បាននិយាយ អំពីមេដឹកនាំភូមិភាគពាយ័ព្យ ជារឿងពិតឡើង "បាទ ខ្ញុំអត់ជឿទេ ព្រោះការនិយាយ ហើយនិងសកម្មភាពជាក់ស្តែង វាអត់ស្របគ្នា”[3472]។

### ១.៤. សុន្ទរកថានៅបុរីកីឡា នៅចំពោះមុខកងទ័ព (ឆមាសទីពីរឆ្នាំ ១៩៧៧)

1482. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ បានផ្តល់សក្ខីកម្មថា គាត់ត្រូវបានបញ្ជូនទៅបុរីកីឡា នៅទីក្រុងភ្នំពេញ ដើម្បីចូលរួមក្នុងកិច្ចប្រជុំ នៅឆមាសទីពីរឆ្នាំ ១៩៧៧[3473] ដែលមានកងទ័ពដទៃទៀតចូលរួមប្រហែល ១០០០នាក់[3474]។

1483. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ បានពន្យល់ថា អ្នកនៅបុរីកីឡាត្រូវប្រជុំជួរ ដើម្បីចូលស្តាប់សុន្ទរកថា៖ “រយៈក្នុងពេលដែលប្រជុំជួរនោះ ក្រោយពីលោកទាំងបីនាក់ លោក សុន សេន លោកតា ម៉ុក និងលោកមា នួន ជា អីហ្នឹងហើយ លោកមា នួន ជា គាត់ជាអ្នកទទួលខុសត្រូវផ្នែកខាងយោធា ហើយជាការពិត។ ហើយគាត់បានមានប្រសាសន៍ទៅលើកទឹកចិត្តដោយពួកយើងខ្ញុំជិត១០០០នាក់ នោះថាដែលជាទ័ពចាស់ៗ។ ប៉ុណ្ណឹងបាទ លើកទឹកចិត្តខ្ញុំ”[3475]។

[3471] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/500.1** ទំព័រ ៣២ បន្ទាត់ ១-៣។

[3472] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី សុន ឯម ប្រតិចារឹក ថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/500.1** ទំព័រ ៣១ ទំព័រ ៩។

[3473] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ ប្រតិចារឹក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៨១-៨២ បន្ទាត់ ២៥-១។

[3474] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ ប្រតិចារឹក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៧២ បន្ទាត់ ២២-២៤។

[3475] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ ប្រតិចារឹក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៧៤ បន្ទាត់ ១២-១៥។

1484. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ បានរំឭកពីសុន្ទរកថារបស់ នួន ជា[3476] "គាត់បានលើកទឹកចិត្តដល់ពួកខ្ញុំថា "សមមិត្ត យុទ្ធមិត្ត ប្អូនៗសុទ្ធសឹងជាអ្នកធ្លាប់បានប្រយុទ្ធ ច្បាំងជាមួយនឹងចក្រពត្តិអាមេរិកាំង និងឆ្កែបរិវារបម្រើដាច់ថ្លៃរបស់វា បានវាយដណ្តើមយកជ័យជម្នះនៅថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ជូនបក្សបដិវត្តប្រជាជនយើង ធ្វើឲ្យល្បីរន្ទឺពាលពេញសកលលោក។ ក៏ប៉ុន្តែមកដល់ពេលឥឡូវនេះ អាខ្មាំងយួនវាបាន វាមិនអាចលះបង់នូវមហិច្ឆិតារបស់វា លោភលន់ចង់បាន នាំកម្ពុជាប្រជាធិបតេយ្យរបស់យើង ចូលទៅក្នុងសហព័ន្ធឥណ្ឌូចិនរបស់វាទេ។ វាបានលើកកងទ័ពរាប់សិបកងពល ហើយនិងបញ្ជូននូវចារកម្មរបស់វា ដើម្បីរំលោភឈ្លានពានមកលើទឹកដីកម្ពុជាប្រជាធិបតេយ្យយើងជាបន្តបន្ទាប់។ ក៏បានត្រូវកងទ័ពដ៏អង់អាចក្លាហានរបស់យើង បានវាយបំបាក់និងចាប់បានជាឈ្លើយសឹកជាច្រើននាក់។ ហេតុនេះបក្សយើងសង្ឃឹមជឿជាក់លើសមមិត្តយុទ្ធមិត្ត ប្អូនៗទាំងអស់ ដាច់ខាតមិនអនុញ្ញាតឲ្យអាខ្មាំងយួន រំលោភឈ្លានពានបានទៀតជាដាច់ខាត"។ ខ្ញុំចប់ប៉ុណ្ណឹងបាទ ចាំប៉ុណ្ណឹង"[3477]។

1485. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ បានផ្តល់សក្ខីកម្មថា "នៅក្រោយបញ្ចប់ពីការលើកទឹកចិត្ត របស់លោកមានួន ជា ក្តី តា ម៉ុក ហើយនិងទាំងអស់ហ្នឹង គេក៏រៀបចាត់ចែងបញ្ជូនពួកខ្ញុំហ្នឹងជាពីរផ្លូវមួយចំនួនទៅឆ្លងអ្នកលឿង ឆ្លងសាឡាងអ្នកលឿង ហើយពួកខ្ញុំប្រហែលជា៤០០នាក់ហ្នឹង គេឲ្យឆ្លងសាឡាងនៅខាងជើងស្ពានជ្រោយចង្វារ ហើយនិងទៅឆ្លងទន្លេបិទ សាឡាងនៅទន្លេបិទទៀត"[3478]។

## ២. ភូមិភាគបូព៌ា

### ២.១. ការដឹងព្រួញទៅ

***ទស្សនកិច្ចទៅសហករណ៍ត្រាំកក់ (ឆ្នាំ១៩៧៧)***

[3476] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ប្រតិចារឹក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៨១-៨២ បន្ទាត់ ២៥-១។

[3477] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ប្រតិចារឹក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៧៤-៧៥ បន្ទាត់ ១៨-៣។

[3478] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដាវ ប្រតិចារឹក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៧៦ បន្ទាត់ ៥-៨។

1486. ដូចដែលបានពិភាក្សាខាងលើ ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គីមឡន[3479] និងដើមបណ្ដឹងរដ្ឋប្បវេណី អ៊ឹម សារឿន[3480] បានផ្ដល់សក្ខីកម្មថា ខៀវ សំផន បានធ្វើទស្សនកិច្ចនៅសហករណ៍ត្រាំកក់ ជាមួយតា ម៉ុក ប៉ុល ពត និងនួន ជា ក្នុងឆ្នាំ ១៩៧៧។

1487. ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គីមឡនបានផ្ដល់សក្ខីកម្មថា គាត់ដឹងថា ខៀវ សំផន ទៅធ្វើទស្សនកិច្ចនៅសហករណ៍ត្រាំកក់ "ខ្ញុំធ្លាប់ឃើញតាំងពីសង្គមរាស្ត្រនិយម ព្រោះអីមានកាសែតបិទរូបតំណាងរាស្ត្រ ហើយខ្ញុំបានអាន បានស្គាល់ឈ្មោះគាត់តាំងពីសង្គមរាស្ត្រនិយមជំនាន់មុន។ ហើយដល់ពេលហ្នឹងគាត់ចុះទៅ ក៏ខ្ញុំបានស្គាល់គាត់។ ចាស ហើយគាត់បានដើរហៅមេកង មេក្រុម ប្រធានភូមិ គណៈឃុំអីដើរតាមគាត់ហ្នុងទៅៗ ហើយខ្ញុំរែកដីបន្តចាស។ ហើយគាត់ទៅដល់ ថ្ងៃហ្នឹងគាត់ទៅដល់សហករណ៍កង១ ទៀត។ បងខ្ញុំនៅខាងជើងសហករណ៍កង១ គាត់បានឃើញដែរ ឃើញមេដឹកនាំខ្មែរក្រហមទាំងបីនាក់ ដើរទៅដល់មុំហួសសហករណ៍កង១ បន្តិចចាស"[3481]។ ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ឹម សារឿន បានផ្ដល់សក្ខីកម្មថា គាត់មិនស្គាល់ខៀវ សំផនដោយផ្ទាល់ទេ គឺមេកងរបស់គាត់ជាអ្នកប្រាប់គាត់អំពីឈ្មោះខៀវ សំផន បន្ទាប់ពីដំណើរទស្សនកិច្ចនាពេលនោះ[3482]។

### *វត្តមាននៅផ្សារធំថ្មី ទីក្រុងភ្នំពេញ ដើម្បីចែកក្រមាខៀវ ដល់អ្នកត្រូវបានជម្លៀសពីភូមិភាគបូព៌ា (ឆ្នាំ ១៩៧៨)*

1488. ដើមបណ្ដឹងរដ្ឋប្បវេណី ខៀវ នាប បានផ្ដល់សក្ខីកម្មថា នៅអំឡុងចូលឆ្នាំថ្មីឆ្នាំ ១៩៧៨ ខៀវ សំផន បានចែកក្រមានៅផ្សារធំថ្មី ក្នុងទីក្រុងភ្នំពេញ "នៅខែគេជម្លៀសប្រជាពលរដ្ឋចេញមកពីព្រៃវែង គឺខាងខាងខេត្តបូព៌ា តែខ្ញុំមិនដឹងថាណាទេ ឮគេថាដែរ តែខ្ញុំនៅនោះអីដែរ។ ដល់ប្រជាពលរដ្ឋមកនៅដាក់នឹងផ្សារថ្មីទៅ ពួកខ្ញុំនេះគេឱ្យដាំបាយចែកចាយធ្វើជាម្ហូប ចែកពួកនោះអីទៅ។ ហើយនិងមាន

---

[3479] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គីមឡន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/252.1** ទំព័រ ៥១-៥២ បន្ទាត់ ២៥-៤។

[3480] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ២៣-២៤ បន្ទាត់ ២១-១០។

[3481] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជូ គីមឡន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៥ ឯកសារ **E1/252.1** ទំព័រ ៥២ បន្ទាត់ ១៥-២០។

[3482] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ុង សារឿន ប្រតិចារឹក ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ ២០១៥ ឯកសារ **E1/283.1** ទំព័រ ៨ បន្ទាត់ ៧-៨ ទំព័រ ៣២ បន្ទាត់ ១៧។

សម្ភារៈសម្លៀកបំពាក់ដូចជា ក្រមា សំពត់ ខោអាវនេះ ចែកទៅពួកគាត់។ ដល់ស្រាប់តែខ្ញុំឈរឆ្ងាយ ប្រហែលជាបីម៉ែត្រ ខ្ញុំឃើញថាមេដឹកនាំជាន់ខ្ពស់គឺតា ខៀវ សំផន។ ខ្ញុំបានឃើញផ្ទាល់ទាញមកហុច ទៅប្រជាពលរដ្ឋនៅក្នុងផ្សារថ្មីនោះឯង"[3483]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានផ្ដល់សក្ខីកម្មថាប្ដីរបស់គាត់ប្រាប់គាត់ថាអ្នកនៅផ្សារនោះគឺ ខៀវ សំផន "ខ្ញុំសួរប្ដីខ្ញុំថាពីណានេះឯង។ ប្ដីខ្ញុំប្រាប់ថានេះឯងអង្គការ។ ខ្ញុំថាឈ្មោះអី? នេះឯងហៅថា អង្គការខៀវ សំផន។ បានខ្ញុំចំណាំជាប់ថា នេះឯងមេដឹកនាំប្រទេស។ គាត់និយាយប្រាប់ខ្ញុំអីចេះឯង។ ហើយគាត់មកឈរនៅឯនោះមួយភ្លែតទៅប្រហែលជាប្រាំនាទី ស្រាប់បាត់គាត់មិនដឹងទៅណាទៀតទៅ"[3484]។ ដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ជាក់ថា "នាងខ្ញុំមិនចាំទេកាលបរិច្ឆេទ ប៉ុនចាំជាខែដូចថាពេលភ្ជុំរួច ខែណា? ពេលយើងភ្ជុំបិណ្ឌរួច"[3485]។ ហើយថា "គាត់ចែកក្រមារពណ៌ខៀវ ឆ្នូតស នៅផ្សារថ្មីហ្នឹងឯង"[3486]។ ដើមបណ្ដឹងរដ្ឋប្បវេណីក៏បាន "ឃើញគាត់ចែកក្រមាខៀវឆ្នូតស ទៅឲ្យយាយចាស់ម្នាក់"[3487]។

## ២.២. ការឃោសនា វគ្គអប់រំ និងវគ្គបណ្ដុះបណ្ដាលជាសាធារណៈ

### i. វគ្គរៀនសូត្រនៅវត្តឧណ្ណាលោម ទីក្រុងភ្នំពេញ (ឆ្នាំ ១៩៧៥)

1489. ដើមបណ្ដឹងរដ្ឋប្បវេណី ជា ខៀប បានផ្ដល់សក្ខីកម្មថា មុនពេលគាត់រៀបការ នៅចុងឆ្នាំ ១៩៧៥ "លោកតា ខៀវ សំផន ខ្ញុំបានជួបគាត់នៅវត្ត នៅកន្លែងវត្តឧណ្ណាលោម គឺគាត់បើកសន្និបាត។ គាត់បើកសិទ្ធិទាំងអស់ហៅនារីយុទ្ធជនទៅរៀន នៅវត្តឧណ្ណាលោម។ ហ្នឹងខ្ញុំបានជួបគាត់នៅកន្លែង

---

[3483] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ខៀវ នាប ប្រតិចារឹក ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/503.1** ទំព័រ ៦៥-៦៦ បន្ទាត់ ២១-១។

[3484] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ខៀវ នាប ប្រតិចារឹក ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/503.1** ទំព័រ ៦៦ បន្ទាត់ ៥-៨។

[3485] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ខៀវ នាប ប្រតិចារឹក ថ្ងៃទី ២៩ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/503.1** ទំព័រ ៦៦ បន្ទាត់ ២១-២២។

[3486] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ខៀវ នាប ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៧ បន្ទាត់ ២២-២៣។

[3487] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ខៀវ នាប ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ១២ បន្ទាត់ ១១-១៣។

ហ្នឹងម្តង"[3488]។ ដើមបណ្តឹងរដ្ឋប្បវេណីបានរំឭកបន្ថែមថា "គាត់និយាយថា សូមស្នើសមមិត្តនារីយុទ្ធជនទាំងអស់ ប្រឹងធ្វើការជូនរដ្ឋ ហើយយុទ្ធជនដែលយុទ្ធជននារី ដែលមានអាយុពី១៩ឆ្នាំឡើងទៅឱ្យតាមកម្មាភិបាល តាមមុខក្រសួងទាំងអស់ឱ្យរៀបចំ ឱ្យមានគ្រួសារទៅ គាត់ថាអីចឹង កុំទុកឱ្យនៅច្រើនពេក"[3489]។ ដើមបណ្តឹងរដ្ឋប្បវេណី ជា ឡៀប ត្រូវបានហៅទៅចូលរួមប្រជុំ នៅវត្តឧណ្ណាលោមដោយ "ប្រធាននៅកន្លែងខ្ញុំឈ្មោះ ផាន ពេលដែលខ្ញុំនៅផ្សារទួលទំពូង។ ហើយមានអ្នកមកពីមុខព្រួញដទៃទៀត បានចូលរួមក្នុងការប្រជុំ នៅវត្តឧណ្ណាលោមនោះដែរ។ គឺមានមនុស្សរាប់រយនាក់"[3490]។

### *ការផ្សព្វផ្សាយគោលនយោបាយកម្ពុជាប្រជាធិបតេយ្យទូទៅ*

1490. ដើមបណ្តឹងរដ្ឋប្បវេណី ជា ឡៀប បានរំឭកថានៅវត្តឧណ្ណាលោម "ខៀវ សំផន គាត់បាននិយាយដែរ មុននឹងគាត់និយាយរឿងរៀបការហ្នឹង ក៏គាត់ដឹកនាំយុទ្ធជននារី ឱ្យខិតខំធ្វើការជូនរដ្ឋ ជូនបក្សអីចឹងទៅ កុំឱ្យមានដូចថា កុំឱ្យមានឆ្វេងស្តាំអី ឆ្វេងអីខុសពីវិន័យអីចឹងទៅ គាត់និយាយហូរហែអីចឹងមែនហ្នឹង។ គាត់និយាយពីគោលនយោបាយរបស់អង្គការអីចឹងទៅ។ គាត់គ្មាននិយាយពីអីទៀតទេ គាត់និយាយច្រើនតែពាក្យអីចឹង"[3491]។

### *ការផ្សព្វផ្សាយស្តីពីគោលនយោបាយលើកំណើនប្រជាជន/ការគ្រប់គ្រងលើការរៀបអាពាហ៍ពិពាហ៍*

1491. ដើមបណ្តឹងរដ្ឋប្បវេណី ជា ឡៀប បានផ្តល់សក្ខីកម្មថា ក្នុងអំឡុងវគ្គរៀនសូត្រនៅវត្តឧណ្ណាលោម ខៀវ សំផន "បាននិយាយថា "សូមស្នើសមមិត្តនារីយុទ្ធជនទាំងអស់ ប្រឹងធ្វើការជូនរដ្ឋ ហើយយុទ្ធជនដែលយុទ្ធជននារី ដែលមានអាយុពី ១៩ ឆ្នាំឡើងទៅ ឱ្យតាមកម្មាភិបាល តាមមុខក្រសួង

---

[3488] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឡៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥១ បន្ទាត់ ១៣-១៥។

[3489] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឡៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥២ បន្ទាត់ ១-៣។

[3490] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឡៀប ប្រតិចារឹក ថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/467.1** ទំព័រ ៤០ បន្ទាត់ ៨-១០។

[3491] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឡៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៧២ បន្ទាត់ ២១-២៤។

ទាំងអស់ ឲ្យរៀបចំឲ្យមានគ្រួសារទៅ" គាត់ថាអីចឹង កុំទុកឲ្យនៅច្រើនពេក"[3492]។ "គាត់មិនបាន និយាយថា ស្រឡាញ់គ្នាស្រឡាញ់អីទេ គាត់គ្រាន់តែប្រាប់ថាឲ្យរៀបចំគ្រួសារទៅ តាំងពីអាយុ១៩ ឡើងទៅ យុទ្ធជនអាយុ២៥ អីទុកធ្វើអីទៀត។ ស្នើតាមក្រសួងមន្ទីរទាំងអស់ ឲ្យគិតគូររៀបការ យុទ្ធជននារីឲ្យអស់ទោ គាត់គ្រាន់ ទុកតែក្មេងៗសិនទីបានហើយ។ គាត់និយាយអីចឹង"[3493]។

1492. នៅវត្តឧណ្ណាលោម ជា ឌៀប បានផ្តល់សក្ខីកម្មថា ខៀវ សំផន បានប្រកាស់ថា យុវជន យុវនារី ដែលចាស់ៗ "គាត់ថារៀបការទៅ ដើម្បីបង្កើតកូន កើតចៅឲ្យបានគ្នា បានកូនចៅច្រើនទៅ ដើម្បី ជាកម្លាំងការពារប្រទេសជាតិ។ គាត់និយាយប៉ុណ្ណឹង"[3494]។ "ក្រោយពីគាត់និយាយរួច មិនទាន់បាន ប៉ុន្មានផង ពួកយើងខ្ញុំក៏ត្រូវរៀបការជំនាន់ខ្មែរក្រហមនោះដែរ"[3495]។

## ២.៣. សេចក្តីថ្លែងការណ៍ជាសាធារណៈ

### i. ការប្រកាសតាមវិទ្យុ (ឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៦)

1493. ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ បានផ្តល់សក្ខីកម្មថា "ខ្ញុំអត់ដែលបានឃើញផ្ទាល់សោះ អត់ដែល បានឃើញ។ លោកមា ខៀវ សំផន គឺខ្ញុំមិនដែលបានឃើញគាត់ទេ គ្រាត់តែឮតែសម្តីតែ ប៉ុណ្ណោះ"[3496]។ ដើមបណ្តឹងរដ្ឋប្បវេណីបន្តថា "ក្នុងរយៈកាលដែលរបបកម្ពុជាប្រជាធិបតេយ្យហ្នឹង កើតឡើងភ្លាម គាត់និយាយ ប៉ុន្តែខ្ញុំវាមិនអាចចាំបានទេ កាលនោះខ្ញុំស្តាប់វ៉ាដ្យូ ខ្ញុំតាមដានវ៉ាដ្យូ។ ភាគច្រើនគេចាក់ចម្រៀងអីចឹងក្នុងវ៉ាដ្យូហ្នឹង ហើយនិងសេចក្តីថ្លែងការណ៍អីផ្សេងៗ អីចឹង

[3492] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥២ បន្ទាត់ ១-៣។

[3493] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥២ បន្ទាត់ ៨-១០។

[3494] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥២ បន្ទាត់ ១៥-១៦។

[3495] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ជា ឌៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥២ បន្ទាត់ ២០-២១។

[3496] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី អ៊ូ ដារ ប្រតិចារឹក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៨៤ បន្ទាត់ ៤-៥។

បាទ"[3497]។ ដើមបណ្ដឹងរដ្ឋប្បវេណី "ស្ដាប់សំឡេងរបស់លោក ខៀវ សំផន ហ្នឹងគឺតាមវិទ្យុ ស្ដាប់តាមវិទ្យុផ្សព្វផ្សាយ។ វិទ្យុគាត់ផ្សព្វផ្សាយអំពីអ្វីដែល នៅក្នុងឆ្នាំ៧៥ ៧៦អីហ្នឹងខ្ញុំឮ នៅក្នុងឆ្នាំ៧៦ច្បាស់តែនៅក្នុងឆ្នាំ៧៦ ខ្ញុំបានស្ដាប់សំឡេងរបស់មាស ខៀវ សំផន ហ្នឹងគាត់បាននិយាយ បាននិយាយតាមវិទ្យុ"[3498]។ ដើមបណ្ដឹងរដ្ឋប្បវេណីផ្ដល់សក្ខីកម្មថា "គាត់និយាយគឺសុទ្ធតែពាក្យល្អៗទាំងអស់ហ្នឹង។ គាត់ដូចជារបបអង្គរ ដល់ប្រជាជនកម្ពុជាទូទៅគឺ ដូចជារបបអង្គរអីហ្នឹង ថាក្នុងមួយនាក់ ទទួលបានមួយកំប៉ុងកន្លះ ឬពីរកំប៉ុង នៅពេលដែលគាត់ប្រកាសអីចឹង។ ហើយគាត់ប្រកាសប្រាប់តាមវិទ្យុអីចឹង ក្នុង១ថ្ងៃ ក្នុងម្នាក់ បងប្អូនប្រជាជនទូទាំងប្រទេសហ្នឹង"[3499]។

### ii. ការប្រជុំនៅបុរីកីឡា (ឆ្នាំ ១៩៧៥)

1494. ដើមបណ្ដឹងរដ្ឋប្បវេណី ជា ខៀប បានផ្ដល់សក្ខីកម្មថា គាត់បានឃើញខៀវ សំផន នៅបុរីកីឡា "ខ្ញុំបានជួបគាត់ស្ដាតបុរីកីឡា ហ្នឹងថ្ងៃដែលកាត់ទោស ហ៊ូ នឹម ហ៊ូ យន់ ខ្ញុំក៏បានចូលរួមដែរ គាត់ជាទីប្រឹក្សានៅកន្លែងនុង។ ដល់ពេលខ្ញុំទៅហ្នឹង គាត់ហៅពួកនីរសារ ហ៊ូ នឹម ហ៊ូ យន់ មកសួរចម្លើយ។ ដល់ថ្ងៃហ្នឹងក៏ខ្ញុំមិនបាននៅចប់ចុងចប់ដើមដែរ ព្រោះដល់ពេលនីរសារ ហ៊ូ នឹម ហ៊ូ យន់ឆ្លើយអីចឹងទៅមួយរយៈទៅ ខ្ញុំក៏គ្រុនញាក់ទៅ គេយកខ្ញុំមកដេកពេទ្យទៅ។ ខ្ញុំក៏បានតែត្រឹមនុង អត់បានតទៅទៀតទេ ហ្នឹងបានជួបគាត់ត្រឹមហ្នឹងទៀតហ្នឹង ហ្នឹងតា ខៀវ សំផនផ្ទាល់ហ្នង ប៉ុនជំនាន់ហ្នឹងខ្ញុំហៅគាត់ថា អ៊ំៗ"[3500]។

### iii. សុន្ទរកថានៅផ្សារច្បារអំពៅ ភ្នំពេញ (ឆ្នាំ ១៩៧៧)

---

[3497] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ូ ដារ ប្រតិចារឹក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៨៤ បន្ទាត់ ២១-២៣។

[3498] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ូ ដារ ប្រតិចារឹក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៨៤ បន្ទាត់ ៩-១១។

[3499] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី អ៊ូ ដារ ប្រតិចារឹក ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/498.1** ទំព័រ ៨៤ បន្ទាត់ ១៥-១៨។

[3500] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្ដឹងរដ្ឋប្បវេណី ជា ខៀប ប្រតិចារឹក ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០១៦ ឯកសារ **E1/466.1** ទំព័រ ៥១ បន្ទាត់ ១៥-២០។ ដើមបណ្ដឹងរដ្ឋប្បវេណីផ្ដល់សក្ខីកម្មថា គាត់បានជួប ខៀវ សំផន ពីរដងមុនពេលគាត់រៀបការ ហើយវាបានកើតឡើងនៅក្នុងឆ្នាំ ១៩៧៥ (ឯកសារ **E1/467.1** ទំព័រ ៤០ បន្ទាត់ ៨-១០, ឯកសារ **E1/466.1** ទំព័រ ៦៩-៧០ បន្ទាត់ ២៣-៦) គាត់បានរៀបការរយៈពេល ៦ ឬ ៧ ខែ បន្ទាប់ពីគាត់បានមកដល់ទីក្រុងភ្នំពេញ (ឯកសារ **E1/467.1** ទំព័រ ៣៤ បន្ទាត់ ១៤)។

1495. ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ផុន បានផ្តល់សក្ខីកម្មថា បានឃើញខៀវ សំផន នៅក្នុងឆ្នាំ ១៩៧៧ នៅផ្សារច្បារអំពៅ[3501]។ ដើមបណ្តឹងរដ្ឋប្បវេណីបានរៀបរាប់ថា "ពេលដែលលោក ខៀវ សំផន គាត់អញ្ជើញមកដល់ផ្សារនោះ គឺថាគេឱ្យយើង ឱ្យប្រជាពលរដ្ឋហ្នឹង ដើម្បីយើងតម្រៀបជួរ ដើម្បីរង់ចាំស្តាប់ប្រសាសន៍របស់គាត់ ចាំទទួលអបអរគាត់ នៅក្នុងពេលនុង។ ដើម្បីឱ្យប្រជាពលរដ្ឋហ្នឹងតម្រង់ជួរ រៀបជាជួរដើម្បីធ្វើជាអង្គប្រជុំមួយ សម្រាប់ទទួលគាត់នៅក្នុងពេលនុង។ ហើយពេលគាត់មកដល់ហើយហ្នឹង គាត់ក៏មានប្រសាសន៍ឡើងថាដែរ គាត់មានប្រសាសន៍ឡើង ដូចខ្ញុំរៀបរាប់អម្បាញ់មិញខ្លះដែរ។ ពេលនោះគាត់ក៏បានមានប្រសាសន៍ថា យើងបង្កើត ធ្វើបដិវត្តនេះ ធ្វើដើម្បីលុបបំបាត់របបប៉ុល ពត អ! របប លន់ នល់ (សូមទោស) របប លន់ នល់។ មួយទៀតគឺថាលុបបំបាត់របបនាយទុន សក្តិភូមិ បញ្ញវន្ត គាត់មិនឱ្យមានទេ។ ហ្នឹងគាត់មានប្រសាសន៍ដែលគាត់លើកឡើង។ ពេលនោះគាត់និយាយច្រើន ប៉ុន្តែខ្ញុំយូរឆ្នាំពេក ខ្ញុំវាភ្លេចអស់ដែរ ខ្ញុំមិនបានចាំអស់ទេ គ្រាន់តែខ្ញុំចាំកន្លែងសំខាន់ៗ។ បាទខ្ញុំចាំបាច់ប៉ុណ្ណឹង"[3502]។

1496. ដើមបណ្តឹងរដ្ឋប្បវេណីបានបញ្ជាក់ថា "បានជាខ្ញុំហ៊ានអះអាងថា គាត់ជាលោក ខៀវ សំផន ពីព្រោះខ្ញុំបានធ្លាប់មើលខ្សែរភាពយន្ត កាលដែលគេមិនទាន់ជម្លៀសមក មានកងទ័ពយកទៅបញ្ចាំងតាមភូមិឱ្យមើល។ មានឃើញរូបគាត់ ហើយគេអ្នកស្គាល់ គេប្រាប់ថា ហ្នឹងហើយលោក ខៀវ សំផន។ ពេលនោះហើយបានខ្ញុំហ៊ានកំណត់ថា ច្បាស់ជាគាត់មែន ពីព្រោះខ្ញុំបានធ្លាប់ឃើញគាត់នៅក្នុងខ្សែភាពយន្ត"[3503]។

1497. ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ផុន បានរៀបរាប់ថា "ក្នុងពេលដែលគាត់អញ្ជើញមកដល់ គាត់មានប្រសាសន៍ថា គាត់មានប្រសាសន៍ប្រាប់ប្រជាពលរដ្ឋថា យើងធ្វើបដិវត្តន៍នេះ ធ្វើដើម្បីនឹងផ្តួលរំលំរបបលន់ នល់ ពីព្រោះលន់ នល់ ជាអ្នកប្រឆាំងបដិវត្តន៍។ មួយទៀតធ្វើនេះដើម្បីប្រឆាំងនឹងរបប

---

3501 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ផុន ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៦៨ បន្ទាត់ ១៤-១៨។

3502 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ផុន ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៦៩ បន្ទាត់ ៩-១៧។

3503 សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប ផុន ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៦៨-៦៩ បន្ទាត់ ២៤-២។

នាយទុន សក្តិភូមិ បញ្ញវន្ត។ ហើយបន្ទាប់មកគាត់ថា ក្នុងបដិវត្តន៍នេះមិនឱ្យមានអ្នកមាន មានអ្នកក្រទេ គឺថាឱ្យប្រជាជនមានភាពស្មើៗគ្នា មានភាពស្មើៗគ្នា"[3504]។

1498. "គាត់បានផ្តាំផ្ញើថា ដែលអង្គការជម្លៀសបងប្អូនមកនេះ គឺថាជម្លៀសដើម្បីឱ្យផុតពីពួកយួនឈ្លានពាន ខ្លាចយួនសម្លាប់ពុកម៉ែបងប្អូន បានជម្លៀសឱ្យយើងទៅនៅខាងនិរតី ឱ្យផុតពីកងទ័ពវៀតណាម ដែលវាប្រុងចូលមក ពីព្រោះកន្លងមកមានចូលមកខ្លះៗហើយ កាលនោះតាមព្រំដែនរហូតដល់គេជម្លៀសចេញមក។ ហ្នឹងក្នុងពេលហ្នឹងគាត់នេះអីចឹង។ ដល់គាត់ផ្តាំផ្ញើមួយទៀតគាត់ថា ពេលដែលបងប្អូនទៅដល់និរតី ដល់បាត់ដំបងនោះ គឺថាធ្វើយ៉ាងណាឱ្យពុកម៉ែបងប្អូនទាំងអស់គោរពតាមគោលនយោបាយ មាគ៌ារបស់បក្សឱ្យបានម៉ឺងម៉ាត់។ ហ្នឹងគាត់មានប្រសាសន៍អីចឹង។ ធ្វើយ៉ាងណាកុំក្បត់នឹងបក្ស តែក្បត់នឹងបក្សបើបក្សដឹង ត្រូវសម្លាប់ចោល។ ហ្នឹងគាត់បានមានប្រសាសន៍អីចឹង។ ហើយគាត់បន្ថែមចុងក្រោយទៀត គាត់ថាទុកក៏មិនចំណេញ យកចេញក៏មិនខាតដែរ ពួកក្បត់នឹងបដិវត្តន៍។ ហើយតមកទៀតគាត់និយាយច្រើន ប៉ុន្តែខ្ញុំមិនបានចាំអស់ក្នុងពេលនោះ ពីព្រោះវាយូរឆ្នាំហើយ។ សូមអស់យោបល់"[3505]។

## V. ផ្នែកសម្រេចសេចក្តី

**អាស្រ័យហេតុនេះ** សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំដោយសេចក្តីគោរព ដល់អង្គជំនុំជម្រះសាលាដំបូង

(១) អនុវត្តដោយត្រឹមត្រូវនូវច្បាប់ ស្របតាមសារណារបស់ព្រះរាជអាជ្ញា

(២) ពិចារណាទៅលើការបង្ហាញខាងលើ អំពីភ័ស្តុតាងរបស់ដើមបណ្តឹងរដ្ឋប្បវេណី នៅពេលពិចារណាថាតើ អំពើដែលមានចែកនៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ បង្កើតបានជាឧក្រិដ្ឋកម្ម ដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ដែរឬយ៉ាងនា និងថាតើជនជាប់ចោទបានប្រព្រឹត្ត អំពើទាំងអស់នោះដែរឬយ៉ាងណា

[3504] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប តុន ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៧៣ បន្ទាត់ ១២-១៦។

[3505] សក្ខីកម្មផ្ទាល់មាត់របស់ដើមបណ្តឹងរដ្ឋប្បវេណី ព្រាប តុន ប្រតិចារឹក ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០១៦ ឯកសារ **E1/504.1** ទំព័រ ៧៣ បន្ទាត់ ១៦-២៥។

(៣) ទទួលស្គាល់នូវព្យសនកម្មដែលដើមបណ្តឹងរដ្ឋប្បវេណីបានទទួលរង ដែលជាលទ្ធផលនៃការប្រព្រឹត្តឧក្រិដ្ឋកម្ម ដែលជនជាប់ចោទត្រូវបានផ្តន្ទាទោស

ដោយសេចក្តីគោរព

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២ ខែ តុលា ឆ្នាំ២០១៧ | ពេជ អង្គ<br>សហមេធាវីនាំមុខជាតិ | ភ្នំពេញ | [signature] |
| | Marie GUIRAUD<br>សហមេធាវីនាំមុខអន្តរជាតិ | ភ្នំពេញ | [signature] |